## ធ្វើបុណ្យបានបុណ្យ

ធ្វើបុណ្យបានបុណ្យធ្វើបាបបានបាប
តាមជាប់ជាប់ជាប់តាំងនៅខ្ជាប់ខ្លួន
អន្ទោលតាមប្រាណមិនឃ្លាតពីខ្លួន
ទោះបីរត់ពួនក៏គេចមិនបាន ។
កសាងកុសលបានផលសុខជា
ទានសីលភាវនាទៅតាមលំអាន
ឲ្យយើងបានសុខគ្រប់រូបរាល់ប្រាណ
ព្រះពុទ្ធទ្រង់បានទេសនាពណ៌នា ។

♣ ♣ ♣

ភិក្ខុវិនយធរោ មហាយិន-នឿន
វត្តខ្មែរសាន់តាអាណា
2630 N. Grand Ave.
Santa Ana, CA 92705
(714) 744-2834
U.S.A.

ព.ស.២៥៥២

វិសុទ្ធិមគ្គប្រែ

ភាគទី៣

# វិសុទ្ធិមគ្គប្រែ

## ភាគ ទី ៣

ប្រែដោយ
សាស្ត្រាចារ្យ ឆែន-សុខន

រៀបរៀងដោយ
ភិក្ខុវិនយធរោ មហាយិន-នឿន

បោះពុម្ពផ្សាយជាធម្មទាន ចេញពី
វត្តខ្មែរសាន់តាអាណា
នៅសហរដ្ឋអាមេរិក

លើកទី១

ចំនួន ៥,០០០ ក្បាល

រក្សាសិទ្ធិ

ព. ស. ២៥៥២



**ភិក្ខុវិនយធរោ មហាយិន-នឿន**

កើត ថ្ងៃទី១០ ខែកក្កដា ១៩៥២
ភូមិទួលព្រាំ ឃុំកកោះ ស្រុកមោងឬស្សី
ខេត្តបាត់ដំបង



**សាស្ត្រាចារ្យ ធែន-សុខន**

កើតថ្ងៃទី០៦ ខែ០១ ឆ្នាំ១៩២៨
នៅភូមិសំព័រ ឃុំត្រពាំងសាលាខាងលិច
ស្រុកបន្ទាយមាស ខេត្តកំពត

## រូបំ ជីរតិ មច្ចានំ នាមគោត្តំ ន ជីរតិ

រូបកាយ របស់សត្វទាំងឡាយ តែងចាស់គ្រាំគ្រា
ចំណែកឯនាមនិងគោត្រមិនដែលចាស់ជរាឡើយៗ

# អារម្ភកថា

(របស់អ្នករៀបរៀង)

សៀវភៅ "**បករណ៍វិសេសឈ្មោះវិសុទ្ធិមគ្គប្រែ**" ដែលសាធុជនអ្នកស្រឡាញ់ព្រះធម៌ កំពុងតែអានជាប់ទីងដៃនេះ បានកើតឡើងដោយព្រះរាជយោបល់នៃ **សម្ដេចព្រះមហាឃោសានន្ទ (វ៉ា-យ៉ាវ)** នៅពេលដែលខ្ញុំ (**ភិក្ខុវិនយធរោ មហាយិន-នឿន**) បានយកគម្ពីរមង្គលត្ថទីបនីប្រែទាំងបួនភាគ ទៅថ្វាយសម្ដេច នៅវត្តសំពៅមាស ខែវិសាខ ឆ្នាំ កុរ ឆស័ក ព.ស. ២៥៣៩ គឺឆ្នាំ ១៩៩៥ នោះ ។ សម្ដេចទ្រង់បានមានព្រះរាជបន្ទូលថា "សៀវភៅមង្គលត្ថទីបនីប្រែ ទាំង ៤ ភាគនេះ ជួយជាប្រយោជន៍ ដល់ពុទ្ធបរិស័ទខ្មែរយើងបានច្រើនណាស់... បើអាចប្រែគម្ពីរ វិសុទ្ធិមគ្គ ទាំងបីភាគ [១] ដែលនៅជាភាសាបាលី មកជាភាសាសំរាយខ្មែរយើងបានទៀតនោះ គឺជាការប្រសើរណាស់ ព្រោះខ្មែរយើងសព្វថ្ងៃនេះ មានការខ្វះខាតក្បួនច្បាប់ ខាងផ្នែកព្រះពុទ្ធសាសនា ច្រើនណាស់ សូមប្រែនិងរៀបរៀងសៀវភៅ វិសុទ្ធិមគ្គ ទាំងបីភាគ ឲ្យបានជាបន្តទៅទៀត ដើម្បីជួយខ្មែរយើង..." ។

ហេតុនេះ ខ្ញុំក៏បានទទួលថា នឹងប្រែ ហើយរៀបរៀងធ្វើសៀវភៅ វិសុទ្ធិមគ្គ នេះ ឲ្យបានសម្រេច សមតាមព្រះរាជយោបល់នៃសម្ដេចព្រះមហាឃោសានន្ទ ។ នៅក្នុងឆ្នាំកុរ ឆស័ក ព.ស ២៥៣៩ ដដែលនោះ ខ្ញុំក៏បានជួបប្រឹក្សា ជាមួយលោកសាស្ត្រាចារ្យជាច្រើនរូប ដែលកំពុងតែបង្រៀនសមណនិស្សិត នៅពុទ្ធិកវិទ្យាល័យ នាទីក្រុងភ្នំពេញ រួមមាន

---

១- គម្ពីរ វិសុទ្ធិមគ្គទាំងបីភាគ មានលោកអ្នកប្រែពីមុនមកខ្លះៗ ហើយដែរ ប៉ុន្តែមិនបានប្រែឲ្យចប់សព្វគ្រប់ទាំងអស់ទេ ប្រែកាត់ចោលបាលីភាគច្រើន គឺប្រែជ្រើសរើសយកតែសេចក្ដីបែបខ្លីៗ មករៀបរៀងតែប៉ុណ្ណោះឯង ពុំបានចប់សព្វគ្រប់ទេ ។



លោកសាស្ត្រាចារ្យ **រស់-សារេន**, លោកសាស្ត្រាចារ្យ **ជិត-ជន ហៅ យិន-សូត្រ**) និង សាស្ត្រាចារ្យ **ទែន-សុខន** ជាដើម ដើម្បីរួមដៃគ្នាបកប្រែគម្ពីរ បករណ៍វិសេស ឈ្មោះវិសុទ្ធិមគ្គ ដែលនៅជាភាសាបាលីមកជាភាសាសម្រាយខ្មែរយើង ឲ្យបានចប់សព្វគ្រប់ទាំងបីភាគ ហើយក៏បានសំរេចគ្នាជាឯកច្ឆ័ន្ទថា ឲ្យលោកសាស្ត្រាចារ្យ ជិត-ជន ទទួលប្រែភាគទី១ លោកសាស្ត្រាចារ្យ រស់-សារេន ប្រែភាគទី២ និង ឲ្យលោកសាស្ត្រាចារ្យ ទែន-សុខន ទទួលប្រែភាគទី៣ ហើយបានសំរេច ឲ្យខ្ញុំជាអ្នកកែសំរួល ត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និង រៀបរៀង ព្រមទាំងរកនូវថវិកាដើម្បីបោះពុម្ពផង ។ បន្ទាប់ពីបានប្រឹក្សាគ្នារួចស្រេចហើយ យើងទាំងអស់គ្នា មានសេចក្ដីរំភើបខ្លាំងណាស់ចំពោះកិច្ចការនេះ ។

នៅពេលដែលលោកសាស្ត្រាចារ្យទាំង ៣ បានបកប្រែមកជាភាសាខ្មែរយើងខ្លះៗ ហើយ ក៏បានបញ្ជូននូវសំណៅ ដែលសរសេរជាអក្សរដៃទៅឲ្យខ្ញុំ ដើម្បីកែសំរួលផ្ទៀងផ្ទាត់ និងរៀបរៀងជាបណ្ដើរៗ ពេលដែលខ្ញុំបានទទួលសំណៅនោះហើយ ខ្ញុំបានយកទៅពិនិត្យផ្ទៀងផ្ទាត់ ជាមួយនឹងគម្ពីរវិសុទ្ធិមគ្គ ជាភាសាបាលី ដែលព្រះពុទ្ធឃោសាចារ្យ បានរៀបរៀងជាងមួយពាន់ឆ្នាំ កន្លងមកហើយនោះ ដើម្បីកុំឲ្យមានការខុសក្លាំងក្លាត់ពីភាសាបាលីដើមនោះ ដោយបានយកចិត្តទុកដាក់បំផុត... (តែបើមានការក្លាំងក្លាត់ដោយអចេតនា សូមលោកអ្នកអានជួយកែតម្រូវផង)។

ដូច្នេះ ការដែលលោកសាស្ត្រាចារ្យទាំងនោះ បកប្រែនេះ ខ្ញុំឃើញថា បានប្រែតាមព្រះត្រៃបិដកខ្លះ ប្រែផ្សេងពីព្រះត្រៃបិដកខ្លះ តែសេចក្ដីនឹងអត្ថន័យមិនជាខុសគ្នាទេ ។ លុះខ្ញុំឃើញដូច្នេះ ខ្ញុំក៏បានកែសំរួលឲ្យត្រូវតាមព្រះត្រៃបិដកជាភាសាខ្មែរយើង ហើយខ្ញុំបានដាក់ជាលេខយោង

–

ដើម្បីបញ្ជាក់ប្រាប់គម្ពីរ (ភាគ និង ទំព័រ) ឲ្យបានច្បាស់ និង ដើម្បីងាយស្រួលក្នុងការស្រាវជ្រាវបន្ថែម សំរាប់សមណនិស្សិតនិងអ្នកបតិបត្តិ ។

ខ្ញុំបានយកសំណៅវិសុទ្ធិមគ្គប្រែ ភាគទី១ ដែលលោកសាស្ត្រាចារ្យ ជិត-ជន បានប្រែហើយនោះ មកកែសំរួល និង រៀបរៀង មុនគេបង្អស់ នៅក្នុងខែមាឃ ព.ស. ២៥៣៩ (១២ មីនា ឆ្នាំ ១៩៩៦) ហើយបាន ចប់សព្វគ្រប់ នៅថ្ងៃច័ន្ទ ៣ កើត ខែផល្គុណ ឆ្នាំជូត អដ្ឋស័ក ព.ស. ២៥៤០ ត្រូវនឹងថ្ងៃទី១០ ខែមីនា ១៩៩៧ ។

បន្ទាប់ពីរៀបរៀងភាគទី១ ចប់ហើយទើបខ្ញុំចាប់ផ្តើមកែសំរួលផ្ទៀងផ្ទាត់ ភាគទី៣ បន្តទៅទៀត ដែលលោកសាស្ត្រា ទែន-សុខន បានប្រែខ្លះៗហើយ ។ ជាអកុសល គួរឲ្យស្តាយខ្លាំងណាស់ លោកសាស្ត្រាចារ្យ ទែន-សុខន ប្រែបានពាក់កណ្តាលតែប៉ុណ្ណោះ លោកក៏បានអនិច្ចកម្មទៅ បន្សល់ទុកនូវភារៈនេះឲ្យទៅលោកសាស្ត្រាចារ្យ នូ-ឌឹម ទទួលប្រែបន្តទៅទៀត តែលោកសាស្ត្រា នូ-ជឹម ប្រែបានតែបីបួនទំព័រ ក៏ឈប់ទៅវិញ ព្រោះមានការរវល់ខ្លាំងពេក ដូច្នេះភារៈនេះ ត្រូវធ្លាក់មកលើខ្ញុំអ្នករៀបរៀងទៅវិញ ហើយខ្ញុំក៏បានចាប់ផ្តើមប្រែ... និង បានចប់សព្វគ្រប់នៅថ្ងៃ ពុធ ៨ រោច ខែកត្តិក ឆ្នាំខាល សំរិទ្ធិស័ក ព.ស. ២៥៤២ ត្រូវនឹង ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ។ ហើយបានឲ្យ ភិក្ខុ អឿ-សៅ ជួយវាយចម្លង... តែពុំទាន់បានសំរេចទេ ខ្ញុំត្រូវកែសាជាថ្មីម្តងទៀត ។

ចំណែកឯសំណៅ វិសុទ្ធិមគ្គប្រែ ភាគទី២ វិញនោះ ភិក្ខុ មហាសម-យស វត្តម៉ាក់សី នៅប្រទេសបារាំង ទទួលយកទៅកែសំរួល និង រៀបរៀង តែលោករវល់ខ្លាំងពេក ក៏បានប្រគល់មកឲ្យខ្ញុំកែសំរួល និង រៀបរៀង នៅឯប្រទេសសហរដ្ឋអាមេរិកវិញ ខ្ញុំបានទទួលសំណៅវិសុទ្ធិមគ្គ



ភាគទី២ ដែលលោកសាស្ត្រា រស់-សារះខន ប្រែនោះ មកចាប់ផ្តើមកែសំរួល និង រៀបរៀង នៅថ្ងៃច័ន្ទ ៥ កើត ខែភទ្របទ ឆ្នាំច អដ្ឋស័ក ព.ស. ២៥៥០ ត្រូវនឹងថ្ងៃទី ២៨ ខែសីហា ឆ្នាំ ២០០៦ ហើយបានចប់សព្វគ្រប់ នៅថ្ងៃអង្គារ ៣កើត ខែចេត្រ ឆ្នាំជូត នព្វស័ក ព.ស. ២៥៥១ ត្រូវនឹងថ្ងៃទី ៨ ខែមេសា ឆ្នាំ ២០០៨ ។

គម្ពីរវិសុទ្ធិមគ្គប្រែ ទាំងបីភាគនេះ ដែលក្របានបោះពុម្ពផ្សាយនោះ មកពីរង់ចាំភាគទី២ ផង និង ព្រោះពុំទាន់មានថវិកាគ្រប់គ្រាន់ផង ។

ក្នុងការប្រែរៀបរៀងនេះ ខ្ញុំសូមខន្តីអភ័យទោសអំពីសំណាក់ព្រះតេជះព្រះគុណ ព្រះថេរានុថេរៈ អស់លោកដែលឆ្លៀវឆ្លាតក្នុងភាសាខ្មែរ និងភាសាបាលី ហើយសូមមេត្តាអនុគ្រោះ ដល់អ្នករៀបរៀងផង ។ ខ្ញុំសូមទទួលនូវការរិះគន់ពីគ្រប់មជ្ឈដ្ឋានទាំងអស់ ដែលបានឃើញកំហុសត្រង់កន្លែងណាទីមួយនោះ ហើយផ្តល់ជាយោបល ដើម្បីនឹងជួយកែលំអគម្ពីរវិសុទ្ធិមគ្គប្រែ ទាំងបីភាគនេះ ឲ្យបានល្អប្រសើរឡើង និង ដើម្បីជួយទ្រទ្រង់នូវអាយុជីវិត នៃព្រះពុទ្ធសាសនា របស់អង្គព្រះសម្មាសម្ពុទ្ធនៃយើង ឲ្យបានរីកចំរើន រុងរឿង រៀងតទៅមុខទៀត ។ សូមអរព្រះគុណ និង សូមអរគុណទុកជាមុន ។

**ភិក្ខុវិនយធរោ មហាយិន-នឿន**

វត្តខ្មែរសាន់តាអាណា សហរដ្ឋអាមេរិក

ថ្ងៃច័ន្ទ ១៥ កើត ខែវិសាខ ឆ្នាំជូត សំរិទ្ធិស័ក ព.ស. ២៥៥២

ត្រូវនឹងថ្ងៃទី ១៩ ខែឧសភា ឆ្នាំ ២០០៨

## សេចក្ដីថ្លែងអំណរគុណ

ខ្ញុំអ្នករៀបរៀង សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅ

-ចំពោះលោកសាស្ត្រាចារ្យទាំងបួនរូប ដែលបានលះបង់ពេលវេលាដ៏មានតម្លៃ របស់លោក ហើយបានប្រឹងប្រែងប្រែគម្ពីរបករណ៍វិសេសឈ្មោះវិសុទ្ធិមគ្គទាំង ៣ ភាគនេះ ឲ្យបានសម្រេច សមដូចសេចក្ដីប៉ងប្រាថ្នា តាំងតែពីដើមរៀងមក រហូតដល់ទីបញ្ចប់ ។

-ចំពោះភិក្ខុ ប្រាជ្ញ-សារាន និង ភិក្ខុ ហួត-វ៉េត ព្រមទាំងសហការីដែលបានជួយយកសំណៅវិសុទ្ធិមគ្គប្រែ អំពីលោកសាស្ត្រាចារ្យ ជិត-ជន មកឲ្យខ្ញុំដើម្បីកែសំរួល និង រៀបរៀង ។

-ចំពោះភិក្ខុ អឿ-សៅ ដែលបានយកចិត្តទុកដាក់ជួយវាយចម្លងគម្ពីរវិសុទ្ធិមគ្គប្រែ ភាគទី៣ និង ចំពោះព្រះមហា សម-យស ភាគទី២ ។

-ចំពោះសមណនិស្សិត និង សាស្ត្រាចារ្យមួយចំនួនទៀតជាពិសេសគឺលោកសាស្ត្រាចារ្យ នៅពុទ្ធិកវិទ្យាល័យ អ៊ុំ-ស៊ួង វត្តពោធិវាល ទីរួមខេត្តបាត់ដំបង ដែលត្រូវការគម្ពីរវិសុទ្ធិមគ្គប្រែទាំងបីភាគនេះ ជាងគេហើយទទូចចង់បាន និង ជំរុញ... ឲ្យខ្ញុំប្រញាប់រៀបរៀង ដើម្បីទុកជាប្រយោជន៍ដល់ព្រះពុទ្ធសាសនាផង និង ដល់សមណនិស្សិត ព្រមទាំងពុទ្ធបរិស័ទផង...ដែលជាហេតុធ្វើឲ្យខ្ញុំរឹងរឹតតែមានកម្លាំងកាយ-ចិត្តខិតខំកែសំរួល និពិត្យផ្ទៀងផ្ទាត់ និង រៀបរៀង ដើម្បីឲ្យបានសំរេចជាគម្ពីរវិសុទ្ធិមគ្គប្រែ ទាំងបីភាគនេះឡើង ។

-ចំពោះព្រះថេរានុថេរៈ ព្រមទាំងពុទ្ធបរិស័ទ គ្រប់មជ្ឈដ្ឋានទាំងអស់ដែលបានជួយឧបត្ថម្ភ ក្នុងធម្មទាននេះ ទាំងថវិកា ទាំងកម្លាំងប្រាជ្ញា និងស្មារតី តាំងតែពីដើមមក រហូតដល់គម្ពីរវិសុទ្ធិមគ្គប្រែនេះ ចប់បរិបូរ ។

## ឧទ្ទិសកថា

ខ្ញុំសូមឧទ្ទិសព្រះរាជកុសល ដែលកើតពីធម្មទានដ៏ថ្លៃថ្លានេះ ថ្វាយ

-សម្ដេចព្រះមហាឃោសានន្ទ (វ៉ា-យ៉ាវ) សូមទ្រង់សោយនូវព្រះរាជមហាកុសលនេះ សមតាមព្រះរាជហឫទ័យ ។

-សម្ដេចព្រះសង្ឃរាជទាំងពីរគណៈ ទាំងមហានិកាយ ទាំងធម្មយុត្តដែលទ្រង់សោយនូវព្រះទីវង្គត កន្លងទៅហើយនោះ សូមព្រះអង្គទ្រង់សោយព្រះរាជមហាកុសលនេះ ។

សូមឧទ្ទិសកុសលនៃធម្មទានានិសង្សនេះ ប្រគេន

-ចំពោះព្រះថេរានុថេរៈព្រះសង្ឃសមណនិស្សិតដែលបានបូជាជីវិតដើម្បីព្រះពុទ្ធសាសនា សំរាប់ទុកឲ្យព្រះសង្ឃជំនាន់ក្រោយ បានយកធ្វើជាគំរូដ៏ល្អៗ... សូមបានទទួលបុណ្យកុសលនេះកុំបីខាន ។

-ចំពោះលោកសាស្ត្រាចារ្យ ឆែន-សុខន ដែលបានកសាងធម្មទានខិតខំប្រែ គម្ពីរវិសុទ្ធិមគ្គ ភាគទី៣ ទោះជាពុំទាន់បានចប់ចុងចប់ដើម ក៏ដោយ នេះជាស្នាដៃមួយដ៏ល្អ សំរាប់ព្រះពុទ្ធសាសនា... សូមលោកសាស្ត្រាចារ្យបានទទួលនូវកុសលនេះ ហើយបានទៅកើត ក្នុងសុគតិភពសមតាមមនោរថទៅហោង ។

-ចំពោះអ្នកដឹកនាំ ពួកបញ្ញវន្ត អ្នកស្នេហាជាតិ យុវជនយុវតី ប្រជាពលរដ្ឋខ្មែរ គ្រប់ជាន់ថ្នាក់ទាំងអស់ ដែលបានបូជាជីវិត ដើម្បីមាតុភូមិដោយទឹកចិត្តដ៏ស្មោះត្រង់ សូមឲ្យវិញ្ញាណក្ខន្ធអ្នកទាំងនោះបានទទួលនូវកុសលនេះ សូមបានទៅកើត ក្នុងទីសុខទីសួគ៌ កុំបីខានឡើយ ។

សូមប្រគេនមគ្គផលដែលកើតអំពីធម្មទាននេះ ចំពោះព្រះតេជះព្រះគុណ ព្រះថេរានុថេរៈ ព្រះសង្ឃគ្រប់អង្គ ដែលបានជួយឧបត្ថម្ភ ក្នុងការ

 បោះពុម្ពគម្ពីរ វិសុទ្ធិមគ្គប្រែទាំងបីភាគនេះ ឲ្យបានសំរេចជាស្ថាពរ សូមព្រះអង្គមានព្រះជន្មាយុយឺនយូរជាងរយព្រះវស្សា ដើម្បីជាម្លប់ដ៏ត្រជាក់ និង ជាទីពឹងពាក់ពំនាក់អាស្រ័យដល់ពុទ្ធបរិស័ទទាំងឡាយតរៀងទៅ ។

សូមញាតិញោម ជាពុទ្ធបរិស័ទ អស់លោក លោកស្រី លោកយាយ លោកតា កុមារា កុមារីទាំងអស់ ដែលបានជួយឧបត្ថម្ភផងដែរនោះ បានទទួលនូវកុសលដែលកើតពីធម្មទាននេះស្មើៗ គ្នា ប្រាថ្នាយ៉ាងណាៗ សូមឲ្យបានសំរេច សមដូចសេចក្ដីប្រាថ្នា ទៅហោង ។

សូមជូនបុណ្យកុសលនេះផងដែរ ដល់អ្នកដឹកនាំខ្មែរ គ្រប់ជាន់ថ្នាក់ គ្រប់គណៈបក្សទាំងអស់ សូមដឹកនាំប្រទេសជាតិ ប្រកបដោយជោគជ័យ ដើម្បីប្រយោជន៍សុខ ដល់ប្រជាជនដែលសង្ឃឹមទាំងស្រុងទៅលើមាគ៌ានៃការដឹកនាំដ៏ត្រឹមត្រូវ សុចរិត យុត្តិធម៌ និង សាមគ្គីភាព... ។

## ការមិនបៀតបៀនគ្នាជាសុខក្នុងលោក
## ការមិនចងគំនុំគុំកួននឹងគ្នាជាការប្រសើរ

**ភិក្ខុវិនយធរោ មហាយិន-ឡឿន**

វត្តខ្មែរសាន់តាអាណា សហរដ្ឋអាមេរិក

ថ្ងៃច័ន្ទ ១៥ កើត ខែវិសាខ ឆ្នាំជូត សំរិទ្ធិស័ក ព.ស. ២៥៥២
ត្រូវនឹងថ្ងៃទី ១៩ ខែឧសភា ២០០៨



## ធ្វើបុណ្យបានបុណ្យ

ធ្វើបុណ្យបានបុណ្យធ្វើបាបបានបាប  តាមជាប់ដរាបតាំងនៅខ្ជាប់ខ្ជួន
អន្ទោលតាមប្រាណមិនឃ្លាតពីខ្លួន  ទោះបីរត់រត់ពួនក៏គេចមិនបាន ។
កសាងកុសលបានផលសុខជា  ទានសីលភាវនាទៅតាមលំអាន
ឲ្យយើងបានសុខគ្រប់រូបរាល់ប្រាណ  ព្រះពុទ្ធទ្រង់បានទេសនាពណ៌នា។
សាងអកុសលបានផលថោកទាប  មានទុក្ខដុនដាបបានបាបគ្រប់គ្រា
ត្រូវគេចជៀសវាងកុំធ្វើបំពារ  បាបកម្មវេរាមានទុក្ខជាផល ។
យើងកាន់សាសនាព្រះពុទ្ធជាម្ចាស់  ព្រះអង្គទ្រង់ត្រាស់ឲ្យលះអកុសល
សាងអំពើល្អជម្រះកង្វល់  បានបុណ្យកើតផលផ្ដល់សុខចំរើន។

♣ ♣ ♣

**ភិក្ខុវិនយធរោ មហាយិន-ឡឿន**

វត្តខ្មែរសាន់តាអាណា សហរដ្ឋអាមេរិក

ថ្ងៃច័ន្ទ ១៥ កើត ខែវិសាខ ឆ្នាំជូត សំរិទ្ធិស័ក ព.ស. ២៥៥២

ត្រូវនឹងថ្ងៃទី ១៩ ខែឧសភា ឆ្នាំ ២០០៨

# មាតិការឿង

លេខរៀង | ទំព័រ


អារម្ភកថា របស់អ្នករៀបរៀង និង មាតិកា ក-ឃ

ខន្ធនិទ្ទេស

(១) ធម្មជាតិអ្វី ឈ្មោះថា បញ្ញា ១
(២) បញ្ញា ដោយអត្ថថាដូចម្តេច ២
សញ្ញា វិញ្ញាណ បញ្ញា មានការដឹងផ្សេងគ្នា ២
(៣) អ្វីជាលក្ខណៈ កិច្ច បច្ចុបដ្ឋាន និងបទដ្ឋាន របស់បញ្ញា ៥
(៤) បញ្ញា មានប៉ុន្មានយ៉ាង ៥
បញ្ញា មាន ១ យ៉ាង ៥
បញ្ញា មាន ២ យ៉ាង ៦
បញ្ញា មាន ៣ យ៉ាង ៨
បញ្ញា មាន ៤ យ៉ាង ១១
បដិសម្ភិទា ៤ យ៉ាង ១២
អត្ថប្បដិសម្ភិទា ១២
ធម្មប្បដិសម្ភិទា ១៣
និរុត្តិបដិសម្ភិទា ១៤
បដិភាណប្បដិសម្ភិទា ១៥
ភូមិបដិសម្ភិទា ២ យ៉ាង ១៥
បដិសម្ភិទាក្លៀវក្លាដោយអាការៈ៥ យ៉ាង ១៦
(៥) បញ្ញា ត្រូវចំរើនដូចម្តេច ១៨
ភូមិរបស់បញ្ញា ១៨
ខន្ធ ៥ ១៨
រូបក្ខន្ធ ១៩
ភូតរូប ឧបាទាយរូប ១៩
បសាទរូប ៥ ១៩
ចក្ខុ ២៣
សោតៈ ២៤
ឃានៈ ២៥
ជិវ្ហា ២៥
កាយ ២៥




លេខរៀង | ទំព័រ


គោចររូប ៤ ២៦
ភាវរូប ២ ជីវិតរូប ២៧
ហទយរូប ១ ២៨
វិញ្ញត្តិរូប ២ ២៩
បរិច្ឆេទរូប ១ ៣០
វិការរូប ៣ ៣១
លក្ខណរូប ៤ ៣២
ឱជារូប ១ ៣៤
រូប ១, រូប ២ ៣៥
រូប ៣ ៣៧
រូប ៣៨
រូប ៥ ៣៩
នាមក្ខន្ធ ៤ (វេទនា សញ្ញា សង្ខារ និង វិញ្ញាណ) ៤០
កុសលវិញ្ញាណ ៤២
អកុសលវិញ្ញាណ ៤៥
អព្យាកតវិញ្ញាណ ៤៨
កាមាវចរកុសលវិបាក ៥០
កាមាវចរអកុសលវិបាក ៥១
រូបាវចរ អរូបាវចរ និង លោកុត្តរវិបាក ៥២
កិរិយាវិញ្ញាណ ៥៣
វិញ្ញាណទាំងពួងប្រព្រឹត្តទៅដោយអាការៈ ៤ យ៉ាង ៥៤
បដិសន្ធិ ៥៥
ភវង្គៈ អាវជ្ជនៈ ៥៦
ទស្សនៈ, សវនៈ, ឃាយនៈ, សាយនៈ ៥៧
សាយនៈ និង ផុសនៈ ៥៧
សម្បដិច្ឆនៈ សន្តីរណៈ ៥៨
វោដ្ឋពនៈ ជវនៈ ៥៩
តទារម្មណ៍ ចុតិ ៦០
វេទនាខន្ធ ៦១
សញ្ញាខន្ធ ៦៤

| លេខរៀង | ទំព័រ |
|---|---|
| សង្ខារខន្ធ | ៦៥ |
| កុសលសង្ខារ ៣៦ | ៦៦ |
| យេវាបនកសង្ខារ ៤ | ៧៥ |
| អកុសលសង្ខារ លោភមូល ១៧ | ៨០ |
| អកុសលសង្ខារ ទោសមូល ១៨ | ៨៥ |
| អកុសលសង្ខារ មោហមូល ១៣ | ៨៧ |
| អព្យាកតសង្ខារ ផ្នែកខាងវិបាក | ៨៩ |
| អព្យាកតសង្ខារ ផ្នែកខាងកិរិយា | ៩០ |
| ខន្ធវិភាគ | ៩១ |
| វិនិច្ឆ័យខន្ធ ដោយន័យ ៦ យ៉ាង | ១០៣ |
| ន័យដោយលំដាប់ | ១០៣ |
| ន័យដោយប្លែកផ្សេងគ្នា | ១០៥ |
| ន័យដោយមិនមានខ្វះ មិនមានលើស | ១០៧ |
| ន័យដោយឧបមា | ១០៨ |
| ន័យដែលគប្បីឃើញដោយអាការៈ ២ | ១០៩ |
| ន័យសេចក្តីសំរេចប្រយោជន៍ដល់អ្នកឃើញ | ១១០ |
| **អាយតន ធាតុនិទ្ទេស** | |
| អាយតននិទ្ទេស | |
| ១១៣ | |
| វិនិច្ឆ័យអាយតនៈ ដោយអត្ថ | ១១៣ |
| ដោយលក្ខណៈ ដោយមានតែប៉ុណ្ណោះ | ១១៧ |
| ដោយលំដាប់ | ១១៩ |
| ដោយសង្ខេប និង ពិស្តារ | ១២០ |
| ដោយជារបស់ដែលគប្បីឃើញ | ១២១ |
| ធាតុនិទ្ទេស | |
| វិនិច្ឆ័យអាយតនៈ ដោយអត្ថ | ១២៣ |
| ដោយលក្ខណៈជាដើម ដោយលំដាប់ | ១២៦ |
| ដោយហេតុមានប្រមាណប៉ុណ្ណោះ | ១២៧ |
| ដោយការរាប់ | ១៣១ |
| ដោយបច្ច័យ | ១៣២ |
| ដោយរបស់ដែលគប្បីឃើញ | ១៣៤ |



| លេខរៀង | ទំព័រ |
|---|---|
| **ឥន្ទ្រិយសច្ចនិទ្ទេស** | |
| ឥន្ទ្រិយនិទ្ទេស | |
| វិនិច្ឆ័យឥន្ទ្រិយ ដោយអត្ថ | ១៣៧ |
| ដោយលក្ខណៈជាដើម | ១៣៩ |
| ដោយលំដាប់ | ១៤០ |
| ដោយញែក និង មិនញែក,ដោយកិច្ច | ១៤១ |
| ដោយភូមិ | ១៤៣ |
| សច្ចនិទ្ទេស | |
| វិនិច្ឆ័យអរិយសច្ច ដោយវិភាគ | ១៤៥ |
| ដោយអត្ថវិគហៈ | ១៤៧ |
| វិនិច្ឆ័យដោយលក្ខណៈជាដើម | ១៤៩ |
| ដោយអត្ថ | ១៥០ |
| ដោយអត្ថុទ្ធារៈ | ១៥២ |
| ដោយមិនខ្វះ មិនលើស | ១៥៣ |
| ដោយលំដាប់ | ១៥៥ |
| ទុក្ខនិទ្ទេស | |
| វិនិច្ឆ័យស័ព្ទមានជាតិជាដើម | ១៥៧ |
| ជាតិទុក្ខ | ១៥៩ |
| គព្ភបរិហរណមូលកទុក្ខ | ១៦១ |
| គព្ភវិបត្តិមូលទុក្ខ, វិជ្ជាយនមូលកទុក្ខ | ១៦២ |
| ពហិនិក្ខមនមូលកទុក្ខ | ១៦២ |
| អត្តុបក្កមមូលកទុក្ខ, បរបក្កមមូលកទុក្ខ | ១៦៣ |
| ជរាទុក្ខ | ១៦៥ |
| មរណទុក្ខ | ១៦៦ |
| សោកទុក្ខ | ១៦៨ |
| បរិទេវទុក្ខ, ទុក្ខ | ១៦៩ |
| ទោមនស្សទុក្ខ | ១៧០ |
| ឧបាយាសទុក្ខ | ១៧១ |
| អប្បិយសម្បយោគទុក្ខ | ១៧២ |

| លេខរៀង | ទំព័រ |
|---|---|
| បិយវិប្បយោគទុក្ខ | ១៧៣ |
| ឥច្ឆិតាលាភទុក្ខ | ១៧៤ |
| បញ្ចុបាទានក្ខន្ធទុក្ខ | ១៧៥ |
| ទុក្ខសមុទយនិទ្ទេស | ១៧៧ |
| ទុក្ខនិរោធនិទ្ទេស | ១៧៨ |
| បញ្ហាស្មុគស្មាញ ក្នុងរឿងព្រះនិព្វាន | ១៨០ |
| ទុក្ខនិរោធគាមិនីបដិបទានិទ្ទេស | ១៨៥ |
| ដោយកិច្ចញ្ញាណ | ១៨៨ |
| ដោយប្រភេទនៃធម៌ក្នុងអរិយសច្ច | ១៩០ |
| ដោយឧបមា | ១៩១ |
| ដោយចតុក: | ១៩២ |
| ដោយសោះសូន្យ | ១៩៤ |
| ដោយវិធីផ្សេងៗ | ១៩៥ |
| ដោយមានចំណែកស្មើ និង មិនស្មើ | ២០០ |
| **បញ្ញាភូមិនិទ្ទេស** | |
| បដិច្ចសមុប្បាទ | ២០៣ |
| សេចក្តីនៃបដិច្ចសមុប្បាទ | ២០៤ |
| កែបទឥទប្បច្ចយតា | ២០៧ |
| បដិច្ចសមុប្បាទធម៌ដែលជាផល | ២១២ |
| បដិច្ចសមុប្បាទធម៌ដែលជាហេតុ | ២១៣ |
| បដិច្ចសមុប្បាទធម៌ដែលជាមជ្ឈិមាបដិបទា | ២១៥ |
| វិនិច្ឆ័យដោយប្រភេទនៃទេសនា | ២១៨ |
| វិនិច្ឆ័យដោយអត្ថ | ២២៦ |
| វិនិច្ឆ័យដោយលក្ខណ:ជាដើម | ២៣២ |
| វិនិច្ឆ័យដោយប្រការផ្សេងៗ | ២៣៤ |
| វិត្ថារន័យ នៃបដិច្ចសមុប្បាទ | ២៣៦ |
| កែបទអវិជ្ជា | ២៣៦ |
| កែបទសង្ខារ | ២៣៨ |
| បច្ច័យ ២៤ | ២៤២ |





| លេខរៀង | ទំព័រ |
|---|---|
| កែបច្ច័យសព្ទ | ២៤៣ |
| កែអារម្មណប្បច្ច័យ | ២៤៥ |
| កែអធិបតិប្បច្ច័យ | ២៤៦ |
| កែអនន្តរប្បច្ច័យ និង សមនន្តរប្បច្ច័យ | ២៤៧ |
| កែសហជាតប្បច្ច័យ | ២៤៩ |
| កែអញ្ញមញ្ញបច្ច័យ, និស្សយប្បច្ច័យ | ២៥០ |
| កែឧបនិស្សយប្បច្ច័យ | ២៥១ |
| អារម្មណូបនិស្សយប្បច្ច័យ | ២៥១ |
| អនន្តរូបនិស្ស័យ | ២៥២ |
| បកតូបនិស្ស័យ | ២៥៤ |
| កែបុរេជាតប្បច្ច័យ | ២៥៥ |
| កែបច្ឆាជាតប្បច្ច័យ,អាសេវនប្បច្ច័យ,កម្មប្បច្ច័យ | ២៥៦ |
| កែវិបាកប្បច្ច័យ, អាហារប្បច្ច័យ | ២៥៧ |
| កែឥន្ទ្រិយប្បច្ច័យ | ២៥៨ |
| កែឈានប្បច្ច័យ, មគ្គប្បច្ច័យ | ២៥៩ |
| កែសម្បយុត្តប្បច្ច័យ, វិប្បយុត្តប្បច្ច័យ | ២៦០ |
| កែអត្ថិប្បច្ច័យ | ២៦១ |
| កែនត្ថិប្បច្ច័យ, វិគតប្បច្ច័យ, អវិគតប្បច្ច័យ | ២៦៣ |
| កែបទអវិជ្ជាបច្ចយា សង្ខារា | ២៦៤ |
| កែបទសង្ខារប្បច្ចយា វិញ្ញាណ | ២៧៣ |
| ការប្រព្រឹត្តិទៅនៃវិញ្ញាណ | ២៧៦ |
| បវត្តិកាល និង បដិសន្ធិ | ២៧៦ |
| បដិសន្ធិ មានប៉ុន្មានយ៉ាង | ២៨០ |
| បដិសន្ធិចិត្ត មានប៉ុន្មានយ៉ាង | ២៨០ |
| បដិសន្ធិ មានក្នុងភពណា | ២៨០ |
| អ្វីជាអារម្មណ៍នៃបដិសន្ធិ | ២៨០ |
| កែបទវិញ្ញាណប្បច្ចយា នាមរូបំ | ៣០៥ |
| សេចក្តីវិនិច្ឆ័យការប្រព្រឹត្តិទៅនៃនាមរូប | ៣០៥ |
| កែបទនាមរូបបច្ចយា សឡាយតនំ | ៣១៤ |
| កែបទសឡាយតនប្បច្ចយា ផស្សោ | ៣២១ |

លេខរៀង ទំព័រ


កែបទផស្សប្បច្ចយា វេទនា ៣២៥
កែបទវេទនាបច្ចយា តណ្ហា ៣២៧
កែបទតណ្ហាបច្ចយា ឧបាទានំ ៣៣១
កែបទឧបាទានប្បច្ចយា ភវោ ៣៣៧
កែបទភវប្បច្ចយា ជាតិ ៣៤៩
កែបទជាតិប្បច្ចយា ជរាមរណំ ៣៥០
ភវចក្រ ៣៥១
បដិសន្ធិ ៣ ៣៥៧
សង្គហៈ ៤, អាការៈ ២០, អតីតហេតុ ៥ ៣៥៨
ផលក្នុងបច្ចុប្បន្ន ៥ ៣៦០
បច្ចុប្បន្នហេតុ ៥ ៣៦១
ផលជាអនាគត ៥ ៣៦២
វដ្ដៈ ៣ ៣៦៣
ដោយកិច្ច ៣៥៤
ដោយគ្រឿងរារាំង ៣៦៥
ដោយឧបមា ៣៦៦
ដោយការផ្សេងគ្នានៃគម្ភីរភាព ៣៦៨
ជ្រាលជ្រៅដោយផល ៣៦៨
ជ្រាលជ្រៅដោយហេតុ ៣៦៩
ជ្រាលជ្រៅដោយការសំដែង ៣៧០
ជ្រាលជ្រៅដោយបដិវេធ ៣៧០
ដោយន័យផ្សេងៗ ៣៧២
ឯកត្តន័យ ៣៧២
នានត្តន័យ, អព្យាបាទន័យ ៣៧៣
ឯវំធម្មតាន័យ ៣៧៤


### ទិដ្ឋិវិសុទ្ធិនិទ្ទេស


វិបស្សនាវិធី ៣៧៦
កំណត់នាមរូប ដោយធាតុ ១៨ ៣៨០
កំណត់នាមរូប ដោយអាយតនៈ ១២ ៣៨១
កំណត់នាមរូប ដោយខន្ធ ៥ ៣៨២




លេខរៀង ទំព័រ


កំណត់នាមរូប ដោយសង្ខេប ៣៨៣
អរូបធម៌ប្រាកដដោយអាការៈ៣, ដោយផស្សៈ ៣៨៥
អរូបធម៌ប្រាកដដោយវិញ្ញាណ ៣៨៦


### កង្ខាវិតរណវិសុទ្ធិនិទ្ទេស


ការពិចារណាហេតុបច្ច័យនៃនាមរូប ៤០០
កំណត់ហេតុបច្ច័យនៃនាមរូប ទី ១ ៤០១
សេចក្តីសង្ស័យ ១៦ យ៉ាង ៤០២
កំណត់បច្ច័យនៃនាមរូប ទី ២ ៤០៣
កំណត់បច្ច័យនៃនាមរូប ទី ៣ ៤០៤
កំណត់បច្ច័យនៃនាមរូប ទី ៤...ទី ៥ ៤០៥
កម្មឲ្យផល តាមកាល ៤ យ៉ាង ៤០៦
កម្មឲ្យផល តាមលំដាប់ ៤ យ៉ាង ៤០៧
កម្មឲ្យផល តាមកិច្ច ៤ យ៉ាង ៤០៨
គាថាសរុបចុតិបដិសន្ធិចិត្ត ៤១៣


### មគ្គាមគ្គញ្ញាណទស្សនវិសុទ្ធិនិទ្ទេស


បរិញ្ញា ៣ ៤១៨
ភូមិរបស់បញ្ញា ៤១៩
បាលីសម្មសនញ្ញាណ ៤២១
អភិញ្ញេយ្យនិទ្ទេស ៤២៣
វិធីធ្វើការពិចារណា ៤២៦
ចុះកាន់សម្មត្តនិយាមធម៌ ដោយអាការៈ ៤០ ៤២៩
សង្គ្រោះសម្មសនៈ ៤០ ក្នុងអនុបស្សនា ៣ ៤៣៦
ធ្វើឥន្ទ្រិយ ឲ្យចាស់ក្លា ដោយអាការៈ ៩ យ៉ាង ៤៣៧
វិភាគនៃកម្មជរូប ៤៣៩
វិភាគនៃចិត្តជរូប ៤៤១
វិភាគនៃអាហារជរូប ៤៤២
វិភាគនៃឧតុជរូប ៤៤៤
ពិចារណារូប តាមកាល ៤៤៦
ពិចារណារូប និង អរូប ដោយអាការៈ ៧ ៤៤៨
រូបសត្តកៈ ៤៤៨

| លេខរៀង | ទំព័រ |
|---|---|


អាទាននិក្ខេបនតោ ៤៤៩
វយោវុឌ្ឍត្ថគាមតោ ៤៥០
ការពិចារណារូប ៤៥៩
ការកំណត់ដោយសមុដ្ឋាន ៤ ៤៦១
កំណត់ក្នុងអាហារមយរូប ៤៦១
កំណត់ក្នុងឧតុមយរូប ៤៦២
កំណត់កម្មជរូប ៤៦៣
កំណត់ក្នុងចិត្តសមុដ្ឋានរូប ៤៦៣
ធម្មតារូប ៤៦៦
ដោយកលាប ៤៦៨
ដោយជាគូ, ដោយខណៈ ៤៦៩
ដោយលំដាប់ ៤៧០
ដោយដកចេញនូវទិដ្ឋិ, ដកមានះ ៤៧១
ដោយគ្របសង្កត់នូវសេចក្តីត្រេកអរ ៤៧១
មហាវិបស្សនា ១៨ ៤៧៤
ឧទយព្វយានុបស្សនាញាណ ៤៧៧
ការជាក់ច្បាស់នៃសច្ចៈ ៤៨១
បដិច្ចសមុប្បាទធម៌ និងបដិច្ចសមុប្បន្នធម៌ប្រាកដ ៤៨២
ន័យទាំង ៤ ប្រាកដ ៤៨២
ការប្រាកដនៃលក្ខណៈ ៤៨៣
វិបស្សនូបកិលេស ១០ ៤៨៥
វិបស្សនូបកិលេស ១០ ចែកជា ៣០ ៤៩៤


## បដិបទាញាណទស្សនវិសុទ្ធិនិទ្ទេស


មុញ្ចិតុកម្យតាញាណ ៤៦៣
ឧបមា នៃមុញ្ចិតុកម្យតាញាណ ៥២៤
បដិសង្ខានុបស្សនាញាណ ៥២៥
ឧបមា នៃបដិសង្ខានុបស្សនាញាណ ៥២៨
សង្ខារុបេក្ខាញាណ ៥៣១
កំណត់សុញ្ញតា ដោយអាការៈ ៦ ៥៣២
កំណត់សុញ្ញតា ដោយអាការៈ ៨ ៥៣៣




| លេខរៀង | ទំព័រ |
|---|---|


កំណត់សុញ្ញតា ដោយអាការៈ ១០...អាការៈ ៤២ ៥៣៨
សង្ខារុបេក្ខាញាណ ប្រៀបដូចសត្វក្អែកប្រាប់ទិស ៥៣៩
វិមោក្ខ ៣ ៥៤០
វិមោក្ខ ៣ បានដល់អរិយមគ្គ ៥៤២
វិមោក្ខ ២ បានដល់វិបស្សនាញាណ ៥៤២
ព្រះអរិយបុគ្គល ៧ ពួក ៥៤៤
វុដ្ឋានគាមិនីវិបស្សនា ៥៤៨
ឧបមា នៃវុដ្ឋានគាមិនីវិបស្សនា ១២ ៥៥៣
ការបំពេញឧទយព្វយញ្ញាណបន្ថែម ៤៩៨
ការវិភាគនៃត្រៃលក្ខណ៍ ៤៩៩
ភង្គានុបស្សនាញាណ ៥០១
អានិសង្សនៃភង្គានុបស្សនាញាណ ៥០៩
ភយតុបដ្ឋានញ្ញាណ ៥១០
ឧបមា នៃភយតុដ្ឋានញ្ញាណ ៥១១
អាទីនវានុបស្សនាញាណ ៥១៥
ឧបមា នៃអាទីនវានុបស្សនាញាណ ៥១៦
និព្វិទានុបស្សនាញាណ ៥២២
ឧបមា នៃនិព្វិទានុបស្សនាញាណ ៥២២
អនុលោមញ្ញាណ ៥៦៧
សេចក្តីឧបមា នៃអនុលោមញ្ញាណ ៥៦៩
ឈ្មោះផ្សេងៗ នៃអនុលោមញ្ញាណ ៥៧០


## ញាណទស្សនវិសុទ្ធិនិទ្ទេស


បឋមញ្ញាណ... គោត្រភូញាណ ៥៧៣
ឧបមា នៃអនុលោមញ្ញាណ និង គោត្រភូញាណ ៥៧៥
ការធ្វើកិច្ចនៃអនុលោមញ្ញាណ និងគោត្រភូញាណ ៥៧៦
អានិសង្សផ្សេងៗ នៃមគ្គ ៥៧៨
ទុតិយញ្ញាណ ៥៧៩
បច្ចវេក្ខណៈ ១៩ ៥៨០
តតិយញ្ញាណ ៥៨២
ចតុត្ថញ្ញាណ ៥៨៣

| លេខរៀង | ទំព័រ |
| --- | --- |


ចតុត្ថមគ្គញ្ញាណ ៥៨៣
អានុភាពនៃមគ្គញ្ញាណ... ពោធិបក្ខិយធម៌ ៥៨៥
វិភាគនៃពោធិបក្ខិយធម៌ ជា ៦ ប្រការ ៥៩០
វុដ្ឋានៈ និង ពលយោគៈ ៥៩១
ពលសមាយោគៈ ៥៩៣
មគ្គញ្ញាណ លះកិលេសនៅពេលណា ៦០២
ការផ្សេងគ្នា នៃភូមិ និង ភូមិលទ្ធៈ ៦០៦
កិច្ច ក្នុងអរិយមគ្គ ៦១២
មគ្គញ្ញាណ ធ្វើកិច្ចដូចប្រទីប ៦១២
មគ្គញ្ញាណ ធ្វើកិច្ចដូចព្រះអាទិត្យ ៦១៣
មគ្គញ្ញាណ ធ្វើកិច្ចដូចនាវាជំនួញ ៦១៤
ត្រាស់ដឹងអរិយសច្ច ដោយអាការៈ ១៦ ៦១៤
កិច្ច ៤ យ៉ាង ក្នុងអរិយសច្ច ៦១៨
បរិញ្ញាកិច្ច ៦១៨
ញាតបរិញ្ញា.... តីរណបរិញ្ញា ៦១៩
បហានបរិញ្ញា ៦២០
បហានកិច្ច ៦២១
វិក្ខម្ភនបហានៈ.... តទង្គប្បហានៈ ៦២១
សមុច្ឆេទបហានៈ ៦២៧
សច្ឆិកិរិយាកិច្ច ៦២៨
ភាវនាកិច្ច ៦២៩
បញ្ហាភាវនានិសង្សនិទ្ទេស ៦៣២
ការកំចាត់កិលេសផ្សេងៗ ៦៣២
ការសោយរសនៃអរិយផល ៦៣៣
ផលសមាបត្តិ គឺជាអ្វី ៦៣៤
អ្នកណាចូលសមាបត្តិបាន និង មិនបាន ៦៣៥
ចូលដូចម្តេច...តាំងនៅដូចម្តេច....ចេញដូចម្តេច ៦៣៦
អ្វីមាន ក្នុងលំដាប់នៃផល ៦៣៨
និរោធសមាបត្តិ គឺជាអ្វី ៦៤១
អ្នកណា ចូលនិរោធបាន អ្នកណា...មិនបាន ៦៤១




| លេខរៀង | ទំព័រ |
| --- | --- |


ពលៈ ២ ៦៤២
វិបស្សនាពលៈ ៦៤៣
ការរម្ងាប់នៃសង្ខារ ៣, ញាណចរិយា ១៦ ៦៤៤
សមាធិចរិយា ៩, វសី ៥ ៦៤៥
ចូលបាន ក្នុងទីណា ៦៤៧
ចូលព្រោះហេតុអ្វី... ចូលដូចម្តេច ៦៤៨
វិបស្សនា ៣, លំដាប់នៃការចូលសមាបត្តិ ៦៤៩
បុព្វកិច្ច មុនការចូល ៦៥០
នានាពទ្ធអវិកោបនៈ ៦៥០
សង្ឃប្បដិមាននៈ ៦៥១
សត្ថុបក្កោសនៈ ៦៥២
អទ្ធានបរិច្ឆេទ ៦៥៣
ការចូលនិរោធ ៦៥៤
ចូលហើយស្ថិតនៅ ដូចម្តេច ចេញដូចម្តេច ៦៥៥
ចិត្តអ្នកចូលហើយបង្អោនទៅរកអ្វី ៦៥៦
អ្នកស្លាប់ និងមនុស្សចូលនិរោធផ្សេងគ្នាដូចម្តេច ៦៥៦
និរោធសមាបត្តិ ជាសង្ខតៈ ឬ អសង្ខតៈ ៦៥៧
ការសំរេចជាព្រះអាហុនេយ្យបុគ្គលជាដើម ៦៥៧
ប្រភេទនៃព្រះអរិយបុគ្គល ៦៥៨
និគមវចនៈ ៦៦២
ឧទ្ទិសកុសល ៦៦៣
ពាក្យសច្ចាធិដ្ឋាន ៦៦៤
គុណសម្បត្តិព្រះពុទ្ធឃោសាចារ្យ ១១ ប្រាការ ៦៦៥
ពុទ្ធឃោសាប្បវត្តិកថា ៦៦៧
សង្គហគាថា ៦៧៣
អវសានកិច្ចអ្នករៀបរៀង ៦៨១

## អក្សរសង្ខេប ប្រើក្នុងលេខយោង

| | | | | |
|---|---|---|---|---|
| អភិ. | ធា. | គឺ | អភិធម្មបិដក | ធាតុកថា |
| អភិ. | ប | គឺ | អភិធម្មបិដក | បដ្ឋាន |
| អភិ. | វិ. | គឺ | អភិធម្មបិដក | វិភង្គ |
| អភិ. | សំ. | គឺ | អភិធម្មបិដក | សង្គណិ |
| សុ. | | គឺ | សុត្តន្តបិដក | |
| អំ. | អ. | គឺ | អង្គុត្តរនិកាយ | អដ្ឋកនិបាត |
| អំ. | ឯ. | គឺ | អង្គុត្តរនិកាយ | ឯកនិបាត |
| អំ. | ឯក. | គឺ | អង្គុត្តរនិកាយ | ឯកាទសកនិបាត |
| អំ. | ច. | គឺ | អង្គុត្តរនិកាយ | ចតុក្កនិបាត |
| អំ. | ឆ. | គឺ | អង្គុត្តរនិកាយ | ឆកនិបាត |
| អំ. | តិ. | គឺ | អង្គុត្តរនិកាយ | តិកនិបាត |
| អំ. | ទ. | គឺ | អង្គុត្តរនិកាយ | ទសកនិបាត |
| អំ. | ន. | គឺ | អង្គុត្តរនិកាយ | នវកនិបាត |
| អំ. | ប. | គឺ | អង្គុត្តរនិកាយ | បញ្ចកនិបាត |
| អំ. | ស. | គឺ | អង្គុត្តរនិកាយ | សត្តកនិបាត |
| ខុ. | ឥ. | គឺ | ខុទ្ទកនិកាយ | ឥតិវុត្តកៈ |
| ខុ. | ឧ. | គឺ | ខុទ្ទកនិកាយ | ឧទាន |
| ខុ. | ខុ. | គឺ | ខុទ្ទកនិកាយ | ខុទ្ទកបាឋ |
| ខុ. | ចុ. | គឺ | ខុទ្ទកនិកាយ | ចុឡនិទ្ទេស |
| ខុ. | ជា. ឯ. | គឺ | ខុទ្ទកនិកាយ | ជាតក ឯកនិបាត |
| ខុ. | ជា. តិ. | គឺ | ខុទ្ទកនិកាយ | ជាតក តិកនិបាត |
| ខុ. | ធម្ម. | គឺ | ខុទ្ទកនិកាយ | ធម្មបទ |
| ខុ. | បដិ. | គឺ | ខុទ្ទកនិកាយ | បដិសម្ភិទាមគ្គ |
| ខុ. | មហា. | គឺ | ខុទ្ទកនិកាយ | មហានិទ្ទេស |
| ខុ. | សុ. | គឺ | ខុទ្ទកនិកាយ | សុត្តនិបាត |
| ទី. | បា. | គឺ | ទីឃនិកាយ | បាដិកវគ្គ |
| ទី. | ម. | គឺ | ទីឃនិកាយ | មហាវគ្គ |
| ទី. | សី. | គឺ | ទីឃនិកាយ | សីលក្ខន្ធវគ្គ |
| ម. | ឧ. | គឺ | មជ្ឈិមនិកាយ | ឧបរិបណ្ណាសក |
| ម. | ម. | គឺ | មជ្ឈិមនិកាយ | មជ្ឈិមបណ្ណាសក |
| ម. | មូ. | គឺ | មជ្ឈិមនិកាយ | មូលបណ្ណាសក |
| វិ. | ម. | គឺ | វិនយបិដក | មហាវិភង្គ |
| វិ. | ប. | គឺ | វិន័យបិដក | បរិវារ |
| វិ. | ម. ម. | គឺ | វិន័យបិដក | មហាវិភង្គ មហាខន្ធក |
| សំ. | ខ. | គឺ | សំយុត្តនិកាយ | ខន្ធវារវគ្គ |
| សំ. | និ. | គឺ | សំយុត្តនិកាយ | និទានវគ្គ |
| សំ. | ម. | គឺ | សំយុត្តនិកាយ | មហាវគ្គ |
| សំ. | សគ. | គឺ | សំយុត្តនិកាយ | សគាថវគ្គ |
| សំ. | ស. | គឺ | សំយុត្តនិកាយ | សឡាយតនវគ្គ |



## ត្រូវស្នេហាជាតិ

ខ្មែរអើយរក្សាកេរមត៌កជាតិ កុំឲ្យខូចខាតការពារឲ្យគង់
នាំគ្នាស្តារឡើងលើកស្ទួយតម្រង់ កុំឲ្យបាត់បង់រក្សាឲ្យបាន ។

វប្បធម៌ជាតិទំនៀមទំលាប់ ប្រាសាទក្បួនច្បាប់កេរពីបូរាណ
ជាព្រលឹងជាតិអង្គរថ្កើងថ្កាន រក្សាឲ្យបានដើម្បីជាតិរស់ ។

ជួយកសាងជាតិនិងសាសនា ឲ្យបានថ្លៃថ្លាដោយចិត្តដ៏ស្មោះ
រួបរួមគ្នាឡើងទាំងសង្ឃគ្រហស្ថ លើកស្ទួយសង្គ្រោះព្រលឹងជាតិខ្មែរ ។

ទាំងតូចទាំងធំខេមរាគ្រប់ប្រាណ សាមគ្គីឲ្យបានកុំឲ្យបែកបែរ
ខំសាងស្រុកទេសជួយរក្សាផែ យើងពូជពង្សខ្មែរត្រូវស្នេហាជាតិ ។

♣ ♣ ♣

**ភិក្ខុវិនយធរោ មហាយិន-នឿន**

## ឯកសារជំនួយ

១- ព្រះត្រៃបិដកខ្មែរ ។

២- វិសុទ្ធិមគ្គបាលី ភាគទី ១-២-៣ ។

៣- វិសុទ្ធិមគ្គសង្ខេប អាចារ្យអ៊ុច-រស់ និង អាចារ្យឈឹម-ទូច

៤- សទ្ទានុក្រមបាលី-ខ្មែរ ចេញថ្មី ព.ស. ២៥៥១

៥- បទានុក្រមធម្មបទ ភាគ ១-២-៣ ។

៦- អភិធានប្បទីបិកា មឹង-សេស

៧- វិធីប្រែបាលី

៨- មង្គលត្ថទីបនីប្រែ ភាគទី ១-២-៣-៤

៩- វចនានុក្រមខ្មែរ ភាគ ១-២ សម្តេចជួន-ណាត

១០- ធាតុប្បទីបិកា

១១- ប្រជុំភាណវារៈបាលី-ប្រែ ពិសេស

១២- សម្ពន្ធមាលា និង ឯកសារផ្សេងៗ មួយចំនួនទៀត ។



## ព្រះរាជនិពន្ធ

### សម្តេចព្រះសង្ឃរាជ ជួន-ណាត ជោតញ្ញាណោ

ជនណាបាន ប្រព្រឹត្តធម៌ នេះទៀងទាត់,
ពុំដែលភ្លាត់ តែងរស់នៅ យូរអង្វែង,
ដូចភាសិត ដែលព្រះពុទ្ធ ទ្រង់សំដែង,
ជនទោះឯង តែងបានសុខ ប្រសើរបោង។

ខត្តឧណ្ណាលោម ទីក្រុងភ្នំពេញ

*ថ្ងៃពុធ ទី២៤ កក្កដា ព.ស. ២៥១២ គ.ស.១៩៦៨*

♣ ♣ ♣

# បករណ៍វិសេសឈ្មោះវិសុទ្ធិមគ្គប្រែ

## ភាគទី៣

*នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។*

## ខន្ធនិទ្ទេស

*(២៦៣) ក្នុងកាលឥឡូវនេះ សមាធិ ដែលព្រះមានព្រះភាគទ្រង់សំដែងហើយ ក្នុងបាទគាថានេះថា* “សីលេ បតិដ្ឋាយ នរោ សប្បញ្ញោ ចិត្តំ បញ្ញញ្ច ភាវយំ” *ដោយប្រធាន គឺចិត្ត ជាសមាធិ គឺភិក្ខុអ្នកប្រកបព្រមហើយ ដោយការចម្រើន នូវសមាធិ ដ៏រឹងប៉ឹងក្រៃលែង មានអានិសង្ស ដែលខ្លួនបានសម្រេចហើយ ដោយអំណាចនៃអភិញ្ញា យ៉ាងនេះ បានចម្រើនរួចស្រេចហើយ ដោយប្រការទាំងពួង, ក៏បញ្ញា ដែលមានក្នុងលំដាប់ នៃសមាធិនោះ ភិក្ខុ អ្នកប្រកបព្រមដោយសមាធិភាវនានោះ គប្បីចម្រើន, ក៏ប៉ុន្តែ បញ្ញានោះ គឺបុគ្គលមិនងាយនឹងធ្វើបាន ដោយកិរិយាត្រឹមតែការយល់ដឹង ប៉ុណ្ណោះទេ, មិនចាំបាច់ពោលទៅថ្វីដល់ការអប់រំ ព្រោះភាវៈនៃបញ្ញានោះ ព្រះអង្គទ្រង់ត្រាស់ ដោយសង្ខេបក្រៃពេក, ព្រោះហេតុនោះ ដើម្បីសម្តែងនូវសេចក្តីពិស្តារ របស់បញ្ញានោះ និង វិធី ក្នុងការអប់រំផង ទើបមានបញ្ហាកម្មនេះ ថា :*

(១) ធម្មជាតិអ្វី ឈ្មោះថា បញ្ញា,

(២) បញ្ញា ដោយអត្ថថា ដូចម្តេច,

(៣) អ្វីជាលក្ខណៈ, កិច្ច, ផល និង ហេតុ របស់បញ្ញានោះ,

(៤) បញ្ញា មានប៉ុន្មានយ៉ាង,

(៥) បញ្ញា ត្រូវចម្រើនយ៉ាងដូចម្តេច,



(៦) អ្វីជាអានិសង្ស នៃការចម្រើនបញ្ញា ។

*ក្នុងបញ្ហាកម្មនោះ មានការដោះស្រាយ ដូចតទៅនេះ :*

### (ធម្មជាតិអ្វី ឈ្មោះថា បញ្ញា)

*(២៦៤) ត្រង់បញ្ហាកម្មថា* “ធម្មជាតិអ្វី ឈ្មោះថាបញ្ញា” *មានការវិសជ្ជនា ថា : បញ្ញា មានច្រើនយ៉ាង ច្រើនប្រការ, ការវិសជ្ជនា គឺខ្ញុំកាលប្រារព្ធ សំដែងឲ្យច្បាស់ នូវបញ្ញាទាំងអស់នោះ មិនគប្បីញ៉ាំងប្រយោជន៍ដែលលោកប៉ងយកហើយ ឲ្យសម្រេចផង ទាំងប្រព្រឹត្តទៅដើម្បីសេចក្តីរាយមាយ តទៅទៀតផង ព្រោះហេតុនោះ យើងពោលសំដៅយកនូវបញ្ញា ដែលលោកបំណងយកហើយ ក្នុងអធិការនេះតែប៉ុណ្ណោះ, (គឺ) វិបស្សនាញាណ ដែលសម្បយុត្ត ដោយកុសលចិត្ត ឈ្មោះថា* បញ្ញា ។

### (បញ្ញា ដោយអត្ថថាដូចម្តេច)

*(២៦៥) ត្រង់បញ្ហាកម្មថា* “បញ្ញា ដោយអត្ថថាដូចម្តេច” *មានវិសជ្ជនាថា: ដែលហៅថា បញ្ញា ព្រោះអត្ថថា ដឹងសព្វគ្រប់ ។ តើធម្មជាតិអ្វី ឈ្មោះថា ការដឹងសព្វ? ។ គឺការដឹង ដោយប្រការផ្សេងៗ ពិសេសជាងអាការៈដឹងជាក់ និង អាការៈដឹងច្បាស់ ។ ពិតមែនហើយ កាលបើភាវៈនៃសញ្ញា វិញ្ញាណ និង បញ្ញា មានការដឹងដូចគ្នា, សញ្ញាគ្រាន់តែកំណត់ចាំបាននូវអារម្មណ៍ថា “(រូបនោះ) មានពណ៌ខៀវ, មានពណ៌លឿង” ដូច្នេះតែប៉ុណ្ណោះ, តែមិនអាចញ៉ាំងបុគ្គលឲ្យដល់នូវការចាក់ធ្លុះ នូវលក្ខណៈ ថា* “អនិច្ចំ, ទុក្ខំ, អនត្តា” *ដូច្នេះបានឡើយ, វិញ្ញាណ ដឹងបាន នូវអារម្មណ៍ថា “(រូបនោះ) មានពណ៌ខៀវ, មានពណ៌លឿង” ដូច្នេះផង, ញ៉ាំងបុគ្គលឲ្យដល់នូវការចាក់ធ្លុះ នូវលក្ខណៈ*

បានផង, តែមិនអាចខ្វះខ្វែង ញ៉ាំងបុគ្គលឲ្យដល់នូវភាវៈជាអ្នកចាក់ធ្លុះនូវលក្ខណៈបានឡើយ, ចំណែកខាងបញ្ញាដឹងនូវអារម្មណ៍ផង, ញ៉ាំងបុគ្គលឲ្យដល់នូវការចាក់ធ្លុះ នូវលក្ខណៈផង, ថែមទាំងជាអ្នកខ្វះខ្វែងញ៉ាំងបុគ្គល ឲ្យដល់នូវភាពជាអ្នកដល់នូវការចាក់ធ្លុះនូវមគ្គផង ដោយអំណាចន័យដែលលោកពោលហើយ ។ ប្រៀបឧបមាដូចជា នាកាលជនទាំង ៣ ពួក គឺ : ទារក មិនទាន់ដឹងក្តី ១ បុរសអ្នកនៅក្នុងស្រុក ១ ជាងធ្វើប្រាក់១ កាលឃើញនូវគំនរ នៃកហាបណៈ ដែលបុគ្គលដាក់ហើយ លើផែននៃប្រាក់, ទារក មិនទាន់ដឹងក្តី ស្គាល់បានត្រឹមតែភាពនៃបរិមណ្ឌលមានជ្រុងវែង និង បួនជ្រុងនៃកហាបណៈទាំងឡាយដែលបុគ្គលធ្វៃ និង វិចិត្រហើយតែប៉ុណ្ណោះ មិនអាចដឹងបានថា វត្ថុនេះ ជាគ្រឿងឧបភោគបរិភោគ ដែលគេសន្មតហៅថា ជារតនវត្ថុ របស់មនុស្សទាំងឡាយ, បុរសអ្នកស្រុក ដឹងនូវភាវៈនៃវត្ថុដែលជាងធ្វៃ និង វិចិត្រហើយជាដើម ថា : វត្ថុនេះ ជាគ្រឿង ឧបភោគបរិភោគ ដែលគេសន្មតហៅថា ជារតនវត្ថុ របស់មនុស្សទាំងឡាយ, ប៉ុន្តែមិនដឹងនូវការវិភាគនេះ ថា : របស់នេះសុទ្ធ, របស់នេះក្លែងក្លាយ, របស់នេះក្រឡៃ, បុរសជាងប្រាក់ ដឹងនូវបការៈទាំងអស់នោះផង កាលដឹង រមិលមើលស្គាល់នូវកហាបណៈផង ឮសម្លេងនៃកហាបណៈ ដែលបុគ្គលគោះហើយផង, ធុំក្លិនផង ជញ្ជក់រសជាតិផង ទ្រទ្រង់ដោយដៃផង ដឹងថាសភាវៈនេះ គឺបុគ្គលធ្វើហើយ ក្នុងស្រុកឯណោះក្តី ក្នុងនិគមឯណោះក្តី ក្នុងនគរឯណោះក្តី ក្នុងភ្នំឯណោះក្តី ទៀបឆ្នេរនៃស្ទឹងក្តី ឬក៏ ដឹងថាគ្រូឈ្មោះឯណោះ ធ្វើហើយ, សេចក្តីនេះ មានឧបមា យ៉ាងណាមិញ, បណ្ឌិត គប្បីជ្រាបពាក្យឧបមេយ្យនេះ យ៉ាងនោះដែរ ។ សេចក្តីថា



សញ្ញាប្រៀបដូចជាការឃើញនូវកហាបណៈនៃទារក ដែលមិនទាន់ដឹងក្តី ព្រោះការកាន់យក នូវវត្ថុត្រឹមតែអាការៈនៃការតាំងឡើង នៃអារម្មណ៍ ដោយអំណាចនៃវត្ថុមានពណ៌ខៀវជាដើម។ វិញ្ញាណដូចជាការឃើញកហាបណៈនៃបុរសអ្នកស្រុក ព្រោះការកាន់យកនូវអាការៈនៃអារម្មណ៍ ដោយអំណាចនៃពណ៌ មានពណ៌ខៀវជាដើមផង ព្រោះការញ៉ាំងកិរិយាចាក់ធ្លុះចំពោះនូវលក្ខណៈ ដ៏ខ្ពង់ខ្ពស់លើ ឲ្យដល់ព្រមផង ។ បញ្ញា ទុកដូចជាការឃើញនូវកហាបណៈនៃជាងប្រាក់ហើយ កាន់យកនូវអាការៈនៃអារម្មណ៍ ដោយអំណាចនៃពណ៌ខៀវជាដើម ហើយញ៉ាំងការចាក់ធ្លុះចំពោះនូវលក្ខណៈ ឲ្យដល់ហើយ ញ៉ាំងភាវៈនៃកិរិយាដល់នូវមគ្គដ៏ខ្ពង់ខ្ពស់លើ អំពីនោះតទៅទៀត ឲ្យដល់ផង ។ ព្រោះហេតុនោះ ការដឹងដោយប្រការផ្សេងៗ ពិសេស គឺជាអាការៈដែលដឹងជាក់ ។ ការដឹងច្បាស់នុ៎ះឯណា, ការដឹងនេះ គឺបណ្ឌិតគប្បីជ្រាបថា ជាការដឹងច្បាស់ ។ សេចក្តីថា ពាក្យនេះថា “បញ្ញា ដោយអត្ថថា ដឹងច្បាស់” គឺលោកពោលហើយ ព្រោះសំដៅយកនូវពាក្យថា ដឹងច្បាស់នេះ ។

ចំណែកខាងបញ្ញានេះនោះដ៏ល្អិត ដែលបុគ្គលឃើញបាន ដោយកម្រ ព្រោះភាវៈនៃបញ្ញានោះ គឺបុគ្គលមិនគប្បីបែងចែក ឲ្យផ្សេងគ្នាថា : ធម្មជាតិនេះ ជាសញ្ញា, ធម្មជាតិនេះ ជាវិញ្ញាណ, ធម្មជាតិនេះ ជាបញ្ញា ព្រោះភាវៈនៃប្រាជ្ញានោះ គឺបុគ្គលមិនគប្បីបែងចែក ដោយធម៌ទាំងនោះ, សញ្ញា និង វិញ្ញាណទាំងឡាយ មាន ក្នុងចិត្តុប្បាទណា, បញ្ញា មិនមាន ដោយចំណែក ១ ក្នុងចិត្តុប្បាទនោះ, សញ្ញា មាន ក្នុងកាលណា បញ្ញា មានក្នុងកាលនោះ ។ ព្រោះហេតុនោះ ព្រះនាគសេនដ៏មានអាយុ ពោលហើយថា: ថ្វាយព្រះពរ មហារាជ! អំពើដែលបុគ្គល

ធ្វើបានដោយកម្រ គឺព្រះមានជោគ ទ្រង់បានធ្វើហើយ ។

(ព្រះរាជាទ្រង់ព្រះនាមមាលិន្ទ ទូលសួរថា): បពិត្រព្រះនាគសេន ដ៏ចំរើន ចុះអំពើដែលបុគ្គលធ្វើបានដោយកម្រ ដូចម្ដេច គឺព្រះមានព្រះភាគទ្រង់ធ្វើហើយ? ។ (ព្រះនាគសេន ទ្រង់ពោលថា) : ថ្វាយព្រះពរ មហារាជ អំពើដែលបុគ្គលធ្វើបានដោយកម្រ គឺព្រះមានព្រះភាគ ទ្រង់ធ្វើហើយ, គឺការស្ទង់ណា នូវធម៌ទាំងឡាយជារបស់មិនមានរូប គឺចិត្ត និង ចេតសិកនេះ កាលប្រព្រឹត្តទៅក្នុងអារម្មណ៍តែមួយ ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយថា : “សភាវៈនេះ ឈ្មោះថា ផស្សៈ, ធម្មជាតិនេះ ឈ្មោះថា វេទនា, ធម្មជាតិនេះ ឈ្មោះថា សញ្ញា, ធម្មជាតិនេះ ឈ្មោះថា ចេតនា, ធម្មជាតនេះ ឈ្មោះថា ចិត្ត” ដូច្នេះ ។

**អ្វីជាលក្ខណៈ, កិច្ច, ផល និង ហេតុ របស់បញ្ញា)**

(២៦៦) ក៏សេចក្ដីវិនិច្ឆ័យ ក្នុងបញ្ហាកម្មនេះ ថា : “កានស្សា លក្ខណរសប្បច្ចុប្បដ្ឋានបទដ្ឋានានិ” មានន័យ ថា : “អ្វីជាលក្ខណៈ, ជាកិច្ច, ជាបច្ចុប្បដ្ឋាន, និង ជាបទដ្ឋាន របស់បញ្ញានោះ” បណ្ឌិតគប្បីជ្រាបដូចតទៅនេះ: បញ្ញា មានការចាក់ធ្លុះ ចំពោះនូវសភាវៈនៃធម៌ ជាលក្ខណៈ មានការកំចាត់បង់នូវងងឹត គឺមោហៈដែលជាគ្រឿងបិទបាំងនូវសភាវៈ នៃធម៌ទាំងឡាយ ជាកិច្ច មានការមិនវង្វេង ជាផល ។ ចំណែកខាងសមាធិ ជាហេតុនៃបញ្ញានោះ ព្រោះព្រះពុទ្ធដីកា មានជាអាទិ៍ថា : (ព្រះយោគី) មានចិត្តតំកល់មាំហើយ ដឹង គឺថា ឃើញត្រង់តាមសេចក្ដីពិត ។

**(បញ្ញា មានប៉ុន្មានយ៉ាង)**

ត្រង់បញ្ហាកម្មថា “បញ្ញា មានប៉ុន្មានយ៉ាង” មានវិសជ្ជនាថា បញ្ញា



មានតែ ១ ប៉ុណ្ណោះ ដោយការចាក់ធ្លុះនូវសភាវធម៌ ជាលក្ខណៈ ។

បញ្ញា មាន ២ ប្រការ ដោយអំណាច នៃលោកិយប្បញ្ញា និង លោកុត្តរប្បញ្ញា, បញ្ញា មានពីរប្រការដូចគ្នា ដោយអំណាចនៃហេតុ មានបញ្ញាដែលប្រព្រឹត្តទៅមួយអន្លើដោយអាសវៈ និង បញ្ញាដែលមិនប្រព្រឹត្តទៅមួយអន្លើដោយអាសវៈ ជាដើមផង ដោយអំណាចនៃបញ្ញាសំរាប់កំណត់ នូវនាម និង រូបផង ដោយអំណាចនៃសោមនស្សប្បញ្ញា និង ឧបេក្ខាសហគតប្បញ្ញាផង ដោយអំណាចនៃភូមិ គឺទស្សនៈ និង ភាវនាផង ។

បញ្ញា មាន ៣ ប្រការ គឺ ដោយអំណាច នៃចិន្តាមយបញ្ញា និង សុតមយបញ្ញា និង ភាវនាមយបញ្ញា, បញ្ញា មាន ៣ ប្រការដូចគ្នា គឺ ដោយអំណាច នៃបរិត្តារម្មណ៍ និង មហគ្គតារម្មណ៍ និង អប្បមាណារម្មណ៍ផង ដោយអំណាចនៃបញ្ញាឆ្លៀវឆ្លាស ក្នុងហេតុមិនមានឧបាយ និង ឧបាយផង ដោយអំណាចនៃបញ្ញា មានបញ្ញាប្រកាន់ស្អិត នូវខន្ធរបស់ខ្លួនជាដើមផង ។

បញ្ញា មាន ៤ ប្រការ ដោយអំណាចញាណ ក្នុងសច្ចទាំងឡាយ ៤ ផង ដោយអំណាច នៃបដិសម្ភិទា ៤ ផង ក្នុងចំណែកនៃបញ្ញាទាំងនោះ បញ្ញាដែលមានប្រការមួយ មានសេចក្ដីរាក់ ឬ ផ្សារហើយប៉ុណ្ណោះ ។

(២៦៧) សេចក្ដីវិនិច្ឆ័យ ក្នុងចំណែកមាន ២ ប្រការ បណ្ឌិតគប្បីជ្រាបដូចតទៅ ។ បញ្ញា ដែលប្រកបព្រមហើយ ដោយលោកិយមគ្គ ឈ្មោះថា លោកិយប្បញ្ញា, បញ្ញា ដែលប្រកបព្រមហើយ ដោយលោកុត្តរមគ្គ ឈ្មោះថា លោកុត្តរប្បញ្ញា ព្រោះហេតុនោះ បញ្ញា មាន

*ពីរប្រការ ដោយអំណាចនៃលោកិយប្បញ្ញា និង លោកុត្តរប្បញ្ញា យ៉ាងនេះឯង ។ សេចក្តីវិនិច្ឆ័យក្នុងប្រមាណពីរ នៃបញ្ញាទីពីរ បណ្ឌិតគប្បីជ្រាបដូចតទៅ ។ បញ្ញា ដែលជាអារម្មណ៍ នៃអាសវៈទាំងឡាយ ហៅថា បញ្ញាប្រព្រឹត្តទៅ មួយអន្លើដោយអាសវៈ, បញ្ញា ដែលមិនមែនជាអារម្មណ៍នៃអាសវៈទាំងឡាយនោះ ហៅថា បញ្ញាមិនមានអាសវៈ ។ បើពោលតាមសេចក្តី បញ្ញានេះ ជាលោកិយ និង ជាលោកុត្តរនោះឯង។ បញ្ញាដ៏សម្បយុត្តហើយដោយអាសវៈ ឈ្មោះថា បញ្ញាប្រព្រឹត្តទៅមួយអន្លើដោយអាសវៈ, បញ្ញា ដែលប្រាសចាកអាសវៈ ឈ្មោះថា បញ្ញាមិនមានអាសវៈ ព្រោះហេតុដូច្នោះ ន័យក្នុងបទទាំងឡាយ មានបទ (ដែលយើងពោលរួចមកហើយ) ជាដើម ដូចជាន័យនេះដែរ ។ បញ្ញាមានពីរប្រការ ដោយអំណាចនៃបញ្ញា ដែលប្រព្រឹត្តទៅមួយអន្លើដោយអាសវៈ និង មិនមានអាសវៈជាដើម យ៉ាងនេះឯង ។*

*សេចក្តីវិនិច្ឆ័យ ក្នុងប្រមាណពីរនៃបញ្ញាទីបី (បណ្ឌិតគប្បីជ្រាបដូចតទៅ) ។ បញ្ញា ក្នុងការកំណត់នូវអរូបក្ខន្ធទាំងឡាយ ៤ នៃព្រះយោគី អ្នកមានបំណង ដើម្បីប្រារព្ធនូវវិបស្សនា, បញ្ញានេះ ឈ្មោះថា នាមវវត្ថាបនប្បញ្ញា, បញ្ញា ឯណា ក្នុងការកំណត់នូវរូបក្ខន្ធ, បញ្ញានោះ ឈ្មោះថា រូបវវត្ថាបនប្បញ្ញា ព្រោះហេតុនោះ បញ្ញា មានពីរប្រការ ដោយអំណាចនៃការកំណត់នូវនាម និង រូប យ៉ាងនេះឯង ។*

*សេចក្តីវិនិច្ឆ័យ ក្នុងប្រមាណពីរ នៃបញ្ញាទីបួន (គឺបណ្ឌិតគប្បីជ្រាប ដូចតទៅ) ។ បញ្ញា ប្រព្រឹត្តទៅមួយអន្លើដោយសោមនស្ស ក្នុងកាមាវចរកុសលចិត្តទាំងឡាយពីរផង ក្នុងមគ្គចិត្តទាំងឡាយ ១៦ ប្រកបដោយឈានមានប្រមាណ ៤ តាមបញ្ចកន័យផង បញ្ញា ប្រព្រឹត្ត*



*ទៅមួយអន្លើដោយឧបេក្ខា ក្នុងកាមាវចរកុសលចិត្តទាំងឡាយពីរផង ក្នុងមគ្គចិត្តទាំងឡាយ ៤ ប្រកបដោយឈាន ទី ៥ ព្រោះហេតុនោះ (បញ្ញានោះ) មានពីរប្រការ ដោយអំណាចសោមនស្សសហគត និង ឧបេក្ខាសហគតបញ្ញា យ៉ាងដូច្នេះឯង ។*

*សេចក្តីវិនិច្ឆ័យ ក្នុងប្រមាណ ២ នៃបញ្ញា ទី ៥ បណ្ឌិត គប្បីជ្រាបដូចតទៅ : បញ្ញា សម្រាប់ដឹងនូវមគ្គទីមួយ ហៅថា ទស្សនភូមិ, បញ្ញា សំរាប់ដឹងនូវប្រជុំបីនៃមគ្គដ៏សេស ហៅថា ភាវនាភូមិ, ព្រោះហេតុនោះ បញ្ញា មាន ២ ប្រការ ដោយអំណាចនៃទស្សនភូមិ និង ភាវនាភូមិ យ៉ាងនេះឯង ។*

(បញ្ញា ៣ យ៉ាង)

*(២៦៨) សេចក្តីវិនិច្ឆ័យ ក្នុងបណ្តាបញ្ញា មានប្រមាណបីទាំងឡាយ បញ្ញា មានប្រមាណបីទីមួយ (បណ្ឌិតគប្បីជ្រាបដូចតទៅ) ។ បញ្ញា ដែលបុគ្គលបានចំពោះហើយ ព្រោះមិនស្តាប់ (អំពីសំណាក់) បុគ្គលដទៃ ឈ្មោះថា ចិន្តាមយបញ្ញា ព្រោះភាពនៃបញ្ញា ដែលខ្លួនសំរេចហើយ ដោយអំណាចនៃការគិតរបស់ខ្លួន, បញ្ញា ដែលខ្លួនបានចំពោះហើយ ព្រោះស្តាប់អំពីបុគ្គលដទៃ ឈ្មោះថា សុតមយបញ្ញា ព្រោះភាវៈ នៃបញ្ញាសំរេចហើយ ដោយអំណាចនៃការស្តាប់, បញ្ញា ដែលសំរេចហើយតាមតែបាន ដោយអំណាចនៃភាវនា រហូតដល់អប្បនា ឈ្មោះថា ភាវនាមយបញ្ញា ។ សមដូចជាព្រះពុទ្ធដីកានេះ ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយថា : បណ្តាបញ្ញាទាំងឡាយនោះ ចិន្តាមយបញ្ញា តើដូចម្តេច ? បុគ្គលមិនបានឮ ពីបុគ្គលដទៃ រមែងបានចំពោះ នូវកម្មស្សកតាញាណ ឬ សច្ចានុលោមិកញាណ (គឺ*

វិបស្សនាញាណដែលប្រព្រឹត្តទៅដោយន័យ)ថា រូបមិនទៀង ដូច្នេះក្តី ថា វេទនា, សញ្ញា, សង្ខារ, វិញ្ញាណ មិនទៀង ដូច្នេះក្តី ឬ នូវខន្តី នូវទិដ្ឋិ នូវសេចក្តីគាប់ចិត្ត នូវកិរិយាដឹង នូវការសម្លឹង នូវការអត់ធន់ដែលគួរដល់កិរិយាសម្លឹង នូវធម៌មានសភាព ដែលជាអនុលោមិកៈបែបនេះឯណា ក្នុងទីជាទីកើតនៃការងារទាំងឡាយ ដែលប្រាសចាកយោគៈក្តី ក្នុងទីជាទីកើតនៃសិប្បៈទាំងឡាយ ដែលប្រាសចាកយោគៈក្តី ក្នុងទី(ជាទីកើត)នៃវិជ្ជាទាំងឡាយដែលប្រាសចាកយោគៈក្តី, បញ្ញានេះ គឺព្រះមានព្រះភាគត្រាស់ថា ចិន្តាមយបញ្ញា ។ល។ ឮ រមែងបានចំពោះ, បញ្ញានេះ ព្រះមានព្រះភាគទ្រង់ត្រាស់ថា សុតមយបញ្ញា, បញ្ញាទាំងអស់ហ្នឹងឯង របស់ព្រះយោគី អ្នកដែលចូលកាន់សមាបត្តិ ឈ្មោះថា ភាវនាមយបញ្ញា ។ បញ្ញា មានបីយ៉ាង ដោយអំណាចចិន្តាមយបញ្ញា, សុតមយបញ្ញា និង ភាវនាមយបញ្ញា យ៉ាងនេះឯង ។ សេចក្តីវិនិច្ឆ័យក្នុងប្រមាណបី នៃបញ្ញា ទីពីរ (គឺបណ្ឌិតគប្បីជ្រាប ដូចតទៅនេះ) ។ បញ្ញា ដែលប្រព្រឹត្តទៅ ព្រោះប្រារព្ធនូវធម៌ទាំងឡាយ ជាកាមាវចរៈ ឈ្មោះថា បរិត្តារម្មណបញ្ញា, បញ្ញា ដែលប្រព្រឹត្តទៅ ព្រោះប្រារព្ធ (នូវធម៌ទាំងឡាយ) ជារូបាវចរៈ និង អរូបាវចរៈ ឈ្មោះថា មហគ្គតារម្មណបញ្ញា, បញ្ញានោះ ឈ្មោះថា លោកិយវិបស្សនា, បញ្ញា ដែលប្រព្រឹត្តទៅ ព្រោះប្រារព្ធ នូវព្រះនិព្វាន ឈ្មោះថា អប្បមាណារម្មណបញ្ញា, បញ្ញានោះ ឈ្មោះថា លោកុត្តរវិបស្សនា ព្រោះហេតុនោះ បញ្ញា មាន ៣ ប្រការ ដោយអំណាចបរិត្តារម្មណបញ្ញា មហគ្គតារម្មណបញ្ញា និង អប្បមាណារម្មណបញ្ញា យ៉ាងដូច្នេះឯង ។

សេចក្តីវិនិច្ឆ័យ ក្នុងប្រមាណ ៣ នៃបញ្ញា ទី៣ មានដូចតទៅនេះ ។



សេចក្តីចំរើន ឈ្មោះថា អាយៈ ។ សេចក្តីចំរើននោះ មាន ២ យ៉ាង គឺ : កិរិយាមិនសាបសូន្យចាកប្រយោជន៍ ១ កិរិយាញុំាងប្រយោជន៍ឲ្យកើត ១ ។ ភាពនៃការឈ្លាសវៃ ក្នុងសេចក្តីចំរើននោះ ឈ្មោះថា អាយកោសល្ល ។ សមដូចជាព្រះមានព្រះភាគទ្រង់ត្រាស់ ថា ។

បណ្តាកោសល្លទាំងឡាយនោះ អាយកោសល្ល តើដូចម្តេច? កាលតថាគត ធ្វើទុកក្នុងចិត្តនូវធម៌ទាំងឡាយនេះ, ធម៌ទាំងឡាយ ជាអកុសល មិនទាន់កើតឡើងផង រមែងកើតឡើងមិនបាន, ធម៌ទាំងឡាយជាអកុសល កើតឡើងហើយក្តី រមែងសាបសូន្យទៅ, ម្យ៉ាងវិញទៀត កាលតថាគតធ្វើទុកក្នុងចិត្តនូវធម៌ទាំងឡាយនេះ, ធម៌ទាំងឡាយដែលជាកុសល ដែលមិនទាន់កើតឡើងហើយផង រមែងកើតឡើងបាន, ធម៌ទាំងឡាយ ជាកុសលដែលកើតឡើងហើយផង រមែងប្រព្រឹត្តទៅដើម្បីភាវៈនៃសេចក្តីចំរើន ដ៏ក្រៃលែង ដើម្បីការពេញលេញ នៃភាវនាព្រោះហេតុដូច្នោះ បណ្តាធម៌ទាំងឡាយនោះ បញ្ញា ការដឹងច្បាស់ណា ។ល។ ការមិនវង្វេង ការសន្សំធម៌ ការយល់ឃើញត្រូវណា, នេះ តថាគត ពោលថា អាយកោសល្ល ។ ក៏ការមិនចំរើន ឈ្មោះថា អបាយៈ ។ ការមិនចំរើននោះឯង មាន ២ យ៉ាង គឺ ការសាបសូន្យចាកប្រយោជន៍ ១, ការកើតឡើងអំពីសេចក្តីវិនាស ១ ។ ភាពនៃការឈ្លាសវៃ ក្នុងបទថា អបាយៈ ទាំង ២ យ៉ាងនោះ ឈ្មោះថា អបាយកោសល្ល ។ សមដូចជាព្រះពុទ្ធដីកា ដែលព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ថា ។ បណ្តាកោសល្លទាំងឡាយនោះ អបាយ-កោសល្ល តើដូចម្តេច? ព្រះអង្គទ្រង់មានព្រះពុទ្ធដីកា ថា : កាលតថាគត កំពុងធ្វើទុកក្នុងចិត្ត នូវធម៌ទាំងឡាយនេះ ធម៌ទាំងឡាយ ជា

កុសលមិនទាន់កើតឡើងហើយ រមែងមិនកើតឡើងផង ដូច្នេះជាដើម ។ ក៏ភាពនៃការឈ្លាសវៃ ប្រព្រឹត្តទៅ ក្នុងខណៈនោះ គឺកើតឡើងតាមឋានៈ គឺក្នុងអបាយភូមិ ក្នុងហេតុនៃការកើតឡើងទាំងឡាយនៃធម៌ទាំងឡាយនោះៗ ទាំងពួង ឈ្មោះថា ឧបាយកោសល្លំ ។ សមដូចជាព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ ថា ។ បញ្ញា ជាឧបាយក្នុងការលះអកុសលធម៌ និង ការចំរើនកុសលធម៌នោះទាំងអស់ហ្នឹង ហៅថា ឧបាយកោសល្លំ ។ បញ្ញា មាន ៣ ប្រការ ដោយអំណាចនៃអាយកោសល្យ, អបាយកោសល្យ និង ឧបាយកោសល្យ យ៉ាងនេះ ។

សេចក្តីវិនិច្ឆ័យ ក្នុងប្រមាណបី នៃបញ្ញាទីបួន (បណ្ឌិតគោងជ្រាប ដូចតទៅ) ។ វិបស្សនាបញ្ញា ដែលបុគ្គលប្រារព្ធប្រកាន់យកនូវខន្ធទាំងឡាយរបស់ខ្លួន ឈ្មោះថា ការប្រកាន់មាំនូវខន្ធ របស់ខ្លួន, បញ្ញា ដែលបុគ្គលប្រារព្ធប្រកាន់យក នូវហេតុខាងក្រៅ ដែលមិនជាប់ដោយឥន្ទ្រិយ ឬ ខន្ធ របស់បុគ្គលដទៃ ឈ្មោះថា ការប្រកាន់មាំនូវខន្ធខាងក្រៅ, បញ្ញា ដែលបុគ្គលប្រារព្ធប្រកាន់យកនូវខន្ធទាំងពីរ ឈ្មោះថា ការប្រកាន់មាំទាំងខាងក្នុង ទាំងខាងក្រៅ, ព្រោះហេតុនោះ បញ្ញា មានបីយ៉ាង ដោយអំណាចនៃហេតុមានការប្រកាន់មាំ នូវខន្ធខាងក្រៅជាដើម យ៉ាងនេះឯង ។

**(បញ្ញា ៤ យ៉ាង)**

(២៦៩) សេចក្តីវិនិច្ឆ័យ ក្នុងបណ្តាប្រមាណ ៤ ទាំងឡាយ ប្រមាណ ៤ ទី ១ បណ្ឌិតគប្បីជ្រាប ដូចតទៅនេះ ។ ញាណ ដែលបុគ្គលឲ្យប្រព្រឹត្តទៅហើយ ព្រោះប្រារព្ធនូវទុក្ខសច្ច ឈ្មោះថា ទុក្ខេ ញាណំ, ញាណ ដែលបុគ្គលឲ្យប្រព្រឹត្តទៅហើយ ព្រោះប្រារព្ធនូវ



ហេតុជាទីកើត នៃសេចក្តីទុក្ខ ឈ្មោះថា ទុក្ខសមុទយេ ញាណំ, ញាណ ដែលបុគ្គលឲ្យប្រព្រឹត្តទៅហើយ ព្រោះប្រារពនូវហេតុជាគ្រឿងរំលត់សេចក្តីទុក្ខ ឈ្មោះថា ទុក្ខនិរោធេ ញាណំ, ញាណ ដែលបុគ្គលឲ្យប្រព្រឹត្តទៅហើយ ព្រោះប្រារព្ធនូវបដិបទា ដែលជាគ្រឿងដល់នូវហេតុជាគ្រឿងរំលត់នូវសេចក្តីទុក្ខ ឈ្មោះថា ទុក្ខនិរោធគាមិនីយា បដិបទាយ ញាណំ, ព្រោះហេតុនោះ បញ្ញា មាន ៤ ប្រការ ដោយអំណាចនៃញាណ ក្នុងសច្ចៈទាំងឡាយ ៤ យ៉ាងដូច្នេះឯង ។

សេចក្តីវិនិច្ឆ័យ ក្នុងប្រមាណ ៤ នៃញាណទីពីរ ។ ញាណទាំងឡាយ ៤ ដល់ហើយនូវការផ្សេងគ្នា ក្នុងបដិសម្ភិទាទាំងឡាយ មានអត្ថប្បដិសម្ភិទាជាដើម ឈ្មោះថា បដិសម្ភិទា ៤ ។ សមដូចជាព្រះពុទ្ធវចនៈ ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់សំដែងហើយ ថាៈ ការដឹងក្នុងអត្ថ ឈ្មោះថា អត្ថប្បដិសម្ភិទា, ការដឹង ក្នុងធម៌ ឈ្មោះថា ធម្មប្បដិសម្ភិទា, ការដឹងនូវភាសាជាគ្រឿងយល់នូវអត្ថ និង ធម៌ទាំងឡាយ ឈ្មោះថា និរុត្តិប្បដិសម្ភិទា, ការដឹង ក្នុងញាណទាំងឡាយ ឈ្មោះថា បដិភាណប្បដិសម្ភិទា ។

**(អត្ថប្បដិសម្ភិទា)**

បណ្តាបទទាំងឡាយនោះ បទថា "អត្ថោ" សេចក្តីថា (បើពោលដោយសង្ខេប ពាក្យនេះ ជាឈ្មោះនៃហេតុ និង ផល ។ សេចក្តីថាហេតុ និង ផល គឺបុគ្គលឲ្យប្រព្រឹត្តទៅ គឺឲ្យត្រាស់ដឹង ឲ្យសំរេចតាមទំនងរបស់ហេតុ ព្រោះហេតុណា, ព្រោះហេតុនោះ ហេតុ និង ផលនោះ លោកហៅថា អត្ថ ។ បើពោលតាមប្រភេទ ធម៌ទាំងឡាយ ៥ នេះ គឺ អ្វីមួយដែលកើតឡើង តាមបច្ច័យ ១, ព្រះនិព្វាន ១, អត្ថ នៃ

ភាសិត ១, វិបាក ១, កិរិយា ១, គឺបណ្ឌិត គប្បីជ្រាបថា ជាអត្ថ ។ កាលបើព្រះយោគី ពិចារណាឃើញច្បាស់នូវសេចក្តីនោះ, ញាណ ដល់ហើយនូវការជំនាញ ក្នុងអត្ថនោះ ឈ្មោះថា អត្ថប្បដិសម្ភិទា ។

### ធម្មប្បដិសម្ភិទា

(បើពោល) ដោយសង្ខេប ពាក្យនេះ ថា ធម៌ ក៏មាន ជាឈ្មោះ របស់បច្ច័យ ។ មែនពិត បច្ច័យ រមែងគាំទ្រ ឬ គឺ ញ៉ាំងផលនោះៗ ឲ្យប្រព្រឹត្តទៅ ឬក៏ ឲ្យដើម្បីញ៉ាំងផលនោះឲ្យដល់ព្រម ព្រោះហេតុណា ព្រោះហេតុនោះ បច្ច័យនេះ លោកឲ្យឈ្មោះថា ធម៌ ។ តែបើពោលតាមប្រភេទ ធម៌ទាំងឡាយ ៥ នេះ គឺ ហេតុជាគ្រឿងញ៉ាំងផលឲ្យសំរេចណាមួយ, អរិយមគ្គ, ភាសិត, កុសល, អកុសល បណ្ឌិតគប្បីជ្រាបថា “ជាធម៌” ។ កាលបើព្រះយោគី ពិចារណាឃើញច្បាស់នូវធម៌នោះ, ញាណ ដល់ហើយនូវការជំនាញ ក្នុងធម៌នោះ ឈ្មោះថា ធម្មប្បដិសម្ភិទា ។ សេចក្តីអធិប្បាយថា : អត្ថនេះឯង ក្នុងអភិធម្ម គឺព្រះមានព្រះភាគទ្រង់សំដែងបែងចែក តាមន័យមានជាអាទិ៍ថា: ការដឹងក្នុងសេចក្តីទុក្ខ ឈ្មោះថា អត្ថប្បដិសម្ភិទា, ការដឹង ក្នុងហេតុជាទីកើតនូវសេចក្តីទុក្ខ ឈ្មោះថា ធម្មប្បដិសម្ភិទា, ការដឹង ក្នុងហេតុជាគ្រឿងរំលត់នូវសេចក្តីទុក្ខ ឈ្មោះថា អត្ថប្បដិសម្ភិទា, ការដឹង ក្នុងបដិបទា ជាហេតុដល់នូវធម៌ជាគ្រឿងរំលត់នូវសេចក្តីទុក្ខ ឈ្មោះថា ធម្មប្បដិសម្ភិទា, ការដឹង ក្នុងហេតុ ឈ្មោះថា ធម្មប្បដិសម្ភិទា, ការដឹង ក្នុងហេតុ និង ផល ឈ្មោះថា អត្ថប្បដិសម្ភិទា, ធម៌ទាំងឡាយណា កើតហើយ គឺថា កើតហើយ កើតព្រមហើយ, កើតហើយ កើតចំពោះហើយ កើតប្រាកដហើយ, ការដឹង ក្នុងធម៌ទាំងឡាយ



នេះ ឈ្មោះថា អត្ថប្បដិសម្ភិទា, ធម៌ទាំងឡាយនោះ កើតហើយ គឺថា កើតហើយ កើតព្រមហើយ កើតហើយ កើតចំពោះហើយ កើតប្រាកដហើយ អំពីធម៌ ឯណា, ការដឹង ក្នុងធម៌ទាំងឡាយនោះ ឈ្មោះថា ធម្មប្បដិសម្ភិទា, ការដឹង ក្នុងជរា និង មរណៈ ឈ្មោះថា អត្ថប្បដិសម្ភិទា, ការដឹង ក្នុងហេតុជាទីកើត នៃជរា និង មរណៈ ឈ្មោះថា ធម្មប្បដិសម្ភទា ។លេ។ ការដឹងក្នុងធម៌ជាគ្រឿងរំលត់នូវសង្ខារ ឈ្មោះថា អត្ថប្បដិសម្ភិទា, ការដឹង ក្នុងបដិបទាជាគ្រឿងដល់នូវធម៌ជាទីរំលត់នូវសង្ខារ ឈ្មោះថា ធម្មប្បដិសម្ភិទា, ភិក្ខុ ក្នុងសាសនានេះ ចេះនូវធម៌ គឺ សុត្ត, គេយ្យ, ។លេ។ វេទល្ល, ធម៌នេះគឺលោកហៅថា ធម្មប្បដិសម្ភិទា, ភិក្ខុនោះ ចេះនូវអត្ថនៃភាសិតនោះៗ ឯង ថា: នេះជាអត្ថនៃភាសិតនេះ, (ភាពនៃការចេះនូវអត្ថ) នេះ គឺលោកហៅថា អត្ថប្បដិសម្ភិទា, ធម៌ទាំងឡាយណាខ្លះ ជាកុសល, ចិត្តជាកាមាវចរកុសល កើតក្នុងសម័យណា ។លេ។ ធម៌ទាំងឡាយនេះ ជាកុសល, ការដឹង ក្នុងធម៌ទាំងឡាយនេះ ឈ្មោះថា ធម្មប្បដិសម្ភិទា, ការដឹង ក្នុងវិបាក នៃធម៌ទាំងឡាយនោះ ឈ្មោះថា អត្ថប្បដិសម្ភិទា ។

### (និរុត្តិបដិសម្ភិទា)

ពាក្យថា “ញាណេសុ ញាណំ” អធិប្បាយថា : វាចាដែលត្រឹមត្រូវ គឺវាចាដែលមិនល្អៀងឃ្លៀងឃ្លាតឯណា ក្នុងអត្ថ និង ធម៌នោះ, ការដឹង ក្នុងការថ្លែងវាចានោះ គឺក្នុងការពោល ក្នុងការបញ្ចេញវាចានោះ បានដល់ ការដឹង ដល់នូវការស្ទាត់ជំនាញ ក្នុងភាសាជាដើមរបស់សត្វទាំងឡាយទាំងពួង គឺ ភាសាមគធៈ ដែលជាភាសាពិតត្រឹមត្រូវ ដែលបានឈ្មោះថា ធម្មនិរុត្តិនោះ ដោយន័យយ៉ាងនេះ ថា :

គ្រាន់តែបានឮនូវវាចា ដែលគេនិយាយ ដែលគេពោល ដែលគេចរចា ហើយនោះ ក៏ដឹងបានថា នេះជាភាសាត្រឹមត្រូវ នេះមិនមែនជាភាសាត្រឹមត្រូវ ដូច្នេះ ឈ្មោះថា និរុត្តិបដិសម្ភិទា ។ មែនពិត បុគ្គលដល់ហើយ នូវនិរុត្តិបដិសម្ភិទា គ្រាន់តែឮនូវពាក្យ មានពាក្យថា “ផស្សោ វេទនា” យ៉ាងនេះជាដើម ក៏ដឹងបាន ថា : ភាសានេះ ជាសភាវនិរុត្តិ (គ្រាន់តែឮ) នូវពាក្យមានពាក្យថា “ផស្សា វេទនោ” យ៉ាងនេះជាដើម (ក៏ដឹងបាន) ថា : ភាសានេះ មិនមែនជាសភាវនិរុត្តិ ទេ ។

(បដិភាណប្បដិសម្ភិទា)

ត្រង់ពីរបទថា “ញាណេសុ ញាណំ” សេចក្ដីថា ញាណ មានញាណជាអារម្មណ៍ របស់ព្រះយោគី កាលពិចារណាធ្វើនូវញាណ ឲ្យជាអារម្មណ៍ ក្នុងញាណទាំងឡាយទាំងពួង, ម្យ៉ាងវិញទៀត ដោយពិស្ដារ ញាណ ឈ្មោះថា បដិភាណប្បដិសម្ភិទា ដោយអំណាចនៃអារម្មណ៍ និង កិច្ចរបស់ខ្លួនជាដើម ក្នុងញាណដែលពោលហើយនោះ ។

(ភូមិបដិសម្ភិទា ២ យ៉ាង)

ម្យ៉ាងទៀត បដិសម្ភិទាទាំងឡាយ ៤ នេះ ដល់នូវការបែងចែក ក្នុងភូមិទាំងឡាយពីរ គឺ សេខភូមិ ១ អសេខភូមិ ១ ។ បណ្ដាភូមិទាំងពីរនោះ បដិសម្ភិទាទាំងឡាយ របស់ព្រះអគ្គសាវកទាំងឡាយ និង មហាសាវកទាំងឡាយ ដល់ហើយនូវសេចក្ដីជំនាញ ក្នុងអសេខភូមិ បដិសម្ភិទា របស់ព្រះសេខអរិយសាវកទាំងឡាយ មានព្រះអានន្ទ, ចិត្តគហបតី, ធម្មិកឧបាសក, ឧបាលិគហបតី និង ឧបាសិកា ឈ្មោះខុជ្ជុត្តរា ជាដើម ដល់ហើយនូវការជំនាញ ក្នុងសេខភូមិ ។



(បដិសម្ភិទា ភ្លឺច្បាស់ដោយអាការៈ ៥ យ៉ាង)

ម្យ៉ាងវិញទៀត បដិសម្ភិទាទាំងឡាយនេះ សូម្បីកាលដល់នូវការផ្សេងគ្នា ក្នុងភូមិទាំងឡាយពីរយ៉ាងនេះ រមែងភ្លឺច្បាស់ដោយអាការៈទាំងឡាយ ៥ នេះ ដូច្នេះ គឺ ការត្រាស់ដឹង ១, ព្រះបរិយត្តិ ១, ការស្ដាប់ ១, ការសាកសួរ ១ និង ការប្រកបក្នុងខាងដើម ១ ។ បណ្ដាអាការៈទាំងឡាយ ៥ យ៉ាងនោះ ការដល់នូវព្រះអរហត្ត ឈ្មោះថា អធិគមៈ ។ ការរៀនយកនូវពុទ្ធវចនៈ ឈ្មោះថា ព្រះបរិយត្តិ ។ ការស្ដាប់នូវព្រះសទ្ធម្ម ធ្វើឲ្យចុចដល់ឆ្អឹង ដោយគោរព ឈ្មោះថា ការស្ដាប់ ។ កថាសំរាប់វិនិច្ឆ័យបទដ៏កំបាំង និង បទនៃសេចក្ដីអធិប្បាយ ក្នុងបាលី និង អដ្ឋកថាជាដើមទាំងឡាយ ឈ្មោះថា ការសាកសួរ ។ ការប្រកបរឿយៗ នូវវិបស្សនា រហូតដល់ថ្នាក់ជិតអនុលោមញាណ និង គោត្រភូញាណ ដោយភាវៈ នៃព្រះយោគី អ្នកមានកិរិយាត្រាច់ទៅត្រាច់មក ក្នុងសាសនានៃព្រះពុទ្ធ ពីជំនាន់មុនទាំងឡាយ ឈ្មោះថា បុព្វយោគ ។ អាចារ្យទាំងឡាយដទៃទៀត ពោល ថា :

បច្ច័យនៃបដិសម្ភិទា (មាន៨) គឺ ការប្រកបក្នុងខាង
ដើម១ ភាពនៃបុគ្គលមានការចេះចាំពុទ្ធវចនៈច្រើន១
សំដីសំរាប់ប្រទេស ១ មគ្គ និង ផលជាទីមក ១
ការសាកសួរ ១ ការលុះ ១ ការនៅអាស្រ័យ ក្នុង
សំណាក់គ្រូ ១ ដូចគ្នា ការដល់ព្រមដោយមិត្ត ១ ។

(២៧០ បណ្ដាបច្ច័យទាំងឡាយនោះ បុព្វយោគ មានន័យគឺយើងពោលរួចមកហើយ ។ ភាពនៃការឈ្លាសវៃ ក្នុងគម្ពីរទាំងឡាយនោះៗ ផង ក្នុងកន្លែងជាទីកើត នៃសិល្បៈទាំងឡាយ ឈ្មោះថា ពាហុសច្ចៈ ។

*ភាពនៃការឆ្លៀវឆ្លាស ក្នុងភាសា ១០១ ឈ្មោះថា ទេសភាសា, តែបើពោលដោយវិសេស ភាពនៃការឈ្លាសវាងវៃ ក្នុងជនអ្នកនៅក្នុងដែនមគធៈ (ក៏ឈ្មោះថាទេសភាសាដែរ) ។ ការរៀនពុទ្ធវចនៈ ដោយហោចទៅ ត្រឹមតែភាពនៃការឧបមា របស់វគ្គ ហៅថា អធិគមៈ, ការវិនិច្ឆ័យ និង ការសាកសួរនូវអត្ថ សូម្បីនៃគាថា ១ ឈ្មោះថា សាកសួរ ។ ភាពនៃសោតាបន្នបុគ្គលក្តី ។លេ។ ភាពនៃបុគ្គលជាព្រះអរហន្តក្តី ឈ្មោះថា អធិគមៈ ។ ការនៅក្នុងសំណាក់នៃគ្រូទាំងឡាយដែលមានការស្ទាត់ជំនាញ និង ការចេះដឹងច្រើន ឈ្មោះថា គរុសន្និស្សយៈ ។ ការបានចំពោះ នូវមិត្តទាំងឡាយ មានសភាពបែបនោះឯង ឈ្មោះថា មិត្តសម្បត្តិ ដូច្នេះឯង ។ បណ្តាបច្ច័យទាំងឡាយនោះ ព្រះពុទ្ធទាំងឡាយក្តី ព្រះបច្ចេកពុទ្ធទាំងឡាយក្តី តែងបាននូវបដិសម្ភិទាទាំងឡាយ ព្រោះអាស្រ័យនូវបុព្វបយោគផង នូវអធិគមៈផង ។ សាវកទាំងឡាយ (រមែងបាន ព្រោះអាស្រ័យនូវហេតុទាំងឡាយនេះ ទាំងអស់ហ្នឹងឯង) ។ ចំណែកខាងឈ្មោះថា ការប្រកបនូវការចំរើន នូវកម្មដ្ឋាន ផ្សេងដោយឡែក ដើម្បីដល់នូវបដិសម្ភិទា ពុំមានឡើយ ។ ប៉ុន្តែ គុណជាត មាន ក្នុងទីបំផុត នៃវិមោក្ខ ព្រោះផលនៃសេក្ខៈ របស់បុគ្គលទាំងឡាយ, គុណជាត មាន ក្នុងទីបំផុត នៃវិមោក្ខ ព្រោះផលនៃអសេក្ខៈ របស់អសេក្ខបុគ្គលទាំងឡាយ ឈ្មោះថា ជាការដល់នូវបដិសម្ភិទា ។ មែនពិត បដិសម្ភិទាទាំងឡាយ រមែងសំរេច ដោយអរិយផលហ្នឹងឯង ដល់ព្រះអរិយៈទាំងឡាយ ដូចជាកម្លាំងទាំង ១០ (កាលសំរេច) ដល់ព្រះតថាគតទាំងឡាយ ដូច្នោះឯង ។*

*ពាក្យថា "បញ្ញា មាន ៤ ប្រការ" ដោយអំណាចបដិសម្ភិទា ៤ គឺលោកបានពោលហើយ ព្រោះសំដៅយកនូវបដិសម្ភិទាទាំងឡាយនេះ ។*



(បញ្ញា ត្រូវចំរើនដូចម្តេច)

*(២៧១) ក៏សេចក្តីវិនិច្ឆ័យ ក្នុងបញ្ហាកម្មនេះថា "កថំ ភាវេតព្វា" (គឺបណ្ឌិតគប្បីជ្រាបដូចតទៅ) ។ ធម៌ទាំងឡាយ មានខន្ធ, អាយតនៈ, ធាតុ, ឥន្ទ្រិយ, សច្ច និង បដិច្ចសមុប្បាទ ជាដើមជាប្រភេទ ឈ្មោះថា ជាភូមិរបស់បញ្ញានេះ, វិសុទ្ធិទាំងឡាយ ២ នេះ គឺ សីលវិសុទ្ធិ ១, ចិត្តវិសុទ្ធិ ១, ឈ្មោះថា ជាមូល, វិសុទ្ធិទាំង ៥ នេះ គឺ ទិដ្ឋិវិសុទ្ធិ ១, កង្ខាវិតរណវិសុទ្ធិ ១, មគ្គាមគ្គញាណទស្សនវិសុទ្ធិ ១, បដិបទាញាណ-ទស្សនវិសុទ្ធិ ១, ញាណទស្សនវិសុទ្ធិ ១ ចាត់ជាសរីរៈ ព្រោះហេតុណា, ព្រោះហេតុនោះ បញ្ញានុ៎ះ គឺព្រះយោគី ធ្វើនូវការប្រឹង ក្នុងញាណ ដោយអំណាចនៃការរៀនយក និង ការសាកសួរ ក្នុងធម៌ទាំងឡាយនោះ ដែលជាភូមិ ញ៉ាំងវិសុទ្ធិទាំងឡាយពីរដែលជាមូល ឲ្យដល់ព្រម ញ៉ាំងវិសុទ្ធិទាំងឡាយ ៥ ដែលជាសរីរៈ ឲ្យដល់ព្រម គប្បីចំរើន ។ នេះជាសេចក្តីសង្ខេប ក្នុងបញ្ហាកម្មនេះ ។ សេចក្តីពិស្តារ មានដូចតទៅ ។*

(ភូមិនៃបញ្ញា)

*ពាក្យណា ដែលយើងពោលហើយខាងដើម ត្រង់បញ្ហាកម្ម ថា :* "ធម៌ទាំងឡាយ ផ្សេងដោយខន្ធ, អាយតនៈ, ធាតុ, ឥន្ទ្រិយ, សច្ចៈ, និង បដិច្ចសមុប្បាទ ជាភូមិ (នៃបញ្ញា)" *បណ្ឌិត គប្បីជ្រាបវិនិច្ឆ័យ ក្នុងពាក្យនុ៎ះ ដូចតទៅនេះ ។*

(ខន្ធ ៥)

*ឈ្មោះថា ខន្ធ បានដល់ខន្ធទាំង ៥ គឺ រូបក្ខន្ធ ១, វេទនាខន្ធ ១, សញ្ញាខន្ធ ១, សង្ខារក្ខន្ធ ១, វិញ្ញាណក្ខន្ធ ១ ។*

(រូបក្ខន្ធ)

បណ្ដាបញ្ចក្ខន្ធទាំងនោះ ធម្មជាត ឯណាមួយ មានការវិនាស ដោយបច្ច័យទាំងឡាយ មានត្រជាក់ជាដើម, ធម្មជាតទាំងអស់នោះ បណ្ឌិត គប្បីជ្រាបថា រូបក្ខន្ធ ព្រោះរួមចូលក្នុងទីជាមួយគ្នា ។ ពាក្យថា រូបក្ខន្ធ នោះនេះ មានតែមួយ ដោយសេចក្ដីវិនាស ជាលក្ខណៈ, មាន ពីរយ៉ាង ផ្សេងគ្នាដោយភូតរូប និង ឧបាទាយរូប ។

(ភូតរូប)

(២៧២) បណ្ដារូបទាំងពីរនោះ ភូតរូប មាន ៤ យ៉ាង គឺ បឋវីធាតុ, អាបោធាតុ, តេជោធាតុ, វាយោធាតុ ។ លក្ខណៈ, កិច្ច និង ផលទាំងឡាយ នៃធាតុទាំងឡាយនោះ គឺព្រះមានព្រះភាគ ត្រាស់ហើយ ក្នុងធាតុវវដ្ឋាន ៤ ។ តែបើពោលដោយហេតុវិញ ធាតុទាំងឡាយនោះទាំងអស់ មានប្រជុំបី នៃធាតុដ៏សេស ជាហេតុ ។

(ឧបាទាយរូប)

ឧបាទាយរូប មាន ២៤ យ៉ាង គឺ ចក្ខុ ១, សោតៈ ១, ឃានៈ ១, ជិវ្ហា១, កាយ១, រូប១, សទ្ទ១, គន្ធ១, រស១, ឥត្ថិន្ទ្រិយ១, បុរិសិន្ទ្រិយ១, ជីវិតិន្ទ្រិយ១, ហទយវត្ថុ១, កាយវិញ្ញត្តិ១, វចីវិញ្ញត្តិ១, អាកាសធាតុ១, រូបស្ស លហុតា ១, រូបស្ស មុទុតា ១, រូបស្ស កម្មញ្ញតា ១, រូបស្ស ឧបចយោ ១, រូបស្ស សន្តតិ ១, រូបស្ស ជរតា ១, រូបស្ស អនិច្ចតា ១, កវឡិង្ការាហារ ១ ។

(បសាទរូប ៥)

(២៧៣) បណ្ដាឧបាទាយរូប ២៤ នោះ ចក្ខុបសាទរូប មាន ប្រសាទនៃភូតរូប ដែលគួរដល់ការខ្ទាំងខ្ទប់នូវរូបជាលក្ខណៈ ឬថា មាន



ប្រសាទនៃភូតរូប ដែលកើតអំពីកម្ម មានភាវៈនៃខ្លួន មានបំណងដើម្បីឃើញថា មានការប្រគល់ឲ្យនូវផល ជាលក្ខណៈ, មានការទាញមកក្នុងរូបទាំងឡាយ ជាកិច្ច, មានភាវៈនៃការទ្រទ្រង់ នូវចក្ខុវិញ្ញាណ ជាផល, មានប្រសាទនៃភូតរូបដែលកើតអំពីកម្ម មានភាវៈនៃខ្លួន មានបំណងដើម្បីឃើញថា មានការប្រគល់ឲ្យនូវផល ជាហេតុ ។

សោតបសាទរូប មានប្រសាទនៃភូតរូប ដែលគួរដល់ការខ្ទាំងខ្ទប់នូវសម្លេង ជាលក្ខណៈ ឬថា មានប្រសាទ នៃភូតរូប ដែលកើតមកអំពីកម្ម មានភាវៈនៃខ្លួនមានបំណងដើម្បីនឹងស្ដាប់ ជាការប្រគល់ឲ្យនូវផល ជាលក្ខណៈ, មានការទាញមក ក្នុងសម្លេងទាំងឡាយ ជាលក្ខណៈ, មានភាវៈនៃការទ្រទ្រង់នូវសោតវិញ្ញាណ ជាផល, មានភូតរូប ដែលកើតអំពីកម្ម មានភាវៈនៃខ្លួនមានបំណងដើម្បីស្ដាប់ ជាហេតុ ។

ឃានបសាទរូប មានប្រសាទនៃភូតរូប ដែលគួរដល់ការខ្ទាំងខ្ទប់ក្លិន ជាលក្ខណៈ ឬថា មានប្រសាទនៃភូតរូប ដែលកើតអំពីកម្ម មានភាវៈនៃខ្លួនមានបំណងដើម្បីហិត ជាលក្ខណៈ, មានការទាញមក ក្នុងក្លិនទាំងឡាយជាកិច្ច មានភាវៈនៃការទ្រទ្រង់នូវឃានវិញ្ញាណជាផល, មានភូតរូបដែលកើតពីកម្ម មានភាវៈនៃខ្លួនមានបំណងដើម្បីហិត ជាហេតុ ។

ជិវ្ហាបសាទរូប មានប្រភេទនៃភូតរូប ដែលគួរដល់ការខ្ទាំងខ្ទប់នូវរស ជាលក្ខណៈ ឬថា មានប្រសាទនៃភូតរូបដែលកើតអំពីកម្ម មានភាវៈនៃខ្លួន មានបំណងដើម្បីលិទ្ធ ជាការប្រគល់នូវផល ជាលក្ខណៈ, មានការទាញមកនូវរសទាំងឡាយ ជាកិច្ច, មានភាវៈនៃការទ្រទ្រង់នូវជិវ្ហាវិញ្ញាណ ជាផល, មានភូតរូបដែលកើតអំពីកម្ម មានភាវៈនៃខ្លួនមានបំណងដើម្បីលិទ្ធ ជាការប្រគល់ឲ្យនូវផល ជាហេតុ ។

កាយបសាទរូប មានប្រសាទនៃភូតរូប ដែលគួរដល់ការខ្ទាំងខ្ទប់ នូវផោដ្ឋព្វៈ ជាលក្ខណៈ ឬថា មានប្រសាទនៃភូតរូប ដែលកើតមកអំពីកម្ម មានភាវៈនៃខ្លួនមានបំណងដើម្បីពាល់ត្រូវ ជាលក្ខណៈ, មានការទាញមក ក្នុងផោដ្ឋព្វៈទាំងឡាយ ជាកិច្ច, មានភាវៈនៃការទ្រទ្រង់ នូវកាយវិញ្ញាណ ជាផល, មានភូតរូប ដែលកើតអំពីកម្ម មានភាវៈនៃខ្លួនមានបំណងដើម្បីពាល់ត្រូវ ជាការប្រគល់ឲ្យ ជាហេតុ ។

ប៉ុន្តែអាចារ្យពួកខ្លះ ពោលថា : ចក្ខុ គឺជាប្រសាទ នៃភូតរូបទាំងឡាយ ច្រើនដោយធាតុភ្លើង, សោតៈ, ឃានៈ, ជិវ្ហា, និង កាយ នៃភូតរូបទាំងឡាយទាំងពួង ជាបសាទនៃភូតរូបទាំងឡាយ ច្រើនដោយធាតុខ្យល់, ដី, និង ទឹក ។

អាចារ្យមួយពួកទៀត ពោលថា "ចក្ខុ គឺជាប្រសាទ នៃភូតរូបទាំងឡាយដែលច្រើនដោយភ្លើង, សោតៈ, ឃានៈ, ជិវ្ហា, និង កាយ គឺជាប្រសាទនៃភូតរូបទាំងឡាយ ដែលច្រើនដោយអាកាស, ខ្យល់, ទឹក និង ដី " ។

អាចារ្យទាំងនោះ គឺគេគប្បីពោលថា : អ្នកទាំងឡាយ ចូរទាញយកព្រះសូត្រមក(បង្ហាញ) ។ ត្រូវហើយ អាចារ្យទាំងឡាយ នឹងរកព្រះសូត្រ មកសំដែងបង្ហាញពុំបាន ដោយពិត ។

ប៉ុន្តែក្នុងពាក្យ របស់កេចិអាចារ្យទាំងនុ៎ះ អាចារ្យទាំងឡាយពួកខ្លះ ពោលនូវហេតុ ថា ព្រោះភាវៈនៃធាតុទាំងឡាយ មានធាតុភ្លើងជាដើម ដែលគុណទាំងឡាយ មានរូបជាដើម គប្បីជួយអនុគ្រោះ ។

អាចារ្យទាំងឡាយនោះ គឺគេគប្បីពោលថា : ចុះនរណា ពោលយ៉ាងនេះ ថា "សភាវៈទាំងឡាយ មានរូបជាដើម ជាគុណនៃធាតុទាំង



ឡាយ មានតេជោធាតុជាដើម ព្រោះថា នាកាលភូតរូបទាំងឡាយ ដែលប្រព្រឹត្តទៅ មិនបានដាច់ពីគ្នា គឺបុគ្គលណា ក៏មិនគប្បីពោលបានថា : នេះ ជាគុណនៃភូតរូបនេះ, នេះ ជាគុណនៃភូតរូបនេះ" ។

កាលបើយ៉ាងនេះ មានអាចារ្យទាំងឡាយនោះ គប្បីពោលថា : អ្នកទាំងឡាយ ប្រាថ្នានូវកិច្ចទាំងឡាយ មានការទ្រទ្រង់ជាដើម នៃភូតរូបទាំងឡាយ មានបឋវីធាតុជាដើម ព្រោះភាវៈនៃភូតរូបនោះៗ ជារបស់ដ៏លើសលុប មានក្នុងសម្ភារៈទាំងឡាយនោះៗ មានឧបមាយ៉ាងណាមិញ, ពាក្យថា : សភាវៈទាំងឡាយមានរូបជាដើម ជាគុណនៃធាតុទាំងឡាយ មានធាតុដីជាដើម គឺបុគ្គលគប្បីប្រាថ្នា ព្រោះភាវៈមានរូបជាដើម ប្រាកដជាមានចំនួនយ៉ាងច្រើនលើសលុប ក្នុងសម្ភារៈទាំងឡាយ ដែលច្រើនលើសលុប ដោយធាតុទាំងឡាយ មានធាតុភ្លើងជាដើម ក៏យ៉ាងដូច្នោះដែរ ។

អាចារ្យទាំងឡាយនោះ គឺត្រូវគេតវ៉ា ថា "យើងទាំងឡាយ គប្បីប្រាថ្នា, បើក្លិនក្នុងកប្បាស ដែលក្រៃលែងដោយដី ជាក្លិនដ៏ក្រៃលែងជាងក្លិននៃគ្រឿងត្រាំ ដែលក្រៃលែងដោយធាតុទឹក និង ពណ៌ នៃទឹកត្រជាក់ គប្បីថាជាងពណ៌នៃទឹកក្តៅ ដែលក្រៃលែង ដោយធាតុភ្លើង, តែធម្មជាតិទាំងពីរយ៉ាងនេះ មិនមានទេ ព្រោះហេតុណា, ព្រោះហេតុនោះ អ្នកទាំងឡាយ គប្បីលះបង់ការកត់សម្គាល់ឃើញ នៃសេចក្តីខុសផ្សេងពីគ្នា ដែលជាទីអាស្រ័យនៃបសាទរូប មានចក្ខុបសាទ ជាដើមនោះ, បណ្ឌិត គប្បីជឿពាក្យនេះថា "វត្ថុទាំងឡាយមានរូប និង រសជាដើម នៃភូតរូបទាំងឡាយ ក្នុងកលាបជាមួយគ្នា សូម្បីមិនវិសេសជាងគ្នា ក៏រមែងមិនដូចគ្នា យ៉ាងណាមិញ, ប្រសាទទាំងឡាយ មាន

ចក្ខុបសាទជាដើម កាលបើហេតុនៃសេចក្ដីវិសេសដទៃ សូម្បីមិនមាន ក៏មិនដូចគ្នា ក៏យ៉ាងនោះដែរ ។

សួរថា : ចុះហេតុណា ដែលមិនទូទៅដល់គ្នានឹងគ្នា ? ហេតុនោះ តើដូចម្ដេច ? ។

ឆ្លើយថា : ក៏កម្មហ្នឹងឯង ជាហេតុដ៏វិសេស នៃការប្លែកផ្សេងគ្នា នៃបសាទរូប មានចក្ខុបសាទជាដើមនោះ ព្រោះហេតុនោះ សេចក្ដីប្លែកគ្នា នៃបសាទរូបទាំងឡាយនេះ ព្រោះប្លែកគ្នានៃកម្ម មិនមែនប្លែកគ្នា ដោយភូតរូបឡើយ ។ ព្រោះថា នាកាលសេចក្ដីប្លែកគ្នានៃភូតរូបមាន, សេចក្ដីជ្រះថ្លាហ្នឹងឯង រមែងកើតឡើងមិនបានទេ ។

បោរាណាចារ្យទាំងឡាយ ពោលថា: សេចក្ដីជ្រះថ្លា (រមែងមាន) កាលបើភូតរូបទាំងឡាយស្មើគ្នា, កាលបើភូតរូបទាំងឡាយមិនស្មើគ្នាទេ សេចក្ដីជ្រះថ្លា ក៏មិនមាន ។ បើបសាទរូបទាំងនេះ មានសេចក្ដីប្លែកគ្នា ដោយសេចក្ដីប្លែកគ្នានៃកម្ម យ៉ាងនេះ, ចក្ខុ និង សោតៈ ទទួលយកអារម្មណ៍ដែលមិនទាន់មកដល់ ព្រោះភាវៈនៃចក្ខុប្បសាទជាដើម ជាហេតុនៃវិញ្ញាណ ក្នុងវិសយរូប ដែលមានទីអាស្រ័យ មិនជាប់ស្អិតនឹងនិស្ស័យរបស់ខ្លួន, ឃានៈ, ជិវ្ហា និង កាយទាំងឡាយទទួលនូវអារម្មណ៍ ដែលដល់ព្រមហើយ ព្រោះភាវៈនៃឃានៈជាដើម ជាហេតុនៃវិញ្ញាណ ក្នុងអារម្មណ៍ដែលជាប់ស្អិតហើយ នូវ (និស្ស័យ) របស់ខ្លួន ដោយជានិស្ស័យ និង ដោយខ្លួនឯង ។

(ចក្ខុ)

ក៏បណ្ដាបសាទរូបទាំងឡាយនេះ ចក្ខុបសាទ ឯណានេះ ដែលត្រឡប់ហើយ ដោយរោមនៃត្របកភ្នែក មានពណ៌លឿង ដែលវិចិត្រ



ហើយ ដោយមណ្ឌលខ្មៅ និង ស ប្រាកដស្មើដោយស្រទាប់ នៃផ្កាឧប្បលខៀវ គឺបណ្ឌិត ពោលថា ចក្ខុ ក្នុងលោក, ចក្ខុនោះ ដោយប្រមាណប៉ុនក្បាលចៃ មានឧបការៈ គឺធាតុទាំង ៤ ដែលមានកិច្ច(នាទី) ញ៉ាំងស្រទាប់ភ្នែកទាំង ៧ ជាន់ ឲ្យជ្រួតជ្រាប ដូចជាប្រេងដែលបុគ្គលដាក់ (ស្រោច) លើស្រទាប់សំឡី ៧ ជាន់ ញ៉ាំងស្រទាប់សំឡី ឲ្យជ្រួតជ្រាប ដូច្នោះហើយ ទ្រទ្រង់ ចងរឹត ធ្វើឲ្យក្ដៅ ផ្សព្វផ្សាយ ធ្វើហើយ ឲ្យដូចជាខត្តិយកុមារ មានឧបការៈ គឺមេទំទាំងឡាយ ៤ ដែលមានភារកិច្ច បី-ព ឲ្យស្រង់ទឹក តាក់តែងកាយ បក់ផ្លិត ធ្វើថ្វាយ ដូច្នោះ ដែលរដូវ ចិត្ត និង អាហារទាំងឡាយឧបត្ថម្ភ ដែលអាយុថែរក្សា ដែលអវិនិព្ភោគរូប មានពណ៌ ក្លិន និង រសជាដើម រុំព័ទ្ធហើយ ញ៉ាំងភាវៈនៃវត្ថុ និង ទ្វារ តាមសមគួរ ដល់វិថីចិត្តទាំងឡាយ មានចក្ខុវិញ្ញាណជាដើម ឲ្យសំរេច ឋិតនៅ ក្នុងកន្លែងដែលជាទីកើតឡើង នៃទ្រង់ទ្រាយរាងកាយ របស់រូបទាំងឡាយ ដែលឋិតនៅចំពោះមុខ ត្រង់កណ្ដាល នៃរង្វង់ភ្នែកខ្មៅ ដែលវង់ភ្នែកព័ទ្ធជុំវិញហើយ នៃចក្ខុព្រមទាំងសម្ភារៈនោះ ។ សមដូចជាពាក្យ ដែលព្រះសារីបុត្ត ជាធម្មសេនាបតី ពោលហើយ ថា :

បុគ្គល ពិចារណាឃើញរឿយៗ នូវរូបទាំងឡាយ
ដោយចក្ខុប្បសាទណា, ចក្ខុប្បសាទនោះ តូច ល្អិត
មានសេចក្ដីឧបមាដូចជាក្បាលនៃចៃ ។

(សោតៈ)

(២៧៤) ឯសោតប្បសាទ មានឧបការៈ ដែលធាតុទាំងឡាយ មានឧបការៈ ដែលលោកពោលហើយ ធ្វើហើយ ដែលរដូវ ចិត្ត និង

អាហារទាំងឡាយ ទំនុកបំរុង គឺអាយុ កាលតាមរក្សា គឺអវិនិព្ភោគរូបទាំងឡាយ មានសម្បុរជាដើម ព័ន្ធព័ទ្ធហើយ កាលញ៉ាំងភាវៈនៃវត្ថុ និង ទ្វារ តាមសមគួរ ដល់វិថីចិត្តទាំងឡាយ មានសោតវិញ្ញាណជាដើម ឲ្យសំរេច ស្ថិតនៅ ក្នុងប្រទេស មានទ្រង់ទ្រាយ ដូចជាវង់នៃចិញ្ចៀន មានដុះដោយរោម ដូចជាពណ៌នៃទង់ដែង ឰដ៏ខាងក្នុង នៃរន្ធរបស់សោតប្បសាទ ដែលប្រកបដោយសម្ភារៈ ។

(ឃានៈ)

ឃានប្បសាទ មានឧបការៈ, ការឧបត្ថម្ភ, ការតាមរក្សា និងបរិវារ មានបការៈដូចដែលលោកពោលហើយ កាលញ៉ាំងភាវៈនៃវត្ថុ និង ទ្វារ ដ៏សមគួរ ដល់វិថីចិត្តទាំងឡាយ មានឃានវិញ្ញាណជាដើម ឲ្យសំរេច ស្ថិតនៅ ក្នុងប្រទេសមានទ្រង់ទ្រាយ ដូចជាជើងនៃពពែ ឰដ៏ខាងក្នុង នៃរន្ធច្រមុះ ព្រមទាំងសម្ភារៈ ។

(ជិវ្ហា)

ជិវ្ហាបសាទ មានឧបការៈ, ការទំនុកបំរុង, ការតាមរក្សា និងគ្រឿងបរិវារ ដូចដែលលោកពោលហើយ ញ៉ាំងភាវៈនៃវត្ថុ និង ទ្វារ ដ៏គួរ ដល់វិថីចិត្តទាំងឡាយ មានជិវ្ហាវិញ្ញាណជាដើម ឲ្យសំរេច ស្ថិតនៅ ក្នុងប្រទេស មានទ្រង់ទ្រាយ ដូចជាចុងនៃផ្កាឧប្បល ឰដ៏ខាងលើ ត្រង់កណ្ដាលនៃអណ្ដាត ព្រមទាំងសម្ភារៈ ។

(កាយ)

ចំណែក ឧបាទិន្នករូប ក្នុងកាយនេះ មាននៅ ដរាបណា, ដរាបនោះ កាយ ហាក់ដូចជាប្រេង ក្នុងស្រទាប់នៃកប្បាស មានឧបការៈ, ការទំនុកបំរុង, ការតាមរក្សា និង បរិវារ មានបការៈដែលលោកពោល



ហើយ ដូចគ្នា ញ៉ាំងភាវៈនៃវត្ថុ និង ទ្វារ គួរដល់វិថីចិត្តទាំងឡាយ មានកាយវិញ្ញាណជាដើម ឲ្យសំរេច ស្ថិតនៅ ក្នុងទីសព្វអន្លើ ។ ចក្ខុបសាទជាដើមទាំងឡាយនេះ បណ្ឌិតគប្បីឃើញថា វាដូចជាការទន់ ទៅដោយការប្រព្រឹត្តិទៅ មួយអន្លើដោយគោចររបស់វា មានរូបជាដើមនោះឯង ដូចជាពស់, ក្រពើ, សត្វស្លាប, ឆ្កែស្រុក និង ឆ្កែព្រៃជាដើម ដូចជាទន់ទៅ ដោយកិរិយាប្រព្រឹត្តិទៅ មួយអន្លើដោយគោចរ របស់វា ពោលគឺ ដំបូក, ទឹក, អាកាស, ស្រុក, និង ទីស្មសាន ដូច្នោះ ។

(គោចររូប ៤)

ចំណែកក្នុងគោចររូបទាំងឡាយ មានរូបជាដើម ដទៃអំពីបសាទរូបនោះទៅ មានសេចក្ដីវិនិច្ឆ័យ ដូចតទៅនេះ ។ រូបមានការខ្ទាំងខ្ទប់នូវចក្ខុ ជាលក្ខណៈ, មានភាវៈនៃចក្ខុវិញ្ញាណ ជាអារម្មណ៍ (ជាកិច្ច), មានគោចរ នៃចក្ខុវិញ្ញាណនោះឯង ជាផល, មានមហាភូតរូប ៤ ជាហេតុ ។

ក៏ការដែលមហាភូតរូប ៤ ជាហេតុនេះ (មាន) យ៉ាងណាមិញ, ឧបាទាយរូបទាំងឡាយទាំងអស់ហ្នឹងឯង ក៏មាន យ៉ាងនោះដែរ ។ បើសេចក្ដីវិសេស មានក្នុងរូបណា, យើងនឹងពោល ក្នុងរូបនោះ ។

ក៏រូបនោះនេះ មានច្រើនប្រការ ដោយអំណាចនៃពាក្យ មានពាក្យថា : ពណ៌ខៀវ ពណ៌លឿងជាដើម ។

សម្លេង មានការខ្ទាំងខ្ទប់នូវសោតៈ ជាលក្ខណៈ, មានភាវៈនៃសោតវិញ្ញាណ ជាអារម្មណ៍ ជាកិច្ច, មានគោចរនៃសោតវិញ្ញាណនោះឯង ជាផល, សម្លេងមានច្រើនប្រការ ដោយន័យមានន័យថា: សម្លេងនៃស្គរ សម្លេងនៃសម្ភោរជាដើម ។

ក្លិន មានការខ្ទាំងខ្ទប់នូវប្រមុះ ជាលក្ខណៈ, មានភាវៈនៃឃានវិញ្ញាណ ជាអារម្មណ៍ ជាកិច្ច, មានគោចរ នៃឃានវិញ្ញាណនោះឯង ជាផល, ក្លិន មានច្រើនប្រការ ដោយន័យមានន័យថា ក្លិននៃឫស ក្លិននៃខ្លឹមជាដើម ។

រស មានការខ្ទាំងខ្ទប់នូវអណ្តាត ជាលក្ខណៈ, មានភាវៈនៃជិវ្ហាវិញ្ញាណ ជាអារម្មណ៍ ជាកិច្ច, មានគោចរ នៃជិវ្ហាវិញ្ញាណ ជាហេតុ, (រស) មានច្រើនប្រការ ដោយន័យមានន័យ ថាៈ រសនៃឫស រសនៃដើមជាដើម ។

**(ភាវរូប ២)**

(២៧៥) ឥត្ថិន្ទ្រិយ មានឥត្ថីភាវៈ ជាលក្ខណៈ, មានការប្រកាសថា ឥត្ថី ជាកិច្ច, មានភាវៈនៃកិរិយាធ្វើនូវភេទ, និមិត្ត, ការលេង និង អាកប្បកិរិយា ជាផល ។

បុរិសិន្ទ្រិយ មានបុរសភាវៈ ជាលក្ខណៈ, មានការប្រកាស ថា បុរិស ជាកិច្ច, មានភាវៈនៃកិរិយាធ្វើនូវភេទ, និមិត្ត, ការលេង និង អាកប្បកិរិយា ជាផល ។

ភាពនៃរូបទាំងពីរនោះឯង ជ្រួតជ្រាបពេញសរីរៈទាំងមូល ហាក់បីដូចជាកាយប្បសាទដែរ តែថា មិនបានដល់នូវភាពដែលបុគ្គលគប្បីពោលបាន ថា "វាស្ថិតនៅហើយ ក្នុងឱកាសដែលកាយប្បសាទ មិនស្ថិតនៅហើយ" ដូច្នេះ, ការលាយឡំគ្នាទៅវិញទៅមក មិនមាន ដូចជាវត្ថុទាំងឡាយ មានរូប និង រសជាដើម ដូច្នោះទេ ។

**(ជីវិតរូប)**

(២៧៦) ជីវិតិន្ទ្រិយ មានការរក្សានូវរូប ដែលកើតជាមួយគ្នា ជា



លក្ខណៈ, មានការប្រព្រឹត្តិទៅ នៃសហជរូបទាំងឡាយនោះ ជាកិច្ច, មានការតាំងនៅ នៃសហជរូបទាំងឡាយនោះ ជាផល, មានភូតរូប ដែលខ្លួនគប្បីឲ្យប្រព្រឹត្តទៅ ជាហេតុ ។

ម្យ៉ាងវិញទៀត បើមានការងារ មានការតាមថែរក្សាជាដើម ជាលក្ខណៈ, ជីវិតិន្ទ្រិយនោះ តែងតាមរក្សា នូវរូបដែលកើតជាមួយគ្នាទាំងឡាយ ក្នុងខណៈដែលមាន ដូចជាទឹក (កាលតាមរក្សា) នូវវត្ថុទាំងឡាយមានផ្កាឧប្បលជាដើម, ម្យ៉ាងវិញទៀត តែងរក្សានូវធម៌ទាំងឡាយ ដែលជាបច្ច័យកើតឡើង តាមសមគួររបស់ខ្លួន ដូចជាស្ត្រីមេដោះ កាលរក្សានូវកុមារ ដែលនៅចំពោះមុខ, តែថា ជីវិតិន្ទ្រិយនោះ ប្រព្រឹត្តទៅ ដោយការចងភ្ជាប់នូវធម៌ ដែលខ្លួនឲ្យប្រព្រឹត្តទៅ ដោយខ្លួនឯង ដូចជាអ្នកកាន់ចង្កូត រមែងមិនប្រព្រឹត្តទៅ ខាងលើអំពីការ បែកធ្លាយផង ព្រោះការមិនមាននៃធម៌ទាំងឡាយ ដែលខ្លួនគប្បីឲ្យប្រព្រឹត្តទៅផង រមែងមិនតាំងនៅ ក្នុងខណៈនៃការបែកធ្លាយ របស់ខ្លួនផង ព្រោះភាវៈនៃជីវិតិន្ទ្រិយ កំពុងបែកធ្លាយដោយខ្លួនឯង ប្រៀបដូចជាប្រទេះ និង ប្រេងកាលអស់ទៅ មិនតំកល់ប្រទេះប្រទីបបានឡើយ តែថា (ជីវិតិន្ទ្រិយនោះ) គឺបណ្ឌិត មិនគប្បីឃើញថា ប្រាសហើយចាកអានុភាព នៃការតាមរក្សា និង ការប្រព្រឹត្តិទៅ និង ការតំកល់ទុក ព្រោះកិរិយាញុំាងធម៌នោះៗ ឲ្យសំរេច ក្នុងខណៈនៃពាក្យ ដូចដែលយើងបានពោលមកហើយ ។

**(ហទយវត្ថុ ១)**

(២៧៧) ហទយវត្ថុ មានភាពទីនៅអាស្រ័យ នៃមនោធាតុ និង មនោវិញ្ញាណធាតុទាំងឡាយ ជាលក្ខណៈ, មានការទ្រទ្រង់នូវធាតុទាំង

ឡាយនោះឯង ជាកិច្ច, មានការលើកឡើងនូវធាតុទាំងនោះ ជាផល ។

ហទយវត្ថុ អាស្រ័យនូវលោហិត មានប្រការដែលលោកពោលហើយ ក្នុងកាយគតាសតិកថា មានឧបការៈ គឺភូតរូបទាំងឡាយដែលមានការទ្រទ្រង់ជាដើម ធ្វើហើយ ដែលរដូវ ចិត្ត និង អាហារទាំងឡាយឧបត្ថម្ភ ដែលអាយុ ជួយតាមរក្សា ញុំាងភាវៈជាវត្ថុនៃមនោធាតុ និង មនោវិញ្ញាណធាតុ និង ធម៌ដែលសម្បយុត្តដោយធាតុទាំងពីរនោះឲ្យសំរេច តាំងនៅ ឰដ៏ខាងក្នុង នៃហទយៈ ។

(វិញ្ញត្តិរូប ២)

(កាយវិញ្ញត្តិ)

(២៧៨) ការប្រែប្រួលនៃអាការៈ ជាបច្ច័យ នៃវាយោធាតុ ដែលមានចិត្តជាសមុដ្ឋាន ប្រព្រឹត្តទៅដោយអាការៈ មានការឈានទៅ ជាដើម មានការទប់ទល់, ការទ្រទ្រង់, និង ការកំរើកនៃរូបកាយ ដែលកើតជាមួយគ្នា ហៅថា កាយវិញ្ញត្តិ, មានការប្រកាស នូវសេចក្ដីប៉ុនប៉ង ជាកិច្ច, មានភាវៈជាហេតុនៃការញាប់ញ័រនៃកាយ ជាផល, មានវាយោធាតុ ដែលមានចិត្តកើតឡើង ជាហេតុ ។ ក៏វិញ្ញត្តិនោះនេះ គឺលោកពោលថា កាយវិញ្ញត្តិ ព្រោះភាវៈនៃកាយវិញ្ញត្តិនោះ ជាធម្មជាតិញុំាងហេតុ ញុំាងបុគ្គលឲ្យដឹងច្បាស់ ព្រោះកិរិយាស្ទុះស្ទាទៅ នៃកាយផង ព្រោះភាវៈនៃកាយវិញ្ញត្តិនោះ ជាធម្មជាតិ គឺបុគ្គលគប្បីដឹង ដោយកាយ ពោលគឺការស្ទុះស្ទាទៅ នៃកាយនោះ ដោយខ្លួនឯងផង ។

ចំណែកខាង ឥរិយាបថទាំងឡាយ មានការឈានទៅមុខ និង ការឈានថយក្រោយជាដើម គឺបណ្ឌិតគប្បីជ្រាបថា ប្រព្រឹត្តទៅ ព្រោះកិរិយាកំរើក នៃរូបទាំងឡាយ មានរូបដែលកើតអំពីរដូវជាដើមហ្នឹងឯង



ដែលពាក់ព័ន្ធគ្នា ដោយរូបដែលកើតអំពីចិត្តទាំងឡាយ ដែលកំរើកហើយ ព្រោះកាយវិញ្ញត្តិនោះ ។

(វចីវិញ្ញត្តិ)

ការប្រែប្រួលនៃអាការៈ មានបច្ច័យនៃការតក្លាប់ នូវឧបាទិន្នករូបនៃបឋវីធាតុដែលមានចិត្តជាសមុដ្ឋាន ប្រព្រឹត្តទៅដោយវចីភេទ ឈ្មោះថា វចីវិញ្ញត្តិ, វចីវិញ្ញត្តិនោះ មានការប្រកាសនូវសេចក្ដីប៉ុនប៉ង ជាកិច្ច, មានភាវៈនៃហេតុនៃការគឹកកងដោយសំដី ជាផល, មានបឋវីធាតុដែលមានចិត្តកើតឡើង ជាហេតុ ។ ក៏វិញ្ញត្តិនេះនោះ គឺលោកពោល ថា វចីវិញ្ញត្តិ ព្រោះភាវៈនៃវចីវិញ្ញត្តិនោះ ជាធម្មជាតិញុំាងហេតុ ញុំាងបុគ្គលឲ្យដឹងច្បាស់ ដោយសេចក្ដីប៉ុនប៉ង ព្រោះកិរិយាគឹកកង នៃសំដីផង ព្រោះភាវៈនៃវចីវិញ្ញត្តិនោះ ជាធម្មជាតិ គឺបុគ្គលគប្បីដឹង ដោយវាចា ពោលគឺការគឹកកង នៃសំដីនោះ ដោយខ្លួនឯងផង ។

ប្រៀបដូចជាបុគ្គលឃើញនូវនិមិត្តនៃទឹក មានក្បាលគោជាដើម ដែលបុគ្គលលើកឡើងហើយ ចងទុកក្នុងព្រៃ ក៏ដឹងបានថា ទឹកមានក្នុងទីនេះ យ៉ាងណា, សូម្បីកាយវិញ្ញត្តិ និង វចីវិញ្ញត្តិទាំងឡាយ គឺបុគ្គលកាន់យកនូវកិរិយាស្ទុះស្ទាទៅនៃកាយផង នូវកិរិយាគឹកកង នៃសំដីផង ហើយដឹងច្បាស់ ក៏យ៉ាងនោះដែរ ។

(បរិច្ឆេទរូប ១)

(២៧៩) ក្នុងរូបដែលបុគ្គលកំណត់ហើយ ថា រូបនេះអំពីរូបនេះ ខាងលើផង ខាងក្រោមផង ត្រង់ទទឹងផង មានដោយអាកាសធាតុណា អាកាសធាតុនោះ មានការកំណត់នូវរូបជាលក្ខណៈ, មានការប្រកាស នូវទីបំផុតនៃរូប ជាកិច្ច, មានដែននៃរូប ជាផល, មានភាវៈនៃខ្លួនដែល

ធាតុ មិនពាល់ត្រូវហើយ និង ភាវៈនៃខ្លួនជាប្រហោង និង ជាចន្លោះ ជាផល ឬក៏ មានរូបដែលកំណត់ ជាហេតុ ។

(វិការរូប ៣)

ភាវៈនៃរូបដ៏ស្រាល មានភាវៈនៃការមិនយឺតយូរ ជាលក្ខណៈ, មានការបន្ទោបង់នូវភាវៈនៃរូបទាំងឡាយដ៏ធ្ងន់ ជាកិច្ច, មានភាវៈនៃការប្រព្រឹត្តិរហ័ស ជាផល, មានរូបដ៏ស្រាល ជាហេតុ ។

ភាវៈនៃរូបដ៏ទន់មានភាវៈនៃរូបមិនរឹង ជាលក្ខណៈ, មានការបន្ទោបង់នូវភាវៈនៃរូបទាំងឡាយដ៏រឹង ជាកិច្ច, មានភាវៈនៃការមិនភ្ជាំងភ្ជាត់ក្នុងកិរិយាទាំងពួងទាំងឡាយ ជាផល, មានរូបដ៏ទន់ ជាហេតុ ។

ភាវៈនៃរូបគួរដល់ការងារ មានភាវៈនៃរូបដ៏សមគួរ និង គួរដល់ការងារក្នុងកិរិយានៃសរីរៈ ជាលក្ខណៈ, មានកិរិយាបន្ទោបង់នូវភាវៈនៃរូបមិនគួរដល់ការងារ ជាកិច្ច, មានភាវៈនៃរូបមិនមានកម្លាំងខ្សោយ ជាផល, មានរូបគួរដល់ការងារ ជាហេតុ ។

ក៏រូបជាតិទាំងឡាយបីនេះ មិនលះបង់គ្នាបានឡើយ ។ ទោះបីជាយ៉ាងនេះក៏ដោយ សេចក្តីប្លែកគ្នានៃរូបជាតិទាំងឡាយនេះ គឺបុគ្គលគប្បីជ្រាប យ៉ាងដូច្នេះ ថា "ភាវៈនៃរូបទាំងឡាយដ៏ស្រាលណា ដូចជាភាវៈនៃរូបរបស់បុគ្គលមិនមានរោគ, មានភាវៈមិនយឺតយូរ និង កិរិយាផ្លាស់ប្តូរដោយរហ័សជាបការៈ, មានកិរិយាធ្វើនូវភាវៈនៃរូបដ៏យឺតយូរ និង កិរិយាកំរើកនូវធាតុ និង បច្ច័យជាបដិបក្ស ជាសមុដ្ឋាន, ការប្រែប្រួលនៃរូបនោះ ឈ្មោះថា រូបស្ស លហុតា (ភាពស្រាលនៃរូប) ។

ក៏រូបវិការៈឯណា ជាភាពទន់នៃរូបទាំងឡាយ ដូចជាស្បែកដែលបុគ្គលសម្ងាប់បានល្អហើយ មានភាពទន់ភ្លន់ ដោយការបង្ក្រាប់បញ្ញាបាន



ក្នុងកិរិយាទាំងពួងប្លែកៗ ពីគ្នា ជាបការៈ, មានបច្ច័យដែលជាបដិបក្សដល់ការកំរើកនៃធាតុ ដែលធ្វើឲ្យរូបមានភាពរឹង ជាសមុដ្ឋាន, រូបវិការៈនោះ ឈ្មោះថា រូបស្ស មុទុតា (ភាពទន់ភ្លន់នៃរូប) ។

ក៏រូបវិការៈឯណា ដែលគួរដល់ការងារ នៃរូបទាំងឡាយ ដូចជាមាសដែលបុគ្គលជំរះល្អហើយ មានភាវៈដ៏សមគួរដល់កិរិយា នៃរាងកាយជាបការៈទូទៅ, មានបច្ច័យដែលជាបដិបក្ស ដល់ការកំរើកនៃធាតុដែលមានការធ្វើមិនសមគួរ ដល់កិរិយានៃសរីរៈ ជាសមុដ្ឋាន, រូបវិការៈនោះ ឈ្មោះថា រូបស្ស កម្មញ្ញតា (ភាពគួរដល់ការងារនៃរូប)" ដូច្នេះ ។

(លក្ខណរូប ៤)

(២៨០) ការកកើតនៃរូប មានការសន្សំ ជាលក្ខណៈ, មានការដកនូវកំពស់នៃរូបទាំងឡាយ ដោយទីបំផុតខាងដើម ជាកិច្ច, មានការស្រោចស្រប់ ជាផល ឬក៏ មានភាវៈនៃការពេញគ្រប់គ្រាន់ ជាផល, មានរូបដែលកើតឡើងហើយ ជាហេតុ ។

តំណនៃរូប មានការប្រព្រឹត្តិទៅ ជាលក្ខណៈ, មានការភ្ជាប់គ្នា ជាកិច្ច, មានការមិនចូលទៅកាត់ជាផល, មានរូបដែលតភ្ជាប់គ្នា ជាហេតុ ។

រូបទាំងពីរយ៉ាងនេះឯង ជាឈ្មោះ នៃរូបដែលកើតហើយ ។ តែការលើកឡើង និង ការសំដែង ដែលព្រះមានព្រះភាគ ទ្រង់ធ្វើហើយថា "ការកកើត តំណ" ដូច្នេះ ក៏ព្រោះភាវៈនៃជាតិរូបនោះមានអាការៈផ្សេងៗ ផង ដោយអំណាចនៃវេនេយ្យសត្វផង ។ តែបើពោលតាមសេចក្តី ក្នុងលក្ខណរូបទាំងឡាយនេះ ភាពផ្សេងគ្នា មិនមានទេ ព្រោះហេតុណា, ព្រោះហេតុនោះ ក្នុងនិទ្ទេសនៃបទទាំងឡាយនេះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហើយថា "ការកកើត នៃអាយតនៈទាំងឡាយ

ឯណា, ការកកើតនោះ ឈ្មោះថា រូបស្ស ឧចយោ, ការកកើតនៃរូបណា ការកកើតនោះ ឈ្មោះថា រូបស្ស សន្តតិ” ។

សូម្បីក្នុងអដ្ឋកថា ក៏ព្រះអដ្ឋកថាចារ្យពោលហើយថា “ការកើតឡើង ឈ្មោះថា អាចយៈ, ការចំរើន ឈ្មោះថា ឧបចយៈ, ការប្រព្រឹត្តិទៅ ឈ្មោះថា សន្តតិ” ហើយធ្វើឧបមា ថា “ការកកើត ឈ្មោះថា អាចយៈ ដូចជាកាលជាទីឡើងនៃទឹកក្នុងរណ្តៅ ដែលបុគ្គលជីកហើយទៀបឆ្នេរនៃស្ទឹង, ការចំរើន ឈ្មោះថា ឧបចយៈ ដូចជាកាលដែលទឹកពេញ, ការប្រព្រឹត្តិទៅ ឈ្មោះថា សន្តតិ បីដូចជាកាលដែលទឹកហៀរលិចហើយហូរទៅ យ៉ាងដូច្នោះឯង” ។ ក៏ក្នុងកាលជាទីបំផុត នៃពាក្យឧបមា លោកពោល ថា “សួរថា កាលបើពាក្យយ៉ាងនេះមាន, តើពាក្យដូចម្តេច ជាពាក្យដែលលោកពោលហើយ?” ។ ឆ្លើយថា: “ការពេញឡើង ដោយអាយតនៈ គឺអដ្ឋកថាចារ្យ ពោលហើយ, អាយតនៈ គឺអដ្ឋកថាចារ្យ ពោលហើយ ដោយការកកើត” ។ ព្រោះហេតុនោះ ការកកើតឡើងជាដំបូង ឯណា នៃរូបទាំងឡាយ, ការកកើតឡើងនោះ គប្បីជ្រាបថា ឈ្មោះថា អាចយៈ, ការកកើតឡើង នៃរូបទាំងឡាយដទៃ កាលកើតឡើងព្ធដ៏ខាងលើ នៃរូបទាំងឡាយនោះ, ការកកើតឡើងនោះ គប្បីជ្រាបថា ឈ្មោះថា ឧបចយៈ ព្រោះប្រាកដឡើង ដោយអាការៈចំរើនឡើង, ការកើតឡើងឯណា នៃរូបទាំងឡាយដទៃទៀត ដែលកើតឡើងរឿយៗ ព្ធដ៏ខាងលើ នៃរូបទាំងឡាយនោះឯង គប្បីជ្រាបថា ឈ្មោះថា សន្តតិ ព្រោះកិរិយាប្រាកដឡើង ដោយអាការៈនៃការតភ្ជាប់គ្នា ។

កិរិយាទ្រុឌទ្រោមទៅនៃរូបមានការចាស់ជរាទៅនៃរូប ជាលក្ខណៈ, មានកិរិយាចូលទៅជិត ជាកិច្ច, មានកិរិយាប្រាសចាកភាវៈថ្មី ជាផល, សូម្បីកាលបើសភាវៈ (មានការជ្រីវជ្រួញជាដើម) មិនបានប្រាសចាកទៅ ក៏ដោយ, មានរូបដែលចាស់ជរា ជាហេតុ ដូចជាភាពចាស់គ្រាំគ្រានៃស្រូវ យ៉ាងដូច្នោះឯង ។



ជរាភាពនេះ គឺព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រោះសំដៅយកនូវជរាដែលប្រាកដឡើង ព្រោះសំដែងឡើងនូវការប្លែកគ្នា ក្នុងអាការៈទាំងឡាយ មានធ្មេញជាដើម ដោយភាវៈមានការបាក់ជាអាទិ៍ ។

ចំណែកការចាស់ជរានៃអរូបធម៌ទាំងឡាយ ឈ្មោះថា បដិច្ឆន្នជរា, សេចក្តីប្លែកនេះ មិនមានដល់បដិច្ឆន្នជរានោះទេ, ចំណែកខាងជរាដែលមិនមានអណ្តាតណា ក្នុងទីទាំងឡាយមានដី, ទឹក, ភ្នំ, ព្រះច័ន្ទ និងព្រះអាទិត្យជាដើម, វិការភាពនុ៎ះ (នៃជរា បិទបាំងនោះ) ក៏មិនមានដូចគ្នាដែរ ។

ភាពនៃរូបមិនទៀង មានការបែកធ្លាយ ជាលក្ខណៈ, មានការទ្រុឌទ្រោមទៅ ជាកិច្ច, មានការអស់ទៅ និង សូន្យទៅ ជាផល, មានរូបដែលកំពុងបែកធ្លាយទៅ ជាហេតុ ។

(ឱជារូប ១)

(២៨១) អាហារដែលបុគ្គលធ្វើជាពំនូត មានចម្ងាញ់ ជាលក្ខណៈ, មានការនាំមកនូវរូប ជាកិច្ច, មានការទំនុកបំរុង ជាផល, មានវត្ថុដែលបុគ្គលគប្បីនាំមកធ្វើឲ្យជាពំនូតហើយ លេបចូលទៅ ជាហេតុ ។

ពួកសត្វញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយឱជាណា, ពាក្យថា កវឡិង្ការាហារនេះ ជាឈ្មោះ នៃឱជានោះ ។ រូបទាំងឡាយដែលមានមកហើយ ក្នុងបាលី មានតែប៉ុណ្ណោះឯង ។

ក៏ក្នុងអដ្ឋកថា ពាក្យថា “រូបជាកម្លាំង រូបជាដែនកើត រូបជាទីកើត រូបជារោគ” គឺអដ្ឋកថាចារ្យ បាននាំមកនូវរូបទាំងឡាយដទៃទៀតយ៉ាងនេះ ថា “រូប គឺការកើតឡើងដោយគំនិត នៃអាចារ្យទាំងឡាយពួកខ្លះ” ហើយពោលនូវពាក្យទាំងឡាយ មានពាក្យថា “បពិត្រព្រះអង្គជាស្តេចនៃអ្នកប្រាជ្ញ ជាព្រះសម្ពុទ្ធ ដោយពិត, ធម៌ជាគ្រឿងរារាំងទាំងឡាយ របស់ព្រះអង្គ មិនមានទេ” ដូច្នេះជាដើម ហើយឃាត់ ថា : “សេចក្តីងុយងោក មិនមានដោយពិត” ដូច្នេះ ។

បណ្តារូបទាំងឡាយក្រៅពីនេះ រូបនៃរោគ គឺលោកសង្គ្រោះយកហើយដោយស័ព្ទ គឺជរតា និង អនិច្ចតា, រូបជាទីកើតគឺលោកសង្គ្រោះយកហើយដោយស័ព្ទគឺឧបចយៈ និង សន្តតិ, រូបជាដែនកើត គឺលោកសង្គ្រោះយកហើយ ដោយអាបោធាតុ, រូបជាកម្លាំង គឺលោកសង្គ្រោះយកហើយដោយវាយោធាតុ ។ ព្រោះហេតុនោះ ទើបដល់ហើយនូវការសន្និដ្ឋានថា បណ្តារូបទាំងឡាយនោះ រូបសូម្បី ១ ផ្សេងគ្នា ក៏មាន ។ រូបមាន ២៨ យ៉ាងនេះ គឺ ឧបាទាយរូប ២៤ និង មហាភូតរូប ៤ ដែលលោកពោលហើយ ក្នុងកាលមុនមិនខ្វះមិនលើស ដូចរៀបរាប់មកនេះ។

(រូប ១)

(២៨២) រូបទាំងអស់នោះឯង មាន ១ ប្រការ ដោយន័យមានន័យថា : រូបមិនមានហេតុ, ឥតហេតុ, ប្រាសចាកហេតុ, ប្រព្រឹត្តទៅមួយអន្លើដោយបច្ច័យ, ជាលោកិយ, ប្រព្រឹត្តទៅមួយអន្លើដោយអាសវៈ ។

រូប មាន ២ យ៉ាង ដោយអំណាចរូបមានជាអាទិ៍ថា អជ្ឈត្តិករូប, ពាហិររូប, ឱឡារិករូប, សុខុមរូប, ទូររូប, សន្តិកេរូប, និប្ផន្នរូប, អនិប្ផន្នរូប, បសាទរូប, ន បសាទរូប, ឥន្ទ្រិយរូប, អនិន្ទ្រិយរូប,



ឧបាទិន្នរូប, អនុបាទិន្នរូប ។

បណ្តារូបទាំងឡាយនោះ រូប មាន ៥ យ៉ាង មានចក្ខុជាដើម ឈ្មោះថា អជ្ឈត្តិករូប ព្រោះភាវៈនៃរូបនោះ ប្រព្រឹត្តទៅហើយ ចំពោះអត្តភាព ។ រូបដ៏សេស ឈ្មោះថា ពាហិររូប ព្រោះភាវៈនៃរូបនោះប្រព្រឹត្តទៅខាងក្រៅ អំពីអជ្ឈត្តិករូបនោះ ។

រូប មាន ១២ ប្រការ គឺ រូប ៩ មានចក្ខុជាដើមផង, ធាតុ ៣ វៀរចាកអាបោធាតុផង ហៅថា ឱឡារិករូប ព្រោះថារូបគឺបុគ្គលគប្បីកាន់យក ដោយអំណាចនៃការតភ្ជាប់គ្នា, រូបដ៏សេស ហៅថា សុខុមរូប ព្រោះភាវៈនៃរូបនោះដទៃអំពីឱឡារិករូប ។

រូបឯណា ហៅថា សុខុមរូប, រូបនោះឯង ឈ្មោះថា ទូររូប ព្រោះភាវៈនៃរូបនោះ ជាសភាវៈដែលបុគ្គលដឹងបានដោយកម្រ, រូបក្រៅពីនេះ ឈ្មោះថា សន្តិកេរូប ព្រោះភាវៈនៃរូបនោះជាសភាវៈដែលបុគ្គលដឹងបានដោយងាយ ។

រូប មាន ១៨ យ៉ាង គឺ ធាតុ ៤, រូប ១៣ មានចក្ខុរូបជាដើម និងកវឡិង្ការាហារ ឈ្មោះថា និប្ផន្នរូប ព្រោះជាសភាព គឺបុគ្គលគប្បីរំលងនូវបរិច្ឆេទរូប, វិការរូប និង លក្ខណរូប ហើយកំណត់យកតាមសភាវៈហ្នឹងឯង, រូបដ៏សេស ឈ្មោះថា អនិប្ផន្នរូប ព្រោះភាវៈនៃរូបនោះ ជាទំនាស់ដល់និប្ផន្នរូបនោះ ។

រូប មាន ៥ ប្រការ មានចក្ខុរូបជាដើម ឈ្មោះថា បសាទរូប ព្រោះភាវៈនៃរូបនោះ ថ្លាយង់ ដូចជាផ្ទៃនៃកញ្ចក់ ដោយភាវៈជាបច្ច័យជាទីកាន់យក នូវអារម្មណ៍ទាំងឡាយមានរូបជាដើម, រូបក្រៅពីនេះ មិនឈ្មោះថា បសាទរូបទេ ព្រោះភាវៈនៃរូបនោះផ្ទុយគ្នាពីបសាទរូបនោះ ។

បសាទរូបហ្នឹងឯង ជាមួយនឹងឥន្ទ្រិយរូប ៣ មានឥត្ថិន្ទ្រិយជាដើម ហៅថា ឥន្ទ្រិយរូប ដោយអត្ថថា ជាអធិបតី, រូបដ៏សេស ហៅថា អនិន្ទ្រិយរូប ព្រោះភាវៈនៃរូបនោះ ផ្ទុយគ្នាអំពីឥន្ទ្រិយរូបនោះ ។

រូប ដែលយើងនឹងពោលក្នុងខាងមុខថា "កម្មជរូប" "រូបដែលកើតអំពីកម្មនោះ" ឈ្មោះថា ឧបាទិន្នរូប ព្រោះភាវៈនៃរូបនោះ អាស្រ័យហើយដោយកម្ម, រូបដ៏សេស ឈ្មោះថា អនុបាទិន្នរូប ព្រោះសភាវៈនៃរូបនោះ ផ្ទុយគ្នាអំពីឧបាទិន្នរូប ។

(២៨៣) រូបទាំងអស់ហ្នឹងឯង មាន ៣ យ៉ាង ដោយអំណាចតិកៈទាំងឡាយ មាន សនិទស្សនត្តិកៈ និង កម្មជាទិតិកៈ ។ បណ្តារូបទាំងនោះ រូប ក្នុងឱឡារិករូប ឈ្មោះថា សនិទស្សនសប្បដិឃរូប (រូបដែលមើលឃើញបានផង ខ្ទាំងខ្ទប់បានផង), ឱឡារិករូប ដ៏សេស ឈ្មោះថា អនិទស្សនសប្បដិឃរូប (រូបដែលមើលមិនឃើញ ប៉ុន្តែខ្ទាំងខ្ទប់បាន), សុខុមរូបទាំងអស់ ឈ្មោះថា អនិទស្សនអប្បដិឃរូប (រូបដែលមើលមិនឃើញផង ទាំងខ្ទាំងខ្ទប់មិនបានផង) ។ រូប មាន ៣ យ៉ាង ដោយអំណាចនៃសនិទស្សនត្តិកៈ យ៉ាងនេះមុនគេ ។

ក៏សេចក្តីវិនិច្ឆ័យ គឺបណ្ឌិត គប្បីជ្រាប ដោយអំណាចតិកៈ មានកម្មជាទិតិកៈ ជាដើម (ដូចតទៅ) ។

រូប ដែលកើតហើយអំពីកម្ម ឈ្មោះថា កម្មជរូប, រូបដែលកើតហើយអំពីបច្ច័យ នៃកម្មជដទៃអំពីកម្មជរូបនោះ ឈ្មោះថា អកម្មជរូប, រូប ដែលមិនមែនកើតអំពីអ្វីមួយទេ ឈ្មោះថា នេវកម្មជនាកម្មជរូប (មិនមែនកើតមកអំពីកម្ម មិនមែនកើតមកអំពីកម្ម ក៏មិនមែន) ។

រូប ដែលកើតហើយអំពីចិត្ត ឈ្មោះថា ចិត្តជរូប, រូបដែលកើត



ហើយអំពីបច្ច័យនៃកម្មជដទៃអំពីចិត្តជរូបនោះ ឈ្មោះថា អចិត្តរូប, រូប ដែលមិនមែនកើតមកអំពីអ្វីមួយទេ ឈ្មោះថា នេវចិត្តជនាចិត្តជរូប (មិនមែនកើតអំពីចិត្ត ក៏មិនមែន) ។

រូប ដែលកើតហើយពីអាហារ ឈ្មោះថា អាហារជរូប, រូប ដែលកើតមកហើយ អំពីបច្ច័យនៃកម្មជដទៃ អំពីអាហារជរូបនោះ ឈ្មោះថា អនាហារជរូប, រូបដែលមិនមែនកើតអំពីអ្វីមួយទេ ឈ្មោះថា នេវ-អាហារជនអនាហារជរូប (មិនមែនកើតអំពីអាហារ ក៏មិនមែន) ។

រូប ដែលកើតអំពីរដូវ ឈ្មោះថា ឧតុជរូប, រូប ដែលកើតអំពីបច្ច័យនៃកម្មជដទៃអំពីរដូវនោះ ឈ្មោះថា អនុតុជរូប, រូប ដែលមិនមែនកើតអំពីអ្វីមួយទេ ឈ្មោះថា នេវឧតុជនអនុតុជរូប (មិនមែនកើតអំពីរដូវក៏មិនមែន) ។

រូបមាន ៣ ប្រការ ដោយអំណាចនៃតិកៈ មានកម្មជាទិតិកៈជាដើម ដូចរៀបរាប់មកនេះឯង ។

(រូប ៤)

(២៨៤) រូប មាន ៤ ប្រការទៀត ដោយអំណាចប្រមាណ ៤ នៃទិដ្ឋាទិរូប, រូបាទិរូប, វត្ថាទិរូប ។

ជាបឋម គប្បីជ្រាបរូប ៤ ប្រការ ដោយអំណាចនៃទិដ្ឋាទិចតុក្កៈ យ៉ាងនេះ គឺ បណ្តារូបទាំងឡាយនោះ រូបាយតនៈ ឈ្មោះថា ទិដ្ឋរូប ព្រោះភាវៈនៃរូបនោះ ជាអារម្មណ៍នៃការឃើញ, សទ្ទាយតនរូប ឈ្មោះថា សុតរូប ព្រោះភាវៈនៃរូបនោះ ជាអារម្មណ៍នៃការស្តាប់, ប្រជុំ ៣ នៃក្លិន, រស និង ផោដ្ឋព្វៈ ឈ្មោះថា មុតរូប ព្រោះភាវៈនៃរូបនោះ ជាអារម្មណ៍នៃឥន្ទ្រិយសំរាប់កាន់យក នូវអារម្មណ៍ដែលដល់ព្រមហើយ,

រូបដ៏សេស ឈ្មោះថា វិញ្ញត្តិរូប ព្រោះជាវិស័យនៃវិញ្ញាណទុំះឯង ។

ចំណែករូប ៤ យ៉ាង ដោយអំណាចនៃរូបរូបាទិចតុក្កៈ គប្បីជ្រាបយ៉ាងនេះ គឺ បណ្ដារូបទាំងនេះ និប្ផន្នរូប ហៅថា រូបរូប, អាកាសធាតុ ហៅថា បរិច្ឆេទរូប, រូប មានកាយវិញ្ញត្តិជាដើម មានភាវៈគួរដល់ការងារ ជាទីបំផុត ហៅថា វិការរូប, ជាតិ, ជរា និង មរណៈ ហៅថា លក្ខណរូប ។

ចំណែក រូប ៤ យ៉ាង ដោយអំណាចនៃវត្ថាទិចតុក្កៈ គប្បីជ្រាបយ៉ាងនេះ គឺ បណ្ដារូបទាំងនេះ រូបណា ឈ្មោះថា ហទយរូប, រូបនោះ ជាវត្ថុរូប មិនមែនជាទ្វាររូបទេ, វិញ្ញត្តិរូបពីរ ជាទ្វាររូប មិនមែនជាវត្ថុរូបទេ, បសាទរូប ជាវត្ថុរូបផង ជាទ្វាររូបផង, រូបក្រៅអំពីនេះ ជាវត្ថុរូប ក៏មិនមែន, ជាទ្វាររូប ក៏មិនមែនដែរ ។

(រូប ៥)

រូប មាន ៥ យ៉ាងទៀត ដោយអំណាចនៃរូបទាំងឡាយនេះ ដូច្នេះ គឺ រូប ជាឯករូប, ទ្វិជរូប, តិជរូប, ចតុជរូប និង រូបដែលមិនកើតអំពីអ្វីមួយ ។

បណ្ដារូបទាំង ៥ យ៉ាងនោះ រូបដែលកើតអំពីកម្ម និង កើតអំពីចិត្តតែម្យ៉ាង ឈ្មោះថា ឯកជរូប ។ បណ្ដារូបដែលកើតអំពីកម្ម និង កើតអំពីចិត្តទាំងនោះ ឥន្ទ្រិយរូបមួយអន្លើដោយហទយវត្ថុ ជាកម្មជរូប (រូបដែលកើតអំពីកម្មតែម្យ៉ាង) ។ វិញ្ញត្តិរូប ២ ជា ចិត្តជរូប (រូបដែលកើតអំពីចិត្តតែម្យ៉ាង) ។

ក៏រូបឯណា កើតអំពីចិត្តផង អំពីរដូវផង, រូបនោះ ឈ្មោះថា ទ្វិជរូប, ទ្វិជរូបនោះ បានដល់ សទ្ទាយតនៈហ្នឹងឯង ។ រូបណា ដែល



កើតអំពីរដូវ ចិត្ត និង អាហារទាំងឡាយ, រូបនោះ ឈ្មោះថា តិជរូប, ក៏តិជរូបនោះ បានដល់ វិការរូប ៣ មានលហុតារូបជាដើមហ្នឹងឯង ។

រូបណា កើតហើយអំពីបច្ច័យទាំង ៤ មានកម្មជាដើម, រូបនោះ ឈ្មោះថា ចតុជរូប, ចតុជរូបនោះ ជារូបដ៏សេសវៀរចាកលក្ខណរូប ។ ឯលក្ខណរូប មិនមែនកើតអំពីអ្វីមួយឡើយ ។

សួរថា : ព្រោះហេតុអ្វី? ។ ឆ្លើយថា : ព្រោះការកើតឡើងនៃឧប្បាទៈ មិនដែលមាន, មួយទៀត ប្រជុំពីរ នៃរូបក្រៅពីនេះ គ្រាន់តែជាការចាស់គ្រាំគ្រា និង ការបែកធ្លាយទៅ នៃរូបដែលកើតឡើងហើយតែប៉ុណ្ណោះ ។ សូម្បីភាវៈនៃជាតិកើតហើយអំពីបច្ច័យណាមួយ ដែលលោកអនុញ្ញាតហើយ ក្នុងបាលី មានជាអាទិ៍ ថា : “ធម៌ទាំងឡាយ គឺ រូបាយតនៈ ១, សទ្ទាយតនៈ ១, គន្ធាយតនៈ ១, រសាយតនៈ ១, ផោដ្ឋព្វាយតនៈ១, អាកាសាយតនៈ១, អាបោធាតុ១, រូបស្សលហុតា១, រូបស្ស មុទុតា ១, រូបស្ស កម្មញ្ញតា ១, រូបស្ស ឧបចយោ ១, រូបស្ស សន្តតិ ១, កវឡិង្ការាហារ ១, ទាំងនេះ មានចិត្តជាសមុដ្ឋាន” ដូច្នេះ បណ្ឌិត គប្បីជ្រាបថា ដែលលោកអនុញ្ញាតហើយ ព្រោះជនកបច្ច័យនៃរូបទាំងឡាយ ប្រាកដហើយ ក្នុងលក្ខណៈ គឺអានុភាពនៃកិច្ច ។

នេះ ជាប្រធាននៃការពណ៌នា ដោយពិស្ដារ ក្នុងរូបក្ខន្ធ ជាដំបូង ។

(នាមក្ខន្ធ ៤)

(២៨៥) ក៏សេចក្ដីវិនិច្ឆ័យ ក្នុងខន្ធទាំងឡាយក្រៅពីនេះ (បណ្ឌិតគប្បីជ្រាប ដូចតទៅ) ។ ធម្មជាតិណាមួយ មានការទទួលនូវអារម្មណ៍ ជាលក្ខណៈ, វេទនាខន្ធ គឺបណ្ឌិតគប្បីជ្រាប ព្រោះធ្វើនូវធម្មជាតិនោះទាំងអស់ក្នុងទីជាមួយគ្នា ។ ធម្មជាតិណាមួយ មានការដឹង ជាលក្ខណៈ,

សញ្ញាខន្ធ គឺបណ្ឌិត គប្បីជ្រាប ព្រោះធ្វើនូវធម្មជាតទាំងអស់នោះ ក្នុងទីជាមួយគ្នា ។ ធម្មជាតណាមួយ មានការតាក់តែង ជាលក្ខណៈ, សង្ខារក្ខន្ធ គឺបណ្ឌិត គប្បីជ្រាប ព្រោះធ្វើនូវធម្មជាតទាំងអស់នោះ ក្នុងទីជាមួយគ្នា ។ ធម្មជាតណាមួយ មានការដឹងច្បាស់ ជាលក្ខណៈ, វិញ្ញាណក្ខន្ធ គឺបណ្ឌិត គប្បីជ្រាប ព្រោះធ្វើនូវធម្មជាតទាំងអស់នោះ ក្នុងទីជាមួយគ្នា ។

បណ្ដាខន្ធទាំង ៤ នោះ កាលបើវិញ្ញាណក្ខន្ធ គឺបុគ្គលដឹងច្បាស់ហើយ, ធម៌ទាំងឡាយ មានខន្ធជាដើមក្រៅនេះ ងាយយល់ទេ ព្រោះហេតុណា, ព្រោះហេតុនោះ យើងនឹងធ្វើនូវសេចក្ដីអធិប្បាយ ចាប់ផ្ដើមអំពីវិញ្ញាណក្ខន្ធជាដើម (ដូចតទៅនេះ) ។

(វិញ្ញាណក្ខន្ធ)

ក៏ពាក្យថា “ធម្មជាត ឯណាមួយ មានការដឹងច្បាស់ ជាលក្ខណៈ វិញ្ញាណក្ខន្ធ គឺបណ្ឌិត គប្បីជ្រាប ព្រោះធ្វើនូវធម្មជាតទាំងអស់នោះ ក្នុងទីជាមួយគ្នា” ដូច្នេះ ព្រះអដ្ឋកថាចារ្យ ពោលទុកហើយ ។ សួរថា: ធម្មជាត មានកាដើងច្បាស់ជាលក្ខណៈ ឈ្មោះថា វិញ្ញាណ តើយ៉ាងដូចម្ដេច ? ។ ឆ្លើយថា : ធម្មជាត មានការដឹងច្បាស់ ជាលក្ខណៈ ឈ្មោះថា វិញ្ញាណ ។ ដូចជាព្រះសារីបុត្តត្ថេរ ពោលហើយថា : ម្នាលអាវុសោ ! ព្រោះធម្មជាតដែលដឹងច្បាស់ ដឹងប្រាកដ ហេតុនោះឯងធម្មជានោះ ទើបឲ្យឈ្មោះថា វិញ្ញាណ ។ (បើពោល) តាមអត្ថ ស័ព្ទថា“ វិញ្ញាណ, ចិត្ត, មនៈ” នេះ ជាពាក្យតែមួយ ។ វិញ្ញាណនេះនោះ មានតែមួយ តាមសភាវៈ ព្រោះមានការដឹងច្បាស់ ជាលក្ខណៈ, មានបីយ៉ាង គឺ កុសល, អកុសល និង អព្យាកតៈ ដោយអំណាយនៃជាតិ ។



(កុសលវិញ្ញាណ)

(២៨៦) បណ្ដាវិញ្ញាណទាំង ៣ យ៉ាងនោះ កុសលវិញ្ញាណ ចែកតាមភូមិ មាន ៤ យ៉ាង គឺ កាមាវចរភូមិ ១, រូបាវចរភូមិ ១, អរូបាវចរភូមិ ១, លោកុត្តរភូមិ ១ ។ បណ្ដាភូមិទាំងឡាយ ៤ យ៉ាងនោះ កាមាវចរភូមិ មាន ៨ ប្រការ ដោយញែកតាមសោមនស្ស, ឧបេក្ខា, ញាណ និង សង្ខារ ។ តើកាមាវចរភូមិ ៨ នេះ គឺដូចម្ដេចខ្លះ ? ។

(បានដល់ កុសលចិត្ត មាន ៨ យ៉ាង គឺ)

-សោមនស្សសហគតញាណសម្បយុត្ត អសង្ខារិក កុសលចិត្ត ប្រកបដោយសោមនស្សវេទនា និង ព្រមដោយប្រាជ្ញា មិនប្រកបដោយសង្ខារ គឺ មិនមានបុគ្គលដឹកនាំ (ក្លៀវក្លាដោយទំនើងខ្លួនឯង) ។

-សោមនស្សសហគតញាណសម្បយុត្ត សសង្ខារិក កុសលចិត្ត ប្រកបដោយសោមនស្សវេទនា និង ព្រមដោយប្រាជ្ញា ប្រកបដោយសង្ខារ គឺ មានបុគ្គលដឹកនាំ (មិនក្លៀវក្លាដោយទំនើងខ្លួនឯង) ។

-សោមនស្សសហគតញាណវិប្បយុត្ត អសង្ខារិក កុសលចិត្ត ប្រកបដោយសោមនស្សវេទនា តែប្រាសចាកប្រាជ្ញាមិនប្រកបដោយសង្ខារ ។

-សោមនស្សសហគតញាណវិប្បយុត្ត សសង្ខារិក កុសលចិត្ត ប្រកបដោយសោមនស្សវេទនា តែប្រាសចាកប្រាជ្ញា ប្រកបដោយសង្ខារ ។

-ឧបេក្ខាសហគតញាណសម្បយុត្ត អសង្ខារិក កុសលចិត្ត ប្រកបដោយឧបេក្ខាវេទនា និង ព្រមដោយប្រាជ្ញា មិនប្រកបដោយសង្ខារ ។

-ឧបេក្ខាសហគតញាណសម្បយុត្ត សសង្ខារិក កុសលចិត្ត ប្រកបដោយឧបេក្ខាវេទនា និង ព្រមដោយប្រាជ្ញា ប្រកបដោយសង្ខារ ។

-ឧបេក្ខាសហគតញាណវិប្បយុត្ត អសង្ខារិក កុសលចិត្ត ប្រកបដោយ

ឧបេក្ខាវេទនា តែប្រាសចាកប្រាជ្ញា មិនប្រកបដោយសង្ខារ ។

-ឧបេក្ខាសហគតញាណវិប្បយុត្ត សសង្ខារិក កុសលចិត្ត ប្រកបដោយឧបេក្ខាវេទនា តែប្រាសចាកប្រាជ្ញា ប្រកបដោយសង្ខារ ។

សេចក្តីថា ក្នុងពេលណា បុគ្គលមានចិត្តត្រេកអរ រីករាយហើយ ព្រោះអាស្រ័យ នូវការដល់ព្រមដោយខណៈ មានទេយ្យធម៌ និង បដិគ្គាហកៈជាដើមផង នូវហេតុនៃសោមនស្សដទៃផង កាលធ្វើនូវសម្មាទិដ្ឋិ ឲ្យប្រព្រឹត្តទៅ ដោយន័យមានជាអាទិ៍ថា "ទាន ដែលបុគ្គលឲ្យហើយ រមែងមានផល" ដូច្នេះ ឲ្យជាត្រីមុខ មិនរួញថយ មិនចាំបាច់គឺជនទាំងឡាយដទៃជាស់តឿនឡើយ ហើយធ្វើនូវបុណ្យទាំងឡាយមានទានជាដើម, ក្នុងពេលនោះ ចិត្តរបស់បុគ្គលនោះ ជាសោមនស្សសហគតញាណសម្បយុត្ត អសង្ខារិក ។ ប៉ុន្តែក្នុងពេលណា បុគ្គលមានចិត្តត្រេកអររីករាយហើយ ធ្វើនូវសម្មាទិដ្ឋិ ឲ្យប្រព្រឹត្តទៅ ក្នុងខាងមុខ ដោយន័យដែលបានពោលហើយ កាលរួញថយផង ជនទាំងឡាយដទៃជាស់តឿនផង ដោយអំណាចនៃសទ្ធា មានសភាវៈនៃបុគ្គលមានចាគៈមិនលះបង់ស្រឡះហើយទើបធ្វើ, ក្នុងពេលនោះ ចិត្តនោះឯងរបស់បុគ្គលនោះ ឈ្មោះថា ជាចិត្តប្រកបដោយសង្ខារ ។

ក៏ក្នុងសេចក្តីនេះ ពាក្យនេះថា "សង្ខារ" ជាឈ្មោះនៃប្រយោគខាងដើម ដែលប្រព្រឹត្តទៅ ដោយអំណាចនៃខ្លួនក្តី នៃជនទាំងឡាយដទៃក្តី ។ ម្យ៉ាងទៀត ក្នុងពេលណា ពួកក្មេងតូចៗ មានការថ្នឹកអំពីកំណើត ដោយសារការឃើញសេចក្តីបដិបត្តិ នៃជនជាញាតិ ឃើញភិក្ខុទាំងឡាយ មានសេចក្តីសោមនស្សកើតឡើង តែងប្រគេនវត្ថុបន្តិចបន្តួច ដែលខ្លួនមានក្នុងដៃក្តី ថ្វាយបង្គំក្តី ដោយប្រញាប់ប្រញាល់, ក្នុង



ពេលនោះ ចិត្ត ទី៣ រមែងកើតឡើង ដល់ក្មេងតូចទាំងឡាយនោះ ។ តែក្មេងទាំងឡាយ ដែលពួកញាតិជាស់តឿនថា : អ្នកទាំងឡាយ ចូរឲ្យ(ទាន) ចូរថ្វាយបង្គំហើយ ប្រតិបត្តិ យ៉ាងនេះ ក្នុងកាលណា, ចិត្តទី៤ រមែងកើតឡើង ដល់ក្មេងទាំងនោះ ក្នុងកាលនោះ ។

ចំណែកជនទាំងឡាយ ជាអ្នកប្រាសចាកសោមនស្ស ក្នុងហេតុទាំងឡាយ ៤ ព្រោះអាស្រ័យនូវការមិនដល់ព្រម ដោយខណៈ មានទេយ្យធម៌ និង បដិគ្គាហកៈជាដើមក្តី នូវការមិនមាននៃហេតុ របស់សោមនស្សទាំងឡាយដទៃក្តី ក្នុងកាលណា, ឧបេក្ខាសហគតចិត្តទាំងឡាយ ៤ ដ៏សេស រមែងកើតឡើង ក្នុងកាលនោះ ដូច្នេះឯង ។

កាមាវចរកុសលចិត្ត មាន ៨ ប្រការ បណ្ឌិតគប្បីជ្រាប ដោយការផ្សេងនៃសោមនស្ស, ឧបេក្ខា, ញាណ និង សង្ខារ ដូចពោលនេះ ។

ចំណែករូបាវចរកុសល មាន ៥ ដោយការញែក ព្រោះប្រកបដោយអង្គឈាន ។ សួរថា : តើរូបាវចរកុសល ៥ ដូចម្តេចខ្លះ ? ។ ឆ្លើយថា : រូបាវចរកុសល ៥ នោះ គឺ កាមាវចរកុសល ទី១ ប្រកបដោយវិតក្កៈ, វិចារៈ, បីតិ, សុខៈ និង សមាធិ, កាមាវចរកុសល ទី២ រំលងវិតក្កចេញ, តពីនោះ កាមាវចរកុសលទី៣ រំលងវិចារៈ, តពីនោះ កាមាវចរកុសល ទី៤ រំលងបីតិ, កាមាវចរកុសល ទី៥ មានសេចក្តីសុខអស់ហើយ ប្រកបដោយឧបេក្ខា និង សមាធិ ។

អរូបាវចរកុសល មាន ៤ ប្រការ ដោយអំណាចនៃការប្រកបនៃអារុប្បទាំងឡាយ ៤ ។ គឺថា អារុប្ប ទី១ ប្រកបព្រមហើយដោយអាកាសានញ្ចាយតនជ្ឈាន មានប្រការដែលលោកពោលហើយ, អារុប្ប ទី២ ទី៣ និង ទី៤ ទាំងឡាយ (ប្រកបព្រមហើយ) ដោយឈាន

ទាំងឡាយ មានវិញ្ញាណញ្ចាយតនជ្ឈានជាដើម ។ លោកុត្តរកុសល មាន ៤ ប្រការ ដោយការប្រកបដោយមគ្គ ៤ ដូច្នេះឯង ។ វិញ្ញាណជាកុសលហ្នឹងឯង មាន ២១ ប្រការ ដូចរៀបរាប់មកនេះឯង ជាបឋម ។

(អកុសលវិញ្ញាណ)

(២៨៧) បើពោលតាមភូមិ អកុសលវិញ្ញាណ មាន ១ ប្រការ គឺ កាមាវចរតែម្យ៉ាង ។ (បើពោល) តាមមូល អកុសល មាន ៣ យ៉ាង គឺ លោភមូល ១, ទោសមូល ១, មោហមូល ១ ។

បណ្ដាអកុសលមូលទាំងនោះ លោភមូល មាន ៨ យ៉ាង គឺ : សោមនស្ស, ឧបេក្ខា, ទិដ្ឋិគតៈ និង សង្ខារ ។ លោភមូល ៨ យ៉ាង នេះ តើដូចម្ដេចខ្លះ ? ។ លោភមូល ៨ យ៉ាងនោះ គឺ :

១- សោមនស្សសហគតទិដ្ឋិគតសម្បយុត្ត អសង្ខារិក អកុសលចិត្ត ប្រកបដោយសោមនស្ស ប្រព្រឹត្តទៅមួយអន្លើដោយសេចក្ដីយល់ខុស មិនប្រកបដោយសង្ខារ គឺមិនមានបុគ្គលដឹកនាំ (ក្បៀវក្លា ដោយទំនើងខ្លួនឯង) ។

២- សោមនស្សសហគតទិដ្ឋិគតសម្បយុត្ត សសង្ខារិក អកុសលចិត្ត ប្រកបដោយសោមនស្ស ប្រព្រឹត្តទៅមួយអន្លើដោយសេចក្ដីយល់ខុស ប្រកបដោយសង្ខារ ។

៣- សោមនស្សសហគតទិដ្ឋិគតវិប្បយុត្ត អសង្ខារិក អកុសលចិត្ត ប្រកបដោយសោមនស្ស មិនប្រព្រឹត្តទៅជាមួយនឹងការយល់ខុស មិនមានបុគ្គលដឹកនាំ ។

៤- សោមនស្សសហគតទិដ្ឋិគតវិប្បយុត្ត សសង្ខារិក អកុសលចិត្ត ប្រកបដោយសោមនស្ស មិនប្រព្រឹត្តទៅ ជាមួយនឹងការយល់ខុស



គឺមានបុគ្គលដឹកនាំ ។

៥- ឧបេក្ខាសហគតទិដ្ឋិគតសម្បយុត្ត អសង្ខារិក អកុសលចិត្ត ប្រកបដោយឧបេក្ខាវេទនា ប្រកបដោយការយល់ខុស មិនប្រកបដោយសង្ខារ គឺមិនមានបុគ្គលដឹកនាំ ។

៦- ឧបេក្ខាសហគតទិដ្ឋិគតសម្បយុត្ត សសង្ខារិក អកុសលចិត្ត ប្រកបដោយឧបេក្ខាវេទនាប្រកបដោយការយល់ខុស គឺមានគេដឹកនាំ ។

៧- ឧបេក្ខាសហគតទិដ្ឋិគតវិប្បយុត្ត អសង្ខារិក អកុសលចិត្ត ប្រកបដោយឧបេក្ខាវេទនា មិនប្រកបដោយការយល់ខុស គឺមិនមានបុគ្គលដឹកនាំ ។

៨- ឧបេក្ខាសហគតទិដ្ឋិគតវិប្បយុត្ត សសង្ខារិក អកុសលចិត្ត ប្រកបដោយឧបេក្ខាវេទនា មិនប្រកបដោយការយល់ខុស គឺប្រកបដោយសង្ខារ ។

សេចក្ដីថាៈ បុគ្គល មានចិត្តត្រេកអររីករាយហើយ ធ្វើនូវមិច្ឆាទិដ្ឋិឲ្យប្រព្រឹត្តទៅ ក្នុងខាងមុខ ដោយន័យមានន័យថា “ទោស ក្នុងកាមទាំងឡាយមិនមាន” ដូច្នេះជាដើម ហើយបរិភោគនូវកាមទាំងឡាយក្តី ជឿនូវមង្គលទាំងឡាយ មានទិដ្ឋមង្គលជាដើម ដោយថា ជារបស់មានខ្លឹមសារក្តី មានចិត្តឥតមានបុគ្គលជាស់តឿន ក្បៀវក្លា តាមទំនើងខ្លួនឯង ក្នុងកាលណា, អកុសលចិត្តជាដំបូង រមែងកើតឡើង ក្នុងកាលនោះ ។ បុគ្គល មានចិត្តនៅទន់ជ្រាយ មានបុគ្គលដទៃជាស់តឿន ក្នុងកាលណា, អកុសលចិត្តទីពីរ រមែងកើតឡើង ក្នុងកាលនោះ ។

បុគ្គល មិនធ្វើនូវមិច្ឆាទិដ្ឋិ ឲ្យប្រព្រឹត្តទៅខាងមុខ គ្រាន់តែមានចិត្តរីករាយ ត្រេកអរហើយតែប៉ុណ្ណោះ សេពនូវមេថុនធម្មក្តី សម្លឹងរំពៃនូវ

សម្បត្តិអ្នកដទៃក្តី លួចយកទ្រព្យសម្បត្តិអ្នកដទៃក្តី មានចិត្តឥតមានបុគ្គលជាស់តឿនក្មៀវក្លាដោយទំនើងខ្លួនឯង ក្នុងកាលណា, អកុសលចិត្តទីបី (រមែងកើតឡើង) ក្នុងកាលនោះ ។ បុគ្គល មានចិត្តទន់ជ្រាយ មានគេជាស់តឿន ក្នុងកាលណា, អកុសលចិត្តទីបួន (រមែងកើតឡើង) ក្នុងកាលនោះ ។

ក៏ក្នុងកាលណា បុគ្គលទាំងឡាយ ជាអ្នកប្រាសចាកសោមនស្ស ក្នុងហេតុទាំងឡាយ ៤ ព្រោះអាស្រ័យនូវការមិនដល់ព្រម នៃកាមទាំងឡាយក្តី ព្រោះមិនមាននៃហេតុរបស់សោមនស្សទាំងឡាយដទៃក្តី ឧបេក្ខាសហគតចិត្តទាំងឡាយ ៤ ដ៏សេស រមែងកើតឡើង ក្នុងកាលនោះ ដូច្នេះឯង ។

លោភមូល មាន ៨ យ៉ាង គឺបណ្ឌិតគប្បីជ្រាប ដោយកិរិយាផ្សេងគ្នា នៃសោមនស្ស, ឧបេក្ខា, ទិដ្ឋិគតៈ និង សង្ខារ យ៉ាងនេះឯង ។

ចំណែកខាង ទោសមូល ប្រព្រឹត្តទៅមួយអន្លើដោយទោមនស្ស ប្រកបព្រមដោយសេចក្តីថ្នាំងថ្នាក់ មានតែ ២ ប្រការប៉ុណ្ណោះឯង គឺ អសង្ខារិក ១, សសង្ខារិក ១ ។ ការកើតឡើងនៃទោសមូលចិត្តនោះ គប្បីជ្រាប ក្នុងកាលជាទីប្រព្រឹត្តទៅនៃចិត្តដ៏ក្មៀវក្លា និង ចិត្តដ៏ទន់ ក្នុងអកុសលកម្មទាំងឡាយ មានបាណាតិបាតជាដើម ។

មោហមូល ប្រព្រឹត្តទៅមួយអន្លើដោយឧបេក្ខា មាន ២ ប្រការ គឺ សម្បយុត្តដោយវិចិកិច្ឆា ១, សម្បយុត្តដោយឧទ្ធច្ចៈ ១ ។ រឿងរ៉ាវនៃមោហមូលចិត្តនោះ គប្បីជ្រាប ក្នុងកាលនៃកិរិយាមិនចូលចិត្ត និង កិរិយារាយមាយ (នៃចិត្ត) ដូច្នេះឯង ។

អកុសលវិញ្ញាណ មាន ១២ ប្រការ ដូចបានពោលមកនេះឯង ។



(អព្យាកតវិញ្ញាណ)

(២៨៨) អព្យាកតវិញ្ញាណ (បើ) ចែកតាមជាតិ មាន ២ ប្រការ គឺ វិបាក ១, កិរិយា ១ ។ បណ្តាអព្យាកតចិត្តទាំងនោះ វិបាក(បើចែក) តាមភូមិ មាន ៤ យ៉ាង គឺ កាមាវចរភូមិ ១, រូបាវចរភូមិ ១, អរូបាវចរភូមិ ១, លោកុត្តរភូមិ ១ ។ បណ្តាភូមិទាំងឡាយ ៤ នោះ កាមាវចរភូមិ មាន ២ យ៉ាង គឺ កុសលវិបាក ១, អកុសលវិបាក ១ ។

(កាមាវចរកុសលវិបាក)

ឯកុសលវិបាក ក៏មាន២ យ៉ាងដែរ គឺអហេតុកៈ១, សហេតុកៈ១។ បណ្តាកុសលវិបាកទាំង ២ នោះ វិញ្ញាណ ប្រាសហើយចាកហេតុ មានវិបាក មានអលោភៈជាដើម ឈ្មោះថា អហេតុកៈ ។ អហេតុកនោះ មាន ៨ យ៉ាង គឺ ចក្ខុវិញ្ញាណ ១, សោតវិញ្ញាណ ១, ឃានវិញ្ញាណ ១, ជិវ្ហាវិញ្ញាណ ១, កាយវិញ្ញាណ ១, មនោវិញ្ញាណធាតុ ដែលមាននាទីទទួលនូវអារម្មណ៍ ១, មនោវិញ្ញាណធាតុទាំង ២ ដែលមាននាទីពិចារណានូវអារម្មណ៍ជាដើម ។

បណ្តាអហេតុកវិបាក ៨ ប្រការនោះ ចក្ខុវិញ្ញាណ មានការអាស្រ័យនូវចក្ខុហើយ ដឹងច្បាស់នូវរូប ជាលក្ខណៈ, មានអារម្មណ៍ត្រឹមតែរូប ជាកិច្ច, មានភាវៈចំពោះមុខនៃរូប ជាផល, មានកិរិយាប្រាសចាកទៅនៃកិរិយាមនោធាតុ ដែលមានរូបជាអារម្មណ៍ ជាហេតុ ។

សោតវិញ្ញាណ, ឃានវិញ្ញាណ, ជិវ្ហាវិញ្ញាណ និង កាយវិញ្ញាណ ទាំងឡាយ មានការដឹងច្បាស់នូវអារម្មណ៍ មានសម្លេងជាដើម ដែលអាស្រ័យហើយ ក្នុងវិញ្ញាណ មានសោតវិញ្ញាណជាដើម ជាលក្ខណៈ, មានអារម្មណ៍ត្រឹមតែធ្វើ នូវសម្លេងជាដើម ជាកិច្ច, មានភាវៈនៃមុខឆ្ពោះ

ទៅរកអារម្មណ៍ មានសម្ទារម្មណ៍ជាដើមជាផល, មានកិរិយាទៅប្រាសចាកកិរិយាមនោធាតុ មានសម្ទារម្មណ៍ជាដើមជាអារម្មណ៍ ជាហេតុ ។

មនោធាតុ មានកិរិយាដឹងច្បាស់ នូវអារម្មណ៍ មានរូបជាដើម ក្នុងលំដាប់នៃវិញ្ញាណទាំងឡាយ មានចក្ខុវិញ្ញាណជាដើម ជាលក្ខណៈ, មានកិរិយាទទួលនូវអារម្មណ៍ មានរូបជាដើម ជាកិច្ច, មានភាវៈយ៉ាងនោះ ជាផល, មានកិរិយាទៅប្រាសចាកវិញ្ញាណ មានចក្ខុវិញ្ញាណជាដើម ជាកិច្ច ។

មនោវិញ្ញាណធាតុ មានសន្តីរណៈជាដើម ជាកិច្ច, ទាំងពីរប្រការ មានកិរិយាដឹងនូវអារម្មណ៍ទាំង៦ ជាលក្ខណៈ, បន្ទាប់ពីអហេតុកវិបាក មានសន្តីរណៈជាដើមជាកិច្ច, មានភាវៈយ៉ាងនោះជាផល, មានហទយ-វត្ថុជាហេតុ ។ ចំណែកខាង ប្រភេទនៃមនោវិញ្ញាណធាតុនោះ (មាន) ព្រោះកិរិយាប្រកបនូវសោមនស្ស និង ឧបេក្ខាផង ព្រោះកិរិយាផ្សេងគ្នា នៃទីតាំង ២ និង ៥ ផង ។ មែនពិត បណ្តាមនោវិញ្ញាណធាតុទាំង ២ នេះ មនោវិញ្ញាណធាតុ ១ ប្រកបព្រមដោយសោមនស្ស ព្រោះភាវៈប្រព្រឹត្តទៅ ក្នុងអារម្មណ៍ជាទីប្រាថ្នា ដោយចំណែក ១ ជាទ្វិដ្ឋានៈ (មានឋានៈ ២) ព្រោះកិរិយាប្រព្រឹត្តិទៅ ក្នុងបញ្ចទ្វារផង ក្នុងវិថីវិញ្ញាណ មានជវនៈទីបំផុតផង ដោយអំណាចនៃសន្តីរណៈ និង តទារម្មណៈ, មនោវិញ្ញាណធាតុ ១ ឈ្មោះថា ប្រកបព្រមហើយដោយឧបេក្ខា ព្រោះសភាវៈប្រព្រឹត្តទៅ ក្នុងអារម្មណ៍ជាកណ្តាលគួរជាទីប្រាថ្នាជាបញ្ចដ្ឋាន (ជាមនោវិញ្ញាណធាតុ មានស្ថាន ៥) ព្រោះកិរិយាប្រព្រឹត្តិទៅដោយអំណាចនៃសន្តីរណៈ, តទារម្មណ៍, បដិសន្ធិ ភវង្គ និង ចុតិ ។

ម្យ៉ាងវិញទៀត អហេតុកវិបាកវិញ្ញាណនេះ មាន ៨ យ៉ាង, មាន



២ យ៉ាង ព្រោះភាវៈនៃអហេតុកវិបាកវិញ្ញាណ ជានិយតារម្មណ៍ ១ ជាអនិយតារម្មណ៍ ១, មាន ៣ យ៉ាង ដោយការផ្សេងគ្នានៃឧបេក្ខា, សុខ និង សោមនស្ស។ មែនពិត បណ្តាវិញ្ញាណទាំងនោះ វិញ្ញាណ ៥ ឈ្មោះថា និយតារម្មណ៍ ព្រោះកិរិយាប្រព្រឹត្តិទៅ ក្នុងអារម្មណ៍ទាំងឡាយ មានរូបជាដើមហ្នឹងឯងតាមលំដាប់, វិញ្ញាណដ៏សេស ឈ្មោះថា អនិយតារម្មណ៍ ។ ព្រោះបណ្តាវិញ្ញាណ ដែលជាអនិយតារម្មណ៍ទាំងនោះ មនោធាតុ ប្រព្រឹត្តទៅ ក្នុងអារម្មណ៍ទាំងឡាយ មានរូបជាដើមទាំង ៥, មនោវិញ្ញាណធាតុទាំង ២ ប្រប្រឹត្តទៅ ក្នុងអារម្មណ៍ទាំង ៦ ដូច្នេះឯង ។ ប៉ុន្តែបណ្តាវិញ្ញាណទាំង ៣ នេះ កាយវិញ្ញាណ ប្រកបដោយសេចក្តីសុខ ។ មនោវិញ្ញាណធាតុ ដែលជាទ្វិដ្ឋាន (មានឋាន ២) ប្រកបដោយសោមនស្ស ។ វិញ្ញាណដ៏សេស ប្រកបហើយ ដោយឧបេក្ខា ដូច្នេះឯង ។

កុសលវិញ្ញាណ ៨ ដែលជាអហេតុកៈ ក្នុងកុសលវិបាក បណ្ឌិតគប្បីជ្រាប ដូចបានពោលមកហើយនេះឯង ជាដំបូង ។

(កាមាវចរកុសលវិបាក)

(២៨៩) ចំណែកអព្យាកតវិញ្ញាណ ដែលប្រកបដោយវិបាកហេតុ មានអលោភៈជាដើម ឈ្មោះថា សហេតុកៈ ។ កុសលវិបាក ដែលជាសហេតុកៈនោះ មាន ៨ ប្រការ ដោយកិរិយាផ្សេងគ្នា មានសោមនស្សជាដើម ដូចជាកាមាវចរកុសលវិញ្ញាណ ។ តែសហេតុកអព្យាកតៈនេះ មិនប្រព្រឹត្តទៅ ដូចជាកុសលវិញ្ញាណ ដែលប្រព្រឹត្តទៅ ក្នុងអារម្មណ៍ទាំង ៦ ដោយអំណាចនៃបុញ្ញកិរិយាវត្ថុទាំងឡាយ មានទានជាដើមឡើយ ។ ក៏សហេតុកអព្យាកតវិញ្ញាណនេះ ប្រព្រឹត្តទៅ ក្នុងអារម្មណ៍

ទាំង ៦ ដែលរាប់បញ្ចូលក្នុងបរិតធម៌ គឺកាមាវចរៈតែប៉ុណ្ណោះ ដោយអំណាច នៃ (កិច្ចគឺ) បដិសន្ធិ, ភវង្គ, ចុតិ និង តទារម្មណ៍ ។

ចំណែកក្នុងសហេតុកអព្យាកតវិញ្ញាណនេះ ភាវៈនៃកុសលវិញ្ញាណជាសសង្ខារិក និង អសង្ខារិក បណ្ឌិត គប្បីជ្រាប ដោយអំណាចនៃហេតុមានអាគមន៍ជាដើម ។ មួយទៀត កាលបើសេចក្ដីដ៏វិសេសនៃសម្បយុត្តធម៌ទាំងឡាយសូម្បីមិនមាន ក៏គប្បីជ្រាបថា វិបាកវិញ្ញាណមិនមានសេចក្ដីខ្នះខ្នែង ដូចស្រមោលមុខ ក្នុងទីទាំងឡាយមានផ្ទៃកញ្ចក់ជាដើម, កុសលវិញ្ញាណ ប្រកបដោយសេចក្ដីខ្នះខ្នែង ដូចជាមុខ ។

## (កាមាវចរអកុសលវិបាក)

ចំណែកអកុសលវិបាកវិញ្ញាណ គឺជាអហេតុកៈ តែប៉ុណ្ណោះឯង ។ អកុសលវិបាកវិញ្ញាណ ដែលជាអហេតុកៈនោះ មាន ៧ ប្រការ គឺ ចក្ខុវិញ្ញាណ ១, សោតវិញ្ញាណ ១, ឃានវិញ្ញាណ ១, ជិវ្ហាវិញ្ញាណ ១, កាយវិញ្ញាណ១, មនោធាតុ មានការទទួលរង ជាកិច្ច១, មនោវិញ្ញាណធាតុ មានឋានៈ ៥ មានការពិចារណាជាដើម ជាកិច្ច១ ។ (បើពោល) តាមលក្ខណៈជាដើម អកុសលវិបាកជាអហេតុក ៧ នោះ បណ្ឌិតគប្បីជ្រាប តាមន័យដែលបានពោលហើយ ក្នុងកុសលអហេតុកវិបាក ។ តែកុសលវិបាកទាំងឡាយ មានអារម្មណ៍ជាទីប្រាថ្នា និង អារម្មណ៍ជាកណ្ដាលតែប៉ុណ្ណោះ ។ អកុសលវិបាកទាំងឡាយនេះ មានអារម្មណ៍មិនជាទីប្រាថ្នា និង អារម្មណ៍ជាកណ្ដាល ។

ក៏អកុសលវិបាកវិញ្ញាណទាំងឡាយនេះ មាន ៣ ប្រការ ផ្សេងដោយឧបេក្ខា, សុខ និង សោមនស្ស ។ អកុសលវិបាកទាំងឡាយនេះ មាន ២ ប្រការ ដោយអំណាចនៃទុក្ខ និង ឧបេក្ខា ។ ក៏បណ្ដា



អកុសលវិបាកវិញ្ញាណ មាន ២ ប្រការនេះ កាយវិញ្ញាណ ប្រព្រឹត្តទៅមួយអន្លើដោយទុក្ខហ្នឹងឯង, វិញ្ញាណទាំងឡាយដ៏សេស ប្រព្រឹត្តទៅមួយអន្លើដោយឧបេក្ខា ។ ក្នុងអកុសលវិបាកវិញ្ញាណទាំងនោះ ឧបេក្ខានោះ ដ៏ថោកទាប មិនក្លៀវក្លាពេក ដូចជាទុក្ខទេ ។ ឧបេក្ខា ក្នុងកុសលវិបាកវិញ្ញាណ ក្រៅអំពីនេះ ដ៏ប្រណីត មិនក្លៀវក្លាពេកទេ ដូចជាសេចក្ដីសុខ ។

កាមាវចរវិបាកវិញ្ញាណ មាន ២៣ ប្រការ ដោយអំណាចនៃអកុសលវិបាកទាំងឡាយ ៧ នេះផង នៃកុសលវិបាកទាំងឡាយ ១៦ មានពួដ៏ខាងដើមផង យ៉ាងដូច្នេះឯង ។

## (រូបាវចរ, អរូបាវចរ និង លោកុត្តរវិបាក)

ចំណែករូបាវចរវិបាកវិញ្ញាណ មាន ៥ យ៉ាង ដូចជាកុសលវិញ្ញាណដែរ ។ ចំណែកខាងកុសលវិញ្ញាណ ប្រព្រឹត្តទៅ ក្នុងជវនវិថីដោយអំណាចនៃសមាបត្តិ ។ រូបាវចរវិបាកនេះ (ប្រព្រឹត្តទៅ) ដោយអំណាចនៃបដិសន្ធិ, ភវង្គ និង ចុតិ ក្នុងឧបបត្តិភព ។

ក៏រូបាវចរវិញ្ញាណ មានយ៉ាងណា សូម្បីអរូបាវចរវិញ្ញាណ ក៏មាន ៤ យ៉ាង ដូចជាកុសល យ៉ាងនោះដែរ ។ ក៏ការផ្សេងគ្នានៃការប្រព្រឹត្តិទៅនៃអរូបាវចរវិបាកនោះ មានន័យដូចដែលលោកពោលហើយ ក្នុងរូបាវចរវិញ្ញាណហ្នឹងដែរ ។

លោកុត្តរវិបាក មាន ៤ យ៉ាង ព្រោះភាវៈនៃលោកុត្តរវិបាកមានផលចិត្តប្រកបដោយមគ្គ ៤ ។ លោកុត្តរវិបាកនោះ ប្រព្រឹត្តទៅ ដោយប្រការ ២ ដោយអំណាចនៃមគ្គវិថីផង ដោយអំណាចនៃផលសមាបត្តិផង ដូច្នេះឯង ។ វិបាកវិញ្ញាណទាំងអស់ហ្នឹង មាន ៣៦ ប្រការ ក្នុង

ភូមិទាំងឡាយ ៤ យ៉ាងនេះឯង ។

### (កិរិយាវិញ្ញាណ)

(២៩០) ចំណែកកិរិយាវិញ្ញាណ (បើ) ចែកតាមភូមិ មានបី យ៉ាង គឺ កាមាវចរវិញ្ញាណ ១, រូបាវចរវិញ្ញាណ ១, អរូបាវចរវិញ្ញាណ ១ ។ បណ្ដាភូមិទាំង ៣ យ៉ាងនោះ កាមាវចរវិញ្ញាណ មាន ២ យ៉ាង គឺ អហេតុកៈ ១, សហេតុកៈ ១ ។ បណ្ដាកាមាវចរវិញ្ញាណទាំង ២ នោះ កាមាវចរវិញ្ញាណ ដែលប្រាសហើយចាកកិរិយាហេតុ មានអលោភៈជាដើម ឈ្មោះថា អហេតុកៈ ។ អហេតុកញ្ញាណនោះ មាន២ យ៉ាង ដោយការបែងចែកជាមនោធាតុ និង មនោវិញ្ញាណធាតុ ។ បណ្ដាអហេតុក-ញ្ញាណទាំង២ នោះ មនោធាតុ មានការត្រាច់ទៅខាងមុខនៃចក្ខុវិញ្ញាណជាដើម និង ការដឹងច្បាស់នូវអារម្មណ៍មានរូបជាដើមជាលក្ខណៈ, មានការស្រាវជ្រាវរក ជាកិច្ច, មានភាវៈក្នុងទីចំពោះមុខអារម្មណ៍មានរូបជាដើម ជាផល, មានការផ្ដាច់បង់នូវភវង្គ ជាហេតុ ។ មនោធាតុនោះ ជាធម្មជាតប្រកបហើយ ដោយឧបេក្ខាប៉ុណ្ណោះ ។

ចំណែកមនោវិញ្ញាណធាតុ មាន ២ យ៉ាង គឺ : សាធារណៈ ១, អសាធារណៈ ១ ។ បណ្ដាមនោវិញ្ញាណធាតុទាំង ២ យ៉ាងនោះ មនោវិញ្ញាណធាតុ ជាសាធារណៈ គឺជាអហេតុកកិរិយា ប្រព្រឹត្តទៅមួយអន្លើដោយឧបេក្ខា មានការដឹងច្បាស់នូវអារម្មណ៍ ៦ ជាលក្ខណៈ, មានការកត់ត្រាទុក និង រំពឹងនឹកគិត ក្នុងបញ្ចទ្វារ និង មនោទ្វារទាំងឡាយ ដោយអំណាចនៃកិច្ច ជាកិច្ច, មានភាវៈដោយប្រការយ៉ាងដូច្នោះ ជាផល, មានកិរិយាទៅប្រាសអហេតុកវិបាក មនោវិញ្ញាណធាតុ និង ភវង្គទាំងឡាយ អារម្មណ៍ណាមួយ ជាហេតុ, មនោវិញ្ញាណធាតុ ដែល



ជាអសាធារណៈ ជាហេតុកកិរិយា ប្រកបដោយសោមនស្ស, មានកិរិយាដឹងច្បាស់នូវអារម្មណ៍ ៦ ជាលក្ខណៈ, មានកិរិយាញ៉ាំងចិត្តរីករាយ ក្នុងវត្ថុទាំងឡាយមិនលើសលុប ឲ្យកើតឡើង ដល់ព្រះអរហន្តទាំងឡាយ ដោយអំណាចនៃកិច្ច ជាកិច្ច, មានភាវៈដោយប្រការដូច្នោះ ជាផល, មានហទយវត្ថុ ដោយចំណែកមួយ ជាហេតុ យ៉ាងដូច្នេះឯង ។

កាមាវចរកិរិយាវិញ្ញាណ ដែលជាអហេតុកៈ មាន ៣ យ៉ាង ដូចដែលបានរៀបរាប់មកនេះឯង ។

ចំណែកកាមាវចរវិញ្ញាណ ជាសហេតុកៈ មាន ៨ ប្រការ ដោយកិរិយាញែកមានសោមនស្សជាដើម ដូចជាកុសលវិញ្ញាណ ។ ប៉ុន្តែនេះ ជាការប្លែកផ្សេងគ្នា ក្នុងកុសលវិញ្ញាណ និង កិរិយាវិញ្ញាណនេះ គឺ កុសលវិញ្ញាណ រមែងកើតឡើង ដល់សេខបុគ្គល និង បុថុជ្ជនទាំងឡាយតែប៉ុណ្ណោះ, កិរិយាវិញ្ញាណនេះ (រមែងកើតឡើង) ដល់ព្រះអរហន្តទាំងឡាយតែម្យ៉ាង ។

កិរិយាវិញ្ញាណ ជាកាមាវចរៈ មាន ១១ ប្រការ យ៉ាងនេះឯងជាដំបូង ។ ចំណែកកិរិយាវិញ្ញាណ ជារូបាវចរកុសលក្តី អរូបាវចរ-កុសលក្តី មាន ៥ យ៉ាង ក៏មាន, មាន ៤ យ៉ាង ក៏មាន ដូចជាកុសលដែរ ។ ក៏សេចក្តីប្លែកគ្នាពីកុសលវិញ្ញាណ នៃកិរិយាវិញ្ញាណទាំង ២ នេះ បណ្ឌិត គប្បីជ្រាប ដោយអំណាចនៃការកើតឡើងដល់ព្រះអរហន្តទាំងឡាយតែប៉ុណ្ណោះឯង ។

កិរិយាវិញ្ញាណទាំងអស់ ក្នុងភូមិទាំង ៣ មាន ២០ យ៉ាងដូច្នេះ ។

### (វិញ្ញាណទាំងពួងប្រព្រឹត្តទៅ ដោយអាការៈ ៤)

(២៩១) វិញ្ញាណទាំងឡាយណា រមែងប្រព្រឹត្តទៅ ដោយអាការៈ

ទាំង ១៤ ដោយអំណាចនៃបដិសន្ធិ ១, ភវង្គ ១, វជ្ជនៈ ១, ទស្សនៈ ១, សវនៈ ១, ឃាយនៈ ១, សាយនៈ ១, ផុសនៈ ១, សម្បដិច្ឆនៈ ១, សន្តីរណៈ ១, វោដ្ឋវនៈ ១, ជវនៈ ១, តទារម្មណៈ ១ និង ចុតិ ១, វិញ្ញាណទាំងអស់នោះ គឺ កុសលវិញ្ញាណ ២១, អកុសលវិញ្ញាណ ១២, វិញ្ញាណ ៣៦, កិរិយាវិញ្ញាណ ២០, រួមត្រូវជា វិញ្ញាណ ៨៩ ដូចបានរៀបរាប់មកហើយនេះឯង ។ សួរថាៈ តើដូចម្តេច? ។

(បដិសន្ធិ)

ឆ្លើយដូចតទៅ : ដូចជាពួកសត្វកើតក្នុងទេវតា និង មនុស្សទាំងឡាយ ដោយអានុភាពនៃកាមាវចរកុសលទាំងឡាយ ៨ ក្នុងកាលណា, ក្នុងកាលនោះ វិបាកចិត្តទាំងឡាយ ៩ គឺ សហេតុកកាមាវចរវិបាក ៨ និង អហេតុកវិបាកមនោវិញ្ញាណធាតុ ដែលជាឧបេក្ខាសហគតៈ ជាវិបាកនៃទ្វិហេតុកកុសល យ៉ាងទន់ នៃសត្វទាំងឡាយដែលដល់នូវភាវៈនៃជនមានជនខ្វិយជាដើម ក្នុងមនុស្សទាំងឡាយផង ធ្វើនូវបណ្តា-កម្ម, កម្មនិមិត្ត និង គតិនិមិត្តទាំងឡាយ កម្ម ឯណានីមួយ ដែលប្រាកដឡើង ក្នុងកាលជាទីស្លាប់នៃសត្វទាំងឡាយនោះ ឲ្យជាអារម្មណ៍ រមែងប្រព្រឹត្តទៅ ដោយអំណាចបដិសន្ធិ ។ សត្វទាំងឡាយកើតឡើង ក្នុងរូបភព និង អរូបភពទាំងឡាយ ដោយអានុភាពនៃរូបាវចរកុសល និង អរូបាវចរកុសល ក្នុងកាលណា, រូបាវចរវិបាកចិត្ត និង អរូបាវចរ-វិបាកចិត្តទាំង ៩ ធ្វើនូវកម្មនិមិត្តហ្នឹងឯង ដែលតាំងឡើងប្រាកដហើយ ក្នុងកាលជាទីស្លាប់នៃសត្វទាំងឡាយនោះ ឲ្យជាអារម្មណ៍ ប្រព្រឹត្តទៅ ដោយអំណាចបដិសន្ធិ ក្នុងកាលនោះ ។ ក៏មួយទៀត ពួកសត្វ កើតក្នុងអបាយ ដោយអានុភាពនៃអកុសល ក្នុងកាលណា, ក្នុងកាលនោះ



អហេតុកមនោវិញ្ញាណធាតុ ដែលជាវិបាកនៃអកុសល ធ្វើនូវបណ្តាកម្ម, កម្មនិមិត្ត និង គតិនិមិត្តទាំងឡាយ កម្មណាមួយ ដែលតាំងឡើងប្រាកដហើយ ក្នុងកាលជាទីស្លាប់នៃជនទាំងឡាយនោះ ឲ្យជាអារម្មណ៍ប្រព្រឹត្តទៅ ដោយអំណាចបដិសន្ធិ ដូច្នេះឯង ។

ការប្រព្រឹត្តិទៅ នៃវិបាកវិញ្ញាណទាំងឡាយ ២១ ដោយអំណាចនៃបដិសន្ធិ បណ្ឌិត គប្បីជ្រាប ដូចពោលមកហើយ ក្នុងវិញ្ញាណក្ខន្ធនេះ ត្រឹមប៉ុណ្ណេះមុនសិនចុះ ។

(ភវង្គៈ)

(២៩២) លុះតែកាលបើបដិសន្ធិវិញ្ញាណ រលត់ហើយ ឈ្មោះថាភវង្គវិញ្ញាណ ប្រាកដយ៉ាងដូច្នោះឯង ដែលជាវិបាកនៃកម្មនោះៗ ឯងដែលជាប់តាម នូវបដិសន្ធិវិញ្ញាណនោះៗ រមែងប្រព្រឹត្តទៅ ក្នុងអារម្មណ៍នោះឯង ។ កាលបើចិត្តុប្បាទដទៃ ដែលជាហេតុញុំាងសន្តានឲ្យប្រែត្រឡប់មិនមាន យ៉ាងនេះ គឺ (ចិត្ត) បែបនោះ (រមែងប្រព្រឹត្តទៅ) ម្តងទៀត, (ចិត្ត) បែបនោះ (រមែងប្រព្រឹត្តទៅ) ម្តងទៀត, ភវង្គវិញ្ញាណ (របស់បុគ្គល) កាលមិនឃើញសុបិន រមែងប្រព្រឹត្តទៅ រាប់ប្រមាណមិនបាន ដោយពិត ក្នុងកាលទាំងឡាយ មានកាលជាទីដេកលក់ជាដើម ដូចជាខ្សែទឹក យ៉ាងដូច្នោះឯង ។

ការប្រព្រឹត្តិទៅ នៃវិញ្ញាណទាំងឡាយនោះឯង បណ្ឌិត គប្បីជ្រាប ដោយអំណាចនៃភវង្គ ដូចបានពោលមកហើយនេះឯង ។

(អាវជ្ជនៈ)

ក៏នាកាលសន្តាននៃភវង្គប្រព្រឹត្តទៅយ៉ាងនេះ ឥន្ទ្រិយទាំងឡាយ របស់សត្វទាំងឡាយ ជាឥន្ទ្រិយគួរទទួលនូវអារម្មណ៍បានក្នុងកាលណា,

ក្នុងកាលនោះ ការប៉ះទង្គិចនូវចក្ខុប្បសាទ ព្រោះអាស្រ័យនូវរូបក្នុងរូប ដែលមកកាន់វង្វង់នៃចក្ខុ តែងកើតមាន ។ ក្នុងលំដាប់នោះ ការកំរើក នៃភវង្គ រមែងមានដោយអានុភាពនៃការប៉ះទង្គិច ។ លំដាប់នោះ កាល បើភវង្គរលត់ហើយ កិរិយាមនោធាតុ កាលញ៉ាំងអាវជ្ជនកិច្ច ឲ្យសំរេច ដូចជាកាលកាត់ផ្តាច់នូវភវង្គ ធ្វើនូវរូបនោះឯង ឲ្យជាអាម្មណ៍ កើត ឡើង ។ ន័យក្នុងទ្វារទាំងឡាយ មានសោតទ្វារជាដើម ក៏ដូចគ្នា នឹងន័យនេះដែរ ។ តែកាលបើអារម្មណ៍ទាំង ៦ ប្រការ ក្នុងមនោទ្វារ មកកាន់វង្វង់, អហេតុកកិរិយាមនោវិញ្ញាណធាតុ ប្រព្រឹត្តទៅមួយអន្ទើ ដោយឧបេក្ខា កាលញ៉ាំងអាវជ្ជនកិច្ចឲ្យសំរេច ដូចជាការផ្តាច់នូវភវង្គ រមែងកើតឡើងបាន បន្ទាប់អំពីភវង្គចលនា ។

ការប្រព្រឹត្តិទៅ នៃកិរិយាវិញ្ញាណទាំងឡាយ ២ យ៉ាង ដោយ អំណាចនៃអាវជ្ជនៈ បណ្ឌិត គប្បីជ្រាប ដូចបានពោលមកនេះឯង ។

**(ទស្សនៈ, សវនៈ, ឃាយនៈ, សាយនៈ និង ផុសនៈ)**

ក៏បន្ទាប់ពីអាវជ្ជនកិច្ចមក ចក្ខុវិញ្ញាណ ជាវត្ថុនៃចក្ខុប្បសាទ កាលញ៉ាំងទស្សនកិច្ច ឲ្យសំរេចមុន ក្នុងចក្ខុវិញ្ញាណ, សោតវិញ្ញាណ, ឃានវិញ្ញាណ, ជិវ្ហាវិញ្ញាណ និង កាយវិញ្ញាណទាំងឡាយ ញ៉ាំង សវនកិច្ចជាដើម ឲ្យសំរេច ក្នុងទ្វារទាំងឡាយ មានសោតទ្វារជាដើម រមែងប្រព្រឹត្តទៅបាន ។ វិញ្ញាណទាំងឡាយនោះ ជាកុសលវិបាក (រមែងប្រព្រឹត្តទៅ) ក្នុងអារម្មណ៍ទាំងឡាយ ដែលខ្ជួនប្រាថ្នាហើយៗ និង អារម្មណ៍មិនជាទីប្រាថ្នា ជាកណ្តាល, ជាអកុសលវិបាក រមែង ប្រព្រឹត្តទៅ ក្នុងអារម្មណ៍ទាំងឡាយ ដែលមិនជាទីប្រាថ្នា និង មិនជាទី ប្រាថ្នា ជាកណ្តាល យ៉ាងដូច្នេះឯង ។



ការប្រព្រឹត្តិទៅ នៃវិបាកវិញ្ញាណទាំងឡាយ ១០ យ៉ាងនេះ បណ្ឌិត គប្បីជ្រាប ដោយអំណាចនៃការឃើញ, ការស្តាប់, ការធុំក្លិន, ការ លិទ្ធភ្លក្ស និង ការពាល់ត្រូវ យ៉ាងដូច្នេះឯង ។

**(សម្បដិច្ឆនៈ)**

ព្រោះព្រះបាលីថា “ចិត្ត, មនោ, មានសៈ ។លេ។ មនោធាតុ ដែលកើតអំពីចិត្តនោះ ក្នុងលំដាប់នៃចក្ខុវិញ្ញាណធាតុ ដែលកើតឡើង ហើយរលត់ទៅវិញ រមែងកើតឡើង” ដូច្នេះ ក៏មនោធាតុ ដែលជាលំ ដាប់នៃវិញ្ញាណ មានចក្ខុវិញ្ញាណជាដើម ជាកុសលវិបាក ក្នុងលំដាប់ នៃកុសលវិបាកវិញ្ញាណ, ជាអកុសលវិបាក ក្នុងលំដាប់នៃអកុសល វិបាកវិញ្ញាណ ទទួលនូវអារម្មណ៍ នៃវិញ្ញាណទាំងនោះ កើតឡើង ។

ការប្រព្រឹត្តិទៅ នៃវិបាកវិញ្ញាណទាំងឡាយ ២ ប្រការ បណ្ឌិត គប្បីជ្រាប ដោយអំណាចនៃការទទួល ដូចរៀបរាប់មកនេះឯង ។

**(សន្តីរណៈ)**

មួយទៀត ព្រោះព្រះបាលីថា “ចិត្ត, មនោ, មានសៈ, ។លេ។ មនោវិញ្ញាណធាតុ ដែលកើតអំពីចិត្តនោះ រមែងកើតឡើង ក្នុងលំដាប់ នៃមនោធាតុ ដែលកើតឡើងហើយ រលត់ទៅវិញ” ដូច្នេះជាដើម វិបាកាហេតុកមនោវិញ្ញាណធាតុ ដែលជាលំដាប់នៃអកុសលវិបាកមនោ ធាតុ ជាអកុសលវិបាក, ដែលជាលំដាប់នៃកុសលវិបាកមនោធាតុ ជាកុសលវិបាក ប្រព្រឹត្តទៅមួយអន្ទើដោយសោមនស្ស ក្នុងឥដ្ឋារម្មណ៍ ប្រព្រឹត្តទៅមួយអន្ទើដោយឧបេក្ខា ក្នុងឥដ្ឋារម្មណ៍ជាកណ្តាល ធ្វើនាទី ជាអ្នកពិចារណានូវអារម្មណ៍ ដែលមនោធាតុទទួលយកនោះឯង រមែង កើតឡើង ដូច្នេះឯង ។

ការប្រព្រឹត្តិទៅ នៃវិបាកវិញ្ញាណទាំង ៣ យ៉ាង ដោយអំណាចនៃការពិចារណា គឺបណ្ឌិត គប្បីជ្រាប យ៉ាងដូច្នេះចុះ ។

(វោដ្ឋពនៈ)

ចំណែកកិរិយាហេតុកមនោវិញ្ញាណធាតុ ប្រព្រឹត្តទៅមួយអន្ទើ ដោយឧបេក្ខា កាលកំណត់នូវអារម្មណ៍នោះឯង រមែងកើតឡើង បន្ទាប់អំពីសន្តីរណៈមក ដូច្នេះឯង ។

កិរិយាប្រព្រឹត្តិទៅ នៃកិរិយាមនោវិញ្ញាណធាតុតែមួយ បណ្ឌិត គប្បីជ្រាប ដោយអំណាចនៃការកត់ចំណាំ ដូច្នេះឯង ។

(ជវនៈ)

ប្រសិនបើអារម្មណ៍ មានរូបារម្មណ៍ជាដើម ជាអារម្មណ៍ធំបន្ទាប់ពីវោដ្ឋវនៈមក, លំដាប់នោះ ជវនៈទាំងឡាយ៦ ក្តី ៧ ក្តី ដោយអំណាចនៃបណ្តាកាមាវចរកុសលទាំងឡាយ ៨ ក្តី អកុសលទាំងឡាយ ១២ ក្តី កាមាវចរកិរិយា ដ៏សេសទាំងឡាយ ៩ ក្តី កាមាវចរកុសលណាមួយ រមែងស្ទុះទៅ ក្នុងអារម្មណ៍ទាំងឡាយដែលវោដ្ឋវនចិត្ត កំណត់ហើយ យ៉ាងណា ។ ន័យក្នុងបញ្ចទ្វារ ចប់ត្រឹមប៉ុណ្ណោះឯង ។ ចំណែកក្នុងមនោទ្វារ កាមាវចរជវនទាំងឡាយនោះ (រមែងស្ទុះទៅ) ក្នុងលំដាប់អំពីមនោទ្វារាវជ្ជនៈ មក ។ បន្ទាប់អំពីគោត្រភូ មក ការប្រព្រឹត្តិទៅ ដោយអំណាចនៃជវនៈ នៃកុសលាកុសលកិរិយាវិបាកវិញ្ញាណទាំងឡាយ ៥៥ គឺបណ្ឌិត គប្បីជ្រាប ដូច្នេះ គឺ “បណ្តាជវនៈទាំងឡាយនេះ ដូច្នេះ គឺ អំពីរូបាវចរៈ កុសលជវនៈទាំងឡាយ ៥ កិរិយាជវនៈ ៥, អំពីអរូបាវចរៈ កុសលជវនៈទាំងឡាយ ៤ កិរិយាជវនៈ ៤, មគ្គចិត្តទាំងឡាយ ៤ ផលចិត្តទាំងឡាយ ៤ អំពីលោកុត្តរ ជវនៈណាមួយ ជាជវនៈ



ដែលបានបច្ច័យហើយ ជវនៈ នោះៗ រមែងស្ទុះទៅ” យ៉ាងដូច្នេះឯង ។

(តទារម្មណ៍)

ក៏ក្នុងទីបំផុតនៃជវនៈ ប្រសិនបើអារម្មណ៍នោះ ជាអារម្មណ៍ធំពេកក្នុងបញ្ចទ្វារ និង ជាអារម្មណ៍ ដែលប្រាកដច្បាស់ក្នុងមនោទ្វារ លំដាប់នោះ បច្ច័យណាៗ ដែលខ្វះបានហើយ ដោយអំណាចនៃអារម្មណ៍ទាំងឡាយ មានឥដ្ឋារម្មណ៍ជាដើម និង នៃបុរិមកម្ម និង ចិត្តមានជវនចិត្តជាដើម ក្នុងទីបំផុតនៃកាមាវចរជវនៈ នៃសត្វដែលជាកាមាវចរទាំងឡាយ, វិបាកវិញ្ញាណ ក្នុងបណ្តាសហេតុកកាមាវចរវិបាក ៨ និង វិបាកហេតុកមនោវិញ្ញាណធាតុ ៣ យ៉ាង ណាមួយ ដែលជាប់តាមនូវជវនៈ ដែលស្ទុះទៅ ក្នុងអារម្មណ៍ដទៃ អំពីអារម្មណ៍របស់ភវង្គ ដូចជាទឹកដែលហូរបញ្ច្រាសខ្សែទឹក ស្ទុះទៅក្នុងខណៈបន្តិចបន្តួច ជាប់តាមនូវទូកដែលទៅបញ្ច្រាសខ្សែទឹកដូច្នោះ រមែងកើតឡើង អស់ ២ ដង ឬ ១ ដង ដោយអំណាចនៃបច្ច័យនោះៗ ។ វិបាកវិញ្ញាណនេះនុ៎ះ ជាចិត្តដែលគួរដល់ការប្រព្រឹត្តិទៅ ក្នុងអារម្មណ៍នៃភវង្គ ក្នុងទីបំផុតនៃជវនៈ ទើបលោកហៅថា “តទារម្មណ៍” ព្រោះធ្វើអារម្មណ៍នៃជវនៈនោះ ឲ្យជាអារម្មណ៍ហើយប្រព្រឹត្តទៅ ។

ការប្រព្រឹត្តិទៅ នៃវិបាកវិញ្ញាណទាំងឡាយ ១១ យ៉ាង បណ្ឌិត គប្បីជ្រាប ដោយអំណាចនៃតទារម្មណ៍ យ៉ាងដូច្នេះឯង ។

(ចុតិ)

ចិត្តសន្តានជាបច្ច័យដែលខ្វះបានហើយ យ៉ាងនេះគឺ “ក៏ក្នុងទីបំផុតនៃតទារម្មណ៍ ភវង្គចិត្តហ្នឹងឯង រមែងប្រព្រឹត្តទៅទៀត កាលបើភវង្គដាច់ហើយ វិថីវិញ្ញាណទាំងឡាយមានអាវជ្ជនៈជាដើម រមែងប្រព្រឹត្តទៅ

ទៀត” ដូច្នេះ រមែងប្រព្រឹត្តទៅរឿយៗ ដោយអំណាចនៃកិរិយាកំណត់នូវចិត្តរឿយៗថា “អាវជ្ជនៈ មានបន្ទាប់អំពីភវង្គ, វិញ្ញាណកិច្ច មានការឃើញជាដើម មានបន្ទាប់អំពីអាវជ្ជនៈ” ដូច្នេះជាដើម ដរាបដល់ការអស់ទៅនៃភវង្គក្នុងភពមួយ ។ មែនពិត ភវង្គចិត្តណា មានក្នុងទីបំផុតនៃជវនចិត្តទាំងអស់ ក្នុងភពមួយ, ភវង្គចិត្តនោះ លោកឲ្យឈ្មោះថា ចុតិ ព្រោះភាវៈនៃភវង្គចិត្តនោះ ច្យុតអំពីភពនោះ ។ ព្រោះហេតុនោះ ចុតិចិត្តនោះឯង មាន ១៩ ប្រភេទ ដូច្នេះដែរ ។

ការប្រព្រឹត្តិទៅ នៃវិបាកវិញ្ញាណ ១៩ ដួង គឺបណ្ឌិត គប្បីជ្រាប ដោយអំណាចនៃចុតិ យ៉ាងដូច្នេះឯង ។

ចិត្តសន្តានដែលមិនដាច់រយៈ របស់ពួកសត្វដែលអន្ទោលទៅមកក្នុងភព, គតិ, ឋិតិ និង ការនៅទាំងឡាយ រមែងប្រព្រឹត្តទៅយ៉ាងនេះ ដូច្នេះ គឺ “បដិសន្ធិអំពីចុតិ(មាន)ទៀត, ភវង្គអំពីបដិសន្ធិ(មាន)ទៀត” តែបណ្តាសត្វទាំងនុ៎ះ សត្វណា លុះនូវព្រះអរហត្ត, កាលបើចុតិចិត្តរបស់សត្វនោះ រលត់ហើយ, ចិត្តសន្តាន ឈ្មោះថា រលត់ហើយដែរ ដូច្នេះឯង ។

នេះ ជាប្រការនៃការពោល ដោយពិស្តារ ក្នុងវិញ្ញាណក្ខន្ធ ។

(វេទនាខន្ធ)

(២៩៣) ក្នុងកាលឥឡូវនេះ ពាក្យណាដែលលោកពោលហើយ គប្បីជ្រាបសេចក្តីវិនិច្ឆ័យ ក្នុងពាក្យនេះឯង ដូច្នេះ គឺ ធម្មជាត ណាមួយ មានការសោយ ជាលក្ខណៈ, វេទនាខន្ធ គឺបណ្ឌិត គប្បីជ្រាប ព្រោះធ្វើនូវធម្មជាតទាំងអស់នោះ ក្នុងទីជាមួយគ្នា ។

ធម្មជាតិមានការសោយជាលក្ខណៈ ឈ្មោះថា វេទនា ។ សមដូច



ជាព្រះសារីបុត្តត្ថេរ ពោលថា ម្នាលអាវុសោ ! ធម្មជាតិណា សោយ គឺថា ដឹង ព្រោះហេតុនោះ ធម្មជាតិនោះឯង ឈ្មោះថា វេទនា ។

(វេទនា ១ វេទនា ៣)

ក៏វេទនានោះ មានតែម្យ៉ាងប៉ុណ្ណោះ ដោយភាពមានការសោយជាលក្ខណៈ (វេទនា) មាន ៣ យ៉ាង ក៏មាន គឺ កុសល១, អកុសល១, អព្យាកតៈ១ ដោយអំណាចនៃជាតិ ។ បណ្តាវេទនាទាំង ៣ យ៉ាងនោះ គប្បីជ្រាបថា “វេទនាដែលសម្បយុត្តហើយ ដោយកុសលវិញ្ញាណដែលលោកបានពោលហើយ ដោយន័យមានន័យថាៈ កាមាវចរកុសល មាន ៨ ប្រការ ដោយកិរិយាញែកតាមសោមនស្ស ឧបេក្ខា ញាណ និង សង្ខារ” ដូច្នេះជាដើម ជាកុសលវេទនា ដ៏សម្បយុត្តហើយ ដោយអកុសលវិញ្ញាណ ជាអកុសលវេទនា សម្បយុត្តហើយ ដោយអព្យាកតវិញ្ញាណ គឺលោកពោលហើយថា អព្យាកតវេទនា ។

(វេទនា ៥)

(បើ)ចែកតាមប្រក្រតី វេទនានោះ មាន ៥ ប្រការ គឺ សុខ ១, ទុក្ខ១, សោមនស្ស ១, ទោមនស្ស ១, ឧបេក្ខា ១, ។ បណ្តាវេទនាទាំងឡាយ ៥ យ៉ាងនោះ សុខដ៏សម្បយុត្តដោយកាយវិញ្ញាណ ជាកុសល-វិបាក, ទុក្ខដែលសម្បយុត្ត ដោយកាយវិញ្ញាណ ជាអកុសលវិបាក សោមនស្ស សម្បយុត្តដោយវិញ្ញាណ ៦២ យ៉ាងនេះ គឺ ខាងកាមាវចរវិញ្ញាណកុសល ៤, សហេតុកវិបាក ៤, អហេតុកវិបាក ១, សហេតុកកិរិយា ៤, អហេតុកកិរិយា ៤, អកុសល ៤, ខាងរូបាវចរវិញ្ញាណលើកលែងតែបញ្ចមជ្ឈានវិញ្ញាណចេញ កុសល៤, វិបាក៤, កិរិយា៤, ខាងលោកុត្តរវិញ្ញាណ ឈ្មោះថា លោកុត្តរវិញ្ញាណ ដែលមិនប្រកប

ដោយឈាន មិនមាន ព្រោះហេតុណា, ព្រោះហេតុនោះ លោកុត្តរវិញ្ញាណ ៨ ត្រូវជា ៤០ ដោយអំណាចនៃឈានទាំងឡាយ ៥, ក្នុងលោកុត្តរវិញ្ញាណទាំង ៤០ នោះ លើកលែងតែវិញ្ញាណ ដែលប្រព្រឹត្តទៅក្នុងបញ្ចមជ្ឈាន ៨ ចេញ នៅសល់កុសលវិបាក ៣២, ទោមនស្សសម្បយុត្ត ដោយអកុសលវិញ្ញាណ ២, ឧបេក្ខា សម្បយុត្ត ដោយវិញ្ញាណ ៥៥ ដែលសេសសល់ ។

(លក្ខណៈ នៃវេទនា ៥)

បណ្ដាវេទនាទាំងឡាយ ៥ នោះ សេចក្ដីសុខ មានការសោយនូវផោដ្ឋព្វៈ ដែលជាទីប្រាថ្នា ជាលក្ខណៈ, មានការចំរើនសម្បយុត្តធម៌ទាំងឡាយ ជាកិច្ច, មានការត្រេកអរ ដែលប្រព្រឹត្តទៅ ក្នុងកាយ ជាផល, មានកាយិន្ទ្រិយ ជាហេតុ ។ ទុក្ខ មានការសោយនូវផោដ្ឋព្វៈ មិនជាទីប្រាថ្នា ជាលក្ខណៈ, មានការញ៉ាំងសម្បយុត្តធម៌ទាំងឡាយ ឲ្យស្រពាប់ ជាកិច្ច, មានអាពាធដែលប្រព្រឹត្តទៅ ក្នុងកាយ ជាផល, មានកាយិន្ទ្រិយ ជាហេតុ ។ សោមនស្ស មានការសោយនូវឥដ្ឋារម្មណ៍ ជាលក្ខណៈ, មានការជួបប្រទះ នូវអាការៈជាទីប្រាថ្នា តាមតែបាន ជាកិច្ច, មានការរីករាយដែលប្រព្រឹត្តទៅ ក្នុងចិត្ត ជាផល, មានបស្សទ្ធិ ជាហេតុ ។ ទោមនស្ស មានការសោយនូវអនិដ្ឋារម្មណ៍ ជាលក្ខណៈ, មានការជួបប្រទះនូវអាការៈមិនជាទីប្រាថ្នាតាមតែបាន ជាកិច្ច, មានសេចក្ដីលំបាកដែលប្រព្រឹត្តទៅ ក្នុងចិត្ត ជាផល, មានហទយវត្ថុ ដោយចំណែក ១ ជាហេតុ ។ ឧបេក្ខា មានការសោយនូវអារម្មណ៍ដែលជាកណ្ដាល ជាលក្ខណៈ, មានកិរិយាញ៉ាំងសម្បយុត្តធម៌ទាំងឡាយ មិនឲ្យចំរើនពេកនិង មិនឲ្យស្រពោនពេក ជាកិច្ច, មានភាវៈស្ងប់ស្ងាត់ ជាផល, មានចិត្ត



មិនប្រកបដោយបីតិ ជាហេតុ ដូច្នេះឯង ។

នេះ ជាកថាមុខ ដោយពិស្ដារ ក្នុងវេទនាខន្ធ ។

(សញ្ញាខន្ធ)

(២៩៤) ក្នុងកាលឥឡូវនេះ ពាក្យណាដែលលោកពោលហើយ គប្បីជ្រាបសេចក្ដីវិនិច្ឆ័យ ក្នុងពាក្យនេះឯងថា: ធម្មជាតិណាមួយ មានការដឹងច្បាស់ជាលក្ខណៈ, សញ្ញាខន្ធ គឺបណ្ឌិត គប្បីជ្រាប ព្រោះធ្វើនូវធម្មជាតិនោះទាំងអស់ ក្នុងទីជាមួយគ្នា ដូច្នេះ ។

ធម្មតាធម្មជាតិដែលជាគ្រឿងសំគាល់ បានដល់ សញ្ញានោះឯង ។ សមដូចជាព្រះសារីបុត្តត្ថេរ បានពោលហើយថា ។ ម្នាលអាវុសោ ! ធម្មជាតិណា ចាំបាន ដឹងច្បាស់ ព្រោះហេតុណា, ព្រោះហេតុនោះ ធម្មជាតិនោះ គឺលោកហៅថា “សញ្ញា” ។

(សញ្ញា ១ សញ្ញា ៣)

ក៏សញ្ញានោះនេះ មានតែមួយ ដោយសភាវៈ មានកិរិយាចាំបាន ជាលក្ខណៈ, មាន ៣ ប្រការ គឺកុសល ១, អកុសល ១, អព្យាកតៈ ១ ដោយអំណាចនៃជាតិ ។ បណ្ដាសញ្ញាទាំងឡាយ ៣ នោះ (សញ្ញា) ដែលសម្បយុត្តហើយ ដោយកុសលវិញ្ញាណ ហៅថា កុសលសញ្ញា, (សញ្ញា)ដ៏សម្បយុត្តហើយដោយអកុសលវិញ្ញាណ ហៅថា អកុសលសញ្ញា, (សញ្ញា) ដ៏សម្បយុត្តហើយដោយអព្យាកតវិញ្ញាណ ហៅថា អព្យាកតសញ្ញា ។ ព្រោះថា (វិញ្ញាណ)ណា ប្រកបប្រាសហើយចាកសញ្ញា, វិញ្ញាណនោះ មិនឈ្មោះថា មានទេ ព្រោះហេតុនោះ ការញែកនៃវិញ្ញាណ មានប្រមាណប៉ុណ្ណា ការញែកនៃសញ្ញា ក៏មានប្រមាណប៉ុណ្ណោះដែរ ។

(លក្ខណៈនៃសញ្ញា)

ក៏សញ្ញានេះនុ៎ះ សូម្បីមានប្រភេទស្មើគ្នាដោយវិញ្ញាណ យ៉ាងនេះ បើពោលតាមអាការៈ មានលក្ខណៈជាដើម សញ្ញាទាំងអស់នោះឯង មានការចាំបានជាលក្ខណៈ, មានការធ្វើនូវនិមិត្តជាបច្ច័យ នៃការដឹងច្បាស់តទៅទៀតថា “នុ៎ះ គឺជារបស់នេះឯង” ដូច្នេះ ជាកិច្ច ដូចជាជាងឈើជាដើមធ្វើនូវការសំគាល់ ក្នុងវត្ថុទាំងឡាយមានឈើជាដើម, មានការធ្វើនូវការប្រកាន់ស្អិត ដោយអំណាចនិមិត្ត ដែលខ្លួនកាន់យកហើយ យ៉ាងណា ជាផល ដូចជាមនុស្សខ្វាក់ស្ទាបដំរីទាំងឡាយ ធ្វើការប្រកាន់ស្អិត ដោយនិមិត្តដែលខ្លួនកាន់យកហើយ យ៉ាងណានោះឯង, មានអារម្មណ៍ដែលតាំងនៅហើយ យ៉ាងណា ជាបទដ្ឋាន ដូចជាការចាំដែលកើតឡើង ដល់ពួកកូនសត្វម្រឹគ ក្នុងមនុស្សដែលចង ដោយបាច់ស្មៅថា “ជាបុរស” ដូច្នោះឯង ។

នេះ ជាប្រធាននៃការពោល ដោយពិស្ដារ ក្នុងសញ្ញាខន្ធ ។

(សង្ខារក្ខន្ធ)

(២៩៥) ក៏ពាក្យណា ដែលលោកពោលហើយ, សេចក្ដីវិនិច្ឆ័យថា “ធម្មជាតណាមួយ មានការតាក់តែងជាលក្ខណៈ, សង្ខារក្ខន្ធ គឺបណ្ឌិត គប្បីជ្រាប ព្រោះធ្វើនូវធម្មជាតទាំងអស់នោះ ក្នុងទីជាមួយគ្នា” ដូច្នេះ, គឺបណ្ឌិត គប្បីជ្រាប ក្នុងពាក្យនេះ (ដូចតទៅនេះ) ។

ការធ្វើនូវគំនរជាលក្ខណៈ ឈ្មោះថា មានការតាក់តែង ជាលក្ខណៈ ។ ពាក្យសួរថា : ចុះធម្មជាតនោះ ដូចម្ដេច ? ។ ចម្លើយថា : បានដល់សង្ខារហ្នឹងឯង ។ សមដូចជាព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ថា : ម្នាលភិក្ខុទាំងឡាយ ! បទេសរាជទាំងឡាយ តាក់



តែងនូវសង្ខតធម៌ ព្រោះហេតុណា, ព្រោះហេតុនោះ បទេសរាជទាំងឡាយនោះ តថាគត ហៅថា សង្ខារ ។

(លក្ខណៈ...នៃសង្ខារ)

សង្ខារទាំងឡាយនោះ មានការតាក់តែង ជាលក្ខណៈ, មានការប្រមូលមក ជាកិច្ច, មានការផ្សព្វផ្សាយ ជាផល, មានការប្រជុំនៃខន្ធបីដ៏សេស ជាហេតុ ។

(សង្ខារ ១ សង្ខារ ៣)

សង្ខារទាំងឡាយនោះ មានតែមួយក៏មាន ដោយប្រភេទមានលក្ខណៈជាដើមយ៉ាងនេះ, មាន ៣ ក៏មាន គឺ កុសល ១, អកុសល ១, អព្យាកតៈ ១ ដោយអំណាចនៃជាតិ ។ បណ្ដាសង្ខារទាំងបីនោះ សង្ខារទាំងឡាយ ដែលសម្បយុត្តដោយកុសលវិញ្ញាណ លោកឲ្យឈ្មោះថា កុសលសង្ខារ, ដែលសម្បយុត្តដោយអកុសលវិញ្ញាណ លោកឲ្យឈ្មោះថា អកុសលសង្ខារ, ដែលសម្បយុត្តដោយអព្យាកតវិញ្ញាណ លោកឲ្យឈ្មោះថា អព្យាកតសង្ខារ ។

(កុសលសង្ខារ ៣៦)

បណ្ដាសង្ខារទាំងឡាយបីយ៉ាងនោះ ជាដំបូង សង្ខារទាំងឡាយដ៏សម្បយុត្តដោយកុសលវិញ្ញាណទីមួយ ជាកាមាវចរ មាន ៣៦ យ៉ាង គឺសង្ខារជានិយតៈ មកដោយរូបរបស់ខ្លួន ២៧, ជាយេវាបនកន័យ ៤, អនិយតៈ ៥ ។ បណ្ដាសង្ខារទាំង ៣៦ នោះ សង្ខារទាំង ២៧ នេះ មកហើយ ដោយរូបរបស់ខ្លួន គឺ : ផស្សៈ ១, ចេតនា ១, វិតក្កៈ ១, វិចារៈ១, បីតិ១, វិរិយៈ១, ជីវិត១, សមាធិ១, សទ្ធា១, សតិ១, ហិរិ១, ឱត្តប្បៈ ១, អលោភៈ ១, អទោសៈ ១, អមោហៈ ១, កាយបស្សទ្ធិ ១

ចិត្តប្បស្សទ្ធិ ១, កាយលហុតា ១, ចិត្តលហុតា ១, កាយមុទុតា ១, ចិត្តមុទុតា ១, កាយកម្មញ្ញតា ១, ចិត្តកម្មញ្ញតា ១, កាយបាគុញ្ញតា ១, ចិត្តបាគុញ្ញតា ១, កាយុជុកតា ១, ចិត្តុជុកតា ១ ។ សង្ខារទាំងឡាយ ៤ យ៉ាងនេះ ជាយេវាបនកន័យ គឺៈ ឆន្ទៈ ១, អធិមោក្ខៈ ១, មនសិការៈ ១, តត្រមជ្ឈត្តា ១ ។ សង្ខារទាំងឡាយនេះ ជាអនិយតសង្ខារ មាន ៥ គឺៈ ករុណា ១, មុទិតា ១, កាយទុច្ចរិតវិរតិ ១, វចីទុច្ចរិតវិរតិ ១, មិច្ឆាជីវវិរតិ ១ ។ ព្រោះក្នុងកាលខ្លះ សង្ខារទាំងឡាយនេះ រមែងកើតឡើង ក៏កាលកើតឡើង រមែងមិនកើតឡើង ក្នុងទីជាមួយគ្នាទេ ។

(និយតសង្ខារ ២៧)

(ផស្សៈ)

(២៩៦) វិនិច្ឆ័យក្នុងបទទាំងនោះ សភាវៈណាពាល់ត្រូវ សភាវៈនោះ ឈ្មោះថា ផស្សៈ ។ ផស្សៈនោះនេះមានការពាល់ត្រូវជាលក្ខណៈ មានការប៉ះទង្គិចជាកិច្ច, មានការប្រជុំគ្នាជាផល, មានអារម្មណ៍ដែលមកក្នុងគន្លងជាហេតុ ។ មែនពិត ផស្សៈនេះ សូម្បីជាអរូបធម៌ក៏តែងប្រព្រឹត្តទៅដោយអាការៈជាហេតុពាល់ត្រូវ ក្នុងអារម្មណ៍ ម្យ៉ាងទៀត ផស្សៈនេះសូម្បីមិនជាប់ដោយឯកទេស ក៏គង់ញុាំងចិត្ត និង អារម្មណ៍ឲ្យប៉ះគ្នាបានដែរ ដូចជារូបប៉ះនឹងភ្នែក និង ដូចជាសម្លេងប៉ះនឹងត្រចៀកយ៉ាងដូច្នោះ ។ ផស្សៈនោះ ឈ្មោះថា មានការប្រជុំជាផល ព្រោះភាវៈនៃផស្សៈប្រាកដច្បាស់ហើយ ដោយអំណាចនៃហេតុរបស់ខ្លួន ពោលគឺការប្រជុំនៃពួកបី ។ ផស្សៈ ឈ្មោះថា មានអារម្មណ៍ដែលមកហើយកាន់វន្លង់ជាហេតុ ព្រោះកើតឡើង ក្នុងអារម្មណ៍ដែលការប្រជុំនៃគំនិតដ៏សមគួរដល់ផស្សៈនោះផង ដែលឥន្ទ្រិយផង តាក់តែងហើយ ដោយ



មិនមានអន្តរាយឡើយ ។ តែផស្សៈ គឺបុគ្គលគប្បីឃើញ ដូចជាមេគោមិនមានស្បែក ព្រោះភាវៈជាទីតាំងនៃវេទនា ។

(ចេតនា)

ធម្មជាតិណាសន្សំ ធម្មជាតិនោះ ឈ្មោះថា ចេតនា, អធិប្បាយថា ត្រេកត្រអាល ។ ចេតនានោះ មានភាវៈជាហេតុត្រិះរិះ ជាលក្ខណៈ, មានការប្រមូលមកជាកិច្ច, មានការចាត់ចែង ជាផល, មានការញុាំងកិច្ចរបស់ខ្លួន និង កិច្ចរបស់បុគ្គលដទៃឲ្យសំរេច ដូចជាសិស្សច្បង និង ជាងឈើជាធំជាដើម ។ ក៏ឯចេតនានោះ កាលប្រព្រឹត្តទៅ ប្រាកដដោយភាវៈញុាំងសម្បយុត្តធម៌ទាំងឡាយ ឲ្យខ្នះខ្នែងឡើង ក្នុងកិច្ចទាំងឡាយ មានកិរិយារលឹកនូវកម្ម យ៉ាងឆាប់រហ័សជាដើម ។

(វិតក្កៈ វិចារៈ បីតិ)

ពាក្យណា ជាពាក្យដែលលោកគប្បីពោល ក្នុងវិតក្កៈ, វិចារៈ និង បីតិទាំងឡាយ, ពាក្យទាំងអស់នោះ គឺលោកពោលហើយ ក្នុងអដ្ឋកថានៃបឋមជ្ឈាន ត្រង់បឋវីកសិណនិទ្ទេស ។

(វីរិយៈ)

ភាវៈនៃសេចក្តីព្យាយាម ឈ្មោះថា វីរិយៈ ។ ភាវៈនៃសេចក្តីព្យាយាមនោះ មានសេចក្តីអង់អាច ជាលក្ខណៈ, មានកិរិយាទំនុកបំរុងនូវសហជាតធម៌ទាំងឡាយ ជាកិច្ច, មានភាវៈនៃការមិនរួញរា ជាផល, មានសេចក្តីតក់ស្លុត ជាហេតុ ឬក៏ មានវត្ថុដែលបុគ្គលព្យាយាមប្រារព្ធហើយ ជាហេតុ ព្រោះព្រះពុទ្ធដីកាថាៈ បុគ្គលតក់ស្លុតហើយ រមែងតាំងទុកហើយ ដោយឧបាយនៃប្រាជ្ញា, បណ្ឌិត គប្បីជ្រាបថា សេចក្តីព្យាយាម ដែលបុគ្គលបានប្រារព្ធហើយ ដោយប្រពៃត្រឹមត្រូវ រមែងជា

ឬសគល់ នៃសម្បត្តិទាំងពួងទាំងឡាយ ។

(ជីវិត)

សហជាតធម៌ទាំងឡាយ រស់នៅដោយធម្មជាតនោះ ព្រោះហេតុនោះ ធម្មជាតនោះ ឈ្មោះថា ជីវិត ។ មួយទៀត ធម្មជាតនោះ រស់ដោយខ្លួនឯង ព្រោះហេតុនោះ ធម្មជាតនោះ ឈ្មោះថា ជីវិត ។ ម្យ៉ាងវិញទៀត ធម្មជាតនោះ ត្រឹមតែកិរិយារស់នៅប៉ុណ្ណោះ ព្រោះហេតុនោះ ធម្មជាតនោះ ទើបឈ្មោះថា ជីវិត ។ រីឯប្រភេទទាំងឡាយ មានលក្ខណៈជាដើម នៃជីវិតនោះ គឺបណ្ឌិត គប្បីជ្រាប តាមន័យដែលលោកពោលហើយ ក្នុងរូបជីវិត ។ ព្រោះថា ការធ្វើផ្សេងៗ គ្នា ក្នុងជីវិតទាំង ២ នុ៎ះ គឺ ជីវិតនោះ គឺជាជីវិតរបស់រូបធម៌ទាំងឡាយ, ជីវិតនេះ ជាជីវិត របស់អរូបធម៌ទាំងឡាយ ប៉ុណ្ណោះឯង ។

(សមាធិ)

ធម្មជាតណា តម្កល់ចិត្តទុកស្មើក្នុងអារម្មណ៍ ហេតុនោះ ធម្មជាតនោះ ឈ្មោះថា សមាធិ, មួយទៀត ធម្មជាតណា តាំងចិត្ត ដោយប្រពៃក្នុងអារម្មណ៍ ព្រោះហេតុនោះ ធម្មជាតនោះ ឈ្មោះថា សមាធិ ។ មួយវិញទៀត ធម្មជាតដែលឈ្មោះថា សមាធិ នោះ គឺ ការតម្កល់មាំនៃចិត្តហ្នឹងឯង ។

(លក្ខណៈ...នៃសមាធិ)

សមាធិនោះ មានការមិនរាយមាយ ជាលក្ខណៈ ឬក៏ មានការមិនរាយមាយ ជាលក្ខណៈ, មានការប្រមូលមក នូវសហជាតធម៌ទាំងឡាយ ជាកិច្ច ដូចជាទឹកនៃលំអិតសំរាប់ងូតទាំងឡាយ, មានការស្ងប់រម្ងាប់ ជាផល, មានសេចក្តីសុខ ដោយវិសេស ជាហេតុ, សមាធិនោះ



គឺបណ្ឌិត គប្បីឃើញថា មានកិរិយាឈប់ស្ងៀមនៃចិត្ត ដូចជាការឈប់ស្ងៀមនៃប្រឆេះរបស់ប្រទីបទាំងឡាយ ក្នុងទីដែលមិនមានខ្យល់ ។

(សទ្ធា)

សត្វទាំងឡាយជឿ ដោយធម្មជាតិនេះ ឬក៏ សត្វជឿ ដោយខ្លួនឯង ឬមួយ ក៏ធម្មជាតិនេះ ត្រឹមតែកិរិយាជឿ ព្រោះហេតុនោះ ធម្មជាតិនោះ ឈ្មោះថា សទ្ធា ។

(លក្ខណៈ ... នៃសទ្ធា)

សទ្ធានោះ មានការជឿ ជាលក្ខណៈ ឬក៏ មានការចុះស៊ប់ ជាលក្ខណៈ, មានការជ្រះថ្លា ជាកិច្ច ដូចជាកែវមណីសំរាប់ញ៉ាំងទឹក ឲ្យថ្លា ឬមួយក៏ មានការស្ទុះទៅ ជាកិច្ច ដូចជាស្ទុះទៅ ក្នុងកាលជាទីឆ្លងនូវអន្លង់, មានភាវៈនៃការមិនល្អក់ ជាផល ឬក៏ថា មានការចុះចិត្តស៊ប់ ជាផល, មានវត្ថុដែលគួរជឿ ជាហេតុ ឬក៏ មានអង្គនៃសោតាបត្តិមគ្គ មានការស្តាប់នូវព្រះសទ្ធម្មជាដើម ជាហេតុ, សទ្ធានោះ គឺបណ្ឌិត គប្បីឃើញដូចជាដៃ ដូចជាទ្រព្យ និង ដូចជាពូជទាំងឡាយ ។

(សតិ)

ជនទាំងឡាយរលឹកឃើញ ដោយធម្មជាតិនេះ ឬក៏ ធម្មជាតិណា រលឹកឃើញដោយខ្លួនឯង ឬមួយក៏ ធម្មជាតិនេះ ត្រឹមតែការរលឹក ព្រោះហេតុនោះ ធម្មជាតិនោះ ឈ្មោះថា សតិ ។

សតិនោះ មានការមិនស្រពេចស្រពិល ជាលក្ខណៈ, មានការមិនភ្លេច ជាកិច្ច, មានការរក្សា ជាផល ឬក៏ មានភាវៈនៃអារម្មណ៍ ក្នុងទីចំពោះមុខ ជាផល, មានសញ្ញាដ៏ខ្ជាប់ខ្ជួន ជាហេតុ ឬក៏ មានសតិបដ្ឋាន មានកាយានុបស្សនាសតិបដ្ឋានជាដើម ជាផល ។

ចំណែកខាងសតិ គឺបុគ្គលគប្បីឃើញ ដូចជាសសរគោម ព្រោះភាវៈនៃសតិធ្លាក់ចុះស៊ប់ហើយ ក្នុងអារម្មណ៍ផង ដូចជាឆ្មាំទ្វារ ព្រោះកិរិយារក្សានូវទ្វារ មានចក្ខុទ្វារជាដើមផង ។

(ហិរិ ឱត្តប្បៈ)

ធម្មជាតិណា គឺជនខ្មាស ចាកអំពើទុច្ចរិតទាំងឡាយ មានកាយ-ទុច្ចរិតជាដើម ហេតុនោះ ធម្មជាតិនោះ ឈ្មោះថា ហិរិ ។ ពាក្យថា ហិរិ នេះ ជាឈ្មោះនៃសេចក្ដីខ្មាស ។ ធម្មជាតណា តក់ស្លុត ព្រោះទុច្ចរិតទាំងឡាយនោះឯង ព្រោះហេតុនោះ ធម្មជាតនោះ ឈ្មោះថា ឱត្តប្បៈ ។ ពាក្យថា ឱត្តប្បៈ នេះ ជាឈ្មោះនៃសេចក្ដីតក់ស្លុតចំពោះបាប ។

(លក្ខណៈ...នៃហិរិ និង ឱត្តប្បៈ)

បណ្ដាហិរិ និង ឱត្តប្បៈទាំងនោះ ហិរិ មានការខ្ពើមចាកបាបជាលក្ខណៈ, ឱត្តប្បៈ មានការតក់ស្លុត ជាលក្ខណៈ ។ ហិរិ មានការមិនធ្វើបាបទាំងឡាយ ដោយអាការៈនៃការខ្មាស ជាកិច្ច, ឱត្តប្បៈ មានការមិនធ្វើបាបទាំងឡាយ ដោយអាការៈតក់ស្លុត ជាកិច្ច ។ ចំណែកខាងគុណជាតទាំង ២ យ៉ាងនេះ មានការរួញរាចាកបាប ជាបច្ចុប្បដ្ឋាន មានការគោរពចំពោះខ្លួន និង គោរពចំពោះបុគ្គលដទៃជាហេតុ ដោយបការៈដែលលោកពោលហើយហ្នឹងឯង ។ មែនពិត បុគ្គលធ្វើនូវខ្លួនឲ្យធ្ងន់ លះបង់នូវបាបដោយហិរិ ដូចជាស្រីក្រមុំ, លះបង់នូវបាបដោយឱត្តប្បៈ ធ្វើបុគ្គលដទៃឲ្យធ្ងន់ ដូចជាស្រីផ្កាមាស ។ ក៏ធម៌ទាំង ២ នេះ គឺបណ្ឌិត គប្បីឃើញថា ជាធម៌សំរាប់ឃុំគ្រងនូវលោក ។

(អលោភៈ អទោសៈ អមោហៈ)

សត្វទាំងឡាយ មិនល្មោភ ដោយសភាវៈនោះ ឬក៏ សភាវៈណា



មិនល្មោភ ដោយខ្លួនឯង ឬមួយក៏ ធម្មជាតនោះ ត្រឹមតែកិរិយាមិនលោភ ព្រោះហេតុនោះ សភាវៈនោះ ឈ្មោះថា អលោភៈ ។ សេចក្ដីពន្យល់ ក្នុងអទោសៈ និង អមោហៈទាំងឡាយហ្នឹងឯង ដូចជាន័យនេះដែរ គឺបណ្ឌិត គប្បីជ្រាបផងចុះ ។

(លក្ខណៈ...នៃអលោភៈ អទោសៈ អមោហៈ)

បណ្ដាធម៌ទាំង៣ នោះ អលោភៈ មានការមិនជាប់ជំពាក់ចិត្ត ក្នុងអារម្មណ៍ជាលក្ខណៈ ឬថា មានភាវៈមិនជាប់ចិត្ត ជាលក្ខណៈ ដូចជាដំណក់នៃទឹកមិនជាប់លើស្លឹកឈូក, មានការមិនហួងហែងជាកិច្ច ដូចជាភិក្ខុដែលរួចហើយ (ចាកយាវាសធម៌), មានភាវៈនៃកិរិយា មិនជាប់ស្អិត ជាផល ដូចជាបុរសដែលធ្លាក់ចុះហើយ ក្នុងវត្ថុមិនស្អាត ។

អទោសៈ មានការមិនកាច ជាលក្ខណៈ ឬក៏ មានការមិនខឹងជាលក្ខណៈ បីដូចជាមិត្តអ្នកប្រព្រឹត្តទៅតាម, មានការកំចាត់បង់នូវគំនុំជាកិច្ច, ម្យ៉ាងទៀត មានការកំចាត់បង់នូវសេចក្ដីក្ដៅក្រហាយ ជាកិច្ចដូចជាខ្លឹមចន្ទន៍, មានភាវៈនៃសេចក្ដីរីករាយ ជាផល ប្រៀបដូចជាព្រះច័ន្ទពេញវង់ ដូច្នោះឯង ។

អមោហៈ មានការត្រាស់ដឹង តាមសភាវៈពិត ជាលក្ខណៈ ឬក៏ មានការចាក់ធ្លុះ ដោយមិនភ្លាំងភ្លាត់ ជាលក្ខណៈ ដូចជាការចាក់ធ្លុះនូវកូនសរដែលខ្មាន់ធ្នូអ្នកឆ្លាតបាញ់ទៅហើយ, មានការបំភ្លឺនូវអារម្មណ៍ជាកិច្ច ដូចជាប្រទីប, មានការមិនភ្លេចភ្លាំង ជាផល ដូចជាបុរសអ្នកបង្ហាញនូវផ្លូវដល់ជនអ្នកដើរក្នុងព្រៃ ។

ក៏ធម៌ទាំងឡាយ ៣ នេះឯង គឺបណ្ឌិត គប្បីជ្រាបថា ជាឫសគល់នៃកុសលទាំងពួងទាំងឡាយ ។

(កាយប្បស្សទ្ធិ ចិត្តប្បស្សទ្ធិ)

ការរម្ងាប់នៃកាយ ឈ្មោះថា កាយប្បស្សទ្ធិ ។ ការរម្ងាប់នៃចិត្ត ឈ្មោះថា ចិត្តប្បស្សទ្ធិ ។ តែក្នុងពាក្យថា កាយប្បស្សទ្ធិនេះ ខន្ធទាំងឡាយបី មានវេទនាខន្ធជាដើម ឲ្យឈ្មោះថា កាយ ។ កាយប្បស្សទ្ធិ និង ចិត្តប្បស្សទ្ធិ រួមចូលគ្នាទាំង ២ នោះ មានការចូលទៅរម្ងាប់នូវសេចក្តីក្រវល់ក្រវាយនៃកាយ និង ចិត្ត ជាលក្ខណៈ, មានការប្របាច់ញាំញីចេញ នូវសេចក្តីក្តៅក្រហាយនៃកាយ និង ចិត្ត ជាកិច្ច, មានភាវៈនៃសេចក្តីត្រជាក់ ព្រោះកិរិយាមិនអន្ទះអន្ទែងនៃកាយ និង ចិត្តទាំងឡាយ ជាផល, មានកាយ និង ចិត្ត ជាហេតុ, គឺបណ្ឌិត គប្បីជ្រាបថា កាយប្បស្សទ្ធិ និង ចិត្តប្បស្សទ្ធិនេះ ជាទំនាស់ចំពោះកិលេសទាំងឡាយ មានឧទ្ធច្ចៈជាដើម ជាគ្រឿងធ្វើនូវកាយ និង ចិត្ត មិនឲ្យស្ងប់ ។

(កាយលហុតា ចិត្តលហុតា)

ភាវៈនៃកាយស្រាល ឈ្មោះថា កាយលហុតា ។ ភាវៈនៃចិត្តដ៏ស្រាល ឈ្មោះថា ចិត្តលហុតា ។ កាយលហុតា និង ចិត្តលហុតា នោះ មានការចូលទៅរម្ងាប់ នូវភាវៈនៃកាយ និង ចិត្ត ដ៏ធ្ងន់ ជាលក្ខណៈ, មានការញាំញីនូវភាវៈនៃកាយ និង ចិត្ត ដ៏ធ្ងន់ ជាកិច្ច, មានភាវៈនៃការមិនយឺតយូរនៃកាយ និង ចិត្ត ជាផល, មានកាយ និង ចិត្ត ជាហេតុ, លហុតានេះ បណ្ឌិត គប្បីជ្រាបថា ជាទំនាស់ចំពោះកិលេសមានថីនមិទ្ធៈជាដើម ជាគ្រឿងធ្វើនូវភាវៈនៃកាយ និង ចិត្តទាំងឡាយឲ្យធ្ងន់ ។

(កាយមុទុតា ចិត្តមុទុតា)

ភាវៈនៃកាយដ៏ទន់ ឈ្មោះថា កាយមុទុតា ។ ភាវៈនៃចិត្ត ដ៏ទន់ ឈ្មោះថា ចិត្តមុទុតា ។ កាយមុទុតា និង ចិត្តមុទុតា ២ នេះ មានការ



រម្ងាប់នូវកិរិយារឹងត្អឹង នៃកាយ និង ចិត្ត ជាកិច្ច, មានការមិនខ្ទាំងខ្ទប់ ជាផល, មានកាយ និង ចិត្ត ជាហេតុ, មុទុតានេះ គឺបណ្ឌិត គប្បីជ្រាបថា ជាគូទំនាស់ដល់កិលេស មានទិដ្ឋិ និង មានះ ជាគ្រឿងធ្វើនូវភាវៈនៃការរឹងត្អឹង នៃកាយ និង ចិត្តទាំងឡាយ ។

(កាយកម្មញ្ញតា ចិត្តកម្មញ្ញតា)

ភាវៈនៃកាយគួរដល់ការងារ ឈ្មោះថា កាយកម្មញ្ញតា ។ ភាវៈនៃចិត្តគួរដល់ការងារ ឈ្មោះថា ចិត្តកម្មញ្ញតា ។ កាយកម្មញ្ញតា និង ចិត្តកម្មញ្ញតានោះ មានការចូលទៅរម្ងាប់នូវភាវៈនៃកាយ និង ចិត្តមិនគួរដល់ការងារ ជាលក្ខណៈ, មានការញាំញីនូវភាវៈនៃកាយ និង ចិត្តមិនគួរដល់ការងារ ជាកិច្ច, មានកិរិយាដល់ព្រមនូវកិរិយាធ្វើនូវកាយនិងចិត្តទាំងឡាយឲ្យជាអារម្មណ៍ ជាផល, មានកាយ និង ចិត្ត ជាហេតុ, កម្មញ្ញតានេះ បណ្ឌិត គប្បីជ្រាបថា ជាគូទំនាស់ចំពោះកិលេស មាននីវរណៈដ៏សេស ជាគ្រឿងធ្វើនូវភាវៈនៃកាយ និង ចិត្តទាំងឡាយមិនគួរដល់ការងារជាដើម ជាគុណនាំមកនូវសេចក្តីជ្រះថ្លា ក្នុងវត្ថុដែលគួរជ្រះថ្លាទាំងឡាយ នាំមកនូវភាវៈគួរដល់ការប្រកបផ្សេងៗ ក្នុងការធ្វើប្រយោជន៍ទាំងឡាយ ដូចជាមាសដែលស្អាតបរិសុទ្ធ យ៉ាងនោះឯង ។

(កាយបាគុញ្ញតា ចិត្តបាគុញ្ញតា)

ភាវៈនៃកាយដ៏ស្ទាត់ ឈ្មោះថា កាយបាគុញ្ញតា ។ ភាវៈនៃចិត្តដ៏ស្ទាត់ជំនាញ ឈ្មោះថា ចិត្តបាគុញ្ញតា ។ កាយបាគុញ្ញតា និង ចិត្តបាគុញ្ញតាទាំង ២ នោះ មានភាវៈនៃការមិនមានជំងឺ នៃកាយ និង ចិត្ត ជាលក្ខណៈ, មានការញាំញី នូវការឈឺចាប់នៃកាយ និង ចិត្ត ជាកិច្ច, មានការមិនមានទោស ជាផល, មានកាយ និង ចិត្ត ជាហេតុ ។

បាគុញ្ញតានេះ បណ្ឌិត គប្បីជ្រាបថា ជាគូទំនាស់ដល់កិលេស មានការមិនមានសទ្ធាជាដើម ដែលជាគ្រឿងធ្វើនូវភាវៈនៃការឈឺចាប់នៃកាយ និង ចិត្តទាំងឡាយ ។

(កាយុជ្ជុកតា ចិត្តុជ្ជុកតា)

ភាវៈនៃកាយដ៏ត្រង់ ឈ្មោះថា កាយុជុកតា ។ ភាវៈនៃចិត្តដ៏ត្រង់ ឈ្មោះថា ចិត្តុជុកតា ។ កាយុជុកតា និង ចិត្តុជុកតានេះ មានភាវៈនៃកាយ និង ចិត្តដ៏ត្រង់ ជាលក្ខណៈ, មានការញាំញីនូវភាវៈនៃកាយ និង ចិត្តមិនកោងកាច ជាកិច្ច, មានភាវៈមិនរពើតរពើង ជាផល, មានកាយ និង ចិត្ត ជាហេតុ, ឧជុកតានេះ គឺបណ្ឌិតគប្បីជ្រាបថា ជាគូទំនាស់ដល់កិលេសមានមាយា និង សាថេយ្យជាដើម ដែលជាគ្រឿងធ្វើនូវភាព កោងកាច នៃកាយ និង ចិត្តទាំងឡាយ ។

(ឆន្ទះ)

(២៩៧) ពាក្យថា “ឆន្ទៈ” នេះ ជាឈ្មោះនៃការមានបំណងដើម្បីនឹងធ្វើ ។ ហេតុនោះ ឆន្ទៈនោះ ទើបមានភាវៈជាអ្នកចង់ធ្វើ ជាលក្ខណៈ, មានការស្វែងរកនូវអារម្មណ៍ ជាកិច្ច, មានភាវៈជាអ្នកត្រូវការ ដោយអារម្មណ៍ ជាផល ។ មានអារម្មណ៍នោះឯង ជាហេតុនៃឆន្ទៈនោះ ។

ចំណែកខាងឆន្ទៈនេះ គឺបណ្ឌិត គប្បីឃើញ ដូចជាកិរិយាលានូវដៃនៃចិត្ត ក្នុងការកាន់យកនូវអារម្មណ៍ ។

(អធិមោក្ខ)

ការចុះចិត្តស៊ប់ ឈ្មោះថា អធិមោក្ខ ។ ការចុះចិត្តស៊ប់នោះ មានការចូលចិត្តស៊ប់ ជាលក្ខណៈ, មានការមិនរើរុះ ជាកិច្ច, មានការដាច់ស្រេច ជាផល, មានធម៌ គឺបុគ្គលគប្បីចូលចិត្តស៊ប់ ជាហេតុ ។



អធិមោក្ខនេះ បណ្ឌិតគប្បីជ្រាបថា ដូចជាសសរខឿន ដោយភាវៈមិនមានកំរើកក្នុងអារម្មណ៍ ។

(មនសិការៈ)

ការធ្វើ ឈ្មោះថា ការៈ, ការធ្វើទុកក្នុងចិត្ត ឈ្មោះ មនសិការៈ, ចេតសិកធម៌ណា ធ្វើនូវចិត្តឲ្យផ្សេងគ្នាអំពីចិត្តមុន ព្រោះហេតុនោះឯង ចេតសិកនោះ ឈ្មោះថា មនសិការៈ ។ មនសិការៈនោះនេះ មាន ៣ ប្រការ គឺៈ ជាគ្រឿងទ្រទុកនូវអារម្មណ៍ ១ ជាគ្រឿងទ្រទុកនូវវិថី ១ ជាគ្រឿងឃាំងទុកនូវជវនៈ ១ ។

បណ្តាមនសិការៈទាំងបីនោះ មនសិការៈ ជាគ្រឿងឃាំងទុកនូវអារម្មណ៍ ឈ្មោះថា មនសិការៈ ព្រោះធ្វើទុកក្នុងចិត្ត ។ មនសិការៈនោះ មានការញ៉ាំងសម្បយុត្តធម៌ឲ្យស្ទុះទៅ ជាលក្ខណៈ, មានការចងក្រៀកទុកនូវសម្បយុត្តធម៌ទាំងឡាយ ក្នុងអារម្មណ៍ ជាកិច្ច, មានភាវៈបែរមុខឆ្ពោះទៅកាន់អារម្មណ៍ ជាផល, មានអារម្មណ៍ ជាហេតុ ។

មនសិការៈនេះ បណ្ឌិត គប្បីជ្រាបថា ជាធម៌រាប់បញ្ចូលហើយ ក្នុងសង្ខារក្ខន្ធ ព្រោះជាធម៌ញ៉ាំងសម្បយុត្តធម៌ឲ្យស្ទុះទៅ ក្នុងអារម្មណ៍ ដូចជានាយសារថី (ញ៉ាំងសេះឲ្យស្ទុះទៅ) យ៉ាងនោះឯង ។

ក៏ពាក្យនេះថា “វីថិប្បដិបាទកោ” គឺជាឈ្មោះ នៃបញ្ចទ្វារាវជ្ជនៈ ។ ពាក្យនេះថា “ជវនប្បដិបាទកោ” គឺជាឈ្មោះ នៃមនោទ្វារាវជ្ជនៈ ។

មនសិការៈទាំង ២ នោះ គឺលោកមិនបានអធិប្បាយហើយ ក្នុងអធិការនេះទេ ។

(តត្រមជ្ឈត្តតា)

ភាពនៃការព្រងើយកន្តើយ ក្នុងធម៌ទាំងឡាយនោះ ឈ្មោះថា

តត្រមជ្ឈត្តតា ។ តត្រមជ្ឈត្តតានោះ មានការនាំនូវចិត្ត និង ចេតសិកទាំងឡាយដោយស្មើ ជាលក្ខណៈ, មានការពត់នូវភាវៈលើស និង ខ្វះ ជាកិច្ច ឬក៏ មានការចូលទៅកាត់ផ្ដាច់នូវការធ្លាក់ចុះទៅក្នុងពួក ជាកិច្ច, មានភាវៈព្រងើយកន្ដើយ ជាផល ។ តត្រមជ្ឈត្តតានេះ ព្រោះភាវៈព្រងើយកន្ដើយនៃចិត្ត និង ចេតសិកទាំងឡាយ បណ្ឌិត គប្បីឃើញថា ដូចជានាយសារថីសម្លឹងមើល (ព្រងើយៗ) នូវសេះអាជានេយ្យទាំងឡាយ ដែលបោលទៅយ៉ាងស្រួល ដូច្នោះឯង ។

(អនិយតសង្ខារ ៥)

ករុណាក្ដី មុទិតាក្ដី គឺបណ្ឌិត គប្បីជ្រាប តាមន័យដែលលោកពោលហើយត្រង់ព្រហ្មវិហារនិទ្ទេស ។ មែនពិត ករុណា និង មុទិតាទាំងពីរនេះ ជារូបាវចរ ដល់ហើយនូវអប្បនា, ករុណា និង មុទិតានោះ ជាកាមាវចរៈតែប៉ុណ្ណោះ ព្រោះហេតុនោះ សេចក្ដីប្លែកគ្នាប៉ុណ្ណោះឯង ។ តែអាចារ្យទាំងឡាយពួកខ្លះ ប៉ងយកនូវមេត្តាចេតសិក និង ឧបេក្ខាចេតសិកទាំងឡាយហ្នឹងឯងក្នុងអនិយតសង្ខារទាំងឡាយ ។ ការប៉ុនប៉ងយកនោះពុំគួរជឿបានទេ ។ បើពោលតាមសេចក្ដី មេត្តា ជាគុណជាតិពុំមានទោសទេ ។ ឧបេក្ខា ចាត់ជា តត្រមជ្ឈត្តុបេក្ខា តែម្តងដូច្នេះឯង ។

(កាយទុច្ចរិតវិរតិ)

ការវៀរចាកកាយទុច្ចរិត ឈ្មោះថា កាយទុច្ចរិតវិរតិ ។ ន័យនេះ (ដូចគ្នានឹង) ន័យដ៏សេសទាំងឡាយដែរ ។ បើពោលតាមអាការៈមានលក្ខណៈជាដើម វិរតិទាំងនេះ មាន ៣ យ៉ាង មានការមិនប្រព្រឹត្តិកន្លងនូវវត្ថុទាំងឡាយ មានកាយទុច្ចរិតជាដើម, អធិប្បាយថា មានការមិនល្មើសជាលក្ខណៈ, វិរតិទាំងបីនេះ មានការរួញចាកវត្ថុមានកាយទុច្ចរិត



ជាដើម ជាកិច្ច, មានការមិនធ្វើ ជាផល, មានគុណ គឺ សទ្ធា, ហិរិ ឱត្តប្បៈ និង អប្បិច្ឆតាជាដើម ជាហេតុ ។ វិរតិនេះ គឺបណ្ឌិត គប្បីជ្រាបថា មានភាវៈនៃចិត្តបែរមុខចាកកិរិយាធ្វើនូវបាប ។

(២៩៨) សង្ខារទាំងឡាយ ៣៦ នេះ គឺបណ្ឌិត គប្បីជ្រាបថា រមែងដល់នូវការប្រមូលមក ដោយកុសលវិញ្ញាណ ជាកាមាវចរៈ ទីមួយ ដូចរៀបរាប់មកនេះ ។ ក៏ពួកសង្ខារទាំង ៣៦ ដែលសម្បយោគដោយកាមាវចរកុសលវិញ្ញាណដំបូង យ៉ាងណា, សង្ខារទាំងឡាយដែលសម្បយោគដោយកុសលវិញ្ញាណទីពីរ ក៏យ៉ាងនោះដែរ។ ក៏ហេតុត្រឹមតែភាវៈប្រកបដោយសង្ខារ ជាការប្លែកគ្នា ក្នុងកាមាវចរកុសលវិញ្ញាណទីពីរនេះ ។ ក៏សង្ខារដ៏សេសទាំងឡាយលើកលែងតែអមោហៈបណ្ឌិតគប្បីជ្រាប តាមកាមាវចរកុសលវិញ្ញាណទីបី ផងចុះ ។ ចំណែកខាងកាមាវចរកុសលវិញ្ញាណ ទី ៤ ក៏ដូចគ្នាដែរ ។ ការប្លែកគ្នាតែក្នុងវិញ្ញាណ ទី ៤ នេះ ជាសសង្ខារប៉ុណ្ណោះឯង ។ ក៏ក្នុងសង្ខារទាំងឡាយដែលខ្ញុំពោលហើយ ក្នុងកាមាវចរកុសលទីមួយ សង្ខារដ៏សេសទាំងឡាយ លើកលែងតែបីតិចេញ រមែងដល់នូវការប្រមូលចូល ដោយកាមាវចរកុសល ទី ៥ ។ ក៏សង្ខារដ៏សេស ដែលសម្បយោគ ដោយកាមាវចរកុសលវិញ្ញាណ ទី ៥ យ៉ាងណា, ដែលសម្បយោគ ដោយកាមាវចរកុសលវិញ្ញាណ ទី ៦ ក៏យ៉ាងនោះដែរ ។ ព្រោះថា ហេតុត្រឹមតែភាវៈប្រកបដោយសង្ខារ ជាសេចក្ដីប្លែកគ្នាត្រង់បទនេះ ។ ចំណែកសង្ខារទាំងឡាយដ៏សេស លើកលែងតែអមោហៈចេញ បណ្ឌិត គប្បីជ្រាប តាមកាមាវចរកុសលវិញ្ញាណ ទី ៧ ផងចុះ ។ សង្ខារដ៏សេសដែលសម្បយោគដោយកាមាវចរកុសលវិញ្ញាណទី៨ ក៏យ៉ាងនោះដែរ ។

សេចក្តីប្លែកគ្នា ក្នុងវិញ្ញាណ ទី៨ នេះ គ្រាន់តែជាសសង្ខារតែប៉ុណ្ណោះ ។

ក៏ក្នុងសង្ខារទាំងឡាយ ដែលលោកពោលហើយ ក្នុងកាមាវចរកុសលវិញ្ញាណ ទី១, សង្ខារ ដ៏សេសទាំងឡាយ វៀរលែងតែវិរតិ ៣ រមែងដល់នូវការប្រមូលចូលគ្នា ដោយកាមាវចរកុសលទី១ ក្នុងរូបាវចរកុសលទាំងឡាយ ។ តអំពីនោះ សង្ខារដ៏សេសទាំងឡាយ វៀរចាកវិតក្កៈ បណ្ឌិត គប្បីជ្រាបថា ដល់នូវការប្រមូលចូលគ្នា ដោយកាមាវចរកុសលវិញ្ញាណ ទី ២ ។ តអំពីនោះ សង្ខារ ដ៏សេសទាំងឡាយ វៀរចាកវិចារៈ បណ្ឌិត គប្បីជ្រាបថា ដល់នូវការប្រមូលចូល ដោយកាមាវចរកុសលវិញ្ញាណទីបីចុះ ។ តពីនោះ សង្ខារដ៏សេសទាំងឡាយ វៀរចាកបីតិ បណ្ឌិតគប្បីជ្រាបថា ដល់នូវការប្រមូលចូល ដោយកុសលវិញ្ញាណ ទី៤ ចុះ ។ តពីនោះ ក្នុងពួកសង្ខារដែលជាអនិយតៈ សង្ខារដ៏សេសទាំងឡាយ វៀរចាកករុណា និង មុទិតា បណ្ឌិត គប្បីជ្រាបថា ដល់នូវការប្រមូលចូល ដោយកាមាវចរកុសលវិញ្ញាណ ទី៥ ផងចុះ ។

សង្ខារទាំងឡាយនោះឯង រមែងដល់នូវការប្រមូលចូល ក្នុងអារុប្បកុសលវិញ្ញាណទាំង ៤ ។ ក៏ភាវៈនៃអរូបាវចរកុសលហ្នឹងឯង ជាសេចក្តីប្លែកគ្នា ក្នុងអារុប្បកុសលនេះ ។

ក្នុងលោកុត្តរវិញ្ញាណទាំងឡាយ សង្ខារទាំងឡាយនោះ ក្នុងមគ្គវិញ្ញាណដែលមានក្នុងបឋមជ្ឈាន បណ្ឌិតគប្បីជ្រាប តាមន័យដែលពោលហើយ ក្នុងបឋមរូបាវចរវិញ្ញាណជាមុន, សង្ខារទាំងឡាយ ក្នុងមគ្គវិញ្ញាណផ្សេងដោយមគ្គវិញ្ញាណ មានទុតិយជ្ឈានជាដើម បណ្ឌិតគប្បីជ្រាប តាមន័យដែលលោកពោលហើយ ក្នុងវិញ្ញាណទាំងឡាយ មានទុតិយរូបាវចរវិញ្ញាណជាដើម ។ ក៏ការប្លែកគ្នានេះ ក្នុងលោកុត្តរ-



វិញ្ញាណ គឺការមិនមាននៃករុណា និង មុទិតា ១ វិរតិជានិយតសង្ខារ ១ ជាលោកុត្តរវិញ្ញាណ ១ ។ សង្ខារទាំងឡាយជាកុសលហ្នឹងឯង បណ្ឌិតគប្បីជ្រាប ជាដំបូង ត្រឹមតែប៉ុណ្ណោះ ។

(អកុសលសង្ខារ លោភមូល)

បណ្តាអកុសលសង្ខារទាំងឡាយ សង្ខារ ១៧ ដែលសម្បយុត្តដោយកុសលវិញ្ញាណ ទី១ ក្នុងលោភមូល គឺ និយតសង្ខារ ១៣ មកហើយដោយរូបរួម, យេវាបនកសង្ខារ ៤ ។ ក្នុងអកុសលសង្ខារ ១៧ នោះ សង្ខារ ១៣ នេះ ជានិយតៈ មកហើយដោយរូបរួម គឺ ផស្សៈ ១, ចេតនា ១, វិតក្កៈ ១, វិចារៈ ១, បីតិ ១, វីរិយៈ ១, ជីវិត ១, សមាធិ១, អហិរិកៈ ១, អនោត្តប្បៈ ១, លោភៈ ១, មោហៈ ១ មិច្ឆាទិដ្ឋិ ១ ។ សង្ខារទាំងឡាយ ៤ នេះ គឺ : ឆន្ទៈ ១, អធិមោក្ខៈ ១, ឧទ្ធច្ចៈ ១, មនសិការៈ ១ ឈ្មោះថា យេវាបនកសង្ខារ ។

(អហិរិកៈ និង អនោត្តប្បៈ)

បណ្ឌិត គប្បីជ្រាបអធិប្បាយ ក្នុងអកុសលសង្ខារទាំងឡាយនោះ (ដូចតទៅនេះ) :

បុគ្គលណា មិនអៀនខ្មាស ហេតុនោះ បុគ្គលនោះ ហៅថា អហិរិកៈ ។ ភាវៈនៃការមិនអៀនខ្មាស ហៅថា អហិរិកៈ ។ ភាវៈ នៃការមិនខ្លាចបាប ឈ្មោះថា អនោត្តប្បៈ ។ បណ្តាអកុសលទាំង ២ នោះ អហិរិកៈ មានការមិនខ្ពើមចាកទុច្ចរិតទាំងឡាយ មានកាយទុច្ចរិតជាដើម ជាលក្ខណៈ ឬក៏ មានការមិនខ្មាស ចាកទុច្ចរិតទាំងឡាយ ជាលក្ខណៈ, អនោត្តប្បៈ មានភាវៈនៃការមិនព្រឺព្រួច ចាកទុច្ចរិតទាំងឡាយនោះឯង ជាលក្ខណៈ ឬក៏ មានការមិនតក់ស្លុត ចាកទុច្ចរិតទាំង

ឡាយ ជាលក្ខណៈ ។ នេះ គឺជាសេចក្តីសង្ខេប ក្នុងអហិរិកៈ និង អនោត្តប្បៈនេះ ។ ចំណែកសេចក្តីពិស្តារ បណ្ឌិត គប្បីជ្រាប ដោយអំណាចនៃការផ្ទុយគ្នានៃហិរិ និង ឱត្តប្បៈទាំងឡាយ ដែលលោកបានពោលមកហើយ ។

(លោភៈ មោហៈ)

សត្វទាំងឡាយ លោភលន់ ដោយចេតសិកធម៌នោះជាហេតុ ចេតសិកធម៌នោះ ទើបឈ្មោះថា លោភៈ ឬថា ចេសិកធម៌ណា លោភ ដោយខ្លួនឯង ចេតសិកធម៌នោះ ឈ្មោះថា លោភៈ ឬក៏ ធម្មជាតនោះ ត្រឹមតែកិរិយាលោភលន់ ព្រោះហេតុនេះ ទើបឈ្មោះថា លោភៈ ។

សត្វទាំងឡាយ វង្វេងដោយចេតសិកធម៌នោះជាហេតុ ចេតសិកធម៌នោះ ទើបឈ្មោះថា មោហៈ ឬក៏ ចេតសិកធម៌ណា វង្វេងដោយខ្លួនឯង ចេតសិកធម៌នោះ ឈ្មោះថា មោហៈ ឬក៏ ធម្មជាតនោះ ត្រឹមតែកិរិយាវង្វេង ព្រោះហេតុនោះ ទើបឈ្មោះថា មោហៈ ។

បណ្តាលោភៈ និង មោហៈទាំងឡាយនោះ លោភៈ មានការកាន់យកនូវអារម្មណ៍ ជាលក្ខណៈ ដូចជាទ្រុងដាក់នូវសត្វស្វា, មានការជាប់នៅស្អិត ជាកិច្ច ដូចជាដុំសាច់ដែលបុគ្គលបោះទៅហើយ ក្នុងអំបែងដ៏ក្តៅ, មានការមិនបរិច្ចាគ ជាផល ដូចជាប្រេងសំរាប់បន្តក់, មានការឃើញនូវសេចក្តីត្រេកអរ ក្នុងធម៌ដែលគួរប្រកបទាំងឡាយ ជាហេតុ ។

លោភៈនេះ បណ្ឌិត គប្បីឃើញថា កាលចំរើនឡើង ដោយភាវៈដូចជាស្ទឹងគឺតណ្ហា រមែងចាប់(សត្វ)ឲ្យទៅកាន់អបាយតែម្យ៉ាង ដូចជាស្ទឹងមានខ្សែទឹកដ៏ខ្លាញ់តែងក្បួចទៅកាន់មហាសមុទ្រតែម្យ៉ាងដូច្នោះឯង ។

មោហៈ មានភាវៈនៃចិត្តងងឹត ជាលក្ខណៈ ឬក៏ មានការមិនដឹង



ជាលក្ខណៈ, មានការមិនត្រាស់ដឹង ជាកិច្ច ឬក៏ មានការបិទបាំងនូវសភាវៈនៃអារម្មណ៍ ជាកិច្ច, មានការប្រតិបត្តិមិនត្រូវ ជាផល ឬមួយក៏មានការងងឹត ជាផល, មានការមិនធ្វើទុកក្នុងចិត្តដោយឧបាយនៃប្រាជ្ញាជាហេតុ, មោហៈនេះ បណ្ឌិត គប្បីឃើញថា ជាឫសគល់នៃអកុសលទាំងពួងទាំងឡាយ ។

(មិច្ឆាទិដ្ឋិ)

សត្វទាំងឡាយ ឃើញខុស ដោយធម្មជាតិនោះ ឬក៏ ធម្មជាតិណា យល់ខុស ដោយខ្លួនឯង ហេតុនោះ ធម្មជាតិនោះ ឈ្មោះថា មិច្ឆាទិដ្ឋិ ឬមួយក៏ ធម្មជាតិនេះ គ្រាន់តែយល់ខុសប៉ុណ្ណោះ ព្រោះហេតុនោះ ឈ្មោះថា មិច្ឆាទិដ្ឋិ ។

មិច្ឆាទិដ្ឋិនោះ មានការប្រកាន់ស្អិត ដោយឧបាយមិនមែនជាប្រាជ្ញាជាលក្ខណៈ, មានការស្ទាបអង្អែលជាកិច្ច, មានការប្រកាន់ស្អិតខុសជាផល, មានភាវៈជាអ្នកមិនចង់ឃើញ នូវព្រះអរិយៈទាំងឡាយជាដើមជាហេតុ, មិច្ឆាទិដ្ឋិនេះ បណ្ឌិតគប្បីឃើញថា ជាទោសដ៏ក្រៃលែង ។

(ឧទ្ធច្ចៈ)

ភាវៈនៃចិត្តដែលអណ្តែតអណ្តូង ឈ្មោះថា ឧទ្ធច្ចៈ ។ ឧទ្ធច្ចៈ នោះ មានការមិនចូលទៅរម្ងាប់ ជាលក្ខណៈ បីដូចជាទឹកដែលកំរើកហើយដោយខ្យល់, មានការមិនឈប់នៅស្ងៀម ជាកិច្ច ដូចជាទង់ និង ផ្កាំងនៃសំពត់ដែលត្រូវខ្យល់បក់បោក, មានភាវៈភ្ញាក់ផ្អើល ជាផល ដូចជាផេះដែលប៉ើងឡើងដោយការខ្ទាំងខ្ទប់នឹងថ្ម, មានការមិនស្ងប់នៃចិត្ត និង កិរិយាមិនធ្វើទុកក្នុងចិត្ត ដោយឧបាយនៃប្រាជ្ញា ជាហេតុ, ឧទ្ធច្ចៈ នេះ គឺបណ្ឌិត គប្បីឃើញថា ជាការក្រឡុកនៃចិត្ត ។

អកុសលសង្ខារទាំងឡាយដ៏សេស បណ្ឌិត គប្បីជ្រាប តាមន័យដែលលោកពោលហើយ ក្នុងកុសលសង្ខារ ។ ក៏ភាវៈនៃសង្ខារជាអកុសល និង ជាចេតសិកធម៌ដ៏លាមកផង, ភាវៈនៃសង្ខារជាអកុសលប៉ុណ្ណោះ ជាសេចក្ដីប្លែកគ្នា នៃអកុសលសង្ខារនេះ អំពីកុសលសង្ខារទាំងឡាយនោះ ។

សង្ខារទាំងឡាយ ១៧ នេះ គឺបណ្ឌិត គប្បីជ្រាបថា ដល់នូវការប្រមូលរួមដោយអកុសលវិញ្ញាណជាដំបូង ដូចបានរៀបរាប់មកនេះ ។ ក៏សង្ខារទាំងឡាយ ១៧ គឺបណ្ឌិត គប្បីជ្រាប ដោយអកុសលវិញ្ញាណជាដំបូង យ៉ាងណា, សង្ខារទាំងឡាយ ១៧ នោះ គឺបណ្ឌិតគប្បីជ្រាបដោយអកុសលវិញ្ញាណទីពីរហ្នឹងឯង យ៉ាងនោះដែរ ។ ចំណែកខាងការប្លែកគ្នា ក្នុងអកុសលវិញ្ញាណទីពីរនេះ ក៏គឺភាវៈនៃហេតុប្រព្រឹត្តិទៅមួយអន្លើដោយសង្ខារ និង ភាពនៃថីនមិទ្ធៈ ដែលជាអនិយតៈ ។

(ថីនមិទ្ធៈ)

ក្នុងថីនមិទ្ធៈនោះ ភាវៈនៃសេចក្ដីធុញទ្រាន់ ឈ្មោះថា ថីនៈ, ភាពនៃសេចក្ដីងោកងុយ ឈ្មោះថា មិទ្ធៈ, អធិប្បាយថា : ភាពនៃការមិនខ្មីឃ្មាត និង លិចចុះ និង ការកំចាត់បង់ ព្រោះមិនមាននៃសតិ, ភាពនៃការធុញទ្រាន់ និងភាពនៃការងោកងុយ ឈ្មោះថា ថីនមិទ្ធៈ ។ បណ្ដាថីនៈ និង មិទ្ធៈ ទាំងពីរនោះ ថីនៈ មានការមិនខ្មីឃ្មាត ជាលក្ខណៈ, មានការបន្ទោបង់នូវភាវៈនៃសេចក្ដីព្យាយាម ជាកិច្ច, មានការលិចចុះជាផល, មិទ្ធៈ មានភាវៈជាអ្នកមិនគួរដល់ការងារ ជាលក្ខណៈ, មានការជ្រប់ចុះ ជាហេតុ, មានភាពនៃការរួញរា ជាផល ឬក៏ មានការងោកងុយ ជាផល ។ ថីនៈ និង មិទ្ធៈទាំងពីរយ៉ាង មានការមិនធ្វើទុកក្នុងចិត្ត



ដោយឧបាយនៃប្រាជ្ញា ព្រោះការមិនត្រេកអរ និង ការមិតពត់កាយជាដើម ជាហេតុ ។

បណ្ដាសង្ខារទាំងឡាយ ដែលលោកពោលហើយ ក្នុងអកុសល-វិញ្ញាណទីមួយ សង្ខារដ៏សេសទាំងឡាយ លើកលែងនូវមិច្ឆាទិដ្ឋិចេញ បណ្ឌិត គប្បីជ្រាបថា សម្បយោគហើយ ដោយកុសលវិញ្ញាណទីបី ។ តែមានះ ក្នុងអកុសលវិញ្ញាណទី ៣ នេះ មិនទៀងទាត់, នេះជាសេចក្ដីប្លែកគ្នា បណ្ឌិត គប្បីជ្រាបផងចុះ ។

(មានះ)

មានះនោះ មានការលើកដំកើងខ្លួនឲ្យខ្ពស់ ជាលក្ខណៈ, មានការលើកអំនួត ជាកិច្ច, មានភាវៈញាប់ញ័រដូចជាទង់ ជាផល, មានលោភៈដែលប្រាសចាកទិដ្ឋិ ជាហេតុ, មានះនេះ គឺបណ្ឌិត គប្បីឃើញថា ដូចជាមនុស្សឆ្កួត ។

ក្នុងសង្ខារទាំងឡាយ ដែលលោកពោលហើយ ក្នុងអកុសល-វិញ្ញាណ ទី ២, សង្ខារទាំងឡាយដ៏សេស លើកលែងតែមិច្ឆាទិដ្ឋិចេញ បណ្ឌិត គប្បីជ្រាបថា សម្បយោគដោយអកុសលវិញ្ញាណទី៤ ។ សូម្បីក្នុងអកុសលវិញ្ញាណ ទី ៤ នេះឯង មានះ ក៏ជាសង្ខារ ក្នុងអនិយតៈទាំងឡាយ ដូចគ្នាដែរ ។ ឯក្នុងសង្ខារទាំងឡាយ ដែលលោកពោលហើយ ក្នុងអកុសលវិញ្ញាណទីមួយ សង្ខារទាំងឡាយដ៏សេស លើកលែងតែបីតិ ដល់នូវការប្រមូលចូល ដោយអកុសលវិញ្ញាណទីប្រាំ ។ ក៏សង្ខារទាំងឡាយ ដល់នូវការប្រមូលចូល ដោយអកុសលវិញ្ញាណទីប្រាំ យ៉ាងណាមិញ, សង្ខារទាំងឡាយ រមែងដល់នូវការប្រមូលចូលដោយអកុសលវិញ្ញាណទីប្រាំមួយ ក៏យ៉ាងនោះដែរ ។

ភាពនៃសង្ខារប្រកប ដោយការជាស់តឿនក្តី ភាពនៃថីនមិទ្ធៈ មិនទៀងទាត់ក្តី ជាសេចក្តីប្លែកគ្នា ក្នុងអកុសលវិញ្ញាណ ទី ៦ នេះ ។ ក្នុងសង្ខារទាំងឡាយ ដែលលោកពោលហើយ ក្នុងអកុសលវិញ្ញាណ ទី ៥ សង្ខារទាំងឡាយ ដ៏សេសសល់ លើកលែងតែទិដ្ឋិចេញ បណ្ឌិត គប្បីជ្រាបថា សម្បយោគ ដោយអកុសលវិញ្ញាណ ទី ៧ ។ ប៉ុន្តែមានះ ក្នុងអកុសលវិញ្ញាណ ទី ៧ នេះ ចាត់ជា អនិយតៈ ។ បណ្តាសង្ខារទាំងឡាយដែលលោកពោលហើយ ក្នុងអកុសលវិញ្ញាណ ទី ៦ សង្ខារទាំងឡាយដ៏សេស លើកលែងទិដ្ឋិចេញ បណ្ឌិត គប្បីជ្រាបថា សម្បយោគ ដោយអកុសលវិញ្ញាណ ទី៨ ។ ក៏សូម្បីក្នុងអកុសលវិញ្ញាណ ទី៨ នេះ មានះ ក៏ជាសង្ខារ ក្នុងពួកអនិយតៈទាំងឡាយ ដូចគ្នាដែរ ។

(អកុសលសង្ខារ ទោសមូល ១៨)

(៣០០) ចំណែកក្នុងទោសមូលទាំង ២ ជាដំបូង អកុសលសង្ខារទាំងឡាយ ដែលសម្បយុត្តដោយអកុសលវិញ្ញាណទី១ មាន ១៨ គឺ : ជាអនិយតៈ មកហើយដោយរូបរបស់ខ្លួន ១១, ជាយេវាបនកៈ ៤, ជាអនិយតៈ ៣ ។ ក្នុងអកុសលសង្ខារទាំង ១៨ នោះ សង្ខារទាំងឡាយ ១១ គឺ : ផស្សៈ, ចេតនា, វិតក្កៈ, វិចារៈ, វិរិយៈ, ជីវិត, សមាធិ, អហិរិកៈ, អនោតប្បៈ, ទោសៈ, មោហៈ, ទាំងអស់នេះ ជាអនិយតៈ មកដោយរូបរបស់ខ្លួន ។ សង្ខារ ៤ យ៉ាងនេះ គឺ ឆន្ទៈ ១, អធិមោក្ខ ១, ឧទ្ធច្ចៈ ១, មនសិការៈ ១ ហៅថា យេវាបនកៈ ។ សង្ខារទាំងឡាយ ៣ នេះ គឺ ឥស្សា ១, មច្ឆរិយៈ ១, កុក្កុច្ចៈ ១ ឈ្មោះថា អនិយតសង្ខារ ។

(ទោសៈ)

គប្បីជ្រាបវិនិច្ឆ័យ ក្នុងបទទាំងនោះ សត្វទាំងឡាយប្រទូស្ត ដោយ



ចេតសិកធម៌នោះ ព្រោះហេតុនេះ ចេតសិកធម៌នោះ ទើបឈ្មោះថា ទោសៈ ឬក៏ ចេតសិកធម៌ណា ប្រទូស្តដោយខ្លួនឯង ព្រោះហេតុនេះ ចេតសិកធម៌នោះ ទើបឈ្មោះថា ទោសៈ ឬមួយក៏ ធម្មជាតនោះ ត្រឹមតែការប្រទូស្ត ព្រោះហេតុនោះ ទើបឈ្មោះថា ទោសៈ ។

ទោសៈនោះ មានភាវៈកាច ជាលក្ខណៈ ដូចជាអសិរពិសដែលបុគ្គលប្រហារហើយផង មានការខ្ជាស់ឡើងនូវពិស ជាកិច្ច ដូចជាការជ្រៀតជ្រែកនូវពិសផង មានការដុតនូវនិស្ស័យរបស់ខ្លួន ជាកិច្ច ដូចជាភ្លើងព្រៃផង មានការប្រទូស្ត ជាផល ដូចជាសត្រូវដែលបានឱកាសហើយផង មានវត្ថុសំរាប់គុំគួន ជាហេតុ, ទោសៈនេះ គឺបណ្ឌិត គប្បីឃើញ ដូចជាទឹកមូតស្អុយដែលបុគ្គលលាយហើយដោយថ្នាំពិស ។

(ឥស្សា)

ការប្រព្រឹត្តិប្រណែន ឈ្មោះថា ឥស្សា ។ ការប្រណែននោះ មានការប្រណែនចំពោះសម្បត្តិនៃជនដទៃទាំងឡាយ ជាលក្ខណៈ, មានការមិនពេញចិត្ត ក្នុងសម្បត្តិទាំងឡាយនោះៗ ជាកិច្ច, មានភាវៈបែរមុខចេញអំពីសម្បត្តិរបស់អ្នកដទៃនោះ ជាផល, មានសម្បត្តិនៃបុគ្គលដទៃជាហេតុ, ឥស្សា នេះ គឺបណ្ឌិតគប្បីយល់ថា ជាសំយោជនៈ ។

(មច្ឆរិយៈ)

ភាពនៃការលាក់លៀម ហៅថា មច្ឆរិយៈ ។ មច្ឆរិយៈនោះ មានការហួងហែងនូវសម្បត្តិទាំងឡាយរបស់ខ្លួន ដែលខ្លួនបានហើយ ឬថាគឺខ្លួនគប្បីបាន ជាលក្ខណៈ, មានការមិនអត់ទ្រាំ នូវភាវៈនៃសម្បត្តិទាំងឡាយរបស់ខ្លួននោះឯង នឹងជារបស់ទូទៅ ដោយជនទាំងឡាយដទៃ ជាកិច្ច, មានមុខជូរ ជាផល ឬក៏ មានភាវៈនៃការរួញរា ជាផល, មាន

សម្បត្តិរបស់ខ្លួន ជាហេតុ, មច្ឆរិយៈនេះ គឺបណ្ឌិត គប្បីឃើញថា ជាភាពនៃចិត្តមានការខុសប្លែក ។

(កុក្កុច្ចៈ)

អំពើដែលបុគ្គលធ្វើ ដែលបណ្ឌិតគួរខ្ពើមរអើម ឈ្មោះថា កុកតៈ ភាពនៃអំពើដែលបណ្ឌិតគួរខ្ពើម ឈ្មោះថា កុក្កុច្ចៈ ។ កុក្កុច្ចៈ នោះ មានការក្តៅជាខាងក្រោយ ជាលក្ខណៈ, មានការសោកស្តាយនូវអំពើដែលបុគ្គលធ្វើហើយនិងមិនធ្វើ ជាកិច្ច, មានការស្តាយក្រោយ ជាផល, មានអំពើដែលបុគ្គលធ្វើហើយ និង អំពើដែលបុគ្គលមិនធ្វើហើយ ជាហេតុ, កុក្កុច្ចៈ នេះ គឺបណ្ឌិតគប្បីឃើញថា ដូចជាភាពខ្ញុំគេ ។

អកុសលសង្ខារទាំងឡាយ ក្រៅអំពីនោះ មានប្រការ គឺលោកពោលរួចហើយ ដូច្នោះឯង ។

សង្ខារទាំងឡាយ ១៨ នេះ គឺបណ្ឌិតគប្បីជ្រាបថា ដល់នូវការរួមដោយទោសមូល ជាដំបូង ដូចរៀបរាប់មកនេះ ។ ក៏សង្ខារទាំងឡាយ ១៨ គឺបណ្ឌិត គប្បីជ្រាប ដោយអកុសលវិញ្ញាណទីមួយ យ៉ាងណា, សង្ខារទាំងឡាយ រមែងដល់នូវការចូលរួមដោយអកុសលវិញ្ញាណទីពីរក៏យ៉ាងនោះដែរ ។ ភាពនៃហេតុប្រព្រឹត្តិទៅមួយអន្លើដោយសង្ខារ និងការកើតព្រមនៃថីនៈ និង មិទ្ធៈ ក្នុងអនិយតៈទាំងឡាយជាការប្លែកគ្នា ។

(អកុសលសង្ខារ មោហមូល ១៣)

(៣០១) ចំណែកក្នុងមោហមូល ២ ពោលដោយសង្ខារដែលសម្បយុត្តដោយវិចិកិច្ឆា ជាដំបូង សង្ខារទាំងឡាយ ១៣ គឺ សង្ខារដែលមកដោយរូបរបស់ខ្លួន មាន ១១ គឺ : ផស្សៈ, ចេតនា, វិតក្កៈ, វិចារៈ, វិរិយៈ, ជីវិត, ចិត្តដ្ឋិតិ, អហិរិក, អនោត្តប្បៈ, មោហៈ, វិចិកិច្ឆា



និង សង្ខារដែលជាយេវាបនកៈ ២ គឺ ឧទ្ធច្ចៈ, មនសិការៈ ។

ក្នុងពាក្យទាំងនោះ ពាក្យថា “ចិត្តដ្ឋិតិ” សំដៅយកអាការៈគ្រាន់តែការតាំងនៅនៃបវត្តិចិត្ត បានដល់ សមាធិ មានកម្លាំងខ្សោយ ។

ការនឹងនួន ទៅប្រាសហើយ ហេតុនោះ ឈ្មោះថា វិចិកិច្ឆា ។ វិចិកិច្ឆានោះ មានការងឿងឆ្ងល់ ជាលក្ខណៈ, មានការញាប់ញ័រជាកិច្ច, មានការមិនដាច់ស្រេច ជាផល ឬក៏ មានការប្រកាន់នូវចំណែកដ៏ច្រើន ជាផល, មានការធ្វើទុកក្នុងចិត ដោយឧបាយមិនមែនជាប្រាជ្ញា ក្នុងវិចិកិច្ឆា ជាហេតុ, វិចិកិច្ឆានេះ គឺបណ្ឌិត គប្បីឃើញថា ជាធម៌ធ្វើនូវសេចក្តីអន្តរាយដល់ការប្រតិបត្តិ ។

សង្ខារទាំងឡាយដទៃទៀត មានប្រការ គឺយើងពោលហើយ ។

បណ្តាសង្ខារទាំងឡាយ ដែលលោកពោលហើយ ក្នុងធម៌ដែលសម្បយុត្តដោយវិចិកិច្ឆា ដោយធម៌សម្បយុត្តដោយឧទ្ធច្ចៈ សង្ខារទាំងឡាយ ១២ ដ៏សេស លើកលែងតែវិចិកិច្ឆាចេញ ជាឧទ្ធច្ចសម្បយុត្ត ។ តែព្រោះក្នុងឧទ្ធច្ចសម្បយុត្តនេះ មិនមានវិចិកិច្ឆាឧទ្ធច្ចៈនេះ អធិមោក្ខទើបកើតឡើង ។ សង្ខារទាំងឡាយ ១៣ ហ្នឹងឯង (ឧប្បត្តិឡើង) ជាមួយនឹងអធិមោក្ខនោះ ។ មួយទៀត សមាធិ ជាសភាវៈដ៏មានកម្លាំងជាង ព្រោះមានអធិមោក្ខ ។ ក៏ឧទ្ធច្ចៈណា ក្នុងឧទ្ធច្ចសម្បយុត្តនេះ ឧទ្ធច្ចៈនោះ មកដោយរបស់ខ្លួនពិត, អធិមោក្ខ និង មនសិការ មកហើយដោយអំណាចយេវាបនកសង្ខារ ដូច្នេះឯង ។

អកុសលសង្ខារទាំងឡាយ គឺបណ្ឌិត គប្បីជ្រាប យ៉ាងនេះឯង ។

(អហេតុកវិបាក)

(៣០២) បណ្តាសង្ខារទាំងឡាយ ជាអព្យាកតៈ ជាដំបូង សង្ខារ

ជាវិបាកាព្យាកតៈ មាន ២ ដោយញែកជាអហេតុកៈ និង សហេតុកៈ ។ បណ្ដាសង្ខារទាំង ២ យ៉ាងនោះ អព្យាកតសង្ខារ ប្រកបហើយ ដោយអហេតុកវិបាកវិញ្ញាណ ឈ្មោះថា អហេតុកសង្ខារ ។ បណ្ដាអហេតុកសង្ខារទាំងឡាយនោះ ជាដំបូង សង្ខារទាំងឡាយ ដែលប្រកបដោយចក្ខុវិញ្ញាណដែលជាកុសលវិបាក និង អកុសលវិបាក មាន ៥ គឺ : សង្ខារដែលមកហើយដោយរួបរួម មាន ៤ គឺ ផស្សៈ ១, ចេតនា ១, ជីវិត ១, ចិត្តដ្ឋិតិ ១ ដែលជាយេវាបនកៈ មានតែមនសិការមួយទេ ។ សង្ខារទាំងឡាយ ៥ នេះឯង សូម្បីប្រកបហើយ ដោយសោតៈ, ឃានៈ, ជិវ្ហា, កាយ និង វិញ្ញាណ គឺបណ្ឌិត គប្បីជ្រាបផងចុះ ។ ក្នុងមនោធាតុដែលជាវិបាកទាំង ២ ខាង សង្ខារទាំងឡាយ ៨ ដូច្នេះ គឺ សង្ខារទាំងឡាយ ៥ នេះឯង និង វិតក្កៈ, វិចារៈ និង អធិមោក្ខ ។ សង្ខារទាំងឡាយ ៨ ក្នុងអហេតុកមនោវិញ្ញាណធាតុ ៣ ប្រការ ក៏ដូច្នោះដែរ ។ តែក្នុងអហេតុកមនោវិញ្ញាណធាតុនេះ មនោវិញ្ញាណធាតុ ណា ប្រកបដោយសោមនស្ស, បីតិ (ដែលកើត) ជាមួយនឹងមនោវិញ្ញាណធាតុនោះ គឺបណ្ឌិតគប្បីជ្រាបថា អធិកបីតិ ។

(សហេតុកវិបាក)

ក៏អព្យាកតសង្ខារទាំងឡាយ ប្រកបព្រមហើយ ដោយសហេតុកវិបាកវិញ្ញាណ ហៅថា សហេតុកសង្ខារ ។ ក្នុងសហេតុកសង្ខារទាំងឡាយនោះ សង្ខារទាំងឡាយដែលប្រកបហើយ ដោយកាមាវចរវិបាក ៨ សុទ្ធតែប្រាកដស្មើដោយសង្ខារ ដែលប្រកបដោយកាមាវចរកុសលទាំងឡាយ ៨ ដោយពិត ។ តែករុណា និង មុទិតាទាំងឡាយណា ក្នុងអនិយតសង្ខារទាំងឡាយ, ករុណា និង មុទិតាទាំងឡាយនោះ មិន



មានក្នុងវិបាកទាំងឡាយទេ ព្រោះភាវៈនៃករុណា និង មុទិតា មានសត្វជាអារម្មណ៍ ។ ចំណែកកាមាវចរវិបាកសង្ខារទាំងឡាយ មានកាមាវចរធម៌ ជាអារម្មណ៍ ដោយចំណែកមួយ ។ មិនត្រឹមតែករុណា និង មុទិតាទាំងឡាយប៉ុណ្ណោះទេ ដែលមិនមាន ក្នុងវិបាកទាំងឡាយ សូម្បីវិរតិទាំងឡាយ ក៏មិនមានក្នុងវិបាកសង្ខារទាំងឡាយដែរ ។ ព្រោះលោកពោលហើយថា "សិក្ខាបទទាំង ៥ សុទ្ធតែជាកុសលប៉ុណ្ណោះ" ។ ក៏អព្យាកតសង្ខារទាំងឡាយ ដែលប្រកបព្រមដោយវិបាកវិញ្ញាណ ដែលជារូបាវចរ, អរូបាវចរ និង លោកុត្តរ សុទ្ធតែប្រាកដស្មើ ដោយសង្ខារដែលប្រកបហើយ ដោយកុសលវិញ្ញាណទាំងឡាយ នៃវិបាកវិញ្ញាណទាំងនោះឯង ។

(អព្យាកតសង្ខារផ្នែកកិរិយា)

សង្ខារទាំងឡាយសូម្បីជាកិរិយាអព្យាកតៈ មានពីរប្រការ ដោយញែកជាអហេតុកៈ និង សហេតុកៈ ។ បណ្ដាសង្ខារទាំង ២ ប្រការនោះ សង្ខារទាំងឡាយ ដែលប្រកបព្រមហើយ ដោយអហេតុកកិរិយាវិញ្ញាណ ហៅថា អហេតុកៈ ។ អហេតុកកិរិយាសង្ខារទាំងឡាយនោះ ស្មើគ្នា ដោយសង្ខារទាំងឡាយ ដែលប្រកបហើយ ដោយប្រជុំ ២ នៃកុសលវិបាកមនោធាតុ និង អហេតុកមនោវិញ្ញាណធាតុ ។ តែវិរិយៈ ដែលប្រកបដោយប្រជុំពីរ នៃមនោវិញ្ញាណធាតុ ជាវិរិយៈដ៏ក្រៃលែង ចំណែកខាង សមាធិ ជាសមាធិដល់ហើយនូវកម្លាំង តាមសភាពនៃវិរិយៈ ។ នេះ ជាសេចក្ដីប្លែកគ្នា ក្នុងសង្ខារដែលប្រកបដោយមនោវិញ្ញាណធាតុទាំង ២ នេះ ។

ឯអព្យាកតសង្ខារទាំងឡាយ ប្រកបព្រម ដោយសហេតុកកិរិយា-

វិញ្ញាណ ហៅថា សហេតុកា ។ បណ្តាសហេតុកកិរិយាសង្ខារទាំងឡាយនោះ សង្ខារទាំងឡាយ ដែលប្រកបដោយកាមាវចរកិរិយា-វិញ្ញាណ ៨ លើកលែងតែវិរតិទាំងឡាយប៉ុណ្ណោះ ប្រាកដស្មើដោយសង្ខារដែលប្រកបដោយកាមាវចរកុសលទាំងឡាយ ៨ ។ ក៏សង្ខារទាំងឡាយដែលប្រកបព្រមហើយ ដោយរូបាវចរកិរិយាវិញ្ញាណ និង អរូបា-វចរកិរិយាវិញ្ញាណ សុទ្ធតែប្រាកដស្មើដោយសង្ខារ ដែលប្រកបដោយអកុសលវិញ្ញាណ នៃកិរិយាវិញ្ញាណទាំងនោះ ដោយអាការៈទាំងពួងដូច្នេះឯង ។ សង្ខារទាំងឡាយសូម្បីជាអព្យាកតៈ គឺបណ្ឌិត គប្បីជ្រាបយ៉ាងនេះដែរ ។ នេះ ជាកថាមុខ ដោយពិស្តារ ក្នុងសង្ខារក្ខន្ធ ។ នេះជាកថាមុខ យ៉ាងពិស្តារ ក្នុងខន្ធទាំងឡាយ តាមន័យក្នុងបទភាជនីយ ក្នុងអភិធម្ម ចប់ត្រឹមតែប៉ុណ្ណោះ ។

(ខន្ធវិភាគ)

(៣០៣) ក៏ខន្ធទាំងឡាយ គឺព្រះមានព្រះភាគ ទ្រង់សំដែងឲ្យពិស្តារហើយ យ៉ាងនេះ គឺៈ រូបណាទីមួយ ជាអតីត, អនាគត, បច្ចុប្បន្ន ខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតសុខុមក្តី ថោកទាបក្តី ថ្លៃថ្លា ក្តី រូបណាក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី គំនររូបនេះ គឺព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅថា រូបក្ខន្ធ ព្រោះប្រមូលផ្តុំបំព្រួញនូវរូបនោះ ចូលជាមួយគ្នា, វេទនា ណា, សញ្ញា ណា, សង្ខារទាំងឡាយ ណា វិញ្ញាណ ណា ជាអតីត, អនាគត, បច្ចុប្បន្ន, ប្រព្រឹត្តទៅព្ធដ៏ខាងក្នុងក្តី ។ល។ គំនរវិញ្ញាណនេះ គឺព្រះមានព្រះភាគ ត្រាស់ហៅថា វិញ្ញាណក្ខន្ធ ព្រោះប្រមូលផ្តុំបំព្រួញនូវវិញ្ញាណនោះ ចូលជាមួយគ្នា ដូច្នេះឯង ។

បណ្តាបទបាលីទាំងនោះ បទថា “យំ កិញ្ចិ” ជាពាក្យដែល



លោករួបរួមគ្មានសេសសល់ ។ បទថា “រូបំ” ជាពាក្យសំរាប់និយមនូវសភាពដ៏ចំពោះតែម្តង ។ ការកំណត់នូវរូបមិនមានសេសសល់ ជាសភាវៈ ព្រះមានព្រះភាគ ទ្រង់ធ្វើហើយដោយប្រជុំពីរនៃបទយ៉ាងនេះ ។ បន្ទាប់អំពីនោះ ព្រះមានព្រះភាគ ទ្រង់ប្រារព្ធនូវការបែងចែកនូវរូបនោះ ដោយរូបជាអតីតជាដើម ។ ក៏រូបនោះ គឺរូបជាអតីត ក៏មានខ្លះ ដ៏ផ្សេងគ្នា ដោយរូបមានរូបជាអនាគតជាដើម ក៏មានខ្លះ ។ ន័យ ក្នុងខន្ធទាំងឡាយ មានវេទនាខន្ធជាដើម ដូចគ្នាដែរ ។

(រូបក្ខន្ធ)

បណ្តាខន្ធទាំងនោះ រូបមាន ៤ ប្រការ ដោយអំណាចនៃកាល, តំណ, សម័យ, និង ខណៈ ឈ្មោះថា ជាអតីតរូប ។ រូប ជាអនាគត និង បច្ចុប្បន្ន ក៏ដូចគ្នាដែរ ។

ក្នុងចំណែកទាំង ៤ នោះ ដោយអំណាចនៃដំណើរកាលឆ្ងាយ ដំបូងក្នុងភព ១ រូបនៃបុគ្គលម្នាក់ក្នុងកាលមុន អំពីបដិសន្ធិ ឈ្មោះថា ជាអតីត, រូប ក្នុងកាលខាងលើអំពីចុតិទៅ ឈ្មោះថា ជាអនាគត, រូប ក្នុងចន្លោះនៃរូបទាំង ២ នោះ ឈ្មោះថា ជាបច្ចុប្បន្ន ។

សេចក្តីវិនិច្ឆ័យ ដោយអំណាចនៃសន្តតិរូប គឺបណ្ឌិត គប្បីជ្រាបដូចតទៅ : រូបមានចំណែកស្មើគ្នា និង រដូវតែ ១ ជាសមុដ្ឋានផង, មានអាហារតែ ១ ជាសមុដ្ឋានផង សូម្បីកាលប្រព្រឹត្តទៅ ដោយអំណាចខាងដើម និង ខាងចុង ហៅថា បច្ចុប្បន្នរូប, រូបមានចំណែកមិនស្មើគ្នា មានរដូវ និង អាហារជាសមុដ្ឋាន ក្នុងកាលមុនអំពីកាលនោះ ហៅថា អតីតរូប, រូបខាងក្រោយ ឈ្មោះថា អនាគតរូប ។ សូម្បីរូបកើតអំពីចិត្ត មានវិថីចិត្ត ១, ជវន ១ និង សមាបត្តិ ១ ជាសមុដ្ឋាន ឈ្មោះថា

បច្ចុប្បន្នរូប, រូបក្នុងកាលមុនអំពីកាលនោះ ឈ្មោះថា អតីតរូប, រូបក្នុងកាលជាខាងក្រោយ ឈ្មោះថា អនាគតរូប ។ ប្រភេទនៃរូបមានអតីតរូបជាដើម ដោយអំណាចនៃតំណាផ្សេងគ្នាដោយចំណែក ១ នៃរូបដែលមានកម្មជាសមុដ្ឋាន មិនមានទេ ។ ក៏ភាពនៃរូបនោះ មានអតីតរូបជាដើម គឺបណ្ឌិត គប្បីជ្រាប ដោយអំណាចនៃការទំនុកបំរុង នៃរដូវ, អាហារ និង ចិត្ត ជាសមុដ្ឋានទាំងឡាយនោះឯង ។

សេចក្តីវិនិច្ឆ័យ ដោយអំណាចនៃកាល គឺបណ្ឌិត គប្បីជ្រាប ដូចតទៅ: រូបមានយាមនោះៗ ជាពេល កាលប្រព្រឹត្តទៅដោយអំណាចនៃតំណ ក្នុងយាមទាំងឡាយ មានយាម ១, ពេលព្រឹក, ពេលល្ងាច ពេលយប់ និង ពេលថ្ងៃជាដើម ឈ្មោះថា បច្ចុប្បន្នរូប, រូបមុនអំពីនោះ ហៅថា អតីតរូប, រូបខាងក្រោយ ហៅថា អនាគតរូប ។

សេចក្តីវិនិច្ឆ័យ ដោយអំណាចនៃខណៈ គឺបណ្ឌិត គប្បីជ្រាប ដូចតទៅនេះ: រូបដែលរាប់បញ្ចូល ក្នុងខណៈ ៣ មានឧបាទខណៈជាដើម ឈ្មោះថា បច្ចុប្បន្នរូប, ខាងដើមអំពីរូបនោះ ឈ្មោះថា អនាគតរូប, ខាងក្រោយ ឈ្មោះថា អតីតរូប ។ មួយវិញទៀត រូបមានហេតុកិច្ច និង បច្ច័យកិច្ច ដែលជាហេតុកន្លងទៅហើយ ឈ្មោះថា អតីតរូប, រូបដែលមានកិច្ចនៃហេតុសំរេចហើយ តែមានកិច្ចនៃបច្ច័យ មិនទាន់សំរេចហើយ ឈ្មោះថា បច្ចុប្បន្នរូប, រូបដែលមិនសំរេចហើយ ដោយកិច្ចទាំងពីរ ឈ្មោះថា អនាគតរូប ។ មួយវិញទៀត រូបក្នុងខណៈ ធ្វើកិច្ចរបស់ខ្លួន ហៅថា បច្ចុប្បន្នរូប, ខាងដើមអំពីនោះទៅ ហៅថា អនាគតរូប, ខាងក្រោយ ហៅថា អតីតរូប ។

ក្នុងការពណ៌នាចំណែករូបនេះ វាចាជាគ្រឿងពោលនូវប្រភេទ មាន



ខណៈជាដើម អស់សេចក្តីត្រឹមតែប៉ុណ្ណេះ, ពាក្យទាំងឡាយ ដ៏សេសនៅមានសេចក្តីតទៅទៀត ។ ប្រភេទនៃអជ្ឈត្តរូប និង ពហិទ្ធារូប មានន័យ គឺយើងពោលរួចមកហើយ ។ ចំណែកក្នុងអធិការនេះ បណ្ឌិតគប្បីជ្រាបថា រូបខាងក្នុង ដែលអាស្រ័យនូវខ្លួន ឈ្មោះថា អជ្ឈត្តិករូប និង រូបដែលប្រព្រឹត្តទៅ ក្នុងបុគ្គលដទៃ ជារូបខាងក្រៅ ។ ប្រភេទនៃឱឡារិករូប និង សុខុមរូប មានន័យ គឺយើងពោលរួចហើយ ។

ប្រភេទនៃហីនរូប និង បណីតរូប មាន ២ យ៉ាង គឺ : ដោយបរិយាយ ១ មិនមានបរិយាយ ១ ។ បណ្តារូបទាំងឡាយនោះ រូបនៃសុទស្សីព្រហ្មទាំងឡាយ ថោកទាបជាងរូបនៃអកនិដ្ឋព្រហ្មទាំងឡាយ ។ រូបនៃសុទស្សីព្រហ្មនោះឯង ប្រណីតជាងរូបនៃព្រហ្មជាន់សុទស្សាទាំងឡាយ ដោយប្រការដូច្នេះ ។ រូបរបស់សត្វនរកទាំងឡាយ យ៉ាងណា, ភាពនៃរូបដ៏ថោកទាប និង ថ្លៃថ្លា គឺបណ្ឌិតគប្បីជ្រាប ដោយបរិយាយយ៉ាងនោះ ។ តែបើពោលដោយអស់ជើង ភាវៈនៃរូបថោកទាប និង ប្រណីត បណ្ឌិត គប្បីជ្រាបថា អកុសលវិបាកវិញ្ញាណ កើតក្នុងរូបណា, រូបនោះ ឈ្មោះថា ហីនរូប ។ កុសលវិញ្ញាណ (កើត) ក្នុងរូបណា, រូបនោះ ឈ្មោះថា បណីតរូប ។

សូម្បីពាក្យនេះឯងថា “រូប (មាន) ក្នុងទីឆ្ងាយ, ក្នុងទីជិត” ក៏មានន័យដូចលោកពោលរួចហើយ ។ ចំណែកខាង ភាពនៃរូបមាន ក្នុងទីឆ្ងាយ និង ទីជិត ដែលអាស្រ័យអែបនែប ក្នុងរូបនេះ បណ្ឌិត គប្បីជ្រាប ដោយឱកាសផងចុះ ។

ក្នុងបទទាំងឡាយថា “តទេកជ្ឈំ អភិសញ្ញូហិត្វា អភិសង្ខិបិត្វា” នេះ មានសេចក្តីយ៉ាងនេះ ថា: រូបនោះ គឺព្រះមានព្រះភាគ ទ្រង់ត្រាស់

ហៅថា រូបក្ខន្ធ ព្រោះទ្រង់ធ្វើនូវរូបដែលទ្រង់ជំរែងចេញផ្សេងៗ គ្នា ដោយបទទាំងឡាយ មានបទថា អតីត ជាដើម ឲ្យចូលជាគំនរជាមួយគ្នា ដោយបញ្ញា ក្នុងភាពមាន ១ ប្រការ ពោលគឺ ការចាក់រុក ជាលក្ខណៈ ។ រូបទាំងអស់ហ្នឹងឯង គឺលោកបង្ហាញហើយ ជារូបក្ខន្ធ ព្រោះកិរិយាចូលទៅដល់ភាវៈជាគំនរ ក្នុងលក្ខណៈនៃការចាក់រុក ដោយបទនេះ ។ ឈ្មោះថា រូបក្ខន្ធ ដទៃអំពីរូប មិនមានក៏ទេដែរ ។

(វេទនាវិភាគ)

ក៏រូប គឺលោកសំដែងហើយថា រូបក្ខន្ធ យ៉ាងណា, អារម្មណ៍ទាំងឡាយមានវេទនាជាដើម គឺលោកសំដែងហើយថា វេទនាខន្ធ ដោយការចូលទៅកំណត់នូវភាវៈជាគំនរ ក្នុងខន្ធទាំងឡាយ មានវេទនាខន្ធដែលបុគ្គលគប្បីកំណត់ដឹង ជាលក្ខណៈជាដើម ក៏យ៉ាងនោះដែរ ។ ព្រោះថា ខន្ធទាំងឡាយ មានវេទនាខន្ធជាដើម ដទៃអំពីខន្ធទាំងឡាយមានវេទនាខន្ធជាដើម រមែងមានក៏ទេ ។

ឯក្នុងវេទនាខន្ធនេះ ក្នុងការចែកដោយកាល មានអតីតកាល ជាដើម បណ្ឌិត គប្បីជ្រាបភាវៈនៃអតីត, អនាគត និង បច្ចុប្បន្ន នៃវេទនា ដោយអំណាចនៃតំណ និង ដោយអំណាចនៃហេតុមានខណៈជាដើម ។

ក្នុងសន្តតិ និង ខណៈជាដើមនោះ វេទនាទាំងឡាយ ដែលរាប់បញ្ចូល ក្នុងវិថីចិត្ត ១, ជវនចិត្ត ១ និង សមាបត្តិចិត្ត ១ ដោយអំណាចនៃសន្តតិ និង វេទនា ដែលប្រព្រឹត្តទៅ ព្រោះប្រកបព្រម ដោយអារម្មណ៍ ១ ប្រការ ឈ្មោះថា បច្ចុប្បន្ន, វេទនាខាងដើមអំពីនោះ ហៅថា អតីត, វេទនា ខាងក្រោយ ហៅថា អនាគត ។

ដោយអំណាច នៃខណៈជាដើម វេទនាទាំងឡាយ ដែលបានរាប់



បញ្ចូលហើយ ដោយខណៈ ៣ និង វេទនា ដែលកំពុងធ្វើនូវកិច្ចរបស់ខ្លួន ដែលទៅហើយក្នុងភាពជាហេតុ ដែលបុគ្គលគប្បីដឹងមុន និង ហេតុដែលបុគ្គលគប្បីដឹងក្រោយ និង កណ្តាល ឈ្មោះថា ជាបច្ចុប្បន្ន, វេទនា ក្នុងពេលមុនអំពីនោះ ឈ្មោះថា អតីត, វេទនា ខាងក្រោយ ឈ្មោះថា អនាគត ។

ប្រភេទនៃវេទនា ខាងក្នុង និង ខាងក្រៅ បណ្ឌិតគប្បីជ្រាប ដោយអំណាចនៃវេទនាខាងក្នុងខ្លួន និង បុគ្គលដទៃ ។ ប្រភេទនៃវេទនា ដ៏គ្រោតគ្រាត និង ល្អិត គឺបណ្ឌិត គប្បីជ្រាប ដោយអំណាចនៃជាតិ, សភាវៈ, បុគ្គល, លោកិយ និង លោកុត្តរៈ ដែលលោកពោលហើយ ក្នុងវិភង្គ ដោយន័យមានជាអាទិ៍ ថា : វេទនា ជាអកុសល ជាវេទនាដ៏គ្រោតគ្រាត, វេទនា ជាកុសល និង អព្យាកតៈ ជាវេទនាដ៏ល្អិត ។

ជាដំបូង ពោលដោយជាតិ វេទនា ជាអកុសល ជាវេទនាគ្រោតគ្រាត ជាងកុសលវេទនា ហេតុប្រព្រឹត្តទៅមិនស្ងប់រម្ងាប់ ព្រោះជាហេតុនៃការធ្វើកម្មដែលមានទោស និង ព្រោះភាវៈនៃការក្តៅក្រហាយ ដោយកិលេស ជាវេទនាដ៏គ្រោតគ្រាត ជាងវិបាកអព្យាកតៈ ព្រោះប្រព្រឹត្តទៅដោយព្យាយាម ព្រោះប្រព្រឹត្តទៅដោយឧស្សាហៈ ព្រោះប្រព្រឹត្តទៅដោយវិបាក ព្រោះមានសេចក្តីក្តៅក្រហាយ ដោយកិលេស ព្រោះប្រព្រឹត្តទៅ ដោយសេចក្តីព្យាបាទ និង ព្រោះប្រព្រឹត្តទៅ ដោយទោស, ជាវេទនាគ្រោតគ្រាតជាងវេទនាជាកិរិយាអព្យាកតៈ ព្រោះមានវិបាកផង ព្រោះភាពនៃការញុំាងកិលេស ឲ្យក្តៅសព្វផង ព្រោះមានព្យាបាទផង ព្រោះមានទោសផង ។ ចំណែកវេទនា ជាកុសល និង ជាអព្យាកតៈ ជាវេទនា សុខុម ជាងវេទនាដែលជាអកុសល ព្រោះ

ជាទំនាស់នឹងពាក្យដែលលោកពោលហើយ ។ កុសល និង អកុសលវេទនាទាំងពីរយ៉ាង ឈ្មោះថា ជាវេទនា ដ៏គ្រោតគ្រាត ជាងវេទនាដែលជាអព្យាកតៈទាំង ២ ប្រការ ព្រោះមានសេចក្តីខ្វល់ខ្វាយផង ព្រោះមានសេចក្តីប្រឹងប្រែងផង ព្រោះមានវិបាកផង តាមសមគួរដល់ការប្រកប ។ វេទនា ជាអព្យាកតៈទាំង ២ ចាត់ជាវេទនាដ៏ល្អិត ជាងវេទនាដែលជាកុសល និង វេទនាដែលជាអកុសលទាំងពីរនោះ ព្រោះជាទំនាស់ដល់ពាក្យដែលលោកពោលហើយ ។ ភាពនៃវេទនាដ៏គ្រោតគ្រាត និង ល្អិតទាំងឡាយ គឺបណ្ឌិត គប្បីជ្រាប ដោយអំណាចនៃជាតិតែប៉ុណ្ណេះសិនចុះ ។

បើពោលដោយសភាវៈ ទុក្ខវេទនា ជាវេទនា ដ៏គ្រោតគ្រាត ជាងវេទនាទាំងឡាយពីរក្រៅពីនេះ ព្រោះមិនមាននៃសេចក្តីជ្រះថ្លាផង ព្រោះមានការផ្សាយទៅផង ព្រោះជាទីតាំងនៃសេចក្តីតក់ស្លុតផង ព្រោះការគ្របសង្កត់ផង ។ ឯវេទនាទាំងឡាយក្រៅពីនេះ ឈ្មោះថា ជាវេទនាដ៏ល្អិត ជាងទុក្ខវេទនា ព្រោះត្រជាក់ផង ព្រោះស្ងប់ផង ព្រោះជ្រះថ្លាផង ព្រោះជាទីពេញចិត្តផង ព្រោះជាកណ្តាលផង តាមគួរដល់ការប្រកប ។ ម្យ៉ាងទៀត សុខ និង ទុក្ខវេទនាទាំងឡាយទាំងពីរដ៏គ្រោតគ្រាតជាងសភាព មិនមានជាទុក្ខ និង មិនមានជាសុខ ព្រោះផ្សាយទៅផង ព្រោះការធ្វើនូវសេចក្តីភ្ញាក់ផ្អើលផង ព្រោះការប្រាកដផង ។ អទុក្ខមសុខវេទនានោះ ឈ្មោះថា ល្អិតជាងសុខវេទនា និង ទុក្ខវេទនាទាំងពីរយ៉ាងនោះ ព្រោះការទំនាស់គ្នាដល់ពាក្យ ដែលលោកពោលហើយ ។ ភាពនៃវេទនា ដ៏គ្រោតគ្រាត និង ល្អិត គឺបណ្ឌិត គប្បីជ្រាបដោយអំណាចនៃសភាព យ៉ាងនេះ ។



ចំណែកពោលដោយបុគ្គល វេទនា របស់ព្រះយោគី ដែលមិនបានចូលសមាបត្តិ គ្រោតគ្រាត ជាងវេទនា របស់ព្រះយោគី ដែលបានចូលសមាបត្តិហើយ ព្រោះវេទនារបស់ព្រះយោគី ដែលមិនបានចូលសមាបត្តិនោះ រាយមាយក្នុងអាម្មណ៍ផ្សេងៗ, វេទនាទាំងឡាយ ក្រៅពីនេះ ដ៏ល្អិត ដោយបរិយាយដែលផ្ទុយគ្នា ។ ភាពនៃវេទនាដែលគ្រោតគ្រាត និងល្អិត គឺបណ្ឌិតគប្បីជ្រាបដោយអំណាចនៃបុគ្គលយ៉ាងនេះ ។

តែបើពោលដោយលោកិយ និង លោកុត្តរៈ វេទនាដែលប្រព្រឹត្តទៅដោយអាសវៈ ជាលោកិយវេទនា ។ វេទនាដែលប្រព្រឹត្តទៅដោយអាសវៈនោះ ជាវេទនាគ្រោតគ្រាតជាងវេទនាមិនមានអាសវៈ ព្រោះជាហេតុនៃការកើតនូវអាសវៈផង ព្រោះញ៉ាំងសត្វឲ្យលិចចុះផង ព្រោះប្រព្រឹត្តទៅដើម្បីប្រកបផង ព្រោះជាគ្រឿងសាំញ៉ាំផង ព្រោះជាគ្រឿងរាំងផង ព្រោះជាគ្រឿងប្រកាន់មាំផង ព្រោះជាគ្រឿងសៅហ្មងព្រមផង ព្រោះជាបុថុជ្ជនផង ព្រោះជាទូទៅផង ។ វេទនាដែលមិនមានអាសវៈនោះ ជាសភាវៈដ៏ល្អិតជាងវេទនាដែលប្រព្រឹត្តទៅ ដើម្បីអាសវៈ ដោយបរិយាយផ្ទុយពីគ្នា ។ ភាពនៃវេទនាដ៏គ្រោតគ្រាត និង ល្អិត គឺបណ្ឌិតគប្បីជ្រាប ដោយអំណាចនៃវេទនាជាលោកិយ និង លោកុត្តរដូចបានពោលមកយ៉ាងនេះឯង ។

(៣០៤) ការប្រឡំដោយអំណាចនៃជាតិជាដើម គឺបណ្ឌិតគប្បីនាំមកប្តូរគ្នា ក្នុងសេចក្តីគ្រោតគ្រាត និង ល្អិតនោះ ។ ព្រោះថា វេទនាដែលប្រកបដោយកាយវិញ្ញាណដែលជាអកុសលវិបាក បើទុកជាវេទនាដ៏ល្អិត ព្រោះជាអព្យាកតៈ ដោយអំណាចនៃជាតិ ក៏ដោយ គង់ទៅជាវេទនា ដ៏គ្រោតគ្រាតដដែល ដោយអំណាចនៃសភាវៈជាដើម ដូចជាព្រះ

បាលីដែលព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយថា “អព្យាកតវេទនា ជាវេទនាដ៏ល្អិត, ទុក្ខវេទនា ជាវេទនាដ៏គ្រោតគ្រាត, វេទនា របស់ព្រះយោគីដែលមិនបានចូលសមាបត្តិហើយ ឈ្មោះថា វេទនា គ្រោតគ្រាត, វេទនារបស់ព្រះយោគីដែលចូលសមាបត្តិហើយ ឈ្មោះថា ជាវេទនាដ៏ល្អិត, វេទនា ប្រព្រឹត្តទៅមួយអន្លើដោយអាសវៈ ឈ្មោះថា វេទនាដ៏គ្រោតគ្រាត, វេទនាមិនមានអាសវៈ ឈ្មោះថា វេទនាដ៏ល្អិត” ដូច្នេះ ។ ចំណែកខាងវេទនាជាទុក្ខ យ៉ាងណា, វេទនាទាំងឡាយ មានសុខវេទនាជាដើម ជាវេទនាដ៏គ្រោតគ្រាត ដោយអំណាចនៃជាតិ តែជាវេទនាដ៏ល្អិត ដោយអំណាចនៃសភាពជាដើម ក៏យ៉ាងនោះដែរ ។ ព្រោះហេតុនោះ ការប្រឡំគ្នាដោយអំណាចជាតិជាដើម មិនមាន យ៉ាងណា, ភាពនៃវេទនាទាំងឡាយដ៏គ្រោតគ្រាត និង ថ្លៃថ្លា គឺបណ្ឌិតគប្បីជ្រាបយ៉ាងនោះ ។ សួរថា តើយ៉ាងដូចម្តេច? ។ ឆ្លើយថា វេទនាដែលជាអព្យាកតៈ ជាវេទនាដ៏ល្អិតជាងកុសលវេទនា និង អកុសលវេទនាទាំងឡាយ ដោយអំណាចនៃជាតិ ។ ប្រភេទនៃអាការៈមានសភាពជាដើម គឺបុគ្គលមិនគប្បីប៉ះពាល់ យ៉ាងនេះថា : បណ្តាវេទនាទាំងឡាយនោះ អព្យាកតវេទនា តើដូចម្តេច? ជាទុក្ខឬ, ជាសុខឬ?, ជារបស់ព្រះយោគីដែលបានចូលសមាត្តិឬ, ជារបស់ព្រះយោគី ដែលមិនបានចូលសមាបត្តិឬ? មានអាសវៈឬ, មិនមានអាសវៈឬ? ។ ន័យក្នុងវេទនាទាំងឡាយទាំងពួង ក៏មានន័យយ៉ាងនេះដែរ ។

ម្យ៉ាងទៀត ក្នុងវេទនាទាំងឡាយ មានអកុសលវេទនាជាដើម វេទនាដែលប្រកបព្រមហើយដោយទោសៈ ជាវេទនាដ៏គ្រោតគ្រាតជាងវេទនា ដែលប្រព្រឹត្តទៅ ដោយលោភៈ ព្រោះការដុតនូវអារម្មណ៍ របស់



ខ្លួន ដូចជាភ្លើង, វេទនាដែលប្រព្រឹត្តទៅ ដោយលោភៈ ជាវេទនាដែលល្អិត ព្រោះព្រះពុទ្ធដីកាថា “ឬក៏ វេទនាទាំងឡាយ ដ៏គ្រោតគ្រាត និងល្អិត បណ្ឌិតគប្បីយល់ ព្រោះអាស្រ័យតៗគ្នា នូវវេទនានោះៗឯង” ។ សូម្បីវេទនា ដែលប្រព្រឹត្តទៅមួយអន្លើដោយទោសៈ ដែលជានិយតៈ ចាត់ថា ជាវេទនាគ្រោតគ្រាត, ដែលជាអនិយតៈ ចាត់ថា ជាវេទនាដ៏ល្អិត, សូម្បីវេទនាដ៏ទៀងដែលស្ថិតនៅហើយអស់កប្ប ក៏ឈ្មោះថាគ្រោតគ្រាត, ឯវេទនាក្រៅអំពីនេះ ហៅថា វេទនា ដ៏ល្អិត ។ សូម្បីក្នុងពួកវេទនាដែលស្ថិតនៅអស់កប្ប វេទនា ដែលជាអសង្ខារិក ហៅថាគ្រោតគ្រាត, វេទនាក្រៅពីនេះ ហៅថា ដ៏ល្អិត ។ តែវេទនាទាំងឡាយដែលប្រព្រឹត្តទៅ មួយអន្លើដោយលោភៈ ដ៏សម្បយុត្តហើយ ដោយទិដ្ឋិ ឈ្មោះថា គ្រោតគ្រាត, វេទនាក្រៅពីនេះ ហៅថា ល្អិត ។ សូម្បីវេទនាដែលសម្បយុត្តដោយទិដ្ឋិ ដែលទៀងទាត់ ស្ថិតនៅអស់កប្ប ដែលជាអសង្ខារិក ជាវេទនាដ៏គ្រោតគ្រាត, វេទនាក្រៅពីនេះ ឈ្មោះថា ល្អិត ។

តែបើនិយាយដោយមិនប្លែកគ្នា អកុសលវេទនា ដែលមានវិបាកច្រើន ឈ្មោះថា គ្រោតគ្រាត, មានវិបាកតិច ឈ្មោះថា ដ៏ល្អិត ។ ចំណែក កុសលវេទនា ដែលមានវិបាកតិច ឈ្មោះថា គ្រោតគ្រាត, ដែលមានវិបាកច្រើន ឈ្មោះថា ល្អិត ។

មួយទៀត វេទនាទាំងឡាយ ដែលជាកាមាវចរកុសល ចាត់ថាគ្រោតគ្រាត, ជារូបាវចរកុសល ចាត់ថា ដ៏ល្អិត, វេទនា ជាអរូបាវចរល្អិតជាងរូបាវចរកុសលវេទនានោះ, លោកុត្តវេទនា ល្អិតជាងអរូបាវចរកុសលវេទនានោះ ។ វេទនា ជាកាមាវចរទាំងឡាយ ដែលសំរេចអំពីទាន ឈ្មោះថា ដ៏គ្រោតគ្រាត, ដែលសំរេចអំពីសីល ឈ្មោះថា ដ៏ល្អិត,

ដែលសំរេចអំពីភាវនា ឈ្មោះថា ល្អិតជាងវេទនា ដែលសំរេចពីសីលនោះ ។ សូម្បីវេទនាដែលសំរេចអំពីភាវនាដែលជាទុហេតុកៈ ឈ្មោះថា គ្រោតគ្រាត, ជាតិហេតុកៈ ឈ្មោះថា ដ៏ល្អិត ។ សូម្បីវេទនា ជាត្រៃហេតុ ប្រកបដោយសង្ខារ ជាវេទនាដ៏គ្រោតគ្រាត, មិនប្រកបដោយសង្ខារ ឈ្មោះថា ដ៏ល្អិត ។ ចំណែកខាងវេទនាជារូបាវចរទាំងឡាយដែលប្រកបដោយបឋមជ្ឈាន ជាវេទនាដ៏គ្រោតគ្រាត ។ល។ ប្រកបដោយបញ្ចមជ្ឈាន ចាត់ថា ជាវេទនាដ៏ល្អិត ។ ចំណែកខាងវេទនាទាំងឡាយ ជាអរូបាវចរៈ ប្រកបព្រមហើយ ដោយអាកាសានញ្ចាយតនៈ ចាត់ថា ដ៏គ្រោតគ្រាត ។ល។ ដ៏សម្បយុត្តហើយ ដោយនេវសញ្ញា-នាសញ្ញាយតនៈ ចាត់ថា ជាល្អិត ។ ឯវេទនាជាលោកុត្តរៈ ប្រកបព្រមដោយសោតាបត្តិមគ្គ ឈ្មោះថា គ្រោតគ្រាត ។ល។ វេទនាដែលប្រកបព្រមហើយដោយអរហត្តមគ្គ ឈ្មោះថា ល្អិតជាងវេទនា ដែលសម្បយុត្តដោយអនាគាមិមគ្គ មែនពិត ។

ន័យក្នុងវេទនាដែលជាវិបាក និង កិរិយាដែលប្រព្រឹត្តទៅ ក្នុងភូមិទាំងឡាយនោះៗ និង ក្នុងវេទនាដែលលោកពោលហើយទាំងឡាយ ដោយអំណាចនៃសភាវៈមានទុក្ខវេទនាជាដើម ដោយអំណាចនៃបុគ្គលដែលមិនចូលសមាបត្តិហើយជាដើម និង ដោយអំណាចនៃលោកិយដែលជាសាសវៈជាដើម ក៏ន័យនេះដែរ ។

ម្យ៉ាងទៀត បើពោលដោយឱកាស ទុក្ខវេទនា ក្នុងនរក ឈ្មោះថា ដ៏គ្រោតគ្រាត ទុក្ខវេទនា ក្នុងកំណើតនៃសត្វតិរច្ឆាន ឈ្មោះថា ដ៏ល្អិត ទុក្ខវេទនា ក្នុងកំណើតនៃមនុស្ស ឈ្មោះថា ល្អិតជាងទុក្ខវេទនា ក្នុងកំណើតសត្វតិរច្ឆាន ។ល។ ទុក្ខវេទនា ក្នុងស្ថានទេវលោក ឈ្មោះថា



បរនិម្មិតវសវត្តីទាំងឡាយ ឈ្មោះថា ជាវេទនាដ៏ល្អិត ជាងទុក្ខវេទនាក្នុងស្ថានទេវលោកឈ្មោះនិមានតី មែនពិត ។ ក៏ទុក្ខវេទនា បុគ្គលគប្បីប្រកប យ៉ាងណា, សូម្បីសុខវេទនា គឺបុគ្គលគប្បីប្រកប ដ៏សមគួរក្នុងភូមិទាំងឡាយទាំងពួង ក៏យ៉ាងនោះដែរ ។

ក៏បើពោល ដោយអំណាចវត្ថុ វេទនា ណាទីមួយ ដែលមានវត្ថុដ៏ថោកទាប ឈ្មោះថា ជាវេទនាគ្រោតគ្រាត, មានវត្ថុដ៏ថ្លៃថ្លា ឈ្មោះថា ជាវេទនាដ៏ល្អិត ។

ក្នុងការផ្សេងគ្នា ដោយថោកទាប និង ថ្លៃថ្លា បណ្ឌិតគប្បីយល់ថា វេទនា ឯណា ដ៏គ្រោតគ្រាត វេទនានោះ ឈ្មោះថា ថោកទាប, ចំណែកខាងវេទនាណា ដ៏ល្អិត វេទនានោះ ឈ្មោះថា ជាវេទនាថ្លៃថ្លា ។

ក៏បទថា “ឆ្ងាយ” គឺព្រះមានព្រះភាគ បែងចែកហើយ ក្នុងគម្ពីរវិភង្គ ដោយន័យ មានជាអាទិ៍ថា “វេទនា ជាអកុសល ក្នុងទីឆ្ងាយ ដោយវេទនាទាំងឡាយជាកុសល និង អព្យាកតៈ” ដូច្នេះជាដើម, បទថា “ជិត” គឺព្រះមានព្រះភាគ បែងចែកហើយ ក្នុងគម្ពីរវិភង្គ ដោយន័យ មានជាអាទិ៍ថា “វេទនាជាអកុសល ជិតដោយវេទនាដែលជាអកុសល” ដូច្នេះជាដើម ព្រោះហេតុនោះ វេទនាជាអកុសល ឈ្មោះថា ឆ្ងាយអំពីកុសលវេទនា និង អព្យាកតវេទនា ព្រោះមិនស្មើគ្នាផង ព្រោះមិនទាក់ទងគ្នាផង ព្រោះមិនប្រហែលគ្នាផង, ភាពនៃវេទនាជាកុសល និង អព្យាកតៈ ឆ្ងាយអំពីអកុសលវេទនា ក៏យ៉ាងដូច្នោះ, សេចក្តីពន្យល់ក្នុងវារៈទាំងពួង ក៏ន័យដូចនេះដែរ, ចំណែក វេទនាជាអកុសល ជិតដោយអកុសលវេទនា ព្រោះមានចំណែកស្មើគ្នាផង និង ព្រោះប្រហែលគ្នាផង ។

នេះ ជាកថាមុខ ដោយពិស្តារ ក្នុងការញែកនូវវេទនាខន្ធ ដោយចំណែកផ្សេងៗ មានអតីតជាដើម ។

ចំណែកកថាមុខ យ៉ាងពិស្តារ ក្នុងការចែកសូម្បីនៃខន្ធទាំងឡាយ មានសញ្ញាខន្ធជាដើម ដ៏សម្បយុត្ត ដោយវេទនានោះៗ បណ្ឌិត គប្បីជ្រាប យ៉ាងដូច្នេះឯង ។

លុះជ្រាប យ៉ាងនេះហើយ

> ន័យនៃការវិនិច្ឆ័យ គឺអ្នកប្រាជ្ញ គប្បីជ្រាបដោយប្រពៃ គឺដោយលំដាប់ផង ដោយសេចក្តីប្លែកគ្នាផង ដោយការមិនខ្វះ មិនលើសផង ដោយសេចក្តីឧបមា ដោយជារបស់ដែលបុគ្គលគប្បីឃើញ ដោយចំណែកពីរ និងដោយការសំរេច នូវប្រយោជន៍ ដល់បុគ្គលដែលឃើញយ៉ាងដូច្នោះផង ដើម្បីបែកធ្លាយនៃញាណ ក្នុងខន្ធទាំងឡាយនុ៎ះឯង ។

### (ន័យដោយលំដាប់)

(៣០៥) ក្នុងន័យទាំង ៦ នោះ ក្នុងពាក្យថា "ដោយលំដាប់" នេះ មានវិនិច្ឆ័យថា លំដាប់ មានច្រើនយ៉ាង គឺ : លំដាប់នៃការកើត ១ លំដាប់នៃការលះបង់ ១ លំដាប់នៃការប្រតិបត្តិ ១ លំដាប់នៃភូមិ១ និង លំដាប់នៃការសំដែង ១ ។ បណ្តាលំដាប់ទាំងនោះ លំដាប់ជាអាទិ៍យ៉ាងនេះថា "រូបដំបូង គឺកលលៈ រួចពីកលលៈទៅ គឺអព្វុទៈ" ដូច្នេះ ឈ្មោះថា លំដាប់នៃការកើត ។ លំដាប់យ៉ាងនេះជាដើម គឺ ធម៌ទាំងឡាយ គឺព្រះយោគី គប្បីលះបង់ ដោយការឃើញ, ធម៌ទាំងឡាយ គឺ



បុគ្គលគប្បីលះបង់ដោយភាវនា"ដូច្នេះ ហៅថា លំដាប់នៃការលះបង់ ។ លំដាប់មានជាដើមយ៉ាងនេះថា "សីលវិសុទ្ធិ, ចិត្តវិសុទ្ធិ" ដូច្នេះ ហៅថា លំដាប់នៃសេចក្តីប្រតិបត្តិ ។ លំដាប់មានជាដើមយ៉ាងនេះថា "ធម៌ទាំងឡាយជាកាមាវចរៈ, ធម៌ទាំងឡាយជារូបាវចរៈ" ដូច្នេះ ហៅថា លំដាប់នៃភូមិ ។ លំដាប់មានជាអាទិ៍យ៉ាងនេះថា "សតិប្បដ្ឋានទាំងឡាយ ៤, សម្មប្បធានទាំងឡាយ ៤" ឬថា "ទានកថា, សីលកថា" ដូច្នេះ ហៅថា លំដាប់នៃការសំដែង ។

បណ្តាលំដាប់ទាំងឡាយនោះ លំដាប់នៃការកើតឡើង ក្នុងទីនេះ មិនសមរម្យ ដោយពិត ព្រោះខន្ធទាំងឡាយ មិនបានកើតឡើង ដោយការកំណត់នៃអាចារ្យខាងដើម ដូចជាកលលៈជាដើម, លំដាប់នៃការលះបង់ រមែងមិនសមរម្យ ព្រោះខន្ធដែលជាកុសល និង អព្យាកតៈទាំងឡាយ គឺបុគ្គល មិនគប្បីលះបង់ ។ លំដាប់នៃការប្រតិបត្តិ រមែងមិនសមរម្យ ព្រោះខន្ធទាំងឡាយ ដែលជាអកុសល គឺបុគ្គលមិនគប្បីប្រតិបត្តិ ។ លំដាប់នៃភូមិ រមែងមិនសមរម្យ ព្រោះខន្ធទាំងឡាយ មានវេទនាខន្ធជាដើម រាប់បញ្ចូល ក្នុងភូមិទាំង ៤ ។ ចំណែកឯលំដាប់នៃទេសនា រមែងសមរម្យ ។ ត្បិតថា ព្រះមានព្រះភាគ ទ្រង់មានព្រះរាជបំណង ដើម្បីដោះ នូវវេនេយ្យសត្វ ដែលធ្លាក់ចុះទៅ ក្នុងសេចក្តីប្រកាន់ថា ខ្លួន ក្នុងខន្ធទាំងឡាយ ៥ ដោយមិនផ្សេងគ្នា ឲ្យរួចផុតអំពីការប្រកាន់ថា ខ្លួន ព្រោះកិរិយាឃើញ នូវការបែងចែកជាសមូហៈ និងជាដុំ ទ្រង់មានព្រះបំណង ដើម្បីប្រយោជន៍ ទើបទ្រង់សំដែងនូវរូបក្ខន្ធជាដំបូង ដ៏គ្រោតគ្រាត ដែលជាអារម្មណ៍ នៃប្រសាទទាំងឡាយ មានចក្ខុប្បសាទជាដើម ដើម្បីការកាន់យកបាន ដោយស្រួល ដល់ជននោះ,

តពីនោះ ទ្រង់សំដែងនូវវេទនា ដែលជាធម្មជាតិសោយនូវរូបជាទីប្រាថ្នា និង រូបមិនជាទីប្រាថ្នា, ទ្រង់សំដែងនូវសញ្ញា ជាទីកាន់យកនូវអាការៈនៃអារម្មណ៍របស់វេទនា យ៉ាងនេះដូច្នេះ គឺ ខ្វនសោយនូវអារម្មណ៍ណា ស្គាល់ច្បាស់នូវអារម្មណ៍នោះ, ទ្រង់សំដែងនូវសង្ខារទាំងឡាយ ជាអភិសង្ខារ ដោយអំណាចនៃសញ្ញា ទ្រង់សំដែងវិញ្ញាណ ដែលជាទីអាស្រ័យនៃខន្ធទាំងឡាយ មានវេទនាខន្ធជាដើមនោះ និង ជាអធិបតីនៃខន្ធទាំងឡាយនោះដូច្នេះឯង ។ ន័យនៃសេចក្តីវិនិច្ឆ័យ តាមលំដាប់ គឺបណ្ឌិតគប្បីជ្រាប ត្រឹមតែប៉ុណ្ណោះសិនចុះ ។

(ន័យដោយប្លែកផ្សេងគ្នា)

(៣០៦) បទថា "វិសេភាគោ" សេចក្តីថា : ដោយសេចក្តីប្លែកគ្នានៃខន្ធទាំងឡាយផង នៃឧបាទានក្ខន្ធទាំងឡាយផង ។ សួរថា : ចុះសេចក្តីប្លែកគ្នានៃខន្ធ និង ឧបាទានក្ខន្ធទាំងឡាយនោះ តើដូចម្តេច? ។ ឆ្លើយថា: ខន្ធទាំងឡាយ គឺព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ក្នុងខន្ធ និង ឧបាទានក្ខន្ធនេះ ដោយមិនប្លែកគ្នាត្រឹមនេះ ។ ឧបាទានក្ខន្ធទាំងឡាយ គឺព្រះមានព្រះភាគទ្រង់ត្រាស់ហើយឲ្យវិសេស ដោយភាវៈនៃខន្ធប្រកបដោយអាសវៈ និង ជាទីតាំងនៃឧបាទាន ។ សមដូចជាព្រះមានព្រះភាគ ទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ! តថាគត នឹងសំដែងនូវខន្ធទាំងឡាយ ៥ ហ្នឹងឯង (និង) ឧបាទានក្ខន ៥ ដល់អ្នកទាំងឡាយ, អ្នកទាំងឡាយ ចូរប្រុងស្តាប់នូវខន្ធនោះ, ម្នាលភិក្ខុទាំងឡាយ! ចុះខន្ធ ៥ ទាំងឡាយ តើយ៉ាងដូចម្តេច? ម្នាលភិក្ខុទាំងឡាយ! រូប ណានីមួយ ដែលជាអតីត, អនាគត និង បច្ចុប្បន្ន ។បេ។ ក្នុងទីជិតក្តី, ម្នាលភិក្ខុទាំងឡាយ! នេះ តថាគត ហៅថា រូបក្ខន្ធ, វេទនា ណានីមួយ ។បេ។



សញ្ញា ណានីមួយ ។បេ។ សង្ខារទាំងឡាយ ណានីមួយ ។បេ។ វិញ្ញាណ ណានីមួយ ។បេ។ ក្នុងទីជិតក្តី, ម្នាលភិក្ខុទាំងឡាយ ! ខន្ធទាំងឡាយនេះ តថាគត ហៅថា វិញ្ញាណក្ខន្ធ, ម្នាលភិក្ខុទាំងឡាយ ខន្ធទាំងឡាយនេះ តថាគត ហៅថា បញ្ចក្ខន្ធ ។

ម្នាលភិក្ខុទាំងឡាយ! ចុះឧបាទានក្ខន្ធទាំងឡាយ ៥ តើដូចម្តេច? ម្នាលភិក្ខុទាំងឡាយ! រូប ណានីមួយ ។បេ។ ក្នុងទីជិតក្តី ប្រកបដោយអាសវៈក្តី ប្រកបដោយសេចក្តីប្រកាន់ក្តី ម្នាលភិក្ខុទាំងឡាយ ! នេះ តថាគត ហៅថា រូបូបាទានក្ខន្ធ វេទនា ណានីមួយ ។បេ។ សញ្ញា ណានីមួយ ។បេ។ សង្ខារទាំងឡាយ ណានីមួយ ។បេ។ វិញ្ញាណ ណានីមួយ ។បេ។ ក្នុងទីជិតក្តី ប្រកបដោយអាសវៈក្តី មានការប្រកាន់មាំក្តី, ម្នាលភិក្ខុទាំងឡាយ នេះ តថាគត ហៅថា វិញ្ញាណូបាទានក្ខន្ធ, ម្នាលភិក្ខុទាំងឡាយ ខន្ធទាំងឡាយនេះ តថាគត ហៅថា ឧបាទានក្ខន្ធ ៥ យ៉ាងដូច្នេះឯង ។

ក៏បណ្តាឧបាទានក្ខន្ធទាំង ៥ នេះ ខន្ធទាំងឡាយ មានវេទនាខន្ធជាដើម មានអាសវៈក្តី មិនមានអាសវៈក្តី មាន យ៉ាងណា, រូបមិនមាន យ៉ាងនោះទេ ។ តែភាវៈនៃរូបនោះ ហៅថា ខន្ធ ដោយអត្ថថា គំនរ រមែងសមរម្យ ព្រោះហេតុណា, ព្រោះហេតុនោះ រូបនោះ គឺព្រះមានព្រះភាគ ទ្រង់ត្រាស់ ក្នុងខន្ធទាំងឡាយ ។ ភាវៈនៃឧបាទានក្ខន្ធ រមែងសមគួរ ដោយអត្ថថា ជាគំនរផង ដោយអត្ថថា មានអាសវៈផង ព្រោះហេតុណា, ព្រោះហេតុនោះ រូបនោះ គឺតថាគត ពោលហើយ ក្នុងឧបាទានក្ខន្ធទាំងឡាយ ។ ក៏ខន្ធទាំងឡាយ មានវេទនាខន្ធជាដើម សុទ្ធតែមិនមានអាសវៈ គឺព្រះដ៏មានព្រះភាគ ទ្រង់បានត្រាស់សំដែងហើយ

ក្នុងខន្ធទាំងឡាយ, ខន្ធទាំងឡាយ មានអាសវៈ គឺព្រះមានព្រះភាគ ទ្រង់សំដែងហើយ ក្នុងឧបាទានក្ខន្ធទាំងឡាយ ។

ក៏អត្ថាធិប្បាយ យ៉ាងនេះថា : ខន្ធទាំងឡាយ មានឧបាទាន ជាអារម្មណ៍ ហៅថា ឧបាទានក្ខន្ធ គឺបណ្ឌិត គប្បីយល់ ត្រង់ពាក្យថា "ឧបាទានក្ខន្ធា" នេះ ។ តែខន្ធទាំងឡាយនេះទាំងអស់ គឺលោកប៉ុនយកហើយ ធ្វើឲ្យបូលគ្នាតែមួយថា "ខន្ធ" ក្នុងវិសុទ្ធិមគ្គនេះ ។

(ន័យដោយមិនខ្វះ មិនលើស)

(៣០៧) សេចក្តីវិនិច្ឆ័យ ត្រង់បទថា "អនូនាធិកតោ" គឺបណ្ឌិតគប្បីជ្រាប ដូចតទៅនេះ ។ សួរថា : ចុះខន្ធទាំង ៥ ហ្នឹងឯង គឺព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ មិនខ្វះ មិនលើស តើព្រោះហេតុអ្វី? ។ ឆ្លើយថា : ព្រោះការរួបរួមនូវធម៌ ដែលមានចំណែកស្មើគ្នា ពោលគឺសង្ខតធម៌ទាំងពួងផង ព្រោះជាហេតុនៃវត្ថុ ដែលប្រកាន់ថា ខ្លួន និងប្រកាន់ថា របស់ខ្លួនមានខន្ធនោះ យ៉ាងក្រៃលែងផង ព្រោះកិរិយាប្រជុំចុះនៃខន្ធទាំងឡាយដទៃ ក្នុងខន្ធនោះផង ។

ក៏នាកាលសង្ខតធម៌ទាំងឡាយ មានប្រភេទផ្សេងៗ គឺលោករួបរួមបូល ដោយអំណាចនៃចំណែកស្មើគ្នា រូបចាត់ថា ជាខន្ធ ១ ដោយអំណាចនៃការរួបរួមនូវធម៌ ដែលមិនមានចំណែកស្មើគ្នានឹងរូប, វេទនាចាត់ ជាខន្ធ ១ ដោយអំណាចនៃការរួបរួម នូវធម៌ដែលមានចំណែកស្មើគ្នានឹងវេទនា, ន័យនេះ ដូចគ្នា ក្នុងខន្ធទាំងឡាយមានសញ្ញាខន្ធជាដើម ។ ហេតុនោះ ខន្ធទាំង ៥ ហ្នឹងឯង គឺព្រះមានព្រះភាគ ទ្រង់ត្រាស់ ដោយការរួបរួម នូវធម៌ដែលមានចំណែកស្មើគ្នា ដោយសង្ខតធម៌ទាំងពួង ។

ខន្ធទាំង ៥ មានរូបក្ខន្ធជាដើម នេះឯណា, វត្ថុ ដែលប្រកាន់ ថា



ខ្លួន ថា ជារបស់ខ្លួន នោះ មានប្រមាណប៉ុណ្ណោះ ។ សមដូចជាព្រះពុទ្ធតម្រាស់ ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយថា : ម្នាលភិក្ខុទាំងឡាយ កាលបើរូបមាន ទិដ្ឋិប្រកាន់នូវរូប ប្រកាន់ស្អិតនូវរូប រមែងកើតឡើង យ៉ាងនេះថា រូបនេះ ជារបស់អញ, នេះ គឺអញ នេះ ខ្លួនរបស់អញ ដូច្នេះ, កាលបើវេទនា---សញ្ញា---សង្ខារ-- វិញ្ញាណ មាន, ទិដ្ឋិប្រកាន់វេទនា ប្រកាន់ស្អិតនូវវេទនា ប្រកាន់សញ្ញា---សង្ខារទាំងឡាយ--វិញ្ញាណ ប្រកាន់ស្អិតនូវវិញ្ញាណ រមែងកើតឡើង យ៉ាងនេះថា វិញ្ញាណនេះ ជារបស់អញ, អញនេះ មាន, នេះ ជាវិញ្ញាណ របស់អញ ។ ព្រោះហេតុនោះ ខន្ធទាំង ៥ ហ្នឹងឯង គឺព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រោះវត្ថុដែលប្រកាន់ថា ខ្លួន ថា របស់ខ្លួននោះ មានប្រមាណប៉ុណ្ណោះ ។

ម្យ៉ាងវិញទៀត ធម្មក្ខន្ធទាំងឡាយ ៥ ឯណាដទៃ មានសីលក្ខន្ធជាដើម គឺព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ, ធម្មក្ខន្ធទាំងឡាយនោះឯង គង់ដល់នូវការប្រជុំចុះ ក្នុងបញ្ចក្ខន្ធទាំងឡាយ ៥ នេះឯង ព្រោះភាវៈនៃខន្ធទាំងឡាយនោះ រាប់បញ្ចូលហើយ ក្នុងសង្ខារក្ខន្ធ ។ ព្រោះហេតុនោះ ខន្ធទាំងឡាយ ៥ នេះឯង គឺព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រោះហេតុនៃធម្មក្ខន្ធទាំងឡាយដទៃ ប្រជុំចុះហើយ ក្នុងខន្ធទាំងឡាយនោះដែរ ។ ន័យ សំរាប់វិនិច្ឆ័យ ដោយមិនខ្វះ មិនលើស គឺបណ្ឌិតគប្បីជ្រាប យ៉ាងនេះឯង ។

(ន័យដោយឧបមា)

(៣០៨) សេចក្តីវិនិច្ឆ័យ ត្រង់បទមាតិកានេះ ថា "ឧបមាតោ" គឺបណ្ឌិត គប្បីជ្រាបដូចតទៅៈ រូបូបាទានក្ខន្ធ ប្រៀបដូចជាផ្ទះ នៃអ្នកជម្ងឺ

ព្រោះជាកន្លែងជាទីនៅអាស្រ័យនៃឧបាទានក្ខន្ធ គឺវិញ្ញាណ ដែលប្រៀប ឧបមាបីដូចជាអ្នកជំងឺ ដោយអំណាចនៃវត្ថុ, ទ្វារ និង អារម្មណ៍ ។ វេទនូបាទានក្ខន្ធ មានសេចក្តីប្រៀបធៀប ដោយជំងឺ ព្រោះភាវៈនៃអ្នកជំងឺជាអ្នកមានអាពាធ ។ សញ្ញូបាទានក្ខន្ធ មានសេចក្តីប្រៀបធៀប ដោយសមុដ្ឋាននៃជំងឺ ព្រោះជាទីកើតព្រម នៃវេទនាដែលប្រកបដោយកិលេស មានរាគៈជាដើម ដោយអំណាច នៃសញ្ញា មានកាមសញ្ញាជាដើម ។ សង្ខារូបាទានក្ខន្ធ មានសេចក្តីប្រៀធៀប ដោយការសេពនូវវត្ថុមិនជាទីសប្បាយ ព្រោះភាវៈនៃសង្ខារូបាទានក្ខន្ធ ជាហេតុនៃជំងឺ គឺវេទនា ។ សមដូចជាពាក្យ ដែលពោលហើយថា "សង្ខារទាំងឡាយរមែងតាក់តែងនូវវេទនា ដើម្បីឲ្យនៅជាវេទនា" ដូច្នេះ ។ ពិតដូច្នោះមែន វិញ្ញាណូបាទានក្ខន្ធ ប្រៀបដូចជាអ្នកជម្ងឺ ព្រោះមិនរួចផុតស្រឡះពីជម្ងឺគឺវេទនា ព្រោះព្រះបាលីថា "កាយវិញ្ញាណ ដែលជាវិបាកប្រព្រឹត្តទៅមួយអន្លើដោយសេចក្តីទុក្ខ កើតឡើងហើយ ព្រោះភាវៈនៃកម្ម ដែលជាអកុសល គឺខ្លួនបានធ្វើហើយ បានសន្សំហើយ" ដូច្នេះ ។

ម្យ៉ាងវិញទៀត ឧបាទានក្ខន្ធទាំងឡាយនេះ មានសេចក្តីប្រៀបធៀបបីដូចជាគុក, ការដាក់ទោស, អ្នកធ្វើទោស, អ្នកមានទោស និង ប្រៀបដូចជាភាជនៈ, ភោជន, ម្ហូបគ្រៀម, ចុងភៅ និង អ្នកទទួលទាន ។

ន័យ សំរាប់សេចក្តីវិនិច្ឆ័យ ដោយពាក្យឧបមា បណ្ឌិត គប្បីជ្រាបដូចបានរៀបរាប់មកនេះឯង ។

(ន័យដែលគប្បីឃើញដោយចំណែក ២)

(៣០៩) ពាក្យថា "ដោយភាពជារបស់គប្បីឃើញ ដោយអាការៈ ២" មានសេចក្តីថា ក៏ន័យនៃសេចក្តីវិនិច្ឆ័យ ក្នុងបទមាតិកាទាំងឡាយ



នេះ គឺបណ្ឌិត គប្បីជ្រាប ដោយភាពជារបស់គឺបុគ្គលគប្បីឃើញដោយចំណែក ២ យ៉ាងនេះ គឺ ដោយសង្ខេប ១ ដោយពិស្តារ ១ ។

មែនពិត បើពោលដោយសេចក្តីបំព្រួញ ឧបាទានក្ខន្ធទាំង ៥ គឺ បណ្ឌិត គប្បីឃើញ ដូចជាសត្រូវមានដាវលើកឡើងហើយ តាមន័យដែលលោកពោលហើយ ក្នុងអាសីវិសូបមសូត្រ, ដោយថា ជារបស់ធន់ ដោយអំណាច នៃភារសូត្រ, ដោយថា ជាអ្នកទំពាស៊ី ដោយអំណាចនៃការបរិយាយ នូវវត្ថុដែលបុគ្គលគប្បីទំពាស៊ី ដោយថា ជារបស់មិនទៀង, ជាទុក្ខ, អនត្តា, ជាសង្ខតៈ និង ជាអ្នកសម្លាប់ ដោយអំណាចនៃយមកសូត្រ ។ បើពោលដោយសេចក្តីពិស្តារ ក្នុងអធិការនេះ រូប គឺបណ្ឌិត គប្បីឃើញថា ដូចជាដុំនៃពពុះទឹក ព្រោះការអត់ទ្រាំមិនបាននូវការញាំញី, វេទនា គឺបណ្ឌិត គប្បីឃើញ ដូចជាក្រពេញនៃទឹក ព្រោះជារបស់ដែលគួរីករាយបាន តែមួយភ្លែត, សញ្ញា បណ្ឌិត គប្បីឃើញ ដូចជាថ្ងៃបណ្តើរកូន ព្រោះការរវើរវាយចិត្ត, សង្ខារទាំងឡាយ បណ្ឌិត គប្បីឃើញដូចជាដើមចេក ព្រោះមិនមានខ្លឹម, វិញ្ញាណ បណ្ឌិតគប្បីឃើញ ដូចជាកលមាយា ព្រោះជាអ្នកបោកបញ្ឆោត ។

បើពោលដោយវិសេស រូបខាងក្នុង សូម្បីដ៏លើសលុប បណ្ឌិត គប្បីឃើញថា ជារបស់មិនល្អ, វេទនា គឺបុគ្គលគប្បីឃើញថា ជាទុក្ខ ព្រោះមិនរួចចាកទុក្ខទាំងឡាយ ៣, សញ្ញា និង សង្ខារទាំងឡាយ គឺ បុគ្គលគប្បីឃើញថា ជារបស់អនត្តា ព្រោះមិនចេះស្តាប់បង្គាប់តាម, វិញ្ញាណ គឺបណ្ឌិត គប្បីឃើញថា ជារបស់មិនទៀង ព្រោះមានការកើតឡើង និង សូន្យទៅវិញ ជាធម្មតា ។

(ន័យសេចក្តីសំរេចប្រយោជន៍ដល់អ្នកឃើញ)

*(៣១០) សេចក្តីវិនិច្ឆ័យ ត្រង់បទថា “ដោយការសំរេចប្រយោជន៍ដល់អ្នកឃើញយ៉ាងនេះ” បណ្ឌិត គប្បីជ្រាបដូចតទៅ: ក៏សេចក្តីសំរេចប្រយោជន៍ណា រមែងមាន ដល់បុគ្គលកាលឃើញ ដោយចំណែក ២ ដោយអំណាចនៃសេចក្តីសង្ខេប និង ពិស្តារ យ៉ាងនេះ, ន័យនៃការវិនិច្ឆ័យ អំពីការសំរេចនូវប្រយោជន៍នោះ គឺបណ្ឌិតគប្បីជ្រាបខ្វះផង ។ សំនួរថា: តើដូចម្តេច ? ។ ចម្លើយថា: ដំបូង បើពោល ដោយសង្ខេប ព្រះយោគាវចរ កាលឃើញឧបាទានក្ខន្ធទាំង ៥ ដោយភាវៈនៃបញ្ចុបាទានក្ខន្ធនោះ ដូចជាសត្រូវមានដាវ លើកឡើងហើយជាដើម រមែងមិនក្តៅក្រហាយ ព្រោះខន្ធទាំងឡាយ, តែបើពោល ដោយពិស្តារ ព្រះយោគាវចរ កាលឃើញ នូវខន្ធទាំងឡាយ មានរូបក្ខន្ធជាដើម ដោយភាវៈនៃខន្ធប្រាកដស្មើ ដោយដុំនៃពពុះទឹកជាដើម ឈ្មោះថា ជាអ្នកមិនឃើញថា មានខ្លឹមសារ ក្នុងធម៌ដែលមិនមានខ្លឹមសារទាំងឡាយ ។*

*បើពោលដោយសេចក្តីប្លែកគ្នាមួយទៀត បុគ្គលកាលឃើញនូវរូបខាងក្នុង ដោយថា ជាអសុភៈ ឈ្មោះថា កំណត់ដឹងនូវកវឡិង្ការាហារ រមែងឃើញសេចក្តីវិបល្លាសថាជារបស់ល្អ ក្នុងរបស់ដែលមិនល្អ កន្លងបង់នូវកាមោឃៈ ឆាកខ្លួនចេញបានពីកាមោឃៈ ជាអ្នកមិនមានអាសវៈ ដោយកាមាសវៈ ទំលាយបង់នូវកិលេស ជាគ្រឿងចងធ្វាក់នូវកាយ គឺអភិជ្ឈា មិនប្រកាន់នូវកាមុបាទាន, បុគ្គលអ្នកឃើញនូវវេទនាថា ជាទុក្ខ ឈ្មោះថា កំណត់ដឹងនូវផស្សាហារ រមែងលះបង់នូវការយល់ខុស ថា ជាសុខ ក្នុងរបស់ដែលជាទុក្ខ កន្លងបង់នូវភវោឃៈ រើបម្រះចេញអំពីភវយោគៈ ជាអ្នកមិនមានអាសវៈ ដោយភវាសវៈ រមែងទំលាយបង់នូវកិលេស ជាគ្រឿងចងធ្វាក់នូវកាយ គឺព្យាបាទ រមែងមិនប្រកាន់មាំនូវ*



*សីលព្វតុបាទាន, អ្នកឃើញសញ្ញា និង សង្ខារទាំងឡាយ ដោយថា ជាអនត្តា ឈ្មោះថា កំណត់ដឹងនូវមនោសញ្ចេតនាហារ រមែងលះបង់នូវការយល់ខុសថា ខ្លួន ក្នុងរបស់ដែលមិនមែនជាខ្លួន រមែងកន្លងបង់នូវទិដ្ឋោឃៈ រើបម្រះចេញអំពីទិដ្ឋិយោគៈ ជាអ្នកមិនមានអាសវៈ ដោយទិដ្ឋាសវៈ ទំលាយនូវកិលេស ជាគ្រឿងចងធ្វាក់នូវកាយ គឺការប្រកាន់ថា មានយ៉ាងនេះពិត មិនប្រកាន់មាំនូវអត្តវាទុបាទាន, អ្នកឃើញនូវវិញ្ញាណ ដោយថា ជារបស់មិនទៀងទាត់ ឈ្មោះថា កំណត់ដឹងនូវវិញ្ញាណាហារ លះបង់ការយល់ខុសថា ជារបស់ទៀងទាត់ ក្នុងរបស់ដែលមិនទៀងទាត់ កន្លងបង់នូវអវិជ្ជោឃៈ រើបម្រះចេញអំពីអវិជ្ជោឃៈ ជាអ្នកមិនមានអាសវៈ ដោយអវិជ្ជាសវៈ ទំលាយបង់នូវកិលេស ជាគ្រឿងចងធ្វាក់នូវកាយ គឺការប្រកាន់នូវសីល និង វត មិនប្រកាន់មាំនូវទិដ្ឋុបាទាន ។*

ការឃើញ (ខន្ធ) ដោយអំណាចហេតុ មានបុគ្គលអ្នក
សម្លាប់ជាដើម មានអានិសង្សច្រើនយ៉ាងនេះ ព្រោះ
ហេតុណា, ព្រោះហេតុនោះ ធីរជន គប្បីឃើញនូវខន្ធ
ទាំងឡាយ ដោយអំណាចនៃហេតុ មានបុគ្គលអ្នក
សម្លាប់ជាដើម យ៉ាងដូច្នោះចុះ ។

*បរិច្ឆេទ ទី១៤ ឈ្មោះខន្ធនិទ្ទេស ក្នុងអធិការនៃបញ្ញាភាវនា*
*ក្នុងវិសុទ្ធិមគ្គ ដែលលោកធ្វើហើយ ដើម្បីប្រយោជន៍*
*ដល់បាមោជ្ជៈនៃសាធុជន យ៉ាងនេះឯង ។*

## អាយតន ធាតុនិទ្ទេស

*ការសំដែងនូវអាយតនៈ និង ធាតុ*

### អាយតននិទ្ទេស

*(៣១១) អាយតនៈ ១២ គឺ : ចក្ខាយតនៈ ១, រូបាយតនៈ ១, សោតាយតនៈ ១, សទ្ទាយតនៈ ១, ឃានាយតនៈ ១, គន្ធាយតនៈ ១, ជិវ្ហាយតនៈ ១, រសាយតនៈ ១, កាយាយតនៈ ១, ផោដ្ឋព្វាយតនៈ ១, មនាយតនៈ ១ និង ធម្មាយតនៈ ១ ហៅថា អាយតនៈទាំងឡាយ ។*

ក្នុងអាយតនៈទាំងឡាយនោះ បណ្ឌិតគប្បីជ្រាបសេចក្ដីវិនិច្ឆ័យ ដោយអត្ថ និង ដោយលក្ខណៈ ដោយសេចក្ដីមានប្រមាណប៉ុណ្ណោះ ដោយលំដាប់ ដោយបំព្រួញ ដោយពិស្ដារ និង ដោយភាវៈជារបស់ដែលបុគ្គលគប្បីឃើញ ដូច្នោះឯង ។

(ដោយអត្ថ)

*ក្នុងបទទាំងនោះ បើពោលដោយវិសេស ធម្មជាតណា ឃើញ ធម្មជាតនោះ ឈ្មោះថា ចក្ខុ, អធិប្បាយថា រមែងត្រេកអរ និង ប្រកាសឲ្យឃើញច្បាស់នូវរូប (ហៅថា ចក្ខុ) ។ ធម្មជាតណា វិនាសទៅ, ធម្មជាតនោះ ឈ្មោះថា រូប, អធិប្បាយថា : រូប កាលដល់នូវការប្រែប្រួលនៃពណ៌ រមែងប្រកាសនូវភាវៈនៃហទយៈ (ហៅថា រូប) ។*

*ធម្មជាតណា ឮ ធម្មជាតនោះ ឈ្មោះថា សោតៈ ។ សភាវៈណា គឹកកង សភាវៈនោះ ឈ្មោះថា សទ្ទៈ, អធិប្បាយថា សភាវៈណា*



*គឺបុគ្គលបន្លឺឡើង សភាវៈនោះ (ហៅថា សម្លេង) ។*

*ធម្មជាតណា ហិតក្លិន ធម្មជាតនោះ ឈ្មោះថា ឃានៈ ។ សភាវៈណា ជុំធ្លូល សភាវៈនោះ ហៅថា ក្លិន, អធិប្បាយថា សភាវៈចាក់ចុចនូវទីតាំងរបស់ខ្លួន ។*

*ធម្មជាតណា ទំនុកបំរុងនូវជីវិត ធម្មជាតនោះ ឈ្មោះថា ជិវ្ហា ។ សត្វទាំងឡាយ រមែងត្រេកអរ នូវអាហារនោះ ព្រោះហេតុនោះ អាហារនោះ ឈ្មោះថា រស, អធិប្បាយថា រីករាយ ។*

*សភាវៈណា ជាទីវិលមកនៃធម៌ទាំងឡាយដ៏លាមក គឺនៃធម៌ទាំងឡាយដែលមានអាសវៈ ព្រោះហេតុនោះ សភាវៈនោះ ឈ្មោះថា កាយ ។ ប្រទេសជាទីកើត ហៅថា អាយៈ (ទីមក) ។*

*ធម្មជាតណា គឺជនពាល់ត្រូវ ធម្មជាតនោះ ឈ្មោះថា ផោដ្ឋព្វៈ ។*

*សភាវៈណា ដឹង សភាវៈនោះ ឈ្មោះថា មនៈ ។*

*សភាវៈទាំងឡាយណា ទ្រទ្រង់នូវលក្ខណៈ របស់ខ្លួន សភាវៈទាំងឡាយនោះ ឈ្មោះថា ធម៌ ។*

*បើពោលដោយមិនប្លែកគ្នា វត្ថុមានចក្ខុជាដើម គឺបណ្ឌិត គប្បីជ្រាបថា អាយតនៈ ព្រោះកិរិយាតភ្ជាប់គ្នា ១ ព្រោះផ្សព្វផ្សាយនូវអាយៈទាំងឡាយ ១ ព្រោះការនាំទៅនូវអាយតៈ ១ ។*

*អដ្ឋកថាចារ្យ ពោលអត្ថរូបនេះថា: ក៏ធម៌ទាំងឡាយដែលប្រព្រឹត្តទៅ ក្នុងចិត្ត និង ចេតសិក មានទ្វារនោះៗ ជាអារម្មណ៍ រមែងតភ្ជាប់ គឺថា តាំងឡើង គឺថា ខ្វាំងខ្វប់ ឬថា ព្យាយាមទៅតាមកិច្ច របស់ខ្លួនៗ មានការសោយជាដើម ក្នុងរូបទាំងឡាយ មានចក្ខុរូបជាដើម ។*

*អដ្ឋកថាចារ្យ ពោលអត្ថរូបនេះ ថា : ក៏ឯទ្វារ និង អារម្មណ៍ទាំង*

ឡាយនោះ ត្រដាង ញ៉ាំងបុគ្គលឲ្យលាតចេញ នូវធម៌ទាំងឡាយនោះ ដែលជាទីមក ។

អដ្ឋកថាចារ្យ ពោលអត្ថរូបនេះថា ក៏សំសារទុក្ខនេះ ប្រព្រឹត្តទៅ គឺថា កន្ទងទៅ គឺថា ប្រព្រឹត្តកន្ទងទៅ ក្នុងសំសារ គឺពុទ្ធញ្ញាណកំណត់មិនបានហើយ, ទ្វារ និង អារម្មណ៍ទាំងឡាយនោះ មិនងាកត្រឡប់ចេញ ដរាបណា, ក៏រមែងនាំទៅ គឺញ៉ាំងសំសារទុក្ខ ឲ្យប្រព្រឹត្តទៅដរាបនោះឯង ។

ធម៌ទាំងឡាយទាំងអស់នេះឯង គឺលោកពោលថា : អាយតនៈៗ ព្រោះតក្អាប់គ្នាផង ព្រោះកិរិយាផ្សព្វផ្សាយទៅ នៃអាយៈទាំងឡាយផង ព្រោះការនាំទៅនៃអាយតៈផង ដូចថ្លែងមកនេះឯង ។

ម្យ៉ាងវិញទៀត អាយតនៈ គឺបណ្ឌិត គប្បីជ្រាប ដោយអត្ថថា ជាកន្លែងជាទីនៅផង ដោយអត្ថថា ជាកន្លែងជាទីប្រជុំចុះផង ដោយអត្ថថា ជាប្រទេសជាទីកើតផង ដោយអត្ថថា ជាហេតុផង ។

ពិតដូច្នេះមែន កន្លែងជាទីនៅ លោកពោលថា "អាយតនៈ" ក្នុងប្រយោគទាំងឡាយ មានប្រយោគជាអាទិ៍ថា "កន្លែងជាទីនៅអាស្រ័យនៃឥស្សរជន, កន្លែងជាទីនៅនៃឥស្សរជន ឈ្មោះថា វាសុទេព" ក្នុងលោក ។ អណ្ដូងជាកន្លែងកើត ហៅថា "អាយតនៈ" ក្នុងប្រយោគទាំងឡាយ មានប្រយោគជាអាទិ៍ថា: អណ្ដូងជាទីកើតនៃមាស, អណ្ដូងជាទីកើតនៃកែវ ។ តែកន្លែងជាទីប្រជុំ លោកហៅថា "អាយតនៈ" ក្នុងប្រយោគទាំងឡាយ មានប្រយោគជាដើមថា: ក៏ក្នុងសាសនា សត្វស្លាបទាំងឡាយ ក្នុងព្រៃជាទីប្រជុំ គួរជាទីរីករាយ រមែងទំជ្រកនៅនឹងដើមឈើធំនោះ ។ ប្រទេសជាទីកើត លោកហៅថា "អាយតនៈ" ក្នុង



ប្រយោគទាំងឡាយ មានប្រយោគជាដើមថា : ប្រទេស ឈ្មោះថា ទក្ខិណាបថជាទីកើតនៃគោទាំងឡាយ ។ ហេតុ ក៏ហៅថា "អាយតនៈ" ក្នុងប្រយោគទាំងឡាយ មានប្រយោគជាដើមថា: កាលបើហេតុ មានប្រាកដ, ភិក្ខុនោះ រមែងដល់នូវភាពនៃខ្លួនជាបន្ទាល់ ក្នុងធម៌ទាំងឡាយនោះៗ ។

ម្យ៉ាងវិញទៀត ធម៌ទាំងឡាយ គឺចិត្ត និង ចេតសិកនោះៗ នៅអាស្រ័យ ក្នុងទ្វារ និង អារម្មណ៍ទាំងឡាយ មានចក្ខុជាដើម ព្រោះភាវៈនៃចិត្ត និង ចេតសិកទាំងឡាយនោះ ប្រព្រឹត្តទៅជាប់ជំពាក់នឹងចក្ខុជាដើមនោះៗ ព្រោះហេតុដូច្នោះ ទ្វារ និង អារម្មណ៍មានចក្ខុជាដើម ទើបឈ្មោះថា ជាកន្លែងជាទីនៅនៃចិត្ត និង ចេតសិកទាំងឡាយនោះ ។

ម្យ៉ាងទៀត ចិត្ត និង ចេតសិកទាំងឡាយនោះ ប្រទ្បំហើយ ក្នុងអាយនៈទាំងឡាយ មានចក្ខាយតនៈជាដើម ព្រោះភាវៈនៃធម៌ទាំងឡាយនោះ អាស្រ័យចក្ខុជាដើមនោះផង ព្រោះភាវៈនៃអាយតនៈទាំងឡាយមានរូបជាដើមនោះ ជាអារម្មណ៍ផង ព្រោះហេតុនោះ ទ្វារ និង អារម្មណ៍ទាំងឡាយ មានចក្ខុជាដើម ឈ្មោះថា ជាអណ្ដូង នៃចិត្ត និង ចេតសិកទាំងឡាយនោះ ។បេ។,

ក៏ ទ្វារ និង អារម្មណ៍ទាំងឡាយ មានចក្ខុជាដើម ឈ្មោះថា ជាកន្លែង ជាទីប្រជុំចុះនៃចិត្ត និង ចេតសិកទាំងឡាយនោះ ព្រោះកិរិយាប្រជុំចុះ ក្នុងចិត្ត និង ចេតសិកទាំងឡាយនោះៗ ដោយអំណាចនៃវត្ថុ ទ្វារ និង អារម្មណ៍ ។

ចំណែក ទ្វារ និង អារម្មណ៍ទាំងឡាយ មានចក្ខុជាដើម ឈ្មោះថា ជាប្រទេសជាទីកើត នៃចិត្ត និង ចេតសិកទាំងឡាយនោះ ព្រោះកិរិយា

កើត តែក្នុងចក្ខុជាដើមនោះប៉ុណ្ណោះ ដោយមានចក្ខុជាដើមនោះ ជាទីអាស្រ័យ និង មានរូបជាដើម ជាអារម្មណ៍ ។

ចំណែកខាង ទ្វារ និង អារម្មណ៍ មានចក្ខុជាដើម បានឈ្មោះថា ជាហេតុនៃចិត្ត និង ចេតសិកទាំងឡាយនោះ ព្រោះកាលបើទ្វារ និង អារម្មណ៍ទាំងនោះ មិនមាន ចិត្តចេតសិក ក៏មិនមាន ។

ធម៌ទាំងឡាយនេះ បានឈ្មោះថា “អាយតនៈៗ” ដោយហេតុទាំងឡាយយ៉ាងនេះឯង គឺ ដោយអត្ថថា ជាទីនៅអាស្រ័យ ១ ដោយអត្ថថា ជាទីកើត ១ ដោយអត្ថថា ជាទីប្រជុំចុះ ១ ដោយអត្ថថា ជាប្រទេសជាទីកើត ១ ដោយអត្ថថា ជាហេតុ ១ ដូចន័យដែលបានពោលមកហើយនេះឯង ។

ព្រោះហេតុនោះ បណ្ឌិត គប្បីវិនិច្ឆ័យ ក្នុងអាយតនៈទាំងឡាយនេះ ដោយអត្ថ យ៉ាងនេះជាមុន ថា “ចក្ខុផង ចក្ខុនោះ ជាអាយតនៈ ដោយអត្ថ ដូចដែលបានពោលមកហើយផង ព្រោះហេតុនេះ ទើបឈ្មោះថា ចក្ខាយតនៈ ។ល។ ធម៌ទាំងឡាយផង ធម៌ទាំងឡាយនោះ ជាអាយតនៈ ដោយអត្ថតាមដែលបានពោលមកហើយផង ព្រោះហេតុនេះ ទើបឈ្មោះថា ធម្មាយតនៈ” ។

**(ដោយលក្ខណៈ)**

(៣១២) បើពោលតាមលក្ខណៈ នៃអាយតនៈទាំងឡាយ មានចក្ខាយតនៈជាដើម គឺបណ្ឌិត គប្បីជ្រាបសេចក្តីវិនិច្ឆ័យ ក្នុងបទនេះថា “លក្ខណៈ” តែថា លក្ខណៈទាំងឡាយនោះ នៃចក្ខុទាំងឡាយនោះ បណ្ឌិត គប្បីជ្រាប តាមន័យដែលពោលហើយ ក្នុងខន្ធនិទ្ទេសផងចុះ ។

**(ដោយមានតែប៉ុណ្ណោះ)**



បទថា “តាវតូតោ” សេចក្តីថា ដោយភាវៈនៃអាយតនៈ មានប្រមាណប៉ុណ្ណោះ ។ មានព្រះពុទ្ធតម្រាស់នេះថា: បើអាចារ្យអ្នកចោទគប្បីចោទថា ក៏ធម៌ទាំងឡាយមានចក្ខុជាដើម ឈ្មោះថា ធម៌ ហ្នឹងឯង បើមានហេតុយ៉ាងនេះដូច្នេះ ព្រោះហេតុអ្វី បានជាព្រះអង្គ មិនទ្រង់ត្រាស់ថា “ធម្មាយតនៈ” (បែរជា) ទ្រង់ត្រាស់អាយតនៈ ១២ (វិញ) ។ អាចារ្យអ្នកដោះស្រាយ គប្បីពោលដោះស្រាយថា : ព្រោះក្នុងទីនេះ កំណត់យកជាទ្វារ ១ ជាអារម្មណ៍ ១ នៃក្រុមវិញ្ញាណទាំង ៦ ព្រោះកំណត់ជាឧប្បត្តិទ្វារ និង អារម្មណ៍ នៃវិញ្ញាណទាំង ៦, នេះ ជាការផ្សេងគ្នា នៃធម៌ទាំងឡាយ មានចក្ខុជាដើមនោះ ព្រោះហេតុនោះ ទើបអាយតនៈទាំង ១២ គឺព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ។ មែនពិតចក្ខាយតនៈហ្នឹងឯង ចាត់ជា ឧប្បត្តិទ្វារ និង រូបាយតនៈប៉ុណ្ណោះ ជាអារម្មណ៍ នៃកាយវិញ្ញាណ ដែលរាប់បញ្ចូលក្នុងវិថីនៃចក្ខុវិញ្ញាណ ។ អាយតនៈទាំងឡាយក្រៅពីនេះ ក៏ជាឧប្បត្តិទ្វារ និង ជាអារម្មណ៍ នៃកាយវិញ្ញាណ ដែលរាប់បញ្ចូល ក្នុងវិថីនៃវិញ្ញាណទាំងឡាយក្រៅពីនេះ ដូចគ្នានោះដែរ ។ ក៏ចំណែក ១ នៃមនាយតនៈ សំដៅយកភវង្គមនៈប៉ុណ្ណោះ ចាត់ជាឧប្បត្តិទ្វារ និង ធម្មាយតនៈ ចាត់ជាអារម្មណ៍ នៃវិញ្ញាណ ទី៦ មិនទូទៅទេ” ដូច្នេះឯង ។

អាយតនៈទាំងឡាយ ១២ គឺ ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ព្រោះការកំណត់ដោយឧប្បត្តិទ្វារ និង ជាអារម្មណ៍នៃក្រុមវិញ្ញាណទាំង ៦ ដូចបានរៀបរាប់មកនេះ ។

សេចក្តីវិនិច្ឆ័យ ដោយមានសេចក្តីប្រមាណប៉ុណ្ណោះ គឺបណ្ឌិតគប្បីជ្រាប ក្នុងអាយតនៈទាំងឡាយនេះ យ៉ាងនេះឯង ។

(ដោយលំដាប់)

*(៣១៣) បណ្ដាលំដាប់ទាំងឡាយ មានឧប្បត្តិកមៈជាដើម ដែលលោកពោលហើយ ក្នុងកាលមុន ត្រង់បទនេះឯងថា "កមតោ" លំដាប់នៃទេសនាហ្នឹងឯង ទើបយកជាការបាន ។ មែនពិត បណ្ដាអាយតនៈទាំងឡាយដែលប្រព្រឹត្តទៅឰដ៏ខាងក្នុង ចក្ខ្វាយតនៈជាអាយតនៈប្រាកដ ព្រោះភាវៈជាវិស័យដែលឃើញបាន និង ការប៉ះទង្គិចបាន ព្រោះហេតុនោះ ចក្ខ្វាយតនៈ គឺព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សំដែងមុនគេ ។ តអំពីនោះ ទ្រង់សំដែងអាយតនៈទាំងឡាយដទៃ មានសោតាយតនៈជាដើម ជាវិស័យដែលឃើញមិនបាន តែប៉ះពាល់បាន ។ ម្យ៉ាងវិញទៀត បណ្ដាអាយតនៈ ដែលប្រព្រឹត្តទៅ ឰដ៏ខាងក្នុង ចក្ខ្វាយតនៈ និង សោតាយតនៈទាំងឡាយ គឺព្រះមានព្រះភាគទ្រង់ត្រាស់សំដែងហើយមុន ព្រោះភាវៈនៃអាយតនៈទាំងនោះ មានឧបការៈច្រើន ដោយភាវៈជាហេតុនៃទស្សនានុត្តរិយៈ និង សវនានុត្តរិយៈ ។ បន្ទាប់អំពីនោះមក ទើបទ្រង់សំដែងអាយតនៈទាំងឡាយ ៣ មានឃានាយតនៈជាដើម ។ មនាយតនៈ គឺព្រះភគវន្តទ្រង់ត្រាស់សំដែងហើយ ក្នុងទីបំផុត ព្រោះភាវៈជាគោចរវិស័យ នៃអាយតនៈទាំងឡាយ ៥ មានចក្ខ្វាយតនៈ ជាដើម ។ តែបណ្ដាអាយតនៈទាំងឡាយខាងក្រៅ អាយតនៈទាំងឡាយមានរូបាយតនៈជាដើម ទ្រង់សំដែងជាលំដាប់ៗ នៃអាយតនៈខាងក្នុងនោះៗ ព្រោះជាគោចរនៃអាយតនៈទាំងឡាយមានចក្ខ្វាយតនៈជាដើម ។*

*ម្យ៉ាងទៀត លំដាប់នេះ នៃអាយតនៈទាំងឡាយមានចក្ខ្វាយតនៈជាដើមនោះ គឺបណ្ឌិត គប្បីជ្រាប ដោយការកំណត់ នូវហេតុនៃការកើតឡើងនៃវិញ្ញាណ ។ សមដូចជាព្រះតម្រាស់ដែលមានព្រះភាគ ទ្រង់*



*ត្រាស់សំដែងហើយថា "ចក្ខុវិញ្ញាណ រមែងកើតឡើង ព្រោះអាស្រ័យនូវចក្ខុផង នូវរូបទាំងឡាយផង ។ល។ មនោវិញ្ញាណ រមែងកើតឡើង ព្រោះអាស្រ័យនូវចិត្តផង នូវធម៌ទាំងឡាយផង" ដូច្នេះ ។*

*ក៏សេចក្ដីវិនិច្ឆ័យ ដោយលំដាប់ ក្នុងអាយតនៈទាំងឡាយនេះ គឺបណ្ឌិតគប្បីជ្រាប ដូចបានពណ៌នាមកនេះឯង ។*

(ដោយសង្ខេប និង ពិស្ដារ)

*(៣១៤) (ក្នុងបទនេះ) ថា "សង្ខេបវិត្ថារា" បណ្ឌិត គប្បីជ្រាប សេចក្ដីវិនិច្ឆ័យ (ដូចតទៅ) ។ បើពោលដោយសង្ខេប អាយតនៈទាំងឡាយ ទាំង ១២ គ្រាន់តែជានាមរូបប៉ុណ្ណោះ ព្រោះភាវៈនៃមនាយតនៈ និង ធម្មាយតនៈ ជាឯកទេស លោកសង្គ្រោះដោយនាម និង អាយតនៈទាំងឡាយដែលសេសសល់អំពីនោះ សង្គ្រោះដោយរូប ។ តែបើពោលដោយពិស្ដារ បណ្ដាអាយតនៈ ឰដ៏ខាងក្នុង ចក្ខ្វាយតនៈ គ្រាន់តែជាចក្ខុប្បសាទ ដោយអំណាចនៃជាតិតែប៉ុណ្ណោះ, តែថា ចក្ខ្វាយតនៈនោះ មានប្រភេទជាអនន្ត ដោយការញែកនូវបច្ច័យ, គតិ, និកាយ និង បុគ្គល ។ អាយតនៈទាំង ៤ មានសោតាយតនៈជាដើម ក៏ដូចគ្នាដែរ ។ មនាយតនៈ មាន ៨៩ ប្រភេទ ដោយការញែក តាមកុសលវិញ្ញាណ អកុសលវិញ្ញាណ វិបាកវិញ្ញាណ និង កិរិយាវិញ្ញាណ, ម្យ៉ាងវិញទៀត មនាយតនៈ មានដល់ទៅ ១២១ ប្រភេទ, បើពោលតាមប្រភេទនៃវត្ថុ និង បដិបទាជាដើម មនាយតនៈ មានប្រភេទជាអនន្ត ។*

*អាយតនៈ គឺៈ រូប សម្លេង ក្លិន និង រសទាំងឡាយ ដោយការញែកមានការញែកតាមចំណែកមិនស្មើគ្នា និង បច្ច័យជាដើម ឈ្មោះថាមានប្រភេទជាអនន្ត ។ ផោដ្ឋព្វាយតនៈ មាន ៣ ប្រភេទ ដោយអំណាច*

នៃបឋវីធាតុ តេជោធាតុ និង វាយោធាតុ, មានប្រភេទដ៏ច្រើន ដោយការផ្សេងគ្នា នៃបច្ច័យជាដើម ។ ធម្មាយតនៈ ក៏មានច្រើនប្រភេទ ដោយការញែកតាមសភាវៈ និង ភាវៈផ្សេងៗ គ្នា នៃវេទនាខន្ធ, សញ្ញាខន្ធ, សង្ខារក្ខន្ធ, រូបដ៏ល្អិត និង ព្រះនិព្វាន យ៉ាងដូច្នេះឯង ។

សេចក្ដីវិនិច្ឆ័យ ដោយបំព្រួញ និង ដោយពិស្ដារ គឺបណ្ឌិត គប្បីជ្រាប ដូចបានពោលមកហើយ យ៉ាងនេះឯង ។

(ដោយជារបស់ដែលគប្បីឃើញ)

(៣១៥) ក៏សេចក្ដីវិនិច្ឆ័យ ក្នុងបទថា "ទដ្ឋព្វតោ" នេះដូចតទៅ ។ អាយតនៈទាំងឡាយ ដែលបច្ច័យប្រជុំតាក់តែងហើយទាំងអស់ហ្នឹងឯង គឺបណ្ឌិត គប្បីជ្រាប ដោយការមិនមកផង ដោយការមិនចេញទៅផង ។ មែនពិត អាយតនៈទាំងឡាយនោះ មុនកើតឡើង ក៏មិនបានមានមកអំពីទីណាមួយទេ ទាំងមិនដែលទៅ ក្នុងទីណាមួយ អំពីខាងលើនៃការសូន្យទៅទេ, បើតាមពិត អាយតនៈទាំងឡាយនេះ មានសភាពគឺបុគ្គលមិនបានហើយក្នុងកាលមុនអំពីការកើត, ជាសភាពតែងបែកធ្លាយ ខាងលើអំពីការសូន្យទៅ ជាអាយតនៈ មិនមានអំណាច រមែងប្រព្រឹត្តទៅ ព្រោះភាពនៃអាយតនៈ ដែលប្រព្រឹត្តជាប់តាមបច្ច័យ ត្រង់កណ្ដាល ត្រង់ខាងដើម និង ខាងចុង, ហេតុនោះ អាយតនៈទាំងនោះ បណ្ឌិត គប្បីឃើញ ដោយការមិនមកផង ដោយការមិនចេញទៅផង ។

អាយតនៈទាំងឡាយនោះ គឺបណ្ឌិត គប្បីយល់ ដោយមិនចាំបាច់រិះគិតផង ដោយពុំចាំបាច់ខ្វល់ខ្វាយផង យ៉ាងដូច្នោះដែរ ។ មែនពិត ការគិតយ៉ាងនេះ រមែងមិនមាន ដល់អាយតនៈទាំងឡាយ មានចក្ខុ និង រូបជាដើមថា: ឱ! ធ្វើម្ដេចទៅហ្ន៎ ឈ្មោះថា វិញ្ញាណ គប្បីកើតឡើង



និមិត្តសាមគ្គី របស់ពួកយើង ។ ទាំងអាយតនៈទាំងឡាយ មានចក្ខុ និង រូបជាដើមនោះ មិនបាច់រិះគិត មិនដល់នូវការខ្វល់ខ្វាយ ដោយភាវៈជាទ្វារក្ដី ដោយភាវៈជាវត្ថុក្ដី ដោយភាវៈជាអារម្មណ៍ក្ដី ដើម្បីឲ្យវិញ្ញាណកើតឡើង ។ បើតាមពិត វិញ្ញាណទាំងឡាយ មានចក្ខុវិញ្ញាណជាដើម រមែងកើតឡើងព្រម និមិត្តសាមគ្គី នៃអាយតនៈ មានចក្ខុ និង រូបជាដើមណា, ធម្មជាតិនេះ ចាត់ជាធម្មតាទេ ដូច្នេះឯង ។ ព្រោះហេតុនោះ អាយតនៈទាំងឡាយនោះ បណ្ឌិត គប្បីជ្រាប ដោយពុំចាំបាច់រិះគិតផង ដោយពុំចាំបាច់ខ្វល់ខ្វាយផង ។

ម្យ៉ាងវិញទៀត អាយតនៈខាងក្នុង បណ្ឌិតគប្បីឃើញ ដូចជាស្រុកដ៏ស្ងាត់ ព្រោះភាវៈនៃស្រុកនោះ ប្រាសហើយចាកភាពដ៏ទៀងទាត់, ល្អ, សុខ និង ភាពជាខ្លួនប្រាណ ។ អាយតនៈទាំងឡាយខាងក្រៅ គប្បីឃើញដូចជាចោរអ្នកសម្លាប់នូវអ្នកស្រុក ព្រោះភាវៈនៃអាយតនៈខាងក្រៅនោះ ជាអ្នកសម្លាប់នូវអាយតនៈទាំងឡាយខាងក្នុង ។ សមដូចជាព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយថា: ម្នាលភិក្ខុទាំងឡាយ! ចក្ខុ តែងត្រូវបៀតបៀន ដោយរូបទាំងឡាយ ជាទីពេញចិត្តខ្លះ មិនជាទីពេញចិត្តខ្លះ" ដូច្នេះជាដើម, សេចក្ដីពិស្ដារ គឺបណ្ឌិតគប្បីជ្រាបផងចុះ ។

ម្យ៉ាងវិញទៀត អាយតនៈខាងក្នុង បណ្ឌិត គប្បីឃើញ ដូចជាសត្វ ៦ ពួក ។ អាយតនៈខាងក្រៅ បណ្ឌិត គប្បីឃើញដូចជាស្រុកជាទីគោចរនៃសត្វ ៦ ពួកនោះ ដូច្នេះឯង ។

សេចក្ដីវិនិច្ឆ័យ ដោយជាវត្ថុ គឺបណ្ឌិត គប្បីឃើញ ក្នុងអាយតនៈទាំងឡាយនេះគឺបណ្ឌិតគប្បីជ្រាប ដូចបានពោលមកនេះឯង ។

នេះជាកថាមុខដោយពិស្ដារ នៃអាយតនៈទាំងឡាយចប់ត្រឹមនេះ ។

## ធាតុនិទ្ទេស

*(៣១៦) ក៏បន្ទាប់អំពីអាយតនៈនោះមក ធាតុទាំងឡាយ ១៨ គឺ ចក្ខុធាតុ ១, រូបធាតុ ១, ចក្ខុវិញ្ញាណធាតុ ១, សោតធាតុ១, សទ្ទធាតុ១, សោតវិញ្ញាណធាតុ១, ឃានធាតុ ១, គន្ធធាតុ ១, ឃានវិញ្ញាណធាតុ ១, ជិវ្ហាធាតុ១, រសធាតុ១, ជិវ្ហាវិញ្ញាណធាតុ១, កាយធាតុ១, ផោដ្ឋព្វធាតុ១, កាយវិញ្ញាណធាតុ ១, មនោធាតុ ១, ធម្មធាតុ ១, មនោវិញ្ញាណធាតុ ១ ហៅថា ធាតុ ។*

> សេចក្ដីវិនិច្ឆ័យ ក្នុងធាតុទាំងឡាយនោះ គឺបណ្ឌិតគប្បីជ្រាប ដោយអត្ថផង ដោយលក្ខណៈជាដើម ទាំងឡាយផង ដោយលំដាប់ ដោយហេតុមានប្រមាណប៉ុណ្ណោះផង ដោយការរាប់ចំនួនផង ដោយបច្ច័យផង ឬក៏ ដោយហេតុ គឺបុគ្គលគប្បីឃើញ ។

(ដោយអត្ថ)

*បណ្ដាបទទាំងនោះ ត្រង់បទថា "អត្ថតោ" ។ មានសេចក្ដីថា : បណ្ឌិត គប្បីជ្រាបសេចក្ដីវិនិច្ឆ័យ ដោយសេចក្ដីដ៏វិសេស នៃអាយតនៈទាំងឡាយ មានចក្ខាយតនៈជាដើម ដោយន័យ មានន័យជាដើមថា : ធម្មជាតណា មើលឃើញ ធម្មជាតិនោះ ឈ្មោះថា ចក្ខុ, ធម្មជាតណា វិនាសទៅ ធម្មជាតនោះ ឈ្មោះថា រូប, ការដឹងច្បាស់នៃចក្ខុ ឈ្មោះថា ចក្ខុវិញ្ញាណ ដូច្នេះមុនគេ ។ ចំណែកសេចក្ដីវិនិច្ឆ័យ ដោយអត្ថ មិនប្លែកគ្នា បណ្ឌិតគប្បីជ្រាប ដូចតទៅនេះ :*

*ធម្មជាតណា ចាត់ចែង ហេតុនោះ ធម្មជាតនោះ ឈ្មោះថា ធាតុ ។*



*ឬថា ធម៌ទាំងឡាយណា គឺសត្វទាំងឡាយទ្រទ្រង់ទុក ព្រោះហេតុនោះ ធម៌ទាំងឡាយនោះ ឈ្មោះថា ធាតុ ។*

*ឬថា វិធាន គឺការតាំងទុក ឈ្មោះថា ធាតុ ។*

*ឬក៏ ទុក្ខ គឺសត្វទាំងឡាយទ្រទ្រង់ទុក ដោយធម្មជាតិនោះ ព្រោះហេតុនោះ ធម្មជាតិនោះ ទើបឈ្មោះថា ធាតុ ។*

*ឬក៏ថា សេចក្ដីទុក្ខ គឺសត្វទាំងឡាយទ្រទ្រង់ទុក ក្នុងធម្មជាតិនោះ ព្រោះហេតុនោះ ធម្មជាតិនោះ ឈ្មោះថា ធាតុ ។*

*មែនពិត ធាតុទាំងឡាយដែលជាលោកិយៈ ជារបស់ដែលធម្មតាកំណត់ទុកហើយ ដោយភាវៈជាតួហេតុ រមែងចាត់ចែង នូវសំសារទុក្ខ ដែលមានប្រការផ្សេងៗ ដូចជាធាតុទាំងឡាយ មានមាស និង ប្រាក់ជាដើម ចាត់ចែងនូវវត្ថុធាតុ មានមាស និង ប្រាក់ជាដើម ដូច្នេះឯង ។*

*លោកិយធាតុទាំងឡាយ គឺសត្វទាំងឡាយទ្រទ្រង់ អធិប្បាយថា ទ្រទ្រង់ ដូចជាភារៈ គឺមនុស្សអ្នកនាំ នូវភារៈទាំងឡាយ លីសែងទៅ ដូច្នោះឯង ។*

*មួយទៀត លោកិយធាតុនោះ គ្រាន់តែជារបៀបបែបផែន នៃទុក្ខ ព្រោះមិនប្រព្រឹត្តទៅ ក្នុងអំណាច ។*

*ម្យ៉ាងទៀត សំសារទុក្ខ គឺសត្វទាំងឡាយ កសាងរឿយៗ ដោយធាតុទាំងឡាយនុ៎ះ ដែលជាហេតុ ។*

*ម្យ៉ាងទៀតថា សំសារទុក្ខនោះ ដែលត្រូវធម្មតា កំណត់ហើយយ៉ាងដូច្នោះ គឺសត្វទាំងឡាយទ្រទ្រង់ អធិប្បាយថា: តម្កល់ទុក ក្នុងធាតុទាំងឡាយនោះឯង ។*

*ក្នុងធម៌ទាំងឡាយ មានចក្ខុជាដើម ធម៌មួយៗ ទ្រង់ត្រាស់ហៅថា*

“ធាតុ” ដោយអំណាចនៃសេចក្តីមានជាអាទិ៍ថា “ចាត់ចែងឡើង គឺសត្វទាំងឡាយទ្រទ្រង់ទុក” ដូច្នេះ តាមសមគួរដល់ការកើតមាន ដោយប្រការដូច្នេះឯង ។

ន័យមួយទៀតថា ឈ្មោះថា អត្តា របស់ពួកតិរ្ថិយ មិនមាន តាមសភាពយ៉ាងណា, ធាតុទាំងឡាយនេះ ក៏មិនមាន យ៉ាងដូច្នោះដែរ, តែធាតុនេះ ឈ្មោះថា ធាតុ ព្រោះទ្រទ្រង់នូវសភាវៈរបស់ខ្លួន ។

ន័យមួយយ៉ាងទៀតថា អវយវៈនៃថ្មទាំងឡាយ មានកែវប្រពាល និង មនោសិលាជាដើម ដែលវិចិត្រ ក្នុងលោក គេហៅថា “ធាតុ” យ៉ាងណាមិញ, សូម្បីធាតុទាំងឡាយនេះ ក៏ដូចជាធាតុទាំងឡាយនោះដែរ ព្រោះវាជាអវយវៈនៃការដឹង និង ជារបស់ដែលបុគ្គល គប្បីដឹងយ៉ាងវិចិត្រ ក៏ដូច្នោះដែរ ។

សេចក្តីមួយទៀតថា ការហៅថា ធាតុ ក្នុងអវយវៈទាំងឡាយ មានរស និង ឈាមជាដើម ពោលគឺ សរីរៈជាទីកើត ជាអវយវៈដែលលោកកំណត់ហើយ ដោយលក្ខណៈទៅវិញទៅមក និង មានចំណែកមិនស្មើគ្នា រមែងមាន យ៉ាងណាមិញ, ការកំណត់ហៅថា ធាតុ គឺបណ្ឌិត គប្បីជ្រាប ក្នុងអវយវៈទាំងឡាយនេះឯង នៃអត្តភាព ពោលគឺ ខន្ធ ៥ ក៏យ៉ាងនោះដែរ ព្រោះថា អាយតនៈទាំងឡាយ មានចក្ខ្វាយតនៈជាដើមនេះ គឺលោកកំណត់ហើយ ដោយលក្ខណៈទៅវិញទៅមក និង មានចំណែកមិនស្មើគ្នា ដូច្នេះ ។

សេចក្តីម្យ៉ាងទៀតថា ពាក្យថា “ធាតុ” នោះ ជាឈ្មោះនៃវត្ថុមិនមានជីវិតប៉ុណ្ណោះ ។ ពិតដូច្នោះមែន ព្រះមានព្រះភាគ ទ្រង់បានធ្វើនូវការសំដែងនូវធាតុ ដើម្បីកិរិយាដកឡើង នូវសេចក្តីសំគាល់ ថា



មានជីវិត ក្នុងព្រះបាលី មានជាដើមថា : ម្នាលភិក្ខុ ! បុរសនេះ មានធាតុ ៦ ដូច្នេះឯង ។

ព្រោះហេតុនោះ តាមអត្ថ ដូចដែលលោកពោលហើយថា ចក្ខុផង ចក្ខុនោះ ជាធាតុផង ទើបឈ្មោះថា ចក្ខុធាតុ ។ល។ មនោវិញ្ញាណផង មនោវិញ្ញាណនោះ ជាធាតុផង ទើបឈ្មោះថា មនោវិញ្ញាណធាតុ ។

សេចក្តីវិនិច្ឆ័យ ដោយអត្ថ ក្នុងធាតុទាំងឡាយនេះ បណ្ឌិត គប្បីជ្រាប ដូចបានពោលមកនេះ ជាដំបូង ។

(ដោយលក្ខណៈជាដើម)

(៣១៧) ពាក្យថា “ដោយលក្ខណៈជាដើម” មានសេចក្តីថា ក៏សេចក្តីវិនិច្ឆ័យ ដោយលក្ខណៈជាដើម នៃអាយតនៈទាំងឡាយ មានចក្ខុជាដើម ក្នុងធាតុនិទ្ទេសនេះ បណ្ឌិត គប្បីជ្រាបផងដែរ ។ តែលក្ខណៈជាដើមនោះ បណ្ឌិត គប្បីជ្រាប តាមន័យដែលបានពោលហើយ ក្នុងខន្ធនិទ្ទេសនុ៎ះឯង ។

(ដោយលំដាប់)

សេចក្តីវិនិច្ឆ័យ ត្រង់បទថា “ដោយលំដាប់” គឺបណ្ឌិត គប្បីជ្រាប ដូចតទៅនេះ ។ បណ្តាលំដាប់ទាំងឡាយ មានលំដាប់ នៃការកើតជាដើម ដែលលោកពោលហើយ ក្នុងកាលមុន ត្រង់បទនិទ្ទេសនេះឯង លំដាប់នៃការសំដែងហ្នឹងឯង ទើបត្រឹមត្រូវ ។ ក៏ឯលំដាប់នោះនេះ គឺលោកពោលហើយ ដោយអំណាចនៃការកំណត់ តាមលំដាប់នៃហេតុ និង ផល ។ ក៏ប្រជុំពីរនៃធាតុនេះ គឺ ចក្ខុធាតុ, រូបធាតុ ឈ្មោះថា ជាហេតុ ។ ធាតុមួយ គឺចក្ខុវិញ្ញាណធាតុ ឈ្មោះថា ជាផល ។

លំដាប់យ៉ាងនេះ បណ្ឌិត គប្បីជ្រាប ក្នុងធាតុទាំងឡាយទាំងពួង ។

(ដោយហេតុមានប៉ុណ្ណោះ)

*(៣១៨) បទថា “តាវតូតោ” គឺដោយភាវៈនៃធាតុ មានប្រមាណប៉ុណ្ណោះ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយថា បើមានពាក្យសួរថា: ក៏ធាតុទាំងឡាយដទៃ មានយ៉ាងនេះជាដើមថា អាភាធាតុ, សុភាធាតុ, អាកាសានញ្ចាយតនធាតុ, វិញ្ញាណញ្ចាយតនធាតុ, អាកិញ្ចញ្ញាយតនធាតុ, នេវសញ្ញានាសញ្ញាយតនធាតុ, សញ្ញាវេទយិតនិរោធធាតុ, កាមធាតុ, ព្យាបាទធាតុ, វិហឹសាធាតុ, នេក្ខម្មធាតុ, អព្យាបាទធាតុ, អវិហឹសាធាតុ, សុខធាតុ, ទុក្ខធាតុ, សោមនស្សធាតុ, ទោមនស្សធាតុ, ឧបេក្ខាធាតុ, អវិជ្ជាធាតុ, អារម្ភធាតុ, និក្កមធាតុ, បរក្កមធាតុ, ហីនធាតុ, មជ្ឈិមធាតុ, បណីតធាតុ, អាបោធាតុ, តេជោធាតុ, វាយោធាតុ, អាកាសធាតុ, វិញ្ញាណធាតុ, សង្ខតធាតុ, អសង្ខតធាតុ, លោក មានធាតុជាអនេក លោក មានធាតុផ្សេងៗ” ដូច្នេះជាដើម ឃើញមាន ក្នុងប្រទេសនៃព្រះសូត្រ និង ព្រះអភិធម្មទាំងឡាយនោះៗ, កាលបើមានហេតុយ៉ាងនេះ, ការកំណត់ត្រឹមតែប៉ុណ្ណោះថា ធាតុ ១៨ គឺព្រះមានព្រះភាគ មិនធ្វើនូវការកំណត់ ដោយអំណាច នៃធាតុទាំងឡាយទាំងពួងធ្វើហើយ ព្រោះហេតុអ្វី? ។ ពាក្យដោះស្រាយថា: ព្រោះភាវៈនៃធាតុទាំងពួងទាំងឡាយ មានតាមសភាព ជាធាតុដ៏លាយចម្រុះគ្នា ពួដ៏ខាងក្នុងនៃធាតុ ១៨ នោះ ។*

*មែនពិត អាភាធាតុ គឺរូបធាតុហ្នឹងឯង, រីឯ សុភធាតុ ជាប់ទាក់ទងហើយ ដោយអាការៈ មានរូបធាតុជាដើម ។ សួរថា: ព្រោះហេតុអ្វី? ឆ្លើយថា: ព្រោះភាវៈនៃរូបធាតុនោះ ជាសុភនិមិត្ត ។ ពិតមែនហើយ សុភធាតុ ហៅថា សុភនិមិត្ត, ក៏សុភធាតុនោះ ដែលផុតស្រឡះចាក*



*ធាតុមានរូបជាដើម មិនមានទេ ។ ក៏ធម៌ទាំងឡាយ មានរូបជាដើម មានកុសលវិបាក ជាអារម្មណ៍ ឈ្មោះថា សុភធាតុ ព្រោះហេតុនោះ សុភធាតុនោះ គ្រាន់តែជាធាតុ មានរូបជាដើមប៉ុណ្ណោះ ។*

*ចិត្ត ក្នុងធាតុទាំងឡាយ មានអាកាសានញ្ចាយតនធាតុជាដើម ហៅថា មនោវិញ្ញាណធាតុ ។ ធម៌ទាំងឡាយដ៏សេស ហៅថា ធម្មធាតុ ។ ចំណែកសញ្ញាវេទយិតនិរោធធាតុ មិនមាន តាមសភាពទេ ។ ព្រោះថា សញ្ញាវេទយិតនិរោធធាតុនោះ គ្រាន់តែជាទីរំលត់ នូវប្រជុំ ២ នៃធាតុប៉ុណ្ណោះ ។*

*កាមធាតុ គ្រាន់តែជាធម្មធាតុប៉ុណ្ណោះ ។ សមដូចជាព្រះមានព្រះភាគ ទ្រង់ត្រាស់ថា “បណ្តាធាតុទាំងឡាយនោះ កាមធាតុតើដូចម្តេច? កាមធាតុ គឺការគិត ការត្រិះរិះ ។ល។ មិច្ឆាសង្កប្បៈ ដែលប្រកបហើយដោយកាម” ដូច្នេះ ។ ឬ ធាតុទាំងឡាយមាន ១៨ ក៏មាន។ សមដូចជាព្រះមានព្រះភាគ ទ្រង់ត្រាស់ថា: ខន្ធ, ធាតុ, អាយតនៈ និង អរូបទាំងឡាយណា, វេទនាណា, សញ្ញាណា, សង្ខារទាំងឡាយណា, វិញ្ញាណណា ដែលលោករាប់បញ្ចូលហើយ ក្នុងភពនេះ ធ្វើនូវអវីចិនរកជាទីបំផុត អំពីខាងក្រោម ធ្វើនូវបរនិម្មិតវសវត្តីទេវតាទាំងឡាយ ពួដ៏ខាងលើ ពួដ៏ខាងក្នុង ដែលត្រាច់ទៅ ក្នុងភពនោះ ត្រង់ចន្លោះនោះ, ខន្ធជាដើមនេះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា កាមធាតុ ។*

*នេក្ខម្មធាតុ គឺធម្មធាតុនោះហ្នឹងឯង ។ មនោវិញ្ញាណធាតុហ្នឹងឯងរមែងមាន ព្រោះព្រះពុទ្ធដីកាថា : ធម៌ទាំងឡាយទាំងអស់ហ្នឹងឯង ជាកុសល ឈ្មោះថា នេក្ខម្មធាតុ ។*

*ព្យាបាទធាតុ, វិហឹសាធាតុ, អព្យាបាទធាតុ, អវិហឹសាធាតុ, សុខ-*

ធាតុ, ទុក្ខធាតុ, សោមនស្សធាតុ, ទោមនស្សធាតុ, ឧបេក្ខាធាតុ, អវិជ្ជាធាតុ, អារម្ភធាតុ, និក្កមធាតុ, បរក្កមធាតុ គឺជាធម្មធាតុហ្នឹងឯង ។

ហីនធាតុ, មជ្ឈិមធាតុ និង បណីតធាតុ គឺធាតុត្រឹមតែ ១៨ ហ្នឹងឯង ។ តាមពិត ធាតុទាំងឡាយ មានចក្ខុធាតុជាដើម ជាធាតុដ៏ថោកទាប ហៅថា ហីនធាតុ, ភាពនៃធាតុជាមជ្ឈិម និង បណីត ចាត់ជាមជ្ឈិមផង ជាបណីតផង ។ បើមិនពោល តាមបរិយាយ ធម្មធាតុ និង មនោវិញ្ញាណធាតុទាំងឡាយ ជាអកុសល ហៅថា ហីនធាតុ ។ ធាតុទាំងកុសល និង អព្យាកតៈ និង ធាតុទាំងឡាយ មានចក្ខុធាតុ ជាដើម ដែលជាលោកិយៈ ជាមជ្ឈិមធាតុ ។ ចំណែកខាង ធម្មធាតុ និង មនោវិញ្ញាណធាតុទាំងឡាយ ជាលោកុត្តរៈ ចាត់ជាបណីតធាតុ ។

បឋវីធាតុ, តេជោធាតុ និង វាយោធាតុទាំងឡាយ ចាត់ជាផោដ្ឋព្វ-ធាតុ ។ អាបោធាតុ និង អាកាសធាតុចាត់ជាធម្មធាតុ ។ សេចក្ដីបំព្រួញវិញ្ញាណធាតុ ៧ មានចក្ខុវិញ្ញាណធាតុជាដើម ហៅថា វិញ្ញាណធាតុ ។

ធាតុទាំងឡាយ ១៧ ចាត់ជាចំណែកមួយ នៃធម្មធាតុ ចាត់ជាសង្ខតធាតុ ។ ចំណែកធាតុដែលបច្ច័យមិនប្រជុំតាក់តែងទេ ចាត់ជាធម្មធាតុ ដោយចំណែកមួយតែម្យ៉ាង ។

ចំណែកលោក គឺអនេកធាតុ និង នានាធាតុ គ្រាន់តែជាប្រភេទនៃធាតុ ១៨ តែប៉ុណ្ណោះ ដូច្នេះឯង ។ ធាតុទាំងឡាយ ១៨ ហ្នឹងឯង គឺព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រោះភាវៈនៃធាតុទាំងពួងទាំងឡាយ មានតាមសភាព ជាហេតុលាយឡំចម្រុះ ក្នុងធាតុ ១៨ នោះ ដូចដែលបានរៀបរាប់មកនេះឯង ។

ម្យ៉ាងទៀត ធាតុទាំងឡាយ ១៨ ហ្នឹងឯង គឺព្រះដ៏មានព្រះភាគ



ទ្រង់ត្រាស់ហើយ ដើម្បីដកចេញ នូវសញ្ញាពួកបុគ្គលអ្នកសំគាល់ ថា : មានជីវៈ ក្នុងវិញ្ញាណ ដែលមានការដឹងច្បាស់ជាសភាវៈ ។ មែនពិត សត្វទាំងឡាយ មានសេចក្ដីសំគាល់ថា មានជីវិតក្នុងវិញ្ញាណ ដែលមានការដឹងច្បាស់ជាសភាវៈ, ធាតុទាំងឡាយ ១៨ គឺ ព្រះមានព្រះភាគ ទ្រង់មានព្រះបំណង ដើម្បីប្រកាស នូវភាវៈនៃវិញ្ញាណនោះមានច្រើន ដោយការផ្សេងគ្នា នៃចក្ខុវិញ្ញាណធាតុ, សោតវិញ្ញាណធាតុ, ឃានវិញ្ញាណធាតុ, ជិវ្ហាវិញ្ញាណធាតុ, កាយវិញ្ញាណធាតុ, មនោធាតុ និង មនោវិញ្ញាណធាតុផង នូវភាវៈនៃធាតុទាំងឡាយ មិនទៀង ព្រោះកិរិយាប្រព្រឹត្តិទៅ ជាបច្ច័យនៃរូប មានចក្ខុរូបជាដើម ហើយដកចេញនូវសេចក្ដីសំគាល់ថា មានជីវិតដែលដេកនៅហើយ អស់រាត្រីដ៏វែង របស់បុគ្គលទាំងឡាយនោះ ទ្រង់ប្រកាសហើយ ។

ពាក្យតិចតួច គឺខ្ញុំគប្បីពោល នៅមាន តទៅទៀត ។ ធាតុទាំងឡាយ ១៨ ហ្នឹងឯង គឺព្រះមានព្រះភាគ ទ្រង់ប្រកាសហើយ ដោយអំណាចនៃអជ្ឈាស្រ័យនៃសត្វ ដែលព្រះអង្គគប្បីទូន្មានបាន ដោយប្រការដែលបានពោលហើយផង, មួយទៀត សត្វទាំងឡាយណាដែលព្រះអង្គគប្បីទូន្មានបាន ដោយទេសនា ដែលមិនបានវែងពេក មិនបានខ្លីពេកនេះ ដោយអំណាចនៃអជ្ឈាស្រ័យ របស់សត្វទាំងឡាយនោះផង ។

សេចក្ដីថា ភាពងងឹត ក្នុងហឫទ័យរបស់វេនេយ្យសត្វ
ទាំងឡាយ គឺតេជៈនៃព្រះសទ្ធម្ម របស់ព្រះមានព្រះ
ភាគអង្គនោះ កំចាត់បង់ហើយ រមែងដល់នូវសេចក្ដី
ខ្ចាត់ខ្ចាយ ដោយឆាប់រហ័ស ដោយប្រការណាៗ,

ព្រះមានព្រះភាគអង្គនុ៎ះ តែងប្រកាសនូវព្រះធម៌ ដោយសង្ខេបខ្លះ ដោយពិស្តារខ្លះ ដោយប្រការនោះៗ យ៉ាងនេះឯង ។

*សេចក្ដីវិនិច្ឆ័យ ក្នុងធាតុនិទ្ទេស គឺបណ្ឌិត គប្បីជ្រាប ដោយការៈនៃធាតុ មានប្រមាណប៉ុណ្ណោះ យ៉ាងនេះឯង ។*

(ដោយការរាប់)

*(៣១៩) សេចក្ដីវិនិច្ឆ័យ ត្រង់បទថា "សង្ខតោ" បណ្ឌិតគប្បីជ្រាបដូចតទៅនេះ ។ បើពោលតាមជាតិពិត ចក្ខុធាតុ ដល់នូវការរាប់ថា ជាធម៌មួយ គឺជាចក្ខុប្បសាទ ដូច្នេះឯង ។ សោតធាតុ, ឃានធាតុ, ជិវ្ហាធាតុ, កាយធាតុ, រូបធាតុ, សទ្ទធាតុ, គន្ធធាតុ, រសធាតុទាំងឡាយ ក៏យ៉ាងនោះដែរ រមែងដល់នូវការរាប់ថា ជាធម៌មួយ ដោយអំណាចនៃប្រសាទ មានសោតប្បសាទជាដើម ។ ប៉ុន្តែ ផោដ្ឋព្វធាតុ ដល់នូវការរាប់ថា ជាធម៌ ៣ ដោយអំណាចបឋវីធាតុ តេជោធាតុ និង វាយោធាតុ ចក្ខុវិញ្ញាណធាតុ រមែងដល់នូវការរាប់ថា ជាធម៌ ២ ដោយអំណាចនៃកុសលវិបាកវិញ្ញាណ និង អកុសលវិបាកវិញ្ញាណ, សោតវិញ្ញាណធាតុ, ឃានវិញ្ញាណធាតុ, ជិវ្ហាវិញ្ញាណធាតុ, កាយវិញ្ញាណធាតុទាំងឡាយ ក៏ដូចគ្នានឹងដែរ ។ ចំណែកឯ មនោធាតុ ដល់នូវការរាប់បានថា ជាធម៌ ៣ ដោយអំណាចនៃបញ្ចទ្វារាវជ្ជនៈ កុសលាកុសលវិបាក និង សម្បដិច្ឆនៈ ។ ធម្មធាតុ ដល់នូវការរាប់ថា ជាធម៌ ២០ ដោយអំណាចនៃអរូបក្ខន្ធទាំងឡាយ ៣ ផង នៃសុខុមរូបទាំងឡាយ ១៦ ផង នៃធាតុជាអសង្ខតផង ។ មនោវិញ្ញាណធាតុ ដល់នូវការរាប់ថា ជាធម៌ ៧៦*



*ដោយអំណាចនៃកុសលវិញ្ញាណ អកុសលវិញ្ញាណ និង អព្យាកតវិញ្ញាណ ដ៏សេស ដូច្នេះឯង ។*

*សេចក្ដីវិនិច្ឆ័យ ដោយការរាប់ ក្នុងធាតុនិទ្ទេសនេះ គឺបណ្ឌិតគប្បីជ្រាប យ៉ាងនេះឯង ។*

(ដោយបច្ច័យ)

*(៣២០) សេចក្ដីវិនិច្ឆ័យ ត្រង់បទមាតិកានេះថា "បច្ចយា" គឺបណ្ឌិត គប្បីជ្រាបដូចតទៅ ។ ដំបូង ចក្ខុធាតុ ជាបច្ច័យ ដោយបច្ច័យទាំង ៦ ដោយអំណាចវិប្បយុត្តបច្ច័យ, បុរេជាតប្បច្ច័យ, អត្ថិប្បច្ច័យ, អវិគតប្បច្ច័យ និស្សយប្បច្ច័យ និង ឥន្ទ្រិយប្បច្ច័យទាំងឡាយ នៃចក្ខុវិញ្ញាណធាតុប៉ុណ្ណោះ ។ រូបធាតុ ជាបច្ច័យដោយបច្ច័យទាំងឡាយ ៤ ដោយអំណាចនៃបុរេជាតប្បច្ច័យ, អត្ថិប្បច្ច័យ, អវិគតប្បច្ច័យ និង អារម្មណប្បច្ច័យ ។ ធាតុទាំងឡាយ មានសោតធាតុ និង សទ្ទធាតុជាដើម ជាបច្ច័យនៃធាតុ មានសោតវិញ្ញាណធាតុជាដើម យ៉ាងនេះ ។ ចំណែកខាង អាវជ្ជនមនោធាតុ ជាបច្ច័យ ដោយបច្ច័យទាំងឡាយ ៥ ដោយអំណាចនៃសមនន្តរប្បច្ច័យ, អនន្តរប្បច្ច័យ, នត្ថិប្បច្ច័យ, វិគតប្បច្ច័យ, និង អនន្តរូបនិស្សយប្បច្ច័យ នៃវិញ្ញាណធាតុ ទាំង ៥ នោះ ។ ចំណែកខាង វិញ្ញាណធាតុទាំងឡាយ ៥ នោះ ជាបច្ច័យនៃសម្បដិច្ឆនមនោធាតុ ទាំង ៥ ។ សម្បដិច្ឆនមនោធាតុ ក៏ជាបច្ច័យនៃសន្តីរណមនោវិញ្ញាណធាតុ ដូចគ្នា ។ ចំណែកខាង សន្តីរណមនោវិញ្ញាណធាតុនោះ ក៏ជាបច្ច័យនៃវោដ្ឋវនមនោវិញ្ញាណធាតុ, ចំណែកខាងវោដ្ឋវនមនោវិញ្ញាណធាតុ ក៏ជាបច្ច័យនៃជវនមនោវិញ្ញាណធាតុ, ឯជវនមនោវិញ្ញាណធាតុ ជាបច្ច័យដោយបច្ច័យទាំងឡាយ ៦ គឺបច្ច័យ*

ទាំងឡាយ ៥ នោះផង និង អាសេវនប្បច្ច័យផង នៃជវនមនោវិញ្ញាណធាតុ ជាលំដាប់ៗ ទៅ ។ នេះ ជាន័យ ក្នុងបញ្ចទ្វារ មុនសិន ។ ឯក្នុងមនោទ្វារ ភវង្គមនោវិញ្ញាណធាតុ ជាបច្ច័យនៃអាវជ្ជនមនោវិញ្ញាណធាតុ និង អាវជ្ជនមនោវិញ្ញាណធាតុ ក៏ជាបច្ច័យ នៃជវនមនោវិញ្ញាណធាតុ ដោយបច្ច័យទាំងឡាយ ៥ ខាងដើមហ្នឹងឯង ។ ឯធម្មធាតុ ជាបច្ច័យ ដោយចំណែកច្រើន ដោយបច្ច័យទាំងឡាយ មានសហជាតប្បច្ច័យ, អញ្ញមញ្ញប្បច្ច័យ, និស្សយប្បច្ច័យ, សម្បយុត្តប្បច្ច័យ, អត្ថិប្បច្ច័យ និង អវិគតប្បច្ច័យ ជាដើម នៃវិញ្ញាណធាតុទាំង ៧ ។ ឯធាតុទាំងឡាយ មានចក្ខុធាតុ ជាដើម និង ធម្មធាតុពួកខ្លះ ជាបច្ច័យ ដោយបច្ច័យទាំងឡាយ មានអារម្មណប្បច្ច័យ ជាដើម នៃមនោវិញ្ញាណធាតុពួកខ្លះ ។ បច្ច័យទាំងឡាយ មានចក្ខុ និង រូបជាដើម មិនត្រឹមតែជាបច្ច័យ នៃធាតុទាំងឡាយ មានចក្ខុវិញ្ញាណធាតុ ជាដើម ប៉ុណ្ណោះទេ ថែមទាំងធម៌ទាំងឡាយ មានអាលោកជាដើម (ជាបច្ច័យដល់គ្នានឹងគ្នាផងដែរ) ។ ព្រោះហេតុនោះ ទើបបុព្វាចារ្យទាំងឡាយពោលថា ចក្ខុវិញ្ញាណ រមែងកើតឡើង ព្រោះអាស្រ័យនូវចក្ខុ, រូប, អាលោកៈ និង មនសិការៈ ។ សោតវិញ្ញាណ រមែងកើតឡើង ព្រោះអាស្រ័យសោតៈ, សទ្ទៈ, ចន្លោះ និង មនសិការៈទាំងឡាយ ។ ឃានវិញ្ញាណ រមែងកើតឡើង ព្រោះអាស្រ័យឃានៈ, ក្លិន, ខ្យល់ និង មនសិការៈ ។ ជិវ្ហាវិញ្ញាណ រមែងកើតឡើង ព្រោះអាស្រ័យជិវ្ហា, រស, ទឹក និង មនសិការៈ ។ កាយ–វិញ្ញាណ រមែងកើតឡើង ព្រោះអាស្រ័យកាយ, ផោដ្ឋព្វៈ, បឋវី និង មនសិការៈ ។ មនោវិញ្ញាណ រមែងកើតឡើង ព្រោះអាស្រ័យភវង្គមនៈ, ធម៌ និង មនសិការៈ ដូច្នេះឯង ។



នេះ ជាសេចក្តីបំព្រួញ ក្នុងបទថា បច្ច័យនេះ ។

ចំណែកប្រភេទនៃបច្ច័យ ដោយសេចក្តីពិស្តារ នឹងមានមកប្រាកដក្នុងបដិច្ចសមុប្បាទនិទ្ទេស ឯណោះ ។

សេចក្តីវិនិច្ឆ័យ សូម្បីដោយបច្ច័យ ក្នុងធាតុនិទ្ទេសនេះ គឺបណ្ឌិតគប្បីជ្រាប ដូចបានពោលមកនេះឯង ។

**(ដោយរបស់ដែលគប្បីឃើញ)**

(៣២១) តង់បទថា “ទដ្ឋព្វ” សេចក្តីថា : មួយទៀត សេចក្តីវិនិច្ឆ័យ ក្នុងធាតុនិទ្ទេសនេះ គឺបណ្ឌិត គប្បីជ្រាប តាមហេតុដែលបុគ្គលគប្បីឃើញ ។ ពិតមែនដូច្នោះហើយ ធាតុ គឺបច្ច័យប្រជុំតាក់តែងទាំងឡាយទាំងពួងនោះឯង គឺបណ្ឌិត គប្បីឃើញ ដោយភាវៈជារបស់ទទេទាំងទីបំផុតខាងដើម ទាំងទីបំផុតខាងចុង ដោយសូន្យចាកភាពទៀងទាត់ សេចក្តីល្អ សេចក្តីសុខ និង ភាវៈ ថា ខ្លួន និង ដោយការប្រព្រឹត្តិទៅតាមបច្ច័យ មិនដាច់ ។

បើពោលដោយវិសេស បណ្តាធាតុទាំងនេះ ចក្ខុធាតុ បណ្ឌិតគប្បីឃើញដូចជាផ្ទៃនៃស្គរ, រូបធាតុ គឺបណ្ឌិត គប្បីឃើញដូចជាអន្ទូង, ចក្ខុវិញ្ញាណ គឺបណ្ឌិត គប្បីឃើញដូចជាសម្លេង ។ ន័យដូចគ្នានោះដែរ ចក្ខុធាតុ ដូចជាផ្ទៃនៃកញ្ចក់, រូបធាតុ ដូចជាមុខ, ចក្ខុវិញ្ញាណធាតុ គឺបណ្ឌិត គប្បីឃើញដូចជាស្រមោលនៃមុខ ។ មួយវិញទៀត ចក្ខុធាតុ ដូចជាអំពៅ និង គ្រាប់ល្ង, រូបធាតុ ដូចជាឃ្នាបគៀបអំពៅ និង ត្បាល់បុកល្ង, ចក្ខុវិញ្ញាណ ដូចជារស នៃអំពៅ និង ប្រេងល្ងទាំងឡាយ ។ ន័យដូចគ្នានោះដែរ ចក្ខុធាតុ បណ្ឌិត គប្បិឃើញថា ដូចជាឈើពំនួតភ្លើង ខាងក្រោម, រូបធាតុ ដូចជាឈើពំនួតភ្លើង ខាងលើ,

ចក្ខុវិញ្ញាណធាតុ គប្បីឃើញថា ដូចជាភ្លើង ។

ន័យ ក្នុងធាតុទាំងឡាយមានសោតធាតុជាដើម ដូចន័យនេះដែរ ។ ឯមនោធាតុ គឺបណ្ឌិតគប្បីឃើញដូចជាការត្រាច់ទៅមុន និង ការត្រាច់ទៅក្រោយ នៃធាតុទាំងឡាយ មានចក្ខុវិញ្ញាណធាតុជាដើម តាមគួរដល់ការកើតព្រម ។ វេទនាខន្ធ ក្នុងធម្មធាតុ គឺបណ្ឌិត គប្បីឃើញដូចជាសរ និង លំពែង ។ សញ្ញាខន្ធ និង សង្ខារក្ខន្ធទាំងឡាយ ដូចជាមនុស្សដែលក្តៅក្រហាយ ព្រោះការបាញ់ត្រូវ ដោយសរ និង លំពែង គឺវេទនា, ម្យ៉ាងទៀត សញ្ញា របស់បុថុជ្ជនទាំងឡាយ ដូចជាក្តាប់ដៃទទេ ព្រោះញ៉ាំងទុក្ខ ដោយសេចក្តីសង្ឃឹម ឲ្យកើតឡើង ដូចជាសត្វម្រឹគព្រៃ ព្រោះធ្វើឲ្យប្រកាន់យកនូវនិមិត្ត ដោយភាពមិនទៀងទាត់ ។ សង្ខារ ដូចជាបុរសបោលក្នុងរណ្តៅភ្លើង ព្រោះការបោះបោល ក្នុងបដិសន្ធិ ដូចជាចោរ ដែលរាជបុរសដេញតាមចាប់ ព្រោះជាតិទុក្ខ ជាប់តាម, ដូចជាពូជនៃឈើជាពិស ព្រោះហេតុនៃខន្ធសន្តាន ជាទីនាំមកនូវសេចក្តីវិនាសសព្វយ៉ាង ។ រូប គឺបុគ្គលគប្បីឃើញដូចជាចក្រដ៏មុត ព្រោះស្រមោលនៃឧបទ្រព មានប្រការផ្សេងៗ ។ ក៏ធាតុ ដែលសង្ខារមិនបានតាក់តែងហើយ គឺបណ្ឌិត គប្បីឃើញ ដោយថា អមតៈផង, ដោយថា ស្ងប់ផង, ដោយថា ក្សេមក្សាន្តផង ។ សួរថាៈ ព្រោះហេតុអ្វី? ។ ឆ្លើយថា : ព្រោះភាវៈនៃធាតុនោះ ជាទំទាស់ ដល់សេចក្តីវិនាសទាំងពួង ។ មនោ-វិញ្ញាណធាតុ គឺបុគ្គល គប្បីឃើញ ដូចជាសត្វស្វា ក្នុងព្រៃ ព្រោះមិនមាននៃការកំណត់ ក្នុងអារម្មណ៍ទាំងឡាយ, ដូចជាសេះ មានជើងខូក ព្រោះការបង្ហាត់បានដោយក្រ, ដូចដំបងដែលគេគ្រវែងទៅលើវេហាស៍ ព្រោះវាធ្លាក់ទៅ តាមចំណង់របស់វា, ដូចជាអ្នករបាំក្នុងរង្គសាល ព្រោះ



ការប្រកបដោយភេទ គឺកិលេស មានប្រការផ្សេងៗ មានលោភៈ និង ទោសៈ ជាដើម ដូច្នេះឯង ។

បរិច្ឆេទ ទី១៥ ឈ្មោះអាយតនធាតុនិទ្ទេស
ក្នុងបញ្ញាភាវនា ក្នុងវិសុទ្ធិមគ្គ
ដែលលោកធ្វើហើយ ដើម្បីប្រយោជន៍
ដល់ការញ៉ាំងសាធុជនឲ្យរីករាយ យ៉ាងនេះឯង ។

## ឥន្ទ្រិយសច្ចនិទ្ទេស

(៣២២) ក៏ឥន្ទ្រិយទាំងឡាយ ២២ ដែលព្រះអង្គ ទ្រង់បានសំដែងហើយ ក្នុងលំដាប់នៃធាតុទាំងឡាយ គឺ: ចក្ខុន្ទ្រិយ ១, សោតិន្ទ្រិយ ១, ឃានិន្ទ្រិយ ១, ជិវ្ហិន្ទ្រិយ ១, កាយិន្ទ្រិយ ១, មនិន្ទ្រិយ ១, ឥត្ថិន្ទ្រិយ ១, បុរិសិន្ទ្រិយ ១, ជីវិតិន្ទ្រិយ ១, សុខិន្ទ្រិយ ១, ទុក្ខិន្ទ្រិយ ១, សោមនស្សិន្ទ្រិយ ១, ទោមនស្សិន្ទ្រិយ ១, ឧបេក្ខិន្ទ្រិយ ១, សទ្ធិន្ទ្រិយ១, វីរិយិន្ទ្រិយ ១, សតិន្ទ្រិយ ១, សមាធិន្ទ្រិយ ១, បញ្ញិន្ទ្រិយ ១, អនញ្ញតញ្ញស្សាមីតិន្ទ្រិយ ១, អញ្ញិន្ទ្រិយ ១, អញ្ញាតាវិន្ទ្រិយ ១ ឈ្មោះថាឥន្ទ្រិយ ។

> បណ្ឌិតទាំងឡាយ គប្បីដឹងនូវសេចក្តីវិនិច្ឆ័យ ក្នុងឥន្ទ្រិយទាំងឡាយនោះ ដោយអត្ថផង ដោយប្រភេទទាំងឡាយមានលក្ខណៈជាដើមផង ដោយលំដាប់ផង ឬក៏ ដោយការញែក និង មិនញែកផង ដោយកិច្ចផង ដោយភូមិផង ។

(ដោយអត្ថ)

អធិប្បាយ នូវឥន្ទ្រិយទាំងឡាយ មានចក្ខុជាដើម គឺព្រះមានព្រះភាគ ទ្រង់ប្រកាសហើយ ជាដំបូង ដោយន័យ មានន័យជាអាទិ៍ ថា : ធម្មជាតិណា ឃើញ ហេតុនោះ ធម្មជាតិនោះ ឈ្មោះថា ចក្ខុ ដូច្នេះ ជាដើម ក្នុងឥន្ទ្រិយទាំងឡាយនោះ ។

ក៏បណ្តាឥន្ទ្រិយទាំងឡាយ ៣ មាន ពួកខាងក្រោយ ឥន្ទ្រិយ ទី១ គឺព្រះមានព្រះភាគទ្រង់ត្រាស់ហើយថា អនញ្ញតញ្ញស្សាមីតិន្ទ្រិយ ព្រោះការកើតឡើង ដល់បុគ្គលដែលប្រតិបត្តិហើយ យ៉ាងនេះថា: អាត្មាអញ



នឹងដឹងនូវបទនៃធម៌ ឈ្មោះអមតៈផង នូវធម៌ គឺសច្ចៈ ៤ ផង ដែលខ្លួនមិនទាន់ដឹងហើយ ក្នុងភាគខាងដើម” ដូច្នេះ និងព្រោះមានអត្ថនៃឥន្ទ្រិយកើតព្រមផង ។ ឥន្ទ្រិយ ទី២ ឈ្មោះថា អញ្ញិន្ទ្រិយ ព្រោះការដឹងផង ព្រោះការកើតព្រម ដោយអត្ថថា ឥន្ទ្រិយ ផង, ឥន្ទ្រិយ ទី៣ ឈ្មោះថា អញ្ញាតាវិន្ទ្រិយ ព្រោះការកើតឡើង ដល់ព្រះខីណាស្រព អ្នកដឹងទូទៅ គឺមានកិច្ច ដោយញាណ សំរេចហើយ ក្នុងសច្ចៈ ទាំង ៤ និង ព្រោះការកើតព្រម ដោយអត្ថ គឺឥន្ទ្រិយ ។

សួរថា: ចុះអ្វីទៅ ឈ្មោះថា ជាអត្ថ នៃភាវៈជាឥន្ទ្រិយ នៃឥន្ទ្រិយទាំងឡាយនោះ? ។ ឆ្លើយថា: អត្ថ នៃគ្រឿងសំគាល់របស់ដែលជាធំ ឈ្មោះថា អត្ថ នៃភាពជាឥន្ទ្រិយ, អត្ថ នៃរបស់ដែលព្រះមានព្រះភាគ ទ្រង់សំដែងហើយ ដោយភាវៈជាធំ ឈ្មោះថា អត្ថ នៃភាពជាឥន្ទ្រិយ, អត្ថ នៃរបស់ដែលព្រះមានព្រះភាគ ទ្រង់ឃើញហើយ ដោយភាវៈជាធំ ឈ្មោះថា អត្ថនៃភាពជាឥន្ទ្រិយ, អត្ថ នៃរបស់ដែលជាធំចាត់ចែងហើយ ឈ្មោះថា អត្ថ នៃភាពជាឥន្ទ្រិយ, អត្ថ នៃរបស់ដែលព្រះមានព្រះភាគសេព ដោយភាវៈជាធំ ឈ្មោះថា អត្ថ នៃភាពជាឥន្ទ្រិយ ។ អត្ថទាំងអស់ហ្នឹងឯង គួរប្រើបានតាមដែលគួរប្រើ ក្នុងឥន្ទ្រិយនិទ្ទេសនេះ ។

ពិតមែន ព្រះមានព្រះភាគ ទ្រង់ត្រាស់ដឹង ដោយប្រពៃចំពោះព្រះអង្គឯង ឈ្មោះថា ជាធំ ព្រោះភាវៈដ៏ប្រសើរក្រៃលែង ។ ចំណែកខាងអំពើជាកុសល និង អកុសល ឈ្មោះថា ជាធំ ព្រោះការមិនមានអ្នកណាមួយជាធំ ក្នុងកម្មទាំងឡាយ ។ ព្រោះហេតុនោះ បណ្តាឥន្ទ្រិយទាំងឡាយនោះ ឥន្ទ្រិយទាំងឡាយ ដែលកម្មឲ្យកើតហើយមុន រមែងចាត់ចែង នូវកម្មជាកុសល និង អកុសល, មួយទៀត ឥន្ទ្រិយទាំង

ឡាយនោះ គឺកម្មនោះ ចាត់ចែង (ឲ្យកើត) ហើយ ព្រោះហេតុនោះ ឥន្ទ្រិយទាំងឡាយនោះ ទើបឈ្មោះថា ជាធំ ដោយអត្ថថា ធ្វើបញ្ចាំង នូវភេទជាធំផង ដោយអត្ថថា ជាអ្នកចាត់ចែង ដោយភាវៈជាធំផង ។ ក៏ឥន្ទ្រិយទាំងឡាយទាំងអស់ហ្នឹងឯង គឺព្រះមានព្រះភាគ ទ្រង់ប្រកាសហើយផង ទ្រង់ត្រាស់ដឹងចំពោះហើយ តាមសេចក្តីពិតផង ព្រោះហេតុនោះ ឥន្ទ្រិយទាំងឡាយនោះ ទើបឈ្មោះថា ជាធំ ដោយអត្ថថា គឺព្រះមានព្រះភាគទ្រង់សំដែងហើយ ដោយភាវៈជាធំផង ដោយអត្ថថា គឺព្រះមានព្រះភាគ ទ្រង់ឃើញហើយ ដោយភាវៈជាធំផង ។ ក៏ឥន្ទ្រិយទាំងឡាយពួកខ្លះ គឺព្រះមានព្រះភាគជាធំជាងអ្នកប្រាជ្ញនោះឯង ទ្រង់សេពហើយ ដោយការសេពជាអារម្មណ៍, ឥន្ទ្រិយទាំងឡាយពួកខ្លះ គឺព្រះមានព្រះភាគ ទ្រង់សេពហើយ ដោយការសេព តាមភាវនា ព្រោះហេតុនោះ ទើបឈ្មោះថា ឥន្ទ្រិយ ដោយអត្ថថា គឺព្រះដ៏មានព្រះភាគ សេពហើយ ដោយភាវៈជាធំ ។

ម្យ៉ាងវិញទៀត ចក្ខុទាំងឡាយជាដើមនេះ ឈ្មោះថា ឥន្ទ្រិយ ដោយអត្ថថា ជាធំ សំដៅយកភាពជាធំ ។ មែនពិត ភាវៈជាអធិបតីនៃឥន្ទ្រិយទាំងឡាយ មានចក្ខុន្ទ្រិយជាដើម ឈ្មោះថា សំរេចផល ក្នុងការប្រព្រឹត្តិទៅនៃវិញ្ញាណ មានចក្ខុវិញ្ញាណជាដើម ព្រោះកាលបើភាវៈនៃឥន្ទ្រិយនោះក្លៀវក្លា វិញ្ញាណនោះ ក៏ក្លៀវក្លាដែរ កាលបើឥន្ទ្រិយនោះទន់ខ្សោយ វិញ្ញាណ ក៏ទន់ខ្សោយដែរ ដូច្នេះឯង ។

នេះ ជាសេចក្តីវិនិច្ឆ័យ ដោយអត្ថ ត្រង់ឥន្ទ្រិយនិទ្ទេសនេះ ។

(ដោយលក្ខណៈជាដើម)

(៣២៣) បទថា "លក្ខណាទីហិ" អធិប្បាយថា បណ្ឌិតគប្បីជ្រាប



នូវការវិនិច្ឆ័យ នៃវិញ្ញាណទាំងឡាយ មានចក្ខុវិញ្ញាណជាដើម ដោយលក្ខណៈ, កិច្ច, ផល និង ហេតុទាំងឡាយហ្នឹងឯង ។ ក៏ប្រភេទទាំងឡាយមានលក្ខណៈជាដើមនោះ នៃចក្ខុទាំងឡាយជាដើមនោះឯង គឺព្រះមានព្រះភាគទ្រង់ត្រាស់រួចហើយ ក្នុងខន្ធនិទ្ទេស ។ ចំណែកឯ ឥន្ទ្រិយទាំងឡាយ ៤ មាន បញ្ញិន្ទ្រិយជាដើម តាមសេចក្តី គឺអមោហៈនុ៎ះឯង ។ ឥន្ទ្រិយទាំងឡាយ ដ៏សេស មកហើយ ដោយសរុប ក្នុងខន្ធនិទ្ទេសនោះ ដូច្នេះឯង ។

(ដោយលំដាប់)

សូម្បីលំដាប់ ក្នុងបទថា "ដោយលំដាប់" នេះ ក៏ជាលំដាប់នៃទេសនានោះឯង ។ បណ្តាឥន្ទ្រិយទាំងឡាយនោះ ការបានចំពោះនូវអរិយភូមិ រមែងមាន ដោយការកំណត់ដឹងនូវធម៌ខាងក្នុង ព្រោះហេតុនោះ ឥន្ទ្រិយទាំងឡាយ មានចក្ខុន្ទ្រិយជាដើម ដែលលោករាប់បញ្ចូលហើយ ក្នុងអត្តភាព គឺព្រះមានព្រះភាគ ទ្រង់ត្រាស់សំដែងមុនហើយ ។ ក៏អត្តភាពនោះ រមែងដល់នូវការរាប់ថា ស្ត្រីក្តី បុរសក្តី ព្រោះអាស្រ័យនូវធម៌ណា ដើម្បីទ្រង់បង្ហាញថា នោះ គឺធម៌នេះ ទើបទ្រង់សំដែងឥត្ថិន្ទ្រិយក្តី បុរិសិន្ទ្រិយក្តី អំពីឥន្ទ្រិយនោះ ទ្រង់សំដែងជីវិតិន្ទ្រិយ អំពីឥន្ទ្រិយនោះ ដើម្បីឲ្យបានដឹងថា "សូម្បីធម៌ទាំង ២ យ៉ាងនោះ ក៏មានការប្រព្រឹត្តិទៅ ដើម្បីជាប់ទាក់ទង ដោយជីវិតិន្ទ្រិយ" បន្ទាប់អំពីនោះ ទ្រង់សំដែងឥន្ទ្រិយទាំងឡាយ មានសុខិន្ទ្រិយជាដើម ដើម្បីឲ្យដឹងថា ការប្រព្រឹត្តិទៅនៃជីវិតិន្ទ្រិយនោះ នៅមាន ដរាបណា, ការមិនត្រឡប់នៃការសោយអារម្មណ៍ទាំងនោះ ក៏មាននៅ ដរាបនោះដែរ, ការសោយអារម្មណ៍ណានីមួយ មាន, ការសោយអារម្មណ៍ទាំងអស់នោះ ជាទុក្ខ"

ដូច្នេះ, តអំពីនោះ ទ្រង់សំដែងឥន្ទ្រិយទាំងឡាយ មានសទ្ធិន្ទ្រិយជាដើម ដើម្បីសំដែងសេចក្តីប្រតិបត្តិ ថា “ធម៌ទាំងឡាយនុ៎ះ គឺបុគ្គលគប្បីចំរើន ដើម្បីរំលត់នូវការសោយអារម្មណ៍នោះ” ដូច្នេះ បន្ទាប់អំពីនោះ ទ្រង់សំដែងអនញ្ញាតញ្ញស្សាមីតិន្ទ្រិយ ដើម្បីសំដែងនូវភាវៈដែលមិនអត់អំពើនៃការប្រតិបត្តិ ថា “ដោយការប្រតិបត្តិនោះ ធម៌នេះ រមែងកើតប្រាកដក្នុងខ្លួន ជាបឋម” ដូច្នេះ, បន្ទាប់អំពីនោះ ទ្រង់សំដែងអញ្ញិន្ទ្រិយ ព្រោះជាផលនៃអនញ្ញាតញ្ញស្សាមីតិន្ទ្រិយនោះឯងផង និង ព្រោះជាធម៌ដែលគប្បីចំរើន ក្នុងលំដាប់បន្ទាប់អំពីធម៌នោះផង នៅក្នុងទីបំផុត ទ្រង់សំដែងអញ្ញាតាវិន្ទ្រិយ ដែលជាទីជ្រះថ្លា យ៉ាងក្រៃលែង ដើម្បីឲ្យដឹងថា “ការសំរេចធម៌នោះ រមែងមាន ព្រោះភាវនា បន្ទាប់អំពីនោះមក ក៏កាលបើធម៌នេះ គឺព្រះយោគី បានសំរេចហើយ កិច្ចណាមួយ ដែលត្រូវធ្វើ ឲ្យប្រើនជាងនេះ មិនមានឡើយ” ដូច្នេះឯង ។

លំដាប់ត្រង់ឥន្ទ្រិយនិទ្ទេសនេះ ចប់ត្រឹមនេះឯង ។

(ដោយភេទ និង មិនភេទ)

(៣២៤) ក៏ត្រង់បទថា “ភេទាភេទា” នេះ ជីវិតិន្ទ្រិយតែម្យ៉ាង មានការផ្សេងគ្នា ។ ព្រោះឥន្ទ្រិយនោះ មាន ២ យ៉ាង គឺៈ រូបជីវិតិន្ទ្រិយ ១ អរូបជីវិតិន្ទ្រិយ ១ ។ ឥន្ទ្រិយទាំងឡាយដ៏សេស មិនមានសេចក្តីផ្សេងគ្នាឡើយ ។ បណ្ឌិត គប្បីជ្រាបនូវការវិនិច្ឆ័យ ដោយការផ្សេងគ្នា និង មិនផ្សេងគ្នា ក្នុងឥន្ទ្រិយនិទ្ទេសនេះ យ៉ាងនេះ ។

(ដោយកិច្ច)

សេចក្តីវិនិច្ឆ័យ ត្រង់បទថា “ដោយកិច្ច” បណ្ឌិតគប្បីជ្រាប ដូចតទៅ : បើអាចារ្យអ្នកចោទ គប្បីចោទថា កិច្ច របស់ឥន្ទ្រិយទាំងឡាយ



តើដូចម្តេចខ្លះ? ។ អាចារ្យអ្នកឆ្លើយ ដោះស្រាយថាៈ “ព្រោះព្រះបាលីថា ចក្ខាយតនៈ ជាបច្ច័យ ដោយជាឥន្ទ្រិយបច្ច័យ នៃចក្ខុវិញ្ញាណធាតុ និង នៃធម៌ទាំងឡាយ ដែលសម្បយុត្ត ដោយចក្ខុវិញ្ញាណធាតុនោះផង” ដូច្នេះ, ការញ៉ាំងធម៌ទាំងឡាយ មានចក្ខុវិញ្ញាណធាតុជាដើម ឲ្យប្រព្រឹត្តទៅតាមអាការៈរបស់ខ្លួន ដែលពោលថា ជាអាការៈដ៏ក្លៀវក្លា និង ទន់ជាដើម ដែលត្រូវឲ្យបានសំរេច ដោយភាពជាឥន្ទ្រិយបច្ច័យ និង ដោយភាពនៃខ្លួនមានអាការៈក្លៀវក្លា និង ទន់ជាដើមផងនោះឯង, នេះ គឺជាកិច្ចនៃចក្ខុន្ទ្រិយជាដំបូង, កិច្ច នៃសោតិន្ទ្រិយ, ឃានិន្ទ្រិយ, ជិវ្ហិន្ទ្រិយ និង កាយិន្ទ្រិយ ក៏មានន័យយ៉ាងនេះដែរ, តែការញ៉ាំងសហជាតធម៌ទាំងឡាយ ឲ្យប្រព្រឹត្តទៅ ក្នុងអំណាចរបស់ខ្លួន ជាកិច្ច នៃមនិន្ទ្រិយ ។ ការតាមរក្សានូវសហជាតធម៌ ជាកិច្ចនៃជីវិតិន្ទ្រិយផង, វិធីនៃអាការៈគឺភេទ និង និមិត្ត និង ការលេង និង អាកប្បកិរិយា នៃស្ត្រី និង បុរស ជាកិច្ចនៃឥត្ថិន្ទ្រិយ និង បុរិសិន្ទ្រិយទាំងឡាយ, កិរិយាគ្របសង្កត់នូវសហជាតធម៌ទាំងឡាយ ហើយញ៉ាំងសហជាតធម៌ទាំងនោះ ឲ្យដល់នូវអាការៈដ៏គ្រោតគ្រាត តាមនាទីរបស់ខ្លួន ជាកិច្ច នៃសុខិន្ទ្រិយ និង ទុក្ខិន្ទ្រិយ សោមនស្សិន្ទ្រិយ និង ទោមនស្សិន្ទ្រិយទាំងឡាយ, ការញ៉ាំងសហជាតធម៌ទាំងឡាយ ឲ្យដល់អាការៈ ជាកណ្តាលៗ ដែលជាអាការៈស្ងប់ ថ្លៃថ្លា ជាកិច្ច នៃឧបេក្ខិន្ទ្រិយ, ការគ្របសង្កត់នូវធម៌ដែលជាសឹកសត្រូវ និង ការញ៉ាំងសម្បយុត្តធម៌ទាំងឡាយ ឲ្យដល់នូវភាវៈនៃចំណែកមានអាការៈជាទីជ្រះថ្លាជាដើម ជាកិច្ច នៃឥន្ទ្រិយទាំងឡាយ មានសទ្ធិន្ទ្រិយជាដើម, ការលះបង់ នូវសំយោជនៈ ៣ និង ការធ្វើនូវសម្បយុត្តធម៌ទាំងឡាយ ឲ្យមានភាវៈនៃមុខឆ្ពោះទៅ ក្នុងការលះបង់នូវ

*សំយោជនៈ ៣ នោះផង ជាកិច្ច នៃអនញ្ញាតញ្ញស្សាមីតិន្ទ្រិយ, ការលះដោយការធ្វើសំយោជនៈទាំងឡាយ មានកាមរាគៈ និង ព្យាបាទជាដើម ឲ្យស្រាលស្តើង និង ការញ៉ាំងសហជាតធម៌ទាំងឡាយ ឲ្យប្រព្រឹត្តទៅក្នុងអំណាចរបស់ខ្លួនផង ជាកិច្ច នៃអញ្ញិន្ទ្រិយ, ការលះបង់នូវសេចក្តីខ្វល់ខ្វាយ ក្នុងកិច្ចទាំងពួងទាំងឡាយ និង ភាវៈជាបច្ច័យឲ្យសម្បយុត្តធម៌ទាំងឡាយ មានមុខឆ្ពោះទៅកាន់អមតធម៌ផង ជាកិច្ច នៃអញ្ញាតាវិន្ទ្រិយ ដូច្នេះឯង ។*

*បណ្ឌិត គប្បីជ្រាបសេចក្តីវិនិច្ឆ័យ ដោយកិច្ច ក្នុងឥន្ទ្រិយនិទ្ទេសនេះ ដោយប្រការយ៉ាងនេះឯង ។*

### (ដោយភូមិ)

*(៣២៥) សេចក្តីវិនិច្ឆ័យ ត្រង់បទថា* “ដោយភូមិ” *គឺបណ្ឌិតគប្បីជ្រាបដូចតទៅនេះ ។*

*ក៏បណ្តាឥន្ទ្រិយទាំងឡាយ ចក្ខុន្ទ្រិយ, សោតិន្ទ្រិយ, ឃានិន្ទ្រិយ, ជិវ្ហិន្ទ្រិយ, កាយិន្ទ្រិយ, ឥត្ថិន្ទ្រិយ, បុរិសិន្ទ្រិយ, សុខិន្ទ្រិយ, ទុក្ខិន្ទ្រិយ, និងទោមនស្សិន្ទ្រិយ ជាកាមាវចរ ដោយពិត, មនិន្ទ្រិយ, ជីវិតិន្ទ្រិយ និង ឧបេក្ខិន្ទ្រិយទាំងឡាយក្តី, សទ្ធិន្ទ្រិយ, វីរិយិន្ទ្រិយ, សតិន្ទ្រិយ, សមាធិន្ទ្រិយ, និង បញ្ញិន្ទ្រិយទាំងឡាយក្តី លោករាប់បញ្ចូលហើយក្នុងភូមិ ៤, សោមនស្សិន្ទ្រិយ រាប់បញ្ចូលហើយ ក្នុងប្រមាណនៃភូមិ ៣ ដោយអំណាចនៃកាមាវចរ, រូបាវចរ និង លោកុត្តរៈ, ឥន្ទ្រិយទាំងឡាយ ៣ ក្នុងទីបំផុត ជាលោកុត្តរៈ ។*

*បណ្ឌិត គប្បីជ្រាបវិនិច្ឆ័យ ដោយភូមិ ក្នុងឥន្ទ្រិយទាំងឡាយនេះ ដូចបានរៀបរាប់មកហើយនេះឯង ។*



ព្រោះថា ភិក្ខុ កាលដឹងច្បាស់ យ៉ាងនេះ ជាអ្នក
ច្រើន ដោយសេចក្តីតក់ស្លុត ស្ថិតនៅហើយ ក្នុង
ការសង្រួមនូវឥន្ទ្រិយ ដឹងច្បាស់ហើយនូវឥន្ទ្រិយ
ទាំងឡាយ និង ធ្វើនូវទីបំផុតនៃសេចក្តីទុក្ខ ។

*នេះ ជាប្រធាននៃសេចក្តីពណ៌នា ដោយសេចក្តីពិស្តារ*
*នៃឥន្ទ្រិយទាំងឡាយ ។*

(សច្ចនិទ្ទេស)

(៣២៦) ក៏អរិយសច្ចៈទាំងឡាយ ៤ បន្ទាប់អំពីឥន្ទ្រិយនោះ គឺ ទុក្ខអរិយសច្ច ១, ទុក្ខសមុទយអរិយសច្ច ១, ទុក្ខនិរោធអរិយសច្ច ១, ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ១, ឈ្មោះថា សច្ច ។

សេចក្ដីវិនិច្ឆ័យ ក្នុងអរិយសច្ច ជាលំដាប់ នៃសាសនានោះ អ្នកមានប្រាជ្ញា គប្បីជ្រាប ដោយកិរិយាចែកផង, ដោយប្រភេទ មានការវែកញែក និង លក្ខណៈជាដើមផង, ដោយអត្ថ និង កិរិយាបើឡើងនូវអត្ថផង, ដោយមិនបានខ្វះ និង មិនបានលើសផង, ដោយលំដាប់ផង, ដោយវិនិច្ឆ័យនូវទុក្ខទាំងឡាយ មានជាតិទុក្ខជាដើមផង, ដោយកិច្ចគឺញាណផង, ដោយប្រភេទនៃធម៌ទាំងឡាយដែលលាយចូលគ្នា ពួដ៏ខាងក្នុងផង, ដោយសេចក្ដីប្រៀបធៀបផង, ដោយប្រមាណ៤ ផង, ដោយសោះសូន្យផង, ដោយចំណែកនៃសច្ចៈទាំងឡាយ មានចំណែក១ ជាដើមផង, ដោយត្រូវគ្នា និង មិនត្រូវគ្នាផង ។

(ដោយការចែក)

បណ្ដាបទមាតិកាទាំងឡាយនោះ ត្រង់បទមាតិកា ថា "វិភគតោ" មានសេចក្ដីថា: អត្ថទាំងឡាយឯណា គឺព្រះយោគាវចរទាំងឡាយ កាលកំណត់ដឹង នូវសច្ចៈទាំងឡាយ មានទុក្ខសច្ចជាដើម គប្បីកំណត់ដឹង, អត្ថទាំងឡាយនោះ នៃសច្ចទាំងឡាយ មានទុក្ខសច្ចជាដើម គឺព្រះមានព្រះភាគ ទ្រង់បែងចែកហើយ ជា ៤ ៗ ជារបស់ពិត មិនប្រែប្រួល



មិនមែនជារបស់ដទៃ ។ សមដូចជាព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយថា: អត្ថ នៃទុក្ខសច្ចៈ គឺការបៀតបៀន, អត្ថថា តាក់តែង, អត្ថថា ញុំាំងសត្វឲ្យក្ដៅ, អត្ថថា ប្រែប្រួល, អត្ថ ទាំង ៤ យ៉ាងនេះ ជាអត្ថ គឺទុក្ខ នៃទុក្ខសច្ចៈ ជារបស់ពិត មិនប្រែប្រួល មិនមែនជារបស់ដទៃ,

អត្ថ នៃសមុទយៈ គឺជាគ្រឿងប្រមូលមក អត្ថថា ជាគ្រឿងប្រគល់ឲ្យ អត្ថថា ជាគ្រឿងប្រកបព្រម អត្ថថា ជាគ្រឿងកង្វល់, អត្ថទាំង ៤ យ៉ាងនេះ ជាអត្ថ គឺសមុទយៈ នៃសមុទយសច្ចៈ ជារបស់ពិត មិនប្រែប្រួល មិនមែនជារបស់ដទៃ,

អត្ថ នៃនិរោធសច្ចៈ គឺការរលាស់ចេញ អត្ថគឺការស្ងប់ស្ងាត់, អត្ថគឺមិនមានបច្ច័យតាក់តែង, អត្ថ គឺមិនចេះស្លាប់, អត្ថ ទាំង ៤ យ៉ាងនេះ ជាអត្ថ គឺនិរោធ នៃនិរោធសច្ចៈ ជារបស់ពិត មិនប្រែប្រួល មិនមែនជារបស់ដទៃ,

អត្ថ នៃមគ្គ គឺការនាំចេញ, ហេតុ, ការឃើញ, ភាពជាធំ, អត្ថទាំង ៤ យ៉ាងនេះ ជាអត្ថ គឺមគ្គ នៃមគ្គសច្ចៈ ជារបស់ពិត មិនប្រែប្រួល មិនមែនជារបស់ដទៃ ។

បាលីមានជាដើម យ៉ាងនេះថា: អត្ថថា បៀតបៀន, អត្ថថា តាក់តែង, អត្ថថា ញុំាំងសត្វឲ្យក្ដៅ, អត្ថថា ប្រែប្រួល អត្ថថា ត្រាស់ដឹង នៃទុក្ខសច្ចៈ ក៏ដូចគ្នានោះដែរ ។

អរិយសច្ចទាំងឡាយ មានទុក្ខសច្ចជាដើម បណ្ឌិតគប្បីជ្រាប ដោយអំណាចអត្ថទាំងឡាយ ៤ ៗ ដែលព្រះមានព្រះភាគទ្រង់បែងចែកហើយ យ៉ាងនេះ ដោយប្រការដូច្នេះឯង ។ សេចក្ដីវិនិច្ឆ័យ ដោយការបែងចែក ក្នុងឥន្ទ្រិយសច្ចនិទ្ទេស ចប់តែប៉ុណ្ណោះឯង ។

(ដោយអត្ថវិគ្គហៈ)

(៣២៧) ក៏ក្នុងបទមាតិកានេះថា “និព្វចនលក្ខណាទិប្បភេទតោ” មានសេចក្ដីវិនិច្ឆ័យ ដូចតទៅ ។ ក្នុងបទថា “ទុក្ខំ” នេះ គឺបណ្ឌិត គប្បីជ្រាប ដោយអត្ថវិគ្គហៈ មុនថា ស័ព្ទនេះថា “ទុ” ប្រាកដ ក្នុងសេចក្ដីថា គឺបណ្ឌិតគួរខ្ពើម ។ ដូចជាអាចារ្យទាំងឡាយពួកខ្លះ ហៅនូវកូនដែលបណ្ឌិតគួរខ្ពើមថា កូនអាក្រក់ ។ ចំណែកស័ព្ទថា “ខំ” ចុះ ក្នុងអត្ថថា ទទេ ។ តួយ៉ាង ទីទទេ គឺអាកាស គឺលោកហៅថា ខំ ។ ក៏សច្ចៈ ទី១ នេះ ឈ្មោះថា គឺបណ្ឌិតគួរខ្ពើម ព្រោះជាទីតាំង នៃសេចក្ដីអន្តរាយមានឧបទ្រព ដ៏ច្រើនជាដើម ឈ្មោះថា ទទេ ព្រោះប្រាសចាកការទៀង, ល្អ, សុខ, ជាខ្លួនប្រាណ, ដែលពាលជនប្រាថ្នាហើយ ព្រោះហេតុនោះ សច្ចៈ ទី១ គឺបណ្ឌិត ពោលថា ទុក្ខ ព្រោះភាវៈនៃអត្តភាពនោះ គឺបណ្ឌិតគួរខ្ពើម និង ព្រោះជារបស់ទទេផង ។

ក៏ស័ព្ទនេះថា “សំ” សំដែងចេញនូវការប្រកបចូល ក្នុងប្រយោគទាំងឡាយ មានជាដើមថា ការជួបជុំគ្នា ការប្រជុំគ្នា ។ ស័ព្ទនេះថា “ឧ” បំភ្លឺនូវការកើតឡើង ក្នុងប្រយោគទាំងឡាយ មានជាអាទិ៍ ថា : ធម្មជាតិ កើតឡើង គឺថា តាំងឡើងហើយ ។ ស័ព្ទថា “អយៈ” បំភ្លឺនូវហេតុ ។ ក៏ប៉ុន្តែ ទុតិយសច្ចៈ នេះ កាលបើមានកិរិយាប្រកបចូលនូវបច្ច័យ ដ៏សេស ជាហេតុនៃការកើតឡើងនៃសេចក្ដីទុក្ខ ។ ហេតុនោះ ទើបព្រះមានព្រះភាគ ត្រាស់ហៅថា ទុក្ខសមុទយៈ ព្រោះកាលបើមានការប្រកបចូលគ្នា ជាហេតុកើតឡើង នៃសេចក្ដីទុក្ខ ។

ក៏សច្ចៈ ទី៣ ព្រោះហេតុនៃ និ ស័ព្ទ បំភ្លឺនូវការមិនមាន និង រោធ



ស័ព្ទ បំភ្លឺនូវការប្រព្រឹត្តិទៅ ព្រោះហេតុនោះ ការមិនមាននៃការប្រព្រឹត្តិទៅ នៃទុក្ខ ពោលគឺការប្រព្រឹត្តិទៅ ក្នុងសំសារវដ្ដ ក្នុងសច្ចៈនេះ ទើបឈ្មោះថា ទុក្ខនិរោធ ព្រោះសោះសូន្យចាកគតិទាំងពួង ឬថា កាលបើព្រះយោគាវចរ បានសំរេចសច្ចៈនេះហើយ ក៏មិនមានការប្រព្រឹត្តិទៅនៃទុក្ខ ពោលគឺការប្រព្រឹត្តិទៅ ក្នុងសំសារវដ្ដ ព្រោះសច្ចៈនេះ ជាគូទំនាស់ដល់សេចក្ដីទុក្ខនោះ ព្រោះហេតុយ៉ាងនេះឯង ទើបលោក ហៅថា ទុក្ខនិរោធ ។ មួយទៀត តតិយសច្ចៈ ឈ្មោះថា ទុក្ខនិរោធ ព្រោះភាវៈនៃសច្ចៈនោះ ជាបច្ច័យនៃការរលត់ គឺការមិនកើតឡើង នៃសេចក្ដីទុក្ខ ។

ចំណែកឯសច្ចៈ ទី៤ ព្រះអង្គត្រាស់ហៅថា ទុក្ខនិរោធគាមិនីបដិទា ព្រោះហេតុដែលសច្ចៈនេះ ឈ្មោះថា ដល់នូវការរំលត់សេចក្ដីទុក្ខ ព្រោះភាវៈនៃសច្ចៈនោះ មានមុខឆ្ពោះទៅកាន់ទីរំលត់ទុក្ខនោះ ដោយអំណាចនៃអារម្មណ៍ និង ជាបដិបទា នៃការបានសំរេចនូវការរំលត់ទុក្ខផង ។

ក៏ព្រះអរិយៈទាំងឡាយ មានព្រះពុទ្ធជាដើម រមែងចាក់ធ្លុះចំពោះនូវអរិយសច្ចៈទាំងឡាយនេះ ហេតុណា, ហេតុនោះ អរិយសច្ចៈទាំងឡាយ ៤ នោះ គឺព្រះអង្គទ្រង់ត្រាស់ហៅថា អរិយសច្ចៈ ។ សមដូចជាព្រះមានព្រះភាគ ទ្រង់ត្រាស់ថា: “ម្នាលភិក្ខុទាំងឡាយ! អរិយសច្ចៈទាំងឡាយ ៤ នេះ, អរិយសច្ចៈទាំងឡាយ ៤ នេះ តើដូចម្ដេចខ្លះ? ។ល។ ម្នាលភិក្ខុទាំងឡាយ អរិយសច្ចៈទាំងឡាយ ៤ នេះឯង, ព្រះអរិយៈទាំងឡាយ រមែងចាក់ធ្លុះចំពោះនូវអរិយសច្ចៈទាំងឡាយនេះ ព្រោះហេតុនោះ សច្ចៈទាំងឡាយនោះ ទើបលោកហៅថា អរិយសច្ចៈ” ដូច្នេះ ។

មួយទៀត សច្ចៈ ទាំងឡាយរបស់ព្រះអរិយៈ ព្រោះហេតុនោះឯង ទើបហៅថា អរិយសច្ចៈ ។ សមដូចជាព្រះមានព្រះភាគ ទ្រង់ត្រាស់ថា :

ក្នុងលោកព្រមទាំងទេវលោក ។ល។ ព្រះតថាគត ឈ្មោះថា ប្រសើរជាងទេវតា និង មនុស្ស ព្រោះហេតុនោះ សច្ចៈទាំងឡាយនោះ គឺព្រះមានព្រះភាគទ្រង់ត្រាស់ថា អរិយសច្ចៈ ។

មួយវិញទៀត សច្ចៈទាំងឡាយនោះ ឈ្មោះថា អរិយសច្ចៈ ព្រោះកិរិយាសំរេច នូវភាវៈជាព្រះអរិយៈបាន ព្រោះភាវៈនៃសច្ចៈទាំងឡាយនេះ គឺព្រះអង្គត្រាស់ដឹងចំពោះហើយ ។ សមដូចជាព្រះមានព្រះភាគទ្រង់ត្រាស់ថា: ម្នាលភិក្ខុទាំងឡាយ! តថាគត បានឆ្ងាយចាកកិលេសទ្រង់ត្រាស់ដឹង ដោយប្រពៃចំពោះព្រះអង្គឯង ទើបបានឈ្មោះថា ព្រះអរិយៈ ព្រោះបានត្រាស់ដឹង នូវអរិយសច្ចទាំងឡាយ ៤ នេះឯង តាមសមគួរ ដល់សេចក្ដីពិត ។

ម្យ៉ាងវិញទៀត សច្ចៈទាំងឡាយប្រសើរ ព្រោះហេតុនោះ ឈ្មោះថា អរិយសច្ចៈ ។ ត្រង់បទនេះថា “អរិយានិ” សេចក្ដីថា សច្ចៈទាំងឡាយ ពិត មិនប្រែប្រួល មិនក្លែងក្លាយ ។ សមដូចជាព្រះមានព្រះភាគ ទ្រង់ត្រាស់ថា: ម្នាលភិក្ខុទាំងឡាយ! អរិយសច្ចៈទាំងឡាយ ៤ នេះឯង ពិត មិនប្រែប្រួល មិនក្លែងក្លាយ ព្រោះហេតុនោះ សច្ចៈទាំងឡាយនោះ ទើបឈ្មោះថា អរិយសច្ចៈ ។

សេចក្ដីវិនិច្ឆ័យ ដោយអត្ថវិគ្គហៈ ក្នុងអរិយសច្ចនិទ្ទេសនេះ គឺបណ្ឌិតគប្បីជ្រាប យ៉ាងនេះឯង ។

(ដោយប្រភេទនៃលក្ខណៈជាដើម)

(២៣៨) សួរថា : តើបុគ្គលគប្បីវិនិច្ឆ័យ ដោយការផ្សេងគ្នា នៃហេតុ មានលក្ខណៈជាដើម ដូចម្ដេច? ។ ឆ្លើយថា: ក៏បណ្ដាសច្ចៈទាំងឡាយ ៤ នេះ ទុក្ខសច្ចៈ មានការបៀតបៀន ជាលក្ខណៈ, មានការ



ញុំាងសត្វឲ្យក្ដៅ ជាកិច្ច, មានការប្រែប្រួល ជាផល,

សមុទយសច្ចៈ មានដែនជាទីកើត ជាលក្ខណៈ, មានការធ្វើនូវការចូលទៅកាត់ផ្ដាច់ ជាកិច្ច, មានការកង្វល់ ជាផល,

និរោធសច្ចៈ មានការស្ងប់ ជាលក្ខណៈ មានការមិនច្យុត ជាកិច្ច, មានការមិនមាននិមិត្ត ជាផល,

មគ្គសច្ចៈ មានការនាំចេញ ជាលក្ខណៈ, មានកិរិយាធ្វើនូវការលះនូវកិលេស ជាកិច្ច, មានការចេញចាកកិលេស ជាផល ។

ម្យ៉ាងវិញទៀត សច្ចៈទាំងឡាយនោះ មានការប្រព្រឹត្តិទៅ, ហេតុឲ្យប្រព្រឹត្តទៅ, ការប្រព្រឹត្តិត្រឡប់ និង ហេតុឲ្យប្រព្រឹត្តត្រឡប់ ជាលក្ខណៈ តាមលំដាប់លំដោយ ។ ម្យ៉ាងវិញទៀត សច្ចៈទាំងឡាយនោះ មានការឃើញនូវតណ្ហា ដែលមានបច្ច័យតាក់តែង និង ការឃើញ នូវតណ្ហា ដែលមិនមានបច្ច័យតាក់តែង ជាលក្ខណៈ តាមលំដាប់លំដោយគ្នា ក៏ដូច្នោះដែរ ។

សេចក្ដីវិនិច្ឆ័យ ដោយប្រភេទនៃសច្ចៈ មានលក្ខណៈជាដើម គឺបណ្ឌិតគប្បីជ្រាប ក្នុងអរិយសច្ចនិទ្ទេសនេះ យ៉ាងនេះឯង ។

(ដោយអត្ថ)

ក៏សេចក្ដីវិនិច្ឆ័យ ក្នុងបទមាតិកានេះថា “អត្ថត្ថុទ្ធារតោ ចេវ” គឺបណ្ឌិត គប្បីជ្រាប ដូចតទៅនេះ ។ គប្បីជ្រាបសេចក្ដីវិនិច្ឆ័យ ដោយអត្ថ ជាមុនសិន ។

ប្រសិនបើអាចារ្យអ្នកចោទ គប្បីចោទថា “អ្វីជាអត្ថ នៃសច្ចៈ?” អាចារ្យអ្នកឆ្លើយ គប្បីឆ្លើយថា: “សភាវៈណា កាលបើព្រះយោគាវចរទាំងឡាយ ចូលទៅពិចារណា ដោយបញ្ញាចក្ខុ ជាសភាវៈមិនប្រែប្រួល

*ដូចជាកលមាយា, មិនមែនជាសភាវៈបោកបញ្ឆោត ដូចជាថ្ងៃបណ្ដើរកូន និង មិនមែនជាសភាវៈ គឺបុគ្គលចូលទៅរកមិនបាន បីដូជាអត្តារបស់ពួកតិរ្ថិយ៍ឡើយ, តែជាអារម្មណ៍ (ជាគោចរ) របស់អរិយញ្ញាណតែម្យ៉ាង ដោយភាវៈជារបស់ទៀងទាត់ មិនប្រែប្រួល ពិតប្រាកដ ដែលមានការបៀតបៀន, ជាដែនកើត, ស្ងប់រម្ងាប់ និង ជាធម៌គ្រឿងនាំចេញ, សភាវៈជារបស់ទៀងទាត់ មិនប្រែប្រួល និង ពិតប្រាកដ បីដូចជាលក្ខណៈនៃភ្លើង និង ដូចជាលោកជាប្រក្រតីនោះ បណ្ឌិត គប្បីជ្រាបថាជាអត្ថនៃសច្ចៈ ។ សមដូចជាព្រះមានព្រះភាគ ទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ! ពាក្យថា នេះ គឺទុក្ខ នុ៎ះជាពាក្យពិត, នុ៎ះ ជាពាក្យមិនប្រែប្រួល, នុ៎ះ ជាពាក្យមិនប្រែប្រួល ទៅជាប្រការដទៃ" ដូច្នេះជាដើម ។*

*បណ្ឌិតគប្បីយកសេចក្ដីពិស្ដារ មកពណ៌នាផងចុះ ។*

*(៣២៩) ម្យ៉ាងវិញទៀត*

សេចក្ដីទុក្ខ មិនមែនជាគ្រឿងមិនបៀតបៀនទេ, ធម្មជាតដទៃក្រៅអំពីសេចក្ដីទុក្ខ ជាគ្រឿងបៀតបៀនមិនមានទេ ព្រោះហេតុណា, ព្រោះហេតុនោះ សេចក្ដីទុក្ខនេះ ទើបឈ្មោះថា ជារបស់ពិត ព្រោះទៀងទាត់ ក្នុងភាវៈជាធម្មជាតបៀតបៀន ។

វៀរចាកតណ្ហានោះចេញ សេចក្ដីទុក្ខក្រៅអំពីហេតុដទៃមិនមាន, តណ្ហានោះ មិនមាន និង សេចក្ដីទុក្ខនោះក៏មិនមានដែរ ព្រោះហេតុណា, ព្រោះហេតុនោះ វិសត្តិកា គឺតណ្ហាចងសត្វ ទើបឈ្មោះថា ជារបស់ពិត ព្រោះ



ទៀងទាត់ ក្នុងភាវៈជាហេតុ នៃសេចក្ដីទុក្ខ ។

សេចក្ដីស្ងប់ ដទៃក្រៅអំពីនិព្វាន មិនមានទេ, សន្តៈ គឺព្រះនិព្វាននោះ មិនមាន, សេចក្ដីស្ងប់នោះ ក៏មិនមានដែរ ព្រោះហេតុណា, ព្រោះហេតុនោះ ព្រះនិព្វាននេះ ទើបឈ្មោះថា ជារបស់ពិត ព្រោះទៀងទាត់ ក្នុងភាវៈជាធម្មជាតស្ងប់ ។

ការនាំចេញ ដទៃក្រៅអំពីផ្លូវ (មគ្គ) ពុំមានទេ និងនិយ្យានៈគឺមគ្គ មិនមាន, សូម្បីមគ្គជាគ្រឿងនាំចេញនោះក៏មិនមានដែរ ព្រោះហេតុណា, ព្រោះហេតុនោះ ផ្លូវនោះទើបបានឈ្មោះថា ជារបស់ពិត ព្រោះភាវៈជាធម៌ដែលជាគ្រឿងនាំចេញ ដោយពិតប្រាកដ ។

បណ្ឌិតទាំងឡាយ តែងពោល នូវភាពទៀង, ភាពមិនប្រែប្រួល និង ភាពពិតប្រាកដ ក្នុងសច្ចៈទាំង ៤ មានទុក្ខសច្ចៈជាដើម ថា ជាអត្ថនៃសច្ចៈ ដោយប្លែកគ្នា ដូចបានរៀបរាប់មក យ៉ាងនេះឯង ។

*សេចក្ដីវិនិច្ឆ័យ ដោយអត្ថ គឺបណ្ឌិត គប្បីជ្រាប ក្នុងសច្ចនិទ្ទេសនេះ ដូចបានពោលមកហើយនេះឯង ។*

(ដោយអត្ថុទ្ធារៈ)

*សួរថា: សេចក្ដីវិនិច្ឆ័យ ត្រង់បទថា "អត្ថុទ្ធារតោ" តើដូចម្ដេច? ។ ឆ្លើយថា : សច្ចៈសព្ទនេះ ក្នុងទីនេះ សំដែង (បញ្ជាក់) ក្នុងអត្ថទាំងឡាយ ដ៏ច្រើន ។ សួរថា : តើដូចម្ដេចខ្លះ? ។ ឆ្លើយថា : សច្ចសព្ទ*

*សំដែងត្រង់វាចាសច្ច ក្នុងប្រយោគទាំងឡាយ មានជាដើមថាៈ បុគ្គលគប្បីពោលពាក្យពិត មិនគប្បីខឹង ។ សច្ចសច្ច រមែងមានក្នុងវិរតិសច្ចៈ ត្រង់ប្រយោគទាំងឡាយ មានជាដើមថាៈម្យ៉ាងវិញទៀត សមណៈ និង ព្រាហ្មណ៍ទាំងឡាយ ស្ថិតនៅហើយ ក្នុងសច្ចៈ ។ សច្ចសច្ច រមែងមាន ក្នុងទិដ្ឋិសច្ចៈ ក្នុងប្រយោគទាំងឡាយ មានជាដើមថាៈ ព្រោះហេតុអ្វីបាន ជាពួកជន អ្នកឆ្លាតខាងសំដីទាំងឡាយ តែងពោល នូវពាក្យសច្ចៈទាំងឡាយផ្សេងៗ គ្នា គប្បីពោលអាង(ដូច្នេះ) ។ សច្ចសច្ច រមែងមាន ក្នុងបរមត្ថសច្ចៈ គឺព្រះនិព្វានផង គឺមគ្គផង ក្នុងប្រយោគទាំងឡាយ មានជាដើមថាៈ សេចក្តីពិត គឺសច្ចៈ មានតែមួយ មិនដែលមានពីរ ។ សច្ចសច្ច រមែងមានមកក្នុងអរិយសច្ច ត្រង់ប្រយោគទាំងឡាយ មានជាដើមថាៈ បណ្តាសច្ចៈទាំង ៤ សច្ចៈ ប៉ុន្មាន ដែលជាកុសល? ។ សច្ចៈនេះនោះ រមែងប្រព្រឹត្តទៅ ក្នុងអរិយសច្ចៈ ត្រង់ពាក្យនេះដូច្នេះឯង ។*

*សេចក្តីវិនិច្ឆ័យ សូម្បីដោយអត្ថុទ្ធារៈ ត្រង់សច្ចនិទ្ទេសនេះ បណ្ឌិតគប្បីជ្រាប យ៉ាងនេះឯង ។*

(ដោយមិនខ្វះ មិនលើស)

*(៣៣០) ក្នុងបទថា* “នន្ធូនាធិកតោ” *សេចក្តីវិនិច្ឆ័យ គឺបណ្ឌិតគប្បីជ្រាបដូចតទៅ ។ ប្រសិនបើអាចារ្យអ្នកចោទ គប្បីពោលចោទថាៈ ចុះព្រោះហេតុអ្វី បានជាអរិយសច្ចៈទាំងឡាយ ៤ ហ្នឹងឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ មិនខ្វះ មិនលើស ? ។ អាចារ្យអ្នកឆ្លើយ គប្បីពោលថាៈ ព្រោះភាវៈនៃសេចក្តីដទៃ គឺបុគ្គលមិនគប្បីបញ្ចូលបានផង ព្រោះភាវៈនៃសេចក្តីដទៃ គឺបុគ្គលមិនគប្បីនាំយកចេញបានផង ។ ពិតមែន អរិយសច្ចៈដទៃ លើសអំពីសច្ចៈទាំង ៤ នេះ ឬថា បណ្តាសច្ចៈ*



*ទាំង ៤ នេះ សូម្បីសច្ចៈ១ ដែលបុគ្គលគប្បីដកចេញមិនសមឡើយ ។ សមដូចព្រះមានព្រះភាគ ទ្រង់ត្រាស់ថាៈ ម្នាលភិក្ខុទាំងឡាយ សមណៈក្តី ព្រាហ្មណ៍ក្តី ក្នុងសាសនានេះ គប្បីមកពោលថា សេចក្តីទុក្ខនេះ ពុំមែនជាអរិយសច្ចទេ, សេចក្តីទុក្ខដទៃ ជាអរិយសច្ច, ខ្ញុំនឹងលើកលែងនូវទុក្ខអរិយសច្ចនេះចេញ ហើយបញ្ញត្ត នូវទុក្ខអរិយសច្ចៈដទៃ ជំនួសវិញ ព្រោះហេតុនោះ ពាក្យនេះ មិនមែនជាហេតុជាទីតាំងទេ” ដូច្នេះជាដើម ។ សមដូចព្រះមានព្រះភាគ ទ្រង់ត្រាស់ថាៈ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើសមណៈក្តី ព្រាហ្មណ៍ក្តីណាទីមួយ គប្បីពោល យ៉ាងនេះថា ទុក្ខអរិយសច្ចណា គឺព្រះសមណគោតម សំដែងហើយ ទុក្ខអរិយសច្ចនេះ មិនមែនជាដំបូងទេ, ខ្ញុំលះបង់ហើយ នូវសេចក្តីទុក្ខនេះ ជាអរិយ-សច្ច ដំបូង នឹងបញ្ញត្តនូវសេចក្តីទុក្ខដទៃ ថា ជាអរិយសច្ចៈ ជាដំបូងវិញ ព្រោះហេតុនោះ ហេតុនេះ មិនមែនជាហេតុជាទីតាំងទេ” ដូច្នេះជាដើម ។*

*ម្យ៉ាងវិញទៀត ព្រះមានព្រះភាគ កាលទ្រង់បង្ហាញនូវប្រវត្តិ ទ្រង់សំដែងប្រាប់ព្រមទាំងហេតុ កាលទ្រង់បង្ហាញ នូវនិវត្តិ ក៏ទ្រង់ត្រាស់សំដែងប្រាប់ព្រមទាំងឧបាយផង ។ សច្ចៈទាំងឡាយ ៤ ហ្នឹងឯង គឺព្រះមានព្រះភាគ ទ្រង់ត្រាស់សំដែងហើយ ព្រោះមានប្រវត្តិ, និវត្តិ និងហេតុនៃប្រវត្តិ និង និវត្តិទាំងពីរយ៉ាងនេះ តែប៉ុណ្ណោះឯង ។ ន័យដូចគ្នានោះដែរ សច្ចៈទាំងឡាយ ៤ ហ្នឹងឯង គឺព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ដោយអំណាចនៃធម៌ គឺបុគ្គលគប្បីកំណត់ដឹង, ធម៌គឺបុគ្គលគប្បីលះបង់, ធម៌ គឺបុគ្គលគប្បីធ្វើឲ្យជាក់ច្បាស់ និង ធម៌ គឺបុគ្គលគប្បីចំរើនផង នៃវត្ថុនៃតណ្ហា, តណ្ហា, ការរំលត់នូវតណ្ហា និង ឧបាយជាគ្រឿងរំលត់នូវតណ្ហាទាំងឡាយផង នៃសេចក្តីអាល័យ, ភាវៈនៃបុគ្គលដែលមាន*

សេចក្តីអាល័យ ជាទីមកត្រេកអរ, កិរិយាដកឡើង នូវសេចក្តីអាល័យ និង ឧបាយជាទីដកឡើង នូវសេចក្តីអាល័យទាំងឡាយផង ។

សេចក្តីវិនិច្ឆ័យ ដោយមិនខ្វះ និង មិនលើស ក្នុងអរិយសច្ចនេះ គឺបណ្ឌិតគប្បីជ្រាប យ៉ាងនេះ ។

(ដោយលំដាប់)

(៣៣១) សូម្បីលំដាប់នេះ ក្នុងបទថា "កមតោ" ក៏គឺលំដាប់នៃការសំដែងនេះឯង ។ ក៏បណ្តាសច្ចៈទាំង ៤ នេះ ទុក្ខសច្ច គឺព្រះមានព្រះភាគ ទ្រង់ត្រាស់សំដែងហើយជាដំបូង ព្រោះថាដឹងបាន ដោយងាយ ព្រោះភាវៈនៃសច្ចៈ គ្រោតគ្រាតផង ព្រោះភាវៈនៃសច្ចៈទូទៅ ដល់សត្វទាំងពួងផង ។ សមុទយសច្ចៈ គឺព្រះមានព្រះភាគ ទ្រង់ត្រាស់សំដែងហើយ បន្ទាប់អំពីទុក្ខសច្ចនោះ ដើម្បីសំដែងហេតុ នៃទុក្ខសច្ចនោះឯង ។ បន្ទាប់អំពីសមុទយសច្ចៈនោះមក ព្រះមានព្រះភាគ ទ្រង់ត្រាស់សំដែងនិរោធសច្ចៈ ដើម្បីកិរិយាញ៉ាំងឲ្យដឹងថា ការរលត់នូវផល តែងមានព្រោះការរលត់នូវហេតុ គឺតណ្ហា ។ មគ្គសច្ចៈ គឺព្រះមានព្រះភាគត្រាស់សំដែងហើយ ក្នុងទីបំផុត ដើម្បីកិរិយាពន្យល់នូវឧបាយជាគ្រឿងបាននូវនិរោធសច្ចៈនោះ ។ ម្យ៉ាងទៀត ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយនូវទុក្ខសច្ចៈ ជាដំបូង ដើម្បីញ៉ាំងសេចក្តីសង្វេគ ឲ្យកើតឡើង ដល់សត្វទាំងឡាយ ដែលជល់ហើយ នូវសេចក្តីត្រេកអរ ក្នុងសេចក្តីសុខ ក្នុងភព ។ សមុទយសច្ចៈ គឺព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ បន្ទាប់ពីទុក្ខសច្ចៈនោះមក ដើម្បីញ៉ាំងសត្វឲ្យដឹងថា សេចក្តីទុក្ខនោះ គឺតណ្ហាមិនបានតាក់តែងហើយក៏មិនមក, ទុក្ខនោះ រមែងមាន ព្រោះហេតុខាង



ក្រៅ មានព្រះជាធំបណ្តាលឲ្យជាដើម ក៏មិនមែនទេ, តែសេចក្តីទុក្ខនេះរមែងមាន ព្រោះតណ្ហានេះឯង ។ តអំពីនោះមក ព្រះមានព្រះភាគទ្រង់ត្រាស់សំដែងហើយ នូវនិរោធសច្ចៈ ដើម្បីញ៉ាំងសេចក្តីរីករាយ ដោយការឃើញនូវការរលាស់ខ្លួនចេញចាកទុក្ខ ឲ្យកើតឡើង ដល់បុគ្គលទាំងឡាយ ដែលមានចិត្តសង្វេគតក់ស្លុត ព្រោះត្រូវសេចក្តីទុក្ខ ព្រមទាំងហេតុគ្របសង្កត់ហើយ ស្វែងរកនូវការរលាស់ខ្លួន ចេញចាកពីសេចក្តីទុក្ខ ។ បន្ទាប់អំពីនោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់សំដែងហើយ នូវមគ្គសច្ចៈ ដែលជាគ្រឿងញ៉ាំងនិរោធសច្ចៈឲ្យដល់ព្រមហើយ ដើម្បីបានសំរេចនូវនិរោធ យ៉ាងដូច្នេះឯង ។

សេចក្តីវិនិច្ឆ័យ តាមលំដាប់ ក្នុងអរិយសច្ចនេះ គឺបណ្ឌិតគប្បីជ្រាប ដូចបានពណ៌នាមកហើយនេះឯង ។

## ទុក្ខនិទ្ទេស

(៣៣២) ត្រង់ពីរបទថា "ជាតិអាទីនំ និច្ឆយោ" សេចក្តីវិនិច្ឆ័យ គឺបណ្ឌិត គប្បីជ្រាប ដូចតទៅ ។ ធម៌ទាំងឡាយណា មានជាតិជាដើមនោះឯង គឺព្រះដ៏មានព្រះភាគ កាលទ្រង់សំដែងអរិយសច្ចៈទាំងឡាយ ទ្រង់ត្រាស់សំដែងហើយ ក្នុងនិទ្ទេសនៃសច្ចទាំង ៤ ដូច្នេះ គឺៈ ធម៌ទាំងឡាយ ១២ គឺព្រះមានព្រះភាគ ទ្រង់ត្រាស់សំដែងហើយ ក្នុងទុក្ខនិទ្ទេសថាៈ ជាតិហ្នឹងឯង ជាទុក្ខ, ជរា ក៏ជាទុក្ខ, មរណៈ ក៏ជាទុក្ខ, សោក, ការខ្សឹកខ្សួល, ការទោមនស្ស និង ការចង្អៀតចង្អល់ទាំងឡាយ រមែងជាទុក្ខ, ការប្រកបព្រម ដោយរបស់មិនជាទីស្រឡាញ់ទាំងឡាយ ក៏ជាទុក្ខ, ការព្រាត់ប្រាសចាករបស់ដែលជាទីស្រឡាញ់ទាំងឡាយ ក៏ជាទុក្ខ, បុគ្គលចង់បាននូវវត្ថុណា មិនបាននូវវត្ថុនោះ ក៏ជាទុក្ខ, ឧបាទានក្ខន្ធទាំង

ទ្បាយ ៥ ដោយបំព្រួញ ក៏ឈ្មោះថា ជាទុក្ខ” ដូច្នេះ, តណ្ហា ៣ យ៉ាង ព្រះអង្គ ត្រាស់ហើយ ក្នុងសមុទយនិទ្ទេសថា: តណ្ហា នេះណា ដែល ញុំាងសត្វឲ្យកើត ក្នុងភពថ្មីទៀត, ប្រព្រឹត្តទៅ មួយអន្លើដោយនន្ទិរាគៈ, មានកិរិយាត្រេកអរចំពោះហើយ ក្នុងអារម្មណ៍ទាំងឡាយនោះៗ ជា ប្រក្រតី, តណ្ហាទាំងនេះ តើដូចម្ដេច? គឺ កាមតណ្ហា ១ ភវតណ្ហា ១ វិភវតណ្ហា ១” ដូច្នេះ, និព្វាន មានតែ ១ ដោយអត្ថ ទ្រង់ត្រាស់ហើយ ក្នុងនិរោធនិទ្ទេស យ៉ាងនេះថា: ការរំលត់នៃតណ្ហា ដោយអរិយមគ្គ មិន ឲ្យសេសសល់នុ៎ះឯណា គឺ ការលះបង់, ការរលាស់ចោល, កិរិយារួច ផុត, ការមិនមានអាល័យ ក្នុងតណ្ហានោះ ឯណា” ដូច្នេះ, ធម៌ទាំង ឡាយ ៨ ប្រការ ព្រះអង្គត្រាស់ហើយ ក្នុងមគ្គនិទ្ទេស យ៉ាងនេះថា : ទុក្ខនិរោធគាមិនីបដិបទា អរិយសច្ចៈ តើដូចម្ដេច?, គឺ មគ្គ ដ៏ប្រសើរ ប្រកបដោយអង្គ ៨ នេះឯង, តើអរិយមគ្គ មានអង្គ ៨ នេះ ដូចម្ដេច? (មគ្គ ប្រកបដោយអង្គ ៨ គឺ:) សម្មាទិដ្ឋិ ១ ។ល។ សម្មាសមាធិ ១” ដូចបានរៀបរាប់មកនេះឯង ។

សេចក្ដីវិនិច្ឆ័យ ត្រង់បទទាំងពីរនេះ ថា “ជាតិអាទីនំ និច្ឆយា” នៃធម៌ទាំងឡាយនោះ គឺបណ្ឌិតគប្បីជ្រាប ដូចតទៅនេះ ។

(ដោយវិនិច្ឆ័យថា ជាតិ ជាដើម)

(ជាតិទុក្ខ)

សេចក្ដីវិនិច្ឆ័យនេះ តើដូចម្ដេច? ។ ក៏ស័ព្ទថា “ជាតិ” នេះ មាន អត្ថច្រើនយ៉ាង ។ ពិតមែនដូច្នោះ ស័ព្ទថា ជាតិ នេះ មានមកហើយ ក្នុងអត្ថថា ភព ត្រង់បទនេះថា “នូវជាតិ ១ ក៏មាន, នូវជាតិទាំងឡាយ



២ ក៏មាន” ដូច្នេះជាដើម ។ ស័ព្ទថា ជាតិ នេះ មានមកហើយ ក្នុងអត្ថ គឺពួក ត្រង់បទនេះថា “ម្នាលនាងវិសាខា សមណជាតិ ឈ្មោះថា និគ្រន្ថ រមែងមាន” ដូច្នេះជាដើម ។ ស័ព្ទថា ជាតិ នេះ មានមកហើយ ក្នុង អត្ថថា មានការតាក់តែង ជាលក្ខណៈ ត្រង់បទនេះថា ជាតិ គឺលោក សង្គ្រោះយកហើយ ដោយខន្ធទាំងឡាយពីរ” ដូច្នេះជាដើម ។ ស័ព្ទថា ជាតិ នេះ មានមកហើយ ក្នុងអត្ថថា បដិសន្ធិ ត្រង់បទនេះថា “ចិត្តណា ជាដំបូងកើតឡើងហើយ វិញ្ញាណណាជាដំបូង កើតប្រាកដហើយ ក្នុង ផ្ទៃនៃមាតា, ជាតិនេះនោះ (រមែងកើតឡើង) ព្រោះអាស្រ័យនូវចិត្ត គឺបឋមវិញ្ញាណនោះឯង” ដូច្នេះជាអាទិ៍ ។ ស័ព្ទថា ជាតិ នោះ មានមក ហើយ ក្នុងអត្ថថា ប្រសូត ត្រង់បទនេះថា “ម្នាលអានន្ទ ព្រះពោធិសត្វ កើតហើយ អស់កាលមួយរំពេច” ដូច្នេះ ។ ស័ព្ទថា ជាតិ នេះ មាន មកហើយ ក្នុងអត្ថថា ត្រកូល ត្រង់បទនេះថា “ជាអ្នកគឺគេមិនជេរហើយ គឺគេមិនតិះដៀលហើយ ដោយវាទៈ ថា ជាតិ” ដូច្នេះ ។ ស័ព្ទថា ជាតិ នេះ មានមកហើយ ក្នុងអត្ថថា អរិយសីល ត្រង់បទនេះថា “ម្នាលប្អូន ស្រី អាត្មាភាព កើតហើយ ដោយអរិយជាតិ អំពីកាលណា” ដូច្នេះ ។ ស័ព្ទថា ជាតិ នេះនុ៎ះ ក្នុងទីនេះ បណ្ឌិត គប្បីជ្រាបថា មកហើយ ក្នុងខន្ធ ទាំងឡាយ ដែលប្រព្រឹត្តទៅហើយ ចាប់ដើមអំពីបដិសន្ធិ នៃសត្វទាំង ឡាយដែលដេកនៅ ក្នុងផ្ទៃ រហូតដល់ការប្រសូតិ ចាកផ្ទៃនៃមាតា, មក ហើយ ក្នុងបដិសន្ធិទាំងឡាយប៉ុណ្ណោះ ចំពោះពួកសត្វក្រៅអំពីនេះ ។ ក៏វិនិច្ឆ័យកថា ដែលពោលមកនេះ គឺជាសេចក្ដីអធិប្បាយផ្សេងៗ តែ ប៉ុណ្ណោះឯង ។ តែបើអធិប្បាយ ដោយត្រង់ ខន្ធទាំងឡាយណាៗ កើត ប្រាកដ ដល់សត្វទាំងឡាយ ដែលកើតឡើង ក្នុងភពទាំងឡាយនោះៗ,

ការកើតប្រាកដ ជាដំបូង នៃសត្វទាំងឡាយនោះៗ ហៅថា ជាតិ ។

ជាតិនេះនោះ មានការកើតថ្មី ជាដំបូង ក្នុងភពនោះៗ ជាលក្ខណៈ, មានការដុះដាល ជាកិច្ច, មានការ (ចេញចាក) អតីតភព ងើបមកកើតក្នុងភពនេះ ជាផល ឬថា មានភាវៈដ៏វិចិត្រដោយសេចក្តីទុក្ខ ជាផល ។

(ជាតិទុក្ខ)

ប្រសិនបើអាចារ្យអ្នកចោទ គប្បីចោទថា : ចុះព្រោះហេតុអ្វី បានជា ជាតិនេះ ជាទុក្ខ? ។ អាចារ្យអ្នកដោះស្រាយ គប្បីដោះស្រាយថា : ព្រោះភាវៈនៃជាតិជាហេតុនៃទុក្ខទាំងឡាយច្រើនអនេក ។ មែនពិត សេចក្តីទុក្ខ មានច្រើនណាស់ ។ តើទុក្ខ ដូចម្តេចខ្លះ? ។ ទុក្ខទាំងនោះ គឺ ទុក្ខត្រួតលើទុក្ខ ១, ទុក្ខព្រោះការប្រែប្រួល ១, ទុក្ខប្រចាំសង្ខារ ១, ទុក្ខកំបាំងមុខ ១, ទុក្ខមិនកំបាំងមុខ ១, ទុក្ខមានបរិយាយ ១, ទុក្ខមិនមានបរិយាយ ១ ។

បណ្តាទុក្ខទាំងឡាយនោះ ទុក្ខវេទនា ដែលប្រព្រឹត្តទៅក្នុងផ្លូវកាយ និង ក្នុងផ្លូវចិត្ត គឺលោកពោលហើយថា “ទុក្ខទុក្ខ” ព្រោះភាវៈនៃជាតិនោះ ជាទុក្ខ ដោយការប្រព្រឹត្តិទៅ តាមសភាវៈផង ដោយឈ្មោះផង ។ សុខវេទនា ឈ្មោះថា វិបរិណាមទុក្ខ ព្រោះជាហេតុនៃការកើតឡើងនៃសេចក្តីទុក្ខ ព្រោះការប្រែប្រួល ។ ឧបេក្ខាវេទនា ក្តី សង្ខារទាំងឡាយដ៏សេស ប្រព្រឹត្តទៅក្នុងភូមិបី ក្តី គឺលោកឲ្យឈ្មោះថា សង្ខារទុក្ខ ព្រោះភាវៈនៃឧបេក្ខាវេទនា និង សង្ខារ ត្រូវបានការកើតឡើង និងសូន្យទៅវិញ បៀតបៀន ។ អាពាធ ដែលប្រព្រឹត្តទៅ ក្នុងផ្លូវកាយ និង ចិត្ត មានការឈឺត្រចៀក, ឈឺធ្មេញ និង សេចក្តីក្តៅក្រហាយ ដែលកើតអំពីរាគៈ និង ការក្តៅក្រហាយ ដែលកើតអំពីទោសៈជាដើម ហៅថា



សេចក្តីទុក្ខកំបាំងមុខ ព្រោះភាវៈនៃសេចក្តីទុក្ខនោះ គឺបុគ្គលត្រូវតែសួរសិន ទើបដឹងបាន និង ព្រោះមិនប្រាកដដល់បុគ្គលព្យាយាម ។ អាពាធ មានការធ្វើនូវអំពើ ៣២ យ៉ាង ជាដើមជាមុដ្ឋាន ឈ្មោះថា សេចក្តីទុក្ខមិនមានកំបាំងមុខ ព្រោះភាវៈនៃសេចក្តីទុក្ខនោះ មិនចាំបាច់នឹងសួរ ក៏ដឹងបាន និង ព្រោះប្រាកដ ដល់បុគ្គលអ្នកព្យាយាមផង ។ សេចក្តីទុក្ខមានជាតិទុក្ខជាដើម ដ៏សេស ដែលមានមកហើយ ក្នុងទុក្ខសច្ចវិភង្គ លើកលែងតែទុក្ខត្រួតលើទុក្ខចេញ, សេចក្តីទុក្ខទាំងអស់ហ្នឹង ឈ្មោះថា បរិយាយទុក្ខ ព្រោះភាវៈជាវត្ថុ នៃទុក្ខនោះៗ ។ ចំណែកឯ ទុក្ខត្រួតលើទុក្ខ គឺព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយថា និប្បរិយាយទុក្ខ ។

(គព្ភោក្កន្តិមូលកទុក្ខ)

បណ្តាទុក្ខទាំងឡាយនោះ ទុក្ខដែលប្រព្រឹត្តទៅ ក្នុងអបាយណានោះ ដែលព្រះមានព្រះភាគទ្រង់ប្រកាសហើយ ដោយអំណាចសេចក្តីឧបមា ក្នុងសូត្រទាំងឡាយមានពាលបណ្ឌិតសូត្រជាដើម និង សេចក្តីទុក្ខ ឯណា ផ្សេងដោយហេតុ មានការយាងចុះកាន់គភ៌ជាមូល ជាដើម ក្នុងមនុស្សលោក រមែងកើតឡើង ក្នុងសុគតិ, ជាតិនេះ ឈ្មោះថា ជាទុក្ខ ព្រោះភាវៈនៃជាតិជាទីតាំង នៃសេចក្តីទុក្ខនោះ ។

បណ្តាទុក្ខទាំងឡាយនោះ សេចក្តីទុក្ខនេះ ជាទុក្ខមានការយាងចុះកាន់គភ៌ ជាមូលជាដើម ជាប្រភេទ ។

ព្រោះថា សត្វនេះ កាលកើត ក្នុងផ្ទៃនៃមាតា រមែងមិនកើត ក្នុងទីទាំងឡាយមានផ្កាឧប្បល និង ផ្កាឈូកជាដើមទេ, បើតាមពិត សត្វនេះ រមែងកើតឡើង ត្រង់ប្រទេសនៃផ្ទៃ ពួដ៏ខាងក្រោម នៃអាហារថ្មី ពួដ៏ខាងលើនៃអាហារចាស់ ត្រង់កណ្តាលនៃដំបារពោះ និង ទ្រនុងខ្នងទាំង

ឡាយ គួរខ្ពើមរអើមក្រៃពេក ដ៏ចង្អៀតក្រៃលែង មានងងឹត យ៉ាងខ្លាំង ដ៏ហ៊ុមព័ទ្ធហើយ ដោយក្លិននៃសាកសពផ្សេងៗ និង ប្រោះព្រំដោយក្លិនអាក្រក់ក្រៃលែង ដូចជាដង្កូវ ក្នុងទីទាំងឡាយមានត្រីស្អុយ, នំផ្អូម និង ទឹកជ្រាំទាំងឡាយជាដើមដូច្នេះ ។ សត្វនោះ កើតហើយ ក្នុងប្រទេសគឺផ្ទៃនៃមាតានោះ គឺចំហាយដែលកើតអំពីផ្ទៃនៃមាតា ចំអិន ដូចជាកញ្ចប់នំអន្សម ចំហុយដូចជាដុំនៃម្សៅ ប្រាសហើយចាកឥរិយាបថ មានការបត់និងលាជាដើម រមែងទទួលនូវសេចក្តីទុក្ខ ហួសប្រមាណ អស់ ១០ ខែ ដូច្នេះឯង ។ សេចក្តីទុក្ខនេះ ជាទុក្ខមានការយាងចុះកាន់គភ៌ ជាមូលយ៉ាងដូច្នេះឯង ។

(គព្ភបរិហរណមូលកទុក្ខ)

ចំណែកសត្វនេះនោះ រមែងទទួលនូវសេចក្តីទុក្ខណា ដ៏ក្រៃលែង ដោយសេចក្តីព្យាយាមមានការដើរទៅខាងមុខ និង ដើរមកខាងក្រោយ និង ឱនចុះ និង ងើបឡើងជាដើម ក្នុងកាលទាំងឡាយ មានកាលជាទីភ្លាត់ដួល, កាលជាទីទៅ, កាលជាទីអង្គុយចុះ, កាលជាទីក្រោកឡើង និង កាលជាទីផ្លាស់ប្តូរជាដើម យ៉ាងរហ័សនៃមាតា ដូចជាកូននៃពពែដែលទៅហើយ ក្នុងដៃនៃអ្នកប្រមឹកស្រាផង ដូចជាកូនពស់ ដែលទៅហើយ ក្នុងដៃនៃហ្មពស់ផង ។ម្យ៉ាងទៀត សត្វនោះ សោយទុក្ខណាដ៏ក្តៅក្លា ដូចជាសត្វដែលកើតឡើងហើយ ក្នុងនរកដ៏ត្រជាក់ ក្នុងកាលជាទីផឹកនូវទឹកត្រជាក់ របស់មាតាផង ដូចជារលាកហើយ ដោយភ្លៀងនៃរងើកភ្លើង ក្នុងកាលដែលមាតា លេបនូវវត្ថុ មានបបរ និង ភត្តដ៏ក្តៅជាដើមផង ហាក់ដូចជាដល់ហើយ នូវការដាក់ទោស មានការស្រោចប្រាស់ និង កិរិយាចាំងជាដើម ក្នុងកាលជាទីលេប នូវវត្ថុ មានអំបិល



និង អំពិលជាដើមផង, ទុក្ខនេះ ជាទុក្ខមានការរក្សានូវគភ៌ ជាហេតុ ។

(គព្ភវិបត្តិមូលកទុក្ខ)

ម្យ៉ាងទៀត ទុក្ខណា កើតឡើងដល់សត្វនេះ ដោយកិច្ចទាំងឡាយមានការកាត់ និង ការវះជាដើម ក្នុងកន្លែងជាទីកើតឡើងនៃទុក្ខ មិនគួរដល់ការឃើញ ដោយជនទាំងឡាយ មានមិត្ត អាមាត្យ និង សម្លាញ់ជាដើម នៃមាតាដែលមានគភ៌សន្ទប់សន្ទិនហើយ, សេចក្តីទុក្ខនេះ ជាទុក្ខព្រោះការវិបត្តិនៃគភ៌ ជាហេតុ ។

(វិជាយនមូលកទុក្ខ)

សេចក្តីទុក្ខណា រមែងកើតឡើង ដល់សត្វនោះដែលត្រូវខ្យល់ទាំងឡាយ កើតអំពីកម្មនៃមាតា កាលប្រសូតបង្វិលត្រឡប់ហើយ កាលធ្លាក់ចុះកាន់មាត់ នៃយោនី ដែលបុគ្គលគួរខ្លាច យ៉ាងសម្បើម ដូចជាការធ្លាក់ចុះ ក្នុងនរកផង ត្រូវជនទាញចេញតាមមាត់នៃយោនី ដ៏ចង្អៀតដូចជាដំរីធំ ដែលគេទាញតាមប្រហោងកូនសោផង ត្រូវកិនកម្ទេចដោយភ្នំឃ្លាបទាំងឡាយ ដូចសត្វនរក ដែលត្រូវភ្នំឃ្លាបគៀបដូច្នោះ, ទុក្ខនេះឈ្មោះថា ជាទុក្ខមានការប្រសូត ជាហេតុ ។

(ពាហិនិក្ខមនមូលកទុក្ខ)

ក៏សេចក្តីទុក្ខណា ប្រាកដស្មើដោយការចាក់ និង ការវះ ដោយមុខនៃម្ជុល និង មុខនៃកាំបិតកោរទាំងឡាយ កើតឡើង ដល់សត្វដែលកើតហើយ មានសរីរៈដ៏ទន់ភ្លន់ ប្រាកដស្មើដោយដំបៅខ្ទី ក្នុងកាលមានកាលជាទីចាប់ដោយដៃ និង ជាទីផ្ងូត ជាទីលាង ជាទីជូត ដោយកំណាត់ជាដើម, សេចក្តីទុក្ខនេះ ឈ្មោះថា ជាទុក្ខ មានការចេញខាងក្រៅ ចាកផ្ទៃនៃមាតា ជាហេតុ ។

(អត្តុបក្កមមូលកទុក្ខ)

*សេចក្តីទុក្ខណា រមែងមានដល់សត្វ ដែលសម្លាប់នូវខ្លួនដោយខ្លួនឯង ក្នុងប្រវត្តិកាល បន្ទាប់ពីបដិសន្ធិនោះក្តី ដែលប្រកបហើយរឿយៗ នូវសេចក្តីព្យាយាម ជាគ្រឿងញ៉ាំងសត្វឲ្យក្តៅសព្វ និង ការក្តៅទូទៅ ដោយអំណាចនៃវត្ត មានអចេលកវត្តជាដើមក្តី អ្នកមិនបរិភោគ និងអ្នកចង-ក សម្លាប់ខ្លួន ដោយអំណាច នៃសេចក្តីក្រោធក្តី, សេចក្តីទុក្ខនេះ ឈ្មោះថា ជាទុក្ខ មានសេចក្តីព្យាយាមរបស់ខ្លួន ជាហេតុ ។*

(បរុបក្កមមូលកទុក្ខ)

*មួយទៀត សេចក្តីទុក្ខណា កើតឡើងដល់សត្វ កាលសោយបាបកម្មទាំងឡាយ មានការសម្លាប់ និង ការចងជាដើម អំពីបុគ្គលដទៃ, សេចក្តីទុក្ខនេះ ឈ្មោះថា ជាទុក្ខ មានសេចក្តីព្យាយាម នៃបុគ្គលដទៃជាហេតុ ដូច្នេះឯង ។*

(សរុបជាតិទុក្ខ)

*ជាតិនេះ សុទ្ធតែជាទីតាំង នៃសេចក្តីទុក្ខទាំងអស់នេះ ដោយពិតដូចបានរៀបរាប់មកហើយនេះ ។*

*ព្រោះហេតុនោះ ទើបលោកអ្នកប្រាជ្ញ ពោលគាថានេះ ថា :*

បើសត្វមិនគប្បីកើត ក្នុងនរកទាំងឡាយ, សត្វនោះ
មិនគប្បីបាននូវសេចក្តីទុក្ខ មានកំដៅនៃភ្លើង ក្នុងនរក
នោះជាដើម ដែលបុគ្គលអត់ទ្រាំមិនបាន, សេចក្តីទុក្ខ
នឹងបាននូវទីពឹង ក្នុងទីណា ព្រោះហេតុនោះ បានជាព្រះ
ពុទ្ធជាអ្នកប្រាជ្ញ ទ្រង់ត្រាស់ហៅសេចក្តីកើត ក្នុងនរកនេះ



ថា នាំមកនូវសេចក្តីទុក្ខ ។

សេចក្តីទុក្ខណា ក្នុងសត្វតិរច្ឆានទាំងឡាយ ជាអនេក មានដែនជាទីកើតនៃការប្រហារ មានការប្រហារដោយរំពាត់ ផ្តៅ, ជន្លួញ និង ដំបងជាដើម, សេចក្តីទុក្ខនោះ វៀរចាកជាតិ គប្បីមាន ក្នុងតិរច្ឆានទាំងឡាយនោះ ដូចម្តេចកើត, ព្រោះហេតុនោះ ការកើត ក្នុងកំណើតតិរច្ឆាននោះ ជាទុក្ខ ។

មួយទៀត សេចក្តីទុក្ខ ក្នុងប្រេតទាំងឡាយ មានដែនជាទីកើតឡើងអំពីហេតុ មានសេចក្តីស្រេកឃ្លាន, ខ្យល់ និង កំដៅថ្ងៃជាដើម ដ៏វិចិត្រ រមែងមិនមាន ដល់សត្វដែលមិនកើតហើយ ក្នុងប្រេតទាំងឡាយនោះទេ ព្រោះហេតុណា, ព្រោះហេតុនោះឯង ព្រះពុទ្ធ ជាអ្នកប្រាជ្ញ ទ្រង់ត្រាស់ហៅ នូវជាតិ ថា ជាទុក្ខ ។

ម្យ៉ាងទៀត សេចក្តីទុក្ខណា ក្នុងពួកអសុរ ត្រង់ចន្លោះនៃលោកដែលមានងងឹត និង ត្រជាក់ ដែលបុគ្គលមិនគប្បីអត់ទ្រាំបានផង, បើសេចក្តីកើត របស់សត្វនោះ មិនគប្បីមាន នៅក្នុងចន្លោះលោកនោះទេ, សេចក្តីទុក្ខនោះ ក៏មិនគប្បីមានដែរ ព្រោះហេតុណា, ព្រោះហេតុនោះឯង ជាតិនេះ នាំមកនូវសេចក្តីទុក្ខ ។

មួយទៀត សត្វដែលនៅ ក្នុងផ្ទៃនៃមាតា បីដូចជារណ្តៅ ដ៏ពេញហើយដោយលាមក អស់កាលយ៉ាងយូរ និងកាលចេញចាកគភ៌ នៃមាតានោះ មកខាងក្រៅ រមែងបាននូវ

ទុក្ខដ៏ខ្លាំងក្លាឯណា, ទុក្ខនេះឯង វៀរចាកជាតិមិនមានឡើយ ព្រោះហេតុនោះឯង ជាតិនេះ ពិតជានាំមកនូវសេចក្ដីទុក្ខ ។

ប្រយោជន៍អ្វីទៅ ដោយការពោលពាក្យ យ៉ាងច្រើន, ក្រែងទុក្ខឯណា សូម្បីតែបន្តិចបន្តួច មាននៅក្នុងទីណាៗ ក្នុងលោកនេះ ក៏ដោយ, សេចក្ដីទុក្ខនេះ វៀរចាកជាតិហើយ រមែងមិនមាន ក្នុងទីណាៗ ឡើយ ព្រោះហេតុណា, ព្រោះហេតុនោះ ព្រះពុទ្ធ ព្រះអង្គទ្រង់ស្វែងរកនូវគុណដ៏ធំ ទ្រង់ត្រាស់ នូវជាតិនេះ ថា ជាទុក្ខ មុនគេជាងទុក្ខទាំងពួង ។

*នេះ ជាសេចក្ដីវិនិច្ឆ័យ ក្នុងជាតិ ជាដំបូង ។*

(ជរាទុក្ខ)

*(៣៣៣) សេចក្ដីវិនិច្ឆ័យ ត្រង់បទនេះថា "ជរាបិ ទុក្ខា" គឺបណ្ឌិតគប្បីជ្រាបដូចតទៅ ។ ជរា មានពីរ គឺ លក្ខណៈនៃធម៌ដែលបច្ច័យប្រជុំតាក់តែង ១ គឺភាវៈនៃខន្ធចាស់ ដែលលោករាប់បញ្ចូលហើយ ក្នុងភពមួយ ក្នុងទី-ត ដែលលោកសន្មតហើយ ដោយហេតុមានធ្មេញបាក់ ជាដើម ១ ។ ជរា គឺការចាស់ទៅ នៃខន្ធនោះ គឺលោកអធិប្បាយហើយក្នុងទីនេះ ។*

*ក៏ជរានោះនេះ មានការចាស់ទ្រុឌទ្រោមទៅនៃខន្ធជាលក្ខណៈ មានការនាំទៅជិតកាន់សេចក្ដីស្លាប់ ជាកិច្ច មានការវិនាសចាកវ័យក្មេង ជាផល ឈ្មោះថា ជាទុក្ខ ព្រោះភាវៈនៃសង្ខារជាទុក្ខផង ព្រោះជាហេតុនៃសេចក្ដីទុក្ខផង ។ មែនពិត សេចក្ដីទុក្ខដែលប្រព្រឹត្តទៅ តាមផ្លូវកាយ និង ចិត្ត នេះឯណា មានបច្ច័យដ៏ច្រើន មានភាវៈនៃអវយវៈតូច-ធំ យុរ*



*យារ, ការប្រែប្រួលនៃឥន្ទ្រិយ, ភាវៈនៃរូបដ៏ប្លែក, សេចក្ដីវិនាសនៃវ័យក្មេង, ការទៅប្រាសចាកសេចក្ដីព្យាយាម, សេចក្ដីជ្រះថ្លា សតិ ប្រាជ្ញា និង ការគ្របសង្កត់ពីបុគ្គលដទៃជាដើម រមែងកើតឡើង, ជរា ចាត់ថាជាទីតាំង នៃសេចក្ដីទុក្ខនោះ ។ ព្រោះហេតុនោះ លោកអ្នកប្រាជ្ញ ទើបពោលពាក្យនេះ ថា :*

សត្វតែងដល់នូវសេចក្ដីទុក្ខណា ដែលប្រព្រឹត្តទៅក្នុងផ្លូវកាយ និង ផ្លូវចិត្ត ព្រោះភាវៈនៃអវយវៈទាំងឡាយ ជារបស់យុរយារផង ព្រោះការប្រែប្រួល នៃឥន្ទ្រិយទាំងឡាយផង ព្រោះការវិនាសចាកវ័យក្មេងផង ព្រោះការថមថយកម្លាំងផង ព្រោះការទៅប្រាសចាកគុណធម៌ទាំងឡាយ មានសតិជាដើមផង ព្រោះកូន និង ប្រពន្ធទាំងឡាយ របស់ខ្លួន មិនគួរជ្រះថ្លាផង ព្រោះដល់នូវភាវៈទន់ខ្សោយក្រៃពេកផង, ដូច្នេះ ទុក្ខទាំងអស់នេះ មានជរាជាហេតុ ព្រោះហេតុណា, ព្រោះហេតុនោះ ជរា ទើបឈ្មោះថា ជាទុក្ខ ។

*សេចក្ដីវិនិច្ឆ័យ ក្នុងជរា ចប់ត្រឹមតែប៉ុណ្ណេះ ។*

(មរណទុក្ខ)

*(៣៣៤) សេចក្ដីវិនិច្ឆ័យ ត្រង់បទនេះថា "មរណម្បិ ទុក្ខំ" គឺបណ្ឌិតគប្បីជ្រាប ដូចតទៅ ។ មរណៈ មាន ២ យ៉ាង គឺសង្ខតលក្ខណៈ ដែលព្រះមានព្រះភាគ ទ្រង់សំដៅយក ត្រាស់ហើយថា : ជរា និង មរណៈ លោកសង្គ្រោះហើយ ដោយខន្ធទាំងឡាយ ២" ដូច្នេះ ១ ការផ្ដាច់បង់*

*នូវទី-ត នៃជីវិតិន្ទ្រិយ ដែលរាប់បញ្ចូល ក្នុងភពមួយ ដែលព្រះមានព្រះភាគ ទ្រង់សំដៅយក ត្រាស់ហើយថា “សេចក្តីភ័យខ្លាច អំពីមរណៈរមែងមាន ជានិច្ច” ដូច្នេះ ១, មរណៈ គឺការផ្តាច់នូវជីវិតិន្ទ្រិយនោះ គឺលោកពោលហើយ ក្នុងទីនេះ ។ សូម្បីពាក្យថា “សេចក្តីស្លាប់ មានព្រោះជាតិជាបច្ច័យ, សេចក្តីស្លាប់ ព្រោះសេចក្តីព្យាយាម, សេចក្តីស្លាប់ ព្រោះសេចក្តីត្រេកអរ, សេចក្តីស្លាប់ ដោយអស់អាយុ, សេចក្តីស្លាប់ ដោយអស់បុណ្យ” ដូច្នេះ ក៏ជាឈ្មោះ នៃសេចក្តីស្លាប់ គឺការផ្តាច់បង់នូវជីវិតិន្ទ្រីយ៍នោះឯង ។*

*សេចក្តីស្លាប់នេះនោះ មានការច្យុត ជាលក្ខណៈ, មានការព្រាត់ប្រាស ជាកិច្ច, មានការផ្លាស់ប្តូរនៃគតិ ជាផល, មួយវិញទៀត មរណៈគឺបណ្ឌិតគប្បីជ្រាបថា “ជាទុក្ខ” ព្រោះភាវៈនៃសេចក្តីស្លាប់នោះជាទីតាំងនៃសេចក្តីទុក្ខ ។*

*ព្រោះហេតុនោះ លោកអ្នកប្រាជ្ញ បានពោលគាថានេះ ថា :*

សេចក្តីទុក្ខ ឯណា មានក្នុងចិត្ត កើតមាន ដល់មនុស្ស
ទៀបនឹងស្លាប់ ដែលជាបុគ្គលបាប ពិចារណាឃើញ នូវ
និមិត្ត មានបាបកម្មជាដើម សូម្បីដល់បុគ្គលល្អ ដែល
អត់ទ្រាំមិនបាន ប្រព្រឹត្តស្រឡាញ់ នូវវត្ថុជាទីស្រឡាញ់
ដែលព្រាត់ប្រាសទៅ ដោយមិនប្លែកគ្នា ។ ម្យ៉ាងវិញ
ទៀត សេចក្តីទុក្ខផ្លូវកាយណា មានការដាច់នូវទី-ត និង
សរសៃគ្រឿងចងជាដើម មានសេចក្តីស្រឡាញ់ ស្លាប់
ក្រឡា ត្រូវខ្យល់ដ៏កំណាច ចាក់ដោត រមែងមាន ដល់



បុគ្គលទាំងពួងទាំងឡាយ, សេចក្តីទុក្ខនេះ ជាទុក្ខដែល
បុគ្គលមិនគប្បីអត់ធន់បាន ដែលបុគ្គលមិនគប្បីធ្វើតបបាន
សេចក្តីស្លាប់នេះ ឈ្មោះថា ជាទីតាំង នៃសេចក្តីទុក្ខនោះ
ព្រោះហេតុណា, ព្រោះហេតុនោះ សេចក្តីស្លាប់នេះ ព្រះ
មានព្រះភាគ ត្រាស់ហៅថា “ជាទុក្ខ” ពិតមែន ។

*នេះ ជាសេចក្តីវិនិច្ឆ័យ ក្នុងមរណៈ ។*

(សោកទុក្ខ)

*(៣៣៥) ក្នុងបកិណ្ណកទុក្ខ មានសេចក្តីសោកជាដើម ការក្តៅក្រហាយ ក្នុងចិត្ត នៃបុគ្គលដែលទុក្ខទាំងឡាយ មានការព្រាត់ប្រាសទៅនៃញាតិទាំងឡាយពាល់ត្រូវហើយ ឈ្មោះថា សេចក្តីសោក ។ សេចក្តីសោកនោះ បើតាមសេចក្តី គឺជាទោមនស្ស ក៏ពិតមែនហើយ, ទុកជាយ៉ាងនេះក៏ដោយ សេចក្តីសោកនោះ មានការខ្លោចផ្សាខាងក្នុង ជាលក្ខណៈ, មានការរោលរាលនៃចិត្ត ជាកិច្ច, មានការស្ងួតស្ងប់រឿយៗ ជាផល, តែសេចក្តីសោក បានឈ្មោះថា ជាទុក្ខ ព្រោះទុក្ខត្រួតលើទុក្ខនិង ព្រោះជាហេតុ នៃសេចក្តីទុក្ខផង ។ ព្រោះហេតុនោះ ទើបលោកអ្នកប្រាជ្ញ ពោលគាថាព័ន្ធន៍នេះ ថា :*

សេចក្តីសោក តែងចាក់ដោត នូវហឫទ័យ របស់សត្វទាំង
ឡាយ ដូចជាកូនសរ ដែលត្រាំដោយពិសចាក់ដោត តែង
ដុតយ៉ាងក្លៀវក្លា នូវហឫទ័យសត្វ ដូចជាលំពែង ដែលក្តៅ
ហើយ ដោយភ្លើងផង តែងប្រមូលមកនូវសេចក្តីទុក្ខ មាន
ប្រការផ្សេង ៗ មានព្យាធិ ជរា និង មរណៈ មកទៀតផង

ព្រោះហេតុណា, ព្រោះហេតុនោះ សេចក្តីសោកនោះ
ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ជាទុក្ខ ។

*នេះ ជាសេចក្តីវិនិច្ឆ័យ ក្នុងសេចក្តីសោក ។*

(បរិទេវទុក្ខ)

*(៣៣៦) ការនិយាយប៉ប៉ាច់ប៉ប៉ោច ដោយសំដីនៃបុគ្គលដែលទុក្ខទាំងឡាយ មានទុក្ខព្រោះសេចក្តីវិនាសនៃញាតិជាដើម ពាល់ត្រូវហើយ ឈ្មោះថា សេចក្តីខ្សឹកខ្សួល ។ ការខ្សឹកខ្សួលនោះ មានការពោលរៀបរាប់ ជាលក្ខណៈ, មានការសំដែងនូវគុណ និង ទោស ជាកិច្ច, មានការក័ន្ទភាំង ជាផល, ឯបរិទេវៈនោះ បានឈ្មោះថា ជាទុក្ខ ព្រោះភាវៈនៃសង្ខារ ជាទុក្ខផង ព្រោះជាហេតុ នៃទុក្ខផង ។ ព្រោះហេតុនោះ ទើបលោកអ្នកប្រាជ្ញ បានពោលគាថាព័ន្ធន៍នេះ ថា :*

បុគ្គលមានសរគឺសេចក្តីសោក កំចាត់បង់ហើយ កាលខ្សឹកខ្សួល រមែងបានទទួលសេចក្តីទុក្ខ ហួសប្រមាណ ដែលញុំាងសេចក្តីរីងស្ងួតក្នុង-ក និង បបូរមាត់ និង ផ្ទៃពិតានឲ្យកើត ដែលបុគ្គលអត់ធន់មិនបាន ព្រោះហេតុណា, ព្រោះហេតុនោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ នូវសេចក្តីខ្សឹកខ្សួលថា ជាទុក្ខ ។

*នេះ ជាសេចក្តីវិនិច្ឆ័យ ក្នុងសេចក្តីខ្សឹកខ្សួល ។*

(ទុក្ខ)

*(៣៣៧) សេចក្តីលំបាកដែលប្រព្រឹត្តទៅ ក្នុងកាយ ឈ្មោះថា ទុក្ខ*



*សេចក្តីទុក្ខនោះ មានការបៀតបៀននូវកាយ ជាលក្ខណ, មានការធ្វើនូវសេចក្តីតូចចិត្ត ចំពោះបុគ្គលឥតប្រាជ្ញាទាំងឡាយ ជាកិច្ច, មានអាពាធដែលប្រព្រឹត្តទៅក្នុងកាយជាផល, តែទុក្ខ បណ្ឌិតគប្បីជ្រាបថា ឈ្មោះថា ជាទុក្ខ ព្រោះជាទុក្ខត្រួតលើទុក្ខផង ព្រោះការនាំមកនូវសេចក្តីទុក្ខ ក្នុងចិត្តផង ។ ព្រោះហេតុនោះ លោកអ្នកប្រាជ្ញ បានពោលគាថាព័ន្ធន៍នេះថា*

ក៏សេចក្តីទុក្ខនេះ ប្រព្រឹត្តទៅក្នុងផ្លូវកាយ តែងបៀតបៀន (កាយ) ទាំងញុំាងទុក្ខដែលមានក្នុងចិត្ត ឲ្យកើតឡើងថែមទៀតផង ព្រោះហេតុណា, ព្រោះហេតុនោះ សេចក្តីទុក្ខប្រព្រឹត្តទៅក្នុងផ្លូវកាយនោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយថា ជាទុក្ខ ដោយវិសេស ។

*នេះ ជាសេចក្តីវិនិច្ឆ័យ ក្នុងទុក្ខ ។*

(ទោមនស្សទុក្ខ)

*(៣៣៨) សេចក្តីលំបាកដែលមានក្នុងចិត្ត ឈ្មោះថា ទោមនស្ស, ទោមនស្សនោះ មានការបៀតបៀននូវចិត្ត ជាលក្ខណៈ, មានការខ្ទាំងខ្ទប់នូវចិត្ត ជាកិច្ច, មានការឈឺចាប់ដែលមានក្នុងចិត្ត ជាផល, ប៉ុន្តែទោមនស្ស បណ្ឌិតគប្បីជ្រាបថា ឈ្មោះថា ជាទុក្ខ ព្រោះត្រួតលើទុក្ខផង ព្រោះការនាំមកនូវសេចក្តីទុក្ខ ដែលប្រព្រឹត្តទៅក្នុងកាយផង ។ មែនពិតសត្វទាំងឡាយ ដែលពោរពេញទៅដោយសេចក្តីទុក្ខ ក្នុងផ្លូវចិត្តហើយ រមែងសោយនូវសេចក្តីទុក្ខ មានប្រការផ្សេងៗ ដូចជារំសាយនូវសក់ទាំងឡាយហើយ កន្ទក់កន្ទេញ គក់នូវទ្រូង ប្រមៀលទៅប្រមៀលមក, ដាំដូងយកជើងឡើងលើ, កន្ទ្រាក់នូវកាំបិត, លេបនូវថ្នាំពិស, យកខ្សែ*

*ចង-ក, រត់ចូលភ្លើង ។ ព្រោះហេតុនោះ លោកអ្នកប្រាជ្ញ ទើបពោលគាថាព័ន្ធន៍នេះ ថា :*

សេចក្តីទោមនស្ស បៀតបៀននូវចិត្ត និង ប្រមូលនូវការ
បៀតបៀនផ្លូវកាយមក ឲ្យទៀតផង ព្រោះហេតុណា,
ព្រោះហេតុនោះ ព្រះពុទ្ធទាំងឡាយ ទ្រង់ប្រាសចាក
ទោមនស្សហើយ ទ្រង់ត្រាស់នូវទោមនស្សថា ជាទុក្ខ ។

*នេះ ជាសេចក្តីវិនិច្ឆ័យ ក្នុងទោមនស្ស ។*

**(ឧបាយាសៈ)**

*(៣៣៩) ទោសដែលមានដែនជាទីកើត នៃសេចក្តីទុក្ខ ក្នុងចិត្តហួសប្រមាណ នៃបុគ្គលដែលទុក្ខទាំងឡាយ មានការវិនាសនៃញាតិជាដើម ពាល់ត្រូវហើយទុំះឯង ហៅថា ឧបាយាសៈ ។ អាចារ្យទាំងឡាយពួកខ្លះ ពោលថា ឧបាយាសៈ គឺជាធម៌មួយដែលលោករាប់បញ្ចូលហើយ ក្នុងសង្ខារក្ខន្ធ ។ ឧបាយាសៈនោះ មានការដុតរោលក្នុងចិត្ត ជាលក្ខណៈ, មានការថ្ងូញថ្ងែរ ជាកិច្ច, មានការមិនគាប់ចិត្ត ជាផល, តែឧបាយាសៈ ឈ្មោះថា ជាទុក្ខ បណ្ឌិត គប្បីជ្រាបថា ព្រោះភាវៈនៃសង្ខារជាទុក្ខផង ព្រោះការដុតនូវចិត្តផង ព្រោះធ្វើរាងកាយឲ្យក្រៀមក្រំផង ។*

*ព្រោះហេតុនោះ លោកអ្នកប្រាជ្ញ ទើបពោលគាថាព័ន្ធន៍នេះ ថា :*

ឧបាយាសៈ ញុំាងសេចក្តីទុក្ខណា ឲ្យកើតឡើង, សេចក្តី
ទុក្ខនោះ មានប្រមាណក្រៃលែង ព្រោះដុតរោលចិត្តផង
ព្រោះញុំាងកាយឲ្យក្រៀមក្រំផង ហេតុណា, ហេតុនោះ
ឧបាយសៈនោះ ព្រះពុទ្ធទ្រង់ត្រាស់ថា ជាទុក្ខ ។



*នេះ ជាសេក្តីវិនិច្ឆ័យ ក្នុងឧបាយាសៈ ។*

*(៣៤០) ក៏បណ្តាសេចក្តីទុក្ខទាំងឡាយ មានសោក, បរិទេវៈ, និង ឧបាយាសៈនេះ សេចក្តីសោក បណ្ឌិត គប្បីឃើញថា ដូចជា(ទឹក)ដាំពុះ ឮដ៏ខាងក្នុងភាជនៈ ដោយភ្លើងក្តៅឧណ្ហៗ, បរិទេវៈ គប្បីជ្រាបថា ដូចជាការហៀរហូរចេញមកខាងក្រៅ អំពីភាជនៈ នៃទឹកដែលបុគ្គលដាំដោយភ្លើងដ៏ខ្លាំងផង, ឧបាយាសៈ គប្បីឃើញថា ដូចជាការពុះ រហូតដល់រីងខះអស់ទៅ ឮដ៏ខាងក្នុងភាជនៈនោះឯង នៃទឹកដ៏សេស ដែលហូរចេញមកខាងក្រៅហើយ មិនល្មមដើម្បីនឹងហូរចេញមកបានទៀត ។*

**(អប្បិយសម្បយោគទុក្ខ)**

*ការជួបប្រទះដោយសត្វ និង សង្ខារទាំងឡាយ មិនជាទីពេញចិត្ត ឈ្មោះថា ការជួបប្រទះសត្វ និង សង្ខារមិនជាទីស្រឡាញ់ ។ ការជួបប្រទះនូវសត្វ និង សង្ខារ មិនជាទីស្រឡាញ់នោះ មានការជួបប្រទះនូវសត្វ និង សង្ខារ មិនជាទីប្រាថ្នា ជាលក្ខណៈ, មានការធ្វើនូវការខ្វាំងខ្ទប់នៃចិត្ត ជាកិច្ច, មានការកើតអនត្ថៈ ជាផល, អប្បិយសម្បយោគទុក្ខ មានឈ្មោះថា ជាទុក្ខ បណ្ឌិត គប្បីជ្រាប ព្រោះជាហេតុនៃសេចក្តីទុក្ខ ។*

*ព្រោះហេតុនោះ លោកអ្នកប្រាជ្ញ ពោលពាក្យជាគាថាព័ន្ធន៍នេះថា:*

សេចក្តីទុក្ខ កើតជាដំបូងក្នុងចិត្ត ព្រោះតែឃើញនូវសត្វ
និង សង្ខារទាំងឡាយ ដែលមិនជាទីស្រឡាញ់, តពីនោះ
សេចក្តីទុក្ខនោះ ដែលកើតអំពីសេចក្តីព្យាយាម រមែង
កើតមាន ក្នុងកាយនេះ ក្នុងលោកនេះ ព្រោះហេតុណា,
ព្រោះហេតុនោះ ការជួបប្រទះនឹងរបស់មិនជាទីគាប់ចិត្ត

នោះ បណ្ឌិត គប្បីដឹងថា គឺព្រះមានព្រះភាគទ្រង់ស្វែង
រកនូវគុណដ៏ធំ ទ្រង់ត្រាស់ហើយថា ជាទុក្ខ ព្រោះជា
ហេតុជាទីតាំង នៃសេចក្តីទុក្ខទាំង ២ ។

*នេះ ជាសេចក្តីវិនិច្ឆ័យ ក្នុងអប្បិយសម្បយោគទុក្ខ ។*

(បិយវិប្បយោគទុក្ខ)

*ការព្រាត់ប្រាសចាកសត្វ និង សង្ខារទាំងឡាយ ជាទីស្រឡាញ់ ឈ្មោះថា ការព្រាត់ប្រាសចាកសត្វ និង សង្ខារជាទីស្រឡាញ់ ។ ការព្រាត់ប្រាសចាកសត្វ និង សង្ខារដែលជាទីស្រឡាញ់នោះ មានការព្រាត់ប្រាសចាកវត្ថុជាទីប្រាថ្នា ជាលក្ខណៈ មានការញ៉ាំងសេចក្តីសោក ឲ្យកើតឡើង ជាកិច្ច, មានសេចក្តីវិនាសជាផល, តែបិយវិប្បយោគទុក្ខបាន ឈ្មោះថា ជាទុក្ខ គប្បីជ្រាបថា ព្រោះជាហេតុនៃទុក្ខ គឺសេចក្តីសោក ។ ព្រោះហេតុនោះ ទើបលោកអ្នកប្រាជ្ញ ពោលគាថាព័ន្ធន៍នេះ ថា :*

ពួកជនពាលទាំងឡាយ ស្មៀតណែនហើយ ដោយសរគឺ
សេចក្តីសោក ព្រោះព្រាត់ប្រាសចាកសត្វ និង សង្ខារ
ដែលជាទីស្រឡាញ់ មានញាតិ និង ទ្រព្យជាដើម តែង
អន្ទះអន្ទែង ព្រោះហេតុណា, ព្រោះហេតុនោះ ការព្រាត់
ប្រាសចាកសត្វ និង សង្ខារ ដែលជាទីស្រឡាញ់នេះ
គឺព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយថា ជាទុក្ខ ។

*នេះ ជាសេចក្តីវិនិច្ឆ័យ ក្នុងបិយវិប្បយោគទុក្ខ ។*



(ឥច្ឆិតាលាភទុក្ខ)

*(៣៤១) សេចក្តីវិនិច្ឆ័យ ត្រង់បទនេះថា* “យម្បិច្ឆំ ន លភតិ” *គឺបណ្ឌិត គប្បីជ្រាប ដូចតទៅ ។ សេចក្តីប្រាថ្នាណា ក្នុងវត្ថុដែលបុគ្គលមិនគប្បីបាន ក្នុងប្រយោគទាំងឡាយ មានប្រយោគថា “ឲ្យធ្វើដូចម្តេចទៅហ្ន៎! យើងទាំងឡាយ នឹងជាអ្នកមិនគប្បីមានជាតិជាធម្មតា” ដូច្នេះជាដើម, សេចក្តីប្រាថ្នានោះ គឺព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ថា : “បុគ្គលប្រាថ្នានូវវត្ថុណា មិនបានវត្ថុនោះ ជាទុក្ខ” ។ សេចក្តីប្រាថ្នានោះ មានចំណង់ ក្នុងវត្ថុដែលបុគ្គលមិនគប្បីបាន ជាលក្ខណៈ, មានការស្វែងរកនូវវត្ថុដែលមិនគួរបាននោះ ជាកិច្ច, មានការមិនសំរេច នូវវត្ថុទាំងឡាយនោះ ជាផល, តែសេចក្តីប្រាថ្នាបានជាឈ្មោះថា ជាទុក្ខ គប្បីជ្រាបថា ព្រោះជាហេតុនៃសេចក្តីទុក្ខ ។*

*ព្រោះហេតុនោះ ទើបលោកអ្នកប្រាជ្ញ ពោលគាថាព័ន្ធន៍នេះ ថា :*

សេចក្តីទុក្ខណា សំរេចហើយ ដោយការខ្វាំងខ្វប់ នៃចិត្ត
រមែងកើតឡើង ដល់សត្វទាំងឡាយ ក្នុងលោកនេះ
ព្រោះកាលបើពួកគេប៉ុនប៉ង នូវវត្ថុនោះៗ តែមិនបាន នូវ
វត្ថុនោះៗ, សេចក្តីប្រាថ្នានូវវត្ថុ ដែលខ្លួនមិនគប្បីបានទាំង
ឡាយ ជាហេតុ នៃសេចក្តីទុក្ខនោះ ព្រោះហេតុណា,
ព្រោះហេតុនោះ ព្រះពុទ្ធទ្រង់ឈ្នះហើយ ទ្រង់ត្រាស់
សំដែងនូវវត្ថុដែលខ្លួនមិនបាន តាមបំណងថា ជាទុក្ខ ។

*នេះ គឺជាសេចក្តីវិនិច្ឆ័យ ក្នុងកិរិយាមិនបាននូវវត្ថុដែលខ្លួនប្រាថ្នាចង់បានហើយ ។*

(បញ្ចុបាទានក្ខន្ធទុក្ខ)

*ក៏សេចក្ដីវិនិច្ឆ័យ ក្នុងបទមាតិកាថា* “សង្ខិត្តេន បញ្ចុបាទានក្ខន្ធាបិ ទុក្ខា” *គឺបណ្ឌិតគប្បីជ្រាប ដូចតទៅនេះ ។*

> សេចក្ដីទុក្ខណា ចាប់ដើមអំពីជាតិទុក្ខមក ដែលព្រះពុទ្ធទ្រង់មិនញាប់ញ័រ ទ្រង់ត្រាស់ហើយ ក្នុងទុក្ខនិទ្ទេសនេះក្ដី សេចក្ដីទុក្ខឯណា ដែលព្រះអង្គមិនបានត្រាស់ហើយ ក្នុងទុក្ខនិទ្ទេសនេះក្ដី សេចក្ដីទុក្ខទាំងអស់នោះ វៀរចាកបញ្ចុប្បាទានក្ខន្ធទាំងឡាយនេះ មិនដែលមាន ព្រោះហេតុណា, ព្រោះហេតុនោះ ឧបាទានក្ខន្ធទាំងឡាយនេះ គឺព្រះពុទ្ធអង្គ ទ្រង់ស្វែងរក នូវគុណដ៏ធំ ទ្រង់សំដែងនូវព្រះនិព្វាន ជាទីបំផុតនៃទុក្ខ ទើបទ្រង់ត្រាស់ហើយ ថាជាទុក្ខ ដោយសង្ខេប ។

*(៣៤២) ពិតដូច្នោះមែន ទុក្ខទាំងឡាយ មានជាតិជាដើម កាលបៀតបៀននូវឧបាទានក្ខន្ធទាំង៥ នុ៎ះឯង ដោយប្រការផ្សេងៗ ដូចជាភ្លើងព្រៃឆេះនូវរំកាច់ ដូចជាសរសំរាប់ប្រហារបៀតបៀននូវវង់ ដូចជាសត្វទាំងឡាយមានរបោម និង មូសជាដើម ខាំនូវរូបនៃគោ ដូចជាបុគ្គលអ្នកច្រូតស្រូវច្រូតនូវស្រូវ ក្នុងស្រែ ដូចជាពួកចោរប្លន់ស្រុក បៀតបៀនសម្លាប់នូវអ្នកស្រុក តែងកើតឡើង ក្នុងឧបាទានក្ខន្ធទាំងឡាយនុ៎ះឯង ដូចជាវត្ថុទាំងឡាយមានស្មៅ និង វល្លិជាដើម ដែលដុះលើផែនដី ដូចជាពួកផ្កា ផ្លែ និង ពន្លកទាំងឡាយ ដុះព័ន្ធព័ន្ធ លើដើមឈើទាំងឡាយ ដូច្នោះឯង ។ មួយទៀត ទុក្ខខាងដើម នៃឧបាទានក្ខន្ធទាំងឡាយ គឺជាតិ,*



*ទុក្ខត្រង់កណ្ដាល គឺជរា, ទុក្ខក្នុងទីបំផុត គឺមរណៈ ។ សេចក្ដីទុក្ខដែលដុតរោលដោយការខ្ទាំងខ្ទប់នូវទុក្ខក្នុងពេលជិតស្លាប់ ឈ្មោះថា សេចក្ដីសោក ។ ទុក្ខ គឺការរៀបរាប់ ព្រោះការអត់ទ្រាំមិនបាន នូវសេចក្ដីទុក្ខនោះ ឈ្មោះថា សេចក្ដីខ្សឹកខ្សួល ។ តអំពីនោះ សេចក្ដីទុក្ខព្រោះការឈឺចាប់នូវកាយ ព្រោះការប្រកបព្រមដោយការផ្សព្វផ្សាយ មិនជាទីប្រាថ្នា បានដល់ការកំរើកនៃធាតុ ឈ្មោះថា ទុក្ខ ។ ទោមនស្ស ចាត់ជាទុក្ខ ព្រោះការបៀតបៀននូវចិត្ត ដោយការកើតឡើងនូវសេចក្ដីថ្នាំងថ្នាក់ក្នុងទុក្ខកាយនោះ នៃបុថុជ្ជនទាំងឡាយដែលត្រូវសេចក្ដីទុក្ខនោះ បៀតបៀន ។ ទុក្ខ គឺសេចក្ដីតូញត្អែរ នៃបុគ្គលទាំងឡាយដែលមានសេចក្ដីក្រៀមក្រំ ដែលការកើតឡើង នៃទុក្ខមានសេចក្ដីសោកជាដើម ធ្វើឲ្យកើតឡើងហើយ ឈ្មោះថា ឧបាយាសៈ ។ ទុក្ខ ព្រោះការមិនបានសមតាមប្រាថ្នា របស់ជនទាំងឡាយ ដែលដល់ហើយ នូវការខ្ទាំងខ្ទប់នូវចំណង់ ក្នុងចិត្ត ឈ្មោះថា ការមិនបានតាមសេចក្ដីប្រាថ្នា ។ ព្រោះហេតុនោះ ឧបាទានក្ខន្ធទាំងឡាយហ្នឹងឯង បើត្រិះរិះពិចារណា ដោយប្រការផ្សេងៗ ដូចបានពោលមកនេះ រមែងជាទុក្ខ ពិតមែន ។*

*សេចក្ដីទុក្ខណានេះ ដែលព្រះមានព្រះភាគ ទ្រង់សំដែងម្ដងមួយៗ ហើយនោះ គឺបុគ្គលណាមួយ មិនអាចដើម្បីពោល ដោយមិនប្លែកគ្នា ដោយកប្បទាំងឡាយ ដ៏ច្រើនបានឡើយ ព្រោះហេតុនោះ ព្រះមានព្រះភាគ ទ្រង់បានត្រាស់ហើយថា “ដោយសង្ខេប ឧបាទានក្ខន្ធ៥ ក៏ជាទុក្ខ” ដូច្នេះ ដើម្បីសំដែងបំព្រួញ នូវទុក្ខទាំងអស់នោះ ចូលក្នុងឧបាទានក្ខន្ធទាំងឡាយ ៥ ណាមួយ ដូចបុគ្គលចម្រាញ់នូវរស នៃទឹកសមុទ្ទទាំងមូលចូលទៅ ក្នុងដំណក់ទឹកតែមួយ ដូច្នោះឯង ។*

*នេះ ជាសេចក្ដីវិនិច្ឆ័យ ក្នុងឧបាទានក្ខន្ធទាំងឡាយ ។*

*នេះ ជាន័យ ក្នុងទុក្ខនិទ្ទេស ជាបឋម ។*

(ទុក្ខសមុទយនិទ្ទេស)

*(៣៤៣) ចំណែកសេចក្ដីវិនិច្ឆ័យ ក្នុងសមុទយនិទ្ទេស បណ្ឌិតគប្បីជ្រាបដូចតទៅ ។ បទថា* “យាយំ តណ្ហា” *ការកាត់បទជា* “យា អយំ តណ្ហា” *ប្រែថា តណ្ហានេះឯណា ។ ការធ្វើនូវភពថ្មី គឺថា ភពថ្មី ឈ្មោះថា បោនោព្ភវិកា ។ ភពថ្មីជាប្រក្រតី នៃតណ្ហាទុំះ ព្រោះហេតុដូច្នោះ តណ្ហានោះ ឈ្មោះថា បោនោព្ភវិកា ។ តណ្ហា ឯណា ប្រព្រឹត្តទៅមួយអន្លើដោយសេចក្ដីរីករាយ និង ត្រេកអរ ព្រោះហេតុនោះ តណ្ហានោះ ឈ្មោះថា នន្ទិរាគសហគតា ។ អត្ថរូបនេះ គឺអដ្ឋកថាចារ្យពោលហើយថា: តណ្ហា ដល់ហើយនូវភាវៈនៃតណ្ហានោះ ជាធម្មជាតិតែមួយជាមួយនឹងនន្ទិរាគៈដោយសេចក្ដី ។ បទថា* “តត្រ តត្រាភិនន្ទិនី” *សេចក្ដីថា: តណ្ហានោះ កើតក្នុងអត្តភាពណាៗ វា ក៏មានការត្រេកត្រអាលក្នុងអត្តភាពនោះៗ ។ ស័ព្ទថា* “សេយ្យថីទំ” *ជានិបាត ។ នេះជាសេចក្ដីនៃនិបាតស័ព្ទនោះថា : អាចារ្យអ្នកចោទ គប្បីចោទថា “តណ្ហានោះ តើដូចម្ដេច?” ។ ចម្លើយថា: ធម៌ទាំងនេះ គឺកាមតណ្ហា ១, ភវតណ្ហា ១, វិភវតណ្ហា ១ នឹងមានមកប្រាកដ ក្នុងបដិច្ចសមុប្បាទនិទ្ទេស ។ តែក្នុងទីនេះ តណ្ហាទាំង ៣ ប្រការនេះ គឺបណ្ឌិត គប្បីជ្រាបថា : ព្រះមានព្រះភាគ ទ្រង់ប្រមូលនូវភាវៈ នៃតណ្ហានោះ ជាធម្មជាតិតែមួយ ហើយទ្រង់ត្រាស់ថា “ជាទុក្ខសមុទយអរិយសច្ចៈ” ដោយអត្ថថា ជាហេតុញុំាងទុក្ខសច្ចៈ ឲ្យកើត ។*



(ទុក្ខនិរោធនិទ្ទេស)

*(៣៤៤) សេចក្ដីវិនិច្ឆ័យ ក្នុងទុក្ខនិរោធសច្ច គឺបណ្ឌិត គប្បីជ្រាបដូចតទៅ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ការរំលត់នៃសមុទយៈ ដោយន័យថា* “យោ តស្សាយេវ តណ្ហា” *ដូច្នេះជាដើម ។ មានពាក្យសួរថា “ព្រោះហេតុអ្វី បានជាសមុទយនិរោធនោះ គឺព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ” ។ ឆ្លើយដោះស្រាយថា “ការរំលត់ទុក្ខ កើតមាន ព្រោះការរំលត់សមុទយៈ, មែនពិត ទុក្ខ រមែងរំលត់ទៅ ព្រោះការរំលត់ទៅនៃសមុទយៈ, មិនមែនដោយហេតុដទៃទៀតឡើយ ។ ព្រោះហេតុនោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយថា :*

> ដើមឈើ កាលបើឫសនៅមាំ មិនមានសេចក្ដីអន្តរាយ បើទុកជាត្រូវបុគ្គលកាត់ហើយ ក៏គង់តែដុះឡើងវិញបានទៀត យ៉ាងណាមិញ, ទុក្ខនេះក៏យ៉ាងនោះដែរ កាលបើអកុសលធម៌ជាគ្រឿងដេកត្រាំ គឺតណ្ហា ដែលបុគ្គលមិនទាន់បានដកចេញហើយ (ដោយអរហត្តមគ្គញ្ញាណ) ក៏រមែងកើតឡើងរឿយៗ ។

*សេចក្ដីទុក្ខ រមែងរំលត់ ព្រោះរំលត់នៃសមុទយៈនុ៎ះឯង ដូចបានពោលមកហើយ ព្រោះហេតុណា, ព្រោះហេតុនោះ ព្រះមានព្រះភាគ កាលទ្រង់សំដែងនូវការរំលត់នៃទុក្ខ ទើបទ្រង់សំដែង ដោយការរំលត់នៃសមុទយៈហ្នឹងឯង ។*

*សេចក្ដីពិតថា ព្រះតថាគតទាំងឡាយ ជាអ្នកមានការប្រព្រឹត្តិស្មើដោយសត្វសីហៈជាប្រក្រតី ។ ព្រះតថាគតទាំងឡាយនោះ កាលរំលត់*

នូវសេចក្តីទុក្ខផង កាលសំដែងប្រាប់នូវធម៌ជាគ្រឿងរំលត់ នូវសេចក្តីទុក្ខផង ឈ្មោះថា ប្រតិបត្តិក្នុងហេតុ មិនឈ្មោះថា ប្រតិបត្តិក្នុងផលទេ។ ប៉ុន្តែតិរ្ថិយ៍ទាំងឡាយ អ្នកមានប្រក្រតីប្រព្រឹត្តដូចជាសត្វក្អែ ។ តិរ្ថិយ៍ទាំងឡាយ កាលរំលត់នូវសេចក្តីទុក្ខ និង សំដែងប្រាប់ធម៌ជាគ្រឿងរំលត់នូវសេចក្តីទុក្ខ ឈ្មោះថា ប្រតបត្តិ ក្នុងផល ដោយកិច្ចទាំងឡាយមានការសំដែងនូវអត្តកិលមថានុយោគជាដើម មិនឈ្មោះថា ប្រតិបត្តិក្នុងហេតុទេ ។

ប្រយោជន៍ ដោយការសំដែង នូវការរំលត់សេចក្តីទុក្ខ គឺបណ្ឌិតគប្បីជ្រាប ដោយអំណាចនៃការរំលត់នូវសមុទយៈ យ៉ាងនេះមុន ។

ចំណែកអត្ថាធិប្បាយ មានដូចតទៅនេះ ។ ពាក្យថា “តស្សាយេវ តណ្ហាយ” សេចក្តីថា នៃតណ្ហានោះ ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់ថា “បោនោព្ភវិកា” ដូច្នេះជាដើម ហើយទ្រង់ញែក ដោយអំណាចនៃហេតុ មានកាមតណ្ហាជាដើម ។

មគ្គ គឺព្រះមានព្រះភាគ ទ្រង់ត្រាស់ថា “វិរាគៈ” ។ ក៏ពាក្យថា “ព្រះអរិយសាវ័ក រមែងរួចស្រឡះព្រោះវិរាគៈ” គឺព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ។ ការរំលត់បង់(នូវតណ្ហា) ព្រោះវិរាគៈ ឈ្មោះថា ការរំលត់បង់(តណ្ហា) ព្រោះវិរាគៈ ។ ការរំលត់បង់(តណ្ហា) ព្រោះវិរាគធម៌ មិនឲ្យមានសល់ ព្រោះការដកឡើងនូវធម៌ជាគ្រឿងដេកត្រាំ ឈ្មោះថា ការរំលត់ (នូវតណ្ហា) ព្រោះវិរាគធម៌ មិនឲ្យសេសសល់ ។ ម្យ៉ាងវិញទៀត ការលះបង់ គឺព្រះមានព្រះភាគទ្រង់ត្រាស់ថា វិរាគៈ ។ ហេតុនោះ ក្នុងបទថា “អសេសវិរាគនិរោធោ” នេះ គឺបណ្ឌិត គប្បីឃើញការប្រកបសេចក្តីយ៉ាងនេះថា “ការលះ ដោយគ្មានសេសសល់ ការរំលត់ ដោយ



គ្មានសេសសល់” ដូច្នេះក៏បាន ។ តែបើពោល ដោយអត្ថ ពាក្យទាំងឡាយទាំងអស់នេះឯង ជាពាក្យសំរាប់ផ្លាស់ប្តូរគ្នា នៃនិព្វានសព្ទ ។ ព្រោះដោយបរមត្ថ ព្រះនិព្វាន គឺព្រះមានព្រះភាគត្រាស់ថា: ទុក្ខនិរោធ-អរិយសច្ចៈ ។ ក៏តណ្ហា រមែងស្រេកស្រុតផង រមែងរំលត់ផង ព្រោះអាស្រ័យ នូវព្រះនិព្វាននោះ ព្រោះហេតុណា, ព្រោះហេតុនោះ ព្រះនិព្វាននោះ ព្រះអង្គទ្រង់ត្រាស់ថា: វិរាគធម៌ផង និរោធធម៌ផង ។ មួយទៀត ធម៌ទាំងឡាយ មានការលះបង់ជាដើម នៃតណ្ហានោះ រមែងមានព្រោះអាស្រ័យនូវព្រះនិព្វាននោះឯង, មួយវិញទៀត ក៏បណ្តាអាល័យគឺកាមគុណទាំងឡាយ អាល័យសូម្បីមួយ ក៏មិនមាន ក្នុងព្រះនិព្វាននោះទេ ព្រោះហេតុណា, ព្រោះហេតុនោះ ព្រះនិព្វាននោះ គឺព្រះមានព្រះភាគទ្រង់ត្រាស់ថា: ចាគៈ, បដិនិស្សគ្គៈ, មុត្តិ, អនាលយៈ ។

ព្រះនិព្វាននោះនេះ មានការស្ងប់ស្ងាត់ ជាលក្ខណៈ, មានការមិនច្យុតជាកិច្ច ឬថា មានការធ្វើឲ្យស្រោលចិត្ត ជាកិច្ច, មិនមាននិមិត្ត ជាផល ឬថា មិនមានការយឺតយូរ ជាផល ។

(បញ្ហាស្តួតស្ទាញក្នុងរឿងព្រះនិព្វាន)

ប្រសិនបើអាចារ្យអ្នកចោទ គប្បីពោលចោទថា: ព្រះនិព្វាន មិនមានទាល់តែសោះ ព្រោះមិនមែនជារបស់ ដែលបុគ្គលគប្បីរកបាន ដូចជាស្នែង នៃទន្សាយនោះឡើយ ។ អាចារ្យអ្នកឆ្លើយ គប្បីឆ្លើយដោះស្រាយថា ព្រះនិព្វាន មិនមែនមិនមានទេ ព្រោះព្រះនិព្វាននោះ ជាគុណជាតគឺបុគ្គលគប្បីកំណត់បាន ដោយឧបាយ ។ មែនពិត ព្រះនិព្វាននោះ គឺបុគ្គលកំណត់បាន ដោយឧបាយ ពោលគឺ សេចក្តីប្រតិបត្តិ ដ៏សមគួរដល់ព្រះនិព្វាននោះ ដូចជាលោកុត្តរចិត្ត របស់ពួកជនដទៃ គឺព្រះអរិយ

ទាំងឡាយ ដឹងបាន ដោយចេតោបរិញ្ញាណ យ៉ាងដូច្នោះឯង ។ ព្រោះហេតុនោះ ព្រះនិព្វាននោះ គឺអាចារ្យមិនគប្បីពោលថា: ព្រះនិព្វាន គ្មាន ព្រោះជាធម្មជាត គឺបុគ្គលមិនគប្បីកំណត់បានទេ ។ បញ្ជាក់សេចក្តីថា បុគ្គលមិនគួរពោលថា: ពួកពាលបុថុជ្ជន កំណត់មិនបាន នូវគុណជាតឯណា, គុណជាតនោះ មិនមានទេ ។ មួយវិញទៀត បុគ្គល មិនគប្បីពោលថា: និព្វាន មិនមានទេ ។ សួរថា: ព្រោះហេតុអ្វី? ។ ឆ្លើយថា: ព្រោះការដល់នូវភាវៈនៃសេចក្តីប្រតិបត្តិជារបស់អារ ។ សេចក្តីថា កាលបើព្រះនិព្វានមិនមាន ភាពនៃសេចក្តីប្រតិបត្តិ ដោយប្រពៃ ដែលលោកសង្គ្រោះ ក្នុងខន្ធ ៣ មានសីលខន្ធជាដើម ដែលមានសម្មាទិដ្ឋិស្ទុះទៅមុខជាសេចក្តីប្រតិបត្តិអារ រមែងមាន ។ ចំណែកសេចក្តីប្រតិបត្តិដោយប្រពៃនេះ មិនមែនជារបស់អារទេ ព្រោះជាហេតុឲ្យបានសំរេចដល់ព្រះនិព្វាន ។

បើអាចារ្យអ្នកចោទ គប្បីចោទថា: ការដល់នូវភាវៈនៃសេចក្តីប្រតិបត្តិជារបស់អារ មិនមានទេ ព្រោះភាវៈនៃសេចក្តីប្រតិបត្តិ ជាហេតុញុំាងសត្វឲ្យដល់នូវការមិនមាន ។ អាចារ្យអ្នកឆ្លើយ គប្បីពោលដោះសា ថា: ភាពមិនមាន ជាព្រះនិព្វាន មិនមានទេ ព្រោះមិនមាន នៃការដល់នូវព្រះនិព្វាន ក្នុងការមិនមាន ក្នុងអតីត និង អនាគត ។ បើអាចារ្យអ្នកចោទគប្បីចោទថា: សូម្បីការមិនមាន នៃខន្ធទាំងឡាយ ជាបច្ចុប្បន្នក៏ឈ្មោះថា ព្រះនិព្វានផងដែរ ។ អាចារ្យអ្នកឆ្លើយ គប្បីពោលដោះសាថា: ពាក្យដែលអ្នកពោលហើយ មិនសមគួរឡើយ ព្រោះព្រះនិព្វានមិនមែនមាន ព្រោះមិនមាន នៃខន្ធទាំងឡាយ ជាបច្ចុប្បន្នទេ, មួយទៀត ព្រោះកាលបើខន្ធ ក្នុងបច្ចុប្បន្ន មិនមាន, ព្រះនិព្វាន ក៏គង់ដល់នូវភាវៈ



ដែលមិនប្រព្រឹត្តទៅផងដែរ និង ព្រោះការមិនមានជាទោស ព្រោះការដល់នូវសឧបាទិសេសនិព្វានធាតុ ក្នុងខណៈនៃមគ្គចិត្ត ដែលអាស្រ័យនូវខន្ធបច្ចុប្បន្នផង ។ បើអាចារ្យអ្នកចោទ គប្បីចោទថា: ការមិនមានជាទោស ព្រោះភាវៈនៃកិលេសទាំងឡាយមិនមាន ក្នុងកាលនោះឬ ? ។ អាចារ្យអ្នកឆ្លើយ គប្បីឆ្លើយថា: ពាក្យដែលអ្នកពោលនោះ មិនត្រឹមត្រូវទេ ព្រោះការសំរេចអរិយមគ្គ ជាសភាវៈមិនមានប្រយោជន៍ ។ មែនពិត កាលបើហេតុយ៉ាងនេះមាន កិលេសទាំងឡាយ មិនមានសូម្បីក្នុងកាលមុន អំពីខណៈនៃអរិយមគ្គ ព្រោះហេតុនោះ អរិយមគ្គ ក៏ដល់នូវភាពជាគុណជាតមិនមានប្រយោជន៍ ព្រោះហេតុនោះ ពាក្យដែលអ្នកពោលនេះ យកជាការមិនបានទេ ។

ប្រសិនបើអាចារ្យអ្នកចោទ គប្បីពោលថា: ការអស់ទៅ (នៃរាគៈ, ទោសៈ និង មោហៈទាំងឡាយ) ឈ្មោះថា ព្រះនិព្វាន ព្រោះព្រះពុទ្ធដីកាមានជាអាទិ៍ថា: ម្នាលអាវុសោ! ការអស់ទៅនៃរាគៈ ណាហ្នឹងឯង ។ អាចារ្យអ្នកឆ្លើយ គប្បីពោលថា: ពាក្យដែលអ្នកពោលហើយនេះ មិនត្រឹមត្រូវទេ ព្រោះការដល់នូវព្រះអរហត្ត ដោយគ្រាន់តែការអស់ទៅប៉ុណ្ណោះទេ ។ សេចក្តីថា ព្រះអរហត្តនោះឯង គឺព្រះមានព្រះភាគ ទ្រង់សំដែងចេញហើយ ដោយន័យមានជាដើមថា: ម្នាលអាវុសោ ការអស់ទៅនៃរាគៈណាហ្នឹងឯង ។ នៅមានអ្វី(វិរុទ្ធ)តទៅទៀត គឺ ព្រោះទោស គឺព្រះនិព្វានប្រែជាធម្មជាតមានរយៈពេលដ៏ខ្លីជាដើម ។ មែនពិត កាលបើហេតុយ៉ាងនេះមាន ព្រះនិព្វាន រមែងដល់នូវកាលមួយរំពេចផង នូវលក្ខណៈនៃធម៌គឺបច្ច័យប្រជុំតាក់តែងហើយផង នូវភាវៈនៃព្រះនិព្វាន គឺបុគ្គលគប្បីត្រាស់ដឹង ដោយការមិនអើពើ ទៅដល់សេចក្តីព្យាយាម

ត្រូវផង។ មួយទៀត ព្រោះភាវៈនៃព្រះនិព្វានោះមានការប្រជុំតាក់តែងជាលក្ខណៈ ព្រះនិព្វាន រមែងដល់នូវការរាប់បញ្ចូលហើយក្នុងសង្ខារដែលមានបច្ច័យតាក់តែងហើយផង, ព្រោះភាវៈនៃព្រះនិព្វាននោះ ដល់ហើយនូវការរាប់បញ្ចូល ក្នុងសង្ខារដែលមានបច្ច័យប្រជុំតាក់តែងហើយ ព្រះនិព្វាន ក៏ដល់នូវភាវៈគឺត្រូវភ្លើងទាំងឡាយ មានរាគៈជាដើម ដុតពេលហើយ និង ព្រោះភាវៈនៃព្រះនិព្វានជាធម្មជាត ត្រូវភ្លើងរាគៈជាដើម ដុតពេលហើយ ព្រះនិព្វាន ក៏ដល់នូវភាវៈ គឺជាទុក្ខ ថែមទៀតផង ។

ប្រសិនបើអាចារ្យអ្នកចោទ គប្បីចោទថាៈ ឈ្មោះថា ការប្រព្រឹត្តិទៅដ៏ក្រៃលែង ចាប់ផ្ដើមអំពីការអស់ទៅ (នៃអកុសលធម៌ទាំងឡាយមានរាគៈជាដើម) ឯណា មិនមានទេ, ទោស ក៏មិនមានទេ ព្រោះភាវៈនៃការអស់ទៅនោះជាព្រះនិព្វាន ។ អាចារ្យអ្នកឆ្លើយ គប្បីដោះស្រាយថា ពាក្យដែលអ្នកពោលហើយ មិនត្រឹមត្រូវទេ ព្រោះការមិនមាននៃការអស់ទៅ ប្រាកដដូច្នោះផង ព្រោះកាលបើមានការអស់ទៅនោះពិត ក៏មិនបានប្រព្រឹត្តកន្លងនូវទោស មានប្រការ ដែលយើងពោលហើយនោះផង ព្រោះអរិយមគ្គ នឹងដល់ នូវភាវៈជាព្រះនិព្វានផង ។ ព្រោះថាអរិយមគ្គ ញុំាងទោសទាំងឡាយឲ្យអស់ទៅ ព្រោះហេតុនោះ (អរិយមគ្គនោះ) គឺព្រះមានព្រះភាគ ទ្រង់ត្រាស់ថា អស់ទៅ, ក៏ចាប់ផ្ដើមអំពីការអស់ទៅនោះ ការប្រព្រឹត្តិទៅនៃទោសទាំងឡាយដ៏ក្រៃលែង ពុំមានទេ ។ តែព្រោះព្រះនិព្វាននោះ ជាឧបនិស្ស័យ នៃការអស់ទៅ បានដល់ការរំលត់នូវការមិនកើតឡើង ដោយបរិយាយ ។ ឧបនិស្ស័យនៃព្រះនិព្វានណា មាន, ព្រះនិព្វាននោះ គឺព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយថា ៈ ការអស់ទៅ ដោយក្បែរនៃការអស់ទៅនោះ ។



ប្រសិនបើមានចម្ងល់ថាៈ ព្រោះហេតុអ្វី បានជាព្រះនិព្វាននោះ គឺព្រះមានជោគ មិនទ្រង់សំដែង ដោយសរុបតែម្ដងទៅ? ។ ចម្លើយថា ព្រោះភាវៈនៃព្រះនិព្វាននោះ ជាធម៌ល្អិតក្រៃពេក ។ ក៏ភាវៈនៃព្រះនិព្វាននោះជាធម៌ល្អិតក្រៃលែង សំរេចហើយ ព្រោះជាគ្រឿងនាំមកនូវសេចក្ដីខ្វល់ខ្វាយមានប្រមាណតិច នៃព្រះមានព្រះភាគ និង ព្រោះភាវៈនៃព្រះនិព្វាន ជាធម៌គឺបុគ្គលគប្បីឃើញ ដោយចក្ខុដ៏ប្រសើរផង ។ ព្រោះហេតុដូច្នោះ ព្រះនិព្វាននោះនេះ ជាធម្មជាតមិនទូទៅ ព្រោះជាធម៌គឺបុគ្គលអ្នកព្រមព្រៀងដោយមគ្គគប្បីដល់ ឈ្មោះថា មិនមានដែនកើត ព្រោះការមិនមានខាងដើម និង ខាងចុង ។

ប្រសិនបើមានចម្ងល់ថាៈ ព្រះនិព្វាននោះ មិនមែនជាធម្មជាតមិនមានដែនជាទីកើត ព្រោះកាលបើមានមគ្គ ទើបព្រះនិព្វានមាន។ ចម្លើយថាៈ មិនមែនដូច្នោះទេ ព្រោះភាវៈនៃព្រះនិព្វាន មិនមែនជាធម្មជាត គឺមគ្គ គប្បីឲ្យកើតឡើងបានទេ ។ មែនពិត ព្រះនិព្វាននេះ ជាធម្មជាតគឺបុគ្គលគប្បីដល់ដោយមគ្គតែម្ដង មិនមែនមគ្គគប្បីឲ្យកើតឡើងបានទេ ព្រោះហេតុនោះ ព្រះនិព្វាននោះ ទើបបានឈ្មោះថា មិនមានដែនកើតដោយពិត ។ (ព្រះនិព្វាននោះ) មិនមានជរា និង មរណៈ ព្រោះភាវៈនៃព្រះនិព្វាននោះ ជាគុណជាតមិនមានកន្លែងជាទីកើត ។ ព្រះនិព្វាននោះឈ្មោះថា ទៀង ព្រោះមិនមានជរា និង មរណៈ ជាទីដែនកើត ។

ប្រសិនបើមានចម្ងល់ថា ៈ ការដល់នូវភាវៈ នៃធូលីទាំងឡាយមានធូលីឈ្មោះអណូជាដើម ជារបស់ទៀង ដូចជាកិរិយាដល់នូវព្រះនិព្វាន ថា ជារបស់ទៀងដែរ (មែនទេ?) ។ ចម្លើយថា ៈ អណូជាដើមនោះ មិនឈ្មោះថា ជារបស់ទៀងទេ ព្រោះអណូនោះ មិនមានហេតុ ។

ប្រសិនបើមានចម្ងល់ថា: ធូលីទាំងឡាយ មានធូលីឈ្មោះថាអណូជាដើមនោះ ជាគុណជាតទៀង ព្រោះភាវៈនៃព្រះនិព្វាន ក៏ជាធម្មជាតទៀងដែរ ។ ចម្លើយថា: ពាក្យដែលលោកពោលហើយ មិនទាន់ត្រឹមត្រូវទេ ព្រោះរបស់ទាំងនោះ មិនចូលទៅជិតដល់នូវលក្ខណៈនៃហេតុ ។ ប្រសិនបើមានចម្ងល់ថា: ធូលីទាំងឡាយ មានធូលីឈ្មោះអណូជាដើមនោះ ជាធម្មជាតទៀង ដូចជាព្រះនិព្វាន ព្រោះមិនមាននៃហេតុ ដែលឲ្យកើតឡើងជាដើម (មែនឬ?) ។ ចម្លើយថា : ពាក្យដែលលោកពោលហើយ មិនទាន់ត្រឹមត្រូវទេ ព្រោះភាវៈនៃធូលីទាំងឡាយ មានធូលីឈ្មោះថាអណូ ជាដើមនោះ មិនសំរេចផលទេ ។

ក៏ព្រះនិព្វាននេះឯង ឈ្មោះថា ទៀង តាមសភាពដ៏គួរដល់ពាក្យដែលយើងពោលហើយ ឈ្មោះថា មិនមានរូប ព្រោះកន្លងបង់នូវភាវៈនៃរូប, (បើពោល) តាមបរមត្ថ ព្រះនិព្វាន ឈ្មោះថា មិនមានក៏មិនមែន ព្រោះភាវៈនៃព្រះនិព្វាននោះ គឺបុគ្គលគប្បីត្រាស់ដឹងបាន ដោយញាណដ៏វិសេស ដែលសំរេចដោយសេចក្តីព្យាយាមមិនធូរពេកផង និង ព្រោះជាព្រះពុទ្ធដីកានៃព្រះសព្វញ្ញូផង ។ សមដូចជាព្រះពុទ្ធដីកានេះ គឺព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយថា: ម្នាលភិក្ខុទាំងឡាយ! ធម្មជាតដែលមិនកើត មិនប្រាកដ គឺបុគ្គលធ្វើមិនកើត មិនមានបច្ច័យប្រជុំតាក់តែងបាន រមែងមាន ។

ប្រធាននៃការពោលវិនិច្ឆ័យ ក្នុងទុក្ខនិរោធនិទ្ទេស ចប់ត្រឹមនេះ ។

(ទុក្ខនិរោធគាមិនីបដិបទានិទ្ទេស)

(៣៨៥) ក៏ធម៌ទាំងឡាយ៨ យ៉ាង គឺព្រះមានព្រះភាគ ទ្រង់ត្រាស់សំដែងហើយ ក្នុងទុក្ខនិរោធគាមិនីបដិបទានិទ្ទេស ប្រាកដច្បាស់ហើយ



ដោយសេចក្តី សូម្បីក្នុងខន្ធនិទ្ទេស ក៏ប្រាកដដែរ ។ តែក្នុងសច្ចនិទ្ទេសនេះ យើងនឹងពោល ដើម្បីញ៉ាំងកុលបុត្រ ឲ្យយល់ដឹង នូវសេចក្តីប្លែកគ្នា នៃធម៌ទាំងឡាយនោះ ដែលប្រព្រឹត្តទៅ ក្នុងខណៈតែមួយ ។

(សម្មាទិដ្ឋិ)

មែនពិត បើពោលដោយសង្ខេប បញ្ញាចក្ខុ របស់ព្រះយោគីអ្នកប្រតិបត្តិហើយ ដើម្បីចាក់ធ្លុះនូវសច្ចៈ ៤ មានព្រះនិព្វានជាអារម្មណ៍ ជាគ្រឿងដកឡើងព្រម នូវធម៌ជាគ្រឿងដេកត្រាំ គឺអវិជ្ជា ឈ្មោះថា សម្មាទិដ្ឋិ ។ សម្មាទិដ្ឋិនោះ មានការឃើញត្រូវ ជាលក្ខណៈ, មានការប្រកាសនូវសេចក្តីទៀងទាត់ ជាកិច្ច, មានការកំចាត់បង់ នូវភាពងងឹតពោលគឺអវិជ្ជា ជាផល ។

(សម្មាសង្កប្បៈ)

កិរិយាស្ទុងចុះ នៃចិត្ត ក្នុងផ្លូវនៃព្រះនិព្វាន ដ៏សម្បយុត្តហើយ ដោយសម្មាទិដ្ឋិនោះ ជាគ្រឿងផ្តាច់ផ្តិលនូវការត្រិះរិះខុស នៃបុគ្គលអ្នកមានទិដ្ឋិពេញលេញហើយ យ៉ាងដូច្នោះ ឈ្មោះថា សម្មាសង្កប្បៈ ។ សម្មាសង្កប្បៈនោះ មានការស្ទុងចុះនូវចិត្តត្រូវ ជាលក្ខណៈ, មានការទំលុះនូវឈាន ជាកិច្ច, មានការលះបង់នូវការត្រិះរិះខុស ជាផល ។

(សម្មាវាចា)

ការវៀរចាកមិច្ឆាវាចា ដ៏សម្បយុត្តហើយ ដោយសម្មាសង្កប្បៈនោះ ជាគ្រឿងដកឡើងនូវវចីទុច្ចរិត នៃព្រះយោគីអ្នកឃើញដូច្នោះផង និង ត្រិះរិះដូច្នោះផង ឈ្មោះថា សម្មាវាចា ។ សម្មាវាចានោះ មានការកំណត់ ជាលក្ខណៈ, មានការវៀរចាក (វចីទុច្ចរិត) ជាកិច្ច, មានការលះបង់នូវមិច្ឆាវាចា ជាផល ។

(សម្មាកម្មន្តៈ)

ចេតនា ជាហេតុវៀរចាកកាយទុច្ចរិត មានបាណាតិបាតជាដើម ដ៏ប្រកបព្រមហើយ ដោយសម្មាវាចានោះ កាត់ផ្តាច់មិច្ឆាកម្មន្តៈ បាន យ៉ាងដាច់ខាត នៃព្រះយោគីអ្នកវៀរ ដោយប្រការដូច្នោះ ឈ្មោះថា សម្មាកម្មន្តៈ ។ សម្មាកម្មន្តៈនោះ មានការតាំងកល់ខ្លួន ជាលក្ខណៈ, មាន ការវៀរចាក(មិច្ឆាកម្មន្តៈ) ជាកិច្ច, មានការលះបង់មិច្ឆាកម្មន្តៈ ជាផល ។

(សម្មាអាជីវៈ)

ក៏ការវៀរចាកមិច្ឆាអាជីវៈ ជាសេចក្តីស្អាតបរិសុទ្ធ នៃសម្មាវាចា និង សម្មាកម្មន្តៈទាំងឡាយនោះ ដ៏សម្បយុត្តហើយដោយសម្មាវាចានោះ ចូលទៅកាត់បង់នូវបាបធម៌មានកុហនាជាដើម របស់ព្រះយោគាវចរនោះ ឯណា, វិរតិនោះ ឈ្មោះថា សម្មាអាជីវៈ ។ សម្មាអាជីវៈនោះ មានការ ផូរផង់ ជាលក្ខណៈ, មានការញុំាងអាជីវៈជាគ្រឿងត្រឹមត្រូវ ឲ្យប្រព្រឹត្ត ទៅតាមធម៌ ជាកិច្ច, មានការលះបង់នូវមិច្ឆាអាជីវៈ ជាផល ។

(សម្មាវាយាមៈ)

កាលបើដូច្នោះ ការប្រារព្ធនូវសេចក្តីព្យាយាមណា ដ៏សមគួរដល់ សម្មាអាជីវៈនោះ ប្រកបព្រមហើយដោយសម្មាអាជីវៈនោះ ជាគ្រឿង កាត់ផ្តាច់នូវភាពនៃសេចក្តីខ្ជិលច្រអូស នៃព្រះយោគីនោះ ដែលតម្កល់ នៅមាំហើយ ក្នុងភូមិនៃសីល ពោលគឺវាចាត្រូវ ការងារត្រូវ និង ការ ចិញ្ចឹមជីវិតត្រូវ, ការប្រារព្ធនូវព្យាយាមនុ៎ះ ឈ្មោះថា សម្មាវាយាមៈ ។ សម្មាវាយាមៈនោះ មានកិរិយាផ្គង (នូវចិត្ត) ឡើង ជាលក្ខណៈ មាន សម្មប្បធាន ៤ ដែលញុំាងអកុសលធម៌ដែលមិនទាន់កើតឡើង មិនឲ្យ កើតឡើងបានជាដើម ជាកិច្ច, មានការលះបង់មិច្ឆាវាយាមៈ ជាផល ។



(សម្មាសតិ)

ការមិនភ្លេចប្រឡំនៃចិត្ត ដ៏សម្បយុត្តហើយ ដោយសម្មាវាយាមៈ នោះឯង កំចាត់បង់បោលនូវមិច្ឆាសតិ នៃព្រះយោគីនោះអ្នកព្យាយាម យ៉ាងនេះ ឈ្មោះថា សម្មាសតិ ។ សម្មាសតិនោះ មានការតាំង(សតិ) ទុក ជាលក្ខណៈ, មានការមិនវង្វេង ជាកិច្ច, មានការលះបង់នូវមិច្ឆាសតិ ជាផល ។

(សម្មាសមាធិ)

ភាពនៃចិត្តមានអារម្មណ៍តែមួយ ដែលសម្បយុត្តហើយ ដោយ សម្មាសតិនោះ កំចាត់បង់នូវមិច្ឆាសមាធិ នៃព្រះយោគីដែលមានចិត្ត គឺសតិដ៏ក្រៃលែងឃុំគ្រង យ៉ាងនេះ ឈ្មោះថា សម្មាសមាធិ ។ សម្មា-សមាធិនោះ មានការមិនរាយមាយ(នៃចិត្ត) ជាលក្ខណៈ, មានការតាំង (ចិត្ត)នៅមាំ ជាកិច្ច, មានការលះបង់នូវមិច្ឆាសមាធិ ជាផល ដូច្នេះឯង ។

នេះ ជាន័យ ក្នុងទុក្ខនិរោធគាមិនីបដិបទានិទ្ទេស ។

សេចក្តីវិនិច្ឆ័យ នៃធម៌ទាំងឡាយមានជាតិជាដើម ក្នុងអរិយសច្ចៈ នេះ បណ្ឌិតគប្បីជ្រាប ដូចបានពោលមកយ៉ាងនេះឯង ។

(ដោយកិច្ចញាណ)

ត្រង់បទថា “ដោយកិច្ចនៃញាណ” សេចក្តីថា បណ្ឌិត គប្បីជ្រាប សេចក្តីវិនិច្ឆ័យ សូម្បីដោយកិច្ចនៃសច្ចញាណ ។ ក៏សច្ចញាណ មាន ពីរយ៉ាង គឺ: ញាណសំរាប់ដឹងតាម ១ ញាណសំរាប់ត្រាស់ដឹង ១ ។ បណ្តាញាណទាំងពីរយ៉ាងនោះ អនុពោធិញាណ ជាលោកិយៈ ប្រព្រឹត្ត ទៅ ក្នុងនិរោធសច្ចផង ក្នុងមគ្គសច្ចផង ដោយអំណាចនៃកិច្ចមានការ ស្តាប់ជាដើម ។ បដិវេធញាណ ជាលោកុត្តរៈ ធ្វើនូវនិរោធសច្ច ឲ្យ

ជាអារម្មណ៍ ហើយចាក់ធ្លុះនូវសច្ចៈទាំង ៤ ដោយកិច្ច ។ សមដូចជា (ព្រះមានព្រះភាគ) ទ្រង់ត្រាស់ហើយថាៈ "ម្នាលភិក្ខុទាំងឡាយ បុគ្គលណា ឃើញនូវសេចក្តីទុក្ខ បុគ្គលនោះ ឈ្មោះថាឃើញនូវទុក្ខសមុទយៈដែរ, បុគ្គលណា ឃើញនូវទុក្ខនិរោធហ្នឹងឯង បុគ្គលនោះ ឈ្មោះថាឃើញនូវទុក្ខនិរោធគាមិនីបដិបទាតែម្តង" ដូច្នេះជាដើម, ព្រោះហេតុនោះ ពាក្យទាំងអស់ បណ្ឌិត គប្បី(នាំយកមក)ពោលផងចុះ ។ ក៏កិច្ចនោះនៃបដិវេធញ្ញាណនោះ នឹងមានមកប្រាកដ ក្នុងញាណទស្សនវិសុទ្ធិ។ ក៏សច្ចញ្ញាណ ដែលជាលោកិយៈនេះឯណា, ក្នុងលោកិយញាណនោះ ទុក្ខញ្ញាណ ញ៉ាំងសក្កាយទិដ្ឋិដែលប្រព្រឹត្តទៅដោយអំណាចនៃការគ្របសង្កត់នូវកិលេស ដែលប្រយិតប្រតោង ឲ្យត្រឡប់វិញ ។ សមុទយ-ញ្ញាណ ញ៉ាំងឧច្ឆេទទិដ្ឋិ ឲ្យត្រឡប់ចេញ ។ និរោធញ្ញាណ ញ៉ាំងសស្សតទិដ្ឋិ ឲ្យត្រឡប់វិញ ។ មគ្គញ្ញាណ ញ៉ាំងអកិរិយទិដ្ឋិ ឲ្យត្រឡប់វិញ ។ម្យ៉ាងទៀត ទុក្ខញ្ញាណ ញ៉ាំងសេចក្តីប្រតិបត្តិឃ្លៀងឃ្លាត ក្នុងផលពោលគឺសេចក្តីសំគាល់ថា : ទៀង, ល្អ, ជាសុខ និង ជាខ្លួនប្រាណ ក្នុងខន្ធទាំងឡាយ ដែលទៅប្រាសហើយចាកការទៀង ការល្អ, ជាសុខ, និង ជាខ្លួនប្រាណ ឲ្យត្រឡប់វិញ ។ សមុទយញ្ញាណ ញ៉ាំងសេចក្តីប្រតិបត្តិខុស ក្នុងហេតុ ដែលប្រព្រឹត្តទៅ ដោយការរាប់អានចំពោះហេតុ ក្នុងការមិនមែនជាហេតុថាៈ លោកប្រព្រឹត្តទៅដោយហេតុទាំងឡាយ មានឥស្សរជន, ប្រធាន, កាល និង សភាពជាដើម ឲ្យត្រឡប់វិញ ។ និរោធញ្ញាណ ញ៉ាំងសេចក្តីប្រតិបត្តិឃ្លៀងឃ្លាត ក្នុងនិរោធសច្ចដែលជាគ្រឿងប្រកាន់ថា លែងប្រព្រឹត្តទៅបាន ក្នុងហេតុទាំងឡាយ មានអរូបលោក និង លោកជាកំពូលជាដើម ឲ្យត្រឡប់វិញ ។



មគ្គញ្ញាណ ញ៉ាំងសេចក្តីប្រតិបត្តិឃ្លៀងឃ្លាត ក្នុងឧបាយដែលប្រព្រឹត្តទៅហើយ ដោយអំណាចនៃការប្រកាន់ ក្នុងផ្លូវនៃសេចក្តីមិនបរិសុទ្ធិផ្សេងដោយកាមសុខល្លិកានុយោគ និង អត្តកិលមថានុយោគ ថា ជាផ្លូវនៃសេចក្តីបរិសុទ្ធិ ឲ្យត្រឡប់វិញ ។ ព្រោះហេតុនោះ ពាក្យជាគាថានេះ គឺព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយថា :

នរជនណាមិនដឹងច្បាប់នូវសច្ចៈទាំងឡាយ ត្រឹម
ណា, នរជននោះតែងភ័ន្តច្រឡំ ក្នុងលោកគឺទុក្ខ
សច្ចផង ក្នុងដែនជាទីកើតនៃលោក គឺសមុទយ
សច្ចផង ក្នុងកិរិយាវិនាសទៅនៃលោកគឺនិរោធ
សច្ចផង ក្នុងឧបាយជាគ្រឿងសំរេចព្រះនិព្វន
នោះផង ត្រឹមនោះ ។

សេចក្តីវិនិច្ឆ័យ ដោយកិច្ចនៃញាណ ក្នុងអរិយសច្ចនេះ គឺបណ្ឌិតគប្បីជ្រាប យ៉ាងនេះឯង ។

(ដោយប្រភេទនៃធម៌ក្នុងអរិយសច្ច)

(៣៤៦) សេចក្តីវិនិច្ឆ័យ ត្រង់បទទាំងឡាយថា "អន្តោគតានំ បភេទា" គឺបណ្ឌិត គប្បីជ្រាបដូចតទៅនេះ ។ លើកលែងតែតណ្ហា និង អនាសវធម៌ទាំងឡាយចេញទៅ ធម៌ទាំងពួងទាំងឡាយ ដ៏សេស រាប់ចូលក្នុងទុក្ខសច្ចៈ ។ ធម៌ទាំងឡាយ ដែលផ្ទុយគ្នាអំពីតណ្ហា ៣៦ ឈ្មោះថា លាយចម្រុះគ្នា ខាងក្នុងមគ្គសច្ច ។ និរោធសច្ចៈ មិនច្រឡំនឹងគេឡើយ ។ អង្គនៃធម៌ដែលជាគ្រឿងត្រាស់ដឹង គឺ វិមំសិទ្ធិបាទ បញ្ញិន្ទ្រិយ, បញ្ញាពលៈ និង ធម្មវិចយៈទាំងឡាយ រួមចូល ក្នុងមគ្គសច្ច ដោយមានសម្មាទិដ្ឋិជាប្រធាន, កុសលវិតក្កៈទាំងឡាយមានេក្ខម្មវិតក្កៈ

ជាដើម រាប់បញ្ចូលទៅក្នុងមគ្គសច្ចៈ ដោយការសំដែងអាងដល់សម្មា-សង្កប្បៈ, វចីសុចរិតទាំងឡាយ ៤ រាប់បញ្ចូលទៅ ក្នុងមគ្គសច្ចៈ ដោយកិរិយាសំដែងអាងដល់សម្មាវាចា, កាយសុចរិតទាំងឡាយបី រាប់ចូលក្នុងមគ្គសច្ចៈ ដោយការសំដែងអាងដល់សម្មាកម្មន្តៈ, អប្បិច្ឆតាគុណក្តី សន្តុដ្ឋិតាគុណក្តី រាប់ចូលក្នុងមគ្គសច្ចៈ ដោយប្រធាន គឺសម្មាអាជីវៈ, ម្យ៉ាងទៀត សទ្ធិន្ទ្រិយ សទ្ធាពល និងឆន្ទិទ្ធិបាទទាំងឡាយ រាប់បញ្ចូលក្នុងមគ្គសច្ច ព្រោះសម្មាវាចា, សម្មាកម្មន្តៈ និង សម្មាអាជីវៈទាំងអស់នុ៎ះឯងជាអរិយកន្តសីល (សីលជាទីស្រឡាញ់នៃព្រះអរិយ) និង ព្រោះអរិយកន្តសីល ជាធម៌ដែលបុគ្គលគួរទទួលដោយដៃគឺសទ្ធា ព្រោះភាវៈនៃសទ្ធិន្ទ្រិយ, សទ្ធាពលៈ និង ឆន្ទិទ្ធិបាទទាំងនោះមាន សីលទើបមាន, សម្មប្បធាន ៤, វិរិយិទ្ធិបាទ, វិរិយិន្ទ្រិយ, វិរិយពលៈ និង វិរិយ-សម្ពោជ្ឈង្គទាំងឡាយ រាប់ចូលក្នុងមគ្គសច្ចៈ ដោយមានសម្មាវាយាមៈជាសំអាង, សតិប្បដ្ឋាន ៤, សតិន្ទ្រិយ, សតិពលៈ និងសតិសម្ពោជ្ឈង្គ រាប់បញ្ចូលក្នុងមគ្គសច្ចៈ ដោយសំអាងលើសម្មាសតិ, សមាធិទាំង ៣ មានសវិតក្កៈ និង សវិចារៈជាដើម, ចិត្តសមាធិ, សមាធិន្ទ្រិយ, សមាធិពលៈ, បីតិសម្ពោជ្ឈង្គ, បស្សទ្ធិសម្ពោជ្ឈង្គ, សមាធិសម្ពោជ្ឈង្គ និង ឧបេក្ខាសម្ពោជ្ឈង្គទាំងឡាយ រាប់បញ្ចូលក្នុងមគ្គសច្ចៈ ដោយសំអាងលើសម្មាសមាធិ ។

សេចក្តីវិនិច្ឆ័យ ដោយប្រភេទនៃធម៌ទាំងឡាយ ដែលតាំងនៅហើយ ពួដ៏ខាងក្នុងសច្ចនិទ្ទេសនេះ គឺបណ្ឌិតគប្បីជ្រាប យ៉ាងនេះ ។

**(ដោយឧបមា)**

(៣៤៧) សេចក្តីវិនិច្ឆ័យ ត្រង់បទថា "ឧបមាតោ" គឺបណ្ឌិត គប្បីជ្រាបដូចតទៅនេះ ។ សេចក្តីប្រៀបថា ទុក្ខសច្ចៈ គឺបុគ្គលគប្បីយល់ថាដូចជាគ្រឿងផ្ទុក ។ សមុទយសច្ចៈ គឺបណ្ឌិតគប្បីយល់ថា ដូចជាការកាន់យកនូវបន្ទុក ។ និរោធសច្ចៈ គឺបណ្ឌិតយល់ថា ដូចជាការដាក់ចុះនូវបន្ទុក ។ មគ្គសច្ចៈ បណ្ឌិតគប្បីយល់ថា ដូចជាឧបាយជាគ្រឿងដាក់ចោលនូវបន្ទុក។ ម្យ៉ាងទៀត ទុក្ខសច្ច ទុកដូចជារោគ ។ សមុទយសច្ចៈ ដូចជាហេតុនៃរោគ ។ និរោធសច្ចៈ ទុកដូចជាការរម្ងាប់រោគ។ មគ្គសច្ចៈ ទុកដូចជាថ្នាំ ។ ម្យ៉ាងវិញទៀត ទុក្ខសច្ចៈ ទុកដូចជាបាយដែលបុគ្គលរកបានដោយលំបាក ។ សមុទយសច្ចៈ ទុកដូចជាភ្លៀងធ្លាក់មិនល្អ ។ និរោធសច្ចៈ ទុកដូចជាបាយដែលបុគ្គលរកបានងាយ ។ មគ្គសច្ចៈ ទុកដូចជាភ្លៀងបរិបូរ ។

ម្យ៉ាងវិញទៀត អរិយសច្ចៈទាំងឡាយនេះ គឺបណ្ឌិត គប្បីជ្រាបដោយសេចក្តីប្រៀបធៀប ព្រោះប្រកបដោយបុគ្គលមានពៀរ, ហេតុជាទីតាំងនៃពៀរ, កិរិយាដកឡើងនូវពៀរ និង ឧបាយជាគ្រឿងដកឡើងនូវពៀរទាំងឡាយផង ដោយឈើដែលមានពិស, ឫសនៃឈើ, ការផ្តាច់បង់ នូវឫសនៃឈើ និង ឧបាយជាគ្រឿងផ្តាច់បង់ នូវឫសនៃឈើនោះផង, ដោយភ័យ, ហេតុជាទីតាំងនៃភ័យ, ការមិនមាននៃភ័យ និង ឧបាយជាគ្រឿងសំរេច នូវការមិនមានភ័យនោះផង ដោយត្រើយខាងអាយ, អន្លង់ដ៏ធំ, ត្រើយខាងនាយ និង ការព្យាយាមដើម្បីឲ្យបានដល់ត្រើយនោះផង ។

សេចក្តីវិនិច្ឆ័យ ដោយការឧបមា គឺបណ្ឌិត គប្បីជ្រាប ក្នុងសច្ចនិទ្ទេសនុ៎ះ ដូចបានពណ៌នាមកនេះឯង ។

**(ដោយចតុក្កៈ)**

(៣៤៨) សេចក្តីវិនិច្ឆ័យ ត្រង់បទថា "ចតុក្កតោ" គឺបណ្ឌិត គប្បីជ្រាបដូចតទៅនេះ ។ បណ្តាសច្ចៈទាំង ៤ នេះ សេចក្តីទុក្ខ មិនចាត់ថាជាអរិយសច្ច ក៏មានដែរ ។ អរិយសច្ច មិនចាត់ថា ជាទុក្ខ ក៏មាន ។ សច្ចៈ ឈ្មោះថា ជាទុក្ខផង ឈ្មោះថា ជាអរិយសច្ចផង ក៏មាន ។ សច្ចៈ មិនចាត់ថា ជាទុក្ខផង មិនចាត់ថា ជាអរិយសច្ចៈផង ក៏មាន ។ ន័យក្នុងអរិយសច្ចៈទាំងឡាយ មានសមុទយសច្ចៈជាដើម ក៏មានន័យដូចគ្នានេះដែរ ។

បណ្តាចតុក្កៈនោះ ធម៌ទាំងឡាយ ដ៏សម្បយុត្តហើយដោយមគ្គផង សាមញ្ញផលទាំងឡាយផង ឈ្មោះថា ជាទុក្ខ ព្រោះភាវៈនៃទុក្ខសច្ចៈនោះ ជាទុក្ខប្រចាំសង្ខារ ព្រោះព្រះពុទ្ធដីកាថា "ធម្មជាតិណា មិនទៀង ធម្មជាតិនោះ ជាទុក្ខ" ដូច្នេះជាដើម, (ប៉ុន្តែ) មិនមែនជាអរិយសច្ចទេ, និរោធ ឈ្មោះថា ជាអរិយសច្ចៈ តែមិនមែនជាទុក្ខទេ ។ ចំណែកខាងអរិយសច្ច ២ ក្រៅពីនេះ ចាត់ថា ជាទុក្ខ ក៏មាន ព្រោះមិនទៀង, ក៏ព្រះយោគី ប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់នៃព្រះមានព្រះភាគ ដើម្បីកំណត់ដឹងនូវសេចក្តីទុក្ខណា មិនមែនជាទុក្ខ ដោយភាពជាទុក្ខ យ៉ាងដូច្នោះឡើយ ។ ចំណែកឧបាទានក្ខន្ធ ៥ ឈ្មោះថា ជាទុក្ខផង ឈ្មោះថា ជាអរិយសច្ចៈផង លើកលែងតែតណ្ហាចេញ ដោយអាការៈទាំងពួង ។ ធម៌ទាំងឡាយដែលសម្បយុត្តដោយមគ្គក្តី សាមញ្ញផលទាំងឡាយក្តី មិនចាត់ថា ជាទុក្ខទេ ព្រោះភាវៈជាទុក្ខសំរាប់កំណត់ដឹង នៃព្រះយោគីអ្នកប្រព្រឹត្តនូវព្រហ្មចរិយធម៌ ក្នុងសំណាក់ នៃព្រះមានព្រះភាគ មិនចាត់ថា ជាអរិយសច្ចៈទេ ។

សេចក្តីវិនិច្ឆ័យ សូម្បីដោយប្រមាណ ៤ ក្នុងអរិយសច្ចនេះ គឺ



បណ្ឌិតគប្បីប្រកបហេតុគួរប្រកប ក្នុងសច្ចៈទាំងឡាយ មានសមុទយសច្ចៈ ជាដើម ហើយជ្រាប ដូចបានពោលមកនេះឯង ។

(ដោយសោះសូន្យ)

(៣៤៩) សេចក្តីវិនិច្ឆ័យ ត្រង់បទនេះថា "សុញ្ញតេកវិធានទីហិ" គឺបណ្ឌិត គប្បីជ្រាបដូចតទៅ ។ សេចក្តីវិនិច្ឆ័យ គឺខ្ញុំនឹងពោលដោយថាជារបស់សូន្យជាមុន ។ ព្រោះបើពោល ដោយបរមត្ថ សច្ចៈទាំងអស់ហ្នឹងឯង គឺបណ្ឌិតជ្រាបថា ជាធម្មជាតសូន្យ ព្រោះមិនមានអ្នកដឹង អ្នកធ្វើ អ្នករំលត់ និង អ្នកធ្វើដំណើរ ។ ព្រោះហេតុនោះ ពាក្យនេះ គឺព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយថា :

ពិតណាស់ សេចក្តីទុក្ខមានមែន តែបុគ្គលណាមួយ
ឈ្មោះថា ដល់ហើយ នូវសេចក្តីទុក្ខ មិនមានទេ,
បុគ្គលអ្នកធ្វើ មិនមាន, តែអំពើគឺការធ្វើមានមែនពិត
ទីរំលត់ទុក្ខ គឺនិរោធសច្ច មាន, តែបុរសអ្នករំលត់
ទុក្ខ មិនមានទេ, ផ្លូវមាន តែគ្មានអ្នកធ្វើដំណើរ ។

ម្យ៉ាងវិញទៀត គប្បីជ្រាបសេចក្តីសោះសូន្យ ក្នុងសច្ចៈទាំង ៤ នោះ ដូច្នេះ គឺ សច្ចៈ ២ ខាងដើម សូន្យចាកភាពថា ទៀង, ថាល្អ, ថាសុខ និង ថាខ្លួនប្រាណ, អមតបទ គឺនិរោធ សូន្យហើយចាកប្រាណ, មគ្គ ប្រាសចាកភាពថា ទៀង, ថាសុខ និង ថា ខ្លួនប្រាណ ដូច្នេះ ។ ម្យ៉ាងទៀត សច្ចៈទាំង ៣ សូន្យចាកនិរោធ និង និរោធ ក៏សូន្យចាកសច្ចៈទាំង ៣ ដ៏សេស ។ ម្យ៉ាងទៀត បណ្តាសច្ចៈទាំង ៤ នេះ សច្ចៈជាហេតុ ឈ្មោះថា សូន្យចាកសច្ចៈជាផល ព្រោះការមិនមាននៃទុក្ខក្នុងសមុទយៈផង ព្រោះមិនមាននៃនិរោធ ក្នុងមគ្គផង ។

ហេតុ មិនបានរួមគិកជាមួយផល ដូចជាប្រក្រតីនៃជនទាំងឡាយ មានជនអ្នកពោល នូវពាក្យជាប្រក្រតីឡើយ ។ម្យ៉ាងវិញទៀត សច្ចៈ ជាផល សូន្យចាកហេតុ ព្រោះទុក្ខសច្ចៈជាមួយសមុទយសច្ចៈទាំងឡាយ និង និរោធសច្ចៈ ជាមួយមគ្គសច្ចៈទាំងឡាយ មិនរួមចូលគ្នាបានទេ ។ សច្ចៈ ដែលជាផលនៃហេតុនេះ មិនរួមចូលគ្នា ដោយហេតុដូចជាពាក្យនិយាយថា អណូពីរជាដើម នៃជនទាំងឡាយ មានជនអ្នកពោលដ៏ស្មើជាប្រក្រតីបានឡើយ ។ ព្រោះហេតុនោះ ពាក្យនេះ គឺព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ថា :

បណ្ដាសច្ចទាំងឡាយ ៤ នេះ សច្ចៈ៣ ឈ្មោះថាសូន្យ
ហើយចាកនិរោធ, ការរំលត់ សូន្យចាកសច្ចៈ ៣ នោះ
ឯង, សច្ចៈជាហេតុ រមែងសូន្យចាកសច្ចជាផល ឯ
សច្ចៈ ជាផលនោះ ក៏រមែងសូន្យចាកសច្ចៈជាហេតុ ។

សេចក្ដីវិនិច្ឆ័យ ដោយជាសូន្យ បណ្ឌិតគប្បីជ្រាបប៉ុណ្ណេះសិនចុះ ។

(ដោយវិធីផ្សេងៗ)

(៣៥០) សេចក្ដីវិនិច្ឆ័យ ត្រង់បទថា "ឯកវិធាទីហិ" គឺបុគ្គលគប្បីជ្រាបដូចតទៅនេះ ។ ក៏បណ្ដាសច្ចទាំង ៤ នេះ ទុក្ខទាំងអស់ហ្នឹងឯងមានមួយប្រការ ព្រោះកិរិយាញ៉ាំងភាវៈនៃទុក្ខ ឲ្យប្រព្រឹត្តទៅ ។ ទុក្ខមានពីរប្រការ ព្រោះនាម និង រូប ។ ទុក្ខ មាន ៣ ប្រការ ផ្សេងដោយឧបបត្តិភព, កាមភព, រូបភព និង អរូបភព ។ ទុក្ខ មានបួនប្រការ ដោយញែកតាមអាហារបួន ។ ទុក្ខ មាន ៥ ប្រការ ដោយញែកតាមឧបាទានក្ខន្ធ ៥ ។ រីឯសមុទយៈ មានមួយប្រការ ដោយភាវៈជាអ្នកធ្វើឲ្យសំសារវដ្ដប្រព្រឹត្តទៅ ។ សមុទយៈ មានពីរប្រការ ដោយការ



ប្រកបព្រមដោយទិដ្ឋិ និង មិនប្រកបព្រម (ដោយទិដ្ឋិ) ។ សមុទយៈ មានបីប្រការ ដោយញែកតាមកាមតណ្ហា, ភវតណ្ហា និង វិភវតណ្ហា ។ សមុទយៈ មានបួនប្រការ ព្រោះជាទោស គឺព្រះយោគីគប្បីលះចេញដោយមគ្គបួន ។ សមុទយៈ មានប្រាំប្រការ ដោយការញែកដោយចំណែកមានការត្រេកអរ ក្នុងរូបជាដើម ។ សមុទយៈ មានប្រាំមួយប្រការ ដោយការចែកតាមពួកនៃតណ្ហាប្រាំមួយ ។

ឯនិរោធ មាន ១ ប្រការ ព្រោះភាវៈជាអសង្ខតធាតុ ។ បើពោលតាមបរិយាយ និរោធ មានពីរប្រការ ដោយញែកតាមសឧបាទិសេស និង អនុបាទិសេស ។ និរោធ មានបីប្រការ ព្រោះការចូលទៅរម្ងាប់នូវប្រជុំបីនៃភព ។ និរោធ មានបួនប្រការ ព្រោះជាធម៌គឺព្រះយោគីគប្បីបានដោយមគ្គបួន ។ និរោធ មានប្រាំប្រការ ព្រោះកិរិយាចូលទៅរម្ងាប់នូវអភិនន្ទនៈប្រាំ ។ និរោធ មាន ៦ ប្រការ ដោយការញែកដោយពួកនៃតណ្ហា ៦ ។

ឯរីមគ្គ មានមួយប្រការ ព្រោះជាធម៌ គឺព្រះយោគីគប្បីចំរើន ។ មគ្គ មានពីរប្រការ ដោយការញែកតាមសមថៈ និង វិបស្សនា ឬក៏ដោយញែកតាមទស្សនៈ និង ភាវនា ។ មគ្គ មានបីប្រការ ដោយការញែកតាមប្រមាណបីនៃខន្ធ ។ មែនពិត មគ្គនេះ គឺលោកសង្គ្រោះយកហើយ ដោយខន្ធទាំងឡាយបី ដែលជាគ្រឿងសំដែងអាងច្បាស់លាស់ ព្រោះភាវៈនៃមគ្គនោះប្រព្រឹត្តទៅ ដោយគ្រឿងអាង ដូចជាព្រះនគរ ដែលជនរួបរួមហើយ ដោយរាជសម្បត្តិ ។ សមដូចជាព្រះនាងធម្មទិន្នាថេរី បានពោលថា: ម្នាលវិសាខឧបាសក ដ៏មានអាយុ ខន្ធទាំងឡាយបី គឺលោកមិនបានសង្គ្រោះយកហើយ ដោយអរិយមគ្គ មាន

អង្គប្រាំបីទេ, ម្នាលវិសាខឧបាសក ដ៏មានអាយុ តែមគ្គដ៏ប្រសើរប្រកប ដោយអង្គប្រាំបី គឺលោកសង្គ្រោះយកហើយ ដោយខន្ធទាំងឡាយ ត្រឹមតែបី, ម្នាលវិសាខឧបាសកដ៏មានអាយុ សម្មាវាចាណាក្តី សម្មាកម្មន្តៈណាក្តី សម្មាអាជីវោណាក្តី ធម៌ទាំងឡាយនេះ គឺលោកសង្គ្រោះ ក្នុងសីលខន្ធ, សម្មាវាយាមៈណាក្តី សម្មាសតិណាក្តី សម្មាសមាធិណាក្តី ធម៌ទាំងឡាយនេះ គឺលោកសង្គ្រោះហើយ ក្នុងសមាធិខន្ធ, សម្មាទិដ្ឋិណាក្តី សម្មាសង្កប្បៈណាក្តី ធម៌ទាំងឡាយនេះ គឺលោកសង្គ្រោះហើយ ក្នុងបញ្ញាខន្ធ ។

ក៏ព្រោះក្នុងអរិយមគ្គនេះ ធម៌ទាំងឡាយបី មានសម្មាវាចាជាដើម ចាត់ថា ជាសីលពិត, ព្រោះហេតុនោះ ធម៌ទាំងបីនោះ លោកសង្គ្រោះ ដោយសីលខន្ធ ព្រោះមានកំណើតស្មើគ្នា ។ ក៏ក្នុងបាលីលោកធ្វើការសំដែងចេញត្រង់បទថា “សីលក្ខន្ធេ” ដោយសត្តមីវិភត្តិ ក៏ពិតមែនហើយ ប៉ុន្តែសេចក្តី បណ្ឌិតគប្បីជ្រាប ដោយអំណាចតតិយាវិភត្តិវិញ ។

ចំណែកសមាធិ ក្នុងមគ្គទាំងឡាយបី មានសម្មាវាយាមៈ ជាដើម មិនអាចដើម្បីទំលុះ (នូវឈាន) ដោយភាវៈនៃចិត្តប្រព្រឹត្តទៅ ក្នុងអារម្មណ៍តែមួយ តាមធម្មតារបស់ខ្លួនបានទេ, ក៏កាលបើវិរិយៈញ៉ាំងកិច្ច គឺការផ្គងឡើង ឲ្យសំរេច និង កាលបើសតិ ញ៉ាំងកិច្ច គឺការមិនក័ន្តប្រទ្បំ ឲ្យសំរេច ជាសមាធិ មានឧបការៈបានហើយ ទើបអាច (ដើម្បីដល់នូវឈានបាន) ។

នេះជាសេចក្តីប្រៀបធៀប ក្នុងមគ្គទាំងឡាយបីមានសម្មាវាយាមៈ ជាដើមនោះ ។ ប្រៀបដូចជាបណ្តាសំឡាញ់ទាំងបីនាក់ ចូលទៅហើយ កាន់ឧទ្យាន ដោយគិតថា “យើងទាំងឡាយ នឹងលេងនក្ខត្តឫក្ស” ដូច្នេះ



សម្លាញ់ម្នាក់ ឃើញដើមចំប៉ា មានផ្ការីកស្គុសស្គាយ មិនអាចលូកដៃទៅបេះបាន, គ្រានោះ សម្លាញ់ទីពីររបស់បុរសនោះ ឱនខ្នងឲ្យ, បុរសនោះ ឈរញ័រលើខ្នងនៃបុរសនោះ ពុំអាចចាប់បេះបាន, កាលបើដូច្នោះ បុរសមួយទៀត គប្បីបង្អោនសង្កួយស្មាឲ្យ, បុរសនោះ ឈរលើខ្នងនៃបុរសម្នាក់ ប្រត់ចង្កួយស្មានៃបុរសម្នាក់ហើយ បេះផ្កាទាំងឡាយបានតាមគាប់ចិត្ត ប្រដាប់តាក់តែង លេងនក្ខត្តឫក្ស មានឧបមាយ៉ាងណា, ពាក្យឧបមេយ្យជាគ្រឿងញ៉ាំងពាក្យឧបមាឲ្យដល់ព្រម គឺបណ្ឌិតគប្បីយល់ យ៉ាងនោះដែរ ។ ក៏ធម៌ទាំងឡាយបី មានសម្មាវាយាមៈជាដើម កើតក្នុងទីជាមួយគ្នា ដូចជាបុរសជាសម្លាញ់បីនាក់ ចូលទៅកាន់ឧទ្យាន ក្នុងទីជាមួយគ្នា ។ អារម្មណ៍ ដូចជាដើមចំប៉ាដែលមានផ្ការីកល្អហើយ ។ សមាធិ ដែលមិនអាចដើម្បីទំលុះនូវឈាន ដោយភាវៈនៃចិត្តប្រព្រឹត្តទៅ ក្នុងអារម្មណ៍តែមួយ តាមធម្មតា របស់ខ្លួនបាន ទុកដូចជាបុរសដែលមិនអាចលើកដៃបេះផ្កាបាន ។ សេចក្តីព្យាយាម ទុកដូចជាសម្លាញ់អ្នកឱនខ្នងឲ្យ ។ សតិ ទុកដូចជាសម្លាញ់ ដែលឈរឲ្យចង្កួយស្មា ។ បុរសក្រៅនេះ ឈរលើខ្នងនៃបណ្តាបុរសទាំងឡាយនោះ បុរសម្នាក់ ប្រត់នូវចង្កួយស្មានៃបុរសម្នាក់ អាចបេះយកផ្កាបាន តាមចិត្តប្រាថ្នា យ៉ាងណាមិញ, កាលបើសេចក្តីព្យាយាម ញ៉ាំងកិច្ចគឺការផ្គង(ចិត្ត)ឡើងឲ្យសំរេច និង កាលបើសតិ ញ៉ាំងកិច្ចគឺការមិនក័ន្តប្រទ្បំឲ្យសំរេច, សមាធិ មានឧបការៈដែលខ្លួនបានហើយអាចសំរេចនូវឈាន ដោយភាវៈជាអ្នកមានអារម្មណ៍តែមួយ ក្នុងអារម្មណ៍ ក៏យ៉ាងនោះដែរ ។ ព្រោះហេតុនោះ បណ្តាមគ្គទាំងឡាយបួននេះ សមាធិប៉ុណ្ណោះ គឺលោកសង្គ្រោះហើយ ដោយសមាធិខន្ធ ព្រោះមានជាតិស្មើគ្នា ។ ចំណែកខាង

វាយាមៈ និង សតិ ជាគុណជាតិគឺលោកសង្គ្រោះហើយដោយកិរិយា ។

ក៏បណ្ដាសម្មាទិដ្ឋិ និង សម្មាសង្កប្បៈទាំងឡាយ ប្រាជ្ញាមិនអាចកាត់ នូវអារម្មណ៍ថា “អនិច្ចំ ទុក្ខំ អនត្តា” តាមធម្មតា របស់ខ្លួនបានទេ, លុះណាតែកាលបើវិតក្កៈ គោះឲ្យញយៗ ទើបអាច (កាត់បាន) ។ សំណួរថាៈ តើព្រោះហេតុអ្វី? ។ ចម្លើយថាៈ ដូចជាងប្រាក់កាលដាក់កហាបណៈក្នុងដៃហើយសូម្បីមានបំណងដើម្បីរមិលមើលក្នុងចំណែកទាំងពួង ក៏មិនអាចញ៉ាំងភ្នែកឲ្យប្រព្រឹត្តទៅ ដោយផ្ទៃនៃចក្ខុបានឡើយ លុះតែបង្វិលចុះឡើង ដោយថ្នាំងម្រាមដៃទាំងឡាយ ទើបអាចរមិលមើលពីខាងនេះខាងនោះបាន យ៉ាងណាមិញ ។ បញ្ញា ក៏យ៉ាងដូច្នោះដែរ មិនអាចកាត់នូវអារម្មណ៍ ដោយអំណាចនៃលក្ខណៈ មានអនិច្ចលក្ខណៈជាដើម តាមធម្មតា របស់ខ្លួនបានទេ, តែបញ្ញានោះ អាចកាត់នូវអារម្មណ៍ដែលវិតក្កៈមានការលើកឡើងនូវចិត្ត ជាលក្ខណៈ, មានការប៉ះទង្គិច(អារម្មណ៍)ទៅមក ជាកិច្ច, ហាក់ដូចជាការគោះយកមកឲ្យផងដូចជាចាប់បង្វិលយកមកឲ្យផង ។ ព្រោះហេតុនោះ សូម្បីក្នុងអង្គមគ្គទាំង ២ នេះ សម្មាទិដ្ឋិ ប៉ុណ្ណោះ លោកសង្គ្រោះហើយ ដោយបញ្ញាខន្ធ ព្រោះមានកំណើតដូចគ្នា ។ ចំណែកឯ សម្មាសង្កប្បៈ ជាធម៌គឺលោកសង្គ្រោះហើយ ដោយអំណាចនៃកិរិយា ។

មគ្គ រមែងដល់នូវការសង្គ្រោះដោយខន្ធទាំងឡាយបីនេះ ដូចរៀបរាប់មកនេះ ។ ព្រោះហេតុនោះ ពាក្យនេះថា “មគ្គមានបីប្រការ ដោយការផ្សេងគ្នានៃខន្ធបី” គឺលោកពោលហើយ ។ មគ្គ មាន ៤ ប្រការ ដោយអំណាចនៃមគ្គ មានសោតាបត្តិមគ្គ ជាដើម ។

ម្យ៉ាងវិញទៀត សច្ចៈ ទាំងឡាយទាំងពួងហ្នឹងឯង មានតែមួយ



ប្រការ ព្រោះជាធម៌មិនប្រែក្លាយទៅជាធម៌មិនពិត ឬ ព្រោះជាធម៌ដែលបុគ្គលគប្បីដឹងដ៏ក្រៃលែង ។ មាន ២ យ៉ាង ដោយជាលោកិយៈ និង លោកុត្តរៈ ឬ ដោយសង្ខតៈ និង អសង្ខតៈ ។ មាន ៣ យ៉ាង ដោយភាវៈជាធម៌ដែលត្រូវលះ ដោយទស្សនៈ និងភាវនា និង ដោយភាវៈជាធម៌មិនគួរលះបង់ ។ មាន ៤ យ៉ាង ដោយផ្សេងគ្នាដោយកិច្ច មានធម៌ដែលត្រូវកំណត់ដឹងជាដើម ដោយប្រការដូច្នេះ ។

សេចក្ដីវិនិច្ឆ័យ ដោយប្រការផ្សេងៗ មានប្រការតែមួយជាដើមក្នុងអរិយសច្ចៈនេះ បណ្ឌិតគប្បីជ្រាប ដូចបានពោលមកនេះឯង ។

**(ដោយមានចំណែកស្មើ និង មិនស្មើ)**

(៣៥១) ពាក្យថា “**ដោយចំណែកស្មើគ្នា និង មិនស្មើគ្នា**” មានសេចក្ដីថាៈ សច្ចទាំងឡាយគ្រប់យ៉ាងនុ៎ះឯង មានចំណែកស្មើគ្នានឹងគ្នា ព្រោះជាធម៌មិនប្រែក្លាយទៅជាធម៌មិនពិត ១ ព្រោះជាធម៌សូន្យចាកអត្តា ១ ព្រោះមានការត្រាស់ដឹងដែលធ្វើបានដោយកម្រ ១ ។ សមដូចជាព្រះមានព្រះភាគទ្រង់ត្រាស់ថា “ម្នាលអានន្ទ! អ្នកសំគាល់នូវសេចក្ដីនោះយ៉ាងដូចម្ដេច? កាលដែលបុគ្គលគប្បីបាញ់នូវកូនសរឲ្យចូលតាមរន្ធនៃដើមត្នោតដ៏តូចៗ អំពីទីឆ្ងាយ មិនឲ្យខុសផ្លាតកូនសរមួយហើយមួយទៀត ឬថា កាលដែលបុគ្គលគប្បីយកចុងរោមកន្ទុយសត្វ ដែលបែងជា ៧ ចំរៀក ទៅបាញ់ត្លោះចំចុងរោមនៃកន្ទុយសត្វ តើរបស់ណាមួយ ដែលធ្វើបានដោយលំបាក ឬថា របស់ណាមួយ សម្រេចបានដោយលំបាក? ” ដូច្នេះ ។ ព្រះអានន្ទ ក្រាបទូលថា “បពិត្រព្រះអង្គដ៏ចំរើន កាលដែលបុគ្គលយកចុងរោមនៃកន្ទុយសត្វ ដែលច្រៀកជា ៧ ចំរៀក ទៅបាញ់ចំចុងរោម នៃកន្ទុយសត្វនុ៎ះឯង ជារបស់ធ្វើបានដោយ

លំបាកផង ទាំងជារបស់សំរេចបានដោយលំបាកផង” ។ ព្រះមានព្រះភាគទ្រង់ត្រាស់ ថា “ម្នាលអានន្ទ ! បុគ្គលដែលដឹងជាក់ច្បាស់ តាមសភាវៈពិតថា “នេះជាទុក្ខ ។ល។ ដឹងជាក់ច្បាស់តាមសភាវៈពិតថា “នេះជាទុក្ខនិរោធគាមិនីបដិបទា រមែងដឹងជាក់ច្បាស់ នូវការដឹងជាក់ច្បាស់យ៉ាងលំបាក ជាងការបាញ់រោមកន្ទុយសត្វ ដោយរោមកន្ទុយសត្វនោះទៅទៀត” ដូច្នេះ ។

សច្ចៈទាំងអស់នោះ មានចំណែកមិនស្មើគ្នា ដោយកិរិយាកំណត់ផ្សេងៗ គ្នា តាមលក្ខណៈរបស់ខ្លួន ។ មួយទៀត សច្ចៈពីរខាងដើមជាសច្ចៈមានចំណែកស្មើគ្នា ព្រោះភាវៈជាសច្ចៈមានភាពជ្រាលជ្រៅព្រោះអត្ថថា ពិបាកនឹងដឹងបាន ព្រោះភាវៈជាលោកិយៈនិងជាធម៌ប្រកបដោយអាសវៈ ។ តែសច្ចៈទាំងនោះ មានចំណែកមិនស្មើគ្នា ដោយញែកជាផល និង ជាហេតុផង ដោយភាវៈជាធម៌គួរកំណត់ដឹង និង ជាធម៌គួរលះបង់ផង ។ ចំណែកសច្ចៈ ២ ចុងក្រោយ មានចំណែកស្មើគ្នាដោយភាវៈជាធម៌ដឹងបានដោយលំបាក ព្រោះជាធម៌ជ្រាលជ្រៅ ដោយភាវៈជាលោកុត្តរធម៌ និង ជាធម៌ដែលមិនមានអាសវៈ ។ សច្ចៈទាំងនោះ មានចំណែកមិនស្មើគ្នា ដោយការញែកជាវិស័យ គឺដែនរំលត់ទុក្ខ និង វិស័យ គឺផ្លូវដែលទៅកាន់ដែនរំលត់ទុក្ខនោះ និង ដោយភាវៈជាធម៌គួរធ្វើឲ្យជាក់ច្បាស់ផង ជាធម៌គួរចំរើនផង ។ មួយទៀត សច្ចៈ ទី១ និង សច្ចៈទី៣ ជាសច្ចៈមានចំណែកស្មើគ្នា ដោយជាធម៌សំដែងបញ្ជាក់នូវផលដូចគ្នា ។ តែមានចំណែកមិនស្មើគ្នា ដោយជាសង្ខតធម៌ និង ជាអសង្ខតធម៌ ។ ចំណែកសច្ចៈទី២ និង ទី៤ មានចំណែកស្មើគ្នា ដោយភាពជាធម៌សំដែងចេញនូវហេតុ ដូចគ្នា ។ តែជាសច្ចៈ មានចំណែកមិនស្មើគ្នាដោយជាកុសលចំណែក ១ និង ដោយជាអកុសលចំណែក ១ ។ ចំណែកឯសច្ចៈ ទី១ និង ទី៤ វិញ មានចំណែកស្មើគ្នា ដោយភាពជាសង្ខតធម៌ដូចគ្នា ។ តែមានចំណែកមិនស្មើគ្នា ដោយភាពជាលោកិយធម៌ និង លោកុត្តរធម៌ ។ សច្ចៈ ទី២ និង ទី៣ មានចំណែកស្មើគ្នាដោយភាវៈជាធម៌ របស់ព្រះសេខៈ ក៏មិនមែន និង ជាធម៌ របស់ព្រះអសេខៈ ក៏មិនមែន ។ មានចំណែកមិនស្មើគ្នា ដោយភាពជាធម៌មានអារម្មណ៍ និង ជាធម៌មិនមានអារម្មណ៍ ។



អ្នកមានប្រាជ្ញា គប្បីជ្រាប នូវភាវៈនៃអរិយសច្ចៈទាំងឡាយ មានចំណែកស្មើគ្នា និង មិនស្មើគ្នា ដោយប្រការទាំងឡាយ និង ដោយន័យទាំងឡាយ ដូចន័យដែលបានពោលមកហើយនេះឯង ។

*បរិច្ឆេទ ទី១៦ ឈ្មោះឥន្ទ្រិយនិទ្ទេស*
*ក្នុងអធិការនៃបញ្ញាភាវនា ក្នុងគម្ពីរវិសុទ្ធិមគ្គ*
*គឺខ្ញុំរចនាហើយដើម្បីប្រយោជន៍ដល់សេចក្ដីជ្រះថ្លានៃសាធុជន*
*ដោយប្រការដូច្នោះឯង ។*

❈ ✾ ❈

## (បញ្ញាភូមិនិទ្ទេស)

(៣៥២) ក្នុងធម៌ទាំងឡាយដែលជាភូមិនៃបញ្ញានេះ ដែលលោកពោលហើយយ៉ាងនេះថា "ធម៌ទាំងឡាយផ្សេងដោយខន្ធ, អាយតនៈ, ធាតុ, ឥន្ទ្រិយ៍, សច្ចៈ និង បដិច្ចសមុប្បាទ ជាដើម ជាភូមិ នៃបញ្ញា" ដូច្នេះ បដិច្ចសមុប្បាទ និង បដិច្ចសមុប្បន្នធម៌ទាំងឡាយ ដែលលោកសង្គ្រោះហើយ (រួមបញ្ចូល) ដោយអាទិស័ព្ទ ជាធម៌នៅសេសសល់ ព្រោះហេតុណា, ព្រោះហេតុនោះ ឥឡូវនេះ លំដាប់នៃការសំវណ្ណនានូវបដិច្ចសមុប្បាទ និង បដិច្ចសមុប្បន្នធម៌ទាំងឡាយនោះ ទើបដល់ហើយ ដោយលំដាប់ ។

បណ្ដាធម៌ទាំង ២ យ៉ាងនោះ ធម៌ទាំងឡាយ មានអវិជ្ជា ជាដើម បណ្ឌិត គប្បីជ្រាបថា "ឈ្មោះថា បដិច្ចសមុប្បាទ" ជាដំបូងសិន ។ មែនពិត ពាក្យនេះ គឺព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយថា "ម្នាលភិក្ខុទាំងឡាយ ! ក៏បដិច្ចសមុប្បាទធម៌ តើដូចម្ដេច? ម្នាលភិក្ខុទាំងឡាយ !

សង្ខារទាំងឡាយ កើតមាន ព្រោះអវិជ្ជា ជាបច្ច័យ,
វិញ្ញាណ កើតមាន ព្រោះសង្ខារ ជាបច្ច័យ,
នាមរូប កើតមាន ព្រោះវិញ្ញាណ ជាបច្ច័យ,
សឡាយតនៈ កើតមាន ព្រោះនាមរូប ជាបច្ច័យ,
ផស្សៈ កើតមាន ព្រោះសឡាយតនៈ ជាបច្ច័យ,
វេទនា កើតមាន ព្រោះផស្សៈ ជាបច្ច័យ,
តណ្ហា កើតមាន ព្រោះវេទនា ជាបច្ច័យ,
ឧបាទាន កើតមាន ព្រោះតណ្ហា ជាបច្ច័យ,



ភព កើតមាន ព្រោះឧបាទាន ជាបច្ច័យ,
ជាតិ កើតមាន ព្រោះភព ជាបច្ច័យ,

ជរា, មរណៈ, សោកៈ, បរិទេវៈ, ទុក្ខ, ទោមនស្ស និង ឧបាយាសៈ កើតមាន ព្រោះជាតិជាបច្ច័យ, ការកើតឡើង នៃកងទុក្ខទាំងអស់នោះ តែងមាន ដោយប្រការដូច្នេះឯង, ម្នាលភិក្ខុទាំងឡាយ ! នេះ តថាគត ហៅថា បដិច្ចសមុប្បាទធម៌" ។

ចំណែកធម៌ទាំងឡាយ មានជរា និង មរណៈជាដើម បណ្ឌិតគប្បីជ្រាបថា ឈ្មោះថា បដិច្ចសមុប្បន្នធម៌ ។ មែនពិត ពាក្យនេះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ! ក៏បដិច្ចសមុប្បន្នធម៌ទាំងឡាយ តើដូចម្ដេច? ម្នាលភិក្ខុទាំងឡាយ ជរា និង មរណៈ ជាធម៌មិនទៀង ជាធម៌មានបច្ច័យតាក់តែងឡើង ជាធម៌អាស្រ័យនូវបច្ច័យកើតឡើង ជាធម៌មានការអស់ទៅជាធម្មតា ជាធម៌មានការសូន្យទៅជាធម្មតា ជាធម៌វិនាសទៅជាធម្មតា ជាធម៌រលត់ទៅជាធម្មតា ម្នាលភិក្ខុទាំងឡាយ ជាតិ...ភព...ឧបាទាន...តណ្ហា...វេទនា...ផស្សៈ...សឡាយតនៈ...នាមរូប...វិញ្ញាណ...សង្ខារ...អវិជ្ជា ជាធម៌មិនទៀង ជាធម៌ដែលបច្ច័យប្រជុំតាក់តែងឡើង ជាធម៌អាស្រ័យនូវបច្ច័យកើតឡើង ជាធម៌មានការអស់ទៅជាធម្មតា ជាធម៌មានការសូន្យទៅជាធម្មតា ជាធម៌មានកិរិយាវិនាសទៅជាធម្មតា ជាធម៌មានការរលត់ទៅជាធម្មតា ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងនេះ ហៅថា បដិច្ចសមុប្បន្នធម៌" ។

### (សេចក្ដីនៃបដិច្ចសមុប្បាទ)

(៣៥៣) ចំណែកសេចក្ដីនេះ ជាសេចក្ដីសង្ខេប ក្នុងបដិច្ចសមុប្បាទធម៌ និង បដិច្ចសមុប្បន្នធម៌ទាំងឡាយនោះ ។

ធម៌ដែលជាបច្ច័យទាំងឡាយ បណ្ឌិត គប្បីជ្រាបថា “ឈ្មោះថា បដិច្ចសមុប្បាទធម៌” ។ ធម៌ដែលកើតឡើង ព្រោះបច្ច័យទាំងឡាយនោះៗ បណ្ឌិត គប្បីជ្រាបថា “ឈ្មោះថា បដិច្ចសមុប្បន្នធម៌ ” ។

បើមានពាក្យសួរថា “រឿងនេះ តើគប្បីជ្រាបបានដូចម្ដេច?” ។ គប្បីដោះស្រាយថា “បុគ្គលគប្បីជ្រាបបាន ព្រោះព្រះតម្រាស់នៃព្រះមានព្រះភាគ” ។

មែនពិត ព្រះមានព្រះភាគ ទ្រង់សំដែង បដិច្ចសមុប្បាទធម៌ ក្នុងព្រះសូត្រដែលពោលពីការសំដែងនូវបដិច្ចសមុប្បាទធម៌ និង បដិច្ច-សមុប្បន្នធម៌ ដូច្នេះថា “ម្នាលភិក្ខុទាំងឡាយ [១] ក៏បដិច្ចសមុប្បាទ-ធម៌ តើដូចម្ដេច? ម្នាលភិក្ខុទាំងឡាយ ជរាមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ, ព្រោះការកើតឡើងនៃតថាគតទាំងឡាយក្ដី ព្រោះការមិនទាន់កើតឡើងនៃតថាគតទាំងឡាយក្ដី ធាតុ (សភាវៈនៃធម៌ដែលជាតួនៃបច្ច័យ) នោះ ធម្មដ្ឋិតា (ធម៌កើតឡើងអំពីបច្ច័យអាស្រ័យគ្នាហើយឋិតនៅ) នោះ ធម្មនិយាម (បច្ច័យដែលកំណត់នូវធម៌) នោះ ឥទប្បច្ចយតា (បច្ច័យនៃធម៌មានជរាមរណៈជាដើម) នោះ តែងឋិតនៅជាធម្មតា, តថាគត ត្រាស់ដឹង យល់ច្បាស់ នូវបច្ច័យនោះ លុះត្រាស់ដឹង យល់ច្បាស់ហើយ ទើបប្រាប់ សំដែង ពន្យល់ តែងតាំង បើកបង្ហាញ ចែករំលែក ធ្វើឲ្យរាក់ហើយ ប្រាប់ថែមថា “អ្នកទាំងឡាយ ចូរមើលចុះ” ដូច្នេះ ហើយត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ! ជរាមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ, ម្នាលភិក្ខុទាំងឡាយ! ជាតិ កើតមាន ព្រោះមានភពជាបច្ច័យ ។ល។ ម្នាលភិក្ខុទាំងឡាយ ! សង្ខារទាំង

១- សុ. សំ. និ. ភាគទី ៣១ ទំព័រទី ៥៨ ។



ឡាយ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ ព្រោះការកើត នៃតថាគតទាំងឡាយក្ដី ព្រោះការមិនទាន់កើតឡើង នៃតថាគតទាំងឡាយក្ដី ។ល។ តថាគត...ចែករំលែក ធ្វើឲ្យរាក់ ហើយប្រាប់ថែមថា “អ្នកទាំងឡាយ ចូរមើលចុះ” ដូច្នេះ និង ទ្រង់ត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ, ម្នាលភិក្ខុទាំងឡាយ ! ធម្មជាតណា ជារបស់ពិត ទៀងទាត់ មិនប្រែប្រួល មានសភាវៈនេះជាបច្ច័យ ក្នុងធម៌នោះ, ម្នាលភិក្ខុទាំងឡាយ! នេះ ហៅថា បដិច្ចសមុប្បាទធម៌” ដោយប្រការដូច្នេះឯង ទើបត្រាស់នូវធម៌ដែលជាបច្ច័យទាំងឡាយហ្នឹងឯងថា “ជាបដិច្ចសមុប្បាទធម៌” ដោយពាក្យទាំងឡាយ ជាវេវចនៈ មានពាក្យពិតជាដើម ។ ព្រោះហេតុនោះ បដិច្ចសមុប្បាទធម៌ បណ្ឌិត គប្បីជ្រាបថា “មានសភាពជាបច្ច័យនៃធម៌ទាំងឡាយ មានជរាមរណៈជាដើម ជាលក្ខណៈ, មានការតាមចងនូវទុក្ខជារស, មានការខុសផ្លូវ ជាបច្ចុប្បដ្ឋាន ។ ក៏បដិច្ចសមុប្បាទ-ធម៌នេះនោះ ព្រះមានព្រះភាគទ្រង់ត្រាស់ហៅថា “ជារបស់ពិត” ព្រោះការកើតមាននៃធម៌នោះៗ ព្រោះបច្ច័យទាំងឡាយនោះៗ ដែលមិនខ្វះមិនលើសហ្នឹងឯង ត្រាស់ហៅថា “ជារបស់ទៀងទាត់” ព្រោះកាលបើបច្ច័យទាំងឡាយដល់នូវការព្រមព្រៀងគ្នាហើយ ទើបមិនមានធម៌ទាំងឡាយដែលកើតឡើងព្រោះបច្ច័យនោះ នឹងមិនមានសូម្បីតែមួយរំពេច ទ្រង់ត្រាស់ហៅថា “ជារបស់មិនប្រែប្រួល” ព្រោះការមិនកើតឡើងនៃធម៌ដទៃ ព្រោះបច្ច័យនៃធម៌ដទៃ ទ្រង់ត្រាស់ហៅថា “ជារបស់មានសភាវៈនេះជាបច្ច័យ” ព្រោះភាពជាបច្ច័យ ឬ ព្រោះជាទីប្រជុំនៃបច្ច័យនៃធម៌ដែលជាផលទាំងឡាយ មានជរាមរណៈជាដើមនោះ ដូចដែល

បានពោលមកហើយ ។

(វែកបទឥទប្បច្ចយតា)

នេះជាសេចក្ដីនៃពាក្យក្នុងបទថា "ឥទប្បច្ចយតា" នោះ។ ធម៌ទាំងឡាយណាជាបច្ច័យនៃធម៌ទាំងឡាយនេះ ធម៌ទាំងឡាយនោះ ឈ្មោះថា ឥទប្បច្ចយា ។ ឥទប្បច្ចយតា គឺឥទប្បច្ចយាហ្នឹងឯង ។ម្យ៉ាងទៀត ការប្រជុំនៃឥទប្បច្ចយា ឈ្មោះថា ឥទប្បច្ចយតា ។

ក៏លក្ខណៈ ក្នុងបទថា "ឥទប្បច្ចយតា" នោះ បណ្ឌិតគប្បីស្រាវជ្រាវរកពីគម្ពីរសទ្ទសាស្ត្រផងចុះ ។

ក៏ពួកតិរ្ថិយ៍ខ្លះ ពោលត្រឹមតែកិរិយាកើតឡើង ថា "ជាបដិច្ច-សមុប្បាទ" ដោយន័យយ៉ាងនេះថា "ការអាស្រ័យកើតឡើង និង ការកើតឡើង ដោយប្រពៃ មិនជាប់ទាក់ទងជាមួយនឹងហេតុ ដូចជាការកើតតាមប្រក្រតី និង បុរិស គឺអាត្មន៍ជាដើម ដែលពួកតិរ្ថិយ៍បានកំណត់ហើយ ឈ្មោះថា "បដិច្ចសមុប្បាទធម៌" ។ ពាក្យរបស់តិរ្ថិយ៍នោះ មិនត្រឹមត្រូវទេ ។ ព្រោះហេតុអ្វី? ។ ព្រោះមិនមានព្រះសូត្រ, ព្រោះខុសពីព្រះសូត្រ, ព្រោះមិនកើតឡើងនៃគម្ភីរភាព និង ន័យ និង ព្រោះការបែកធ្លាយនៃស័ព្ទ (សទ្ទភេទ) ។

(មិនមានព្រះសូត្របញ្ជាក់)

មែនពិត ព្រះសូត្រថា "កិរិយាត្រឹមតែការកើតឡើង ឈ្មោះថាបដិច្ចសមុប្បាទ" ដូច្នេះ មិនមានទេ ។ ក៏ការខុសពីបទេសវិហារសូត្រត្រូវមានដល់បុគ្គលអ្នកពោលថា "កិរិយាត្រឹមតែការកើតឡើងនោះ ឈ្មោះថា បដិច្ចសមុប្បាទ" ដូច្នេះផងដែរ ។ សួរថា "តើយ៉ាងដូចម្ដេច?" ។ ឆ្លើយថា: "ក៏ការធ្វើទុកក្នុងចិត្ត នូវបដិច្ចសមុប្បាទធម៌ ដែល



ជាវិហារធម៌គឺការត្រាស់ដឹងជាបឋម របស់ព្រះមានព្រះភាគ ព្រោះព្រះបាលីថា "គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់ធ្វើទុកក្នុងព្រះទ័យនូវបដិច្ចសមុប្បាទ ទាំងអនុលោម និង បដិលោម រហូតបឋមយាមនៃរាត្រី" ដូច្នេះជាដើម ។ ក៏វិហារធម៌ ជាចំណែកមួយនៃបដិច្ច-សមុប្បាទនោះ ឈ្មោះថា បទេសវិហារធម៌ ។ សមដូចជាព្រះមានព្រះភាគទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ តថាគតនោះ បានត្រាស់ដឹងជាដំបូងនៅដោយវិហារធម៌ណា, តថាគតនៅហើយ ដោយប្រទេស (ចំណែកមួយ) នៃវិហារធម៌នោះ" ដូច្នេះ ។ ក៏ព្រះមានព្រះភាគ ទ្រង់អាស្រ័យនៅ ក្នុងបទេសវិហារធម៌នោះ ដោយទ្រង់ពិចារណាមើលនូវបច្ចយាការ ពុំមែនទ្រង់អាស្រ័យនៅ ដោយការពិចារណាត្រឹមតែការកើតឡើងទេ ។ សមដូចជាព្រះអង្គ ទ្រង់ត្រាស់ថា "តថាគតនោះ ដឹងទូទៅ យ៉ាងនេះថា: ការសោយនូវអារម្មណ៍ កើតមាន ព្រោះមិច្ឆាទិដ្ឋិជាបច្ច័យ ក៏មាន, ការសោយនូវអារម្មណ៍ កើតមាន ព្រោះសម្មាទិដ្ឋិជាបច្ច័យ ក៏មាន, ការសោយនូវអារម្មណ៍ កើតមាន ព្រោះការត្រិះរិះខុសជាបច្ច័យ ក៏មាន" ដូច្នេះជាដើម ។ ពាក្យបាលីទាំងអស់ បណ្ឌិតគប្បីសំដែងឲ្យបានពិស្ដារផងចុះ ។ ការខុសពីបទេសវិហារសូត្រ នឹងមានដល់បុគ្គលអ្នកពោលថា "កិរិយាត្រឹមតែការកើតឡើង ឈ្មោះថាបដិច្ចសមុប្បាទ" ដូច្នេះឯង ។

ការខុសពីកច្ចាយនសូត្រ ក៏យ៉ាងដូច្នោះដែរ ។ មែនពិត សូម្បីក្នុងកច្ចាយនសូត្រ ក៏ព្រះអង្គត្រាស់ថា "ម្នាលកច្ចាយនៈ មួយទៀតកាលបុគ្គលឃើញ នូវការកើតឡើងនៃលោក ដោយបញ្ញាដ៏ប្រពៃ តាមសេចក្ដីពិត ការសំគាល់ថា មិនមាន ឯណា ក្នុងលោក, ការសំគាល់ថា

*មិនមាន រមែងមិនមាន” ដូច្នេះ, បដិច្ចសមុប្បាទ ដែលជាអនុលោម ឈ្មោះថា ការកើតឡើងនៃលោក ព្រោះជាបច្ច័យនៃលោក ព្រោះហេតុដូច្នោះ បដិច្ចសមុប្បាទ ដែលជាអនុលោមនោះ គឺព្រះមានព្រះភាគ ទ្រង់ប្រកាសហើយ ដើម្បីគាស់រំលើងនូវឧច្ឆេទទិដ្ឋិ មិនមែនទ្រង់ប្រកាសកិរិយាត្រឹមតែការកើតឡើងទេ ។ ព្រោះថា កិរិយាគាស់រំលើងនូវឧច្ឆេទទិដ្ឋិ រមែងមាន ព្រោះការពិចារណាឃើញត្រឹមតែកិរិយាកើតឡើង ក៏មិនមែនទេ, តែរមែងមាន ព្រោះការពិចារណាឃើញនូវការប្រទាក់ប្រទងគ្នានៃបច្ច័យ ព្រោះតភ្ជាប់គ្នានៃផល តែងមាន និមិត្តការតភ្ជាប់គ្នានៃបច្ច័យ ។ សូម្បីការខុសអំពីកច្ចាយនសូត្រ ក៏ត្រូវមានដល់បុគ្គលអ្នកពោលថា “កិរិយាត្រឹមតែការកើតឡើង ឈ្មោះថា បដិច្ចសមុប្បាទ” ដោយប្រការដូច្នេះ ។*

(មិនមានភាពជ្រាលជ្រៅ និង ន័យ)

*ពាក្យថា* “ព្រោះមិនកើតភាពជ្រាលជ្រៅ និង ន័យ” *សេចក្តីថា ក៏ពាក្យនេះ ព្រះមានព្រះភាគទ្រង់ត្រាស់ហើយថា “ម្នាលអានន្ទ បដិច្ចសមុប្បាទធម៌នេះ ជាធម៌ដ៏ជ្រាលជ្រៅ ទាំងអាការៈដែលប្រាកដក៏ជ្រាលជ្រៅផងដែរ” ដូច្នេះ ។ ក៏ឈ្មោះថា ភាពនៃបដិច្ចសមុប្បាទធម៌នោះ ជាធម៌ជ្រាលជ្រៅ មាន ៤ ប្រការ ។ យើងនឹងពណ៌នានូវភាពជ្រាលជ្រៅ ៤ យ៉ាងនោះខាងមុខ ។ ភាពជ្រាលជ្រៅនោះ មិនមានក្នុងកិរិយាត្រឹមតែការកើតឡើងទេ ។ បណ្ឌិតទាំងឡាយ ពណ៌នានូវបដិច្ចសមុប្បាទធម៌នោះ ដែលប្រដាប់តាក់តែងហើយដោយន័យ ៤ ប្រការ ។ សូម្បីន័យ ៤ ប្រការនោះ ក៏មិនមាន ក្នុងកិរិយាត្រឹមតែការកើតឡើងដែរ ។ កិរិយាត្រឹមតែការកើតឡើង មិនឈ្មោះថា បដិច្ចសមុប្បាទ ទេ*



*ព្រោះមិនកើតមានភាពជ្រាលជ្រៅ និងន័យ ដូចបានពណ៌នាមកនេះឯង ជាប្រការមួយ ។*

*ពាក្យថា* “ព្រោះជាសទ្ទភេទ” *សេចក្តីថា ក៏បដិច្ចស័ព្ទនេះ កាលកត្តាស្មើគ្នាកាលប្រកបក្នុងបុព្វកាលកិរិយាទើបធ្វើសេចក្តីឲ្យសំរេចបាន ។ ប្រៀបដូចជាប្រយោគនេះ ថា “ចក្ខុវិញ្ញាណ អាស្រ័យចក្ខុ និងរូប ទើបកើតឡើង” ។ ប៉ុន្តែក្នុងពាក្យ នៃអាចារ្យពួកនេះ បដិច្ចស័ព្ទនោះ កាលប្រកបជាមួយនឹងឧប្បាទស័ព្ទ ដែលជាភាវសាធនៈ ទើបដល់នូវសទ្ទភេទ ព្រោះមិនមានកត្តាស្មើគ្នា និង មិនញុំាងសេចក្តីអ្វីមួយឲ្យសំរេចបានផង ព្រោះហេតុនោះ កិរិយាត្រឹមតែការកើតឡើង ទើបមិនឈ្មោះថា ជាបដិច្ចសមុប្បាទ ព្រោះជាសទ្ទភេទ ប្រការមួយ ដោយប្រការដូច្នេះឯង ។*

*ក្នុងដំណើរនោះ នឹងមានពាក្យតវ៉ា ថា : យើងនឹងប្រកបជាមួយនឹងហោតិស័ព្ទថា* “បដិច្ចសមុប្បាទោ ហោតិ” *ដូច្នេះក៏បាន។ នឹងមានពាក្យដោះស្រាយថា “ពាក្យនោះ មិនត្រឹមត្រូវទេ” ។ ព្រោះហេតុអ្វី? ។ ព្រោះមិនមានសេចក្តីដែលត្រូវប្រកប ១ ព្រោះទោស គឺការដល់នូវការកើតឡើងនៃការកើតឡើង ១ ។ ព្រោះថា ក្នុងបទទាំងឡាយនេះ គឺ “ម្នាលភិក្ខុទាំងឡាយ តថាគត នឹងសំដែងនូវបដិច្ចសមុប្បាទធម៌ ដល់អ្នកទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ចុះបដិច្ចសមុប្បាទធម៌នោះ តើដូចម្តេច? ។ល។ ម្នាលភិក្ខុទាំងឡាយ នេះឯង តថាគត ហៅថា បដិច្ចសមុប្បាទធម៌” ដូច្នេះ, ហោតិស័ព្ទ មិនដល់នូវការប្រកបជាមួយនឹងបទសូម្បីតែបទមួយផង ទាំងពុំមែនជាការកើតឡើងផង ។ ប្រសិនបើមានការកើតឡើង នៃការកើតឡើង ក៏ត្រូវបានសំរេច ប្រការមួយ ។*

សូម្បីអាចារ្យពួកខ្លះ សំគាល់ថា “ភាវៈនៃឥទប្បច្ចយធម៌ទាំងឡាយ ឈ្មោះថា ឥទប្បច្ចយតា ។ អាការៈឯណា ជាហេតុនៃបច្ច័យធម៌ទាំងឡាយ មានអវិជ្ជាជាដើម ព្រោះការកើតប្រាកដនៃសង្ខារ ជាដើម អាការៈនោះ ឈ្មោះថាៈ ភាវៈ, មួយទៀត ឈ្មោះថា បដិច្ចសមុប្បាទធម៌ ព្រោះការធ្វើឲ្យប្លែកនៃសង្ខារនោះ ពាក្យរបស់អាចារ្យទាំងឡាយនោះមិនត្រឹមត្រូវទេ ។ ព្រោះហេតុអ្វី? ។ ព្រោះសំដែងនូវហេតុនៃបច្ច័យធម៌ទាំងឡាយមានអវិជ្ជាជាដើម ។ មែនពិត បច្ច័យធម៌ទាំងឡាយមានអវិជ្ជាជាដើមហ្នឹងឯង ព្រះមានព្រះភាគទ្រង់ត្រាស់ ថា “ជាហេតុ” ដោយន័យយ៉ាងនេះ ថា “ម្នាលអានន្ទ ព្រោះហេតុនោះឯង នុ៎ះឯងជាហេតុ នុ៎ះជានិទាន នុ៎ះជាសមុទយៈ នុ៎ះជាបច្ច័យ នៃជរាមរណៈ នេះគឺអ្វីខ្លះ? គឺជាតិ ។ល។ នុ៎ះឯងជាហេតុ..........នៃសង្ខារទាំងឡាយ, នេះគឺអ្វីខ្លះ? គឺអវិជ្ជា” ដូច្នេះ ។ មិនមែនជាការធ្វើឲ្យប្លែកគ្នា(វិការៈ)នៃសង្ខារទាំងឡាយនោះទេ ។ ហេតុនោះ បណ្ឌិត គប្បីជ្រាបបច្ច័យធម៌ទាំងឡាយថាៈ “ឈ្មោះថា បដិច្ចសមុប្បាទធម៌” ។ ពាក្យឯណានោះ ដែលខ្ញុំពោលហើយ យ៉ាងនេះ, ពាក្យនោះ បណ្ឌិត គប្បីជ្រាបថា ជាពាក្យដែលពោលត្រឹមត្រូវហើយ ។

(៣៥៤) ចំណែកសេចក្ដីសំគាល់ឯណា កើតឡើង ក្នុងបដិច្ចសមុប្បាទធម៌នោះ ជាការកើតឡើងនេះឯង លោកហៅថា បដិច្ចសមុប្បាទធម៌ ដោយឆាយា នៃព្យញ្ជនៈ ថា : បដិច្ចសមុប្បាទធម៌នេះ, សេចក្ដីសំគាល់នោះ អាចារ្យទាំងឡាយ គប្បីសំគាល់យកនូវអត្ថ នៃបទនេះ ដូចបានពណ៌នាមកនេះឯង ហើយធ្វើឲ្យស្ងប់រម្ងាប់ចុះ ។

ក៏ក្នុងការប្រជុំនៃធម៌ ដែលប្រព្រឹត្តទៅ ព្រោះការ



ប្រជុំនៃបច្ច័យធម៌ទាំងនោះ ពាក្យថា បដិច្ចសមុប្បាទ
ធម៌នេះ គឺលោកប៉ងយកហើយ ដោយចំណែកពីរ
ព្រោះហេតុណា, ព្រោះហេតុនោះ បច្ច័យនៃការ
ប្រជុំនៃធម៌នោះនេះ គឺព្រះមានព្រះភាគ ទ្រង់ត្រាស់
ហៅថា បដិច្ចសមុប្បាទធម៌ ដោយឧបចារៈនៃផល
យ៉ាងដូច្នេះឯង ។

មែនពិត ការប្រជុំនៃធម៌ ដែលប្រព្រឹត្តទៅហើយ ព្រោះការប្រជុំនៃបច្ច័យនេះឯណា, ក្នុងការប្រជុំនៃធម៌នោះ បណ្ឌិតទាំងឡាយបំណងយកពាក្យនេះថា “បដិច្ចសមុប្បាទធម៌” ដោយចំណែក ២ ។

សេចក្ដីអធិប្បាយថា ប្រជុំនៃធម៌នោះ កាលបណ្ឌិតអាស្រ័យរមែងប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍ និង ដើម្បីសេចក្ដីសុខ ព្រោះហេតុណា, ព្រោះហេតុនោះ ប្រជុំនៃធម៌នោះ ឈ្មោះថា បដិច្ចៈ ព្រោះវិគ្រោះថា “បណ្ឌិតទាំងឡាយ គួរដើម្បីអាស្រ័យ នូវប្រជុំនៃធម៌នោះ” និង ប្រយោជន៍នៃធម៌នោះ ឈ្មោះថា សមុប្បាទធម៌ ព្រោះវិគ្រោះថា “ប្រជុំនៃធម៌នោះ កាលកើតឡើង រមែងកើតឡើង ព្រមជាមួយគ្នា និងដោយប្រពៃ ព្រោះមិនបានកើតឡើងតែមួយៗ(ម្ដងមួយៗ) ទាំងមិនបានកើតឡើង ដោយពុំមានហេតុផងដែរ ។ ប្រជុំនៃធម៌នោះ ឈ្មោះថា បដិច្ចសមុប្បាទធម៌ ព្រោះជាទីដែលបណ្ឌិតគួរអាស្រ័យផង ព្រោះកើតឡើងជាមួយគ្នា និង ដោយប្រពៃផង ដោយប្រការដូច្នេះឯង ។ ម្យ៉ាងទៀត ប្រជុំនៃធម៌ណា កើតឡើងព្រមជាមួយគ្នា ព្រោះហេតុនោះ ប្រជុំនៃធម៌នោះ ឈ្មោះថា បដិច្ចសមុប្បាទធម៌ ។ មួយទៀត ប្រជុំនៃ

ធម៌នោះ អាស្រ័យ គឺមិនបដិសេធនូវការព្រមព្រៀងនៃបច្ច័យ កើតឡើង ព្រោះហេតុនោះ ប្រជុំនៃធម៌នោះ ឈ្មោះថា បដិច្ចសមុប្បាទធម៌ ព្រោះប្រជុំនៃធម៌នោះ អាស្រ័យនូវបច្ច័យផង កើតឡើងព្រមជាមួយគ្នាផង ដូចបានរៀបរាប់មកហើយ យ៉ាងដូច្នេះឯង ជាប្រការមួយ ។

(បដិច្ចសមុប្បាទធម៌ដែលជាហេតុ)

ចំណែកឯប្រជុំនៃហេតុនោះ ក៏ជាបច្ច័យ នៃប្រជុំនៃធម៌នោះ ព្រោះហេតុនោះ ប្រជុំនៃធម៌នោះ ទើបឈ្មោះថា តប្បច្ចយៈ ។ ព្រោះភាវៈនៃការប្រជុំនៃហេតុ ជាតប្បច្ចយៈ សូម្បីប្រជុំនៃហេតុនោះឯង បណ្ឌិតគប្បីជ្រាបថា “ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា : បដិច្ចសមុប្បាទធម៌ ដូចគ្នាដោយវោហារនៃផល ប្រៀបដូចជាក្នុងផ្លូវលោក ផែនស្ករអំពៅ ដែលជាបច្ច័យស្លេស្ម លោកហៅថា “ដុំនៃស្លេស្ម” និង ដូចជាក្នុងព្រះសាសនា ការកើតឡើងនៃព្រះពុទ្ធទាំងឡាយ ដែលជាបច្ច័យ នៃសេចក្តីសុខ លោកពោលថា “ការកើតឡើងនៃព្រះពុទ្ធទាំងឡាយ ជាហេតុនាំមកនូវសេចក្តីសុខ” ដូច្នេះឯង ។ ន័យមួយទៀត ថា :

> (៣៥៥) ប្រជុំនៃហេតុនេះ លោកហៅថា: បដិច្ចៈ ព្រោះ
> អត្ថថា ដល់នូវចំពោះមុខ និង ប្រជុំនៃហេតុនោះ លោក
> ហៅថា សមុប្បាទធម៌ ព្រោះអត្ថថា ញ៉ាំងធម៌ទាំងឡាយ
> ដែលប្រព្រឹត្តទៅជាមួយគ្នា ឲ្យកើតឡើង ។

មែនពិត ការប្រជុំហេតុ នៃការកើតឡើង នៃធម៌ទាំងឡាយ មានសង្ខារជាដើម ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់សំដែងដោយជាប្រធាននៃហេតុតែមួយៗ មានអវិជ្ជា ជាដើម នុ៎ះឯណា ការប្រជុំ នៃហេតុនោះ



លោកហៅថា “បដិច្ចៈ” ព្រោះធ្វើអត្ថវិគ្រោះថា “បណ្តាបច្ច័យធម៌ដែលជាអង្គនៃការព្រមព្រៀងគ្នា ដល់នូវទីចំពោះមុខគ្នា គឺជួបប្រសព្វនូវទីចំពោះមុខគ្នា ព្រោះអត្ថថា ញ៉ាំងផលទូទៅឲ្យសំរេច និង ព្រោះអត្ថថា មិនមានខ្វះកន្លះឡើយ ។ ការប្រជុំនៃហេតុនេះនោះ ញ៉ាំងធម៌ទាំងឡាយដែលប្រព្រឹត្តទៅជាមួយគ្នា គឺញ៉ាំងធម៌ទាំងឡាយ ដែលមានការប្រព្រឹត្តិទៅ មិនបែកចេញពីគ្នានឹងគ្នាហ្នឹងឯង ឲ្យកើតឡើង ព្រោះហេតុនោះ ប្រជុំនៃហេតុនោះ ទើបឈ្មោះថា “សមុប្បាទធម៌” ។ ការប្រជុំនៃហេតុលោកហៅថា បដិច្ចសមុប្បាទធម៌ ព្រោះការប្រជុំ នៃហេតុនោះ ជួបប្រសព្វចំពោះមុខគ្នាផង ញ៉ាំងធម៌ដែលប្រព្រឹត្តទៅជាមួយគ្នា ឲ្យកើតឡើងផង ដូចបានពណ៌នាមកនេះឯង ជាប្រការមួយ ។

ន័យមួយទៀត ថា :

> ការប្រជុំនៃបច្ច័យនេះ អាស្រ័យដល់គ្នានឹងគ្នា ញ៉ាំង
> ធម៌ទាំងឡាយ ឲ្យកើតឡើងស្មើគ្នា និង ព្រមជាមួយ
> គ្នា ព្រោះហេតុណា, សូម្បីព្រោះហេតុនោះ ការ
> ប្រជុំនៃបច្ច័យនេះ ព្រះមុនី ទ្រង់ត្រាស់ហើយ ក្នុង
> បដិច្ចសមុប្បាទធម៌នេះ យ៉ាងនេះដូចគ្នា ។

មែនពិត ក្នុងបច្ច័យទាំងឡាយ ដែលព្រះមានព្រះភាគ ទ្រង់សំដែងហើយ ដោយបទជាប្រធាន មានអវិជ្ជាជាដើម បច្ច័យទាំងឡាយណាញ៉ាំងធម៌មានសង្ខារជាដើម ឲ្យកើតឡើង បច្ច័យទាំងឡាយនោះ មិនមែនមិនអាស្រ័យគ្នានឹងគ្នា ហើយអាចញ៉ាំងធម៌ មានសង្ខារជាដើម ឲ្យកើតឡើងបានទេ កាលបើមានការខ្វះខាតពីគ្នានឹងគ្នា ។ ព្រោះហេតុ

នោះ ការប្រជុំនៃបច្ច័យនេះ គឺព្រះមុនីទ្រង់ច្ចាត ក្នុងសំនួនវោហារ តាមសមគួរដល់អត្ថ ថា "ការប្រជុំនៃបច្ច័យនេះ អាស្រ័យគ្នាទៅវិញទៅមក ញ៉ាំងធម៌ទាំងឡាយឲ្យកើតឡើង ដោយស្មើគ្នានឹងគ្នា គឺមិនឲ្យកើតឡើងជាចំណែកមួយៗ ទាំងមិនឲ្យកើតឡើង ដោយមានមុន និង មានក្រោយឡើយ" ដូច្នេះ ទ្រង់ត្រាស់ហើយ ក្នុងពាក្យថា បដិចសមុប្បាទនេះ ដូចគ្នា, សេចក្ដីថា ទ្រង់ត្រាស់ហើយថា បដិច្ចសមុប្បាទហ្នឹងឯង ដោយប្រការដូច្នេះ ។

(បដិច្ចសមុប្បាទជាមជ្ឈិមាបដិបទា)

ក៏ព្រះមុនីនោះ កាលទ្រង់ត្រាស់ យ៉ាងនេះ

> គឺ ទ្រង់សំដែងការមិនមែនជាសស្សតវាទៈ ជាដើម
> ដោយបទខាងដើម និង ទ្រង់សំដែងការទំនាស់គ្នា
> នឹងឧច្ឆេទវាទៈ ជាដើម ដោយបទខាងចុង ទ្រង់
> សំដែងញាយធម៌ ដោយបទទាំងពីរ ។

(៣៥៦) ពាក្យថា "ដោយបទខាងដើម" សេចក្ដីថា : សភាវៈ (ការមិនមែន) ជាសស្សតវាទៈជាដើម ដែលជាប្រភេទនៃសស្សតវាទៈ អហេតុកវាទៈ, វិសមហេតុវាទៈ, វសវត្តិវាទៈ, គឺព្រះមានព្រះភាគ ទ្រង់សំដែងហើយ ដោយបទថា "បដិច្ចៈ" ដែលសំដែងការប្រជុំព្រមគ្នានៃបច្ច័យ ព្រោះភាវៈនៃបវត្តិធម៌ទាំងឡាយ មានការប្រព្រឹត្តិទៅ ជាប់ត-គ្នា ក្នុងការប្រជុំព្រមគ្នានៃបច្ច័យ ។ មែនពិត នឹងមានប្រយោជន៍អ្វី ដោយការប្រជុំព្រមគ្នានៃបច្ច័យ ដល់វាទៈដែលជាសស្សតវាទៈជាដើម ឬ ដល់វាទៈ ដែលប្រព្រឹត្តទៅ ដោយអំណាច នៃរឿងដែលមិនមែន



ជាហេតុជាដើម ។

ពាក្យថា "និង...ដោយបទខាងចុង" សេចក្ដីថា : ឧច្ឆេទវាទៈ, នត្ថិកវាទៈ និង អកិរិយវាទៈ ឈ្មោះថា ត្រូវបានកំចាត់ចោលហើយ ព្រោះការកើតឡើង នៃធម៌ទាំងឡាយ ព្រោះការប្រជុំព្រម នៃបច្ច័យ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគ ត្រាស់សំដែងការជំទាស់គ្នា នឹងឧច្ឆេទវាទៈជាដើម ដោយបទគឺសមុប្បាទ ដែលសំដែងនូវការកើតឡើងនៃធម៌ទាំងឡាយ ។ មែនពិត កាលបើធម៌ទាំងឡាយកើតឡើងរឿយៗ ម្ដងហើយម្ដងទៀត ដោយអំណាចនៃបច្ច័យខាងដើម និង ខាងដើម, ឧច្ឆេទវាទៈ, នត្ថិកវាទៈ និង អកិរិយវាទៈ នឹងមានមកពីណា ។

ពាក្យថា "ដោយបទទាំងពីរ" សេចក្ដីថា: ញាយធម៌ (ធម៌មានមគ្គជាដើម) នេះ គឺមជ្ឈិមាបដិបទា, ការលះបង់នូវវាទៈថា "បុគ្គលនោះធ្វើ, បុគ្គលនោះទទួលផល" ការលះបង់នូវវាទៈ ថា "បុគ្គលដទៃធ្វើ, បុគ្គលដទៃបានទទួលផល" ដូច្នេះ, ការមិនជាប់ចិត្ត ក្នុងភាសាអ្នកជនបទ ការមិនកន្លងវិលេងនូវសាមញ្ញា គឺព្រះមានព្រះភាគ ទ្រង់សំដែងហើយ ដោយពាក្យថា បដិច្ចសមុប្បាទ ទាំងអស់ ព្រោះធម៌ទាំងឡាយនោះៗ កើតឡើង មិនកាត់ផ្ដាច់នូវសន្តតិ (ការតភ្ជាប់គ្នា) នឹងការប្រជុំព្រមគ្នានៃបច្ច័យនោះៗ ។

នេះជាសេចក្ដីនៃពាក្យត្រឹមតែថា "បដិច្ចសមុប្បាទ" ប៉ុណ្ណោះសិន ។

(៣៥៧) ចំណែកឯ ព្រះបាលីនេះឯណា ដែលព្រះមានព្រះភាគ ទ្រង់សំដែងនូវបដិច្ចសមុប្បាទ ទ្រង់បានសំដែងទុកហើយ ដោយន័យថា "សង្ខារ កើតមាន ព្រោះអវិជ្ជា ជាបច្ច័យ" ដូច្នេះជាដើម គឺបណ្ឌិតកាលនឹងធ្វើការពណ៌នាសេចក្ដី នៃព្រះបាលីដែលព្រះមានព្រះភាគ ទ្រង់

*សំដែងទុកនោះ ចុះកាន់មណ្ឌលនៃវិកដ្ឋវាទីហើយ មិនពោលបន្ទាច់នូវអាចារ្យទាំងឡាយ ដែលមិនប្រកាន់ស្និតសកសម័យ គឺមិនប្រកាន់យកតែការបេះដឹងផ្ទាល់ខ្លួន មិនឡើងកាន់បរសម័យ គឺមិនជិះជាន់ការបេះដឹងរបស់អ្នកដទៃ មិនបដិសេធព្រះសូត្រ អនុលោមតាមព្រះវិន័យ ពិនិត្យមើលមហាបទេស សំដែងធម៌(គឺបាលី)បាន ចាប់យកអត្ថបាន រួបរួមសំដែងអត្ថនោះហ្នឹងឯង ដោយបរិយាយផ្សេងៗ ទៀត ទើបគប្បីធ្វើការពណ៌នាសេចក្តីបាន, មួយទៀត តាមប្រក្រតី ការពណ៌នាសេចក្តីនៃបដិច្ចសមុប្បាទធម៌ គឺពិតជាធ្វើបាន ដោយកម្រណាស់ សមដូចជាបុរាណាចារ្យទាំងឡាយ ពោលហើយថា :*

ធម៌ ៤ ប្រការ គឺ សច្ចៈ, សត្វ, បដិសន្ធិ និង
បច្ចយាការហ្នឹងឯង ជាធម៌ដែលយល់បាន ដោយ
លំបាក ទាំងពិបាកនឹងសំដែងថែមទៀតផង ដូច្នេះ

*ព្រោះហេតុណា, ព្រោះហេតុនោះ ការពណ៌នាសេចក្តីនៃបដិច្ចសមុប្បាទវៀរចាកបុគ្គល អ្នកបានសំរេចអាគម គឺព្រះបរិយត្តិ និង អធិគម គឺមគ្គផលហើយ អ្នកណា ក៏មិនអាចធ្វើបានដោយងាយឡើយ ព្រោះហេតុនេះ ខ្ញុំថ្លឹងថ្លែងហើយ*

មានបំណងនឹងពោលពណ៌នាបច្ចយាការ ក្នុងថ្ងៃនេះ
ទាំងពុំទាន់បានសម្រេច នូវទីពឹងអាស្រ័យ ដូចជា
ការចុះទៅកាន់សាគរ ដែលពុំទាន់បានទីពឹង ដូច្នោះ
តែពាក្យប្រៀនប្រដៅនេះ ជាពាក្យដែលប្រដាប់ប្រដា
ដោយន័យទេសនាផ្សេង ៗ ទាំងមាគ៌ា នៃអាចារ្យ



ក្នុងកាលមុន ក៏មិនសាបសូន្យ តែងប្រព្រឹត្តទៅ
ព្រោះហេតុណា, ព្រោះហេតុនោះ ខ្ញុំនឹងអាស្រ័យនូវ
ន័យទាំង ២ យ៉ាងនោះ ផ្តើមពណ៌នាសេចក្តី
នៃបដិច្ចសមុប្បាទធម៌នោះ, ចូរអ្នកទាំងឡាយតាំង
ចិត្តស្តាប់នូវការពណ៌នានោះចុះ ។

*ក៏ពាក្យនេះ បុព្វាចារ្យទាំងឡាយ ពោលហើយថា :*

“បុគ្គលឯណាមួយ បើចូលចិត្តស្តាប់ខ្ញុំ នឹងគប្បីបាន នូវគុណវិសេស ដែលមានតាំងតែពីខាងដើម រហូតដល់ចុងចប់ លុះបាននូវគុណវិសេស ដែលមានតាំងតែពីខាងដើម រហូតដល់ចុងចប់ហើយ ក៏នឹងដល់នូវឋានៈដែលមច្ចុរាជមើលមិនឃើញ” *ដូច្នេះ ។*

*ក៏ក្នុងបាលី នៃបដិច្ចសមុប្បាទ មានពាក្យថា* “សង្ខារទាំងឡាយកើតមាន ព្រោះអវិជ្ជា ជាបច្ច័យ” *ដូច្នេះជាដើម*

បណ្ឌិត គប្បីជ្រាបវិនិច្ឆ័យ ដោយប្រភេទនៃទេសនា
ដោយអត្ថ ដោយលក្ខណៈ ដោយវិធីផ្សេងៗ មានវិធី
តែមួយជាដើម និង ដោយការកំណត់អង្គទាំងឡាយ
ចាប់មុនគេ តាំងតែពីដើមតែម្តង ដូច្នេះឯង ។

(វិនិច្ឆ័យដោយប្រភេទ)

*(៣៥៨) បណ្តាបទទាំងនោះ បទថា* “ដោយប្រភេទ នៃទេសនា” *មានវិនិច្ឆ័យថា “ក៏ការសំដែងនូវបដិច្ចសមុប្បាទធម៌ នៃព្រះមានព្រះភាគ*

មាន ៤ យ៉ាង គឺ ទ្រង់សំដែងតាំងតែពីដើម រហូតដល់ចុងក៏មាន តាំងតែពីកណ្តាលរហូតដល់ចុងក៏មាន ន័យដូចគ្នានេះដែរ ទ្រង់សំដែងតាំងតែពីចុង រហូតទៅដល់ខាងដើមក៏មាន ទ្រង់សំដែងតាំងតែពីកណ្តាលរហូតទៅដល់ខាងដើមក៏មាន ប្រៀបដូចជាការចាប់យកវល្លិ៍ នៃបុរស ៤ នាក់ ដែលស្វែងរកវល្លិ ដូច្នោះឯង ។

(សំដែងតាំងពីដើមដល់ចុង)

ប្រៀបដូចជា បណ្តាបុរស ៤ នាក់ ដែលស្វែងរកវល្លិ៍ បុរសម្នាក់ឃើញគុម្ពវល្លិហ្នឹងឯងមុនគេ បុរសនោះ ក៏កាត់វល្លិ៍នោះ ត្រង់គល់ ហើយទាញយកមកទាំងអស់ ហើយនាំយកទៅ (ប្រើ) ក្នុងការងារយ៉ាងណាមិញ, ព្រះមានព្រះភាគ ក៏យ៉ាងដូច្នោះដែរ ទ្រង់សំដែងនូវបដិច្ចសមុប្បាទធម៌ តាំងតែពីដើម រហូតដល់ចុងថា "ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឯង សង្ខារទាំងឡាយ កើតមាន ព្រោះអវិជ្ជា ជាបច្ច័យ ។ល។ ជរាមរណៈ កើតមាន ព្រោះជាតិ ជាបច្ច័យ" យ៉ាងដូច្នេះ ក៏មាន ។

(សំដែងតាំងតែពីកណ្តាលដល់ចុង)

មួយទៀត បណ្តាបុរសទាំងនោះ បុរសម្នាក់ឃើញត្រង់កណ្តាលនៃវល្លិមុនគេ បុរសនោះ ក៏កាត់វល្លិ៍នោះត្រង់កណ្តាល ហើយទាញយកតែចំណែកខាងលើប៉ុណ្ណោះ ទៅ(ប្រើ) ក្នុងការងារ យ៉ាងណាមិញ, ព្រះមានព្រះភាគ ក៏យ៉ាងដូច្នោះដែរ ទ្រង់សំដែង នូវបដិច្ចសមុប្បាទធម៌ តាំងតែពីកណ្តាល រហូតដល់ខាងចុងថា "កាលបើកុមារនោះត្រេកអរ និយាយសរសើរ នៅប្រកាន់ជាប់ស្អិតនូវវេទនានោះ, សេចក្តីត្រេកអរ រមែងកើតឡើង, សេចក្តីត្រេកអរ ក្នុងវេទនាទាំងឡាយ ឯណា,



នោះ គឺជាឧបាទាន, ភព រមែងកើតមានដល់បុគ្គលនោះ ព្រោះឧបាទានជាបច្ច័យ, ជាតិ កើតមាន ព្រោះភព ជាបច្ច័យ" ដូច្នេះជាដើម ក៏មាន ។

(សំដែងពីចុងដល់ដើម)

មួយទៀត បណ្តាបុរសទាំង ៤ នាក់នោះ បុរសម្នាក់ ឃើញចុងវល្លិមុនគេ បុរសនោះ ក៏ចាប់ចុងវល្លិ៍(នោះ) ទាញយកមកទាំងអស់រហូតដល់គល់ ដោយស្រាវយកតែចុងប៉ុណ្ណោះ ហើយនាំយកទៅប្រកបការងារ យ៉ាងណាមិញ, ព្រះមានព្រះភាគ ក៏យ៉ាងដូច្នោះដែរ ទ្រង់សំដែងនូវបដិច្ចសមុប្បាទធម៌ ចាប់តាំងតែពីខាងចុង រហូតទៅដល់ខាងដើមថា "ក៏ពាក្យថា ជរាមរណៈ កើតមាន ព្រោះជាតិ ជាបច្ច័យ" ដូច្នេះនេះ គឺតថាគតពោលហើយ, ម្នាលភិក្ខុទាំងឡាយ ជរាមរណៈ កើតមាន ព្រោះជាតិជាបច្ច័យមែនឬ? ឬក៏មិនមែនទេ? ឬមួយអ្នកមានសេចក្តីយល់ឃើញ ក្នុងហេតុនេះ យ៉ាងដូចម្តេចដែរ?" ដូច្នេះ, ភិក្ខុទាំងឡាយក្រាបទូលថា "បពិត្រព្រះអង្គដ៏ចំរើន ជរាមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ, ខ្ញុំព្រះករុណាទាំងឡាយ មានសេចក្តីយល់ឃើញក្នុងរឿងនេះ យ៉ាងដូច្នេះថា "ជរាមរណៈ កើតមាន ព្រោះមានជាតិជាបច្ច័យ" ដូច្នេះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា "ពាក្យនេះ តថាគតពោលហើយថា ជាតិ កើតមាន ព្រោះភព ជាបច្ច័យ ។ល។ សង្ខារទាំងឡាយ កើតមាន ព្រោះអវិជ្ជា ជាបច្ច័យ" ដូច្នេះ, ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយ កើតមាន ព្រោះអវិជ្ជា ជាបច្ច័យមែនឬ? ឬក៏មិនមែនទេ? ឬមួយ អ្នកមានសេចក្តីយល់ឃើញ ក្នុងរឿងនេះ យ៉ាងដូចម្តេច?" ដូច្នេះជាដើម ក៏មាន ។

(សំដែងពីកណ្តាលដល់ដើម)

ម្យ៉ាងទៀត បណ្ដាបុរសទាំង ៤ នាក់នោះ បុរសម្នាក់ឃើញវល្លិ ត្រង់កណ្ដាលមុនគេបង្អស់ បុរសនោះ ក៏កាត់វល្លិ(នោះ) ត្រង់កណ្ដាល ហើយស្រាវទាញចុះទៅក្រោម រហូតដល់គល់ ស្រេចហើយក៏នាំយកទៅប្រកបការងារ យ៉ាងណាមិញ, ព្រះមានព្រះភាគ ក៏យ៉ាងដូច្នោះដែរ ទ្រង់សំដែង នូវបដិច្ចសមុប្បាទធម៌ ចាប់ផ្ដើមពីកណ្ដាល រហូតដល់ដើមថា "ម្នាលភិក្ខុទាំងឡាយ ក៏អាហារទាំង ៤ យ៉ាងនេះ មានអ្វីជាដើមហេតុ មានអ្វីជាហេតុឲ្យកើត មានអ្វីជាកំណើត មានអ្វីជាដែនកើត? អាហារទាំង ៤ យ៉ាងនេះ មានតណ្ហាជាដើមហេតុ មានតណ្ហាជាហេតុឲ្យកើត មានតណ្ហាជាកំណើត មានតណ្ហាជាដែនកើត, តណ្ហា មានអ្វីជាដើមហេតុ.... វេទនា.... ផស្សៈ.... សឡាយតនៈ.... នាមរូប............វិញ្ញាណ........... សង្ខារទាំងឡាយ មានអ្វីជាដើមហេតុ ....សង្ខារទាំងឡាយ មានអវិជ្ជា ជាដើមហេតុ ។ល។ មានអវិជ្ជាជាដែនកើត" ដូច្នេះជាដើម ក៏មាន ។

សួរថា "ក៏ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគ ទ្រង់សំដែងយ៉ាងដូច្នេះ?" ។ ឆ្លើយថា "ព្រោះបដិច្ចសមុប្បាទធម៌មានសេចក្ដីល្អ ដោយជុំវិញផង ព្រោះព្រះអង្គឯង ក៏បានសម្រេចនូវសេចក្ដីល្អ ក្នុងទេសនាផង" ។ មែនពិត បដិច្ចសមុប្បាទធម៌ ជាធម៌មានសេចក្ដីល្អ ដោយជុំវិញ ។ បដិច្ចសមុប្បាទធម៌នោះ រមែងប្រព្រឹត្តទៅ ដើម្បីបាក់ធ្ងុះនូវញេយ្យធម៌ ព្រោះទេសនានោះៗ មែនពិត ។ ឯព្រះមានព្រះភាគ ក៏ទ្រង់បានសម្រេចនូវសេចក្ដីល្អ ក្នុងការទេសនា ព្រោះប្រកបដោយវេសារជ្ជញាណ ៤ និង បដិសម្ភិទាញាណ ៤ ផង និង ព្រោះទ្រង់ដល់នូវគម្ពីរភាព ៤ យ៉ាងផង ។ ព្រះមានព្រះភាគ ទ្រង់សំដែងធម៌ ដោយ



ន័យផ្សេងៗ គ្នា ក៏ព្រោះព្រះអង្គ បានសម្រេចនូវសេចក្ដីល្អ ក្នុងការទេសនាហ្នឹងឯង ។

តែដោយការផ្សេងពីគ្នា អនុលោមទេសនា (ការសំដែងបដិច្ចសមុប្បាទធម៌ ដោយអនុលោម) តាំងតែពីដើមឯងណា, អនុលោមទេសនានោះ បណ្ឌិតគប្បីជ្រាបថា "ប្រព្រឹត្តទៅ ដល់ព្រះមានព្រះភាគអង្គនោះ ព្រះអង្គទ្រង់ពិចារណាឃើញ នូវវេនេយ្យជនដែលឈ្វក់វង្វេងក្នុងចំណែកនៃការវិលវល់ ដើម្បីទ្រង់សំដែងនូវការវិលវល់ ដោយហេតុទាំងឡាយ ដែលជារបស់ខ្លួន និង ដើម្បីទ្រង់សំដែងបង្ហាញ នូវលំដាប់នៃការកើតឡើងផង" ដូច្នេះ ។

បដិលោមទេសនា (ការសំដែងនូវបដិច្ចសមុប្បាទធម៌ ដោយបដិលោម) ចាប់ផ្ដើមពីចុងឯណា បដិលោមទេសនានោះ បណ្ឌិតគប្បីជ្រាបថា "ប្រព្រឹត្តទៅ ដល់ព្រះមានព្រះភាគអង្គនោះ ព្រះអង្គទ្រង់តាមសំឡឹងឃើញនូវសត្វលោកដែលដល់នូវសេចក្ដីលំបាក ដោយន័យថា "សត្វលោកនេះ ដល់នូវសេចក្ដីលំបាកហ្ន៎ កើតផង ចាស់ផង ស្លាប់ផង" ដូច្នេះជាដើម ដើម្បីទ្រង់សំដែងបង្ហាញហេតុ នៃសេចក្ដីទុក្ខនោះៗ មានជរា និង មរណៈជាដើម ដែលព្រះអង្គ ទ្រង់បានសម្រេចហើយ តាមលំដាប់នៃការត្រាស់ដឹង ដែលជាចំណែកខាងដើម ។

ទេសនាឯណា ដែលប្រព្រឹត្តទៅ តាំងតែពីកណ្ដាល រហូតដល់ខាងដើម, ទេសនានោះ បណ្ឌិត គប្បីជ្រាបថា "ប្រព្រឹត្តទៅ ដើម្បីទ្រង់សំដែងបង្ហាញលំដាប់នៃហេតុ និង ផល ចាប់ផ្ដើមអំពីឆ្ពង នូវអតីតទ្ធា រហូតទៅដល់អតីតទ្ធា ម្ដងទៀត តាមទំនងនៃការកំណត់ នូវដើមហេតុនៃអាហារ ។

ចំណែកទេសនា ដែលប្រព្រឹត្តទៅ ចាប់ផ្តើមពីកណ្តាល រហូតទៅដល់ចុង, ទេសនានោះ បណ្ឌិត គប្បីជ្រាបថា "ប្រព្រឹត្តទៅ ដើម្បីទ្រង់សំដែងបង្ហាញ នូវធម៌ដែលនឹងមាន ក្នុងកាលជាអនាគត ចាប់ផ្តើមពីការកើតឡើង នៃធម៌ដែលជាហេតុ នៃកាលដែលជាអនាគត ក្នុងកាលបច្ចុប្បន្ន ។

បណ្តាទេសនាទាំង ៤ យ៉ាងនោះ អនុលោមទេសនាឯណា ចាប់តាំងពីខាងដើម គឺព្រះអង្គទ្រង់ត្រាស់ហើយ ដើម្បីទ្រង់សំដែងបង្ហាញការវិលវល់ តាមហេតុទាំងឡាយ ដែលជារបស់ខ្លួន និង ដើម្បីសំដែងបង្ហាញនូវលំដាប់ នៃការកើតឡើង ដល់វេនេយ្យជន ដែលឈ្លក់វង្វេងក្នុងហេតុនៃការវិលវល់, អនុលោមទេសនានោះ បណ្ឌិត គប្បីជ្រាបថា ព្រះមានព្រះភាគ ទ្រង់បានសំដែងហើយ ក្នុងទីនេះ ។

សួរថា "ក៏ព្រោះហេតុអ្វី ក្នុងបច្ចយាការនេះ ព្រះមានព្រះភាគទ្រង់ត្រាស់អវិជ្ជាជាខាងដើម? សូម្បីអវិជ្ជា ជាធម្មជាតិមិនមានហេតុ តែជាតួនៃមូលហេតុនៃលោក ដូចជាប្រក្រតីនៃពួកបុគ្គលដែលជាបកតិវាទីឬ?" ។ ឆ្លើយថា: អវិជ្ជាមិនមែនជាធម្មជាតិមិនមានហេតុទេ ។ ព្រោះហេតុនៃអវិជ្ជា គឺព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយថា "ការកើតឡើងនៃអវិជ្ជា (កើតមាន) ព្រោះការកើតឡើងនៃអាសវៈ" ដូច្នេះ ។ តែអវិជ្ជា ជាមូលហេតុ ដោយបរិយាយណា, បរិយាយនោះ ក៏មាន ។

សួរថា "ក៏បរិយាយនេះគឺអ្វី?" ។ ឆ្លើយថា "គឺភាពនៃអវិជ្ជានោះជាកំពូលនៃហេតុក្នុងការសំដែងអំពីវដ្តៈ" ។ មែនពិត ព្រះមានព្រះភាគកាលសំដែងនូវវដ្តកថា រមែងសំដែងលើកយកនូវធម៌ ២ ប្រការ មកជាប្រធាន គឺអវិជ្ជា ក៏មាន ។ សមដូចជាព្រះអង្គត្រាស់ថា "ម្នាលភិក្ខុទាំង



ឡាយ ទីបំផុតខាងដើម នៃអវិជ្ជា មិនប្រាកដទេ, អវិជ្ជា មិនមាន ក្នុងកាលមុនអំពីកាលនេះ [១] ឬថា កើតឡើង ក្នុងកាលខាងក្រោយឡើយ ព្រោះហេតុនោះ ម្នាលភិក្ខុទាំងឡាយ ពាក្យថា អវិជ្ជានេះ តថាគតពោលយ៉ាងនេះ តែថាអវិជ្ជាតែងប្រាកដ ព្រោះមានរបស់នេះជាបច្ច័យ" ដូច្នេះ ។ គឺភវតណ្ហា ក៏មាន ។ សមដូចព្រះអង្គត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ទីបំផុតខាងដើមនៃភវតណ្ហា មិនប្រាកដទេ, ភវតណ្ហា មិនមានក្នុងកាលមុនអំពីកាលនេះ ឬថា កើតឡើង ក្នុងកាលខាងក្រោយឡើយ ព្រោះហេតុនោះ ម្នាលភិក្ខុទាំងឡាយ! ក៏ពាក្យថា ភវតណ្ហានេះតថាគត ពោលយ៉ាងនេះ តែថា ភវតណ្ហា រមែងប្រាកដ ព្រោះមានរបស់នេះ ជាបច្ច័យ" ដូច្នេះជាដើម ។

សួរថា "ក៏ព្រោះហេតុអ្វី ព្រះមានព្រះភាគ កាលទ្រង់សំដែងនូវវដ្តកថា ទើបទ្រង់ត្រាស់ ដោយលើកយកធម៌ ២ ប្រការនេះ មកជាប្រធាន?" ។ ឆ្លើយថា "ព្រោះធម៌ទាំង ២ ប្រការនេះ ជាហេតុពិសេសនៃកម្មដែលធ្វើសត្វឲ្យដល់នូវសុគតិ និង ទុគ្គតិ" ។ មែនពិត អវិជ្ជា ជាហេតុវិសេសនៃកម្ម ដែលញ៉ាំងសត្វឲ្យដល់នូវទុគ្គតិ ។ តើព្រោះហេតុអ្វី? ។ ព្រោះពួកបុថុជ្ជន ដែលត្រូវអវិជ្ជា គ្របសង្កត់ហើយ រមែងប្រារព្ធធ្វើនូវកម្ម ដែលញ៉ាំងសត្វឲ្យដល់នូវទុគ្គតិ មានប្រការផ្សេងៗមានបាណាតិបាតជាដើម ដែលមិនមានអ្វីជាទីពេញចិត្តសោះ ព្រោះក្តៅក្រហាយដោយកិលេសផង ទាំងនាំមកនូវហេតុដែលមិនចំរើន ដល់ខ្លួនព្រោះធ្វើឲ្យធ្លាក់ចុះទៅ ក្នុងទុគ្គតិផង ប្រៀបដូចជាសត្វគោ ដែលគេនឹងសម្លាប់ ត្រូវការនឿយហត់ ព្រោះត្រូវដុតរោលដោយភ្លើង និង ត្រូវគេ

១- សុ. អំ. ទ. ភាគទី ៥០ ទំព័រទី ២៨៦ ។

សំពងដោយដំបង គ្របសង្កត់ហើយ តែងស្ទុះស្ទាផឹកនូវទឹកក្តៅដែលមិនមានអ្វីជាទីពេញចិត្តផង ទាំងនាំមកនូវសេចក្តីវិនាស ដល់ខ្លួនផង ព្រោះក្រហល់ក្រហាយ ដោយការនឿយហត់នោះ យ៉ាងដូច្នោះឯង ។

ចំណែកភវតណ្ហា ជាហេតុវិសេសនៃកម្ម ដែលធ្វើសត្វឲ្យដល់នូវសុគតិ ។ ព្រោះហេតុអ្វី? ។ ព្រោះពួកបុថុជ្ជន ដែលត្រូវភវតណ្ហាគ្របសង្កត់ហើយ រមែងព្យាយាមធ្វើកម្ម ដែលធ្វើសត្វឲ្យដល់នូវសុគតិ មានប្រការផ្សេងៗ មានការវៀរចាកនូវការសម្លាប់សត្វមានជីវិតជាដើម ជាកម្មដែលមានគុណជាទីពេញចិត្តផង ព្រោះប្រាសចាកសេចក្តីក្តៅក្រហាយដោយសារកិលេសផង ជាកម្មដែលបន្ទោបង់នូវសេចក្តីក្រវល់ក្រវាយ ដោយសារសេចក្តីទុក្ខ ក្នុងទុគ្គតិ របស់ខ្លួនផង ព្រោះញ៉ាំងបុគ្គលអ្នកធ្វើ ឲ្យដល់នូវសុគតិ ដូចជាគោដែលមានអាការៈដូចពោលមកហើយនោះ ព្យាយាមរកទឹកត្រជាក់ផឹក ជាទឹកដែលមានរសជាតិឆ្ងាញ់ផង ជាទឹកដែលបន្ទោបង់ នូវសេចក្តីនឿយហត់ របស់ខ្លួនបានផង ព្រោះស្រេកឃ្លានទឹកត្រជាក់ យ៉ាងនេះឯង ។

ឯក្នុងធម៌ដែលជាប្រធាន ក្នុងវដ្តកថានេះ ក្នុងព្រះសូត្រខ្លះ ព្រះមានព្រះភាគ ទ្រង់សំដែងធម៌ទេសនា លើកយកធម៌មួយ មកជាមូលហេតុ ។ ធម៌នេះ តើយ៉ាងដូចម្តេច? ។ គឺព្រះបាលីថា “ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយ មានអវិជ្ជាជាហេតុ, វិញ្ញាណ មានសង្ខារ ជាហេតុ យ៉ាងនេះឯង” ដូច្នេះជាដើម [១] ។ មួយទៀត ដូចព្រះបាលីថា “ម្នាលភិក្ខុទាំងឡាយ តណ្ហា រមែងចំរើន ដល់បុគ្គលអ្នកពិចារណាឃើញតែសេចក្តីត្រេកអរ ក្នុងធម៌ទាំងឡាយ ដែលជាទីតាំងនៃឧបាទាន,

១- សុ. សំ. និ. ភាគទី ៣១ ទំព័រទី ៦៨ ។



ឧបាទាន កើតមាន ព្រោះតណ្ហាជាបច្ច័យ” ដូច្នេះជាដើម [១] ។ ក្នុងព្រះសូត្រខ្លះ ព្រះមានព្រះភាគ ទ្រង់សំដែងធម៌ទេសនា លើកយកធម៌ទាំងពីរប្រការមកជាមូលហេតុផង ក៏មានខ្លះដែរ ។ នេះ តើយ៉ាងដូចម្តេច? ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពាលដែលមានអវិជ្ជាជាគ្រឿងរាំង ដែលប្រកបដោយតណ្ហា រមែងមានកាយគឺបដិសន្ធិនេះ កើតឡើងយ៉ាងនេះឯង, ដ្បិតផស្សៈ រមែងកើតឡើង ព្រោះអាស្រ័យនូវធម៌ជាគូៗ នឹងគ្នាទុំះ យ៉ាងនេះ គឺកាយនេះផង នាមរូបខាងក្រៅផង, បុគ្គលពាលដែលផស្សាយតនៈទាំង ៦ ឬក៏ បណ្តាផស្សៈទាំងនោះ ណានីមួយពាល់ត្រូវហើយ រមែងទទួលនូវសុខ និង ទុក្ខ” ដូច្នេះជាដើម [២] ។

បណ្តាព្រះធម៌ទេសនាទាំងនោះ ព្រះធម៌ទេសនាថា “សង្ខារទាំងឡាយ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ” ដូច្នេះជាដើម ចំពោះក្នុងទីនេះ បណ្ឌិតគប្បីជ្រាបថា “ជាព្រះធម៌ទេសនា ដែលមានធម៌មួយជាប្រធាន ដោយអំណាចនៃអវិជ្ជា (លើកយកអវិជ្ជា មកជាប្រធាន)” ដូច្នេះ ។

សេចក្តីវិនិច្ឆ័យ ដោយប្រភេទ នៃទេសនា ក្នុងបដិច្ចសមុប្បាទធម៌នេះ បណ្ឌិតគប្បីជ្រាប យ៉ាងនេះឯង ជាមុនសិន ។

**(វិនិច្ឆ័យដោយអត្ថ)**

(៣៥៩) ពាក្យថា “ដោយអត្ថ” គឺដោយសេចក្តី នៃបទទាំងឡាយ មានបទថា អវិជ្ជាជាដើម ។ អត្ថនេះ តើយ៉ាងដូច្នេះខ្លះ? ។

**(អវិជ្ជា)**

(១) អកុសលកម្ម មានកាយទុច្ចរិតជាដើម ឈ្មោះថា អវិន្ទិយៈ ប្រែថា មិនគួរបាន ព្រោះអត្ថថា មិនគួរបំពេញ ។ ធម្មជាតិណា រមែង

១- សុ. សំ. សគ. ភាគទី ៣០ ទំព័រទី ១៨៥ ។ ២- ភាគទី ៣០ ទំព័រទី៥០ ។

បាននូវអវិន្ទិយៈនោះ ហេតុនោះ ធម្មជាតិនោះ ទើបឈ្មោះថា អវិជ្ជា (បាននូវរបស់ដែលមិនគួរបាន) ។

(២) កុសលកម្ម មានកាយសុចរិតជាដើម ឈ្មោះថា វិន្ទិយៈ (ប្រែថា គួរបាន) ព្រោះអត្ថថា ខុសប្លែកគ្នាពីអវិន្ទិយៈនោះ ធម្មជាតិណា មិនបាននូវវិន្ទិយៈនោះ ហេតុនោះ ធម្មជាតិនោះ ទើបឈ្មោះថា អវិជ្ជា (មិនបានរបស់ដែលគួរបាន) ។

(៣) ធម្មជាតិណា ធ្វើអត្ថគឺភាពជាក្រុមនៃខន្ធទាំងឡាយ មិនឲ្យប្រាកដ ធ្វើអត្ថគឺគ្រឿងតភ្ជាប់នៃអាយតនៈទាំងឡាយ មិនឲ្យប្រាកដ ធ្វើអត្ថគឺការសូន្យទទេ នៃធាតុទាំងឡាយមិនឲ្យប្រាកដ ធ្វើអត្ថ គឺភាពជាធំ នៃឥន្ទ្រិយទាំងឡាយ មិនឲ្យប្រាកដ ធ្វើអត្ថគឺភាពពិតប្រាកដ នៃសច្ចៈទាំងឡាយ មិនឲ្យប្រាកដ ព្រោះហេតុនោះ ធម្មជាតិនោះ ទើបឈ្មោះថា អវិជ្ជា (ធ្វើអត្ថ នៃខន្ធជាដើម មិនឲ្យប្រាកដ) ។

(៤) ធម្មជាតិណា ធ្វើអត្ថ ៤ យ៉ាង ដែលបានពោលមកហើយ ដោយអំណាចនៃអត្ថ មានការបៀតបៀនជាដើម នៃសច្ចៈ មានទុក្ខសច្ចៈជាអាទិ៍ មិនឲ្យប្រាកដ ហេតុនេះ ធម្មជាតិនោះ ទើបឈ្មោះថា អវិជ្ជា (ធ្វើអត្ថ នៃអរិយសច្ច មិនឲ្យប្រាកដ) ។

(៥) ធម្មជាតិណា ញ៉ាំងសត្វទាំងឡាយ ឲ្យស្ទុះទៅក្នុងកំណើត, គតិ, ភព, វិញ្ញាណដ្ឋិតិ និង សត្តាវាសទាំងពួង ក្នុងសំសារដែលប្រាសចាកទីបំផុត ហេតុនោះ ធម្មជាតិនោះ ទើបឈ្មោះថា អវិជ្ជា (ញ៉ាំងសត្វឲ្យស្ទុះទៅ ក្នុងសង្សារដែលប្រាសចាកទីបំផុត) ។

(៦) ធម្មជាតណា ស្ទុះទៅក្នុងបញ្ញត្តិធម៌ទាំងឡាយ មានស្ត្រី និង បុរសជាដើម ដែលមិនមានដោយបរមត្ថ មិនស្ទុះទៅ ក្នុងបញ្ញត្តិធម៌ទាំង



ឡាយមានខន្ធជាដើម សូម្បីមានដោយបរមត្ថ ហេតុនេះ ធម្មជាតិនោះ ទើបឈ្មោះថា អវិជ្ជា (ស្ទុះទៅ ក្នុងអវិជ្ជមានបញ្ញត្តិ ឬ មិនស្ទុះទៅ ក្នុងវិជ្ជមានបញ្ញត្តិ) ។

(៧) មួយវិញទៀត ធម្មជាតិនោះ ឈ្មោះថា អវិជ្ជា ព្រោះបិទបាំងនូវវត្ថុ និង អារម្មណ៍នៃវិញ្ញាណមានចក្ខុវិញ្ញាណជាដើម និង នូវធម៌ទាំងឡាយ ដែលជាបដិច្ចសមុប្បាទ (គឺបច្ច័យ) ផង ទាំងបដិច្ចសមុប្បន្ន (គឺផល) ផង ដូច្នេះក៏បាន ។

(បច្ច័យ)

ផល អាស្រ័យធម៌ណា ប្រព្រឹត្តទៅ ធម៌នោះ ឈ្មោះថា បច្ច័យ ។ ពាក្យថា “បដិច្ច គឺអាស្រ័យ” សេចក្តីថា មិនលើកលែងមិនបដិសេធ ។ ពាក្យថា “ឯតិ គឺទៅ” សេចក្តីថា កើតឡើង និង ប្រព្រឹត្តទៅ ។ មួយទៀត អត្ថថា ឧបការកៈ អ្នកឧបត្ថម្ភ ជាអត្ថនៃបច្ច័យស័ព្ទ ។

អវិជ្ជាផង អវិជ្ជានោះ ជាបច្ច័យផង ហេតុនោះ ទើបឈ្មោះថា អវិជ្ជាបច្ចយៈ ប្រែថា អវិជ្ជាជាបច្ច័យ ។ ព្រោះអវិជ្ជា ជាបច្ច័យនោះ ។

(សង្ខារ)

ធម៌ទាំងឡាយណា តាក់តែងនូវសង្ខតធម៌ ហេតុនោះ ធម៌ទាំងឡាយនោះ ទើបឈ្មោះថា សង្ខារ (ធម៌ជាអ្នកតាក់តែងឡើង) ។ តែថា សង្ខារ មានពីរយ៉ាង គឺ សង្ខារដែលមានអវិជ្ជា ជាបច្ច័យ ១ សង្ខារ ដែលមកហើយ ដោយសង្ខារស័ព្ទ ១ ។

បណ្តាសង្ខារទាំងពីរយ៉ាងនោះ សង្ខារទាំងនេះ គឺ បុញ្ញាភិសង្ខារ, អបុញ្ញាភិសង្ខារ និង អនេញ្ជាភិសង្ខារ ត្រូវជា៣, កាយសង្ខារ, វចីសង្ខារ និងចិត្តសង្ខារត្រូវជា៣ ដែរ រួមត្រូវជា៦ ជាអវិជ្ជាបច្ច័យសង្ខារ ។

អវិជ្ជាបច្ចយសង្ខារទាំងអស់នោះ បានដល់កុសលចេតនា និង អកុសលចេតនា ផ្នែកលោកិយហ្នឹងឯង ។ ចំណែកសង្ខារទាំងឡាយ ៤ នោះ គឺ : សង្ខតសង្ខារ (សង្ខារដែលត្រូវបច្ច័យ របស់ខ្លួន តាក់តែងឡើង) អភិសង្ខតសង្ខារ (សង្ខារដែលត្រូវកម្មតាក់តែងឡើង) អភិសង្ខរណកសង្ខារ (សង្ខារ គឺតួកម្មដែលជាម្ចាស់តាក់តែងឡើង) បយោគាភិសង្ខារ (សង្ខារ គឺការព្យាយាម) ជាសង្ខារដែលមកហើយ ដោយសង្ខារសព្ទ ។

ក្នុងសង្ខារទាំងឡាយ ៤ យ៉ាងនោះ ធម៌ដែលមានបច្ច័យទាំងពួងដែលបានពោលហើយ ក្នុងបាលីទាំងឡាយ មានពាក្យថា "សង្ខារទាំងឡាយ មិនទៀងមែនពិត" ដូច្នេះជាដើម ឈ្មោះថា សង្ខតសង្ខារ ។ អភិសង្ខតសង្ខារ ដែលបានពោលមកហើយ ក្នុងអដ្ឋកថាទាំងឡាយថា "រូបធម៌ និង អរូបធម៌ទាំងឡាយ ដែលកើតអំពីកម្ម ប្រព្រឹត្តទៅ ក្នុងត្រៃភូមិ ឈ្មោះថា អភិសង្ខតសង្ខារ" ដូច្នេះ, សូម្បីអភិសង្ខតសង្ខារទាំងឡាយនោះ ក៏ដល់នូវការសង្គ្រោះចូល ក្នុងបាលីនេះ ថា "សង្ខារទាំងឡាយ មិនទៀងមែនពិត" ដូចគ្នាដែរ ។ ប៉ុន្តែអាគតដ្ឋាន(ទីជាទីមក) នៃអភិសង្ខតសង្ខារទាំងឡាយនោះ មិនបានប្រាកដ ដោយចំពោះទេ ។ ចំណែកកុសលចេតនា និង អកុសលចេតនា ដែលប្រព្រឹត្តទៅ ក្នុងត្រៃភូមិ លោកហៅថា អភិសង្ខរណកសង្ខារ ។ អាគតដ្ឋាន នៃអភិសង្ខរណកសង្ខារនោះ ប្រាកដ ក្នុងបាលីទាំងឡាយ មានជាអាទិ៍ ថា "ម្នាលភិក្ខុទាំងឡាយ បុរសបុគ្គលនេះធ្លាក់ចុះទៅ ក្នុងអវិជ្ជា រមែងសាងនូវសង្ខារ គឺបុណ្យខ្លះ" ដូច្នេះជាដើម ។ ចំណែកឯ សេចក្តីព្យាយាមដែលប្រព្រឹត្តទៅតាមផ្លូវកាយ និង ផ្លូវចិត្ត លោកហៅថា បយោគាភិសង្ខារ ។ បយោគាភិសង្ខារនោះ មកហើយ ក្នុងបាលីទាំងឡាយ ថា



"ការប្រព្រឹត្តិទៅ នៃអភិសង្ខារ មានប្រមាណត្រឹមណា, បុគ្គលនោះ ក៏ដើរទៅ បានប្រមាណត្រឹមនោះហើយ ក៏ឈប់ ដូចជារទេះដែលបាក់ភ្លៅយ៉ាងនោះឯង" ដូច្នេះជាដើម ។

មួយទៀត សង្ខារដែលមកហើយ ដោយសង្ខារសព្ទ មិនមែនមានត្រឹមតែសង្ខារទាំងឡាយ ៤ យ៉ាងនេះ ប៉ុណ្ណោះទេ, សង្ខារទាំងឡាយផ្សេងៗ ទៀត ដែលមកដោយសង្ខារសព្ទក៏មានច្រើនជាអនេកដែរ ដោយន័យមានន័យជាអាទិ៍ ថា "ម្នាលវិសាខៈ ដ៏មានអាយុ កាលបើភិក្ខុចូលសញ្ញាវេទយិតនិរោធ វចីសង្ខារ រលត់មុនគេ បន្ទាប់ពីនោះមកកាយសង្ខារ រលត់ បន្ទាប់អំពីនោះមកទៀត ទើបចិត្តសង្ខារ រលត់" ដូច្នេះ ។ បណ្តាសង្ខារទាំងឡាយនោះ សង្ខារណា មិនគប្បីដល់នូវការសង្គ្រោះ ក្នុងសង្ខតសង្ខារ, សង្ខារនោះ មិនមានទេ ។

(អត្ថនៃសព្ទមានវិញ្ញាណជាដើម)

ពាក្យតទៅនេះ លោកពោលហើយ ក្នុងបាលីទាំងឡាយ មានជាដើមថា "វិញ្ញាណ កើតមាន ព្រោះបច្ច័យគឺសង្ខារ" ដូច្នេះ បណ្ឌិតគប្បីជ្រាប តាមន័យដែលបានពោលហើយនុ៎ះឯង ។ ចំណែកក្នុងពាក្យដែលលោកមិនបានពោលហើយ បណ្ឌិត គប្បីជ្រាបដូចតទៅនេះ ។

ធម្មជាតណា ដឹង (នូវអារម្មណ៍ផ្សេងៗ) ហេតុនោះ ធម្មជាតនោះ ឈ្មោះថា វិញ្ញាណ ។ ធម្មជាត ណា បង្អោនទៅរក (អារម្មណ៍) ហេតុនោះ ធម្មជាតនោះ ឈ្មោះថា នាម ។ ធម្មជាត ណា បែកធ្លាយ ហេតុនោះ ធម្មជាតនោះ ឈ្មោះថា រូប ។ ធម្មជាត ណា ផ្សាយទៅ ក្នុងអាយៈ (គឺការរីកចំឡើង) និង នាំទៅកាន់អាយតៈ (គឺការតទៅមុខ) ហេតុនោះ ធម្មជាតនោះ ឈ្មោះថា អាយតនៈ ។ សភាវៈណាពាល់ត្រូវ

*ហេតុនោះ សភាវៈនោះ ឈ្មោះថា ផស្សៈ ។ ធម្មជាតិណា ដឹង(សោយនូវអារម្មណ៍) ហេតុនោះ ធម្មជាតិនោះ ឈ្មោះថា វេទនា ។ ធម្មជាតិណា ក្រហល់ក្រហាយស្រេកឃ្លាន (នូវអារម្មណ៍) ហេតុនោះ ធម្មជាតិនោះ ឈ្មោះថា តណ្ហា ។ ធម្មជាតិណា ប្រកាន់មាំ ហេតុនោះ ធម្មជាតិនោះ ឈ្មោះថា ឧបាទាន ។ សភាវៈណា កើត ឬ ញុំាងសត្វឲ្យកើត ហេតុនោះ សភាវៈនោះ ឈ្មោះថា ភព ។ ការកើត ឈ្មោះថា ជាតិ ។ ការចាស់ជរាគ្រាំគ្រា ឈ្មោះថា ជរា ។ សត្វទាំងឡាយ តែងស្លាប់ដោយធម្មជាតនោះ ព្រោះហេតុនោះ ធម្មជាតនោះ ទើបឈ្មោះថា មរណៈ ។ ការសោកសៅ ឈ្មោះថា សោកៈ ។ ការខ្សឹកខ្សួល ឈ្មោះថា បរិទេវៈ ។ ធម្មជាត ណា ញុំាងសត្វឲ្យលំបាក ហេតុនោះ ធម្មជាតនោះ ឈ្មោះថា ទុក្ខ ។ មួយទៀត ធម្មជាត ណា ជីកដោយចំណែកពីរ ដោយអំណាចនៃការកើតឡើង និង ការតាំងនៅ ហេតុនោះ ធម្មជាតនោះ ឈ្មោះថា ទុក្ខ ។*

*ភាវៈនៃបុគ្គលជាអ្នកមិនសប្បាយចិត្ត ឈ្មោះថា ទោមនស្ស ។ ការក្រៀមក្រំចិត្ត យ៉ាងខ្លាំង ឈ្មោះថា ឧបាយាសៈ ។*

*ពាក្យថា* “សម្ភវន្តិ” *ប្រែថា កើតឡើង ។ ម្យ៉ាងទៀត បណ្ឌិតមិនគប្បីធ្វើការប្រកប សម្ភវន្តិស័ព្ទ ចូលជាមួយបទទាំងឡាយមានបទថា សោកជាដើមតែម្យ៉ាងប៉ុណ្ណោះទេ គប្បីធ្វើការប្រកបសម្ភវន្តិស័ព្ទចូលជាមួយបទទាំងពួងផងដែរ ។ ព្រោះថា កាលបើពោល ដោយប្រការដទៃ ថា* “អវិជ្ជា បច្ចយា សង្ខារា” *សេចក្តី ក៏មិនបានប្រាកដច្បាស់ថា “សង្ខារទាំងឡាយ ធ្វើនូវអ្វី” ដូច្នេះ ។ តែកាលបើមានប្រកបស័ព្ទ ថា* “សម្ភវន្តិ” *ដូច្នេះ ក៏រមែងបានធ្វើការកំណត់ទាំង*



*បច្ចយធម៌ ទាំងបច្ចយុប្បន្នធម៌ ថា “អវិជ្ជាផង អវិជ្ជានោះ ជាបច្ច័យផង ព្រោះហេតុនោះ ទើបឈ្មោះថា អវិជ្ជាបច្ចយៈ, សង្ខារទាំងឡាយ រមែងកើតមាន ព្រោះអវិជ្ជា ជាបច្ច័យនោះ” ដូច្នេះ ។ ក្នុងបទទាំងពួង ក៏មានន័យដូចគ្នានេះដែរ ។*

*ពាក្យថា* “ឯវំ” *ជាពាក្យសំដែងន័យ ដែលបានសំដែងមកហើយ ។ ដោយពាក្យ* ឯវំ *នោះ សំដែង ថា “បច្ចុប្បន្នធម៌ទាំងឡាយ កើតឡើង ព្រោះបច្ចយធម៌ទាំងឡាយ មានអវិជ្ជាជាដើមហ្នឹងឯងជាហេតុ មិនមែនកើតឡើង ព្រោះអ្នកមានអំណាចបង្កើតជាដើមឡើយ” ។ ពាក្យថា* “ឯតស្ស” *គឺតាមដែលបានពោលមកហើយ ។ ពាក្យថា* “កេវលស្ស” *ប្រែថា មិនលាយឡំគ្នា (នឹងសេចក្តីសុខ) ឬថា ទាំងអស់ ។ ពាក្យថា* “ទុក្ខក្ខន្ធស្ស” *ប្រែថា កងទុក្ខគឺមិនមែនជាសត្វ មិនមែនជាសុខ មិនមែនជារបស់ល្អជាដើម ។ ពាក្យថា* “សមុទយោ” *ប្រែថា ការកើតឡើង ។ ពាក្យថា* “ហោតិ” *ប្រែថា កើតមាន ។*

*សេចក្តីវិនិច្ឆ័យ ដោយអត្ថ ក្នុងបាលីបដិច្ចសមុប្បាទនេះ បណ្ឌិតគប្បីជ្រាប ដូចបានពណ៌នាមកនេះឯង ។*

(វិនិច្ឆ័យដោយលក្ខណៈជាដើម)

*(៣៦០) ពាក្យថា* “ដោយលក្ខណៈជាដើម” *គឺដោយលក្ខណៈជាដើម នៃបទទាំងឡាយ មានអវិជ្ជាជាដើម ។ លក្ខណៈជាដើមនេះ តើយ៉ាងដូចម្តេច? ។*

*អវិជ្ជា មានការមិនដឹង ជាលក្ខណៈ, មានការធ្វើឲ្យវង្វេង ជារស, មានការបិទបាំង ជាបច្ចុប្បដ្ឋាន, មានអាសវៈ ជាបទដ្ឋាន ។*

*សង្ខារ មានការតាក់តែង ជាលក្ខណៈ, មានព្យាយាម (ដើម្បីកើត*

បដិសន្ធិ) ជារស, មានចេតនា ជាបច្ចុប្បដ្ឋាន, មានអវិជ្ជា ជាបទដ្ឋាន ។

វិញ្ញាណ មានការវិសេស ជាលក្ខណៈ, មានភាពជាប្រធាន (នៃនាមរូប) ជារស, មានបដិសន្ធិ ជាបច្ចុប្បដ្ឋាន, មានសង្ខារ ជាបទដ្ឋាន, ឬថា មានវត្ថុ និង អារម្មណ៍ ជាបទដ្ឋាន ។

នាម មានការបង្អោនចូលទៅ (កាន់អារម្មណ៍) ជាលក្ខណៈ, មានការប្រកបព្រម ជារស, មានការមិនបែកពីគ្នា ជាបច្ចុប្បដ្ឋាន, មានវិញ្ញាណ ជាបទដ្ឋាន ។

រូបមានការបែកធ្លាយ ជាលក្ខណៈ, មានការខ្ចាត់ខ្ចាយទៅ ជារស, មានភាពជាអព្យាក្រឹត ជាបច្ចុប្បដ្ឋាន, មានវិញ្ញាណ ជាបទដ្ឋាន ។

សឡាយតនៈ មានការតភ្ជាប់គ្នា ជាលក្ខណៈ, មានការឃើញជាដើម ជារស, មានភាពជាវត្ថុ និង ទ្វារ ជាបច្ចុប្បដ្ឋាន, មាននាមរូប ជាបទដ្ឋាន ។

ផស្សៈ មានការពាល់ត្រូវ ជាលក្ខណៈ, មានការប៉ះទង្គិច ជារស, មានការជួបប្រទះ ជាបច្ចុប្បដ្ឋាន, មានសឡាយតនៈ ជាបទដ្ឋាន ។

វេទនា មានការតាមសោយ ជាលក្ខណៈ, មានការសោយនូវរស ជារស, មានសុខ និង ទុក្ខ ជាបច្ចុប្បដ្ឋាន, មានផស្សៈ ជាបទដ្ឋាន ។

តណ្ហា មានភាពជាហេតុ (គឺជាហេតុឲ្យកើតទុក្ខ) ជាលក្ខណៈ, មានការត្រេកអរ ជារស, មានការមិនចេះឆ្អែត ជាបច្ចុប្បដ្ឋាន, មានវេទនា ជាបទដ្ឋាន ។

ឧបាទាន មានកិរិយាប្រកាន់ ជាលក្ខណៈ, មានការមិនស្រាយចេញ ជារស, មានការយល់ឃើញ ដោយអំណាចនៃការរឹងមាំនៃតណ្ហា ជាបច្ចុប្បដ្ឋាន, មានតណ្ហា ជាបទដ្ឋាន ។



ភព មានកម្ម និង ផលនៃកម្ម ជាលក្ខណៈ, មានការជួបប្រសព្វនូវការកើតមាន ជារស, មានកុសល, អកុសល និង អព្យាក្រឹត ជាបច្ចុប្បដ្ឋាន, មានឧបាទាន ជាបទដ្ឋាន ។

លក្ខណៈជាដើម នៃជាតិជាដើម បណ្ឌិត គប្បីជ្រាប តាមន័យដែលបានពោលហើយ ក្នុងសច្ចនិទ្ទេសនុ៎ះចុះ ។

បណ្ឌិត គប្បីជ្រាបវិនិច្ឆ័យ ដោយលក្ខណៈជាដើម ក្នុងបាលីបដិច្ចសមុប្បាទធម៌នេះ ដូចបានពណ៌នាមកនេះឯង ជាប្រការមួយ ។

(ដោយប្រការផ្សេងៗ មានប្រការ ១ ជាដើម)

(៣៦១) ក្នុងបទថា “ដោយប្រការផ្សេងៗ មានប្រការ ១ ជាដើម” មានវិនិច្ឆ័យថា : អវិជ្ជា មានតែមួយ ព្រោះភាវៈគឺការមិនដឹង ការមិនឃើញ ឬ ការវង្វេងជាដើម, មាន ២ យ៉ាង ព្រោះការមិនប្រតិបត្តិ និង ប្រតិបត្តិខុស, មួយទៀត មាន ២ យ៉ាង ព្រោះសង្ខារ និង អសង្ខារ, មាន ៣ យ៉ាង ព្រោះប្រកបព្រមដោយវេទនា ៣ យ៉ាង, មាន ៤ យ៉ាង ព្រោះការមិនចាក់ធ្លុះ នូវសច្ចៈ ៤, មាន ៥ យ៉ាង ព្រោះបិទបាំងនូវទោស ក្នុងគតិ ៥, ចំណែកភាវៈនៃតណ្ហា មាន ៦ យ៉ាង ក្នុងអង្គនៃបដិច្ចសមុប្បាទធម៌ ដែលជាអរូបធម៌ទាំងអស់ បណ្ឌិត គប្បីជ្រាប តាមទ្វារ និង អារម្មណ៍ ។

សង្ខារ មានតែមួយ ព្រោះជាសាសវធម៌ ជាវិបាកធម៌ជាធម្មតាជាដើម, មាន ២ យ៉ាង ព្រោះជាកុសល និង អកុសល, មួយទៀត មាន ២ យ៉ាង ព្រោះជាបរិត្តៈ, មហគ្គតៈ, ហីនៈ, មជ្ឈិមៈ, មិច្ឆត្តៈ, សម្មត្តៈ, និយតៈ, ជាអនិយតៈ, មាន ៣ យ៉ាង ព្រោះជាអភិសង្ខារ ៣ មានបុញ្ញាភិសង្ខារ ជាដើម, មាន ៤ យ៉ាង ព្រោះឲ្យប្រព្រឹត្តទៅ ក្នុង

កំណើត ៤, មាន ៥ យ៉ាង ព្រោះញ៉ាំងសត្វ ឲ្យទៅកើត ក្នុងគតិ ៥ ។

វិញ្ញាណ មានតែមួយ ព្រោះភាពជាលោកិយវិបាកជាដើម, មាន ២ យ៉ាង ព្រោះជាសហេតុកៈ និង អហេតុកៈជាដើម, មាន ៣ យ៉ាង ព្រោះរាប់បញ្ចូល ក្នុងភពបី ព្រោះប្រកបព្រមដោយវេទនាបី និង ព្រោះជាអហេតុកៈ, ទុហេតុកៈ និង តិហេតុកៈ, មាន ៤ យ៉ាង និង មាន ៥ យ៉ាង ដោយអំណាចនៃកំណើត (៤) និង គតិ (៥) ។

នាមរូប មានតែមួយ ព្រោះជាទីអាស្រ័យនៃវិញ្ញាណ និង ព្រោះជាបច្ច័យនៃកម្ម, មាន ២ យ៉ាង ព្រោះមានអារម្មណ៍ និង មិនមានអារម្មណ៍, មាន ៣ យ៉ាង ព្រោះកាលដែលជាអតីតៈជាដើម, មាន ៤ យ៉ាង និង មាន ៥ យ៉ាង ដោយអំណាចនៃកំណើត និង គតិ ។

សឡាយតនៈ មានតែមួយ ព្រោះជាទីកើតព្រម និង ជាទីប្រជុំព្រម, មាន ២ យ៉ាង ព្រោះជាទីជ្រះថ្លានៃភូតរូប និងជាហេតុដឹងពិសេសជាដើម, មាន ៣ យ៉ាង ព្រោះទទួលអារម្មណ៍ដែលមកដល់, អារម្មណ៍ដែលមិនទាន់បានមកដល់ និង ទទួលអារម្មណ៍ ដែលមិនមែនទាំង ២ យ៉ាងនោះ, មាន ៤ យ៉ាង និង មាន ៥ យ៉ាង ព្រោះរាប់បញ្ចូល ក្នុងកំណើត និង គតិ” ។

សូម្បីភាវៈមានផ្សេងៗ មាន ១ យ៉ាងជាដើម នៃអង្គដែលសេសសល់ មានផស្សៈជាអាទិ៍ បណ្ឌិត គប្បីជ្រាប តាមន័យនេះផងចុះ ។

បណ្ឌិត គប្បីជ្រាបសេចក្តីវិនិច្ឆ័យ ដោយភពផ្សេងៗ មានមួយយ៉ាងជាដើម ក្នុងបាលីបដិច្ចសមុប្បាទនេះ ដូចបានពណ៌នាមកនេះឯង ប្រការមួយ ។

(ដោយកំណត់អង្គ)



(៣៦២) ក្នុងពាក្យថា “និងដោយកំណត់អង្គទាំងឡាយ” មានវិនិច្ឆ័យថា ក៏ក្នុងបដិច្ចសមុប្បាទធម៌ទាំងនេះ ធម៌ទាំងឡាយមានសេចក្តីសោកជាដើម ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ដើម្បីសំដែងនូវការមិនដាច់រយៈ នៃភវចក្រ ។ ព្រោះធម៌មានសេចក្តីសោកជាដើមនោះ រមែងកើតមាន ដល់បុគ្គលដែលត្រូវជរា និង មរណៈប៉ះទង្គិចហើយ ។ សមដូចជាព្រះអង្គត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនអ្នកមិនបានស្តាប់ហើយ ជាអ្នកត្រូវទុក្ខវេទនា ខាងផ្លូវកាយពាល់ត្រូវហើយ រមែងសៅសោក លំបាក ខ្សឹកខ្សួល គក់ទ្រូងគគ្រក់កន្ទេញ ដល់នូវការវង្វេងវង្វន់” ដូច្នេះជាដើម ។ មួយទៀត ព្រោះព្រះពុទ្ធវចនៈ ថា “ការប្រព្រឹត្តិទៅ នៃធម៌ទាំងឡាយ មានសេចក្តីសោកសៅជាដើមនោះ នៅមានជរាបណា, ការប្រព្រឹត្តិទៅនៃអវិជ្ជា ក៏នៅតែមាន ជរាបនោះដែរ” ដូច្នេះ, ភវចក្រ រមែងជាប់ទាក់ទងគ្នានឹងបទថា “អវិជ្ជាបច្ចយា សង្ខារា” ម្តងទៀត ។ ព្រោះហេតុនោះ ធម៌ ១២ ប៉ុណ្ណោះ បណ្ឌិត គប្បីជ្រាបថា “ជាអង្គនៃបដិច្ចសមុប្បាទធម៌” ព្រោះរួបរួមនូវសង្ខេបធម៌ មានសេចក្តីសោកជាដើមនោះឯង ចូលគ្នាតែមួយនឹងជរាមរណៈហ្នឹងឯង ។

វិនិច្ឆ័យ ដោយកំណត់អង្គទាំងឡាយ ក្នុងបាលីបដិច្ចសមុប្បាទធម៌នេះ បណ្ឌិត គប្បីជ្រាប ដូចបានពណ៌នាមកនេះឯង ប្រការមួយ ។

នេះគឺគាន់តែជាសង្ខេបកថា ក្នុងបដិច្ចសមុប្បាទធម៌នេះទេ ។ ចំណែកសេចក្តី (តទៅនេះ) ជាន័យពិស្តារ ។

(កែបទ អវិជ្ជា)

(៣៦៣) ដោយបរិយាយ ក្នុងព្រះសូត្រ ការមិនដឹង ក្នុងឋានៈ ៤ មានទុក្ខជាដើម ឈ្មោះថា អវិជ្ជា ។ ដោយបរិយាយ ក្នុងព្រះអភិធម្ម

ការមិនដឹង ក្នុងឋានៈ ៨ ព្រមទាំងឋានៈ មានគោលខាងដើមជាអាទិ៍ ឈ្មោះថា អវិជ្ជា ។ សមដូចជាព្រះមានព្រះភាគ ទ្រង់ត្រាស់ថា “ក្នុងធម៌ទាំងនោះ អវិជ្ជា តើដូចម្តេច? ការមិនដឹង ក្នុងទុក្ខ ។ល។ ការមិនដឹង ក្នុងទុក្ខនិរោធគាមិនីបដិបទា, ការមិនដឹង ក្នុងគោលខាងដើម, ការមិនដឹង ក្នុងគោលខាងចុង, ការមិនដឹង ក្នុងគោលខាងដើម និងខាងចុង, ការមិនដឹង ក្នុងធម៌ទាំងឡាយ ដែលជាឥទប្បច្ចយតា និងបដិច្ចសមុប្បន្នធម៌ ហៅថា អវិជ្ជា” ដូច្នេះ ។

ក្នុងឋានៈទាំងនោះ លើកលែងតែសច្ចៈ២ ដែលជាលោកុត្តរៈចេញ អវិជ្ជា រមែងកើតឡើង ក្នុងឋានៈដ៏សេស សូម្បីដោយអំណាច នៃអារម្មណ៍ ក៏ពិតមែនហើយ តែទោះបីជាយ៉ាងដូច្នោះក៏ដោយ ក្នុងបាលីនេះ លោកបំណងប៉ងយកហើយ ដោយអំណាចនៃការបិទបាំងប៉ុណ្ណោះឯង ។ មែនពិត អវិជ្ជានោះ ដែលកើតឡើងហើយ រមែងបិទបាំងនូវទុក្ខសច្ចៈ ហើយតាំងនៅ មិនឲ្យចាក់ធ្លុះនូវលក្ខណៈ ដែលជារសដោយអំណាចតាមភាវៈពិតបាន ន័យដូចគ្នានោះដែរ រមែងបិទបាំងនូវសមុទយសច្ចៈ និរោធសច្ចៈ មគ្គសច្ច ខន្ធបញ្ចកៈជាអតីត ដែលរាប់ថាជាខាងដើម ខន្ធបញ្ចកៈ ដែលជាអនាគត ដែលរាប់ថា ជាខាងចុង ខន្ធបញ្ចកៈ ទាំងពីរយ៉ាងនោះ ដែលរាប់ថា ជាខាងដើម និង ខាងចុង ឥទប្បច្ចយា និង បដិច្ចសមុប្បន្នធម៌ទាំងឡាយ ដែលរាប់ថា ជាឥទប្បច្ចយតា និង បដិច្ចសមុប្បន្នធម៌ ហើយតាំងនៅ ។ អវិជ្ជានោះ មិនឲ្យចាក់ធ្លុះនូវលក្ខណៈ ជារស ដែលជាសភាវៈប្រចាំខ្លួន តាមការពិតក្នុងទុក្ខសច្ច ជាដើមនោះ យ៉ាងនេះថា “នេះ ជាអវិជ្ជា នេះ ជាសង្ខារ” ដូច្នេះជាដើម ព្រោះហេតុនោះ ទើបលោកហៅថា “ការមិនដឹង ក្នុងទុក្ខ



។ល។ ការមិនដឹង ក្នុងធម៌ទាំងឡាយ ដែលជាឥទប្បច្ចយតា និង បដិច្ចសមុប្បន្នធម៌” ដូច្នេះ ។

(កែបទសង្ខារ)

(៣៦៤) បទថា “សង្ខារទាំងឡាយ” បានដល់ សង្ខារ ៦ ដែលពោលហើយ ដោយសង្ខេប ឰដ៏ខាងដើម យ៉ាងនេះថា “សង្ខារ ៣ មានបុញ្ញាភិសង្ខារជាដើម, សង្ខារ ៣ មានកាយសង្ខារជាដើម” ។

តែបើពោលដោយពិស្តារវិញ បណ្តាសង្ខារទាំងនោះ សង្ខារទាំង ៣ បានដល់ ចេតនា ២៩ គឺ បុញ្ញាភិសង្ខារ បានដល់ ចេតនា ១៣ គឺ ចេតនា ដែលជាកាមាវចរកុសល ៨ ដែលប្រព្រឹត្តទៅ ដោយអំណាចនៃកុសលមានទាន និងសីលជាដើម និង ចេតនាដែលជារូបាវចរកុសលប្រាំ ដែលប្រព្រឹត្តទៅ ដោយអំណាច នៃភាវនាតែម្យ៉ាង, អបុញ្ញាភិសង្ខារ បានដល់ អកុសលចេតនា ១២ ដែលប្រព្រឹត្តទៅ ដោយអំណាចនៃអកុសល មានបាណាតិបាតជាដើម, អនេញ្ជាភិសង្ខារ បានដល់ចេតនាដែលជាអរូបាវចរកុសល ៤ ដែលប្រព្រឹត្តទៅដោយអំណាចនៃភាវនា ដូចគ្នា ។

ចំណែកក្នុងសង្ខារទាំងឡាយ ៣ ក្រៅពីនេះ កាយសញ្ចេតនា ជាកាយសង្ខារ, វចីសញ្ចេតនា ជាវចីសង្ខារ, មនោសញ្ចេតនា ជាចិត្តសង្ខារ ។ តិកៈនេះ លោកពោលហើយដើម្បីសំដែងនូវការប្រព្រឹត្តិទៅនៃអភិសង្ខារ ៣ មានបុញ្ញាភិសង្ខារជាដើម តាមទ្វារ ក្នុងខណៈដែលព្យាយាមធ្វើនូវកម្ម ។ មែនពិត ចេតនា ២០ គត់ គឺកាមាវចរកុសលចេតនា ៨ អកុសលចេតនា ១២ ដែលញុំាងកាយវិញ្ញត្តិ ឲ្យកើតឡើងហើយ ប្រព្រឹត្តទៅ តាមកាយទ្វារ ឈ្មោះថា កាយសង្ខារ ។ ចេតនា

ទាំងឡាយនេះឯង ដែលញុំាងវចីវិញ្ញត្តិ ឲ្យកើតឡើង ហើយប្រព្រឹត្តទៅតាមវចីទ្វារ ឈ្មោះថា វចីសង្ខារ ។

តែអភិញ្ញាចេតនា មិនមែនជាបច្ច័យនៃវិញ្ញាណដទៃទៀតទេ ព្រោះហេតុនោះ ទើបលោកមិនប្រកាន់យក ក្នុងពាក្យថា “កាយវចីសង្ខារ” នេះ ។ ក៏អភិញ្ញាចេតនា មិនមែន ជាបច្ច័យនៃវិញ្ញាណ យ៉ាងណា, សូម្បីឧទ្ធច្ចចេតនា ក៏មិនមែនជាបច្ច័យនៃវិញ្ញាណ យ៉ាងនោះដែរ ព្រោះហេតុនោះ សូម្បីឧទ្ធច្ចចេតនានោះសោត ក៏ត្រូវនាំយកចេញ ក្នុងភាវៈជាបច្ច័យនៃវិញ្ញាណ ។ ប៉ុន្តែចេតនាទាំងពួងនោះ ក៏គង់ជាធម៌ដែលមានអវិជ្ជា ជាបច្ច័យហ្នឹងឯង ។

ឯចេតនាទាំងអស់ ២៩ ដែលកើតហើយ ក្នុងមនោទ្វារ មិនញុំាងវិញ្ញត្តិទាំងពីរ ឲ្យកើតឡើង ជាចិត្តសង្ខារ ។

តិកៈនេះ ចូលកាន់តិកៈ ខាងដើមហ្នឹងឯង ព្រោះហេតុនោះ ដោយសេចក្តី ភាវៈនៃអវិជ្ជា ជាបច្ច័យ បណ្ឌិត គប្បីជ្រាប ដោយអំណាចនៃបច្ច័យ នៃអភិសង្ខារ ៣ មានបុញ្ញាភិសង្ខារជាដើមនុ៎ះឯង ដោយប្រការដូច្នេះ ។

ក្នុងដំណើរនោះ បើមានពាក្យសួរថា “ក៏រឿងនេះ នឹងគប្បីដឹងបាន យ៉ាងដូចម្តេច ថាៈ សង្ខារទាំងឡាយនេះ មានអវិជ្ជា ជាបច្ច័យ?” ។

ឆ្លើយថា “គប្បីដឹងបាន ព្រោះកាលបើអវិជ្ជា មាន, សង្ខារទាំងឡាយ ក៏មាន” ដូច្នេះ ។

មែនពិត ការមិនដឹង ក្នុងឋានៈទាំងឡាយ មានទុក្ខជាដើម ដែលហៅថា អវិជ្ជា គឺបុគ្គលណា លះបង់មិនទាន់បានហើយ, បុគ្គលនោះរមែងកាន់យក នូវសំសារទុក្ខ ដោយសំគាល់ថា ជាសុខ ហើយបង្កនូវ



សង្ខារទាំង ៣ យ៉ាង ដែលជាហេតុនៃសំសារទុក្ខនោះឯង ឲ្យកើតឡើង ព្រោះមិនដឹងក្នុងទុក្ខ និង ឋានៈក្រៅពីនេះ មានខាងដើមជាអាទិ៍ជាមុន ។ ព្រោះមិនដឹង ក្នុងសមុទយៈ ទើបសំគាល់នូវសង្ខារទាំងឡាយ ដែលមានតណ្ហាជាគ្រឿងប្រដាប់ ជាហេតុនៃទុក្ខផង ដោយថា ជាហេតុនៃសុខទៅវិញ ទើបបង្កនូវសង្ខារទាំង ៣ (ឲ្យកើតឡើង) ។ មួយទៀត ព្រោះមិនដឹងក្នុងនិរោធ និង ក្នុងមគ្គ ទើបជាអ្នកមានសេចក្តីសំគាល់ ក្នុងគតិពិសេស ទោះបីមិនមែនជាទីរំលត់នូវទុក្ខក៏ដោយ ថា ជាទីរំលត់នូវទុក្ខទៅវិញ ជាអ្នកមានសេចក្តីសំគាល់ ក្នុងពាហិរមគ្គទាំងឡាយ មានការបូជាយញ្ញ និង អមរតបៈជាដើម សូម្បីមិនមែនជាផ្លូវនៃការរំលត់ទុក្ខក៏ដោយ ថា ជាផ្លូវរំលត់ទុក្ខទៅវិញ, កាលប្រាថ្នានូវការរំលត់ទុក្ខ ទើបបង្កនូវសង្ខារទាំង ៣ យ៉ាង (ឲ្យកើតឡើង) តាមមុខពាហិរមគ្គ មានយញ្ញ និង អមរតបៈជាដើម ។

មួយវិញទៀត បុគ្គលនោះ ព្រោះលះបង់អវិជ្ជានោះ ក្នុងសច្ចៈ ៤ មិនបាន ក៏មិនដឹងនូវទុក្ខ ពោលគឺផលនៃបុណ្យ សូម្បីជ្រៀតជ្រែកដោយទោសច្រើនជាអនេក មានជាតិ, ជរា, រោគ និង មរណៈជាដើម ដោយពិសេស ដោយថា ជាទុក្ខបាន ទើបបង្កនូវបុញ្ញាភិសង្ខារ ដែលមានកាយសង្ខារ វចីសង្ខារ និង ចិត្តសង្ខារជាប្រភេទ ដើម្បីបានសំរេចនូវផលនៃបុណ្យនោះ ប្រៀបដូចជាបុគ្គលដែលប្រាថ្នានូវនាងទេពអប្សរ ផ្តើមលោតទៅជល់នឹងជ្រោះភ្នំ យ៉ាងនោះឯង ។

ម្យ៉ាងទៀត បុគ្គលនោះ មិនឃើញទាំងភាវៈនៃផលនៃបុណ្យនោះ សូម្បីដែលសន្មតថា ជាសុខ ជាវិបរិណាមទុក្ខ ដែលញុំាងសេចក្តីក្តៅក្រហាយចិត្តយ៉ាងច្រើន ឲ្យកើត ក្នុងទីបំផុត និង មិនឃើញនូវភាវៈនៃ

ផលនៃបុណ្យនោះ ជាគុណគួរឲ្យត្រេកអរ មានប្រមាណតិចតួច ទើបបង្កើតនូវបុញ្ញាភិសង្ខារ ដែលមានប្រការដូចពោលមកហើយ ដែលជាបច្ច័យនៃវិបរិណាមទុក្ខហ្នឹងឯង ប្រៀបដូចជាសត្វមមាច ហើរចូលទៅរោមអណ្តាតភ្លើង និង ប្រៀបដូចជាសត្វដែលល្មោភចង់ក្រេបតំណក់ទឹកឃ្មុំ ផ្តើមចូលទៅលិទ្ធមុខកាំបិតដ៏មុត ដែលប្រឡាក់ទឹកឃ្មុំ ដូច្នោះឯង ។ មួយទៀត មិនឃើញទោស ក្នុងលោកិយវិស័យ មានការសេពកាមជាដើម ព្រមទាំងផលរបស់វា ព្រោះសំគាល់ថា ជាសុខ និង ត្រូវកិលេសគ្របសង្កត់ផង ទើបបង្កើតនូវអបុញ្ញាភិសង្ខារ ដែលប្រព្រឹត្តទៅក្នុងទ្វារទាំង ៣ ប្រៀបដូចជាកូនក្មេងខ្ទីផ្តើមលេងលាមក និង ប្រៀបដូចជាមនុស្សដែលចង់ស្លាប់ ផ្តើមលេបថ្នាំពុល យ៉ាងនោះឯង ។ ប្រការមួយទៀត មិនដឹងនូវភាវៈនៃសង្ខារក្នុងផ្នែកនៃអរូបវិបាក ជាវិបរិណាមទុក្ខ ទើបបង្កើតនូវអនេញ្ជាភិសង្ខារ ដែលជាចិត្តសង្ខារ ដោយវិបល្លាសថា ជារបស់ទៀងទាត់ជាដើម ប្រៀបបាននឹងបុគ្គលវង្វេងទិស ចាប់ផ្តើមទៅកាន់ផ្លូវដែលមានមុខឆ្ពោះទៅកាន់ស្រុកបិសាច យ៉ាងដូច្នោះឯង ។

សង្ខារ មាន ព្រោះមានអវិជ្ជា មិនមែនសង្ខារមាន ព្រោះមិនមានអវិជ្ជា ដូចបានពណ៌នាមកទេ ព្រោះហេតុណា, ព្រោះហេតុនោះ បណ្ឌិតគប្បីជ្រាបពាក្យនេះថា "សង្ខារទាំងនេះ ជាធម៌មានអវិជ្ជា ជាបច្ច័យ" ដូច្នេះ ។ មែន ពាក្យនេះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយថា "ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកមិនឆ្លាត លុះក្នុងអំណាចនៃអវិជ្ជា រមែងតាក់តែងនូវបុញ្ញាភិសង្ខារខ្លះ រមែងតាក់តែង នូវអបុញ្ញាភិសង្ខារខ្លះ រមែងតាក់តែងនូវអនេញ្ជាភិសង្ខារខ្លះ, ម្នាលភិក្ខុទាំងឡាយ! ក៏ពេលណា ភិក្ខុលះបង់អវិជ្ជាបានហើយ វិជ្ជា ក៏កើតឡើងហើយ, ពេលនោះ ភិក្ខុនោះ



ព្រោះការសំរកនូវអវិជ្ជា ព្រោះការកើតឡើងនៃវិជ្ជា ទើបមិនតាក់តែងនូវបុញ្ញាភិសង្ខារឡើយ" ដូច្នេះជាដើម ។

ក្នុងបទថា "អវិជ្ជា" នេះ យើងនឹងចាប់យកសេចក្តីនេះថា "អវិជ្ជាជាបច្ច័យនៃសង្ខារទាំងឡាយ" ដូច្នេះមុន ។ ក៏សេចក្តីនេះ បណ្ឌិតគប្បីពោលថា "អវិជ្ជាជាបច្ច័យនៃសង្ខារទាំងឡាយបែបណា តើដូចម្តេច?" ។ ក្នុងភាវៈនៃអវិជ្ជា ជាបច្ច័យនោះ លោកនឹងពោលដូចតទៅនេះ ។

(បច្ច័យ ២៤)

(៣៥៦) ក៏បច្ច័យទាំង ២៤ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ថា "ហេតុប្បច្ច័យ អារម្មណប្បច្ច័យ អធិបតិប្បច្ច័យ អនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ ឧបនិស្សយប្បច្ច័យ បុរេជាតប្បច្ច័យ បច្ឆាជាតប្បច្ច័យ អាសេវនប្បច្ច័យ កម្មប្បច្ច័យ វិបាកប្បច្ច័យ អាហារប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ ឈានប្បច្ច័យ មគ្គប្បច្ច័យ សម្បយុត្តប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ វិគតប្បច្ច័យ អវិគតប្បច្ច័យ" ដូច្នេះ ។

(កែបទហេតុបច្ច័យ)

ក្នុងឧទ្ទេសនៃបទទាំងនោះ ធម៌នោះ ជាហេតុផង ជាបច្ច័យផង ព្រោះហេតុនោះ ទើបឈ្មោះថា ហេតុប្បច្ច័យ គឺជាបច្ច័យ ព្រោះជាហេតុ អធិប្បាយថា ជាបច្ច័យ ដោយភាវៈជាហេតុ ។ សូម្បីក្នុងឧទ្ទេសផ្សេងៗទៀត មានអារម្មណប្បច្ច័យជាដើម ក៏មានន័យដូចគ្នានោះដែរ ។

(កែហេតុសព្ទ)

ក្នុងបទថា "ហេតុប្បច្ចយោ" នោះ ពាក្យថា "ហេតុ" នេះ ជាពាក្យសំដែងនូវសំនួរនៃពាក្យការណៈ និង មូលៈ (ពាក្យដែលជាឫសគល់) ។

ក៏ក្នុងផ្លូវលោក ដូចជាពាក្យថា "បដិញ្ញាហេតុ(គឺខប្បដ្ឋា)" ដូច្នេះជាដើម វចនាវយវៈ លោកហៅថា "ហេតុ" ។ តែក្នុងផ្លូវសាសនា ការណៈ លោកហៅថា "ហេតុ" ដូចក្នុងពាក្យថា "ធម៌ទាំងឡាយណាមានហេតុជាដែនកើត" ដូច្នេះជាដើម ។ មូលៈ លោកពោលថា "ហេតុ" ដូចក្នុងពាក្យថា "ហេតុនៃកុសល ៣ ហេតុនៃអកុសល ៣" ដូច្នេះជាដើម ។ មូលៈ នោះ លោកបំណងយកហើយ ក្នុងពាក្យថា "ហេតុ" នេះ ។

(វែកបច្ច័យស័ព្ទ)

ចំណែកសេចក្តីនេះ ជាសេចក្តីនៃពាក្យ ក្នុងពាក្យថា "បច្ច័យ" នេះដូច្នេះ ។ ធម៌ (ដែលជាផល) អាស្រ័យទៅអំពីធម៌ (ដែលជាហេតុ) នោះ ព្រោះហេតុនោះ ធម៌នោះ ទើបឈ្មោះថា បច្ច័យ ។ អធិប្បាយថា មិនបដិសេធធម៌(ដែលជាហេតុ)នោះប្រព្រឹត្តទៅ ។ មានពាក្យអធិប្បាយថា "ក៏ធម៌ (ដែលជាផល)ឯណា អាស្រ័យ គឺមិនបដិសេធនូវធម៌(ដែលជាហេតុ)ឯណាមួយ ហើយតាំងនៅ ឬ កើតឡើង, ធម៌ (ដែលជាហេតុ) នោះ ឈ្មោះថា ជាបច្ច័យនៃធម៌ (ដែលជាផល) នោះ" ។ តែដោយលក្ខណៈ បច្ច័យមានការឧបត្ថម្ភ ជាលក្ខណៈ ។ ព្រោះថា ធម៌(ដែលជាហេតុ) ណា ជាធម៌ជួយឧបត្ថម្ភ ដើម្បីការតាំងនៅ ឬ ការកើតឡើងនៃធម៌ (ដែលជាផល)ណា ធម៌ (ដែលជាហេតុ) នោះ លោកហៅថា ជាបច្ច័យនៃធម៌ (ដែលជាផល) នោះ ។

ពាក្យថា "បច្ច័យ, ហេតុ, ការណៈ, និទាន, សម្ភវៈ, បភវៈ" ដូច្នេះជាដើម ដោយសេចក្តីដូចគ្នាតែមួយ, ផ្សេងគ្នាតែដោយព្យញ្ជនៈ ។

ធម៌ ឈ្មោះថា ហេតុ ព្រោះអត្ថថា ជាមូល ឈ្មោះថា ជាបច្ច័យ ព្រោះអត្ថថា សភាវៈជួយឧបត្ថម្ភ ដូចពោលមកនេះឯង ព្រោះហេតុនោះ



ដោយសង្ខេប ធម៌ដែលជាអ្នកជួយឧបត្ថម្ភ ព្រោះអត្ថថា ជាមូល ឈ្មោះថា ហេតុប្បច្ច័យ ។

សេចក្តីអធិប្បាយ របស់អាចារ្យទាំងឡាយ ថា "ហេតុប្បច្ច័យនោះ ជាសភាវៈញ៉ាំងភាពជាកុសលជាដើមឲ្យសំរេច ដល់ធម៌ទាំងឡាយមានកុសលជាដើម ដូចជាពូជទាំងឡាយ មានពូជស្រូវសាលីជាដើម ញ៉ាំងពូជទាំងឡាយមានពូជនៃស្រូវសាលីជាដើមឲ្យសំរេច និង ដូចជាពណ៌នៃកែវមណីជាដើម ញ៉ាំងពន្លឺនៃកែវមណីជាដើមឲ្យសំរេច យ៉ាងនោះឯង" ។ តែកាលបើយ៉ាងដូច្នោះ ភាពជាហេតុប្បច្ច័យ ក៏មិនសំរេចក្នុងរូបទាំងឡាយ ដែលមានហេតុនោះជាសមុដ្ឋាន ព្រោះថាហេតុប្បច្ច័យនោះ មិនញ៉ាំងភាពជាកុសលជាដើម ឲ្យសំរេច ដល់រូបទាំងឡាយនោះទេ តែមិនមែនជាបច្ច័យ ក៏មិនមែនដែរ ។ សមដូចជាពាក្យដែលលោកពោលថា "ហេតុ ជាបច្ច័យ ដោយជាហេតុប្បច្ច័យ នៃធម៌ទាំងឡាយដែលសម្បយុត្តជាមួយហេតុ និង នៃរូបទាំងឡាយ ដែលមានហេតុនោះជាសមុដ្ឋាន [១]" ។ មួយទៀត សំរាប់អហេតុកចិត្តទាំងឡាយ ភាពជាអព្យាក្រឹត ប្រាសចាកហេតុនោះហើយក៏សំរេចបានដែរ ។ ចំណែកឯសហេតុកចិត្តទាំងឡាយ ភាពជាកុសលជាដើម ជាប់ទាក់ទង ដោយយោនិសោមនសិការជាដើម មិនមែនជាប់ទាក់ទង ដោយសម្បយុត្ត-ហេតុឡើយ ។ មួយទៀត បើភាពជាកុសលជាដើម គប្បីមាន តាមសភាវៈមែនពិត ក្នុងសម្បយុត្តហេតុទាំងឡាយ, ក្នុងសម្បយុត្តធម៌ទាំងឡាយ អលោភៈដែលជាប់ទាក់ទងជាមួយហេតុ គប្បីជាកុសលខ្លះ ជាអព្យាក្រឹតខ្លះ តែព្រោះហេតុដែលបានទាំងពីរយ៉ាង (បើ)ភាពជាកុសល

១- អភិ. ប. ភាគទី ៩៨ ទំព័រទី ១ ។

ជាដើម ក្នុងសម្បយុត្តធម៌ទាំងឡាយ មាន យ៉ាងណា, សូម្បីក្នុងហេតុទាំងឡាយ បណ្ឌិតគប្បីស្វែងរកភាពជាកុសលជាដើមក៏យ៉ាងនោះដែរ ។

តែតាមពិត កាលបើអត្ថថា ជាមូល នៃហេតុទាំងឡាយ គឺបណ្ឌិតមិនបានកាន់យក ដោយអំណាចជាហេតុ ញុំាងភាវៈជាកុសលជាដើមឲ្យសំរេច ហើយកាន់យក ដោយអំណាចជាហេតុ ញុំាងភាពតាំងនៅដោយល្អឲ្យសំរេច ក៏មិនជាខុសអ្វីឡើយ ។ មែនពិត ធម៌ទាំងឡាយដែលបានហេតុប្បច្ច័យហើយ រមែងជាធម៌ឋិតថេរ តាំងមាំមួនយ៉ាងល្អ បីដូចជាដើមឈើទាំងឡាយ ដែលមានឫសល្អ ក៏រមែងឋិតនៅបានយូរយ៉ាងដូច្នោះឯង ។ អហេតុកធម៌ទាំងឡាយ ជាធម៌តាំងនៅមិនបានល្អ ដូចជាសារាយទាំងឡាយ មានសារាយពូជតិលពីជកៈជាដើម តាំងនៅមិនបានល្អ យ៉ាងនោះឯង ។

ហេតុប្បច្ច័យ ជាធម៌ជួយឧបត្ថម្ភ ដោយអត្ថថា ជាមូល ដូច្នេះ ព្រោះហេតុនោះ ធម៌ដែលឧបត្ថម្ភ ដោយញុំាងភាវៈនៃការតាំងនៅយ៉ាងល្អ ឲ្យសំរេច បណ្ឌិតគប្បីជ្រាបថា ឈ្មោះថា ហេតុប្បច្ច័យ ។

**(វែកអារម្មណប្បច្ច័យ)**

(៣៦៦) ក្នុងឧទ្ទេសនៃបទក្រៅពីនោះទៅ ធម៌ដែលឧបត្ថម្ភ ដោយភាពជាអារម្មណ៍ ឈ្មោះថា អារម្មណប្បច្ច័យ ។ ធម៌ឯណាមួយដែលមិនមែនជាអារម្មណប្បច្ច័យនោះ មិនមាន ព្រោះពាក្យនិទ្ទេស ដែលលោកលើកឡើងខាងដើម ថា "រូបាយតនៈ ជាបច្ច័យ ដោយភាពជាអារម្មណប្បច្ច័យ នៃចក្ខុវិញ្ញាណធាតុ" ដូច្នេះជាដើម តែដល់ខាងចុងបញ្ចប់ ថា "ធម៌ទាំងឡាយណាៗ ដែលជាចិត្ត ចេតសិកធម៌ ប្រារព្ធនូវធម៌ណាៗ កើតឡើង, ធម៌ទាំងឡាយនោះៗ រមែងជាបច្ច័យ ដោយភាព



ជាអារម្មណប្បច្ច័យ នៃធម៌ទាំងឡាយនោះៗ" ដូច្នេះ ។ ប្រៀបដូចជាបុរស ខ្សោយកម្លាំង តោងនូវដំបង ឬ ខ្សែហ្នឹងឯង ទើបក្រោកឡើង និង ឈរបានផង យ៉ាងណាមិញ, ចិត្ត និង ចេតសិកធម៌ទាំងឡាយ ក៏យ៉ាងនោះដែរ ប្រារព្ធនូវអារម្មណ៍មានរូបជាដើមហ្នឹងឯង ទើបកើតឡើង និង តាំងនៅបាន ។ ព្រោះហេតុនោះ ធម៌ទាំងឡាយ ដែលជាអារម្មណ៍នៃចិត្ត និង ចេតសិកទាំងឡាយទាំងពួង បណ្ឌិត គប្បីជ្រាបថា ឈ្មោះថា អារម្មណប្បច្ច័យ ។

**(វែកអធិបតិប្បច្ច័យ)**

(៣៦៧) ធម៌ ដែលឧបត្ថម្ភ ដោយអត្ថថា ជាធំ ឈ្មោះថា អធិបតិប្បច្ច័យ ។ អធិបតិប្បច្ច័យនោះ មាន ២ យ៉ាង ដោយអំណាចនៃសហជាតធម៌ និង អារម្មណ៍ ។ ក្នុងធម៌ពីរយ៉ាងនោះ ធម៌ទាំងឡាយ ៤ ប្រការ ពោលគឺ ឆ័ន្ទៈ, វិរិយៈ, ចិត្តៈ និង វិមំសា បណ្ឌិត គប្បីជ្រាបថា "ឈ្មោះថា ជាអធិបតិប្បច្ច័យ នៃសហជាតធម៌" ព្រោះព្រះបាលីថា "ឆន្ទាធិបតី ជាបច្ច័យ ដោយជាអធិបតិប្បច្ច័យ នៃធម៌ទាំងឡាយ ដែលសម្បយុត្តជាមួយនឹងឆន្ទៈ និង នៃរូបទាំងឡាយ ដែលមានឆន្ទៈនោះជាសមុដ្ឋាន" ដូច្នេះជាដើម ។ តែធម៌ទាំង ៤ យ៉ាងនេះ មិនបានជាអធិបតីដោយរួមគ្នាតែមួយទេ ។ មែនពិត នៅពេលណា ចិត្តធ្វើឆន្ទៈឲ្យជាធុរៈធ្វើឆន្ទៈឲ្យជាធំប្រព្រឹត្តទៅ, នៅពេលនោះ ឆន្ទៈប៉ុណ្ណោះ ជាធំ, ធម៌ក្រៅពីនេះ មិនបានជាធំទេ ។ ក្នុងធម៌ទាំងឡាយដ៏សេស ក៏ន័យនេះដែរ ។

ចំណែកអរូបធម៌ទាំងឡាយ ធ្វើនូវធម៌ណា ឲ្យជាធម៌ធ្ងន់ ហើយប្រព្រឹត្តទៅ, ធម៌នោះ ជាអារម្មណាធិបតី នៃអរូបធម៌ទាំងឡាយនោះ ។ ព្រោះហេតុនោះ ទើបលោកពោលពាក្យនេះថា "ធម៌ទាំងឡាយ ឯណា

ជាចិត្ត ចេតសិកធម៌ ធ្វើធម៌ឯណា ឲ្យធ្ងន់ ហើយកើតឡើង, ធម៌ទាំងឡាយនោះៗ ជាបច្ច័យ ដោយជាអធិបតិប្បច្ច័យ នៃធម៌ទាំងឡាយនោះៗ" [១] ដូច្នេះ ។

(វែកអនន្តរប្បច្ច័យ និង សមនន្តរប្បច្ច័យ)

(៣៦៨) ធម៌ដែលឧបត្ថម្ភ ដោយភាពជាធម៌មិនមានចន្លោះ ឈ្មោះថា អនន្តរប្បច្ច័យ ។ ធម៌ដែលជាឧបការៈ ដោយភាពជាធម៌ដែលនៅជិតបំផុត ឈ្មោះថា សមនន្តរប្បច្ច័យ ។ ក៏អាចារ្យទាំងឡាយ ពោលអធិប្បាយបច្ច័យទាំង ២ នេះ ច្រើនប្រការ ។ តែសេចក្តីនេះ ជាសារប្រយោជន៍ ក្នុងបច្ច័យទាំង ២ នេះ ។

ក៏ចិត្តនិយម មានជាអាទិ៍ថា "មនោធាតុ មានក្នុងលំដាប់ នៃចក្ខុ-វិញ្ញាណ, មនោវិញ្ញាណធាតុ មានក្នុងលំដាប់នៃមនោធាតុ" ដូច្នេះ នេះឯណា, ចិត្តនិយមនោះ រមែងសំរេច ដោយអំណាចនៃចិត្តមុនៗប៉ុណ្ណោះ មិនមែនសំរេចដោយប្រការដទៃទេ ព្រោះហេតុណា, ព្រោះហេតុនោះ ធម៌ដែលអាច ក្នុងការញ៉ាំងចិត្តុប្បាទ ដែលសមគួរឲ្យកើតឡើង ក្នុងលំដាប់នៃខ្លួនៗ ឈ្មោះថា អនន្តរប្បច្ច័យ ។

ព្រោះហេតុនោះឯង ទើបព្រះមានព្រះភាគទ្រង់ត្រាស់ថា : បទថា "អនន្តរប្បច្ច័យ" សេចក្តីថា : ចក្ខុវិញ្ញាណធាតុ និង ធម៌ទាំងឡាយដែលសម្បយុត្តជាមួយនឹងចក្ខុវិញ្ញាណធាតុនោះ ជាបច្ច័យ ដោយជាអនន្តរប្បច្ច័យ នៃមនោធាតុ និង នៃធម៌ទាំងឡាយដែលសម្បយុត្តជាមួយនឹងមនោធាតុនោះ [២] " ដូច្នេះជាដើម ។

អនន្តរប្បច្ច័យ យ៉ាងណា, សមនន្តរប្បច្ច័យ ក៏យ៉ាងនោះដែរ ។

១- ២- អភិ. ប. ភាគទី ៩៤ ទំព័រទី ៣ ។



មែនពិត ការផ្សេងគ្នា ក្នុងបច្ច័យទាំង ២ នេះ គ្រាន់តែផ្សេងគ្នា ដោយព្យញ្ជនៈប៉ុណ្ណោះ ដូចការផ្សេងគ្នា ដោយព្យញ្ជនៈ ក្នុងឧបចយៈ និង សន្តតិ និង ដូចជាក្នុងពាក្យគូនឹងគ្នា គឺអធិវចនៈ និង និរុត្តិ ដូច្នោះឯង ។ តែសេចក្តីផ្សេងគ្នា ដោយអត្ថ មិនមានទេ ។

ចំណែកមតិណា នៃអាចារ្យទាំងឡាយថា "ធម៌ឈ្មោះថា អនន្ត-រប្បច្ច័យ ព្រោះជាធម៌មិនមានជាចន្លោះ ដោយអត្ថ ឈ្មោះថា សមនន្ត-រប្បច្ច័យ ព្រោះភាវៈជាធម៌មិនមានចន្លោះ ដោយកាល" ដូច្នេះ, មតិ នៃអាចារ្យទាំងឡាយនោះ ខុសពីបាលីថា "កាលបើព្រះយោគាវចរ ចេញពីនិរោធ នេវសញ្ញានាសញ្ញាយតនកុសល រមែងជាបច្ច័យ ដោយជាសមនន្តរប្បច្ច័យ នៃផលសមាបត្តិ" ដូច្នេះជាដើម ។

ក្នុងភាពនៃធម៌ ដែលជាសមនន្តរប្បច្ច័យ ព្រោះជាធម៌មិនមានជាចន្លោះ ដោយកាលនោះ អាចារ្យទាំងឡាយ ពោលពាក្យឯណាថា "ភាពនៃធម៌នោះ ជាធម៌អាចក្នុងការញ៉ាំងធម៌ទាំងឡាយ ឲ្យកើតឡើង មិនសាបសូន្យទៅ តែព្រោះត្រូវកម្លាំងនៃភាវនាពាំងហើយ ធម៌ទាំងឡាយដែលជាសមនន្តរៈ ទើបកើតឡើងមិនបាន" ដូច្នេះ, សូម្បីពាក្យនោះ ក៏ញ៉ាំងការមិនមាននៃភាពជាកាលានន្តរៈហ្នឹងឯងឲ្យសំរេច, ក៏ពាក្យណាថា "ភាពជាកាលានន្តរៈ ក្នុងធម៌នោះ មិនមាន ដោយកម្លាំងនៃភាវនា" ដូច្នេះ, យើងពោលនូវពាក្យនោះឯង ។ ភាពជាកាលានន្តរៈ មិនមាន ព្រោះហេតុណា, ព្រោះហេតុនោះ ភាពនៃធម៌នោះ ជាសមនន្តរប្បច្ច័យ ក៏មិនគួរ ។ ព្រោះហេតុថា ការយល់ឃើញរបស់អ្នកទាំងឡាយ ថា "ធម៌ ឈ្មោះថា ជាសមនន្តរប្បច្ច័យ នៃធម៌ទាំងឡាយនោះ ព្រោះជាធម៌មិនមានចន្លោះ ដោយកាល" ដូច្នេះ ។

ព្រោះហេតុនោះ អ្នកទាំងឡាយ កុំធ្វើការប្រកាន់មាំឡើយ គប្បីជឿថា ការផ្សេងគ្នាក្នុងបច្ច័យនេះ ក៏ត្រឹមតែព្យញ្ជនៈប៉ុណ្ណោះ មិនមែនផ្សេងគ្នា ដោយអត្ថឡើយ ។ ការផ្សេងគ្នាដោយព្យញ្ជនៈ តើយ៉ាងដូម្ដេច? ។ ផ្សេងគ្នាយ៉ាងនេះ គឺ ចន្លោះនៃធម៌ទាំងឡាយនោះ មិនមាន ព្រោះហេតុនោះ ទើបឈ្មោះថា មិនមានចន្លោះ (អនន្តរៈ) ធម៌ទាំងឡាយនោះ ឈ្មោះថា អនន្តរៈ ដោយប្រពៃ ព្រោះមិនមានការឈប់សំរាក ព្រោះហេតុនោះ ធម៌ទាំងឡាយនោះ ទើបឈ្មោះថា សមនន្តរៈ (មិនមានចន្លោះ ដោយប្រពៃ) ។

(ក្នុងសហជាតប្បច្ច័យ)

(៣៦៩) ធម៌ជាឧបការៈដោយភាពជាធម៌កាលកើត ក៏ញ៉ាំងធម៌ដទៃឲ្យកើតឡើង ព្រមជាមួយគ្នាដែរ ឈ្មោះថា សហជាតប្បច្ច័យ ប្រៀបដូចជាប្រទីប ជាបច្ច័យដោយញ៉ាំងពន្លឺ ឲ្យកើតឡើង ព្រមជាមួយគ្នាយ៉ាងនោះឯង ។ សហជាតប្បច្ច័យនោះមាន ៦ យ៉ាង ដោយអំណាចនៃអរូបក្ខន្ធជាដើម ។ សមដូចជាព្រះបាលីថា "ខន្ធទាំងឡាយ ៤ ដែលមិនមានរូបជាបច្ច័យ ដោយជាសហជាតប្បច្ច័យដល់គ្នានឹងគ្នា, មហាភូតរូប ៤ ជាបច្ច័យ ដោយជាសហជាតប្បច្ច័យដល់គ្នានឹងគ្នា, នាម និងរូប ក្នុងខណៈដែលចុះកាន់គភ៌ ជាបច្ច័យដោយសហជាតប្បច្ច័យដល់គ្នានឹងគ្នា ចិត្តនិងចេតសិកធម៌ទាំងឡាយជាបច្ច័យ ដោយសហជាតប្បច្ច័យនៃរូបទាំងឡាយដែលមានចិត្ត ជាសមុដ្ឋាន, មហាភូតរូបទាំងឡាយ ជាបច្ច័យ ដោយសហជាតប្បច្ច័យ នៃឧបាទាយរូបទាំងឡាយ, ធម៌ទាំងឡាយដែលមានរូប ជាបច្ច័យ ដោយសហជាតប្បច្ច័យ នៃអរូបធម៌ទាំងឡាយ ក្នុងកាលខ្លះ, មិនជាបច្ច័យ ដោយសហជាតប្បច្ច័យ ក្នុងកាល



ខ្លះ" ដូច្នេះ ។ ពាក្យនេះលោកពោលសំដៅយកតែហទយវត្ថុប៉ុណ្ណោះ ។

(ក្នុងអញ្ញមញ្ញប្បច្ច័យ)

(៣៧០) ធម៌ដែលជាឧបការៈ ដោយភាពជាធម៌ញ៉ាំងគ្នានឹងគ្នាឲ្យកើតឡើង និង ឧបត្ថម្ភដល់គ្នាទៅវិញទៅមក ឈ្មោះថា អញ្ញមញ្ញប្បច្ច័យ ប្រៀបដូចជាកំណាត់ឈើបីដុំ ទ្រគ្នាទៅវិញទៅមកដូច្នោះឯង ។ អញ្ញមញ្ញប្បច្ច័យនោះមាន ៣ យ៉ាង ដោយអំណាចនៃអរូបក្ខន្ធជាដើម ។ សមដូចជាលោកពោលហើយថា "ខន្ធទាំងឡាយ ៤ ដែលមិនមានរូបជាបច្ច័យ ដោយអញ្ញមញ្ញប្បច្ច័យ, មហាភូតរូប ៤ ជាបច្ច័យ ដោយអញ្ញមញ្ញប្បច្ច័យ, នាម និង រូប ជាបច្ច័យ ដោយអញ្ញមញ្ញប្បច្ច័យ ក្នុងពេលចុះកាន់គភ៌" ដូច្នេះ ។

(ក្នុងនិស្សយប្បច្ច័យ)

(៣៧១) ធម៌ជាឧបការៈ ដោយអាការៈដែលជាទីតាំង និង ដោយអាការៈដែលជាទីអាស្រ័យ ឈ្មោះថា និស្សយប្បច្ច័យ ប្រៀបដូចជាផែនដី និង ផ្ទាំងសំពត់ជាដើម ជាទីតាំង និង ជាទីអាស្រ័យ នៃដើមឈើ និង ចិត្តកម្មជាដើមយ៉ាងនោះឯង ។ និស្សយប្បច្ច័យនោះ បណ្ឌិតគប្បីជ្រាប តាមន័យដែលបានពោលហើយ ក្នុងសហជាតប្បច្ច័យនុ៎ះឯងយ៉ាងនេះ ថា "ខន្ធទាំងឡាយ ៤ ដែលមិនមានរូប ជាបច្ច័យ ដោយជានិស្សយប្បច្ច័យ ដល់គ្នាទៅវិញទៅមក" ដូច្នេះជាដើម ។ តែកោដ្ឋាសៈគឺចំណែក ទី ៦ ក្នុងបច្ច័យនេះ លោកបានចែកហើយ យ៉ាងដូច្នេះ គឺ "ចក្ខាយតនៈ ជាបច្ច័យ ដោយនិស្សយបច្ច័យ នៃចក្ខុវិញ្ញាណធាតុ និងនៃធម៌ទាំងឡាយដែលសម្បយុត្ត ដោយចក្ខុវិញ្ញាណធាតុនោះ [១] ។ល។

១- អភិ. ប. ភាគទី ៩៤ ទំព័រទី ៩ ។

សោតាយតនៈ... ឃានាយតនៈ... ជិវ្ហាយតនៈ... កាយាយតនៈ ជាបច្ច័យ ដោយជានិស្សយប្បច្ច័យ នៃកាយវិញ្ញាណធាតុ និង នៃធម៌ទាំងឡាយដែលសម្បយុត្ត ដោយកាយវិញ្ញាណធាតុនោះ, មនោធាតុ និង មនោវិញ្ញាណធាតុ អាស្រ័យនូវរូបណាប្រព្រឹត្តទៅ, រូបនោះ ជាបច្ច័យ ដោយនិស្សយប្បច្ច័យ នៃមនោធាតុ និង មនោវិញ្ញាណធាតុ និង នៃធម៌ទាំងឡាយ ដែលសម្បយុត្ត ដោយមនោវិញ្ញាណធាតុនោះ" ដូច្នេះ ។

(វែកឧបនិស្សយប្បច្ច័យ)

(៣៧២) ចំណែកក្នុងបទថា "ឧបនិស្សយប្បច្ច័យ" នេះ គប្បីជ្រាបសេចក្ដីនៃពាក្យនេះជាមុនសិន ។ ធម៌ដែលផលនៃខ្លួនអាស្រ័យហើយ គឺមិនបដិសេធហើយ ព្រោះមានការប្រព្រឹត្តិទៅជាប់ទាក់ទង ជាមួយនឹងធម៌នោះ ព្រោះហេតុនោះ ធម៌នោះ ទើបឈ្មោះថា និស្ស័យ (ជាទីដែលផលនៃខ្លួនអាស្រ័យ)។ ប្រៀបដូចជាការបង្អៀតបង្អល់ចិត្តដ៏ខ្លាំង ឈ្មោះថា ឧបាយាសៈ យ៉ាងណាមិញ, ធម៌ជាទីដែលផលនៃខ្លួនអាស្រ័យ (និស្ស័យ) ដ៏ក្រៃលែង ឈ្មោះថា ឧបនិស្ស័យ ក៏យ៉ាងដូច្នោះដែរ ។ ពាក្យថា "ឧបនិស្ស័យ" នោះ ជាឈ្មោះនៃហេតុដែលមានកម្លាំងខ្លាំង ។ ព្រោះហេតុនោះ ធម៌ដែលជាឧបការៈ ដោយភាវៈជាហេតុ ដ៏មានកម្លាំង បណ្ឌិតគប្បីជ្រាប ថា : "ឈ្មោះថា ឧបនិស្សយប្បច្ច័យ" ។

ឧបនិស្សយប្បច្ច័យនោះ មាន ៣ យ៉ាង គឺ: អារម្មណូបនិស្ស័យ, អនន្តរូបនិស្ស័យ, បកតូបនិស្ស័យ ។

(អារម្មណូបនិស្សយប្បច្ច័យ)

បណ្ដាឧបនិស្ស័យទាំង ៣ យ៉ាងនោះ ជាបឋម លោកចំណែក អារម្មណូបនិស្ស័យ មិនបានធ្វើភាពផ្សេងគ្នា ជាមួយនឹងអារម្មណាធិបតី



ដោយន័យជាអាទិ៍ យ៉ាងនេះ ថា "ការកបុគ្គលឲ្យទានហើយ សមាទានសីលហើយ បំពេញឧបោសថកម្មហើយ ពិចារណានូវកុសលកម្មដែលពោលហើយនោះ ធ្វើកុសលកម្មនោះឲ្យជាទីគោរព ពិចារណាកុសលកម្មទាំងឡាយ ដែលខ្លួនបានប្រព្រឹត្តហើយ ក្នុងកាលមុន ធ្វើកុសលកម្មនោះ ឲ្យជាទីគោរព ចេញពីឈានហើយ ពិចារណានូវឈាន ធ្វើ (ឈាន) នោះ ឲ្យជាទីគោរព, ព្រះសេខបុគ្គលទាំងឡាយ ពិចារណានូវគោត្រភូ ធ្វើ(គោត្រភូនោះ)ឲ្យជាទីគោរព ពិចារណានូវវោទានៈ គឺការផូរផង់ចិត្ត ធ្វើ(វោទានៈនោះ)ឲ្យជាទីគោរព, ព្រះសេខបុគ្គលទាំងឡាយ ចេញពីមគ្គហើយ ពិចារណានូវមគ្គ ធ្វើ (មគ្គនោះ) ឲ្យជាទីគោរព" [១] ដូច្នេះ ។

បណ្ដាអារម្មណ៍ទាំងនោះ ចិត្ត និង ចេតសិកទាំងឡាយ [២] ធ្វើអារម្មណ៍ណា ឲ្យជារបស់ធ្ងន់ កើតឡើង, អារម្មណ៍នោះ ដោយនិយមជាអារម្មណ៍ដ៏មានកម្លាំង ក្នុងអារម្មណ៍ទាំងឡាយនោះ ។ ដោយហេតុដូចពោលមកនេះ ការផ្សេងគ្នានៃអារម្មណ៍ទាំងឡាយនោះ បណ្ឌិតគប្បីជ្រាបយ៉ាងនេះថា "ជាអារម្មណាធិបតី ដោយអត្ថថា ត្រឹមតែអារម្មណ៍ដែលគប្បីធ្វើឲ្យជារបស់ធ្ងន់ ជាអារម្មណូបនិស្ស័យ ដោយអត្ថថា ជាអារម្មណ៍ដែលជាហេតុមានកម្លាំង" ដូច្នេះ ។

(អនន្តរូបនិស្ស័យ)

សូម្បីអនន្តរូបនិស្ស័យ ក៏លោកចំណែកហើយ ដោយមិនធ្វើនូវភាពផ្សេងគ្នា ជាមួយនឹងអនន្តរប្បច្ច័យផងដែរ ដោយន័យជាអាទិ៍ ថា "ខន្ធទាំងឡាយដែលជាកុសលមុនៗ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ នៃ

---

១- ២- អភិ. ប. ភាគទី ៩៤ ទំព័រទី ២៥៦-២៥៧ ។

ខណទាំងឡាយដែលជាកុសលក្រោយៗ” ដូច្នេះ ។ តែក្នុងមាតិកានិក្ខេប ការប្លែកពីគ្នា ក្នុងនិក្ខេប នៃចិត្ត និង ចេតសិកទាំងឡាយនោះ រមែងមាន ព្រោះអនន្តរប្បច្ច័យ មកហើយ ដោយន័យថា “ចក្ខុវិញ្ញាណធាតុ និង ធម៌ទាំងឡាយ ដែលសម្បយុត្ត ដោយចក្ខុវិញ្ញាណធាតុនោះ ជាបច្ច័យ ដោយអនន្តរប្បច្ច័យ នៃមនោធាតុ និង នៃធម៌ទាំងឡាយដែលសម្បយុត្តហើយ ដោយមនោធាតុនោះ” ដូច្នេះជាដើម (និង) ព្រោះឧបនិស្ស័យ មកហើយ ដោយន័យថា “ធម៌ទាំងឡាយ ដែលជាកុសលមុនៗ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ នៃធម៌ទាំងឡាយដែលជាកុសលក្រោយៗ” ដូច្នេះជាដើម ។

សូម្បីការប្លែកពីគ្នា ក្នុងនិក្ខេបនោះ ដោយសេចក្តី ក៏រមែងដល់នូវភាពតែមួយហ្នឹងឯង ។ សូម្បីកាលបើយ៉ាងដូច្នេះក៏ដោយ ភាពជាអនន្តរប្បច្ច័យ បណ្ឌិត គប្បីជ្រាប ដោយភាវៈជាធម៌អាច ក្នុងការញុំាងចិត្តុប្បាទ ដែលសមគួរដល់លំដាប់នៃខណៗ ឲ្យប្រព្រឹត្តទៅ, (ចំណែក) ភាពជាអនន្តរូបនិស្ស័យ បណ្ឌិត គប្បីជ្រាប ដោយភាវៈនៃចិត្តខាងដើម (មុន) ជាហេតុមានកម្លាំង ក្នុងការញុំាងចិត្តខាងចុង (ក្រោយ) ឲ្យកើតឡើង ។ ព្រោះថា ចិត្តសូម្បីប្រាសចាកធម៌ណាមួយ បណ្តាធម៌ទាំងឡាយ មានហេតុប្បច្ច័យធម៌ជាដើម ក៏រមែងកើតឡើងយ៉ាងណា, ធម្មតាការកើតឡើង នៃចិត្ត វៀរលែងតែចិត្ត ជាលំដាប់ហើយ នឹងមានយ៉ាងដូច្នោះ មិនបានទេ ព្រោះហេតុនោះ អនន្តរូបនិស្ស័យ ទើបជាបច្ច័យដ៏មានកម្លាំង ។ ដោយប្រការដូចបានពោលមកនេះ បណ្ឌិត គប្បីជ្រាប ភាពផ្សេងគ្នា នៃធម៌ទាំងពីរយ៉ាងនោះ យ៉ាងដូច្នេះថា “ធម៌ ជាអនន្តរប្បច្ច័យ ដោយអំណាចនៃការញុំាងចិត្ត ដែលសមគួរដល់លំដាប់នៃខណៗ



ឲ្យកើតឡើង ជាអនន្តរូបនិស្ស័យ ដោយអំណាចនៃហេតុដែលមានកម្លាំង” ដូច្នេះ ។

(បកតូបនិស្ស័យ)

ចំណែក បកតូបនិស្ស័យ បណ្ឌិតគប្បីជ្រាបថា “ឧបនិស្ស័យដែលធ្វើហើយដោយល្អ ឈ្មោះថា បកតូបនិស្ស័យ ។

បច្ច័យធម៌ដែលបុគ្គលកសាងហើយ(ឲ្យសំរេច) ក្នុងសន្តាន របស់ខណក្តី បច្ច័យខាងក្រៅមានរដូវ និង ភោជនជាដើម ដែលបុគ្គលសេពហើយ ដោយអំណាចនៃសទ្ធា និង សីលជាដើមក្តី ឈ្មោះថា បកតៈ (កសាងហើយយ៉ាងល្អ) ។

ន័យមួយទៀត ឧបនិស្ស័យ ដោយប្រក្រតីហ្នឹងឯង ឈ្មោះថា បកតូបនិស្ស័យ ។ មានសេចក្តីថា: មិនប្រឡូកប្រឡល់ដោយអារម្មណូ-បនិស្ស័យ និង អនន្តរូបនិស្ស័យ ។

បណ្ឌិត គប្បីជ្រាបប្រភេទ នៃបកតូបនិស្ស័យនោះ ដោយអនេក-ប្បការ ដោយន័យជាអាទិ៍ ថា “បកតូបនិស្ស័យ គឺបុគ្គលអាស្រ័យសទ្ធាហើយ រមែងឲ្យទាន សមាទានសីល បំពេញឧបោសថកម្ម ញុំាងឈានឲ្យកើតឡើង ញុំាងវិបស្សនាឲ្យកើត ញុំាងមគ្គឲ្យកើត ញុំាងអភិញ្ញាឲ្យកើត ញុំាងសមាបត្តិឲ្យកើត អាស្រ័យនូវសីល...នូវសុតៈ...នូវចាគៈ ...នូវបញ្ញាហើយ រមែងឲ្យទាន ។ល។ រមែងញុំាងសមាបត្តិ ឲ្យកើតឡើង សទ្ធា, សីល, សុតៈ, ចាគៈ, បញ្ញា ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ នៃសទ្ធា សីល សុតៈ ចាគៈ បញ្ញា” [១] ដូច្នេះ ។

ធម៌ទាំងឡាយ មានសទ្ធាជាដើមនេះ គឺបុគ្គលធ្វើល្អហើយផង ជា

១- អភិ. ប. ភាគទី ៩៤ ទំព័រទី ២៥៧ ។

ឧបនិស្ស័យ ដោយអត្ថថា ជាហេតុមានកម្លាំងផង ដូចពណ៌នាមកនេះឯង ព្រោះហេតុនេះ ទើបឈ្មោះថា បកតូបនិស្ស័យ ។

(កែបុរេជាតប្បច្ច័យ)

(៣៧៣) ធម៌ដែលជាឧបការៈ ដោយភាវៈជាធម៌កើតឡើងមុនគេហើយប្រព្រឹត្តទៅ ឈ្មោះថា បុរេជាតប្បច្ច័យ ។ បុរេជាតប្បច្ច័យនោះមាន ១១ យ៉ាង ដោយអំណាចនៃវត្ថុ, អារម្មណ៍ និង ហទយវត្ថុ ក្នុងបញ្ចទ្វារ ។ ដូចជាព្រះមានព្រះភាគ ត្រាស់ថា “ចក្ខាយតនៈ ជាបច្ច័យដោយបុរេជាតប្បច្ច័យ នៃចក្ខុវិញ្ញាណធាតុ និង នៃធម៌ទាំងឡាយដែលសម្បយុត្តដោយចក្ខុវិញ្ញាណធាតុនោះ, សោតាយតនៈ... ឃានាយតនៈ...ជិវ្ហាយតនៈ...កាយាយតនៈ ជាបច្ច័យ ដោយបុរេជាតប្បច្ច័យនៃកាយវិញ្ញាណធាតុ និង នៃធម៌ទាំងឡាយដែលសម្បយុត្ត ដោយកាយ-វិញ្ញាណធាតុនោះ, រូបាយតនៈ ជាបច្ច័យ ដោយបុរេជាតប្បច្ច័យ នៃចក្ខុវិញ្ញាណធាតុ និង នៃធម៌ទាំងឡាយដែលសម្បយុត្ត ដោយកាយ-វិញ្ញាណធាតុនោះ, សទ្ទាយតនៈ...គន្ធាយតនៈ...រសាយតនៈ...ផោដ្ឋព្វាយតនៈ ជាបច្ច័យ ដោយបុរេជាតប្បច្ច័យនៃមនោធាតុ, មនោធាតុ និង មនោវិញ្ញាណធាតុ អាស្រ័យនូវរូបណាហើយ ប្រព្រឹត្តទៅ, រូបនោះ ជាបច្ច័យ ដោយបុរេជាតប្បច្ច័យ នៃមនោធាតុ និង នៃធម៌ទាំងឡាយដែលសម្បយុត្ត ដោយមនោធាតុនោះ ជាបច្ច័យ ដោយបុរេជាតប្បច្ច័យ នៃមនោវិញ្ញាណធាតុ និង នៃធម៌ទាំងឡាយ ដែលសម្បយុត្ត ដោយមនោវិញ្ញាណធាតុនោះ ក្នុងកាលខ្លះ, មិនជាបច្ច័យដោយបុរេជាតប្បច្ច័យក្នុងកាលខ្លះ [១] ” ដូច្នេះ ។

១□ អភិ. ប. ភាគទី ៩៤ ទំព័រទី ១១ ។



(កែបច្ឆាជាតប្បច្ច័យ)

(៣៧៤) អរូបធម៌ ដែលជាឧបការៈ ដោយភាពជាធម៌ ជួយឧត្ថម្ភនូវរូបធម៌ទាំងឡាយដែលកើតមុន ឈ្មោះថា បច្ឆាជាតប្បច្ច័យ ប្រៀបដូចជាចេតនា គឺប្រាថ្នា ក្នុងអាហារ ឧបត្ថម្ភនូវរាងកាយ នៃកូនសត្វត្មាតយ៉ាងនោះឯង ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ថា “ចិត្ត និង ចេតសិកធម៌ទាំងឡាយ ដែលកើតក្រោយ ជាបច្ច័យ ដោយបច្ឆាជាតប្បច្ច័យ នៃកាយនេះ ដែលកើតមុន” ដូច្នេះ ។

(កែអាសេវនប្បច្ច័យ)

ធម៌ដែលជាឧបការៈ ដោយអត្ថ គឺអាសេវនៈ ដើម្បីភាពស្ទាត់ជំនាញនិងមានកម្លាំងនៃអនន្តរធម៌ទាំងឡាយ ឈ្មោះថា អាសេវនប្បច្ច័យ ប្រៀបដូចជាសេចក្តីព្យាយាម ដ៏ក្រៃលែងមុនៗ ក្នុងការសិក្សាគម្ពីរជាដើម (ដើម្បីការស្ទាត់ជំនាញ ក្នុងការសិក្សាគម្ពីរក្រោយៗ) យ៉ាងនេះឯង ។ អាសេវនប្បច្ច័យនោះ មានបីយ៉ាង ដោយអំណាចនៃជវនៈដែលជាកុសល, អកុសល និង កិរិយា ។ សមដូចជាព្រះមានព្រះភាគត្រាស់ថា “កុសលធម៌ទាំងឡាយមុនៗ ជាបច្ច័យ ដោយអាសេវ-នប្បច្ច័យ នៃកុសលធម៌ទាំងឡាយក្រោយៗ កិរិយាព្យាកតធម៌ទាំងឡាយ ជាបច្ច័យ ដោយអាសេវនប្បច្ច័យ នៃកិរិយាព្យាកតធម៌ទាំងឡាយក្រោយៗ [១] ” ដូច្នេះ ។

(កែកម្មប្បច្ច័យ)

(៣៧៥) ធម៌ដែលជាឧបការៈ ដោយភាវៈជាអ្នកធ្វើ ពោលគឺចិត្តប្បយោគ (គឺការប្រកបតាមផ្លូវចិត្ត) ឈ្មោះថា កម្មប្បច្ច័យ ។

១□ អភិ. ប. ភាគទី ៩៤ ទំព័រទី ១២ ។

កម្មប្បច្ច័យនោះ មាន ២ យ៉ាង ដោយអំណាចនៃកុសលចេតនា និង អកុសលចេតនា ដែលប្រព្រឹត្តទៅក្នុងខណៈផ្សេង និង ដោយអំណាចនៃចេតនាទាំងពួងដែលកើតព្រមជាមួយគ្នា ។ សមដូចជាព្រះមានព្រះភាគត្រាស់ថា "កុសលកម្ម និង អកុសលកម្ម ជាបច្ច័យ ដោយកម្មប្បច្ច័យ នៃខន្ធទាំងឡាយដែលជាវិបាក និង នៃកដត្តារូប គឺរូបដែលកើតមកពីកម្មទាំងឡាយផង, សហជាតចេតនា ជាបច្ច័យ ដោយកម្មប្បច្ច័យ នៃធម៌ទាំងឡាយ ដែលសម្បយុត្ត ដោយចេតនា និង នៃរូបទាំងឡាយ ដែលមានចេតនានោះ ជាសមុដ្ឋានផង" ដូច្នេះ ។

(វែកវិបាកប្បច្ច័យ)

(៣៧៦) វិបាកធម៌ ដែលជាឧបការៈ ដោយភាពជាធម៌ស្ងប់ស្ងាត់ មិនមានឧស្សាហ៍ ដើម្បីភាពជាធម៌ស្ងប់ស្ងាត់ មិនមានឧស្សាហ៍ ឈ្មោះថា វិបាកប្បច្ច័យ ។ វិបាកប្បច្ច័យនោះ ជាបច្ច័យនៃរូបទាំងឡាយដែលមានចិត្តជាសមុដ្ឋាន ក្នុងប្រវត្តិកាល និង នៃកដត្តារូបទាំងឡាយ ក្នុងបដិសន្ធិកាល និង នៃសម្បយុត្តធម៌ទាំងឡាយ ក្នុងកាលទាំងពួងផង ។ សមដូចជាព្រះមានព្រះភាគ ត្រាស់ថា "ខន្ធ ១ ដែលជាវិបាកអព្យាក្រឹត ជាបច្ច័យ ដោយវិបាកប្បច្ច័យ នៃខន្ធទាំងឡាយ៣ និង នៃរូបទាំងឡាយដែលមានចិត្តជាសមុដ្ឋាន ។បេ។ ខន្ធ ១ ជាវិបាកអព្យាកតៈ ជាបច្ច័យ ដោយវិបាកប្បច្ច័យ នៃខន្ធទាំងឡាយ ៣ និង នៃកដត្តារូបទាំងឡាយ ក្នុងខណៈនៃបដិសន្ធិ, ខន្ធទាំងឡាយ ៣ ជាបច្ច័យ ដោយវិបាកប្បច្ច័យ នៃខន្ធ ១, ខន្ធ ២ ជាបច្ច័យដោយវិបាកប្បច្ច័យនៃខន្ធ២ និង នៃកដត្តារូបទាំងឡាយ, ខន្ធទាំងឡាយ ជាបច្ច័យដោយវិបាកប្បច្ច័យនៃវត្ថុ" ដូច្នេះ ។

(វែកអាហារប្បច្ច័យ)



(៣៧៧) អាហារ ៤ ដែលជាឧបការៈ ដោយអត្ថ គឺជាអ្នកជួយឧបត្ថម្ភដល់រូប និង អរូបទាំងឡាយ ឈ្មោះថា អាហារប្បច្ច័យ ។ សមដូចជាព្រះមានព្រះភាគត្រាស់ថា "កពឡិង្ការាហារ [១] ជាបច្ច័យដោយអាហារប្បច្ច័យ នៃកាយនេះ, អាហារទាំងឡាយដែលមិនមានរូប ជាបច្ច័យ ដោយអាហារប្បច្ច័យ នៃសម្បយុត្តធម៌ទាំងឡាយ និង នៃរូបទាំងឡាយដែលមានអរូបាហារនោះជាសមុដ្ឋាន" ដូច្នេះ ។ តែក្នុងបញ្ហាវារៈ លោកពោលថា "ក្នុងបដិសន្ធិខណៈ អាហារទាំងឡាយ ដែលជាវិបាកអព្យាកតៈ ជាបច្ច័យ ដោយអាហារប្បច្ច័យ នៃខន្ធទាំងឡាយដែលសម្បយុត្ត ដោយអាហារនោះ និង នៃកដត្តារូបទាំងឡាយផង" ដូច្នេះផងដែរ ។

(វែកឥន្ទ្រិយប្បច្ច័យ)

(៣៧៨) ឥន្ទ្រីយ៍ ២០ លើកលែងឥត្ថិន្ទ្រីយ៍ និង បុរិសិន្ទ្រីយ៍ចេញ ដែលជាឧបការៈ ដោយអត្ថគឺជាធំ ឈ្មោះថា ឥន្ទ្រិយប្បច្ច័យ ។ ក៏ក្នុងឥន្ទ្រីយ៍ទាំង ២០ នោះ ឥន្ទ្រីយ៍ ៥ មានចក្ខុន្ទ្រីយ៍ជាដើម ជាបច្ច័យនៃអរូបធម៌ទាំងឡាយតែប៉ុណ្ណោះ, ឥន្ទ្រីយ៍ទាំងឡាយដ៏សេស ជាបច្ច័យនៃរូបធម៌ និង អរូបធម៌ទាំងឡាយ ។ សមដូចជាព្រះមានព្រះភាគត្រាស់ថា "ចក្ខុន្ទ្រីយ៍ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ [២] នៃចក្ខុវិញ្ញាណធាតុ និង នៃធម៌ទាំងឡាយ ដែលសម្បយុត្ត ដោយចក្ខុវិញ្ញាណធាតុនោះ ។បេ។ សោតិន្ទ្រីយ៍... ឃានិន្ទ្រីយ៍... ជិវ្ហិន្ទ្រីយ៍... កាយិន្ទ្រីយ៍ ជាបច្ច័យ ដោយឥន្ទ្រិយប្បច្ច័យ នៃកាយវិញ្ញាណធាតុ និង ធម៌ទាំងឡាយដែលសម្បយុត្តដោយកាយវិញ្ញាណធាតុនោះ, រូបជីវិតិន្ទ្រិយ៍ ជាបច្ច័យ

---

១- អភិ. ប. ភាគទី ៩៨ ទំព័រទី ២៧៩ ។ ២- អភិ. ប. ភាគ ៩៨ ទំព័រ ១៣ ។

ដោយឥន្ទ្រិយប្បច្ច័យ នៃកដត្តារូបទាំងឡាយ, ឥន្ទ្រីយ៍ទាំងឡាយដែលជាអរូប ជាបច្ច័យ ដោយឥន្ទ្រិយប្បច្ច័យ នៃសម្បយុត្តធម៌ទាំងឡាយ និង នៃរូបទាំងឡាយ ដែលមានអរូបឥន្ទ្រិយ៍នោះ ជាសមុដ្ឋាន" ដូចេះ ។ តែក្នុងបញ្ហាវារៈ លោកពោលថា "ក្នុងបដិសន្ធិខណៈ ឥន្ទ្រីយ៍ទាំងឡាយ ដែលជាវិបាកអព្យាក្រឹត ជាបច្ច័យ ដោយឥន្ទ្រិយប្បច្ច័យ នៃសម្បយុត្តខន្ធទាំងឡាយ និង នៃកដត្តារូបទាំងឡាយផង" ដូច្នេះផងដែរ ។

(កែឈានប្បច្ច័យ)

(៣៧៩) អង្គឈានទាំងឡាយ ៧ ផ្សេងដោយកុសលឈាន ជាដើមទាំងពួង វៀរលែងវេទនា ២ គឺសុខវេទនា និង ទុក្ខវេទនា ក្នុងទ្វិបញ្ចវិញ្ញាណចេញ ដែលជាឧបការៈ ដោយអត្ថ គឺចូលទៅសំឡឹង ឈ្មោះថា ឈានប្បច្ច័យ ។ សមដូចព្រះមានព្រះភាគត្រាស់ថា "អង្គឈានទាំងឡាយ ជាបច្ច័យ ដោយឈានប្បច្ច័យ នៃធម៌ទាំងឡាយដែលសម្បយុត្តដោយឈាន និង នៃរូបទាំងឡាយដែលមានឈាននោះជាសមុដ្ឋាន" ដូច្នេះ ។ តែក្នុងបញ្ហាវារៈ លោកពោលថា "ក្នុងបដិសន្ធិខណៈ អង្គឈានទាំងឡាយ ដែលជាវិបាកអព្យាកតៈ ជាបច្ច័យ ដោយឈានប្បច្ច័យ នៃសម្បយុត្តខន្ធទាំងឡាយ និង នៃកដត្តារូបទាំងឡាយផង" ដូច្នេះទៀតផង ។

(កែមគ្គប្បច្ច័យ)

(៣៨០) អង្គមគ្គទាំងឡាយ១២ [១] ផ្សេងដោយកុសលមគ្គជាដើម ជាឧបការៈ ដោយអត្ថ គឺនាំចេញ អំពីរបស់ណានីមួយនោះ ឈ្មោះថា មគ្គប្បច្ច័យ ។ សមដូចព្រះមានព្រះភាគ ត្រាស់ថា "អង្គមគ្គទាំងឡាយ

១- កន្លែងខ្លះ មាន៨ កន្លែងខ្លះ មាន១០ សម្មាទិដ្ឋិ-សម្មាវិមុត្តិ (១២ ពុំដែលឃើញ) ។



ជាបច្ច័យ ដោយមគ្គប្បច្ច័យ នៃធម៌ទាំងឡាយដែលសម្បយុត្ត ដោយមគ្គ និង នៃរូបទាំងឡាយ ដែលមានមគ្គនោះ ជាសមុដ្ឋានផង" ដូច្នេះ ។ តែ ក្នុងបញ្ហាវារៈ លោកពោលថា "ក្នុងបដិសន្ធិខណៈ អង្គមគ្គទាំងឡាយ ដែលជាវិបាកអព្យាក្រឹត ជាបច្ច័យ ដោយមគ្គប្បច្ច័យ នៃសម្បយុត្តខន្ធទាំងឡាយ និង នៃកដត្តារូបទាំងឡាយផង" ដូច្នេះខ្លះ ។

តែឈានប្បច្ច័យ និង មគ្គប្បច្ច័យ ទាំង ២ នោះ បណ្ឌិតគប្បីជ្រាបថា "តែងមិនបាន ក្នុងទ្វិបញ្ចវិញ្ញាណ និង អហេតុកចិត្តទាំងឡាយ" ដូច្នេះ ។

(កែសម្បយុត្តប្បច្ច័យ)

(៣៨១) អរូបធម៌ទាំងឡាយ ដែលជាឧបការៈ ដោយភាពជាសម្បយុត្តធម៌ ពោលគឺ មានវត្ថុតែមួយ មានអារម្មណ៍តែមួយ និង កើតជាមួយគ្នា រលត់ជាមួយគ្នា ឈ្មោះថា សម្បយុត្តប្បច្ច័យ ។ សមដូចជាព្រះមានព្រះភាគ ត្រាស់ថា "ខន្ធទាំងឡាយ ៤ ដែលជាអរូប ជាបច្ច័យ ដោយសម្បយុត្តប្បច្ច័យ ដល់គ្នានឹងគ្នាទៅវិញទៅមក" ដូច្នេះ ។

(កែវិប្បយុត្តប្បច្ច័យ)

ធម៌ទាំងឡាយដែលមានរូប ជាឧបការៈ ដោយមិនចូលទៅកាន់ភាពជាធម៌ មានវត្ថុតែមួយជាដើម ឈ្មោះថា វិប្បយុត្តប្បច្ច័យ នៃរូបធម៌ទាំងឡាយ, សូម្បីអរូបធម៌ទាំងឡាយ ក៏ជាវិប្បយុត្តប្បច្ច័យ នៃរូបធម៌ទាំងឡាយដែរ ។ វិប្បយុត្តប្បច្ច័យទាំងឡាយនោះ មាន ៣ ដោយអំណាច នៃសហជាត, បច្ឆាជាត និង បុរេជាត ។ សមដូចជាព្រះមានព្រះភាគត្រាស់ថា "កុសលខន្ធទាំងឡាយ ដែលជាសហជាត ជាបច្ច័យដោយវិប្បយុត្តប្បច្ច័យ នៃរូបទាំងឡាយដែលមានចិត្តជាសមុដ្ឋាន,

កុសលខន្ធទាំងឡាយ ដែលជាបច្ឆាជាត ជាបច្ច័យ ដោយវិប្បយុត្ត-ប្បច្ច័យ នៃកាយនេះ ដែលជាបុរេជាត” ដូច្នេះ ។ តែក្នុងសហជាតវិភង្គ នៃបទអព្យាកតៈ លោកពោលថា “ក្នុងបដិសន្ធិខណៈ ខន្ធទាំងឡាយ ដែលជាវិបាកអព្យាកតៈ ជាបច្ច័យ ដោយវិប្បយុត្តប្បច្ច័យ នៃកដត្តារូបទាំងឡាយ, ខន្ធទាំងឡាយ ជាបច្ច័យ ដោយវិប្បយុត្តប្បច្ច័យ នៃវត្ថុ, វត្ថុ ជាបច្ច័យ ដោយវិប្បយុត្តប្បច្ច័យ នៃខន្ធទាំងឡាយ” ដូច្នេះ ក៏មាន ។ ចំណែកដែលជាបុរេជាត បណ្ឌិត គប្បីជ្រាប ដោយអំណាចនៃវត្ថុ មានឥន្ទ្រិយ៍ជាដើមហ្នឹងឯង ។ ដូចព្រះមានព្រះភាគ ត្រាស់ថា “ចក្ខាយតនៈ ដែលជាបុរេជាត ជាបច្ច័យ ដោយវិប្បយុត្តប្បច្ច័យនៃចក្ខុវិញ្ញាណ ។ល។ កាយាយតនៈ ដែលជាបុរេជាត ជាបច្ច័យ ដោយវិប្បយុត្តប្បច្ច័យ នៃកាយវិញ្ញាណ, វត្ថុ ជាបច្ច័យ ដោយវិប្បយុត្តប្បច្ច័យ នៃខន្ធទាំងឡាយ ដែលជាវិបាកអព្យាក្រឹត ជាកិរិយាអព្យាក្រឹត ។ល។ វត្ថុ (ហទយវត្ថុ) ជាបច្ច័យ ដោយវិប្បយុត្តប្បច្ច័យ នៃកុសលខន្ធទាំងឡាយ ។ល។ វត្ថុ ជាបច្ច័យ ដោយវិប្បយុត្តប្បច្ច័យ នៃអកុសលខន្ធទាំងឡាយ” ដូច្នេះ ។

(វែកអត្ថិប្បច្ច័យ)

(៣៨២) ធម៌ដែលជាឧបការៈ ដោយភាពជាធម៌ ជួយឧបត្ថម្ភ ដល់ធម៌ដែលប្រាកដ ដូចនោះដែរ ដោយភាវៈគឺមាននៅ ដែលមានលក្ខណៈជាបច្ចុប្បន្ន ឈ្មោះថា អត្ថិប្បច្ច័យ ។ មាតិកា នៃអត្ថិប្បច្ច័យនោះ លោកបានតាំងទុកហើយ (មាន) ៧ ប្រការ ដោយអំណាច នៃអរូបក្ខន្ធ, មហាភូត, នាមរូប, ចិត្ត, ចេតសិក, មហាភូតរូប, អាយតនៈ និង វត្ថុ (ហទយវត្ថុ) ។ សមដូចព្រះមានព្រះភាគ ត្រាស់ថា “ខន្ធទាំងឡាយ ៤ ដែលជាអរូប ជាបច្ច័យ ដោយអត្ថិប្បច្ច័យ ដល់គ្នានឹងគ្នា, មហាភូតរូប



៤ ជាបច្ច័យ ដោយអត្ថិប្បច្ច័យដល់គ្នានឹងគ្នា, នាមរូប ជាបច្ច័យ ដោយអត្ថិប្បច្ច័យដល់គ្នានឹងគ្នា ក្នុងឱក្កន្តិខណៈ(ខណៈចុះកាន់គភ៌) ចិត្ត និងចេតសិកធម៌ទាំងឡាយ ជាបច្ច័យ ដោយអត្ថិប្បច្ច័យ នៃរូបទាំងឡាយ ដែលមានចិត្តជាសមុដ្ឋាន, មហាភូតរូប ជាបច្ច័យ ដោយអត្ថិប្បច្ច័យ នៃឧបាទាយរូបទាំងឡាយ, ចក្ខាយតនៈ ជាបច្ច័យ ដោយអត្ថិប្បច្ច័យ នៃចក្ខុវិញ្ញាណធាតុ ។ល។ កាយាយតនៈ ។ល។ រូបាយតនៈ ។ល។ ផោដ្ឋព្វាយតនៈ ជាបច្ច័យ នៃកាយវិញ្ញាណធាតុ និង ធម៌ទាំងឡាយ ដែលសម្បយុត្ត ដោយកាយវិញ្ញាណធាតុនោះ, រូបាយតនៈ ។ល។ ផោដ្ឋព្វាយតនៈ ជាបច្ច័យ ដោយអត្ថិប្បច្ច័យនៃមនោធាតុ និង ធម៌ទាំងឡាយ ដែលសម្បយុត្តដោយមនោធាតុនោះ, មនោធាតុ និង មនោ-វិញ្ញាណធាតុ អាស្រ័យរូបណាប្រព្រឹត្តទៅ, រូបនោះ ជាបច្ច័យ ដោយអត្ថិប្បច្ច័យ នៃមនោធាតុ និង មនោវិញ្ញាណធាតុ និង ធម៌ទាំងឡាយ ដែលសម្បយុត្តដោយមនោវិញ្ញាណធាតុនោះ” ដូច្នេះ ។ តែក្នុងបញ្ហា-វារៈ លោកតាំងមាតិកាបន្ថែមទៀតគឺ “សហជាត, បុរេជាត, បច្ឆាជាត, អាហារ, ឥន្ទ្រិយ៍” ដូច្នេះហើយ ធ្វើនិទ្ទេស ក្នុងសហជាត ជាមុន ដោយន័យជាអាទិ៍ថា “ខន្ធ ១ ជាបច្ច័យ ដោយអត្ថិប្បច្ច័យ នៃខន្ធ ៣ និង នៃរូបទាំងឡាយដែលមានខន្ធ ៣ នោះ ជាសមុដ្ឋាន” ដូច្នេះ ។ ក្នុងបុរេជាត លោកធ្វើនិទ្ទេស ដោយអំណាចនៃអាយតនៈ មានចក្ខុជាដើម ដែលជាបុរេជាត ។ ក្នុងបច្ឆាជាត លោកធ្វើនិទ្ទេស ដោយអំណាចនៃកាយនេះ ដែលជាបច្ឆាជាត ជាបច្ច័យនៃចិត្ត និង ចេតសិកធម៌ទាំងឡាយ ដែលជាបច្ឆាជាត ។ ក្នុងអាហារ និង ឥន្ទ្រិយ៍ លោកធ្វើនិទ្ទេស យ៉ាងនេះ ថា “កពឡិង្ការាហារ ជាបច្ច័យ ដោយអត្ថិប្បច្ច័យ នៃកាយនេះ, រូប-

ជីវិតិន្ទ្រិយ៍ ជាបច្ច័យ ដោយអត្ថិប្បច្ច័យនៃកដត្តារូបទាំងឡាយ” ដូច្នេះ ។

(វែកនត្ថិប្បច្ច័យ)

អរូបធម៌ ទាំងឡាយ ដែលរលត់ទៅហើយយ៉ាងរហ័ស ជាឧបការៈ ដោយឲ្យនូវឱកាស ដើម្បីការប្រព្រឹត្តិទៅ នៃអរូបធម៌ទាំងឡាយ ដែលកើតឡើងក្នុងលំដាប់នៃខ្លួន ឈ្មោះថា នត្ថិប្បច្ច័យ ។ សមដូចព្រះមានព្រះភាគត្រាស់ថា “ចិត្ត និង ចេតសិកធម៌ទាំងឡាយ ដែលរលត់ហើយ ដោយឆាប់រហ័ស រមែងជាបច្ច័យ ដោយនត្ថិប្បច្ច័យ នៃចិត្ត និង ចេតសិកធម៌ទាំងឡាយ ដែលជាបច្ចុប្បន្ន” ដូច្នេះ ។

(វែកវិគតប្បច្ច័យ)

(៣៨៣) នត្ថិប្បច្ច័យទាំងឡាយនោះឯង ឈ្មោះថា វិគតប្បច្ច័យ ព្រោះជាធម៌ ធ្វើនូវឧបការៈ ដោយភាពជាធម៌ ទៅប្រាសហើយ ។ សមដូចព្រះមានព្រះភាគត្រាស់ថា “ចិត្ត និង ចេតសិកធម៌ទាំងឡាយ ដែលទៅប្រាសហើយយ៉ាងឆាប់រហ័ស ជាបច្ច័យ ដោយវិគតប្បច្ច័យ នៃចិត្ត និង ចេតសិកធម៌ទាំងឡាយ ដែលជាបច្ចុប្បន្ន” ដូច្នេះ ។

(វែកអវិគតប្បច្ច័យ)

មួយទៀត អត្ថិប្បច្ច័យធម៌ទាំងឡាយហ្នឹងឯង បណ្ឌិតគប្បីជ្រាបថា ឈ្មោះថា អវិគតប្បច្ច័យ ព្រោះជាធម៌មានឧបការៈ ដោយភាពជាធម៌ដែលមិនទាន់ទៅប្រាសហើយ ។

ក៏ទុកៈនេះ ព្រះមានព្រះភាគ ត្រាស់ហើយ ដោយសេចក្ដីលំអរនៃទេសនា ឬ ដោយអំណាចនៃវេនេយ្យសត្វ ដែលព្រះអង្គគប្បីដឹកនាំដោយទេសនាវិធីនោះ ដូចជាហេតុវិប្បយុត្តទុកៈ សូម្បីព្រះអង្គត្រាស់អហេតុទុកៈហើយ ក៏ទ្រង់ត្រាស់បន្ថែមទៀត យ៉ាងនោះឯង ។



(វែកបទអវិជ្ជាបច្ចយា សង្ខារា)

(៣៨៤) ក្នុងបច្ច័យ ២៤ ដូចបានពោលមកហើយនេះ

អវិជ្ជានេះ រាប់ថា ជាបច្ច័យ នៃអភិសង្ខារ គឺបុណ្យ
ទាំងឡាយ ដោយប្រការ២ តែអវិជ្ជានោះ ជាបច្ច័យ
នៃអភិសង្ខារដទៃទៀត (គឺអបុញ្ញាភិសង្ខារ) ដោយ
ប្រការជាអនេក ជាបច្ច័យនៃអភិសង្ខារ ជាទីបំផុត
(គឺអនេញ្ជាភិសង្ខារ)ដោយប្រការ១ យ៉ាងនេះឯង ។

បណ្ដាពាក្យទាំងនោះ ពាក្យថា “ជាបច្ច័យ នៃអភិសង្ខារ គឺបុណ្យទាំងឡាយ ដោយប្រការ ២” សេចក្ដីថា អវិជ្ជា ជាបច្ច័យ (នៃបុញ្ញាភិសង្ខារ) ដោយប្រការ ២ គឺ ដោយអារម្មណប្បច្ច័យ ១ ដោយឧបនិស្សយប្បច្ច័យ ១ ។ អធិប្បាយថា : អវិជ្ជានោះ ជាបច្ច័យ ដោយអារម្មណប្បច្ច័យ នៃបុញ្ញាភិសង្ខារទាំងឡាយ ដែលជាកាមាវចរ ក្នុងពេលដែលពិចារណានូវអវិជ្ជា ដោយការអស់ទៅសូន្យទៅ, ជាបច្ច័យដោយអារម្មណប្បច្ច័យ នៃបុញ្ញាភិសង្ខារដែលជារូបាវចរ ក្នុងពេលដែលដឹងនូវចិត្ត ដែលប្រកបដោយមោហៈ ដោយអភិញ្ញាចិត្ត ។ ប៉ុន្តែកាលបើបុគ្គលបំពេញបុញ្ញកិរិយាវត្ថុ ដែលជាកាមាវចរទាំងឡាយ មានទានជាដើម ក្ដី ញុំាងរូបាវចរជ្ឈាន ឲ្យកើតឡើង ក្ដី ដើម្បីប្រយោជន៍ដល់ការកន្លងនូវអវិជ្ជា, អវិជ្ជានោះ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ នៃបុញ្ញាភិសង្ខារទាំង ២ យ៉ាងនោះ ។ កាលបើបុគ្គលប្រាថ្នានូវសម្បត្តិ ក្នុងកាមភព និង រូបភពហើយ ធ្វើបុណ្យទាំងនោះឯង ព្រោះជាអ្នកវង្វេង ព្រោះអវិជ្ជា (ការមិនដឹង) ក៏យ៉ាងដូច្នោះដែរ (មានន័យថា

*អវិជ្ជានោះ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ នៃបុញ្ញាភិសង្ខារទាំង ២ យ៉ាង ដូចគ្នានោះដែរ) ។*

*ពាក្យថា* “តែអវិជ្ជានោះ ជាបច្ច័យ នៃអភិសង្ខារដទៃទៀត (បន្ទាប់គ្នា)ដោយអនេកប្បការ” *សេចក្តីថា អវិជ្ជា ជាបច្ច័យនៃអបុញ្ញាភិសង្ខារទាំងឡាយ ដោយច្រើនប្រការ ។ សួរថា “តើយ៉ាងដូចម្តេច?” ។ ឆ្លើយថា “ក៏អវិជ្ជានុ៎ះ ជាបច្ច័យ (នៃអបុញ្ញាភិសង្ខារ) ដោយច្រើនប្រការ គឺក្នុងកាលដែលចេតសិក មានរាគៈជាដើម ប្រារព្ធនូវអវិជ្ជា កើតឡើង, អវិជ្ជានោះ ជាបច្ច័យ ដោយអារម្មណប្បច្ច័យ, ក្នុងពេលដែលធ្វើអវិជ្ជាឲ្យជាទីគោរពហើយត្រេកអរ, អវិជ្ជា ជាបច្ច័យ ដោយអារម្មណាធិបតី និង អារម្មណូបនិស្ស័យ, កាលបើបុគ្គលអ្នកវង្វេង ព្រោះការមិនដឹង មិនឃើញទោស ធ្វើបាបទាំងឡាយ មានបាណាតិបាតជាដើម អវិជ្ជានោះ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ, អវិជ្ជានោះ ជាបច្ច័យ ដោយអនន្តរ...សមនន្តរ...អនន្តរូបនិស្ស័យ...អាសេវនៈ...នត្ថិប្បច្ច័យ និង វិគតប្បច្ច័យ នៃជវនចិត្តទាំងឡាយ មានជវនចិត្ត ទី ២ ជាដើម កាលបើបុគ្គលធ្វើអកុសលឯណាមួយ អវិជ្ជានោះ ជាបច្ច័យ ដោយហេតុប្បច្ច័យ...សហជាត...អញ្ញមញ្ញ...និស្សយ...សម្បយុត្ត...អត្ថិប្បច្ច័យ និង វិគតប្បច្ច័យ” ដូច្នេះ ។*

*ពាក្យថា* “អវិជ្ជានោះ រាប់ថា ជាបច្ច័យ នៃអភិសង្ខារ ជាទីបំផុតដោយប្រការ ១” *សេចក្តីថា: អវិជ្ជានោះ រាប់ថា ជាបច្ច័យ ដោយប្រការ ១ គឺដោយឧបនិស្សយប្បច្ច័យ នៃអនេញ្ជាភិសង្ខារទាំងឡាយតែប៉ុណ្ណោះ ។ ក៏ភាវៈនៃអវិជ្ជានោះ ជាឧបនិស្សយប្បច្ច័យនោះ បណ្ឌិតគប្បីជ្រាប តាមន័យដែលបានពោលហើយ ក្នុងបុញ្ញាភិសង្ខារនោះឯង ។*



*(៣៨៥) ក្នុងបទថា “សង្ខារទាំងឡាយ កើតមាន ព្រោះអវិជ្ជា ជាបច្ច័យ” នេះ ចោទកាចារ្យសួរថា “ក៏អវិជ្ជា នេះ តែមួយប៉ុណ្ណោះ ជាបច្ច័យ នៃសង្ខារទាំងឡាយ ឬ ឬក៏ បច្ច័យទាំងឡាយដទៃទៀត ក៏មានដែរ?” ។ អាចារ្យអ្នកឆ្លើយៗ ថា “ក៏ក្នុងបញ្ហាខនេះ នឹងចាំបាច់ពោលធ្វើអ្វី បើអវិជ្ជា តែម្យ៉ាង ជាបច្ច័យ ក៏នឹងត្រូវពួកឯកការណវាទ (អ្នកពោលថា មានហេតុតែមួយ) បើមានបច្ច័យផ្សេងៗ ទៀត ឯកការណនិទ្ទេស ថា “សង្ខារទាំងឡាយ កើតមាន ព្រោះអវិជ្ជា ជាបច្ច័យ” ក៏មិនកើតប្រយោជន៍” ។ អាចារ្យអ្នកឆ្លើយ ពោលទៀតថា “ឯកការណនិទ្ទេសនោះ នឹងមិនកើតប្រយោជន៍ ក៏មិនមែនដែរ” ។*

*ព្រោះហេតុអ្វី? ។ ព្រោះថា :*

> ផល ១ (កើត) ពីហេតុ ១ មិនមាន, សូម្បីផល
> ជាអនេក (កើត) ពីហេតុ ១ ក៏មិនមាន, ផល ១
> (កើត)ពីហេតុជាអនេក ក៏មិនមាន, តែប្រយោជន៍
> ក្នុងការសំដែងហេតុ ១ និង ផល ១ មាន ។

*មែនពិត ផលមួយ (កើត) ពីហេតុមួយ ឥតមានអ្វីមួយឡើយ ក្នុងបច្ចយាការនេះ, ផលច្រើនជាអនេក (កើត)ពីហេតុមួយ ក៏មិនមាន, ផលមួយ (កើត) ពីហេតុច្រើនជាអនេក ក៏មិនមាន ។ តែថា ផលច្រើនយ៉ាង (កើត) ពីហេតុច្រើនយ៉ាងហ្នឹងឯងមាន ។ ពិតមែនដូច្នោះ ផលច្រើនយ៉ាង បានដល់រូប, ក្លិន រស ជាដើម និង ពន្លកហ្នឹងឯង រមែងកើតប្រាកដពីហេតុទាំងឡាយជាច្រើន ពោលគឺរដូវ, ដី, ពូជ និង ទឹក ។ តែការសំដែងហេតុមួយ និង ផលមួយនោះឯណា ដែលព្រះ*

មានព្រះភាគទ្រង់ធ្វើហើយថា “អវិជ្ជាបច្ចយា សង្ខារា សង្ខារប្បច្ចយា វិញ្ញាណំ” ដូច្នេះ, ក្នុងការសំដែងហេតុមួយ និង ផលមួយនោះ អត្ថ មានប្រយោជន៍ ក៏មាន ។

មែនពិត ព្រះមានព្រះភាគ ទ្រង់សំដែងហេតុមួយខ្លះ ផលមួយខ្លះ ដូចគ្នាដែរ ដោយកិរិយាសមគួរដល់សេចក្ដីល្អនៃទេសនា និង ដល់វេនេយ្យសត្វទាំងឡាយខ្លះ ក្នុងបទខ្លះ ព្រោះហេតុផលជាប្រធាន ក្នុងបទខ្លះ ព្រោះជាហេតុប្រាកដ ក្នុងបទខ្លះ ព្រោះជាហេតុដែលមិនទូទៅ ។ អធិប្បាយថា ព្រះមានព្រះភាគទ្រង់ត្រាស់ហេតុមួយផង ផលមួយផង ព្រោះភាវៈនៃហេតុ និង ផល ជាប្រធាន ដូចក្នុងបទថា “ផស្សប្បច្ចយា វេទនា” ដូច្នេះ ។ ព្រោះថា ផស្សៈ ជាដើមហេតុនៃវេទនា ព្រោះកំណត់វេទនា តាមសមគួរដល់ផស្សៈ ។ ឯវេទនា ជាប្រធានផលនៃផស្សៈ ព្រោះកំណត់ផស្សៈ តាមសមគួរដល់វេទនា ។ ព្រះមានព្រះភាគទ្រង់ត្រាស់ឯកហេតុ ព្រោះជាហេតុប្រាកដ ដូចក្នុងពាក្យថា “អាពាធទាំងឡាយមានស្លេស្ម៍ ជាសមុដ្ឋាន” ។ ព្រោះថា ក្នុងអាពាធនេះ ស្លេស្ម៍ជាហេតុប្រាកដ ហេតុដទៃមានកម្មជាដើម មិនបានប្រាកដ ។ ព្រះមានព្រះភាគ ត្រាស់ឯកហេតុ ព្រោះជាហេតុអាពាធនោះ ដូចក្នុងប្រយោគថា “ម្នាលភិក្ខុទាំងឡាយ! អកុសលធម៌ទាំងឡាយ ឯណានីមួយ មានអកុសលធម៌ទាំងឡាយទាំងពួងនោះ មានអយោនិសោមនសិការ ជាមូល” ដូច្នេះ ។ ព្រោះអយោនិសោមនសិការ ជាហេតុអសាធារណៈ, ហេតុដទៃទៀត មានវត្ថុ និង អារម្មណ៍ជាដើម ជាហេតុសាធារណៈដល់កុសលទាំងឡាយ ដោយប្រការដូច្នេះ ។

ព្រោះហេតុនេះ ក្នុងបច្ចយាការនេះ អវិជ្ជា នេះ សូម្បីកាលបើមាន



ហេតុ នៃសង្ខារទាំងឡាយដទៃទៀត មានវត្ថុ, អារម្មណ៍ និង សហជាតធម៌ជាដើម គប្បីជ្រាបថា “ព្រះមានព្រះភាគ ទ្រង់សំដែងហើយ ដោយភាវៈជាហេតុនៃសង្ខារទាំងឡាយ ព្រោះអវិជ្ជានោះ ជាសង្ខារហេតុដែលជាប្រធាន នៃសង្ខារហេតុទាំងឡាយដទៃទៀត មានតណ្ហាជាដើម ព្រោះព្រះបាលីថា “តណ្ហា រមែងចំរើនដល់បុគ្គលអ្នកពិចារណាឃើញថាជាទីត្រេកអរ [១] ” ដូច្នេះជាដើម និង ព្រោះព្រះបាលីថា “ការកើតឡើងនៃអាសវៈ កើតមាន ព្រោះការកើតឡើងនៃអវិជ្ជា [២] ” ដូច្នេះជាដើម ព្រោះជាហេតុប្រាកដ និង ព្រោះជាហេតុអសាធារណៈផង ព្រោះព្រះបាលីថា “ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកមិនដឹង លុះក្នុងអំណាចនៃអវិជ្ជា រមែងតាក់តែង នូវបុញ្ញាភិសង្ខារខ្លះ” ដូច្នេះជាដើម ។ ក៏ប្រយោជន៍ ក្នុងការត្រាស់សំដែងឯកហេតុ និង ឯកផល ក្នុងបទទាំងពួង បណ្ឌិត គប្បីជ្រាប ដោយពាក្យអធិប្បាយ នូវការសំដែងឯកហេតុ និង ឯកផលនោះហ្នឹងឯង ។

(៣៨៦) ក្នុងបទថា “អវិជ្ជាបច្ចយា សង្ខារា” នេះ ចោទកាចារ្យសួរថា “សូម្បីកាលបើយ៉ាងដូច្នោះ ភាវៈនៃអវិជ្ជា ជាធម៌ដែលមានទោស មានផលដែលមិនជាទីប្រាថ្នា ដោយចំណែកមួយ ជាបច្ច័យនៃបុញ្ញាភិសង្ខារ និង អនេញ្ជាភិសង្ខារ នឹងសមគួរយ៉ាងដូចម្ដេច? ព្រោះថា អំពៅ នឹងកើតអំពីពូជស្ដៅ មិនបានឡើយ” យ៉ាងដូច្នេះ ។ អាចារ្យអ្នកឆ្លើយៗ ថា “នឹងមិនសមគួរ យ៉ាងដូចម្ដេច ព្រោះថា ក្នុងលោក

**បច្ច័យ នៃធម៌ទាំងឡាយ ដែលខុសគ្នាក្ដី មិន**

---

១☐ សុ. សំ. ភាគទី ៣១ ទំព័រទី ១៨៩ ។ ២☐ សុ. ភាគទី ២០ ទំព័រទី ១៨២ ។

ខុសគ្នាក្តី ដែលដូចគ្នាក្តី មិនដូចគ្នាក្តី ក៏យ៉ាងដូច្នោះ
រមែងសំរេចផល, តែធម៌ទាំងឡាយនោះ មិនមែន
ជាវិបាកឡើយ ។

*មែនពិត បច្ច័យដែលខុសគ្នា ដោយឋានៈ សភាវៈ និង កិច្ច ជាដើម នៃធម៌ទាំងឡាយក្តី ដែលមិនខុសគ្នាក្តី រមែងជាហេតុសំរេច ក្នុងលោក ។ ព្រោះថា ចិត្តមុន ជាបច្ច័យដែលខុសគ្នា ដោយឋានៈ នៃចិត្តក្រោយ និង ការសិក្សា មានការសិក្សាសិល្បៈជាអាទិ៍ខាងដើម ជាបច្ច័យដែលខុសគ្នា ដោយឋានៈនៃការងារទាំងឡាយ មានការប្រកបសិល្បៈជាអាទិ៍ ដែលប្រព្រឹត្តទៅឰដ៏ខាងក្រោយ ។ កម្ម ជាបច្ច័យដែលខុសគ្នា ដោយសភាវៈនៃរូប និង ភេសជ្ជៈ មានទឹកដោះស្រស់ជាដើម ជាបច្ច័យដែលខុសគ្នា ដោយសភាវៈនៃទឹកដោះជូរជាដើម ។ ពន្លឺ ជាបច្ច័យដែលខុសគ្នាដោយកិច្ច នៃចក្ខុវិញ្ញាណ និង ទឹកអំពៅជាដើម ជាបច្ច័យដែលខុសគ្នា ដោយកិច្ច នៃវត្ថុមានទឹកជាគ្រឿងត្រាំជាដើម ។ ចំណែកចក្ខុ និង រូបជាដើម ជាបច្ច័យដែលមិនខុសគ្នា ដោយឋានៈនៃចក្ខុវិញ្ញាណជាដើម ។ ជវនចិត្តមុនជាអាទិ៍ ជាបច្ច័យមិនខុសគ្នា ដោយភាវៈ និង មិនខុសគ្នា ដោយកិច្ច នៃជវនចិត្តក្រោយជាដើម ។*

*មួយទៀត បច្ច័យដែលខុសគ្នា និងមិនខុសគ្នា ជាហេតុសំរេចបានយ៉ាងណា, សូម្បីបច្ច័យដែលដូចគ្នា និងមិនដូចគ្នា ក៏ជាហេតុសំរេចបានយ៉ាងនោះដែរ ។ មែនពិត រូបពោលគឺរដូវ និង អាហារដែលដូចគ្នាហ្នឹងឯង ជាបច្ច័យនៃរូប និង ពូជនៃស្រូវសាលីជាដើម ដែលដូចគ្នានោះឯង ក៏ជាបច្ច័យ នៃគ្រាប់ស្រូវសាលីជាដើម ។ រូប ដែលមិនដូចគ្នា តែ*



*ជាបច្ច័យនៃអរូបបាន, ចំណែកអរូបក៏ជាបច្ច័យនៃរូបបាន និង រោមគោ រោមចៀម ស្នែងសត្វ ទឹកដោះជូរ ល្ង និង ម្សៅជាដើម ដែលមិនដូចគ្នា ក៏ជាបច្ច័យនៃស្មៅចិញ្ចៀន និង ស្លឹកគ្រៃជាដើម ក៏បានដែរ ។ តែបច្ច័យធម៌ទាំងនោះ ជាបច្ច័យដែលខុសគ្នា, មិនខុសគ្នា, ដូចគ្នា និង មិនដូចគ្នា នៃធម៌ទាំងឡាយណា ក៏ដោយ, ធម៌ទាំងឡាយនោះ ក៏មិនមែនជាវិបាក នៃធម៌ទាំងឡាយនោះឡើយ ។*

*ដូចបានរៀបរាប់មកនេះឯង អវិជ្ជានេះ ដោយអំណាចនៃវិបាក ជាធម៌ដែលមានផលមិនជាទីប្រាថ្នា ដោយចំណែកមួយ និងដោយអំណាចនៃសភាវៈ ក៏ជាធម៌ដែលមានទោស បណ្ឌិត គប្បីជ្រាបថា “អវិជ្ជានេះ ជាបច្ច័យ នៃសង្ខារ មានបុញ្ញាភិសង្ខារជាដើម ទាំងអស់នោះ ដោយអំណាចជាបច្ច័យដែលខុសគ្នា, មិនខុសគ្នា ដោយឋានៈ, កិច្ច និង សភាវៈ និង ដោយអំណាចជាបច្ច័យដែលដូចគ្នា មិនដូចគ្នា តាមសមគួរ” ។ ក៏ភាវៈនៃអវិជ្ជា ជាបច្ច័យនោះ លោកពោលហើយ ដោយន័យថា “ការមិនដឹង ពោលគឺ អវិជ្ជា ក្នុងទុក្ខជាដើម គឺបុគ្គលលះមិនទាន់បានហើយ បុគ្គលនោះ ព្រោះមិនដឹង ក្នុងទុក្ខជាមុន និង ក្នុងវត្ថុ នៃអវិជ្ជាទាំងឡាយ មានខន្ធបញ្ចកៈ ដែលជាអតីតៈជាដើម ទើបប្រកាន់យកនូវសង្សារទុក្ខ ដោយសំគាល់ថា ជាសុខហើយ ក៏ចាប់ផ្តើមនូវសង្ខារ ៣ យ៉ាង ដែលជាហេតុ នៃសង្សារទុក្ខនោះឡើង” ដូច្នេះ ជាដើមនោះឯង ។ នេះ គឺជាបរិយាយមួយផ្សេងពីនេះទៀត ថា :*

បុគ្គលណា វង្វេង ក្នុងចុតិ និង បដិសន្ធិ ក្នុង
សង្សារ និង ក្នុងលក្ខណៈ នៃសង្ខារទាំងឡាយ
និង ក្នុងបដិច្ចសមុប្បាទធម៌ទាំងឡាយ, បុគ្គល

> នោះ រមែងកសាងនូវសង្ខារទាំងឡាយ ៣ នេះ ឡើង ព្រោះហេតុដែលអវិជ្ជានេះ ជាបច្ច័យ នៃសង្ខារទាំងឡាយ ៣ នោះ ។

*បើមានពាក្យសួរថា “ក៏ព្រោះហេតុអ្វី? បុគ្គលណា វង្វេង ក្នុងធម៌ទាំងឡាយនោះ បុគ្គលនោះ ទើបឈ្មោះថា ធ្វើនូវសង្ខារទាំងបីនោះ” ដូច្នេះ ។ គប្បីឆ្លើយថា “ជាដំបូង បុគ្គលអ្នកវង្វេងក្នុងចុតិ មិនប្រកាន់យក ក្នុងចុតិថា “ការបែកធ្លាយនៃខន្ធទាំងឡាយ ក្នុងភពទាំងពួង ឈ្មោះថា មរណៈ” ដូច្នេះ តែកំណត់ទុកថា សត្វស្លាប់, សេចក្តីស្លាប់គឺកិរិយាឃ្លានទៅកាន់រាងកាយ របស់សត្វ” ដូច្នេះជាដើម ។*

*បុគ្គលអ្នកវង្វេង ក្នុងបដិសន្ធិ មិនកាន់យកនូវបដិសន្ធិ(ឧបបាត) ថា “ការប្រាកដនៃខន្ធទាំងឡាយ ក្នុងទីទាំងពួង ឈ្មោះថា ជាតិ” ដូច្នេះ តែកំណត់ថា “សត្វកើតឡើង, ការកើតឡើង គឺការប្រាកដនៃរាងកាយថ្មីនៃសត្វ” ដូច្នេះជាដើម ។*

*បុគ្គលអ្នកវង្វេង ក្នុងសង្សារ មិនកាន់យកនូវសង្សារ (ការអន្ទោលទៅមក) ដែលលោកពណ៌នា យ៉ាងនេះ ថា :*

> “លំដាប់ នៃខន្ធ, ធាតុ, និង អាយតនៈទាំងឡាយ កំពុងប្រព្រឹត្តទៅ មិនដាច់រយៈ លោកហៅថា សង្សារ” *ដូច្នេះ,*

*តែកំណត់ទុកថា “សត្វនេះ (ចេញ) ពីលោកនេះ ទៅកាន់លោកដទៃ (ចេញ) ពីលោកដទៃ មកកាន់លោកនេះ” ដូច្នេះជាដើម ។*



*បុគ្គលអ្នកវង្វេង ក្នុងលក្ខណៈនៃសង្ខារទាំងឡាយ មិនកាន់យកនូវសភាវលក្ខណៈ និង សាមញ្ញលក្ខណៈ នៃសង្ខារទាំងឡាយ តែកំណត់យកសង្ខារទាំងឡាយ ដោយថា ជាខ្លួន ថា ជារបស់ខ្លួន ថា ជារបស់ឋិតថេរ ថា ជារបស់ស្អាត និង ដោយថា ជារបស់មានសេចក្តីសុខ ។*

*បុគ្គលអ្នកវង្វេង ក្នុងបដិច្ចសមុប្បន្នធម៌ទាំងឡាយ មិនប្រកាន់នូវការប្រព្រឹត្តិទៅ នៃបដិច្ចសមុប្បន្នធម៌ទាំងឡាយមានសង្ខារជាដើម ព្រោះបច្ច័យធម៌ទាំងឡាយ មានអវិជ្ជាជាដើម តែកំណត់ទុកថា “អត្តា ដឹងខ្លះ មិនដឹងខ្លះ អត្តានោះឯង ធ្វើ (ខ្លួនឯង) ផង ប្រើអ្នកដទៃឲ្យធ្វើផង, ក្នុងបដិសន្ធិ អត្តានោះឯងកើតឡើង, អ្នកបណ្តាលមានអណុ និង អ្នកមានអំណាចជាដើម ចាត់ចែងនូវរាងកាយឲ្យដល់នូវអត្តានោះ ដោយភាពជាកលលៈជាដើម សាងឥន្ទ្រីយ៍ ឲ្យបានគ្រប់គ្រាន់, អត្តានោះ បរិបូរដោយឥន្ទ្រីយ៍ហើយ ទើបពាល់ត្រូវ ដឹង ចង់បាន ប្រកាន់មាំ ព្យាយាម, អត្តានោះ រមែងមានក្នុងភពថ្មីទៀត” ដូច្នេះខ្លះថា “សត្វទាំងឡាយទាំងពួង ប្រែប្រួលទៅតាមសភាវៈ គឺការប្រព្រឹត្តិទៅតាមជោគ និង គ្រោះ” ដូច្នេះខ្លះ ។*

*បុគ្គលនោះ គឺអវិជ្ជា ធ្វើឲ្យងងឹតងងល់ហើយ កំណត់យកយ៉ាងនោះឯង រមែងកសាងឡើង នូវសង្ខារដែលជាបុណ្យខ្លះ មិនមែនជាបុណ្យខ្លះ ជាអនេញ្ជខ្លះ ប្រៀបដូចជាមនុស្សខ្វាក់ កាលត្រាច់ទៅលើផែនដី ក៏តែងតែដើរត្រូវផ្លូវខ្លះ ខុសផ្លូវខ្លះ កាន់ទីទួលខ្លះ ទីទាបខ្លះ ទីរាបស្មើខ្លះ ទីមិនរាបស្មើខ្លះ យ៉ាងដូច្នោះឯង ។*

*ព្រោះហេតុនោះ ទើបលោកពោលពាក្យនេះ ថា :*

> បុគ្គលពាល ត្រាច់ទៅក្នុងសង្សារវដ្ដ មិនមានអ្នកដឹក

នាំ ពេលខ្លះ ធ្វើបុណ្យ ពេលខ្លះ ធ្វើកម្មមិនមែនជាបុណ្យ ប្រៀបដូចជាមនុស្សខ្វាក់អំពីកំណើត មិនមានអ្នកដឹកដៃ (អ្នកនាំផ្លូវ) ពេលខ្លះ ក៏ដើរទៅតាមផ្លូវ ពេលខ្លះ ក៏ដើរទៅក្រៅផ្លូវ (ដើរខុសផ្លូវ) យ៉ាងដូច្នោះឯង, ក៏ពេលណា បុគ្គលនោះ នឹងដឹងធម៌ហើយ ត្រាស់ដឹងនូវសច្ចៈទាំងឡាយ, ពេលនោះ បុគ្គលនោះ នឹងជាអ្នកស្ងប់រម្ងាប់ ត្រាច់ទៅព្រោះស្ងប់រម្ងាប់អវិជ្ជា” ។

*នេះ ជាវិត្ថារកថាមុខ ក្នុងបទថា* “អវិជ្ជាបច្ចយា សង្ខារា” ។

(វែកបទសង្ខារប្បច្ចយា វិញ្ញាណំ)

*(៣៨៧) វិត្ថារកថា ក្នុងបទថា* “វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ” *(ដូចតទៅនេះ)* ។

*ពាក្យថា* “វិញ្ញាណ” *បានដល់ វិញ្ញាណ៦ មានចក្ខុវិញ្ញាណជាដើម ។ បណ្តាវិញ្ញាណទាំង ៦ នោះ ចក្ខុវិញ្ញាណ មាន ២ យ៉ាង គឺចក្ខុវិញ្ញាណជាកុសលវិបាក ១ ជាអកុសលវិបាក ១ ។ សោតវិញ្ញាណ, ឃានវិញ្ញាណ, ជិវ្ហាវិញ្ញាណ និង កាយវិញ្ញាណ ក៏យ៉ាងដូច្នោះដែរ ។ មនោវិញ្ញាណ មាន ២២ គឺ មនោធាតុ ២ ជាកុសលវិបាក និង អកុសលវិបាក, មនោវិញ្ញាណធាតុ ជាអហេតុកៈ ៣ កាមាវចរវិបាកចិត្ត ជាសហេតុកៈ ៨, រូបាវចរចិត្ត ៥, អរូបាវចរចិត្ត ៤ ។ វិបាកវិញ្ញាណដែលជាលោកិយៈ ទាំងអស់ ៣២ គឺលោកសង្គ្រោះចូលហើយ ដោយវិញ្ញាណទាំង ៦ នេះ ដោយប្រការដូច្នេះឯង ។ ចំណែកវិញ្ញាណដែល*



*ជាលោកុត្តរៈទាំងឡាយ មិនគួរ ក្នុងវដ្តកថាទេ ព្រោះហេតុនោះ ទើបលោកមិនបានកំណត់យកហើយ ។*

*ក្នុងបទថា* “វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ” *នោះ ទើបមានពាក្យសួរថាៈ ពាក្យនេះ គប្បីដឹងបាន យ៉ាងដូចម្តេចថា “វិញ្ញាណមានប្រការដូចបានពោលហើយនេះ កើតមាន ព្រោះសង្ខារជាបច្ច័យ” ដូច្នេះ ។ ឆ្លើយថា “គប្បីដឹងបាន ព្រោះកាលបើកម្មដែលខ្លួនបានសន្សំហើយ មិនមាន វិបាក ក៏មិនមាន ។ មែនពិត វិញ្ញាណនោះ ជាវិបាក, វិបាកនោះ កាលបើកម្មដែលខ្លួនសន្សំ មិនមាន ក៏មិនកើតឡើងដែរ, បើវិបាក គប្បីកើតឡើង (ដោយមិនបានអាស្រ័យកម្ម) វិបាកវិញ្ញាណគ្រប់យ៉ាង គប្បីកើតឡើង ដល់សត្វទាំងពួង តែវាមិនកើតឡើងឡើយ” ដូច្នេះ ព្រោះហេតុនោះ ពាក្យថា “វិញ្ញាណនេះ កើតមាន ព្រោះមានសង្ខារ ជាបច្ច័យ” បណ្ឌិតគប្បីជ្រាប យ៉ាងនេះចុះ ។*

*បើមានពាក្យសួរថា “វិញ្ញាណ មួយណា កើតមាន ព្រោះសង្ខារមួយណាជាបច្ច័យ?” ដូច្នេះ ។ គប្បីឆ្លើយថា “ជាដំបូង វិញ្ញាណ ១៦ គឺ វិញ្ញាណទាំងឡាយមានចក្ខុវិញ្ញាណជាដើម ដែលជាកុសលវិបាក ៥, ក្នុងមនោវិញ្ញាណ មនោធាតុ ១, មនោវិញ្ញាណធាតុ ២, កាមាវចរវិបាកវិញ្ញាណ ៨ កើតមាន ព្រោះបុញ្ញាភិសង្ខារ ដែលជាកាមាវចរ ជាបច្ច័យ ។ សមដូចជាព្រះមានព្រះភាគ ត្រាស់ថា “ព្រោះកម្ម [១] ដែលជាកាមាវចរកុសល ដែលបុគ្គលបានធ្វើហើយ បានសន្សំហើយ ចក្ខុវិញ្ញាណ ដែលជាវិបាក ទើបកើតឡើងហើយ, សោតវិញ្ញាណ...ឃានវិញ្ញាណ.. .ជិវ្ហាវិញ្ញាណ... កាយវិញ្ញាណ ដែលជាវិបាក*

*១- អភិ. សំ ភាគទី ៧៨ ទំព័រទី ២៥៩ ។*

កើតឡើងហើយ ព្រោះកម្មដែលជាកាមាវចរកុសល គឺបុគ្គលបានធ្វើហើយ បានសន្សំហើយ, មនោធាតុ ដែលជាវិបាក កើតឡើងហើយ, មនោវិញ្ញាណធាតុ ដែលច្រឡំដោយសោមនស្ស កើតឡើងហើយ, មនោវិញ្ញាណធាតុ ដែលច្រឡំដោយឧបេក្ខា កើតឡើងហើយ ។ល។ ដែលច្រឡំដោយសោមនស្ស ប្រកបដោយញាណ ។ល។ ដែលច្រឡំដោយសោមនស្ស ប្រកបដោយញាណ ប្រកបដោយសង្ខារ ។ល។ ដែលច្រឡំដោយសោមនស្ស ប្រាសចាកញាណ ។ល។ ដែលច្រឡំដោយសោមនស្សប្រាសចាកញាណ ប្រកបដោយសង្ខារ ។ល។ ដែលច្រឡំដោយឧបេក្ខា ប្រកបដោយញាណ ។ល។ ដែលច្រឡំដោយឧបេក្ខា ប្រកបដោយញាណ ប្រកបដោយសង្ខារ ។ល។ ដែលច្រឡំដោយឧបេក្ខា ប្រាសចាកញាណ ។ល។ ដែលច្រឡំដោយឧបេក្ខា ប្រាសចាកញាណ ប្រកបដោយសង្ខារ កើតឡើងហើយ” ដូច្នេះ ។

ចំណែករូបាវចរវិបាកញាណ ៥ កើតមាន ព្រោះបុញ្ញាភិសង្ខារដែលជារូបាវចរជាបច្ច័យ ។ សមដូចព្រះមានព្រះភាគត្រាស់ថា “ព្រោះកម្មដែលជារូបាវចរកុសលនោះឯង គឺបុគ្គលបានធ្វើហើយ បានសន្សំហើយ (បុគ្គលនោះ) បានស្ងាត់ចាកកាមទាំងឡាយហើយ ។ល។ បានដល់បឋមជ្ឈាន ។ល។ បញ្ចមជ្ឈាន ដែលជាវិបាក” [១] ដូច្នេះ ។

វិញ្ញាណ ២១ កើតមាន ព្រោះបុញ្ញាភិសង្ខារ ជាបច្ច័យ យ៉ាងដូច្នេះឯង ។

ចំណែកវិញ្ញាណ ៧ យ៉ាងដូច្នេះ គឺៈ វិញ្ញាណ មានចក្ខុវិញ្ញាណជាដើម ដែលជាអកុសលវិបាក ៥, មនោធាតុ ១, មនោវិញ្ញាណធាតុ ១

១- អភិ. សំ. ភាគទី ៧៨ ទំព័រទី ២៦០ ។



កើតមាន ព្រោះអបុញ្ញាភិសង្ខារជាបច្ច័យ ។ សមដូចព្រះមានព្រះភាគត្រាស់ថា “ព្រោះកម្មដែលជាអកុសល គឺបុគ្គលបានធ្វើហើយ បានសន្សំហើយ ចក្ខុវិញ្ញាណដែលជាវិបាក កើតឡើងហើយ, សោតវិញ្ញាណ... ឃានវិញ្ញាណ....ជិវ្ហាវិញ្ញាណ....កាយវិញ្ញាណ ដែលជាវិបាក កើតឡើងហើយ, មនោធាតុ ដែលជាវិបាក... មនោវិញ្ញាណធាតុ ដែលជាវិបាក កើតឡើងហើយ” ដូច្នេះ ។

ចំណែកវិញ្ញាណ ៤ យ៉ាងនេះ គឺ វិញ្ញាណដែលជាអរូបវិបាក ៤ កើតមាន ព្រោះអនេញ្ជាភិសង្ខារជាបច្ច័យ ។ សមដូចព្រះមានព្រះភាគត្រាស់ថា “ព្រោះកម្មដែលជាអរូបាវចរកុសលនោះឯង គឺបុគ្គលបានធ្វើហើយ បានសន្សំហើយ ព្រោះកន្លងបង់នូវរូបសញ្ញាទាំងឡាយ ដោយប្រការទាំងពួង លះបង់នូវសុខ និង ទុក្ខ ហើយចូលដល់ចតុត្ថជ្ឈាន មានវិញ្ញាណជាវិបាក ប្រកបដោយអាកាសានញ្ចាយតនសញ្ញា ប្រកបដោយវិញ្ញាណញ្ចាយតនសញ្ញា ប្រកបដោយអកិញ្ចញ្ញាយតនសញ្ញា និង នេវសញ្ញានាសញ្ញាយតនសញ្ញា” ដូច្នេះ ។

**(ការប្រព្រឹត្តិទៅនៃវិញ្ញាណ)**

វិញ្ញាណ ឯណា កើតមាន ព្រោះសង្ខារណាជាបច្ច័យ, ឥឡូវនេះ បុគ្គល ជ្រាបវិញ្ញាណនោះ យ៉ាងដូច្នេះហើយ គប្បីជ្រាបការប្រព្រឹត្តិទៅនៃវិញ្ញាណនោះ យ៉ាងនេះ ។

ក៏វិញ្ញាណទាំងអស់នេះឯង រមែងប្រព្រឹត្តទៅ ដោយចំណែក ២ ដោយអំណាចនៃការប្រព្រឹត្តិទៅ និង បដិសន្ធិ ។ ក្នុងចំណែកពីរយ៉ាងនោះ វិញ្ញាណ ១៣ នេះ គឺៈ បញ្ចវិញ្ញាណ ២, មនោធាតុ ២, មនោ-វិញ្ញាណធាតុ ដែលជាអហេតុកៈ ដែលប្រកបដោយសោមនស្ស រមែង

ប្រព្រឹត្តទៅ ក្នុងប្រវត្តិកាល ក្នុងបញ្ចវោការភពតែប៉ុណ្ណោះ ។ វិញ្ញាណដ៏សេស ១៩ រមែងប្រព្រឹត្តទៅ ក្នុងប្រវត្តិកាលផង ក្នុងបដិសន្ធិផង តាមសមគួរ ក្នុងភពទាំង ៣ ។

សួរថា “ តើប្រព្រឹត្តទៅ យ៉ាងដូចម្ដេច ? ” ។

ឆ្លើយថា : ក្នុងអដ្ឋកថាមជ្ឈិមនិកាយ លោកពោលថា “ជាបឋមវិញ្ញាណ ៥ មានចក្ខុវិញ្ញាណជាដើម ដែលជាកុសលវិបាក ប្រារព្ធនូវអារម្មណ៍មានរូបជាដើម ដែលមកកាន់វង្វង់នៃទ្វារ មានចក្ខុជាដើម នៃបុគ្គលអ្នកកើតហើយ ដោយកុសលវិបាក ឬ អកុសលវិបាក មានឥន្ទ្រីយ៍ចូលដល់ភាពចាស់ក្លាហើយដោយលំដាប់ ដែលជាឥដ្ឋារម្មណ៍ក្ដី ជាឥដ្ឋមជ្ឈត្តារម្មណ៍ ក្ដី ហើយអាស្រ័យប្រសាទ មានចក្ខុប្រសាទ ជាដើម ញុំាងកិច្ច គឺការឃើញ, ការបានស្ដាប់, ការហិត និង ការក្រេបឲ្យសម្រេច ទើបប្រព្រឹត្តទៅ ។ វិញ្ញាណ ៥ ដែលជាអកុសលវិបាក ក៏យ៉ាងដូច្នោះដែរ ។ តែអារម្មណ៍របស់អកុសលវិបាកវិញ្ញាណ ទាំង ៥ នោះ ជាអនិដ្ឋារម្មណ៍ ឬ អនិដ្ឋមជ្ឈត្តារម្មណ៍ទាំងអស់ ។ នេះឯង ជាសេចក្ដីដែលប្លែកគ្នា ។

មែនពិត វិញ្ញាណទាំងឡាយ ១០ នោះ មានទ្វារ, អារម្មណ៍, វត្ថុ និង ឋានៈ ទៀងទាត់ និង មានកិច្ចទៀងទាត់ ប៉ុណ្ណោះឯង ។ បន្ទាប់ពីនោះមក មនោធាតុ ដែលជាកុសលវិបាក ក្នុងលំដាប់នៃវិញ្ញាណទាំងឡាយ មានចក្ខុវិញ្ញាណជាដើមដែលជាកុសលវិបាក ប្រារព្ធនូវអារម្មណ៍នៃវិញ្ញាណទាំងឡាយនោះឯង អាស្រ័យនូវហទយវត្ថុហើយ ញុំាងសម្បដិច្ឆនកិច្ច ឲ្យសម្រេចទើបប្រព្រឹត្តទៅ ។ មនោធាតុ ដែលជាអកុសលវិបាក ក្នុងលំដាប់ នៃអកុសលវិបាកវិញ្ញាណទាំងឡាយ ក៏



ប្រព្រឹត្តទៅ យ៉ាងដូច្នោះដែរ ។ តែមនោធាតុ ១ គូ នេះ មានទ្វារ និង អារម្មណ៍មិនទៀងទាត់ទេ តែមានវត្ថុ និង ឋានៈទៀងទាត់ និង មានកិច្ចក៏ទៀងទាត់ដែរ ។ ចំណែកអហេតុកមនោវិញ្ញាណធាតុ ដែលប្រកបដោយសោមនស្ស ក្នុងលំដាប់នៃមនោធាតុដែលជាកុសលវិបាក ប្រារព្ធអារម្មណ៍ នៃកុសលវិបាកមនោធាតុនោះឯង អាស្រ័យហទយវត្ថុហើយ ញុំាងសន្តីរណកិច្ចឲ្យសំរេច កាត់ផ្ដាច់នូវភវង្គវិថី ក្នុងទីបំផុត នៃជវនៈ ដែលសម្បយុត្ត ដោយលោភៈ យ៉ាងច្រើន នៃសត្វដែលជាកាមាវចរទាំងឡាយ កាលបើអារម្មណ៍ទាំងនោះ ជាអារម្មណ៍មានកម្លាំង ក្នុងទ្វារទាំង ៦ ប្រព្រឹត្តទៅ អស់វារៈ ១ ដងខ្លះ អស់វារៈ ២ ដងខ្លះ ដោយអំណាចតទារម្មណ៍ ក្នុងអារម្មណ៍ដែលជវនៈកាន់យកហើយ” ដូច្នេះ ។ តែក្នុងអដ្ឋកថាអភិធម្ម វារៈចិត្ត ២ មកហើយ ក្នុងតទារម្មណ៍ ។ ក៏ចិត្តនេះ បានឈ្មោះ ២ គឺ : តទារម្មណ៍ ១, បិដ្ឋិភវង្គ (មានភវង្គអែបនៅពីក្រោយ) ១ ។ ចិត្តនេះ ជាចិត្តមានទ្វារ និង អារម្មណ៍ មិនទៀងទាត់ទេ តែមានវត្ថុទៀងទាត់ និង មានកិច្ច និង ឋានៈ មិនទៀងទាត់ ។

វិញ្ញាណទាំងឡាយ ១៣ បណ្ឌិត គប្បីជ្រាបថា “រមែងប្រព្រឹត្តទៅក្នុងប្រវត្តិកាល ក្នុងបញ្ចវោការភពប៉ុណ្ណោះ” ដូចបានពណ៌នាមកនេះជាមុនសិន ។

ក្នុងវិញ្ញាណ ១៩ ដ៏សេស វិញ្ញាណណាមួយមិនប្រព្រឹត្តទៅដោយបដិសន្ធិដែលសមគួរដល់ខ្លួន ក៏មិនមែន ។ តែក្នុងប្រវត្តិកាលជាដំបូង មនោវិញ្ញាណធាតុ ដែលជាអហេតុកៈ ២ ដែលជាកុសលវិបាក និង អកុសលវិបាក ញុំាងកិច្ចទាំងឡាយ ៤ ឲ្យសំរេច គឺញុំាងសន្តីរណកិច្ចក្នុងលំដាប់នៃមនោធាតុ ដែលជាកុសលវិបាក និង អកុសលវិបាកទាំង

ឡាយ ក្នុងបញ្ចទ្វារឲ្យសំរេច ញុំាងតទារម្មណកិច្ចក្នុងទ្វារទាំង ៦ ដោយន័យដែលបានពោល ក្នុងកាលមុននោះឯងឲ្យសំរេច, កាលបើចិត្តុប្បាទដែលចូលទៅកាត់ផ្តាច់ភវង្គមិនមាន, ញុំាងភវង្គកិច្ចខាងលើ ពីបដិសន្ធិដែលខ្ជូនឲ្យហើយឲ្យសំរេច និង ញុំាងចុតិកិច្ច ក្នុងទីបំផុត ឲ្យសំរេច ជាវិញ្ញាណធាតុ មានវត្ថុទៀងទាត់ តែមានទ្វារ, អារម្មណ៍, ឋាន: និង កិច្ច មិនទៀងទាត់ ប្រព្រឹត្តទៅ ។ សហេតុកចិត្ត ដែលជាកាមាវចរ ៨ ញុំាងកិច្ចទាំងឡាយ ៣ ឲ្យសំរេច គឺ: ញុំាងតទារម្មណកិច្ច ក្នុងទ្វារ ៦ ដោយន័យដែលបានពោលមកហើយនោះឯងឲ្យសំរេច, កាលបើចិត្តុប្បាទ ដែលចូលទៅកាត់ផ្តាច់នូវភវង្គ មិនមាន, ញុំាងភវង្គកិច្ចខាងលើពីបដិសន្ធិ ដែលខ្ជូនឲ្យហើយ ឲ្យសំរេច និង ញុំាងចុតិកិច្ច ក្នុងទីបំផុតឲ្យសំរេច ជាចិត្តមានវត្ថុទៀងទាត់ តែមានទ្វារ, អារម្មណ៍, ឋាន: និងកិច្ច មិនទៀងទាត់ប្រព្រឹត្តទៅ ។ រូបាវចរវិញ្ញាណ ៥ និង អរូបាវចរវិញ្ញាណ ៤ ញុំាងកិច្ច ២ យ៉ាង ឲ្យសំរេច គឺ: កាលបើចិត្តុប្បាទ ដែលចូលទៅកាត់ផ្តាច់ភវង្គ មិនមាន, ញុំាងភវង្គកិច្ច ព្ធដ៏ខាងលើ ពីបដិសន្ធិដែលខ្ជូនឲ្យហើយ ឲ្យសំរេច និង ញុំាងចុតិកិច្ច ក្នុងទីបំផុតឲ្យសំរេច ។ បណ្តាចិត្តទាំងពីរប្រភេទនោះ រូបាវចរចិត្តទាំងឡាយ មានវត្ថុ ទ្វារ និង អារម្មណ៍ទៀងទាត់ តែមានឋាន: និង កិច្ច មិនទៀងទាត់ តែអរូបាវចរ-ចិត្តទាំងឡាយក្រៅពីនេះ ជាចិត្តមានវត្ថុទៀងទាត់ មានអារម្មណ៍ទៀងទាត់ តែមានឋាន: និង កិច្ច មិនទៀងទាត់ ប្រព្រឹត្តទៅ ដោយប្រការដូច្នេះឯង ។

វិញ្ញាណទាំង ៣២ យ៉ាង រមែងប្រព្រឹត្តទៅ ក្នុងប្រវត្តិកាល ព្រោះសង្ខារជាបច្ច័យ ដូចបានពោលមកហើយ ជាបឋម ។



(៣៨៨) សង្ខារទាំងឡាយនោះៗ រមែងជាបច្ច័យ ដោយកម្មប្បច្ច័យផង ដោយឧបនិស្សយប្បច្ច័យផង នៃវិបាកវិញ្ញាណ ៣២ នោះ ក្នុងការប្រព្រឹត្តិទៅ (បវត្តិកាល) ។

ចំណែកពាក្យណាដែលខ្ញុំពោលថា “ក្នុងវិញ្ញាណ ដ៏សេសសល់ ១៩ វិញ្ញាណឯណាមួយ មិនប្រព្រឹត្តទៅ ដោយបដិសន្ធិ ដែលសមគួរដល់ខ្លួន ក៏មិនមែន” ដូច្នេះ, ពាក្យនោះ គឺដឹងបានដោយលំបាក ព្រោះជាពាក្យដែលសង្ខេបហួសពេក ព្រោះហេតុនោះ ខ្ញុំនឹងពោល ដើម្បីសំដែងនូវន័យពិស្តារ នៃបដិសន្ធិវិញ្ញាណនោះ (ដូចមានបញ្ហាកម្ម) ថា :

(១) បដិសន្ធិ មានប៉ុន្មានយ៉ាង ?,

(២) បដិសន្ធិចិត្ត មានប៉ុន្មានយ៉ាង ?,

(៣) បដិសន្ធិ តែងមាន ក្នុងភពណា ដោយចិត្តអ្វី ?,

(៤) អ្វីជាអារម្មណ៍នៃបដិសន្ធិ ?” ។

( មានពាក្យឆ្លើយថា )

(១) បដិសន្ធិ មាន ២០ ព្រមទាំងបដិសន្ធិ នៃអសញ្ញីសត្វ (គឺ បដិសន្ធិចិត្ត មានតែ ១៩ ប៉ុន្តែរាប់បដិសន្ធិ របស់ពួកអសញ្ញីសត្វ ចូលផង ទើបត្រូវជា ២០),

(២) បដិសន្ធិចិត្ត មាន ១៩ ដូចបានពោលមកហើយហ្នឹងឯង,

(៣) ក្នុងបដិសន្ធិ ទាំង ១៩ នោះ បដិសន្ធិ ក្នុងអបាយទាំងឡាយ រមែងមាន ដោយអហេតុកមនោវិញ្ញាណធាតុ ដែលជាអកុសលវិបាក, បដិសន្ធិ នៃមនុស្សខ្វាក់អំពីកំណើត, មនុស្សថ្លង់ពីកំណើត, មនុស្សឆ្កួតអំពីកំណើត, មនុស្សគពីកំណើត និង មនុស្សខ្ទើយទាំងឡាយជាដើម ក្នុងមនុស្សលោក រមែងមាន ដោយអហេតុកមនោវិញ្ញាណធាតុ ដែល

ជាកុសលវិបាក, បដិសន្ធិនៃពួកបុគ្គលអ្នកមានប្រាជ្ញា ក្នុងពួកទេវតាជាន់កាមាវចរក្ដី ក្នុងពួកមនុស្សក្ដី រមែងមាន ដោយសហេតុកាមាវចរវិបាកចិត្ត ៨, បដិសន្ធិ ក្នុងព្រហ្មលោកដែលមានរូប រមែងមាន ដោយរូបាវចរវិបាកចិត្ត ៥, បដិសន្ធិ ក្នុងព្រហ្មលោក ដែលមិនមានរូប រមែងមាន ដោយអរូបាវចរវិបាកចិត្ត ៤, ក៏បដិសន្ធិ រមែងមាន ក្នុងភពណា ដោយចិត្តឯណា ដូចពណ៌នាមកនេះ, បដិសន្ធិនោះឯង ឈ្មោះថា បដិសន្ធិដែលសមគួរដល់វិញ្ញាណនោះ,

(៤) ចំណែកអារម្មណ៍ នៃបដិសន្ធិ ដោយសង្ខេប មាន ៣ គឺ : អតីតារម្មណ៍ បច្ចុប្បន្នារម្មណ៍ និង អារម្មណ៍ដែលមិនគួរពោលថាជាអតីត ឬ បច្ចុប្បន្ន តែបដិសន្ធិ នៃអសញ្ញីសត្វ ជាអារម្មណ៍ គឺ មិនមានអារម្មណ៍ ។

ក្នុងអារម្មណ៍ទាំង ៣ នោះ អារម្មណ៍របស់បដិសន្ធិ នៃសត្វជាន់វិញ្ញាណញ្ចាយតនៈ និង នេវសញ្ញានាសញ្ញាយតនៈ ជាអតីតារម្មណ៍តែម្យ៉ាង នៃពួកសត្វជាន់កាមាវចរ ១០ ជាអតីតារម្មណ៍ខ្លះ ជាបច្ចុប្បន្នារម្មណ៍ខ្លះ នៃពួកសត្វដ៏សេស ជានវត្តព្វារម្មណ៍មែនពិត ។

ម្យ៉ាងទៀត បដិសន្ធិ ដែលកំពុងប្រព្រឹត្តទៅ ក្នុងអារម្មណ៍ទាំង ៣ យ៉ាងនេះ រមែងប្រព្រឹត្តទៅ ក្នុងលំដាប់នៃចុតិចិត្ត ដែលមានអារម្មណ៍ជាអតីតខ្លះ ជានវត្តព្វារម្មណ៍ខ្លះតែប៉ុណ្ណោះ ព្រោះធម្មតា ចុតិចិត្ត ជាបច្ចុប្បន្នារម្មណ៍ មិនមានទេ ព្រោះហេតុណា, ព្រោះហេតុនោះ បណ្ឌិតគប្បីជ្រាបអាការៈ ដែលប្រព្រឹត្តទៅ នៃបដិសន្ធិ ដែលមានអារម្មណ៍ណាមួយ បណ្ដាអារម្មណ៍ទាំង ៣ ក្នុងលំដាប់នៃចុតិ ដែលមានអារម្មណ៍ណាមួយ បណ្ដាអារម្មណ៍ទាំង ២ ដោយអំណាចនៃសុគតិ និង ទុគ្គតិ ។



ដំណើរនេះ តើយ៉ាងដូចម្ដេចទៅ ? ។

ជាបឋម បាបកម្ម តាមដែលខ្លួនបានសន្សំហើយក្ដី កម្មនិមិត្តក្ដី រមែងមកកាន់គន្លង ក្នុងមនោទ្វារ នៃបុគ្គលអ្នកឋិតនៅ ក្នុងសុគតិ ជាន់កាមាវចរ ប៉ុន្តែជាបុគ្គលមានបាបកម្ម ជាអ្នកដេកនៅលើគ្រែមរណៈ ដោយបាលីថា “កម្មទាំងឡាយរមែងតោងជាប់(ក្នុងចិត្ត) នៃបុគ្គលនោះ” ដូច្នេះជាដើម ។ ចុតិចិត្ត ធ្វើអារម្មណ៍នៃភវង្គ ឲ្យជាអារម្មណ៍កើតឡើង ក្នុងលំដាប់នៃជវនវិថី ដែលប្រារព្ធនូវកម្ម ឬ កម្មនិមិត្តនោះ កើតឡើង មានតទារម្មណ៍ជាទីបំផុត ។ កាលបើចុតិចិត្តនោះ រលត់ទៅហើយ, បដិសន្ធិចិត្ត ដែលកម្លាំងនៃកិលេស ដែលខ្លួនកាត់ផ្ដាច់ពុំទាន់បាន ដឹកនាំហើយ ទាញទំលាក់ចូលទៅ ក្នុងទុគ្គតិ ក៏ប្រារព្ធកម្ម ឬ កម្មនិមិត្ត ដែលមកកាន់គន្លងនោះឯង កើតឡើង ។ នេះ ជាបដិសន្ធិ ដែលមានអារម្មណ៍ជាអតីត ក្នុងលំដាប់នៃចុតិដែលមានអារម្មណ៍ជាអតីត ។

ក្នុងមរណសម័យ ទុគ្គតិនិមិត្ត ដែលមានពណ៌នៃអណ្ដាតភ្លើង ជាដើម ក្នុងទុគ្គតិទាំងឡាយ មាននរកជាអាទិ៍ រមែងមកកាន់គន្លង ក្នុងមនោទ្វារ នៃបុគ្គលអ្នកមានបាបកម្មដទៃទៀត ដោយអំណាច នៃកម្មមានប្រការដូចពោលមកហើយ, កាលបើភវង្គចិត្ត កើតឡើងហើយរលត់ទៅវិញ អស់វារៈពីរដង, វិថីចិត្ត ៣ គឺ អាវជ្ជនៈ ១ ជវនៈ ៥ ព្រោះជាចិត្តមានកម្លាំងខ្សោយ ព្រោះមានមរណៈ ចូលមកដល់ជិត តទារម្មណ៍ ២ ប្រារព្ធនូវអារម្មណ៍នោះ កើតឡើង ដល់បុគ្គលនោះ, តអំពីនោះមក ចុតិចិត្តមួយ ធ្វើអារម្មណ៍នៃភវង្គ ឲ្យជាអារម្មណ៍ កើតឡើង ។ ខណចិត្ត ១១ (បានដល់ភវង្គ ២, អាវជ្ជនៈ ១, ជវនៈ ៥, តទារម្មណ៍ ២, ចុតិ ១) មានប្រមាណប៉ុណ្ណោះ ចាត់ជាអតីត ។ លំដាប់

នោះ បដិសន្ធិចិត្ត រមែងកើតឡើងដល់បុគ្គលនោះ ក្នុងអារម្មណ៍នោះឯង ដែលមានអាយុត្រឹមតែ ៥ ខណចិត្តដ៏សេស ។ នេះ ជាបដិសន្ធិមានអារម្មណ៍ជាបច្ចុប្បន្ន ក្នុងលំដាប់នៃចុតិដែលជាអតីតារម្មណ៍ ។

ក្នុងមរណសម័យ អារម្មណ៍ដ៏អាក្រក់ ដែលជាហេតុនៃកិលេសមានរាគៈជាដើម មកកាន់គន្លងក្នុងទ្វារណាមួយ បណ្ដាទ្វារទាំង៥ របស់បុគ្គលម្នាក់ទៀត ។ ជវនៈ ៥ ព្រោះជាចិត្តដែលមានកម្លាំងទន់ខ្សោយដោយភាពដែលមានមរណៈចូលមកជិត និង តទារម្មណៈ ២ រមែងកើតឡើងក្នុងទីបំផុត នៃវោដ្ឋព្វនៈដែលកើតឡើង តាមលំដាប់ ដល់បុគ្គលនោះ, បន្ទាប់អំពីនោះមក ចុតិចិត្តមួយដួង ធ្វើអារម្មណ៍នៃភវង្គ ឲ្យជាអារម្មណ៍ហើយ កើតឡើង ។ ក៏ខណៈចិត្ត ១៥ គឺភវង្គ ២, អាវជ្ជនៈ ១, ទស្សនៈ ១, សម្បដិច្ឆនៈ ១, សន្តីរណៈ ១, វោដ្ឋព្វនៈ ១, ជវនៈ ៥, តទារម្មណ៍ ២, ចុតិចិត្ត ១ មានប្រមាណប៉ុណ្ណោះជាអតីត ។ លំដាប់នោះ បដិសន្ធិចិត្ត រមែងកើតឡើងក្នុងអារម្មណ៍នោះឯង ដែលមានអាយុត្រឹមតែមួយខណៈចិត្តដ៏សេស ។ សូម្បីបដិសន្ធិនេះ ក៏ជាបដិសន្ធិដែលមានអារម្មណ៍ជាបច្ចុប្បន្ន ក្នុងលំដាប់នៃចុតិដែលមានអារម្មណ៍ជាអតីត ។

នេះ គឺជាអាការៈដែលប្រព្រឹត្តទៅ នៃទុគ្គតិបដិសន្ធិ ដែលមានអារម្មណ៍ជាអតីតខ្លះ ជាបច្ចុប្បន្នខ្លះ ក្នុងលំដាប់នៃចុតិជាសុគតិ ដែលមានអារម្មណ៍ជាអតីត ប៉ុណ្ណោះសិនចុះ ។

សម្រាប់បុគ្គលដែលឋិតនៅក្នុងទុគ្គតិ មានកម្មដែលមិនមានទោសគឺខ្លួនសន្សំទុកហើយ ពាក្យទាំងអស់ បណ្ឌិត គប្បីជ្រាប តាមន័យមានខាងដើមហ្នឹងឯង ព្រោះដាក់ពាក្យដែលជាចំណែកខាង-ស (បញ្ចូលទៅ) ក្នុងពាក្យដែលជាចំណែកខាងខ្មៅ ថា "កម្មដែលមិនមានទោសក្តី កម្ម-



និមិត្តក្តី រមែងមកកាន់គន្លង ក្នុងមនោទ្វារ" ដូច្នេះជាដើម តាមន័យដែលបានពោលមកហើយហ្នឹងឯង ។ នេះជាអាការៈដែលប្រព្រឹត្តទៅនៃសុគតិបដិសន្ធិ ដែលមានអារម្មណ៍ជាអតីតខ្លះ បច្ចុប្បន្នខ្លះ ក្នុងលំដាប់នៃចុតិជាទុគ្គតិ ដែលមានអារម្មណ៍ជាអតីត ។

ចំណែកបុគ្គលអ្នកឋិតនៅក្នុងសុគតិ មានកម្មដែលមិនមានទោសដែលខ្លួនបានសន្សំហើយ ដេកនៅលើគ្រែមរណៈ កម្មដែលមិនមានទោស តាមដែលខ្លួនបានសន្សំហើយក្តី កម្មនិមិត្តក្តី រមែងមកកាន់គន្លងក្នុងមនោទ្វារ ព្រោះបាលីថា "ក្នុងសម័យនោះ កម្មដែលមិនមានទោសទាំងឡាយនោះ រមែងតោងជាប់(ក្នុងចិត្ត) នៃបុគ្គលនោះ" ដូច្នេះជាដើម ប៉ុន្តែអនន្តរិយកម្ម ឬកម្មនិមិត្ត នឹងមកកាន់គន្លងក្នុងមនោទ្វារនោះ ចំពោះតែបុគ្គលអ្នកសន្សំអនន្តរិយកម្ម ផ្នែកកាមាវចរប៉ុណ្ណោះឯង ។ ចំណែកបុគ្គលអ្នកសន្សំមហគ្គតកម្ម មានតែកម្មនិមិត្តម្យ៉ាង មកកាន់គន្លង (ក្នុងមនោទ្វារ), ចុតិចិត្ត ធ្វើអារម្មណ៍នៃភវង្គឲ្យជាអារម្មណ៍ហើយ កើតឡើងក្នុងលំដាប់នៃជវនវិថី មានតទារម្មណ៍ជាទីបំផុត ឬ ជវនវិថីសុទ្ធសាធដែលប្រារព្ធនូវកម្ម ឬ កម្មនិមិត្តនោះ កើតឡើង ។ កាលបើចុតិចិត្តនោះរលត់ទៅហើយ, បដិសន្ធិចិត្ត ដែលកម្លាំងនៃកិលេស គឺខ្លួនពុំទាន់បានកាត់ផ្តាច់នៅឡើយ ដឹកនាំ ហើយចូលទៅកាន់សុគតិ ក៏ប្រារព្ធកម្ម ឬ កម្មនិមិត្ត ដែលមកកាន់វង្វង់ (ក្នុងមនោទ្វារ)នោះឯង កើតឡើង ។ នេះគឺជាបដិសន្ធិ ជាអតីតារម្មណ៍ខ្លះ ជានវត្តព្វារម្មណ៍ខ្លះ (កើតឡើង) ក្នុងលំដាប់នៃចុតិ ដែលជាអតីតារម្មណ៍ ។

បុគ្គលអ្នកមានអនន្តរិយកម្ម បានសន្សំទុកហើយ ដទៃទៀត ក្នុងមរណសម័យ មានសុគតិនិមិត្ត ពោលគឺវណ្ណរូប នៃផ្ទៃរបស់មាតា ក្នុង

មនុស្សលោកខ្លះ ពោលគឺវណ្ណរូបនៃឧទ្យាន វិមាន និង ដើមកល្បព្រឹក្សជាដើម ក្នុងទេវលោកខ្លះ មកកាន់វង្វង់ ក្នុងមនោទ្វារ ដោយអំណាចនៃអនវជ្ជកម្ម ដែលជាកាមាវចរ ។ បដិសន្ធិចិត្ត រមែងកើតឡើង ដល់បុគ្គលនោះ ក្នុងលំដាប់នៃចុតិចិត្ត តាមលំដាប់ដែលបានសំដែងមកហើយ ក្នុងទុគ្គតិនិមិត្តហ្នឹងឯង ។ នេះ ជាបដិសន្ធិ ដែលមានអារម្មណ៍ជាបច្ចុប្បន្ន ក្នុងលំដាប់នៃចុតិ ដែលជាអតីតារម្មណ៍ ។

ក្នុងសម័យជាទីស្លាប់នៃសត្វដទៃទៀត ពួកញាតិនិយាយថា “នែអ្នក! ពុទ្ធបូជានេះ គឺយើងធ្វើ ដើម្បីប្រយោជន៍ ដល់អ្នក, អ្នកចូរតាំងចិត្ត ឲ្យជ្រះថ្លាចុះ” និយាយនូវរូបារម្មណ៍ ដោយអំណាចនៃវត្ថុមានកម្រងនៃផ្កា និង ទង់ជាយ និង ទង់ជ្រុងជាដើមផង នូវសទ្ទារម្មណ៍ ដោយអំណាចនៃបុញ្ញកម្ម មានការស្តាប់នូវធម៌ និង ការបូជាដោយគ្រឿងតូរ្យតន្ត្រីជាដើមផង នូវគន្ធារម្មណ៍ ដោយអំណាចនៃសក្ការៈ មានធូប និង គ្រឿងអប់ និង គ្រឿងក្រអូបជាដើមផង និយាយនូវរសារម្មណ៍ ដោយអំណាចនៃវត្ថុមានទឹកឃ្មុំ និង ស្ករអំពៅជាដើមថា “នែអ្នក! អ្នកចូរភ្លក្ស នូវវត្ថុនេះចុះ, ទេយ្យធម៌នេះ យើងគប្បីឲ្យ ដល់អ្នកហើយផង, នាំចូលទៅជិត ក្នុងបញ្ចទ្វារ នូវផោដ្ឋព្វារម្មណ៍ ដោយអំណាចនៃវត្ថុមានសំពត់ដែលគេនាំមកអំពីប្រទេសចិន និង សំពត់ដែលគេធ្វើអំពីសំបកឈើជាដើម ព្រោះពោលថា : នែអ្នក! អ្នកចូរពាល់នូវវត្ថុនេះ គឺយើងគប្បីឲ្យនូវទេយ្យធម៌ ដើម្បីប្រយោជន៍ដល់អ្នក ។ កាលអារម្មណ៍ មានរូបារម្មណ៍ជាដើមនោះ មកហើយ កាន់វង្វង់នៃសត្វនោះ ជវនៈទាំងឡាយ ៥ ក្តី តទារម្មណ៍ទាំងឡាយ ២ ក្តី រមែងកើតឡើងបាន ព្រោះភាពនៃជវនៈ និង តទារម្មណ៍ ជាធម្មជាត មានកម្លាំង ដ៏ទន់ខ្សោយ ដោយភាព



នៃសត្វមានសេចក្តីស្លាប់នៅកៀក ក្នុងទីបំផុតនៃការកំណត់ នៃអារម្មណ៍ដែលកើតឡើងហើយ តាមលំដាប់ យ៉ាងណា, តពីនោះមក ចុតិចិត្ត ១ ធ្វើនូវអារម្មណ៍ក្នុងភវង្គ ឲ្យជាអារម្មណ៍ រូបកើតឡើង, បដិសន្ធិចិត្ត កើតឡើង ក្នុងអារម្មណ៍ដែលស្ថិតនៅអស់ខណៈនៃចិត្ត ១ នោះ ក្នុងទីបំផុតនៃអារម្មណ៍នោះ ។ បដិសន្ធិនេះឯង ជាបដិសន្ធិមានអារម្មណ៍ជាបច្ចុប្បន្ន ក្នុងលំដាប់នៃចុតិ មានអារម្មណ៍ជាអតីត ។

(៣៨៩) ក៏បណ្តាកាមាវចរកុសលកម្ម និង កម្មនិមិត្ត និង គតិនិមិត្តទាំងឡាយ កម្មណាមួយក្តី និមិត្ត នៃកសិណ មានបឋវីកសិណជាដើមក្តី មហគ្គតចិត្តក្តី ក្នុងសម័យជាទីស្លាប់ រមែងមកកាន់វង្វង់ ក្នុងមនោទ្វារនៃសត្វដទៃ ដែលមានមហគ្គតចិត្ត ដែលខ្លួនបានចំពោះហើយ ដោយអំណាចនៃឈាន មានបឋវីកសិណជាដើម ដែលស្ថិតនៅហើយ ក្នុងសុគតិកព, អារម្មណ៍ដ៏ប្រណីត ដែលជាហេតុកើតឡើង នៃកុសលក្នុងបណ្តាចក្ខុទ្វារ និង សោតទ្វារទាំងឡាយ ទ្វារណាមួយ រមែងមកកាន់វង្វង់ ។ ជវនៈទាំងឡាយ ៥ រមែងកើតឡើងដល់បុគ្គលនោះ ក្នុងទីបំផុតនៃការកត់ត្រា ដែលកើតឡើងហើយ តាមលំដាប់ ព្រោះភាពនៃកិលេសមានកម្លាំងខ្សោយ ដោយភាពនៃសេចក្តីស្លាប់ មានក្នុងទីជិត ។ ព្រោះតទារម្មណ៍ មិនមាន ដល់ពពួកសត្វប្រកបដោយគតិជាមហគ្គតចិត្ត ព្រោះហេតុនោះ ចុតិចិត្តមួយកើតឡើង ធ្វើនូវអារម្មណ៍នៃភវង្គ ឲ្យជាអារម្មណ៍ ក្នុងលំដាប់នៃជវនៃ ។ ដិសន្ធិចិត្ត ដែលរាប់បញ្ចូលហើយក្នុងបណ្តាសុគតិទាំងឡាយ ជាកាមាវចរ និង ជាមហគ្គតសុគតិ ណាមួយ មានបណ្តាអារម្មណ៍ទាំងឡាយ ដែលប្រាកដហើយយ៉ាងណា អារម្មណ៍ណាមួយ រមែងកើតឡើង ក្នុងទីបំផុត នៃចុតិចិត្តនោះ ។ បដិសន្ធិនេះ

ជាបដិសន្ធិមានបណ្តាអតីតារម្មណ៍, បច្ចុប្បន្នារម្មណ៍ និង នវត្តព្វារម្មណ៍ទាំងឡាយ អារម្មណ៍ណាមួយ ក្នុងចន្លោះ នៃចុតិជាសុគតិ ជានវត្តព្វា-រម្មណ៍ ។ សូម្បីបដិសន្ធិ ក្នុងចន្លោះនៃចុតិជាអារុប្ប គឺបណ្ឌិត គប្បីជ្រាបផងចុះ តាមលំអាននេះ ។

អាការៈនេះ ជាអាការៈនៃការប្រព្រឹត្តិទៅ ក្នុងបដិសន្ធិ ជាអតីតា-រម្មណ៍ និង នវត្តព្វារម្មណ៍ និង បច្ចុប្បន្នារម្មណ៍ ក្នុងចន្លោះនៃចុតិ ជាសុគតិ ដែលជាអតីតារម្មណ៍ និង នវត្តព្វារម្មណ៍ ។

ចំណែកខាងកម្មនោះ ទោះជាកម្មនិមិត្តក្តី ទោះជាគតិនិមិត្តក្តី ក្នុងមនោទ្វារ នៃសត្វមានបាបកម្ម ដែលស្ថិតនៅហើយ ក្នុងទុគ្គតិភព តាមន័យដែលលោកពោលរួចមកហើយ ឬក៏ អារម្មណ៍ដែលពិតជាហេតុនៃការកើតឡើងនៃអកុសល រមែងមកកាន់វន្ធ ក្នុងបញ្ចទ្វារ ។ លំដាប់នោះ បដិសន្ធិចិត្ត មានបណ្តាអារម្មណ៍ទាំងឡាយនោះ អារម្មណ៍ណាមួយ ដែលរាប់បញ្ចូលហើយ ក្នុងទុគ្គតិ ក្នុងទីបំផុតនៃចុតិចិត្ត ដោយតាមលំដាប់ រមែងកើតឡើងដល់សត្វនោះ ។ អាការៈនេះ ជាអាការៈនៃការប្រព្រឹត្តិទៅ នៃបដិសន្ធិជាអតីតារម្មណ៍ និង បច្ចុប្បន្នារម្មណ៍ ក្នុងចន្លោះ នៃចុតិជាទុគ្គតិ ជាអតីតារម្មណ៍ ។

(៣៩០) ការប្រព្រឹត្តិទៅ នៃវិញ្ញាណទាំង ១៩ យ៉ាង ជាគុណជាតិគឺលោកទ្រង់បំភ្លឺហើយ ដោយអំណាចនៃបដិសន្ធិ ដោយហេតុមានប្រមាណប៉ុណ្ណេះ ។ វិបាកវិញ្ញាណនោះនេះ ទាំងអស់ហ្នឹង

កាលប្រព្រឹត្តទៅ យ៉ាងដូច្នេះ ក្នុងបដិសន្ធិកាល
ប្រព្រឹត្តទៅដោយកម្ម ដោយចំណែក២, ការផ្សេង
គ្នានៃវិបាកវិញ្ញាណនោះ មានអាការៈ មានចំណែក



២ ជាដើម ដោយប្រភេទទាំងឡាយ មានប្រភេទ
ដែលលាយឡំគ្នាជាដើមផង ដោយប្រភេទទាំង
ឡាយផង ។

មែនពិត វិបាកវិញ្ញាណ មាន ១៩ ប្រការនេះ កាលប្រព្រឹត្តទៅក្នុងបដិសន្ធិ ប្រព្រឹត្តទៅ ដោយកម្ម ២ ផ្នែក ។ ក៏ជនកកម្ម នៃវិបាកវិញ្ញាណនោះនេះ តាមសមគួរជារបស់ខ្លួន ជាបច្ច័យ ដោយកម្មប្បច្ច័យប្រព្រឹត្តទៅក្នុងខណៈផ្សេងៗផង ដោយឧបនិស្សយប្បច្ច័យផង ។ សមដូចជាពាក្យនេះ គឺអដ្ឋកថាចារ្យ ពោលហើយថា : កុសលកម្ម និងអកុសលកម្ម ជាបច្ច័យ នៃវិបាក ដោយឧបនិស្សយប្បច្ច័យ ។

ក៏ការផ្សេងគ្នា សូម្បីមាន ២ ប្រការជាដើម ដោយការផ្សេងគ្នាទាំងឡាយ មានការលាយឡំគ្នាជាដើម នៃវិបាកវិញ្ញាណនោះ កាលប្រព្រឹត្តទៅយ៉ាងនេះ គឺបណ្ឌិត គប្បីជ្រាបផងចុះ ។ សួរថា : តើវិបាក-វិញ្ញាណ ដូចម្តេចខ្លះ? ។ ឆ្លើយថា សេចក្តីថា វិបាកវិញ្ញាណនេះ សូម្បីកាលប្រព្រឹត្តទៅ ដោយចំណែក ១ ដោយចំណែកនៃបដិសន្ធិ (តែ)មាន ២ ចំណែក ផ្សេងដោយការលាយឡំជាមួយរូប និង មិនលាយឡំគ្នា, មាន ៣ ចំណែក ដោយការផ្សេងគ្នានៃកាមភព, រូបភព និង អរូបភព, មាន ៤ ចំណែក ដោយអំណាចនៃអណ្ឌជកំណើត, ជលាពុជកំណើត, សំសេទជកំណើត និង ឧបបាតិកកំណើត, មាន ៥ ចំណែក ដោយអំណាចនៃគតិ, មាន ៧ យ៉ាង ដោយអំណាចនៃវិញ្ញាណដ្ឋិតិ, មាន ៨ ចំណែក ដោយអំណាចនៃសត្តាវាស ។

ក្នុងវិញ្ញាណដែលលាយឡំគ្នា និង មិនលាយឡំគ្នានោះ

វិញ្ញាណច្រឡំគ្នា (ដោយរូប) ក្នុងវិបាកវិញ្ញាណ
ទាំងឡាយនោះ មាន ដោយចំណែក ២ ព្រោះ
ផ្សេងគ្នានៃភាវៈ, ចំណែកខាង វិញ្ញាណ ដែលជា
ភាវៈ ក្នុងវិបាកវិញ្ញាណទាំងឡាយនោះ ក៏មាន
ដោយចំណែក ២ ដែរ, ទសកៈ ២ ឬ ៣ យ៉ាង
ទាប (កើតឡើង) ជាមួយនឹងវិញ្ញាណខាងដើម ។

ត្រង់បាទនៃគាថា ថា “មិស្សំ ទ្វិធា ភាវភេទា” នោះ សេចក្តីថា មែនពិត ក្នុងវិញ្ញាណច្រឡំគ្នា (ដោយរូប) ក្នុងវិបាកវិញ្ញាណ បដិសន្ធិវិញ្ញាណនេះឯណាដែលលាយឡំដោយរូប កើតឡើងក្នុងវិបាកវិញ្ញាណនេះ វៀរចាកអរូបភពចេញ, បដិសន្ធិវិញ្ញាណនោះ មាន ២ ប្រការ គឺ : ប្រកបដោយភាវៈ ១ មិនប្រកបដោយភាវៈ ១ ព្រោះការកើតឡើង វៀរចាកភាវៈ ពោលគឺ ឥត្ថិន្ទ្រីយ៍ និង បុរិសិន្ទ្រីយ៍ ក្នុងរូបភព, ព្រោះការកើតឡើង មួយអន្លើដោយភាវៈ ក្នុងកាមភព លើកលែងតែបដិសន្ធិរបស់មនុស្សខ្វើយពីកំណើតចេញ ។

បាទនៃគាថា ថា “សភាវំ តត្ថ ច ទ្វិធា” សេចក្តីថា: ក៏បដិសន្ធិវិញ្ញាណ ប្រកបដោយភាវៈឯណា ក្នុងវិញ្ញាណនោះ បដិសន្ធិវិញ្ញាណប្រកបដោយភាវៈនោះ មាន ២ ប្រការ ព្រោះការកើតឡើងមួយអន្លើដោយបណ្តាភាវៈនៃស្ត្រី និង បុរសទាំងឡាយ ភាវៈឯណាមួយ ។

បាទគាថាទាំងឡាយ ២ ថា “ទ្វេ វា តយោ វា ទសកា ឱមតោ អាទិនា សហ” សេចក្តីថា ក៏ឯបណ្តាវិញ្ញាណទាំងឡាយនេះ បដិសន្ធិវិញ្ញាណ ឯណា ដែលលាយឡំដោយរូប ជាខាងដើម ក្នុងប្រជុំ ២ នៃ



វិញ្ញាណនោះ គឺវិញ្ញាណដែលលាយឡំ ១ និង វិញ្ញាណដែលមិនលាយឡំ ១, ប្រមាណ ១០ ទាំងឡាយ ២ (ទសកៈ ២) ដោយអំណាចនៃវត្ថុទសកៈ និងកាយទសកៈ ឬ ឬថា ទសកៈ ៣ ដោយអំណាចវត្ថុទសកៈ, កាយទសកៈ និង ភាវទសកៈ រមែងកើតឡើង មួយអន្លើដោយបដិសន្ធិវិញ្ញាណនោះ ដោយថយថោក, ការសោបសូន្យ នៃរូបទាំងឡាយ ក្រៅអំពីនេះ មិនមានទេ ។

ក៏បដិសន្ធិវិញ្ញាណនេះនោះ មានប្រមាណដ៏ថយថោក យ៉ាងនេះ កាលកើតឡើងនៃវិញ្ញាណ រាប់បានជាកលលៈ មានប្រមាណ ដោយសប្បិដ៏ថ្លា ដែលបុគ្គលយករោមពពែ១ សរសៃ (ជ្រលក់)រលាស់ឡើង ក្នុងកំណើតទាំងឡាយ ២ ដែលមានឈ្មោះថា អណ្ឌជៈ និង ជលាពុជៈ រមែងកើតឡើងបាន ។ ប្រភេទនៃការជួបប្រទះ ដោយអំណាចនៃគតិ នៃកំណើតទាំងឡាយ គឺបណ្ឌិត គប្បីជ្រាប ក្នុងបដិសន្ធិវិញ្ញាណទាំងឡាយនោះ ។ ក៏បណ្តាគតិ នៃកំណើតទាំងឡាយនេះ

កំណើតទាំងឡាយ ៣ ខាងដើម មិនមានក្នុងនរក
ផង ក្នុងទេវតាទាំងឡាយផង វៀរចាកភូមិ, រីឯ
កំណើតទាំងឡាយ ៤ មាន ក្នុងគតិ ៣ ។

កំណើតទាំងឡាយ ៣ ខាងដើម គឺបណ្ឌិត គប្បីជ្រាបថា មិនមាន ក្នុងនរកផង ក្នុងទេវតាទាំងឡាយ វៀរចាកភូមិផង យ៉ាងណាមិញ, កំណើតទាំងឡាយ ៣ ខាងដើម ក្នុងនិជ្ឈាមតណ្ហិកប្រេតទាំងឡាយ គឺ បណ្ឌិត គប្បីជ្រាបថា មិនមាន ក៏យ៉ាងនោះដែរ ដោយ ច សព្ទ ត្រង់គាថានោះថា “ទេវេសុ ច” ដូច្នេះ ។ ចំណែក នេរយិកសត្វទាំងឡាយ

នោះ ជាឱបបាតិកកំណើតមែន ។ ក៏កំណើតទាំងឡាយ ៤ ដ៏សេស មាន ក្នុងប្រជុំបីនៃគតិ បានដល់តិរច្ឆាន, បេត្តិវិស័យ និង មនុស្សផង ក្នុងទេវតា វៀរចាកភូមិទាំងឡាយ ក្នុងកាលមុនផង ។

ក្នុងគតិ និង កំណើតទាំងនោះ

> រូបទាំងឡាយ ៣០ ផង ៩ ផង កើតឡើង ក្នុងព្រហ្មមានរូបទាំងឡាយ, ម្យ៉ាងទៀត រូបទាំងឡាយ ៧០ កើតឡើង ក្នុងសំសេទជៈ និង ឧបបាតិកកំណើតទាំងឡាយ ដោយចំណែកខាងខ្ពស់, ម្យ៉ាងវិញទៀត រូបទាំងឡាយ ៣០ កើតឡើង ដោយចំណែកខាងទាប ។

ជាដំបូង រូបទាំងឡាយ ៣០ ផង ៩ ផង កើតឡើង មួយអន្លើ ដោយបដិសន្ធិវិញ្ញាណ ដោយអំណាចនៃសំណុំ (កលាបៈ) នៃរូបទាំងឡាយ ៤ គឺ ចក្ខុទសកៈ, សោតទសកៈ និង វត្ថុទសកៈ ទាំងឡាយ ក្នុងឱបបាតិកកំណើតទាំងឡាយ ក្នុងរូបព្រហ្មទាំងឡាយ ។ ចំណែករូបទាំងឡាយនោះ ៧០ ដោយអំណាចនៃចក្ខុទសកៈ, សោតទសកៈ, ឃានទសកៈ, ជិវ្ហាទសកៈ, កាយទសកៈ, វត្ថុទសកៈ និង ភាវទសកៈ ទាំងឡាយ ដោយចំណែកខាងខ្ពស់ កើតឡើង ក្នុងពួកសំសេទជៈ និង ពួកឱបបាតិកកំណើតទាំងឡាយ ដទៃទៀត លើកលែងតែរូបព្រហ្មទាំងឡាយចេញ, ក៏រូបទាំងឡាយ ៧០ នោះ រមែងកើតមាន ក្នុងទេវតាទាំងឡាយ អស់កាលជានិច្ច ។

បណ្ដាទសកៈទាំងឡាយនោះ ពួកនៃរូប ១០ នេះ គឺ វណ្ណៈ ១, គន្ធៈ ១, រសៈ ១, ឱជា ១, ធាតុ ៤១, ចក្ខុប្បសាទ ១, ជីវិត ១, ឈ្មោះថា ចក្ខុទសកៈ ។ ពួកនៃរូបទាំងឡាយដ៏សេស គឺបណ្ឌិត គប្បីជ្រាប យ៉ាងនេះចុះ ។



ចំណែកខាង រូបទាំងឡាយ ៣០ កើតឡើង ដោយអំណាចនៃជិវ្ហាទសកៈ, កាយទសកៈ និង វត្ថុទសកៈទាំងឡាយ នៃមនុស្សខ្វាក់អំពីកំណើត, ថ្លង់អំពីកំណើត, ក្អិតច្រមុះ និង ខ្ទើយ ដោយយ៉ាងទាប ។ ចំណែកខាងសេចក្ដីកំណត់ គឺបណ្ឌិតគប្បីជ្រាប តាមសមគួរ ក្នុងចន្លោះនៃចំណែកខាងខ្ពស់ និង ចំណែកខាងទាបទាំងឡាយ ។

លុះជ្រាប យ៉ាងនេះហើយ

> ការប្លែកគ្នា នៃការញែក និង ការមិនញែក នៃចុតិ និង បដិសន្ធិទាំងឡាយ គឺបណ្ឌិត គប្បីកំណត់ដឹង ដោយខន្ធ, អារម្មណ៍, គតិ, ហេតុ, វេទនា, បីតិ, វិតក្កៈ និង វិចារៈទាំងឡាយ បន្ថែមទៀត ។

(៣៩១) សេចក្ដីអធិប្បាយថា ក៏បដិសន្ធិណានេះ មាន២ ប្រការ ដោយការលាយឡំគ្នា និង មិនលាយឡំគ្នា ១, ចុតិណា ជាលំដាប់នៃបដិសន្ធិដែលកន្លងហើយ១ ការផ្សេងគ្នានៃការលាយឡំគ្នា និង មិនលាយឡំគ្នា ដោយធម៌ទាំងឡាយ មានខន្ធជាដើមនេះ នៃបដិសន្ធិ និង ចុតិទាំងឡាយនោះ គឺបណ្ឌិត គប្បីជ្រាបផងចុះ ។ សួរថាៈ ព្រោះហេតុអ្វី? ។ ឆ្លើយថាៈ ដ្បិតថា បដិសន្ធិ មានត្រឹមតែខន្ធ ៤ ប៉ុណ្ណោះ កើតមានក្នុងចន្លោះនៃចុតិ របស់បុគ្គលអ្នកបាននូវអារុប្បឈាន មានខន្ធ ៤ ជួនកាល មិនប្លែកគ្នាពីអារម្មណ៍ទេ, ជួនកាល បដិសន្ធិ ដែលជាមហ-

គ្គតារម្មណ៍ និង អជ្ឈត្តារម្មណ៍កើតមាន ក្នុងលំដាប់នៃចុតិរបស់បុគ្គលអ្នកបាននូវអារុប្បឈានមានខន្ធ៤ ដែលមិនមែនជាមហគ្គតារម្មណ៍ និងពហិទ្ធារម្មណ៍។ នេះជាន័យ ក្នុងអរូបភូមិទាំងឡាយត្រឹមប៉ុណ្ណោះសិន ។

ក៏ក្នុងកាលខ្លះ បដិសន្ធិ ជាកាមាវចរ ដែលមានខន្ធ ៥ មានក្នុងលំដាប់អំពីចុតិនៃបុគ្គលអ្នកបាន នូវអារុប្បឈានមានខន្ធ ៤, ក្នុងកាលខ្លះ បដិសន្ធិ ជាអារុប្បឈាន ដែលមានខន្ធ ៤ មាន ក្នុងចន្លោះ នៃចុតិជាកាមាវចរក្តី នៃចុតិជារូបាវចរក្តី ដែលមានខន្ធ ៥ ។ បដិសន្ធិ ជាបច្ចុប្បន្នារម្មណ៍ នៃចុតិជាអតីតារម្មណ៍ យ៉ាងនេះឯង ។

បដិសន្ធិ ជាទុគ្គតិ នៃសត្វពួកខ្លះ មានក្នុងលំដាប់ នៃចុតិជាសុគតិនៃសត្វពួកខ្លះ, បដិសន្ធិ ប្រព្រឹត្តទៅមួយអន្លើដោយហេតុ មានក្នុងលំដាប់ នៃចុតិជាអហេតុកៈ, បដិសន្ធិ ជាត្រៃហេតុ មានក្នុងលំដាប់នៃចុតិជាទុហេតុកៈ, បដិសន្ធិ ជាសោមនស្សសហគតចិត្ត មានក្នុងលំដាប់ នៃចុតិ ជាឧបេក្ខាសហគតៈ, បដិសន្ធិ ប្រកបដោយបីតិ មានក្នុងលំដាប់នៃចុតិមិនមានបីតិ, បដិសន្ធិ ប្រកបដោយវិតក្កៈ មានក្នុងលំដាប់ នៃចុតិមិនមានវិតក្កៈ, បដិសន្ធិប្រកបដោយវិចារៈ មានក្នុងលំដាប់នៃចុតិ មិនមានវិចារៈ, បដិសន្ធិ ប្រកបដោយវិតក្កៈ និង វិចារៈ មានក្នុងលំដាប់នៃចុតិ មិនមានវិតក្កៈ និង វិចារៈ ព្រោះហេតុនោះ ការប្រកបដ៏សមគួរគឺបណ្ឌិតគប្បីប្រកប ដោយការផ្សុំយគ្នាអំពីចុតិ និង បដិសន្ធិនោះៗ ។

ធម៌ត្រឹមតែវិញ្ញាណនេះ ថា មានបច្ច័យបានហើយ
រមែងចូលទៅកាន់ភពដទៃ, ការឈានកន្លងអំពី
ភពនោះនៃរូបនោះ មិនមានទេ, រូប វៀរចាកហេតុ
អំពីអតីតភពនោះ ក៏មិនមានដែរ ។



សេចក្តីអធិប្បាយថា វិញ្ញាណ មានបច្ច័យដែលបានហើយត្រឹមតែធម៌ គឺរូប និង អរូបនេះ កាលកើតឡើង មិនមែនជាសត្វ មិនមែនជីវិត គឺលោកពោលថា ចូលទៅកាន់ចន្លោះនៃភព, ចំណែកខាង ការរំកិលទៅអំពីអតីតភព ក្នុងភពនេះនៃរូប និង អរូបធម៌នោះ មិនមានទេ, បាតុភាព ក្នុងភពនេះ វៀរចាកហេតុអំពីភពមុននោះក៏មិនមានដែរ ។ យើងនឹងប្រកាសនូវចុតិបដិសន្ធិវិញ្ញាណនោះនេះ តាមលំដាប់ នៃចុតិបដិសន្ធិនៃមនុស្សដែលច្បាស់លាស់ឡើង ។

សេចក្តីថាៈ កាលបើសត្វ មានសេចក្តីស្លាប់ ជិតណាស់ហើយដោយកិច្ចរបស់ខ្លួន ឬ ឬថា ដោយសេចក្តីព្យាយាម កាលអត់ទ្រាំមិនបាន នូវការប្រជុំនៃគ្រឿងសស្ត្រាវុធ គឺវេទនា ដែលមានសេចក្តីស្លាប់ជាទីបំផុត ដែលកាត់នូវទី-ត និង សរសៃនៃអវយវៈតូច និងអវយវៈធំទាំងពួង ដែលធន់ពុំបាន, កាលបើសរីរៈ កាលចូលដល់នូវការរីងស្ងួតតាមលំដាប់ ដូចជាស្លឹកត្នោតដែលបុគ្គលដាក់ចុះហើយ លើកំដៅថ្ងៃ កាលបើឥន្ទ្រីយ៍ទាំងឡាយមានចក្ខុន្ទ្រីយ៍ជាដើម រលត់ហើយ, កាលបើកាយិន្ទ្រីយ៍, មនិន្ទ្រីយ៍ និងជីវិតិន្ទ្រីយ៍ទាំងឡាយស្ថិតនៅហើយក្នុងទីត្រឹមតែហទយវត្ថុ, វិញ្ញាណដែលអាស្រ័យនៅរួម ក្នុងហទយវត្ថុដ៏សេស ក្នុងខណៈនោះ រមែងប្រព្រឹត្តទៅ ព្រោះប្រារព្ធនូវបណ្តាគរុកម្ម, សមាសេវិតកម្ម, អាសន្នកម្ម និង កម្មដែលបុគ្គលធ្វើហើយ ក្នុងកាលមុន ទាំងឡាយ កម្មណាមួយ នូវកម្មគឺការតាក់តែង នូវបច្ច័យដ៏សេសដែលខ្លួនបានហើយក្តី នូវអារម្មណ៍ ពោលគឺកម្មនិមិត្ត និង គតិនិមិត្តដែលតាំងឡើងប្រាកដហើយ អំពីកម្មនោះ, តណ្ហា ញុំាងវិញ្ញាណនោះកាលប្រព្រឹត្តទៅយ៉ាងនេះ ឲ្យឱនទៅ ក្នុងអារម្មណ៍នោះ ដែលមានទោស

គឺអវិជ្ជាបិទបាំងហើយ ព្រោះភាពនៃតណ្ហា និង អវិជ្ជាទាំងឡាយ គឺខ្ទួន មិនទាន់លះបង់ហើយ, សង្ខារ ដែលកើតរួមគ្នាទាំងឡាយ រមែងបោះទៅ, វិញ្ញាណនោះ គឺតណ្ហាកាលបង្អោនទៅ គឺសង្ខារទាំងឡាយ កាលបោះទៅ ដោយអំណាចនៃតំណ លះបង់នូវទីអាស្រ័យមុនផង ដូចជាបុគ្គលអ្នកតោង នូវខ្សែដែលគេចងនូវដើមឈើ នាត្រើយខាងអាយហើយ ឆ្លងនូវប្រឡាយ ត្រេកអរនូវទីអាស្រ័យខាងក្រោយ ដែលកម្មឲ្យតាំងឡើងព្រមហើយផង មិនគួរត្រេកអរផង ប្រព្រឹត្តទៅដោយបច្ច័យទាំងឡាយ មានអារម្មណ៍ជាដើមហ្នឹងឯង ។

ក៏បណ្ដាវិញ្ញាណទាំងឡាយនេះ វិញ្ញាណខាងដើម ឈ្មោះថា ចុតិ-វិញ្ញាណ ព្រោះការឃ្លាត, វិញ្ញាណខាងក្រោយ គឺព្រះមានព្រភាគ ទ្រង់ត្រាស់ថា បដិសន្ធិវិញ្ញាណ ព្រោះការតភ្ជាប់មកពីខាងដើមនៃភពដទៃ ។ វិញ្ញាណនោះនេះ គឺបណ្ឌិត គប្បីជ្រាបថា "មិនចេញមកពីភពមុនហើយមកក្នុងភពនេះឡើយថា មិនមែនវៀរលែង នូវហេតុមានកម្ម, សង្ខារ, តណ្ហា និង អារម្មណ៍ជាដើម អំពីភពនោះ ហើយកើតប្រាកដផង" ។

ក្នុងវិញ្ញាណនេះ ធម៌ទាំងឡាយមានសម្លេងគឺកកង
ជាដើម ជានិទស្សនៈ, មួយទៀត ព្រោះការចង
ជាប់ ក្នុងសន្តាន ភាពនៃវិញ្ញាណតែមួយក្ដី ក៏មិន
មាន, ភាពនៃវិញ្ញាណផ្សេងគ្នាក្ដី ក៏មិនមានដែរ ។

(៣៩២) មែនពិត ក្នុងអធិការនេះ ធម៌ទាំងឡាយ មានសម្លេងគឺកកង, ប្រទីប, ជញ្ជីងត្រាដូរ និង រូបសំណាកជាបការៈ ជាគំរូក្នុងដំណើរនេះ គឺក្នុងការមិនចេញមកអំពីភពមុន ក្នុងភពនេះ និង ក្នុងការកើត



ឡើង ព្រោះហេតុដែលលោករាប់បញ្ចូលហើយ ក្នុងអតីតភពទាំងឡាយនៃវិញ្ញាណនោះ ។ ដូចជាសម្លេងគឺកកង, ប្រទីប, ជញ្ជីងត្រាដូរ និង ជាធម្មជាតិប្រកបដោយហេតុ មានសម្លេងជាដើម ទើបមាន ប្រាសចាកសម្លេងជាដើមទៅហើយមិនបានយ៉ាងណា, ចិត្តនេះ ក៏យ៉ាងនោះដែរ ។ ក៏ក្នុងអធិការនេះ ព្រោះការចងភ្ជាប់ក្នុងសន្តាន, ភាពនៃវិញ្ញាណតែមួយក្តី ក៏មិនមាន ភាពនៃវិញ្ញាណផ្សេងគ្នាក្ដី ក៏មិនមានដែរ, ប្រសិនណាបើកាលបើការចងភ្ជាប់ ក្នុងសន្តាន មាន ភាពនៃវិញ្ញាណតែ ១ ក្នុងទីតែ ១ គប្បីមាន, ទឹកដោះជូរ មិនមានកើតព្រមអំពីទឹកដោះស្រស់ទេ, ភាពនៃវិញ្ញាណផ្សេងគ្នាតែ ១ គប្បីមាន, ទឹកដោះជូរ ក៏មិនជាទីអាស្រ័យទឹកដោះស្រស់ទេ ។ ន័យក្នុងហេតុទាំងពួង និង ការកើតឡើងនៃហេតុទាំងឡាយ ដូចជាន័យនេះដែរ ។ ក៏នាកាលភាព នៃវិញ្ញាណផ្សេងគ្នាកាលមាន ការលុបនូវលោកវោហារទាំងពួងចេញ គប្បីមាន, ក៏ការលុបនោះ មិនសំរេចទេ, ព្រោះហេតុនោះ ភាពនៃវិញ្ញាណតែ ១ ក្នុងទីតែ ១ ក្ដី ភាពនៃវិញ្ញាណផ្សេងគ្នាក្ដី ក្នុងអធិការនេះ គឺបណ្ឌិតមិនគប្បីប្រកាន់ជឿបានទេ ។

អាចារ្យអ្នកចោទ ក៏គប្បីចោទ ក្នុងអធិការនេះថា: ក្រែងកាលបើការរំកិលទៅ និងភាពប្រាកដកាលមានយ៉ាងនេះ ផលនោះ ក៏មានដល់បុគ្គលដទៃ ឬអំពីកម្មដទៃ ព្រោះភាពនៃខន្ធទាំងឡាយ ក្នុងអត្តភាពជាមនុស្សនេះ រលត់ទៅ និង ព្រោះកម្មដែលជាបច្ច័យនៃផល មិនទៅក្នុងទីកើតនៃផលនោះ មិនមែនទេឬ? ។ មួយទៀត ដូចជាកាលបើបុគ្គលអ្នកចូលទៅជិត បរិភោគមិនមានទេ ផលនោះ នឹងមាន ដល់អ្នកណា, ព្រោះហេតុនោះ ពាក្យដែលអ្នកពោលហើយនេះ ជារបៀបមិនល្អទេ ។

*ពាក្យជាគាថានេះ ក្នុងអធិការនេះ គឺអាចារ្យពោលថា :*

ផលណា កើតក្នុងសន្តាន ផលនោះ មិនមានដល់
បុគ្គលដទៃទេ និង មិនមានអំពីកម្មដទៃទេ សភាព
សំរាប់តាក់តែង នៃពូជទាំងឡាយ ជាគ្រឿងញ៉ាំង
សេចក្តីនេះ ឲ្យសំរេច ។

*ផលកាលកើតឡើង ក្នុងសន្តានតែ ១ គឺបុគ្គលមិនគប្បីពោលបានថា : ជាផលនៃបុគ្គលដទៃ ឬ ឬថា ជាផលអំពីកម្មដទៃ ព្រោះភាពនៃផលនោះ ជាធម្មជាត ក្នុងទីជាមួយគ្នា និង ផ្សេងគ្នា ដោយចំណែកក្នុងសន្តាននោះ ត្រូវបដិសេធហើយ ។ ក៏សភាពជាគ្រឿងផ្សំនៃពូជទាំងឡាយ ជាគ្រឿងសំរេចនៃអត្ថរបស់ពាក្យនេះ។ មែនពិត នាកាលភាពជាគ្រឿងផ្សំទាំងឡាយនៃពូជទាំងឡាយមានស្វាយជាដើម ដែលបុគ្គលធ្វើហើយ ផលដ៏វិសេស កាលកើតឡើង ក្នុងចន្លោះនៃកាល ព្រោះបច្ច័យនៃផលដែលខ្វនបានហើយ ក្នុងសន្តាននៃពូជនោះ ទាំងមិនមែនជាបច្ច័យ នៃពូជដទៃទាំងឡាយ ទាំងមិនមែនកើតឡើង ព្រោះបច្ច័យសំរាប់តាក់តែងដទៃ, ពូជទាំងឡាយនោះក្តី សភាពជាគ្រឿងផ្សំទាំងឡាយក្តី មិនមែនដល់នូវទីតាំង នៃផលឡើយ យ៉ាងណាមិញ, ពាក្យប្រៀបធៀប ជាហេតុញ៉ាំងពាក្យឧបមេយ្យ ឲ្យដល់ព្រមនេះ គឺបណ្ឌិតគប្បីជ្រាប ក៏យ៉ាងនោះដែរ ។ ន័យមួយទៀត អត្ថាធិប្បាយនេះ គឺបណ្ឌិត គប្បីជ្រាប ដោយគុណទាំងឡាយមានវិជ្ជា, សិប្បៈ និង ឱសថជាដើម ដែលបុគ្គលចូលទៅប្រកបហើយ ក្នុងសរីរៈនៃក្មេង ដែលឲ្យផល ក្នុងហេតុទាំងឡាយមានសរីរៈ នៃមនុស្សចាស់ជាដើម ក្នុងចន្លោះ*



*នៃកាល ។ អត្ថាធិប្បាយនេះ គឺបណ្ឌិតគប្បីជ្រាបផងចុះ ។ ពាក្យណាដែលយើងពោលហើយថា: ក៏កាលបើមិនមានអ្នកបរិភោគទេ, ផលនោះគប្បីមានដល់បុគ្គលណា, សេចក្តីវិនិច្ឆ័យ ក្នុងពាក្យនោះ គឺបណ្ឌិតគប្បីជ្រាបផងចុះ ។*

ការសន្មតថា ឈើចេញផ្លែ ព្រោះការកើតឡើង នៃ
ផ្លែឈើ យ៉ាងណា, ការសន្មតថា ជនអ្នកបរិភោគ
សំរេចហើយ ព្រោះការកើតឡើង នៃផល ក៏យ៉ាង
នោះដែរ ។

*ដូចជាឈើ គឺលោកហៅថា កំពុងតែផ្លែឬ ឬថា ផ្លែហើយ ព្រោះការកើតឡើង នៃផ្លែឈើជាឯកទេសនៃធម្មតាទាំងឡាយ ពោលគឺឈើហ្នឹងឯង មានឧបមាយ៉ាងណា, ទេវតាក្តី មនុស្សក្តី គឺលោកពោលថាចូលទៅបរិភោគក្តី ថា ដល់ហើយនូវសេចក្តីសុខក្តី ថា ដល់ហើយនូវសេចក្តីទុក្ខក្តី ដោយការកើតឡើងនៃផលនៃសេចក្តីសុខ និង សេចក្តីទុក្ខ ពោលគឺឧបភោគជាឯកទេស នៃខន្ធទាំងឡាយ ពោលគឺទេវតា និងមនុស្ស ក៏មានឧបមេយ្យយ៉ាងដូច្នោះដែរ, ព្រោះហេតុនោះ ប្រយោជន៍ណាមួយ ដោយបុគ្គលអ្នកចូលទៅបរិភោគដទៃ មិនមាន ក្នុងសន្តានតែមួយនេះទេ ។*

*អាចារ្យណាគប្បីពោលថា កាលបើយ៉ាងហ្នឹងក៏ដោយ សង្ខារទាំងឡាយកាលមានក្តី កាលមិនមានក្តី គប្បីជាបច្ច័យរបស់ផល, ក៏ប្រសិនបើមាន ទើបជាបច្ច័យ គឺវិបាក របស់សង្ខារទាំងឡាយនោះ គប្បីមានក្នុងខណៈនៃបវត្តិកាល ។ ម្យ៉ាងវិញទៀត កាលបើមិនមានទេ ក៏ជា*

បច្ច័យបាន គប្បីនាំមកនូវផលអស់កាលជានិច្ច ខាងដើមអំពីបវត្តិកាលផង ខាងចុងអំពីបវត្តិកាលផង ។

ព្រោះហេតុនោះ អាចារ្យនោះ គឺបណ្ឌិតគប្បីពោល យ៉ាងនេះថា :

> សង្ខារទាំងឡាយនេះ ជាបច្ច័យរបស់ផល ព្រោះ
> ភាពនៃផលគឺខ្លួនធ្វើហើយ, ប៉ុន្តែសង្ខារទាំងឡាយ
> នោះ មិនមែននាំមកនូវផល អស់កាលជានិច្ចទេ,
> ហេតុមានបុគ្គលអ្នកធានាជាដើម ជាតួយ៉ាង គឺ
> បណ្ឌិតគប្បីជ្រាប ក្នុងសេចក្តីនោះផងចុះ ។

ព្រោះថា សង្ខារទាំងឡាយ ជាបច្ច័យនៃផលរបស់ខ្លួន ព្រោះភាពនៃសង្ខារទាំងឡាយគឺសត្វធ្វើហើយ មិនមែនព្រោះភាពនៃសង្ខារកាលមាន ឬ មិនមានទេ ។ សមដូចព្រះពុទ្ធដីកាព្រះមានព្រះភាគទ្រង់ត្រាស់ហើយថា: ពាក្យជាដើមថា ចក្ខុវិញ្ញាណជាវិបាកកើតឡើងហើយ ព្រោះភាពនៃកាមាវចរកុសល គឺខ្លួនធ្វើហើយផង ព្រោះភាពនៃកាមាវចរ-កុសល គឺខ្លួនសន្សំហើយផង ។ ក៏សង្ខារទាំងឡាយនោះ ជាបច្ច័យនៃផលរបស់ខ្លួន គួរយ៉ាងណា មិនមែនជាសភាវៈនាំមកនូវផលទៀតឡើយ ព្រោះមានវិបាកចាស់ហើយ ។ ក៏ហេតុ មានការធានាជាដើមនេះជាតួយ៉ាង គឺបណ្ឌិតគប្បីជ្រាប ក្នុងការបំភ្លឺនូវសេចក្តីនេះ ។ តួយ៉ាងដូចជាបុគ្គលណាមួយ ជាអ្នកធានាដើម្បីការចាត់ចែង នូវប្រយោជន៍ដល់បុគ្គលណាមួយ ទិញនូវទ្រព្យក្តី កាន់យកនូវបំណុលក្តី, ហេតុគ្រាន់តែការធ្វើនូវកិរិយានោះ ចំពោះបុគ្គលនោះ ជាបច្ច័យ ក្នុងខាងដើមនៃការប្រគល់សេចក្តីនោះ, ភាពនៃកិរិយាកាលមានក្តី, ភាពនៃកិរិយា



កាលមិនមានក្តី មិនមែនជាបច្ច័យឡើយ, បុគ្គលនោះ គឺជាអ្នករ៉ាប់រងបន្ទាប់អំពីហេតុ មានការប្រគល់ឲ្យនូវវត្ថុនោះជាដើម ព្រោះហេតុអ្វី? ព្រោះភាពនៃកិច្ចទាំងឡាយ មានការតាក់តែងជាដើម គឺខ្លួនធ្វើហើយយ៉ាងណាមិញ, សូម្បីសង្ខារទាំងឡាយដែលបុគ្គលធ្វើហើយហ្នឹងឯងរមែងជាបច្ច័យ របស់ខ្លួនយ៉ាងនេះ មិនមែនជាសភាពនាំមកនូវផលខាងមុខ អំពីការឲ្យនូវផល ដ៏សមគួរយ៉ាងណាទេ ក៏យ៉ាងនោះដែរ ។

កិរិយាប្រព្រឹត្តិទៅ នៃបដិសន្ធិវិញ្ញាណ កាលប្រព្រឹត្តទៅ ដោយចំណែក ២ ដោយអំណាចនៃភេទដែលលាយឡំគ្នា និង មិនលាយឡំគ្នា ព្រោះមានសង្ខារជាបច្ច័យ ជាធម្មជាតិ គឺព្រះមានព្រះភាគ ទ្រង់ត្រាស់បំភ្លឺហើយ ដោយហេតុមានប្រមាណប៉ុណ្ណេះ ។

(៣៩៣) ក្នុងកាលឥឡូវនេះ ដើម្បីកំចាត់បង់ នូវការភ័ន្តច្រឡំ ក្នុងវិបាកវិញ្ញាណទាំងឡាយ ៣២ ទាំងអស់ហ្នឹងឯង

> សង្ខារទាំងឡាយនោះ ជាបច្ច័យ នៃវិបាកវិញ្ញាណ
> ទាំងឡាយណា ដោយប្រការណា, វិបាកវិញ្ញាណ
> ទាំងឡាយនេះ បណ្ឌិតគប្បីជ្រាប ក្នុងទីទាំងឡាយ
> មានភពជាដើម ដោយអំណាច នៃបដិសន្ធិ និង
> ប្រវត្តិកាល (ដោយប្រការនោះ) ។

សេចក្តីអធិប្បាយ ក្នុងគាថានោះថា ធម៌ទាំងឡាយនេះ គឺ ភព ៣, កំណើត ៤, គតិ ៥, វិញ្ញាណដ្ឋិតិ ៧, សត្តាវាស ៩ ឈ្មោះថា ទីកើតមានភពជាដើម ។ សង្ខារទាំងឡាយនេះ ជាបច្ច័យ នៃវិបាកវិញ្ញាណទាំងឡាយណា ក្នុងទីទាំងឡាយ មានភពជាដើមនេះ ក្នុងបដិសន្ធិផង

ក្នុងប្រវត្តិកាលផង ។ ក៏សង្ខារទាំងឡាយជាបច្ច័យ ដោយប្រការណា, បណ្ឌិតគប្បីជ្រាប ដោយប្រការនោះ ។

បណ្ដាសង្ខារទាំងឡានោះ អធិប្បាយ ក្នុងបុញ្ញាភិសង្ខារ ជាមុន បុញ្ញាភិសង្ខារ ចែកទៅតាមចេតនា ៨ ជាកាមាវចរ ជាបច្ច័យ ដោយចំណែក ២ គឺកម្មប្បច្ច័យ ប្រព្រឹត្តទៅ ក្នុងខណៈផ្សេងៗ ១, ឧបនិស្សយប្បច្ច័យ ១ ក្នុងបដិសន្ធិ នៃវិបាកវិញ្ញាណទាំងឡាយ ៩ ក្នុងសុគតិជាកាមភព ដោយមិនប្លែកគ្នា ។ បុញ្ញាភិសង្ខារ មានកុសលចេតនា ៥ ជារូបាវចរ ជាប្រភេទ ជាបច្ច័យ នៃវិបាកវិញ្ញាណទាំងឡាយ ៥ ក្នុងរូបភពផង ក្នុងបដិសន្ធិកាលហ្នឹងឯងផង ។ ចំណែកខាងបុញ្ញាភិសង្ខារ ជាកាមវចរ មានប្រភេទដែលលោកពោលហើយ ជាបច្ច័យ ដោយចំណែក ២ នៃវិបាកវិញ្ញាណដ៏ស្ងួចស្តើងទាំងឡាយ ៧ ដែលវៀរចាកអហេតុកមនោវិញ្ញាណធាតុ ដែលប្រព្រឹត្តទៅ មួយអន្លើដោយឧបេក្ខា ក្នុងសុគតិ ជាកាមភព តាមន័យដែលពោលរួចហើយ, មិនមែនជាបច្ច័យ ក្នុងបដិសន្ធិ ក្នុងបវត្តិកាលទេ ។ បុញ្ញាភិសង្ខារ ជាកាមាវចរនោះឯង ជាបច្ច័យដូចគ្នាដែរ នៃវិបាកវិញ្ញាណទាំងឡាយ ៥ ក្នុងរូបភពមិនមែនជាបច្ច័យ ក្នុងបដិសន្ធិ ក្នុងប្រវត្តិកាលទេ ។

ចំណែកខាង បុញ្ញាភិសង្ខារ ជាកាមាវចរ មានប្រភេទដែលលោកពោលហើយ ជាបច្ច័យដូចគ្នា នៃវិបាកវិញ្ញាណ ដ៏ស្ងួចស្តើងទាំងឡាយ ៨ ក្នុងទុគ្គតិ ជាកាមភព ពុំមែនជាបច្ច័យក្នុងបដិសន្ធិ ក្នុងប្រវត្តិកាលទេ។ ក្នុងនរក កាមាវចរ មានប្រភេទដូចលោកពោលហើយនោះ ជាបច្ច័យក្នុងការជួបប្រទះ នូវអារម្មណ៍ជាទីប្រាថ្នា ក្នុងកាលទាំងឡាយ មានកាលជាទីត្រាច់ទៅកាន់តំបន់(ស្ថាន) នរក នៃព្រះមហាមោគ្គល្លានត្ថេរ ។



ក៏ឥដ្ឋារម្មណ៍ គឺបណ្ឌិតបាន ក្នុងសត្វតិរច្ឆានទាំងឡាយផង ក្នុងមហិទ្ធិឫទ្ធិ នៃប្រេតទាំងឡាយផង ។ កាមាវចរ មានប្រភេទដែលលោកពោលហើយនោះឯង ជាបច្ច័យដូចគ្នា នៃវិបាកវិញ្ញាណ ជាកុសលទាំងឡាយ ១៦ ក្នុងសុគតិភព ជាកាមភព ក្នុងប្រវត្តិកាលផង ក្នុងបដិសន្ធិផង ។ ចំណែកបុញ្ញាភិសង្ខារ ជាបច្ច័យដូចគ្នា នៃវិបាកវិញ្ញាណទាំងឡាយ ១០ ក្នុងរូបភព ក្នុងប្រវត្តិកាលផង ក្នុងបដិសន្ធិផង ដោយមិនប្លែកគ្នាទេ ។

អបុញ្ញាភិសង្ខារ មានចេតនាជាអកុសល១២ ជាប្រភេទ ជាបច្ច័យដោយចំណែក ២ ដូចគ្នានៃវិញ្ញាណ ១ ក្នុងទុគ្គតិជាកាមភព ក្នុងបដិសន្ធិ មិនមែនជាបច្ច័យក្នុងប្រវត្តិកាល ជាបច្ច័យ នៃអកុសលវិបាកវិញ្ញាណទាំងឡាយ ៦ ក្នុងប្រវត្តិកាល មិនមែនជាបច្ច័យ ក្នុងបដិសន្ធិកាលទេ ជាបច្ច័យ នៃវិបាកវិញ្ញាណ ជាអកុសលទាំងឡាយ ៧ ក្នុងបវត្តិកាលផង ក្នុងបដិសន្ធិកាលផង ។ ក៏អបុញ្ញាភិសង្ខារ ក្នុងកាមភព ជាបច្ច័យដូចគ្នា នៃអកុសលវិបាកវិញ្ញាណ ៧ នោះឯង ក្នុងសុគតិភព មិនមែនជាបច្ច័យក្នុងបដិសន្ធិ ក្នុងប្រវត្តិកាលទេ ។ អបុញ្ញាភិសង្ខារក្នុងរូបភព ជាបច្ច័យដូចគ្នា នៃវិបាកវិញ្ញាណទាំងឡាយ ៤ មិនមែនជាបច្ច័យ ក្នុងបដិសន្ធិ ក្នុងប្រវត្តិកាលទេ ។ អបុញ្ញាភិសង្ខារនោះឯង តែងមានដោយអំណាចនៃការឃើញរូប និង ការឮនូវសំឡេង មិនជាទីប្រាថ្នា ក្នុងកាមាវចរ ។ ចំណែកអារម្មណ៍ទាំងឡាយ មានរូបារម្មណ៍ជាដើម ដែលមិនជាទីប្រាថ្នា មិនមានក្នុងព្រហ្មលោកទេ, អារម្មណ៍ទាំងឡាយ មានរូបារម្មណ៍មិនជាទីប្រាថ្នាជាដើម ក៏មិនមាន ក្នុងទេវលោកជាន់កាមាវចរ ដូចគ្នាដែរ ។

ចំណែកខាង អនេញ្ជាភិសង្ខារ ជាបច្ច័យ នៃវិបាកវិញ្ញាណទាំងឡាយ ៤ ក្នុងអរូបភពទាំងឡាយ ដូចគ្នាដែរ ក្នុងប្រវត្តិកាលផង ក្នុង

បដិសន្ធិកាលផង ។ សង្ខារទាំងឡាយនេះជាបច្ច័យនៃវិបាកវិញ្ញាណទាំងឡាយណា ដោយអំណាចនៃការប្រព្រឹត្តិទៅ នៃបដិសន្ធិទាំងឡាយ ក្នុងភពទាំងឡាយ យ៉ាងនេះតែប៉ុណ្ណោះ ។ ក៏វិបាកវិញ្ញាណទាំងឡាយនោះជាបច្ច័យយ៉ាងណា បណ្ឌិតគប្បីជ្រាប ក៏យ៉ាងនោះដែរ ។ សង្ខារទាំងឡាយ គឺបណ្ឌិត គប្បីជ្រាប ក្នុងទីទាំងឡាយ មានកំណើតជាដើម តាមន័យនេះឯង ។ ការប្រកាសនេះ ក្នុងសង្ខារទាំងឡាយនោះ ជាការប្រកាសគ្រាន់តែជាប្រធាន ចាប់តាំងអំពីដើមតែប៉ុណ្ណោះ ។

ព្រោះថា បណ្តាសង្ខារទាំងឡាយនេះ បុញ្ញាភិសង្ខារឲ្យនូវបដិសន្ធិក្នុងភពទាំងឡាយ ២ ប៉ុណ្ណោះ ញុំាងវិបាកទាំងអស់ របស់ខ្លួនឲ្យកើតឡើង ឲ្យបដិសន្ធិ ក្នុងកំណើតទាំងឡាយ ៤ មានអណ្ឌជកំណើត ជាដើម ក្នុងគតិទាំងឡាយ២ ពោលគឺទេវតា និង មនុស្ស ក្នុងវិញ្ញាណដ្ឋិតិទាំងឡាយ ៤ បានដល់ មានកាយផ្សេងគ្នា និង មានសញ្ញាផ្សេងគ្នា, មានកាយផ្សេងគ្នា និង មានសញ្ញាតែមួយ, មានកាយតែមួយ និង មានសញ្ញាផ្សេងគ្នា, មានកាយតែមួយ និង មានសញ្ញាតែមួយ និង ក្នុងសត្តាវាសទាំង ៤ ព្រោះថា បុញ្ញាភិសង្ខារនេះ តាក់តែងត្រឹមតែរូបក្នុងលំនៅ នៃអសញ្ញីសត្វតែប៉ុណ្ណោះ ហើយញុំាងវិបាកទាំងអស់របស់ខ្លួន ឲ្យកើតឡើង យ៉ាងដូច្នោះដែរ ព្រោះហេតុណា, ព្រោះហេតុនោះ បុញ្ញាភិសង្ខារនោះ ជាបច្ច័យ នៃវិបាកវិញ្ញាណទាំងឡាយ ២១ ក្នុងភពទាំងឡាយ ២ នេះផង, ក្នុងកំណើតទាំងឡាយ ៤ ផង, ក្នុងគតិទាំងឡាយ ២ ផង, ក្នុងវិញ្ញាណដ្ឋិតិទាំងឡាយ ៤ ផង, ក្នុងសត្តាវាសទាំងឡាយ ៤ ផង តាមន័យដែលលោកពោលហើយ តាមសមគួរដល់ការកើត ក្នុងបដិសន្ធិកាលផង ក្នុងបវត្តិកាលផង ។



ក៏អបុញ្ញាភិសង្ខារឲ្យផលក្នុងកាមភព ១ ប៉ុណ្ណោះផង ក្នុងកំណើតទាំងឡាយ ៤ ក្នុងគតិទាំងឡាយ ៣ ដ៏សេសផង, ក្នុងវិញ្ញាណដ្ឋិតិ ១ សំដៅយកមានកាយផ្សេងគ្នា មានសញ្ញា តែ ១ ផង, ក្នុងសត្តាវាស ១ ប្រាកដដូច្នោះផង ដោយអំណាចបដិសន្ធិ ព្រោះហេតុណា, ព្រោះហេតុនោះ អបុញ្ញាភិសង្ខារនេះ ជាបច្ច័យនៃវិបាកវិញ្ញាណទាំងឡាយ ៧ ក្នុងភព ១ ផង ក្នុងកំណើតទាំងឡាយ ៤ ផង, ក្នុងគតិទាំងឡាយ ៣ ផង, ក្នុងវិញ្ញាណដ្ឋិតិ ១ ផង, ក្នុងសត្តាវាស ១ ផង តាមន័យដែលលោកពោលហើយ រមែងមាន ក្នុងបដិសន្ធិកាលផង ក្នុងប្រវត្តិកាលផង ។

ចំណែក អនេញ្ជាភិសង្ខារ ឲ្យផល ដោយឲ្យបដិសន្ធិ ក្នុងអរូបភព ១ ប៉ុណ្ណោះឯង ក្នុងឱបបាតិកកំណើត ១ ផង, ក្នុងទេវគតិ ១ ផង, ក្នុងវិញ្ញាណដ្ឋិតិទាំងឡាយ ៣ មានអាកាសានញ្ចាយតនៈជាដើមផង, ក្នុងសត្តាវាសទាំងឡាយ ៤ មានអាកាសានញ្ចាយតនៈជាដើមផង ដោយអំណាចនៃបដិសន្ធិ ព្រោះហេតុណា, ព្រោះហេតុនោះ អនេញ្ជាភិសង្ខារនេះ ជាបច្ច័យនៃវិញ្ញាណទាំងឡាយ ៤ ក្នុងភព ១, ក្នុងកំណើត ១, ក្នុងគតិ ១ ក្នុងវិញ្ញាណដ្ឋិតិទាំងឡាយ ៣, ក្នុងសត្តាវាសទាំងឡាយ ៤ តាមន័យដែលលោកពោលហើយ ក្នុងបដិសន្ធិកាលផង ក្នុងបវត្តិកាលផង ។

សង្ខារទាំងឡាយ ជាបច្ច័យ នៃវិញ្ញាណទាំងឡាយ
ណា យ៉ាងណាមិញ, វិបាកវិញ្ញាណទាំងឡាយនេះ
គឺបណ្ឌិតគប្បីជ្រាប ក្នុងទីទាំងឡាយ មានភពជា
ដើម ដោយអំណាយ នៃបដិសន្ធិ និង ប្រវត្តិកាល
ទាំងឡាយ ក៏យ៉ាងនោះដែរ ។

ពាក្យនេះ ជាពាក្យពិស្តារ ក្នុងបទថា “វិញ្ញាណ(កើតព្រម) ព្រោះមានសង្ខារជាបច្ច័យ” ។

> បណ្ឌិត គប្បីជ្រាប វិនិច្ឆ័យ ដោយការញែក នូវនាម និង រូបទាំងឡាយ ដោយការប្រព្រឹត្តិទៅ ក្នុងទីទាំងឡាយ មានភពជាដើម ដោយការរួបរួម ដោយបច្ចយន័យ ។

(៣៩៤) សេចក្តីវិនិច្ឆ័យត្រង់បទថា “នាមរូប (កើតព្រម) ព្រោះមានវិញ្ញាណ ជាបច្ច័យ” ។

ក៏សេចក្តីវិនិច្ឆ័យ ត្រង់បទថា “ដោយការញែក នូវនាម និង រូបទាំងឡាយ” នេះ មានដូចតទៅៈ ខន្ធទាំងឡាយ ៣ មានវេទនា ជាដើម ឈ្មោះថា នាម ព្រោះការឱនទៅ មានមុខឆ្ពោះទៅកាន់អារម្មណ៍ ។

មហាភូតរូបទាំងឡាយ ៤ ក្តី, ឧបាទាយរូប នៃមហាភូតរូបទាំងឡាយ ៤ ក្តី ឲ្យឈ្មោះថា រូប ។ ការបែងចែក នូវនាមរូបទាំងឡាយនោះ គឺលោកពោលហើយ ក្នុងខន្ធនិទ្ទេសឯណោះ ។

សេចក្តីវិនិច្ឆ័យ ក្នុងបដិច្ចសមុប្បាទទាំងឡាយនេះ គឺបណ្ឌិតគប្បីជ្រាបយ៉ាងនេះ ព្រោះការបែងចែកនូវនាម និង រូបចប់ត្រឹមនេះឯង ។

សេចក្តីវិនិច្ឆ័យ ក្នុងបទទាំងឡាយនេះថា “ព្រោះការប្រព្រឹត្តិទៅក្នុងទីទាំងឡាយ មានភពជាដើម” គឺបណ្ឌិត ប្បីជ្រាប ដូចតទៅនេះ ។

នាម តែងប្រព្រឹត្តទៅ ក្នុងភពទាំងពួង, កំណើត, គតិ, វិញ្ញាណដ្ឋិតិ និង សត្តាវាស ដ៏សេសទាំងឡាយ លើកលែងតែសត្តាវាស១ ចេញ ។ រូបព្រព្រឹត្តទៅ ក្នុងភពទាំងឡាយ ១, ក្នុងកំណើតទាំងឡាយ ៤, ក្នុងគតិ



ទាំងឡាយ ៥ ក្នុងវិញ្ញាណដ្ឋិតិទាំងឡាយ ៤ មាន ក្នុងខាងដើម, ក្នុងសត្តាវាសទាំងឡាយ ៥ ។ ក៏កាលបើនាមរូបនេះ ប្រព្រឹត្តទៅយ៉ាងនេះ, ក្បាលនៃខ្សែតំណាទាំងឡាយ ២ ផង ខន្ធទាំងឡាយ ៣ មិនមានរូបផង រមែងកើតប្រាកដអំពីរូប ក្នុងខណៈនៃបដិសន្ធិ របស់សត្វទាំងឡាយ ដែលដេកនៅ ក្នុងគភ៌មិនទាន់មានផង ក្នុងខណៈនៃបដិសន្ធិ របស់សត្វទាំងឡាយដែលកើតអំពីពងផង ដោយអំណាចវត្ថុទសកៈ និង កាយ-ទសកៈ ព្រោះហេតុណា, ព្រោះហេតុនោះ ធម៌ទាំងឡាយ ២៣ នេះ គឺ ធម៌ទាំងឡាយ ២០ អំពីរូបរបស់រូប និង ខន្ធទាំងឡាយ ៣ មិនមានរូប គឺបណ្ឌិត គប្បីជ្រាបថា នាមរូប (កើតព្រម) ព្រោះមានវិញ្ញាណ ជាបច្ច័យ ដោយពិស្តារ នៃក្បាលរបស់តំណាទាំងឡាយ ២ នោះ ។ បើពោលតាមស័ព្ទ ដែលលោកមិនប្រកាន់យកហើយ ធម៌ទាំងឡាយ ១៤ ដកចេញ នូវរូបធម៌ទាំងឡាយ ៩ អំពីក្បាលនៃខ្សែតំណា ១ គឺបណ្ឌិតគប្បីជ្រាបផងចុះ ។ ធម៌ទាំងឡាយ ៣៣ ដាក់បញ្ចូលនូវភាវទសកៈ នៃសត្វដែលមានភាវរូបទាំងឡាយ គឺបណ្ឌិត គប្បីជ្រាបផងចុះ ។ ធម៌ទាំងឡាយ ១៥ ដកចេញនូវរូបធម៌ទាំងឡាយ ១៨ ចាកការប្រជុំ ២ នៃក្បាលរបស់ខ្សែតំណា ដោយស័ព្ទដែលលោកមិនកាន់យកហើយ នូវរូបធម៌ទាំងឡាយនោះ គឺបណ្ឌិតគប្បីជ្រាបផងចុះ ។

ក៏ក្បាលនៃតំណាទាំងឡាយ ៤ ក្តី ខន្ធទាំងឡាយ ៣ មិនមានរូបក្តី កើតប្រាកដអំពីរូប ដោយអំណាច នៃចក្ខុទសកៈ, សោតទសកៈ និង វត្ថុទសកៈទាំងឡាយផង នៃជីវិតិន្ទ្រិយនវកៈផង ក្នុងខណៈនៃបដិសន្ធិ របស់បណ្តាសត្វទាំងឡាយ មានទេវតាដែលប្រព្រឹត្តទៅ ក្នុងពួកនៃព្រហ្មជាដើម ក្នុងសត្វដែលជាឧបបាតិកកំណើតទាំងឡាយ ព្រោះហេតុណា,

ព្រោះហេតុនោះ ធម៌ទាំងឡាយ ៤២ នេះ គឺ ធម៌ទាំងឡាយ ៣៩ ដោយរូបរូប, ខន្ធទាំងឡាយ ៣ មិនមានរូប គឺបណ្ឌិតគប្បីជ្រាបថា: នាមរូប (កើតព្រម) ព្រោះមានវិញ្ញាណ ជាបច្ច័យ ដោយពង្រីករូបព្រហ្មទាំងឡាយនោះ ។ បើនឹងពោលតាមស័ព្ទ ដែលលោកមិនទាន់បានកាន់យកហើយ ធម៌ទាំងឡាយ ១៥ ដកចេញ នូវធម៌ទាំងឡាយ ២៧ ដោយប្រជុំបីនៃប្រធាននៃខ្សែតំណ ។

ចំណែកខាង ក្នុងកាមភព ប្រធាននៃខ្សែតំណទាំងឡាយ ៧ ក្តី ខន្ធទាំងឡាយ ៣ មិនមានរូបក្តី រមែងកើតប្រាកដដោយរូប ក្នុងខណៈនៃបដិសន្ធិ របស់សត្វជាឱបបាតិកៈ ដ៏សេសទាំងឡាយផង នៃសត្វជាសំសេទជៈទាំងឡាយផង ដោយមានភាវៈ និង អាយតនៈគ្រប់គ្រាន់បរិបូរហើយ ព្រោះហេតុណា, ព្រោះហេតុនោះ ធម៌ទាំងឡាយ ៧៣ នេះ គឺធម៌ទាំងឡាយ ៧០ ដោយរូបរូប និង ខន្ធទាំងឡាយ ៣ មិនមានរូប គឺបណ្ឌិត គប្បីជ្រាបថា នាមរូប កើតព្រម ព្រោះមានវិញ្ញាណជាបច្ច័យ ព្រោះពង្រីកនូវរូបទាំងឡាយនោះ ។ ធម៌ទាំងឡាយ ១៩ ដកចេញនូវធម៌ទាំងឡាយ ៥៤ អំពីប្រមាណ ៦ នៃប្រធាន នៃសន្តតិរូប ដោយស័ព្ទដែលព្រះមានព្រះភាគ មិនទ្រង់បំណាងយកហើយ ។ ន័យនេះ គឺបណ្ឌិតគប្បីជ្រាប ដោយចំណែកយ៉ាងខ្ពស់ ។ បើនឹងពោល ដោយកិរិតទាបធម៌ទាំងឡាយ គឺបណ្ឌិតគប្បីរំលាស់ចេញ ដោយអំណាច នៃប្រមាណ ៦ នៃប្រធាន របស់សន្តតិរូបនោះៗ នៃសត្វដែលខ្វះខាតនូវប្រធាន នៃសន្តតិរូបនោះៗ ហើយជ្រាបថា បានដល់នាម និង រូបដែលកើតព្រម ព្រោះមានវិញ្ញាណ ជាបច្ច័យ ក្នុងបដិសន្ធិ ដោយបំព្រួញផង ដោយពិស្តារផង ។



ចំណែកខាងខន្ធទាំងឡាយ ៣ ហ្នឹង ដែលមិនមានរូបប្រាកដ ក្នុងបដិសន្ធិនៃព្រហ្មមិនមានរូបទាំងឡាយ ជីវិតិន្ទ្រិយនវកៈ ប្រាកដដោយរូប ក្នុងបដិសន្ធិ នៃអសញ្ញីសត្វទាំងឡាយប៉ុណ្ណោះឯង ។ ន័យ ក្នុងបដិសន្ធិនេះ គឺបណ្ឌិតគប្បីជ្រាបមុន ។

ចំណែកសុទ្ធដ្ឋករូប មានរដូវជាសមុដ្ឋាន កើតប្រាកដអំពីរដូវដែលប្រព្រឹត្តទៅមួយអន្លើដោយបដិសន្ធិចិត្ត ក្នុងការប្រព្រឹត្តិទៅ ក្នុងទីទាំងពួងដែលប្រព្រឹត្តទៅនៃរូប ក្នុងខណៈនៃការតាំងនៅ របស់បដិសន្ធិចិត្ត ។ ក៏បដិសន្ធិចិត្ត មិនញុំាងរូបឲ្យតាំងនៅបានទេ ។ ព្រោះថា បដិសន្ធិចិត្តនោះ មិនអាចញុំាងរូប ឲ្យតាំងនៅបាន ព្រោះភាពនៃបដិសន្ធិចិត្តនោះជាធម្មជាតមានកម្លាំងខ្សោយ ព្រោះភាពនៃខ្លួន មានវត្ថុមានកម្លាំងថយប្រៀបបានទៅនឹងបុរស ដែលធ្លាក់ចុះទៅក្នុងជ្រោះ មិនអាចជាទីពំនាក់អាស្រ័យរបស់បុគ្គលដទៃបានទេ ។

ចំណែកសុទ្ធដ្ឋករូប ដែលមានចិត្តជាសមុដ្ឋាន ចាប់ដើមអំពីភវង្គចិត្តដំបូង តអំពីបដិសន្ធិ រមែងប្រាដក ។ រូបមានសម្លេងជាគំរប់ ៩ ប្រាកដអំពីរដូវ ដែលប្រព្រឹត្តទៅខាងលើ អំពីខណៈនៃបដិសន្ធិ ក្នុងកាលជាទីកើតប្រាកដ នៃសទ្ទរូបផងអំពីចិត្តផង ។ ក៏សត្វដែលដេកនៅហើយក្នុងផ្ទៃទាំងឡាយណា មានការចូលទៅចិញ្ចឹមជីវិត ដោយអាហារជាពំនូត សុទ្ធដ្ឋករូប មានអាហារជាសមុដ្ឋាន (កើតប្រាកដ) ក្នុងសរីរៈនៃសត្វដែលដេក ក្នុងផ្ទៃទាំងឡាយនោះ ដែលជ្រួតជ្រាបចូលទៅហើយដោយអាហារដែលមាតាលេបចូលទៅហើយ ក្នុងកាលជាទីលេបចូលទៅនូវទឹកមាត់ ដែលតាំងនៅហើយ ក្នុងមាត់របស់ខ្លួន ជាដំបូងបង្អស់នៃឱបបាតិកកំណើតទាំងឡាយ ព្រោះព្រះពុទ្ធដីកា ថា :

បើមាតារបស់សត្វនោះ បរិភោគនូវបាយ, ទឹក និង
ភោជនណា, សត្វនោះ ដែលតាំងនៅហើយ ក្នុង
ផ្ទៃនៃមាតា តែងញ៉ាំងអត្តភាព ឲ្យប្រព្រឹត្តទៅ ក្នុង
ផ្ទៃមាតានោះ ដោយវត្ថុមានបាយជាដើមនោះ ។

ធម៌ទាំង ៩៩ ដោយបំព្រួញ គឺ រូបមាន ៩៦ ប្រការនេះ គឺ ២៦ ប្រការ ដោយអំណាច នៃសុទ្ធដ្ឋករូប មានអាហារជាសមុដ្ឋាននេះផង នៃនវករូបទាំងឡាយ២ ដោយថ្នាក់ខ្ពស់ មានរដូវនិងចិត្ត ជាសមុដ្ឋានផង មាន ៧០ ប្រការដែលមានកម្មជាសមុដ្ឋាន កាលកើតឡើង អស់វារៈបីផង ក្នុងខណៈនៃចិត្តតែមួយ ក្នុងកាលមុន ដែលព្រះមានព្រះភាគទ្រង់ត្រាស់ហើយផង គឺខន្ធទាំងឡាយ ៣ មិនមានរូបផង ។ ម្យ៉ាងទៀត សទ្ទរូប មិនទៀងទាត់ ព្រោះភាពនៃសទ្ទរូប កើតប្រាកដ ក្នុងកាលខ្លះប៉ុណ្ណោះ ព្រោះហេតុណា, ព្រោះហេតុនោះ ធម៌ទាំងឡាយ ៩៧ នេះ ដកចេញ នូវធម៌ពីរប្រការនោះ គឺបណ្ឌិតគប្បីជ្រាបថា: នាមរូប (កើតព្រម) ព្រោះមានវិញ្ញាណ ជាបច្ច័យ របស់សត្វទាំងពួងទាំងឡាយ តាមសមគួរដល់ការកើត ។ ព្រោះថា កាលបើសត្វទាំងឡាយនោះ ដេកលក់ក្តី ប្រមាទក្តី កាលបរិភោគក្តី កាលផឹកក្តី ធម៌ទាំងឡាយ ៩៧ ប្រការនេះ តែងប្រព្រឹត្តទៅ ក្នុងពេលថ្ងៃផង ក្នុងពេលយប់ផង ព្រោះមានវិញ្ញាណជាបច្ច័យ ។ តទៅ យើង នឹងពណ៌នា នូវភាពនៃធម៌ទាំងឡាយ ៩៧ នោះ ជាបច្ច័យនៃវិញ្ញាណនោះ ក្នុងខាងមុខ ។

បណ្តារូបទាំងឡាយនេះ កម្មជរូបណានេះ, កម្មជរូបនោះ សូម្បីការតាំងឡើងមុន ជាងរូបទាំងឡាយ ក្នុងភព, កំណើត, គតិ, ឋិតិ និង



សត្តាវាសទាំងឡាយ គឺរូបមានសមុដ្ឋានបី មិនបានជួយទប់ទល់ហើយ មិនអាចតាំងនៅបាន, រូបប្រកបដោយសមុដ្ឋានបី គឺកម្មជរូបនោះ មិនជួយទប់ទល់ហើយ ក៏មិនអាចតាំងនៅបានដែរ ។ បើតាមពិត កម្មជរូបទាំងឡាយនេះ សុទ្ធតែជាធម៌ជួយឧបត្ថម្ភគ្នា ទៅវិញទៅមក ទើបមិនធ្លាក់ចុះ រមែងតាំងនៅបាន អស់ឆ្នាំ ១ ក្តី អស់ឆ្នាំទាំងឡាយ២ ក្តី ។ល។ អស់រយៈនៃឆ្នាំក្តី ប្រព្រឹត្តទៅ ដរាបដល់អស់ទៅនៃអាយុក្តី ការអស់ទៅនៃបុណ្យក្តី របស់សត្វទាំងឡាយនោះ ដូចជាបាច់បបុសទាំងឡាយដែលឬសចាក់ដុះជាប់ហើយ ក្នុងទិសទាំង ៤ សូម្បីគឺខ្យល់បក់បោកត្រូវហើយ ក៏ស្ថិតនៅបាន និង ដូចជានាយសំពៅទាំងឡាយដែលទៅហើយ ក្នុងមហាសមុទ្រ មានសំពៅបែកធ្លាយហើយ ជាបុគ្គលមានទីពឹងបានហើយ ក្នុងឱកាសណាមួយ សូម្បីកម្លាំងនៃរលកបក់បោកហើយ ក៏ទ្រាំនៅបានដូច្នោះ ។

ក៏សេចក្តីវិនិច្ឆ័យ ក្នុងបដិច្ចសមុប្បាទនេះ គឺបណ្ឌិតគប្បីជ្រាបអំពីការប្រព្រឹត្តិទៅ ក្នុងទីទាំងឡាយ មានភពជាដើម យ៉ាងនេះ ។

(៣៩៥) ក៏សេចក្តីវិនិច្ឆ័យ ក្នុងបទមាតិកានេះថា “សង្គហៈ” មាន (ដូចតទៅនេះ) ។ នាមហ្នឹងឯងណា (កើតព្រម) ព្រោះមានវិញ្ញាណជាបច្ច័យ ក្នុងប្រវត្តិកាល និង ក្នុងបដិសន្ធិកាល ក្នុងអរូបភព និង ក្នុងការប្រព្រឹត្តិទៅ ក្នុងបញ្ចវោការភពក្តី, រូបហ្នឹងឯងណា (កើតព្រម) ព្រោះមានវិញ្ញាណជាបច្ច័យ ក្នុងអសញ្ញីភពទាំងឡាយផង និង ក្នុងការប្រព្រឹត្តិទៅ ក្នុងបញ្ចវោការភព ក្នុងទីទាំងពួងក្តី, នាមរូបណា កើតព្រម ក្នុងទីទាំងពួង ក្នុងបញ្ចវោការភព ព្រោះមានវិញ្ញាណជាបច្ច័យក្តី, នាមរូបនោះទាំងអស់ គឺលោករួបរួមហើយ ដោយឯកទេសន័យ ដោយ

*អរូប ដោយចំណែក ១ យ៉ាងនេះថា: នាមក្តី រូបក្តី នាម និង រូបក្តី ឈ្មោះថា នាមរូប គឺបណ្ឌិតគប្បីជ្រាបថា : នាមរូប (កើតព្រម) ព្រោះមានវិញ្ញាណ ជាបច្ច័យ ។*

*បើមានសំនួរថា : ពាក្យថា នាមរូប មិនគួរទេ ព្រោះមិនមាននៃវិញ្ញាណ ក្នុងអសញ្ញិកពទាំងឡាយ ។ ចម្លើយថា: នាមរូប (កើតព្រម) ព្រោះមានវិញ្ញាណ ជាបច្ច័យ មិនមែនជាមិនគួរទេ ។ ព្រោះថា :*

> វិញ្ញាណណានេះ ជាហេតុនៃនាមរូប, វិញ្ញាណនោះ គឺលោកពោលហើយ ដោយចំណែក ២ គឺ វិបាក-វិញ្ញាណ និង មិនមែនវិបាកវិញ្ញាណ ព្រោះហេតុណា ព្រោះហេតុនោះ ពាក្យថា នាមរូប (កើតព្រម) ព្រោះមានវិញ្ញាណជាបច្ច័យ ជាពាក្យត្រឹមត្រូវមែនហើយ ។

*ក៏វិញ្ញាណណា ជាហេតុនៃនាមរូប, វិញ្ញាណនោះ គឺលោកពោលហើយដោយចំណែក២ ដោយការផ្សេងគ្នានៃវិបាកវិញ្ញាណ និង មិនមែនវិបាកវិញ្ញាណ, ក៏វិញ្ញាណនេះ ក្លាយទៅជារូប កើតហើយ ព្រោះមានអភិសង្ខារដែលប្រព្រឹត្តទៅ ក្នុងបញ្ចវោការភព ដែលមានវិញ្ញាណ ជាបច្ច័យ ព្រោះភាពនៃវិញ្ញាណនោះ ជាសមុដ្ឋាននៃកម្ម ក្នុងអសញ្ញីសត្វទាំងឡាយ, វិញ្ញាណនោះ មានកម្ម ជាសមុដ្ឋាន ក្នុងខណៈនៃចិត្ត មានកុសលចិត្តជាដើម ក្នុងប្រវត្តិកាល ក្នុងបញ្ចវោការភព ដូចគ្នា ព្រោះហេតុនោះ ពាក្យថា នាមរូបនេះ (កើតព្រម) ព្រោះមានវិញ្ញាណជាបច្ច័យ ជាពាក្យត្រឹមត្រូវណាស់ហើយ ។*

*ក៏សេចក្តីវិនិច្ឆ័យ ក្នុងបដិច្ចសមុប្បាទនេះ គឺបណ្ឌិតគប្បីជ្រាប*



*ដោយសង្ខេប យ៉ាងនេះ ។ ចំណែកសេចក្តីវិនិច្ឆ័យ ត្រង់បទមាតិកានេះ ថា “បច្ចយនយា” ដូចតទៅ ។*

> វិបាកវិញ្ញាណ ជាបច្ច័យនៃនាម មាន ៩ ប្រការ, ជាបច្ច័យ នៃវត្ថុរូប មាន ៩ ប្រការ, ជាបច្ច័យនៃសេសរូប មាន ៨ ប្រការ, អភិសង្ខារវិញ្ញាណ ជាបច្ច័យនៃរូប មាន ១ ប្រការ, ឯវិញ្ញាណក្រៅពី វិបាកវិញ្ញាណ និង អភិសង្ខារវិញ្ញាណនោះ ជាបច្ច័យ នៃនាមរូបនោះៗ គួរតាមពិត ។

*ក៏នាមណានេះ បានដល់វិបាក ដែលប្រព្រឹត្តទៅក្នុងបដិសន្ធិកាលក្តី ក្នុងប្រវត្តិកាលក្តី វិបាកវិញ្ញាណ ជាបដិសន្ធិដទៃក្តី នៃនាមនោះដែលលាយឡំដោយរូបក្តី ដែលមិនលាយឡំក្តី ជាបច្ច័យ មាន ៩ ប្រការ ដោយសហជាតប្បច្ច័យ, អញ្ញមញ្ញប្បច្ច័យ, និស្សយប្បច្ច័យ, សម្បយុត្តប្បច្ច័យ, វិបាកប្បច្ច័យ, អាហារប្បច្ច័យ, ឥន្ទ្រិយប្បច្ច័យ, អត្ថិប្បច្ច័យ និង អវិគតប្បច្ច័យទាំងឡាយ, វិបាកវិញ្ញាណ នៃវត្ថុរូបក្នុងបដិសន្ធិកាល មាន ៩ ប្រការ ដោយសហជាតប្បច្ច័យ, អញ្ញមញ្ញ-ប្បច្ច័យ, និស្សយប្បច្ច័យ, វិបាកប្បច្ច័យ, អាហារប្បច្ច័យ, ឥន្ទ្រិយ-ប្បច្ច័យ, វិប្បយុត្តប្បច្ច័យ, អត្ថិប្បច្ច័យ និង អវិគតប្បច្ច័យទាំងឡាយ, តែថា វិបាកវិញ្ញាណ ជាបច្ច័យនៃរូបដ៏សេស លើកលែងតែវត្ថុរូប ដកចេញនូវបណ្តាបច្ច័យទាំងឡាយ ៩ នេះ អញ្ញមញ្ញប្បច្ច័យ ដោយបច្ច័យទាំងឡាយ ៨ ដ៏សេស ។ ចំណែកខាងអភិសង្ខារវិញ្ញាណ ជាបច្ច័យនៃរូបអសញ្ញីសត្វផង នៃកម្មជរូប ក្នុងបញ្ចវោការភពផង មានតែមួយ*

ដោយអំណាច នៃឧបនិស្សយប្បច្ច័យតែប៉ុណ្ណោះ តាមបែបដែលមានក្នុងព្រះសូត្រ ។ វិញ្ញាណដ៏សេសទាំងអស់ ចាប់ដើមអំពីភវង្គជាដំបូង គឺបណ្ឌិតគប្បីជ្រាបថា ជាបច្ច័យនៃនាមរូបនោះៗ តាមសមគួរដល់កាល។ កាលសំដែងបង្ហាញបច្ចយន័យ នៃនាមរូបនោះ ដោយពិស្តារ គឺបណ្ឌិតគប្បីធ្វើបដ្ឋានកថាទាំងអស់ឲ្យពិស្តារ ព្រោះហេតុនោះ យើងមិនប្រារព្ធនូវសេចក្តីពិស្តារនោះទេ ។

សំណួរថា : ចុះក៏ពាក្យនេះ គឺយើងគប្បីជ្រាបបាន ក្នុងអធិការនេះថា: បដិសន្ធិ និង នាមរូប កើតឡើងបាន ព្រោះមានវិញ្ញាណជាបច្ច័យ តើដូចម្តេច? ។ ចម្លើយថា: ពាក្យដែលអ្នកពោលហើយ តាមព្រះសូត្រផង តាមពាក្យប្រកបផង ។ ព្រោះថា ក្នុងព្រះសូត្រ ភាពនៃធម៌ទាំងឡាយមានវេទនាជាដើម មានវិញ្ញាណជាបច្ច័យ សំរេចហើយ ដោយចំណែកច្រើន ដោយន័យមានន័យថា : ធម៌ទាំងឡាយ មានការប្រព្រឹត្តិទៅតាមនូវចិត្ត ។ បើនិយាយតាមពាក្យគួរវិញ ពាក្យនេះ គឺអាចារ្យពោលហើយ ថា :

> សេចក្តីថា វិញ្ញាណ រមែងសំរេច ដោយរូប
> ដែលកើតអំពីចិត្ត ដែលសត្វឃើញហើយ ក្នុង
> លោកនេះ ក៏ជាបច្ច័យនៃរូបដែលសត្វ មិនបាន
> ឃើញហើយ ។

ព្រោះថា ដោយន័យនេះ ថា : កាលបើចិត្តជ្រះថ្លាក្តី មិនជ្រះថ្លាក្តី រូបទាំងឡាយ ដ៏សមគួរដល់ចិត្តនោះ កាលកើតឡើង ឈ្មោះថា រូបដែលមើលឃើញហើយ និង ការដឹងតាមនូវរូប ដែលសត្វមើលមិន



ឃើញហើយ ដោយរូបដែលសត្វបានឃើញហើយ ដូច្នេះ ពាក្យនេះថា “វិញ្ញាណ ជាបច្ច័យនៃបដិសន្ធិរូប សូម្បីគឺវិញ្ញាណ មើលមិនឃើញ” ដូច្នេះ បណ្ឌិតគប្បីជ្រាប ដោយចិត្តជរូបដែលគួរឃើញ ក្នុងលោកនេះ ។ ភាពនៃរូបនោះ សូម្បីដែលមានកម្ម ជាសមុដ្ឋាន ក៏មានវិញ្ញាណជាបច្ច័យដូចជារូប ដែលមានចិត្ត ជាសមុដ្ឋាន មានមកហើយ ក្នុងបដ្ឋាន ។ ក៏សេចក្តីវិនិច្ឆ័យ ក្នុងបទថា “វិញ្ញាណប្បច្ចយា នាមរូបំ” នេះ គឺបណ្ឌិតគប្បីជ្រាប តាមន័យនៃបច្ច័យយ៉ាងនេះដូច្នេះឯង ។ ពាក្យនេះជាពាក្យដ៏ពិស្តារក្នុងបទថា “នាមរូប (កើតព្រម) ព្រោះមានវិញ្ញាណជាបច្ច័យ”។

៣៩៦) សេចក្តីវិនិច្ឆ័យ ត្រង់បទថា “សឡាយតនៈ (កើតព្រម) ព្រោះមាននាមរូបជាបច្ច័យ” គឺបណ្ឌិតគប្បីជ្រាប ដូចតទៅនេះ ។

> ប្រជុំបីនៃខន្ធ ឈ្មោះថា នាម, រូបមានភូតរូប និង
> វត្ថុរូបជាដើមនេះ ឈ្មោះថា រូប, នាមរូបនោះមាន
> ឯកសេស គឺលោកពោលហើយ ជាបច្ច័យ នៃ
> សឡាយតនៈនោះ ប្រាកដដូចជានោះដែរ ។

សេចក្តីថា: នាមរូប ជាបច្ច័យនៃសឡាយតនៈ នេះឯណា ក្នុងនាមរូបនោះ ។ ពួកបីនៃខន្ធមានវេទនាខន្ធជាដើម ហៅថា នាម ។ ចំណែកខាងរូបដែលលោករាប់បញ្ចូលហើយ ក្នុងសន្តតិរបស់ខ្លួន មានភូតរូបនិង វត្ថុរូបជាដើមយ៉ាងនេះ គឺ ភូតរូប ៤, វត្ថុរូប ៦ ជីវិតិន្ទ្រិយ ដោយការកំណត់ ឈ្មោះថា រូប គឺបណ្ឌិត គប្បីជ្រាបថា គឺលោកពោលហើយ ។ ក៏នាមរូបនោះ មានឯកសេស គឺលោកធ្វើហើយ យ៉ាងនេះថា នាមក្តី រូបក្តី នាមរូបក្តី ឈ្មោះថា នាមរូប, ឆដ្ឋាយតនៈក្តី សឡាយតនៈ

ក្តី ឈ្មោះថា សឡាយតនៈ, ព្រោះហេតុនោះ អាយតនៈនោះ ជាបច្ច័យនៃសឡាយតនៈ មានឯកសេសគឺលោកពោលហើយយ៉ាងនេះ បណ្ឌិតគប្បីជ្រាបផងចុះ ។ សួរថា: តើព្រោះហេតុអ្វី? ។ ឆ្លើយថា: ព្រោះថា នាមហ្នឹងឯង ជាបច្ច័យក្នុងអារូប្បភព, ក៏នាមនោះ ជាបច្ច័យនៃឆដ្ឋាយតនៈតែប៉ុណ្ណោះ មិនមែនជាបច្ច័យនៃអាយតនៈដទៃទេ ។ ក៏ពាក្យថា ឆដ្ឋាយតនៈ (កើតព្រម) ព្រោះមាននាមជាបច្ច័យ គឺព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ក្នុងវិភង្គ ។

អាចារ្យអ្នកចោទ ក៏គប្បីចោទ ក្នុងបទថា "ឆដ្ឋាយតនៈ" នោះ ថា ចុះពាក្យនេះថា: "នាមរូប ជាបច្ច័យនៃសឡាយតនៈ" តើយើងគប្បីដឹងយ៉ាងដូចម្តេចបាន? ។ អាចារ្យអ្នកឆ្លើយ គប្បីឆ្លើយថា : នាមរូប ជាបច្ច័យនៃសឡាយតនៈ យើងគប្បីដឹង ព្រោះភាព(ដែលវាកើតមាន) ក្នុងភាពនៃនាម និង រូប(កើតមាន) ។ ព្រោះថា កាលបើមាននាម និង រូបនោះៗ អាយតនៈនោះទើបមាន, មិនមែនមានដោយប្រការដទៃឡើយ ។ ក៏ភាពនៃអាយតនៈនោះមាន ព្រោះភាពនៃនាម និង រូបនោះ មានដែរនឹងមានមកប្រាកដ ក្នុងបច្ចយន័យ ។ ព្រោះហេតុនោះ

នាមរូបណា ជាបច្ច័យនៃសឡាយតនៈណា មាន
ក្នុងបដិសន្ធិក្តី ក្នុងប្រវត្តិកាលក្តី និង ជាបច្ច័យ
ដោយប្រការណា, នាមរូបនោះ គឺអ្នកមាន
បញ្ញាគប្បីជ្រាប ដោយប្រការនោះ ។

ក្នុងគាថានោះ មានសេចក្តីបំភ្លឺដូចតទៅនេះ

សេចក្តីថា នាមហ្នឹងឯង ជាបច្ច័យ ក្នុងអារូប្បភព
ក្នុងបដិសន្ធិកាល និង ប្រវត្តិកាលទាំងឡាយ,



នាមនោះ ជាបច្ច័យ មាន ដោយចំណែក ៧
ដោយចំណែក ៦ ដោយចំណែកខាងទាប ។

សំណួរថា : តើព្រោះហេតុអ្វី? ។ ចម្លើយថា : នាម ជាបច្ច័យនៃឆដ្ឋាយតនៈ ដោយចំណែក ៧ ដោយសហជាតប្បច្ច័យ, អញ្ញមញ្ញប្បច្ច័យ, និស្សយប្បច្ច័យ, សម្បយុត្តប្បច្ច័យ, វិបាកប្បច្ច័យ, អត្ថិប្បច្ច័យ និង អវិគតប្បច្ច័យទាំងឡាយ ដោយចំណែកខាងទាប ក្នុងបដិសន្ធិកាលមុន ។ ក៏ក្នុងបដិសន្ធិកាលនេះ នាមខ្លះ ជាបច្ច័យ ដោយហេតុបច្ច័យ, នាមខ្លះ ជាបច្ច័យដោយអាហារជាបច្ច័យ ព្រោះហេតុនោះ នាមនោះ ជាបច្ច័យ ដោយឡែកយ៉ាងនេះ ។ ចំណែកខាងខ្ពស់និងខាងទាប ដោយអំណាចនៃហេតុបច្ច័យនោះ គឺបណ្ឌិតគប្បីជ្រាបផងចុះ ។ នាមដែលជាវិបាក ជាបច្ច័យ ក្នុងប្រវត្តិកាល តាមន័យដែលលោកពោលហើយ។ តែបើពោលតាមចំណែកខាងទាប ក្នុងបច្ច័យទាំងឡាយមានប្រការដូចពោលមកហើយ នាមក្រៅពីនេះ ជាបច្ច័យ ដោយបច្ច័យទាំងឡាយ ៦ ដែលវៀរហើយចាកវិបាកបច្ច័យ ។ ក៏ក្នុងបដិសន្ធិកាល នាមខ្លះ ជាបច្ច័យដោយហេតុជាបច្ច័យ, នាមខ្លះ ជាបច្ច័យដោយអាហារជាបច្ច័យ ព្រោះហេតុនោះ អវិបាកនាមនោះ ជាបច្ច័យ ដោយឡែកយ៉ាងនេះ ។ ចំណែកខាងខ្ពស់ និង ចំណែកខាងទាប គឺបណ្ឌិតគប្បីជ្រាប ដោយអំណាច នៃហេតុបច្ច័យជាដើមនោះ ។

នាមជាបច្ច័យនៃអាយតនៈទី ៦ ក្នុងភពដទៃ, ក្នុង
បដិសន្ធិកាល ក៏ដូចគ្នាដែរ, នាមនោះ ជាបច្ច័យ
នៃអាយតនៈក្រៅអំពីនេះ ដោយអាការៈទាំង ៦ ។

ក៏សូម្បីក្នុងភពដទៃក្រៅពីអរូបភព គឺក្នុងបញ្ចវោការភព វិបាកនាមនោះ ជានាមរូមគ្នា ដោយហទយវត្ថុ ជាបច្ច័យនៃអាយតនៈ ទី៦ គឺមនាយតនៈ ដោយចំណែក ៧ ដោយថ្នាក់ទាប ដោយបការដែលលោកពោលហើយក្នុងអរូប្ប ។ តែវិបាកនាមនោះ ជានាមរួមគ្នា ដោយមហាភូតរូប ៤ ជាបច្ច័យនៃអាយតនៈទាំងឡាយ មានចក្ខាយតនៈជាដើម, ៥ ក្រៅពីនេះ ជាបច្ច័យ ដោយអាការៈ ៦ ដោយអំណាចសហជាតប្បច្ច័យ, និស្សយប្បច្ច័យ, វិបាកប្បច្ច័យ, វិប្បយុត្តប្បច្ច័យ, អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ ។ ក៏ក្នុងបដិសន្ធិកាលនេះ វិបាកនាមពួកខ្លះ ជាបច្ច័យដោយហេតុប្បច្ច័យ, វិបាកនាមពួកខ្លះ ជាបច្ច័យ ដោយអាហារប្បច្ច័យ ព្រោះហេតុនោះ វិបាកនាម ជាបច្ច័យ ដោយឡែកអំពីគ្នាយ៉ាងនេះ ។ ចំណែកខាងខ្ពស់ និង ចំណែកខាងទាប គឺបណ្ឌិត គប្បីជ្រាប ដោយអំណាចនៃហេតុប្បច្ច័យជាដើមនោះ ។

វិបាកនាម ជាបច្ច័យនៃអាយតនៈ ទី ៦ ជាវិបាក
មាន ក្នុងប្រវត្តិកាលដូច្នោះ អវិបាកនាមជាបច្ច័យ
នៃអាយតនៈ ទី ៦ ដែលជាអវិបាក ដោយ
ចំណែក ៦ ។

សេចក្តីថា វិបាកនាម ជាបច្ច័យនៃអាយតនៈ ទី ៦ ដែលជាវិបាក ដោយចំណែកទាបដោយចំណែក ៧ ក្នុងបញ្ចវោការភព ក្នុងប្រវត្តិកាល ដោយបការដែលវិបាកនាម ប្រព្រឹត្តទៅ ក្នុងបដិសន្ធិកាល ។ ចំណែកអវិបាកនាម ជាបច្ច័យនៃអាយតនៈ ទី៦ ដែលជាអវិបាកដោយចំណែកខាងទាបប៉ុណ្ណោះ ដោយចំណែក ៦ ព្រោះដកចេញនូវវិបាកប្បច្ច័យ អំពីបច្ច័យទាំង ៧ នោះ ។ ចំណែកក្នុងអធិការនេះ ចំណែកខាងខ្ពស់ និងខាងទាបគឺបណ្ឌិតគប្បីជ្រាប តាមន័យដែលលោកពោលហើយផងចុះ ។



វិបាកនាម ជាបច្ច័យ នៃអាយតនៈទាំងឡាយ ៥
ដ៏សេស គប្បីមាន ក្នុងបដិសន្ធិកាលនោះឯង,
ចំណែកខាងវិបាកនាម គឺលោកប្រកាសហើយ
ដោយចំណែក ៤ ដូចគ្នា យ៉ាងនេះដែរ ។

ពិតមែន វិបាកនាម មានចក្ខុប្បសាទជាដើមជាវត្ថុក្តី មានវត្ថុក្រៅនេះក្តី ជាបច្ច័យនៃអាយតនៈទាំងឡាយ ៥ មានចក្ខាយតនៈជាដើម ដ៏សេសក្នុងប្រវត្តិកាលនោះឯង ដោយចំណែក៤ ដោយបច្ឆាជាតប្បច្ច័យ, វិប្បយុត្តប្បច្ច័យ, អត្ថិប្បច្ច័យ និង អវិគតប្បច្ច័យទាំងឡាយ។ ចំណែកខាងវិបាកនាម ជាបច្ច័យ យ៉ាងណា, ឯអវិបាកនាម គឺលោកប្រកាសហើយយ៉ាងនោះ, ព្រោះហេតុនោះ សូម្បីប្រភេទនៃនាម មានកុសលជាដើម គឺបណ្ឌិតគប្បីជ្រាបថា ជាបច្ច័យនៃអាយតនៈទាំងឡាយនោះ ដោយចំណែក ៤ ។ នាមហ្នឹងឯង ជាបច្ច័យនៃអាយតនៈណាៗ ក្នុងបដិសន្ធិកាលក្តី ក្នុងប្រវត្តិកាលក្តី, ក៏នាម ជាបច្ច័យ យ៉ាងណា, បណ្ឌិតគប្បីជ្រាប យ៉ាងនោះ ត្រឹមតែប៉ុណ្ណោះឯង ។

ក៏រូបជាបច្ច័យ កើតក្នុងអារុប្បភពនេះ, ឯរូបនោះ
មិនមែនជាបច្ច័យក្នុងភពមានខន្ធ ៥ នៃអាយតនៈ
១ ទេ ។ រូប ជាវត្ថុ ជាបច្ច័យ នៃអាយតនៈ ទី ៦
មាន ដោយចំណែក ៦ ក្នុងបដិសន្ធិកាល អំពី

រូប, ភូតរូបទាំងឡាយ ជាបច្ច័យ នៃអាយតនៈទាំង
ឡាយ ៥ មាន ៤ ដោយមិនប្លែកគ្នាឡើយ ។

*បើពោលតាមរូប វត្ថុរូបក្នុងបដិសន្ធិកាល ជាបច្ច័យនៃមនាយតនៈទី ៦ ដោយប្រការ ៦ ដោយសហជាតប្បច្ច័យ, អញ្ញមញ្ញប្បច្ច័យ, និស្សយប្បច្ច័យ, វិប្បយុត្តប្បច្ច័យ, អត្ថិប្បច្ច័យ និង អវិគតប្បច្ច័យទាំងឡាយ ។ ចំណែកខាង ភូតរូបទាំងឡាយ ៤ ជាបច្ច័យ នៃអាយតនៈទាំងឡាយ ៥ មានចក្ខាយតនៈជាដើម ដោយចំណែក ៤ ដោយសហជាតប្បច្ច័យ, និស្សយប្បច្ច័យ, អត្ថិប្បច្ច័យ និង អវិគតប្បច្ច័យទាំងឡាយ ដោយអំណាចនៃអាយតនៈណាៗ កើតឡើង ក្នុងបដិសន្ធិកាលផង ក្នុងប្រវត្តិកាលផង ដោយមិនប្លែកគ្នា អាយតនៈនោះៗ ។*

ជីវិតរូប និង អាហាររូប ជាបច្ច័យ នៃអាយតនៈ
ទាំងឡាយ ៥ នេះ ដោយចំណែក ៣ ក្នុងប្រវត្តិ-
កាល, អាយតនៈទាំងឡាយ៥ នោះឯង ជាបច្ច័យ
នៃអាយតនៈ ទី៦ ដោយចំណែក ៦, វត្ថុរូប ជា
បច្ច័យ នៃអាយតនៈនោះឯង ដោយចំណែក ៥ ។

*ចំណែកខាង រូបជីវិត នៃអាយតនៈទាំងឡាយ ៥ មានចក្ខាយតនៈជាដើមនេះ ជាបច្ច័យ ក្នុងបដិសន្ធិកាលផង ក្នុងប្រវត្តិកាលផង ដោយចំណែក ៣ ដោយអំណាចអត្ថិប្បច្ច័យ, អវិគតប្បច្ច័យ និង ឥន្ទ្រិយប្បច្ច័យ ។ បទថា* “អាហារោ ច” *សេចក្ដីថា: ចំណែកខាងអាហារ ជាបច្ច័យ ដោយចំណែក ៣ ដោយអំណាចនៃអត្ថិប្បច្ច័យ, អវិគតប្បច្ច័យ និង អាហារប្បច្ច័យ ។*



*ចំណែកខាងអាហារនោះ ជាបច្ច័យ មាន ក្នុងប្រវត្តិកាល ក្នុងកាយដែលជ្រួតជ្រាប ដោយអាហារ នៃសត្វទាំងឡាយណា រស់នៅ ដោយអាហារ, សត្វទាំងឡាយនោះ មិនមែនជាបច្ច័យ ក្នុងបដិសន្ធិកាល ។ ក៏អាយតនៈទាំងឡាយ ៥ នោះ មានចក្ខាយតនៈជាដើម ជាបច្ច័យនៃមនាយតនៈ បានដល់ ចក្ខុវិញ្ញាណ, សោតវិញ្ញាណ, ឃានវិញ្ញាណ, ជិវ្ហាវិញ្ញាណ និង កាយវិញ្ញាណទី ៦ ក្នុងប្រវត្តិកាល ដោយអាការៈទាំងឡាយ ៦ ដោយអំណាច នៃនិស្សយប្បច្ច័យ, បុរេជាតប្បច្ច័យ, ឥន្ទ្រិយប្បច្ច័យ, វិប្បយុត្តប្បច្ច័យ, អត្ថិប្បច្ច័យ និង អវិគតប្បច្ច័យ មិនមែន ក្នុងបដិសន្ធិកាលទេ ។ ចំណែកខាងវត្ថុរូប ជាបច្ច័យនៃមនាយតនៈដ៏សេសនោះឯង លើកលែងតែវិញ្ញាណទាំងឡាយ ៥ ជាបច្ច័យ ក្នុងប្រវត្តិកាល ដោយចំណែក ៥ ដោយអំណាច នៃនិស្សយប្បច្ច័យ, បុរេជាតប្បច័យ, វិប្បយុត្តប្បច្ច័យ, អត្ថិប្បច្ច័យ និង អវិគតប្បច្ច័យ មិនមែន ក្នុងបដិសន្ធិកាលទេ ។ រូបហ្នឹងឯង ជាបច្ច័យ នៃអាយតនៈណាៗ ក្នុងបដិសន្ធិកាលក្តី ក្នុងប្រវត្តិកាលក្តី, រូប ជាបច្ច័យ ដោយប្រការយ៉ាងណា, បណ្ឌិតគប្បីជ្រាប ដោយប្រការយ៉ាងនោះ ។*

ក៏នាម និង រូបទាំង ២ ណា ជាបច្ច័យ នៃអាយតនៈ
ណា និង មាន ដោយប្រការណា, នាមរូបនោះឯង
គឺបណ្ឌិត គប្បីជ្រាប ក្នុងភពទាំងឡាយទាំងពួង
ដោយប្រការនោះ ។

*សំណួរថា : តើដោយប្រការដូចម្ដេចខ្លះ? ។ ចម្លើយថា : នាមរូប*

*បានដល់ វត្ថុរូបក្នុងប្រជុំនៃខន្ធ ៣ ក្នុងបញ្ចវោការភព ត្រង់បដិសន្ធិកាល មុនគេ ជាបច្ច័យនៃអាយតនៈ ទី៦ ដោយបច្ច័យទាំងឡាយ មានសហជាតប្បច្ច័យ, អញ្ញមញ្ញប្បច្ច័យ, និស្សយប្បច្ច័យ, វិបាកប្បច្ច័យ សម្បយុត្តប្បច្ច័យ, វិប្បយុត្តប្បច្ច័យ, អត្ថិប្បច្ច័យ និង អវិគតប្បច្ច័យ ជាដើម ព្រោះហេតុនោះ ពាក្យនេះ គ្រាន់តែជាបង្គោល ត្រង់ភាវៈនៃនាមរូបជាបច្ច័យនេះ, ប៉ុន្តែគឺអ្នកណាអាចដើម្បីបែងចែក តាមលំអាននៃន័យ ដែលខ្ញុំពោលហើយ ឲ្យសព្វគ្រប់បាន ព្រោះហេតុនោះ សេចក្តីពិស្តារ គឺខ្ញុំមិនពោលហើយ ក្នុងភាពនៃនាមរូបជាបច្ច័យនេះ ។ ការពោលដោយពិស្តារ ត្រង់បទថា* “សឡាយតនៈ (កើតព្រម) ព្រោះមាននាមរូបជាបច្ច័យ” *ចប់ហើយ ។*

*(៣៩៧) សេចក្តីវិនិច្ឆ័យ ត្រង់បទថា* “ផស្សៈ (កើតព្រម) ព្រោះមានអាយតនៈ ៦ ជាបច្ច័យ” *គឺបណ្ឌិតគប្បីជ្រាប ដូចតទៅនេះ ។*

> ផស្សៈទាំងឡាយ មានចក្ខុសម្ផស្សជាដើម មាន ៦
> គត់ ដោយសង្ខេប, (បើពោល) ដោយពិស្តារ
> ផស្សៈទាំងនោះ មាន ៣២ ដូចជាវិញ្ញាណដែរ ។

*បើពោលដោយសង្ខេបក្នុងបទថា:* “សឡាយតនប្បច្ចយា ផស្សោ” *ផស្សៈទាំងឡាយនេះ ៦ គត់ មានចក្ខុសម្ផស្សជាដើម គឺចក្ខុសម្ផស្ស ១, សោតសម្ផស្ស ១, ឃានសម្ផស្ស ១, ជិវ្ហាសម្ផស្ស១, កាយសម្ផស្ស ១, មនោសម្ផស្ស ១ ។ បើពោលដោយពិស្តារ សម្ផស្សទាំងឡាយ មានចក្ខុសម្ផស្សជាដើមទាំងអស់ មាន ៣២ ដូចជាវិញ្ញាណ ដែលព្រះមានព្រះភាគទ្រង់ត្រាស់ថា: (កើតព្រម) ព្រោះមានសង្ខារជាបច្ច័យ យ៉ាងនេះ គឺ*



*ផស្សៈ ១០ ដូច្នេះ គឺកុសលវិបាក ៥, អកុសលវិបាក ៥, គឺផស្សៈ ២២ ដ៏សម្បយុត្តហើយ ដោយវិបាកវិញ្ញាណជាលោកិយៈ ២២ ដ៏សេស ។ ក៏សឡាយតនៈណា ជាបច្ច័យនៃផស្សៈទាំង ៣២ នេះ, សេចក្តីវិនិច្ឆ័យ បណ្ឌិតគប្បីជ្រាប ក្នុងសឡាយតនៈនោះ*

> អ្នកប្រាជ្ញ មានប្រាជ្ញាសំរាប់ពិចារណាឃើញទាំង
> ឡាយ តែប្រាថ្នានូវអាយតនៈមានចក្ខាយតនៈ ជា
> ដើម ជាខាងក្នុង មួយអន្លើដោយអាយតនៈ ទី ៦
> ខ្លះ ប្រាថ្នា នូវអាយតនៈ ៦ មួយអន្លើដោយ
> អាយតនៈទាំងឡាយ ៦ ជាខាងក្រៅខ្លះ ។

*បណ្តាបុគ្គលអ្នកមានប្រាជ្ញាទាំងនោះ បុគ្គលអ្នកមានប្រាជ្ញាទាំងឡាយណា បំភ្លឺនូវបច្ច័យផង នូវធម៌ដែលកើតឡើងពីបច្ច័យផង ដែលរាប់បញ្ចូលហើយ ក្នុងតំណរបស់ខ្លួនថា នេះជាកថា ប្រព្រឹត្តទៅ ដោយឧបាទិន្នកសង្ខារមុន, បុគ្គលអ្នកមានប្រាជ្ញាទាំងឡាយនោះ ប្រាថ្នានូវអាយតនៈ មានចក្ខាយតនៈជាដើម ជាខាងក្នុង មួយអន្លើដោយអាយតនៈ ទី៦ ថា សឡាយតនៈ ព្រោះធ្វើអាយតនៈ ៦ ក្នុងអារុប្បភព ដោយការលើកតាមបាលីថា* “ផស្សៈ (កើតព្រម) ព្រោះមានអាយតនៈ ៦ ជាបច្ច័យ” *ផង, នូវអាយតនៈ ៦ ដោយការរួបរួមនូវអាយតនៈទាំងអស់ក្នុងភពដទៃ ឲ្យមានឯកសេសដែលលោករួបរួមហើយ ដោយឯកសេស ថា ឈ្មោះថា ជាបច្ច័យនៃផស្សៈផង ។ ព្រោះថា ពាក្យនោះដល់នូវការរាប់ថា: អាយតនៈ ទី៦ នោះក្តី សឡាយតនៈនោះក្តី ឈ្មោះថា សឡាយតនៈ ដូចគ្នា ។*

*ក៏បុគ្គលអ្នកមានប្រាជ្ញាទាំងឡាយណា បំភ្លឺនូវធម៌ដែលកើតឡើងពីបច្ច័យហ្នឹងឯងរាប់បញ្ចូលនូវមុខតំណាតែមួយរួចហើយ បំភ្លឺនូវបច្ច័យដែលមានតំណាផ្សេងគ្នា ក៏ដោយ, ពួកជនអ្នកមានប្រាជ្ញាទាំងឡាយនោះកាលបំភ្លឺ នូវអាយតនៈណាៗ ជាបច្ច័យនៃផស្សៈ អាយតនៈនោះទាំងអស់ កំណត់យកនូវអាយតនៈខាងក្រៅ ប្រាជ្ញានូវអាយតនៈជាខាងក្នុងនោះឯង មួយអន្លើដោយអាយតនៈ ទី៦ ព្រមទាំងអាយតនៈទាំងឡាយខាងក្រៅ មានរូបាយតនៈជាដើម ឈ្មោះថា សឡាយតនៈ ។ ក៏ពាក្យដែលពោលនោះឯង នាកាលសេសនៃបទមួយ នៃពាក្យទាំងឡាយនេះគឺ: ឆដ្ឋាយតនៈក្តី សឡាយតនៈក្តី ឈ្មោះថា សឡាយតនៈ គឺលោកធ្វើហើយ រមែងដល់នូវការរាប់ថា សឡាយតនៈ ដូចគ្នា ។*

*អាចារ្យអ្នកចោទ បានចោទក្នុងបទនេះថា ផស្សៈ ១ មិនកើតព្រមអំពីអាយតនៈទាំងឡាយទាំងពួងបានទេ, ផស្សៈទាំងឡាយទាំងពួង ក៏មិនកើតព្រមអំពីអាយតនៈមួយបានដែរ, ចំណែកផស្សៈតែមួយនេះ គឺព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយថា* "ផស្សៈ (កើតព្រម) ព្រោះមានសឡាយតនៈជាបច្ច័យ" *តើផស្សៈនោះ គឺព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រោះហេតុអ្វី ? ។*

*ការដោះស្រាយ ក្នុងបញ្ហាកម្មនោះ ដូចតទៅនេះ ពាក្យនេះថា: ផស្សៈ ១ កើតព្រមដោយអាយតនៈទាំងឡាយទាំងពួង មិនបាន ឬក៏ផស្សៈទាំងឡាយទាំងពួង មិនកើតព្រមអំពីអាយតនៈ ១ នោះពិត, តែផស្សៈ ១ កើតព្រម ដោយអាយតនៈទាំងឡាយ ដ៏ច្រើនបាន ដូចជាចក្ខុសម្ផស្ស (កាលកើតព្រម) អំពីចក្ខាយតនៈផង អំពីរូបាយតនៈផងពីមនាយតនៈ ពោលគឺចក្ខុវិញ្ញាណផង, ពីធម្មាយតនៈ ដែលសម្បយុត្ត*



*ដោយធម៌ដ៏សេសផង គឺបណ្ឌិតគប្បីប្រកប ក្នុងផស្សៈទាំងឡាយ មានសោតសម្ផស្សជាដើមទាំងពួងយ៉ាងនេះ តាមសមគួរដល់ការប្រកប ។*

*ក៏ព្រោះហេតុនោះឯង*

> ផស្សៈនេះ តែមួយគត់ ក្នុងបទថា "សឡាយតន-
> ប្បច្ចយា ផស្សោ" នេះ គឺព្រះពុទ្ធជាបុគ្គលនឹង
> នួនទ្រង់បំភ្លឺហើយ ថា ផស្សៈ ១ មានអាយតនៈ
> ច្រើនយ៉ាង ជាដែនកើត ដោយការចង្អុលបង្ហាញ
> នូវពាក្យមួយម៉ាត់ ។

*អត្ថាធិប្បាយត្រង់បទថា* "ឯកវចននិទ្ទេសេន" *សេចក្តីថា ផស្សៈ ១ គឺព្រះមានព្រះភាគទ្រង់ជាអ្នកនឹងនួន ទ្រង់បំភ្លឺហើយថា មានដោយអាយតនៈទាំងឡាយដ៏ច្រើន ដោយការសំដែងចេញ នូវពាក្យមួយម៉ាត់នេះថា ផស្សៈ (កើតព្រម) ព្រោះមានសឡាយតនៈជាបច្ច័យ ។*

*ក៏បណ្តាអាយតនៈទាំងឡាយ*

> បណ្ឌិត គប្បីពន្យល់អាយតនៈទាំងឡាយ ៥ ក្នុង
> ភាវៈជាបច្ច័យ នៃផស្សៈនោះ ដោយចំណែក ៦,
> បន្ទាប់អំពីនោះ គប្បីពន្យល់មនាយតនៈ ១ ក្នុង
> ភាវៈជាបច្ច័យ នៃផស្សៈនោះ ដោយចំណែក ៩,
> គប្បីពន្យល់អាយតនៈទាំងឡាយ ៦ ពួដ៏ខាងក្រៅ
> ដោយបច្ច័យនៃផស្សៈ តាមសមគួរដល់ការកើត ។

*នេះ គឺជាវាចា ជាគ្រឿងពន្យល់ ក្នុងគាថានោះ ។ អាយតនៈទាំង*

*៥ មានចក្ខាយតនៈជាដើម ជាបច្ច័យនៃផស្សៈ មាន ៥ ប្រការ ដោយប្រភេទនៃសម្ផស្ស មានចក្ខុសម្ផស្សជាដើម ដោយប្រការ ៦ ដោយនិស្សយប្បច្ច័យ, បុរេជាតប្បច្ច័យ, ឥន្ទ្រិយប្បច្ច័យ, វិប្បយុត្តប្បច្ច័យ, អត្ថិប្បច្ច័យ និង អវិគតប្បច្ច័យ មុន ៗ ខាងមុខអំពីអាយតនៈនោះទៅ អាយតនៈ ១ គឺ វិបាកមនាយតនៈ ជាបច្ច័យនៃវិបាកមនោសម្ផស្ស មានច្រើនប្រភេទ ដោយប្រការ ៩ ដោយអំណាចសហជាតប្បច្ច័យ, អញ្ញមញ្ញប្បច្ច័យ, និស្សយប្បច្ច័យ, វិបាកប្បច្ច័យ, អាហារប្បច្ច័យ, ឥន្ទ្រិយប្បច្ច័យ, សម្បយុត្តប្បច្ច័យ, អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ ។ ចំណែកបណ្ដាអាយតនៈទាំងឡាយខាងក្រៅ រូបាយតនៈ ជាបច្ច័យ នៃចក្ខុសម្ផស្ស ដោយប្រការ ៤ ដោយអំណាចនៃអារម្មណប្បច្ច័យ, បុរេជាតប្បច្ច័យ, អត្ថិប្បច្ច័យ និង អវិគតប្បច្ច័យ, អាយតនៈទាំងឡាយ មានសទ្ទាយតនៈជាដើម ជាបច្ច័យនៃសម្ផស្សទាំងឡាយមានសោតសម្ផស្សជាដើម ដូចគ្នា, ក៏អាយតនៈទាំងឡាយនោះក្ដី ធម្មារម្មណ៍ក្ដី ជាបច្ច័យដោយបការដូច្នេះផង ដោយគ្រាន់តែជាបច្ច័យនៃអារម្មណ៍ផង ព្រោះហេតុនោះ បណ្ឌិត គប្បីពន្យល់នូវអាយតនៈទាំងឡាយ៦ ខាងក្រៅ ក្នុងភាពនៃអាតយនៈនេះ ជាបច្ច័យនៃផស្សៈនោះ គួរដល់ការកើតឡើង ៗ ការពោល ដោយពិស្ដារ ក្នុងបទថា:* “ផស្សៈ (កើតព្រម) ព្រោះមានសឡាយនៈ ជាបច្ច័យ” *ចប់ហើយ ៗ*

*(៣៩៨) សេចក្ដីវិនិច្ឆ័យត្រង់បទថា* “វេទនា (កើតព្រម) ព្រោះមានផស្សៈជាបច្ច័យ” *គឺបណ្ឌិតគប្បីជ្រាប ដូចតទៅនេះ :*

វេទនាទាំងឡាយ មានវេទនាដែលកើតអំពីចក្ខុសម្ផស្ស



ជាដើម គឺព្រះមានព្រះភាគ ទ្រង់ត្រាស់ ដោយទ្វារមានតែប្រាំមួយទេ, ប៉ុន្តែវេទនាទាំងនោះ គឺព្រះមានព្រះភាគ ទ្រង់ត្រាស់ថា មានដល់ទៅ ៨៩ តាមប្រភេទ ។

*សេចក្ដីថា : វេទនាទាំងឡាយ ៦ គត់ ក្នុងវិភង្គនៃបទនេះ គឺព្រះមានព្រះភាគទ្រង់សំដែងហើយតាមទ្វារ យ៉ាងនេះ គឺ: វេទនាដែលកើតអំពីចក្ខុសម្ផស្ស, វេទនាដែលកើតអំពីសោតសម្ផស្ស, ឃានសម្ផស្ស, ជិវ្ហាសម្ផស្ស, កាយសម្ផស្ស និង មនោសម្ផស្ស ៗ តែវេទនាទាំងឡាយនោះ គឺព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយថា មាន ៨៩ ព្រោះភាពនៃវេទនាទាំងនោះ សម្បយុត្តដោយចិត្តទាំងឡាយ ៨៩ ដួង តាមប្រភេទ ៗ*

តែបណ្ដាវេទនាទាំងឡាយនោះ វេទនាទាំងឡាយ ៣២ សុទ្ធតែប្រកបហើយ ដោយវិបាកចិត្ត គឺលោកពោលហើយថា ជាវេទនាដែលព្រះមានព្រះភាគ ទ្រង់ប៉ងយកហើយ ក្នុងបទនេះ ។ ក្នុងវេទនាទាំងនោះ ផស្សៈ ជាបច្ច័យ នៃវេទនាទាំងឡាយ ៥ ក្នុងទ្វារ ៥ ដោយប្រការ ៨ ជាបច្ច័យនៃវេទនាទាំងឡាយ ដ៏សេស ដោយចំណែក ១ ផស្សៈនោះ (ជាបច្ច័យនៃវេទនា) សូម្បីក្នុងមនោទ្វារ ក៏ដូចគ្នាដែរ ។

*មែនពិត ផស្សៈ មានចក្ខុសម្ផស្សជាដើម នៃវេទនាទាំងឡាយ ៥*

មានចក្ខុប្បសាទជាដើម ជាទីតាំង ក្នុងបញ្ចទ្វារ ក្នុងវេទនាទាំងនោះ ជាបច្ច័យដោយចំណែក៨ ដោយអំណាចនៃសហជាតប្បច្ច័យ, អញ្ញមញ្ញប្បច្ច័យ, និស្សយប្បច្ច័យ, វិបាកប្បច្ច័យ, អាហារប្បច្ច័យ, សម្បយុត្តប្បច្ច័យ, អត្ថិប្បច្ច័យ និង អវិគតប្បច្ច័យ។ តែផស្សៈនោះ មានចក្ខុសម្ផស្សជាដើម ជាបច្ច័យនៃវេទនា ដ៏សេស គឺជាវិបាក ជាកាមាវចរទាំងឡាយដែលប្រព្រឹត្តទៅ ក្នុងទ្វារនីមួយៗ ដោយអំណាចនៃសម្បដិច្ឆនចិត្ត សន្តីរណចិត្ត និង តទាលម្ពណចិត្ត ដោយចំណែកតែមួយ ដោយអំណាចនៃឧបនិស្សយប្បច្ច័យ ។

បទថា “មនោទ្វារេបិ សោ តថា” សេចក្តីថា ផស្សៈនោះ បានដល់មនោសម្ផស្សដែលកើតរួមគ្នា ជាបច្ច័យនៃវិបាកវេទនា ជាកាមាវចរទាំងឡាយ ដែលប្រព្រឹត្តទៅហើយ ដោយអំណាច នៃតទារម្មណចិត្ត ក្នុងមនោទ្វារហ្នឹងឯង ដោយចំណែក ៨ ដោយប្រការដូច្នោះឯង មិនតែប៉ុណ្ណោះ (ផស្សៈនោះ ជាបច្ច័យ នៃវិបាកវេទនាដែលប្រកបដោយភូមិបីដែលប្រព្រឹត្តទៅ ដោយអំណាចនៃបដិសន្ធិចិត្ត និង ភវង្គចុតិចិត្ត ។ ចំណែកកាមាវចរវេទនាណានេះ ដែលប្រព្រឹត្តទៅ ក្នុងមនោទ្វារ ដោយអំណាចនៃតទារម្មណចិត្ត, មនោសម្ផស្ស កើតព្រមហើយ ដោយមនោទ្វារាវជ្ជនៈ ជាបច្ច័យនៃវេទនាទាំងឡាយនោះ ដោយចំណែក ១ ដោយអំណាចនៃឧបនិស្សយដូច្នេះឯង ។ ពាក្យនេះ ជាពាក្យពិស្តារ ត្រង់បទថា “វេទនា (កើតព្រម) ព្រោះមានផស្សៈជាបច្ច័យ” ។

(៣៩៩) សេចក្តីវិនិច្ឆ័យ ត្រង់បទថា “តណ្ហា (កើតព្រម) ព្រោះមានវេទនា ជាបច្ច័យ” គឺបណ្ឌិត គប្បីជ្រាប ដូចតទៅនេះ :

តណ្ហាទាំងឡាយ ៦ គឺព្រះមានព្រះភាគទ្រង់ត្រាស់



បំភ្លឺហើយ ត្រង់បទថា “តណ្ហានេះ ដោយប្រភេទ
មានរូបតណ្ហាជាដើម”, បណ្តាតណ្ហាទាំងឡាយ
នោះ តណ្ហានីមួយៗ មាន ៣ ប្រការ គឺព្រះមាន
ព្រះភាគទ្រង់ត្រាស់ហើយ ដោយអាការៈ ដែល
ប្រព្រឹត្តទៅហើយ ។

សេចក្តីថា ត្រង់បទនេះ តណ្ហាទាំងឡាយ ៦ ក្នុងវិភង្គ គឺព្រះមានព្រះភាគ ទ្រង់បំភ្លឺហើយ ដោយអំណាចនៃឈ្មោះ តាមអារម្មណ៍ ដូច្នេះគឺ តណ្ហា, សទ្ទតណ្ហា, គន្ធតណ្ហា, រសតណ្ហា, ផោដ្ឋព្វតណ្ហា និងធម្មតណ្ហា ដូចជាកូន ដោយអំណាច នៃឈ្មោះអំពីបិតា គឺសេដ្ឋីបុត្ត, ព្រាហ្មណបុត្ត ដូច្នោះ ។ តែថា បណ្តាតណ្ហាទាំងនោះ តណ្ហានីមួយៗ គឺព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ដោយចំណែក ៣ យ៉ាងនេះ គឺ : កាមតណ្ហា ១ ភវតណ្ហា ១, វិភវតណ្ហា ១ ដោយអាការៈដែលប្រព្រឹត្តទៅហើយ ។

សេចក្តីថា រូបតណ្ហាហ្នឹងឯង គឺបុគ្គលកាលត្រេកអរនូវរូបារម្មណ៍ ដែលមកកាន់រង្វង់នៃចក្ខុ ប្រព្រឹត្តទៅហើយ ដោយអំណាចនៃសេចក្តីត្រេកអរ ក្នុងកាម ក្នុងកាលណា ទើបឈ្មោះថា កាមតណ្ហា ក្នុងកាលនោះ, រូបតណ្ហានោះ ប្រព្រឹត្តទៅមួយអន្លើដោយសស្សតទិដ្ឋិ ដែលប្រព្រឹត្តទៅថា: អារម្មណ៍នោះឯង ទៀងទាត់, ស្ថិតស្ថេរ ក្នុងកាលណា, ក្នុងកាលនោះ ទើបឈ្មោះថា ភវតណ្ហា, ក៏រាគៈដែលប្រព្រឹត្តទៅមួយអន្លើដោយសស្សតទិដ្ឋិ ទើបលោកហៅថា ភវតណ្ហា, ចំណែករូបតណ្ហាប្រព្រឹត្តទៅមួយអន្លើដោយឧច្ឆេទទិដ្ឋិ ដែលប្រព្រឹត្តទៅថា អារម្មណ៍នោះឯង រមែងដាច់សូន្យ វិនាស ក្នុងកាលណា, ក្នុងកាលនោះ ឈ្មោះថា

*វិភវតណ្ហា ព្រោះថា រាគៈ ប្រព្រឹត្តទៅមួយអន្លើដោយឧច្ឆេទទិដ្ឋិ ទើបលោកហៅថា វិភវតណ្ហា ។ ន័យសូម្បីក្នុងតណ្ហាទាំងឡាយ មានសទ្ទ-តណ្ហាជាដើម ដូចជាន័យនេះដែរដូច្នោះឯង ។ តណ្ហាទាំងឡាយនេះមាន ១៨ ។ តណ្ហាទាំងឡាយនោះ មាន ៣៦ គឺ តណ្ហា ១៨ ក្នុងរូបទាំងឡាយ មានរូបដែលស្ថិតនៅ ពួដ៏ខាងក្នុងជាដើមផង តណ្ហា ១៨ ដែលប្រព្រឹត្តទៅ ពួដ៏ខាងក្រៅផង ។ តណ្ហា ១០៨ ទាំងឡាយ គឺ ៣៦ ផ្នែកខាងអតីត, ៣៦ ផ្នែកខាងអនាគត, ៣៦ ផ្នែកខាងបច្ចុប្បន្ន ដូចរៀបរាប់មកនេះ ។ តណ្ហាទាំងឡាយនោះ គឺលោកកាលបំព្រួញចុះមកទៀត គប្បីជ្រាបថា: តណ្ហា មាន ៦ ដោយអំណាចនៃអារម្មណ៍មានរូបារម្មណ៍ជាដើមផង, តណ្ហាទាំងឡាយ មានត្រឹមតែ ៣ ដោយអំណាចនៃតណ្ហាមានកាមតណ្ហាជាដើមផង ។*

*សេចក្តីប្រៀបថា: ពួកសត្វនេះ ត្រេកអរនូវវេទនាដែលកើតឡើងដោយអំណាចនៃអារម្មណ៍ មានរូបារម្មណ៍ជាដើម រមែងធ្វើនូវសក្ការៈដ៏ច្រើន ដល់ជនទាំងឡាយ មានជាងគំនូរ, អ្នករបាំ, ជាង, ជនអ្នកធ្វើនូវគ្រឿងក្រអូប, អ្នកតម្បាញ, អ្នកជញ្ជក់ និង ពេទ្យអ្នកចាត់ចែងជាដីមជាអ្នកឲ្យនូវអារម្មណ៍មានរូបជាដើម ព្រោះសេចក្តីរាប់អាន ក្នុងវេទនាថា ដូចជារបស់ខ្លួន ដូចជាមាតានៃទារក កាលធ្វើនូវមហាសក្ការៈ ដល់ស្រីមេដោះ ដោយសេចក្តីរាប់អានចំពោះកូនទាំងឡាយ ដូចជាកូនរបស់ខ្លួន ព្រោះហេតុណា, ព្រោះហេតុនោះ តណ្ហាទាំងអស់នេះឯង គឺបណ្ឌិតគប្បីជ្រាបថា* “តណ្ហា មាន ព្រោះមានវេទនាជាបច្ច័យ” ។

ក៏វេទនា ដែលមានវិបាកជាសុខ លោកអធិប្បាយហើយ ក្នុងបទថា “តណ្ហា (កើតព្រម) ព្រោះមាន



វេទនាជាបច្ច័យ” នេះ ព្រោះហេតុណា, ព្រោះហេតុនោះ សុខវេទនានេះ ជាបច្ច័យ នៃតណ្ហាមានតែ ១ ដោយចំណែកមួយតែប៉ុណ្ណោះ ។

*បទថា* “ឯកធា” *សេចក្តីថា: វេទនា មានវិបាកជាសុខ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យហ្នឹងឯង ។ ន័យមួយទៀត ថា :*

ក៏បុគ្គលមានទុក្ខ តែងចង់បានសេចក្តីសុខ, អ្នកមានសេចក្តីសុខ តែងប្រាថ្នា (សេចក្តីសុខ) ដ៏ក្រៃលែង, ចំណែកខាងឧបេក្ខាវេទនា គឺព្រះមានព្រះភាគទ្រង់ត្រាស់ហើយថា ជាសុខ ដោយដាច់ខាត ព្រោះភាពនៃឧបេក្ខាវេទនា ជាធម្មជាតិ ដ៏ស្ងប់យ៉ាងក្រៃលែង, វេទនាទាំងឡាយ ៣ ហ្នឹងឯង ជាបច្ច័យនៃតណ្ហា ព្រោះហេតុណា, ព្រោះហេតុនោះ តណ្ហា មានវេទនាជាបច្ច័យ គឺព្រះមានព្រះភាគ ទ្រង់ស្វែងរកគុណដ៏ធំ ទ្រង់ត្រាស់ហើយថា តណ្ហា (កើតព្រម) ព្រោះមានវេទនាជាបច្ច័យ តែងវៀរចាកអនុសយកិលេស ព្រោះហេតុណា, ព្រោះហេតុនោះ វេទនានោះ មិនមានដល់ព្រះខីណាសវព្រាហ្មណ៍ ព្រោះលោកមានព្រហ្មចរិយធម៌ នៅចប់ហើយ ។

*សេចក្តីពោល ដោយពិស្តារ ត្រង់បទថា* “ តណ្ហា (កើតព្រម)

ព្រោះមានវេទនាជាបច្ច័យ” *ចប់ហើយ ។*

*(៤០០) សេចក្ដីវិនិច្ឆ័យ ត្រង់បទថា* “ឧបាទាន (កើតព្រម) ព្រោះមានតណ្ហាជាបច្ច័យ” *គឺបណ្ឌិត គប្បីជ្រាប ដូចតទៅនេះ :*

> ឧបាទានមាន ៤, បណ្ឌិតគប្បីពន្យល់នូវឧបាទានទាំងឡាយ ៤ នោះ ដោយការញែកសេចក្ដីផង ដោយធម៌យ៉ាងសង្ខេប និង ពិស្ដារផង ដោយលំដាប់ផង ។

*សេចក្ដីពន្យល់ ក្នុងគាថានោះ ដូចតទៅ ។ ឧបាទានទាំងឡាយ ៤ នេះ ក្នុងបទថា* “ឧបាទាន (កើតព្រម) ព្រោះមានតណ្ហាជាបច្ច័យ” *នេះ គឺកាមុបាទាន ១, ទិដ្ឋុបាទាន ១, សីលព្វតុបាទាន ១, អត្តវាទុបាទាន ១, (គឺបណ្ឌិត គប្បីជ្រាប) ជាមុន ។ ការវិភាគ នូវសេចក្ដីនៃឧបាទានទាំងឡាយនោះ ដូចតទៅនេះ :*

*កិលេសជាតណា គឺសត្វប្រកាន់មាំនូវកាម គឺវត្ថុ ព្រោះហេតុនោះ កិលេសជាតនោះ ឈ្មោះថា កាមុបាទាន ។*

*សេចក្ដីប្រាថ្នាផង ការប្រកាន់នោះផង ព្រោះហេតុនេះ ឈ្មោះថា កាមុបាទាន ។*

*ការប្រកាន់មាំ ឈ្មោះថា ឧបាទាន ។ ក៏ស័ព្ទថា* ឧប *មានសេចក្ដីថា មាំ ត្រង់បទថា* “ឧបាទាន” *ដូចជាឧបស័ព្ទ ត្រង់បទទាំងឡាយមានបទថា* “សេចក្ដីចង្អៀតចង្អល់ ចូលទៅជិតហើយ” *ដូច្នេះជាដើម ។*

*ម្យ៉ាងទៀត ទិដ្ឋិផង ការប្រកាន់មាំផង ព្រោះហេតុនោះ ការប្រកាន់មាំ គឺទិដ្ឋិ ។*



*ម្យ៉ាងវិញទៀត ធម្មជាតណា គឺជនប្រកាន់មាំនូវទិដ្ឋិ ព្រោះហេតុនោះ ធម្មជាតនោះ ឈ្មោះថា ទិដ្ឋុបាទាន ។ តួយ៉ាងដូចជា ទិដ្ឋិខាងក្រោយ គឺសត្វប្រកាន់មាំ នូវទិដ្ឋិខាងមុខ ដូចជាក្នុងប្រយោគទាំងឡាយមានប្រយោគ ថា : ខ្លួនក្ដី លោកក្ដី ទៀងទាត់ ដូច្នេះជាដើម ។*

*ម្យ៉ាងទៀត កិលេសជាត ណា គឺសត្វប្រកាន់ នូវសីល និង វត្ត ព្រោះហេតុនោះ សីល និង វត្ត នោះ កិលេសជាតនោះ ឈ្មោះថា ការប្រកាន់នូវសីល និង វត្ត (សីលព្វតុបាទាន) ។*

*សីល និង វត្ត នោះផង ជាគ្រឿងប្រកាន់មាំផង ព្រោះហេតុនោះ កិលេសជាតនោះ ឈ្មោះថា សីល និង វត្ត ជាគ្រឿងប្រកាន់មាំ ។ តួយ៉ាងដូចជា កិច្ចទាំងឡាយ មានសីល របស់គោ និង វត្ត របស់គោជាដើម ជាគ្រឿងប្រកាន់មាំ ដោយខ្លួនឯង ព្រោះការប្រកាន់ស្អិត ថា : សេចក្ដីបរិសុទ្ធិ យ៉ាងនេះ ។*

*ម្យ៉ាងវិញទៀត ជនទាំងឡាយណា ពោល ដោយសភាវៈនេះ ព្រោះហេតុនោះ សភាវៈនោះ ឈ្មោះថា ជាគ្រឿងពោលនៃជន ។*

*ជនទាំងឡាយណា ប្រកាន់មាំ ដោយកិលេសជាតនេះ ព្រោះហេតុនោះ កិលេសជាតនោះ ឈ្មោះថា ជាគ្រឿងប្រកាន់មាំ នៃជន ។*

*សួរថា: សត្វទាំងឡាយណា ពោលក្ដី ប្រកាន់មាំក្ដី នូវធម៌ ថា ដូចម្ដេច? ។ ឆ្លើយថា: ពោលប្រកាន់មាំ នូវខ្លួន ។*

*ការប្រកាន់មាំនូវវាទៈ របស់ខ្លួនថា ជាខ្លួន ឈ្មោះថា ការប្រកាន់មាំនូវវាទៈ ថា ជាខ្លួន ។*

*ម្យ៉ាងទៀត សត្វទាំងឡាយណា ប្រកាន់មាំនូវហេតុត្រឹមតែការពោលនូវខ្លួន ថាខ្លួន ដោយហេតុនេះ ព្រោះហេតុដូច្នោះ សត្វទាំងឡាយ*

នោះ ឈ្មោះថា ជាគ្រឿងប្រកាន់មាំនូវពាក្យពោលថា ខ្លួន ។

ការវិភាគសេចក្តី នៃឧបាទានទាំងឡាយនោះ ចប់ត្រឹមនេះឯង ។

ក៏សេចក្តីវិនិច្ឆ័យ គឺបណ្ឌិតគប្បីជ្រាប ក្នុងបទសង្ខេប និង ពិស្តារ នៃធម៌ ។ ដំបូងបើពោលដោយសង្ខេប ភាពនៃតណ្ហាជាធម្មជាតិ ដ៏មាំ គឺលោកហៅថា កាមុបាទាន ព្រោះកាមុបាទាននេះ មកហើយ ក្នុងបាលីថា "បណ្តាឧបាទានទាំងនោះ តើកាមុបាទានដូចម្តេច? កាមច្ឆន្ទៈណាក្តី, កាមរាគក្តី, កាមនន្ទិក្តី, កាមតណ្ហាក្តី, កាមស្នេហាក្តី, កាមបរិឡាហៈក្តី, ការជ្រប់ ក្នុងកាមក្តី, ការសញ្ជប់សញ្ជឹង ក្នុងកាមក្តី ក្នុងកាមទាំងឡាយ, ការពេញចិត្ត ក្នុងកាមជាដើមនេះ គឺលោកហៅថា កាមុបាទាន" ។

តណ្ហាខាងដើម ឈ្មោះថា ជាភាពនៃតណ្ហាដ៏មាំ, តណ្ហាខាងចុងវិញ ឈ្មោះថា កើតព្រមដ៏មាំ ដោយឧបនិស្សយប្បច្ច័យ ។

ចំណែកខាង អាចារ្យទាំងឡាយពួកខ្លះ ពោលថា ការប្រាថ្នា នូវអារម្មណ៍ដែលមិនទាន់សម្រេចហើយ ឈ្មោះថា ជាតណ្ហា ដូចជាការលានូវដៃ ក្នុងទីងងឹតនៃចោរ, ឧបាទាន មានការកាន់យកនូវអារម្មណ៍ដែលដល់ព្រមហើយ ដូចជាការកាន់យកនូវទ្រព្យនៃចោរនោះឯង, មិនតែប៉ុណ្ណោះទេ ធម៌ទាំងឡាយនោះ ជាសត្រូវ ដល់អប្បិច្ឆតាគុណ និង សន្តុដ្ឋិតាគុណ, ធម៌ទាំងឡាយនោះ ជាឫសគល់នៃសេចក្តីទុក្ខ ព្រោះការស្វែងរក និង ការថែរក្សា ដូចគ្នា ដូច្នោះឯង ។ បើពោលដោយសង្ខេប ឧបាទាន ៣ ដ៏សេស គ្រាន់តែជាទិដ្ឋិប៉ុណ្ណោះ ។

បើពោលដោយពិស្តារ ភាពនៃតណ្ហា មានប្រភេទ ១០៨ ដែលយើងពោលហើយ ក្នុងអារម្មណ៍ទាំងឡាយ មានរូបារម្មណ៍ជាដើម ក្នុងកាលមុន ឈ្មោះថា កាមុបាទាន, មិច្ឆាទិដ្ឋិ មានវត្ថុ ១០ យ៉ាង ហៅថា



ទិដ្ឋុបាទាន ។ សមដូចជាព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយថា "បណ្តាឧបាទានទាំងឡាយនោះ តើទិដ្ឋុបាទានដូចម្តេច?, ទិដ្ឋិណា ។ល។ ការប្រកាន់ខុស បែបនេះ គឺ: ទានដែលបុគ្គលធ្វើហើយ មិនមានផលទេ, សក្ការបូជា ដែលបុគ្គលបូជាហើយ មិនមានផលទេ ។ល។ សមណ-ព្រាហ្មណ៍ទាំងឡាយឯណា ធ្វើឲ្យជាក់ច្បាស់ សំដែងប្រាប់, សមណ-ព្រាហ្មណ៍ទាំងឡាយនោះ មិនមាន ក្នុងលោក" ដូច្នេះ, ការប្រកាន់ខុសមានទិដ្ឋិជាដើមនេះ គឺលោកហៅថា ទិដ្ឋុបាទាន ។

ចំណែកខាងការបបោសអង្អែល ដោយគិតថា : ការស្អាត ដោយសីល និង វត្ត ហៅថា សីលព្វតុបាទាន ។ សមដូចព្រះមានព្រះភាគទ្រង់ត្រាស់ថា "បណ្តាឧបាទានទាំងឡាយនោះ តើសីលព្វតុបាទាន ដូចម្តេច? ។ ទិដ្ឋិ ណា ។ល។ ការប្រកាន់ខុស មានសភាពបែបនេះ គឺ : សេចក្តីស្អាត មានដោយសីល, សេចក្តីស្អាត មានដោយវត្ត, សេចក្តីស្អាត មានដោយសីល និង វត្ត" ដូច្នេះ ។ ការយល់ឃើញជាដើមនេះ គឺលោកហៅថា សីលព្វតុបាទាន ដូច្នេះឯង ។

សក្កាយទិដ្ឋិ មានវត្ថុ ២០ ឈ្មោះថា អត្តវាទុបាទាន ។ សមដូចជាព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយថា "បណ្តាឧបាទានទាំងឡាយនោះ អត្តវាទុបាទាន តើដូចម្តេច? ។ បុគ្គលជាបុថុជ្ជន ក្នុងសាសនានេះ ជាអ្នកមិនស្តាប់ ។លេ។ មិនទូន្មានហើយ ក្នុងសប្បុរិសធម៌ ពិចារណាឃើញច្បាស់នូវរូប ដោយថាជាខ្លួន ។ល។ ការកាន់យកនូវការប្រកាន់ខុស" ដូច្នេះ, អំពើមានការប្រកាន់ខុសជាដើមនេះ គឺលោកហៅថា អត្តវាទុបាទាន ដូច្នេះឯង ។

ធម៌ យ៉ាងសង្ខេប និង ពិស្តារ ក្នុងឧបាទាននេះ ចប់ហើយ ។

ក៏សេចក្ដីវិនិច្ឆ័យ ក្នុងបទនេះថា "ដោយលំដាប់" មានដូចតទៅៈ លំដាប់ មាន ៣ ប្រការ គឺៈ លំដាប់នៃការកើតឡើង ១, លំដាប់នៃការលះបង់ ១, លំដាប់នៃការសំដែង ១ ។

បណ្ដាលំដាប់ទាំងឡាយនោះ លំដាប់នៃការកើតឡើង គឺលោកមិនពោលហើយ ដោយមិនមានបរិយាយ ព្រោះការមិនមាននៃកិលេសទាំងឡាយថាៈ ការកើតឡើងជាដំបូង នៃឧបាទាននេះ ក្នុងសំសារ គឺពុទ្ធញាណ កំណត់ដឹងមិនបានហើយ ។ បើនិយាយដោយបរិយាយ អត្តវាទុបាទាន កើតឡើងមុនគេ, តមក ទិដ្ឋុបាទាន, សីលព្វតុបាទាន និង កាមុបាទាន រមែងកើតឡើង ព្រោះអធិប្បាយយ៉ាងនេះថាៈ ដោយច្រើន ក្នុងភពមួយ ការប្រកាន់ស្អិត ថាៈ សត្វទៀង និង សូន្យ មានការប្រកាន់ខ្លួន ជាប្រធានដល់មុន(រមែងកើតឡើង) តមក សីលព្វតុបាទាន ដែលមានសេចក្ដីបរិសុទ្ធិនៃខ្លួនជាអត្ថ រមែងកើតឡើង ដល់បុគ្គលអ្នកប្រកាន់ថា "ខ្លួននេះទៀងទាត់" ដូច្នេះ, កាមុបាទាន រមែងកើតឡើងដល់បុគ្គលដែលប្រកាន់ថា "ខ្លួននេះសាបសូន្យ" ដូច្នេះ, អ្នកមិនពិចារណាមើលបរលោក ព្រោះហេតុនោះ នេះជាលំដាប់នៃការកើតឡើង ក្នុងភពមួយ នៃឧបាទានទាំងឡាយ ៤ នេះ ។

ក៏បណ្ដាឧបាទានទាំងឡាយនេះ ឧបាទានទាំងឡាយមានទិដ្ឋុបាទានជាដើម គឺលោកលះបង់ជាដំបូង ព្រោះភាពនៃឧបាទាននេះ ជាធម្មជាត គឺលោកគប្បីសម្លាប់ ដោយសោតាបត្តិមគ្គ, កាមុបាទាន គឺលោកលះបង់ ជាខាងក្រោយ ព្រោះភាពនៃកាមុបាទាននោះ ជាទោសជាត គឺបុគ្គលគប្បីសម្លាប់ ដោយអរហត្តមគ្គ ព្រោះហេតុនោះ លំដាប់នេះជាលំដាប់នៃការលះបង់ នៃឧបាទានទាំងឡាយនេះ ។



ចំណែកបណ្ដាឧបាទានទាំងឡាយនេះ កាមុបាទាន គឺព្រះមានព្រះភាគទ្រង់សំដែងហើយមុន ព្រោះភាពនៃកាមុបាទាននោះ មានអារម្មណ៍ដ៏ធំផង, ព្រោះភាពនៃកាមុបាទាននោះប្រាកដផង។ ព្រោះថា កាមុបាទាននោះមានអារម្មណ៍ដ៏ធំ ព្រោះការប្រកបព្រមដោយចិត្ត ៨, ឧបាទានទាំងឡាយក្រៅអំពីនេះ ឈ្មោះថា មានអារម្មណ៍ដ៏តិច ព្រោះការប្រកបព្រមដោយចិត្ត ៤ ។ មួយទៀត បើពោលដោយច្រើន កាមុបាទាន ប្រាកដដល់សត្វ ព្រោះភាពនៃសត្វ មានសេចក្ដីអាល័យ ជាទីមកត្រេកអរ, ឧបាទានទាំងឡាយក្រៅនេះ មិនប្រាកដទេ ។ បុគ្គលអ្នកមានកាមុបាទានជាអ្នកច្រើនដោយមង្គលមានមង្គលភ្ញាក់ផ្អើលជាដើម ដើម្បីកិរិយាបានសំរេចដូចបំណងនៃកាមទាំងឡាយ, សស្សតទិដ្ឋិ មិនដូច្នោះទេ ព្រោះហេតុនោះ ទិដ្ឋុបាទាន ព្រះមានព្រះភាគ ទ្រង់ត្រាស់សំដែងហើយ បន្ទាប់អំពីកាមុបាទាននោះ ។ ទិដ្ឋុបាទាននោះ គឺលោកកាលបែងចែក មាន ២ ប្រការ ដោយអំណាចនៃសីលព្វតុបាទាន និង អត្តវាទុបាទាន ។ បណ្ដាប្រជុំពីរនៃឧបាទាននោះ សីលព្វតុបាទាន គឺព្រះមានព្រះភាគទ្រង់ត្រាស់សំដែងហើយ ជាដំបូងថា គ្រោតគ្រាត ព្រោះសីលព្វតុបាទាន គឺបណ្ឌិតគប្បីឃើញ នូវកិរិយារបស់គោ ឬ ឬថា នូវកិរិយារបស់កូនឆ្កែហើយយល់បាន, អត្តវាទុបាទាន គឺព្រះអង្គទ្រង់ត្រាស់សំដែងហើយក្នុងទីបំផុត ព្រោះភាពនៃឧបាទាន ជាគុណជាតដ៏ល្អិត ។ នេះជាលំដាប់នៃការសំដែង នៃឧបាទានទាំងឡាយ ៤ នេះ ។

ក៏បណ្ដាឧបាទានទាំងឡាយនេះ តណ្ហា ជាបច្ច័យ
ដោយចំណែក១ នៃឧបាទាន មាន ក្នុងខាងដើម,
តណ្ហានោះ ជាបច្ច័យនៃប្រជុំបី នៃតណ្ហាដ៏សេស

ដោយចំណែក ៧ ខ្លះ ដោយចំណែក ៨ ខ្លះ ។

*ក៏ក្នុងឧបាទានទាំង ៤ នេះ គឺក្នុងប្រមាណ ៤ នៃឧបាទានដែលព្រះមានព្រះភាគ ទ្រង់ត្រាស់សំដែងហើយ យ៉ាងនេះ, កាមតណ្ហា ជាបច្ច័យ ដោយចំណែកតែមួយគត់ នៃឧបាទាន មានព្វជ៏ខាងដើម គឺកាមុបាទាន ដោយអំណាចឧបនិស្ស័យ ព្រោះការកើតឡើង ក្នុងអារម្មណ៍ទាំងឡាយ ដែលតណ្ហាឲ្យស្រើបស្រាលហើយ ។ តែតណ្ហានោះ ជាបច្ច័យ ដោយចំណែក ៧ នៃពួកបីនៃតណ្ហាដ៏សេស ដោយអំណាចសហជាតប្បច្ច័យ, អញ្ញមញ្ញប្បច្ច័យ, និស្សយប្បច្ច័យ, សម្បយុត្តប្បច្ច័យ, អត្ថិប្បច្ច័យ, អវិគតប្បច្ច័យ និង ហេតុប្បច្ច័យផង, ជាបច្ច័យ ដោយចំណែក ៨ ខ្លះ ព្រមដោយឧបនិស្ស័យ ។ តែតណ្ហានោះ ជាបច្ច័យ ដោយអំណាច នៃឧបនិស្ស័យ ក្នុងកាលណា, ក្នុងកាលនោះ តណ្ហានោះ មិនមែនជាសហជាតប្បច្ច័យទេ ។ នេះ ជាការពោល ដោយពិស្តារ ក្នុងបទ ថា :* "ឧបាទាន (កើតព្រម) ព្រោះមានតណ្ហាជាបច្ច័យ" ។

*(៤១០) សេចក្តីវិនិច្ឆ័យ ត្រង់បទថា* "ភព (កើតព្រម) ព្រោះមានឧបាទានជាបច្ច័យ" *គឺបណ្ឌិតគប្បីជ្រាប ដូចតទៅនេះ ។*

> សេចក្តីវិនិច្ឆ័យ គឺបណ្ឌិត គប្បីជ្រាបថា ជាបច្ច័យ នៃភពណា ដោយធម៌ផង ដោយធម៌ដែលប្រព្រឹត្តទៅ មួយអន្លើ ដោយអត្ថផង ដោយប្រភេទ និង ការរួបរួមផង ពីឧបាទាននោះ នៃភពនោះ ។

*សេចក្តីវិនិច្ឆ័យ ក្នុងបទនោះថា : សភាវធម៌ណា កើត សភាវធម៌នោះ ឈ្មោះថា ភព ។ ភពនោះ មាន ២ យ៉ាង គឺ កម្មភព ១, ឧបបត្តិភព ១ ។ ដូចជាព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយថា "ភព គឺលោកកំណត់ហើយ ដោយចំណែក ២ គឺកម្មភពក៏មាន ឧបបត្តិភពក៏មាន" ។*

*បណ្តាភពទាំង ២ នោះ កម្មភព គឺកម្ម ឈ្មោះថា កម្មភព, ភព គឺការកើតដូចគ្នា ឈ្មោះថា ឧបបត្តិភព ។ ក៏បណ្តាភពទាំងឡាយ ២ នោះ ឧបបត្តិភព គឺបណ្ឌិត គប្បីជ្រាប ព្រោះវិគ្គហៈថា: សភាវៈណាកើត សភាវៈនោះ ឈ្មោះថា ភព, ចំណែកកម្ម គឺបណ្ឌិតគប្បីជ្រាបថា: ភព ដោយពាក្យសំរាប់ហៅនូវផល ព្រោះភាពនៃកម្មនោះ ជាហេតុនៃភព ដូចជាការកើតឡើង នៃព្រះពុទ្ធទាំងឡាយ តែងនាំមកនូវសេចក្តីសុខ ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រោះភាពនៃការកើតឡើង នៃព្រះពុទ្ធទាំងឡាយនោះ ជាហេតុនៃសេចក្តីសុខ ។*

*សេចក្តីវិនិច្ឆ័យ ត្រង់បទនៃមាតិកានេះ គឺបណ្ឌិតគប្បីជ្រាប តាមសេចក្តីយ៉ាងនេះចុះ ។*

(កម្មភព)

*ក៏ បើពោលតាមធម្មតា សេចក្តីវិនិច្ឆ័យ គឺបណ្ឌិតគប្បីជ្រាប ដូចតទៅ ។ បើពោលដោយបំព្រួញ ចេតនាក្តី ធម៌ទាំងឡាយពោលគឺកម្ម មានអភិជ្ឈាជាដើមក្តី ដែលសម្បយុត្ត ដោយចេតនា ឈ្មោះថា កម្មភពមុនគេ ។ សមដូចជាព្រះមានព្រះភាគ ទ្រង់ត្រាស់ថា: បណ្តាភពទាំង ២ នោះ កម្មភព តើដូចម្តេច? ។ បុញ្ញាភិសង្ខារក្តី, អបុញ្ញាភិសង្ខារក្តី, អានេញ្ជាភិសង្ខារក្តី មានភូមិតូចខ្លះ, មានភូមិធំខ្លះ, បុញ្ញាភិសង្ខារ ជាដើមនេះ គឺលោកពោលថា : កម្មភព, កម្មដែលញ៉ាំងសត្វឲ្យកើត ក្នុងភពទាំងអស់ ឈ្មោះថា កម្មភព ។*

ក៏បណ្ដាសង្ខារទាំងឡាយ មានបុញ្ញាភិសង្ខារជាដើមនេះ ចេតនាទាំងឡាយ ១៨ ឈ្មោះថា បុញ្ញាភិសង្ខារ, ចេតនាទាំងឡាយ ១២ ឈ្មោះថា អបុញ្ញាភិសង្ខារ, ចេតនាទាំងឡាយ ៤ ឈ្មោះថា អានេញ្ជាភិសង្ខារ ។ ភាពនៃចេតនាទាំងឡាយនោះឯង មានផលតិច និង ផលច្រើន គឺព្រះមានព្រះភាគ ត្រាស់ហើយ ដោយបទនេះថា "មានភូមិតូចខ្លះ មានភូមិធំខ្លះ" យ៉ាងនេះ ។ ក៏បាបធម៌ទាំងឡាយ មានអភិជ្ឈា ជាដើម សម្បយុត្តដោយចេតនា គឺព្រះមានព្រះភាគ ត្រាស់ហើយ ដោយបទនេះថា "កម្ម ដែលញ៉ាំងសត្វឲ្យកើត ក្នុងភពទាំងអស់" ។

(ឧបបត្តិភព)

ក៏ខន្ធទាំងឡាយដែលកើតថ្មីព្រោះកម្ម ឈ្មោះថាឧបបត្តិភព ដោយសង្ខេប, បើនិយាយតាមប្រភេទ ឧបបត្តិភពនោះ មាន ៩ ប្រការ ។ សមដូចជាព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយថា "បណ្ដាភពទាំងឡាយ ៩ ប្រការនោះ ឧបបត្តិភព តើដូចម្ដេច? ។ កាមភព, រូបភព, អរូបភព, សញ្ញាភព, អសញ្ញាភព, នេវសញ្ញានាសញ្ញាភព, ឯកវោការភព, ចតុវោការភព, បញ្ចវោការភព ។ ភពមានកាមភពជាដើមនេះ គឺលោកហៅថា ឧបបត្តិភព ។

បណ្ដាឧបបត្តិភពទាំងនោះ ភព ពោលគឺកាម ហៅថា កាមភព ។ ន័យក្នុងរូបភព និង អរូបភពទាំងឡាយ ដូចជាន័យនេះដែរ គឺបណ្ឌិតគប្បីជ្រាបផងចុះ ។ ភពនៃសត្វទាំងឡាយ ដែលមានសញ្ញា ឈ្មោះថាសញ្ញាភព ។ ម្យ៉ាងទៀត សញ្ញា មានក្នុងភពនេះ ព្រោះហេតុដូច្នោះ ភពនោះ ឈ្មោះ សញ្ញាភព ។ អសញ្ញាភព គឺបណ្ឌិត គប្បីជ្រាប ដោយទំនាស់នឹងសញ្ញាភព ។



សមាបត្តិ ដែលមានសញ្ញា ក៏មិនមែន មិនមានសញ្ញា ក៏មិនមែន មានក្នុងភពនោះ ព្រោះមិនមាននៃសញ្ញា ដ៏គ្រោតគ្រាតផង ព្រោះមានតែសញ្ញា ដ៏ល្អិតផង ព្រោះហេតុនោះ ភពនោះ ឈ្មោះថា នេវសញ្ញានាសញ្ញាភព ។

ភពប្រឡូកប្រឡំហើយ ដោយរូបក្ខន្ធ ១ ហៅថា ឯកវោការភព ឬថា ខន្ធដ៏ប្រឡូកប្រឡំ នៃភពនោះ មានតែមួយ ព្រោះហេតុនោះ ភពនោះ ឈ្មោះថា ឯកវោការភព ។ ន័យ ក្នុងចតុវោការភព និង បញ្ចវោការភពទាំងឡាយ ក៏ដូចគ្នានឹងន័យនេះដែរ ។

បណ្ដាភពទាំងឡាយនោះ ខន្ធ ដែលមានវិញ្ញាណ ចូលទៅជិតអាស្រ័យទាំងឡាយ ៥ ឈ្មោះថា កាមភព ។ រូបភព ក៏ដូចគ្នាដែរ ។

ឧបាទិន្នក្ខន្ធទាំងឡាយ ៤ ឈ្មោះថា អរូបភព ។ ឧបាទិន្នក្ខន្ធទាំងឡាយ ៥ ជាសញ្ញាភព ។ ខន្ធ ដែលមានវិញ្ញាណចូលទៅជិតអាស្រ័យ ១ ហៅថា អសញ្ញាភព ។ ឧបាទិន្នក្ខន្ធទាំង ៤ ហៅថា នេវសញ្ញានាសញ្ញាភព ។ ខន្ធ ១ និង ខន្ធ ៤ និង ខន្ធ ៥ ទាំងឡាយ មានឯកវោការភពជាដើម (មួយអន្លើ) ដោយខន្ធដែលមានវិញ្ញាណចូលទៅជិតអាស្រ័យទាំងឡាយ គឺបណ្ឌិត គប្បីជ្រាបផងចុះ ។ សេចក្ដីវិនិច្ឆ័យ ក្នុងបទមាតិកានេះ គឺបណ្ឌិតគប្បីជ្រាប ដោយធម្មតា យ៉ាងនេះឯង ។

(៤០២) ត្រង់បទថា "សាត្ថតោ" សេចក្ដីវិនិច្ឆ័យ គឺបណ្ឌិតគប្បីជ្រាប ដូចតទៅ: ក៏អភិសង្ខារទាំងឡាយ មានបុញ្ញាភិសង្ខារជាដើម គឺព្រះមានព្រះភាគត្រាស់ហើយ ក្នុងភវនិទ្ទេស យ៉ាងណា, ក្នុងសង្ខារនិទ្ទេស ក៏យ៉ាងនោះដែរ ។ ក៏ពិតមែនហើយ កាលបើហេតុយ៉ាងនេះមាន, សង្ខារទាំងឡាយខាងដើម គឺព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ

ក្នុងភពជាបច្ចុប្បន្ននេះ ដោយអំណាចនៃកម្មជាអតីត ព្រោះភាពនៃសង្ខារជាបច្ច័យនៃបដិសន្ធិ, សង្ខារទាំងឡាយនេះ គឺព្រះមានព្រះភាគទ្រង់ត្រាស់សំដែងហើយ តទៅ ដោយអំណាចនៃកម្មជាបច្ចុប្បន្ន ព្រោះភាពនៃសង្ខារជាបច្ច័យ នៃបដិសន្ធិ ព្រោះហេតុដូច្នោះ ពាក្យសំរាប់ពោលបន្ថែម មានប្រយោជន៍ណាស់ដែរ ។ ម្យ៉ាងទៀត ក្នុងកាលខាងដើម ចេតនាហ្នឹងឯង លោកហៅថា សង្ខារ ដោយន័យយ៉ាងនេះ ថា បណ្ដាអភិសង្ខារទាំងនេះ បុញ្ញាភិសង្ខារតើដូចម្ដេច? ចេតនា ជាកុសលជាកាមាវចរ ហៅថា បុញ្ញាភិសង្ខារ យ៉ាងដូច្នោះជាដើម, ប៉ុន្តែក្នុងទីនេះ ធម៌ទាំងឡាយ ដ៏សម្បយុត្តដោយចេតនា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រោះបាលីថា: សូម្បីកម្ម ដែលញ៉ាំងសត្វឲ្យកើត ក្នុងភពទាំងអស់ ក៏ឈ្មោះថា កម្មភព ។ ម្យ៉ាងវិញទៀត កម្ម មានវិញ្ញាណ ជាបច្ច័យពិត គឺព្រះមានព្រះភាគទ្រង់ត្រាស់ថា សង្ខារ ក្នុងកាលមុន, ទាំងកម្ម ដែលញ៉ាំងសត្វឲ្យកើត ក្នុងអសញ្ញាភព គឺព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ក្នុងកាលឥឡូវនេះ ។ ម្យ៉ាងទៀត ប្រយោជន៍អ្វី ដោយការនិយាយច្រើនពេក ។

ធម៌ទាំងឡាយជាកុសល និង អកុសល មានបុញ្ញាភិសង្ខារជាដើម គឺព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ត្រង់បទនេះថា "សង្ខារទាំងឡាយ (កើតព្រម) ព្រោះមានអវិជ្ជាជាបច្ច័យ" ។ តែថា ធម៌ទាំងឡាយ ជាកុសល, អកុសល និង ជាអព្យាក្រឹត ត្រង់បទនេះថា "ភព (កើតព្រម) ព្រោះមានឧបាទានជាបច្ច័យ" ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រោះភាពនៃឧបបត្តិភព ព្រះអង្គទ្រង់សង្គ្រោះយកហើយ ។ ព្រោះហេតុនោះ ពាក្យសំរាប់ពោលទៀតនេះ សុទ្ធតែជាពាក្យមានប្រយោជន៍ត្រង់ៗ ក្នុង



បទទាំងឡាយទាំងពួងដូច្នោះឯង ។ សេចក្ដីវិនិច្ឆ័យ ត្រង់បទមាតិកានេះ គឺបណ្ឌិត គប្បីជ្រាប ដោយហេតុប្រកបដោយប្រយោជន៍ យ៉ាងនេះ ។

សេចក្ដីវិនិច្ឆ័យ ត្រង់បទមាតិកា ថា "ព្រោះការបែងចែក និង ការសង្គ្រោះ" គឺបណ្ឌិតគប្បីជ្រាប ដូចតទៅ : ដោយការញែកនូវភពដោយមានឧបាទានជាបច្ច័យផង ដោយការរួបរួមផង ។

ព្រោះថា កម្មណា ដែលញ៉ាំងសត្វឲ្យកើត ក្នុងកាមភព គឺសត្វធ្វើទុក ព្រោះមានកាមុបាទានជាបច្ច័យ, វាទះថា កម្មនោះ ឈ្មោះថាកម្មភព, ខន្ធទាំងឡាយដែលកើតអំពីកម្មនោះ ឈ្មោះថា ឧបបត្តិភព ។ ន័យក្នុងរូបភព និង អរូបភពទាំងឡាយ ក៏មានន័យដូចនេះដែរ ។

ភពទាំងឡាយ ៦ មួយអន្លើដោយភព ដែលលាយចម្រុះគ្នាទាំងឡាយ គឺ: កាមភពទាំងឡាយ ២ និង សញ្ញាភព និង បញ្ចវោការភព ដែលលាយចម្រុះគ្នា ពួដ៏ខាងក្នុងនៃកាមភពទាំង ២ នោះ, រូបភពទាំងឡាយ ២ ដែលលាយចម្រុះគ្នា ពួដ៏ខាងក្នុង និង សញ្ញាភព, អសញ្ញាភព, ឯកវោការភព និង បញ្ចវោការភពផង, អរូបភពទាំងឡាយ ២ ដែលលាយចម្រុះគ្នា ពួដ៏ខាងក្នុង និង សញ្ញាភព ពួដ៏ខាងក្នុង និង សញ្ញាភព, នេវសញ្ញានាសញ្ញាភព និង ចតុវោការភព ព្រោះមានកាមុបាទានជាបច្ច័យយ៉ាងនេះ ។ ក៏ភពទាំង ៦ ព្រមទាំងភពដែលមាននៅខាងក្នុង ព្រោះមានឧបាទានជាបច្ច័យ យ៉ាងណា, ភពទាំងឡាយ ៦ មួយអន្លើដោយភព ដែលលាយចម្រុះគ្នា ពួដ៏ខាងក្នុងទាំងឡាយ ព្រោះមានឧបាទានដ៏សេសជាបច្ច័យ ក៏យ៉ាងនោះដែរ ។ ភពទាំងឡាយ ២៤ មួយអន្លើដោយភពដែលលាយចម្រុះគ្នា ពួដ៏ខាងក្នុងទាំងឡាយ ដោយការផ្សេងគ្នា ព្រោះមានឧបាទានជាបច្ច័យ ។

តែបើពោលតាមការសង្គ្រោះ មានវិនិច្ឆ័យថា ភពទាំងឡាយ ៣ កាមភព ១ រួមគ្នាដោយភពដែលលាយចម្រុះគ្នា ពួដ៏ខាងក្នុងទាំងឡាយ គឺរូបភព និង អរូបភពទាំងឡាយ ដូចគ្នា ដោយមានកាមុបាទាន ជាបច្ច័យ ព្រោះធ្វើនូវកម្មភពផង នូវឧបបត្តិភពផង ក្នុងទីជាមួយគ្នា, ភពទាំងឡាយដូចគ្នាដែរ ព្រោះមានឧបាទានដ៏សេសជាបច្ច័យ ។ ភពទាំងឡាយ ១២ មួយអន្លើដោយភព ដែលលាយចម្រុះគ្នា ពួដ៏ខាងក្នុងទាំងឡាយ គឺលោកសង្គ្រោះហើយ ព្រោះមានឧបាទានជាបច្ច័យយ៉ាងនេះ ។

ម្យ៉ាងវិញទៀត កម្មដែលញ៉ាំងសត្វឲ្យដល់នូវកាមភព ឈ្មោះថា កម្មភព ព្រោះមានឧបាទានជាបច្ច័យ ដោយមិនប្លែកគ្នា, ខន្ធទាំងឡាយដែលកើតអំពីកម្មនោះ ឈ្មោះថា ឧបបត្តិភព ។ ន័យ ក្នុងរូបភព និង អរូបភពទាំងឡាយ ដូចគ្នាដែរ គឺបណ្ឌិតគប្បីជ្រាបផងចុះ ។ ភពទាំងឡាយ ៦ គឺលោកសង្គ្រោះហើយ ដោយបរិយាយផ្សេងទៀត គឺ កាម-ភព ២, រូបភព ២, អរូបភព ២ មួយអន្លើដោយភពដែលលាយចម្រុះគ្នា ពួដ៏ខាងក្នុងទាំងឡាយ ព្រោះមានឧបាទានជាបច្ច័យយ៉ាងនេះ ។

ម្យ៉ាងវិញទៀត ភពទាំងឡាយ ៣ មួយអន្លើដោយភពដែលលាយចម្រុះគ្នា ពួដ៏ខាងក្នុងទាំងឡាយ ព្រោះមិនបានរាប់បញ្ចូលនូវការផ្សេងគ្នា ក្នុងកម្មភព និងឧបបត្តិភព ដោយអំណាចភពមានកាមភពជាដើម ។ ម្យ៉ាងវិញទៀត ភពទាំងឡាយ មាន ២ ដោយអំណាចនៃកម្មភព និង ឧបបត្តិភព ព្រោះមិនបានរាប់បញ្ចូលនូវការផ្សេងគ្នា នៃភពមានកាម-ភពជាដើម ។ ម្យ៉ាងទៀត ភព មានតែមួយគត់ ដោយអំណាចនៃភព គឺ : ភព (កើតព្រម) ព្រោះមានឧបាទានជាបច្ច័យ ព្រោះមិនបានរាប់បញ្ចូលនូវការផ្សេងគ្នានៃកម្មភព និង ឧបបត្តិភព ដូច្នេះឯង ។



សេចក្តីវិនិច្ឆ័យ ត្រង់បទមាតិកានេះ គឺបណ្ឌិតគប្បីជ្រាប ដូចតទៅនេះ : ព្រោះការបែងចែក និង ការសង្គ្រោះនូវភព ព្រោះមានឧបាទានជាបច្ច័យ ។

(៤០៥) សេចក្តីអធិប្បាយត្រង់បទ ថា “យំ យស្ស បច្ចយោ ច” សេចក្តីថា ក៏ក្នុងបទថា “ឧបាទានបច្ចយា ភវោ” នេះ សេចក្តីវិនិច្ឆ័យ គឺបណ្ឌិត គប្បីជ្រាប ដោយឧបាទានជាបច្ច័យនៃភពណា, ឧបាទាននោះជាបច្ច័យ នៃភពនោះ ។

សួរថា : ចុះបណ្តាឧបាទានទាំងឡាយនេះ ឧបាទានដូចម្តេច ជាបច្ច័យនៃភពណា? ។

ឆ្លើយថា: ឧបាទានណានីមួយជាបច្ច័យនៃភពណានីមួយមែនពិត ។

សេចក្តីប្រៀបថា មនុស្សបុថុជ្ជន ទុកដូចជាមនុស្សឆ្កួត ។ មនុស្សឆ្កួតនោះ មិនបានពិចារណា ថា : នេះគួរ, នេះមិនគួរទេ ប្រាថ្នានូវភពណានីមួយ ដោយអំណាចនៃឧបាទានណាមួយ ធ្វើមិនដាច់នូវកម្មណានីមួយដែរ ។ ព្រោះហេតុនោះ ជនទាំងឡាយពួកខ្លះ ពោលនូវពាក្យណាថា រូបភព និង អរូបពភទាំងឡាយ មិនមាន ដោយការប្រកាន់មាំនូវសីល និង វត្តទេ, ពាក្យនោះ គឺកុលបុត្រ មិនគួរជឿទេ ។ តែពាក្យថា “ភពទាំងអស់ មាន ព្រោះការប្រកាន់មាំនូវសីល និង វត្តទាំងពួង” គឺកុលបុត្រ គប្បីជឿចុះ ។

សួរថា : តើព្រោះហេតុអ្វី ? ។

ឆ្លើយថា: សត្វទាំងឡាយពួកខ្លះ ក្នុងលោកនេះ គិតដោយអំណាចនៃការឮ តៗ គ្នា ឬ ឬថា តាមលំអាននៃចក្ខុដែលខ្លួនឃើញហើយ ថា កាមទាំងនេះ សំរេចហើយ ក្នុងមនុស្សលោក ឬ ឬថា ក្នុងត្រកូល

ទាំងឡាយមានត្រកូលខត្តិយមហាសាលជាដើម ឬមួយ ក្នុងទេវលោក គឺកាមាវចរសួគ៌ ៦ ជាន់ គឺគេបញ្ឆោតហើយ ដោយហេតុទាំងឡាយមានការមិនឲ្យស្តាប់ នូវព្រះសទ្ធម្មជាដើម ដើម្បីការបាន នូវកាមទាំងឡាយនោះ កាលសំគាល់ ថា: កាមទាំងឡាយ រមែងសំរេច ព្រោះកម្មនេះ តែងធ្វើនូវទុច្ចរិតទាំងឡាយ មានកាយទុច្ចរិតជាដើម ដោយអំណាច នៃកាមុបាទាន ។ បុគ្គលនោះ រមែងកើត ក្នុងអបាយ ព្រោះការបំពេញនូវទុច្ចរិត ។ ក៏បុគ្គលកាលចង់បាននូវកាមទាំងឡាយ ក្នុងបច្ចុប្បន្ន កាលគ្រប់គ្រងនូវកាមទាំងឡាយ ដែលខ្លួនបានចំពោះហើយ រមែងធ្វើអំពើទុច្ចរិតទាំងឡាយ មានកាយទុច្ចរិតជាដើម ដោយអំណាចកាមុបាទាន ។ បុគ្គលនោះ រមែងកើត ក្នុងអបាយ ព្រោះការបំពេញនូវទុច្ចរិត ។

កម្ម ដែលជាហេតុនៃការចូលទៅជិត កើតក្នុងអបាយ នៃបុគ្គលនោះ ឈ្មោះថា កម្មភព ។ ខន្ធទាំងឡាយដែលកើតថ្មី ព្រោះកម្ម ឈ្មោះថា ឧបបត្តិភព ។ ចំណែកខាងសញ្ញាភព និង បញ្ចវោការភពទាំងឡាយ សុទ្ធតែជាភពលាយចម្រុះ ពួជ៏ខាងក្នុង នៃឧបបត្តិភពនោះ ។

ចំណែកខាងបុគ្គលខ្លះទៀត មានញាណចំរើនហើយ ដោយកិច្ចទាំងឡាយ មានការស្តាប់នូវព្រះសទ្ធម្មជាដើម កាលសំគាល់ថា: កាមទាំងឡាយ រមែងកើតឡើង ព្រោះតែកម្មនេះ ធ្វើនូវសុចរិតទាំងឡាយ មានកាយសុចរិតជាដើម ដោយអំណាចនៃកាមុបាទាន ។ បុគ្គលនោះ រមែងកើត ក្នុងទេវតាទាំងឡាយ ឬ ឬថា ក្នុងមនុស្សទាំងឡាយ ។

កម្ម ដែលជាហេតុនៃការចូលទៅកើត ក្នុងទេវលោក ឬ មនុស្ស នៃបុគ្គលនោះ ហៅថា កម្មភព ។ ខន្ធទាំងឡាយដែលកើតថ្មី ព្រោះកម្ម ឈ្មោះថា ឧបបត្តិភព ។ ចំណែកខាងសញ្ញាភព និង បញ្ចវោការភព



ទាំងឡាយ សុទ្ធតែជាវត្ថុលាយឡំ ពួជ៏ខាងក្នុង នៃឧបបត្តិភពនោះ ។

កាមុបាទាន ជាបច្ច័យនៃកាមភព ប្រព្រឹត្តទៅមួយអន្លើដោយការញែក ព្រមទាំងភពដែលមាននៅខាងក្នុង ដូចបានរៀបរាប់មកនេះ ។

បុគ្គលពួកខ្លះ ឮ ក្តី ត្រិះរិះ ក្តី ថា : កាមទាំងឡាយសំរេច ដោយវិសេសជាងកាមភពនោះ ក្នុងរូបភព និង អរូបភពទាំងឡាយ ញុំាងរូបសមាបត្តិ និង អរូបសមាបត្តិទាំងឡាយ ឲ្យកើត ដោយអំណាចកាមុបាទាន តែម្យ៉ាង ហើយកើត ក្នុងលោក គឺរូបព្រហ្ម និង អរូបព្រហ្ម ដោយកម្លាំង នៃសមាបត្តិ ។

កម្ម ដែលជាហេតុ នៃការចូលទៅកើត ក្នុងព្រហ្មលោកនោះ នៃបុគ្គលនោះ ឈ្មោះថា កម្មភព ។ ខន្ធទាំងឡាយ ដែលកើតថ្មីអំពីកម្ម ឈ្មោះថា ឧបបត្តិភព ។ ចំណែកខាងសញ្ញាភព, អសញ្ញាភព, នេវ-សញ្ញានាសញ្ញាភព, ឯកវោការភព, ចតុវោការភព និង បញ្ចវោ-ការភពទាំងឡាយ សុទ្ធតែលាយឡំ ពួជ៏ខាងក្នុង នៃឧបបត្តិភពនោះ ។ កាមុបាទាន ជាបច្ច័យ នៃរូបភព និង អរូបភពទាំងឡាយ ដែលប្រព្រឹត្តទៅមួយអន្លើដោយប្រភេទ ព្រមទាំងភពដែលមាននៅខាងក្នុង ដូចបានថ្លែងមកនេះឯង ។

បុគ្គលពួកខ្លះ ធ្វើនូវអំពើដែលចូលទៅដល់ទិដ្ឋិនោះ ព្រោះអាស្រ័យនូវឧច្ឆេទទិដ្ឋិ ថា: នាកាលភពដ៏ពេញដោយសម្បត្តិជាកាមាវ-ចរ ក្តី នាកាលជុំនុំរូបភព និង អរូបភពទាំងឡាយ ភពណាមួយ ក្តី ដាច់សូន្យហើយ ខ្លួននេះ ជាអត្តភាពដាច់សូន្យហើយដែរ ។ កម្មនោះ របស់បុគ្គលនោះ ឈ្មោះថា កម្មភព ។ ខន្ធទាំងឡាយដែលកើតថ្មី ព្រោះកម្ម ឈ្មោះថា ឧបបត្តិភព ។ ចំណែកភពទាំងឡាយ មានសញ្ញាភពជាដើម

ឈ្មោះថា វត្តុលាយឡំហើយ ពួជ៏ខាងក្នុង នៃឧបបត្តិភពនោះ ។

ទិដ្ឋុបាទាន ជាបច្ច័យនៃកាមភព, រូបភព និង អរូបភពទាំងឡាយ ៣ ហ្នឹងឯង ប្រព្រឹត្តទៅ មួយអន្លើដោយប្រភេទ ព្រមទាំងភពដែលមាននៅខាងក្នុង ដូចរៀបរាប់មកនេះ ។

បុគ្គលខ្លះ ធ្វើនូវអំពើគួរដល់ឧបបត្តិភពនោះ ព្រោះការប្រកាន់មាំនូវអត្តវាទ ដោយការគិត ថា : ខ្លួននេះ មានសេចក្តីក្តៅក្រហាយប្រាសចេញហើយ ជាអ្នកមានសេចក្តីសុខ ក្នុងភព គឺសម្បត្តិ ជាកាមាវចរ ក្តី ក្នុងបណ្តារូបភព និង អរូបភពទាំងឡាយ ភពណាមួយក្តី ។ កម្មនោះ របស់បុគ្គលនោះ ឈ្មោះថា កម្មភព ។ ខន្ធទាំងឡាយដែលកើតថ្មីព្រោះកម្មនោះ ឈ្មោះថា ឧបបត្តិភព ។ ចំណែកភពទាំងឡាយមានសញ្ញាភពជាដើម ឈ្មោះថា វត្តុលាយឡំហើយ ពួជ៏ខាងក្នុងនៃឧបបត្តិភពនោះ ។ អត្តវាទុបាទាន ជាបច្ច័យនៃភពទាំងឡាយ ៣ មួយអន្លើដោយប្រភេទ ព្រមទាំងភព ដែលមាននៅខាងក្នុង ដូចរៀបរាប់មកនេះ ។

បុគ្គលខ្លះ (គិត) ថា : សីល និង វត្ត នេះ ដល់នូវសេចក្តីសុខ គឺថានូវការពេញលេញ ដល់បុគ្គលកាលបំពេញ ក្នុងភព គឺសម្បត្តិ ជាកាមាវចរ ក្តី ក្នុងបណ្តារូបភព និង អរូបភពទាំងឡាយ ភពណាមួយ ក្តី ដូច្នេះ ក៏ធ្វើនូវកម្ម គួរដល់ការយល់ឃើញនោះ ដោយអំណាចនៃការប្រកាន់នូវសីល និង វត្ត ។

កម្មនោះ របស់បុគ្គលនោះ ឈ្មោះថា កម្មភព ។ ខន្ធទាំងឡាយដែលកើតថ្មី ព្រោះកម្មនោះ ឈ្មោះថា ឧបបត្តិភព ។ ក៏ភពទាំងឡាយមានសញ្ញាភពជាដើម ឈ្មោះថា វត្តុលាយឡំហើយ ពួជ៏ខាងក្នុង នៃឧបបត្តិភពនោះឯង ។ ក៏ឧបាទាន គឺ សីល និង វត្ត ជាបច្ច័យនៃភព



ទាំងឡាយបី ប្រព្រឹត្តទៅ មួយអន្លើដោយប្រភេទ ព្រមទាំងភពដែលមាននៅខាងក្នុង ដូចរៀបរាប់មកនេះ ។

សេចក្តីវិនិច្ឆ័យ ក្នុងភវនិទ្ទេសនេះ យ៉ាងនេះ គឺបណ្ឌិត គប្បីជ្រាបដោយឧបាយណា ជាបច្ច័យនៃភពណា ភពនោះឯង ។

បើមានពាក្យចោទ ថា : ចុះក្នុងបទនេះ ឧបាទានអ្វី? ជាបច្ច័យ នៃភពណា ដោយប្រការដូចម្តេច? ។ គប្បីឆ្លើយ ថា :

> ឧបាទានណា ជាឧបនិស្សយបច្ច័យ នៃរូបភព
> និង អរូបភពទាំងឡាយ, ឧបាទាននោះ គឺ
> បណ្ឌិតគប្បីជ្រាបថា ជាបច្ច័យ នៃកាមភព
> ដោយបច្ច័យទាំងឡាយ មានសហជាតប្បច្ច័យ
> ជាដើម ។

សេចក្តីអធិប្បាយថា: ឧបាទានទាំង ៤ យ៉ាងនេះឯង ជាបច្ច័យនៃរូបភព និង អរូបភពទាំងឡាយផង នៃភពដែលលោករាប់បញ្ចូលហើយ ក្នុងកាមភពផង នៃឧបបត្តិភព ជាកុសលកម្ម នៃកម្មភពផង ដោយចំណែកតែមួយគត់ ដោយឧបនិស្សយប្បច្ច័យ, ឧបាទាននោះ ជាបច្ច័យនៃកម្មភព ជាអកុសល សម្បយុត្តដោយខ្លួន ក្នុងកាមភព ដោយបច្ច័យទាំងឡាយ មានសហជាតប្បច្ច័យជាដើម ផ្សេងដោយសហ-ជាតប្បច្ច័យ, អញ្ញមញ្ញប្បច្ច័យ, និស្សយប្បច្ច័យ, សម្បយុត្តប្បច្ច័យ, អត្ថិប្បច្ច័យ, អវិគតប្បច្ច័យ និង ហេតុប្បច្ច័យ, តែថា ឧបាទាននោះ ជាបច្ច័យនៃភព ជាវិប្បយុត្ត ដោយឧបនិស្សយប្បច្ច័យហ្នឹងឯង ។

ពាក្យនេះ ជាពាក្យដោយពិស្តារ ក្នុងភព ថា : ភព (កើតព្រម)

ព្រោះមានឧបាទានជាបច្ច័យ ។

(៤០៤) សេចក្ដីវិនិច្ឆ័យនៃទុក្ខទាំងឡាយ មានជាតិទុក្ខជាដើម ក្នុងបទទាំងឡាយមានបទថា “ជាតិ (កើតព្រម) ព្រោះមានភពជាបច្ច័យ” គឺបណ្ឌិតគប្បីជ្រាប តាមន័យដែលលោកពោលហើយ ក្នុងសច្ចនិទ្ទេសផងចុះ ។ ក៏កម្មភពហ្នឹងឯង គឺព្រះមានព្រះភាគ ទ្រង់ប៉ងយកហើយ ត្រង់បទនេះថា “ភព” ។ ព្រោះថា កម្មភពនោះ ជាបច្ច័យនៃជាតិ, ឧបបត្តិភព មិនមែនជាបច្ច័យនៃជាតិទេ ។ ប៉ុន្តែថា កម្មភពនោះ ជាបច្ច័យ នៃជាតិ ដោយចំណែក ២ ដោយអំណាច នៃកម្មប្បច្ច័យ និង ឧបនិស្សយប្បច្ច័យ ដូច្នេះឯង ។

បើអាចារ្យអ្នកចោទ គប្បីចោទ ក្នុងអធិការនេះថា: ចុះពាក្យនេះថា ភពជាបច្ច័យនៃជាតិ តើយើងគប្បីដឹង ដូចម្ដេចបាន? ។

អាចារ្យអ្នកឆ្លើយគប្បីឆ្លើយ ថា : បានជាយើងគប្បីដឹងបាន ព្រោះការសំដែងនូវសេចក្ដីប្លែកគ្នានៃហេតុ សូម្បីនាកាលភាពនៃបច្ច័យខាងក្រៅដ៏ស្មើមាន មានសេចក្ដីប្លែកគ្នា នៃបុគ្គលថោកទាប និង ថ្លៃថ្លាជាដើម ។ ក៏នាកាលភាវៈនៃបច្ច័យទាំងឡាយមានឈាម-ស នៃមាតា និង បិតា និង អាហារជាដើមដ៏ស្មើ មានព្ទដ៏ខាងក្រៅ សេចក្ដីប្លែកគ្នានៃហេតុ មានភាវៈជាអ្នកថោកទាប និង ថ្លៃថ្លាជាដើម រមែងប្រាកដដល់សត្វទាំងឡាយ សូម្បីកាលមានជាគូ (កូនភ្លោះ) ។ ក៏សេចក្ដីប្លែកគ្នានោះ មិនមែនជាឥតហេតុឡើយ ព្រោះមិនមានដល់សត្វទាំងឡាយទាំងពួង សព្វកាលទេ ទាំងមិនមែនជាហេតុដទៃអំពីកម្មភពឡើយ ព្រោះមិនមាននៃហេតុដទៃ ក្នុងសន្តានខាងក្នុង នៃពួកសត្វ ដែលកើតថ្មី ក្នុងភពនោះឡើយ ព្រោះហេតុនោះ សេចក្ដីប្លែកគ្នានោះ ហៅថា ជាហេតុ



នៃកម្មភព ។ ពិតមែន កម្ម ជាហេតុនៃសេចក្ដីផ្សេងគ្នា នៃសត្វទាំងឡាយ មានភាវៈជាអ្នកថោកទាប និង ថ្លៃថ្លាជាដើម ។ ព្រោះហេតុនោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា: កម្ម តែងចែកសត្វទាំងឡាយ ឲ្យថោកទាប និង ថ្លៃថ្លា ។ ព្រោះហេតុនោះ ពាក្យនេះ គឺយើងត្រូវតែដឹង ថា : “ភព ជាបច្ច័យ នៃជាតិ” ។

ក៏កាលបើជាតិមិនមានទេ ឈ្មោះថា ជរា និង មរណៈ ឬ ធម៌ទាំងឡាយមានសោកជាដើម ក៏មិនមាន, តែកាលបើជាតិមាន ជរា និង មរណៈក្ដី ធម៌ទាំងឡាយ មានសេចក្ដីសោកជាដើម ដែលជាប់ចំពោះហើយ ដោយជរា និង មរណៈ នៃជនពាល ដែលធម៌គឺទុក្ខ បានដល់ជរា និង មរណៈពាល់ត្រូវហើយផង ដែលមិនជាប់ទាក់ទងហើយ ដល់ជនពាល ដែលធម៌គឺទុក្ខនោះៗ ពាល់ត្រូវហើយ រមែងមាន ព្រោះហេតុណា, ព្រោះហេតុនោះ ជាតិនេះឯង គឺបណ្ឌិត គប្បីជ្រាបថា ជាបច្ច័យនៃជរា និង មរណៈផង នៃធម៌ទាំងឡាយ មានសោកជាដើមផង ។ ក៏ជាតិនោះ ជាបច្ច័យ ដោយទីបំផុត នៃឧបនិស្សយប្បច្ច័យ ដោយចំណែកមួយពិត ដូច្នេះឯង ។ នេះ ជាសេចក្ដីពិស្ដារ ក្នុងបទទាំងឡាយមានបទថា: “ជាតិ (កើតព្រម) ព្រោះមានភពជាបច្ច័យ” ។

(៤០៥) សេចក្ដីថា : បណ្ដាទុក្ខធម៌ទាំងឡាយនេះ ទុក្ខធម៌ទាំងឡាយ មានសេចក្ដីសោកជាដើម គឺព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ក្នុងទីបំផុត ព្រោះហេតុណា, ព្រោះហេតុនោះ អវិជ្ជាណានោះ គឺព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ក្នុងខាងដើម នៃចក្រគឺភពនេះ យ៉ាងនេះ ថា “សង្ខារទាំងឡាយ (កើតព្រម) ព្រោះមានអវិជ្ជាជាបច្ច័យ, អវិជ្ជានោះ សំរេចហើយ ដោយទុក្ខធម៌ទាំងឡាយ មានសេចក្ដីសោកជាដើម,

*ភវចក្រនេះ បណ្ឌិតគប្បីជ្រាបថា មានការមិនដឹងច្បាស់ ប្រាសហើយចាកអ្នកធ្វើ និង អ្នកសោយ សូន្យចាកសុញ្ញតាទាំង ១២ ប្រការ ប្រព្រឹត្តទៅរឿយៗ ទៀងទាត់” ។*

*បើសំណួរថា: ចុះបណ្ដាទុក្ខធម៌ទាំងឡាយមានជរា និង មរណៈជាដើមនេះ អវិជ្ជា សំរេចហើយដោយទុក្ខធម៌ទាំងឡាយមានសោកជាដើម តើដូចម្ដេច?, ភវចក្រនេះ មានខាងដើម មិនច្បាស់លាស់ដូចម្ដេច?, ភវចក្រ ប្រាសហើយចាកអ្នកធ្វើ និង អ្នកសោយដូចម្ដេច?, ភវចក្រឈ្មោះថា សូន្យចាកភពនៃភវចក្រនោះ មានប្រការ ១២ តើដូចម្ដេច? ។*

*ចម្លើយថា: ក៏ក្នុងបដិច្ចសមុប្បាទ ធម៌ទាំងឡាយនេះ សេចក្ដីសោក, ទុក្ខ, ទោមនស្ស និង ឧបាយាសៈទាំងឡាយ រមែងមានដល់បុគ្គលដែលមិនប្រាសចាកអវិជ្ជា, ក៏ជម្ងឺតា សេចក្ដីខ្សឹកខ្សួល រមែងមានដល់បុគ្គលដែលវង្វេងហើយ (ក៏ដូចគ្នាដែរ) ព្រោះហេតុនោះ កាលបើទុក្ខធម៌ទាំងឡាយ មានសេចក្ដីសោកជាដើមនោះ សំរេចហើយមុន, អវិជ្ជាក៏សំរេចហើយដែរ ។ ម្យ៉ាងវិញទៀត ព្រះពុទ្ធដីកាថា: ហេតុជាដែនកើតនៃអវិជ្ជា (កើតមាន) ព្រោះមានអាសវៈជាដែនកើតមុន គឺព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ។ ក៏ធម៌ទាំងឡាយ មានសេចក្ដីសោកជាដើមនេះ មាន ព្រោះមានអាសវៈ ជាដើមជាដែនកើត ។ សំណួរថា : ព្រោះហេតុអ្វី? ។ ចម្លើយថា : សេចក្ដីសោក មានកាមាសវៈ ជាដែនកើតមុន ក្នុងការប្រាសចាកវត្ថុកាម ។*

*សមដូចជាព្រះមានព្រះភាគ ទ្រង់ត្រាស់ ថា :*

ប្រសិនបើ កាលបើសត្វនោះ មានកាមជាយាន
មានឆន្ទៈ កើតហើយ, កាមទាំងឡាយនោះ



របស់សត្វ រមែងសាបសូន្យ, សត្វនោះ រមែង
ចាប់ពើត ដូចសត្វដែលត្រូវសរមុតហើយ ។

*ដូចជាព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយថា: សេចក្ដីសោក កើតអំពីកាម ។ ចំណែកខាង ធម៌ទាំងឡាយ មានសេចក្ដីសោកជាដើមនេះ ជាធម៌ជាដែនកកើត គឺទិដ្ឋាសវៈ ។ ដូចជាព្រះមានព្រះភាគទ្រង់ត្រាស់ហើយថា: សេចក្ដីសោក, ការខ្សឹកខ្សួល, ទុក្ខទោមនស្ស និងឧបាយាសទាំងឡាយ រមែងកើតមាន ដល់សត្វនោះ ដែលមានសេចក្ដីប្រកាន់ខ្ជាប់ថា រូបគឺអញ រូបជារបស់អញ ព្រោះភាវៈនៃរូបជារបស់ប្រែប្រួលទៅ ។*

*ក៏ធម៌ទាំងឡាយ មានសេចក្ដីសោកជាដើម កើតមាន ព្រោះមានទិដ្ឋាសវៈជាដែនកើត យ៉ាងណា, ធម៌ទាំងឡាយនោះ កើតមាន សូម្បីព្រោះហេតុកកើតនៃភវាសវៈ ក៏យ៉ាងនោះដែរ ។ សមដូចជាព្រះមានព្រះភាគទ្រង់ត្រាស់ហើយថា: ទេវតាទាំងឡាយណានោះ មានអាយុវែង មានពណ៌ ច្រើនដោយសេចក្ដីសុខ ស្ថិតនៅក្នុងវិមានទាំងឡាយដ៏ខ្ពស់ អស់កាលដ៏យូរ គឺថា អស់កាលដ៏វែង, ទេវតាទាំងឡាយនោះឯង ស្ដាប់ធម៌ទេសនា របស់ព្រះតថាគត រមែងដល់នូវភ័យនូវសេចក្ដីស្ញប់ស្ញែង នូវការតក់ស្លុត ។ សេចក្ដីសោក កើតមានដល់ទេវតាទាំងនោះ ដូចជាការឃើញ នូវបុព្វនិមិត្តទាំងឡាយ ៥ របស់ទេវតាទាំងឡាយ គឺភ័យអំពីសេចក្ដីស្លាប់ គម្រាមហើយ ។ ក៏ធម៌ទាំងឡាយនោះ រមែងកើតមាន ព្រោះការកកើតឡើង នៃភវាសវៈ យ៉ាងណាមិញ, ធម៌ទាំងឡាយ ក៏រមែងកើតមាន ព្រោះអវិជ្ជាសវៈកើតឡើង ក៏យ៉ាងនោះដែរ ។ សមដូចជាព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយថា: ម្នាលភិក្ខុទាំងឡាយ!*

បុគ្គលពាលនោះឯង រមែងសោយនូវទុក្ខទោមនស្ស មាន ៣ ប្រការ ក្នុងបច្ចុប្បន្ន ។

ធម៌ទាំងឡាយនេះ កើតមាន ព្រោះមានអាសវៈជាដែនកើត ព្រោះហេតុណា, ព្រោះហេតុនោះ ធម៌ទាំងឡាយនេះ កាលសំរេចញុំាង អាសវៈទាំងឡាយដែលជាហេតុនៃអវិជ្ជា ឲ្យសំរេច, ក៏កាលបើអាសវៈ ទាំងឡាយសំរេចហើយ សូម្បីអវិជ្ជា ក៏សំរេចហើយដែរ ព្រោះកាល បើមានបច្ច័យ ធម៌ដែលកើតពីបច្ច័យ ក៏មានដែរ ។ អវិជ្ជា គឺបណ្ឌិត គប្បីជ្រាបថា សំរេចហើយ ដោយធម៌ទាំងឡាយ មានសេចក្ដីសោកជា ដើម ក្នុងបដិច្ចសមុប្បាទនេះ ត្រឹមតែប៉ុណ្ណេះ ។

ក៏កាលបើអវិជ្ជាសំរេចហើយ ព្រោះកាលបើបច្ច័យមាន ធម៌ដែល កើតពីបច្ច័យក៏មានដែរយ៉ាងនេះឯង, ទីបំផុតនៃការ-តៗ គ្នានៃហេតុ និង ផល យ៉ាងនេះ ដូច្នេះជាដើមថា "សង្ខារទាំងឡាយ (កើតព្រម) ព្រោះ មានអវិជ្ជាជាបច្ច័យ, វិញ្ញាណ (កើតព្រម) ព្រោះមានសង្ខារជាបច្ច័យ" មិនមានទេ ព្រោះហេតុណា, ព្រោះហេតុនោះ ភវចក្រនោះ មានអង្គ ១២ ប្រព្រឹត្តទៅហើយ ដោយអំណាចនៃការចងភ្ជាប់នូវហេតុ និង ផល ទើប សំរេចបានថា "មានខាងដើមមិនច្បាស់លាស់" ។

អាចារ្យអ្នកចោទ គប្បីចោទ ថា : កាលបើមានហេតុ យ៉ាងនេះ ពាក្យនេះថា: សង្ខារទាំងឡាយ (កើតព្រម) ព្រោះមានអវិជ្ជាជាបច្ច័យ ជាពាក្យសំរាប់ពោលខាងដើម រមែងខុសឬទេ? ។

ចម្លើយថា : ពាក្យនេះ មិនមែនជាពាក្យសំរាប់ពោលថា ភវចក្រ មានខាងដើមទេ ។ តែពាក្យនេះ ជាពាក្យសំរាប់ពោលចំពោះ ។

ពិតមែន អវិជ្ជា គឺជាប្រធាន នៃវដ្ដៈទាំងឡាយ ៣ ។ ព្រោះថា



កិលេសវដ្ដៈ ដ៏សេសក្ដី វដ្ដៈទាំងឡាយមានកម្មវដ្ដៈជាដើមក្ដី រមែងរួប រឹតនូវជនពាល ដោយការប្រកាន់នូវអវិជ្ជា ដូចជាសរីរៈនៃពស់ដ៏សេស កាលរួបរឹតនូវដើមដៃ (អ្នកចាប់) ដោយការកាន់យកនូវក្បាលពស់ ។ ក៏នាកាលការកាត់ផ្ដាច់នូវអវិជ្ជា គឺព្រះយោគីធ្វើហើយ ការរួចស្រឡះ ចាកអកុសលទាំងឡាយ មានអវិជ្ជាជាដើមនោះ រមែងមាន ដូចជាកាល បើការកាត់នូវក្បាលពស់ គឺព្រះយោគីធ្វើហើយ ការរួចស្រឡះពី (ការ រុំរួត) ដើមដៃ ដែលពស់រួបរឹតហើយក៏មាន ។ សមដូចជាព្រះមានព្រះ ភាគ ទ្រង់ត្រាស់ពោលហើយថា : ពាក្យជាអាទិ៍ថា ការរលត់នូវសង្ខារ ទាំងឡាយ(កើតព្រម) ព្រោះការរលត់ នៃអវិជ្ជាហ្នឹងឯង ដោយវិរាគធម៌ មិនឲ្យសេសសល់ ។ កាលបើព្រះយោគី កាន់យកនូវធម៌ណា ចំណង ក៏មានការរួច, ការរួចស្រឡះ រមែងមាន, ពាក្យនេះ ជាពាក្យសំរាប់ ពោលនូវធម៌ជាប្រធាននោះ មិនមែនពោលភាវៈ នៃភវចក្រ មានខាង ដើមនោះទេ ។ ទោសជាតមានភវចក្រនេះ គឺបណ្ឌិតគប្បីជ្រាបថា មាន ខាងដើម មិនច្បាស់លាស់ យ៉ាងនេះឯង ។

ការប្រព្រឹត្តិទៅនៃធម៌ទាំងឡាយ មានសង្ខារជាដើម ដោយហេតុ ទាំងឡាយមានអវិជ្ជាជាដើម ព្រោះហេតុណា, ព្រោះហេតុនោះ ភវចក្រ នោះនេះ ឈ្មោះថា ប្រាសចាកបុគ្គលអ្នកកសាងសំសារ មានព្រហ្ម ជា ដើម ដែលកំណត់ហើយ យ៉ាងនេះថា "ព្រហ្ម, មហាព្រហ្ម អ្នកប្រសើរ ដែលបុគ្គលអ្នកចាត់ចែងហើយ" ដទៃពីហេតុ មានអវិជ្ជាជាដើមនោះក្ដី ចាកអ្នកសោយសុខ និង ទុក្ខ គឺដែលខ្ជួនកំណត់ យ៉ាងនេះថា: ក៏អត្តា របស់អញនេះនោះឯង ជាអ្នកពោល ជាអ្នកសោយដូច្នេះក្ដី ។ ភវចក្រ នេះ គឺបណ្ឌិត គប្បីជ្រាបថា: ប្រាសហើយចាកអ្នកធ្វើ និង អ្នកសោយ

ដោយប្រការដូច្នេះ ។

ក៏ក្នុងបដិច្ចសមុប្បាទធម៌នេះ អវិជ្ជា ឈ្មោះថា សូន្យ ដោយភាពទៀង ព្រោះភាពនៃអវិជ្ជានោះ ជាធម្មជាតិ កើតឡើង និង សូន្យទៅវិញជាធម្មតាផង, ដោយសេចក្ដីល្អ ព្រោះជាសង្កិលេសធម៌ ព្រោះភាពនៃអវិជ្ជាសៅហ្មងព្រមផង, ដោយភាពដ៏ល្អ ព្រោះភាវៈនៃអវិជ្ជា ប្រកបព្រមដោយសេចក្ដីសៅហ្មងផង ដោយភាពដ៏ស្រួល ព្រោះភាពនៃអវិជ្ជានោះ គឺការកើតឡើង និងសូន្យទៅបៀតបៀនហើយផង ដោយភាពថាខ្លួន គឺជារបស់ប្រព្រឹត្តទៅ ក្នុងអំណាច ព្រោះជាគ្រឿងប្រព្រឹត្តិទៅជាប់ដោយបច្ច័យផង ដោយភាពថា ខ្លួន ព្រោះជាគ្រឿងប្រព្រឹត្តិទៅ ក្នុងអំណាចផង, សូម្បីអង្គទាំងឡាយ មានសង្ខារជាដើម ក៏ដូចគ្នា ព្រោះហេតុណា, ម្យ៉ាងវិញទៀត អវិជ្ជា មិនមែនខ្លួន មិនមែនរបស់ខ្លួន មិនមែនមានក្នុងខ្លួន មិនប្រព្រឹត្តទៅក្នុងខ្លួន, អង្គទាំងឡាយ មានសង្ខារជាដើមក៏ដូចគ្នា ព្រោះហេតុណា, ព្រោះហេតុនោះ ភវចក្រនេះ គឺបណ្ឌិតគប្បីជ្រាបថា សូន្យ ព្រោះភាពនៃអវិជ្ជាសូន្យចាកវត្ថុ ១២ យ៉ាង ។

(៤០៦) លុះជ្រាប យ៉ាងនេះហើយ គប្បីជ្រាប តទៅទៀត ថា :

អវិជ្ជា និង តណ្ហា ជាឫសគល់ នៃភវចក្រនោះ
កាលទាំងឡាយ នៃអវិជ្ជា និង តណ្ហានោះ
មាន ៣ មានអតីតៈជាដើម, បណ្ដាកាលទាំង
ឡាយនោះ អង្គទាំងឡាយ ២ ក្តី ៨ ក្តី (ដែល
មានមកហើយ) ក្នុងកាលទាំងឡាយ ៣ នោះ
ដោយបំព្រួញនៅត្រឹមតែ ២ ប៉ុណ្ណោះ ។



ចំណែកធម៌ទាំងឡាយ ២ យ៉ាង គឺ “អវិជ្ជា ១, តណ្ហា ១” បណ្ឌិតគប្បីជ្រាបថា ជាមូល នៃភវចក្រនោះៗឯង ។ ភវចក្រនោះ ជាធម្មជាតមាន ២ យ៉ាងគឺ មានអវិជ្ជា ជាឫសគល់ មានវេទនាជាទីបំផុត ព្រោះជាគ្រឿងនាំមក នូវទីបំផុតខាងដើម ១ មានតណ្ហាជាឫសគល់ មានជរានិងមរណៈជាទីបំផុត ព្រោះជាគ្រឿងតភ្ជាប់ដោយទីបំផុតខាងចុង។ ក្នុងភវចក្រទាំងឡាយ ២ យ៉ាងនោះ ភវចក្រខាងដើម គឺលោកពោលហើយដោយអំណាច នៃបុគ្គលដែលជាទិដ្ឋិចរិត, ភវចក្រខាងចុង គឺលោកពោលហើយ ដោយអំណាចនៃបុគ្គលដែលជាតណ្ហាចរិត ។ ក៏អវិជ្ជានៃជនទាំងឡាយជាទិដ្ឋិចរិតក្តី ជាធម្មជាតិ នាំមកនូវសំសារ, តណ្ហារបស់ជនទាំងឡាយ ជាតណ្ហាចរិតក្តី ក៏ជាធម្មជាតិ នាំមកនូវសំសារ ។ ម្យ៉ាងទៀត ភវចក្រ ទី១ (ត្រូវបានព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ) ដើម្បីដកចេញនូវឧច្ឆេទទិដ្ឋិ ព្រោះជាគ្រឿងប្រកាស នូវការផ្ដាច់សូន្យមិនទាន់បាននូវហេតុទាំងឡាយ ព្រោះការកើតឡើងនៃផល ។ ភវចក្រទី២ (ក៏ត្រូវបានព្រះមានព្រះភាគទ្រង់ត្រាស់ហើយ) ដើម្បីដកចេញនូវសស្សតទិដ្ឋិ ព្រោះជាគ្រឿងប្រកាសនូវជរា និង មរណៈ នៃសត្វទាំងឡាយដែលកើតហើយ ។ ម្យ៉ាងវិញទៀត ភវចក្រខាងដើម (ត្រូវបានព្រះមានព្រះភាគទ្រង់ត្រាស់ហើយ) ព្រោះជាគ្រឿងបំភ្លឺនូវប្រវត្តិ តាមលំដាប់ហូរហែ ដោយអំណាចនៃសត្វអ្នកដេកក្នុងគភ៌ ។ ភវចក្រខាងចុង (ត្រូវបានព្រះមានព្រះភាគទ្រង់ត្រាស់ហើយ) ដោយអំណាចនៃឧបបាតិកកំណើត ព្រោះជាគ្រឿងបំភ្លឺនូវការកើតជាមួយគ្នា ។

ឯកាលទាំងបី សំរាប់ភវចក្រនោះ គឺ អតីតកាល, បច្ចុប្បន្នកាល, អនាគតកាល ។

អង្គទាំងឡាយ ២ គឺ "អវិជ្ជា ១, សង្ខារ ១" ក្នុងចំណោមកាលទាំងឡាយបីនោះ គឺបណ្ឌិត គប្បីជ្រាបថា ជាអតីតកាល, អង្គទាំងឡាយ ៨ មានវិញ្ញាណជាដើម មានភពជាទីបំផុត គឺបណ្ឌិត គប្បីជ្រាបថា ជាបច្ចុប្បន្នកាល, អង្គទាំងឡាយ ២ ទៀត គឺជាតិ ១ ជរាមរណៈ១ បណ្ឌិតគប្បីជ្រាបថា ជាអនាគតកាល ដោយអំណាចនៃអង្គទាំងឡាយនេះ មានមកហើយ ដោយសរុប ក្នុងព្រះបាលី [១] ។

(៤០៧) បណ្ឌិតគប្បីជ្រាប យ៉ាងនេះ តទៅទៀត ថា :

ភវចក្រនេះ មាន ទី-ត ៣ គឺ ហេតុ, ផល និង
ហេតុខាងដើម រួបរួម ដោយប្រភេទ ៤ មានកាំ
គឺអាការៈ ២០ មានវដ្តៈ ៣ មិនតាំងនៅនឹងទេ
តែងតែវិលទៅមិនចេះឈប់ឈរ" ។

(សន្ធិ ៣)

បណ្ដាបដិសន្ធិទាំង ៣ នោះ ទី-ត ១ ក្នុងចន្លោះ នៃសង្ខារ និងបដិសន្ធិវិញ្ញាណ ឈ្មោះថា ហេតុផលសន្ធិ គឺៈ ត-ហេតុ និង ផល, ទី-ត ១ ក្នុងចន្លោះ នៃវេទនា និង តណ្ហា ឈ្មោះថា ផលហេតុសន្ធិ គឺ :

(១) ចាប់តាំងពីទំព័រទី១ ដល់ទំព័រទី៣៥៥ គឺលោកសាស្ត្រាចារ្យ ផែន-សុខន ជាអ្នកបកប្រែ ។ គួរឲ្យសោកស្ដាយណាស់...លោកសាស្ត្រាចារ្យ ក៏បានអនិច្ចកម្មទៅ ដោយរោគាពាធ ។ បន្ទាប់មក ខ្ញុំ ភិក្ខុវិនយធរោ មហាយិន-នឿន ក៏បានទាក់ទងឲ្យលោកសាស្ត្រាចារ្យ នូ-ឌីម ជួយបកប្រែ ចាប់ពីទំព័រទី ៣៥៦ ដល់ទំព័រ ៣៥៧ ត្រង់គាថានេះ ហើយលោកសាស្ត្រា ក៏បានឈប់ទៅវិញ ព្រោះជាប់រវល់ខ្លាំងពេក ។
ដូច្នេះ កិច្ចការនេះបានធ្លាក់មកលើរូបខ្ញុំជាអ្នកបកប្រែបន្ត រហូតដល់ចប់ ហើយក៏បានរៀបរៀងសំរេចកើតបានជា "វិសុទ្ធិមគ្គប្រែ ភាគ ទី៣" នេះមក ។



ត ផល ជាមួយនឹងហេតុ, ទី-ត ១ ក្នុងចន្លោះនៃភព និងជាតិ ឈ្មោះថា ហេតុផលសន្ធិ គឺៈ ត ហេតុជាមួយនឹងផល ព្រោះហេតុនោះ ភវចក្រនេះ គឺបណ្ឌិតគប្បីជ្រាបថា "មានសន្ធិ ៣ មានពាក្យថា ហេតុផល និង ផលហេតុ ជាបទដើម" យ៉ាងដូច្នេះឯង ។

(សង្គហៈ ៤)

ចំណែកសង្គហៈទាំងឡាយ ដែលកំណត់ដោយអង្គខាងដើម និងខាងចុងនៃសន្ធិទាំងឡាយ ទើបមាន ៤ ។ គឺយ៉ាងដូចម្ដេចខ្លះ ។ គឺអវិជ្ជា និងសង្ខារជាសង្គហៈទី១, វិញ្ញាណ, នាមរូប, សឡាយតនៈ, ផស្សៈ និង វេទនា ជាសង្គហៈ ទី២ ។ តណ្ហា, ឧបាទាន និង ភព ជាសង្គហៈទី៣ ។ ជាតិ, ជរា និង មរណៈ ជាសង្គហៈ ទី៤ ព្រោះហេតុនោះ ភវចក្រ នេះ បណ្ឌិតគប្បីជ្រាបថា "មានសង្គហៈ ៤ ប្រភេទ" យ៉ាងដូច្នេះឯង ។

(អាការៈ ២០)

មួយទៀត ភវចក្រនេះ បណ្ឌិតគប្បីជ្រាបថា មានអាការៈ ២០ ដោយកាំ ពោលគឺអាការៈ ២០ នោះឯង គឺ :

ហេតុ ក្នុងអតីតកាល មាន ៥, ផល ក្នុងកាល
ឥឡូវនេះ មាន ៥, ហេតុ ក្នុងកាលឥឡូវនេះ
មាន ៥, ផល ក្នុងកាលតទៅ មាន ៥ ។

(អតីតហេតុ ៥)

ក្នុង ៤ យ៉ាងនោះ ពាក្យថា "ហេតុ ក្នុងអតីតៈ មាន ៥" សេចក្ដីថា ធម៌ ២ ប្រការនេះ គឺ អវិជ្ជា និង សង្ខារ គឺលោកពោលហើយហ្នឹងឯង ជាដំបូង ។ តែព្រោះហេតុដែលបុគ្គលមិនដឹង រមែងតក់ស្លុត បុគ្គល

អ្នកតក់ស្លុត រមែងប្រកាន់មាំ ព្រោះការប្រកាន់មាំជាបច្ច័យរបស់បុគ្គលនោះ ភព ក៏កើតមាន ហេតុនោះ សូម្បីតណ្ហា, ឧបាទាន និង ភព គឺលោក សង្គ្រោះយកហើយ ។ ព្រោះហេតុនោះ ទើបព្រះធម្មសេនាបតីសារីបុត្រ លោកពោលថា “សេចក្ដីវង្វេង ក្នុងបុរិមកម្មភព គឺជាអវិជ្ជា, ចេតនាដែលប្រមូលមកហើយ ក្នុងបុរិមកម្មភព ជាសង្ខារ, ចំណង់ក្នុងបុរិមកម្មភព ជាតណ្ហា, ការជាប់ជំពាក់ ក្នុងបុរិមកម្មភព ជាឧបាទាន, ចេតនា ក្នុងបរិមកម្មភព ឈ្មោះថា ភព ព្រោះហេតុនោះ ធម៌ទាំង ៥ នេះ ជាបច្ច័យនៃបដិសន្ធិ ក្នុងបរិមកម្មភព ក្នុងភពនេះ ដូច្នេះឯង ។

បណ្ដាបទទាំងនោះ បទថា “ក្នុងបរិមកម្មភព” បានដល់ កម្មភពដែលមានមកពីដើម ។ សេចក្ដីថា “ក្នុងកម្មភព ដែលសត្វធ្វើ ក្នុងអតីតជាតិ” ។

ពាក្យថា “មោហៈ ឈ្មោះថា អវិជ្ជា” មានសេចក្ដីថា: សេចក្ដីវង្វេង ក្នុងធម៌ដែលជាហេតុ ឲ្យវង្វេងទាំងឡាយ មានទុក្ខជាដើម ក្នុងកាលនោះ ឯណាមួយ, បុគ្គលដែលវង្វេងហើយ រមែងធ្វើកម្ម ដោយសេចក្ដីវង្វេងណាមួយ, សេចក្ដីវង្វេងនោះ ឈ្មោះថា អវិជ្ជា ។

ពាក្យថា “ចេតនាដែលប្រមូលទុកហើយ ឈ្មោះថា សង្ខារ” បានដល់ ចេតនាខាងដើមឯណា របស់បុគ្គលអ្នកធ្វើកម្មនោះ ប្រៀបដូចជាចេតនាខាងដើម ដែលកើតឡើងដល់ទាយក អ្នកញុំាងចិត្តឲ្យកើតឡើងថា “អាត្មាអញនឹងឲ្យទាន” ដូច្នេះ ហើយចាត់ចែង នូវឧបករណ៍ ក្នុងទានទាំងឡាយ រហូត ១ ខែក្ដី ១ ឆ្នាំក្ដី ។ ចំណែកចេតនា របស់ទាយកនោះ អ្នកដាក់នូវទក្ខិណាទាន លើដៃនៃបដិគ្គាហកៈទាំងឡាយ លោកហៅថា “ភព” ។ ន័យមួយទៀត ចេតនា ក្នុងជវនៈទាំងឡាយ ៦ ដែល



ជាចិត្តមានអាវជ្ជនៈតែមួយ ឈ្មោះថា ចេតនាដែលប្រមូលមក ឈ្មោះថាជាសង្ខារ, ចេតនា ទី៧ ឈ្មោះថា ភព, ឬថា ចេតនា គ្រប់យ៉ាងឈ្មោះថា ភព, ធម៌ទាំងឡាយដែលសម្បយុត្ត (ដោយចេតនានោះ) ឈ្មោះថា ចេតនា ដែលប្រមូលមក ចាត់ជាសង្ខារ ។

ពាក្យថា “ចំណង់ ឈ្មោះថា តណ្ហា” សេចក្ដីថា: កាលបើបុគ្គលកំពុងធ្វើកម្ម សេចក្ដីចំណង់ គឺសេចក្ដីប្រាថ្នា ក្នុងឧបបត្តិភព ដែលជាផល នៃកម្មនោះឯណា, សេចក្ដីចំណង់នោះ ឈ្មោះថា តណ្ហា ។

ពាក្យថា “ការចូលទៅជិត(ប្រកាន់មាំ)ឈ្មោះថាឧបាទាន” សេចក្ដីថា ការធ្វើកម្មនេះឯណា ដែលជាបច្ច័យនៃកម្មភព ហើយជាប់ជំពាក់ គឺកាន់យក គឺប្រកាន់មាំដែលប្រព្រឹត្តទៅ ដោយន័យថា “អាត្មាអញ នឹងសេពនូវកាមទាំងឡាយ ក្នុងទីឈ្មោះនោះ, អាត្មាអញនឹងសូន្យ” ដូច្នេះជាដើម, សេចក្ដីប្រកាន់មាំនេះ ឈ្មោះថា ឧបាទាន ។

ពាក្យថា “ចេតនា ឈ្មោះថា ភព” សេចក្ដីថា: ចេតនាដែលបានពោលមកហើយ ក្នុងទីបំផុតនៃការប្រមូលមក ឈ្មោះថា ភព បណ្ឌិតគប្បីជ្រាបសេចក្ដីអធិប្បាយដូច្នេះឯង ។

(ផលក្នុងបច្ចុប្បន្ន ៥)

ពាក្យថា “ក្នុងពេលឥឡូវនេះ ផល មាន ៥” បានដល់ អង្គមានវិញ្ញាណជាដើម មានវេទនាជាទីបំផុត មកហើយ ក្នុងបាលីហ្នឹងឯង ។ ដូចព្រះអង្គត្រាស់ថា: បដិសន្ធិ ក្នុងបច្ចុប្បន្នភពនេះ ឈ្មោះថា វិញ្ញាណ, ការចុះកាន់(គភ៌) ក្នុងបច្ចុប្បន្នភពនេះ ឈ្មោះថា នាមរូប, សេចក្ដីជ្រះថ្លាក្នុងបច្ចុប្បន្នភព ឈ្មោះថា អាយតនៈ, ភាវៈដែលប៉ះទង្គិចអារម្មណ៍ក្នុងបច្ចុប្បន្នភព ឈ្មោះថា ផស្សៈ, ការសោយ (ផល) ក្នុងបច្ចុប្បន្នភព

ឈ្មោះថា វេទនា ព្រោះហេតុនោះ ធម៌ទាំង៥ នេះ មាន ក្នុងឧបបត្តិភព នេះ ព្រោះកម្មដែលបុគ្គលធ្វើហើយ ក្នុងភពខាងដើមជាបច្ច័យ ។

បណ្តាពាក្យទាំងនោះ ពាក្យថា "បដិសន្ធិ ឈ្មោះថា វិញ្ញាណ" សេចក្តីថា: ធម្មជាតណា ដែលលោកហៅថា "បដិសន្ធិ" ព្រោះកើតឡើង ដោយអំណាចការតភ្ជាប់ចំពោះភពដទៃ, ធម្មជាតនោះ ឈ្មោះថា វិញ្ញាណ ។

ពាក្យថា "ការចុះកាន់(គភ៌) ឈ្មោះថា នាមរូប" សេចក្តីថា: ការចុះកាន់នៃរូបធម៌ និង អរូបធម៌ទាំងឡាយ ក្នុងគភ៌ ដូចជាមកហើយចូលទៅ ក្នុងគភ៌ឯណា, នេះ ឈ្មោះថា នាមរូប ។

ពាក្យថា "សេចក្តីជ្រះថា ឈ្មោះថា អាយតនៈ" នេះ លោកពោលហើយ ដោយអំណាចនៃអាយតនៈ ៥ មានចក្ខ្វាយតនៈជាដើម ។

ពាក្យថា "ភាវៈប៉ះទង្គិច(អារម្មណ៍) ឈ្មោះថា ផស្សៈ" សេចក្តីថា សភាវៈណា ប៉ះ គឺទង្គិចនូវអារម្មណ៍ កើតឡើង, សភាវៈនេះ ឈ្មោះថា ផស្សៈ ។

ពាក្យថា "កិរិយាសោយ (វិបាក) ឈ្មោះថា វេទនា" សេចក្តីថា ការសោយនូវវិបាកឯណា ដែលកើតឡើងហើយ ព្រមទាំងបដិសន្ធិវិញ្ញាណក្តី ព្រមទាំងផស្សៈ ដែលមានសឡាយតនៈ ជាបច្ច័យក្តី, ការសោយ នូវវិបាកនោះ ឈ្មោះថា វេទនា ។ បណ្ឌិត គប្បីជ្រាបសេចក្តីអធិប្បាយ យ៉ាងនេះឯង ។

(បច្ចុប្បន្នហេតុ ៥)

ពាក្យថា "ហេតុក្នុងពេលឥឡូវនេះ (មាន) ៥" បានដល់ កិលេសជាតិ មានតណ្ហាជាដើម ។ កិលេសជាតិ មានតណ្ហា ជាដើមនោះ មក



ហើយ ក្នុងបាលី ក៏គឺតណ្ហា, ឧបាទាន និង ភព ។ តែកាលបើភព គឺលោកកាន់យកហើយ, សង្ខារ ដែលជាបុព្វភាគនៃភពនោះក្តី ដែលសម្បយុត្តហើយជាមួយនឹងភពនោះក្តី គឺលោកកាន់យកហើយផងដែរ ក៏ដោយការកាន់យកតណ្ហា ឧបាទាន, អវិជ្ជា ដែលសម្បយុត្តហើយដោយតណ្ហា និង ឧបាទាននោះ ឬ បុគ្គលដែលវង្វេងហើយដោយអវិជ្ជាណា, អវិជ្ជានោះ ក៏ឈ្មោះថា គឺលោកកាន់យកហើយដូចគ្នាដែរ ព្រោះហេតុនោះ បច្ចុប្បន្នហេតុ ទើបមាន ៥ យ៉ាងនោះឯង ។ ព្រោះហេតុនេះ ព្រះសារីបុត្រ ពោលថា "ព្រោះភាវៈនៃអាយតនៈទាំងឡាយ ចាស់ក្លាហើយ ក្នុងភពនេះ មោហៈ ឈ្មោះថា អវិជ្ជា, ចេតនា ដែលប្រមូលមកហើយ ឈ្មោះថា សង្ខារ, ចំណង់ ឈ្មោះថា ភព, ការចូលទៅជិត (ការប្រកាន់ខ្ជាប់) ឈ្មោះថា ឧបាទាន, ចេតនា ឈ្មោះថា ភព ព្រោះហេតុនោះ ធម៌ទាំងឡាយនេះ ក្នុងកម្មភពនេះ ជាបច្ច័យនៃបដិសន្ធិ បន្តទៅ" ។

បណ្តាពាក្យទាំងនោះ ពាក្យថា "ព្រោះភាវៈនៃអាយតនៈទាំងឡាយក្នុងភពនេះ ចាស់ក្លាហើយ" គឺលោកសំដែងសេចក្តីវង្វេងស៊ប់ ក្នុងកាលដែលធ្វើកម្ម នៃបុគ្គលអ្នកមានអាយតនៈចាស់ក្លាហើយ ។

ពាក្យដ៏សេស មានសេចក្តីរាក់មែនពិត ។

(ផលខាងអនាគត ៥)

ពាក្យថា "ផលក្នុងកាលតទៅ ៥" បានដល់ អង្គ ៥ មានវិញ្ញាណជាដើម ។ ធម៌ទាំង ៥ នោះ លោកពោលហើយ ដោយការកាន់យកថាជាតិ ។ ចំណែកជរា និង មរណៈ គឺជរា និង មរណៈនៃធម៌ទាំង ៥ នោះឯង ។ ហេតុនោះ ទើបព្រះសារីបុត្រ ពោលថា "បដិសន្ធិ ក្នុងភពតទៅ ជាវិញ្ញាណ, កិរិយាចុះកាន់គភ៌ ក្នុងភពតទៅ ឈ្មោះថា នាមរូប,

សេចក្ដីជ្រះថ្លា ក្នុងភព តទៅ ឈ្មោះថា អាយតនៈ, សភាវៈប៉ះទង្គិចអារម្មណ៍ ក្នុងភព តទៅ ឈ្មោះថា ផស្សៈ, ការសោយអារម្មណ៍ ក្នុងភព តទៅ ឈ្មោះថា វេទនា ហេតុនោះ ធម៌ទាំងឡាយ៥ យ៉ាងនេះ មានក្នុងឧបបត្តិភព បន្តទៀត ព្រោះកម្មដែលបុគ្គលធ្វើហើយ ក្នុងភពនេះជាបច្ច័យ ។ ភវចក្រនេះ មានកាំ គឺអាការៈ ២០ ដូចរៀបរាប់មកនេះឯង ។

(វដ្ដៈ ៣ យ៉ាង)

ចំណែកក្នុងបទថា "ភវចក្រ មានវដ្ដៈ ៣ វិលទៅមិនឈប់" នេះ មានសេចក្ដីអធិប្បាយថា: ភវចក្រនេះ មានវដ្ដ ៣ ដោយវដ្ដទាំងឡាយ ៣ នេះ គឺ: សង្ខារ និង ភពជាកម្មវដ្ដៈ, អវិជ្ជា, តណ្ហា និង ឧបាទានជាកិលេសវដ្ដ, វិញ្ញាណ, នាមរូប, សឡាយតនៈ, ផស្សៈ និង វេទនាជាវិបាកវដ្ដ បណ្ឌិតគប្បីជ្រាបថា កិលេសវដ្ដៈ មិនទាន់សាបសូន្យ ដរាបណា ក៏ឈ្មោះថា រមែងវិលទៅ ព្រោះប្រព្រឹត្តទៅជុំវិញ ម្ដងហើយម្ដងទៀត, ឈ្មោះថា មិនចេះឈប់ឈរ ព្រោះមានបច្ច័យពុំទាន់សាបសូន្យនោះឯង ដរាបនោះ ។

(៤០៨) ភវចក្រនេះនោះ កាលវិលទៅ យ៉ាងនេះ

> បណ្ឌិត គប្បីជ្រាប ដោយការកើតអំពីសច្ចៈ ១,
> ដោយកិច្ច ១, ដោយគ្រឿងរារាំង ១, ដោយ
> ឧបមាទាំងឡាយ ១, ដោយការផ្សេងគ្នា នៃ
> គម្ភីរភាព ១, ដោយការផ្សេងគ្នានៃន័យ ១
> តាមសមគួរ ។

បណ្ដាបទទាំងនោះ កម្មដែលជាកុសល និង អកុសល គឺលោក



ពោលហើយ ក្នុងសច្ចវិភង្គ ថា "សមុទយសច្ចៈ" ដោយមិនផ្សេងពីគ្នា ព្រោះហេតុណា, ព្រោះហេតុនោះ ក្នុងបទថា "អវិជ្ជាបច្ចយា សង្ខារា" ជាដើម សេចក្ដីថា សង្ខារ (កើតមាន)ព្រោះអវិជ្ជា ឈ្មោះថាទុតិយសច្ចៈ កើតមកអំពីទុតិយសច្ចៈ, វិញ្ញាណ (កើតមាន) ព្រោះសង្ខារទាំងឡាយជាបឋមសច្ចៈ កើតអំពីទុតិយសច្ចៈ, អង្គទាំងឡាយ មាននាមរូប ជាដើម មានវិបាកវេទនាជាទីបំផុត (កើតមាន) ព្រោះវិញ្ញាណជាដើម ជាបឋមសច្ចៈ កើតអំពីបឋមសច្ចៈ, តណ្ហា (កើតមាន) ព្រោះវេទនាជាទុតិយសច្ចៈ កើតអំពីបឋមសច្ចៈ, ឧបាទាន (កើតមាន) ព្រោះតណ្ហាជាទុតិយសច្ចៈ កើតអំពីទុតិយសច្ចៈ, ភព (កើតមាន) ព្រោះឧបាទានជាបឋមសច្ចៈ និង ទុតិយសច្ចៈ ទាំង ២ យ៉ាង កើតអំពីទុតិយសច្ចៈ, ជាតិ (កើតមាន) ព្រោះភព ជាបឋមសច្ចៈ កើតអំពីទុតិយសច្ចៈ, ជរា និង មរណៈ (កើតមាន) ព្រោះជាតិ ជាបឋមសច្ចៈ កើតអំពីបឋមសច្ចៈ, ព្រោះហេតុដូច្នោះ បណ្ឌិត គប្បីជ្រាបភវចក្រនេះ ដោយកើតអំពីសច្ចៈ តាមសមគួរ យ៉ាងដូច្នេះ ជាដំបូង ។

(ដោយកិច្ច)

ម្យ៉ាងវិញទៀត ក្នុងអង្គទាំងឡាយនោះ អវិជ្ជា តែងនាំសត្វទាំងឡាយឲ្យវង្វេង ក្នុងវត្ថុទាំងឡាយ និង ជាបច្ច័យ ដើម្បីសេចក្ដីប្រាកដឡើងនៃសង្ខារទាំងឡាយ, ដូចគ្នានោះដែរ សង្ខារទាំងឡាយតាក់តែងនូវសង្ខតធម៌ និង ជាបច្ច័យនៃវិញ្ញាណផងដែរ, សូម្បីវិញ្ញាណ ក៏ទទួលដឹងនូវវត្ថុ(អារម្មណ៍) និង ជាបច្ច័យនៃនាមរូបផងដែរ, ឯនាមរូបសោតក៏ឧបត្ថម្ភគាំទ្រ ដល់គ្នានឹងគ្នា និង ជាបច្ច័យ នៃសឡាយតនៈទៀតផង, សូម្បីសឡាយតនៈ ក៏រមែងប្រព្រឹត្តទៅ ក្នុងវិស័យរបស់ខ្លួន និង ជា

បច្ច័យនៃផស្សៈថែមទៀត, ឯផស្សៈ រមែងពាល់ត្រូវនូវអារម្មណ៍ និង ជាបច្ច័យនៃវេទនាផងដែរ, វេទនាសោត ក៏សោយនូវរស អារម្មណ៍ និង ជាបច្ច័យនៃតណ្ហាថែមទៀត, សូម្បីតណ្ហា ក៏ត្រេកអររីករាយ ក្នុងធម៌ដែលជាទីតាំង នៃសេចក្ដីត្រេកអររីករាយ និង ជាបច្ច័យនៃឧបាទានផង, សូម្បីឧបាទាន ក៏ប្រកាន់មាំ ក្នុងធម៌ដែលជាទីតាំងនៃឧបាទាន និង ជាបច្ច័យនៃភពដែរ, ឯភព ក៏រាលដាលទៅក្នុងគតិផ្សេងៗ និងជាបច្ច័យនៃជាតិថែមទៀត, ចំណែកជាតិ ក៏ញាំងខន្ធទាំងឡាយឲ្យកើតឡើង និង ជាបច្ច័យនៃជរាមរណៈ ព្រោះប្រព្រឹត្តទៅ ដោយភាវៈនៃការកើតឡើងនៃខន្ធទាំងឡាយនោះផងដែរ ។ ឯជរា មរណៈ ក៏គ្របសង្កត់នូវការចាស់ក្លា និង ការបែកធ្លាយនៃខន្ធទាំងឡាយ និង ជាបច្ច័យនៃការកើតប្រាកដនៃភពដទៃទៀត ព្រោះជាទីតាំងនៃទុក្ខទាំងឡាយ មានសោកជាដើម ព្រោះហេតុណា, ព្រោះហេតុនោះ ភវចក្រនេះ បណ្ឌិត គប្បីជ្រាបសូម្បីដោយកិច្ច គឺការប្រព្រឹត្តិទៅ ដោយ ២ យ៉ាង ក្នុងបទទាំងពួងតាមសមគួរចុះ ។

(ដោយគ្រឿងរារាំង)

(៤០៩) មួយទៀត បណ្ដាបទទាំងនោះ បទថា "សង្ខារ (កើតមាន) ព្រោះអវិជ្ជា ជាបច្ច័យ" នេះ ជាគ្រឿងបដិសេធនូវទស្សនៈថា មានអ្នកធ្វើ(អ្នកសាង) ។ បទថា "វិញ្ញាណ(កើតមាន) ព្រោះសង្ខារជាបច្ច័យ" គឺជាគ្រឿងបដិសេធ រារាំងនូវទស្សនៈថា : អត្តៈ គឺខ្លួន កំរើកបាន ។ បទថា "នាមរូប (កើតមាន) ព្រោះវិញ្ញាណ ជាបច្ច័យ" គឺជាគ្រឿងបដិសេធនូវសេចក្ដីសំគាល់ថា ជាដុំ ព្រោះសំដែងនូវការបែកធ្លាយ នៃវត្ថុដែលបុគ្គលពោលកំណត់ថា "អត្តា" ដូច្នេះ ។ បទថា "សឡាយតនៈ



(កើតមាន) ព្រោះនាមរូបជាបច្ច័យ" ជាដើម ជាគ្រឿងរារាំងនូវទស្សនៈមានការឃើញថា "ខ្លួនឃើញ ។ល។ ខ្លួនដឹង, ខ្លួនពាល់ត្រូវ, ខ្លួនសោយ, ខ្លួនត្រេកត្រអាល, ខ្លួនប្រកាន់មាំ, ខ្លួនមាន, ខ្លួនកើត, ខ្លួនចាស់គ្រាំគ្រា, ខ្លួនស្លាប់" ដូច្នេះជាដើម ព្រោះហេតុណា, ព្រោះហេតុនោះ ភវចក្រនេះ បណ្ឌិតគប្បីជ្រាប សូម្បីដោយគ្រឿងរារាំង(បដិសេធ) នូវការយល់ឃើញខុស តាមសមគួរ ។

(ដោយឧបមា)

ម្យ៉ាងទៀត ក្នុងអង្គទាំងនោះ អវិជ្ជា ប្រៀបដូចមនុស្សខ្វាក់ ព្រោះមិនឃើញនូវធម៌ ដោយអំណាចនៃលក្ខណៈរបស់ខ្លួន និង សាមញ្ញ-លក្ខណៈ, សង្ខារ (កើតមាន) ព្រោះអវិជ្ជា ជាបច្ច័យ ប្រៀបដូចជាការជាន់ទៅផ្លាតនៃបុគ្គលដែលខ្វាក់, វិញ្ញាណ (កើតមាន) ព្រោះសង្ខារ ជាបច្ច័យ ប្រៀបបីដូចជាការដួលចុះ នៃបុគ្គលដែលជាន់ផ្លាតហើយ, នាមរូប (កើតមាន) ព្រោះវិញ្ញាណ ជាបច្ច័យ ប្រៀបដូចជាការកើតឡើង នៃបូស នៃបុគ្គលដែលដួលហើយ, សឡាយតនៈ (កើតមាន) ព្រោះនាមរូប ជាបច្ច័យ ប្រៀបដូចជាក្បាលបូសដែលបែក, ផស្សៈ (កើតមាន) ព្រោះសឡាយតនៈជាបច្ច័យ ប្រៀបដូចជាការដំ ដែលមកប៉ះនូវក្បាលបូស, វេទនា (កើតមាន) ព្រោះផស្សៈជាបច្ច័យ ប្រៀបដូចជាសេចក្ដីទុក្ខដែលកើតឡើង ព្រោះការប៉ះទង្គិច, តណ្ហា (កើតមាន) ព្រោះវេទនាជាបច្ច័យ ប្រៀបដូចជាសេចក្ដីប្រាថ្នា និង ការដោះស្រាយ(បំបាត់) នូវសេចក្ដីទុក្ខ, ឧបាទាន (កើតមាន) ព្រោះតណ្ហាជាបច្ច័យ ប្រៀបដូចជាការកាន់យកនូវថ្នាំ ដែលជាពិសពុល ដោយការប្រាថ្នា និង ការដោះស្រាយ (បំបាត់នូវទុក្ខ), ភព (កើតមាន) ព្រោះមានឧបាទានជាបច្ច័យ

ប្រៀបដូចការលាបថ្នាំដែលមានពិសពុលដែលខ្លួនកាន់យកហើយ, ជាតិ (កើតមាន) ព្រោះភពជាបច្ច័យ ប្រៀបដូចជាការកើតឡើងនៃបូសដែលក្លាយ ព្រោះការលាបថ្នាំដែលមានពិសពុល, ជរាមរណៈ (កើតមាន) ព្រោះជាតិជាបច្ច័យ ប្រៀបដូចជាការបែកធ្លាយនៃបូស ព្រោះបូសដែលក្លាយ ព្រោះហេតុណា, ម្យ៉ាងទៀត បណ្ដាអង្គទាំងនោះ អវិជ្ជា តែង គ្របសង្កត់ នូវសត្វទាំងឡាយ ដោយការធ្វើមិនឲ្យប្រតិបត្តិ ឬក៏ ឲ្យប្រតិបត្តិខុស ប្រៀបដូចជាគម្របដែលគ្របបិទភ្នែកទាំងពីរជិត, បុគ្គលពាល ដែលត្រូវអវិជ្ជានោះ គ្របសង្កត់ហើយ តែងតែវេចខ្ចប់ រុំព័ទ្ធខ្លួន ដោយសង្ខារទាំងឡាយដែលនាំទៅរកភពថ្មី ប្រៀបដូចជាកូននាង រុំព័ទ្ធខ្លួន (សង្ខារ) ដោយចំណែកនៃសរសៃនៃសូត្រ, វិញ្ញាណ ដែលសង្ខារគ្រប់គ្រងហើយ រមែងបាននូវទីអាស្រ័យ ក្នុងគតិទាំងឡាយ ប្រៀបដូចជាព្រះរាជកុមារ ដែលបរិវារយកទៅគ្រប់គ្រងរក្សាហើយ រមែងបាននូវការឧបត្ថម្ភ ក្នុងរាជសម្បត្តិ, វិញ្ញាណ ញ៉ាំងនាមរូបមានច្រើនប្រការឲ្យកើតឡើង ក្នុងបដិសន្ធិ ព្រោះត្រិះរិះពិចារណានូវអារម្មណ៍ដែលជានិមិត្តនៃឧបបត្តិ ប្រៀបដូចជាអ្នកលេងល្បិចកល (លេងសៀក) ធ្វើជាល្បិចកល ឲ្យកើតឡើងច្រើនប្រការ, សឡាយតនៈ ដែលតាំងនៅស៊ប់ហើយ ក្នុងនាមរូប រមែងដល់នូវសេចក្ដីចម្រើនលូតលាស់ទូលំទូលាយ ប្រៀបដូចជាគុម្ពឈើ ក្នុងព្រៃដែលដុះតាំងនៅស៊ប់ ក្នុងផែនដីដែលមានជីវជាតិល្អ រមែងដល់នូវការលូតលាស់ចំរើនឡើង, ផស្សៈ កើតឡើង ព្រោះការប៉ះទង្គិចនៃអាយតនៈ ប្រៀបដូចជាភ្លើងកើតឡើង ព្រោះការសង្កៀតនៃឈើដែលសង្កៀតខាងលើ, វេទនា កើតឡើង ដល់បុគ្គលដែលត្រូវផស្សៈពាល់ត្រូវហើយ ប្រៀបដូចជាកំដៅដែលកើតឡើង ដល់



បុគ្គលដែលត្រូវភ្លើងពាល់ត្រូវហើយ, តណ្ហា រមែងចំរើនឡើង ដល់បុគ្គលដែលកំពុងតែសោយវេទនា ប្រៀបដូចជាការស្រេកឃ្លាន កើតច្រើនឡើង ដល់បុគ្គលដែលផឹកទឹកសមុទ្រ, បុគ្គលដែលស្រេកឃ្លានហើយ(ដោយតណ្ហា) រមែងធ្វើសេចក្ដីប្រាថ្នា ក្នុងភពទាំងឡាយ ប្រៀបដូចបុគ្គលដែលស្រេកទឹក ប្រាថ្នាក្នុងការផឹកទឹក, ការធ្វើសេចក្ដីប្រាថ្នានោះ ជាការប្រកាន់មាំ របស់បុគ្គលនោះ, បុគ្គលនោះ តែងប្រកាន់មាំនូវភព ព្រោះឧបាទាន ប្រៀបដូចជាត្រីត្របាក់សន្ទូចជាប់ ព្រោះសេចក្ដីលោភលន់ក្នុងចំណី(នុយ), កាលបើភពមាន, ជាតិក៏មាន, ប្រៀបដូចជាកាលបើមានពូជ, ពន្លក ក៏មាន, ជរាមរណៈ រមែងកើតមាន ដល់បុគ្គលដែលកើតហើយដោយពិត ប្រៀបដូចជាការរលំដួល ដែលកើតមានដល់ដើមឈើ ដែលកើតហើយដោយពិត ដូច្នោះឯង ព្រោះហេតុណា, ព្រោះហេតុនោះ ភវចក្រនេះ បណ្ឌិត គប្បីជ្រាប ដោយឧបមាទាំងឡាយ តាមសមគួរ ដូចបានពណ៌នាមកនេះឯង ។

(ដោយការផ្សេងគ្នានៃគម្ភីរភាព)

(៤១០) មួយវិញទៀត ពាក្យជាបាលីថា “ម្នាលអានន្ទ ក៏បដិច្ចសមុប្បាទនេះ ជាធម៌ជ្រាលជ្រៅផង ការប្រាកដចេញមក ក៏ជ្រាលជ្រៅផងដែរ” ដូច្នេះ គឺព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ សំដៅយកនូវភាវៈនៃបដិច្ចសមុប្បាទនោះ ជាធម៌ជ្រាលជ្រៅ ដោយអត្ថផង ដោយធម៌ផង ដោយការសំដែងផង ដោយបដិវេធផង ព្រោះហេតុណា, ព្រោះហេតុនោះ ភវចក្រនេះ គឺបណ្ឌិត គប្បីជ្រាប ដោយការផ្សេងគ្នានៃគម្ភីរភាព តាមសមគួរ ។

(ជ្រាលជ្រៅដោយផល)

ក្នុងគម្ពីរភាពទាំងនោះ អត្ថគឺភាពនៃជរាមរណៈ កើតឡើងប្រព្រឹត្តទៅព្រម ព្រោះជាតិជាបច្ច័យ ឈ្មោះថា ជាធម៌ជ្រាលជ្រៅ ព្រោះអត្ថគឺភាពនៃជរា និង មរណៈប្រព្រឹត្តទៅព្រម ព្រោះជាតិជាបច្ច័យ យ៉ាងនេះ គឺៈ ជរាមរណៈ មិនមានអំពីជាតិ ក៏មិនមែនដែរ និង ប្រាសចាកជាតិជរាមរណៈ នឹងមានអំពីហេតុដទៃ ក៏មិនមែនដែរ ហើយជរាមរណៈនេះ រមែងប្រព្រឹត្តទៅព្រមអំពីជាតិ ដោយប្រការដូច្នេះ ជាធម៌ដែលដឹងបានដោយកម្រ, ន័យដូចគ្នានោះដែរ អត្ថគឺភាពនៃជាតិ កើតឡើង ប្រព្រឹត្តទៅព្រម ព្រោះភពជាបច្ច័យ ។ល។ អត្ថ គឺភាវៈនៃសង្ខារទាំងឡាយ កើតឡើង ប្រព្រឹត្តទៅព្រម ព្រោះអវិជ្ជាជាបច្ច័យ សុទ្ធតែជាធម៌ជ្រាលជ្រៅ ព្រោះហេតុណា, ព្រោះហេតុនោះ ភវចក្រនេះ ទើបឈ្មោះថា ជ្រាលជ្រៅដោយអត្ថ, នេះជាសេចក្ដីជ្រាលជ្រៅ ដោយអត្ថ ក្នុងភវចក្រនេះ ជាដំបូង ។ មែនពិត ផលដែលកើតពីហេតុ លោកហៅថា អត្ថ ។ ដូចជាបាលីថា “ញាណ គឺការដឹង ក្នុងផលដែលកើតពីហេតុ ឈ្មោះថា អត្ថប្បដិសម្ភិទា” ។

(ជ្រាលជ្រៅដោយហេតុ)

មួយវិញទៀត អត្ថ គឺភាវៈនៃអវិជ្ជា ជាបច្ច័យនៃសង្ខារទាំងឡាយ ព្រោះអវិជ្ជា ជាបច្ច័យនៃសង្ខារទាំងឡាយនោះៗ ដោយអាការៈណា និង ដោយស្ថានណា, អាការៈនោះ និង ស្ថាននោះ ជាករណីដែលដឹងបានដោយលំបាក, ន័យដូចគ្នាហ្នឹងដែរ អត្ថ គឺភាវៈនៃសង្ខារទាំងឡាយ ជាបច្ច័យនៃវិញ្ញាណ ។ល។ អត្ថ គឺភាវៈនៃជាតិជាបច្ច័យនៃជរាមរណៈ សុទ្ធតែជាធម៌ជ្រាលជ្រៅ ព្រោះហេតុណា, ព្រោះហេតុនោះ ភវចក្រនេះ ឈ្មោះថា ជ្រាលជ្រៅដោយធម៌, នេះ ជាសេចក្ដីជ្រាលជ្រៅ ដោយធម៌



ក្នុងភវចក្រនេះ ដោយប្រការដូច្នេះឯង ។ មែនពិត ពាក្យថា “ធម៌” គឺ ជាឈ្មោះនៃហេតុ ។ សមដូចជាលោកពោលថា “ការដឹង ក្នុងហេតុ ឈ្មោះថា ធម្មប្បដិសម្ភិទា” ។

(ជ្រាលជ្រៅដោយការសំដែង)

ម្យ៉ាងវិញទៀត សូម្បីការសំដែងនូវបដិច្ចសមុប្បាទនោះ ក៏ឈ្មោះថា ជ្រាលជ្រៅ ព្រោះសំដែងទីពឹងឲ្យប្រព្រឹត្តទៅ ដោយហេតុនោះៗ ដោយប្រការនោះៗ, ញាណដទៃក្រៅពីសព្វញ្ញុតញ្ញាណ រមែងមិនបានទីពឹង ក្នុងបដិច្ចសមុប្បាទនោះ, ពិតមែនដូច្នោះ ភវចក្រនេះ ក្នុងព្រះសូត្រខ្លះ ព្រះអង្គទ្រង់សំដែងហើយ ដោយអនុលោម ក្នុងព្រះសូត្រខ្លះ ទ្រង់សំដែង ដោយបដិលោម ក្នុងព្រះសូត្រខ្លះ ទ្រង់សំដែងទាំងដោយអនុលោម ទាំងដោយបដិលោម ក្នុងព្រះសូត្រខ្លះ ទ្រង់សំដែងចាប់ផ្ដើមអំពីពាក់កណ្ដាល ដោយអនុលោមខ្លះ ដោយបដិលោមខ្លះ ក្នុងព្រះសូត្រខ្លះ ទ្រង់សំដែងសន្ធិ ៣ សង្ខេប ៤ ក្នុងព្រះសូត្រខ្លះ ទ្រង់សំដែងសន្ធិ ២ សង្ខេប ៣ ក្នុងព្រះសូត្រខ្លះ ទ្រង់សំដែងតែសន្ធិ ១ សង្ខេប ២ ព្រោះហេតុណា, ព្រោះហេតុនោះ ភវចក្រនេះ ទើបឈ្មោះថា ជ្រាលជ្រៅដោយការសំដែងយ៉ាងនេះ ។ នេះជាសេចក្ដីជ្រាលជ្រៅ នៃការសំដែង ។

(ជ្រាលជ្រៅដោយបដិវេធ)

មួយវិញទៀត ក្នុងបដិច្ចសមុប្បាទធម៌នេះ សភាវៈនៃធម៌ មានអវិជ្ជាជាដើមនោះឯណា, មួយទៀត ធម៌ទាំងឡាយ មានអវិជ្ជាជាដើម ឈ្មោះថា ជាធម៌ គឺ ព្រះយោគីចាក់ធ្លុះហើយ ដោយប្រពៃ ព្រោះជាលក្ខណៈរបស់ខ្លួន ដោយសភាវៈឯណា ដែលខ្លួនបានចាក់ធ្លុះហើយ, សភាវៈនោះ ឈ្មោះថា ជ្រាលជ្រៅ ព្រោះជ្រាលជ្រៅ ចុះទៅបានដោយ

កម្ម ព្រោះហេតុណា, ព្រោះហេតុនោះ ភវចក្រនេះ ទើបឈ្មោះថាជ្រាលជ្រៅ ដោយបដិវេធ ។

ន័យដូចគ្នាហ្នឹងដែរ ក្នុងបដិច្ចសមុប្បាទនេះ អត្ថ គឺការមិនដឹង, ការមិនឃើញ និង ការមិនចាក់ធ្លុះ ដោយប្រពៃនូវសច្ចៈនៃអវិជ្ជា ក៏ឈ្មោះថា ជ្រាលជ្រៅ, អត្ថ គឺការតាក់តែង, ការដុះដាលឡើង, ការប្រព្រឹត្តិទៅដោយរាគៈ, ការប្រាសចាករាគៈ នៃសង្ខារទាំងឡាយ ក៏ឈ្មោះថា ជ្រាលជ្រៅ, អត្ថ គឺការសាបសូន្យ, ការមិនខ្វល់ខ្វាយ, ការមិនកម្រើក, ការប្រាកដដោយបដិសន្ធិ នៃវិញ្ញាណ ក៏ឈ្មោះថា ជ្រាលជ្រៅ, អត្ថ គឺការកើតឡើងជាមួយគ្នា, ការបែកចេញអំពីគ្នា, ការបែកចេញអំពីគ្នាមិនបាន, ការបង្អោនទៅ និង ការបែកធ្លាយ នៃនាមរូប ក៏ឈ្មោះថា ជ្រាលជ្រៅ, អត្ថ គឺភាពជាអធិបតី, ភាពជាលោក, ភាពជាទ្វារ, ភាពជាខេត្ត, ភាពជាវិស័យ គឺឥន្ទ្រិយ៍នៃសឡាយតនៈ ក៏ឈ្មោះថា ជ្រាលជ្រៅ, អត្ថ គឺការប៉ះពាល់គ្នា, ការជិតដិត(កៀកគ្នា)ការប៉ះដល់គ្នា, ការប្រជុំព្រមគ្នា នៃផស្សៈ ក៏ឈ្មោះថា ជ្រាលជ្រៅ, អត្ថ គឺការសោយនូវអារម្មណ៍, ភាពជាសុខ, ភាពជាទុក្ខ និង ជាកណ្តាលៗ ការសោយដោយបែបនិជ្ជីវៈ គឺមិនមានអត្តា ជាអ្នកសោយ នៃវេទនា ក៏ឈ្មោះថា ជ្រាលជ្រៅ, អត្ថ គឺការក្រើតក្រើន, ការរំសាយចិត្ត, សេចក្តីប្រាថ្នា ដូចជាស្ទឹង, ដូចជាលតា (វល្លិដែលវារទន្ទ្រានឡើងលើដើមឈើ) ដូចជាទន្លេ និង ការមិនចេះពេញ ដូចជាសមុទ្រនៃតណ្ហា ក៏ឈ្មោះថា ជ្រាលជ្រៅ, អត្ថ គឺការប្រកាន់, ការកាន់យក, ការប្រកាន់ស្អិត, ការប្រកាន់មាំ, ការប្រព្រឹត្តិកន្លងបានដោយក្រនៃឧបាទាន ក៏ឈ្មោះថា ជ្រាលជ្រៅ, អត្ថ គឺការប្រមូល, ការតាក់តែង និង ការបោះទម្លាក់ទៅ ក្នុងកំណើត



ក្នុងគតិ ក្នុងឋិតិ និង ក្នុងនិវាសៈ ទីនៅអាស្រ័យនៃភព ក៏ឈ្មោះថាជ្រាលជ្រៅ, អត្ថ គឺការកើត, ការបានកំណើត, ការចុះកាន់គភ៌, ការកើតឡើង, ការប្រាកដឡើងនៃជាតិ ក៏ឈ្មោះថា ជ្រាលជ្រៅ, អត្ថ គឺការអស់ទៅ, ការសូន្យទៅ, ការបែកធ្លាយ និង ការប្រែប្រួលទៅ នៃជរាមរណៈ ក៏ឈ្មោះថា ជ្រាលជ្រៅ ព្រោះហេតុណា, ព្រោះហេតុនោះ ភវចក្រនេះ ទើបឈ្មោះថា ជ្រាលជ្រៅដោយបដិវេធ, នេះ ជាសេចក្តីជ្រាលជ្រៅ ដោយបដិវេធ ក្នុងបដិច្ចសមុប្បាទធម៌នេះ ។

(ដោយន័យផ្សេងគ្នា)

មួយទៀត ក្នុងបដិច្ចសមុប្បាទធម៌នេះ ន័យនៃអត្ថ (អត្ថន័យ) មាន ៤ យ៉ាង គឺ: ន័យនៃអត្ថតែមួយ, ន័យនៃអត្ថផ្សេងគ្នា, ន័យនៃអត្ថ ថាមិនមានការខ្វល់ខ្វាយ, ន័យនៃអត្ថថា ជាធម៌ដូច្នោះឯង ព្រោះហេតុណា, ព្រោះហេតុនោះ ភវចក្រនេះ បណ្ឌិតគប្បីជ្រាប សូម្បីដោយការផ្សេងគ្នានៃន័យ តាមសមគួរ ។

(ឯកត្តន័យ)

ក្នុងន័យទាំង ៤ យ៉ាងនោះ ការមិនចូលទៅកាត់ផ្តាច់នៃទី-ត យ៉ាងនេះ គឺ: សង្ខារ(កើតមាន) ព្រោះអវិជ្ជាជាបច្ច័យ, វិញ្ញាណ (កើតមាន) ព្រោះសង្ខារជាបច្ច័យ ដូច្នេះជាដើម ដូចជាភាពនៃពូជកកើតទៅជាដើមឈើបាន ក៏ព្រោះការកើតមាននៃអវយវៈ នៃដើមឈើមានពន្លកជាដើម ដូច្នោះ ឈ្មោះថា ឯកត្តន័យ ។

ព្រះយោគី កាលឃើញនូវឯកត្តន័យណា ដោយប្រពៃ រមែងលះបង់នូវឧច្ឆេទទិដ្ឋិ ព្រោះបានដឹងនូវការមិនចូលទៅកាត់ផ្តាច់នៃទី-ត ដែលប្រព្រឹត្តទៅ ដោយការជាប់ទាក់ទងគ្នា នៃហេតុ និង ផល កាលបើព្រះ

*យោគី យល់ឃើញខុស រមែងប្រកាន់មាំ នូវសស្សតទិដ្ឋិ ព្រោះប្រកាន់យកនូវភាវៈនៃការមិនចូលទៅកាត់ផ្ដាច់នៃទី-ត ដែលប្រព្រឹត្តទៅ ដោយការជាប់ទាក់ទងគ្នានៃហេតុ និង ផល ថា មានតែមួយ ។ (នេះ ឈ្មោះថា ឯកត្តន័យ) ។*

(នានត្តន័យ)

*ចំណែកខាងការកំណត់លក្ខណៈ តាមសមគួរដល់ខ្លួន នៃធម៌ទាំងឡាយមានអវិជ្ជាជាដើម ឈ្មោះថា នានត្តន័យ។ ព្រះយោគីកាលឃើញនានត្តន័យណា ដោយប្រពៃ រមែងលះបង់នូវសស្សតទិដ្ឋិ ព្រោះឃើញនូវការកើតឡើង នៃវត្ថុដែលថ្មីៗទាំងឡាយ កាលឃើញខុស រមែងប្រកាន់មាំនូវឧច្ឆេទទិដ្ឋិ ព្រោះប្រកាន់យកនូវភាវៈ នៃហេតុ និង ផល ដែលធ្លាក់ចុះ ក្នុងសន្តានតែមួយ ជាសន្តានដែលបានបែកធ្លាយហើយហ្នឹងឯង ថា ជារបស់ផ្សេងគ្នា ។ (នេះ ឈ្មោះថា នានត្តន័យ) ។*

(អព្យាបារន័យ)

*ភាពនៃអវិជ្ជា មិនមានសេចក្ដីខ្វល់ខ្វាយ មានជាអាទិ៍យ៉ាងនេះថា "សង្ខារទាំងឡាយ គឺខ្ញុំធ្វើឲ្យកើតឡើង" ដូច្នេះ ឬថា "សង្ខារ មិនមានសេចក្ដីខ្វល់ខ្វាយ ថា វិញ្ញាណ គឺយើងធ្វើឲ្យកើតឡើង" ដូច្នេះ ឈ្មោះថា អព្យាបាទន័យ ។ ព្រះយោគីកាលឃើញនូវន័យណា ដោយប្រពៃ រមែងលះបង់នូវសេចក្ដីសំគាល់ថា មានខ្លួន ព្រោះដឹងនូវភាពមិនមានអ្នកធ្វើ(អ្នកកសាង) កាលឃើញខុស រមែងប្រកាន់មាំ នូវអកិរិយទិដ្ឋិ ព្រោះមិនប្រកាន់យក នូវភាវៈនៃហេតុ នៃធម៌ទាំងឡាយ មានអវិជ្ជា ជាដើម ដែលសំរេចបាន ដោយសភាវនិយម កាលបើសេចក្ដីខ្វល់ខ្វាយមិនមាន ។ (នេះ ឈ្មោះថា អព្យាបាទន័យ) ។*



(ឯវំធម្មតាន័យ)

*ចំណែកន័យនេះថា "ការកើតឡើងនៃផល មានសង្ខារជាដើម រមែងកើតមានអំពីហេតុទាំងឡាយ មានអវិជ្ជាជាដើមប៉ុណ្ណោះ ដូចជាការកើតឡើង នៃវត្ថុទាំងឡាយ មានទឹកដោះជូរជាដើម រមែងកើតមានអំពីទឹកដោះស្រស់ជាដើម ដូច្នោះឯង មិនមែនមានមកអំពីវត្ថុដទៃឡើយ" ដូច្នេះ ឈ្មោះថា ឯវំធម្មតាន័យ ។ ព្រះយោគីកាលឃើញន័យណា ដោយប្រពៃ រមែងលះបង់អហេតុកទិដ្ឋិ និង អកិរិយទិដ្ឋិ ព្រោះដឹងនូវផល តាមសមគួរដល់បច្ច័យ កាលឃើញខុស រមែងប្រកាន់មាំនូវអហេតុកទិដ្ឋិ និង និយតវាទ ព្រោះមិនកាន់យកនូវការប្រព្រឹត្តិទៅនៃផលដែលសមគួរដល់បច្ច័យ ហើយប្រកាន់មាំថា របស់អ្វីៗ មិនដែលកើតមកអំពីហេតុណាមួយទេ ។ (នេះ ឈ្មោះថា ឯវំធម្មតាន័យ) ។*

*ភវចក្រនេះ*

បណ្ឌិត គប្បីជ្រាប ដោយការកើតអំពីសច្ចៈ ១,
ដោយកិច្ច ១, ដោយការរារាំង១, ដោយឧបមា
ទាំងឡាយ១ ដោយការផ្សេងគ្នានៃគម្ភីរភាព ១,
ដោយការផ្សេងគ្នា នៃន័យ ១ តាមសមគួរ

*ដោយប្រការដូច្នេះឯង ។*

*ព្រោះបុគ្គលទាំលាយមិនបាននូវភវចក្រនេះ ដែលជ្រាលជ្រៅ ក្រៃលែង ព្រោះជាធម៌ដ៏ជ្រាលជ្រៅ ដែលតទល់បានដោយកម្រ ព្រោះកំណត់យក ដោយន័យផ្សេងៗ ដោយការបិត គឺញាណ ដែលបានសំ-លៀង យ៉ាង (មុត) ល្អហើយ លើថ្ម ដ៏ប្រសើរ គឺសមាធិ ហើយកន្លង*

នូវសង្សារភ័យ ដែលបៀតបៀនជាប់ជានិច្ច ប្រៀបបីដូចកាំរនុះទៅបាន អ្នកណាម្នាក់ ក៏មិនមាន សូម្បីក្នុងការយល់សប្តិឡើយ ។

ដូចជាព្រះពុទ្ធដីកា ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់ថា "ម្នាលអានន្ទ! ក៏បដិច្ចសមុប្បាទធម៌នេះ ជាធម៌ដ៏ជ្រាលជ្រៅផង ប្រាកដច្បាស់ជាជ្រាលជ្រៅផង, ម្នាលអានន្ទ! ព្រោះការមិនដឹង ព្រោះការមិនចាក់ធ្លុះនូវធម៌នោះ ពួកសត្វនេះ ទើបកើតជាស្មុគស្មាញ ដូចជាតម្បាញ(ដែលកណ្ដុរកាត់) ដូចជាអំបោះ ត្រូវទឹកបាយ របស់ជាងតម្បាញ ឬ សំបុកសត្វស្លាប កើតដូចជាស្មៅយ៉ាបូង និង ស្មៅជំណោកទន្សាយ ដែលជំពាក់គ្នា យ៉ាងនេះ ទើបមិនកន្លងនូវអបាយ, ទុគ្គតិ, វិនិបាត សំសារទៅបាន" ដូច្នេះជាដើម ។ ព្រោះហេតុនោះ បណ្ឌិតអ្នកប្រតិបត្តិ ដើម្បីប្រយោជន៍ និង សេចក្ដីសុខ ដល់ខ្លួន ឬ បុគ្គលដទៃ គប្បីលះបង់នូវកិច្ច ដ៏សេសសល់ហើយ

បាននូវសេចក្ដីចេះដឹង ក្នុងប្រភេទនៃបច្ចយាការ
ដ៏ជ្រាលជ្រៅនេះ ដោយប្រការណា, គប្បីជា
អ្នកមានសតិ ប្រកបជាប់ជានិច្ច ដោយប្រការ
នោះចុះ ដូច្នេះឯង ។

*បរិច្ឆេទ ទី១៧ ឈ្មោះបញ្ញាភូមិនិទ្ទេស ក្នុងអធិការនៃបញ្ញាភាវនា*
*ក្នុងវិសុទ្ធិមគ្គ គឺខ្ញុំធ្វើហើយ ដើម្បីប្រយោជន៍ដល់បាមោជ្ជៈ*
*នៃសាធុជន យ៉ាងដូច្នេះឯង ។*

❀ ❀ ❀



## ទិដ្ឋិវិសុទ្ធិនិទ្ទេស

(៤១១) ឥឡូវនេះ វិសុទ្ធិមគ្គទាំងឡាយណា គឺខ្ញុំបានពោលហើយថា "វិសុទ្ធិ ដែលជាមូល ២ គឺ : សីលវិសុទ្ធិ ១ ចិត្តវិសុទ្ធិ ១ គឺព្រះយោគាវចរកុលបុត្រ ធ្វើនូវការសន្សំបន្ទុំញាណ ដោយការសិក្សា និង ការសាកសួរ ក្នុងធម៌ទាំងឡាយ ដែលជាភូមិ (នៃវិបស្សនា មានខន្ធជាដើម)នេះហើយ គប្បីបំពេញឲ្យបរិបូណ៌ចុះ" ដូច្នេះ, ក្នុងវិសុទ្ធិទាំង ២ នោះ សីល ៤ យ៉ាង មានបាតិមោក្ខសំវរសីលជាដើម ដែលបរិសុទ្ធស្អាតល្អ ឈ្មោះថា សីលវិសុទ្ធិ ។ ក៏សីល ៤ យ៉ាងនោះ គឺខ្ញុំ(សំដែង)ឲ្យពិស្តារហើយ ក្នុងសីលនិទ្ទេសនោះឯង ។ សមាបត្តិ ៨ ព្រមទាំងឧបចារៈ ឈ្មោះថា ចិត្តវិសុទ្ធិ ។ សូម្បីសមាបត្តិទាំង ៨ នោះ ក៏ខ្ញុំបាន(សំដែង) ឲ្យពិស្តារហើយ ដោយអាការៈទាំងពួង ក្នុងសមាធិនិទ្ទេសដែលបានពោលហើយ ដោយលើកយកចិត្តជាប្រធានដើមបទហ្នឹងឯង ព្រោះហេតុនោះ វិសុទ្ធិទាំង ២ នោះ បណ្ឌិតគប្បីជ្រាប តាមន័យដែលខ្ញុំបាន(ពោល)ហើយ ឲ្យពិស្តារ ក្នុងនិទ្ទេសទាំង២ នោះចុះ ។ ចំណែកពាក្យឯណា ដែលខ្ញុំបានពោលហើយថា "វិសុទ្ធិទាំងឡាយ ៥ នេះ គឺ: ទិដ្ឋិវិសុទ្ធិ, កង្ខាវិតរណវិសុទ្ធិ, មគ្គាមគ្គញ្ញាណទស្សនវិសុទ្ធិ, បដិបទាញាណទស្សនវិសុទ្ធិ, ញាណទស្សនវិសុទ្ធិ ជាសរីរៈ" ដូច្នេះ, ក្នុងពាក្យនោះ កិរិយាឃើញនូវនាម និង រូប តាមសេចក្ដីពិត ឈ្មោះថា **ទិដ្ឋិវិសុទ្ធិ** ។

### (វិបស្សនាវិធី)

ជាបឋម ព្រះយោគាវចរ អ្នកប្រាថ្នានឹងញុំាងទិដ្ឋិវិសុទ្ធិនោះ ឲ្យដល់ព្រម ជាអ្នកមានយាន គឺសមថៈ ចេញពីរូបាវចរជ្ឈាន និង អរូបា-

វចរជ្ឈានដ៏សេសទាំងឡាយ ឈានណាមួយ លើកលែងតែនេវសញ្ញានាសញ្ញាយតនៈចេញ គប្បីកំណត់យកអង្គឈានទាំងឡាយ មានវិតក្កៈជាដើម និងធម៌ទាំងឡាយដែលសម្បយុត្ត ដោយអង្គឈាននោះ ដោយលក្ខណៈ និង រសជាដើម ។ លុះកំណត់រួចហើយ គប្បីកំណត់ចាប់យក ថា “ទាំងអស់នោះជានាម ព្រោះអត្ថថា ជារបស់ដែលបង្អោនចូលទៅ ព្រោះបង្អោនមុខឆ្ពោះទៅកាន់អារម្មណ៍” ។ លំដាប់នោះ ប្រៀបដូចជាបុរសឃើញពស់នៅក្នុងផ្ទះ ហើយដេញតាមពស់នោះ ក៏ឃើញទីនៅរបស់វា យ៉ាងណាមិញ, ឯព្រះយោគាវចរនេះ ក៏យ៉ាងដូច្នោះដែរ កាលពិចារណានូវនាមនោះ ស្វែងរកមើលថា “នាមនេះអាស្រ័យនូវអ្វី ទើបប្រព្រឹត្តទៅ?” ដូច្នេះ ទើបឃើញនូវហទយរូបដែលជាទីអាស្រ័យ របស់នាមនោះ ។ បន្ទាប់ពីនោះមក ក៏កំណត់យករូប គឺ “ភូតរូបទាំងឡាយដែលជាទីអាស្រ័យ នៃហទយរូប និង ឧបាទាយរូប ដ៏សេស ដែលអាស្រ័យនូវភូតរូប” ។ ព្រះយោគាវចរនោះ កំណត់ថា “ទាំងអស់នោះជារូប ព្រោះជារបស់ដែលបែកធ្លាយទៅ” ។ បន្តមកទៀត ទើបកំណត់នាមរូប ដោយសង្ខេបថា “របស់ដែលមានការបង្អោនទៅជាលក្ខណៈឈ្មោះថា នាម, របស់ដែលមានការបែកធ្លាយទៅជាលក្ខណៈ ឈ្មោះថា រូប” ដូច្នេះ ។

(កំណត់នាមរូបដោយចតុធាតុវវដ្ឋាន)

ចំណែក ព្រះយោគាវចរ ដែលជាអ្នកវិបស្សនាយានិកសុទ្ធសាធ ឬក៏ ជាសមថយានិកនេះឯង កំណត់ចាប់យកនូវធាតុ ៤ ដោយសង្ខេប ឬ ពិស្តារ ដោយអំណាចនៃវិធីកំណត់ធាតុទាំងឡាយនោះៗ ដែលបានពោលហើយ ក្នុងចតុធាតុវវដ្ឋាន វិធីកំណត់ធាតុ ឯណាមួយ ។ លំដាប់



នោះ ក្នុងធាតុទាំងឡាយដែលប្រាកដច្បាស់ ដោយរស និង លក្ខណៈតាមសេចក្តីពិត ជាដំបូង ក្នុងសក់ដែលមានកម្ម ជាសមុដ្ឋាន រូប ១០ ដោយអំណាចនៃកាយទសកៈ យ៉ាងនេះ គឺ “ធាតុ ៤, ក្លិន, រស, ឱជា, ជីវិត, កាយបសាទ” រូប ១០ ដោយអំណាចនៃភាវទសកៈ ព្រោះក្នុងសក់ដែលមានកម្ម ជាសមុដ្ឋាននោះឯង ក៏មានភាវៈ (គឺភេទ) ដែរ, រូប ២៤ ដទៃទៀត ក្នុងជំពូករូបដែលមានឈ្មោះថាសក់នោះឯង គឺ : ឱជដ្ឋមករូប (ពួករូបដែលមានឱជា ជាគំរប់ ៨) ដែលមានអាហារជាសមុដ្ឋាន, ឱជដ្ឋមករូប ដែលមានឧតុ (រដូវ) ជាសមុដ្ឋាន, ឱជដ្ឋមករូបដែលមានចិត្តជាសមុដ្ឋាន (ក្រុមរូបទីមួយៗ មាន ៨ បូករួមចូលគ្នាត្រូវជា ២៤ ព្រមទាំងរូបខាងដើម ២០ ផង ត្រូវជា ៤៤) តែងប្រាកដដល់ព្រះយោគាវចរនោះឯង, (ក្នុងសក់ មានរូប ៤៤ យ៉ាងណាមិញ), ក្នុងកោដ្ឋាស ២៤ ដែលជាចតុសមុដ្ឋាន ក៏មានរូប ៤៤ ៗ យ៉ាងដូច្នោះដែរ, ចំណែក ក្នុងកោដ្ឋាស ដែលមានរដូវ និង ចិត្តជាសមុដ្ឋានទាំង ៤ នេះ គឺៈ “ញើស, ទឹកភ្នែក, ទឹកមាត់, ទឹកសំបោរ” មានរូប ១៦ ៗ ដោយអំណាចនៃឱជដ្ឋមករូបទាំង ២, ក្នុងកោដ្ឋាសដែលមានរដូវជាសមុដ្ឋាន ៤ នេះ គឺៈ “អាហារថ្មី, អាហារចាស់, ខ្ទុះ, ទឹកមូត្រ” ក៏មានរូប ៨ ៗ ដោយអំណាចនៃឱជដ្ឋមករូប ដែលមានរដូវជាសមុដ្ឋានតែម្យ៉ាង តែងប្រាកដដល់ព្រះយោគាវចរនោះឯង ។ នេះ ជាន័យ ក្នុងអាការៈ ៣២ ជាដំបូង ។

មួយទៀត កាលបើអាការៈ ៣២ នេះ ប្រាកដហើយ, អាការៈទាំងឡាយឯណា ១០ ដទៃទៀត (គឺតេជោកោដ្ឋាស ៤ និង វាយោកោដ្ឋាស ៦ រមែងប្រាកដច្បាស់, ក្នុងអាការៈទាំងនោះ ក្នុងតេជោកោដ្ឋាស ដែល

កើតអំពីកម្ម ដែលញ៉ាំងអាហារ ដែលបុគ្គលទំពាចូលទៅហើយ ឲ្យរលាយ មានរូប ៩ គឺ “ឱជដ្ឋមករូប (៨) និង ជីវិតរូប(១)” ជាមុនសិន, ន័យដូចគ្នានោះដែរ ក្នុងកោដ្ឋាស គឺខ្យល់ចេញ-ចូល ដែលកើតអំពីចិត្ត ក៏មានរូប ៩ ដែរ គឺ “ឱជដ្ឋមករូប(៨) និង សទ្ទរូប(១)” ក្នុងកោដ្ឋាសទាំងឡាយ ៨ ដ៏សេស (តេជោ ៣, វាយោ ៥) ដែលជាចតុសមុដ្ឋាន មានរូប ៣៣ ៗ គឺ “ជីវិតនវករូប (៩) ឱជដ្ឋមករូប ៣” រមែងប្រាកដដល់ព្រះយោគាវចរនោះ ។

កាលបើភូតរូប និង ឧបាទាយរូបទាំងឡាយនេះ កើតប្រាកដដល់ព្រះយោគាវចរនោះ ដោយអំណាចអាការៈ ៤២ យ៉ាងពិស្តារ ដូច្នេះហើយ, រូបទាំងឡាយដទៃទៀត ៦០ គឺ “រូបកលាប ៥ មានចក្ខុទសកៈជាដើម និងហទយវត្ថុទសកៈ” ដោយអំណាចវត្ថុនិងទ្វារ រមែងប្រាកដ។

ព្រះយោគាវចរនោះ រមែងឃើញថា “នេះគឺជារូប” ព្រោះរួបរួមទាំងអស់នោះឯង ចូលជាមួយគ្នា ដោយលក្ខណៈ គឺការបែកធ្លាយ ។ អរូបធម៌ទាំងឡាយ តែងប្រាកដដល់ព្រះយោគាវចរនោះ ជាអ្នកកំណត់យករូបបានហើយ ដោយអំណាចនៃទ្វារ យ៉ាងនោះឯង ។ អរូបធម៌នេះ គឺអ្វីខ្លះ? ។ គឺៈ លោកិយចិត្ត ៨១ មាន ទ្វិបញ្ចវិញ្ញាណ (ត្រូវជា ១០), មនោធាតុ ៣, មនោវិញ្ញាណធាតុ ៦៨ ។ មួយទៀត ដោយអំណាចមិនខុសគ្នា បានដល់ ចេតសិក ៧ នេះ គឺ ផស្សៈ, វេទនា, សញ្ញា, ចេតនា, ជីវិត, ចិត្តដ្ឋិតិ, មនសិការ ដែលកើតព្រមគ្នាជាមួយចិត្តទាំងនោះឯង ។

ចំណែក លោកុត្តរចិត្តទាំងឡាយ រមែងដល់នូវការកំណត់យកដល់ព្រះយោគាវចរ អ្នកចំរើនវិបស្សនាសុទ្ធសាធ ពុំបានទេ ដល់ព្រះ



យោគាវចរដែលជាសមថយានិកក៏ពុំបានដែរ ព្រោះមិនទាន់បានសំរេច។

ព្រះយោគាវចរនោះ ឃើញថា “នោះជានាម” ព្រោះរួបរួមអរូបធម៌ទាំងឡាយនោះចូលគ្នា ដោយលក្ខណៈ គឺការបង្អោនចូលទៅហ្នឹងឯង ។ ព្រះយោគាវចរមួយរូបទៀត កំណត់នាមរូប យ៉ាងពិស្តារ ដោយវិធី គឺចតុធាតុវវដ្ឋាន ដូចបានពណ៌នាមកនេះឯង ។

### (កំណត់នាមរូបដោយធាតុ ១៨)

ព្រះយោគាវចរមួយរូបទៀត កំណត់នាមរូប ដោយអំណាចធាតុ ១៨ ។ កំណត់យ៉ាងដូចម្តេច? ។ គឺ ភិក្ខុក្នុងសាសនានេះ ពិចារណាធាតុទាំងឡាយថា “ក្នុងអត្តភាពនេះ មានចក្ខុធាតុ, រូបធាតុ, ចក្ខុ-វិញ្ញាណធាតុ ។ល។ មនោធាតុ, ធម្មធាតុ, មនោវិញ្ញាណធាតុ” ដូច្នេះហើយ មិនកំណត់យកនូវដុំសាច់ ដែលត្រូវខ្សែរសែចងរឹតជាប់ ត្រង់រណ្តៅភ្នែក មានសណ្ឋានទ្រវែង វិចិត្រដោយទ្រង់ទ្រាយនៃពណ៌ប្រផេះ និង ពណ៌ខ្មៅស្រិល ដែលមនុស្សលោកស្គាល់ច្បាស់ហើយថា “ចក្ខុ” កំណត់យកចក្ខុបសាទ មានប្រការដូចពោលហើយ ក្នុងឧបាទាយរូប ក្នុងខន្ធនិទ្ទេសថា “ចក្ខុធាតុ” ដូច្នេះ ។ មួយទៀត រូបទាំងឡាយណាដ៏សេស ៥៣ មានយ៉ាងនេះ គឺៈ សហជាតរូបទាំងឡាយ ៩ បានដល់ធាតុ ៤ ដែលជាទីអាស្រ័យនៃចក្ខុបសាទនោះ, រូប ៤ គឺ ពណ៌សម្បុរ, ក្លិន, រស និង ឱជា ដែលជាបរិវារ, ជីវិតរូប ដែលជារូបតាមរក្សា, កម្មជរូប ២០ ដោយអំណាចនៃកាយទសកៈ និង ភាវទសករូប ដែលតាំងនៅក្នុងចក្ខុបសាទនោះឯង, អនុបាទិន្នករូប ២៤ ដោយអំណាចនៃឱជដ្ឋមករូប ៣ នៃរូបដែលជាអាហារសមុដ្ឋានជាដើម (៩+២០+២៤=៥៣), ព្រះយោគាវចរ មិនកំណត់យករូបទាំង ៥៣ នោះថា “ជាចក្ខុធាតុ”

ដូច្នោះ ។ សូម្បីក្នុងធាតុទាំងឡាយ មានសោតធាតុជាដើម ក៏មានន័យដូចគ្នានេះដែរ ។ តែក្នុងកាយធាតុ រូបដ៏សេស មាន ៤៣ ។ ប៉ុន្តែអាចារ្យពួកខ្លះ ពោលថា “មាន ៤៥” ព្រោះធ្វើរូបដែលជាឧតុសមុដ្ឋាន និង ចិត្តសមុដ្ឋាន ឲ្យទៅជាមួយក្រុម ៩ ៗ ព្រមជាមួយសទ្ទរូប ។

ព្រះយោគាវចរនោះ កំណត់ថា “រូបទាំងឡាយ ១០ គឺៈ បសាទរូប ៥ ដូចបានពណ៌នាមកនេះ និង វិសយរូប ៥ នៃបសាទរូប ៥ នោះ គឺៈ រូប, សម្លេង, ក្លិន, រស និង ផោដ្ឋព្វៈ ជាធាតុ ១០ ។ រូបដ៏សេស ជាធម្មធាតុតែម្យ៉ាង ។ តែទ្វិបញ្ចវិញ្ញាណ យ៉ាងនេះថា “ចិត្តអាស្រ័យចក្ខុប្រារព្ធរូបប្រព្រឹត្តទៅ ឈ្មោះថា ចក្ខុវិញ្ញាណធាតុ” ដូច្នេះជាដើម ជាវិញ្ញាណធាតុ ៥ ។ ចិត្តមនោធាតុ ៣ ជាមនោធាតុ ១ ។ ចិត្តមនោ-វិញ្ញាណធាតុ ៦៨ ជាមនោវិញ្ញាណធាតុ ១” ។ ព្រះយោគាវចរ កំណត់ថា “លោកិយចិត្តទាំងអស់ ៨១ ដួង, វិញ្ញាណធាតុ ៧, ធម៌ទាំងឡាយមានផស្សៈជាដើម ដែលសម្បយុត្តជាមួយនឹងវិញ្ញាណធាតុនោះ ជាធម្មធាតុ” ។ ក្នុងធាតុ ១៨ នោះ ធាតុ ១០ កន្លះ ជារូប, ធាតុ ៧ កន្លះ ជានាម” ដូច្នេះឯង ។ ព្រះយោគាវចរ ១ រូប កំណត់នាមរូប ដោយអំណាចនៃធាតុ ១៨ ដោយន័យដែលបានពោលមកហើយនេះឯង ។

**(កំណត់នាមរូបដោយអាយតនៈ ១២)**

ព្រះយោគាវចរ ១ រូបទៀត កំណត់យកនាមរូប ដោយអំណាចនៃអាយតនៈ ១២ ។ កំណត់យ៉ាងដូចម្តេច? ។ គឺកំណត់ត្រឹមតែចក្ខុបសាទ លើកលែងតែរូប ៥៣ ចេញ តាមន័យដែលពោលមកហើយក្នុងចក្ខុធាតុហ្នឹងឯងថា “ជាចក្ខាយតនៈ” ដូច្នេះ និង កំណត់សោតធាតុ, ឃានធាតុ, ជិវ្ហាធាតុ និង កាយធាតុ តាមន័យដែលពោលមកហើយ



ក្នុងចក្ខុធាតុនោះ ដូចគ្នាដែរថា “សោតាយតនៈ, ឃានាយតនៈ, ជិវ្ហា-យតនៈ និង កាយាយតនៈ” ដូច្នេះ, កំណត់ធម៌ទាំងឡាយ ៥ ដែលជាវិស័យនៃអាយតនៈទាំងឡាយ៥ នោះថា “ជារូបាយតនៈ, សទ្ទាយតនៈ, គន្ធាយតនៈ, រសាយតនៈ និង ផោដ្ឋព្វាយតនៈ”ដូច្នេះ, កំណត់លោកិយចិត្ត និង សត្តវិញ្ញាណធាតុថា “ជាមនាយតនៈ” ដូច្នេះ, កំណត់ធម៌ទាំងឡាយមានផស្សៈជាដើម ដែលសម្បយុត្តដោយវិញ្ញាណធាតុនោះ និង រូបដែលសេសសល់ថា “ជាធម្មាយតនៈ” ដូច្នេះ ។

ក្នុងអាយតនៈ ១២ នេះ អាយតនៈ១០ កន្លះ ជារូប, អាយតនៈ ១ កន្លះ ជានាម ដូច្នេះឯង ។ ព្រះយោគាវចរមួយរូប កំណត់នាមរូប ដោយអំណាចនៃអាយតនៈ ១២ ដូចបានពណ៌នាមកនេះឯង ។

**(កំណត់នាមរូបដោយអំណាចខន្ធ ៥)**

ព្រះយោគាវចរមួយរូបទៀត កំណត់នាមរូប (ធ្វើ) ឲ្យខ្លីជាងនោះទៅទៀត ដោយអំណាចនៃខន្ធ ។ កំណត់យ៉ាងដូចម្តេច? ។ គឺភិក្ខុ ក្នុងសាសនានេះ កំណត់ថា “ក្នុងសរីរៈនេះ រូបទាំងឡាយ ១៧ នេះ គឺ : ធាតុ ៤ ដែលជាចតុសមុដ្ឋាន, ពណ៌សម្បុរ, ក្លិន, រស, ឱជា ដែលអាស្រ័យធាតុ ៤ នោះ, បសាទរូប ៥ មានចក្ខុបសាទជាដើម, វត្ថុរូប, ភាវរូប, ជីវិតិន្ទ្រីយ៍, សំឡេងដែលជាទ្វិសមុដ្ឋាន ជារូបសំរេចហើយជារូបពិត សមគួរដល់ការពិចារណា, ចំណែកខាង រូបទាំងឡាយ ១០ នេះ គឺកាយវិញ្ញត្តិ, វចីវិញ្ញត្តិ, អាកាសធាតុ, ភាពនៃរូបស្រាល, ភាពនៃរូបទន់ជ្រាយ, ការគួរដល់ការងារនៃរូប, ការចំរើនឡើងនៃរូប, ការតជាប់គ្នានៃរូប, ការចាស់ជរានៃរូប, ការមិនទៀងទាត់នៃរូប មិនមែនជារូបសំរេច មិនមែនជារូបពិត គ្រាន់តែជាអាការៈ, ជាវិការៈ និង ជា

គ្រឿងកំណត់ ក្នុងចន្លោះនៃរូប មិនមែនជារូបសមគួរដល់ការពិចារណាទេ, ប៉ុន្តែថា រូបទាំងនេះ ដល់ហើយនូវការរាប់បានថា “រូប” ដោយត្រឹមតែជាអាការៈ, ជាវិការៈ និង ជាគ្រឿងកំណត់ ក្នុងចន្លោះនៃរូបទាំងឡាយ, រូបទាំងឡាយទាំងពួងនោះ ២៧ ជារូបក្ខន្ធ, វេទនាដែលកើតព្រមគ្នាជាមួយលោកិយចិត្ត ៨១ ជាវេទនាខន្ធ, សញ្ញាដែលសម្បយុត្តជាមួយលោកិយចិត្តនោះ ជាសញ្ញាខន្ធ, សង្ខារទាំងឡាយ ជាសង្ខារក្ខន្ធ, វិញ្ញាណ ជាវិញ្ញាណក្ខន្ធ” ដូច្នេះ, រូបក្ខន្ធ ជារូប, អរូបក្ខន្ធ ៤ ជានាម ដូច្នេះឯង ។

(កំណត់នាមរូបដោយសង្ខេប)

ព្រះយោគាវចរ មួយរូបទៀត កំណត់យករូប ក្នុងអត្តភាពនេះ ដោយសង្ខេបតែម្តង យ៉ាងដូច្នេះថា “រូបឯណាមួយ រូបទាំងពួង គឺ : មហាភូតរូប ៤ និង រូបដែលអាស្រ័យមហាភូតរូបទាំង ៤ ផង” ដូច្នេះហើយ កំណត់យកមនាយតនៈ និង ផ្នែកមួយនៃធម្មាយតនៈថា “ជានាម” ដោយសង្ខេប យ៉ាងដូច្នោះដែរ ស្រេចហើយ ក៏កំណត់នាមរូបដោយសង្ខេបថា “នាមនេះផង រូបនេះផង ដូចពណ៌នាមកនេះឯង, នេះហៅថា នាមរូប” ដូច្នេះ ។

ក៏បើព្រះយោគាវចរនោះ កំណត់រូប ដោយវិធីនោះ (មុន) ហើយកំណត់យកអរូប, អរូប មិនប្រាកដ ព្រោះជាធម៌ដ៏សុខុម, ព្រះយោគាវចរនោះ មិនត្រូវទំលាក់នូវធុរៈចោលទេ ត្រូវតែពិចារណា ធ្វើទុកក្នុងចិត្ត កំណត់កាន់យក កំណត់យកនូវរូបនោះឯង ឲ្យបានជារឿយៗ ។ ព្រោះថា រូប ជារបស់ដែលស្អាត ហ្មត់ចត់ បរិសុទ្ធល្អ មិនមានអ្វីជាប់ពាក់ព័ន្ធ ដោយប្រការណាៗ, អរូបធម៌ទាំងឡាយ ដែលមានរូបធម៌នោះ



ជាអារម្មណ៍ ក៏ប្រាកដ ដល់ព្រះយោគាវចរនោះ ដោយខ្លួនឯង ដោយប្រការនោះៗ ដែរ ។ ប្រៀបដូចជាកាលបើបុរសសំឡឹងមើលស្រមោលមុខ ក្នុងកញ្ចក់ដែលមិនស្រឡះ (មិនស្អាត) ស្រមោល (និមិត្ត) ក៏មិនប្រាកដច្បាស់, បុរសនោះ គិតថា “ស្រមោលមិនប្រាកដច្បាស់” ដូច្នេះហើយ មិនចោលនូវកញ្ចក់នោះទេ, តែថា បុរសនោះជូតនូវកញ្ចក់នោះរឿយៗ, កាលបើកញ្ចក់នោះ ស្រឡះស្អាតល្អហើយ, និមិត្ត (ស្រមោលមុខ) របស់បុរសនោះ រមែងប្រាកដជាក់ច្បាស់ខ្លួនឯងតែម្តង យ៉ាងណាមិញ, មួយទៀត ប្រៀបបីដូចជាបុគ្គលអ្នកត្រូវការប្រេង រោយម្សៅល្ងចូលទៅក្នុងស្នូក ហើយយកទឹកប្រោះព្រំ, កាលបើប្រេងមិនស្រក់ចេញមក ដោយហេតុត្រឹមតែគៀប អស់វារៈមួយដង ពីរដង, បុគ្គលនោះក៏មិនចោលម្សៅល្ងឡើយ, តែបុគ្គលនោះ យកទឹកក្តៅមកប្រោះព្រំម្សៅល្ងនោះ ប្របាច់គៀបជារឿយៗ, កាលបើបុគ្គលនោះ ធ្វើយ៉ាងដូច្នោះ, ប្រេងល្ងដ៏ថ្លាល្អ ក៏ហូរចេញមក យ៉ាងណាមិញ, មួយវិញទៀត ប្រៀបដូចបុគ្គលអ្នកប្រាថ្នាចង់ធ្វើទឹកឲ្យបានថ្លាស្អាត កាន់យកនូវគ្រាប់នៃម្កាក់លូកដៃចូលទៅ ក្នុងពាងទឹក, កាលបើទឹកមិនទាន់ថ្លាល្អ ដោយគ្រាន់តែកកូរ អស់វារៈមួយដង ឬក៏ ពីរដង, ក៏មិនចោលគ្រាប់នៃម្កាក់ឡើយ, តែថា បុគ្គលនោះ កួតត្រដុសនូវគ្រាប់នៃម្កាក់នោះរឿយៗ, កាលបើបុគ្គលនោះ ធ្វើយ៉ាងដូច្នេះ, ភក់ស្តើងៗ (ទឹកដែលកករ) រមែងធ្លាក់ចុះ, ទឹកក៏បានថ្លាស្អាតល្អ យ៉ាងណាមិញ, ភិក្ខុនោះ ក៏យ៉ាងដូច្នោះដែរ មិនទំលាក់ធុរៈចោលទេ ពិចារណាធ្វើទុកក្នុងចិត្ត ប្រកាន់យក កំណត់យកនូវរូបនោះឯងរឿយៗ, ព្រោះថា រូប ជារបស់ដែលស្អាតល្អបរិសុទ្ធ មិនមានអ្វីជាប់ពាក់ព័ន្ធ ដោយប្រការណាៗ, កិលេសទាំងឡាយ ដែលជា

សឹកសត្រូវដល់ញាណ ជាគ្រឿងកំណត់រូបធម៌នោះ រមែងធ្លាក់ចុះ, ចិត្ត រមែងស្អាតបរិសុទ្ធ ដូចជាទឹកក្នុងពាង, អរូបធម៌ទាំងឡាយ ដែលមានរូបធម៌នោះ ជាអារម្មណ៍ រមែងប្រាកដខ្លួនឯង ដោយប្រការនោះៗ ។

បណ្ឌិត គប្បីប្រកាសសេចក្តីនេះ ដោយឧបមាទាំងឡាយផ្សេងៗទៀត មានអំពៅ, ចោរ, គោ, ទឹកដូរ និង ត្រីជាដើម តាមន័យដែលពោលមកហើយ ។

(អរូបធម៌ ប្រាកដដោយអាការៈ ៣)

ក៏អរូបធម៌ទាំងឡាយ រមែងប្រាកដ ដល់ភិក្ខុនោះ អ្នកកំណត់រូបដែលស្អាតបរិសុទ្ធល្អ យ៉ាងនេះ ដោយអាការៈ ៣ គឺៈ ដោយអំណាចផស្សៈខ្លះ, ដោយអំណាចវេទនាខ្លះ, ដោយអំណាចវិញ្ញាណខ្លះ ។ រមែងប្រាកដ យ៉ាងដូចម្តេច? ។

(អរូបធម៌ ប្រាកដដោយផស្សៈ)

(គឺ) ជាដំបូង កាលព្រះយោគាវចរភិក្ខុមួយរូប កំណត់ធាតុទាំងឡាយ ដោយន័យថា "បឋវីធាតុ មានការរឹងជាលក្ខណៈ" ដូច្នេះជាដើម, អរូបធម៌ ដែលធ្លាក់នៅចំពោះមុខ ជាបឋម ឈ្មោះថា ផស្សៈ រមែងប្រាកដ, វេទនា ដែលសម្បយុត្តជាមួយផស្សៈនោះ ឈ្មោថា វេទនាខន្ធ ក៏ប្រាកដ, សញ្ញា ដែលសម្បយុត្តជាមួយផស្សៈនោះ ឈ្មោះថា សញ្ញាខន្ធ រមែងប្រាកដ, ចេតនា ព្រមទាំងផស្សៈ ឈ្មោះថា សង្ខារក្ខន្ធ រមែងប្រាកដ, ចិត្ត ឈ្មោះថា វិញ្ញាណក្ខន្ធ រមែងប្រាកដ ។ ដោយន័យដូចគ្នានោះដែរ ។ កាលបើព្រះយោគាវចរ កំណត់ធាតុទាំងឡាយ ដោយន័យថា "បឋវីធាតុ ក្នុងសក់ មានការរឹងជាលក្ខណៈ ។ល។ បឋវីធាតុ ក្នុងខ្យល់ដកដង្ហើមចូល-ចេញ មានការរឹងជាលក្ខណៈ" ដូច្នេះជាដើម,



អរូបធម៌ ដែលធ្លាក់នៅចំពោះមុខ ជាបឋម ឈ្មោះថា ផស្សៈ រមែងប្រាកដ, វេទនា ដែលប្រកបព្រមដោយផស្សៈនោះ ឈ្មោះថា វេទនាខន្ធ រមែងប្រាកដ ។ល។ ចិត្ត ឈ្មោះថា វិញ្ញាណក្ខន្ធ រមែងប្រាកដ ។ អរូបធម៌ទាំងឡាយ រមែងប្រាកដ ដោយអំណាចផស្សៈ យ៉ាងនេះឯង ។

(អរូបធម៌ប្រាកដដោយអំណាចវេទនា)

កាលបើព្រះយោគាវចរភិក្ខុមួយរូប កំណត់ធាតុទាំងឡាយ ដោយន័យថា "បឋវីធាតុ មានការរឹងជាលក្ខណៈ" ដូច្នេះជាដើម, វេទនា ដែលសោយរសនៃសភាវៈ គឺការរឹងនោះ ឈ្មោះថា វេទនាខន្ធ រមែងប្រាកដ, សញ្ញាដែលសម្បយុត្តដោយវេទនានោះ ឈ្មោះថា សញ្ញាខន្ធ ក៏ប្រាកដ, ផស្សៈ និង ចេតនា ដែលសម្បយុត្ត ដោយវេទនានោះ ឈ្មោះថា សង្ខារក្ខន្ធ តែងប្រាកដ, ចិត្តដែលសម្បយុត្ត ដោយវេទនានោះ ឈ្មោះថា វិញ្ញាណក្ខន្ធ ក៏ប្រាកដ ។ ដោយន័យដូចគ្នានោះដែរ ។ កាលបើព្រះយោគាវចរភិក្ខុ កំណត់ធាតុទាំងឡាយ ដោយន័យថា "បឋវីធាតុ ក្នុងសក់ មានការរឹងជាលក្ខណៈ ។ល។ បឋវីធាតុ ក្នុងខ្យល់ដកដង្ហើមចូល-ចេញ មានការរឹងជាលក្ខណៈ" ដូច្នេះជាដើម, វេទនាដែលសោយនូវរសនៃសភាវៈគឺការរឹងនោះ ឈ្មោះថា វេទនាខន្ធ តែងប្រាកដ ។ល។ ចិត្ត ដែលសម្បយុត្ត ដោយវេទនានោះ ឈ្មោះថា វិញ្ញាណក្ខន្ធ រមែងប្រាកដ ។ អរូបធម៌ទាំងឡាយ រមែងប្រាកដ ដោយអំណាចនៃវេទនា ដូចបានរៀបរាប់មកនេះឯង ។

(អរូបធម៌ប្រាកដដោយអំណាចនៃវិញ្ញាណ)

កាលបើព្រះយោគាវចរភិក្ខុ មួយរូបទៀត កំណត់ធាតុទាំងឡាយ ដោយន័យថា "បឋវីធាតុ មានកិរិយារឹង ជាលក្ខណៈ" ដូច្នេះជាដើម,

វិញ្ញាណ ដែលដឹងជាក់ច្បាស់ចំពោះអារម្មណ៍ ឈ្មោះថា វិញ្ញាណក្ខន្ធ រមែងប្រាកដ, វេទនា ដែលសម្បយុត្ត ដោយវិញ្ញាណនោះ ឈ្មោះថា វេទនាខន្ធ ក៏ប្រាកដ, សញ្ញាដែលសម្បយុត្តដោយវិញ្ញាណនោះ ឈ្មោះថា សញ្ញាខន្ធ រមែងប្រាកដ, ផស្សៈ និង ចេតនាដែលសម្បយុត្តដោយវិញ្ញាណនោះ ឈ្មោះថា សង្ខារក្ខន្ធ រមែងប្រាកដ ។ ដោយន័យដូចគ្នានោះដែរ ។ កាលបើព្រះយោគាវចរភិក្ខុ កំណត់ធាតុទាំងឡាយ ដោយន័យថា “បឋវីធាតុ ក្នុងសក់ មានការរឹងជាលក្ខណៈ ។ល។ បឋវីធាតុ ក្នុងខ្យល់ដកដង្ហើម ចូល-ចេញ មានការរឹងជាលក្ខណៈ” ដូច្នេះជាដើម, វិញ្ញាណ ដែលដឹងជាក់ច្បាស់ចំពោះអារម្មណ៍ ឈ្មោះថា វិញ្ញាណក្ខន្ធ តែងប្រាកដ, វេទនា ដែលសម្បយុត្ត ដោយវិញ្ញាណនោះ ឈ្មោះថា វេទនាខន្ធ រមែងប្រាកដ, សញ្ញា ដែលសម្បយុត្ត ដោយវិញ្ញាណនោះ ឈ្មោះថា សញ្ញាខន្ធ ក៏ប្រាកដ, ផស្សៈ និង ចេតនា ដែលសម្បយុត្ត ដោយវិញ្ញាណនោះ ឈ្មោះថា សង្ខារក្ខន្ធ ក៏ប្រាកដ ។ អរូបធម៌ទាំងឡាយ រមែងប្រាកដ ដោយអំណាចវិញ្ញាណ ដូចពណ៌នាមកនេះឯង ។

ដោយឧបាយនេះហ្នឹងឯង បណ្ឌិតគប្បីធ្វើការប្រកប ក្នុងកោដ្ឋាសនៃធាតុ ៤២ ដោយន័យថា “បឋវីធាតុ ក្នុងសក់ដែលមានកម្មជាសមុដ្ឋាន មានការរឹង ជាលក្ខណៈ” ដូច្នេះជាដើម និង ក្នុងធាតុ ដ៏សេស មានចក្ខុធាតុជាដើម ដោយអំណាចនៃធាតុទាំងឡាយ ៤ ៗ ទៅតាមប្រភេទនៃន័យទាំងឡាយ ក្នុងវិធីនៃការកំណត់ធាតុទាំងឡាយចុះ ។

ម្យ៉ាងទៀត ព្រោះហេតុដែលអរូបធម៌ទាំងឡាយ ប្រាកដដោយអាការៈទាំងឡាយ៣ ដល់ភិក្ខុអ្នកមានការកំណត់រូប ដែលបរិសុទ្ធស្អាតយ៉ាងដូច្នេះប៉ុណ្ណោះ ហេតុនោះ ព្រះយោគាវចរ គប្បីធ្វើការព្យាយាម



ជាគ្រឿងប្រកប ដើម្បីកំណត់អរូបធម៌ ដោយការកំណត់រូប ដែលល្អបរិសុទ្ធស្អាតហ្នឹងឯង, មិនគួរគប្បីធ្វើសេចក្ដីព្យាយាម ជាគ្រឿងប្រកប ដោយការកំណត់ផ្សេងអំពីនេះទេ ។ ព្រោះប្រសិនបើ រូបធម៌មួយ ឬពីរប្រាជកឡើង, ភិក្ខុនោះ លះបង់នូវរូបចោល ចាប់ផ្ដើមកំណត់យកអរូប, ភិក្ខុនោះ រមែងសាបសូន្យអំពីកម្មដ្ឋាន ក៏សឹងមាន ប្រៀបដូចជាគោដែលរកស៊ីលើភ្នំ មានប្រការដូចបានពោលមកហើយ ក្នុងការចំរើនបឋវីកសិណនោះឯង ។ តែកាលបើព្រះយោគាវចរភិក្ខុនោះ ធ្វើការព្យាយាម ដើម្បីកំណត់អរូប ដោយអំណាចនៃការកំណត់រូប ដែលល្អបរិសុទ្ធស្អាតហើយ, កម្មដ្ឋាន រមែងដល់នូវការរីកចំរើន ដុះដាល ទូលំទូលាយ ។ ព្រះយោគាវចរនោះ កំណត់យកអរូបក្ខន្ធ ៤ ដែលប្រាកដឡើង ដោយអំណាចនៃផស្សៈជាដើម ថា “នាម” ដូច្នេះ កំណត់យកមហាភូតរូប ៤ ដែលជាអារម្មណ៍នៃអរូបក្ខន្ធទាំង ៤ នោះ និង កំណត់រូបដែលអាស្រ័យនូវមហាភូតរូបទាំង ៤ នោះ ថា “ជារូប” ដូច្នេះឯង ។

ព្រះយោគាវចរ កំណត់នូវធម៌ទាំងឡាយទាំងពួង ដែលប្រព្រឹត្តទៅ ក្នុងត្រៃភូមិ គឺៈ “ធាតុ ១៨, អាយតនៈ ១២, ខន្ធ ៥” ដោយចែកជាពីរចំណែក គឺ “នាម ១ រូប ១” ប្រៀបដូចជាបុគ្គលបើកស្មុគ្គ (ហឹប) ដោយដាវ និង ដូចជាបុគ្គលយកដាវពុះរះបណ្ដូលត្នោត ដែលព្រែកយ៉ាងនោះឯង, ព្រះយោគាវចរភិក្ខុនោះ រមែងដល់នូវការសំរេច ថា : “ក្រៅអំពីត្រឹមតែនាម និង រូបចេញហើយ របស់ដទៃ ទោះជាសត្វក្ដី បុគ្គលក្ដី ទេវតាក្ដី ព្រហ្មក្ដី មិនមានឡើយ” ដូច្នេះ ។

ព្រះយោគាវចរភិក្ខុនោះ លុះកំណត់នាមរូប តាមសភាវៈពិតយ៉ាងនេះហើយ ដើម្បីប្រយោជន៍ ដល់ការលះបង់ នូវលោកសមញ្ញានេះ ថា

“សត្វ” ថា “បុគ្គល” ដើម្បីប្រយោជន៍ ដល់ការកន្ទងបង់ នូវការវង្វេងថា “សត្វ” (និង) ដើម្បីប្រយោជន៍ដល់ការតាំងចិត្ត ក្នុងទីដែលមិនវង្វេង ឲ្យបានរឹងរឹតតែល្អប្រសើរឡើង ថែមទៀត រមែងកំណត់ប្រៀបធៀប នូវសេចក្ដីនេះថា “នេះ គឺគ្រាន់តែជានាមរូបប៉ុណ្ណោះឯង, សត្វមិនមាន, បុគ្គលមិនមាន” ដូច្នេះ ដោយអំណាចនៃព្រះសូត្រជាច្រើន ។

មែនពិត ភិក្ខុនី ឈ្មោះ វជិរា ពោលពាក្យនេះ ថា :

ប្រៀបដូចជាស័ព្ទដែលបានឈ្មោះថា“រថ”ដូច្នេះ
កើតឡើងបាន ព្រោះបរិបូណ៌ដោយអង្គ យ៉ាង
ណាមិញ, កាលបើខន្ធមានហើយ ការសន្មតិ ថា
“សត្វ” ដូច្នេះ ក៏មានយ៉ាងនោះឯង [១] ។

ព្រះសូត្រមួយទៀត ព្រះសារីបុត្រ ពោលថា “ម្នាលអ្នកទាំងឡាយមានអាយុ អាកាស គឺទីវាល ដែលអាស្រ័យគ្រឿងឈើខ្លះ, អាស្រ័យវល្លិសំរាប់ចងខ្លះ, អាស្រ័យដីសំរាប់លាបខ្លះ, អាស្រ័យស្បូវប្រក់ខ្លះផ្គុំជាមួយគ្នាហើយ ក៏រាប់ហៅថា ផ្ទះបាន យ៉ាងណាមិញ, ម្នាលអ្នកទាំងឡាយមានអាយុ អាកាសដែលអាស្រ័យឆ្អឹងខ្លះ, អាស្រ័យសរសៃខ្លះ, អាស្រ័យសាច់ខ្លះ, អាស្រ័យស្បែកខ្លះ រួបរួមជាមួយគ្នាហើយទើបហៅថា រូបបាន ក៏យ៉ាងដូច្នោះដែរ [២] ” ។

នាងភិក្ខុនី ឈ្មោះ វជិរា ពោលព្រះសូត្រមួយទៀត ថា :

ព្រោះថា សេចក្ដីទុក្ខហ្នឹងឯង រមែងកើតឡើង,
សេចក្ដីទុក្ខ រមែងឋិតនៅផង វិនាសទៅផង,

១- សុ. សំ. ភាគទី ៣០ ទំព័រ ២២ ។ ២☐ សុ. ម. ភាគទី ២១ ទំព័រ ២១១ ។



វៀរចាកសេចក្ដីទុក្ខ ឥតមានធម៌ដទៃ កើតឡើង
វៀរចាកសេចក្ដីទុក្ខ ឥតមានធម៌ដទៃរលត់ទេ ។

(៤១២) នាមរូបនោះឯង គឺព្រះសូត្រទាំងឡាយច្រើនរយ សំដែងហើយថា “មិនមែនជាសត្វ មិនមែនជាបុគ្គល” យ៉ាងដូច្នេះឯង។ ព្រោះហេតុនោះ កាលបើអង្គសម្ភារៈទាំងឡាយ មានក្ងៅ, កង់, ទ្រុង និងចន្ទោលជាដើម តាំងនៅល្អ ដោយអាការៈមួយហើយ, មានត្រឹមតែពាក្យវោហារ ថា “រថ” ប៉ុណ្ណោះឯង, កាលបើអង្គនីមួយៗ គឺបុគ្គលពិចារណា ដោយបរមត្ថ ឈ្មោះថា រថ មិនមានទេ យ៉ាងណាមិញ, មួយទៀត កាលបើគ្រឿងផ្ទះ មានឈើជាដើម ឡោមព័ទ្ធអាកាសឋិតនៅហើយ ដោយអាការៈមួយ មានត្រឹមតែពាក្យវោហារថា “ផ្ទះ” ប៉ុណ្ណោះ, (តែ) បើពិចារណាអង្គមួយៗ ដោយបរមត្ថ ឈ្មោះថា ផ្ទះមិនមានទេ យ៉ាងណាមិញ, មួយទៀត កាលបើម្រាមដៃទាំងឡាយមានមេដៃជាដើម តាំងនៅ ដោយអាការៈមួយហើយ, មានត្រឹមតែពាក្យវោហារ ថា “ក្ដាប់ដៃ” ប៉ុណ្ណោះឯង (តែបើ) ពិចារណាអង្គមួយៗ ដោយបរមត្ថ ឈ្មោះថា ក្ដាប់ដៃ មិនមានទេ យ៉ាងណាមិញ, កាលបើអវយវៈនៃពិណមានស្នូកជាដើម តាំងនៅ ដោយអាការៈមួយហើយ, មានត្រឹមតែពាក្យវោហារថា “ពិណ” ប៉ុណ្ណោះឯង, (តែបើ) ពិចារណាអង្គមួយៗដោយបរមត្ថ ឈ្មោះថា ពិណ មិនមានទេ យ៉ាងណាមិញ, កាលបើក្រុមនៃកងទ័ព មានពលដំរី ពលសេះជាដើម តាំងនៅ ដោយអាការៈមួយហើយ, មានត្រឹមតែពាក្យវោហារថា “កងទ័ព” ប៉ុណ្ណោះឯង, (តែបើ) ពិចារណាអង្គមួយៗ ដោយបរមត្ថ ឈ្មោះថា កងទ័ព មិនមានទេ

យ៉ាងណាមិញ, កាលបើអង្គនៃនគរ មានកំពែង និងស៊ុមទ្វារ(ខ្លោងទ្វារ) ជាដើម តាំងនៅ ដោយអាការៈមួយហើយ, មានត្រឹមតែពាក្យវោហារថា "នគរ" ប៉ុណ្ណោះឯង, (តែបើ)ពិចារណាអង្គមួយៗ ដោយបរមត្ថ ឈ្មោះថា នគរ មិនមានទេ យ៉ាងណាមិញ, កាលបើអវយវៈដើមឈើ មាន គល់, មែក និង ស្លឹកជាដើម តាំងនៅ ដោយអាការៈមួយហើយ, មានត្រឹមតែពាក្យវោហារថា "ដើមឈើ" ប៉ុណ្ណោះឯង, (តែបើ) ពិចារណាអង្គមួយៗ ដោយបរមត្ថ ឈ្មោះថា ដើមឈើ មិនមានទេ យ៉ាងណាមិញ, កាលបើឧបាទានក្ខន្ធ ៥ មាន, ពាក្យវោហារថា "សត្វ" ឬថា "បុគ្គល" ក៏កើតមានប៉ុណ្ណោឯង, (តែបើ) ពិចារណាធម៌មួយៗ ដោយបរមត្ថ ឈ្មោះថា សត្វ ដែលវត្ថុនៃការប្រកាន់មាំថា "អញមាន" ឬថា "ជាអញ" ដូច្នេះ មិនមានទេ, (តែបើពោល) ដោយបរមត្ថ មានត្រឹមតែនាម និង រូបប៉ុណ្ណោះឯង ក៏យ៉ាងដូច្នោះដែរ ។ ក៏ទស្សនៈរបស់ព្រះយោគាវចរនោះ ដែលឃើញយ៉ាងដូច្នេះ ឈ្មោះថា យថាភូតទស្សនៈ ។

ចំណែកបុគ្គលណា លះបង់នូវយថាភូតទស្សនៈនេះហើយប្រកាន់ថា "សត្វមាន" ដូច្នេះ, បុគ្គលនោះ គប្បីដឹងតាមនូវសេចក្តីវិនាស ឬសេចក្តីមិនវិនាស របស់ខ្លួន គឺកាលបើដឹងតាមនូវការមិនបាត់សូន្យ ក៏ធ្លាក់ទៅ ក្នុងសស្សតទិដ្ឋិ, កាលបើដឹងតាមនូវការបាត់សូន្យ ក៏ធ្លាក់ទៅក្នុងឧច្ឆេទទិដ្ឋិ ។ ព្រោះហេតុអ្វី? ។ ព្រោះមិនមានរបស់អ្វីដទៃ ដែលជារបស់ទៅជាមួយនឹងវាបាន ដូចជាទឹកដោះជូរទៅតាមទឹកដោះស្រស់យ៉ាងនោះឯង ។ បុគ្គលនោះ កាលប្រកាន់ថា "សត្វទៀង" ឈ្មោះថា រមែងជាប់នៅ, កាលប្រកាន់ ថា "សត្វ រមែងបាត់សូន្យ" ឈ្មោះថា រមែងស្ទុះទៅ ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ ថា



"ម្នាលភិក្ខុទាំងឡាយ [១] ទេវតា និង មនុស្សទាំងឡាយ ត្រូវទិដ្ឋិទាំងពីររួបរឹតហើយ ពួក១ រមែងជាប់នៅ ពួក១ រមែងស្ទុះទៅ ចំណែកពួកបុគ្គលមានចក្ខុ រមែងឃើញ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួក ១ រមែងជាប់នៅ តើដូចម្តេច?, ម្នាលភិក្ខុទាំងឡាយ ជាអ្នករីករាយ ក្នុងភព ត្រេកអរក្នុងភព ស្រើបស្រាលក្នុងភព កាលតថាគតសំដែងនូវធម៌ ដើម្បីរលត់ភព ចិត្ត របស់ទេវតា និង មនុស្សទាំងឡាយនោះ ក៏មិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនចុះស៊ប់, ម្នាលភិក្ខុទាំងឡាយ ទេវតា និង មនុស្សទាំងឡាយពួក ១ រមែងជាប់នៅ យ៉ាងនេះឯង, ម្នាលភិក្ខុទាំងឡាយ! ទេវតា និង មនុស្សទាំងឡាយពួក ១ រមែងស្ទុះទៅ តើដូចម្តេច?, (ម្នាលភិក្ខុទាំងឡាយ!) ក៏ទេវតា និង មនុស្សទាំងឡាយពួក១ កាលជិនឆ្អន់ នឿយណាយ ស្អប់ខ្ពើមភព រមែងត្រេកអរចំពោះការប្រាសចាកភព ថា "ម្នាលអ្នកដ៏ចំរើន បានឮថា អត្តភាពនេះ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងបាត់សូន្យ វិនាសទៅ មិនកើតទៅក្នុងខាងមុខទៀត ព្រោះហេតុណា នេះជាធម្មជាត ស្ងប់រម្ងាប់ នេះជាធម្មជាតដ៏ឧត្តម នេះ ជាធម្មជាតដ៏ពិត, ម្នាលភិក្ខុទាំងឡាយ ទេវតា និង មនុស្សទាំងឡាយពួក ១ រមែងស្ទុះទៅ យ៉ាងនេះឯង, ម្នាលភិក្ខុទាំងឡាយ ចុះចំណែកបុគ្គលអ្នកមានចក្ខុ រមែងឃើញ តើដូចម្តេច?, ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ឃើញនូវខន្ធបញ្ចកៈ ដោយសភាវៈពិត លុះឃើញនូវខន្ធបញ្ចកៈ ដោយសភាវៈពិតហើយ ជាអ្នកប្រតិបត្តិ ដើម្បីនឿយណាយ ដើម្បីប្រាសចាកតម្រេក ដើម្បីរំលត់នូវខន្ធបញ្ចកៈ, ម្នាលភិក្ខុទាំងឡាយ ចំណែកបុគ្គលមានចក្ខុ រមែងឃើញ

---

១- សុ. ខុ. ឥ. ភាគទី ៥៣ ទំព័រទី ៥៧ ។

យ៉ាងនេះឯង” ដូច្នេះ ។

ព្រោះហេតុនោះ យន្តដែលជាវិការៈនៃឈើ ជារបស់សោះសូន្យ មិនមានជីវៈ មិនមានការត្រិះរិះ តែថា យន្តនោះ រំកិលក៏បាន ឈប់នៅក៏បាន រមែងប្រាកដ ដូចជាមានការត្រិះរិះ ដូចជាមានសេចក្តីព្យាយាម ដោយអំណាច នៃការប្រកបផ្សំគ្នា (ចងភ្ជាប់ចូលគ្នា) នៃឈើ និង ខ្សែ យ៉ាងណា, សូម្បីនាម និង រូបនេះ ក៏បណ្ឌិត គប្បីឃើញថា “ជារបស់សោះសូន្យ មិនមានជីវៈ មិនមានការត្រិះរិះ តែថា នាម និង រូបនេះ ដើរទៅក៏បាន ឈប់នៅក៏បាន រមែងប្រាកដ ដូចជាមានការត្រិះរិះ ដូចជាមានសេចក្តីព្យាយាម ដោយអំណាចនៃការប្រកបចូលជាមួយគ្នា ទៅវិញទៅមក យ៉ាងនោះឯង” ដូច្នេះ ។

ព្រោះហេតុនោះ ទើបបោរាណាចារ្យទាំងឡាយ ពោលថា :

“នាម និង រូប រមែងមានក្នុងលោកនេះ ដោយ
(បរមត្ថ)សច្ចៈ, ក៏ក្នុងនាម និង រូបនោះ សត្វ និង
មនុស្ស មិនមានឡើយ, នាម និង រូបនេះ ជា
របស់សោះសូន្យទទេ ដែលបច្ច័យតាក់តែងឡើង
ប្រៀបដូចជាយន្ត ជាគំនរ នៃសេចក្តីទុក្ខ ប្រៀប
ដូចជាគំនរ នៃស្មៅ និង ឈើ” ដូច្នេះ ។

ម្យ៉ាងទៀត នាម និង រូបនោះ បណ្ឌិតគប្បីសំដែងឲ្យច្បាស់ដោយឧបមា ដោយយន្តជាវិការនៃឈើ តែប៉ុណ្ណឹងក៏មិនបានទេ បណ្ឌិតគប្បីសំដែង ឲ្យជាក់ច្បាស់ ដោយឧបមាទាំងឡាយដទៃទៀត មានគំនរនៃដើមបបុសជាដើម ។ មែនពិត កាលបើបាច់នៃដើមបបុសទាំងឡាយពីរ



គឺបុគ្គលតាំង (បញ្ឈរ) ផ្អែកជាមួយគ្នាហើយ, បាច់នៃដើមបបុសមួយ រមែងគាំទ្រដល់ដើមបបុសមួយ(ទៀត) (វាជួយគាំទ្រគ្នាទៅវិញទៅមក) កាលបើបាច់នៃដើមបបុសមួយ រលំដួល បាច់នៃដើមបបុសមួយទៀត ក៏រលំដួលទៅតាមគ្នាដែរ យ៉ាងណាមិញ, នាម និង រូប ក្នុងបញ្ចវោ-ការភព ក៏រមែងអាស្រ័យដល់គ្នានឹងគ្នាប្រព្រឹត្តទៅ រមែងឧបត្ថម្ភគាំទ្រគ្នាបាន កាលបើ (នាម និង រូប) មួយ ដួលរលំទៅ ដោយអំណាចនៃមរណៈ (នាម និង រូប) ដទៃទៀត ក៏រលំដួលទៅតាមៗ គ្នាដែរ ក៏យ៉ាងនោះឯង ។

ព្រោះហេតុនោះ ទើបបោរាណាចារ្យទាំងឡាយ ពោលថា :

នាម និង រូប ជារបស់គូនឹងគ្នា ទាំងពីរអាស្រ័យ
គ្នាទៅវិញទៅមក កាលបើមួយបែកធ្លាយ នាម
និងរូបទាំងពីរ ក៏រមែងបែកធ្លាយទៅតាមបច្ច័យ ។

មួយទៀត កាលបើសំឡេង អាស្រ័យនូវស្គរដែលបុគ្គលវាយទូងដោយអន្ទូងប្រព្រឹត្តទៅ, ស្គរក៏ទៅផ្សេង, សំឡេងក៏ទៅផ្សេង, ស្គរ និង សំឡេង ជារបស់មិនចូលគ្នាទេ, ស្គរជារបស់សូន្យទទេអំពីសំឡេង, សំឡេងក៏ជារបស់សូន្យទទេអំពីស្គរ យ៉ាងណា, កាលបើនាមអាស្រ័យរូបពោលគឺហទយវត្ថុ, ទ្វារ និង អារម្មណ៍ប្រព្រឹត្តទៅ, រូបជារបស់ផ្សេង, នាម ក៏ជារបស់ផ្សេង, នាម និង រូប ជារបស់មិនប្រឡូកប្រឡល់គ្នាទេ, នាមសូន្យទទេអំពីរូប, រូបក៏សូន្យទទេអំពីនាមដែរ ក៏យ៉ាងដូច្នោះឯង ។ គ្រាន់តែថា នាមអាស្រ័យរូបប្រព្រឹត្តទៅ ប្រៀបដូចជាសំឡេងអាស្រ័យស្គរប្រព្រឹត្តទៅ ដូច្នោះដែរ ។

*ព្រោះហេតុនោះ ទើបបោរាណាចារ្យទាំងឡាយ ពោលថា :*

ធម៌ទាំងឡាយ មានផស្សៈជាគម្រប់ ៥ មិនបាន
កើតអំពីភ្នែក មិនបានកើតអំពីរូប និង មិនបានកើត
ក្នុងចន្លោះនៃភ្នែក និង រូបទាំងពីរ, ធម៌ទាំងឡាយ
នោះជាសង្ខតធម៌ អាស្រ័យហេតុកើតឡើង ប្រៀប
ដូចជា កាលបើស្គរដែលបុគ្គលទូងហើយ សំឡេង
ក៏កើត (១) ឡើង ដូច្នោះឯង,

ធម៌ទាំងឡាយ មានផស្សៈជាគម្រប់ ៥ មិនបាន
កើតអំពីត្រចៀក មិនបានកើតអំពីសំឡេង និង
មិនបានកើត ក្នុងចន្លោះនៃត្រចៀក និង សំឡេង
ទាំងពីរទេ ។ល។,

ធម៌ទាំងឡាយ មានផស្សៈជាគម្រប់ ៥ មិនបាន
កើតអំពីច្រមុះ មិនបានកើតអំពីក្លិន និង មិនបាន
កើតក្នុងចន្លោះនៃច្រមុះ និង ក្លិនទាំងពីរទេ ។ល។,

ធម៌ទាំងឡាយ មានផស្សៈជាគម្រប់ ៥ មិនបាន
កើតអំពីជិវ្ហា មិនបានកើតអំពីរស និង មិនបានកើត
ក្នុងចន្លោះនៃជិវ្ហា និង រសទាំងពីរទេ ។ល។,

ធម៌ទាំងឡាយ មានផស្សៈជាគម្រប់ ៥ មិនបាន
កើតអំពីកាយ មិនបានកើតអំពីផស្សៈ និង មិនបាន
កើតក្នុងចន្លោះនៃកាយនិងផស្សៈទាំងពីរទេ ។ល។,

សង្ខតធម៌ទាំងឡាយ មិនបានកើតអំពីវត្ថុរូប ទាំង
មិនបានចេញ អំពីធម្មាយតនៈ ទាំងឡាយ ផងដែរ,



ធម៌ទាំងឡាយនោះ ជាសង្ខតធម៌ អាស្រ័យនូវ
ហេតុកើតឡើង ប្រៀបដូចជា កាលបើស្គរ ត្រូវ
បុគ្គលទូងហើយ សំឡេងក៏កើតឡើង ដូច្នោះ ។

*មួយទៀតសោត ក្នុងនាម និង រូប, នាម មិនមានតេជះអំណាច មិនអាចប្រព្រឹត្តទៅ ដោយតេជះអំណាច របស់ខ្លួនបានទេ ទំពាស៊ី មិនបាន ផឹកមិនបាន និយាយមិនបាន សំរេចឥរិយាបថ ក៏មិនបានដែរ, សូម្បីរូប ក៏មិនមានតេជះអំណាច មិនអាចប្រព្រឹត្តទៅ ដោយអំណាចតេជះរបស់ខ្លួនបានទេ ទាំងការប្រាថ្នានឹងទំពាស៊ី របស់រូបនោះ ក៏មិនមាន ការប្រាថ្នានឹងផឹក ក៏មិនមាន ការប៉ងប្រាថ្នានឹងនិយាយស្តី ក៏មិនមាន ការប៉ងប្រាថ្នានឹងសំរេចឥរិយាបថ ក៏មិនមានដែរ, តាមពិតនោះ រូប អាស្រ័យនាមប្រព្រឹត្តទៅ, នាម ក៏អាស្រ័យរូបប្រព្រឹត្តទៅ, ក៏ប៉ុន្តែ កាលបើការប៉ងប្រាថ្នានឹងទំពាស៊ី កាលបើការប៉ងប្រាថ្នានឹងផឹក កាលបើការប៉ងប្រាថ្នានឹងនិយាយស្តី កាលបើការប៉ងប្រាថ្នានឹងសំរេចនូវឥរិយាបថ របស់នាម មាន, រូប រមែងទំពាស៊ី ផឹក និយាយស្តី រមែងសំរេចឥរិយាបថ ។*

*មួយទៀត ដើម្បីញ៉ាំងសេចក្តីនេះ ឲ្យបានជាក់ច្បាស់ ទើបអាចារ្យទាំងឡាយ នាំឧបមានេះ មក(សំដែង)អាង (ដូចតទៅ) ។ ប្រៀបដូចជា បុរសដែលខ្វាក់ភ្នែក អំពីកំណើត និង បុរសដែលខ្វិន ជាអ្នកប្រាថ្នានឹងចេញទៅកាន់ទិស, បុរសខ្វាក់អំពីកំណើត និយាយទៅកាន់បុរសខ្វិន យ៉ាងនេះថា "នែសំឡាញ់អើយ! ខ្ញុំអាចប្រើជើងដើរទៅបាន, តែភ្នែកសំរាប់មើលផ្លូវដែលរាបស្មើ និង មិនរាបស្មើ របស់ខ្ញុំមិនមានទេ" ដូច្នេះ*

*ចំណែកបុរសខ្វិន ក៏បាននិយាយប្រាប់បុរសខ្វាក់ពីកំណើត យ៉ាងនេះថា "នែសំឡាញ់! ខ្ញុំអាចប្រើចក្ខុមើលឃើញបាន, តែជើងសំរាប់ដើរឈាន ទៅមុខ ឬ ថយក្រោយ របស់ខ្ញុំមិនមានទេ" ដូច្នេះ, បុរសខ្វាក់ភ្នែកពីកំណើត ត្រេកអររីករាយ ទើបឲ្យបុរសខ្វិនជិះ-ក, បុរសខ្វិន ជិះលើស្មារបស់បុរសខ្វាក់អំពីកំណើតហើយ និយាយប្រាប់ យ៉ាងដូច្នេះ ថា "ចូរសំឡាញ់លះផ្លូវឆ្វេង កាន់យកផ្លូវស្តាំ ចូរលះផ្លូវស្តាំកាន់យកផ្លូវឆ្វេង" ដូច្នេះ, បណ្តាបុរសខ្វាក់ ខ្វិនទាំងពីរនោះ ចំណែកបុរសខ្វាក់ពីកំណើត ជាអ្នកមិនមានអំណាច គ្មានកម្លាំង នឹងដើរទៅដោយអំណាចរបស់ខ្លួនពុំបាន ដើរទៅដោយកម្លាំងរបស់ខ្លួនពុំបាន, បុរសខ្វិនទៀតសោត ក៏ជាអ្នកគ្មានអំណាច គ្មានកម្លាំង នឹងដើរទៅដោយអំណាច ដើរទៅដោយកម្លាំងរបស់ខ្លួន ក៏មិនបានដែរ, តែការអាស្រ័យគ្នាទៅវិញទៅមក ដើរទៅ របស់បុរសខ្វាក់ ខ្វិនទាំងពីរនាក់នោះ ប្រព្រឹត្តទៅមិនបាន ក៏មិនមែនទេ យ៉ាងណាមិញ, សូម្បីនាម ក៏មិនមានអំណាច កើតឡើងដោយអំណាចរបស់ខ្លួន ក៏មិនបាន ប្រព្រឹត្តទៅក្នុងកិរិយានោះៗ ក៏មិនបាន, ចំណែកឯរូប ក៏មិនមានអំណាច កើតឡើងដោយអំណាចរបស់ខ្លួន ក៏មិនបាន ប្រព្រឹត្តទៅក្នុងកិរិយានោះៗ ក៏មិនបាន, តែការអាស្រ័យគ្នានឹងគ្នាទៅវិញទៅមកហើយ កើតឡើង ឬ ប្រព្រឹត្តទៅ នៃនាម និង រូបទាំងពីរនោះ មិនមាន ក៏មិនមែនទេ ក៏យ៉ាងនោះដែរ ។*

*ព្រោះហេតុនោះ ទើបបោរាណាចារ្យទាំងឡាយ ពោលថា :*

ធម៌ទាំងឡាយ ដែលជាសង្ខតធម៌ ទន់ខ្សោយ
ព្រោះកម្លាំងរបស់ខ្លួន កើតដោយកម្លាំងរបស់ខ្លួន
មិនបានទេ ទាំងតាំងនៅ ដោយកម្លាំង របស់ខ្លួន



ក៏មិនបានដែរ, ធម៌ទាំងនោះ មានប្រក្រតីប្រព្រឹត្ត
ទៅ តាមអំណាចនៃធម៌ដទៃទៀត ទើបកើត គឺ
ធម៌ទាំងនេះ តែងកើត ព្រោះធម៌ដទៃជាបច្ច័យ
តាំងនៅព្រម ព្រោះមានធម៌ដទៃជាអារម្មណ៍ និង
ត្រូវអារម្មណ៍ និង បច្ច័យទាំងឡាយដែលធម៌ដទៃ
ឲ្យកើតមាន,

មនុស្សទាំងឡាយ អាស្រ័យនូវនាវា ទើបធ្វើ
ដំណើរទៅក្នុងទន្លេបាន យ៉ាងណាមិញ, នាម
កាយ ក៏អាស្រ័យរូបប្រព្រឹត្តទៅ យ៉ាងនោះដែរ,
នាវា អាស្រ័យ នូវមនុស្សទាំងឡាយ ទើប
អណ្តែតទៅ ក្នុងទន្លេបាន យ៉ាងណា, រូបកាយ
ក៏អាស្រ័យនូវនាម ទើបប្រព្រឹត្តទៅបាន ក៏យ៉ាង
ដូច្នោះដែរ, មនុស្សទាំងឡាយ និង នាវា ទាំងពីរ
លុះអាស្រ័យនូវគ្នានឹងគ្នាហើយ ទើបទៅ ក្នុង
ទន្លេបាន យ៉ាងណាមិញ, នាម និង រូបទាំងពីរ
ក៏ជាធម៌អាស្រ័យគ្នាទៅវិញទៅមក ទើបប្រព្រឹត្ត
ទៅបាន ក៏យ៉ាងនោះដែរ ។

*កិរិយាឃើញនាមរូប តាមសេចក្តីពិត ដែលគ្របសង្កត់នូវសត្តសញ្ញា ហើយតាំងនៅ ក្នុងអសម្មោហភូមិនៃព្រះយោគី អ្នកកំណត់នាមរូប ដោយន័យផ្សេងៗ ដូចបានពណ៌នាមកហើយនេះ បណ្ឌិតគប្បីជ្រាបថា* "ឈ្មោះថា ទិដ្ឋិវិសុទ្ធិ" *ដូច្នេះ ។ ពាក្យថា* "ការកំណត់នាមរូប"

ដូច្នេះក្តី, ពាក្យថា “ការកំណត់សង្ខារ” ដូច្នេះក្តី ជាឈ្មោះនៃការឃើញនាមរូប តាមសេចក្តីពិតហ្នឹងឯង ។

*បរិច្ឆេទ ទី១៨ ឈ្មោះទិដ្ឋិវិសុទ្ធិនិទ្ទេស ក្នុងអធិការ*
*នៃបញ្ញាភាវនា ក្នុងវិសុទ្ធិមគ្គ*
*ដែលខ្ញុំរៀបរៀងហើយ ដើម្បីប្រយោជន៍ដល់កិរិយា*
*ញុំាងសាធុជន ឲ្យរីករាយ*
*ចប់ហើយ ដោយប្រការដូច្នេះឯង ។*



## កង្ខាវិតរណវិសុទ្ធិនិទ្ទេស

(៤១៣) ចំណែកខាងញាណ ដែលកន្លងផុតនូវសេចក្តីសង្ស័យក្នុងអទ្ធា ៣ ដោយការកំណត់បច្ច័យ នៃនាមរូបហ្នឹងឯង ឈ្មោះថា **កង្ខាវិតរណវិសុទ្ធិ** ។

(ការពិចារណាហេតុបច្ច័យនៃនាមរូប)

ភិក្ខុអ្នកប្រាថ្នា នឹងញុំាងកង្ខាវិតរណវិសុទ្ធិនោះឲ្យដល់ព្រម រមែងពិចារណានូវការស្វែងរកនូវហេតុបច្ច័យ នៃនាមរូបនោះ ដូចជាគ្រូពេទ្យដែលឆ្លាត ឃើញរោគហើយ ក៏ស្វែងរកនូវសមុដ្ឋាន (ទីកើត) នៃរោគនោះ យ៉ាងនោះឯង ឬក៏ ដូចជាបុរសអ្នកមានចិត្តអនុគ្រោះ ឃើញនូវកុមារតូចខ្ចី ដេកអង្រើង ដេកលើថ្នល់ហើយ ក៏ពិចារណារកមាតាបិតារបស់កុមារតូចខ្ចីនោះ ដោយនឹកគិតថា “កុមារតូចនេះ ជាកូនរបស់អ្នកណាហ្ន៎?” ដូច្នេះ ក៏ដូច្នោះដែរ ។

ដំបូងបង្អស់ ភិក្ខុនោះ រមែងពិចារណា យ៉ាងនេះថា “នាមរូបនោះដំបូង មិនមែនជារបស់ដែលមិនមានហេតុ ព្រោះវាដល់នូវភាពដូចគ្នាតែមួយ គ្រប់ទិសទីកន្លែង និង គ្រប់ផ្នែកទាំងអស់ មិនមែនជារបស់ដែលមានបច្ច័យខាងក្រៅ មានបុគ្គលជាធំជាដើម ជាហេតុទេ ព្រោះមិនមានរបស់ទាំងឡាយមានបុគ្គលជាធំជាដើម ធំជាងនាមរូបឡើយ ព្រោះសូម្បីបុគ្គលទាំងឡាយណា ពោលត្រឹមតែនាមរូបហ្នឹងឯងថា: ជារបស់ធំជាដើម ដូច្នេះ, នាមរូប ពោលគឺភាពជាធំជាដើម របស់បុគ្គលទាំងឡាយនោះ ជារបស់ដែលមិនមានហេតុ ព្រោះហេតុនោះ ហេតុបច្ច័យទាំងឡាយនៃនាមរូបនោះ គប្បីមាន, ហេតុបច្ច័យទាំងឡាយនោះ បានដល់អ្វីទៅហ្ន៎ ? ” ។

**(កំណត់ហេតុបច្ច័យនៃនាមរូប ទី១)**

*ភិក្ខុនោះ លុះពិចារណានូវហេតុបច្ច័យទាំងឡាយនៃនាមរូប យ៉ាងនេះហើយ រមែងកំណត់យក នូវហេតុបច្ច័យ នៃរូបកាយនេះ ជាដំបូង យ៉ាងដូច្នេះថា "កាយនេះ កាលកើត មិនមែនកើតខាងក្នុងនៃផ្កាមានផ្កាឧប្បល, បទុម, បុណ្ឌរិក (ឈូកស) និង សោគន្ធិកៈ (ចង្កុលណី ឬ ស្គន់) ជាដើមឡើយ មិនមែនកើត ខាងក្នុងរតនៈទាំងឡាយ មានកែវមណី និង កែវមុក្តាហារជាដើមទេ តាមពិត គឺកើតក្នុងក្រពះអាហារថ្មី និង ក្រពះអាហារចាស់ បែរខ្នងទៅរកផ្ទៃពោះ (ខាងមុខ) បែរមុខទៅរកឆ្អឹងខ្នង (ក្រោយ) មានពោះវៀនធំតូច លោមព័ទ្ធជុំវិញ ខ្លួនឯង ក៏ជារបស់បដិកូល មានក្លិនស្អុយគួរខ្ពើមរអើម កើតនៅក្នុងឱកាស ដែលបដិកូល មានក្លិនស្អុយគួរខ្ពើម ជាទីចង្អៀតចង្អល់ យ៉ាងខ្លាំងក្រៃលែង ប្រៀបបាននឹងសត្វដង្កូវ កើតនៅក្នុងត្រីស្អុយ, នំផ្អូម, លូទឹកស្អុយ និង លូទឹកជ្រាំជាដើម យ៉ាងនោះឯង, ធម៌ប្រាំប្រការ ជាហេតុបច្ច័យ នៃរូបកាយនោះ ដែលកើតយ៉ាងនេះ គឺ "ធម៌ ៤ ប្រការនេះ គឺ អវិជ្ជា, តណ្ហា, ឧបាទាន, កម្ម ឈ្មោះថា ជាហេតុ ព្រោះជាអ្នកឲ្យកើត, អាហារ ឈ្មោះថា ជាបច្ច័យ ព្រោះជាអ្នកជួយឧបត្ថម្ភគាំទ្រ" ដូច្នេះ, សូម្បីក្នុងធម៌ ៥ ប្រការនោះ ធម៌ទាំងឡាយបី មានអវិជ្ជាជាដើម ជាទីអាស្រ័យកើតនៃកាយនេះ ប្រៀបដូចជាមាតា ជាទីអាស្រ័យនៃទារក, កម្ម ជាអ្នកញុំាងកាយនេះឲ្យកើត ដូចជាបិតា ញុំាងបុត្រឲ្យកើត, អាហារ ជាអ្នកឧបត្ថម្ភគាំទ្រកាយនេះ ប្រៀបបាននឹងស្រីមេនំ បី-ពរនូវទារក យ៉ាងដូច្នោះ" ។ ភិក្ខុនោះ លុះធ្វើការកំណត់បច្ច័យនៃរូបកាយ យ៉ាងនេះហើយ រមែងធ្វើការកំណត់បច្ច័យ នៃនាមកាយ បន្តទៅទៀត ដោយន័យ*



*ថា "ចក្ខុវិញ្ញាណ អាស្រ័យចក្ខុ និង រូប កើតឡើង" ដូច្នេះជាដើម ។*

**(សេចក្តីសង្ស័យ ១៦ យ៉ាង)**

*ភិក្ខុនោះ លុះឃើញការប្រព្រឹត្តិទៅ នៃនាមរូប តាមបច្ច័យ យ៉ាងនេះហើយ ទើបពិចារណាឃើញច្បាស់ថា "នាមរូបនេះប្រព្រឹត្តទៅ ក្នុងកាលឥឡូវនេះ យ៉ាងណា, សូម្បីក្នុងអតីតកាល នាមរូបនេះ ក៏បានប្រព្រឹត្តទៅហើយតាមបច្ច័យ សូម្បីក្នុងអនាគតកាលទៀតសោត នាមរូបនេះ ក៏នឹងប្រព្រឹត្តទៅ តាមបច្ច័យ ក៏ដូច្នោះដែរ" ដូច្នេះ ។ កាលបើភិក្ខុនេះពិចារណាឃើញច្បាស់យ៉ាងនេះ សេចក្តីសង្ស័យទាំង ៥ ប្រការនោះឯណា ដែលលោកប្រារព្ធ នូវខន្ធធាតុ អាយតនៈ ជាចំណែកខាងដើមគឺអតីតកាល ពោលហើយថា "ក្នុងកាលកន្លងទៅហើយ [១] អាត្មាអញ ធ្លាប់បានកើតឬហ្ន៎ ឬ ក្នុងកាលកន្លងទៅហើយ អាត្មាអញ មិនធ្លាប់បានកើតទេ, ក្នុងកាលកន្លងទៅហើយ អាត្មាអញ បានកើតជាជាតិអ្វីទៅហ្ន៎ ក្នុងកាលកន្លងទៅហើយ អាត្មាអញ បានកើតជាមនុស្ស មានទ្រង់ទ្រាយដូចម្តេច, ក្នុងកាលកន្លងទៅហើយ អាត្មាអញ បានកើតជាជាតិអ្វី បានជាអ្វី ដូច្នេះ បានដែរឬទេ" ដូច្នេះ, សេចក្តីសង្ស័យទាំងឡាយ ៥ ប្រការឯណា ដែលលោកប្រាថ្នា នូវខន្ធធាតុ អាយតនៈ ជាចំណែកខាងមុខ គឺអនាគតកាល ពោលហើយថា "ក្នុងកាលជាអនាគត អាត្មាអញ នឹងកើតឬហ្ន៎ ក្នុងកាលអនាគត អាត្មាអញ នឹងមិនកើតទៀតទេ, ក្នុងកាលជាអនាគត អាត្មាអញ នឹងកើតជាអ្វីហ្ន៎ ក្នុងកាលជាអនាគត អាត្មាអញ នឹងកើតជាមនុស្ស មានទ្រង់ទ្រាយដូចម្តេចហ្ន៎, ក្នុងកាលជាអនាគត អាត្មាអញ នឹងកើតជាជាតិអ្វី បានជាអ្វីដូច្នេះ បានដែរ*

*១- សុ. ម. មូ. ភាគទី ២២ ទំព័រទី ១៧៧ ។*

ឬទេ” ដូច្នេះ, សេចក្តីសង្ស័យទាំងឡាយ ៦ ប្រការ ឯណា ដែលលោកប្រារព្ធនូវខន្ធ ធាតុ អាយតនៈ ជាចំណែកបច្ចុប្បន្នកាល ពោលហើយថា “មួយវិញទៀត បុគ្គលគប្បីសង្ស័យចំពោះខន្ធធាតុ អាយនៈ ជាចំណែកខាងក្នុង ប្រារព្ធនូវកាលជាបច្ចុប្បន្ន ក្នុងកាលឥឡូវនេះ ថា : អាត្មាអញ កើតទៀត ឬ មិនកើតទេ អាត្មាអញកើតជាជាតិអ្វីហ្ន៎ អាត្មាអញ កើតជាមនុស្សមានទ្រង់ទ្រាយដូចម្តេច, សត្វនេះ មកអំពីទីណា សត្វនោះ នឹងទៅកើត ក្នុងទីណាវិញ ដូច្នេះដែរឬទេ” ដូច្នេះ, សេចក្តីសង្ស័យទាំងអស់នោះឯង គឺភិក្ខុនោះ តែងលះបង់បាន ។

(កំណត់បច្ច័យនៃនាមរូប ទី២)

ភិក្ខុមួយរូបទៀត ឃើញបច្ច័យនៃនាមពីរប្រការ ដោយអំណាចនៃសាធារណប្បច្ច័យ និង អសាធារណប្បច្ច័យ ឃើញបច្ច័យនៃរូប ៤ ប្រការ ដោយអំណាចនៃបច្ច័យ មានកម្មប្បច្ច័យជាដើម ។ មែនពិត បច្ច័យនៃនាម មាន ២ ប្រការ គឺ សាធារណប្បច្ច័យ និង អសាធារណ-ប្បច្ច័យ ។ បណ្តាបច្ច័យទាំង ២ ប្រការនោះ ទ្វារ ៦ មានចក្ខុទ្វារជាដើម អារម្មណ៍ ៦ មានរូបារម្មណ៍ជាដើម ជាសាធារណប្បច្ច័យ របស់នាម, ធម៌ទាំងឡាយ មានមនសិការជាដើម ដែលប្រព្រឹត្តទៅអំពីចក្ខុ និង រូបជាដើមនោះ ជាអសាធារណប្បច្ច័យរបស់នាម សព្វគ្រប់ប្រការ ដោយប្រភេទនៃនាម ដែលជាកុសលជាដើម ។ មែនពិត ធម៌ទាំងឡាយមានយោនិសោមនសិការ និង សទ្ធម្មស្សវនៈជាដើម ជាបច្ច័យ នៃនាមដែលជាកុសលតែម្យ៉ាង, ធម៌ដែលផ្ទុយអំពីនេះ ក៏ជាបច្ច័យនៃនាម ដែលជាអកុសល, ធម៌ទាំងឡាយ មានកម្មជាដើម ជាបច្ច័យនៃនាម ដែលជាវិបាក, ធម៌ទាំងឡាយ មានភវង្គជាដើម ជាបច្ច័យនៃនាមដែលជាកិរិយា



ដោយប្រការដូច្នោះឯង ។

ចំណែកឯធម៌ ៤ ប្រការ មានកម្មជាដើមនេះ គឺ “កម្ម, ចិត្ត, រដូវ, អាហារ” ជាបច្ច័យនៃរូប ។ ក្នុងធម៌ ៤ ប្រការនោះ កម្មដែលជាអតីតប៉ុណ្ណោះ ជាបច្ច័យនៃរូប ដែលមានកម្ម ជាសមុដ្ឋាន ។ ចិត្ត ដែលកំពុងកើតឡើង ជាបច្ច័យនៃរូបដែលមានចិត្ត ជាសមុដ្ឋា ។ រដូវ និង អាហារ ជាបច្ច័យនៃរូប ដែលមានរដូវ និង អាហារ ជាសមុដ្ឋាន ក្នុងឋិតិខណៈ ដូច្នេះឯង ។

ភិក្ខុមួយរូប ធ្វើការកំណត់បច្ច័យនៃនាមរូប ដោយន័យដូចបានពណ៌នាមកនេះឯង ។ ភិក្ខុរូបនោះ លុះឃើញការប្រព្រឹត្តិទៅនៃនាមរូប តាមបច្ច័យ យ៉ាងនេះហើយ រមែងពិចារណាឃើញច្បាស់ថា “នាមរូបនេះ ប្រព្រឹត្តទៅ តាមបច្ច័យ ក្នុងកាលឥឡូវនេះ យ៉ាងណាមិញ, សូម្បីក្នុងអតីតកាល នាមរូបនេះ ក៏បានប្រព្រឹត្តទៅហើយ តាមបច្ច័យ, ក្នុងអនាគតកាលសោត នាមរូបនេះ ក៏នឹងប្រព្រឹត្តទៅ តាមបច្ច័យ ក៏យ៉ាងនោះដែរ” ដូច្នេះ ។ សេចក្តីសង្ស័យ ក្នុងកាលទាំង ៣ គឺភិក្ខុរូបនោះ កាលពិចារណាឃើញជាក់ច្បាស់ យ៉ាងនេះហើយ រមែងលះបង់បាន ដោយន័យដែលបានពោលមកហើយហ្នឹងឯង ។

(កំណត់បច្ច័យនៃនាមរូប ទី៣)

ភិក្ខុមួយរូបទៀត ឃើញនូវការដល់នូវជរា នៃសង្ខារទាំងឡាយ ពោលគឺនាមរូបទាំងនោះហ្នឹងឯង និង ការបែកធ្លាយនៃសង្ខារទាំងឡាយ ដែលចាស់ជរាហើយ ធ្វើការកំណត់នូវបច្ច័យនៃនាមរូប ដោយអំណាចនៃបដិច្ចសមុប្បាទ តាមបដិលោម យ៉ាងនេះថា “ធម្មតាជរា និង មរណៈ នៃសង្ខារទាំងនេះ កាលបើជាតិមាន ទើបកើតមាន, ជាតិ កាលបើកព

មាន ទើបមាន, ភព កាលបើមានឧបាទាន ទើបមាន, ឧបាទាន កាលបើមានតណ្ហា ទើបមាន, តណ្ហា កាលបើមានវេទនា ទើបមាន, វេទនា កាលបើមានផស្សៈ ទើបមាន, ផស្សៈ កាលបើមានសឡាយតនៈ ទើបមាន, សឡាយតនៈ កាលបើមាននាមរូប ទើបមាន, នាមរូប កាលបើមានវិញ្ញាណ ទើបមាន, វិញ្ញាណ កាលបើមានសង្ខារទាំងឡាយ ទើបមាន, សង្ខារទាំងឡាយ កាលបើមានអវិជ្ជា ទើបកើតមាន" ដូច្នេះ ។ លំដាប់នោះ សេចក្តីសង្ស័យ គឺកិក្ខុនោះ លះបង់បានហើយ ដោយន័យដូចបានពណ៌នាមកហ្នឹងឯង ។

(ការកំណត់បច្ច័យនៃនាមរូប ទី៤)

ភិក្ខុមួយរូបទៀត ធ្វើការកំណត់បច្ច័យនៃនាមរូប ដោយអំណាចនៃបដិច្ចសមុប្បាទ ដោយអនុលោម ដែលបានសំដែងឲ្យពិស្តារហើយក្នុងកាលខាងដើមថា "សង្ខារទាំងឡាយ កើតមាន ព្រោះមានអវិជ្ជាជាបច្ច័យ យ៉ាងដូច្នេះឯង" ។ លំដាប់នោះ សេចក្តីសង្ស័យ គឺភិក្ខុនោះ លះបង់បានហើយ ដោយន័យដូចបានពណ៌នាមកហើយហ្នឹងឯង ។

(កំណត់បច្ច័យនៃនាមរូប ទី៥)

ភិក្ខុមួយរូបទៀត ធ្វើការកំណត់បច្ច័យនៃនាមរូប ដោយអំណាចនៃកម្មវដ្ត និង វិបាកវដ្ត យ៉ាងដូច្នេះថា "ធម៌ [១] ទាំងឡាយ ៥ នេះ គឺ ការវង្វេងក្នុងកម្មភព ដែលមានក្នុងកាលមុន ជាអវិជ្ជា, ចេតនា ដែលប្រមូលមកក្នុងបុរិមកម្មភព ជាសង្ខារ, ការប្រាថ្នា ក្នុងបុរិមកម្មភព ជាតណ្ហា, កិរិយាប្រកាន់មាំ ក្នុងបុរិមកម្មភព ជាឧបាទាន, ចេតនា ក្នុងបុរិមកម្មភព ជាភព, កាលបើបុរិមកម្មភព មាន, រមែងជាបច្ច័យ នៃ

១- សុ. ខុ. បដិ. ភាគទី ៦៩ ទំព័រទី ១១៩ ។



បដិសន្ធិ ក្នុងឧបបត្តិភពនេះ, ធម៌ទាំងឡាយ ៥ យ៉ាងនេះ គឺ បដិសន្ធិ ក្នុងឧបបត្តិភពនេះ ជាវិញ្ញាណ, ការចូលកាន់គភ៌ ក្នុងឧបបត្តិភពនេះ ជានាមរូប, សេចក្តីជ្រះថ្លា ក្នុងឧបបត្តិភពនេះ ជាអាយតនៈ, សភាវៈដែលបុគ្គលពាល់ត្រូវហើយ ក្នុងឧបបត្តិភពនេះ ជាផស្សៈ, ការសោយ (នូវផល) ក្នុងឧបបត្តិភពនេះ ជាវេទនា, កាលបើឧបបត្តិភពនេះមាន រមែងជាបច្ច័យនៃកម្មដែលបានធ្វើហើយ ក្នុងកាលមុន, ព្រោះអាយតនៈទាំងឡាយចាស់ក្លាហើយ ធម៌ទាំងឡាយ ៥ យ៉ាងនេះ គឺ : សេចក្តីវង្វេង ក្នុងកម្មភពនេះ ជាអវិជ្ជា ។ល។ ចេតនា ក្នុងកម្មភពនេះ ជាភព, កាលបើកម្មភពនេះមាន រមែងជាបច្ច័យនៃបដិសន្ធិ ក្នុងភពជាបន្តបន្ទាប់ទៅទៀត ។

(កម្មឲ្យផល តាមកាល ៤ យ៉ាង)

(៤១៤) បណ្តាកម្ម និង វិបាកនោះ កម្ម មាន ៤ យ៉ាង គឺ : ទិដ្ឋធម្មវេទនីយកម្ម, ឧបបជ្ជវេទនិយកម្ម, អបរាបរិយវេទនីយកម្ម, អហោសិកម្ម ។ បណ្តាកម្មទាំងឡាយ ៤ យ៉ាងនោះ ជវនចេតនា ទី១ ជាកុសលក្តី ជាអកុសលក្តី ក្នុងចិត្តទាំង ៧ ក្នុងជវនវិថី ១ ឈ្មោះថា ទិដ្ឋធម្មវេទនីយកម្ម ។ ទិដ្ឋធម្មវេទនីយកម្មនោះ រមែងឲ្យផល តែក្នុងអត្តភាពនេះ ប៉ុណ្ណោះឯង ។ តែកាលបើមិនអាចឲ្យផល យ៉ាងដូច្នោះទេ ទើបបានឈ្មោះថា ជាអហោសិកម្ម ។ ធម្មតា អហោសិកម្ម តែងមាន ដោយអំណាចនៃតិកៈ (គឺមិនឲ្យផលក្នុងកាលទាំង៣ ដូចក្នុងបាលី) នេះថា "វិបាករបស់កម្ម មិនទាន់មានហើយ វិបាករបស់កម្ម នឹងមិនមាន វិបាក របស់កម្ម [១] មិនមាន" ដូច្នេះ ។

១- សុ. ខុ. បដិ. ភាគទី ៧០ ទំព័រទី ៣៨៣ ។

ចំណែកខាងជវនចេតនា ទី៧ ដែលញ៉ាំងផលឲ្យសំរេច ឈ្មោះថា ឧបបជ្ជវេទនីយកម្ម ។ ឧបបជ្ជវេទនីយកម្មនោះ រមែងឲ្យផល ក្នុងអត្តភាព(ជាបន្ទាប់) ។ កាលបើមិនអាចឲ្យផល យ៉ាងដូច្នោះទេ ក៏បានឈ្មោះថា ជាអហោសិកម្ម តាមន័យដែលបានពោលហើយហ្នឹងឯង ។

ជវនចេតនា ៥ ក្នុងលំដាប់ នៃជវនចេតនាទាំងពីរ ឈ្មោះថា អបរាបរិយវេទនីយកម្ម ។ អបរាបរិយវេទនីយកម្មនោះ បានទូវឱកាសក្នុងពេលណា ទើបឲ្យផល ក្នុងពេលនោះ ក្នុងអនាគត ។ កាលបើការប្រព្រឹត្តិទៅ នៃសង្សារ មាន, អបរាបរិយវេទនីយកម្មនោះ មិនបានឈ្មោះថា ជាអហោសិកម្មទេ ។

(កម្មឲ្យផល តាមលំដាប់ ៤ យ៉ាង)

កម្ម ៤ យ៉ាងផ្សេងទៀត គឺ : កម្ម ដែលជាគរុកម្ម, លហុកម្ម, អាសន្នកម្ម, កដត្តាវាបនកម្ម ។ បណ្តាកម្មទាំង ៤ យ៉ាងនោះ កម្មទោះជាកុសលក្តី ជាអកុសលក្តី បណ្តាកម្មធ្ងន់ និង កម្មស្រាល កម្មណាដែលជាកម្មធ្ងន់ គឺជាកម្មមានការសម្លាប់មាតាជាដើម ឬ ជាមហគ្គតកម្ម កម្មដែលធ្ងន់ (គរុកម្ម) នោះឯង តែងឲ្យផលមុនគេ ។ សូម្បីក្នុងកម្មដែលច្រើន និង កម្មដែលតិចតួច កម្មណា ច្រើន(ក្រាស់ក្រែល) ដូចជាភាពជាអ្នកមានសីលល្អក្តី ភាពជាអ្នកទ្រុស្តសីលក្តី កម្ម ដែលក្រាស់ក្រែលនោះឯង រមែងឲ្យផលមុនគេ ។

កម្មដែលបុគ្គលនឹករលឹកឃើញ ក្នុងពេលជិតនឹងស្លាប់ ឈ្មោះថា អាសន្នកម្ម ។ ក៏បុគ្គលដែលជិតនឹងស្លាប់ អាចរលឹកបានទូវកម្មណា, បុគ្គលនោះ រមែងកើតឡើង ដោយកម្មនោះឯង ។

ចំណែកកម្មដែលបានអាសេវនៈ (ការសេព)ជារឿយៗ ក្រៅពីកម្ម



ទាំង ៣ យ៉ាងនេះ ឈ្មោះថា កដត្តាវាបនកម្ម ។ កាលបើមិនមានកម្មទាំង ៣ យ៉ាងនោះទេ កដត្តាវាបនកម្មនោះ នឹងទាញទៅកាន់បដិសន្ធិ ។

(កម្ម ឲ្យផលតាមកិច្ច ៤ យ៉ាង)

កម្ម ៤ យ៉ាង ក្រៅពីនេះទៀត គឺ ជនកកម្ម, ឧបត្ថម្ភកកម្ម, ឧប-បីឡកកម្ម, ឧបឃាតកកម្ម ។ បណ្តាកម្មទាំង ៤ យ៉ាងនោះ កម្មដែលឈ្មោះថា ជនកកម្ម ជាកុសលផង ជាអកុសលផង ។ ជនកកម្មនោះរមែងញ៉ាំងវិបាកក្ខន្ធ ដែលជាកាមាវចរ, រូបាវចរ និង អរូបាវចរ ឲ្យកើតឡើង ទាំងក្នុងបដិសន្ធិកាលទាំងក្នុងប្រវត្តិកាល។ ចំណែកឧបត្ថម្ភកកម្មមិនអាចញ៉ាំងវិបាក ឲ្យកើតឡើងបានទេ, កាលបើបដិសន្ធិ គឺកម្មដទៃទៀត ឲ្យហើយ, រមែងជួយឧបត្ថម្ភទូវសុខ ឬ ទុក្ខ ដែលកើតឡើងក្នុងវិបាក ដែលកម្មដទៃទៀតឲ្យកើតឡើងហើយ ញ៉ាំង (សុខ និង ទុក្ខនោះ) ឲ្យប្រព្រឹត្តទៅ អស់កាលដ៏យូរ ។ ឧបបីឡកកម្ម កាលបើបដិសន្ធិ ត្រូវកម្មដទៃទៀតឲ្យហើយ រមែងបៀតបៀនទូវសុខ ឬ ទុក្ខ ដែលកើតឡើង ក្នុងវិបាក ដែលកម្មដទៃ ឲ្យកើតឡើងហើយ រមែងមិនឲ្យ (សុខ ឬ ទុក្ខនោះ) ប្រព្រឹត្តទៅអស់កាលយូរ ។ ចំណែកឧបឃាតកកម្មខ្លួនឯង ជាកុសលក្តី ជាអកុសលក្តី រមែងសម្លាប់កម្មដទៃទៀត ដែលមានកម្លាំងទន់ខ្សោយ ហើយហាមឃាត់ទូវវិបាក នៃកម្មដទៃទៀតនោះស្រេចហើយ ក៏បើកឱកាសឲ្យដល់វិបាករបស់ខ្លួន ។ ក៏កាលបើកម្មបើកឱកាសឲ្យយ៉ាងដូច្នោះហើយ វិបាកនោះ បានឈ្មោះថា កើតឡើងហើយ។

(៤១៥) ការផ្សេងគ្នានៃកម្ម និង ការផ្សេងគ្នានៃវិបាកនៃកម្មទាំង ១២ យ៉ាង ដូចពណ៌នាមកនេះ រមែងប្រាកដ តាមសភាវៈពិតប្រាកដចំពោះកម្មវិបាកញាណ នៃព្រះពុទ្ធទាំងឡាយ តែប៉ុណ្ណោះ មិនទូទៅដល់

សាវកទាំងឡាយទេ ។ មួយទៀត បុគ្គលអ្នកបំពេញវិបស្សនា គប្បីយល់ដឹងការផ្សេងគ្នានៃវិបាក(ត្រឹមតែ) ដោយឯកទេស ។ ព្រោះហេតុនោះ ការប្លែកផ្សេងពីគ្នានៃកម្មនេះ គឺលោកសំដែងហើយ ដោយការសំដែងកម្ម ត្រឹមតែប្រមុខ ដោយប្រការដូច្នោះ ។

ភិក្ខុមួយរូប ធ្វើការកំណត់បច្ច័យនៃនាមរូប ដោយអំណាច នៃកម្មវដ្ត និង វិបាកវដ្ត យ៉ាងដូច្នេះ ព្រោះបូកបញ្ចូលកម្មទាំង ១២ យ៉ាងនេះ ទៅក្នុងកម្មវដ្ត ដោយប្រការដូច្នេះឯង ។ ភិក្ខុនោះ ឃើញនូវការប្រព្រឹត្តិទៅនៃនាមរូប តាមបច្ច័យ ដោយអំណាចនៃកម្មវដ្ត និង វិបាកវដ្ត ដូចពោលមកហើយ រមែងពិចារណាឃើញជាក់ច្បាស់ថា "នាមរូបនេះប្រព្រឹត្តទៅ តាមបច្ច័យ ដោយអំណាចនៃកម្មវដ្ត និង វិបាកវដ្ត ក្នុងកាលឥឡូវនេះ យ៉ាងណា, សូម្បីក្នុងកាលដែលកន្លងទៅហើយ ក៏បានប្រព្រឹត្តទៅហើយ តាមបច្ច័យ ដោយអំណាចនៃកម្មវដ្ត និង វិបាកវដ្ត, ក្នុងអនាគតកាលទៀតសោត ក៏នឹងប្រព្រឹត្តទៅ តាមបច្ច័យ ដោយអំណាចនៃកម្មវដ្ត និង វិបាកវដ្ត ក៏យ៉ាងនោះដែរ, កម្ម និង វិបាក នៃកម្មក្តី កម្មវដ្ត និង វិបាកវដ្តក្តី ការប្រព្រឹត្តិទៅនៃកម្ម និង ការប្រព្រឹត្តិទៅនៃវិបាក, កម្មសន្តតិ(តំណនៃកម្ម) និង វិបាកសន្តតិ (តំណនៃវិបាក) ក្តី កិរិយា និង ផលនៃកិរិយាក្តី រមែងប្រព្រឹត្តទៅ ដោយន័យដូច្នេះ

វិបាកទាំងឡាយ រមែងប្រព្រឹត្តទៅ ព្រោះកម្ម,
វិបាក មានកម្មជាដែនកើត, ភពថ្មី កើតមាន
ព្រោះកម្ម លោករមែងប្រព្រឹត្តទៅយ៉ាដូច្នោះឯង ។

កាលបើភិក្ខុនោះ ពិចារណាឃើញច្បាស់ យ៉ាងនេះហើយ សេចក្តី



សង្ស័យនោះ ឯណា ដែលប្រារព្ធ នូវចំណែកខាងដើមជាអាទិ៍ ដែលលោកពោលហើយ ដោយន័យថា : អាត្មាអញបានកើតមកហើយឬហ្ន៎? ដូច្នេះជាដើម, សេចក្តីសង្ស័យទាំងអស់នោះ គឺភិក្ខុនោះ លះបង់បាន ។ ប្រាកដត្រឹមតែនាមរូប ដែលប្រព្រឹត្តទៅ ក្នុងភព, កំណើត, គតិ, ឋិតិ និង និវាសៈទាំងពួង ដោយអំណាច នៃការជាប់ពាក់ព័ន្ធគ្នា នៃហេតុ និង ផលហ្នឹងឯង ។ ភិក្ខុនោះ មិនឃើញ នូវបុគ្គលអ្នកសាង ក្រៅអំពីហេតុទេ មិនឃើញអ្នកសោយផល (ទទួលផល) ក្រៅអំពីការប្រព្រឹត្តិទៅនៃវិបាកឡើយ ទើបឈ្មោះថា ភិក្ខុនោះ ឃើញច្បាស់ ដោយបញ្ញាដ៏ប្រពៃ ថា : កាលបើមានហេតុ បណ្ឌិតទាំងឡាយ តែងពោល ដោយត្រឹមតែពាក្យសមញ្ញា ថា "អ្នកសាង" ដូច្នេះ, កាលបើការប្រព្រឹត្តិទៅនៃវិបាក មាន, បណ្ឌិតទាំងឡាយ តែងពោល ដោយត្រឹមតែពាក្យសមញ្ញា ថា "អ្នកទទួលផល" ដូច្នេះប៉ុណ្ណោះឯង ។

ព្រោះហេតុនោះ ទើបបុរាណាចារ្យទាំងឡាយ ពោលថា :

អ្នកសាងកម្ម មិនមាន និង អ្នកទទួលផល ក៏
មិនមាន, ធម៌សុទ្ធសាធ រមែងប្រព្រឹត្តទៅ, ការ
ឃើញ យ៉ាងនោះនុ៎ះ គឺជាការឃើញប្រពៃ,
កាលបើកម្ម និង វិបាកព្រមទាំងហេតុ ប្រព្រឹត្ត
ទៅ យ៉ាងដូច្នេះ, ខាងដើម ខាងចុង បុគ្គលណា
មួយ ក៏មិនដឹង ដូចជាខាងដើម ខាងចុង នៃពូជ
និង ដើមឈើជាដើម ដែលពុំមានអ្នកដឹងថា ពូជ
កើតមុនដើម ឬក៏ ដើមកើតមុនពូជដូច្នោះ, សូម្បី
ក្នុងអនាគតកាល កាលបើសំសារ មាន ការមិន

ប្រព្រឹត្តិទៅ (នៃកម្ម និង វិបាក) ក៏បុគ្គល មើលមិនឃើញដែរ,

ពួកតិរ្ថិយ មិនដឹងនូវសេចក្តីនេះ ទើបមិនមានអំណាចក្នុងខ្លួន ប្រកាន់យកអត្តសញ្ញា គឺប្រកាន់ថា មានសត្វ, បុគ្គល, តួខ្លួន ហើយជាអ្នកយល់ឃើញថា ទៀងទាត់ ថា សូន្យទទេ ប្រកាន់យកទិដ្ឋិ ៦២ ខ្វែងគំនិតគ្នាទៅវិញទៅមក, ពួកតិរ្ថិយទាំងនោះ ត្រូវគ្រឿងចង គឺទិដ្ឋិ ចងជាប់ហើយអណ្តែតត្រសែតទៅ តាមខ្សែទឹក គឺតណ្ហា, ទើបមិនបានរួចផុត អំពីសេចក្តីទុក្ខ,

ភិក្ខុជាសាវ័កនៃព្រះពុទ្ធ ដឹងច្បាស់ ដោយប្រពៃនូវសេចក្តីនេះ ដូចបានពោលមកហើយ រមែងចាក់ធ្លុះ នូវបច្ច័យ (នៃនាមរូប) ដែលជ្រាលជ្រៅ ល្អិត (និង) ទទេបាន,

កម្ម មិនមាន ក្នុងវិបាក វិបាកមិនមាន ក្នុងកម្ម ទាំងពីរយ៉ាង (កម្ម និង វិបាក) សូន្យទទេពីគ្នានឹងគ្នា, តែថា ប្រាសចាកកម្មហើយ ផល ក៏មិនមាន ប្រៀបដូចជាភ្លើង មិនមាន ក្នុងព្រះអាទិត្យ មិនមានក្នុងកែវមណី មិនមាន ក្នុងគោម័យ (អាចម៍គោស្ងួតសំរាប់បង្កាត់ភ្លើង) ក្រៅអំពីវត្ថុទាំង ៣ យ៉ាងនោះ ភ្លើងនោះ ក៏មិនមាន តែភ្លើងនោះកើតឡើងព្រោះវត្ថុទាំង ៣ យ៉ាងនោះ រួមចូលជាមួយ



គ្នា យ៉ាងណា, វិបាក រកមិនបាន ខាងក្នុងនៃកម្ម សូម្បីខាងក្រៅនៃកម្ម ក៏រកមិនបាន, កម្មសោត ក៏មិនមានក្នុងវិបាកនោះ, កម្មនោះ សូន្យទទេពីផល ផល ក៏មិនមានក្នុងកម្ម, តែថា ផលអាស្រ័យកម្មនោះឯង ទើបកើតឡើង ក៏យ៉ាងនោះដែរ,

មែនពិត ក្នុងការប្រព្រឹត្តិទៅ នៃសំសារនោះ អ្នកសាងសំសារ ទោះជាទេវតា ឬ ព្រហ្ម មិនមានទេ, ធម៌សុទ្ធសាធ តែងប្រព្រឹត្តទៅ ព្រោះការរួមគ្នា នៃហេតុជាបច្ច័យ ដោយប្រការដូច្នេះ ។

*(៤១៦) កាលបើភិក្ខុនោះ ធ្វើការកំណត់បច្ច័យនៃនាមរូប ដោយអំណាចនៃកម្មវដ្ត និង វិបាកវដ្ត រហូតដល់លះបង់នូវសេចក្តីសង្ស័យក្នុងកាលទាំង ៣ បាន យ៉ាងនេះហើយ, ធម៌ទាំងឡាយ ដែលជាអតីតៈ អនាគត និង បច្ចុប្បន្នទាំងពួង ក៏ជាធម៌ គឺភិក្ខុនោះ បានដឹងហើយ ដោយអំណាចនៃចុតិ និង បដិសន្ធិ ។ ការដឹង របស់ភិក្ខុនោះ គឺជាញាតបរិញ្ញា (ធម្មជាតិ គឺបុគ្គលគប្បីកំណត់ដឹងដែលខ្លួនដឹងហើយ) ។*

*ភិក្ខុនោះ ដឹងយ៉ាងនេះថា "ខន្ធទាំងឡាយណា មានកម្មជាបច្ច័យ កើតឡើងហើយ ក្នុងអតីតកាល, ខន្ធទាំងឡាយនោះ ក៏រលត់ហើយ ក្នុងអតីតកាលនោះឯង, ចំណែកខន្ធទាំងឡាយដទៃទៀត មានកម្មដែលជាអតីត ជាបច្ច័យ កើតឡើងហើយ ក្នុងភពនេះ, សូម្បីធម៌មួយ ដែលមកកាន់ភពនេះ ចាកអតីតភព ក៏មិនមាន, សូម្បីខន្ធទាំងឡាយ ដែលកើតឡើង ព្រោះកម្មជាបច្ច័យ ក្នុងភពនេះសោត ក៏នឹងរលត់, ខន្ធទាំង*

ឡាយផ្សេងទៀត នឹងកើតឡើងក្នុងភពថ្មី, សូម្បីធម៌មួយក៏មិនទៅកាន់ភពថ្មីចាកពីភពនេះបានទេ តែថាប្រៀបដូចជាការស្វាធ្យាយអំពីមាត់ នៃអាចារ្យរមែងមិនចូលទៅកាន់មាត់នៃអន្តេវាសិកបានទេ, ឯការស្វាធ្យាយក្នុងមាត់នៃអន្តេវាសិក នឹងប្រព្រឹត្តទៅមិនបាន ព្រោះការស្វាធ្យាយ អំពីមាត់នៃអាចារ្យនោះជាបច្ច័យ ក៏មិនមែនទេ យ៉ាងណាមិញ, ទឹកមន្តដែលបុគ្គលអ្នកផឹកជំនួស (ឲ្យអ្នកមានជំងឺ) រមែងមិនចូលទៅដល់ពោះនៃអ្នកជំងឺបានទេ, ឯរោគនៃអ្នកជំងឺនោះ នឹងមិនជាសះស្បើយ ព្រោះការផឹកទឹកមន្តនៃអ្នកផឹកជំនួសនោះជាបច្ច័យ ក៏មិនមែនទេ យ៉ាងណាមិញ, វិធីស្អិតស្អាងលើមុខ រមែងមិនទៅដល់និមិត្តនៃមុខ ក្នុងគ្រឿងតាក់តែងមុខទាំងឡាយមានផ្ទៃនៃកញ្ចក់ជាដើមបានទេ ឯវិធីតាក់តែង នឹងប្រាកដ ក្នុងគ្រឿងឆ្លុះមុខទាំងឡាយនោះ ព្រោះវិធីតាក់តែងនោះជាបច្ច័យ ក៏មិនមែនទេ យ៉ាងណាមិញ, អណ្តាតប្រទីបនៃប្រទេះ (ចង្កៀង) មួយ រមែងមិនឆ្លងទៅកាន់ប្រទេះចង្កៀងមួយទៀតបានទេ ឯពន្លឺប្រទីប នឹងមិនកើត ក្នុងប្រទេះចង្កៀងដទៃទៀតនោះ ព្រោះអណ្តាតប្រទីប នៃប្រទេះចង្កៀងមួយនោះជាបច្ច័យ ក៏មិនមែនទេ យ៉ាងណាមិញ, ធម៌ឯណានីមួយ រមែងមិនឆ្លងមកកាន់ភពនេះចាកអតីតភព ឬ មិនឆ្លងទៅកាន់ភពថ្មីទៀត ចាកភពនេះបានទេ តែថា ខន្ធ, អាយតនៈ និង ធាតុ នឹងមិនកើត ក្នុងភពនេះ ព្រោះខន្ធ, អាយតនៈ និង ធាតុ ក្នុងអតីតភព ជាបច្ច័យ ឬ ខន្ធ, អាយតនៈ និង ធាតុ ក្នុងភពថ្មី នឹងមិនកើតឡើង ព្រោះខន្ធ, អាយតនៈ និង ធាតុ ក្នុងភពនេះជាបច្ច័យ ក៏មិនមែនទេ យ៉ាងដូច្នោះដែរ" ដូច្នេះ ។

(គាថាសរុបចុតិបដិសន្ធិចិត្ត)

ចក្ខុវិញ្ញាណ មានក្នុងលំដាប់នៃមនោធាតុ តែចក្ខុវិញ្ញាណ



នោះ មិនបានមកអំពីមនោធាតុ ទាំងចក្ខុវិញ្ញាណ
នោះ មិនកើត ក្នុងលំដាប់នៃមនោធាតុ ក៏មិនមែន
យ៉ាងណាក្តី, សន្តតិនៃចិត្ត រមែងប្រព្រឹត្តទៅ ក្នុង
បដិសន្ធិ ក៏យ៉ាងនោះដែរ, ចិត្តមុនបែករលត់ ចិត្ត
ក្រោយ ក៏កើត បន្ទាប់អំពីនោះ ធម្មជាត ដែល
រារាំងចិត្តទាំងពីរយ៉ាងនោះ (ចុតិចិត្ត និង បដិសន្ធិ
ចិត្ត) មិនមានរលកបក់បោក មិនមានដល់ចិត្តទាំង
ពីរយ៉ាងនោះ ចិត្តណាមួយ មិនបានទៅអំពីចុតិចិត្ត
នេះទេ តែបដិសន្ធិចិត្ត រមែងកើត ។

(៤១៧) ញាណ ដែលកំណត់យកបច្ច័យ នៃនាមរូប របស់ភិក្ខុអ្នកដឹងធម៌ទាំងពួង ដោយអំណាចចុតិ និង បដិសន្ធិ យ៉ាងនេះ ជាញាណដែលដល់នូវភាពមានកម្លាំង ដោយអាការៈទាំងពួង ។ សេចក្តីសង្ស័យ ១៦ យ៉ាង គឺភិក្ខុនោះលះបង់បានយ៉ាងល្អប្រសើរ។ មិនមែនតែសេចក្តីសង្ស័យ ១៦ យ៉ាងប៉ុណ្ណោះទេ សូម្បីសេចក្តីសង្ស័យ ៨ យ៉ាង ដែលប្រព្រឹត្តទៅដោយន័យថា "ភិក្ខុតែងសង្ស័យ ក្នុងព្រះសាស្តា" ដូច្នេះជាដើម គឺភិក្ខុនោះ លះបង់បានដូចគ្នាដែរ ។ ទិដ្ឋិ ៦២ រមែងស្ងប់រម្ងាប់ ។

ញាណ ដែលកន្លងនូវសេចក្តីសង្ស័យ ក្នុងកាលទាំង៣ ដោយការកំណត់បច្ច័យ នៃនាមរូប ដោយន័យផ្សេងៗ ដូចពោលមកហើយ ឋិតនៅ បណ្ឌិតគប្បីជ្រាបថា "កង្ខាវិតរណវិសុទ្ធិ" ។ ពាក្យថា "ធម្មដ្ឋិតិញ្ញាណ" ក្តី ពាក្យថា "យថាភូតញ្ញាណ" ក្តី ពាក្យថា "សម្មាទស្សនៈ" ក្តី គឺ ជាពាក្យវេវចនៈ នៃពាក្យថា "កង្ខាវិតរណវិសុទ្ធិ" ហ្នឹងឯង ។

មែនពិត ពាក្យនេះ ព្រះសារីបុត្តត្ថេរ ពោលហើយថា "អវិជ្ជា ជាបច្ច័យ, សង្ខារទាំងឡាយ (កើតឡើងព្រមព្រោះបច្ច័យ), ធម៌ទាំងពីរយ៉ាងនោះ សុទ្ធតែកើតឡើងព្រោះបច្ច័យ, បញ្ញា ក្នុងការកំណត់បច្ច័យដោយន័យដូច្នេះជាដើម ឈ្មោះថា ធម្មដ្ឋិតិញ្ញាណ [១] ដូច្នេះ, ។

សួរថា "ភិក្ខុកាលធ្វើទុកក្នុងចិត្ត ដោយភាពមិនទៀងទាត់ រមែងដឹង រមែងឃើញ តាមពិត នូវធម៌ទាំងឡាយ [២] តើយ៉ាងដូចម្តេច? សម្មាទស្សនៈ ការឃើញប្រពៃ តើយ៉ាងដូចម្តេច? សង្ខារទាំងឡាយទាំងពួង ជាសភាវៈ គឺភិក្ខុនោះ ឃើញប្រពៃហើយ ដោយភាពមិនទៀងទាត់ ព្រោះអាស្រ័យការដឹង ការឃើញប្រពៃនោះ តើយ៉ាងដូចម្តេច? សេចក្តីសង្ស័យ គឺភិក្ខុនោះ លះបង់បានក្នុងធម៌ ដូចម្តេច? ភិក្ខុកាលធ្វើទុកក្នុងចិត្ត ដោយសភាពជាទុក្ខ ដោយសភាពជាអនត្តា រមែងដឹងរមែងឃើញតាមពិត នូវធម៌ទាំងឡាយ តើដូចម្តេច? ។ល។ សេចក្តីសង្ស័យ គឺភិក្ខុនោះ លះបង់បាន ក្នុងធម៌ តើយ៉ាងដូចម្តេច? " ។

ឆ្លើយថា "ភិក្ខុជាយោគាវចរ កាលធ្វើទុកក្នុងចិត្ត ថា មិនទៀង រមែងដឹង ឃើញ តាមពិត នូវនិមិត្ត ព្រោះតែហេតុនោះ ទើបលោកហៅថា ការឃើញប្រពៃ, កាលបើយ៉ាងនេះ សង្ខារទាំងពួង ឈ្មោះថា ភិក្ខុជាយោគាវចរ ឃើញប្រពៃហើយថា មិនទៀង ព្រោះអាស្រ័យការឃើញប្រពៃនោះ ទាំងសេចក្តីងឿងឆ្ងល់ ក្នុងសង្ខារទាំងនុ៎ះ ក៏ភិក្ខុជាយោគាវចរនោះ លះបង់បាន, ភិក្ខុជាយោគាវចរ កាលធ្វើទុកក្នុងចិត្ត ថា ជាទុក្ខ រមែងដឹង ឃើញ តាមពិត នូវការប្រព្រឹត្តិទៅ ព្រោះតែហេតុនោះ ទើបលោកហៅថា ការឃើញប្រពៃ, កាលបើយ៉ាងនេះ សង្ខារ

១- សុ. ខុ. បដិ. ភាគទី ៦៩ ទំព័រ ១១៨ ។ ២- ភាគទី ៧០ ទំព័រ ៣៥៦ ។



ទាំងពួង ឈ្មោះថា ភិក្ខុ ជាយោគាវចរ ឃើញប្រពៃហើយ ថា ជាទុក្ខ ព្រោះអាស្រ័យ នូវការឃើញប្រពៃនោះ ទាំងសេចក្តីងឿងឆ្ងល់ ក្នុងសង្ខារទាំងនុ៎ះ ក៏លះបង់បាន, ភិក្ខុជាយោគាវចរ កាលធ្វើទុកក្នុងចិត្ត ថា មិនមែនខ្លួន រមែងដឹង ឃើញតាមពិត នូវនិមិត្តផង នូវការប្រព្រឹត្តិទៅផង ព្រោះតែហេតុនោះ ទើបលោកហៅថា ការឃើញប្រពៃ, កាលបើយ៉ាងនេះ ធម៌ទាំងពួង ឈ្មោះថា ភិក្ខុ ជាយោគាវចរ ឃើញប្រពៃហើយថា មិនមែនខ្លួន ព្រោះអាស្រ័យការឃើញប្រពៃនោះ ទាំងសេចក្តីងឿងឆ្ងល់ ក្នុងធម៌ទាំងនុ៎ះ ក៏ភិក្ខុ ជាយោគាវចរនោះ លះបង់បាន" ។

សួរថា "ការដឹងតាមពិតណាក្តី, ការឃើញប្រពៃណាក្តី, ការឆ្លងចាកសេចក្តីងឿងឆ្ងល់ណាក្តី, ធម៌ទាំងនេះ មានសេចក្តីផ្សេងគ្នាផង មានព្យញ្ជនៈផ្សេងគ្នាផង ឬក៏ មានសេចក្តីជាមួយគ្នា តែមានព្យញ្ជនៈផ្សេងពីគ្នា?" ។

ឆ្លើយថា "ការដឹងតាមពិតណាក្តី, ការឃើញប្រពៃណាក្តី, ការឆ្លងចាកសេចក្តីងឿងឆ្ងល់ណាក្តី, ធម៌ទាំងនេះ មានសេចក្តីដូចគ្នា តែមានព្យញ្ជនៈផ្សេងពីគ្នា" ដូច្នេះ ។

ក៏ភិក្ខុ អ្នកបំពេញវិបស្សនា ប្រកបព្រមដោយញាណនេះហើយ ជាអ្នកបានសេចក្តីត្រេកអរីករាយ ពេញចិត្ត ជាអ្នកបានទីពឹង ក្នុងព្រះពុទ្ធសាសនា មានគតិ ពិតប្រាកដ ជាអ្នកឈ្មោះថា ចូឡសោតាបន្ន ។

ព្រោះហេតុនោះ ភិក្ខុអ្នកត្រូវការចង់បានកង្ខា-
វិតរណវិសុទ្ធិ គប្បីជាអ្នកមានសតិ កំណត់
យកបច្ច័យ នៃនាមរូប ដោយប្រការទាំងពួង
សព្វកាល ដូច្នេះឯង ។

*បរិច្ឆេទ ទី១៩ ឈ្មោះ កង្ខាវិតរណវិសុទ្ធិ*
*ក្នុងអធិការ នៃបញ្ញាភាវនា ក្នុងគម្ពីរវិសុទ្ធិមគ្គ*
*ដែលខ្ញុំរៀបរៀងហើយ ដើម្បីប្រយោជន៍ដល់កិរិយាញុំាង*
*សាធុជនឲ្យរីករាយ*
*ចប់ហើយ ដោយប្រការដូច្នេះឯង ។*



## មគ្គាមគ្គញ្ញាណទស្សនវិសុទ្ធិនិទ្ទេស

*(៤១៨) ចំណែក ញាណ ដែលដឹងនូវធម៌ដែលមិនមែនជាផ្លូវ ថា "នេះ ជាផ្លូវ នេះ មិនមែនជាផ្លូវ" ដូច្នេះហើយ តាំងនៅ ឈ្មោះថា* **មគ្គាមគ្គញ្ញាណទស្សនវិសុទ្ធិ** *។*

*ភិក្ខុ ជាយោគាវចរ អ្នកប្រាថ្នានឹងបំពេញមគ្គាមគ្គញ្ញាណទស្សន-វិសុទ្ធិនោះ ត្រូវធ្វើសេចក្ដីព្យាយាម ក្នុងវិបស្សនា (ការចំរើនវិបស្សនាតាមន័យបាលី) ដែលហៅថា ការពិចារណាជាកលាប ជាមុន ។ ព្រោះហេតុអ្វី? ។ ព្រោះសំរាប់ព្រះយោគាវចរ ដែលប្រារព្ធវិបស្សនាហើយ កាលបើវិបស្សនូបកិលេស មានឱភាសជាដើម កើតមាន ទើបមានមគ្គាមគ្គញ្ញាណទស្សនៈ ។ មែនពិត កាលបើវិបស្សនូបកិលេសទាំងឡាយ មានឱភាសជាដើម កើតមានហើយ មគ្គាមគ្គញ្ញាណ ទើបមានដល់ព្រះយោគាវចរ ដែលប្រារព្ធនូវវិបស្សនាហើយ ។ ក៏ព្រោះការពិចារណា ជាកលាប (កលាបសម្មសនៈ) ជាខាងដើម នៃវិបស្សនា ។ ហេតុនោះ មគ្គាមគ្គញ្ញាណនុ៎ះ ទើបលោកសំដែងហើយ ក្នុងលំដាប់នៃកង្ខាវិតរណញ្ញាណ ។ មួយទៀត កាលបើតីរណបរិញ្ញា ប្រព្រឹត្តទៅ មគ្គាមគ្គញ្ញាណ ទើបកើតឡើង និង តីរណបរិញ្ញាទៀតសោត ក៏កើតមាន ក្នុងលំដាប់នៃញាតបរិញ្ញា ព្រោះហេតុអ្វី? សូម្បីព្រោះហេតុនោះ ព្រះយោគាវចរ អ្នកប្រាថ្នានឹងបំពេញមគ្គាមគ្គញ្ញាណទស្សនវិសុទ្ធិនោះឲ្យបរិបូណ៌ ត្រូវធ្វើសេចក្ដីព្យាយាម ក្នុងកលាបសម្មសនៈ ជាមុន ។*

### (បរិញ្ញា ៣)

*(៤១៩) នេះ ជាវិនិច្ឆ័យ ក្នុងបរិញ្ញាទាំងឡាយនោះ ។ ក៏លោកិយ-បរិញ្ញា មាន ៣ គឺ : ញាតបរិញ្ញា (ធម្មជាតិ គឺបុគ្គលគប្បីកំណត់ដឹង*

ដែលខ្លួនដឹងហើយ) តីរណបរិញ្ញា (ធម្មជាតិ គឺបុគ្គលគប្បីកំណត់ដឹង ដោយអំណាចនៃការលះបង់ ដោយការពិចារណា) និង បហានបរិញ្ញា (ធម្មជាតិ គឺបុគ្គលគប្បីកំណត់ដឹង ដោយអំណាចនៃការលះបង់) ដែលលោកសំដៅយក ពោលហើយថា "អភិញ្ញាបញ្ញា (បញ្ញាដែលជាគុណជាតិ គឺបុគ្គលគប្បីដឹងច្បាស់) ឈ្មោះថា ញាណ ដោយអត្ថថា ដឹង, បរិញ្ញាបញ្ញា (បញ្ញាដែលជាគុណជាតិ គឺបុគ្គលគប្បីកំណត់ដឹង) ឈ្មោះថា ញាណ ដោយអត្ថថា ពិចារណា, បហានបញ្ញា (បញ្ញា ដែលជាគ្រឿងលះបង់) ឈ្មោះថា ញាណ ដោយអត្ថថា លះស្រឡះ" ។

បណ្ដាបរិញ្ញាទាំង ៣ យ៉ាងនោះ បញ្ញា ដែលប្រព្រឹត្តទៅ ដោយអំណាចនៃបច្ចត្តលក្ខណៈ (លក្ខណៈចំពោះខ្លួន) និង សល្លក្ខណៈ (ការកំណត់ព្រម) នៃធម៌ទាំងឡាយនោះៗ ដោយន័យថា: "រូប មានការវិនាសទៅជាលក្ខណៈ វេទនា មានការសោយ(អារម្មណ៍) ជាលក្ខណៈ" ដូច្នេះជាដើម ឈ្មោះថា ញាតបរិញ្ញា ។ ចំណែកខាងបញ្ញា ដែលមានលក្ខណៈ ឃើញច្បាស់ នូវត្រៃលក្ខណ៍ ជាអារម្មណ៍ ដែលប្រព្រឹត្តទៅ ព្រោះលើកឡើងកាន់សាមញ្ញលក្ខណៈ នៃធម៌ទាំងឡាយនោះឯង ដោយន័យថា "រូប មិនទៀង វេទនា មិនទៀង" ដូច្នេះជាដើម ឈ្មោះថា តីរណបរិញ្ញា ។ ចំណែកបញ្ញា ដែលមានលក្ខណៈឃើញច្បាស់នូវត្រៃលក្ខណ៍ ជាអារម្មណ៍ហ្នឹងឯង ដែលប្រព្រឹត្តទៅ ដោយអំណាច នៃការលះបង់នូវវិប្បលាសសញ្ញា មានសេចក្តីសំគាល់ថា ទៀងជាដើម ក្នុងធម៌ទាំងឡាយនោះឯង ឈ្មោះថា បហានបរិញ្ញា ។

(ភូមិរបស់បញ្ញា)

បណ្ដាបរិញ្ញាទាំង ៣ នោះ ភូមិ របស់ញាតបរិញ្ញា ចាប់ផ្ដើមតាំងពីការកំណត់សង្ខារ គឺនាម និង រូប រហូតដល់ការកំណត់កាន់យកបច្ច័យនៃនាម និង រូប ។ ព្រោះថា ក្នុងចន្លោះនេះ ភាពជាធំ តែងមាន ដល់ការចាក់ធ្លុះ នូវបច្ចត្តលក្ខណៈ នៃធម៌ទាំងឡាយ ប៉ុណ្ណោះ ។



ឯភូមិ របស់តីរណបរិញ្ញា ចាប់ផ្ដើមតាំងពីកលាបសម្មសនៈ (ការពិចារណាកលាប) រហូតដល់ការឃើញ នូវការកើតឡើង និង ការរលត់ទៅវិញ ។ ព្រោះក្នុងចន្លោះនេះ ភាពជាធំ កើតមាន ដល់ការចាក់ធ្លុះ នូវសាមញ្ញលក្ខណៈ ប៉ុណ្ណោះឯង ។

ភូមិ របស់បហានបរិញ្ញា ធ្វើនូវការពិចារណាឃើញ នូវការបែកធ្លាយជាអាទិ៍ ឲ្យខ្ពស់ឡើងទៅៗ ។ ព្រោះថា បន្ទាប់អំពីនោះមក ភាពជាធំ កើតមាន ដល់អនុបស្សនា ៧ ដែលញ៉ាំងការលះបង់ នូវបហាតព្វធម៌ មាននិច្ចសញ្ញាជាដើម ឲ្យសំរេច យ៉ាងនេះ គឺ: ព្រះយោគាវចរកាលពិចារណាឃើញ ថា [១] មិនទៀង រមែងលះបង់សេចក្តីសំគាល់ថា ទៀង កាលពិចារណាឃើញថា ជាទុក្ខ រមែងរលះបង់នូវសេចក្តីសំគាល់ថា ជាសុខ កាលពិចារណាឃើញថា មិនមែនជារបស់ខ្លួន រមែងលះបង់ នូវសេចក្តីសំគាល់ថា ជារបស់ខ្លួន កាលនឿយណាយ រមែងលះបង់ នូវសេចក្តីរីករាយ កាលជិនណាយ រមែងលះបង់នូវតម្រេក កាលរំលត់ រមែងលះបង់នូវការកើត កាលលះបង់ចោល រមែងលះបង់នូវការប្រកាន់មាំ" ដូច្នេះ ។

បណ្ដាបរិញ្ញាទាំង ៣ យ៉ាងនេះ ញាតបរិញ្ញាតែម្យ៉ាង គឺព្រះយោគាវចររូបនេះ បានសំរេចហើយ ចំណែកបរិញ្ញាពីរក្រៅពីនេះ ព្រះយោគាវចរនេះ គប្បីសំរេចផងដែរ ព្រោះសង្ខារបរិច្ឆេទ និង បច្ចយបរិគ្គហៈ

១- សុ. ខុ. បដិ. ភាគទី ៧១ ទំព័រទី ៣២២ ។

ធ្វើឲ្យសំរេចបាន ។ ព្រោះហេតុដូច្នោះ ទើបខ្ញុំពោលថា "កាលបើតីរណបរិញ្ញា ប្រព្រឹត្តទៅ, មគ្គាមគ្គញ្ញាណ ទើបកើតឡើង និង តីរណ-បរិញ្ញាសោត ក៏មាន ក្នុងលំដាប់នៃញាតបរិញ្ញា ព្រោះហេតុណា, ព្រោះហេតុនោះឯង ព្រះយោគី អ្នកប្រាថ្នាចង់បំពេញមគ្គាមគ្គញ្ញាណ-ទស្សនវិសុទ្ធិ ឲ្យពេញបរិបូរ គប្បីធ្វើយោគៈ គឺសេចក្ដីព្យាយាម ក្នុងកលាបសម្មសនៈ ជាមុន" ដូច្នេះ ។

(បាលីសម្មសនញ្ញាណ)

(៤២០) ក្នុងសម្មសនៈនោះ មានបាលី ដូចតទៅនេះ គឺ : បញ្ញាក្នុងការកំណត់សង្ខេប នូវធម៌ទាំងឡាយដែលជាអតីត អនាគត និង បច្ចុប្បន្ន ឈ្មោះថា សម្មសនញ្ញាណ តើយ៉ាងដូចម្ដេច? ។

រូបណាមួយ [១] ជាអតីត អនាគត និង បច្ចុប្បន្ន ខាងក្នុងក្ដី ខាងក្រៅក្ដី គ្រោតគ្រាតក្ដី ល្អិតក្ដី ថោកទាបក្ដី ឧត្ដមក្ដី រូបណា ក្នុងទីឆ្ងាយក្ដី ក្នុងទីជិតក្ដី, ភិក្ខុកំណត់នូវរូបនោះ ថា ជារបស់មិនទៀង, ជាការពិចារណាមួយ (សម្មសនៈ), ភិក្ខុកំណត់ថា ជាទុក្ខ ជាសម្មសនៈមួយ ភិក្ខុកំណត់ ថា មិនមែនជារបស់ខ្លួន ជាសម្មសនៈមួយ វេទនាណាមួយ ។ល។ វិញ្ញាណណាមួយ ។ល។ ភិក្ខុកំណត់ថា មិនមែនជារបស់ខ្លួន ជាសម្មសនៈមួយ ភិក្ខុកំណត់ចក្ខុ ។ល។ ជរាមរណៈដែលជាអតីត អនាគត និង បច្ចុប្បន្ន ថា : ជារបស់មិនទៀង ជាសម្មសនៈមួយ ។ល។ កំណត់ថា ជាទុក្ខ ជាសម្មសនៈមួយ កំណត់ថា មិនមែនជារបស់ខ្លួន ជាសម្មសនៈមួយ ។

បញ្ញា ក្នុងការកំណត់ យ៉ាងសង្ខេបថា "រូបដែលជាអតីត អនាគត

១- សុ ខុ. បដិ. ភាគទី ៧១ ទំព័រទី ២៥៨ ។



និង បច្ចុប្បន្ន ឈ្មោះថា មិនទៀង ដោយអត្ថថា អស់ទៅ ឈ្មោះថា ជាទុក្ខ ដោយអត្ថថា ជាភ័យ ឈ្មោះថា អនត្តា ដោយអត្ថថា គ្មានខ្លឹមសារ" ដូច្នេះ ឈ្មោះថា សម្មសនញ្ញាណ, បញ្ញា ក្នុងការកំណត់ ដោយសង្ខេបថា "វេទនា ។ល។ វិញ្ញាណ ដែលជាអតីត អនាគត និង បច្ចុប្បន្ន ជារបស់មិនទៀង ។ល។" ដូច្នេះ ឈ្មោះថា សម្មសនញ្ញាណ, បញ្ញា ក្នុងការកំណត់ យ៉ាងសង្ខេបថា "ចក្ខុ ។ល។ ជរាមរណៈដែលជាអតីត អនាគត និង បច្ចុប្បន្ន ជារបស់មិនទៀង ។ល។" ដូច្នេះ ឈ្មោះថា សម្មសនញ្ញាណ, បញ្ញា ក្នុងការកំណត់យ៉ាងសង្ខេបថា "រូបដែលជាអតីត អនាគត និង បច្ចុប្បន្ន ជារបស់មិនទៀង មានបច្ច័យតាក់តែង អាស្រ័យនូវបច្ច័យហើយ កើតឡើង មានការអស់ទៅ ជាធម្មតា មានការវិនាសទៅជាធម្មតា មានការប្រាសចាករាគៈជាធម្មតា មានការរលត់ជាធម្មតា" ដូច្នេះ ឈ្មោះថា សម្មសនញ្ញាណ, បញ្ញា ក្នុងការកំណត់ ដោយសង្ខេបថា "វេទនា ។ល។ វិញ្ញាណ ដែលជាអតីត អនាគត និង បច្ចុប្បន្ន ជារបស់មិនទៀង ។ល។ មានការរលត់ទៅ ជាធម្មតា" ដូច្នេះ ឈ្មោះថា សម្មសនញ្ញាណ, បញ្ញា ក្នុងការកំណត់ដោយសង្ខេបថា "ចក្ខុ ។ល។ ជរាមរណៈ ដែលជាអតីត អនាគត និង បច្ចុប្បន្ន ជារបស់មិនទៀង ។ល។ មានការរលត់ទៅជាធម្មតា" ដូច្នេះ ឈ្មោះថា សម្មសនញ្ញាណ, បញ្ញា ក្នុងការកំណត់ ដោយសង្ខេបថា "ជរា មរណៈ មាន ព្រោះជាតិជាបច្ច័យ កាលបើជាតិ មិនមាន ជរា មរណៈ ក៏មិនមាន" ដូច្នេះ ឈ្មោះថា សម្មសនញ្ញាណ, បញ្ញា ក្នុងការកំណត់ ដោយសង្ខេបថា "ទាំងក្នុងអតីត ទាំងក្នុងអនាគត ជរាមរណៈមាន ព្រោះជាតិជាបច្ច័យ កាលបើជាតិ មិនមាន ជរាមរណៈ ក៏មិនមាន"

ដូច្នេះ ឈ្មោះថា សម្មសនញ្ញាណ, បញ្ញា ក្នុងការកំណត់ដោយសង្ខេបថា "ជាតិ មាន ព្រោះភពជាបច្ច័យ ។ល។ សង្ខារទាំងឡាយ មាន ព្រោះអវិជ្ជាជាបច្ច័យ កាលបើមិនមានអវិជ្ជា សង្ខារទាំងឡាយ ក៏មិនមាន" ដូច្នេះ ឈ្មោះថា សម្មសនញ្ញាណ, បញ្ញា ក្នុងការកំណត់ ដោយសង្ខេបថា "ទាំងក្នុងអតីត ទាំងក្នុងអនាគត សង្ខារទាំងឡាយ មាន ព្រោះអវិជ្ជាជាបច្ច័យ កាលបើមិនមានអវិជ្ជា សង្ខារទាំងឡាយ ក៏មិនមាន" ដូច្នេះ ឈ្មោះថា សម្មសនញ្ញាណ, ការដឹងនោះ ឈ្មោះថា ញាណ ដោយអត្ថថា ដឹង ឈ្មោះថា បញ្ញា ដោយអត្ថថា ដឹងច្បាស់, ព្រោះហេតុនោះ ទើបខ្ញុំពោលថា "បញ្ញា ក្នុងការកំណត់ យ៉ាងសង្ខេប នូវធម៌ទាំងឡាយ ដែលជាអតីត អនាគត និង បច្ចុប្បន្ន ឈ្មោះថា សម្មសនញ្ញាណ" ដូច្នេះ ។

ក៏ក្នុងបាលីសម្មសនញ្ញាណនេះ ប្រជុំនៃធម៌ទាំងនេះ គឺ : ធម៌ទាំងឡាយ ដែលប្រព្រឹត្តទៅ ព្រមទាំងទ្វារ និង អារម្មណ៍ទាំងឡាយ, ខន្ធ ៥, ទ្វារ ៦, អារម្មណ៍ ៦, និង វិញ្ញាណ៦, ផស្សៈ ៦, វេទនា ៦, សញ្ញា ៦, ចេតនា ៦, តណ្ហា៦, វិតក្កៈ៦, វិចារៈ៦, ធាតុ៦, កសិណ១០, កោដ្ឋាសគឺអាការៈ ៣២, អាយតនៈ១២, ធាតុ១៨, ឥន្ទ្រិយ ២២, ធាតុ ៣, ភព ៣, ភព៣ ផ្សេងទៀត, ភពក្រៅអំពីនេះ ៣ ទៀត, ឈាន ៤, អប្បមញ្ញា ៤, សមាបត្តិ ៤, អង្គនៃបដិច្ចសមុប្បាទ ១២ បណ្ឌិត គប្បីជ្រាបថា លោកសង្ខេបហើយដោយបេយ្យាលនេះថា ចក្ខុ ។ល។ ជរាមរណៈ" ដូច្នេះ ។

(អភិញ្ញេយ្យនិទ្ទេស)

មែនពិត រឿងនេះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហើយ ក្នុងអភិញ្ញេយ្យនិទ្ទេសថា "ម្នាលភិក្ខុទាំងឡាយ អាយតនៈទាំងអស់ បុគ្គល



ត្រូវដឹងច្បាស់ ម្នាលភិក្ខុទាំងឡាយ អាយតនៈទាំងអស់ បុគ្គលត្រូវដឹងច្បាស់ តើដូចម្ដេច? ម្នាលភិក្ខុទាំងឡាយ [១] ចក្ខុបុគ្គលត្រូវដឹងច្បាស់ រូបបុគ្គលត្រូវដឹងច្បាស់ ចក្ខុវិញ្ញាណ បុគ្គលត្រូវដឹងច្បាស់ ចក្ខុសម្ផស្ស បុគ្គលត្រូវដឹងច្បាស់ ការទទួលអារម្មណ៍ណាជាសុខក្តី ជាទុក្ខក្តី មិនជាទុក្ខ មិនជាសុខក្តី កើតឡើង ព្រោះចក្ខុសម្ផស្សជាបច្ច័យ ការទទួលនូវអារម្មណ៍ហ្នឹងឯង បុគ្គលត្រូវដឹងច្បាស់ សោតៈ បុគ្គលត្រូវដឹងច្បាស់ ។ល។ ការទទួលអារម្មណ៍ណា ជាសុខក្តី ជាទុក្ខក្តី មិនជាទុក្ខ មិនជាសុខក្តី កើតឡើង ព្រោះមនោសម្ផស្ស ជាបច្ច័យ ការទទួលអារម្មណ៍នោះឯង បុគ្គលត្រូវដឹងច្បាស់ រូប ។ល។ វិញ្ញាណ បុគ្គលត្រូវដឹងច្បាស់ ចក្ខុ ។ល។ មនោ បុគ្គលត្រូវដឹងច្បាស់ រូបទាំងឡាយ ។ល។ ធម៌ទាំងឡាយបុគ្គលត្រូវដឹងច្បាស់ ចក្ខុវិញ្ញាណ ។ល។ មនោវិញ្ញាណ បុគ្គលត្រូវដឹងច្បាស់ ចក្ខុសម្ផស្ស ។ល។ មនោសម្ផស្ស បុគ្គលត្រូវដឹងច្បាស់ វេទនាដែលកើតអំពីចក្ខុសម្ផស្ស ។ល។ វេទនាដែលកើតអំពីមនោសម្ផស្ស បុគ្គលត្រូវដឹងច្បាស់ រូបសញ្ញា ។ល។ ធម្មសញ្ញា បុគ្គលត្រូវដឹងច្បាស់ រូបសញ្ចេតនា ។ល។ ធម្មសញ្ចេតនា បុគ្គលត្រូវដឹងច្បាស់ រូបតណ្ហា ។ល។ ធម្មតណ្ហា បុគ្គលត្រូវដឹងច្បាស់ រូបវិតក្កៈ ។ល។ ធម្មវិតក្កៈ បុគ្គលត្រូវដឹងច្បាស់ រូបវិចារៈ ។ល។ ធម្មវិចារៈ បុគ្គលត្រូវដឹងច្បាស់ បឋវីធាតុ ។ល។ វិញ្ញាណធាតុ បុគ្គលត្រូវដឹងច្បាស់ បឋវីកសិណ ។ល។ វិញ្ញាណកសិណ បុគ្គលត្រូវដឹងច្បាស់ សក់ បុគ្គលត្រូវដឹងច្បាស់ ។ល។ ខួរក្នុងក្បាល បុគ្គលត្រូវដឹងច្បាស់ ចក្ខាយតនៈ ។ល។ ធម្មាយតនៈ បុគ្គលត្រូវ

---

១- សុ. ខុ. បដិ. ភាគទី ៦៩ ទំព័រទី ៩ ។

ដឹងច្បាស់ ចក្ខុធាតុ ។ល។ ចក្ខុវិញ្ញាណធាតុ បុគ្គលត្រូវដឹងច្បាស់ មនោធាតុ ។ល។ មនោវិញ្ញាណធាតុ បុគ្គលត្រូវដឹងច្បាស់ ចក្ខុន្ទ្រិយ៍ ។ល។ អញ្ញាតាវិន្ទ្រិយ៍ បុគ្គលត្រូវដឹងច្បាស់ កាមធាតុ រូបធាតុ អរូបធាតុ បុគ្គលត្រូវដឹងច្បាស់ កាមភព រូបភព អរូបភព បុគ្គលត្រូវដឹងច្បាស់ សញ្ញាភព អសញ្ញាភព នេវសញ្ញានាសញ្ញាភព បុគ្គលត្រូវដឹងច្បាស់ ឯកវោការភព (ភព មានខន្ធមួយ គឺរូបក្ខន្ធ បាន ដល់ អសញ្ញាភព) ចតុវោការភព (ភព មានខន្ធ ៤ គឺរូប វេទនា សញ្ញា សង្ខារ វិញ្ញាណ បានដល់ កាមភព និង រូបភព) បុគ្គលត្រូវដឹងច្បាស់ បឋមជ្ឈាន ។ល។ ចតុត្ថជ្ឈាន បុគ្គលត្រូវដឹងច្បាស់ មេត្តាចេតោវិមុត្តិ ។ល។ ឧបេក្ខាចេតោវិមុត្តិបុគ្គលត្រូវដឹងច្បាស់ អាកាសានញ្ចាយតនសមាបត្តិ ។ល។ នេវសញ្ញានាសញ្ញាយតនសមាបត្តិ បុគ្គលត្រូវដឹងច្បាស់ អវិជ្ជា បុគ្គលត្រូវដឹងច្បាស់ ។ល។ ជរាមរណៈ បុគ្គលត្រូវដឹងច្បាស់" ដូច្នេះ,

របស់ដែលបុគ្គលត្រូវដឹងច្បាស់ទាំងអស់នោះ ឈ្មោះថា គឺលោកបានសង្ខេបហើយ ដោយបេយ្យាលទាំងពួង ក្នុងបាលីសម្មសនញ្ញាណនេះ ព្រោះព្រះមានព្រះភាគ ទ្រង់ត្រាស់សំដែងហើយ យ៉ាងពិស្តារ ក្នុងអភិញ្ញេយ្យនិទ្ទេសនោះ ដូចបានពោលមកហើយនេះឯង ។

តែថា លោកុត្តរធម៌ទាំងឡាយណា មកហើយ ក្នុងអភិញ្ញេយ្យនិទ្ទេសនេះ ដែលលោកសង្ខេបហើយ យ៉ាងដូច្នេះ លោកុត្តរធម៌នោះ បុគ្គលមិនត្រូវប្រកាន់យក ក្នុងអធិការនេះទេ ព្រោះមិនចូលដល់សម្មសនៈ។ សូម្បីធម៌ទាំងឡាយណា ចូលដល់សម្មសនៈ ក្នុងធម៌ទាំងឡាយនោះ ធម៌ទាំងឡាយណា ប្រាកដច្បាស់ ដល់នូវការកំណត់ចាប់



យក ដោយងាយស្រួល ដល់ព្រះយោគី រូបណា, ព្រះយោគី រូបនោះ គប្បីប្រារព្ធផ្តើម (ធ្វើ) សម្មសនៈ គឺការពិចារណា ក្នុងធម៌ទាំងឡាយនោះចុះ ។

(វិធីធ្វើការពិចារណា)

(៤២១) ក្នុងសម្មសនញ្ញាណនោះ មានការប្រារព្ធប្រកបវិធីធ្វើការពិចារណា ដោយអំណាចនៃខន្ធ ដូចតទៅនេះថា "រូបណាមួយ ។ល។ ភិក្ខុកំណត់រូបទាំងអស់នោះ ថា ជារបស់មិនទៀង នេះ ជាសម្មសនៈមួយ ភិក្ខុកំណត់ថា ជាទុក្ខ ជាសម្មសនៈមួយ កំណត់ថា មិនមែនជារបស់ខ្លួន ជាសម្មសនមួយ" ដូច្នេះ ។ ដោយហេតុត្រឹមតែប៉ុណ្ណេះ ភិក្ខុនេះ ឈ្មោះថា កំណត់កាត់រូបទាំងពួង ដែលសំដែងហើយដោយមិនចំពោះ យ៉ាងនេះថា "រូបណាមួយ" ដោយឱកាស ១១ គឺៈ ដោយអតីតត្តិកៈ (ពួក៣ ទាំងអតីត គឺអតីត អនាគត និង បច្ចុប្បន្ន ត្រូវជា៣) និង ដោយទុកៈ ៤ មានអជ្ឈត្តទុកៈ (ពួកពីរ ទាំងរូបខាងក្នុង គឺរូបខាងក្នុង រូបខាងក្រៅ) ជាដើម ហើយកំណត់រូបទាំងពួងថា ជារបស់មិនទៀង គឺពិចារណាថា ជារបស់មិនទៀង ។ ពិចារណាដូចម្តេច? ។ ពិចារណាដោយន័យដែលបានពោលបន្តបន្ទាប់ហ្នឹងឯង ។ ព្រោះលោកបានពោលពាក្យនេះហើយថា "រូបដែលជាអតីត អនាគត និង បច្ចុប្បន្ន ឈ្មោះថា មិនទៀង ដោយអត្ថថា អស់ទៅ" ដូច្នេះ ។ ព្រោះហេតុនោះ ភិក្ខុនោះពិចារណា ថា "រូបឯណា ជាអតីត រូបនោះ ក៏អស់ទៅហើយ ក្នុងអតីតហ្នឹងឯង មិនបានមកដល់ភពនេះទេ ព្រោះហេតុណា ព្រោះហេតុនោះ ទើបឈ្មោះថា មិនទៀង ដោយអត្ថថា អស់ទៅ, រូបណា ជាអនាគត នឹងកើតមាន ក្នុងភពជាបន្តបន្ទាប់ សូម្បីរូបនោះ ក៏នឹងអស់ទៅ

ក្នុងភពនុ៎ះឯង នឹងមិនទៅកាន់ភពថ្មីទៀត ក្រៅតែអំពីភពនោះទេ ព្រោះហេតុនោះ ទើបឈ្មោះថា មិនទៀង ដោយអត្ថថា មិនទៀង, រូបណា ជាបច្ចុប្បន្ន រូបនោះ ក៏អស់ទៅ ក្នុងភពនេះឯង មិនបានទៅក្រៅពីភពនេះទេ ព្រោះហេតុនោះ ទើបឈ្មោះថា មិនទៀង ដោយអត្ថថា អស់ទៅ, រូបណា ជារូបខាងក្នុង រូបនោះឯង ក៏អស់ទៅ ត្រង់ខាងក្នុងហ្នឹងឯង មិនមែនដល់នូវភាពជាខាងក្រៅទេ ព្រោះហេតុនោះ ទើបឈ្មោះថា មិនទៀង ដោយអត្ថថា អស់ទៅ, រូបណា ជារូបខាងក្រៅ ។ល។ រូបណា ជារូបគ្រោតគ្រាត រូបល្អិត រូបថោកទាប រូបថ្លៃថ្លា រូបក្នុងទីឆ្ងាយ រូបក្នុងទីជិត រូបនោះឯង ក៏អស់ទៅ ក្នុងទីជិតហ្នឹងឯង មិនមែនដល់នូវភាពជារូបឆ្ងាយទេ ព្រោះហេតុនោះ ទើបឈ្មោះថា មិនទៀង ដោយអត្ថថា អស់ទៅ" យ៉ាងដូច្នេះ ។ ការពិចារណាទាំងអស់នេះឯង ជាការពិចារណាមួយយ៉ាង ដោយអំណាចនៃបទនេះថា "ឈ្មោះថា មិនទៀង ដោយអត្ថថា អស់ទៅ" ដូច្នេះ, តែដោយការចែកចេញជាប្រភេទ គឺ : ការពិចារណា ១១ យ៉ាង ។

មួយទៀត រូបទាំងអស់ហ្នឹងឯង ឈ្មោះថា ជាទុក្ខ ដោយអត្ថ ថាជាភ័យ ។ ពាក្យថា "ដោយអត្ថថា ជាភ័យ" សេចក្ដីថា ព្រោះប្រព្រឹត្តទៅមួយអន្ទើដោយភ័យពន្ទឹក ។ ព្រោះថា របស់ណា មិនទៀង របស់នោះ រមែងនាំភ័យមកឲ្យ ដូចជាភ័យកើតមានដល់ពួកទេវតាទាំងឡាយ ព្រោះបានស្ដាប់សីហោបមសូត្រ ដូច្នោះឯង ។ សូម្បីការពិចារណា ដូចបានពោលមកនេះ ក៏ជាការពិចារណាមួយយ៉ាង ដោយអំណាច នៃបទនេះថា "ឈ្មោះថា ជាទុក្ខ ដោយអត្ថថា ជាភ័យ" ដូច្នេះ តែបើចែកជាប្រភេទ ក៏ជាការពិចារណា ១១ យ៉ាង ដូចគ្នាដែរ ។



មួយទៀត រូបទាំងអស់នោះ ឈ្មោះថា ជាទុក្ខ យ៉ាងណាមិញ, រូបទាំងអស់នោះ ក៏ឈ្មោះថា ជាអនត្តា ដោយអត្ថថា គ្មានខ្លឹមសារ ។ ពាក្យថា "ដោយអត្ថថា គ្មានខ្លឹមសារ" សេចក្ដីថា ព្រោះមិនមានខ្លឹមសារ គឺអត្តា ដែលពួកអត្តវាទី គិតឃើញ យ៉ាងនេះថា "រូប មានអត្តាជាអ្នកគ្រប់គ្រង ជាអ្នកសាង ជាអ្នកសោយ ជាអ្នកមានអំណាច ក្នុងខ្លួន" ដូច្នេះ ។ ព្រោះថា រូបណាមិនទៀង រូបនោះ ជាទុក្ខ មិនអាចហាមនូវភាពជារូបមិនទៀង ឬ ការកើតឡើង, ការរលត់ទៅ និង ការបៀតបៀនរបស់ខ្លួនបានឡើយ, ភាពមានអ្នកសាងរូបជាដើមនោះ នឹងមានមកពីណា ព្រោះហេតុនោះ ទើបព្រះមានព្រះភាគទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ក៏បើសិនជារូបនេះ នឹងបានជាអត្តាមែនហើយ រូបនេះនឹងមិនគប្បីប្រព្រឹត្តទៅ ដើម្បីអាពាធ" ដូច្នេះជាដើម ។ ឯការពិចារណានេះ ជាការពិចារណាមួយ ដោយអំណាចបទនោះថា "ឈ្មោះថា អនត្តា ព្រោះអត្ថថា មិនមានសារៈ" ដូច្នេះ តែ (បើពោល) ដោយប្រភេទ មានការពិចារណា ១១ យ៉ាង ។ ន័យ ក្នុងខន្ធទាំងឡាយ មានវេទនាខន្ធជាដើម ក៏ន័យដូចគ្នានេះដែរ ។

(៤២២) មួយទៀត រូបឯណា មិនទៀង រូបនោះ ជាប្រភេទនៃរូបមានសន្តតៈជាដើម ដោយពិតប្រាកដ ព្រោះហេតុណា, ព្រោះហេតុនោះ ដើម្បីសំដែងនូវបរិយាយ នៃអនិច្ចសព្ទនោះ ឬ ដើម្បីសំដែងនូវការប្រព្រឹត្តិទៅ នៃមនសិការ ដោយអាការៈផ្សេងៗ ទើបលោកពោលបាលីម្តងទៀតថា: រូបដែលជាអតីត អនាគត បច្ចុប្បន្ន ជារបស់មិនទៀង មានបច្ច័យតាក់តែងឡើង អាស្រ័យហេតុ ទើបកើតឡើង មានការអស់ទៅ សាបសូន្យទៅ ជាធម្មតា មានការប្រាសចាកតម្រេក ជាធម្មតា

មានការរលត់ជាធម្មតា” ដូច្នេះ ។ ន័យ ក្នុងខន្ធទាំងឡាយមានវេទនាខន្ធជាដើម ក៏មានន័យដូចគ្នានេះដែរ ។

ដើម្បីជាប្រយោជន៍ ដល់ការស្ថិតស្ថេរ នៃការពិចារណាអនិច្ចលក្ខណៈ, ទុក្ខលក្ខណៈ និង អនត្តលក្ខណៈ ក្នុងបញ្ចក្ខន្ធហ្នឹងឯង ភិក្ខុជាព្រះយោគាវចរនោះ តែងពិចារណានូវបញ្ចក្ខន្ធនេះ ដោយអំណាចនៃការពិចារណាអនិច្ចលក្ខណៈ ជាដើមនោះឯង ដែលព្រះមានព្រះភាគកាលទ្រង់ចំណែកអនុលោមញាណ ត្រាស់ហើយ ដោយប្រភេទ (ផ្សេងៗ) ក្នុងវិភង្គនៃបាលីនោះថា “ភិក្ខុ បាននូវអនុលោមិកខន្តិ ដោយអាការៈ ៤០ តើដូចម្ដេចខ្លះ?, ចុះកាន់សម្មត្តនិយាមធម៌ (អរិយមគ្គ) ដោយអាការៈ ៤០ តើដូចម្ដេចខ្លះ?” ដូច្នេះ មានន័យជាអាទិ៍ថា “ភិក្ខុពិចារណាឃើញនូវខន្ធ ៥ ថា មិនទៀង រមែងបាននូវអនុលោមិកខន្តិ គឺថា កាលពិចារណាឃើញថា “ការរលត់ខន្ធ ៥ គឺព្រះនិព្វាន ដ៏ទៀង” ដូច្នេះ រមែងចុះកាន់សម្មត្តនិយាមធម៌ [១] ដោយអាការៈ ៤០ គឺ :

(១) អនិច្ចតោ ថា មិនទៀង,
(២) ទុក្ខតោ ថា ជាទុក្ខ,
(៣) រោគតោ ថា ជារោគ,
(៤) គណ្ឌតោ ថា ជាបូស,
(៥) សល្លតោ ថា ជាសរ,
(៦) អឃតោ ថា ជារបស់លំបាក,
(៧) អាពាធតោ ថា ជាអាពាធ,
(៨) បរតោ ថា ជារបស់ដទៃ,

១- សុ. ខុ. បដិ. ភាគទី ៧១ ទំព័រទី ៣៣៤ ។



(៩) បលោកតោ ថា ជារបស់វិនាស,
(១០) ព្យសនតោ ថា ជារបស់ចង្រៃ,
(១១) ឧបទ្ទវតោ ថា ជាឧបទ្រព,
(១២) ភយតោ ថា ជាភ័យ,
(១៣) ឧបសគ្គតោ ថា ជាឧបសគ្គ,
(១៤) ចលតោ ថា ជាគ្រឿងញាប់ញ័រ,
(១៥) បភង្គុតោ ថា ជាគ្រឿងបែកធ្លាយ,
(១៦) អទ្ធុវតោ ថា ជារបស់មិនស្ថិតស្ថេរ,
(១៧) អតាណតោ ថា មិនមានទីជ្រកកោន,
(១៨) អលេណតោ ថា មិនមានទីពួន,
(១៩) អសរណតោ ថា មិនមានទីពឹង,
(២០) រិត្តតោ ថា ជាវាល,
(២១) តុច្ឆតោ ថា ទទេ,
(២២) សុញ្ញតោ ថា សោះសូន្យ,
(២៣) អនត្តតោ ថា មិនមែនខ្លួន,
(២៤) អទីនវតោ ថា ជាទោស,
(២៥) វិបរិណាមធម្មតោ ថា មានសេចក្ដីប្រែប្រួលជាធម្មតា,
(២៦) អសារកតោ ថា គ្មានខ្លឹមសារ,
(២៧) អឃមូលតោ ថា ជាឫសគល់នៃសេចក្ដីលំបាក,
(២៨) វធកតោ ថា ជាអ្នកសម្លាប់,
(២៩) វិភវតោ ថា មិនមានសេចក្ដីចំរើន,
(៣០) សាសវតោ ថា ប្រកបដោយអាសវៈ,

(៣១) សន្ធិតតោ ថា ជារបស់ដែលបច្ច័យប្រជុំតាក់តែង,

(៣២) មារាមិសតោ ថា ជាអាមិសនៃមារ,

(៣៣) ជាតិធម្មតោ ថា មានការកើតជាធម្មតា,

(៣៤) ជរាធម្មតោ ថា មានជរាជាធម្មតា,

(៣៥) ព្យាធិធម្មតោ ថា មានព្យាធិជាធម្មតា,

(៣៦) មរណធម្មតោ ថា មានមរណជាធម្មតា,

(៣៧) សោកធម្មតោ ថា មានសេចក្ដីសោកជាធម្មតា,

(៣៨) បរិទេវធម្មតោ ថា មានការខ្សឹកខ្សួលជាធម្មតា,

(៣៩) ឧបាយាសធម្មតោ ថា មានសេចក្ដីចង្អៀតចង្អល់ជាធម្មតា,

(៤០) សំកិលេសិកធម្មតោ ថា មានសេចក្ដីសៅហ្មងជាធម្មតា” ដូច្នេះ ក៏បាន ។

សួរថា : ភិក្ខុ ជាយោគាវចរ ពិចារណាបញ្ចក្ខន្ធ ដោយអំណាចនៃការពិចារណាឃើញអនិច្ចលក្ខណៈជាដើមនោះ តើដូចម្ដេច? ។

ឆ្លើយថា : ក៏ភិក្ខុជាយោគាវចរនោះ ពិចារណាខន្ធមួយៗ ដោយអំណាចនៃការពិចារណាអនិច្ចលក្ខណៈជាដើម ដែលព្រះមានព្រះភាគត្រាស់ហើយ ដោយប្រភេទ (ផ្សេងៗ) យ៉ាងដូច្នេះ ថា :

អនិច្ចតោ ដោយឈ្មោះថា ជារបស់មិនទៀង ព្រោះបញ្ចក្ខន្ធនោះមិនស្ថិតស្ថេរចិរកាលបានឡើយ និង ព្រោះបញ្ចក្ខន្ធនោះ មានខាងដើម និង ខាងចុង,

ទុក្ខតោ ដោយឈ្មោះថា ជាទុក្ខ ព្រោះបញ្ចក្ខន្ធនោះ ត្រូវការកើតឡើង ការរលត់ទៅ (អស់ទៅ) បៀតបៀន និង ព្រោះបញ្ចក្ខន្ធនោះ ជាទីកន្លែងនៃសេចក្ដីទុក្ខ,



រោគតោ ដោយឈ្មោះថា ជារោគ ព្រោះបញ្ចក្ខន្ធនោះ ប្រព្រឹត្តទៅបាន ដោយសារបច្ច័យផង ព្រោះបញ្ចក្ខន្ធនោះ ជាមូល (ដើមចម) នៃរោគផង,

គណ្ឌតោ ដោយឈ្មោះថា ជាបូស ព្រោះជារបស់ដែលប្រកបដោយសេចក្ដីឈឺចាប់ គឺសេចក្ដីទុក្ខ ព្រោះជាទីហូរចេញនូវខ្ទុះ គឺកិលេសផង ព្រោះការហើមប៉ោង ការទ្រុឌទ្រោម និង ការបែកធ្លាយដោយកិរិយាកើតឡើង ការគ្រាំគ្រា និង ការបែកធ្លាយទៅផង,

សល្លតោ ដោយឈ្មោះថា ជាសរ ព្រោះជារបស់ដែលញ៉ាំងការចាក់ដោត (ការចុកចាប់) ឲ្យកើតឡើងផង ព្រោះការចាក់ដោត នៅខាងក្នុងផង ព្រោះជារបស់ដែលនាំយកចេញបាន ដោយកម្រផង,

អឃតោ ដោយឈ្មោះថា ជារបស់លំបាក (ប្រកបដោយការតិះដៀល) ព្រោះជារបស់ដែលអរិយបុគ្គល គួរតិះដៀលផង ព្រោះនាំសេចក្ដីមិនចំរើនមកឲ្យផង ព្រោះជាទីតាំង នៃសេចក្ដីលំបាក (ការតិះដៀល) ផង,

អាពាធតោ ដោយឈ្មោះថា ជាអាពាធ ព្រោះជារបស់ដែលញ៉ាំងភាពមិនមានសិរីសួស្ដី ឲ្យកើតឡើងផង ព្រោះជាបទដ្ឋាននៃជម្ងឺផង,

បរតោ ដោយឈ្មោះថា ជារបស់ដទៃ ព្រោះមិននៅក្នុងអំណាចផង ព្រោះមិនស្ដាប់បង្គាប់ផង,

បលោកតោ ដោយឈ្មោះថា ជារបស់វិនាស ព្រោះវិនាសហិនហោច ដោយព្យាធិ, ជរា និង មរណៈ,

ឦតិតោ ដោយឈ្មោះថា ជារបស់ចង្រៃ ព្រោះនាំសេចក្ដីវិនាសច្រើនជាអនេក មកប្រគល់ឲ្យ,

ឧបទ្ទវតោ ដោយឈ្មោះថា ជាឧបទ្រពចង្រៃ ព្រោះជាទីតាំងនៅនៃឧបទ្រពទាំងពួង ព្រោះនាំមកនូវកម្ម ដែលមិនមែនជាប្រយោជន៍ ដ៏ធំទូលាយទាំងឡាយ ដែលបុគ្គលមិនបានដឹងហើយ,

ភយតោ ដោយឈ្មោះថា ជាភ័យ ព្រោះជាកន្លែងកើតភ័យទាំងពួងផង ព្រោះជាបដិបក្សនៃការសប្បាយចិត្តដ៏ក្រៃលែង ពោលគឺការរម្ងាប់នូវទុក្ខផង,

ឧបសគ្គតោ ដោយឈ្មោះថា ជាឧបសគ្គ ព្រោះជាប់ដោយកម្ម ដែលមិនមែនជាប្រយោជន៍ រាប់មិនអស់ផង ព្រោះត្រូវទោសរារាំងផង ព្រោះមិនគួរដល់ការទទួលយក ដូចជាឧបសគ្គផង ។

ចលតោ ដោយឈ្មោះថា ជាគ្រឿងញាប់ញ័រ ព្រោះញាប់ញ័រ ដោយព្យាធិ, ជរា និង មរណៈផង ដោយលោកធម៌ ៨ ប្រការ មានលាភ និង ខាតលាភជាដើមផង,

បភង្គុតោ ដោយឈ្មោះថា ជាគ្រឿងបែកធ្លាយ ព្រោះមានប្រក្រតីចូលទៅដល់ការបែកធ្លាយ ដោយសេចក្ដីព្យាយាម (របស់ខ្លួន និង អ្នកដទៃ) ដោយការមានឯងៗ ផង,

អទ្ធុវតោ ដោយឈ្មោះថា ជារបស់មិនទៀងទាត់ស្ថិតស្ថេរ ព្រោះមានប្រក្រតីធ្លាក់ទៅកាន់ទីមិនគង់វង់គ្រប់យ៉ាងផង ព្រោះមិនមានភាពស្ថិតស្ថេរ យឺនយូរផង,

អតាណតោ ឈ្មោះថា មិនមានទីជ្រកកោន ព្រោះមិនមានទីឃុំគ្រងផង ព្រោះរកទីក្សេមក្សាន្តមិនបានផង,

អលេណតោ ឈ្មោះថាមិនមានទីពួន ព្រោះមិនមានទីស្ទាត់កំបាំង ដើម្បីនឹងជ្រកពួនបានផង ព្រោះមិនធ្វើទីបិទបាំង សំរាប់មនុស្សដែល



រកទីជ្រកពួនបានផង,

អសរណតោ ឈ្មោះថា មិនមានទីពឹង ព្រោះមិនមានទីសំរាប់កំចាត់នូវភ័យ ដល់បុគ្គលអ្នកនៅអាស្រ័យទាំងឡាយ ។

រិត្តតោ ឈ្មោះថា ជាទីវាល ព្រោះវាលស្រឡះចាកសេចក្ដីស្ថិតស្ថេរទៀងទាត់, សេចក្ដីល្អ និង សេចក្ដីសុខ តាមដែលបុគ្គលល្ងង់ខ្លៅមិនត្រិះរិះទុកហើយ,

តុច្ឆតោ ឈ្មោះថា ជារបស់ទទេ ព្រោះភាពជារបស់ទទេហ្នឹងឯង ឬព្រោះភាពជារបស់តិចតួចក៏បាន ។ ព្រោះថា សូម្បីវត្ថុតិចតួច ក៏ហៅថាជារបស់ទទេ ក្នុងលោក បានដែ,

សុញ្ញតោ ឈ្មោះថា ជារបស់សោះសូន្យ ព្រោះសោះសូន្យចាកម្ចាស់អ្នកនៅអាស្រ័យ អ្នកសាង អ្នកទទួលសោយផល និង អ្នកថែទាំរក្សា,

អនត្តតោ ឈ្មោះថា ជារបស់មិនមែនខ្លួន ព្រោះសូម្បីខ្លួនឯងក៏មិនបានជាម្ចាស់ (ខ្លួនឯង) ជាដើមបានឡើយ,

អាទីនវតោ ឈ្មោះថា ជាទោស ព្រោះសេចក្ដីទុក្ខជារបស់ប្រព្រឹត្តទៅផង ព្រោះសេចក្ដីទុក្ខ ជាទោសផង ។ ម្យ៉ាងទៀត បុគ្គលណា ជួបនូវភាពទុគតិ ដល់នូវភាពទុគ៌ត ភាពទុគ៌ត រមែងប្រព្រឹត្តទៅ ដល់បុគ្គលណា ព្រោះហេតុនោះ បុគ្គលនោះ ឈ្មោះថា អាទីនវៈ (អ្នកដល់នូវភាពទុគ៌ត) ។ ពាក្យថា “អាទីនវៈ” នេះ គឺជាឈ្មោះនៃមនុស្សកំព្រា ។ ក៏សូម្បីខន្ធទាំងឡាយ ក៏ជាសភាពកំព្រាមែនពិត ហេតុនោះទើបឈ្មោះថា ជាទោស ព្រោះប្រៀបដូចជាមនុស្សកំសត់ទុគ៌ត,

វិបរិណាមធម្មតោ ឈ្មោះថា មានសេចក្ដីប្រែប្រួលជាធម្មតា ព្រោះ

មានសេចក្តីប្រែប្រួលទៅជាប្រក្រតី ដោយអាការៈ ២ យ៉ាង គឺ ជរា ១ មរណៈ ១,

អសារកតោ ឈ្មោះថា គ្មានខ្លឹមសារ ព្រោះជារបស់ដែលមានកម្លាំងទន់ខ្សោយផង ព្រោះជារបស់ដែលបាក់បែក បានដោយងាយផង ប្រៀបដូចជាដើមល្ហុងក្អែក,

អឃមូលតោ ឈ្មោះថា ជាដើមហេតុ នៃសេចក្តីលំបាក ព្រោះជាហេតុនៃសេចក្តីទុក្ខលំបាក,

វធកតោ ឈ្មោះថា ជាអ្នកសម្លាប់ ព្រោះបំផ្លាញនូវសេចក្តីស្និទ្ធស្នាលចោល ដូចជាសត្រូវដែលមានមុខមាត់ជាមិត្តសំឡាញ់,

វិភវតោ ឈ្មោះថា វិនាស ព្រោះប្រាសចាកសេចក្តីចំរើន និង ព្រោះជាប្រភពនៃសេចក្តីវិនាស,

សាសវតោ ឈ្មោះថា ប្រព្រឹត្តទៅដោយអាសវៈ ព្រោះជាបទដ្ឋាននៃអាសវៈ,

សង្ខតតោ ឈ្មោះថា សង្ខតៈ ព្រោះជារបស់ដែលហេតុ និង បច្ច័យតាក់តែងឡើង,

មារាមិសតោ ឈ្មោះថា ជាចំណីរបស់មារ ព្រោះជាចំណី របស់មច្ចុមារ និង កិលេសមារ,

ជាតិជរាព្យាធិមរណធម្មតោ ឈ្មោះថា មានជាតិ...ជរា...ព្យាធិ... មរណៈ ជាធម្មតា ព្រោះមានការកើត...ចាស់...ឈឺ...ស្លាប់ ជាប្រក្រតី,

សោកបរិទេវឧបាយាសធម្មតោ ឈ្មោះថា មានសោក...បរិទេវៈ ...ឧបាយាសៈ ជាធម្មតា ព្រោះមានការសៅសោក... ខ្សឹកខ្សួល... ការចង្អៀតចង្អល់ចិត្ត ជាប្រក្រតី,



សង្កិលេសិកធម្មតោ ឈ្មោះថា ជារបស់ដែលមានសេចក្តីសៅហ្មង ជាធម្មតា ព្រោះជាអារម្មណ៍ នៃសង្កិលេស គឺតណ្ហា, ទិដ្ឋិ និង ទុច្ចរិត ជាធម្មតា” ដូច្នេះ ។

(សង្គ្រោះសម្មសនៈ ៤០ ចូលក្នុងអនុបស្សនា ៣)

(៤២៣) ក៏ក្នុងសម្មសនៈ ៤០ នេះ សម្មសនៈ ដោយអាការៈ ១០ គឺៈ ដោយអាការៈមិនទៀង, ដោយអាការៈវិនាស, ដោយអាការៈញាប់ញ័រ, ដោយអាការៈបែកធ្លាយ, ដោយអាការៈមិនជាប់ឋិតថេរ, ដោយអាការៈប្រែប្រួលជាធម្មតា, ដោយអាការៈមិនមានខ្លឹមសារ, ដោយអាការៈវិនាស, ដោយអាការៈមានការតាក់តែងឡើង, ដោយអាការៈមានការស្លាប់ជាធម្មតា ជាអនិច្ចានុបស្សនា ៥០ ដោយរួមជា ១០ ៗ ក្នុងខន្ធមួយ ៗ ។

សម្មសនៈ ដោយអាការៈ ៥ គឺ : ដោយអាការៈជារបស់ដទៃ, ដោយអាការៈជារាល, ដោយអាការៈជារបស់ទទេ, ដោយអាការៈជារបស់សូន្យ, ដោយអាការៈជារបស់មិនមែនខ្លួន, ជាអនត្តានុបស្សនា ២៥ ដោយរួមជា ៥ ៗ ក្នុងខន្ធមួយៗ ។

សម្មសនៈ ដ៏សេស មានជាអាទិ៍ គឺ ដោយអាការៈជាទុក្ខ, ដោយអាការៈជារោគ ជាទុក្ខានុបស្សនា ១២៥ ដោយរួមជា ២៥ ៗ ក្នុងខន្ធមួយៗ ដូច្នេះឯង ។

ក៏កាលព្រះយោគាវចរនោះពិចារណាបញ្ចក្ខន្ធដោយការពិចារណាថា ជារបស់មិនទៀងជាដើមនេះ ដោយចែកចេញជា ២០០ ដូចពោលមកនេះ ការពិចារណាថា ជារបស់មិនទៀង, ជាទុក្ខ និង ជាអនត្តា ដែលហៅថា នយវិបស្សនានោះ រមែងឋិតថេរគង់វង់ ។

*នេះជាពិធីផ្ដើមធ្វើនូវការពិចារណា ក្នុងអធិការនៃសម្មសនញ្ញាណនេះ ដោយទំនងតាមន័យ នៃព្រះបាលីជាមុនសិន ។*

(ធ្វើឥន្ទ្រិយឲ្យចាស់ក្លា ដោយអាការៈ ៩ យ៉ាង)

*(៤២៤) ក៏កាលព្រះយោគាវចររូបណា សូម្បីធ្វើសេចក្ដីព្យាយាម ដោយនយវិបស្សនា ដូចពណ៌នាមុននេះ, នយវិបស្សនា ក៏នៅតែមិនសំរេចទៀត, ព្រះយោគាវចររូបនោះ គប្បីធ្វើឥន្ទ្រិយទាំងឡាយ ឲ្យចាស់ក្លា ដោយអំណាចនៃអាការៈ ៩ ដែលបានពោលមកហើយ យ៉ាងនេះថា "ឥន្ទ្រិយទាំងឡាយ រមែងខ្លាំងក្លា ដោយអាការៈ ៩ នោះ គឺឃើញនូវការអស់ទៅ នៃសង្ខារទាំងឡាយដែលកើតឡើងៗ តែម្យ៉ាង ១, ក្នុងការឃើញនូវការអស់ទៅនៃសង្ខារនោះ ញុំាងវិបស្សនាញាណ ឲ្យដល់ព្រមដោយកិរិយាធ្វើដោយការគោរព ១, ញុំាងវិបស្សនាឲ្យដល់ព្រម ដោយការធ្វើឲ្យជាប់តៗ គ្នា ១, ញុំាងវិបស្សនា ឲ្យដល់ព្រម ដោយកិរិយាធ្វើឲ្យជាទីសប្បាយ (សេពនូវអាវាសសប្បាយជាអាទិ៍) ១, ញុំាងវិបស្សនាឲ្យដល់ព្រម ដោយការចាប់យកនូវនិមិត្តនៃសមាធិ ឲ្យជាប់ ១, ញុំាងវិបស្សនាញាណ ឲ្យដល់ព្រម ដោយការញុំាងពោជ្ឈង្គទាំងឡាយ ឲ្យប្រព្រឹត្តទៅតាមសមគួរ ១, ចូលទៅតម្កល់ទុក នូវការមិនត្រេកអរ ក្នុងកាយ និង ជីវិត ១, ក្នុងកិរិយាតាំងទុកនូវការមិនត្រេកអរ ក្នុងកាយ និងជីវិតនោះ ញុំាងភាវនា ឲ្យដល់ព្រម ដោយការគ្របសង្កត់ (សេចក្ដីទុក្ខ)ឲ្យចេញអស់ទៅ ១, ញុំាងភាវនាឲ្យដល់ព្រម ដោយការមិនលើកលះ ក្នុងចន្លោះ ១ ដោយវៀរចាកនូវអសប្បាយ ៧ សេពនូវសប្បាយ ៧ តាមន័យដែលពោលមកហើយ ក្នុងបឋវីកសិណនិទ្ទេស ពិចារណារូប តាមសមគួរចុះ ។*



(ពិចារណារូប តាមកាល)

*ព្រះយោគាវចរ អ្នកពិចារណារូប គប្បីឃើញការកើតឡើង នៃរូប ។ ការកើតឡើងនៃរូបនេះ តើដូចម្ដេច? ។ ធម្មតារូបនេះ រមែងកើតឡើង ដោយហេតុ ៤ ប្រការ ដោយអំណាចនៃហេតុ មានកម្មជាដើម ។ បណ្ដាហេតុ ៤ យ៉ាងនោះ រូប របស់សត្វទាំងឡាយទាំងពួងកាលកើត រមែងកើតអំពីកម្ម ជាបឋម ។*

*ក៏ក្នុងបដិសន្ធិខណៈនោះឯង ដំបូង សំរាប់ពួកសត្វដែលកើត ក្នុងគភ៌ រូប ៣០ ពោលគឺវត្ថុទសកៈ កាយទសកៈ និង ភាវទសកៈ រមែងកើតឡើង ដោយអំណាចនៃសន្តតិ ៣ ។ ក៏រូបទាំងនោះ រមែងកើតក្នុងឧប្បាទខណៈ នៃបដិសន្ធិចិត្តហ្នឹង ។ ក៏សូម្បីក្នុងឋិតិខណៈ និង ភង្គ-ខណៈ ក៏ដូចគ្នា ក្នុងឧប្បាទខណៈនោះឯង ។ ក្នុងរូប និង ចិត្តនោះ រូបជាធម្មជាត រលត់យឺត ប្រព្រឹត្តទៅ ប្រែប្រួលទៅធ្ងន់, ចិត្ត ជាធម្មជាតរលត់រហ័ស ប្រព្រឹត្តទៅយ៉ាងឆាប់រហ័ស ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគទ្រង់ត្រាស់ ថា "ម្នាលភិក្ខុទាំងឡាយ [១] តថាគត រំពឹងមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈមួយដែលកើតឡើង និង រលត់ទៅរហ័ស ដូចចិត្តនេះសោះឡើយ" ដូច្នេះជាដើម ។ ព្រោះកាលបើរូបមាននៅហ្នឹងឯង, ភវង្គចិត្ត កើតឡើងហើយ រលត់ទៅវិញ អស់ ១៦ ដង ។ ឧប្បាទខណៈក្ដី ឋិតិខណៈក្ដី ភង្គខណៈក្ដី នៃចិត្ត ដូចគ្នាតែមួយ ។ តែឧប្បាទខណៈ និង ភង្គខណៈ នៃរូបនោះឯង ជាខណៈដែលឆាប់រហ័សដូចគ្នានឹងឧប្បាទខណៈ និង ភង្គខណៈនៃចិត្តនោះ ។ ចំណែកឋិតិខណៈ ជាខណៈដ៏ធំ រមែងប្រព្រឹត្តទៅ ស្មើពេលគ្នានឹងចិត្ត ១៦ ដួង*

*១- សុ. អំ. ឯ. ភាគទី ៤០ ទំព័រទី ១៨ ។*

កើតឡើងហើយ រលត់ទៅវិញ ។ ភវង្គចិត្ត ទី២ អាស្រ័យវត្ថុរូបដែលកើតមុន ដែលកើតឡើង ក្នុងឧប្បាទខណៈ នៃបដិសន្ធិចិត្ត ដល់នូវការតាំងនៅហើយកើតឡើង ។ ភវង្គចិត្ត ទី៣ រមែងអាស្រ័យវត្ថុរូប ដែលកើតមុន ដែលកើតឡើងជាមួយគ្នានឹងភវង្គចិត្ត ទី ២ នោះ ដល់នូវការតាំងនៅហើយ កើតឡើង ។ ការប្រព្រឹត្តិទៅនៃចិត្ត រហូតទល់គ្នានឹងអាយុ បណ្ឌិតគប្បីយល់ តាមន័យនេះចុះ ។

(៤២៥) ចំណែកចិត្ត ១៦ ដួង អាស្រ័យវត្ថុរូបដែលកើតមុន ដែលដល់នូវការតាំងនៅហើយ តែមួយនោះឯង រមែងកើតឡើង ដល់សត្វដែលជិតនឹងមរណៈ ។ រូបដែលកើតឡើង ក្នុងឧប្បាទខណៈនៃបដិសន្ធិចិត្ត រមែងរលត់ទៅវិញ ព្រមជាមួយគ្នានឹងចិត្ត ទី១៦ បន្ទាប់អំពីបដិសន្ធិចិត្តទៅ ។ រូបដែលកើតឡើង ក្នុងឋានខណៈ (ឋិតិខណៈ) នៃបដិសន្ធិចិត្ត រមែងរលត់ទៅ ព្រមជាមួយគ្នានឹងឧប្បាទខណៈ នៃចិត្តទី១៧ ។ រូបដែលកើតឡើង ក្នុងភង្គខណៈនៃបដិសន្ធិចិត្ត ដល់នូវឋានខណៈ នៃចិត្ត ទី១៧ រមែងរលត់ទៅវិញ ។ ធម្មតាការប្រព្រឹត្តិទៅ នៅមាន ដរាបណា, រូប ក៏រមែងប្រព្រឹត្តទៅ យ៉ាងនេះ ដរាបនោះដែរ ។

សូម្បីសំរាប់ពួកឱបបាតិកសត្វ រូប ៧០ ក៏ប្រព្រឹត្តទៅ ដោយអំណាចនៃសន្តតិ ៧ ក៏យ៉ាងដូច្នោះដែរ ។

(វិភាគនៃកម្មជរូប)

ក្នុងការប្រព្រឹត្តិទៅ នៃរូបដែលកើតអំពីកម្មនោះ បណ្ឌិត គប្បីជ្រាបវិភាគនេះ គឺៈ កម្ម, រូបដែលមានកម្ម ជាសមុដ្ឋាន, រូបដែលមានកម្ម ជាបច្ច័យ, រូបដែលមានចិត្ត មានកម្ម ជាបច្ច័យ ជាសមុដ្ឋាន, រូបដែលមានអាហារ មានកម្ម ជាបច្ច័យ ជាសមុដ្ឋាន, រូប ដែលមានរដូវ



មានកម្ម ជាបច្ច័យ ជាសមុដ្ឋាន ។

ក្នុងវិភាគទាំងនោះ កុសលចេតនា និង អកុសលចេតនា ឈ្មោះថាកម្ម ។

វិបាកខន្ធទាំងឡាយ និង រូប ៧០ មានចក្ខុទសកៈជាដើម ឈ្មោះថា រូបដែលមានកម្ម ជាសមុដ្ឋាន ។

វិបាកខន្ធ និង រូប ៧០ នោះឯង ឈ្មោះថា រូបមានកម្មជាបច្ច័យ ។ ព្រោះកម្ម រមែងជាបច្ច័យ ដែលជួយឧបត្ថម្ភ ដល់រូបដែលមានកម្ម ជាសមុដ្ឋានផងដែរ ។

រូប ដែលមានវិបាកចិត្ត ជាសមុដ្ឋាន ឈ្មោះថា រូបដែលមានចិត្តមានកម្មជាបច្ច័យ ជាសមុដ្ឋាន ។

ឱជា ដែលដល់នូវការតាំងនៅ ក្នុងរូបដែលមានកម្ម ជាសមុដ្ឋានទាំងឡាយ រមែងញ៉ាំងឱជដ្ឋមករូបដទៃទៀត ឲ្យកើតឡើង, ឱជា ក្នុងឱជដ្ឋមករូបនោះឯង ដែលដល់នូវការតាំងនៅហើយ ក៏ញ៉ាំងឱជដ្ឋមក-រូប ដទៃទៀត ឲ្យកើតឡើង ព្រោះហេតុនេះ ការប្រព្រឹត្តិទៅ ចេះតែមានបន្តគ្នា ៤ ឬ ៥ ដូចបានរៀបរាប់មកនេះឯង ឈ្មោះថា រូបដែលមានអាហារ មានកម្មជាបច្ច័យ ជាសមុដ្ឋាន ។

តេជោធាតុ ដែលកើតអំពីកម្ម ដល់នូវការតាំងនៅហើយ រមែងញ៉ាំងឱជដ្ឋមករូប ដែលមានរដូវជាសមុដ្ឋាន ឲ្យកើតឡើង, រដូវ ក្នុងឱជដ្ឋមករូបនោះសោត ក៏ញ៉ាំងឱជដ្ឋមករូប ដទៃទៀត ឲ្យកើតឡើង ព្រោះហេតុនេះ ការប្រព្រឹត្តិទៅ ចេះតែមានបន្តៗគ្នា ៤ ឬ ៥ ដោយន័យដែលបានរៀបរាប់មកនេះឯង ឈ្មោះថា រូបដែលមានរដូវ មានកម្ម ជាបច្ច័យ ជាសមុដ្ឋាន ។

*បណ្ឌិត បគ្បីឃើញការកើតឡើង នៃកម្មជរូប យ៉ាងនេះជាមុន ។*

(វិភាគនៃចិត្តជរូប)

*(៤២៦) សូម្បីក្នុងចិត្តជរូបទាំងឡាយ ក៏គប្បីជ្រាបវិភាគ ដូចត ទៅនេះ គឺ ចិត្ត, រូប ដែលមានចិត្តជាសមុដ្ឋាន, រូប ដែលមានចិត្ត ជាបច្ច័យ, រូប ដែលមានអាហារ មានចិត្តជាបច្ច័យ ជាសមុដ្ឋាន, រូប ដែលមានរដូវ មានចិត្តជាបច្ច័យ ជាសមុដ្ឋាន ។*

*ក្នុងវិភាគទាំងនោះ ចិត្ត ៨៩ ឈ្មោះថា ចិត្ត ។ បណ្ដាចិត្តទាំងនោះ ចិត្ត ៣២, ចិត្ត ២៦, ចិត្ត ១៩, ចិត្ត ១៦ បណ្ឌិតគប្បីជ្រាប ថា :*

ជាចិត្តធ្វើឲ្យរូប, ឥរិយាបថ និង វិញ្ញត្តិ ឲ្យ
កើតឡើង (ក៏មាន) មិនធ្វើឲ្យរូប, ឥរិយាបថ
និង វិញ្ញត្តិ កើតឡើង (ក៏មាន) ។

*អធិប្បាយថា: ព្រោះជាកាមាវចរចិត្ត ចិត្ត ៣២ គឺ កុសលចិត្ត ៨, អកុសលចិត្ត ១២, កិរិយាចិត្ត ១០ លើកលែងតែមនោធាតុចេញ, អភិញ្ញាចិត្ត ២ ព្រោះជាកុសល និង កិរិយា រមែងញ៉ាំងរូប, ឥរិយាបថ និង វិញ្ញត្តិ ឲ្យកើតឡើង ។*

*ចិត្ត ២៦ គឺ: កាមាវចរចិត្ត ១០ ដ៏សេស លើកលែងវិបាកចិត្តចេញ, អរូបាវចរចិត្ត ៨ និង លោកុត្តរចិត្ត ៨ ផង ញ៉ាំងរូប និង ឥរិយាបថ ឲ្យកើតឡើង តែមិនញ៉ាំងវិញ្ញត្តិ ឲ្យកើតឡើងទេ ។*

*ចិត្ត ១៩ គឺ: ភវង្គចិត្ត ១០ ក្នុងកាមាវចរ, ភវង្គចិត្ត ៥ ក្នុង រូបាវចរ, មនោធាតុ ៣, អហេតុកមនោវិញ្ញាណធាតុ ដែលជាវិបាក ជាសោមនស្សសហគតៈ ១ ញ៉ាំងរូបប៉ុណ្ណោះ ឲ្យកើតឡើង មិនញ៉ាំង*



*ឥរិយាបថ ឲ្យកើត មិនញ៉ាំងវិញ្ញត្តិ ឲ្យកើតទេ ។*

*ចិត្ត ១៦ គឺ បញ្ចវិញ្ញាណ ២, បដិសន្ធិរបស់សត្វទាំងពួង, ចុតិចិត្តរបស់ព្រះខីណាស្រពទាំងឡាយ, អារូបវិបាកចិត្ត ៤ មិនញ៉ាំងរូប ឲ្យកើត មិនញ៉ាំងឥរិយាបថ ឲ្យកើត មិនញ៉ាំងវិញ្ញត្តិ ឲ្យកើតទេ ។*

*ម្យ៉ាងទៀត បណ្ដាចិត្តទាំងនោះ ចិត្តទាំងឡាយណា ញ៉ាំងរូប ឲ្យកើតឡើងបាន, ចិត្តទាំងនោះ ក៏មិនមាន ក្នុងឋិតិខណៈ ឬ ភង្គខណៈទេ ព្រោះចិត្តក្នុងខណៈនោះ ជាចិត្តមានកម្លាំងខ្សោយ, តែចិត្ត ក្នុងឧប្បាទខណៈ ជាចិត្តមានកម្លាំង ព្រោះហេតុនោះ អាស្រ័យវត្ថុរូប ដែលកើតមុនក្នុងខណៈនោះ ទើបញ៉ាំងរូប ឲ្យកើតឡើងបាន ។*

*អរូបក្ខន្ធ ៣ និង រូប ១៧ យ៉ាង គឺ: សទ្ទនវករូប, កាយវិញ្ញត្តិ, វចីវិញ្ញត្តិ, អាកាសធាតុ, លហុតា, មុទុតា, កម្មញ្ញតា, ឧបចយៈ, សន្តតិ ឈ្មោះថា រូបមានចិត្ត ជាសមុដ្ឋាន ។*

*រូបដែលមានសមុដ្ឋាន ៤ ដូចបានពោលហើយ យ៉ាងនេះ ថា "ចិត្ត ចេតសិកធម៌ទាំងឡាយ ដែលកើតជាខាងក្រោយជាបច្ច័យ ដោយបច្ឆាជាតបច្ច័យ នៃកាយនេះ ដែលកើតពីមុន" ដូច្នេះ ឈ្មោះថា រូបមានចិត្ត ជាបច្ច័យ ។*

*ឱជារូប ដែលដល់នូវការតាំងនៅហើយ ក្នុងរូបដែលមានចិត្ត ជាសមុដ្ឋានទាំងឡាយ ញ៉ាំងឱជដ្ឋមករូបដទៃ ឲ្យកើតឡើង, ការប្រព្រឹត្តិទៅ រមែងមានបន្តគ្នា ២-៣ យ៉ាងដូច្នេះ ឈ្មោះថា រូបមានអាហារ មានចិត្តជាបច្ច័យ ជាសមុដ្ឋាន ។*

*បណ្ឌិត គប្បីឃើញការកើតឡើង នៃចិត្តជរូប យ៉ាងដូច្នេះឯង ។*

(វិភាគនៃអាហារជរូប)

*(៥២៧) សូម្បីក្នុងអាហារជរូបទាំងឡាយ បណ្ឌិត គប្បីជ្រាបវិភាគ យ៉ាងនេះ គឺ: អាហារ, រូបដែលមានអាហារជាសមុដ្ឋាន, រូបដែលមានអាហារជាបច្ច័យ, រូបដែលមានអាហារ មានអាហារ (ដូចគ្នា) ជាបច្ច័យជាសមុដ្ឋាន, រូប ដែលមានរដូវ មានអាហារជាបច្ច័យ ជាសមុដ្ឋាន ។*

*ក្នុងវិភាគទាំងនោះ កពលិង្ការាហារ ឈ្មោះថា អាហារ ។*

*រូប ១៤ យ៉ាង គឺ ឱជដ្ឋមករូប ដែលឱជា បានកម្មជរូប ដែលមានចិត្តគ្រប់គ្រងជាបច្ច័យ ហើយតាំងនៅ ក្នុងកម្មជរូបនោះ ដល់នូវការតាំងនៅហើយ ឲ្យកើតឡើង, អាកាសធាតុ, លហុតា, មុទុតា, កម្មញ្ញតា, ឧបចយៈ, សន្តតិ ឈ្មោះថា រូបដែលមានអាហារ ជាសមុដ្ឋាន ។*

*រូបដែលមានសមុដ្ឋាន ៤ ដូចបានពោលមកហើយ យ៉ាងនេះ ថា "កពលិង្ការាហារ ជាបច្ច័យ ព្រោះជាអាហារបច្ច័យនៃកាយនេះ" ឈ្មោះថា រូបមានអាហារជាបច្ច័យ ។*

*ឱជា ដែលដល់នូវការតាំងនៅ ក្នុងរូបដែលមានអាហារ ជាសមុដ្ឋានទាំងឡាយ ញ៉ាំងឱជដ្ឋមករូបដទៃ ឲ្យកើតឡើង, ឱជា ក្នុងឱជដ្ឋមករូបទាំងឡាយនោះសោត ក៏ញ៉ាំងឱជដ្ឋមករូបដទៃទៀត ឲ្យកើតឡើង ព្រោះហេតុនេះ ការប្រព្រឹត្តិទៅ តែងមានបន្តៗ គ្នា អស់ ១០ ទៅ ១២ ជង ដូចន័យដែលបានពោលមកនេះឯង ឈ្មោះថា រូបមានអាហារដែលមានអាហារ (ដូចគ្នា) ជាបច្ច័យ ជាសុមដ្ឋាន ។*

*អាហារ ដែលបុគ្គលបរិភោគហើយ ក្នុងមួយថ្ងៃ រមែងឧបត្ថម្ភ (រូប) បានដល់ទៅមួយសប្តាហ៍ ។ តែឱជា ដែលជាទិព្វ រមែងឧបត្ថម្ភ*



*(រូប) បានដល់ ១ ខែ ទៅ ២ ខែ, សូម្បីអាហារ ដែលមាតាបរិភោគហើយ រមែងផ្សាយទៅដល់សរីរៈ របស់ទារក ហើយញ៉ាំងរូប ឲ្យកើតឡើងបាន ។ សូម្បីតែអាហារ ដែលបុគ្គលលាបហើយ លើសរីរៈ ក៏ញ៉ាំងរូប ឲ្យកើតឡើងបានដែរ ។*

*អាហារដែលកើតអំពីកម្ម ឈ្មោះថា ឧបាទិន្នកាហារ ។ សូម្បីឧបាទិន្នកាហារនោះ ដែលដល់នូវការតាំងនៅហើយ ក៏រមែងញ៉ាំងរូបឲ្យកើតឡើងបានដែរ, ឱជា ក្នុងរូបនោះឯង ក៏ញ៉ាំងរូបដទៃទៀត ឲ្យកើតឡើង ព្រោះហេតុនេះ ការប្រព្រឹត្តិទៅ រមែងមានបន្តៗ គ្នា ៤ ឬ ៥ ដូចន័យដែលបានពោលហើយនេះឯង (ក៏ឈ្មោះថា រូបមានអាហារ ដែលមានអាហារ (ដូចគ្នា) ជាបច្ច័យជាសមុដ្ឋាន ។*

*តេជោធាតុ ដែលមានអាហារ ជាសមុដ្ឋាន ដល់នូវការតាំងនៅហើយ រមែងញ៉ាំងឱជដ្ឋមករូប ដែលមានរដូវជាសមុដ្ឋាន ឲ្យកើតឡើង ឈ្មោះថា រូបដែលមានរដូវ មានអាហារជាបច្ច័យជាសមុដ្ឋាន ។*

*ក្នុងសមុដ្ឋានទាំងនោះ អាហារនេះ ជាបច្ច័យនៃរូប ដែលមានអាហារជាសមុដ្ឋានទាំងឡាយ ព្រោះជាអ្នកឲ្យកើត, ជាបច្ច័យនៃរូបទាំងឡាយ ដ៏សេស ដោយអំណាច នៃនិស្សយប្បច្ច័យ, អាហារប្បច្ច័យ, អត្ថិប្បច្ច័យ និង អវិគតប្បច្ច័យ ដូច្នេះឯង ។*

*ការកើតឡើង នៃអាហារជរូប បណ្ឌិត គប្បីឃើញ ដូចបានពោលមកហើយនេះឯង ។*

(វិភាគនៃឧតុជរូប)

*(៤២៨) សូម្បីក្នុងឧតុជរូបទាំងឡាយ ក៏គប្បីជ្រាបវិភាគ យ៉ាងនេះ គឺ: រដូវ, រូប ដែលមានរដូវ ជាសមុដ្ឋាន, រូប ដែលមានរដូវ ជាបច្ច័យ*

រូបមានរដូវ ដែលមានរដូវ (ដូចគ្នា) ជាបច្ច័យ ជាសមុដ្ឋាន, រូបដែលមានអាហារ មានរដូវជាបច្ច័យ ជាសមុដ្ឋាន ។

ក្នុងវិភាគទាំងនោះ តេជោធាតុ ដែលមានសមុដ្ឋាន ៤ ឈ្មោះថា រដូវ ។ ក៏រដូវនោះ មាន ២ យ៉ាង ដូច្នេះគឺ ឧណ្ហរដូវ ១ សីតរដូវ ១ ។

រដូវដែលមានសមុដ្ឋាន ៤ បានឧបាទិន្នករូបជាបច្ច័យ ដល់នូវការតាំងនៅហើយ ញុំាងរូបឲ្យកើតឡើង ក្នុងសរីរៈ ឈ្មោះថា រូបមានរដូវជាសមុដ្ឋាន ។ រូបដែលមានរដូវជាសមុដ្ឋាននោះ មាន ១៥ យ៉ាង គឺ សទ្ទនវករូប, អាកាសធាតុ, លហុតា, មុទុតា, កម្មញ្ញតា, ឧបចយៈ, សន្តតិ ។

រដូវ រមែងជាបច្ច័យនៃការប្រព្រឹត្តិទៅ និង សេចក្ដីវិនាសទៅនៃរូបដែលប្រកបដោយសមុដ្ឋាន ៤ ទាំងឡាយ ឈ្មោះថា រូបមានរដូវ ជាបច្ច័យ ។

តេជោធាតុ ដែលមានរដូវជាសមុដ្ឋាន ដល់នូវការតាំងនៅហើយ ញុំាងឱជដ្ឋមករូបដទៃទៀត ឲ្យកើតឡើងផងដែរ ព្រោះហេតុនោះ រូបដែលមានរដូវជាសមុដ្ឋាន សូម្បីតាំងនៅ ក្នុងចំណែកនៃអនុបាទិន្នករូបហើយ ក៏រមែងប្រព្រឹត្តទៅហ្នឹងឯង អស់កាលដ៏យូរ មែនពិត តាមដែលបានពោលហើយនេះឯង ឈ្មោះថា រូបមានរដូវ ដែលមានរដូវ (ដូចគ្នា) ជាបច្ច័យ ជាសមុដ្ឋាន ។

ឱជា ដែលមានរដូវជាសមុដ្ឋាន ដល់នូវការតាំងនៅហើយ រមែងញុំាងឱជដ្ឋមករូបដទៃទៀត ឲ្យកើតឡើង, ឱជា ក្នុងឱជដ្ឋមករូបទាំងនោះសោត ក៏ញុំាងឱជដ្ឋមករូបដទៃទៀត ឲ្យកើតឡើងដែរ ព្រោះហេតុនោះ ការប្រព្រឹត្តិទៅ រមែងមានបន្តៗ គ្នា អស់វារៈ ១០ ទៅ ១២ ដង



ដូចន័យដែលបានពោលហើយនេះឯង ឈ្មោះថា រូបមានអាហារ ដែលមានរដូវជាបច្ច័យ ជាសមុដ្ឋាន ។

ក្នុងសមុដ្ឋានទាំងនោះ រដូវនេះ ជាបច្ច័យនៃរូប ដែលមានរដូវជាសមុដ្ឋានទាំងឡាយ ព្រោះជាអ្នកឲ្យកើត, ជាបច្ច័យនៃរូបដ៏សេសដោយអំណាចនៃនិស្សយបច្ច័យ, អត្ថិបច្ច័យ និង អវិគតបច្ច័យ ដូច្នេះឯង ។ ការកើតឡើងនៃឧតុជរូប បណ្ឌិត គប្បីឃើញ ដូចពោលនេះឯង ។ មែនពិត ព្រះយោគាវចរបុគ្គល កាលពិចារណាការកើតឡើងនៃរូប តាមន័យដូចបានពោលមកនេះឯង ឈ្មោះថា ពិចារណារូប តាមកាល ។

(ការពិចារណារូបតាមកាល)

មួយទៀត ការកើតឡើងនៃរូប គឺព្រះយោគាវចរបុគ្គល អ្នកពិចារណារូប គប្បីឃើញ យ៉ាងណា, ការកើតឡើងនៃអរូប សូម្បីព្រះយោគាវចរបុគ្គលពិចារណាអរូប ក៏គប្បីឃើញ យ៉ាងដូច្នោះដែរ ។ ក៏ការកើតឡើង នៃរូបនោះឯង គប្បីឃើញ ដោយអំណាចនៃការកើតឡើង នៃលោកិយចិត្ត ៨១ នោះឯង ។ ការកើតឡើងនៃលោកិយចិត្តនេះ តើដូចម្ដេច? ។ មែនពិត អរូបនេះ ជាដំបូង កើតជាចិត្តុប្បាទ ១៩ ប្រភេទ ក្នុងបដិសន្ធិ ដោយអំណាចនៃកម្ម ដែលបានសន្សំទុកមកហើយក្នុងភពខាងដើម ។ ក៏អាការៈនៃការកើតឡើង នៃអរូបនោះ បណ្ឌិតគប្បីជ្រាប តាមន័យដែលបានពោលមកហើយ ក្នុងបដិសន្ធិសមុប្បាទ-និទ្ទេសនោះឯង ។ អរូបនោះឯង រមែងកើតឡើង ដោយអំណាចនៃភវង្គរាប់តាំងពីចិត្តដែលជាលំដាប់ នៃបដិសន្ធិចិត្តមក រមែងកើតឡើង ដោយអំណាចនៃចុតិ ក្នុងទីបញ្ចប់ នៃអាយុ ។

បណ្ដាចិត្តទាំងនោះ ចិត្ត ឯណា ជាកាមាវចរចិត្តនោះ រមែងកើត

ក្នុងអារម្មណ៍ដែលមានកម្លាំង ក្នុងទ្វារទាំង ៦ ដោយអំណាចនៃតទារម្មណៈ ។ ចំណែកក្នុងបវត្តិកាល ព្រោះចក្ខុមិនទាន់បានទំលាយ ព្រោះរូបទាំងឡាយ មកកាន់រង្វង់នៃចក្ខុ ចក្ខុវិញ្ញាណ ដែលអាស្រ័យនូវពន្លឺ មានមនសិការជាហេតុ រមែងកើតឡើង ព្រមជាមួយសម្បយុត្តធម៌ទាំងឡាយ ។ មែនពិត ក្នុងឋិតិខណៈ នៃចក្ខុបសាទ រូបដែលដល់នូវការតាំងនៅហ្នឹងឯង រមែងប៉ះនឹងចក្ខុ ។ កាលបើចក្ខុនោះ ត្រូវរូបប៉ះហើយ ភវង្គ កើតហើយរលត់ទៅវិញ អស់ ២ ដង ។ តអំពីនោះមក កិរិយាមនោធាតុ ញុំាងអាវជ្ជនកិច្ច ឲ្យសម្រេចកើតឡើង ក្នុងអារម្មណ៍នោះឯង ។ លំដាប់នោះ ចក្ខុវិញ្ញាណ ដែលជាកុសលវិបាកក្តី អកុសលវិបាកក្តី សំឡឹងរំពៃរូបនោះឯង កើតឡើង ។ តពីនោះមកទៀត វិបាកមនោធាតុ ក៏ទទួលយករូបនោះឯង កើតឡើង ។ បន្ទាប់អំពីនោះមក វិបាកអហេតុកមនោវិញ្ញាណធាតុ ពិចារណារូបនោះឯង កើតឡើង ។ តអំពីនោះមក កិរិយាអហេតុកមនោវិញ្ញាណធាតុ ដែលជាឧបេក្ខាសហគតៈ កំណត់យករូបនោះឯង កើតឡើង ។ តអំពីនោះមកទៀត បណ្តាកុសលចិត្ត អកុសលចិត្ត និង កិរិយាចិត្ត ផ្នែកខាងកាមាវចរទាំងឡាយ ចិត្តដែលជាអហេតុកៈ ប្រកបព្រមដោយឧបេក្ខា ១ ឬក៏ ជវនៈ ៥ ដល់ទៅ ៧ ក៏កើតឡើង ។ បន្ទាប់អំពីនោះមក បណ្តាតទារម្មណចិត្ត ១១ នៃកាមាវចរចិត្តទាំងឡាយ តទារម្មណចិត្ត ឯណានីមួយ ដែលគួរដល់ជវនៈ កើតឡើង ។ សូម្បីក្នុងទ្វារ ដ៏សេស ក៏ន័យនេះដែរ ។ ក៏ប៉ុន្តែក្នុងមនោទ្វារ សូម្បីមហគ្គតចិត្តទាំងឡាយ ក៏កើតឡើងផងដែរ ។ កិរិយាកើតឡើង នៃអរូប ក្នុងទ្វារទាំង ៦ គឺបណ្ឌិត គប្បីឃើញ ដូចដែលបានពោលហើយនេះឯង ។ ក៏ព្រះយោគាវចរ កាលឃើញការកើត



ឡើងនៃអរូប ដូចបានពោលហើយនេះ ឈ្មោះថា ពិចារណារអរូប ។

ព្រះយោគាវចរមួយរូប សូម្បីពិចារណារូប តាមកាល ពិចារណាអរូប តាមកាល ដូចពោលមកនេះហើយខាងលើ ចាប់យកត្រៃលក្ខណ៍ប្រតិបត្តិ តាមលំដាប់ ក៏ញុំាងបញ្ញាភាវនា ឲ្យសម្រេចបាន ។

**(ពិចារណារូប និង អរូប ដោយអាការៈ ៧)**

(៤២៩) ព្រះយោគាវចរមួយរូបទៀត ពិចារណាសង្ខារទាំងឡាយ ដោយលើកឡើងកាន់ត្រៃលក្ខណ៍ ដោយអំណាចនៃមនសិការ ដោយអាការៈ ៧ ក្នុងរូប និង នៃមនសិការ ដោយអាការៈ ៧ ក្នុងអរូប ។

**(រូបសត្តកៈ)**

បណ្តាសត្តកៈទាំង ២ យ៉ាងនោះ ព្រះយោគាវចរ កាលពិចារណាលើកឡើង ដោយអាការៈទាំងនេះ គឺ :

អាទាននិក្ខេបនតោ ដោយការកាន់យក និង ការទម្លាក់ចោល,

វយោវុឌ្ឍត្ថគមតោ ដោយការធ្លាក់ចុះនៃរូប ដែលចំរើនឡើងតាមវ័យ,

អាហារមយតោ ដោយថា ជារូបដែលសំរេចមកអំពីអាហារ,

ឧតុមយតោ ដោយថា ជារូបដែលសំរេចមកអំពីរដូវ,

កម្មជតោ ដោយថា ជារូបដែលកើតមកអំពីកម្ម,

ចិត្តសមុដ្ឋានតោ ដោយថា ជារូបដែលមានចិត្តជាសមុដ្ឋាន,

ធម្មតារូបតោ ដោយថា ជារូបតាមធម្មតា

ដូច្នេះ ឈ្មោះថា ពិចារណា លើកឡើង (កាន់ត្រៃលក្ខណ៍) ដោយអំណាចនៃរូបសត្តកៈ ព្រោះហេតុដូច្នេះ ទើបបុរាណាចារ្យទាំងឡាយលោកពោល ថា :

ព្រះយោគាវចរ រមែងឃើញច្បាស់ យ៉ាងពិស្តារ (ដោយអាការៈ) ៧ គឺៈ ដោយការកាន់យក និង ទម្លាក់ចោល ១, ដោយការធ្លាក់ចុះនៃរូប ដែលចំរើនឡើង តាមវ័យ ១, ដោយអាហារ ១, ដោយរដូវ ១, ដោយកម្ម ១, ដោយចិត្ត ១, ដោយរូបធម្មតា ១ ដូច្នេះ ។

### (អាទាននិក្ខេបនតោ)

បណ្ដាបទទាំងនោះ បទថា “ការកាន់យក” បានដល់ បដិសន្ធិ ។ បទថា “ទំលាក់ចោល” បានដល់ ចុតិ ។ ព្រះយោគាវចរ កំណត់ ១០០ ឆ្នាំមួយ ដោយការកាន់យក និង ការទម្លាក់ចោលនេះហើយ លើកឡើងកាន់ត្រៃលក្ខណ៍ ក្នុងសង្ខារទាំងឡាយ ដោយប្រការដូច្នេះ ។ តើយ៉ាងដូចម្ដេច? ។ គឺៈ សង្ខារទាំងឡាយទាំងពួង ក្នុងចន្លោះនៃការកាន់យក និងការទម្លាក់ចោលនេះ ឈ្មោះថា មិនទៀង។ ព្រោះហេតុអ្វី? ។ ព្រោះប្រព្រឹត្តទៅ ដោយអំណាចនៃការកើតឡើង និង វិនាសទៅវិញ ព្រោះប្រែប្រួលទៅបាន ព្រោះប្រព្រឹត្តទៅ តាមកាលកំណត់ និង ព្រោះជាគូប្រឆាំងនឹងសេចក្ដីទៀងទាត់ ។ មួយទៀត ព្រោះហេតុអ្វី សង្ខារទាំងឡាយ ដែលកើតឡើងហើយ ដល់នូវការតាំងនៅ, ក្នុងពេលតាំងនៅ រមែងលំបាកព្រោះជរា ដល់ជរាហើយ រមែងបែកធ្លាយ ដោយពិតប្រាកដ ព្រោះហេតុនោះ សង្ខារទាំងឡាយនោះ ទើបឈ្មោះថា ជាទុក្ខ ព្រោះបៀតបៀនរឿយៗ រហូតមកដល់ពេលឥឡូវនេះ ព្រោះលំបាក ព្រោះទ្រាំបានដោយលំបាក ព្រោះជាទីតាំងនៃទុក្ខ និង ព្រោះជាគូប្រឆាំង



ជាមួយនឹងសេចក្ដីសុខ ។ម្យ៉ាងទៀត ព្រោះហេតុអ្វី ការប្រើអំណាចបង្គាប់បញ្ជា មិនមានដល់អ្នកណាម្នាក់ ក្នុងឋាន ៣ នេះ គឺ “សង្ខារទាំងឡាយដែលកើតឡើងហើយ កុំដល់នូវការតាំងនៅឡើយ, ដែលដល់នូវការតាំងនៅហើយ ចូរកុំប្រែប្រួលឡើយ, ដែលដល់នូវការប្រែប្រួល(ជរា)ហើយ ចូរកុំបែកធ្លាយទៅឡើយ” ដូច្នេះ, សង្ខារទាំងនោះ ជារបស់សូន្យ អំពីអាការៈប្រើអំណាចនោះ មែនពិត ព្រោះហេតុនោះ សង្ខារទាំងឡាយនោះ ទើបឈ្មោះថា អនត្តា ព្រោះជារបស់សូន្យទទេ ព្រោះជារបស់មិនមានម្ចាស់ ព្រោះបង្គាប់បញ្ជាមិនបាន និង ព្រោះជាគូប្រឆាំងនឹងអត្តា ដោយប្រការដូច្នេះឯង ។

### (វយោវុឌ្ឍត្ថង្គមតោ)

(៤៣០) ព្រះយោគាវចរ លុះលើកឡើងកាន់ត្រៃលក្ខណ៍ ក្នុងរូបដែលបានកំណត់ ១០០ ឆ្នាំ ដោយអំណាចនៃការកាន់យក និង ការទម្លាក់ចោល យ៉ាងនេះហើយ បន្ទាប់ពីនោះមកទៀត ក៏លើកឡើងដោយការធ្លាក់ចុះទៅ នៃរូបដែលចំរើនឡើងតាមវ័យ ។

ការតាំងនៅមិនបាន នៃរូបដែលចំរើនឡើង គឺធំធាត់ឡើង ដោយអំណាចនៃវ័យ ឈ្មោះថា ការធ្លាក់ចុះទៅនៃរូបដែលចំរើនឡើង ដោយអំណាចនៃវ័យ ក្នុងបទនោះ ។ អធិប្បាយថា “លើកឡើងកាន់ត្រៃលក្ខណ៍ ដោយអំណាចនៃការតាំងនៅមិនបាន នៃរូបដែលចំរើនឡើងតាមវ័យនោះ” ។ លើកឡើងយ៉ាងដូចម្ដេច? ។ គឺព្រះយោគាវចរនោះ កំណត់ ១០០ ឆ្នាំនោះឯង ដោយវ័យទាំង ៣ គឺ : ដោយបឋមវ័យ, ដោយមជ្ឈិមវ័យ, ដោយបច្ឆិមវ័យ ។ ក្នុងវ័យទាំង ៣ នោះ ៣៣ ឆ្នាំខាងដើម ឈ្មោះថា បឋមវ័យ, បន្ទាប់អំពីនោះមក ៣៤ ឆ្នាំ ឈ្មោះថា

មជ្ឈិមវ័យ, តមក ៣៣ ឆ្នាំ ឈ្មោះថា បច្ឆិមវ័យ ។ ព្រះយោគាវចរ លុះកំណត់ ដោយវ័យទាំង ៣ នេះ ដូចរៀបរាប់មកហើយនេះ ទើបលើកឡើងកាន់ត្រៃលក្ខណ៍ ដោយធ្វើទុកក្នុងចិត្តថា “រូបដែលប្រព្រឹត្តទៅក្នុងបឋមវ័យ ក៏រមែងរលត់ទៅវិញ ក្នុងបឋមវ័យហ្នឹងឯង មិនបានដល់មជ្ឈិមវ័យទេ, ព្រោះហេតុនោះ រូបដែលប្រព្រឹត្តទៅ ក្នុងបឋមវ័យនោះ ទើបឈ្មោះថា មិនទៀង, របស់ណា មិនទៀង របស់នោះ ឈ្មោះថា ជាទុក្ខ, របស់ណា ជាទុក្ខ របស់នោះ ក៏ឈ្មោះថា អនត្តា, រូបដែលប្រព្រឹត្តទៅ ក្នុងមជ្ឈិមវ័យសោត ក៏រលត់ទៅ ក្នុងមជ្ឈិមវ័យនោះឯង មិនបានដល់បច្ឆិមវ័យទេ, ព្រោះហេតុនោះ សូម្បីរូបដែលប្រព្រឹត្តទៅក្នុងមជ្ឈិមវ័យនោះ ក៏ឈ្មោះថា ជារបស់មិនទៀង ជាទុក្ខ ជាអនត្តា, សូម្បីរូបដែលប្រព្រឹត្តទៅ ៣៣ ឆ្នាំ ក្នុងបច្ឆិមវ័យ ឈ្មោះថា អាចនឹងប្រព្រឹត្តទៅ បន្ទាប់ពីមរណៈ ក៏មិនមានឡើយ, ព្រោះហេតុនោះ សូម្បីរូបដែលប្រព្រឹត្តទៅ ក្នុងបច្ឆិមវ័យនោះសោត ក៏ឈ្មោះថា មិនទៀង ជាទុក្ខ ជាអនត្តាដែរ” ដូច្នេះ ។

ព្រះយោគាវចរ លុះលើកឡើងកាន់ត្រៃលក្ខណ៍ ដោយការតាំងនៅមិនបាន នៃរូបដែលចំរើនឡើងតាមវ័យ ដោយអំណាចនៃវ័យ មានបឋមវ័យជាដើម យ៉ាងនេះហើយ លើកឡើងកាន់ត្រៃលក្ខណ៍ ដោយវយោវុឌ្ឍត្ថគមៈ ដោយអំណាចនៃទសកៈ ១០ នេះទៀត គឺ :

មន្ទទសកៈ ១០ ឆ្នាំ នៃវ័យក្មេងខ្ចី,
ខិឌ្ឌាទសកៈ ១០ ឆ្នាំ នៃការស្រវឹងនឹងល្បែង,
វណ្ណទសកៈ ១០ ឆ្នាំ នៃការបរិបូរណ៍ ដោយពណ៌សម្បុរ,
ពលទសកៈ ១០ ឆ្នាំ នៃការពោរពេញ ដោយកម្លាំងកាយ,



បញ្ញាទសកៈ ១០ ឆ្នាំ នៃការបរិបូរណ៍ ដោយប្រាជ្ញា,
ហានិទសកៈ ១០ ឆ្នាំ នៃវ័យដែលចុះថយ,
បព្ភារទសកៈ ១០ ឆ្នាំ នៃវ័យដែលចាស់គ្រាំគ្រាទ្រេតទ្រោត,
វង្កទសកៈ ១០ ឆ្នាំ នៃវ័យដែលចាស់កោងខ្នង,
មោមូហទសកៈ ១០ ឆ្នាំ នៃវ័យដែលវង្វេងវង្វល់ភ្លេចស្មារតី,
សយនទសកៈ ១០ ឆ្នាំ នៃវ័យដែលដេកនៅនឹងកន្លែង ។

ក្នុងទសកៈទាំង ១០ នោះ ១០ ឆ្នាំដំបូង នៃមនុស្សអ្នកមានអាយុ ១០០ ឆ្នាំ ឈ្មោះថា មន្ទទសកៈ មុនគេ ។ ព្រោះថា ក្នុងពេលនោះ បុគ្គលនោះ ជាក្មេង ដែលនៅទន់ខ្ចីធ្ងធ្ងា ។ ១០ ឆ្នាំ បន្ទាប់ពីនោះមកទៀត ឈ្មោះថា ខិឌ្ឌាទសកៈ ។ ព្រោះថា ក្នុងពេលនោះ បុគ្គលនោះ ជាអ្នកច្រើនទៅដោយការត្រេកអរ ក្នុងការលេងសប្បាយ ។ ១០ ឆ្នាំ បន្ទាប់ពីនោះមកទៀត ឈ្មោះថា វណ្ណទសកៈ ។ ព្រោះថា ក្នុងពេលនោះ ផ្នែកនៃពណ៌សម្បុរ នៃបុគ្គលនោះ រមែងដល់នូវការធាត់ធំបរិបូណ៌ ។ ១០ ឆ្នាំ បន្ទាប់ពីនោះមកទៀត ឈ្មោះថា ពលទសកៈ ។ ព្រោះថា ក្នុងពេលនោះ កម្លាំង និង ពលំ របស់បុគ្គលនោះ រមែងដល់នូវការពេញបរិបូរណ៍ ។ ១០ ឆ្នាំ បន្ទាប់អំពីនោះមកទៀត ឈ្មោះថា បញ្ញាទសកៈ ។ ព្រោះថា ក្នុងពេលនោះ បញ្ញា របស់បុគ្គលនោះ រមែងតាំងនៅមាំ ។ បានស្តាប់មកថា បញ្ញាសូម្បីបន្តិចបន្តួច របស់បុគ្គលដែលមានបញ្ញាអន់ថយ តាមប្រក្រតី ក៏កើតឡើង ក្នុងកាលនោះ បានដូចគ្នាដែរ ។ ១០ ឆ្នាំ បន្ទាប់អំពីនោះមកទៀត ឈ្មោះថា ហានិទសកៈ ។ ព្រោះថា ក្នុងពេលនោះ ការត្រេកអរ ក្នុងការលេងសប្បាយ, ពណ៌សម្បុរ, កម្លាំង និង ប្រាជ្ញា របស់បុគ្គលនោះ រមែង

សាបសូន្យ ។ ១០ ឆ្នាំបន្ទាប់ពីនោះមកទៀត ឈ្មោះថា បញ្ញាទសកៈ ។ ព្រោះថា ក្នុងពេលនោះ អត្តភាព របស់បុគ្គលនោះ រមែងទ្រេតទ្រោតទៅខាងមុខ ។ ១០ ឆ្នាំ បន្ទាប់ពីនោះមកទៀត ឈ្មោះថា វង្កទសកៈ ។ ព្រោះថា ក្នុងកាលនោះ អត្តភាព របស់បុគ្គលនោះកោង ដូចចុងកន្ទុយយាមនង្គ័ល ។ ១០ ឆ្នាំ បន្ទាប់ពីនោះមកទៀត ឈ្មោះថា មោមូហទសកៈ ។ ព្រោះថា ក្នុងពេលនោះ បុគ្គលនោះ រមែងវង្វេងវង្វន់ ភ្លេចភ្លាំងនូវកិច្ចការដែលខ្លួនធ្វើហើយៗ ។ ១០ ឆ្នាំ បន្ទាប់ពីនោះមកទៀត ឈ្មោះថា សយនទសកៈ ។ ព្រោះថា បុគ្គលដែលមានអាយុ ១០០ ឆ្នាំ ជាអ្នកច្រើនដោយការដេកហ្នឹងឯង ។

ព្រះយោគីរូបនោះ រមែងពិចារណា ពិចារណាពិនិត្យពិច័យ ដើម្បីលើកឡើងកាន់ត្រៃលក្ខណ៍ ដោយថា ជារបស់តាំងនៅមិនបាន នៃរូបដែលចំរើនឡើងតាមវ័យ ដោយអំណាចនៃទសកៈទាំងនេះ ក្នុងរូបនោះយ៉ាងនេះថា “រូបដែលប្រព្រឹត្តទៅ ក្នុងទសកៈដំបូង តែងរលត់ទៅ ក្នុងទសកៈដំបូងនោះឯង មិនដល់ទសកៈ ទី២ ទេ ព្រោះហេតុនោះ រូបដែលប្រព្រឹត្តទៅ ក្នុងទសកៈ ទី១ នោះ ទើបឈ្មោះថា មិនទៀង ជាទុក្ខ ជាអនត្តា, រូបដែលប្រព្រឹត្តទៅ ក្នុងទសកៈ ទី២ ។ល។ រូបដែលប្រព្រឹត្តទៅ ក្នុងទសកៈ ទី ៩ រមែងរលត់ទៅ ក្នុងទសកៈ ទី៩ នោះឯង មិនដល់ទសកៈ ទី១០ ទេ, រូបដែលប្រព្រឹត្តទៅ ក្នុងទសកៈ ទី ១០ រមែងរលត់ទៅ ក្នុងទសកៈ ទី១០ នេះឯង មិនដល់ភពថ្មីទេ ព្រោះហេតុនោះ សូម្បីរូបដែលប្រព្រឹត្តទៅក្នុងទសកៈ ទី១០ នោះសោត ក៏ឈ្មោះថា ជារបស់មិនទៀង ជាទុក្ខ ជាអនត្តា” ដូច្នេះ ។

ព្រះយោគីនោះលុះលើកឡើងកាន់ត្រៃលក្ខណ៍ ដោយវយោវុឌ្ឍត្ថ-



គមៈ ដោយអំណាចនៃទសកៈ ១០ យ៉ាងនេះហើយ ធ្វើ ១០០ ឆ្នាំនោះឯង ឲ្យទៅជា ២០ ចំណែក ដោយអំណាច (១ចំណែក) ៥ ឆ្នាំៗ ហើយលើកឡើងកាន់ត្រៃលក្ខណ៍ ដោយវយោវុឌ្ឍត្ថគមៈ ម្តងទៀត ។ លើកឡើងយ៉ាងដូចម្តេច? ។ គឺព្រះយោគីនោះ ពិចារណា យ៉ាងនេះថា “រូបដែលប្រព្រឹត្តទៅ ក្នុង ៥ ឆ្នាំ ដំបូង រមែងរលត់ទៅក្នុង ៥ ឆ្នាំ ដំបូងនោះឯង មិនដល់ ៥ ឆ្នាំទី២ ទេ ហេតុនោះ រូប ក្នុង ៥ ឆ្នាំដំបូងនោះ ឈ្មោះថា មិនទៀង ជាទុក្ខ ជាអនត្តា, រូបដែលប្រព្រឹត្តទៅក្នុង ៥ ឆ្នាំទី២ ក៏រលត់ទៅ ក្នុង ៥ ឆ្នាំទី២ នោះឯង មិនដល់ ៥ ឆ្នាំទី៣ ទេ ។ល។ រូបដែលប្រព្រឹត្តទៅ ក្នុង ៥ ឆ្នាំទី១៩ រមែងរលត់ទៅក្នុង ៥ ឆ្នាំ ទី១៩ នោះឯង មិនដល់ ៥ ឆ្នាំ ទី២០ ទេ, រូបដែលប្រព្រឹត្តទៅ ក្នុង ៥ ឆ្នាំ ទី២០ ឈ្មោះថា អាចប្រព្រឹត្តទៅបន្ទាប់ពីមរណៈ មិនមានឡើយ ព្រោះហេតុនោះ សូម្បីរូបដែលប្រព្រឹត្តទៅ ក្នុង ៥ ឆ្នាំ ទី ២០ នោះ ក៏ឈ្មោះថា មិនទៀង ជាទុក្ខ ជាអនត្តា” ដូច្នេះឯង ។

ព្រះយោគីលុះលើកឡើងកាន់ត្រៃលក្ខណ៍ ដោយវយោវុឌ្ឍត្ថគមៈ ដោយអំណាចនៃចំណែក ២០ យ៉ាងនេះហើយ ធ្វើ (១០០ឆ្នាំ) ឲ្យទៅជា ២៥ ចំណែក លើកឡើងដោយអំណាចនៃ(ចំណែក១ៗ) ៤ ឆ្នាំ បន្ថែមទៀត ។ ន័យដូចគ្នានោះដែរ ព្រះយោគីធ្វើឲ្យទៅជា៣៣ ចំណែក ដោយអំណាច(នៃចំណែក១ៗ) ៣ ឆ្នាំ ហើយធ្វើឲ្យទៅជា៥០ ចំណែក ដោយអំណាច(ចំណែក១ៗ) ២ ឆ្នាំ ហើយធ្វើឲ្យទៅជា១០០ ចំណែក លើកឡើងដោយអំណាច(នៃចំណែក១ៗ) ១ ឆ្នាំៗ ។ បន្ទាប់ពីនោះមក ព្រះយោគីនោះ ធ្វើ ១ ឆ្នាំៗ ឲ្យទៅជា ៣ ចំណែកហើយ លើកឡើងកាន់ត្រៃលក្ខណ៍ ក្នុងវយោវុឌ្ឍត្ថគមរូបនោះ ដោយអំណាចរដូវ ១ ៗ ក្នុង

រដូវទាំង ៣ គឺ រដូវភ្លៀង រដូវត្រជាក់ និង រដូវក្តៅ ។ លើកឡើងយ៉ាងដូចម្តេច? ។ គឺព្រះយោគីនោះ ពិចារណាឃើញ យ៉ាងនេះថា "រូបដែលប្រព្រឹត្តទៅអស់ ៤ ខែក្នុងរដូវភ្លៀង ក៏រលត់ទៅហើយក្នុងរដូវភ្លៀងនោះឯង មិនដល់នូវរដូវត្រជាក់ទេ, រូបដែលប្រព្រឹត្តទៅក្នុងរដូវត្រជាក់ ក៏រលត់ទៅហើយ ក្នុងរដូវត្រជាក់នោះឯង មិនដល់រដូវក្តៅទេ, រូបដែលប្រព្រឹត្តទៅក្នុងរដូវក្តៅ ក៏រលត់ទៅហើយ ក្នុងរដូវក្តៅនោះឯង មិនដល់រដូវភ្លៀងទៀតទេ ព្រោះហេតុនោះ រូបដែលប្រព្រឹត្តទៅ ៤ ខែ នោះឈ្មោះថា មិនទៀង ជាទុក្ខ ជាអនត្តា" ដូច្នេះ ។

ព្រះយោគី លុះលើកឡើង យ៉ាងនេះហើយ ធ្វើ១ ឆ្នាំ ឲ្យទៅជា ៦ ចំណែកទៀត ហើយលើកឡើងកាន់ត្រៃលក្ខណ៍ ក្នុងវយោវុឌ្ឍគ្គមរូបនោះ យ៉ាងនេះថា "រូប ដែលប្រព្រឹត្តទៅអស់ ២ ខែ ក្នុងរដូវភ្លៀងរលត់ទៅហើយ ក្នុងរដូវភ្លៀងនោះឯង មិនដល់សរទរដូវ (រដូវដែលមានខ្យល់ ភ្លៀង និង ទឹកសន្សើម)ទេ, រូបដែលប្រព្រឹត្តទៅ ២ ខែ ក្នុងសរទរដូវ រលត់ទៅហើយក្នុងសរទរដូវនោះឯង មិនដល់ហេមន្តរដូវទេ, រូបដែលប្រព្រឹត្តទៅក្នុងហេមន្តរដូវ រលត់ទៅហើយ ក្នុងហេមន្តរដូវនោះឯង មិនដល់សិសិររដូវ(រដូវរងារ)ទេ, រូបដែលប្រព្រឹត្តទៅ ២ ខែ ក្នុងសិសិររដូវ រលត់ទៅហើយក្នុងសិសិររដូវនោះឯង មិនដល់វស្សន្តរដូវទេ, រូបដែលប្រព្រឹត្តទៅ ក្នុងវស្សន្តរដូវ រលត់ហើយ ក្នុងវស្សន្តរដូវនោះឯង មិនដល់គិម្ហរដូវទេ, រូបដែលប្រព្រឹត្តទៅ ២ ខែ ក្នុងគិម្ហរដូវរលត់ទៅហើយ ក្នុងគិម្ហរដូវនោះឯង មិនដល់វស្សន្តរដូវទៀតទេ ព្រោះហេតុនោះ រូបនោះ ទើបឈ្មោះថា មិនទៀង ជាទុក្ខ ជាអនត្តា" ដូច្នេះ ។

ព្រះយោគី លុះលើកឡើង យ៉ាងនេះហើយ បន្ទាប់មក ក៏លើក



ឡើងកាន់ត្រៃលក្ខណ៍ ដោយអំណាចនៃរនោច និង ខ្នើត ថា "រូបដែលប្រព្រឹត្តទៅ ក្នុងកាឡបក្ស ក៏រលត់ទៅ ក្នុងកាឡបក្សនោះឯង មិនដល់ជុណ្ហបក្សទេ, រូបដែលប្រព្រឹត្តទៅក្នុងជុណ្ហបក្ស ក៏រលត់ទៅហើយ ក្នុងជុណ្ហបក្សនោះឯង មិនដល់កាឡបក្សទេ ព្រោះហេតុនោះ រូបនោះ ទើបឈ្មោះថា មិនទៀង ជាទុក្ខ ជាអនត្តា" ដូច្នេះ ។

បន្ទាប់ពីនោះ ព្រះយោគីនោះ ក៏លើកឡើងកាន់ត្រៃលក្ខណ៍ ដោយអំណាចនៃពេលរាត្រី និង ពេលថ្ងៃថា "រូបដែលប្រព្រឹត្តទៅ ក្នុងពេលរាត្រី រលត់វទៅហើយ ក្នុងពេលរាត្រីនោះឯង មិនដល់ពេលថ្ងៃទេ, សូម្បីរូបដែលប្រព្រឹត្តទៅ ក្នុងពេលថ្ងៃ ក៏រលត់ទៅហើយ ក្នុងពេលថ្ងៃនោះឯង មិនដល់ពេលរាត្រីទេ ព្រោះហេតុនោះ រូបនោះ ទើបឈ្មោះថា មិនទៀង ជាទុក្ខ ជាអនត្តា" ដូច្នេះ ។

បន្ទាប់ពីនោះមក ព្រះយោគីនោះ ធ្វើពេលយប់ និង ពេលថ្ងៃនោះឯង ឲ្យទៅជា ៦ ចំណែក ដោយអំណាចពេលវេលាមានពេលជិតភ្លឺជាដើម ហើយលើកឡើង កាន់ត្រៃលក្ខណ៍ថា "រូបដែលប្រព្រឹត្តទៅ ក្នុងពេលទៀបភ្លឺ ក៏រលត់ទៅហើយ ក្នុងពេលទៀបភ្លឺនោះឯង មិនដល់ថ្ងៃត្រង់ទេ, រូបដែលប្រព្រឹត្តទៅ ក្នុងពេលថ្ងៃត្រង់ ក៏រលត់ទៅហើយ ក្នុងពេលថ្ងៃត្រង់នោះឯង មិនដល់ពេលល្ងាចទេ, រូបដែលប្រព្រឹត្តទៅ ក្នុងពេលល្ងាច ក៏រលត់ទៅហើយ ក្នុងពេលល្ងាចនោះឯង មិនដល់យាមទី១ទេ, រូបដែលប្រព្រឹត្តទៅក្នុងយាមទី១ រលត់ទៅហើយ ក្នុងយាមទី១នោះឯង មិនដល់មជ្ឈិមយាមទេ, រូបដែលប្រព្រឹត្តទៅ ក្នុងមជ្ឈិមយាម ក៏រលត់ទៅហើយ ក្នុងមជ្ឈិមយាមនោះឯង មិនដល់បច្ឆិមយាមទេ, រូបដែលប្រព្រឹត្តទៅ ក្នុងបច្ឆិមយាម ក៏រលត់ទៅហើយ ក្នុងបច្ឆិមយាមនោះ

ឯង មិនដល់ពេលទៀបភ្លឺទៀតទេ ព្រោះហេតុនោះ រូបនោះ ទើបឈ្មោះថា មិនទៀង ជាទុក្ខ ជាអនត្តា” ដូច្នេះ ។

ព្រះយោគីនោះ លុះលើកឡើង យ៉ាងនេះហើយ ក៏លើកឡើងកាន់ត្រៃលក្ខណ៍ដោយអំណាចនៃការឈានទៅមុខ, ឈានថយក្រោយ, ក្រឡេកមើល, ងាកមើល, បត់ចូល និង ការលាតចេញ ក្នុងរូបនោះឯងទៀតថា “រូបដែលប្រព្រឹត្តទៅ ក្នុងការឈានទៅមុខ រមែងរលត់ទៅក្នុងការឈានទៅមុខនោះឯង មិនដល់ការឈានថយក្រោយទេ, រូបដែលប្រព្រឹត្តទៅក្នុងការឈានថយក្រោយ ក៏រលត់ទៅក្នុងការឈានថយក្រោយនោះឯង មិនដល់ការក្រឡេកមើលទេ, រូបដែលប្រព្រឹត្ត ក្នុងការក្រឡេកមើល ក៏រលត់ទៅ ក្នុងការក្រឡេកមើលនោះឯង មិនដល់ការងាកមើលទេ, រូបដែលប្រព្រឹត្តទៅ ក្នុងការងាកមើល ក៏រលត់ទៅក្នុងការងាកមើលនោះឯង មិនដល់ការបត់ចូលទេ, រូបដែលប្រព្រឹត្តទៅក្នុងការបត់ចូល ក៏រលត់ទៅក្នុងការបត់ចូលនោះឯង មិនដល់ការលាតចេញទេ ព្រោះហេតុនោះ រូបនោះ ទើបឈ្មោះថា មិនទៀង ជាទុក្ខ ជាអនត្តា” ដូច្នេះ ។

បន្ទាប់ពីនោះមក ព្រះយោគីនោះ ធ្វើចន្លាក់នៃជំហ៊ានជើង ១ ឲ្យទៅជា ៦ ដោយអំណាចនៃការលើកឡើង, ការឈាន, ការផ្លាស់ប្តូរ, ការដាក់ចុះ, ការជាន់ទុក និង ការទប់ ។ ក្នុងចំណែកទាំង៦ នោះ ការលើកជើងពីផែនដី ឈ្មោះថា ការលើកឡើង ។ ការយកជើងទៅដាក់ខាងមុខ ឈ្មោះថា ឈានចុះ ។ ការឃើញជន្លត់ឈើ, បន្លា និង ពស់ជាដើម ណាមួយ ភ្លាមហើយ ក៏ផ្លាស់ប្តូរជើង ទៅខាងនេះ ខាងនោះ ឈ្មោះថា ការផ្លាស់ប្តូរ ។ ការដាក់ជើងចុះក្រោម ឈ្មោះថា ការដាក់ចុះ



ការដាក់ជើងលើផែនដី ឈ្មោះថា ការជាន់ទុក, ការទប់ជើងជាប់ ជាមួយផែនដី ក្នុងពេលលើកជើង (មួយទៀត) ឈ្មោះថា ការទប់(ជើង) ។

បណ្តាចំណែកទាំង ៦ នោះ ក្នុងការលើក (ជើង) ធាតុ ២ គឺ : ធាតុដី ធាតុទឹក មានចំនួនទាប គឺ អន់ថយ, ធាតុ ២ ផ្សេងពីនោះ មានកម្រើកខ្ពស់ គឺមានកម្លាំងខ្លាំង ។ ក្នុងការឈាន និង ការផ្លាស់ប្តូរ ក៏យ៉ាងដូច្នោះដែរ ។ ក្នុងការដាក់ចុះ ធាតុ ២ គឺ: ធាតុភ្លើង ធាតុខ្យល់ មានកម្រិតទាប គឺអន់ថយ, ធាតុ ២ ក្រៅពីនេះ មានកម្រិតខ្ពស់ គឺមានកម្លាំងខ្លាំង ។ ក្នុងការជាន់ទុក និង ការទប់ ក៏ន័យដូចគ្នានោះដែរ ។

ព្រះយោគីនោះ លុះធ្វើឲ្យទៅជា ៦ ចំណែក យ៉ាងនេះហើយ ក៏លើកឡើងកាន់ត្រៃលក្ខណ៍ ក្នុងវយោវុឌ្ឍត្ថគមរូបនោះ ដោយអំណាចនៃចំណែកទាំង ៦ នោះ ។ លើកឡើងដូចម្តេច? ។ គឺព្រះយោគីនោះពិចារណាឃើញយ៉ាងនេះថា “ធាតុទាំងឡាយណា ដែលប្រព្រឹត្តទៅក្នុងការលើកឡើងក្តី ឧបាទាយរូបនៃធាតុទាំងនោះ ឯណាមួយក្តី, ធម៌ទាំងឡាយទាំងពួងនោះ តែងរលត់ទៅ ក្នុងការលើកឡើងនោះឯង មិនដល់ការឈានទេ ព្រោះហេតុនោះ ធម៌ទាំងឡាយនោះ ទើបឈ្មោះថា មិនទៀង ជាទុក្ខ ជាអនត្តា, ន័យដូចគ្នានោះដែរ ធម៌ទាំងឡាយ ដែលប្រព្រឹត្តទៅ ក្នុងការឈាន តែងរលត់ទៅ ក្នុងការឈាននោះឯង មិនដល់ការផ្លាស់ប្តូរទេ, ធម៌ទាំងឡាយដែលប្រព្រឹត្តទៅ ក្នុងការផ្លាស់ប្តូរ តែងរលត់ទៅក្នុងការផ្លាស់ប្តូរនោះឯង មិនដល់ការដាក់ចុះទេ, ធម៌ទាំងឡាយដែលប្រព្រឹត្តទៅ ក្នុងការដាក់ចុះ តែងរលត់ទៅ ក្នុងការដាក់ចុះនោះឯង មិនដល់ការជាន់ទុកទេ, ធម៌ទាំងឡាយដែលប្រព្រឹត្តទៅ ក្នុងការជាន់ទុក តែងរលត់ទៅ ក្នុងការជាន់ទុកនោះឯង មិនដល់នូវការទប់

ទេ, សង្ខារទាំងឡាយដែលកើតឡើង ក្នុងចំណែកនោះៗ រមែងបែកធ្លាយទៅ ក្នុងចំណែកនោះៗ ឯង ជាកង់ៗ ជាតំណៗ ជាដុំៗ មិនដល់ចំណែកក្រៅពីនេះៗ ទេ ប្រៀបដូចជាគ្រាប់ល្ង ដែលបុគ្គលដាក់លើខ្ទះដ៏ក្តៅ ក៏ផ្ទុះបែក ព្ធ តដះៗ យ៉ាងនោះឯង ព្រោះហេតុនោះ សង្ខារទាំងឡាយនោះ ទើបឈ្មោះថា មិនទៀង ជាទុក្ខ ជាអនត្តា” ដូច្នេះ ។

(ការពិចារណារូប)

កាលបើព្រះយោគីនោះ ឃើញច្បាស់នូវសង្ខារទាំងឡាយជាកង់ៗ យ៉ាងនោះ ការពិចារណារូប ជាធម្មជាត សុខុម ។ ក៏ក្នុងការពិចារណារូប ដ៏សុខុមនោះ មានសេចក្តីឧបមា ដូចតទៅនេះ គឺ :

បានឮមកថា: បុរសអ្នកនៅក្នុងជនបទម្នាក់ ជាអ្នកធ្លាប់កាន់គប់ភ្លើង មានគប់ឈើ និង គប់ស្មៅជាដើម មិនធ្លាប់បានឃើញនូវចង្កៀង មកដល់ទីក្រុង បានឃើញភ្លើងចង្កៀងដ៏ភ្លឺស្វាង ក្នុងចន្លោះទីផ្សារ ក៏សួរបុរសម្នាក់ថា “ម្នាលអ្នកដ៏ចំរើន! នុ៎ះគឺជាអ្វី? ជាទីពេញចិត្តយ៉ាងនេះ?” ដូច្នេះ ។ បុរសនោះ ប្រាប់រឿងនោះនឹងបុរសនោះថា “ក្នុងភ្លើងចង្កៀងនោះ តើមានអ្វីជាទីពេញចិត្ត, នោះ គេហៅថា ភ្លើងចង្កៀង ព្រោះការអស់ទៅនៃប្រេង និង ព្រោះការអស់ទៅនៃប្រឆេះ សូម្បីផ្លូវទៅ របស់ចង្កៀងនោះ នឹងមិនប្រាកដឡើយ” ។

បុរសម្នាក់ទៀត ប្រាប់បុរសនោះថា “ការមិនប្រាកដនៃភ្លើងប្រទីប ព្រោះការអស់ប្រេង និង ការអស់ប្រឆេះនេះ ជាធម្មជាតគ្រោតគ្រាតទេ, តាមពិត អណ្តាតភ្លើងនឹងរលត់ ក្នុងចំណែកទី៣ ៗ នៃប្រឆេះនេះ ដែលកំពុងតែឆេះ តាមលំដាប់មិនដល់ទីដទៃៗ ទៀតឡើយ” ដូច្នេះ ។

បុរសម្នាក់ទៀត ពន្យល់ប្រាប់បុរសនោះ ថា “សូម្បីការរលត់ទៅ



នៃអណ្តាតភ្លើង ក្នុងចំណែក ទី៣ ៗ នៃប្រឆេះនេះ ក៏ជាធម្មជាតគ្រោតគ្រាត, តាមពិត អណ្តាតភ្លើង នឹងរលត់ ក្នុងចន្លោះនៃអង្គុលី ១ ៗ នៃប្រឆេះនេះ មិនដល់ប្រទេសអង្គុលីផ្សេងៗពីនេះទេ, នឹងរលត់ក្នុងចន្លោះពាក់កណ្តាលអង្គុលី ១ ៗ នៃប្រឆេះនេះ មិនដល់ប្រទេសពាក់កណ្តាលអង្គុលីក្រៅៗ ពីនេះទេ, នឹងរលត់ក្នុងខ្សែអំបោះ ១ ៗ នៃប្រឆេះនេះ មិនដល់ខ្សែអំបោះផ្សេងៗ ទៀតទេ នឹងរលត់ ក្នុងសរសៃអំបោះ ១ ៗ នៃប្រឆេះនេះ មិនដល់សរសៃអំបោះផ្សេងៗ ទៀតទេ តែ(បើ)អស់សរសៃអំបោះហើយ អ្នកណាក៏មិនញ៉ាំងអណ្តាតភ្លើង ឲ្យប្រាកដបានឡើយ”,

ក្នុងពាក្យឧបមានោះ បណ្ឌិត គប្បីជ្រាបថា “ការលើកឡើងកាន់ត្រៃលក្ខណ៍ ក្នុងរូបដែលកំណត់យក ១០០ ឆ្នាំ ដោយការប្រកាន់មាំ និង ការកំណត់ទុកនៃព្រះយោគី ប្រៀបដូចជាការយល់ដឹង នៃបុរស ថា “សូម្បីផ្លូវទៅ នៃប្រទីប ក៏នឹងមិនប្រាកដ ព្រោះការអស់ទៅ នៃប្រេង និង ព្រោះការអស់ទៅ នៃប្រឆេះ” ដូច្នេះ,

ការលើកឡើងកាន់ត្រៃលក្ខណ៍ ក្នុងវយោវុឌ្ឍត្តគមរូប ដែលកំណត់យកជាចំណែក ទី ៣ ៗ នៃ ១០០ ឆ្នាំ របស់ព្រះយោគី ប្រៀបដូចជាការយល់ដឹង នៃបុរស ថា “អណ្តាតភ្លើង នឹងរលត់ ក្នុងចំណែក ទី ៣ ៗ នៃប្រឆេះ មិនដល់ប្រទេសផ្សេងៗ ពីនេះទេ” ដូច្នេះ,

ការលើកឡើងកាន់ត្រៃលក្ខណ៍ ក្នុងរូបដែលកំណត់យក ១០ ឆ្នាំ ៥ ឆ្នាំ, ៤ ឆ្នាំ, ៣ ឆ្នាំ, ២ ឆ្នាំ, ១ ឆ្នាំ នៃព្រះយោគី ប្រៀបដូចជាការយល់ដឹង របស់បុរស ថា “អណ្តាតភ្លើង នឹងរលត់ ក្នុងចន្លោះ នៃអង្គុលី ១ ៗ មិនដល់ចន្លោះ នៃអង្គុលីដទៃៗ ទៀតទេ” ដូច្នេះ,

ការលើកឡើងកាន់ត្រៃលក្ខណ៍ ក្នុងរូបដែលកំណត់យក ៤ ខែ ២

ខែ ព្រោះចែក ១ ឆ្នាំ ជា ៣ និង ៦ ចំណែក ដោយអំណាចនៃរដូវ ១ ៗ នៃព្រះយោគី ប្រៀបដូចជាការយល់ដឹងនៃបុរសថា "អណ្តាតភ្លើង នឹងរលត់ ក្នុងចន្លោះនៃពាក់កណ្តាលនៃអង្គុលី១ៗ មិនដល់ទីពាក់កណ្តាលនៃអង្គុលី ដទៃទៀតទេ" ដូច្នេះ,

ការលើកឡើងកាន់ត្រៃលក្ខណ៍ ក្នុងរូបដែលកំណត់យក ដោយអំណាចនៃរនោច និង ខ្នើត ដោយអំណាចយប់ និង ថ្ងៃ និង ដោយអំណាចចំណែកនៃថ្ងៃមានពេលព្រឹកជាដើម ព្រោះធ្វើយប់ និង ថ្ងៃ ១ ឲ្យទៅជា ៦ ចំណែក នៃព្រះយោគី ប្រៀបដូចជាការយល់ដឹង របស់បុរសថា "អណ្តាតភ្លើង នឹងរលត់ ក្នុងសរសៃអំបោះ ១ ៗ មិនដល់សរសៃអំបោះផ្សេងៗ ពីនេះទេ" ដូច្នេះ,

ការលើកឡើងកាន់ត្រៃលក្ខណ៍ ក្នុងរូបដែលកំណត់យក ដោយអំណាចអាការៈ ៦ មានការឈានជាដើម និង ដោយអំណាចនៃចំណែក ១ ៗ ក្នុងចំណោមនៃឥរិយាបថ ៦ មានការលើកឡើងជាដើម នៃព្រះយោគី ប្រៀបដូចជាការយល់ដឹង នៃបុរសថា "អណ្តាតភ្លើង នឹងរលត់ ក្នុងសរសៃអំបោះ១ ៗ មិនដល់សរសៃអំបោះផ្សេងៗ ទៀតទេ" ដូច្នេះ។

**(ការកំណត់ដោយអំណាចសមុដ្ឋាន ៤)**

(៤៣១) ព្រះយោគី លុះលើកឡើងកាន់ត្រៃលក្ខណ៍ ក្នុងវយោវុឌ្ឍត្ថគមរូប ដោយអាការៈផ្សេងៗ យ៉ាងនេះហើយ បំបែករូបនោះឯង ធ្វើឲ្យទៅជា៤ ចំណែក ដោយអំណាចសមុដ្ឋាន៤ មានអាហារមយរូបជាដើម ហើយលើកឡើងកាន់ត្រៃលក្ខណ៍ក្នុងចំណែក១ ៗ ម្តងទៀត ។

**(កំណត់ក្នុងអាហារមយរូប)**

ក្នុងរូបទាំង ៤ នោះ អាហារមយរូប រមែងប្រាកដដល់ព្រះយោគី



នោះ ដោយអំណាចនៃការអត់ឃ្លាន និង ការឆ្អែត ។ មែនពិត រូបដែលកើតឡើង ក្នុងពេលអត់ឃ្លាន ជារូបស្រពាប់ស្រពោន (ស្គម) នឿយលំបាក មានសម្បុរអាក្រក់ ខូចទ្រង់ទ្រាយ ដូចជាជន្លត់ឈើដែលត្រូវភ្លើងឆេះ និង ដូចជាសត្វឆ្អែតដែលអែបទំលើកញ្ជើ(កញ្ជ្រែង) នៃធ្យូង ដូច្នោះ ។ រូបដែលតាំងនៅព្រម ក្នុងពេលឆ្អែត ជារូបធាត់ធំ សមរម្យ ល្អ ទ្រលុកទ្រលន់ មានសម្ផស្ស ។

ព្រះយោគីនោះ កំណត់យកអាហារមយរូបនោះហើយ លើកឡើងកាន់ត្រៃលក្ខណ៍ ក្នុងរូបនោះ យ៉ាងនេះថា "រូប ដែលប្រព្រឹត្តទៅក្នុងពេលអត់ឃ្លាន រមែងរលត់ទៅ ក្នុងពេលអត់ឃ្លាននោះឯង មិនដល់ពេលឆ្អែតទេ, ឯរូបដែលកើតឡើង ក្នុងពេលឆ្អែត ក៏រលត់ទៅក្នុងពេលឆ្អែតនោះឯង មិនដល់ពេលអត់ឃ្លានទេ, ព្រោះហេតុនោះ សូម្បីអាហារមយរូបនោះ ទើបឈ្មោះថា មិនទៀង ជាទុក្ខ ជាអនត្តា" ដូច្នេះ ។

**(កំណត់ឧតុមយរូប)**

ឧតុមយរូប រមែងប្រាកដ ដោយអំណាចត្រជាក់ និង ក្តៅ ។ មែនពិត រូបដែលកើតឡើងក្នុងពេលក្តៅ ជារូបដែលស្វិតស្រពោន នឿយលំបាក មានសម្បុរដ៏អាក្រក់ ។ រូបដែលកើតឡើង ព្រោះរដូវត្រជាក់ ជារូបធាត់ធំ ល្អប្រណីត ទ្រលុកទ្រលន់ ។

ព្រះយោគីនោះ កំណត់ឧតុមយរូបនោះហើយ លើកឡើងកាន់ត្រៃលក្ខណ៍ ក្នុងឧតុមយរូបនោះ យ៉ាងនេះថា "រូបដែលប្រព្រឹត្តទៅក្នុងរដូវក្តៅ រមែងរលត់ក្នុងរដូវក្តៅនេះឯង មិនដល់រដូវត្រជាក់ទេ, រូបដែលប្រព្រឹត្តទៅក្នុងរដូវត្រជាក់ ក៏រលត់ទៅក្នុងរដូវត្រជាក់នេះឯង មិនដល់រដូវក្តៅទេ, ព្រោះហេតុនោះ ឧតុមយរូបនោះ ទើបឈ្មោះថា មិនទៀង

ជាទុក្ខ ជាអនត្តា” ដូច្នេះ ។

(កំណត់កម្មជរូប)

កម្មជរូប រមែងប្រាកដ ដោយអំណាចនៃទ្វារគឺអាយតនៈ ។ មែនពិត ក្នុងចក្ខុទ្វារ មានកម្មជរូប ៣០ ដោយអំណាចនៃចក្ខុទសកៈ, កាយទសកៈ និង ភាវទសកៈ, មួយទៀត រូប ២៤ (ទៀត) ដែលឧបត្ថម្ភកម្មជរូបទាំងនោះ មានរដូវ, ចិត្ត និង អាហារជាសមុដ្ឋាន ដូច្នោះ ទើបត្រូវជារូប ៥៤ ។ ក្នុងសោតទ្វារ, ឃានទ្វារ និង ជិវ្ហាទ្វារ ក៏យ៉ាងដូច្នោះដែរ ។ ក្នុងកាយទ្វារ មានរូប ៤៤ ដោយអំណាចនៃកាយទសកៈ និង ភាវទសកៈ និង ដោយអំណាចនៃរូបដែលជួយឧបត្ថម្ភ មានរូបដែលមានរដូវជាសមុដ្ឋានជាដើម ។ ក្នុងមនោទ្វារ មានរូប ៥៤ ដូចគ្នាដែរ ដោយអំណាចហទយវត្ថុទសកៈ, កាយទសកៈ, ភាវទសកៈ និង ដោយអំណាចនៃរូបដែលជួយឧបត្ថម្ភ មានឧតុសមុដ្ឋានរូបជាដើម ។

ព្រះយោគីនោះ ក៏កំណត់យករូបទាំងអស់នោះហើយ លើកឡើងកាន់ត្រៃលក្ខណ៍ ក្នុងរូបនោះ យ៉ាងនេះថា “រូប ដែលប្រព្រឹត្តទៅ ក្នុងចក្ខុទ្វារ រមែងរលត់ ក្នុងចក្ខុទ្វារនោះឯង មិនដល់សោតទ្វារទេ, រូបដែលប្រព្រឹត្តទៅក្នុងសោតទ្វារ រមែងរលត់ ក្នុងសោតទ្វារនេះឯង មិនដល់ឃានទ្វារទេ, រូបដែលប្រព្រឹត្តទៅ ក្នុងឃានទ្វារ រមែងរលត់ ក្នុងឃានទ្វារនេះឯង មិនដល់ជិវ្ហាទ្វារទេ, រូបដែលប្រព្រឹត្តទៅ ក្នុងជិវ្ហាទ្វារ រមែងរលត់ក្នុងជិវ្ហាទ្វារនោះឯង មិនដល់កាយទ្វារទេ, រូបដែលប្រព្រឹត្តទៅក្នុងកាយទ្វារ រមែងរលត់ ក្នុងកាយទ្វារនេះឯង មិនដល់មនោទ្វារទេ, ព្រោះហេតុនោះ ទើបឈ្មោះថា មិនទៀង ជាទុក្ខ ជាអនត្តា” ដូច្នេះ ។

(កំណត់ក្នុងចិត្តសមុដ្ឋានរូប)



រូប ដែលមានចិត្តជាសមុដ្ឋាន រមែងប្រាកដ ដោយអំណាចនៃសោមនស្សចិត្ត និង ទោមនស្សចិត្ត ។ មែនពិត រូប ដែលកើតឡើងក្នុងពេលដែលចិត្តរីករាយសប្បាយ ជារូបល្អិត ទន់ភ្លន់ ប្រណីត មានសម្ផស្ស ។ រូប ដែលកើតឡើង ក្នុងពេលដែលចិត្តមិនរីករាយ ជារូបស្វិតស្រពោន នឿយលំបាក មានរូបអាក្រក់ ។

ព្រះយោគីនោះ កំណត់យកចិត្តសមុដ្ឋានរូបនោះហើយ លើកឡើងកាន់ត្រៃលក្ខណ៍ ក្នុងរូបនោះ យ៉ាងនេះថា “រូប ដែលប្រព្រឹត្តទៅ ក្នុងពេលដែលចិត្តរីករាយ រមែងរលត់ទៅ ក្នុងពេលដែលចិត្តរីករាយសប្បាយនេះឯង មិនដល់ពេលដែលចិត្តកើតទុក្ខទេ, រូប ដែលប្រព្រឹត្តទៅ ក្នុងពេលដែលចិត្តកើតទុក្ខ រមែងរលត់ទៅ ក្នុងពេលដែលចិត្តកើតទុក្ខនេះឯង មិនដល់ពេលដែលចិត្តរីករាយសប្បាយទេ, ព្រោះហេតុនោះ សូម្បីចិត្តសមុដ្ឋានរូបនោះ ក៏ឈ្មោះថា មិនទៀង ជាទុក្ខ ជាអនត្តា” ដូច្នេះ ។

កាលបើព្រះយោគីនោះ កំណត់យករូបដែលមានចិត្តជាសមុដ្ឋានហើយ លើកឡើងកាន់ត្រៃលក្ខណ៍ ក្នុងរូបនោះ យ៉ាងដូច្នេះ, សេចក្តីនេះ នឹងប្រាកដជាក់ច្បាស់ ថា :

> ជីវិត, អត្តភាព, សុខ និង ទុក្ខទាំងអស់ [១] ប្រកប
> ដោយខណៈចិត្តតែមួយ ព្រោះខណៈប្រព្រឹត្តទៅ
> រហ័ស, ពួកទេវតាណា ឋិតនៅអស់ ៨៤ ពាន់
> កប្ប ទេវតាទាំងនោះ មិនមែនប្រកប ដោយចិត្ត ២

---

១- សុ. ខុ. មហា. ភាគទី ៦៨ ទំព័រទី ២២១ ។

ហើយរស់នៅទេ, ខន្ធទាំងឡាយណា របស់បុគ្គល ដែលស្លាប់ទៅក្តី រស់នៅក្តី រលត់ហើយ ក្នុងលោក នេះ, ខន្ធទាំងអស់នោះក៏ដូចគ្នា ទៅបដិសន្ធិទៀត មិនបាន ខន្ធទាំងឡាយណា ដែលកន្លងទៅជាលំដាប់ បែកធ្លាយហើយផង ខន្ធទាំងឡាយណា ជា អនាគត នឹងបែកធ្លាយទៅផង, សេចក្តីផ្សេងគ្នា នៃខន្ធទាំងឡាយ ជាបច្ចុប្បន្ន ដែលរលត់ហើយ ក្នុងចន្លោះ នៃខន្ធទាំង ២ នោះ រមែងមិនមាន ក្នុង លក្ខណៈ, សត្វលោក ដែលកើតហើយ ដោយ អនាគតក្ខន្ធ ដែលមិនទាន់កើត មិនឈ្មោះថា រស់ នៅ ហើយទាំងមិនឈ្មោះថា កំពុងរស់នៅ ក្នុង ខន្ធជាបច្ចុប្បន្នទេ, សត្វលោក ស្លាប់ ដោយការ បែកធ្លាយនៃចិត្ត (នេះជា) បញ្ញត្តិ នៃបរមត្ថ, ការ ប្រែប្រួលទៅ ដោយឆន្ទៈ ដូចទីទាប រមែងប្រព្រឹត្ត ទៅដូច្នោះ, វេទនាទាំងឡាយ មានសឡាយតនៈ ជាបច្ច័យ មានវារៈ មិនដាច់ តែងប្រព្រឹត្តទៅ, ខន្ធ ទាំងឡាយដែលបែកធ្លាយហើយ ក៏មិនដល់នូវការ កំណត់ទុក, គំនរនៃខន្ធ ក្នុងអនាគត ក៏មិនមាន, ខន្ធទាំងឡាយដែលកើតឡើងហើយ រមែងឋិតនៅ ដូចគ្រាប់ស្នែ ដែលឋិតនៅលើចុងដែកស្រួច កាល បើខន្ធទាំងឡាយ កើតឡើងហើយ ការបែកធ្លាយ



នៃខន្ធទាំងនោះ ក៏ឋិតនៅខាងមុខ សភាវៈដែលត្រូវ វិនាសទាំងឡាយ (ខន្ធ) កំពុងឋិតនៅ មិនច្រឡូក ច្រឡំ ដោយខន្ធចាស់ទេ រមែងមកអំពីទីមើលមិន ឃើញ លុះបែកធ្លាយហើយ តែងទៅកាន់ទីមើល មិនឃើញវិញ រមែងកើតឡើងផង រមែងវិនាស ទៅផង ដូចជាផ្លេកបន្ទោរ ក្នុងអាកាស ។

(រូបធម្មតា)

*(៤៣២) ព្រះយោគីនោះ លុះលើកឡើងកាន់ត្រៃលក្ខណ៍ ក្នុងរូប ទាំងឡាយ មានអាហារមយរូបជាដើម យ៉ាងនេះហើយ លើកឡើងកាន់ ត្រៃលក្ខណ៍ ក្នុងរូបធម្មតា ទៀត ។*

*រូបដែលកើតឡើង ចាប់តាំងពីវិវដ្តកប្ប មានប្រភេទដូចដែក, លោហៈ, សំណ, សំណកក់, មាស, ប្រាក់, កែវមុក្តា, កែវមណី, កែវពៃទូរ្យ, ស័ង្ខ, សីលា, កែវប្រពាល, កែវទទឹម, កែវពព្រុះ, ផែនដី, ថ្ម, ភ្នំ, ស្មៅ, ដើមឈើ និង វល្លិ៍ជាដើម ដែលជារូបខាងក្រៅ មិនជាប់ ទាក់ទងនឹងឥន្ទ្រិយ៍ ឈ្មោះថា ធម្មតារូប ។ ធម្មតារូបនោះ តែងប្រាកដ ដល់ព្រះយោគីនោះ ដោយអំណាចនៃចុង នៃដើមអសោកជាដើម ។ មែនពិត ចុងដើមអសោកនោះ ដំបូង ឡើងជាធម្មជាត ក្រហមព្រឿងៗ បន្ទាប់ពីនោះមក ២-៣ ថ្ងៃ ក៏ក្រហមក្រម៉ៅ តមកទៀត ២-៣ ថ្ងៃ ក៏ ក្រហមខ្ចី បន្តមកទៀត ក៏មានពណ៌ដូចស្លឹកឈើខ្ចី ទើបតែនឹងលាស់ បន្ទាប់មក មានពណ៌ខ្ចីប្រម៉ៅបន្តិច បន្ទាប់មកទៀត ក៏មានពណ៌ខៀវខ្ចី*

ខៀវរាងចាស់នោះហើយ ក៏ធ្វើការតគ្នានៃរូប ដែលស្មើគ្នា ឲ្យជាប់ទាក់ទងជាមួយគ្នា ដោយពេលប្រមាណ ១ ឆ្នាំ ទើបទៅជាស្លឹកពណ៌លឿងរបេះចេញពីទងហើយ ក៏ជ្រុះធ្លាក់ចុះមក ។

ព្រះយោគីនោះ កំណត់យកស្លឹកអសោកនោះហើយ លើកឡើងកាន់ត្រៃលក្ខណ៍ ក្នុងធម្មតារូបនោះ យ៉ាងនេះថា “រូប ដែលប្រព្រឹត្តទៅក្នុងពេលដែលមានពណ៌ក្រហមព្រឿងៗ រមែងរលត់ទៅ មិនដល់ពេលដែលវាមានពណ៌ក្រហមក្រម៉ៅទេ, រូប ដែលប្រព្រឹត្តទៅ ក្នុងពេលដែលមានពណ៌ក្រហមរាងក្រម៉ៅ ក៏តែងរលត់ទៅ មិនដល់ពេលដែលវាមានពណ៌ក្រហមខ្ចីទេ, រូប ដែលប្រព្រឹត្តទៅ ក្នុងពេលដែលវាមានពណ៌ក្រហមខ្ចី ក៏រលត់ទៅ មិនដល់ពេលដែលវាមានពណ៌ ដូចស្លឹកឈើខ្ចីទើបនឹងលាស់ទេ, រូបដែលប្រព្រឹត្តទៅ ក្នុងពេលមានពណ៌ដូចស្លឹកឈើខ្ចីទើបនឹងលាស់ថ្មី ក៏រលត់ទៅ មិនដល់ពេលដែលវាមានពណ៌ខ្ចីរាងក្រម៉ៅទេ, រូបដែលប្រព្រឹត្តទៅក្នុងពេលដែលមានពណ៌ខ្ចីរាងក្រម៉ៅ ក៏រលត់ទៅ មិនដល់ពេលដែលមានពណ៌ខៀវខ្ចីទេ, រូបដែលប្រព្រឹត្តទៅក្នុងពេលមានពណ៌ខៀវខ្ចី ក៏រលត់ទៅ មិនដល់ពេលដែលវាមានពណ៌ខៀវរាងក្រម៉ៅទេ, រូបដែលប្រព្រឹត្តទៅ ក្នុងពេលដែលវាមានពណ៌ខៀវក្រម៉ៅ ក៏រលត់ទៅ មិនដល់ពេលដែលមានពណ៌លឿងទេ, រូបដែលប្រព្រឹត្តទៅ ក្នុងពេលដែលមានពណ៌លឿង ក៏រលត់ទៅ មិនដល់ពេលដែលវារបេះចេញពីទងហើយ ជ្រុះធ្លាក់ចុះទេ, ព្រោះហេតុនោះ រូបនោះ ទើបឈ្មោះថា មិនទៀង ជាទុក្ខ ជាអនត្តា” ដូច្នេះហើយ ពិចារណាធម្មតារូបទាំងអស់នោះ ដោយន័យនេះចុះ ។

ព្រះយោគី ពិចារណាសង្ខារទាំងឡាយលើកឡើងកាន់ត្រៃលក្ខណ៍



ដោយអំណាចនៃសត្តករូប ដូចពោលមកនេះឯង ជាមុនសិន ។

(៤៣៣) ចំណែកពាក្យឯណា ដែលខ្ញុំពោលហើយថា “ដោយអំណាចនៃអរូបសត្តកៈ” ដូច្នេះ, នេះ ជាមាតិកា ក្នុងពាក្យនោះ គឺ :

កលាបតោ ព្រោះជាកលាប,
យមកតោ ព្រោះជាគូ,
ខណិកតោ ព្រោះជាខណៈ,
បដិបាដិតោ ព្រោះជាលំដាប់,
ទិដ្ឋិឧគ្ឃាដនតោ ព្រោះដកចេញនូវទិដ្ឋិ,
មានសមុគ្ឃាដនតោ ព្រោះដកចេញនូវមានះ,
និកន្តិបរិយាទានតោ ព្រោះគ្របសង្កត់នូវសេចក្តីត្រេកអរបាន ។

(កលាបតោ)

ក្នុង ៧ យ៉ាងនោះ ពាក្យថា “កលាបតោ” គប្បីជ្រាបអធិប្បាយដូចតទៅ: ធម៌ទាំងឡាយ មានផស្សៈជាគម្រប់ ៥ ។ ពិចារណាដោយកលាបតើដូចម្តេច? ។ ភិក្ខុក្នុងធម្មវិន័យនេះ ពិចារណាឃើញយ៉ាងនេះថា “ធម៌ទាំងឡាយណា មានផស្សៈ ជាគម្រប់ ៥ កើតឡើង ក្នុងការពិចារណាថា: សក់ទាំងឡាយ មិនទៀង ជាទុក្ខ ជាអនត្តា ដូច្នេះ, និងធម៌ទាំងឡាយណា មានផស្សៈជាគម្រប់ ៥ កើតឡើងក្នុងការពិចារណាថា : រោមទាំងឡាយ ។ល។ ខួរក្បាល មិនទៀង ជាទុក្ខ ជាអនត្តា, ធម៌ទាំងអស់នោះ វិនាសទៅជាកង់ ជាកំណាត់ មិនដល់ធម្មជាត ក្រៅអំពីនេះទេ ប្រៀបដូចជាគ្រាប់ល្ង ដែលបុគ្គលបោះទៅលើខ្ទះ ដែលក្តៅបែក ព្រូសូរ តដៈៗ ដូច្នោះ ព្រោះហេតុនោះ ធម៌ទាំងឡាយនោះ ទើបឈ្មោះថា មិនទៀង ជាទុក្ខ ជាអនត្តា” ដូច្នេះ ។

នេះ គឺគ្រាន់តែជាន័យ ក្នុងវិសុទ្ធិកថា ជាដំបូងទេ ។

ចំណែកក្នុងអរិយវំសកថា លោកពោលថា "ព្រះយោគី កាលពិចារណានូវចិត្តដែលប្រព្រឹត្តទៅថា: រូប ក្នុងឋាន: ៧ ក្នុងរូបសត្តក: ពួដ៏ខាងក្រោម មិនទៀង ជាទុក្ខ ជាអនត្តា ដូច្នេះ ដោយចិត្តដទៃទៀតថា: ចិត្តខាងដើមនោះ ក៏មិនទៀង ជាទុក្ខ ជាអនត្តា ដូច្នេះ ឈ្មោះថាពិចារណា ដោយកលាប" ។ ពាក្យដែលពោលហើយក្នុងអរិយវំសកថា សមគួរជាង ។ ព្រោះហេតុនោះ ទើបយើងនឹងចំណែកពាក្យដែលនៅសេសសល់ ដោយន័យនេះដូចគ្នា ។

(យមកតោ)

ពាក្យថា "យមកតោ" សេចក្ដីថា : ភិក្ខុ ក្នុងព្រះធម្មវិន័យនេះ ពិចារណារូបដែល(ខ្លួន)ប្រកាន់មាំ និង រូបដែល(ខ្លួន)ទម្លាក់ចោល ថា "មិនទៀង ជាទុក្ខ ជាអនត្តា" ដូច្នេះហើយ ពិចារណាចិត្តនោះថែមទៀត ដោយចិត្តដទៃទៀតថា "ចិត្តនោះ ក៏មិនទៀង ជាទុក្ខ ជាអនត្តា" ដូច្នេះ ។ ព្រះយោគីនោះពិចារណាវយោវុឌ្ឍត្ថគមរូប អាហារមយរូប ឧតុមយរូប កម្មជរូប ចិត្តសមុដ្ឋានរូប ធម្មតារូប ថា "មិនទៀង ជាទុក្ខ ជាអនត្តា" ដូច្នេះហើយ ពិចារណាចិត្តនោះថែមទៀត ដោយចិត្តដទៃទៀតថា "ចិត្តនោះ ក៏មិនទៀង ជាទុក្ខ ជាអនត្តា"ដូច្នេះ ឈ្មោះថា ពិចារណាថាជាគូ ។

(ខណិកតោ)

ពាក្យថា "ខណិកតោ" សេចក្ដីថា ភិក្ខុក្នុងធម្មវិន័យនេះ ពិចារណារូបដែល(ខ្លួន)ប្រកាន់មាំ និង រូបដែល(ខ្លួន)ទំលាក់ចោលថា "មិនទៀង ជាទុក្ខ ជាអនត្តា" ដូច្នេះហើយ ពិចារណាចិត្ត ទី១ នោះ ដោយចិត្ត ទី២ ថា "សូម្បីចិត្ត ទី១ នោះ ក៏មិនទៀង ជាទុក្ខ ជាអនត្តា.... ពិចារណាចិត្ត



ទី២ ដោយចិត្ត ទី៣... ពិចារណាចិត្ត ទី៣ ដោយចិត្ត ទី៤... ពិចារណាចិត្តទី៤ ដោយចិត្តទី៥ ថា "សូម្បីចិត្តទី២... ចិត្តទី៣... ចិត្តទី៤ នោះ ក៏មិនទៀង ជាទុក្ខជា អនត្តា" ដូច្នេះ ។ ភិក្ខុពិចារណាវយោវុឌ្ឍត្ថគមរូប អាហារមយរូប ឧតុមយរូប កម្មជរូប ចិត្តសមុដ្ឋានរូប ធម្មតារូប ថា "មិនទៀង ជាទុក្ខ ជាអនត្តា" ដូច្នេះហើយ ពិចារណាចិត្តទី១ នោះ ដោយចិត្តទី២... ពិចារណាចិត្តទី២ ដោយចិត្តទី៣... ពិចារណាចិត្តទី៣ ដោយចិត្តទី៤... ពិចារណាចិត្តទី៤ ដោយចិត្តទី៥ ថា "សូម្បីចិត្តទី១... ចិត្តទី២...ចិត្តទី៣...ចិត្តទី៤ នុ៎ះ ក៏មិនទៀង ជាទុក្ខ ជាអនត្តា" ដូច្នេះ ។ ភិក្ខុ កាលពិចារណាចិត្ត (ម្ដង) ៤ ៗ តាំងតែអំពីចិត្តដែលកំណត់រូបជាអារម្មណ៍ ដូចពោលមកនេះ ឈ្មោះថា ពិចារណាថា ជាខណ: ។

(បដិបាដិតោ)

ពាក្យថា "បដិបាដិតោ" សេចក្ដីថា ភិក្ខុ ពិចារណាអាទាននិក្ខេបរូប ថា "មិនទៀង ជាទុក្ខ ជាអនត្តា" ដូច្នេះហើយ ពិចារណាចិត្តទី១ នោះ ដោយចិត្តទី២... ពិចារណាចិត្តទី២ ដោយចិត្តទី៣... ពិចារណាចិត្តទី៣ ដោយចិត្តទី៤ ។ល។ ពិចារណាចិត្តទី១០ ដោយចិត្តទី១១ ថា "សូម្បីចិត្តទី១ ។ល។ ចិត្តទី១០ នុ៎ះ ក៏មិនទៀង ជាទុក្ខ ជាអនត្តា" ដូច្នេះ ។ ភិក្ខុពិចារណាវយោវុឌ្ឍត្ថគមរូប អាហារមយរូប ឧតុមយរូប កម្មជរូប ចិត្តសមុដ្ឋានរូប ធម្មតារូប ថា "មិនទៀង ជាទុក្ខ ជាអនត្តា" ដូច្នេះហើយ ពិចារណាចិត្តទី១ នោះ ដោយចិត្តទី២... ពិចារណាចិត្តទី២ ដោយចិត្តទី៣ ។ល។ ពិចារណាចចិត្តទី១០ ដោយចិត្តទី១១ ថា "សូម្បីចិត្តទី១ ។ល។ ចិត្តទី១០ នុ៎ះ ក៏មិនទៀង ជាទុក្ខ ជាអនត្តា" ដូច្នេះ ។ គួរពិចារណា ទៅតាមលំដាប់នៃវិបស្សនា យ៉ាងនេះ រហូត

អស់ ១ ថ្ងៃក៏បាន ។ ប៉ុន្តែព្រោះត្រឹមតែពិចារណាចិត្តទី១០ រូបកម្មដ្ឋានក្តី អរូបកម្មដ្ឋានក្តី ជាធម្មជាត គឺខ្លួនធ្វើឲ្យស្ទាត់ជំនាញហើយ ។ ហេតុនោះ ទើបលោកពោលថា “គប្បីឈប់ ក្នុងចិត្តទី១០ នោះចុះ” ដូច្នេះ ។ ភិក្ខុពិចារណាដូចបានពោលមកនេះ ឈ្មោះថា ពិចារណាតាមលំដាប់ ។

(ទិដ្ឋិឧគ្ឃាដនះតោ)

ឈ្មោះថា ន័យសំរាប់ពិចារណាផ្សេងៗ គ្នា ក្នុង ៣ បទថា “ទិដ្ឋិ-ឧគ្ឃាដនតោ មានសមុគ្ឃាដនតោ និកន្តិបរិយាទានតោ” នេះមិនមានទេ ។ មែនពិត រូប ឮដ៏ខាងក្រោមនេះឯណាក្តី អរូបដែលកំណត់យកក្នុងទីនេះក្តី ព្រះយោគី កាលឃើញរូប និង អរូបនោះ តែងមិនឃើញវត្ថុដទៃដែលឈ្មោះថា សត្វ ក្រៅអំពីរូប និង អរូបទេ ។ ចាប់តាំងតែពីមិនឃើញសត្វមក សត្តសញ្ញា ក៏បានដកចេញហើយ ។ កាលព្រះយោគីកំណត់យកសង្ខារ ដោយចិត្តដែលដកចេញ នូវសត្តសញ្ញាបានហើយ ទិដ្ឋិ ក៏កើតឡើងមិនបាន ។ កាលបើទិដ្ឋិ កើតឡើងមិនបាន ទិដ្ឋិក៏ឈ្មោះថា បានដកចេញហើយ ។ កាលព្រះយោគី កំណត់យកសង្ខារដោយចិត្តដែលដកនូវទិដ្ឋិបានហើយ មានះ ក៏កើតពុំបាន ។ កាលបើមានះ មិនកើតឡើង មានះ ក៏ឈ្មោះថា (ខ្លួន) បានដកចេញហើយ ។ កាលព្រះយោគី កំណត់សង្ខារ ដោយចិត្តដែលដកមានះចេញបានហើយ តណ្ហា ក៏មិនកើតឡើង កាលបើតណ្ហា មិនកើតឡើង សេចក្តីត្រេកអរក៏ឈ្មោះថា ត្រូវបានគ្រប់គ្រងហើយ ។ ពាក្យត្រឹមនេះឯង ជាពាក្យដែលបានពោលហើយ ក្នុងវិសុទ្ធិកថា ។

ចំណែកក្នុងអរិយវំសកថា លោកតាំងមាតិកាថា “ទិដ្ឋិឧគ្ឃាដនតោ មានសមុគ្ឃាដនតោ និកន្តិបរិយាទានតោ” ដូច្នេះហើយ សំដែងន័យ



យ៉ាងនេះ ថា :

ក៏កាលព្រះយោគី ប្រកាន់យកថា “អាត្មាអញឃើញច្បាស់, ការឃើញច្បាស់ របស់អាត្មាអញ” ដូច្នេះ មិនឈ្មោះថា ដកទិដ្ឋិចេញទេ, តែព្រះយោគី ប្រកាន់យកថា “សង្ខារទាំងឡាយហ្នឹងឯង ឃើញច្បាស់នូវសង្ខារទាំងឡាយ សង្ខារទាំងឡាយហ្នឹងឯង ពិចារណា... ស្ទាបស្ទង់... កំណត់យក... កំណត់កាត់នូវសង្ខារទាំងឡាយ” ដូច្នេះ ទើបឈ្មោះថា ដកនូវទិដ្ឋិចេញបាន, កាលព្រះយោគី ប្រកាន់យកថា “អាត្មាអញ ឃើញច្បាស់ដោយល្អ អាត្មាអញ ឃើញច្បាស់ គួរជាទីពេញចិត្ត” ដូច្នេះ មិនឈ្មោះថា ដកមានះបានទេ, តែកាលបើព្រះយោគីប្រកាន់យកថា “សង្ខារទាំងឡាយហ្នឹងឯង ឃើញច្បាស់នូវសង្ខារទាំងឡាយ, សង្ខារទាំងឡាយហ្នឹងឯង ពិចារណា... ស្ទាបស្ទង់... កំណត់យក កំណត់កាត់នូវសង្ខារទាំងឡាយ” ដូច្នេះ ទើបឈ្មោះថា ដកមានះចេញបាន, កាលព្រះយោគីពេញចិត្តនឹងវិបស្សនា ដោយគិតថា “អាត្មាអញ អាចឃើញច្បាស់បាន” ដូច្នេះ មិនឈ្មោះថា គ្របសង្កត់សេចក្តីត្រេកអរបានទេ, ប៉ុន្តែកាលព្រះយោគីប្រកាន់យកថា “សង្ខារទាំងឡាយហ្នឹងឯង ឃើញច្បាស់នូវសង្ខារទាំងឡាយ, សង្ខារទាំងឡាយហ្នឹងឯង ពិចារណា... ស្ទាបស្ទង់... កំណត់យក... កំណត់កាត់ នូវសង្ខារទាំងឡាយ” ដូច្នេះ ទើបឈ្មោះថា គ្របសង្កត់សេចក្តីត្រេកអរបាន,

កាលព្រះយោគី ឃើញថា “ប្រសិនបើសង្ខារទាំងឡាយ ជាអត្តានឹងកំណត់យកថាៈ សង្ខារទាំងឡាយ ជាអត្តា ដូច្នេះ ក៏សមគួរ, តែសង្ខារទាំងឡាយ មិនមែនជាអត្តា ទេ (បែរជា) ប្រកាន់ថា “ជាអត្តា” ដូច្នេះ (ទៅវិញ) ព្រោះហេតុនោះ សង្ខារទាំងឡាយនោះ ទើបឈ្មោះថា

ជាអនត្តា ព្រោះសេចក្តីថា មិនប្រព្រឹត្តទៅ ក្នុងអំណាច (អ្នកណាមួយ) ឡើយ ឈ្មោះថា មិនទៀង ព្រោះសេចក្តីថា មានហើយ ត្រឡប់ទៅជា មិនមានទៅវិញ ឈ្មោះថា ជាទុក្ខ ព្រោះសេចក្តីថា ត្រូវការកើត និង ការរលត់ទៅវិញ បៀតបៀន” ដូច្នេះ ទើបឈ្មោះថា ដកទិដ្ឋិចេញបាន, កាលព្រះយោគី ឃើញថា “ប្រសិនបើសង្ខារទាំងឡាយ គប្បីជារបស់ទៀង នឹងកំណត់យកថា “សង្ខារទាំងឡាយនោះ ជារបស់ទៀង” ដូច្នេះ ក៏សមគួរ, ប៉ុន្តែសង្ខារទាំងឡាយ មិនទៀងសោះឡើយ (ទៅជា) ប្រកាន់យកថា “សង្ខារទាំងឡាយ ជារបស់ទៀង” ដូច្នេះ(វិញ) ព្រោះហេតុនោះ សង្ខារទាំងឡាយនោះ ទើបឈ្មោះថា ជារបស់មិនទៀង ព្រោះសេចក្តីថា មានហើយ បែរទៅជាមិនមានទៅវិញ ឈ្មោះថា ជាទុក្ខ ព្រោះសេចក្តីថា ត្រូវការកើតឡើង និង ការរលត់ទៅវិញ បៀតបៀន ឈ្មោះថា ជាអនត្តា ព្រោះសេចក្តីថា មិនប្រព្រឹត្តទៅ ក្នុងអំណាច (អ្នកណាមួយ) ឡើយ” ដូច្នេះ ទើបឈ្មោះថា ដកនូវមានះចេញបាន, កាលព្រះយោគី ឃើញថា “ប្រសិនបើសង្ខារទាំងឡាយ គប្បីជាសុខ នឹងប្រកាន់យកថា “សង្ខារទាំងឡាយជាសុខ” ដូច្នេះ ក៏សមគួរ, ក៏ប៉ុន្តែសង្ខារទាំងឡាយ ជាទុក្ខ មែនពិត (បែរទៅជា) ប្រកាន់យក ថា“ សង្ខារទាំងឡាយ ជាសុខ” ដូច្នេះ (វិញ) ព្រោះហេតុនោះ សង្ខារទាំងឡាយនោះ ឈ្មោះថា ជាទុក្ខ ព្រោះសេចក្តីថា ត្រូវការកើតឡើង និង ការរលត់ទៅវិញ បៀតបៀន ឈ្មោះថា មិនទៀង ព្រោះសេចក្តីថា មានហើយ បែរជាមិនមានទៅវិញ ឈ្មោះថា អនត្តា ព្រោះសេចក្តីថា មិនប្រព្រឹត្តទៅក្នុងអំណាច (នៃអ្នកណាមួយ) ឡើយ” ដូច្នេះ ទើបបានឈ្មោះថា គ្របសង្កត់សេចក្តីត្រេកអរបាន ។



ឈ្មោះថា ការដកនូវទិដ្ឋិ រមែងមានដល់ព្រះយោគីអ្នកឃើញ នូវសង្ខារទាំងឡាយថា ជារបស់មិនមែនខ្លួន ឈ្មោះថា ការដកនូវមានះ រមែងមាន ដល់ព្រះយោគីអ្នកឃើញ នូវសង្ខារទាំងឡាយថា ជារបស់មិនទៀង ឈ្មោះថា ការគ្របសង្កត់នូវសេចក្តីត្រេកអរ រមែងមានដល់ព្រះយោគីអ្នកឃើញ នូវសង្ខារទាំងឡាយថា ជាទុក្ខ ដូចបានពណ៌នាមកនោះហើយ, ដូច្នេះ វិបស្សនានេះ ទើបឈ្មោះថា តាំងនៅ ក្នុងឋានៈរបស់ខ្លួនៗ មែនពិត ដូច្នេះឯង ។

ព្រះយោគីពិចារណាសង្ខារទាំងឡាយលើកឡើងកាន់ត្រៃលក្ខណ៍ ដោយអំណាចនៃអរូបសត្តកៈ ដូចពណ៌នាមកនេះឯង ។

ក៏ដោយការវនានុយោគ មានប្រមាណប៉ុណ្ណេះ រូបកម្មដ្ឋានក្តី អរូបកម្មដ្ឋានក្តី របស់ព្រះយោគីនោះ ជាធម្មជាត ច្បាស់លាស់ហើយ ។

(មហាវិបស្សនា ១៨)

(៤៣៤) ព្រះយោគីដែលមានរូបកម្មដ្ឋាន និង អរូបកម្មដ្ឋាន ច្បាស់លាស់ យ៉ាងនេះហើយនោះ មហាវិបស្សនា(គឺអនុបស្សនា) ១៨ ឯណា ដែលខ្លួនគប្បីបានសំរេច ដោយប្រការទាំងពួង ដោយអំណាចបហានបរិញ្ញា ចាប់តាំងពីកង្ខានុបស្សនាញាណ ខាងដើមទៅ កាលចាក់ធ្លុះ នូវចំណែកមួយ នៃមហាវិបស្សនាទាំងនោះ ក្នុងញាណជាគ្រឿងពិចារណា (សម្មសនញាណ) នេះឯង ដំបូង រមែងលះបង់នូវបដិបក្ខធម៌ នៃមហាវិបស្សនានោះបាន ។

បញ្ញា មានអនិច្ចានុបស្សនាជាដើម ឈ្មោះថា មហាវិបស្សនា ១៨ ។ ក្នុងអនុបស្សនាទាំងឡាយណា ព្រះយោគី កាលចំរើនអនិច្ចានុបស្សនា រមែងលះបង់នូវនិច្ចសញ្ញាបាន កាលចំរើននូវទុក្ខានុបស្សនា

រមែងលះបង់នូវសុខសញ្ញា កាលចំរើនអនត្តានុបស្សនា រមែងលះបង់នូវអត្តសញ្ញា កាលចំរើននិព្វិទានុបស្សនា រមែងលះបង់នូវនន្ទិគឺសេចក្តីត្រេកអរ កាលចំរើនវិរាគានុបស្សនា រមែងលះបង់នូវរាគៈ កាលចំរើននិរោធានុបស្សនា រមែងលះបង់នូវសមុទយៈ កាលចំរើនបដិនិស្សគ្គា-នុបស្សនា រមែងលះបង់នូវសេចក្តីប្រកាន់ កាលចំរើនខយានុបស្សនា រមែងលះបង់នូវឃនសញ្ញា (ការសំគាល់ថា ជារបស់ជាប់លាប់រឹងប៉ឹង) កាលចំរើនវយានុបស្សនា រមែងលះបង់ នូវសេចក្តីព្យាយាម កាលចំរើនវិបរិណាមានុបស្សនា (បញ្ញាពិចារណាឃើញការប្រែប្រួល) រមែងលះបង់នូវធុវសញ្ញា (ការសំគាល់ថា ជារបស់គង់វង់) កាលចំរើនអនិមិត្តានុបស្សនា រមែងលះបង់ នូវនិមិត្ត កាលចំរើនអប្បណិហិតា-នុបស្សនា (បញ្ញាពិចារណាឃើញថា ជារបស់មិនគួរប្រាថ្នា) រមែងលះបង់នូវសេចក្តីប្រាថ្នា កាលចំរើនសុញ្ញតានុបស្សនា (បញ្ញាពិចារណាឃើញថា ជារបស់សោះសូន្យ) រមែងលះបង់នូវការប្រកាន់ថា ជាខ្លួនប្រាណ កាលចំរើនអធិប្បញ្ញាធម្មវិបស្សនា (បញ្ញាឃើញជាក់ច្បាស់ក្នុងធម៌ដែលជាអធិបញ្ញា) រមែងលះបង់នូវការប្រកាន់មាំ ដោយអំណាចការប្រកាន់ថា មានសារៈ កាលចំរើនយថាភូតញ្ញាណទស្សនៈ (ការដឹងការឃើញ តាមសភាពពិត) រមែងលះបង់នូវការប្រកាន់មាំដោយអំណាចនៃការភ្លេចស្មារតី កាលចំរើនអាទីនវានុបស្សនា (បញ្ញាពិចារណាឃើញថា ជាទោស) រមែងលះបង់នូវការប្រកាន់មាំ ដោយអំណាចសេចក្តីត្រេកអររឿយៗ កាលចំរើនបដិសង្ខានុបស្សនា (បញ្ញាពិចារណាឃើញផ្លូវដែលរួចស្រឡះ) រមែងលះបង់នូវការមិនត្រិះរកផ្លូវរួចស្រឡះ កាលចំរើនវិវដ្ដានុបស្សនា (បញ្ញា ពិចារណាឃើញនូវផ្លូវ



រួចផុតពីវដ្ដៈ) រមែងលះបង់ការប្រកាន់មាំ ដោយអំណាចសំយោជនៈ ។

ក្នុងមហាវិបស្សនា ១៨ នេះ អនិច្ចានុបស្សនា ទុក្ខានុបស្សនា និង អនត្តានុបស្សនា ឈ្មោះថា គឺព្រះយោគីនោះ បានចាក់ធ្លុះហើយ ព្រោះហេតុដែលលោកឃើញនូវសង្ខារទាំងឡាយ ដោយអំណាចត្រៃលក្ខណ៍មានអនិច្ចលក្ខណៈជាដើម ។ មួយទៀត ព្រោះហេតុដែលលោកពោលថា "អនិច្ចានុបស្សនាឯណាក្តី អនិមិត្តានុបស្សនាឯណាក្តី ធម៌ទាំងនោះមានសេចក្តីតែមួយ ផ្សេងគ្នាតែព្យញ្ជនៈប៉ុណ្ណោះទេ, ន័យដូចគ្នានោះដែរ ទុក្ខានុបស្សនាឯណាក្តី អប្បណិហិតានុបស្សនាឯណាក្តី ធម៌ទាំងនេះមានសេចក្តីតែមួយ ផ្សេងគ្នាតែព្យញ្ជនៈប៉ុណ្ណោះទេ, អនត្តានុបស្សនាឯណាក្តី សុញ្ញតានុបស្សនាឯណាក្តី ធម៌ទាំងនេះ មានសេចក្តីតែមួយ ផ្សេងគ្នាតែព្យញ្ជនៈប៉ុណ្ណោះឯង" ដូច្នេះ ព្រោះហេតុនោះ សូម្បីអនិមិត្តា-នុបស្សនា អប្បណិហិតានុបស្សនា និង សុញ្ញតានុបស្សនាទាំងនោះ ជាធម៌ដែលព្រះយោគីនេះ បានសម្រេចហើយ ។ ចំណែកឯអធិប្បញ្ញា-ធម្មវិបស្សនា បានដល់វិបស្សនាទាំងពួង, យថាភូតញ្ញាណទស្សនៈ ក៏សង្គ្រោះចូលក្នុងកង្ខាវិតរណវិសុទ្ធិហ្នឹងឯង ហេតុនោះ សូម្បីអធិប្ប-ញ្ញាធម្មវិបស្សនា និង យថាភូតញ្ញាណទស្សនៈ ទាំងពីរនេះឯង ក៏ជាធម៌ដែលព្រះយោគីនេះ បានសម្រេចហើយដូចគ្នាដែរ ។ ក្នុងវិបស្សនាញាណទាំងឡាយ ដ៏សេស វិបស្សនាញាណខ្លះ ព្រះយោគីបានចាក់ធ្លុះហើយ វិបស្សនាញាណខ្លះ ព្រះយោគីមិនទាន់បានចាក់ធ្លុះទេ, យើងនឹងអធិប្បាយពង្រីកវិភាគ នៃវិបស្សនាញាណទាំងនោះ ឲ្យបានច្បាស់លាស់ បន្តទៅខាងមុខទៀត ។ ក៏ពាក្យដែលថា "ព្រះយោគីរូបនោះជាអ្នកមានរូបកម្មដ្ឋាន និង អរូបកម្មដ្ឋាន ស្ទាត់ជំនាញហើយ យ៉ាងនេះ,

មហាវិបស្សនា ១៨ ឯណា ដែលព្រះយោគី គប្បីបាន ដោយអាការៈទាំងពួង ដោយអំណាចបហានបរិញ្ញា ចាប់តាំងពីភង្គានុបស្សនា ខាងដើម, ព្រះយោគី កាលចាក់ធ្លុះនូវចំណែកមួយ នៃមហាវិបស្សនាទាំងនោះ ក្នុងសម្មសនញាណនេះឯង ដំបូង ក៏រមែងលះនូវបដិបក្ខធម៌ នៃមហាវិបស្សនាទាំងនោះបាន" ដូច្នេះនេះ ខ្ញុំពោលសំដៅយកវិបស្សនាញាណ ដែលព្រះយោគីនេះ បានចាក់ធ្លុះហើយនោះឯង ។

(ឧទយព្វយានុបស្សនាញាណ)

(៤៣៥) ព្រះយោគីនោះ ជាអ្នកមានញាណដ៏បរិសុទ្ធ ព្រោះលះនូវនិច្ចសញ្ញាជាដើម ដែលជាបដិបក្ខធម៌នៃវិបស្សនា មានអនិច្ចានុបស្សនាជាដើម ដល់ត្រើយនៃសម្មសនញាណ យ៉ាងនេះហើយក៏ផ្ដើមធ្វើសេចក្ដីព្យាយាម ដើម្បីបានសម្រេច នូវឧទយព្វយានុបស្សនាញាណ ដែលលោកពោលហើយ ក្នុងលំដាប់នៃសម្មសនញ្ញាណថា "បញ្ញា [១] ក្នុងការឃើញនូវការប្រែប្រួលនៃពួកធម៌ជាបច្ចុប្បន្ន ឈ្មោះថា ឧទយព្វយានុបស្សនាញាណ (ញាណក្នុងការឃើញនូវការកើតឡើង និង ការសូន្យទៅ)" ដូច្នេះ, ក៏កាលផ្ដើមធ្វើ រមែងចាប់ផ្ដើមធ្វើ ដោយសង្ខេប ជាមុនសិន ។ នេះ គឺជាបាលី ក្នុងការផ្ដើមធ្វើ ដោយសង្ខេបនោះ "សួរថា : បញ្ញា ក្នុងការឃើញនូវការប្រែប្រួលនៃពួកធម៌ដែលជាបច្ចុប្បន្ន ឈ្មោះថា ឧទយព្វយានុបស្សនាញាណ តើដូចម្ដេច?, (ឆ្លើយថា:) រូប ដែលជាបច្ចុប្បន្ន កើតហើយ, ការចំរើនឡើងនៃរូបនោះ ជាលក្ខណៈ នៃការកើត, ការសូន្យទៅ ជាលក្ខណៈនៃការប្រែប្រួល ឈ្មោះថា អនុបស្សនាញាណ, វេទនា កើតហើយ, សញ្ញា កើតហើយ, សង្ខារ កើតហើយ,

១- សុ. ខុ. បដិ. ភាគទី ៦៩ ទំព័រ ១២៩ បន្ទាត់ទី៨ ។



វិញ្ញាណ កើតហើយ, ចក្ខុ កើតហើយ ។ល។ ភពជាបច្ចុប្បន្ន កើតហើយ, ការចំរើនឡើងនៃភពនោះ ជាលក្ខណៈនៃការកើត, ការសូន្យទៅ ជាលក្ខណៈនៃការប្រែប្រួល ឈ្មោះថា អនុបស្សនាញាណ" ។

ព្រះយោគីនោះ សំឡឹងឃើញនូវលក្ខណៈ នៃការកើត គឺជាតិការកើតឡើង អាការៈដែលថ្មីស្រឡាង នៃនាមរូបដែលកើតហើយ ថា "ជាការកើតឡើង" សំឡឹងឃើញលក្ខណៈ នៃការប្រែប្រួលទៅ គឺការអស់ទៅ ការរលត់ទៅ នៃនាមរូបដែលកើតហើយថា "ជាការសូន្យទៅ" ដូច្នេះ តាមន័យក្នុងបាលីនេះ ។ ព្រះយោគីនោះ រមែងដឹងច្បាស់ យ៉ាងនេះថា "ក្នុងកាលខាងដើមនៃការកើតឡើង នៃនាមរូបនេះ គំនរ ឬ ប្រជុំនៃនាមរូបដែលមិនទាន់កើតឡើងហើយ មិនមានទេ, ឈ្មោះថា ការមកពីគំនរ ឬ ប្រជុំនៃនាមរូបដែលកំពុងកើតឡើង ក៏មិនមានដែរ, ឈ្មោះថា ការទៅកាន់ទិសតូច-ធំ នៃនាមរូបដែលកំពុងតែរលត់ ក៏មិនមានដែរ, ឈ្មោះថា ការរួមចុះថា ជាគំនរ ជាទីប្រជុំ ជាអណ្ដូង ក្នុងទីតែមួយ នៃនាមរូប ដែលរលត់ទៅហើយ ក៏មិនមានឡើយ ប្រៀបឧបមាបីដូចជាកាលបើពិណ គឺបុគ្គលកំពុងដេញ ប្រជុំនៃសំឡេងដែលកើតឡើង មិនមែនមាន ក្នុងកាលមុនពីការកើតឡើងទេ, សំឡេងដែលកំពុងតែកើតឡើង ក៏មិនបានមកពីការប្រជុំដែរ, ការទៅកាន់ទិសតូច-ធំ នៃសំឡេងដែលកំពុងរលត់ ក៏មិនមាន, វារលត់ទៅហើយ ក៏មិនបានស្ថិតនៅរួមផ្ដុំក្នុងទីណាមួយឡើយ ។ តាមពិត សំឡេងពិណនោះ មិនមានហើយ រមែងកើតមាន ព្រោះអាស្រ័យពិណ ស្បែកសំរាប់ដាស់ស្នូកពិណ និងសេចក្ដីព្យាយាម ដែលសមគួរដល់ហេតុនោះ របស់បុរស, លុះមានហើយ ក៏ត្រឡប់ជាបាត់ទៅវិញ យ៉ាងណាមិញ ។ ធម៌ទាំងឡាយដែល

មានរូប និង មិនមានរូបទាំងអស់ មិនមានហើយក៏មាន, លុះមានហើយក៏ត្រឡប់ជារលត់ទៅវិញ យ៉ាងដូច្នោះឯង” ។

ព្រះយោគីនោះ លុះធ្វើនូវការធ្វើទុកក្នុងចិត្ត នូវការកើតឡើង និងការរលត់ទៅ ដោយសង្ខេប យ៉ាងនេះហើយ ទើបធ្វើនូវការធ្វើទុកក្នុងចិត្ត យ៉ាងពិស្តារ ដោយបច្ច័យ និង ខណៈ ម្តងទៀតថា “លក្ខណៈទាំងឡាយ ៥០ ឯណា ដែលលោកពោលហើយ ក្នុងវិភង្គនៃឧទយព្វយ-ញ្ញាណនុ៎ះឯង ដោយធ្វើទៅជា ១០ ៗ ព្រោះឃើញការកើតឡើង និងការរលត់ទៅវិញ នៃខន្ធមួយៗ យ៉ាងនេះថា: បុគ្គល [១] ឃើញនូវការចំរើនឡើងនៃរូបក្ខន្ធ ដោយអត្ថថា កើតឡើងនៃបច្ច័យថា “ការកើតឡើងនៃរូប ព្រោះកើតឡើងនៃអវិជ្ជា ១” ដូច្នេះ, ឃើញការកើតឡើងនៃរូបក្ខន្ធ ដោយអត្ថថា កើតឡើងនៃបច្ច័យថា “ការកើតឡើងនៃរូប ព្រោះកើតឡើងនៃតណ្ហា ១... ព្រោះការកើតឡើងនៃកម្ម ១... ព្រោះការកើតឡើងនៃអាហារ ១” ដូច្នេះ, មួយទៀត បុគ្គលកាលឃើញនូវលក្ខណៈនៃការកើត ឈ្មោះថា ឃើញនូវការចំរើនឡើងនៃរូបក្ខន្ធ, បុគ្គលកាលឃើញនូវការចំរើនឡើងនៃរូបក្ខន្ធ ឈ្មោះថា ឃើញនូវលក្ខណៈទាំង ៥ នេះ, បុគ្គលឃើញនូវការសូន្យទៅនៃរូបក្ខន្ធ ដោយអត្ថថា រលត់ទៅ នៃបច្ច័យថា “ ការរលត់ទៅនៃរូប ព្រោះរលត់ទៅនៃអវិជ្ជា ១ ” ឃើញនូវការសូន្យទៅនៃរូបក្ខន្ធ ដោយអត្ថថា រលត់ទៅនៃបច្ច័យថា “ការរលត់ទៅនៃរូបព្រោះរលត់ទៅនៃតណ្ហា ១ ...ព្រោះរលត់ទៅនៃកម្ម ១ ...ព្រោះរលត់ទៅនៃអាហារ ១” ដូច្នេះ, មួយទៀត បុគ្គលកាលឃើញលក្ខណៈដែលប្រែប្រួល ឈ្មោះថា ឃើញនូវការសូន្យទៅ នៃរូបក្ខន្ធ ១” បុគ្គល

១- សុ. ខុ. បដិ. ភាគទី ៦៩ ទំព័រ ១២៥ បន្ទាត់ទី ២ ។



កាលឃើញការសូន្យទៅ នៃរូបក្ខន្ធ ឈ្មោះថា រមែងឃើញនូវលក្ខណៈទាំង ៥,

ន័យដូចគ្នានោះដែរ បុគ្គលឃើញនូវការចំរើនឡើង នៃវេទនាខន្ធ ដោយអត្ថថា កើតឡើងនៃបច្ច័យថា “ការកើតឡើងនៃវេទនា ព្រោះកើតឡើងនៃអវិជ្ជា១” ឃើញនូវការចំរើនឡើងនៃវេទនាខន្ធ ដោយអត្ថថា កើតឡើងនៃបច្ច័យថា “ការកើតឡើងនៃវេទនា ព្រោះកើតឡើងនៃតណ្ហា ១... ព្រោះកើតឡើងនៃកម្ម ១... ព្រោះកើតឡើងនៃផស្សៈ ១” មួយទៀត បុគ្គលឃើញលក្ខណៈកើតឡើង ឈ្មោះថា ឃើញនូវការកើតឡើងនៃវេទនាខន្ធ ១, បុគ្គលកាលឃើញនូវការចំរើនឡើង នៃវេទ-នាខន្ធ រមែងឃើញនូវលក្ខណៈទាំង ៥ នេះ, បុគ្គលឃើញនូវការសូន្យទៅ នៃវេទនាខន្ធ ដោយអត្ថថា រលត់ទៅនៃបច្ច័យថា “ការរលត់ទៅនៃវេទនា ព្រោះរលត់ទៅនៃអវិជ្ជា ១... ព្រោះរលត់ទៅនៃតណ្ហា ១... ព្រោះរលត់ទៅនៃកម្ម១... ព្រោះរលត់ទៅ នៃផស្សៈ ១” មួយទៀត បុគ្គលកាលឃើញនូវលក្ខណៈប្រែប្រួល ឈ្មោះថា ឃើញនូវការសូន្យទៅនៃវេទនាខន្ធ ១, បុគ្គលកាលឃើញនូវការសូន្យទៅនៃវេទនាខន្ធ រមែងឃើញនូវលក្ខណៈទាំង ៥ នេះ, ក៏ចំពោះសញ្ញាខន្ធ, សង្ខារក្ខន្ធ និងវិញ្ញាណក្ខន្ធ ក៏ដូចគ្នានឹងវេទនាខន្ធដែរ, ចំណែកឯសេចក្តីនេះជាសេចក្តីផ្សេងគ្នា នៃវិញ្ញាណក្ខន្ធ គឺប្រែកបពាក្យថា “ព្រោះការកើតឡើង នៃនាមរូប ព្រោះការរលត់ទៅ នៃនាមរូប ក្នុងទីនៃពាក្យថា “ផស្សៈ” ដូច្នេះ, ការកើតឡើងនៃរូប តែងមានយ៉ាងនេះខ្វះ, ការសូន្យទៅនៃរូប តែងមានយ៉ាងនេះខ្វះ, រូប រមែងកើតឡើងយ៉ាងនេះខ្វះ, រូប រមែងរលត់ទៅវិញយ៉ាងនេះខ្វះ ដោយអំណាចនៃលក្ខណៈទាំងឡាយនោះ” ដូច្នេះ ។

កាលព្រះយោគីនោះធ្វើទុកក្នុងចិត្តយ៉ាងនេះ, ញាណថា “ធម៌ទាំងឡាយនេះមិនមានហើយ ក៏កើតមានវិញ លុះមានហើយ ក៏ត្រឡប់ជាវលត់ទៅវិញ យ៉ាងនេះឯង” ដូច្នេះ រមែងប្រាកដច្បាស់ឡើង ។

កាលបើព្រះយោគីនោះ ឃើញនូវការកើតឡើង និង ការសូន្យទៅដោយចំណែក ២ គឺដោយបច្ច័យ ១ ដោយខណៈ ១ យ៉ាងនេះ សេចក្តីផ្សេងគ្នានៃសច្ចៈ, បដិច្ចសមុប្បាទ, ន័យ និង លក្ខណៈ រមែងប្រាកដ ។ ក៏ព្រះយោគីនោះ ឃើញនូវការកើតឡើង នៃខន្ធទាំងឡាយ ព្រោះការកើតឡើងនៃបច្ច័យមានអវិជ្ជាជាដើម និង ការរលត់ទៅនៃខន្ធទាំងឡាយព្រោះការរលត់ទៅនៃបច្ច័យ មានអវិជ្ជាជាដើមឯណា នេះ ជាការឃើញនូវការកើតឡើង និង ការរលត់ទៅព្រោះបច្ច័យ របស់ព្រះយោគីនោះ ។ តែកាលព្រះយោគីឃើញ នូវលក្ខណៈកើតឡើង និង លក្ខណៈប្រែប្រួលទៅ ទើបឈ្មោះថា ឃើញនូវការកើតឡើង និង ការអស់ទៅនៃខន្ធទាំងឡាយឯណា នេះជាការឃើញនូវការកើតឡើង និង ការសូន្យទៅ ព្រោះខណៈ របស់ព្រះយោគីនោះ ។ ព្រោះថា លក្ខណៈដែលកើតរមែងមាន ក្នុងឧប្បត្តិខណៈប៉ុណ្ណោះ និង លក្ខណៈប្រែប្រួល រមែងមានក្នុងភង្គខណៈ ។

(ការជាក់ច្បាស់នៃសច្ចៈ)

ព្រោះហេតុនេះ កាលបើព្រះយោគីនោះ ឃើញនូវការកើតឡើង និង ការសូន្យទៅដោយចំណែក ២ គឺ ដោយសច្ចៈ ១ ដោយខណៈ ១ យ៉ាងនេះ សមុទយសច្ចៈ រមែងប្រាកដ ព្រោះឃើញនូវការកើតឡើងព្រោះបច្ច័យ, ទុក្ខសច្ចៈ រមែងប្រាកដ ព្រោះការឃើញនូវការកើតឡើងព្រោះខណៈ ព្រោះដឹងនូវបច្ច័យដែលជាអ្នកឲ្យកើត, និរោធសច្ចៈ រមែង



ប្រាកដ ព្រោះឃើញនូវការរលត់ ព្រោះបច្ច័យ ព្រោះដឹងនូវជាតិទុក្ខ, ទុក្ខសច្ចៈ រមែងប្រាកដ ម្តងទៀត ព្រោះឃើញនូវការរលត់ទៅ ព្រោះខណៈ ព្រោះដឹងនូវការមិនកើតឡើង នៃវត្ថុដែលមានបច្ច័យ ព្រោះការមិនកើតឡើងនៃបច្ច័យ ព្រោះដឹងនូវមរណទុក្ខ ។ ចំណែកការឃើញនូវការកើតឡើង និង ការសូន្យទៅ របស់ព្រះយោគីនោះឯណា នេះ គឺជាលោកិយមគ្គ ព្រោះហេតុនោះ មគ្គសច្ចៈ រមែងប្រាកដ ព្រោះកំចាត់បង់នូវសម្មោហៈ (ការវង្វេងព្រម) ក្នុងមគ្គនោះបាន ។

(ការប្រាកដនៃបដិច្ចសមុប្បាទ និង បដិច្ចសមុប្បន្នធម៌)

មួយទៀត ព្រោះឃើញនូវការកើតឡើង ព្រោះបច្ច័យ បដិច្ច-សមុប្បាទ ដែលជាអនុលោម រមែងប្រាកដ ដល់ព្រះយោគីនោះ ព្រោះដឹងថា “កាលបើរបស់នេះ មាន, របស់នេះ ទើបមាន” ដូច្នេះ ។ ព្រោះការឃើញនូវការសូន្យទៅ ព្រោះបច្ច័យ បដិច្ចសមុប្បាទ ដែលជាបដិ-លោម រមែងប្រាកដ ព្រោះដឹងថា “ព្រោះការរលត់នូវរបស់នេះ ទើបរបស់នេះរលត់” ដូច្នេះ ។ តែព្រោះការឃើញ នូវការកើតឡើង និង ការសូន្យទៅ ព្រោះខណៈ បដិច្ចសមុប្បន្នធម៌ទាំងឡាយ រមែងប្រាកដ ព្រោះដឹងនូវសង្ខតលក្ខណៈ ។ ព្រោះថា ធម៌ទាំងឡាយដែលមានការកើតឡើង និង ការសូន្យទៅ ជាសង្ខតធម៌ និង សង្ខតធម៌ទាំងនោះជាបដិច្ចសមុប្បន្នធម៌ ។

(ន័យទាំង ៤ ប្រាកដ)

មួយទៀត ព្រោះការឃើញ នូវការកើតឡើង ព្រោះបច្ច័យ ឯកត្តន័យ រមែងប្រាកដ ដល់ព្រះយោគីនោះ ព្រោះដឹងនូវការមិនដាច់វយៈ នៃសន្តាន ព្រោះការជាប់ទាក់ទងគ្នានៃហេតុ និង ផល ។ ដូច្នោះ

ព្រះយោគីនោះ លះបង់នូវឧច្ឆេទទិដ្ឋិ បានយ៉ាងល្អប្រសើរ ។ ព្រោះការឃើញនូវការកើតឡើង ព្រោះខណៈ នានត្តន័យ រមែងប្រាកដ ព្រោះដឹងនូវការកើតឡើងនៃរបស់ដែលថ្មីៗ ។ ដូច្នោះ ព្រះយោគីនោះ រមែងលះបង់នូវសស្សតទិដ្ឋិ បានយ៉ាងល្អប្រសើរ ។ មួយទៀត ព្រោះការឃើញនូវការកើតឡើង និង ការសូន្យទៅ ព្រោះបច្ច័យ, អព្យាបារន័យ រមែងប្រាកដ ដល់ព្រះយោគីនោះ ព្រោះដឹងនូវភាវៈនៃធម៌ទាំងឡាយ មានសភាពមិនប្រព្រឹត្តទៅក្នុងអំណាច ។ ដូច្នោះ ព្រះយោគីនោះ រមែងលះបង់នូវអត្តទិដ្ឋិ បានយ៉ាងល្អប្រសើរ ។ មួយទៀត ព្រោះការឃើញនូវការកើតឡើង ព្រោះបច្ច័យ ឯវំធម្មតាន័យ រមែងប្រាកដ ព្រោះដឹងនូវការកើតឡើងនៃផល តាមសមគួរដល់បច្ច័យ ។ ដូច្នោះ ព្រះយោគី រមែងលះបង់នូវអកិរិយទិដ្ឋិ បានយ៉ាងល្អប្រសើរ ។

(ការប្រាកដនៃលក្ខណៈ)

មួយវិញទៀត ព្រោះការឃើញនូវការកើតឡើង ព្រោះបច្ច័យ លក្ខណៈ រមែងប្រាកដដល់ព្រះយោគីនោះ ព្រោះដឹងនូវភាវៈនៃធម៌ទាំងឡាយ មានការប្រព្រឹត្តិទៅជាប់ទាក់ទងគ្នាជាមួយនឹងបច្ច័យ ដោយមិនមានភ្នាំងភ្នាត់ ។ ព្រោះការឃើញ នូវការកើតឡើង និង ការសូន្យទៅ ព្រោះខណៈ អនិច្ចលក្ខណៈ រមែងប្រាកដ (ដល់ព្រះយោគីនោះ) ព្រោះដឹងនូវភាវៈនៃធម៌ទាំងឡាយមានហើយ (បែរជា) មិនមាន(ទៅវិញ) និង ព្រោះដឹងនូវការសោះសូន្យទៅ (នៃសង្ខារធម៌ទាំងឡាយ) ទាំងខាងដើម ទាំងខាងចុង ។ ទុក្ខលក្ខណៈសោត ក៏រមែងប្រាកដ ព្រោះដឹងនូវការបៀតបៀន ព្រោះការកើតឡើង និង ការសូន្យទៅ ។ សូម្បីសភាវ-លក្ខណៈ ក៏រមែងប្រាកដ ព្រោះដឹងថា ជាធម៌កំណត់ ដោយការកើត



ឡើង និង ការសូន្យទៅ ។ សូម្បីការដែលសង្ខតលក្ខណៈ ប្រព្រឹត្តទៅតាមកាល ក៏រមែងប្រាកដ ក្នុងសភាវលក្ខណៈ ព្រោះដឹងនូវការមិនមាននៃការសូន្យទៅ ក្នុងលក្ខណៈដែលកើត និង នៃការកើតឡើង ក្នុងលក្ខណៈដែលសូន្យទៅ ដូច្នេះឯង ។

សង្ខារទាំងឡាយ រមែងប្រាកដជារបស់ថ្មីជានិច្ច ដល់ព្រះយោគីនោះ ជាអ្នកមានប្រភេទនៃសច្ចៈ, បដិច្ចសមុប្បាទ, ន័យ និង លក្ខណៈ ដែលកើតប្រាកដហើយ យ៉ាងនោះ ព្រោះដឹងថា “ធម្មតាធម៌ទាំងឡាយនេះ មិនមែនមិនធ្លាប់កើត ក៏កើតឡើងនោះទេ តែធម៌ទាំងឡាយនេះកើតឡើងហើយ ក៏រលត់ទៅវិញ” ដូច្នេះ ។ មួយទៀត ធម៌ទាំងឡាយនេះ មិនមែនប្រាកដជារបស់ថ្មី ជាប់ជានិច្ចតែម្យ៉ាងប៉ុណ្ណោះទេ, ធម៌ទាំងឡាយនោះ រមែងប្រាកដ ជារបស់តាំងនៅ អស់កាលដ៏ខ្លី ជាប្រក្រតី ប្រៀបដូចជាតំណក់ទឹកសន្សើម ព្រោះព្រះអាទិត្យរះឡើង ប្រៀបដូចជាក្រពេញទឹក ប្រៀបដូចជាស្នាមគំនូសឈើលើទឹក ប្រៀបដូចជាគ្រាប់ស្ពៃលើចុងដែកស្រួច និង ប្រៀបដូចជាការកើតឡើង នៃផ្លេកបន្ទោរ រមែងប្រាកដ ជារបស់ដែលគ្មានសារៈ និង មិនមានខ្លឹមសារ ប្រៀបដូចជាកលមាយា ដូចថ្ងៃបណ្ដើរកូន ដូចការយល់សប្តិ ដូចឡសំរាប់ដុតភ្លើង ដូចជានគរនៃគន្ធព្វ ដូចជាពពុះទឹក និង ដូចជាដើមចេកជាដើម ។

ដោយការនាវិធី មានប្រមាណប៉ុណ្ណោះ វិបស្សនាញាណ ដ៏ខ្លី ជាបឋម ឈ្មោះថា ឧទយព្វយានុបស្សនា ដែលចាក់ធ្លុះនូវលក្ខណៈ គ្រប់ទាំង ៥០ ហើយតាំងនៅ ដោយអាការៈនេះថា “របស់នេះ មានការសូន្យទៅ ជាធម្មតាហ្នឹងឯង កើតឡើង និង កើតឡើងហើយ ក៏រមែងដល់នូវការសូន្យទៅវិញ” ដូច្នេះ ជាញាណដែលព្រះយោគីនោះ បានសំរេច

ហើយ ព្រោះបានសំរេចនូវតរុណវិបស្សនាញាណ ឯណា, ព្រះយោគី នោះ ទើបបានឈ្មោះថា អារទ្ធវិបស្សក: (អ្នកមានបញ្ញាជាគ្រឿងឃើញច្បាស់ប្រារព្ធហើយ) ។

(វិបស្សនូបកិលេស ១០)

(៤៣៦) លំដាប់នោះ ព្រោះតរុណវិបស្សនានេះ វិបស្សនូប-កិលេស ១០ រមែងកើតឡើង ដល់ព្រះយោគី ដែលជាអ្នកមានបញ្ញាឃើញច្បាស់ប្រារព្ធហើយនោះ។ ក៏វិបស្សនូបកិលេសទាំងឡាយ រមែងមិនកើតឡើង ដល់ព្រះអរិយសាវក អ្នកបានសំរេច នូវបដិវេធហើយ និង ដល់បុគ្គលអ្នកប្រតិបត្តិខុស លះបង់នូវកម្មដ្ឋាន ជាអ្នកខ្ជិលច្រអូស តែរមែងកើតឡើង ដល់កុលបុត្រ អ្នកប្រតិបត្តិដ៏ត្រឹមត្រូវ ប្រកបការនាដ៏សមគួរ ជាអ្នកមានវិបស្សនាប្រារព្ធហើយ តែប៉ុណ្ណោះ ។

សួរថា "ក៏ឧបកិលេស ១០ នោះ តើដូចម្ដេច?" ។ ឆ្លើយថា : "ឧបកិលេស១០ នោះ គឺ ពន្លឺ ញាណ បីតិ បស្សទ្ធិ សុខ: អធិមោក្ខ (សេចក្ដីជឿស៊ប់) បគ្គាហ: (សេចក្ដីព្យាយាម) ឧបដ្ឋាន: (សតិដ៏ក្លៀវក្លា) ឧបេក្ខា និកន្តិ(សេចក្ដីត្រេកអរ)" ។ ក៏ពាក្យនេះ ព្រះធម្មសេនាបតីពោលហើយថា "សួរថា: ចិត្តដែលមិនច្រួលច្រាល់ ដោយឧទ្ធច្ចៈ ក្នុងធម៌ តើដូចម្ដេច [១] ? ឆ្លើយថា: កាលភិក្ខុធ្វើទុកក្នុងចិត្តថា មិនទៀង ពន្លឺ ក៏កើតឡើង, ភិក្ខុនោះ ពិចារណានូវពន្លឺថា ពន្លឺជាធម៌, លំដាប់នោះ សេចក្ដីរាយមាយ សេចក្ដីអណ្ដែតអណ្ដូង (ក៏រមែងកើតឡើង), ភិក្ខុ រូបនោះ មានចិត្តច្រួលច្រាល់ ដោយឧទ្ធច្ចៈនោះ រមែងមិនដឹងតាមពិត នូវការប្រាកដថា មិនទៀង មិនដឹងតាមពិតនូវការប្រាកដថា ជាទុក្ខ មិនដឹង

១- សុ. ខុ. បដិ. ភាគទី ៧១ ទំព័រទី ៣៦ ។



តាមពិតនូវការប្រាកដថា មិនមែនខ្លួន, ន័យដូចគ្នានោះដែរ កាលភិក្ខុធ្វើទុកក្នុងចិត្តថា មិនទៀង ញាណ ក៏កើតឡើង បីតិកើតឡើង បស្សទ្ធិកើតឡើង សុខ កើតឡើង អធិមោក្ខ កើតឡើង បគ្គាហ: កើតឡើង ឧបដ្ឋាន: កើតឡើង ឧបេក្ខា កើតឡើង និកន្តិ ក៏កើតឡើង, ភិក្ខុនោះ រមែងពិចារណានូវនិកន្តិថា: និកន្តិ ជាធម៌ លំដាប់នោះ សេចក្ដីរាយមាយ សេចក្ដីអណ្ដែតអណ្ដូង (ក៏កើតឡើង) ភិក្ខុមានចិត្តច្រួលច្រាល់ ដោយឧទ្ធច្ចៈនោះ រមែងមិនដឹងតាមពិតនូវការប្រាកដថា មិនទៀង មិនដឹងតាមពិត នូវការប្រាកដថា ជាទុក្ខ មិនដឹងតាមពិត នូវការប្រាកដថា មិនមែនខ្លួន" ដូច្នេះ ។

(ឱភាសៈ)

ក្នុងឧបកិលេសទាំង១០ នោះ ពាក្យថា "ឱភាសៈ" បានដល់ ពន្លឺដែលកើតអំពីវិបស្សនា ។ កាលពន្លឺនោះកើតឡើងហើយ ព្រះយោគា-វចរ គិតថា "ក្នុងកាលមុនអំពីនេះ ពន្លឺយ៉ាងនេះ មិនធ្លាប់កើតឡើងដល់អាត្មាអញឡើយ អាត្មាអញជាអ្នកបានសំរេចមគ្គ ជាអ្នកបានសំរេចផល ដោយពិតប្រាកដ" ដូច្នេះហើយ ក៏ប្រកាន់យកនូវរបស់ដែលមិនមែនមគ្គសោះថា ជាមគ្គ ប្រកាន់យកនូវរបស់ដែលមិនមែនជាផលសោះថា ជាផល, កាលបើព្រះយោគាវចរនោះ ប្រកាន់យកនូវរបស់ដែលមិនមែនជាមគ្គ ថា ជាមគ្គ ប្រកាន់យកនូវរបស់ដែលមិនមែនជាផល ថា ជាផល វិបស្សនាវិថី ឈ្មោះថា អាក់ (ដំណើរ) ។ ព្រះយោគាវចរនោះ រមែងលះបង់នូវមូលកម្មដ្ឋានហើយ អង្គុយមើលតែពន្លឺនុ៎ះឯង ។

ក៏ឱភាសៈ (ពន្លឺ) នេះនោះឯង រមែងកើតឡើង ដល់ភិក្ខុខ្លះ បំភ្លឺ

ត្រឹមតែទីបល្ល័ង្កប៉ុណ្ណោះឯង ដល់ភិក្ខុខ្លះ បំភ្លឺខាងក្នុងបន្ទប់ ដល់ភិក្ខុខ្លះ បំភ្លឺទាំងខាងក្រៅបន្ទប់ ដល់ភិក្ខុខ្លះ ឲ្យពន្លឺពេញវិហារ ដល់ភិក្ខុខ្លះ ឲ្យពន្លឺ ១ គាវុត ដល់ភិក្ខុខ្លះ ឲ្យពន្លឺកន្លះយោជន៍... ១ យោជន៍... ២ យោជន៍...៣ យោជន៍ ។ល។ ឱភាសៈនេះ កើតឡើងដល់ភិក្ខុខ្លះ ធ្វើឲ្យមានពន្លឺតែមួយតាំងអំពីផ្ទៃផែនដី រហូតដល់ទៅព្រហ្មលោក ជាន់អកនិដ្ឋៈ ។ តែឱភាសៈ កើតឡើងដល់ព្រះមានព្រះភាគ ឲ្យពន្លឺភ្លឺរហូត ១ ម៉ឺនលោកធាតុ ។ ក៏រឿងនេះ ជារឿងនៃការមានប្រមាណផ្សេងគ្នានៃពន្លឺនោះ ដូចបានពោលហើយ ។

បានឮមកថា ព្រះថេរៈពីររូប អង្គុយធ្វើ(សមាធិ) ខាងក្នុងផ្ទះដែលមានជញ្ជាំងពីរជាន់ នាក្នុំចិត្តបព៌ត ។ ក៏ក្នុងថ្ងៃនោះ ជាថ្ងៃឧបោសថផ្នែកខាងរនោច ។ ទិសទាំងឡាយត្រូវបិទបាំងដោយពពក ងងឹតប្រកបដោយអង្គ ៤ ប្រព្រឹត្តទៅក្នុងចំណែកនៃរាត្រី ។ គ្រានោះ ព្រះថេរៈមួយរូប ពោលថា “បពិត្រលោកដ៏ចំរើន ឥឡូវនេះ ផ្កាបញ្ចពណ៌លើសីហាសនៈ ត្រង់ទីលានព្រះចេតិយ ប្រាកដដល់ខ្ញុំ” ។ ព្រះថេរៈ មួយរូបទៀត ពោលនឹងព្រះថេរៈនោះថា “លោកដ៏មានអាយុ លោកប្រាប់(នោះ) មិនអស្ចារ្យទេ តែឥឡូវនេះ ត្រី និង អណ្តើក ក្នុងទី១ យោជន៍ ក្នុងមហាសមុទ្រ ប្រាកដដល់ខ្ញុំ (នេះទើបអស្ចារ្យ)” ដូច្នេះ ។

ក៏វិបស្សនូបកិលេសនេះ រមែងកើតឡើងដល់បុគ្គល ដែលបានសមថៈ និងវិបស្សនាភាគច្រើន ។ បុគ្គលអ្នកបានសមថៈ និងវិបស្សនានោះ ញុំាងចិត្ត ឲ្យកើតឡើងថា “អាត្មាអញ ជាព្រះអរហន្ត” ព្រោះកិលេសទាំងឡាយ ដែលសមាបត្តិគ្របសង្កត់បានហើយ មិនពុះកញ្ជ្រោលឡើង ដូចព្រះមហានាគត្ថេរ អ្នកអាស្រ័យនៅក្នុងឧច្ចង្កវាលិក-



វិហារ ដូចព្រះមហាទត្តត្ថេរ អ្នកអាស្រ័យនៅក្នុងហង្កនៈ និង ដូចព្រះចូឡសុមនត្ថេរ អ្នកអាស្រ័យនៅក្នុងនិង្កបេណ្ណកបធានឃរៈ នាក្នុំចិត្តលបព៌ត ដូច្នោះឯង ។

នេះ គឺជាការសំដែងរឿងមួយ ក្នុងបុគ្គលដែលបានសមថៈ និងវិបស្សនានោះ ។

បានឮមកថាៈ ព្រះមហាខីណាស្រព មួយរូប ឈ្មោះ ធម្មទិន្នត្ថេរ ជាអ្នកបានឈាន ក្នុងបដិសម្ភិទា អាស្រ័យនៅក្នុងតលង្គរៈ ជាអ្នកឲ្យឱវាទដល់ភិក្ខុសង្ឃជាច្រើនរូប ។ ថ្ងៃមួយ ព្រះមហាខីណាស្រពនោះ អង្គុយ ក្នុងទីអាសនៈពេលថ្ងៃ របស់ខ្លួនហើយ ពិចារណាថា “កិច្ចនៃភាពជាសមណៈ របស់ព្រះមហានាគត្ថេរ អ្នកអាស្រ័យនៅ ក្នុងឧច្ចង្កវាលិកៈ ដែលត្រូវជាអាចារ្យ របស់អាត្មាអញ បានសំរេចដល់ទីបំផុតហើយ ឬ មិនទាន់ដល់ទីបំផុតហ្ន៎?” ដូច្នេះ ក៏ឃើញថា ព្រះមហានាគត្ថេរនោះ នៅជាបុថុជ្ជននៅឡើយទេ និង បានដឹងថា “កាលបើអាត្មាអញមិនទៅទេ ព្រះមហានាគត្ថេរ នឹងធ្វើកាលកិរិយាដែលនៅជាបុថុជ្ជនពិតប្រាកដ” ដូច្នេះហើយ ទើបហោះឡើងទៅកាន់អាកាសវេហា ដោយឫទ្ធិ ហើយចុះនៅក្បែរព្រះថេរៈ ដែលអង្គុយ នាអាសនៈ ក្នុងពេលថ្ងៃ ថ្វាយបង្គំហើយ សំដែងវត្ត រួចអង្គុយ ក្នុងទីដ៏សមគួរមួយ ។ ក៏ព្រះមហាខីណាស្រពនោះ ត្រូវព្រះមហានាគត្ថេរ សួរថា “ម្នាលធម្មទិន្នៈដ៏មានអាយុ ហេតុអ្វីបានជាលោកមក ក្នុងពេលមិនគួរ?” ដូច្នេះហើយ ទើបពោលថា “បពិត្រព្រះគុណម្ចាស់ដ៏ចំរើន ខ្ញុំព្រះករុណាមកដើម្បីសួរនូវបញ្ហា” ដូច្នេះ ។ លំដាប់នោះ កាលបើព្រះមហានាគត្ថេរ ពោលថា “ម្នាលលោកដ៏មានអាយុ! ចូរលោកសួរមកចុះ បើយើងដឹង យើងនឹង

ឆ្លើយ” ដូច្នេះ ព្រះមហាទីណាស្រេព ក៏សួរបញ្ហាមួយពាន់ ។ ព្រះថេរៈ ឆ្លើយតបបញ្ហា ដែលសួរហើយៗ ឥតទើសទាក់ឡើយ ។ លំដាប់នោះ កាលបើព្រះទីណាស្រេព ពោលថា “បពិត្រលោកម្ចាស់ដ៏ចំរើន ញាណ របស់ព្រះគុណម្ចាស់ចាស់ក្លាខ្លាំងណាស់ ធម៌នេះតើព្រះគុណម្ចាស់បាន សំរេចហើយពីកាលណាមក?” ដូច្នេះ ព្រះមហានាគត្ថេរ ទើបពោល ថា “ម្នាលលោកដ៏មានអាយុ ក្នុងកាល ៦០ ឆ្នាំ អំពីនេះ” ។ ព្រះមហា ទីណាស្រេព ពោលថា “បពិត្រព្រះគុណម្ចាស់ដ៏ចំរើន ចូរព្រះគុណម្ចាស់ ប្រើនូវសមាធិ”។ ព្រះមហានាគត្ថេរ ពោលថា “ម្នាលលោកដ៏មានអាយុ ការប្រើសមាធិនេះ មិនធ្ងន់អ្វីទេ” ។ ព្រះមហាទីណាស្រេព ពោល ថា “បពិត្រព្រះគុណម្ចាស់ដ៏ចំរើន! បើដូច្នោះ សូមព្រះគុណម្ចាស់ និម្មិត ដំរីបានមួយ” ។ ព្រះថេរៈ និម្មិតដំរី-ស សុទ្ធហើយ ។ ព្រះមហាទីណា ស្រេព ពោលថា “បពិត្រព្រះគុណម្ចាស់ដ៏ចំរើន ឥឡូវនេះ ចូរព្រះគុណ ម្ចាស់ធ្វើដំរី-ស សុទ្ធនេះ ឲ្យដូចជាដំរីមានត្រចៀកលាតចេញហើយមាន កន្ទុយលាតហើយ ដាក់ប្រមោយចូលទៅ ក្នុងមាត់ហើយ សំឡេង កោញ្ចនាទ គួរឲ្យភ័យខ្លាច មកត្រង់ចំពោះមុខព្រះគុណម្ចាស់” ។ ព្រះ ថេរៈ ក៏ធ្វើ យ៉ាងដូច្នោះហើយ ឃើញអាការៈដែលគួរឲ្យភ័យខ្លាច នៃ ដំរីដែលបោលមក យ៉ាងលឿន រួចហើយ ក្រោកឡើងប្រារព្ធ ដើម្បីនឹង រត់គេចចេញ ។ ព្រះថេរៈ ដែលជាព្រះទីណាស្រេពលាតដៃចាប់ជាយ ចីវរ ហើយពោលនឹងព្រះថេរៈថា “បពិត្រព្រះគុណម្ចាស់ដ៏ចំរើន ធម្មតា ទោស របស់ព្រះទីណាស្រេព មិនមានទេ” ។ ព្រះថេរៈនោះ ដឹងថា ខ្លួន លោកនៅជាបុថុជ្ជន ក្នុងកាលនោះ ទើបពោលថា “ម្នាលធម្មទិន្ន ដ៏ មានអាយុ ! សូមលោកដ៏មានអាយុ ជាទីពឹងអាស្រ័យ របស់ខ្ញុំផង”



ដូច្នេះហើយ អង្គុយប្រហោង ក្បែរបាទមូល ។ ព្រះមហាទីណាស្រេព ពោលថា “បពិត្រព្រះគុណម្ចាស់ដ៏ចំរើន ខ្ញុំព្រះករុណាមកហើយព្រោះ តាំងចិត្តថា: នឹងបានជាទីពឹងពាក់អាស្រ័យ ដល់ព្រះគុណម្ចាស់ សូម ព្រះគុណម្ចាស់កុំគិតឡើយ” ដូច្នេះហើយ ក៏ប្រាប់នូវកម្មដ្ឋាន ។ ព្រះ ថេរៈ ទទួលនូវកម្មដ្ឋានហើយ ឡើងកាន់ទីចង្រ្កម ក្នុងជំហានទីបី ក៏បាន សំរេចផលដ៏ខ្ពស់ គឺព្រះអរហត្ត ។ បានឮមកថា ព្រះថេរៈ ជាបុគ្គល ទោសចរិត ។ ភិក្ខុទាំងនេះ រមែងញាប់ញ័រ ព្រោះពន្លឺ ។

(ញាណ)

ពាក្យថា “ញាណ” បានដល់ វិបស្សនាញាណ ។ ន័យថា ញាណ ដែលខ្លាំងក្លា ក្លៀវក្លា ក្រៃលែង មានកម្លាំងដែលអ្វីៗ កំចាត់មិនបាន ប្រៀបដូចជាវជិរាវុធ របស់ព្រះឥន្ទ្រដែលបាញ់ចេញហើយដូច្នោះ រមែង កើតឡើង ដល់ព្រះយោគីនោះ ដែលថ្លឹងថ្លែងពិចារណារូបធម៌ និង អរូបធម៌ទាំងឡាយ ។

(បីតិ)

ពាក្យថា “បីតិ” បានដល់ បីតិ ក្នុងវិបស្សនា ។ ន័យថា ក្នុង សម័យនោះ បីតិ ៥ យ៉ាងនេះ គឺ: ខុទ្ទកាបីតិ ខណិកាបីតិ ឱក្កន្តិកាបីតិ ឧព្វេង្គាបីតិ ផរណាបីតិ រមែងកើតឡើង ដល់ព្រះយោគីនោះ ពេញទាំង សរីរៈ ។

(បស្សទ្ធិ)

ពាក្យថា “បស្សទ្ធិ” បានដល់ សេចក្តីស្ងប់ក្នុងវិបស្សនា ។ ន័យ ថា ក្នុងសម័យនោះ សេចក្តីក្រវល់ក្រវាយនៃកាយ និង ចិត្តទាំងឡាយ រមែងមិនមាន ដល់ព្រះយោគីនោះ ដែលអង្គុយ ក្នុងទីសម្រាក ក្នុងពេល

យប់ ឬ ក្នុងទីសម្រាក ក្នុងពេលថ្ងៃឡើយ, ការធ្ងន់នៃកាយ និង ចិត្ត ក៏មិនមាន, ការរឹងនៃកាយ និង ចិត្ត ក៏មិនមាន, ការមិនសមគួរ ដល់ការងារ ក៏មិនមាន, ការឈឺចាប់ ក៏មិនមាន, ការកោងនៃកាយ និងចិត្ត ក៏មិនមាន ។ តែក្នុងកាលនោះឯង កាយ និង ចិត្ត របស់ព្រះយោគីនោះ ជាធម្មជាត ស្ងប់រម្ងាប់ ស្រាល ទន់ គួរដល់ការងារ ស្រស់ប្រិមប្រិយ ត្រង់មែនពិត ។ ព្រះយោគីនោះ មានកាយ និង ចិត្ត ត្រូវធម៌ទាំងឡាយ មានបស្សទ្ធិជាដើមនេះ អនុគ្រោះហើយ រមែងសោយនូវសេចក្តីត្រេកអរ ដែលមិនមែនជារបស់មនុស្ស ក្នុងសម័យនោះ ដែលព្រះមានព្រះភាគ ទ្រង់សំដៅយក ត្រាស់ហើយថា :

> សេចក្តីត្រេកអរ ដែលមិនមែនជារបស់មនុស្ស
> រមែងមានដល់ភិក្ខុ អ្នកចូលទៅកាន់ផ្ទះស្ងាត់ អ្នក
> មានចិត្តស្ងប់រម្ងាប់ អ្នកឃើញធម៌ ដោយប្រពៃ ។
> ភិក្ខុពិចារណាការកើតឡើង និងការវិនាសខន្ធទាំង
> ឡាយ ក្នុងកាលណាៗ ក្នុងកាលនោះ ភិក្ខុនោះ
> រមែងបានបីតិ និង បាមោជ្ជៈ, បីតិ និង បាមោជ្ជៈ
> នោះ ឈ្មោះថា អមតធម៌ របស់បណ្ឌិត អ្នកដឹង
> ធម៌ទាំងឡាយ [១] ។

បស្សទ្ធិ ដែលប្រកបព្រមដោយធម៌ មានលហុតា(ការស្រាល) ជាដើម ដែលញុំាងសេចក្តីត្រេកអរ ដែលមិនមែនជារបស់មនុស្សនេះ ឲ្យសំរេច រមែងកើតឡើង ដល់ព្រះយោគីនោះ ដូចពោលមកនេះឯង ។

---

១- សុ. ខុ. ភាគទី ៥២ ទំព័រទី ១០០ បន្ទាត់ទី ៧ ។



(សុខៈ)

ពាក្យថា “សុខៈ” បានដល់ ចេតសិកសុខ ដែលប្រកបព្រមដោយវិបស្សនាចិត្ត ។ ន័យថា ក្នុងសម័យនោះ សេចក្តីសុខ ដែលប្រណីតក្រៃលែង ដែលផ្សព្វផ្សាយទៅ ពេញទាំងរាងកាយ រមែងកើតឡើងដល់ព្រះយោគីនោះ ។

(អធិមោក្ខ)

ពាក្យថា “អធិមោក្ខ” បានដល់ សទ្ធា ។ ព្រោះថា សទ្ធាដែលប្រកបព្រមដោយវិបស្សនានោះឯង ជាសទ្ធាមានកម្លាំង ជាសទ្ធាដែលញុំាងចិត្ត និង ចេតសិក ឲ្យជ្រះថ្លា យ៉ាងក្រៃលែង រមែងកើតឡើងដល់ព្រះយោគីនោះ ។

(បគ្គាហៈ)

ពាក្យថា “បគ្គាហៈ” បានដល់ វីរិយៈ ។ ព្រោះថា វីរិយៈ ដែលប្រកបព្រម ដោយវិបស្សនានុ៎ះឯង ជាវីរិយៈ ដែលបានផ្គងទុកហើយយ៉ាងល្អប្រសើរ ជាវីរិយៈ មិនធូរពេក មិនតឹងពេក រមែងកើតឡើងដល់ព្រះយោគីនោះ ។

(ឧបដ្ឋាន)

ពាក្យថា “ឧបដ្ឋាន” បានដល់ សតិ ព្រោះថា សតិ ដែលប្រកបព្រមដោយវិបស្សនាហ្នឹងឯង ជាសតិដែលតម្កល់ទុកបានល្អហើយ ជាសតិតាំងនៅមាំហើយ ជាបង្គោល មិនញាប់ញ័រ ដូចជារាជបពិត រមែងកើតឡើងដល់ព្រះយោគីនោះ ។ ព្រះយោគីនោះ ត្រិះរិះ ធ្វើទុកក្នុងចិត្ត ពិចារណានូវឋានៈណាៗ, ឋានៈនោះ ៗ រមែងចុះស៊ប់ ស្ទុះទៅ ប្រាកដដល់ព្រះយោគីនោះ ព្រោះសតិប្រៀបដូចជាបរលោក ប្រាកដដល់បុគ្គល

អ្នកបានសំរេចទិព្វចក្ខុ ដូច្នេះឯង ។

(ឧបេក្ខា)

ពាក្យថា "ឧបេក្ខា" បានដល់ ឧបេក្ខាក្នុងវិបស្សនាចិត្តផង ឧបេក្ខាក្នុងអាវជ្ជនចិត្តផង ។ ព្រោះថា ក្នុងសម័យនោះ ទាំងវិបស្សនូបេក្ខា ដែលមានភាពជាកណ្តាល ក្នុងសង្ខារទាំងពួង ជាធម្មជាត មានកម្លាំង រមែងកើតឡើង ទាំងអាវជ្ជនូបេក្ខា ក្នុងមនោទ្វារ ក៏កើតឡើង ដល់ព្រះយោគីនោះ ។ ក៏ឧបេក្ខានោះ កាលបើព្រះយោគីនោះ ពិចារណានូវឋានៈនោះៗ រមែងដឹកនាំទៅ យ៉ាងខ្លាំងក្លា ប្រៀបបាននឹងវជិរាវុធរបស់ព្រះឥន្ទ្រ ដែលបាញ់ទៅហើយ ប្រៀបដូចជាលំពែងដែលក្តៅ គឺបុគ្គលដោតហើយ លើកញ្ចប់ស្លឹកឈើ យ៉ាងនោះឯង ។

(និកន្តិ)

(៤៣៧) ពាក្យថា "និកន្តិ" បានដល់ សេចក្តីត្រេកអរ ក្នុងវិបស្សនា ។ ព្រោះថា សេចក្តីត្រេកអរដ៏សុខុម មានអាការៈស្ងប់ ធ្វើនូវអាល័យ ក្នុងវិបស្សនា ដែលប្រដាប់ដោយវិបស្សនូបកិលេសទាំងឡាយមានពន្លឺជាដើម ដូចបានពោលមកហើយនោះ រមែងកើតឡើង ដល់ព្រះយោគីនោះ ដែលជារបស់គឺព្រះយោគីនោះ មិនអាចដើម្បីនឹងកំណត់បានថា "វាជាកិលេស" ។

ក៏កាលបើពន្លឺ កើតឡើងហើយ យ៉ាងណាមិញ សូម្បីកាលបើឧបកិលេសទាំងឡាយដ៏សេសនេះឯណាមួយ កើតឡើងហើយ ក៏យ៉ាងដូច្នោះដែរ ព្រះយោគាវចរ ក៏គិតថា "ក្នុងកាលមុនអំពីនេះ ញាណដូច្នេះ មិនធ្លាប់កើតមានដល់អាត្មាអញឡើយ, បីតិ... បស្សទ្ធិ... សុខ... អធិមោក្ខ... បគ្គាហៈ... ឧបដ្ឋាន... ឧបេក្ខា.. និកន្តិ យ៉ាងដូច្នេះ មិន



ធ្លាប់កើតមានដល់អាត្មាអញឡើយ អាត្មាអញជាអ្នកបានសំរេចមគ្គ អាត្មាអញ ជាអ្នកបានសំរេចផល" ដូច្នេះហើយ ក៏ប្រកាន់យករបស់ដែលមិនមែនមគ្គថា ជាមគ្គ របស់ដែលមិនមែនជាផលថា ជាផល" ។ កាលបើព្រះយោគីនោះ ប្រកាន់យករបស់ដែលមិនមែនមគ្គថា ជាមគ្គ មិនមែនផលថា ជាផល ដូច្នេះ, វិបស្សនាវិថី ឈ្មោះថា អាក់ (ស្ទះ) ។ ព្រះយោគីនោះ រមែងលះបង់នូវមូលកម្មដ្ឋាន របស់ខ្លួនចោលហើយ អង្គុយ ត្រេកអរសប្បាយតែនឹងនិកន្តិហ្នឹងឯង ។

(ឧបកិលេស ១០ ចែកជា ៣០)

ក៏ក្នុងវិបស្សនូបកិលេស១០ នេះ វិបស្សនូបកិលេសទាំងឡាយ មានឱភាសៈជាដើម លោកហៅថា "ឧបកិលេស" ព្រោះជាទីកើតឡើងនៃឧបកិលេស មិនមែនព្រោះជាអកុសលទេ។ តែនិកន្តិ ជាឧបកិលេសផង ជាទីតាំង(វត្ថុ)នៃកិលេសផង ។ មួយទៀត ដោយអំណាចនៃវត្ថុហ្នឹងឯង វិបស្សនូបកិលេសទាំងនោះ ត្រូវជា ១០ តែបើដោយអំណាចនៃគាហៈ គឺការប្រកាន់យក ត្រូវជា ៣០ គត់ ។ តើដូចម្តេច? ។ គឺ : ក៏ឧបកិលេស មាន ៣០ គត់ ដោយអំណាចនៃការប្រកាន់យក យ៉ាងនេះ គឺ: កាលបើព្រះយោគីនោះ ប្រកាន់យកថា "ពន្លឺកើតឡើង ដល់អាត្មាអញហើយ" ដូច្នេះ ក៏កើតទៅជាការប្រកាន់ ដោយអំណាចនៃទិដ្ឋិ, កាលបើប្រកាន់យកថា "ពន្លឺជាទីពេញចិត្ត កើតឡើងហើយ" ដូច្នេះ ក៏ទៅជាការប្រកាន់ ដោយអំណាចនៃមានះ, កាលបើត្រេកអរនឹងពន្លឺ ក៏កើតទៅជាការប្រកាន់ ដោយអំណាចនៃតណ្ហា, ក្នុងពន្លឺ មានការប្រកាន់ ៣ គឺ: (ដោយអំណាច) ទិដ្ឋិ, មានះ និង តណ្ហា ដូចបានពោលមកហើយ សូម្បីក្នុងឧបកិលេសដ៏សេសទាំងឡាយ ក៏ដូចគ្នានោះដែរ ។

*ព្រះយោគាវចរ អ្នកមិនឆ្លាត មិនវាងវៃ រមែងញាប់ញ័រ រមែងរាយមាយ ព្រោះឧបកិលេសទាំងឡាយមានពន្លឺជាដើម ដោយអំណាចនៃការប្រកាន់ទាំង ៣ យ៉ាងនោះឯង ។ ព្រះយោគាវចរនោះ រមែងឃើញ នូវឧបកិលេសទាំងឡាយ មានពន្លឺជាដើម មួយៗ ថា "នុ៎ះជារបស់អញ អញជាយ៉ាងនុ៎ះ នុ៎ះជាខ្លួនរបស់អញ" ដូច្នេះ ។*

*ព្រោះហេតុនោះ ទើបបុរាណាចារ្យទាំងឡាយ ពោលថា :*

> ចិត្ត រមែងញាប់ញ័រ ដោយហេតុទាំងឡាយឯណា
> ហេតុទាំងឡាយនោះ មាន ១០ គឺ ចិត្តញាប់ញ័រ
> ព្រោះពន្លឺ ១, ញាណ ១ បីតិ ១ បស្សទ្ធិ ១ សុខ ១
> ញាប់ញ័រព្រោះអធិមោក្ខ ១ បគ្គាហៈ ១ ឧបដ្ឋាន ការ
> ពិចារណា ដោយឧបេក្ខា ក្នុងឧបេក្ខា ១ និកន្តិ ១ ។

*ចំណែកព្រះយោគាវចរ អ្នកឆ្លាត ជាបណ្ឌិត ឈ្លាសវាងវៃ ដល់ព្រមដោយការចេះដឹង កាលបើឧបកិលេសទាំងឡាយ មានពន្លឺជាដើម កើតឡើងហើយ រមែងកំណត់ពិចារណាឃើញ នូវឧបកិលេសនោះ ដោយបញ្ញា យ៉ាងនេះថា "ពន្លឺនេះ កើតឡើង ដល់អាត្មាអញហើយ តើហ្ន៎!, ក៏ប៉ុន្តែ ពន្លឺនេះនោះឯង មិនទៀង ជារបស់ត្រូវបានតាក់តែងឡើង អាស្រ័យបច្ច័យកើតឡើង មានការសូន្យទៅជាធម្មតា មានការអស់ទៅជាធម្មតា មានការនឿយណាយជាធម្មតា មានការរលត់ទៅជាធម្មតា" ដូច្នេះខ្លះ ឬ បើមិនដូច្នោះទេ ការពិចារណាឃើញ យ៉ាងនេះ រមែងមាន ដល់ព្រះយោគីនោះថា "ប្រសិនបើពន្លឺ គប្បីជាអត្តា នឹងប្រកាន់ថា "វា ជាអត្តា" ដូច្នេះ ក៏សមគួរ, តែនេះ គឺជាអនត្តា មែន*



*ពិត (បែរជា) ប្រកាន់ថា "វា ជាអត្តា" ទៅវិញ ព្រោះហេតុនោះ ពន្លឺនោះ ទើបឈ្មោះថា អនត្តា ព្រោះអត្ថថា មិនប្រព្រឹត្តទៅ ក្នុងអំណាច ឈ្មោះថា ជារបស់មិនទៀង ព្រោះអត្ថថា មានមកហើយ (បែរជា) មិនមាន(ទៅវិញ) ឈ្មោះថា ជាទុក្ខ ព្រោះអត្ថថា ត្រូវការកើតឡើង និងការសូន្យទៅ បៀតបៀន" ដូច្នេះខ្លះ ។*

*សេចក្ដីពណ៌នាទាំងពួង បណ្ឌិត គប្បី (ធ្វើ) ឲ្យពិស្ដារ តាមន័យដូចពោលហើយ ក្នុងអរូបសត្តកៈចុះ ។ មួយទៀត ការពណ៌នា ក្នុងពន្លឺយ៉ាងណា សូម្បីក្នុងឧបកិលេសដ៏សេស ក៏យ៉ាងនោះដែរ ។*

*ព្រះយោគាវចរនោះ លុះពិចារណាឃើញយ៉ាងនេះហើយ ក៏ឃើញពន្លឺថា "នុ៎ះ មិនមែនជារបស់អញ, នុ៎ះ មិនមែនជាអញ, នុ៎ះ មិនមែនជាអត្តារបស់អញ" ដូច្នេះ រមែងពិចារណាឃើញញាណ ។ល។ ឃើញនិកន្តិថា "នុ៎ះ មិនមែនជារបស់អញ, នុ៎ះមិនមែនជាអញ, នុ៎ះក៏មិនមែនអត្តារបស់អញ" ដូច្នេះ ។ ព្រះយោគាវចរនោះ កាលពិចារណាឃើញយ៉ាងនេះ រមែងមិនកំរើក មិនញាប់ញ័រ ព្រោះឧបកិលេសទាំងឡាយមានពន្លឺជាដើម ។*

*ព្រោះហេតុនោះ ទើបបុរាណាចារ្យទាំងឡាយ ពោលថា :*

> បញ្ញា របស់ភិក្ខុណា សន្សំហើយនូវហេតុ (ឋានៈ)
> ១០ នេះ, ភិក្ខុនោះ ឈ្មោះថា ជាអ្នកឆ្លៀវឈ្លាស
> ចំពោះឧទ្ធច្ចៈ ក្នុងធម៌ និង មិនដល់នូវសេចក្ដីរាយ
> មាយ [១] ។

---

*១- សុ. ខុ. ភាគទី ៥២ ទំព័រទី ១០០ បន្ទាត់ទី ៧ ។*

### (សរុបសេចក្តី)

ព្រះយោគាវចរនោះ កាលមិនដល់ នូវការរាយមាយ យ៉ាងនេះ រមែងកាប់ឆ្ការនូវព្រៃស្អាប់គឺឧបកិលេសទាំង ៣០ ប្រការនោះបានហើយ កំណត់ផ្លូវ និង មិនមែនផ្លូវថា "ធម៌ទាំងឡាយមានពន្លឺជាដើម មិនមែនជាផ្លូវទេ ចំណែកវិបស្សនាញាណ ដែលរួចផុតស្រឡះពីឧបកិលេស ដើរទៅកាន់ផ្លូវ (នៃវិបស្សនា) គឺជាផ្លូវ" ។

ញាណ របស់ព្រះយោគាវចរនោះ ដែលដឹងនូវផ្លូវ និង មិនមែនផ្លូវថា "នេះ គឺជាផ្លូវ នេះមិនមែនជាផ្លូវ" ហើយតាំងនៅ យ៉ាងនេះ បណ្ឌិតគប្បីជ្រាបថា "ឈ្មោះថា មគ្គាមគ្គញ្ញាណទស្សនវិសុទ្ធិ" ។

ក៏ដោយសេចក្តីបរិសុទ្ធិ មានប្រមាណប៉ុណ្ណេះ ការកំណត់នូវ សច្ចៈ ៣ គឺព្រះយោគាវចរនោះ បានធ្វើហើយ ។ ធ្វើការកំណត់បាន យ៉ាងដូចម្តេច? ។ គឺដំបូងក្នុងទិដ្ឋិវិសុទ្ធិ ព្រះយោគាវចរ ឈ្មោះថា បានធ្វើការកំណត់ទុក្ខសច្ចៈ ព្រោះកំណត់នាមរូប, ក្នុងកង្ខាវិតរណវិសុទ្ធិ ឈ្មោះថា បានធ្វើការកំណត់សមុទយសច្ចៈ ព្រោះការកំណត់កាន់យកនូវបច្ច័យ, ក្នុងមគ្គាមគ្គញ្ញាណទស្សនវិសុទ្ធិនោះ ព្រះយោគាវចរ ឈ្មោះថា បានធ្វើការកំណត់នូវមគ្គសច្ចៈ ព្រោះការជ្រើសរើសយកតែផ្លូវដែលត្រឹមត្រូវ ដូច្នេះ ការកំណត់នូវសច្ចៈទាំងឡាយ ៣ ឈ្មោះថា គឺព្រះយោគាវចរនោះ បានធ្វើហើយ ដោយញាណជាលោកិយប៉ុណ្ណឹងឯង ដូចបានពណ៌នាមកហើយនេះឯង ជាដំបូង ។

បរិច្ឆេទ ទី២០ ឈ្មោះ មគ្គាមគ្គញ្ញាណទស្សនវិសុទ្ធិនិទ្ទេស
ក្នុងអធិការនៃបញ្ញាភាវនា ក្នុងគម្ពីរវិសុទ្ធិមគ្គ ដែលខ្ញុំរៀបរៀងហើយ
ដើម្បីបាមោជ្ជៈ ដល់សាធុជន ចប់បរិបូណ៌ហើយ ។



## បដិបទាញាណទស្សនវិសុទ្ធិនិទ្ទេស

(៤៣៨) ចំណែកវិបស្សនា ដែលដល់នូវទីបំផុត ដោយអំណាចនៃញាណ៨ និង ញាណទី៩ គឺសច្ចានុលោមិកញាណនេះឯង ឈ្មោះថា បដិបទាញាណទស្សនវិសុទ្ធិ ។

ក៏ក្នុងពាក្យថា "នៃញាណ ៨" នោះ បណ្ឌិតគប្បីជ្រាបញាណទាំងឡាយ ៨ នេះ គឺៈ ឧទយព្វយានុបស្សនាញាណ ដែលរួចផុតស្រឡះពីឧបកិលេស រាប់ថា ជាវិបស្សនា ដែលធ្វើដំណើរទៅតាមវិថី ភង្គានុបស្សនាញាណ ភយតុបដ្ឋានញ្ញាណ អាទីនវានុបស្សនាញាណ និព្វិទានុបស្សនាញាណ មុញ្ចិតុកម្យតាញាណ បដិសង្ខានុបស្សនាញាណ សង្ខារុបេក្ខាញាណ ។ ពាក្យថា "ញាណ ទី៩ គឺសច្ចានុលោមិកញាណ" នេះ ជាពាក្យហៅ អនុលោមញាណ ។ ព្រោះហេតុនោះ ព្រះយោគាវចរ អ្នកប្រាថ្នាបំពេញបដិបទាញាណទស្សនវិសុទ្ធិនោះ គប្បីធ្វើសេចក្តីព្យាយាម ក្នុងញាណទាំងនោះ ដោយធ្វើឧទយព្វយញ្ញាណ ដែលរួចផុតស្រឡះអំពីឧបកិលេស ឲ្យទៅជាបទដើម ។

### (ការបំពេញឧទយព្វយញ្ញាណបន្ថែម)

បើមានពាក្យសួរថា "ធ្វើសេចក្តីព្យាយាម ក្នុងឧទយព្វយញ្ញាណម្តងទៀត មានប្រយោជន៍ ដូចម្តេច" ។ គប្បីឆ្លើយថា "មានប្រយោជន៍ ដើម្បីកំណត់នូវលក្ខណៈ" ។ ព្រោះថា ឧទយព្វយញ្ញាណ ជាញាណសៅហ្មងហើយ ដោយឧបកិលេស ១០ ខាងក្រោម មិនអាចកំណត់នូវត្រៃលក្ខណ៍ ឲ្យច្បាស់លាស់ តាមសេចក្តីពិតបាន តែរួចផុតស្រឡះពីឧបកិលេសហើយទើបអាចកំណត់បាន ព្រោះហេតុនោះ គប្បីធ្វើសេចក្តីព្យាយាម ក្នុងឧទយព្វយញ្ញាណនោះ បន្ថែមទៀត ដើម្បីកំណត់នូវ(ត្រៃ)

លក្ខណ៍ ឲ្យបានច្បាស់លាស់ ។ ក៏លក្ខណៈទាំងឡាយមិនប្រាកដ ព្រោះអ្វីបិទបាំង ហេតុតែមិនធ្វើទុកក្នុងចិត្តនូវអ្វី? ។ ដំបូង អនិច្ចលក្ខណៈ មិនប្រាកដ ព្រោះត្រូវសន្តតិ បិទបាំងទុក ហេតុតែមិនបានធ្វើទុកក្នុងចិត្តនូវការកើតឡើង និង ការសូន្យទៅ, ទុក្ខលក្ខណៈ មិនប្រាកដ ព្រោះត្រូវឥរិយាបថទាំងឡាយបិទបាំង ហេតុតែមិនធ្វើទុកក្នុងចិត្ត នូវការដែលត្រូវបៀតបៀនជារឿយៗ, អនត្តលក្ខណៈ មិនប្រាកដ ព្រោះត្រូវឃនៈ គឺដុំតាន់បិទបាំង ហេតុតែមិនធ្វើទុកក្នុងចិត្ត នូវការបែកខ្ញែកចេញពីគ្នានៃធាតុផ្សេងៗ ។ ប៉ុន្តែកាលបើសន្តតិ ត្រូវបានធ្វើឲ្យកំរើកហើយ ព្រោះកំណត់នូវការកើត និង ការសូន្យទៅ អនិច្ចលក្ខណៈ ទើបប្រាកដ តាមសេចក្តីពិតបាន, កាលបើឥរិយាបថ ត្រូវដកចេញហើយ ព្រោះធ្វើទុកក្នុងចិត្តនូវការដែលត្រូវបៀតបៀនជារឿយៗ ទុក្ខលក្ខណៈ រមែងប្រាកដ តាមសេចក្តីពិតបាន, កាលបើបានធ្វើការបែកខ្ញែកពីគ្នានៃដុំតាន់(ឃនៈ)ហើយ ព្រោះបំបែកនូវធាតុផ្សេងៗ ចេញអំពីគ្នាបានហើយ អនត្តលក្ខណៈ ទើបប្រាកដ តាមសេចក្តីពិតបាន ។

(ការវិភាគត្រៃលក្ខណ៍)

មួយទៀត ក្នុងត្រៃលក្ខណ៍នេះ គប្បីជ្រាបវិភាគ យ៉ាងនេះគឺ របស់ដែលមិនទៀង លក្ខណៈ នៃរបស់ដែលមិនទៀង, របស់ដែលជាទុក្ខ លក្ខណៈនៃរបស់ដែលជាទុក្ខ, របស់ដែលជាអនត្តា លក្ខណៈ នៃរបស់ដែលជាអនត្តា ។

ក្នុងវិភាគនោះ ខន្ធ៥ ឈ្មោះថា ជារបស់មិនទៀងព្រោះហេតុអ្វី? ។ ព្រោះភាវៈ គឺ វាមានការកើតឡើង ការសូន្យទៅ និង ការប្រែប្រួលទៅ ឬ ព្រោះវាមានមកហើយត្រឡប់ទៅជាមិនមានទៅវិញ ។ ការកើតឡើង



ការសូន្យទៅ និងការប្រែប្រួលទៅ ឬ ការផ្លាស់ប្តូរទៅនៃអាការៈ ពោលគឺការកើតមានមកហើយ ប្រែជាមិនមានទៅវិញ គឺជាលក្ខណៈ នៃរបស់ដែលមិនទៀង ។

មួយទៀត ខន្ធ ៥ នុ៎ះឯង ឈ្មោះថា ទុក្ខ ព្រោះបាលីថា "យទនិច្ចំ តំ ទុក្ខំ របស់ណា មិនទៀង របស់នោះ ជាទុក្ខ" ។ ព្រោះហេតុអ្វី? ។ ព្រោះត្រូវបានបៀតបៀនជារឿយៗ ។ អាការៈ ដែលត្រូវបានបៀតបៀនរឿយៗ ជាលក្ខណៈ នៃទុក្ខ ។

មួយទៀត ខន្ធ ៥ នោះឯង ឈ្មោះថា អនត្តា ព្រោះបាលីថា "យំ ទុក្ខំ តទនត្តា របស់ណា ជាទុក្ខ របស់នោះ ជាអនត្តា" ។ ព្រោះហេតុអ្វី? ។ ព្រោះមិនប្រព្រឹត្តទៅ ក្នុងអំណាច(អ្នកណាមួយ) ។ អាការៈ គឺការមិនប្រព្រឹត្តិទៅ ក្នុងអំណាច(អ្នកណាមួយ) ជាលក្ខណៈ នៃអនត្តា ។

ព្រះយោគាវចរនោះ រមែងកំណត់នូវលក្ខណៈ ៣ និង ខន្ធ ៥ ទាំងអស់នេះនោះ តាមសេចក្តីពិតបាន ព្រោះឧទយព្វយានុបស្សនា ដែលឈ្មោះថា ជាវិបស្សនា ធ្វើដំណើរទៅតាមវិថី ដែលរួចផុតស្រឡះអំពីឧបកិលេសហើយ ។ កាលបើព្រះយោគាវចរកំណត់បានយ៉ាងនេះហើយ ត្រិះរិះពិចារណានូវរូបធម៌ និង អរូបធម៌ទាំងឡាយថា មិនទៀង ជាទុក្ខ ជាអនត្តា រឿយៗ ។ ញាណនោះ រមែងប្រព្រឹត្តទៅខ្លាំងក្លា, សង្ខារទាំងឡាយ រមែងប្រាកដយ៉ាងឆាប់រហ័យ ។ កាលបើញាណ ប្រព្រឹត្តទៅ ដ៏ខ្លាំងក្លា, កាលបើសង្ខារទាំងឡាយ ប្រាកដយ៉ាងឆាប់រហ័ស, ញាណ រមែងមិនជួបប្រទះនូវការកើតឡើង ឬ ការតាំងនៅ, ការប្រព្រឹត្តិទៅ ឬ ក៏និមិត្ត ។ សតិ រមែងតាំងនៅស៊ប់ តែក្នុងការអស់ទៅ ការសូន្យទៅ ការបែកធ្លាយទៅ និង ការរលត់ទៅ តែប៉ុណ្ណោះ ។

(ភង្គានុបស្សនាញាណ)

កាលបើព្រះយោគាវចរនោះ ឃើញថា “របស់ដែលកើតឡើង ជាសង្ខារ ឈ្មោះយ៉ាងនេះហើយ រមែងរលត់ទៅវិញយ៉ាងដូច្នេះឯង” ដូច្នេះ, វិបស្សនាញាណ ឈ្មោះថាភង្គានុបស្សនា រមែងកើតឡើងក្នុងឋានៈនោះ ដែលលោកពោលសំដៅយកហើយថា “សួរថាៈ បញ្ញាក្នុងការពិចារណាឃើញ នូវអារម្មណ៍ថា បែកធ្លាយ ឈ្មោះថា វិបស្សនាញាណ តើដូចម្ដេច? [1] ។ ឆ្លើយថាៈ ចិត្ត មានរូបជាអារម្មណ៍ កើតឡើងហើយបែកធ្លាយទៅវិញ, បុគ្គលពិចារណាឃើញនូវការបែកធ្លាយនោះនៃចិត្ត ព្រោះពិចារណានូវអារម្មណ៍នោះ។ ពាក្យថា “ពិចារណាឃើញ” តើពិចារណាឃើញ ដូចម្ដេច? គឺៈ ពិចារណាឃើញថា មិនទៀង មិនមែនពិចារណាឃើញថា ទៀងទេ ពិចារណាឃើញថា ជាទុក្ខ មិនមែនពិចារណាឃើញថា ជាសុខទេ ពិចារណាឃើញថា មិនមែនខ្លួន មិនមែនពិចារណាឃើញថា ខ្លួនទេ រមែងនឿយណាយ មិនរីករាយ ធុញទ្រាន់ មិនត្រេកអរ រលត់ មិនឲ្យកើតឡើង រលាស់ចោល មិនកាន់យក, បុគ្គល កាលពិចារណាឃើញថា មិនទៀង ក៏លះបង់សញ្ញាថា ទៀង កាលពិចារណាឃើញថា ជាទុក្ខ ក៏លះបង់នូវសញ្ញាថា ជាសុខ កាលពិចារណាឃើញថា មិនមែនខ្លួន ក៏លះបង់នូវសញ្ញាថា ខ្លួន កាលនឿយណាយ ក៏លះបង់នូវសេចក្ដីរីករាយ កាលធុញទ្រាន់ ក៏លះបង់នូវតម្រេក កាលរលត់ ក៏លះបង់នូវការកើតឡើង កាលរលាស់ចោល ក៏លះបង់នូវការប្រកាន់។

ចិត្ត មានវេទនាជាអារម្មណ៍ ។លៗ មានសញ្ញាជាអារម្មណ៍ មានសង្ខារជាអារម្មណ៍ មានវិញ្ញាណជាអារម្មណ៍ មានចក្ខុជាអារម្មណ៍ ។លៗ

១- សុ. ខុ. បដិ. ភាគទី ៦៩ ទំព័រទី ១២៩-១៣០-១៣១ ។



ចិត្តមានជរា និង មរណៈ ជាអារម្មណ៍ កើតឡើងហើយ បែកធ្លាយទៅវិញ ។លៗ បុគ្គលកាលរលាស់ចោល រមែងលះបង់នូវការប្រកាន់ ។

ការរំកិលចិត្តចាកវត្ថុមុន ទៅកាន់វត្ថុផ្សេងវិញក្ដី ការ
វិវដ្ដន៍នៃចិត្ត ដោយបញ្ញាក្ដី កម្លាំង គឺការរំពឹងរក(នូវ
ការបែកធ្លាយ)ក្ដី ឈ្មោះថា ការពិចារណាឃើញ(នូវ
ការបែកធ្លាយ) ការកំណត់នូវសភាពទាំងពីរថា តែ១
ដោយការប្រព្រឹត្តិតាមអារម្មណ៍ ភាពនៃបុគ្គល មាន
ចិត្តចុះស៊ប់ ក្នុងការរលត់ ឈ្មោះថា ពិចារណាឃើញ
នូវលក្ខណៈនៃការសូន្យ ការពិចារណាឃើញនូវ
អារម្មណ៍ក្ដី បុគ្គលឃើញនូវការបែកធ្លាយក្ដី កិរិយា
ប្រាកដឡើងថាសូន្យក្ដី ឈ្មោះថាការពិចារណាឃើញ
ដោយបញ្ញាដ៏ក្រៃលែង, ភិក្ខុ អ្នកឈ្លាសវាងវៃ ក្នុង
អនុបស្សនាទាំង ៣ ផង ក្នុងវិបស្សនាទាំង ៤ ផង
រមែងមិនញាប់ញ័រ ក្នុងទិដ្ឋិទាំងឡាយផ្សេងៗ ព្រោះ
ខ្លួនជាអ្នកឈ្លាសវាងវៃ ក្នុងការប្រាកដទាំង ៣ ។

ដែលឈ្មោះថា ញាណនោះ ដោយអត្ថថា ដឹងនូវធម៌នោះ ឈ្មោះថា បញ្ញា ដោយអត្ថថា ដឹងច្បាស់នូវធម៌នោះ ព្រោះហេតុនោះ ទើបលោកពោលថា បញ្ញា ក្នុងការដឹងនូវអារម្មណ៍ថា បែកធ្លាយ ឈ្មោះថា វិបស្សនាញាណ យ៉ាងដូច្នេះឯង ។

(អធិប្បាយបាលី)

សេចក្ដីអធិប្បាយ ក្នុងបាលីនោះ គប្បីជ្រាប ដូច្នេះថា ពាក្យថា

“អារម្មណប្បដិសង្ខា ពិចារណាឃើញអារម្មណ៍” សេចក្តីថា ពិចារណាហើយ គឺដឹងហើយ បានដល់ឃើញហើយនូវអារម្មណ៍ណាមួយថា អស់ទៅ ថា សូន្យទៅ ។ ពាក្យថា “ភង្គានុបស្សនេ បញ្ញា បញ្ញា ក្នុងការពិចារណាឃើញថាបែកធ្លាយ” សេចក្តីថា បញ្ញាឯណាក្នុងការពិចារណាឃើញនូវការបែកធ្លាយ នៃញាណដែលពិចារណាឃើញនូវអារម្មណ៍ ថា អស់ទៅ ថា សូន្យទៅ ហើយកើតឡើងនោះ នេះ ហៅថា វិបស្សនា-ញាណ, សួរថា: ញាណនោះ តើដូចម្តេច? គឺ នេះជាសេចក្តីអធិប្បាយនៃកថេតុកម្យតាបុច្ឆា ជាដំបូងសិន ។

លំដាប់នោះ ញាណនោះ មានដោយប្រការណា ដើម្បីសំដែងនូវប្រការនោះ ទើបលោកពោលថា “មានរូប ជាអារម្មណ៍” ដូច្នេះជាដើម។

ក្នុងពាក្យទាំងនោះ ពាក្យថា “រូបារម្មណតា ចិត្តំ ឧប្បជ្ជិត្វា ភិជ្ជតិ” សេចក្តីថា ចិត្ត មានរូបជាអារម្មណ៍ កើតឡើងហើយ ក៏បែកធ្លាយទៅវិញ ។ ម្យ៉ាងទៀត សេចក្តីថា ចិត្តកើតឡើង ក្នុងភាពដែលចិត្តមានរូបជាអារម្មណ៍ហើយ ក៏បែកធ្លាយទៅវិញ ។

ពាក្យថា “តំ អារម្មណំ បដិសង្ខា” សេចក្តីថា ពិចារណាហើយ គឺដឹងហើយ បានដល់ ឃើញហើយនូវរូបារម្មណ៍នោះថា អស់ទៅ ថា សូន្យទៅ ។

ពាក្យថា “តស្ស ចិត្តស្ស ភង្គំ អនុបស្សតិ” សេចក្តីថា រូបារម្មណ៍នោះ គឺចិត្តឯណា ឃើញហើយថា អស់ទៅ ថា សូន្យទៅ, ភិក្ខុ រមែងពិចារណាឃើញនូវការបែកធ្លាយនៃចិត្តនោះ ដោយចិត្តមួយផ្សេងទៀត។ ហេតុនោះ បុរាណាចារ្យទាំងឡាយពោលថា “ព្រះយោគាវចរ ឃើញនូវរបស់ដែលត្រូវដឹង គឺអារម្មណ៍ផង នូវញាណ គឺអនុបស្សនាញាណផង



ទាំងពីរយ៉ាង” ។

ក៏ពាក្យថា “អនុបស្សតិ” ក្នុងសេចក្តីនោះ បានដល់ ឃើញរឿយៗ សេចក្តីថា ឃើញរឿយៗ ដោយអាការៈច្រើនយ៉ាង ។ ព្រោះហេតុនោះ ទើបលោកពោលថា “ពាក្យថា ពិចារណាឃើញ គឺពិចារណាឃើញយ៉ាងដូចម្តេច? គឺពិចារណាឃើញថា មិនទៀង” ដូច្នេះជាដើម ។

ក្នុងអាការៈទាំងនោះ ឈ្មោះថា ការបែកធ្លាយ គឺជាទីចុងបំផុត នៃអនិច្ចតា ព្រោះហេតុណា, ព្រោះហេតុនោះ ព្រះយោគាវចរអ្នកពិចារណាឃើញនូវការបែកធ្លាយនោះ រមែងពិចារណាឃើញនូវសង្ខារទាំងពួងថា មិនទៀង មិនមែនពិចារណាឃើញថា ទៀងទេ, លំដាប់នោះ ព្រោះរបស់ដែលមិនទៀង ក៏ជាទុក្ខ និងព្រោះរបស់ដែលជាទុក្ខ ក៏ទៅជាអនត្តា ទើបពិចារណាឃើញ នូវសង្ខារទាំងពួងនោះឯង ថា ជាទុក្ខ មិនមែនពិចារណាឃើញ ថា ជាសុខទេ ពិចារណាឃើញសង្ខារទាំងពួងនោះ ថា ជាអនត្តា មិនមែនពិចារណាឃើញថា ជាអត្តា ទេ ។ មួយទៀត របស់ណា មិនទៀង ជាទុក្ខ ជាអនត្តា របស់នោះ បុគ្គលមិនគប្បីត្រេកអរ និងរបស់ណា មិនគប្បីត្រេកអរ បុគ្គលមិនគប្បីត្រេកអរ ក្នុងរបស់នោះ ព្រោះហេតុណា, ព្រោះហេតុនោះ ព្រះយោគាវចរនោះទើបនឿយណាយ មិនត្រេកអរ ធុញទ្រាន់ មិនរីករាយ ក្នុងសង្ខារដែលខ្លួនឃើញហើយនុ៎ះ ថា “មិនទៀង ជាទុក្ខ ជាអនត្តា” តាមលំដាប់ នៃការពិចារណាឃើញថាបែកធ្លាយ ។

ព្រះយោគាវចរនោះ កាលមិនត្រេកអរ យ៉ាងនេះ ឈ្មោះថា ញុំាងរាគៈឲ្យរលត់ គឺមិនឲ្យកើតឡើង សេចក្តីថា មិនធ្វើឲ្យរាគៈកើតឡើង ដោយញាណ ដែលជាលោកិយៈហ្នឹងឯង ។ ន័យមួយវិញទៀត ព្រះ

យោគាវចរនោះ ជាអ្នកនឿយណាយហើយយ៉ាងនេះ រមែងញុំាងសង្ខារដែលខ្លួនឃើញហើយឲ្យរលត់ មិនឲ្យកើតឡើងយ៉ាងណា ក៏ញុំាងសង្ខារដែលខ្លួនមិនបានឃើញហើយនោះផង ឲ្យរលត់ មិនឲ្យកើតឡើង ដោយអំណាចនៃញាណដែលអនុលោមតាម ក៏យ៉ាងនោះដែរ សេចក្តីថាៈ ធ្វើទុកក្នុងចិត្តថា រលត់តែម្យ៉ាង ឃើញតែការរលត់នៃសង្ខារនោះ តែម្យ៉ាង មិនឃើញការកើតឡើងទេ ។

ព្រះយោគាវចរនោះ ប្រតិបត្តិបាន យ៉ាងនេះហើយ ឈ្មោះថា រលាស់ចោល មិនប្រកាន់យក ។ ពាក្យនោះ មានអធិប្បាយ យ៉ាងដូចម្តេច? ។ អធិប្បាយថា : សូម្បីអនុបស្សនា មានអនិច្ចានុបស្សនា ជាដើមនេះ ក៏ហៅថា បរិច្ចាគប្បដិនិស្សគ្គៈ (ការរលាស់ចោល ដោយការលះបង់) និង បក្ខន្ទនប្បដិនិស្សគ្គៈ (ការរលាស់ចោលដោយការស្ទុះទៅ) ព្រោះលះបង់នូវកិលេសទាំងឡាយព្រមទាំងខន្ធ និង អភិសង្ខារ ដោយអំណាចតទង្គប្បហានៈ និង ព្រោះការឃើញទោស ក្នុងសង្ខារធម៌ ទើបស្ទុះទៅ ក្នុងព្រះនិព្វានដែលផ្ទុយផ្សេងពីគ្នានឹងសង្ខតធម៌នោះ ដោយការបង្អោនចិត្តទៅ ក្នុងព្រះនិព្វាននោះ ព្រោះហេតុនោះ ភិក្ខុអ្នកប្រកបព្រមដោយអនុបស្សនា មានអនិច្ចានុបស្សនាជាដើមនោះ ទើបលះបង់នូវកិលេសទាំងឡាយបានផង ស្ទុះទៅក្នុងព្រះនិព្វានបានផង តាមន័យដែលបានពោលមកហើយ ទាំងមិនប្រកាន់យក នូវកិលេសទាំងឡាយដោយអំណាចឲ្យវាកើតឡើងផង ទាំងមិនប្រកាន់យកនូវអារម្មណ៍ ដែលជាសង្ខតធម៌ ដោយអំណាចនៃការមិនឃើញទោស(ផង) ព្រោះហេតុនោះ ទើបលោកពោលថា "រលាស់ចោល មិនប្រកាន់យក" ។

(៤៣៩) ឥឡូវនេះ ការលះបង់ចោលនូវធម៌ទាំងឡាយណា ដោយ



ញាណទាំងឡាយនោះ រមែងមានដល់ព្រះយោគាវចរនោះ ដើម្បីសំដែងនូវការលះបង់ចោល នូវធម៌ទាំងឡាយនោះ ទើបលោកពោលថា "ព្រះយោគាវចរ កាលពិចារណាឃើញថា មិនទៀង រមែងលះបង់ចោលនូវនិច្ចសញ្ញា" ដូច្នេះជាដើម ។ ក្នុងពាក្យថា "នន្ទី" បានដល់ តណ្ហា ដែលប្រកបដោយបីតិ ។ ពាក្យដ៏សេសមានន័យដូចពោលមកហើយនុ៎ះឯង ។

(អធិប្បាយសេចក្តីនៃគាថា)

ចំណែកក្នុងគាថាទាំងឡាយ គប្បីជ្រាបអធិប្បាយ ដូចតទៅនេះ ។ ពាក្យថា "វត្ថុសង្កមនា" សេចក្តីថា ការពិចារណាដែលឃើញការបែកធ្លាយនៃរូបហើយ រំកិល(ចិត្ត)ចាកវត្ថុមុន ទៅកាន់វត្ថុផ្សេងទៀត ដោយអំណាចនៃការឃើញ នូវការបែកធ្លាយ នៃចិត្តដែលឃើញ នូវការបែកធ្លាយនោះឯង ម្តងទៀត ។

ពាក្យថា "សញ្ញាយ ច វិវដ្ដនា" គឺ ការពិចារណាដែលលះបង់នូវការកើតឡើងហើយ តាំងនៅស៊ប់ ក្នុងការសូន្យទៅ ។ ពាក្យថា "អាវជ្ជនាពលញ្ចេវ" អធិប្បាយថាៈ ឃើញនូវការបែកធ្លាយ នៃរូបហើយ អាចរំពឹងរក(នូវអារម្មណ៍) មិនដាច់រយៈ ដើម្បីឃើញនូវការបែកធ្លាយនៃចិត្តដែលមានការបែកធ្លាយ ជាអារម្មណ៍ ម្តងទៀត ។ ពាក្យថា "បដិសង្ខាវិបស្សនា" សេចក្តីថា ការពិចារណាអារម្មណ៍នោះ ឈ្មោះថា ភង្គានុបស្សនា ។ ពាក្យថា "អារម្មណាន្វយេនេវ ឧភោ ឯកវវត្ថានា" សេចក្តីថា ការកំណត់នូវសភាពទាំងពីរថា តែមួយនោះឯងយ៉ាងនេះថា "សង្ខារនេះ រមែងបែកធ្លាយ យ៉ាងណា, សូម្បីសង្ខារ ក្នុងកាលកន្លងទៅហើយក៏បានបែកធ្លាយហើយ សង្ខារ ក្នុងអនាគតសោត ក៏នឹងបែកធ្លាយយ៉ាងដូច្នោះដែរ" ដូច្នេះ តាមបែបបទ គឺតាមលំដាប់លំដោយ ។

*ក៏សេចក្តីនេះ បុរាណាចារ្យទាំងឡាយ ក៏បានពោលហើយដែរថា :*

> ព្រះយោគាវចរ អ្នកមានទស្សនៈ បរិសុទ្ធស្អាតហើយ ក្នុងសង្ខារដែលមានក្នុងបច្ចុប្បន្ន រមែងនាំនូវទស្សនៈ តាមដែលបានយល់ឃើញទៅ ក្នុងសង្ខារ ដែលជាអតីតៈ និង អនាគត ថាៈ សង្ខារទាំងឡាយទាំងពួង មានការបែកធ្លាយទៅជាប្រក្រតី ប្រៀបដូចជាតំណក់ទឹកសន្សើម កាលបើព្រះអាទិត្យ រះឡើងហើយ ក៏ស្ងួតហួតហែងអស់ទៅ យ៉ាងដូច្នោះឯង ។

*ពាក្យថា* “និរោធេ អធិមុត្តតា” *សេចក្តីថាៈ ការដែលបុគ្គលធ្វើនូវការកំណត់សង្ខារទាំងពីរយ៉ាង ថា តែមួយ ដោយអំណាចនៃការបែកធ្លាយ យ៉ាងនេះហើយ មានចិត្តចុះស៊ប់ ក្នុងការរលត់ ពោលគឺការបែកធ្លាយនោះឯង សេចក្តីថា ជាអ្នកធ្ងន់ក្នុងការរលត់នោះ បង្អោនទៅក្នុងការរលត់នោះ ជ្រេទៅ ក្នុងការរលត់នោះ ផ្តេកផ្តួលទៅ ក្នុងការរលត់នោះ ។ ពាក្យថា* “វយលក្ខណវិបស្សនា” *មានពាក្យអធិប្បាយថា ការពិចារណានោះ ឈ្មោះថា ការពិចារណាឃើញលក្ខណៈនៃការសូន្យទៅ។ ពាក្យថា* “អារម្មណញ្ច បដិសង្ខា” *គឺដឹងនូវអារម្មណ៍ មានរូបារម្មណ៍ជាដើមដែលជាអារម្មណ៍ខាងដើមផង ។ ពាក្យថា* “ភង្គញ្ច អនុបស្សតិ” *គឺឃើញនូវការបែកធ្លាយនៃអារម្មណ៍ខាងដើមនោះហើយ ឃើញនូវការបែកធ្លាយនៃចិត្តដែលមានអារម្មណ៍ខាងដើមនោះជាអារម្មណ៍ ។ ពាក្យថា* “សុញ្ញតោ ច ឧបដ្ឋានំ” *គឺកាលបើព្រះយោគាវចរនោះ ពិចារណាឃើញនូវការបែកធ្លាយនៃសង្ខារនោះយ៉ាងនេះ ការប្រាកដថា សោះសូន្យ ថា “សង្ខារទាំង*



*ឡាយហ្នឹង បែកធ្លាយ, ការបែកធ្លាយនៃសង្ខារទាំងឡាយនោះ ឈ្មោះថា មរណៈ មិនមានអ្វីៗ ផ្សេងពីនេះទេ” ដូច្នេះ រមែងចំរើនឡើង ។*

*ព្រោះហេតុនោះ ទើបបុរាណាចារ្យទាំងឡាយ ពោលថា :*

> ខន្ធទាំងឡាយ រមែងរលត់ទៅ របស់ដទៃទៀត មិនមានឡើយ ការបែកធ្លាយនៃខន្ធទាំងឡាយ ហៅថា មរណៈ ព្រះយោគាវចរអ្នកមិនប្រមាទ រមែងឃើញនូវការអស់ទៅ នៃខន្ធទាំងឡាយនោះ ប្រៀបដូចជាបុគ្គលចោះ នូវកែវមណី ដោយពេជ្រ ដោយឧបាយនៃប្រាជ្ញា យ៉ាងនោះឯង ។

*ពាក្យថា* “អធិប្បញ្ញា វិបស្សនា” *អធិប្បាយថា ការពិចារណាអារម្មណ៍ណាមួយក្តី ការពិចារណាឃើញនូវការបែកធ្លាយណាមួយក្តី ការប្រាកដថា សោះសូន្យណាក្តី ទាំងបីយ៉ាងនេះ ឈ្មោះថា អធិប្បញ្ញា វិបស្សនា ។ ពាក្យថា* “កុសលោ តីសុ អនុបស្សនាសុ” *គឺ ភិក្ខុអ្នកឆ្លាតវាងវៃ ក្នុងអនុបស្សនា ៣ មានអនិច្ចានុបស្សនាជាដើម ។ ពាក្យថា* “ចតស្សោ ច វិបស្សនាសុ” *គឺ ក្នុងវិបស្សនា ៤ មាននិព្វិទានុបស្សនាជាដើមផង ។ ពាក្យថា* “តយោ ឧបដ្ឋានេ កុសលតា” *គឺ ព្រោះជាអ្នកឆ្លាតក្នុងការប្រាកដទាំង៣ នេះ គឺថាអស់ទៅ ថាសូន្យទៅ ថាសោះសូន្យទៅផង ។ ពាក្យថា* “នានាទិដ្ឋីសុ ន កម្បតិ” *គឺ រមែងមិនញាប់ញ័រ ព្រោះទិដ្ឋិទាំងឡាយ មានប្រការផ្សេងៗ មានសស្សតទិដ្ឋិ ជាដើម ។*

*ព្រះយោគាវចរនោះ កាលមិនញាប់ញ័រ យ៉ាងនេះ មានការធ្វើទុកក្នុងចិត្ត ដែលប្រព្រឹត្តទៅថា “របស់ដែលមិនរលត់នុ៎ះឯង កំពុងតែរលត់*

របស់ដែលមិនទាន់បែកធ្លាយហ្នឹងឯង កំពុងតែបែកធ្លាយ” ដូច្នេះ រមែងលះបង់ចោលនូវនិមិត្តនៃការកើតឡើង ការតាំងនៅ និង ការប្រព្រឹត្តិទៅនៃសង្ខារទាំងពួងហើយ ឃើញនូវការបែកធ្លាយតែម្យ៉ាងប៉ុណ្ណោះ ប្រៀបដូចជាឃើញ នូវបំណែកភាជនៈបាក់បែក ដែលគេកំពុងតែបំបែកចោល ដូចជាឃើញនូវបំណែកនៃធូលីដ៏ល្អិត ដែលបុគ្គលកំពុងតែរោយចុះ និង ប្រៀបដូចជាឃើញនូវបំណែកនៃគ្រាប់ល្ងទាំងឡាយ ដែលគេកំពុងតែលីង យ៉ាងនោះឯង ។ ព្រះយោគាវចរនោះ រមែងឃើញថា “សង្ខារទាំងឡាយទាំងពួងកំពុងតែបែកធ្លាយៗ” ដូច្នេះ ឧបមាដូចជាបុរសអ្នកមានចក្ខុ(ល្អ) ឈរនៅក្បែរមាត់ស្រះបោក្ខរណី ឬ ក្បែរមាត់ស្ទឹង កាលបើភ្លៀងមានគ្រាប់ដ៏ធ្ងាស ធ្លាក់ចុះមក ក៏ឃើញនូវពពុះទឹកធំៗ លើផ្ទៃទឹក ដែលកើតឡើងហើយៗ ក៏បែករលាយទៅវិញ យ៉ាងឆាប់រហ័ស យ៉ាងនោះឯង ។ ពិតមែន ព្រះមានព្រះភាគ ទ្រង់សំដៅយកព្រះយោគាវចរនោះ ត្រាស់ថា

> បុគ្គលឃើញពពុះទឹក យ៉ាងណា ឃើញព្រេញថ្ងៃ
> យ៉ាងណា ស្ដេចមច្ចុរាជ មិនឃើញអ្នកពិចារណា
> ខន្ធលោកជាដើម យ៉ាងនោះទេ [១] ។

(អានិសង្សភង្គានុបស្សនាញាណ)

(៤៤០) កាលបើព្រះយោគាវចរនោះ ឃើញរឿយៗ យ៉ាងនេះថា “សង្ខារទាំងឡាយទាំងពួង កំពុងតែបែកធ្លាយៗ” ដូច្នេះ ភង្គានុបស្សនាញាណ ដែលមានអានិសង្ស ៨ ជាបរិវារ ជាញាណមានកម្លាំង ។ នេះជាអានិសង្ស ៨ ក្នុងពាក្យនោះ គឺ :

---

១- សុ. ខុ. បដិ. ភាគទី ៥២ ទំព័រទី ៥៨ ។



(១) ភវទិដ្ឋិប្បហានំ ការលះបង់នូវភវទិដ្ឋិ,

(២) ជីវិតនិកន្តិបរិច្ចាគោ ការលះបង់នូវសេចក្ដីត្រេកអរ ក្នុងជីវិត,

(៣) សទា យុត្តប្បយុត្តតា ការប្រកប(ភាវនា)ដ៏ត្រឹមត្រូវសព្វៗកាល,

(៤) វិសុទ្ធាជីវិតា ភាពមានជីវិត ដ៏បរិសុទ្ធ,

(៥) ឧស្សុក្កប្បហានំ ការលះបង់នូវការខ្វល់ខ្វាយ,

(៦) វិគតភយតា ភាពជាអ្នកមិនមានភ័យ,

(៧) ខន្តិសោរច្ចប្បដិលាភោ ការបានចំពោះនូវខន្តី និង សោរច្ចៈ,

(៨) អរតិរតិសហនតា ការគ្របសង្កត់នូវកិរិយាមិនត្រេកអរ និង កិរិយាត្រេកអរបាន ។

ព្រោះហេតុនោះ ទើបបុរាណាចារ្យទាំងឡាយ ពោលថា :

> ព្រះមុនី អ្នក(សំគាល់ខ្លួន) ប្រៀបដូចជាបុគ្គលមាន
> សំពត់ និង ក្បាល ត្រូវភ្លើងកំពុងឆេះ ឃើញគុណ
> ដ៏ខ្ពស់ខ្ពស់ ៨ យ៉ាងនេះហើយ ពិចារណា ក្នុងភង្គា-
> នុបស្សនានោះ ជារឿយៗ រមែងបានជាភង្គានុបស្សី-
> បុគ្គល ដើម្បីបានសំរេចនូវអមតធម៌ ដូច្នេះឯង ។

កង្គានុបស្សនាញាណ ចប់ហើយ ។

❈ ✤ ❈

(ភយតុបដ្ឋានញាណ)

កាលបើព្រះយោគាវចរនោះ សេពច្រើន ចំរើន ធ្វើឲ្យច្រើននូវភង្គានុបស្សនា ដែលមានការអស់ទៅសូន្យទៅ បែកធ្លាយទៅ រលត់ទៅនៃសង្ខារទាំងពួងជាអារម្មណ៍ យ៉ាងនេះ សង្ខារទាំងឡាយ ដែលមានការ

បែកធ្លាយទៅ ក្នុងភព កំណើត គតិ ឋិតិ និង សត្តាវាសទាំងពួង រមែងប្រាកដ ជារបស់ដែលគួរឲ្យភ័យខ្លាច យ៉ាងសម្បើម ប្រៀបដូចជាសត្វដែលគួឲ្យភ័យខ្លាចទាំងឡាយ មានសីហៈ, ខ្លាធំ, ខ្លាដំបង, ខ្លាឃ្មុំ, ខ្លារខិន, យក្ស, អារក្សទឹក, គោកាច, ឆ្កែកាច, ដំរីចុះប្រេងដែលកាច, ពស់មានពិសដ៏កំណាច(អាសិរ្ពិស), ផ្គររន្ទះ, ទីស្មសាន, ទីសមរភូមិ, និងរណ្ដៅដែលពេញដោយរងើកភ្លើងកំពុងឆេះជាដើម រមែងប្រាកដជារបស់គួរឲ្យភ័យខ្លាចយ៉ាងខ្លាំង ដល់បុរសអ្នកខ្លាចហើយ ជាអ្នកប្រាថ្នានូវជីវិតដោយងាយ យ៉ាងនោះឯង ។ កាលបើព្រះយោគាវចរនោះ ឃើញថា "សង្ខារទាំងឡាយ ជាអតីត រលត់ទៅហើយ ដែលជាបច្ចុប្បន្ន កំពុងតែរលត់ សូម្បីសង្ខារទាំងឡាយ ដែលនឹងកើតឡើង ក្នុងអនាគត ក៏នឹងរលត់ទៅយ៉ាងដូច្នោះដែរ" ដូច្នេះ ញាណ ឈ្មោះថា ភយតុបដ្ឋានញាណ រមែងកើតឡើង ក្នុងឱកាសនោះ ។

នេះជាសេចក្ដីឧបមា ក្នុងភយតុបដ្ឋានញាណនោះ ។ បានឮមកថា កូនប្រុស៣ នាក់ របស់ស្រីម្នាក់ បានធ្វើខុសចំពោះព្រះរាជា ។ ព្រះរាជាត្រាស់បញ្ជាឲ្យកាត់ក្បាលកូនទាំង ៣ នាក់នោះ ។ ស្ត្រីជាមាតានោះ បានទៅកាន់កន្លែងដែលសម្លាប់ ព្រមជាមួយកូនទាំងឡាយ ។ គ្រានោះ រាជបុរស បានកាត់ក្បាលកូនប្រុសច្បងហើយ ក៏ចាប់ផ្ដើមកាត់ក្បាលកូនប្រុសកណ្ដាល ។ នាងជាមាតា ឃើញក្បាលកូនច្បងដាច់ហើយ និងឃើញ ក្បាលកូនកណ្ដាលកំពុងតែដាច់ ក៏លះបង់សេចក្ដីអាល័យ ក្នុងកូនពៅ ដោយគិតថា "សូម្បីកូនពៅនេះ ក៏នឹងដូចគ្នានឹងកូនទាំងពីរនោះដែរ" ដូច្នេះ ។

ក្នុងការឃើញទាំងនោះ ការឃើញនូវការរលត់ទៅ នៃសង្ខារទាំងឡាយដែលជាអតីតៈ របស់ព្រះយោគី ប្រៀបបាននឹងការឃើញក្បាលកូនច្បង របស់ស្ត្រីនោះ ដែលដាច់ហើយ, ការឃើញនូវការរលត់ទៅនៃសង្ខារទាំងឡាយដែលជាបច្ចុប្បន្ន របស់ព្រះយោគី ដូចជាការឃើញនូវក្បាលកូនកណ្ដាល របស់ស្ត្រីនោះ ដែលកំពុងតែដាច់, ការឃើញនូវការរលត់ទៅ នៃសង្ខារទាំងឡាយ ដែលជាអនាគត របស់ព្រះយោគី ដោយឃើញថា "សូម្បីសង្ខារទាំងឡាយ ដែលនឹងកើត ក្នុងអនាគត ក៏នឹងបែកធ្លាយ យ៉ាងនេះ ដូចគ្នាដែរ" ដូច្នេះ ប្រៀបបាននឹងការលះបង់នូវសេចក្ដីអាល័យ ក្នុងកូនពៅ របស់ស្ត្រីនោះ ដោយឃើញថា "សូម្បីកូនពៅនេះ ក៏នឹងដូចគ្នានឹងកូនទាំងពីរនាក់នោះដែរ" ដូច្នេះ ។

កាលបើព្រះយោគីនោះឃើញយ៉ាងនេះ ភយតុបដ្ឋានញាណ រមែងកើតឡើង ក្នុងឱកាសនោះ ។

គប្បីជ្រាបសេចក្ដីឧបមាមួយទៀត ។ បានឮមកថា ស្ត្រីម្នាក់ជាស្រីមានកូនមិនបានល្អ(ស្លាប់) សំរាលទារកបានដប់ ។ បណ្ដាទារកទាំងដប់នោះ ទារក ៩ បានស្លាប់ហើយ ទារកម្នាក់ កំពុងតែស្លាប់ ជាប់នៅនឹងដៃ ។ ទារកម្នាក់ទៀត នៅក្នុងផ្ទៃនាង ។ ស្ត្រីនោះឃើញទារកទី៩ ស្លាប់ហើយ និងទារកទី១០ កំពុងតែស្លាប់ហើយ ក៏លះបង់នូវសេចក្ដីអាល័យក្នុងទារកដែលនៅក្នុងផ្ទៃ ដោយឃើញថា "សូម្បីទារក ដែលនៅក្នុងផ្ទៃនេះ ក៏នឹងដូចជាទារកទាំង ១០ នាក់នោះដែរ" ។

ក្នុងការឃើញទាំងនោះ ការឃើញនូវការរលត់ទៅ នៃសង្ខារដែលជាអតីតៈទាំងឡាយ របស់ព្រះយោគី ប្រៀបដូចជាការរលឹកឃើញដល់សេចក្ដីស្លាប់ របស់ទារក ៩ នាក់ នៃស្ត្រីនោះ, ការឃើញនូវការរលត់ទៅនៃសង្ខារ ដែលជាបច្ចុប្បន្នទាំងឡាយ របស់ព្រះយោគី ប្រៀបដូចជា

ការឃើញនូវភាវៈនៃទារកដែលនៅជាប់នឹងដៃកំពុងតែស្លាប់ នៃស្ត្រីនោះ, ការឃើញនូវការរលត់ទៅ នៃសង្ខារដែលជាអនាគតទាំងឡាយ របស់ព្រះយោគី ប្រៀបដូចជាការលះបង់នូវសេចក្ដីអាល័យ ចំពោះទារកដែលឋិតនៅក្នុងផ្ទៃ នៃស្ត្រីនោះ ។

កាលបើព្រះយោគីនោះ ឃើញយ៉ាងនេះ ភយតុបដ្ឋានញាណ ក៏កើតឡើង ក្នុងខណៈនោះ ។

សួរថា "ក៏ភយតុបដ្ឋានញាណ ភ័យខ្លាច ឬមិនភ័យខ្លាច? ។ ឆ្លើយថា "មិនភ័យខ្លាចទេ" ។ ព្រោះថា ភយតុបដ្ឋានញាណនោះ គ្រាន់តែជាការពិចារណាថា "សង្ខារទាំងឡាយដែលជាអតីតរលត់ទៅហើយ ដែលជាបច្ចុប្បន្ន កំពុងតែរលត់ ដែលជាអនាគត នឹងរលត់" ដូច្នេះប៉ុណ្ណោះ ព្រោះហេតុនោះ ទើបប្រៀបបាននឹងបុរសមានចក្ខុ សំឡឹងឃើញរណ្ដៅនៃរងើកភ្លើង ៣ រណ្ដៅ ក្បែរទ្វារនគរ ខ្លួនឯងមិនបានភ័យខ្លាច បុរសនោះគ្រាន់តែមានការពិចារណាថា "សត្វទាំងឡាយណាៗ នឹងធ្លាក់ទៅក្នុងរណ្ដៅនៃរងើកភ្លើងនេះ សត្វទាំងឡាយនោះៗ នឹងទទួលនូវសេចក្ដីទុក្ខច្រើនជាអនេក" ដូច្នេះតែម្យ៉ាងប៉ុណ្ណោះឯង យ៉ាងណាមិញ ឬ បើមិនដូច្នោះទេ ប្រៀបដូចជាបុរសអ្នកមានចក្ខុ សំឡឹងមើលនូវចម្រូង៣ ដែលគេដោត តាមលំដាប់គ្នា គឺចម្រូងសង្កែ ចម្រូងដែក ចម្រូងមាស ក៏មិនភ័យខ្លាច បុរសនោះ គ្រាន់តែមានការពិចារណាតែម្យ៉ាងប៉ុណ្ណោះឯង ថា "សត្វទាំងឡាយណាៗ នឹងធ្លាក់ទៅ ក្នុងចម្រូងទាំង៣ នោះ, សត្វទាំងឡាយនោះៗ នឹងបានទទួលនូវសេចក្ដីទុក្ខច្រើនជាអនេក" ដូច្នេះ យ៉ាងណាមិញ, ភយតុបដ្ឋានញាណ ក៏យ៉ាងដូច្នោះដែរ ខ្លួនឯង មិនបានភ័យខ្លាច ភយតុបដ្ឋានញាណនោះ គ្រាន់តែមានការពិចារណាតែប៉ុណ្ណោះឯង



ថា "សង្ខារទាំងឡាយជាអតីតៈ ក្នុងភពទាំងឡាយបី ដែលដូចជារណ្ដៅរងើកភ្លើង ៣ និង ដូចជាចម្រូង ៣ រលត់ទៅហើយ ដែលជាបច្ចុប្បន្ន កំពុងតែរលត់ ដែលជាអនាគត នឹងរលត់" ដូច្នេះ ។ តែព្រោះសង្ខារទាំងឡាយ ដែលប្រព្រឹត្តទៅ ក្នុងភព, កំណើត, គតិ, ឋិតិ និង និវាស ទាំងពួង ជារបស់ដែលដល់នូវការវិនាស មានភ័យចំពោះមុខ រមែងប្រាកដថា គួរឲ្យភ័យខ្លាច ដល់ញាណនោះតែម្យ៉ាងគត់ ព្រោះហេតុនោះ ញាណនោះទើបលោកហៅថា ភយតុបដ្ឋាន (ឃើញសង្ខារថាគួរឲ្យភ័យខ្លាច) ។

(បាលីភយតុបដ្ឋានញាណ)

ក៏បាឋៈនេះ ជាបាលីក្នុងការប្រាកដថា ជាភ័យ ដូចបានពោលមកហើយ នៃញាណនោះថា "សួរថា: កាលព្រះយោគាវចរ ធ្វើទុកក្នុងចិត្តថា មិនទៀង តើមានអ្វីប្រាកដឡើងថា ជាភ័យ ការធ្វើទុកក្នុងចិត្តថា ជាទុក្ខ តើមានអ្វីប្រាកដឡើងថា ជាភ័យ កាលធ្វើទុកក្នុងចិត្តថា មិនមែនខ្លួន តើមានអ្វីប្រាកដឡើងថា ជាភ័យ? ។ ឆ្លើយថា: កាលព្រះយោគាវចរ ធ្វើទុកក្នុងចិត្តថា មិនទៀង មាននិមិត្តប្រាកដឡើងថា ជាភ័យ កាលធ្វើទុកក្នុងចិត្តថា ជាទុក្ខ មានបវត្តៈប្រាកដឡើងថា ជាភ័យ កាលធ្វើទុកក្នុងចិត្តថា មិនមែនខ្លួន មាននិមិត្តផង មានបវត្តៈផងប្រាកដឡើងថា ជាភ័យ" ដូច្នេះ ។

(កែអត្ថនៃបាលីភយតុបដ្ឋានញាណ)

បណ្ដាបាឋៈទាំងនោះ បាឋៈ ថា "និមិត្តំ" បានដល់ សង្ខារនិមិត្ត ។ ពាក្យថា "និមិត្ត" នុ៎ះ គឺជាឈ្មោះ នៃសង្ខារទាំងឡាយ ដែលជាអតីតៈ អនាគត និង បច្ចុប្បន្ន ។ មែនពិត ភិក្ខុកាលធ្វើទុកក្នុងចិត្តថា មិនទៀង រមែងឃើញនូវមរណៈ នៃសង្ខារទាំងឡាយតែម្យ៉ាងប៉ុណ្ណោះ ព្រោះហេតុ

នោះ និមិត្ត ទើបប្រាកដថា ជាភ័យ ដល់ភិក្ខុនោះ ។

បាឋៈថា "បវត្តៈ" បានដល់ ការប្រព្រឹត្តិទៅ ក្នុងរូបភព និង អរូបភព ។ មែនពិត ភិក្ខុកាលធ្វើទុកក្នុងចិត្តថា ជាទុក្ខ រមែងឃើញនូវភាវៈគឺការបៀតបៀនរឿយៗ ប៉ុណ្ណោះ នៃការប្រព្រឹត្តិទៅ សូម្បីដែលសំគាល់ថាជាសុខ ហេតុនោះ បវត្តៈ ទើបប្រាកដឡើងថា ជាភ័យ ដល់ភិក្ខុនោះ។

ឯភិក្ខុធ្វើទុកក្នុងចិត្តថា មិនមែនខ្លួន រមែងឃើញនិមិត្ត និង បវត្តៈទាំងពីរនោះ ថា ទទេ ថា សូន្យ ថា សោះសូន្យ ថា ឥតមានម្ចាស់ ថាមិនមានអ្នកណាដឹកនាំ ដូចជាផ្ទះទទេ និង ដូចជាថ្ងៃបណ្តើរកូន និង នគរគន្ធព្វជាដើម ព្រោះហេតុនោះ និមិត្ត និង បវត្តៈ ទើបប្រាកដឡើងថា ជាភ័យ ដល់ភិក្ខុនោះ ដូច្នេះឯង ។

ភយតុបដ្ឋានញាណ ចប់ហើយ ។

❀ ✤ ❀

(អាទីនវានុបស្សនាញាណ)

(៤៤១) កាលបើព្រះយោគាវចរនោះ សេព ចំរើន ធ្វើឲ្យច្រើន នូវភយតុបដ្ឋានញាណនោះ ទីពឹងផ្អែក មិនប្រាកដ ទីជ្រកកោន មិនប្រាកដ ទីទៅ មិនប្រាកដ ទីពឹងអាស្រ័យ ក៏មិនប្រាកដ ក្នុងភព, កំណើត, គតិ, ឋិតិ និង សត្តាវាសទាំងពួង, ការប្រាថ្នា ឬ ការស្ទាបអង្អែល ក្នុងសង្ខារទាំងឡាយដែលប្រព្រឹត្តទៅ ក្នុងភព, កំណើត, គតិ, ឋិតិ និង សត្តាវាស សូម្បីតែសង្ខារមួយ ក៏មិនមាន ។ ភព ៣ ប្រាកដ ដូចរណ្តៅរងើកភ្លើងដែលពេញដោយធ្យូង ប្រាសចាកអណ្តាតភ្លើង, មហាភូតរូប ៤ ប្រាកដឡើងដូចជាអាសិរពិសដែលមានពិសកំណាច, ខន្ធ ៥ ប្រាកដឡើងដូចជាពេជ្ឈឃាតអ្នកលើកដាវដើម្បីនឹងសម្លាប់, អាយតនៈខាងក្នុង ៦ ប្រាកដ



ឡើងដូចជាស្រុកដែលគ្មានមនុស្សនៅ(ស្រុកស្ងាត់), អាយតនៈខាងក្រៅ ៦ ប្រាកដឡើង ដូចជាចោរប្លន់ស្រុក, មួយទៀត វិញ្ញាណឋិតិ ៧ និង សត្តាវាស ៩ ត្រូវភ្លើង ១១ ឆេះហើយ រមែងប្រាកដឡើង បីដូចជាឆេះសន្ធោសន្ធៅ, សង្ខារទាំងឡាយទាំងពួង រមែងប្រាកដឡើង ដូចជាបូស ដូចជារោគ ដូចជាដែកស្រួច(លំពែង) ដូចជាសេចក្តីទុក្ខលំបាក និង ដូចជាជម្ងឺ ជាគំនរ នៃទោសដ៏ធំធេង ប្រាសចាកសេចក្តីប្រាថ្នា ប្រាសចាកសេចក្តីពេញចិត្ត ។ សួរថា "តើដូចម្តេច? ។ ឆ្លើយថា "ដូចជាព្រៃស្ទាប់សូម្បីតាំងនៅព្រមដោយអាការៈជាទីមនោរម្យ តែមានសត្វសាហាវ ដូចជាគុហាដែលមានសត្វខ្លា ដូចជាទឹកដែលមានអារក្សទឹកចាំចាប់ ដូចជាសត្រូវអ្នកលើកដាវចាំកាប់ ដូចជាភោជនដែលមានពិសពុល ដូចជាផ្លូវដែលមានចោរ ដូចជាផ្ទះដែលត្រូវភ្លើងឆេះ ដូចជាសមរភូមិដែលមានទាហ៊ានដែលគេបញ្ជូនទៅដើម្បីធ្វើសឹកសង្គ្រាម រមែងប្រាកដឡើងថា ជាភ័យ ដោយឆាយ ដល់បុរសអ្នកភ័យខ្លាចហើយ អ្នកស្រឡាញ់ជីវិត ។ មែនពិត បុរសនោះ មកដល់កន្លែងមានភ័យទាំងឡាយ មានព្រៃស្ទាប់ដែលមានសត្វកាចសាហាវជាដើមនោះហើយ ជាអ្នកភ័យស្ញុំ ព្រឺរោមឃើញមានតែទោសនៅជុំវិញ(ខ្លួន) យ៉ាងណាមិញ, ព្រះយោគាវចរនេះក៏យ៉ាងដូច្នោះដែរ កាលបើសង្ខារទាំងពួងប្រាកដឡើងថា ជាភ័យ ដោយអំណាច នៃការពិចារណាឃើញការបែកធ្លាយ (នៃសង្ខារ)ហើយ រមែងឃើញតែទោស ដែលប្រាសចាកសេចក្តីពេញចិត្ត ប្រាសចាកសេចក្តីប្រាថ្នា ដោយជុំវិញ(ខ្លួន) ។ កាលបើព្រះយោគាវចរនោះ ឃើញយ៉ាងនេះ អាទីនវញាណ រមែងកើតឡើង ដែលលោកសំដៅយកពោលពាក្យនេះហើយ ថា :

(បាលីក្នុងអាទីនវានុបស្សនាញាណ)

*“សួរថា: បញ្ញា ក្នុងការប្រាកដឡើងថា ជាភ័យ ឈ្មោះថាអាទីនវ-ញាណ តើដូចម្តេច? [១] ។ ឆ្លើយថា: បញ្ញា ក្នុងការប្រាកដឡើងថាជាភ័យ ថា “ការកើតជាភ័យ” ឈ្មោះថា អាទីនវញាណ, បញ្ញា ក្នុងការប្រាកដឡើងថាជាភ័យថា “ការប្រព្រឹត្តិជាភ័យ” ឈ្មោះថាអាទីនវញាណ, ថា និមិត្តជាភ័យ ។ល។ បញ្ញា ក្នុងការប្រាកដឡើងថាជាភ័យ ថា “ការប្រមូលមក ជាភ័យ” ថា “បដិសន្ធិ ជាភ័យ” ថា “គតិ ជាភ័យ” ថា “ការប្រព្រឹត្តិ ជាភ័យ” ថា “ការកើត ជាភ័យ” ថា “ជាតិ ជាភ័យ” ថា “ជរា ជាភ័យ” ថា “ព្យាធិ ជាភ័យ” ថា “មរណៈ ជាភ័យ” ថា “សោក ជាភ័យ” ថា “ការខ្សឹកខ្សួលជាភ័យ” ថា “ការចង្អៀតចង្អល់ចិត្តជាភ័យ” ឈ្មោះថា អាទីនវញាណ, ញាណ ក្នុងសន្តិបទ(បទស្ងប់រម្ងាប់)ថា “ការមិនកើត ជាសេចក្តីក្សេម” ញាណក្នុងសន្តិបទថា “ការមិនប្រព្រឹត្តិ ជាសេចក្តីក្សេម” ។ល។ ញាណក្នុងសន្តិបទថា “សេចក្តីមិនចង្អៀតចង្អល់ចិត្ត ជាសេចក្តីក្សេម” ញាណ ក្នុងសន្តិបទថា “ការកើតជាភ័យ ការមិនកើតឡើង ជាសេចក្តីក្សេម” ញាណ ក្នុងសន្តិបទថា “ការប្រព្រឹត្តិ ជាភ័យ ការមិនប្រព្រឹត្តិ ជាសេចក្តីក្សេម” ។ល។ ញាណ ក្នុងសន្តិបទថា “ការចង្អៀតចង្អល់ចិត្ត ជាភ័យ ការមិនចង្អៀតចង្អល់ចិត្ត ជាសេចក្តីក្សេម” បញ្ញា ក្នុងការប្រាកដឡើងថា ជាភ័យ ថា “ការកើត ជាទុក្ខ” ឈ្មោះថាអាទីនវញាណ ។ល។ បញ្ញា ក្នុងការប្រាកដឡើងថា ជាភ័យ ថា “ការប្រព្រឹត្តិ ជាទុក្ខ” ។ល។ បញ្ញា ក្នុងការប្រាកដឡើងថា ជាភ័យ ថា “ការខ្សឹកខ្សួល ជាទុក្ខ” ឈ្មោះថា អាទីនវញាណ, ញាណ ក្នុងសន្តិបទថា “ការមិនកើត ជាសុខ” ថា “ការមិនប្រព្រឹត្តិជាសុខ” ។ល។ ញាណ ក្នុងសន្តិបទថា “ការមិនចង្អៀតចង្អល់ចិត្ត ជាសុខ”, ញាណក្នុងសន្តិបទថា “ការកើតជាទុក្ខ ការមិនកើតជាសុខ” ញាណក្នុងសន្តិបទថា “ការប្រព្រឹត្តិ ជាទុក្ខ ការមិនប្រព្រឹត្តិ ជាសុខ” ញាណ ក្នុងសន្តិបទថា “ការចង្អៀតចង្អល់ចិត្ត ជាទុក្ខ ការមិនចង្អៀតចង្អល់ចិត្ត ជាសុខ”,*

*បញ្ញា ក្នុងការប្រាកដឡើងថា ជាភ័យ ថា “ការកើត ប្រកបដោយអាមិស” ឈ្មោះថាអាទីនវញាណ, បញ្ញាក្នុងការប្រាកដឡើងថា ជាភ័យថា “ការប្រព្រឹត្តិប្រកបដោយអាមិស” ឈ្មោះថា អាទីនវញាណ ។ល។ បញ្ញា ក្នុងការប្រាកដឡើងថា ជាភ័យថា “ការចង្អៀតចង្អល់ចិត្ត ប្រកបដោយអាមិសៈ” ឈ្មោះថាអាទីនវញាណ, ញាណ ក្នុងសន្តិបទថា “ការមិនកើត មិនប្រកបដោយអាមិសៈ” ញាណ ក្នុងសន្តិបទថា “ការមិនប្រព្រឹត្តិ មិនប្រកបដោយអាមិសៈ” ។ល។ ញាណ ក្នុងសន្តិបទ ថា “ការមិនចង្អៀតចង្អល់ចិត្ត មិនប្រកបដោយអាមិស” ញាណក្នុងសន្តិបទថា“ការកើតប្រកបដោយអាមិសៈ ការមិនកើតមិនប្រកបដោយអាមិសៈ” ញាណក្នុងសន្តិបទថា “ការប្រព្រឹត្តិប្រកបដោយអាមិសៈ ការមិនប្រព្រឹត្តិ មិនប្រកបដោយអាមិសៈ” ។ល។ ញាណ ក្នុងសន្តិបទថា “ការចង្អៀតចង្អល់ចិត្ត ប្រកបដោយអាមិសៈ ការមិនចង្អៀតចង្អល់ចិត្ត មិនប្រកបដោយអាមិសៈ,*

*បញ្ញាក្នុងការប្រាកដឡើងថាជាភ័យថា “ការកើតជាសង្ខារ” ឈ្មោះថា អាទីនវញាណ, បញ្ញាក្នុងការប្រាកដឡើងថាជាភ័យថា “ការប្រព្រឹត្តិជាសង្ខារ” ។ល។ បញ្ញាក្នុងការប្រាកដឡើងថាជាភ័យថា “ការចង្អៀតចង្អល់ចិត្ត ជាសង្ខារ” ឈ្មោះថា អាទីនវញាណ, ញាណ ក្នុងសន្តិបទថា*

---

*១- សុ. ខុ. បដិ. ភាគទី ៦៩ ទំព័រទី ១៣២ ។*

*“ការមិនកើតជានិព្វាន” ថា “ការមិនប្រព្រឹត្តិ ជានិព្វាន” ។ល។ ញាណ ក្នុងសន្តិបទថា “ការមិនចង្អៀតចង្អល់ចិត្ត ជានិព្វាន” ញាណ ក្នុងសន្តិបទ ថា “ការកើត ជាសង្ខារ ការមិនកើត ជានិព្វាន” ញាណ ក្នុងសន្តិបទថា “ការប្រព្រឹត្តិ ជាសង្ខារ ការមិនប្រព្រឹត្តិ ជានិព្វាន” ។ល។ ញាណ ក្នុងសន្តិបទថា “ការចង្អៀតចង្អល់ចិត្ត ជាសង្ខារ ការមិនចង្អៀតចង្អល់ចិត្ត ជានិព្វាន” ។*

> បុគ្គលឃើញនូវការកើត នូវការប្រព្រឹត្តិ នូវនិមិត្ត នូវការប្រមូលមក និង បដិសន្ធិ ថា ជាទុក្ខ, នេះឈ្មោះថា អាទីនវញ្ញាណ, បុគ្គលឃើញនូវការមិនកើត នូវការមិនប្រព្រឹត្តិ នូវការមិនមាននិមិត្ត នូវការមិនប្រមូលមក និងការមិនមានបដិសន្ធិ ថាជាសុខ, នេះឈ្មោះថា ញាណ ក្នុងសន្តិបទ, អាទីនវញ្ញាណនេះ រមែងកើតក្នុងឋានៈ ៥, ញាណ ក្នុងសន្តិបទនេះ តែងកើតក្នុងឋានៈ ៥, បុគ្គល រមែងដឹងច្បាស់ នូវញាណ ១០ (នេះឯង), ភាពនៃបុគ្គលអ្នកឈ្លាសវាងវៃ ក្នុងញាណទាំងពីរ ទើបមិនញាប់ញ័រ ក្នុងទិដ្ឋិផ្សេងៗ ។

*ដែលឈ្មោះថា ញាណ ដោយអត្ថថា ដឹងនូវធម៌នោះ, ឈ្មោះថា បញ្ញា ដោយអត្ថថា ដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា បញ្ញា ក្នុងការប្រាកដឡើងថា ជាភ័យ ឈ្មោះថា អាទីនវញ្ញាណ ។*

(កែអត្ថនៃបាលីអាទីនវញ្ញាណ)

*ក្នុងបាឋៈទាំងនោះ បាឋៈថា “ឧប្បាទោ” បានដល់ការកើតឡើងក្នុង*



*ភពនេះ ព្រោះបច្ច័យគឺកម្មក្នុងភពមុន ។ បាឋៈថា “បវត្តំ” បានដល់ការប្រព្រឹត្តិទៅនៃសង្ខារធម៌ ដែលកើតឡើងហើយយ៉ាងដូច្នោះ ។ បាឋៈថា “និមិត្តំ” បានដល់និមិត្ត គឺសង្ខារទាំងពួង។ បាឋៈថា “អាយូហនា” បានដល់កម្មដែលជាហេតុនៃបដិសន្ធិ តទៅ ។ បាឋៈថា “បដិសន្ធិ” បានដល់ការកើតឡើងតទៅទៀត ។ បាឋៈថា “គតិ” បានដល់គតិដែលបដិសន្ធិមាន ។ បាឋៈថា “និព្វត្តិ” បានដល់ ការកើតឡើង នៃខន្ធទាំងឡាយ ។ បាឋៈថា “ឧបបត្តិ” បានដល់ការប្រព្រឹត្តិទៅនៃវិបាក ដែលលោកពោលហើយយ៉ាងនេះថា “វិបាករមែងមានដល់បុគ្គលអ្នកបានសំរេចខ្លះ ដល់អ្នកចូលទៅដល់ខ្លះ ។ បាឋៈថា “ជាតិ” បានដល់ ជាតិដែលមានព្រោះបច្ច័យ គឺភព ជាបច្ច័យនៃទុក្ខទាំងឡាយមានជាតិទុក្ខជាដើម ។ ធម៌ទាំងឡាយមានជរា និង មរណៈជាដើម ប្រាកដហើយមែនពិត ។ ក៏បណ្តាធម៌ទាំងនោះ ធម៌ទាំងឡាយ ៥ មានការកើតជាដើមប៉ុណ្ណោះ លោកពោលហើយដោយអំណាចវត្ថុនៃអាទីនវញ្ញាណ ។ ធម៌ដ៏សេស លោកពោលហើយ ដោយអំណាចពាក្យជាវេវចនៈនៃធម៌ទាំង ៥ យ៉ាងនោះ ។ មែនពិត ពាក្យ ២ នេះ គឺ “និព្វត្តិ ជាតិ” ជាពាក្យវេវចនៈ នៃឧប្បាទៈ និង បដិសន្ធិនុ៎ះឯង, ពាក្យពីរនេះ គឺ “គតិ ឧបបតិ” ជាពាក្យវេវចនៈ នៃបវត្តៈ, ជរាជាដើម ជាវេវចនៈ នៃនិមិត្តហ្នឹងឯង ។*

*ព្រោះហេតុនោះ ទើបលោកពោលហើយថា :*

> បុគ្គលឃើញនូវការកើត នូវការប្រព្រឹត្តិ នូវនិមិត្ត នូវការប្រមូលមក និង បដិសន្ធិ ថា ជាទុក្ខ, នេះ ឈ្មោះថា អាទីនវញ្ញាណ, ក៏អាទីនវញ្ញាណនេះ តែងកើតក្នុងឋានៈ ៥ ។

ឯពាក្យថា “ញាណ ក្នុងសន្តិបទថា “ការមិនកើតជាសេចក្តីក្សេម” ដូច្នេះជាដើម លោកពោលហើយ ដើម្បីសំដែងនូវញាណ ដែលជាបដិ-បក្ស នៃអាទីនវញាណ ។ម្យ៉ាងទៀត ពាក្យនោះ លោកពោលហើយ ដើម្បីញុំាងសេចក្តីត្រេកអរឲ្យកើតឡើង ដល់ព្រះយោគាវចរទាំងឡាយ ដែលមានចិត្តញាប់ញ័ររន្ធត់ ព្រោះឃើញនូវទោស ដោយការប្រាកដឡើងថាជាភ័យ ថា “សូម្បីហេតុដែលមិនគួរឲ្យភ័យ សេចក្តីក្សេម ហេតុមិនមានទោស ក៏មានដែរ” ។ តែម្យ៉ាងទៀត ធម៌ទាំងឡាយមានការកើតជាដើម រមែងតាំងនៅប្រាកដថាជាភ័យ ចំពោះព្រះយោគាវចរនោះ, ចិត្តរបស់ព្រះយោគាវចរនោះ រមែងបង្អោនទៅរកធម៌ ដែលជាបដិបក្សនោះព្រោះហេតុណា, ព្រោះហេតុនោះ គប្បីជ្រាបថា “ក៏ពាក្យនោះ លោកពោលហើយ ដើម្បីសំដែងនូវអានិសង្ស នៃអាទីនវញាណ ដែលសំរេចដោយអំណាចនៃការប្រាកដឡើងថា ជាភ័យ” ដូច្នេះ ។

មួយទៀត ក្នុងធម៌ដែលជាទោសនេះ របស់ណាជាភ័យ របស់នោះជាទុក្ខ ដោយពិតប្រាកដ, ក៏របស់ណា ជាទុក្ខ របស់នោះ រមែងប្រកបដោយអាមិសតែប៉ុណ្ណោះ ព្រោះមិនរួចផុតអំពីអាមិសក្នុងវដ្តៈ, អាមិសក្នុងលោក និង អាមិសក្នុងកិលេស, មួយទៀត របស់ណាប្រកបដោយអាមិស របស់នោះគ្រាន់តែជាសង្ខារប៉ុណ្ណោះឯង ព្រោះហេតុណា, ព្រោះហេតុនោះ ទើបលោកពោលថា “បញ្ញា ក្នុងការប្រាកដឡើងថា ជាភ័យថា “ការកើតជាទុក្ខ” ឈ្មោះថា អាទីនវញាណ” ដូច្នេះជាដើម ។ កាលបើមានហេតុដូច្នោះ គប្បីជ្រាបការផ្សេងគ្នា ក្នុងធម៌ដែលជាទោសនោះដោយអំណាចនៃការប្រព្រឹត្តិទៅ ព្រោះមានអាការៈផ្សេងគ្នា យ៉ាងនេះ គឺដោយអាការៈ ថា ជាភ័យ ដោយអាការៈ ថា ជាទុក្ខ ដោយអាការៈ ថា



ប្រកបដោយអាមិស” ។

ពាក្យថា “ទស ញាណេ បជានាតិ” អធិប្បាយថា ព្រះយោគាវចរនោះ កាលដឹងច្បាស់នូវអាទីនវញាណ ឈ្មោះថា រមែងដឹងច្បាស់ គឺចាក់ធ្លុះ ធ្វើឲ្យជាក់ច្បាស់នូវញាណ ១០ គឺញាណដែលមានធម៌ ដែលជាទោស មានការកើតជាដើម ជាទីតាំង៥ ញាណមានធម៌ ដែលជាសេចក្តីក្សេមជាដើម ជាទីតាំង ៥ ។

ពាក្យថា “ទ្វិន្នំ ញាណានំ កុសលតា” សេចក្តីថា ព្រោះភាពជាអ្នកឈ្លាសវៃ ក្នុងញាណ ២ នេះ គឺអាទីនវញាណ១ សន្តិបទញាណ១។

ពាក្យថា “នានាទិដ្ឋីសុ ន កម្បតិ” សេចក្តីថា រមែងមិនញាប់ញ័រក្នុងទិដ្ឋិទាំងឡាយ ដែលប្រព្រឹត្តទៅ ដោយអំណាចនៃទិដ្ឋធម្មនិព្វាន ជាបរមត្ថធម៌ជាដើម ។

ពាក្យដ៏សេស ក្នុងបាលីនេះ មានសេចក្តីរាក់ទាំងអស់ ។

អាទីនវានុបស្សនាញាណ ចប់ហើយ ។

❁ ❦ ❁

(និព្វិទានុបស្សនាញាណ)

(៤៤២) ព្រះយោគាវចរនោះ កាលឃើញសង្ខារទាំងឡាយថា ជាទោស យ៉ាងនេះ រមែងនឿយណាយ ធុញទ្រាន់ មិនត្រេកអរ យ៉ាងក្រៃលែង ក្នុងសង្ខារដែលមានការបែកធ្លាយ ប្រព្រឹត្តទៅ ក្នុងភព, កំណើត, គតិ, វិញ្ញាណឋិតិ និង សត្តាវាសទាំងពួង ។ ប្រៀបដូចជាសុវណ្ណរាជ-ហង្ស ដែលត្រេកអរក្បែរជើងភ្នំចិត្តកូដ រមែងមិនត្រេកអរ ក្នុងថ្លុកដែលស្មោកគ្រោកកខ្វក់ ក្បែរទ្វារផ្ទះ នៃមនុស្សចណ្ឌាល រមែងត្រេកអរយ៉ាងក្រៃលែងតែ ក្នុងមហាស្រះ ៧ ប៉ុណ្ណោះឯង យ៉ាងណាមិញ, សូម្បីព្រះ

យោគីរាជហង្សនេះ ក៏យ៉ាងដូច្នោះដែរ រមែងមិនត្រេកអរក្នុងសង្ខារដែលមានការបែកធ្លាយ ដែលមានទោស គឺខ្លួនឃើញជាក់ច្បាស់ហើយ តែរមែងត្រេកអរ តែក្នុងអនុបស្សនា ៧ ប៉ុណ្ណោះ ព្រោះជាអ្នកដល់ព្រមដោយសេចក្តីត្រេកអរក្នុងភាវនា ព្រោះមានភាវនាជាទីត្រេកអរ ។ មួយទៀត ប្រៀបដូចជាសីហៈ ជាស្តេចនៃម្រឹគដែលបុគ្គលឃាំងទុកសូម្បីក្នុងទ្រុងមាសក៏ដោយ ក៏មិនត្រេកអរដែរ តែរមែងត្រេកអរ តែក្នុងព្រៃហិមពាន្ត ដែលមានទំហំប្រមាណបីពាន់យោជន៍តែប៉ុណ្ណោះ យ៉ាងណាមិញ, ព្រះយោគីសីហៈនេះ រមែងមិនត្រេកអរ ក្នុងសុគតិភពទាំង ៣ តែរមែងត្រេកអរ តែក្នុងអនុបស្សនា៣ ប៉ុណ្ណោះឯង ក៏ដូច្នោះដែរ ។ មួយទៀត ប្រៀបដូចជាស្តេចដំរី ឈ្មោះឆទ្ទន្ត ជាដំរី-សសុទ្ធ មានអវយវៈ ៧ [១] យ៉ាង សម្ពស្សនឹងផែនដី មានឫទ្ធិ ហោះហើរទៅលើអាកាសបាន រមែងមិនត្រេកអរ ក្នុងកណ្តាលទីក្រុងទេ រមែងត្រេកអរយ៉ាងក្រៃលែង តែក្នុងស្រះឆទ្ទន្ត និង ព្រៃស្នាប់ ក្នុងព្រៃហិមពាន្តតែប៉ុណ្ណោះ យ៉ាងណាមិញ, ព្រះយោគីវរវារណៈនេះ រមែងមិនត្រេកអរ ក្នុងសង្ខារទាំងពួង រមែងត្រេកអរ តែក្នុងសន្តិបទ ដែលខ្លួនឃើញហើយ ដោយន័យថា "ការមិនកើត ជាសេចក្តីក្សេម" ដូច្នេះជាដើម ក៏យ៉ាងដូច្នោះដែរ ជាអ្នកមានចិត្តបង្អោនទៅ ក្នុងសន្តិបទនោះ ជ្រេទៅ ក្នុងសន្តិបទនោះ ផ្អៀងទៅ ក្នុងសន្តិបទនោះ ដូច្នេះឯង ។

និព្វិទានុបស្សនាញាណ ចប់ហើយ ។

(មុញ្ចិតុកម្យតាញាណ)

(៤៤៣) ក៏និព្វិទានុបស្សនាញាណនេះនោះ ដោយអត្ថ គឺតែមួយ

១- អវយវៈ ៧ គឺ ប្រមោយ, ជើង ៤, កន្ទុយ, ប្រអប់លិង្គ ។



នឹងញាណ២ ខាងដើម ។ ហេតុនោះ ទើបបុរាណាចារ្យទាំងឡាយពោលថា "ភយតុបដ្ឋានញាណ តែមួយហ្នឹងឯង រមែងបាននូវឈ្មោះបី គឺ បានឈ្មោះថា ភយតុបដ្ឋានញាណ ព្រោះបានឃើញសង្ខារទាំងពួងថា ជាភ័យ, បានឈ្មោះថា អាទីនវានុបស្សនា ព្រោះញុំាងទោសក្នុងសង្ខារទាំងពួង ឲ្យកើតឡើង, បានឈ្មោះថា និព្វិទានុបស្សនា ព្រោះមានការនឿយណាយក្នុងសង្ខារទាំងឡាយនោះឯង ។ សូម្បីក្នុងបាលី ក៏លោកពោលហើយថា "បញ្ញា ក្នុងការប្រាកដឡើងថា ជាភ័យក្តី ញាណ ក្នុងអាទីនវៈ (ទោស)ក្តី ការនឿយនាយក្តី ធម៌ទាំងនេះ មានសេចក្តីតែមួយ ផ្សេងគ្នាតែព្យញ្ជនៈប៉ុណ្ណោះឯង" ដូច្នេះ ។

ក៏កាលកុលបុត្រនេះ នឿយណាយធុញទ្រាន់ មិនត្រេកអរ ដោយនិព្វិទាញាណនេះ, ចិត្ត រមែងមិនជាប់ មិនជំពាក់ មិនពាក់ព័ន្ធ ក្នុងសង្ខារទាំងឡាយដែលមានការបែកធ្លាយ ប្រព្រឹត្តទៅ ក្នុងភព, កំណើត, គតិ, វិញ្ញាណឋិតិ និង សត្តាវាសទាំងពួង ជាចិត្តចង់ចេញ ចង់រួចផុត អំពីសង្ខារទាំងពួង ។ ប្រៀបដូចជាអ្វី? ។ ប្រៀបដូចជាសត្វទាំងឡាយ មានជាអាទិ៍យ៉ាងនេះ គឺៈ ត្រីជាប់នៅក្នុងទ្រុង(សំណាញ់) កង្កែបនៅក្នុងមាត់ពស់ មាន់ព្រៃដែលគេក្រុងទុកក្នុងទ្រុង ម្រឹគដែលជាប់អន្ទាក់យ៉ាងជាប់ ពស់នៅនឹងដៃនៃគ្រូពស់ ដំរីចុះប្រេងយ៉ាងខ្លាំង នាគរាជនៅក្នុងមាត់គ្រុឌ ព្រះច័ន្ទ ធ្លាក់ចូលមាត់រាហូ បុរសត្រូវសត្រូវឡោមព័ទ្ធ ជាអ្នកប្រាថ្នាដើម្បីគេចចេញ ប្រាថ្នាដើម្បីរើខ្លួនចេញឲ្យផុតពីចំណងនោះៗ យ៉ាងណា, ចិត្ត របស់ព្រះយោគីនោះ រមែងប្រាថ្នាចង់ចេញ ប្រាថ្នាចង់រើបម្រះចេញ អំពីសង្ខារទាំងពួង ក៏យ៉ាងនោះដែរ ។

លំដាប់នោះ កាលបើព្រះយោគីនោះ មិនមានអាល័យ ក្នុងសង្ខារ

ទាំងពួង ប្រាថ្នាចង់គេច (ខ្លួន) ចេញ ឲ្យផុតពីសង្ខារទាំងពួង យ៉ាងនេះ មុញ្ចិតុកម្យតាញាណ ក៏កើតឡើង ។

មុញ្ចិតុកម្យតាញាណ ចប់ហើយ

❀ ❀ ❀

(បដិសង្ខានុបស្សនាញាណ)

(៤៤៤) ព្រះយោគាវចរនោះ ជាអ្នកប្រាថ្នាដើម្បីនឹងដោះខ្លួន ឲ្យរួចផុតអំពីសង្ខារទាំងឡាយ ដែលមានការបែកធ្លាយ ប្រព្រឹត្តទៅ ក្នុងភព, កំណើត, គតិ, ឋិតិ, និង សត្តាវាស យ៉ាងនេះហើយ ក៏កំណត់យកនូវសង្ខារទាំងនោះឯង ម្តងទៀត លើកឡើងកាន់ត្រៃលក្ខណ៍ ដើម្បីរំដោះខ្លួនចេញអំពីសង្ខារទាំងពួង ដោយបដិសង្ខានុបស្សនាញាណ ។ ព្រះយោគាវចរនោះ រមែងឃើញថា “សង្ខារទាំងឡាយ មិនទៀង” ដោយហេតុទាំងឡាយ មានជាអាទិ៍ ថា :

អនិច្ចន្តិកតោ ថា មិនមែនជារបស់តាំងនៅរៀងរហូតទៅ,
តាវកាលិកតោ ថា ប្រព្រឹត្តទៅ តាមកាលកំណត់,
ឧប្បាទវយបរិច្ឆិន្នតោ ថា ជារបស់កំណត់ទុកហើយដោយការ កើត និង រលត់,
បលោកតោ ថា ជារបស់វិនាសទៅ,
ខណិកតោ ថា ជារបស់ប្រព្រឹត្តទៅតាមខណៈ,
ចលតោ ថា ជារបស់ញាប់ញ័រ
បភង្គុតោ ថា ជារបស់បែកធ្លាយទៅ,
អទ្ធុវតោ ថា ជារបស់មិនទៀងទាត់ស្ថិតស្ថេរ,
វិបរិណាមធម្មតោ ថា មានសេចក្តីប្រែប្រួលជាធម្មតា,



អសារកតោ ថា ជារបស់គ្មានខ្លឹមសារ,
វិភវតោ ថា មិនមានសេចក្តីចំរើន,
សង្ខតតោ ថា ជារបស់ត្រូវបានបច្ច័យប្រជុំតាក់តែង,
មរណតោ ថា មានមរណៈជាធម្មតា

រមែងឃើញថា “សង្ខារទាំងឡាយ ជាទុក្ខ” ដោយហេតុទាំងឡាយមានជាអាទិ៍ ថា :

អភិណ្ហប្បដិបីឡនតោ ថា ជារបស់ត្រូវបៀតបៀនជារឿយៗ,
ទុក្ខមតោ ថា ជារបស់ដែលអត់ទ្រាំបានដោយលំបាក,
ទុក្ខវត្ថុតោ ថា ជាទីកន្លែងនៃទុក្ខ,
រោគតោ ថា ជារោគ,
គណ្ឌតោ ថា ជាបូស,
សល្លតោ ថា ជាសរ,
អឃតោ ថា ជារបស់លំបាក,
អាពាធតោ ថា ជាអាពាធ,
ឦតិតោ ថា ជាចង្រៃ,
ឧបទ្ទវតោ ថា ជាឧបទ្រព,
ភយតោ ថា ជាភ័យ,
ឧបសគ្គតោ ថា ជាឧបសគ្គ,
អតាណតោ ថា មិនមានទីជ្រកកោន,
អលេណតោ ថា មិនមានទីពួន,
អសរណតោ ថា មិនមានទីពឹងពាក់,
អាទីនវតោ ថា ជាទោស,

អឃមូលតោ ថា ជាឫសគល់នៃសេចក្តីលំបាក,

វធកតោ ថា ជាអ្នកសម្លាប់,

សាសវតោ ថា ប្រកបដោយអាសវៈ,

មារាមិសតោ ថា ជាអាមិសនៃមារ,

ជាតិធម្មតោ ថា មានការកើតជាធម្មតា,

ជរាធម្មតោ ថា មានជរាជាធម្មតា,

ព្យាធិធម្មតោ ថា មានព្យាធិជាធម្មតា,

មរណធម្មតោ ថា មានមរណៈជាធម្មតា,

សោកធម្មតោ ថា មានសោកជាធម្មតា,

បរិទេវធម្មតោ ថា មានសេចក្តីខ្សឹកខ្សួលជាធម្មតា,

ឧបាយាសធម្មតោ ថា មានសេចក្តីចង្អៀតចង្អល់ចិត្តជាធម្មតា,

សង្កិលេសិកធម្មតោ ថា មានសេចក្តីសៅហ្មងជាធម្មតា,

រមែងឃើញថា ជារបស់មិនស្អាត ព្រោះជាបរិវារ នៃទុក្ខលក្ខណៈ ដោយហេតុទាំងឡាយ មានជាអាទិ៍ ថា :

អជញ្ញតោ ថា ជារបស់មិនល្អ,

ទុគ្គន្ធតោ ថា ជារបស់មានក្លិនស្អុយ,

ជេគុច្ឆតោ ថា ជារបស់គួរខ្ពើម,

បដិកូលតោ ថា ជារបស់បដិកូល,

អមណ្ឌនហតតោ ថា ជារបស់ដែលកំចាត់បង់ ដោយការតាក់តែង មិនបាន,

វិរូបតោ ថា ជារបស់គួរឆ្អើម,

វិភច្ឆតោ ថា ជារបស់គួរស្អប់ខ្ពើម,



រមែងឃើញ ថា ជាអនត្តា ដោយហេតុទាំងឡាយមានជាអាទិ៍ ថា :

បរតោ ថា ជារបស់ដទៃ,

រិត្តតោ ថា ជាវាល,

តុច្ឆតោ ថា ទទេ,

សុញ្ញតោ ថា ជារបស់សោះសូន្យ,

អស្សាមិកតោ ថា ជារបស់មិនមានម្ចាស់,

អនិស្សរតោ ថា ជារបស់មិនមានអ្នកណាជាធំ,

អវសវត្តិតោ ថា ជារបស់មិនប្រព្រឹត្តទៅក្នុងអំណាច” ដូច្នេះ ។

មែនពិត សង្ខារទាំងឡាយ ឈ្មោះថា គឺព្រះយោគាវចរអ្នកឃើញ យ៉ាងនេះ បានកំណត់លើកឡើងកាន់ត្រៃលក្ខណ៍ ។ សួរថា: ព្រោះហេតុ អ្វី បានជាព្រះយោគាវចរ កំណត់សង្ខារទាំងឡាយនេះ យ៉ាងដូច្នេះ? ។ ឆ្លើយថា: បានជាព្រះយោគាវចរ កំណត់សង្ខារទាំងឡាយ យ៉ាងនេះ ដើម្បីញ៉ាំងឧបាយ នៃការរំដោះ (ខ្លួន) ឲ្យបានសំរេច ។ នេះ ជាឧបមា ក្នុងឧបាយនៃការរំដោះខ្លួននោះ ។

បានឮមកថា: បុរសម្នាក់គិតថា នឹងចាប់ត្រី ហើយចាប់អង្រុត រុតត្រី រុតចុះទៅក្នុងទឹក ។ បុរសនោះ លូកដៃចូលទៅក្នុងមាត់អង្រុតហើយ ចាប់ចំ-ក ពស់ ក្នុងទឹក ទើបមានចិត្តត្រេកអរ ថា អញ ចាប់ត្រីបាន ។ បុរសនោះ គិតថា អញបានត្រីយ៉ាងធំហើយតើ! ហើយក៏លើកយកមក មើល លុះដឹងច្បាស់ថា ជាពស់ ព្រោះឃើញផ្នត់-ក ៣ ជាន់ ក៏ភ័យខ្លាច ឃើញទោស (គ្រោះថ្នាក់) ស្ទាក់ស្ទើរ ក្នុងការចាប់ ទើបប្រាថ្នាចង់លែង ចោល កាលធ្វើឧបាយនៃការលែងពស់ចោល ក៏ច្បូតដៃតាំងពីចុងកន្ទុយ ចេញហើយ លើកដៃឡើងគ្រវី (ពស់) ២-៣ ជុំ លើក្បាល ធ្វើពស់ ឲ្យ

អស់កម្លាំង ហើយបោះចោល ដោយពោលថា នែអាពស់កំណាច! ចូរទៅចុះ រួចហើយ ក៏ប្រញាប់រត់ឡើងមាត់ប្រាំងយ៉ាងលឿន ឈរក្រឡេកមើលផ្លូវដែលខ្លួនបានមក ដោយគិតថា អញបានរួចផុតពីមាត់ពស់យ៉ាងធំហើយ លោកអើយ ! ។

គប្បីជ្រាបសេចក្តីប្រៀបធៀបក្នុងឧបមានោះ ពេលដែលព្រះយោគីនេះ បានទូវអត្តភាពហើយ ត្រេកអរតាំងតែអំពីដើមមក ប្រៀបដូចជាបុរសនោះ ចាប់-ក ពស់ ហើយសប្បាយចិត្តដោយគិតថា ត្រី ដូច្នោះ ។ ការធ្វើការបំបែក(បញ្ចក្ខន្ធ) ដែលជាក្រុម ឲ្យតូចៗ ហើយឃើញនូវត្រៃលក្ខណ៍ ក្នុងសង្ខារទាំងឡាយ នៃព្រះយោគីនេះ ប្រៀបដូចជាការទាញក្បាលពស់ចេញពីមាត់អង្រុតហើយ ឃើញផ្ទត់-ក ៣ ជាន់ របស់បុរសនោះ ។ ញាណ ក្នុងការប្រាកដឡើងថា ជាភ័យ របស់ព្រះយោគីនោះ ប្រៀបដូចជាពេលដែលបុរសនោះភ័យខ្លាចហើយ ។ បន្ទាប់មក ញាណក្នុងការឃើញថា ជាទោស(របស់ព្រះយោគីនោះ)ប្រៀបដូចជាការឃើញទោស(របស់បុរសនោះ)។ ញាណ ក្នុងការឃើញថា គួរឲ្យនឿយណាយ (របស់ព្រះយោគីនោះ) ប្រៀបដូចជាការស្អប់ខ្ពើម ក្នុងការចាប់(ពស់) នៃបុរសនោះ ។ ញាណ ក្នុងការប្រាថ្នាដើម្បីរើខ្លួនឲ្យរួចស្រឡះ (របស់ព្រះយោគីនោះ) ប្រៀបដូចជាការប្រាថ្នា ដើម្បីនឹងលែងពស់ (របស់បុរសនោះ) ។ ការលើកឡើងកាន់ត្រៃលក្ខណ៍ ក្នុងសង្ខារទាំងឡាយ ដោយបដិសង្ខានុបស្សនាញាណ ប្រៀបដូចជាការធ្វើឧបាយ នៃការលែងពស់ (របស់បុរសនោះ) ។ មានឧបមាដូចជាបុរសនោះ គ្រវីពស់ ធ្វើឲ្យមានកម្លាំងចុះអន់ថយ ដើម្បីឲ្យពស់មិនអាចត្រឡប់បែរមកខាំវិញបានហើយបោះចោល យ៉ាងណាមិញ, ព្រះយោគាវចរនេះ ក៏បោះសង្ខារទាំងឡាយ



ចោល ដោយការលើកឡើងកាន់ត្រៃលក្ខណ៍ ធ្វើឲ្យថយកម្លាំងធ្វើឲ្យដល់នូវការមិនអាច ដើម្បីនឹងប្រាកដឡើង ដោយអាការៈថា ទៀង, ថា សុខ, ថា ល្អស្អាត និង ថា ជារបស់ខ្លួន ហើយលះបង់បានយ៉ាងងាយស្រួល មានឧបមេយ្យយ៉ាងនោះឯង ។ ព្រោះហេតុនោះ ទើបពោលថា “ព្រះយោគាវចរនោះ កំណត់ (សង្ខារទាំងឡាយ) យ៉ាងដូច្នេះ ដើម្បីញ៉ាំងឧបាយនៃការរួចស្រឡះ ឲ្យបានសំរេច” ។

ព្រោះការពិចារណា មានប្រមាណប៉ុណ្ណេះ បដិសង្ខាញាណ រមែងកើតឡើង ដល់ព្រះយោគាវចរនោះ (ដូច)ដែលលោកសំដៅយក ពោលហើយថា “សួរថា : កាលព្រះយោគាវចរ [១] ធ្វើទុកក្នុងចិត្តថា ទៀង ញាណ កើតឡើង ព្រោះពិចារណានូវអ្វី កាលធ្វើទុកក្នុងចិត្តថា ជាទុក្ខ ញាណ កើតឡើង ព្រោះពិចារណានូវអ្វី កាលធ្វើទុកក្នុងចិត្តថា មិនមែនខ្លួន ញាណ កើតឡើង ព្រោះពិចារណានូវអ្វី? ។ ឆ្លើយថា: កាលព្រះយោគាវចរធ្វើទុកក្នុងចិត្តថា មិនទៀង ញាណកើតឡើង ព្រោះពិចារណានូវនិមិត្ត កាលធ្វើទុកក្នុងចិត្តថាជាទុក្ខ ញាណកើតឡើង ព្រោះពិចារណានូវការប្រព្រឹត្តិ កាលធ្វើទុក ក្នុងចិត្តថា មិនមែនខ្លួន ញាណ កើតឡើង ព្រោះពិចារណានូវនិមិត្ត និង ការប្រព្រឹត្តិ” ដូច្នេះ ។

ក៏ក្នុងបាលីនេះ ពាក្យថា “និមិត្តំ បដិសង្ខា” សេចក្តីថា ដឹងនូវសង្ខារនិមិត្ត ដោយអំណាចនៃអនិច្ចលក្ខណៈ ថា: សង្ខារនិមិត្ត ជារបស់មិនស្ថិតស្ថេរ ជារបស់ប្រព្រឹត្តទៅ តាមកាលកំណត់ ។ មែនពិត ដឹងមុនហើយ ទើបញាណ កើតឡើងជាខាងក្រោយ ក៏ពិតមែនហើយ ទោះជាដូច្នោះ លោកពោលយ៉ាងនោះ ដោយអំណាចនៃវោហារ ដូចជាពាក្យថា

១- សុ. ខុ. បដិ. ភាគទី ៧០ ទំព័រទី ៣៦០ ។

“មនោវិញ្ញាណ [១] កើតឡើង ព្រោះអាស្រ័យចិត្ត និង ធម៌” ដូច្នេះជាដើម ។ ន័យមួយទៀត គប្បីជ្រាបថា “លោកពោលយ៉ាងនោះ ព្រោះធ្វើពាក្យខាងដើម និង ខាងចុង ឲ្យទៅជាពាក្យតែមួយ ដោយឯកត្តន័យ ។ សេចក្តី ក្នុង ២ បទក្រៅពីនេះ គប្បីជ្រាប ដោយន័យនោះឯង ។

បដិសង្ខានុបស្សនាញាណ ចប់ហើយ

❀ ❀ ❀

(សង្ខារុបេក្ខាញាណ)

(៤៤៥) ព្រះយោគាវចរនោះ លុះកំណត់ថា “សង្ខារទាំងឡាយទាំងពួង ជារបស់សូន្យ” ដោយបដិសង្ខានុបស្សនាញាណ ដូច្នេះហើយ ទើបកំណត់សុញ្ញតា ជា ២ ចំណែក ម្តងទៀតថា “សង្ខារនេះ ជារបស់សូន្យ ចាកខ្លួន ឬ ចាកវត្ថុរបស់ខ្លួន [២] ” ដូច្នេះ ។

ព្រះយោគាវចនោះលុះមិនឃើញនូវខ្លួន មិនឃើញសត្វ និងសង្ខារដទៃ ផ្សេងទៀតណាមួយ ដែលឋិតនៅក្នុងភាពជាបរិក្ខាររបស់ខ្លួន យ៉ាងនេះហើយ ទើបកំណត់នូវសុញ្ញតា ៤ ដែលលោកពោលហើយ ក្នុងសុញ្ញតានុបស្សនានេះ បន្តទៀតថា “ព្រះយោគាវចរនោះ មិនឃើញថាអាត្មាអញ មានក្នុងទីណាៗ ក្នុងភាពជាអ្វីមួយ របស់អ្នកណាមួយ និងមិនឃើញថា : អ្នកដទៃមានក្នុងទីណាៗ ក្នុងភាពជាអ្វីមួយ របស់អាត្មាអញ ក្នុងទីណាមួយឡើយ” ដូច្នេះ ។

សួរថា ការអធិប្បាយសុញ្ញតា ៤ នេះ តើដូម្តេច? ។ ឆ្លើយថា មានអធិប្បាយយ៉ាងនេះថា : ពាក្យថា “នាហំ ក្វចនិ” គឺព្រះយោគាវចរនេះមិនឃើញខ្លួន ក្នុងទីណាមួយឡើយ ។ ពាក្យថា “កស្សចិ កិញ្ចនតស្មឹ”

---

១- សុ. សំ. ភាគ ៣៥ ទំព័រ ១៩៤ ។ ២- សុ. ភាគទី ៦៨ ទំព័រទី ៧៧ ។



គឺមិនឃើញខ្លួន របស់ខ្លួនដែលគប្បីបង្អោនចូលទៅ ក្នុងភាពជាអ្វីមួយរបស់អ្នកណាមួយឡើយ គឺរបស់អ្នកដទៃ, អធិប្បាយថា : មិនឃើញខ្លួន របស់ខ្លួនដែលគប្បីនាំបង្អោនចូលទៅ រាប់រកជាបងប្អូនប្រុស ក្នុងឋានៈជាបងប្អូនប្រុស ឬ ជាសំឡាញ់ក្នុងឋានៈជាសំឡាញ់ ឬ ជាបរិក្ខារក្នុងឋានៈជាបរិក្ខារ ។ ក្នុងពាក្យថា “ន ច មម ក្វចនិ” ដាក់ មម ស័ព្ទទុកមុន, ពាក្យដ៏សេសថា “ន ច ក្វចនិ” មានសេចក្តីយ៉ាងនេះ គឺ មិនឃើញនូវខ្លួន របស់អ្នកដទៃក្នុងទីណាៗ ។ ឥឡូវនេះ នាំយក មម ស័ព្ទមក(ផ្សំ) ថា “មម កិស្មិញ្ចិ កិញ្ចនតត្ថិ” សេចក្តីថា “មិនឃើញថា ខ្លួនរបស់អ្នកដទៃនោះ មានក្នុងភាពជាអ្វីមួយ របស់អាត្មាអញ ក្នុងឋានៈអ្វីមួយឡើយ, អធិប្បាយថា មិនឃើញនូវខ្លួន របស់អ្នកដទៃ ដែលគប្បីបង្អោនចូលទៅ ដោយភាពជាអ្វីៗមួយនេះ ក្នុងឋានៈអ្វីឡើយ គឺ បងប្អូនប្រុស ឬ ជាសំឡាញ់ ក្នុងឋានៈជាសំឡាញ់ ឬ ជាបរិក្ខារ ក្នុងឋានៈជាបរិក្ខារ” ដូច្នេះ ។

ព្រះយោគាវចរនេះ មិនឃើញនូវខ្លួន ក្នុងទីណាៗ, មិនឃើញខ្លួននោះដែលគួរបង្អោនចូលទៅក្នុងភាពជាអ្វីៗ របស់អ្នកដទៃ, មិនឃើញនូវខ្លួនរបស់អ្នកដទៃ, មិនឃើញអ្នកដទៃ ដែលគួរបង្អោនចូលទៅ ក្នុងភាពជាអ្វីមួយ របស់ខ្លួនឡើយ ព្រោះហេតុណា, ព្រោះហេតុនោះ ព្រះយោ-គាវចរនុ៎ះ បានកំណត់សុញ្ញតា ៤ ចំណែកហើយ ដោយប្រការដូច្នេះ ។

(កំណត់សុញ្ញតា ដោយអាការៈ ៦)

ព្រះយោគាវចរ លុះកំណត់នូវសុញ្ញតា ជា ៤ ចំណែក យ៉ាងនេះហើយ ក៏កំណត់នូវសុញ្ញតា ដោយអាការៈ ៦ ទៀត ។ កំណត់ យ៉ាងដូចម្តេច? ។ កំណត់យ៉ាងនេះ ថា “ចក្ខុ ជារបស់សូន្យ ចាកខ្លួនក្តី ចាក

វត្ថុរបស់ខ្លួនក្តី ចាកភាពជារបស់ទៀងក្តី ចាកភាពយឺនយូរក្តី ចាកភាពឋិតថេរក្តី ចាកភាពមិនប្រែប្រួលជាធម្មតាក្តី សោតៈ...ឃានៈ...ជិវ្ហា...កាយ...ចិត្ត ជារបស់សូន្យ...រូបជារបស់សូន្យ...។ល។ ធម្មារម្មណ៍ទាំងឡាយជារបស់សូន្យ...ចក្ខុវិញ្ញាណជារបស់សូន្យ ។ល។ មនោវិញ្ញាណជារបស់សូន្យ...ចក្ខុសម្ផស្ស ជារបស់សូន្យ...ដូច្នេះ បណ្ឌិត គប្បីនាំយកន័យដូចបានពោលមកនេះ រហូតដល់ជរា និង មរណៈ ។

(កំណត់សុញ្ញតា ដោយអាការៈ ៨)

ព្រះយោគាវចរលុះកំណត់នូវសុញ្ញតា ដោយអាការៈ ៦ យ៉ាងនេះហើយ ក៏កំណត់សុញ្ញតា ដោយអាការៈ ៨ ម្តងទៀត ។ គឺកំណត់យ៉ាងដូចម្តេច? ។ គឺកំណត់ថា "រូបជារបស់មិនមានខ្លឹម [1] ឥតខ្លឹម ប្រាសចាកខ្លឹម ដោយខ្លឹម មានខ្លឹមគឺទៀងក្តី ដោយខ្លឹម មានខ្លឹមគឺយឺនយូរក្តី ដោយខ្លឹម មានខ្លឹមគឺសុខក្តី ដោយខ្លឹម មានខ្លឹមគឺរបស់ខ្លួនក្តី ដោយភាពជារបស់ទៀងក្តី យឺនយូរក្តី ឋិតថេរក្តី មិនប្រែប្រួលជាធម្មតាក្តី, វេទនា ...សញ្ញា... សង្ខារ... វិញ្ញាណ... ចក្ខុ... ជរាមរណៈ ជារបស់មិនមានខ្លឹម ឥតខ្លឹម ប្រាសចាកខ្លឹម ដោយខ្លឹម មានខ្លឹមគឺទៀងក្តី ដោយខ្លឹម មានខ្លឹមគឺយឺនយូរក្តី ដោយខ្លឹម មានខ្លឹមគឺសុខក្តី ដោយខ្លឹម មានខ្លឹមគឺរបស់ខ្លួនក្តី ដោយភាពជារបស់ទៀងក្តី យឺនយូរក្តី ឋិតថេរក្តី មិនប្រែប្រួលជាធម្មតាក្តី ប្រៀបដូចជាដើមបបុស ជារបស់មិនមានខ្លឹម ឥតខ្លឹម ប្រាសចាកខ្លឹម យ៉ាងណាមិញ, ដូចជាដើមល្ហុងខ្វៃ... ដូចដើមល្វា... ដូចដើមសេតច្ឆព្រឹក្ស (ពក់ស)... ដូចដើមបាលិភទ្ទព្រឹក្ស (រលួសបាយ)... ដូចជាដុំពពុះទឹក... ដូចក្រពេញទឹក... ដូចថ្ងៃបណ្តើរកូន... ដូចដើមចេក...ដូច

---

១- សុ. ខុ. ចុ. ភាគទី ៦៨ ទំព័រទី ៧១ ។



ជាកលមាយា ជារបស់មិនមានខ្លឹម ឥតខ្លឹម យ៉ាងណាមិញ, រូប...ជរាមរណៈ ជារបស់មិនមានខ្លឹម ឥតខ្លឹម ប្រាសចាកខ្លឹម ដោយខ្លឹម មានខ្លឹម គឺទៀងក្តី ដោយខ្លឹម មានខ្លឹមគឺយឺនយូរក្តី ។ល។ មិនប្រែប្រួលជារបស់ធម្មតាក្តី" ដូច្នេះ ។

(កំណត់សុញ្ញតា ដោយអាការៈ ១០)

ព្រះយោគាវចរ លុះកំណត់សុញ្ញតា ដោយអាការៈ ៨ យ៉ាងនេះហើយ ក៏កំណត់ ដោយអាការៈ ១០ ម្តងទៀត ។ តើកំណត់យ៉ាងដូចម្តេច? ។ កំណត់ដោយអាការៈ១០ យ៉ាងនេះ គឺ "ឃើញរូបថា ជារបស់គ្មាន [1] ១ ថា ជារបស់ទទេ ១ ថា ជារបស់សូន្យ ១ ជារបស់មិនមែនខ្លួនប្រាណ ១ ថា ជារបស់មិនមានអ្វីជាឥស្សរៈ ១ មិនលុះតាមប្រាថ្នា ១ ជា របស់មិនគប្បីបាន (តាមចិត្តប្រាថ្នា) ១ មិនលុះក្នុងអំណាចខ្លួន ១ ជារបស់ដទៃ ១ ថាជារបស់ទទេ ១, ឃើញនូវវេទនា ។ល។ វិញ្ញាណ ថា ជារបស់គ្មាន ។ល។ ឃើញថា ជារបស់ទទេ" ដូច្នេះ ។

ព្រះយោគាវចរនោះ លុះកំណត់សុញ្ញតា ដោយអាការៈ១០ យ៉ាងនេះហើយ ក៏កំណត់ ដោយអាការៈ ១២ ម្តងទៀត ។ កំណត់យ៉ាងដូចម្តេច? ។ គឺកំណត់ថា "រូបមិនមែនសត្វ ១ មិនមែនជីវៈ ១ មិនមែននរៈ ១ មិនមែនមាណព ១ មិនមែនស្ត្រី ១ មិនមែនបុរស ១ មិនមែនខ្លួន ១ មិនមែនរបស់ខ្លួន ១ មិនមែនយើង ១ មិនមែនជារបស់យើង ១ មិនមែនជារបស់អ្នកដទៃ ១ មិនមែនជារបស់អ្នកណាម្នាក់ ១, វេទនា ។ល។ វិញ្ញាណ មិនមែនជារបស់អ្នកណាម្នាក់ ១ " ដូច្នេះ ។

(កំណត់ដោយអាការៈ ៤២)

---

១- សុ. ខុ. ចុ. ភាគទី ៦៨ ទំព័រទី ៧៣-៧៤ ។

ព្រះយោគាវចរ លុះកំណត់សុញ្ញតា ដោយអាការៈ ១២ យ៉ាងនេះ ហើយក៏កំណត់សុញ្ញតា ដោយអាការៈ ៤២ ដោយអំណាចតីរណបរិញ្ញា ម្តងទៀត គឺ ឃើញរូប

អនិច្ចតោ ដោយសភាពជារបស់មិនទៀង,

ទុក្ខតោ ដោយសភាពជាទុក្ខ,

រោគតោ ដោយភាពជារោគ,

គណ្ឌតោ ដោយភាពជាបូស,

សល្លតោ ដោយភាពជាសរ,

អឃតោ ដោយភាពជារបស់លំបាក,

អាពាធតោ ដោយភាពជាអាពាធ,

បរតោ ដោយភាពជារបស់ដទៃ,

បលោកតោ ដោយភាពជារបស់វិនាសទៅ,

ឦតិតោ ដោយភាពជារបស់ចង្រៃ,

ឧបទ្ទវតោ ដោយភាពជាឧបទ្រព,

ភយតោ ដោយភាពជាភ័យ,

ឧបសគ្គតោ ដោយភាពជាឧបសគ្គ,

ចលតោ ដោយភាពជារបស់ញាប់ញ័រ,

បភង្គុតោ ដោយភាពជារបស់បែកធ្លាយ,

អទ្ធុវតោ ដោយកភាពជារបស់មិនយឺនយូរ,

អត្តាណតោ ដោយភាពជារបស់មិនមានទីជ្រកកោន,

អលេណតោ ដោយភាពជារបស់មិនមានទីពួន,

អសរណតោ ដោយភាពជារបស់មិនមានទីពឹងពាក់,



អសរណីភូតតោ ដោយភាពជារបស់មិនគួរយកជាទីពឹង,

រិត្តតោ ដោយភាពជារបស់វាលល្ហ ឬ (គ្មាន),

តុច្ឆតោ ដោយភាពជារបស់ទទេ,

សុញ្ញតោ ដោយភាពជារបស់សោះសូន្យ,

អនត្តតោ ដោយភាពជារបស់មិនមែនខ្លួនប្រាណ,

អនស្សាទតោ ដោយភាពជារបស់មិនជាទីត្រេកអរ,

អាទីនវតោ ដោយភាពជារបស់មានទោស,

វិបរិណាមធម្មតោ ដោយភាពជារបស់មានការប្រែប្រួលជាធម្មតា,

អសារកតោ ដោយភាពជារបស់ឥតខ្លឹមសារ,

អឃមូលតោ ដោយភាពជាឫសគល់នៃសេចក្តីលំបាក,

វធកតោ ដោយភាពជាអ្នកសម្លាប់,

វិភវតោ ដោយភាពជារបស់មិនមានសេចក្តីចំរើន,

សាសវតោ ដោយភាពជារបស់ប្រកបដោយអាសវៈ,

សង្ខតតោ ដោយភាពជារបស់គឺបច្ច័យប្រជុំតាក់តែង,

មារាមិសតោ ដោយភាពជាអាមិសរបស់មារ,

ជាតិធម្មតោ ដោយមានការកើតជាធម្មតា,

ជរាធម្មតោ ដោយមានជរាជាធម្មតា,

ព្យាធិធម្មតោ ដោយមានព្យាធិជាធម្មតា,

មរណធម្មតោ ដោយមានមរណៈជាធម្មតា,

សោកបរិទេវទុក្ខ-ដោយមានសេចក្តីសោក, ខ្សឹកខ្សួល, ទុក្ខ, ទោមនស្សុបាយាសធម្មតោ ទោមនស្ស, សេចក្តីចង្អៀតចង្អល់ចិត្តជាធម្មតា,

*សមុទយតោ ដោយការកើត,*

*អត្ថង្គមតោ ដោយការអស់ទៅ,*

*និស្សរណតោ ដោយការចេញទៅ,*

*ឃើញនូវវេទនា ។ល។ វិញ្ញាណ...ថា ជារបស់មិនទៀង ។ល។ ដោយភាពជារបស់ចេញទៅ ។*

*សូម្បីពាក្យដែលសំដែង នូវសុញ្ញតានេះ ក៏ព្រះមានព្រះភាគទ្រង់ត្រាស់សំដែងហើយថា "បុគ្គលកាលឃើញនូវរូប ដោយភាពជារបស់មិនទៀង ។ល។ ដោយភាពជាគ្រឿងចេញទៅ ឈ្មោះថា ឃើញលោកដោយភាពជារបស់សូន្យ កាលឃើញវេទនា ។ល។ វិញ្ញាណ ដោយភាពជារបស់មិនទៀង ។ល។ ដោយភាពជាគ្រឿងចេញទៅ ឈ្មោះថា ឃើញលោក ដោយភាពជារបស់សោះសូន្យ (និង ទ្រង់ត្រាស់ហើយថា)*

ម្នាលមោឃរាជ! [១] អ្នកចូរមានស្មារតី គ្រប់កាលសំឡឹងឃើញលោក ដោយសភាពជារបស់សូន្យ (ព្រោះ) បុគ្គលដកអត្តានុទិដ្ឋិ ទើបឆ្លងផុតចាកមច្ចុ បុគ្គលសំឡឹងឃើញលោកយ៉ាងនេះ មច្ចុរាជ ទើបមិនឃើញ ។

(សង្ខារុបេក្ខាញាណកើតឡើង)

*(៤៤៦) ព្រះយោគាវចរ លុះឃើញថាជារបស់សោះសូន្យយ៉ាងនេះហើយ កំណត់សង្ខារទាំងឡាយ លើកឡើងកាន់ត្រៃលក្ខណ៍ លះបង់នូវភ័យ និង សេចក្តីត្រេកអរហើយ ជាអ្នកព្រងើយកន្តើយ នៅជាកណ្តាល*

*១- សុ. ខុ. ចុ. ភាគទី ៦៨ ទំព័រទី ៨៨ ។*



*ក្នុងសង្ខារទាំងឡាយ មិនប្រកាន់ថា អញ ឬថា របស់អញ ប្រៀបដូចជាបុរសដែលលែងលះភរិយាហើយ ដូច្នោះឯង ។ បានឮមកថា: ភរិយារបស់បុរស(ម្នាក់) ជាស្ត្រីគួរជាទីប្រាថ្នា ជាទីស្រឡាញ់ ជាទីពេញចិត្ត, បុរសនោះ ប្រាសចាកពីភរិយានោះហើយ មិនអាចនឹងអត់ទ្រាំបានសូម្បីតែមួយភ្លែតក៏ដោយ បុរសនោះ ប្រចណ្ឌនឹងភរិយានោះក្រៃពេក ឃើញស្រីនោះឈរក្តី អង្គុយក្តី ដេកក្តី និយាយក្តី សើចក្តី ជាមួយនឹងបុរសដទៃ ក៏ក្រោធខឹង អាក់អន់ស្រពន់ចិត្ត តូចចិត្ត យ៉ាងក្រៃលែង, សម័យក្រោយមក បុរសនោះ ឃើញកំហុសរបស់ស្រីនោះហើយ ជាអ្នកប្រាថ្នាដោះខ្លួនចេញហើយ ក៏លះបង់នូវស្រីនោះចោល មិនប្រកាន់នាងនោះ ថាជារបស់អញ តាំងពីពេលនោះមក, បុរសនោះ សូម្បីឃើញស្រីនោះធ្វើកិរិយាណាមួយ ជាមួយនឹងបុរសណាមួយក៏ដោយ ក៏មិនក្រោធខឹង មិនដល់នូវការខូចចិត្ត ជាអ្នកព្រងើយ នៅជាកណ្តាលៗ យ៉ាងពិតប្រាកដយ៉ាងណាមិញ, ព្រះយោគាវចរនោះ ជាអ្នកប្រាថ្នាចង់រួចផុតពីសង្ខារទាំងពួង កំណត់យកសង្ខារទាំងឡាយ ដោយបដិសង្ខានុបស្សនា រហូតមិនឃើញថា សង្ខារទាំងពួង ជារបស់មិនគួរប្រកាន់ថា អញ ថា ជារបស់អញហើយ ក៏លះបង់នូវភ័យ និង សេចក្តីត្រេកអរ ជាអ្នកព្រងើយកន្តើយ នៅជាកណ្តាលៗ ក្នុងសង្ខារទាំងពួង ក៏យ៉ាងនោះដែរ ។*

*កាលព្រះយោគាវចរនោះ ដឹងយ៉ាងនេះឃើញយ៉ាងនេះ ចិត្ត រមែងថយ រួញខ្វរត្រឡប់ មិនអាឡោះអាល័យ ក្នុងភព ៣ កំណើត ៤ គតិ ៥ វិញ្ញាណឋិតិ៧ សត្តាវាស៩, ឧបេក្ខា ឬ ភាពគួរខ្ពើម រមែងតាំងនៅមាំ ។ មានឧបមាដូចជាតំណក់ទឹកទាំងឡាយ លើស្លឹកឈូក ដែលផ្អៀងបន្តិច រមែងរមៀលធ្លាក់ជ្រុះចេញ មិនជាប់(នៅលើស្លឹកឈូក) យ៉ាងណាមិញ,*

ចិត្ត ក៏មានឧបមេយ្យយ៉ាងនោះដែរ។ មួយទៀត ប្រៀបដូចជាស្លាបមាន់ ឬសរសៃ និង ស្បែកស្ងួត ដែលបុគ្គលដុតភ្លើងហើយ រមែងរួញ រមូរ រមួល មិនរលាត យ៉ាងណាមិញ, ចិត្ត របស់ព្រះយោគាវចរនោះ រមែងមិនថយរួញខ្នួរ ងគ្រឡប់ មិនអាឡោះអាល័យ ក្នុងភព៣ ។ល។ ឧបេក្ខា ឬ ភាពគួរខ្ពើម រមែងតាំងនៅមាំ ក៏មានឧបមេយ្យយ៉ាងនោះដែរ ។

ក៏សង្ខារុបេក្ខាញាណ កើតឡើងហើយ ដល់ព្រះយោគាវចរនោះ ដោយប្រការដូច្នេះឯង ។

(សង្ខារុបេក្ខាញាណ ប្រៀបដូចក្អែកប្រាប់ទិស)

តែសង្ខារុបេក្ខាញាណនេះនុ៎ះ បើឃើញព្រះនិព្វានដែលជាសន្តិបទ ដោយភាពជាធំមាន រមែងលះនូវការប្រព្រឹត្តិនៃសង្ខារទាំងពួង ហើយ ស្ទុះទៅកាន់ព្រះនិព្វានតែម្តង បើមិនឃើញព្រះនិព្វានថា ជាធម៌មានទេ ក៏រមែងមានតែសង្ខារជាអារម្មណ៍ប្រព្រឹត្តទៅរឿយៗនុ៎ះឯង ប្រៀបដូចជាសត្វក្អែក របស់ពួកអ្នកដើរសមុទ្រ យ៉ាងនោះឯង ។ បានឮមកថា: ពួកពាណិជអ្នកធ្វើដំណើរតាមសមុទ្រ កាលឡើងជិះទូក តែងយកសត្វក្អែក ដែលនាំទិសទៅផង ។ ពេលណា នាវា ត្រូវខ្យល់ព្យុះបក់បោកហើយ រសាត់ទៅខុសទិសដៅ មើលច្រាំងមិនឃើញ ពេលនោះ ពួកពាណិជ ទាំងនោះ ក៏លែងសត្វក្អែកដែលនាំទិសទៅ ។ ក្អែកនោះ ទំលើសសរក្តោង ហោះទៅលើអាកាសហើយ ហើរទៅតាម ទិសធំ-តូច សព្វទិស ទីកន្លែង បើឃើញច្រាំង ក៏មានមុខឆ្ពោះទៅរកទិសនោះភ្លាម តែបើមិនឃើញ ក៏ត្រឡប់មក ចាប់ទំនៅលើសសរក្តោង(នាវា) នុ៎ះឯង ម្តងហើយម្តងទៀត យ៉ាងណាមិញ, សង្ខារុបេក្ខាញាណ បើឃើញព្រះនិព្វានដែលជាសន្តិបទថា ជាធម៌មាន ក៏រមែងលះនូវការប្រព្រឹត្តិទៅនៃសង្ខារទាំងពួង



ហើយ ស្ទុះទៅកាន់ព្រះនិព្វានតែម្តង បើមិនឃើញទេ ក៏រមែងមានតែសង្ខារជាអារម្មណ៍ ប្រព្រឹត្តទៅរឿយៗ ក៏យ៉ាងនោះដែរ ។

វិបស្សនានេះនោះ ប្រៀបដូចជាម្សៅក្នុងចង្អេរ ដែលគេរែង(ទទះ) ដូចជាកប្បាស ដែលគេបកគ្រាប់ហើយរវៃ កំណាត់សង្ខារទាំងឡាយ ដោយប្រការផ្សេងៗ រហូតដល់លះនូវភ័យ និង សេចក្តីត្រេកអរហើយ នៅជាកណ្តាលៗ ក្នុងការពិចារណាសង្ខារ តាំងនៅ ដោយអំណាចនៃអនុបស្សនា ៣ ។ កាលតាំងនៅ យ៉ាងនេះ រមែងដល់នូវភាពជាប្រមុខនៃវិមោក្ខ ៣ ហើយ ជាបច្ច័យ ដើម្បីចំណែកព្រះអរិយបុគ្គល ៧ ពួក ។

(វិមោក្ខ ៣)

ក្នុងការដល់នូវភាពជាប្រមុខនៃវិមោក្ខ និង ក្នុងភាពជាបច្ច័យដើម្បីចំណែកព្រះអរិយបុគ្គលនោះ វិបស្សនាញាណនេះ ឈ្មោះថា ដល់នូវភាពជាប្រមុខនៃវិមោក្ខ៣ ដោយអំណាចនៃភាពជាអធិបតីនៃឥន្ទ្រិយទាំងឡាយ ៣ ដោយអំណាចនៃអនុបស្សនា ៣ ។ មែនពិត អនុបស្សនា ៣ លោកហៅថា “វិមោក្ខ ៣” ។ ដូចបាលីថា “ក៏ឯវិមោក្ខមុខនេះ [១] មាន ៣ យ៉ាង តែងប្រព្រឹត្តទៅ ដើម្បីចេញចាកលោក គឺ ប្រព្រឹត្តទៅ ដើម្បីកិរិយាស្ទុះទៅនៃចិត្ត ក្នុងអនិមិត្តធាតុ ព្រោះកិរិយាឃើញ នូវសង្ខារទាំងពួងថា ជាកិរិយាកំណត់នូវដែន និង ជាផ្លូវ១ ដើម្បីកិរិយាស្ទុះទៅនៃចិត្ត ក្នុងអប្បណិហិតធាតុ ព្រោះកិរិយាញុំាងចិត្តឲ្យអាចហាន ក្នុងសង្ខារទាំងពួង១ ដើម្បីកិរិយាស្ទុះទៅនៃចិត្ត ក្នុងសុញ្ញតធាតុ ព្រោះកិរិយាពិចារណាឃើញ នូវធម៌ទាំងពួងថា ជាចំណែកដទៃ១, នេះ វិមោក្ខ ៣ យ៉ាង តែងប្រព្រឹត្តទៅ ដើម្បីចេញចាកលោក” ដូច្នេះ ។

---

១- សុ. ខុ. បដិ. ភាគទី ៧០ ទំព័រទី ៣១៨ ។

(អធិប្បាយសេចក្ដីនៃបាលី)

*បណ្ដាបាឋៈ ទាំងនោះ បាឋៈ ថា* “បរិច្ឆេទបរិវដុមតោ ជាកិរិយា *កំណត់នូវដែន និង ជាផ្លូវ” គឺថា ជាការកំណត់ផង ថា ជាផ្លូវជុំវិញផង ដោយអំណាចនៃការកើត និង ការរលត់ ។ សេចក្ដីថា អនិច្ចានុបស្សនា កំណត់ថា “ក្នុងកាលខាងដើម នៃការកើត សង្ខារទាំងឡាយ មិនមាន” ហើយតាមពិនិត្យមើលនូវគតិ នៃសង្ខារទាំងឡាយនោះ ហើយពិចារណា ដោយថា ជាផ្លូវជុំវិញថា “បន្ទាប់អំពីការរលត់ សង្ខារទាំងឡាយ មិនទៅ (ណា) ទេ, វា វិនាសទៅ ក្នុងទីនេះឯង” ដូច្នេះ ។*

*បាឋៈថា* “មនោសមុត្តេជនតាយ *ព្រោះកិរិយាញុំាងចិត្ត ឲ្យអាចហាន” សេចក្ដីថាៈ ព្រោះញុំាងចិត្ត ឲ្យកើតសេចក្ដីសង្វេគ ។ មែនពិត ចិត្ត រមែងសង្វេគ ក្នុងសង្ខារទាំងឡាយ ដោយទុក្ខានុបស្សនា ។*

*បាឋៈថា* “បរតោ សមនុបស្សនតាយ *ព្រោះកិរិយាពិចារណា (នូវធម៌ទាំងពួង)ថា ជាចំណែកដទៃ” សេចក្ដីថា ព្រោះកិរិយាពិចារណា(នូវធម៌ទាំងពួង) ថា ជាអនត្តា យ៉ាងនេះថា “មិនមែនជាអញ មិនមែនជារបស់អញ” ដូច្នេះ ។*

*បទទាំង ៣ ដូចពោលមកនេះ គប្បីជ្រាបថា “លោក ពោលហើយ ដោយអំណាច នៃអនុបស្សនា មានអនិច្ចានុស្សនាជាដើម” ព្រោះហេតុនេះឯង ក្នុងការវិសជ្ជនានូវបញ្ហា ក្នុងលំដាប់នោះ ទើបលោកពោល ថា “កាលព្រះយោគាវចរ ធ្វើទុកក្នុងចិត្តថា មិនទៀង [(១)] សង្ខារទាំងឡាយ ប្រាកដឡើងថាអស់ទៅ, កាលធ្វើទុកក្នុងចិត្តថា ជាទុក្ខ សង្ខារទាំងឡាយ ប្រាកដឡើងថា ជាភ័យ, កាលធ្វើទុកក្នុងចិត្តថា មិនមែនខ្លួន, សង្ខារទាំង*

*១- សុ. ខុ. បដិ. ភាគទី ៧០ ទំព័រទី ៣១៩ ។*



*ឡាយ ប្រាកដឡើងថា សូន្យ” ដូច្នេះ ។*

(វិមោក្ខ ៣ បានដល់អរិយមគ្គ)

*សួរថា “ក៏វិមោក្ខដែលមានអនុបស្សនាជាប្រមុខនោះ គឺអ្វីខ្លះ?” ។ ឆ្លើយថា “វិមោក្ខ៣ នុ៎ះ គឺ អនិមិត្តវិមោក្ខ អប្បណិហិតវិមោក្ខ សុញ្ញត-វិមោក្ខ” ។ ក៏ពាក្យនេះ លោកពោលហើយថា “ព្រះយោគាវចរ [(១)] កាលធ្វើទុកក្នុងចិត្តថា មិនទៀង ជាអ្នកច្រើនដោយអធិមោក្ខ រមែងបាននូវអនិមិត្តវិមោក្ខ កាលធ្វើទុកក្នុងចិត្តថាជាទុក្ខ ជាអ្នកច្រើនដោយបស្សទ្ធិ រមែងបាននូវអប្បណិហិតវិមោក្ខ កាលធ្វើទុកក្នុងចិត្តថា មិនមែនខ្លួន ជាអ្នកច្រើនដោយវេទៈ រមែងបាននូវសុញ្ញតវិមោក្ខ” ដូច្នេះ ។*

*ក៏ក្នុងវិមោក្ខ ៣ នោះ អរិយមគ្គ ដែលធ្វើព្រះនិព្វានឲ្យជាអារម្មណ៍ ប្រព្រឹត្តទៅ ដោយអាការៈមិនមាននិមិត្ត ឈ្មោះថា អនិមិត្តវិមោក្ខ ។ មែនពិត អរិយមគ្គនោះ ឈ្មោះថា មិនមាននិមិត្ត ព្រោះកើតឡើង ដោយធាតុដែលមិនមាននិមិត្ត និង ឈ្មោះថា វិមោក្ខ ព្រោះរួចផុតចាកកិលេសទាំងឡាយ ។ ដោយន័យដូចគ្នានោះឯង អរិយមគ្គ ដែលធ្វើព្រះនិព្វានឲ្យជាអារម្មណ៍ ប្រព្រឹត្តទៅ ដោយអាការៈដែលមិនមានបណិធិ គប្បីជ្រាបថា “ឈ្មោះថា អប្បណិហិតវិមោក្ខ” អរិយមគ្គ ដែលធ្វើព្រះនិព្វានឲ្យជាអារម្មណ៍ ប្រព្រឹត្តទៅ ដោយអាការៈសោះសូន្យ គប្បីជ្រាបថា “សុញ្ញតវិមោក្ខ” ។*

(វិមោក្ខ ២ បានដល់វិបស្សនាញាណ)

*ចំណែកឯវិមោក្ខ ២ ឯណា ដែលលោកពោលហើយ ក្នុងអភិធម្ម យ៉ាងនេះថា “ក្នុងសម័យណា [(២)] បុគ្គលចំរើនលោកុត្តរជ្ឈាន ជាគ្រឿង*

*១- សុ. ភាគទី ៧០ ទំព័រ ៣៥០ ។ ២- អភិ. ភាគទី ៧៨ ទំព័រ ២៧៩ ។*

ចេញចាកវដ្តៈ ដល់នូវការមិនសន្សំ ក-ពូនឡើង ដើម្បីលះបង់នូវទិដ្ឋិ ដើម្បីដល់នូវភូមិជាប្រថម បានស្ងាត់ចាកកាមទាំងឡាយ ។ល។ បាន ដល់បឋមជ្ឈាន ជាអប្បណិហិតៈ ជាសុញ្ញតៈ” ដូច្នេះ ។ វិមោក្ខ២ នោះ លោក ពោលសំដៅយកការមកនៃវិបស្សនា ដោយនិប្បរិយាយ ។

មែនពិត វិបស្សនាញាណ លោកហៅថា “សុញ្ញតវិមោក្ខ” ដោយ អំណាចនៃការលះបង់ នូវការប្រកាន់មាំ តាមន័យបាលី ក្នុងបដិសម្ភិទា យ៉ាងនេះថា “អនិច្ចានុបស្សនាញាណ (១) រមែងលះនូវការប្រកាន់ស្អិតថា ទៀង ហេតុនោះ ឈ្មោះថា សុញ្ញតវិមោក្ខ, ទុក្ខានុបស្សនាញាណ រមែងលះបង់ នូវការប្រកាន់ស្អិតថា ជាសុខ ព្រោះហេតុនោះ ឈ្មោះថា សុញ្ញតវិមោក្ខ, អនត្តានុបស្សនាញាណ រមែងលះបង់នូវការប្រកាន់ស្អិតថា ជាខ្លួន ព្រោះហេតុនោះ ឈ្មោះថា សុញ្ញតវិមោក្ខ” ដូច្នេះ និង លោក ហៅថា “អនិមិត្តវិមោក្ខ” ដោយអំណាចការលះនូវនិមិត្ត តាមន័យបាលី យ៉ាងនេះថា “អនិច្ចានុបស្សនាញាណ រមែងលះបង់ នូវនិមិត្តថា ទៀង ហេតុនោះ ឈ្មោះថា អនិមិត្តវិមោក្ខ, ទុក្ខានុបស្សនាញាណ រមែងលះបង់នូវនិមិត្តថា ជាសុខ ហេតុនោះ ឈ្មោះថា អនិមិត្តវិមោក្ខ, អនត្តា-នុបស្សនាញាណ រមែងលះបង់នូវនិមិត្តថា ជាខ្លួន ហេតុនោះ ឈ្មោះថា អនិមិត្តវិមោក្ខ” ដូច្នេះ និង លោកហៅថា “អប្បណិហិតវិមោក្ខ” ដោយ អំណាចការលះបង់សេចក្តីប្រាថ្នា តាមន័យបាលី(ក្នុងបដិសម្ភិទាមគ្គនុ៎ះ) យ៉ាងនេះថា “អនិច្ចានុបស្សនាញាណ (២) លះបង់នូវសេចក្តីប្រាថ្នា ថា ទៀង ហេតុនោះ ឈ្មោះថា អប្បណិហិតវិមោក្ខ, ទុក្ខានុបស្សនាញាណ រមែងលះបង់នូវសេចក្តីប្រាថ្នាថាជាសុខ ព្រោះហេតុនោះ ទើបឈ្មោះថា

១- សុ. ខុ. ភាគទី ៧០ ទំព័រទី ៣៦៩ ។ ២- ភាគទី ៧០ ទំព័រ ៣៧២ ។



អប្បណិហិតវិមោក្ខ, អនត្តានុបស្សនាញាណ រមែងលះបង់ នូវសេចក្តីប្រាថ្នាថា ជាខ្លួន ហេតុនោះ ឈ្មោះថា អប្បណិហិតវិមោក្ខ” ដូច្នេះផង ក៏ពិតមែនហើយ ទោះបីជាដូច្នោះ វិបស្សនាញាណនោះ ក៏នៅពុំទាន់បាន ជាអនិមិត្ត ដោយនិប្បរិយាយទេ ព្រោះលះបង់សង្ខារនិមិត្ត ពុំទាន់បាន ប៉ុន្តែ បានឈ្មោះថា សុញ្ញតៈ និង អប្បណិហិតៈ ដោយនិប្បរិយាយ ពិតប្រាកដ ។ មួយទៀត វិមោក្ខ លោកលើកឡើងហើយ ក្នុងខណៈ នៃអរិយមគ្គ ដោយអំណាចនៃការមកនៃវិបស្សនាញាណនោះ ។ គប្បី ជ្រាបថា “លោកពោលវិមោក្ខ ២ យ៉ាងគឺ អប្បណិហិតៈ ១ សុញ្ញតៈ ១ ក៏ព្រោះហេតុដែលជានិប្បរិយាយនោះ” ។

នេះ ជាវិមោក្ខកថា ក្នុងអធិការនៃវិបស្សនានេះ ជាដំបូង ។

(ព្រះអរិយបុគ្គល ៧ ពួក)

(៤៤៧) គប្បីជ្រាបអធិប្បាយ ក្នុងពាក្យដែលខ្ញុំបានពោលហើយ ម្តងទៀតថា “វិបស្សនានោះ ជាបច្ច័យ ដើម្បីចំណែកនូវព្រះអរិយបុគ្គល ៧ ពួក” ដូចតទៅនេះ :

ដំបូង គប្បីជ្រាបបុគ្គល ៧ ពួកនេះ គឺ សទ្ធានុសារី, សទ្ធាវិមុត្ត, កាយសក្ខី, ឧភតោភាគវិមុត្ត, ធម្មានុសារី, ទិដ្ឋិប្បត្តៈ, បញ្ញាវិមុត្ត ឈ្មោះថា ព្រះអរិយបុគ្គល ៧ ។ សង្ខារុបេក្ខាញាណនេះ រមែងជាបច្ច័យ ដើម្បីចំណែកនូវព្រះអរិយបុគ្គល ៧ នោះ ។

អធិប្បាយថា: បុគ្គលណា ធ្វើទុកក្នុងចិត្តថា មិនទៀង ជាអ្នកច្រើន ដោយអធិមោក្ខ រមែងបាននូវសទ្ធិន្ទ្រិយ៍, បុគ្គលនោះ ជាអ្នកឈ្មោះថា សទ្ធានុសារី ក្នុងខណៈនៃសោតាបត្តិមគ្គ ។ ក្នុងឋានៈ៧ ដ៏សេស ឈ្មោះ ថាសទ្ធាវិមុត្ត ។ ចំណែកបុគ្គលណាធ្វើទុកក្នុងចិត្តថា ជាទុក្ខ ជាអ្នកច្រើន

ដោយបសទ្ធិ រមែងបាននូវសមាធិន្ទ្រិយ៍, បុគ្គលនោះ ជាអ្នកឈ្មោះថា កាយសក្ខី ក្នុងទីទាំងពួង ។ ឯបុគ្គលអ្នកបានសំរេចអរូបជ្ឈានហើយ សំរេចផលដ៏ខ្ពស់ ជាអ្នកឈ្មោះថា ឧភតោភាគវិមុត្ត ។ ចំណែកបុគ្គលណា ធ្វើទុកក្នុងចិត្ត ថា មិនមែនជារបស់ខ្លួន ជាអ្នកច្រើនដោយវេទៈ រមែងបាននូវបញ្ញិន្ទ្រិយ៍, បុគ្គលនោះ ជាអ្នកឈ្មោះថា ធម្មានុសារី ក្នុងខណៈនៃសោតាបត្តិមគ្គ ។ ក្នុងឋានៈ ៦ ឈ្មោះថា ទិដ្ឋិប្បត្តៈ ។ ក្នុងផលដ៏ខ្ពស់ ឈ្មោះថា បញ្ញាវិមុត្ត ។

ក៏ពាក្យនេះ លោកពោលហើយ(ក្នុងបដិសម្ភិទាមគ្គ)ថា "កាលព្រះយោគាវចរ [១] ធ្វើទុកក្នុងចិត្តថា មិនទៀង សទ្ធិន្ទ្រិយ៍ ជាគុណជាតដ៏ក្រៃលែង, ព្រះយោគាវចរ បាននូវសោតាបត្តិមគ្គ ព្រោះមានសទ្ធិន្ទ្រិយ៍ដ៏ក្រៃលែង ព្រោះហេតុនោះ ព្រះយោគាវចរនោះលោកហៅថា សទ្ធានុសារីបុគ្គល" ។ ន័យដូចគ្នានោះដែរ លោកពោលថា "កាលព្រះយោគាវចរ ធ្វើទុកក្នុងចិត្តថា មិនទៀង សទ្ធិន្ទ្រីយ៍ ជាគុណជាតដ៏ក្រៃលែង, ឯសោតាបត្តិផល ជាផលគឺព្រះយោគាវចរនោះ បានធ្វើឲ្យជាក់ច្បាស់ហើយ ព្រោះមានសទ្ធិន្ទ្រីយ៍ដ៏ក្រៃលែង ព្រោះហេតុនោះ ទើបលោកហៅថា សទ្ធាវិមុត្តបុគ្គល ដូច្នេះជាដើម ។ លោកពោលពាក្យផ្សេងទៀតថា "ព្រះយោគាវចរ កាលជឿ រួចផុតហើយ [២] ហេតុនោះ បុគ្គលនោះ ឈ្មោះថា សទ្ធាវិមុត្តបុគ្គល, បុគ្គល កាលធ្វើឲ្យជាក់ច្បាស់ ក្នុងលំដាប់នៃឈានដែលខ្លួនពាល់ត្រូវហើយ ហេតុនោះ បុគ្គលនោះ ឈ្មោះថា កាយសក្ខី, បុគ្គល ដល់ហើយ ក្នុងលំដាប់នៃគុណដែលឃើញហើយ ហេតុនោះ បុគ្គលនោះ ឈ្មោះថា ទិដ្ឋិប្បត្តៈ, បុគ្គល ជឿ រមែងរួចផុត

១- សុ. ភាគទី ៧០ ទំព័រ ៣៣២ ។ ២- ភាគទី ៧០ ទំព័រ ៣២៨ ។



ហេតុនោះ បុគ្គលនោះ ឈ្មោះថា សទ្ធាវិមុត្ត, បុគ្គលពាល់ត្រូវជាដំបូងនូវឈានផស្សៈ ក្រោយមក ទើបធ្វើឲ្យជាក់ច្បាស់នូវនិរោធ គឺនិព្វាន ហេតុនោះ បុគ្គលនោះ ឈ្មោះថា កាយសក្ខី, ញាណ គឺជាធម្មជាតដែលខ្លួនឃើញហើយ ដឹងច្បាស់ហើយ ធ្វើឲ្យជាក់ច្បាស់ហើយ ពាល់ត្រូវហើយ ដោយបញ្ញាថា "សង្ខារទាំងឡាយ ជាទុក្ខ, និរោធ ជាសុខ" ហេតុនោះ បុគ្គលនោះ ទើបឈ្មោះថា ទិដ្ឋិប្បត្តៈ" ដូច្នេះ ។

ចំណែកក្នុង ៤ បទក្រៅពីនេះ គប្បីជ្រាបសេចក្តីនៃពាក្យ យ៉ាងនេះថា "ព្រះអរិយបុគ្គល ដែលឈ្មោះថា សទ្ធានុសារី ព្រោះសេចក្តីថា ប្រព្រឹត្តទៅរកសទ្ធា ឬស្ទុះទៅ គឺទៅដោយសទ្ធា ។ ន័យដូចគ្នានោះដែរ ព្រះអរិយបុគ្គលដែលឈ្មោះថា ធម្មានុសារី ព្រោះសេចក្តីថា ប្រព្រឹត្តទៅ តាមធម៌ ពោលគឺបញ្ញា ឬ ស្ទុះទៅ តាមធម៌ ។ ដែលឈ្មោះថា ឧភតោភាគវិមុត្ត ព្រោះសេចក្តីថា រួចផុតហើយ ដោយចំណែក ២ យ៉ាង គឺ ទាំងដោយអរូបជ្ឈាន ទាំងដោយអរិយមគ្គ ។ ដែលឈ្មោះថា បញ្ញាវិមុត្ត ព្រោះសេចក្តីថា កាលជឿ ក៏ផុតស្រឡះហើយ" ដូច្នេះ ។

(នេះ គឺជា) សង្ខារុបេក្ខាញាណ ។

(៤៤៨) ក៏សង្ខារុបេក្ខាញាណនេះនោះ ដោយសេចក្តី គឺជាមួយគ្នានឹងញាណ ២ ខាងដើម (មុញ្ចិតុកម្យតាញាណ និង បដិសង្ខានុបស្សនាញាណ) ។ ព្រោះហេតុនោះ ទើបបុរាណាចារ្យទាំងឡាយ ពោលថា : "សង្ខារុបេក្ខាញាណនេះ គឺជាមួយគ្នាហ្នឹងឯង, តែបានឈ្មោះ ៣ គឺ ខាងដើម ឈ្មោះថា មុញ្ចិតុកម្យតាញាណ, ត្រង់កណ្តាល បានឈ្មោះថា បដិសង្ខានុបស្សនាញាណ និង ក្នុងទីបំផុត បានឈ្មោះថា សង្ខារុបេក្ខាញាណ ដែលដល់នូវទីបញ្ចប់ ។

សូម្បីក្នុងបាលី ក៏លោកពោលថា “សួរថា បញ្ញា គឺសេចក្តីប្រាថ្នាដើម្បីរួច [១] ឬ ការពិចារណារកឧបាយ ឬក៏ ការព្រងើយកន្តើយ ឈ្មោះថា សង្ខារុបេក្ខាញាណ តើដូចម្តេច? ។ ឆ្លើយថា បញ្ញា គឺសេចក្តីប្រាថ្នាដើម្បីរួច ឬ ការពិចារណារកឧបាយ ឬក៏ ការព្រងើយកន្តើយ ក្នុងការកើត ឈ្មោះថា សង្ខារុបេក្ខាញាណ, បញ្ញា គឺសេចក្តីប្រាថ្នាដើម្បីរួច ឬ ការពិចារណាដើម្បីរកឧបាយ ឬក៏ការព្រងើយកន្តើយក្នុងការប្រព្រឹត្តិ ឈ្មោះថា សង្ខារុបេក្ខាញាណ, បញ្ញា គឺសេចក្តីប្រាថ្នាដើម្បីរួច... ក្នុងនិមិត្ត ។ល។ បញ្ញា គឺសេចក្តីប្រាថ្នាដើម្បីរួច ឬ ការពិចារណាដើម្បីរកឧបាយ ឬក៏ ការព្រងើយកន្តើយក្នុងការបង្អៀតបង្អល់ចិត្ត ឈ្មោះថា សង្ខារុបេក្ខាញាណ, បញ្ញា គឺសេចក្តីប្រាថ្នាដើម្បីរួច ឬ ការពិចារណាដើម្បីរកឧបាយ ឬក៏ ការព្រងើយកន្តើយថា “ការកើតជាទុក្ខ” ឈ្មោះថា សង្ខារុបេក្ខាញាណ ។ល។ ថា “ការកើតជាភ័យ ។ល។ ថា ការកើតប្រកបដោយអាមិស ។ល។ ថា “ការកើត ជាសង្ខារ” ។ល។ បញ្ញា គឺសេចក្តីប្រាថ្នាដើម្បីរួច ឬ ការពិចារណាដើម្បីរកឧបាយ ឬក៏ ព្រងើយកន្តើយថា “សេចក្តីបង្អៀតបង្អល់ចិត្ត ចាត់ជាសង្ខារ” ឈ្មោះថា សង្ខារុបេក្ខាញាណ” ដូច្នេះឯង ។

ក្នុងបទទាំងនោះ បទសមាសថា “មុញ្ចិតុកម្យតាបដិសង្ខាសន្តិដ្ឋនា” មានវិគ្រោះថា មុញ្ចិតុកម្យតា និង បដិសង្ខា និង សន្តិដ្ឋនា ។ ព្រោះហេតុនេះ ការប្រាថ្នាដើម្បីនឹងលះបង់ការកើតជាដើម របស់ព្រះយោគាវចរ អ្នកនឿយណាយហើយ ដោយនិព្វិទាញាណ ក្នុងចំណែកខាងដើម ឈ្មោះថា មុញ្ចិតុកម្យតា ។ ការពិចារណា ត្រង់កណ្តាល ដើម្បីធ្វើនូវ

១- សុ. ខុ. បដិ. ភាគទី ៦៩ ទំព័រទី ១៣៥ ។



ឧបាយនៃការរួចផុត ឈ្មោះថា បដិសង្ខា ។ ការដែលលះបង់បានហើយព្រងើយកន្តើយ ក្នុងទីបញ្ចប់ ឈ្មោះថា សន្តិដ្ឋនា ដែលលោកសំដៅយកពោលហើយថា “ការកើត [១] ចាត់ជាសង្ខារ បុគ្គលរំពឹងមើលនូវសង្ខារទាំងឡាយនោះ ហេតុនោះ ទើបឈ្មោះថា សង្ខារុបេក្ខា” ដូច្នេះជាដើម។ ញាណនេះ ជាមួយគ្នាមែនពិត ដូចពោលមកហើយ។ មួយទៀត គប្បីជ្រាបថា “ញាណនេះ ជាមួយគ្នាមែនពិត តាមបាលីនោះ” ដូច្នេះក៏បាន ។ មែនពិត ពាក្យលោកពោលហើយថា “មុញ្ចិតុកម្យតាញាណឯណាក្តី បដិសង្ខានុបស្សនាញាណ ណាក្តី សង្ខារុបេក្ខាញាណ ណាក្តី ធម៌ទាំងនេះ មានសេចក្តីជាមួយគ្នា តែព្យញ្ជនៈផ្សេងគ្នា” ដូច្នេះ ។

## (វុដ្ឋានគាមិនីវិបស្សនា)

ក៏វិបស្សនា របស់កុលបុត្រនេះ ជាអ្នកបានសំរេចនូវសង្ខារុបេក្ខាញាណ យ៉ាងនេះហើយ ជាគុណជាតិដល់នូវទីបំផុត(សិខាបត្តៈ)ជាគុណជាតិមានប្រក្រតី ទៅដល់ទីចេញ (វុដ្ឋានគាមិនី) ។ ពាក្យថា “សិខាបត្តាវិបស្សនា” ក្តី ពាក្យថា “វុដ្ឋានគាមិនី” ក្តី នុ៎ះ ជាឈ្មោះនៃញាណ ៣ មានសង្ខារុបេក្ខាញាណជាដើម (គឺសង្ខារុបេក្ខាញាណ អនុលោមញាណ និង គោត្រភូញាណ) ហ្នឹងឯង ។ ក៏វិបស្សនានោះ ឈ្មោះថា សិក្ខាបត្តៈ ព្រោះដល់កំពូល គឺភាពខ្ពង់ខ្ពស់ (នៃលោកិយញាណ, ឈ្មោះថា វុដ្ឋានគាមិនី ព្រោះទៅដល់ទីចេញ ។ មគ្គ ហៅថា វុដ្ឋានៈ ព្រោះចេញចាកវត្ថុដែលស្អិតដែលជានិមិត្ត(គឺអារម្មណ៍)ពួជខាងក្រៅ និងចាកការប្រព្រឹត្តិ (គឺសង្ខារ) ពួជខាងក្នុងផង, វិបស្សនានេះ ទៅកាន់វុដ្ឋានៈ គឺមគ្គនោះ ហេតុនោះ ឈ្មោះថា វុដ្ឋានគាមិនី សេចក្តីថា រមែងត ជាមួយនឹងមគ្គ ។

១- សុ. ខុ. ភាគទី ៦៧ ទំព័រទី ១៣៧ ។

(មាតិកានៃវុដ្ឋានៈ)

*នេះជាមាតិកា ដើម្បីប្រយោជន៍ ដល់ការប្រាកដច្បាស់នៃការចេញចាកការប្រកាន់ស្អិត ក្នុងពាក្យដែលពោលហើយ ដោយសង្ខេបនោះ គឺៈ*

អជ្ឈត្តំ អភិនិវិសិត្វា អជ្ឈត្តា វុដ្ឋាតិ *ប្រកាន់ស្អិត(ក្នុងសង្ខារទាំងឡាយ) ពួដ៏ខាងក្នុង ហើយចេញចាក (សង្ខារទាំងឡាយ)ពួដ៏ខាងក្នុង,*

អជ្ឈត្តំ អភិនិវិសិត្វា ពហិទ្ធា វុដ្ឋាតិ *ប្រកាន់ស្អិត(ក្នុងសង្ខារទាំងឡាយ) ពួដ៏ខាងក្នុង ហើយចេញចាក(សង្ខារទាំងឡាយ) ពួដ៏ខាងក្រៅ,*

ពហិទ្ធា អភិនិវិសិត្វា ពហិទ្ធា វុដ្ឋាតិ *ប្រកាន់ស្អិត(ក្នុងសង្ខារទាំងឡាយ) ពួដ៏ខាងក្រៅ ហើយចេញចាក(សង្ខារទាំងឡាយ) ពួដ៏ខាងក្រៅ,*

ពហិទ្ធា អភិនិវិសិត្វា អជ្ឈត្តា វុដ្ឋាតិ *ប្រកាន់ស្អិត(ក្នុងសង្ខារទាំងឡាយ) ពួដ៏ខាងក្រៅ ហើយចេញចាក(សង្ខារទាំងឡាយ) ពួដ៏ខាងក្នុង,*

រូបេ អភិនិវិសិត្វា រូបា វុដ្ឋាតិ *ប្រកាន់ស្អិតក្នុងរូប ហើយចេញចាករូប,*

រូបេ អភិនិវិសិត្វា អរូបា វុដ្ឋាតិ *ប្រកាន់ស្អិតក្នុងរូប ហើយចេញចាកអរូប,*

អរូបេ អភិនិវិសិត្វា អរូបា វុដ្ឋាតិ *ប្រកាន់ស្អិតក្នុងអរូប ហើយចេញចាកអរូប,*

អរូបេ អភិនិវិសិត្វា រូបា វុដ្ឋាតិ *ប្រកាន់ស្អិតក្នុងអរូប ហើយចេញចាករូប,*

ឯកប្បហារេន បញ្ចហិ ខន្ធេហិ វុដ្ឋាតិ *ចេញចាកខន្ធទាំង ៥ ព្រមគ្នាតែម្តង,*

អនិច្ចតោ អភិនិវិសិត្វា អនិច្ចតោ វុដ្ឋាតិ *ប្រកាន់ស្អិត ដោយភាពជារបស់មិនទៀង ហើយចេញចាកភាពជារបស់មិនទៀង,*



អនិច្ចតោ អភិនិវិសិត្វា ទុក្ខតោ...អនត្តតោ វុដ្ឋាតិ *ប្រកាន់ស្អិត ដោយភាពជារបស់មិនទៀង ហើយចេញចាកភាពជាទុក្ខ... ចេញចាកភាពជាអនត្តា,*

ទុក្ខតោ អភិនិវិសិត្វា ទុក្ខតោ... អនិច្ចតោ... អនត្តតោ វុដ្ឋាតិ *ប្រកាន់ស្អិត ដោយភាពជាទុក្ខ ហើយចេញចាកភាពជាទុក្ខ... ចេញចាកភាពជារបស់មិនទៀង... ចាកភាពជាអនត្តា ។*

អនត្តតោ អភិនិវិសិត្វា អនត្តតោ... អនិច្ចតោ... ទុក្ខតោ វុដ្ឋាតិ *ប្រកាន់ស្អិត ដោយភាពជាអនត្តា ហើយចេញចាកភាពជាអនត្តា...ចេញចាកភាពជារបស់មិនទៀង... ចាកភាពជាទុក្ខ ។*

(អធិប្បាយសេចក្តីនៃមាតិកា)

*អធិប្បាយសេចក្តីនៃមាតិកានេះ តើដូចម្តេច? គឺ ព្រះយោគាវចរក្នុងសាសនានេះ ដំបូងបំផុត ប្រកាន់ស្អិតក្នុងសង្ខារ ពួដ៏ខាងក្នុង លុះប្រកាន់ស្អិតហើយ ក៏ឃើញនូវសង្ខារខាងក្នុងទាំងនោះ ។ ប៉ុន្តែព្រោះការចេញដោយមគ្គ នឹងមិនមាន ដោយហេតុត្រឹមតែការឃើញ នូវសង្ខារខាងក្នុងសុទ្ធសាធប៉ុណ្ណោះទេ ត្រូវតែឃើញសង្ខារខាងក្រៅផង ដូចគ្នានោះដែរ ព្រោះហេតុនោះ ព្រះយោគាវចរនោះ ទើបឃើញ នូវរូបក្ខន្ធរបស់អ្នកដទៃផង នូវអនុបាទិន្នកសង្ខារទាំងឡាយផងថា “មិនទៀង ជាទុក្ខ ជាអនត្តា” ។ ព្រះយោគាវចរនោះ រមែងពិចារណាសង្ខារខាងក្នុងតាមកាល ពិចារណាសង្ខារខាងក្រៅ តាមកាល ។ កាលបើព្រះយោ-គាវចរនោះ ពិចារណា យ៉ាងនេះ វិបស្សនា រមែង ត ជាមួយនឹងមគ្គក្នុងពេលពិចារណា នូវសង្ខារខាងក្នុង ។ ព្រះយោគាវចរនេះ ឈ្មោះថា*

ប្រកាន់ស្អិត (ក្នុងសង្ខារទាំងឡាយ) ខាងក្នុង ហើយចេញចាក (សង្ខារទាំងឡាយ)ខាងក្នុង។ តែបើវិបស្សនា ត ជាមួយនឹងមគ្គ ក្នុងពេលដែលព្រះយោគាវចរនោះពិចារណា(សង្ខារទាំងឡាយ)ខាងក្រៅ ។ ព្រះយោ-គាវចរនេះ ឈ្មោះថា ប្រកាន់ស្អិត(ក្នុងសង្ខារទាំងឡាយ)ខាងក្នុង ហើយចេញចាក(សង្ខារទាំងឡាយ)ខាងក្រៅ ។ សូម្បីក្នុងការប្រកាន់ស្អិត ឰដ៏ខាងក្រៅ ហើយចេញចាកខាងក្រៅ និង ខាងក្នុង ក៏ន័យនេះដែរ ។

ព្រះយោគាវចរដទៃទៀត ដំបូង ប្រកាន់ស្អិត ក្នុងរូប លុះប្រកាន់ស្អិតហើយ មើលនូវភូតរូប និង ឧបាទាយរូប ធ្វើជាគំនរ ។ តែព្រោះការចេញរមែងមាន ដោយហេតុត្រឹមតែឃើញរូបសុទ្ធសាធប៉ុណ្ណោះក៏ទេ ត្រូវតែឃើញអរូបដូចគ្នាផងដែរ ហេតុនោះ ព្រះយោគាវចរនោះ ធ្វើរូបនោះឲ្យជាអារម្មណ៍ហើយ ទើបឃើញអរូប គឺ វេទនា, សញ្ញា, សង្ខារ, និង វិញ្ញាណ ដែលកើតឡើងហើយថា "នេះ ជាអរូប" ដូច្នេះ ។ ព្រះយោគាវចរនោះ រមែងពិចារណារូប តាមកាល ពិចារណាអរូប តាមកាល។ កាលបើព្រះយោគាវចរនោះពិចារណាយ៉ាងនេះហើយ វិបស្សនារមែង ត ជាមួយនឹងមគ្គ ក្នុងពេលដែលព្រះយោគាវចរនោះ ពិចារណារូប ។ ព្រះយោគាវចរនេះ ឈ្មោះថា ប្រកាន់ស្អិតក្នុងរូប ហើយចេញចាករូប ។ តែបើវិបស្សនា តជាមួយនឹងមគ្គ ក្នុងពេលដែលព្រះយោគា-វចរនោះ ពិចារណាអរូប, ព្រះយោគាវចរនោះ ឈ្មោះថា ប្រកាន់ស្អិតក្នុងរូប ហើយចេញចាកអរូប ។ សូម្បីក្នុងការប្រកាន់ស្អិត ក្នុងអរូប ហើយចេញចាកអរូប និង រូប ក៏ន័យនេះដែរ ។ ប៉ុន្តែ ក្នុងពេលដែលប្រកាន់ស្អិត យ៉ាងនេះថា "របស់ណា មានការកើតឡើងជាធម្មតា របស់ទាំងអស់នោះ មានការរលត់ទៅវិញជាធម្មតា" ដូច្នេះហើយ ចេញដោយ



ការកំណត់ ដូចគ្នានោះដែរ, ព្រះយោគាវចរនោះ ឈ្មោះថា ចេញចាកខន្ធទាំង ៥ ព្រមជាមួយគ្នាតែម្តង ។

ព្រះយោគាវចរមួយទៀត ដំបូងបំផុត ពិចារណាសង្ខារទាំងឡាយថា ជារបស់មិនទៀង ។ តែព្រោះការចេញ នឹងមាន ដោយហេតុត្រឹមតែការពិចារណាថា ជារបស់មិនទៀងប៉ុណ្ណោះក៏ទេ ត្រូវតែពិចារណាថា ជាទុក្ខ ថា ជាអនត្តា ផងដែរ ដោយពិត ហេតុនោះ ព្រះយោគាវចរនោះទើបពិចារណាថាជាទុក្ខផង ថាជាអនត្តាផង ។ ព្រះយោគាវចនេះ ឈ្មោះថាប្រកាន់ស្អិតថាមិនទៀងហើយ ចេញចាករបស់មិនទៀង។ ប៉ុន្តែប្រសិនបើវុដ្ឋានៈ មាន ក្នុងពេលដែលព្រះយោគាវចរនោះ ពិចារណាថា ជាទុក្ខថា ជាអនត្តា, ព្រះយោគាវចរនោះ ឈ្មោះថា ប្រកាន់ស្អិតថា មិនទៀងហើយចេញចាករបស់ជាទុក្ខ របស់ជាអនត្តា។ សូម្បីក្នុងការប្រកាន់ស្អិតថា ជាទុក្ខ ជាអនត្តា ហើយចេញចាកលក្ខណៈដ៏សេស ក៏ន័យនេះដែរ ។

ក៏បណ្តាបុគ្គល អ្នកចេញចាកការប្រកាន់ស្អិត យ៉ាងនេះ បុគ្គលអ្នកចេញដោយភាពជារបស់មិនទៀងក្តី អ្នកចេញដោយភាពជាទុក្ខក្តី អ្នកចេញដោយភាពជាអនត្តាក្តី តែក្នុងពេលចេញ វុដ្ឋានៈ រមែងមានដោយភាពជារបស់មិនទៀង, បុគ្គលទាំង៣ នាក់នោះ ជាអ្នកច្រើនដោយអធិ-មោក្ខ រមែងបាននូវសទ្ធិន្ទ្រីយ៍ រួបផុតស្រឡះ ដោយអនិមិត្តវិមោក្ខ, ក្នុងខណៈនៃបឋមមគ្គ បានជាសទ្ធានុសារី បានជាសទ្ធាវិមុត្ត ក្នុងឋានៈ ៧ តែប្រសិនបើ វុដ្ឋានៈ មាន ដោយភាពជាទុក្ខ ជនទាំង ៣ (នោះ) ជាអ្នកច្រើនដោយបស្សទ្ធិ រមែងបានសមាធិន្ទ្រីយ៍ រមែងរួបផុតស្រឡះ ដោយអប្បណិហិតវិមោក្ខ បានជាកាយសក្ខី ក្នុងទីទាំងពួង, ប៉ុន្តែ ក្នុងបុគ្គលទាំងនោះ បុគ្គលណា មានអរូបជ្ឈាន ជាបាទ, បុគ្គលនោះ ជាឧភតោ-

*ភាគវិមុត្ត ក្នុងផលដ៏ខ្ពង់ខ្ពស់ ។ គ្រានោះ វុដ្ឋានៈ ដោយភាពជាអនត្តា រមែងមានដល់បុគ្គលទាំងបីនោះ, បុគ្គលទាំងបី(នោះ) ជាអ្នកច្រើនដោយវេទៈ រមែងបាននូវបញ្ញិន្ទ្រីយ៍ រួចផុតស្រឡះ ដោយសុញ្ញតវិមោក្ខ បានជាធម្មានុសារី ក្នុងខណៈនៃបឋមមគ្គ បានជាទិដ្ឋិប្បត្តៈ ក្នុងឋានៈ ៦ បានជាបញ្ញាវិមុត្ត ក្នុងផលដ៏ខ្ពង់ខ្ពស់ យ៉ាងដូច្នេះឯង ។*

(ឧបមានៃវុដ្ឋានគាមិនីវិបស្សនា ១២)

*(៨៤៩) ឥឡូវនេះ គប្បីជ្រាបឧបមា ១២ ប្រការ ដើម្បីប្រយោជន៍ដល់ការជាក់ច្បាស់ នៃវុដ្ឋានគាមិនីវិបស្សនានេះ ព្រមទាំងញាណខាងដើម និង ខាងចុង ។ នេះជាឧទ្ទាននៃឧបមាទាំងនោះ គឺ :*

សត្វប្រចៀវ, ពស់វែក, ផ្ទះ, គោ, យក្ខិនី, ទារក,
សេចក្ដីឃ្លាន, សេចក្ដីស្រេក, ត្រជាក់, ក្ដៅ, ងងឹត
ព្រមទាំងថ្នាំពិស ត្រូវជា ១២ ។

*ក៏ឧបមាទាំងនេះ លោកពោលហើយថា "ចាប់តាំងពីភយតុបដ្ឋានញាណមក នឹងតាំងនៅក្នុងញាណណាមួយហើយនាំមក(ពោល)ក៏គួរ ។ តែកាលនាំមក (ពោល) ក្នុងទីនេះ ញាណទាំងពួង រមែងប្រាកដ តាំងពីភយតុបដ្ឋានញាណ រហូតដល់ផលញាណ ។ ព្រោះហេតុនោះ គប្បីនាំមក (ពោល) ក្នុងទីនេះ ដោយពិត" ។*

(សត្វប្រចៀវ)

*ក្នុងឧបមាថា "សត្វប្រចៀវ" មានសេចក្ដីថា បានឮមកថា សត្វប្រចៀវមួយ គិតថា "អញនឹងបាននូវផ្កា ឬផ្លែ លើដើមស្រគំនេះ" ដូច្នេះហើយ ក៏ទំលើដើមស្រគំដែលមានមែក ៥ ហើយចាប់មែក ១ មិនបាន*



*ឃើញនូវផ្កា ឬ ផ្លែណាមួយ ដែលគួរនឹងខាំស៊ី នៅត្រង់មែកនោះសោះ ។ និង ចាប់មែក ១ (ទៀត) ហើយ ក៏មិនឃើញ (មានផ្កា ឬ ផ្លែណាមួយដែលគួរចាប់ខាំស៊ី) ឡើយ យ៉ាងណាមិញ, ចាប់មែកទី២ ទី៣ ទី៤ ទាំងទី៥ ហើយ ក៏មិនឃើញទាល់តែសោះ ក៏យ៉ាងនោះដែរ ។ វា គិតថា "ដើមឈើនេះ មិនមានផ្លែសោះ (ផ្កា ឬ ផ្លែ) ដែលគួររើសស៊ីលើដើមឈើនេះ គ្មានឡើយ" ដូច្នេះហើយ ទើបដាច់អាល័យលើដើមឈើនោះ ហើយវារឡើង តាមមែកដែលត្រង់ ដាក់ក្បាលតាមប្រឡោះបង្គាបឈើ ងើយមើលទៅខាងលើ ហើរទៅលើអាកាសហើយ ទៅទំលើដើមឈើដែលមានផ្លែផ្សេងទៀត ។*

(សេចក្ដីប្រៀបធៀប)

*ក្នុងសេចក្ដីឧបមានោះ ព្រះយោគាវចរ បណ្ឌិតគប្បីឃើញថា ដូចជាសត្វប្រចៀវ ។ ឧបាទានខន្ធ ៥ ដូចជាដើមស្រគំ ដែលមានមែក ៥ ។ សេចក្ដីប្រកាន់ស្អិត ក្នុងខន្ធ ៥ របស់ព្រះយោគាវចរ ប្រៀបដូចជាការទំលើដើមស្រគំ នៃសត្វប្រចៀវ ។ ការពិចារណារូបក្ខន្ធ មិនឃើញមានអ្វីបន្តិចបន្តួចដែលគួរឲ្យប្រកាន់ ក្នុងរូបក្ខន្ធនោះសោះ ហើយពិចារណា នូវខន្ធដ៏សេស របស់ព្រះយោគាវចរ ប្រៀបដូចជាសត្វប្រចៀវ ទំលើមែកឈើមួយៗ មិនឃើញរបស់អ្វីបន្តិចបន្តួចហើយ ក៏ហើរទៅទំលើមែកឈើមួយទៀត។ ញាណ៣ មានមុញ្ចិតុកម្យតាញាណជាដើម របស់ព្រះយោគីអ្នកនឿយណាយ ក្នុងខន្ធទាំង ៥ ដោយអំណាចការឃើញត្រៃលក្ខណ៍មានអនិច្ចលក្ខណៈជាដើម ប្រៀបដូចជាការគិតថា "ដើមឈើនេះ គ្មានផ្លែសោះ" ហើយក៏លះបង់សេចក្ដីអាល័យ ក្នុងដើមឈើ នៃសត្វប្រចៀវនោះ ។ អនុលោមញាណរបស់ព្រះយោគី ប្រៀបដូចជាការវារឡើងលើ*

តាមមែកឈើដែលត្រង់ នៃសត្វប្រចៀវនោះ ។ គោត្រភូញាណ ប្រៀបដូចជាសត្វប្រចៀវ អើតក្បាលចេញ ហើយត្រឡប់មើលទៅខាងលើ ។ មគ្គញ្ញាណ ប្រៀបដូចសត្វប្រចៀវហើរឡើងលើអាកាស ។ ផលញ្ញាណ ប្រៀបដូចសត្វប្រចៀវ ទំលើដើមឈើផ្សេងទៀត ដែលគ្មានផ្លែ ។

(ពស់វែក)

សេចក្តីឧបមា ដោយពស់វែក លោកពោលហើយ ក្នុងបដិសង្ខាញាណនុ៎ះឯង ។ តែក្នុងការប្រៀបធៀបសេចក្តីឧបមា ក្នុងទីនេះ មានការប្លែកពីគ្នាយ៉ាងនេះ គឺៈ គោត្រភូញាណ ប្រៀបដូចជាការលែងនូវពស់, មគ្គញ្ញាណ ប្រៀបបីដូចជាបុរសលែងពស់ហើយ ឈរមើលផ្លូវមក ។ ផលញ្ញាណ ប្រៀបដូចជាការទៅឈរ ក្នុងទីដែលមិនមានភ័យ ។

(ផ្ទះ)

ក្នុងសេចក្តីឧបមាថា “ផ្ទះ” មានសេចក្តីថា បានឮមកថា កាលបើម្ចាស់ផ្ទះ បរិភោគបាយល្ងាចហើយ ក៏ដេកលក់ទៅ ស្រាប់តែភ្លើងឆេះផ្ទះ ។ ម្ចាស់ផ្ទះនោះ ភ្ញាក់ឡើងហើយ ឃើញភ្លើងឆេះ ក៏កិតភ័យ ម្នីម្នាក្រឡេកមើល ដោយគិតថា “ជាការល្អហើយ បើអញមិនត្រូវភ្លើងឆេះនឹងចេញ” ហើយឃើញផ្លូវ ក៏ចេញទៅឈររកទីដ៏ក្សេម យ៉ាងលឿន ។

(សេចក្តីប្រៀបធៀប)

ក្នុងសេចក្តីឧបមានោះ ការប្រកាន់មាំ ក្នុងខន្ធ ៥ ថា “អញ ថារបស់អញ” នៃពាលបុថុជ្ជន ប្រៀបដូចជាម្ចាស់ផ្ទះ បរិភោគបាយហើយទៅរកដំណេក ហើយដេកលក់ទៅ ។ ការបានដល់នូវការប្រតិបត្តិ ដ៏ត្រឹមត្រូវ ហើយឃើញត្រៃលក្ខណ៍ រហូតដល់កើតភយតុបដ្ឋានញាណ ប្រៀបដូចជាម្ចាស់ផ្ទះ ភ្ញាក់ឡើងហើយ ឃើញភ្លើងក៏ភ័យខ្លាច ដូច្នោះ ។



មុញ្ចិតុកម្យតាញាណ ប្រៀបដូចជាម្ចាស់ផ្ទះសំឡឹងរកផ្លូវចេញ ។ អនុលោមញ្ញាណ ប្រៀបដូចជាការឃើញផ្លូវ ។ គោត្រភូញាណ ប្រៀបដូចជាការដើរចេញទៅ ។ មគ្គញ្ញាណ ប្រៀបដូចជាការទៅ យ៉ាងប្រញាប់ ។ ផលញ្ញាណ ប្រៀបដូចជាការឈរនៅ ក្នុងទីដ៏ក្សេមក្សាន្ត ។

(គោ)

ក្នុងសេចក្តីឧបមាថា “គោ” មានសេចក្តីថា បានឮមកថា មានបុរសអ្នកស្រែម្នាក់ កំពុងតែដេកលក់ ក្នុងពេលយប់ ក៏ស្រាប់តែគោទាំងឡាយ នាំគ្នាទំលាយក្រោលចេញអស់ទៅ ។ ព្រឹកឡើង គាត់ទៅមើលត្រង់ក្រោលគោនោះ ក៏ដឹងថា គោទាំងនោះរត់ចេញអស់ហើយ ទើបដើរទៅតាមស្នាមជើងគោក៏ស្រាប់តែជួបប្រទះប៉ះនឹងគោរបស់ស្តេច ។ គាត់សំគាល់ថា “គោទាំងនោះ ជាគោរបស់គាត់” ទើបដឹកយកមក លុះដល់ក្រោយមក ទើបដឹងច្បាស់ថា “គោទាំងនេះ មិនមែនជាគោ របស់ខ្លួនទេ គឺជាគោរបស់ស្តេច” ហើយ ក៏គិតថា “ដរាបណា រាជបុរស មិនទាន់ចាប់អញ ដោយគិតថា “ជាចោរ” ហើយឲ្យដល់នូវសេចក្តីវិនាស, អញនឹងរត់ចេញ ឲ្យទាល់តែបាន ដរាបនោះ” ដូច្នេះហើយ ក៏លែងគោ ម្នីម្នាប្រញាប់ប្រញាល់ រត់គេចចេញទៅនៅ ក្នុងទីដែលមិនមានភ័យ ។

(សេចក្តីប្រៀបធៀប)

ក្នុងពាក្យឧបមានោះ ការប្រកាន់មាំ នូវខន្ធទាំងឡាយ ថា ជាអញ ជារបស់អញ” របស់ពាលបុថុជ្ជន ប្រៀបដូចជាការចាប់យកគោ របស់ស្តេចថា “ជាគោ របស់ខ្លួន” ។ ការដែលព្រះយោគី ដឹងច្បាស់នូវខន្ធទាំងឡាយថា “វា ជារបស់មិនទៀង ជាទុក្ខ ជាអនត្តា” ដោយអំណាចនៃត្រៃលក្ខណ៍ ប្រៀបដូចជាបុរសដឹងច្បាស់ថា “គោ របស់ស្តេច” ក្នុង

ពេលដែលភ្ញាក់ឡើង ។ ភយតុបដ្ឋានញាណ ប្រៀបដូចជាពេលដែលបុរសនោះភ័យហើយ ។ មុញ្ចិតុកម្យតាញាណ ប្រៀបដូចជាបុរសនោះលែងគោហើយទៅ ។ គោត្រភូញាណ ប្រៀបដូចជាការលែងគោ ។ មគ្គញ្ញាណ ប្រៀបដូចជាការរត់ចេញ ។ ផលញ្ញាណ ប្រៀបដូចជាបុរសរត់គេចហើយ ទៅឈរនៅ ក្នុងទីដែលគ្មានភ័យ ។

(យក្ខិនី)

ត្រង់ពាក្យប្រៀបដូចជា យក្ខិនី នេះ មានសេចក្តីថា: បានឮមកថា បុរសម្នាក់ នៅរួមជាមួយនឹងយក្ខិនី ។ នៅពេលយប់ នាងយក្ខិនីនោះដឹងថា "បុរសនោះ ដេកលក់ហើយ" ក៏ទៅកាន់ទីស្មសានដែលមានខ្មោចស្រស់ហើយទំពាស៊ីនូវសាច់មនុស្ស ។ បុរសនោះ គិតថា "នាងទៅណាអេះ" ដូច្នេះហើយ ក៏ទៅតាម ឃើញនាងកំពុងទំពាស៊ីសាច់មនុស្ស ទើបដឹងថា នាងជាអមនុស្សក៏គិតថា "អញនឹងរត់ចេញទៅ ឲ្យបានមុនពេលនាងយក្ខិនីស៊ីអញ" ហើយភ័យខ្លាចប្រញាប់រត់ទៅនៅក្នុងទីសុខសាន្ត ។

(សេចក្តីប្រៀបធៀប)

ក្នុងពាក្យប្រៀបធៀបនោះការប្រកាន់មាំនូវខន្ធទាំងឡាយថា "អញថា របស់អញ" ដូចជាការនៅរួម ជាមួយនឹងនាងយក្ខិនី ។ ការឃើញត្រៃលក្ខណ៍ហើយដឹងច្បាស់ថា ខន្ធទាំងឡាយ ជារបស់មិនទៀងជាដើម ដូចជាការឃើញនាងយក្ខិនី កំពុងទំពាស៊ីសាច់មនុស្ស ក្នុងទីស្មសាន ហើយដឹងថា "នាងជាយក្ខិនី" ។ ភយតុបដ្ឋានញាណ ដូចជាកាលបុរសភ័យហើយ ។ មុញ្ចិតុកម្យតាញាណ ដូចជាការប្រាថ្នានឹងរត់ចេញទៅ ។ គោត្រភូញាណ ដូចជាការលះបង់នូវព្រៃស្មសាន ។ មគ្គញ្ញាណ ដូចជាការរត់គេចទៅ យ៉ាងឆាប់រហ័ស ។ ផលញ្ញាណ ដូចជាការឈរនៅក្នុង



ប្រទេសដែលមិនមានភ័យ ។

(ទារក)

(៤៥០) ត្រង់ពាក្យថាដូចជាទារកនោះ សេចក្តីថា: បានឮមកថា ស្រ្តីម្នាក់ មានកូនប្រុសតូចមួយ ។ នាងអង្គុយ លើប្រាសាទ ខាងលើហើយ ឮសូរសំឡេងទារកយំ នៅក្បែរថ្នល់ ក៏គិតថា "មានគេវាយកូនរបស់ខ្លួន" ហើយ ក៏រត់យ៉ាងប្រញាប់ ទៅចាប់យកកូនអ្នកដទៃ ដោយយល់ថា "ជាកូនរបស់ខ្លួន" ។ លុះនាងដឹងថា "វាជាកូនអ្នកដទៃ" ក៏ភ័យខ្លាច ងាកមើលនាយមើលអាយ នឹកគិតថា "អ្នកណាមួយ កុំពោលនឹងអញថា: នាងនេះ ជាអ្នកលួចយកទារក ដូច្នេះឡើយ" ហើយក៏ដាក់កូន (គេនោះ)នៅកណ្តាលថ្នល់ហ្នឹងឯង រួចហើយ ក៏ប្រញាប់ប្រញាល់ ឡើងទៅលើប្រាសាទ អង្គុយម្តងទៀត ។

(សេចក្តីប្រៀបធៀប)

ក្នុងពាក្យប្រៀបធៀបនោះ ការប្រកាន់មាំនូវបញ្ចក្ខន្ធថា "ជាអញជារបស់អញ" ដូចជាការចាប់យកកូនអ្នកដទៃ ដោយសំគាល់ថា ជាកូនរបស់ខ្លួន ។ ការដឹងច្បាស់ថា "នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជារបស់អញ" ដោយអំណាចនៃត្រៃលក្ខណ៍ ដូចជាការដឹងច្បាស់ថា "នេះជាកូនរបស់អ្នកដទៃ" ។ ភយតុបដ្ឋានញាណ ដូចជាការភ័យខ្លាច ។ មុញ្ចិតុ-កម្យតាញាណ ដូចជាការក្រឡេកមើលនាយមើលអាយ ។ អនុលោ-មញាណ ដូចជាការដាក់កូនចោលនៅកណ្តាលថ្នល់នុ៎ះឯង ។ គោត្រភូ-ញាណ ដូចជាការដាក់កូនហើយឈរនៅត្រង់ចន្លោះថ្នល់ ។ មគ្គញ្ញាណ ដូចជាការឡើងទៅលើប្រាសាទ ។ ផលញ្ញាណ ដូចជាការឡើងទៅលើប្រាសាទ ហើយអង្គុយ ។

(ការឃ្លាន, ការស្រេក, ត្រជាក់, ក្តៅ, ងងឹត និង ថ្នាំពិស)

ចំណែកឯឧបមា ៦ យ៉ាងនេះ គឺ ការឃ្លាន, ការស្រេក, ត្រជាក់, ក្តៅ, ងងឹត និង ថ្នាំពិស លោកពោលហើយ ដើម្បីសំដែង នូវភាពនៃបុគ្គលអ្នកតាំងនៅ ក្នុងវុដ្ឋានគាមិនីវិបស្សនា ហើយជាអ្នកមានមុខឆ្ពោះទៅ បង្អោនទៅ ជ្រេទៅ ផ្អៀងទៅរកលោកុត្តរធម៌ ។

មែនពិត បុរសមានសេចក្តីឃ្លានគ្របសង្កត់ ជាអ្នកឃ្លានហួសពេក ប្រាថ្នាចង់បរិភោគភោជន មានរស់ដ៏ឆ្ងាញ់ មានឧបមាយ៉ាងណាមិញ, ចំណែកព្រះយោគាវចរ មានសេចក្តីឃ្លាន គឺសង្សារវដ្ដៈ គ្របសង្កត់ហើយ ប្រាថ្នានូវភោជន គឺកាយគតាសតិ ដែលមានរស់ជាអមតៈ ក៏មានឧបមេយ្យយ៉ាងនោះឯង ។

មួយទៀត បុរសដែលស្រេកហើយ មាន-ក និង មាត់ ស្ងួតហែងអស់ហើយ ប្រាថ្នាទឹកដែលមានគ្រឿងផ្សំច្រើនយ៉ាង មានឧបមាយ៉ាងណា, ព្រះយោគាវចរ ដែលត្រូវសេចក្តីស្រេក គឺសង្សារវដ្តប៉ះពាល់ត្រូវហើយនេះ ក៏ប្រាថ្នានូវទឹក គឺអដ្ឋង្គិកមគ្គ ដ៏ប្រសើរ ក៏មានឧបមេយ្យយ៉ាងដូច្នោះឯង ។

មួយទៀត បុរសដែលត្រូវរងា បៀតបៀនហើយ តែងប្រាថ្នានូវកំដៅ យ៉ាងណាមិញ, ព្រះយោគាវចរ ដែលត្រូវរងា គឺប្រេង ពោលគឺតណ្ហា ក្នុងសង្សារវដ្ត ពាល់ត្រូវហើយនេះ តែងប្រាថ្នានូវភ្លើង គឺមគ្គដែលដុតបំផ្លាញនូវកិលេស ក៏យ៉ាងនោះដែរ ។

មួយទៀត បុរសដែលត្រូវកំដៅបៀតបៀនហើយ តែងប្រាថ្នានូវគ្រឿងត្រជាក់ យ៉ាងណាមិញ, ព្រះយោគាវចរ ដែលត្រូវកំដៅ នៃភ្លើង ១១ យ៉ាង ក្នុងសង្សារវដ្ត ដុតកំដៅហើយ តែងប្រាថ្នា នូវព្រះនិព្វាន



ដែលសំរាប់រំលត់នូវគប់ភ្លើង ១១ យ៉ាង ក៏ដូច្នោះដែរ ។

មួយទៀត បុរសដែលដើរទៅ ក្នុងទីដែលងងឹត តែងប្រាថ្នានូវពន្លឺ យ៉ាងណាមិញ, ព្រះយោគាវចរដែលត្រូវងងឹតពោលគឺអវិជ្ជាគ្របសង្កត់ បិទបាំងហើយនេះ តែងប្រាថ្នានូវមគ្គភាវនា ដែលមានពន្លឺសំរេចមកអំពីញាណ ក៏យ៉ាងនោះដែរ ។

មួយវិញទៀត បុរសដែលពុលថ្នាំពិស តែងប្រាថ្នា នូវថ្នាំសំរាប់រម្ងាប់នូវពិស យ៉ាងណាមិញ, ព្រះយោគាវចរ ដែលត្រូវពិសគឺកិលេសពាល់ត្រូវហើយនេះ រមែងប្រាថ្នានូវព្រះនិព្វាន ជាឱសថអមតៈ សំរាប់រម្ងាប់ពិស គឺកិលេស ក៏យ៉ាងដូច្នោះដែរ ។

ព្រោះហេតុនោះ ទើបខ្ញុំពោលថា “កាលបើព្រះយោគាវចរនោះឃើញ យ៉ាងនោះ ឃើញយ៉ាងនេះ ចិត្ត រមែងថយ រួញខ្វរ បែរត្រឡប់ មិនអាឡោះអាល័យក្នុងភព ៣, កំណើត ៤, គតិ ៥, វិញ្ញាណឋិតិ ៧, សត្តាវាស ៩, ឧបេក្ខា ឬ ភាពគួរខ្ពើម រមែងតាំងនៅមាំ ឧបមាដូចជាតំណក់ទឹកទាំងឡាយ លើស្លឹកឈូកដែលផ្អៀងបន្តិច (រមែងធ្លាក់ចុះ ជ្រុះរមៀលចេញ មិនជាប់នៅលើស្លឹកឈូក)” ដូច្នេះជាដើម ។ ពាក្យទាំងពួង គប្បីជ្រាប តាមន័យដែលពោលមកហើយ ខាងដើមនុ៎ះឯង ។

ក៏ដោយបដិបទា ដែលមានប្រមាណប៉ុណ្ណោះ ព្រះយោគាវចរនោះ រមែងបានឈ្មោះថា បដិលីនចរៈ ដែលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សំដៅយកហើយ ថា :

ភិក្ខុណា មិនសំដែងខ្លួនក្នុងភព(ថ្មីទៀត) អ្នកប្រាជ្ញទាំង
ឡាយ ហៅអំពើនោះ របស់ភិក្ខុនោះ អ្នកប្រព្រឹត្តរួញរា
អ្នកភប់ប្រសព្វអាសនៈស្ងាត់ថា ជាភាពសមរម្យហើយ ។

(៤៥១) សង្ខារុបេក្ខាញាណនេះ កំណត់ភាពជាបដិលីនចរៈ នៃព្រះយោគី ដូចពោលមកនេះហើយ កំណត់នូវការផ្សេងគ្នានៃពោជ្ឈង្គ, ការផ្សេងគ្នានៃអង្គមគ្គ, ការផ្សេងនៃអង្គឈាន, ការផ្សេងគ្នានៃបដិបទា, ការផ្សេងគ្នានៃវិមោក្ខ នៃអរិយមគ្គ តទៅទៀតផងដែរ ។

តែព្រះថេរៈអង្គខ្លះ ពោលថា "បាទកជ្ឈាន គឺឈានដែលជាបាទនៃវុដ្ឋានគាមិនីវិបស្សនា ដែលរំកិលទៅជិតនឹងមគ្គ កំណត់នូវការផ្សេងគ្នា នៃពោជ្ឈង្គ នៃអង្គមគ្គ និង នៃអង្គឈាន" ។ ព្រះថេរៈអង្គខ្លះ ពោលថា "ខន្ធ ដែលជាអារម្មណ៍ នៃវិបស្សនា រមែងកំណត់ (ការផ្សេងគ្នានោះ)" ។ ព្រះថេរៈអង្គខ្លះ ពោលថា "អជ្ឈាស្រ័យ របស់បុគ្គល តែងកំណត់" ។ ក្នុងវាទៈនៃព្រះថេរៈទាំង៣ នោះ គប្បីជ្រាបថា "វុដ្ឋានគាមិនីវិបស្សនា ដែលជាបុព្វភាគនេះឯង កំណត់ (ការផ្សេងគ្នានោះ" ដូច្នេះ ។

នេះ ជាវាចា ពោលតាមលំដាប់ ក្នុងការកំណត់នូវការផ្សេងគ្នា នៃពោជ្ឈង្គជាដើម ។

អធិប្បាយថាៈ ពោលដោយការកំណត់វិបស្សនា មគ្គ ដែលកើតឡើងដល់ព្រះសុក្ខវិបស្សកៈក្តី មគ្គ ដែលមិនធ្វើឈាន ឲ្យជាបាទកើតឡើងដល់បុគ្គលអ្នកបានសមាបត្តិក្តី មគ្គ ដែលបុគ្គលអ្នកបានបំពេញវិបស្សនា ធ្វើបឋមជ្ឈាន ឲ្យជាបាទហើយ ពិចារណាសង្ខារពាយរង ឲ្យកើតឡើងក្តី ចាត់ជាបឋមជ្ឈានិកៈ គឺមានបឋមជ្ឈានហ្នឹងឯង ។ ក្នុងមគ្គទាំងអស់ ពោជ្ឈង្គមាន ៧, អង្គមគ្គ មាន ៨, អង្គឈាន មាន ៥ ។ សូម្បីបុព្វភាគវិបស្សនា នៃមគ្គទាំងនោះ ជាសោមនស្សសហគតៈខ្លះ ជាឧបេក្ខាសហគតៈខ្លះ ក្នុងពេលចេញ ក៏បានដល់នូវភាពជាសង្ខារុបេក្ខាហើយ បានជាសោមនស្សសហគតៈ ។



ក្នុងមគ្គទាំងឡាយដែលអ្នកបំពេញវិបស្សនា ធ្វើទុតិយជ្ឈាន តតិយជ្ឈាន និង ចតុត្ថជ្ឈាន ក្នុងបញ្ចកន័យ ឲ្យជាបាទហើយ ធ្វើឲ្យកើតឡើង, ឈាន រមែងមានអង្គ ៤ អង្គ ៣ និង អង្គ ២ តាមលំដាប់ លំដោយពិត ។ តែក្នុងមគ្គទាំងអស់ អង្គមគ្គ មាន ៧ ។ ពោជ្ឈង្គ មាន ៦ ក្នុងមគ្គ ទី ៤ ។ សេចក្តីផ្សេងគ្នានេះ រមែងមាន ទាំងដោយការកំណត់នៃបាទកជ្ឈាន ទាំងដោយការកំណត់នៃវិបស្សនា ។ ក៏បុព្វភាគវិបស្សនានៃមគ្គទាំងនោះសោត ជាសោមនស្សសហគតៈ ក៏មាន ជាឧបេក្ខាសហគតៈ ក៏មាន ។ វុដ្ឋាគាមិនីវិបស្សនា ជាសោមនស្សសហគតៈដូចគ្នាដែរ ។

ចំណែកក្នុងមគ្គដែលកើតឡើងព្រោះធ្វើបញ្ចកជ្ឈានឲ្យជាបាទ អង្គឈាន មាន ២ គឺ ឧបេក្ខា និង ចិត្តេកគ្គតា, ពោជ្ឈង្គ និង មគ្គ មាន ៦ និង ៧ ។ សូម្បីការផ្សេងគ្នានេះ រមែងមាន ដោយអំណាចនៃការនិយមទាំង ២ ។ តែក្នុងន័យនេះ បុព្វភាគវិបស្សនា ជាសោមនស្សសហគតៈខ្លះ ជាឧបេក្ខាសហគតៈខ្លះ ។ វុដ្ឋាគាមិនីវិបស្សនា ជាឧបេក្ខាសហគតៈតែប៉ុណ្ណោះ ។ សូម្បីក្នុងមគ្គដែលអ្នកបំពេញវិបស្សនា ធ្វើអរូបជ្ឈានឲ្យជាបាទហើយ ធ្វើឲ្យកើតឡើង ក៏ន័យដូចគ្នានេះឯង ។

សមាបត្តិដែលចេញហើយ ក្នុងទីជិតនៃមគ្គដែលកើតឡើង ព្រោះចេញពីបាទកជ្ឈានហើយ ពិចារណានូវសង្ខារទាំងឡាយណាមួយ យ៉ាងនេះ រមែងធ្វើនូវភាពនៃមគ្គនោះ ឲ្យស្មើនឹងខ្លួន ប្រៀបដូចជាសម្បុរ នៃផែនដី ធ្វើនូវសម្បុរនៃសត្វទន្សង ឲ្យដូចជាសម្បុរខ្លួន យ៉ាងដូច្នោះ ។

ចំណែកក្នុងវាទៈ នៃព្រះថេរៈទី២ (គប្បីជ្រាបថា) ជាមគ្គដែលកើតឡើងហើយ ព្រោះចេញអំពីសមាបត្តិ ឯណាមួយហើយ ពិចារណានូវ

សមាបត្តិធម៌ទាំងឡាយណាមួយ ក៏រមែងដូចគ្នានឹងសមាបត្តិនោះៗ ពិត។ សេចក្តីថា ស្មើគ្នានឹងសមាបត្តិដែលអ្នកចំរើនវិបស្សនាពិចារណាហើយ។ តែថាពិចារណានូវកាមាវចរធម៌ទាំងឡាយ ចាត់ជាបឋមជ្ឈានិកៈប៉ុណ្ណោះ ក៏ការកំណត់(នូវការផ្សេងគ្នានៃអង្គឈានជាដើម)នៃវិបស្សនា សូម្បីក្នុងវាទៈ ទី២ នោះ ក៏គប្បីជ្រាប តាមន័យដែលពោលមកហើយនេះឯង ។

តែក្នុងថេរវាទ ទី៣ (គប្បីជ្រាបថា) ជាមគ្គដែលកើតឡើង ព្រោះធ្វើឈានណាមួយ ឲ្យជាបាទហើយពិចារណាឈានធម៌ទាំងឡាយ ណាមួយ តាមសមគួរ ដល់អធ្យាស្រ័យរៀងៗ ខ្លួន ក៏រមែងស្មើគ្នានឹងឈាននោះៗ ពិត ។ តែការដែលមគ្គដែលកើតឡើងស្មើនឹងឈាននោះៗ នោះ បើប្រាសចាកឈានដែលជាបាទ ឬ ឈានដែលពិចារណាហើយ នឹងសំរេច ដោយហេតុត្រឹមតែអធ្យាស្រ័យ(របស់ខ្លួន)តែប៉ុណ្ណោះ ក៏មិនបានដែរ ។ សេចក្តីនេះនោះ គប្បីបំភ្លឺ ដោយនន្ទកោវាទកសូត្រ ។

មែនពិត ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ព្រះតម្រាស់នេះថា "ម្នាលភិក្ខុទាំងឡាយ! ក្នុងថ្ងៃឧបោសថ ១៥ កើត សេចក្តីសង្ស័យ ឬ សេចក្តីងឿងឆ្ងល់ថា: ព្រះច័ន្ទកន្លះ (ខែប) ឬ ពេញហើ មិនមាន ដល់ពួកជនច្រើនឡើយ, តាមពិត រមែងមានសេចក្តីសំរេចចិត្តថា ព្រះច័ន្ទពេញវង់ដូចគ្នាទាំងអស់ យ៉ាងណាមិញ, ម្នាលភិក្ខុទាំងឡាយ! ភិក្ខុនីនោះ ជាអ្នកមានចិត្តត្រេកអរ និង មានសេចក្តីត្រិះរិះ ពេញបរិបូណ៌ ដោយធម្មទេសនា របស់ភិក្ខុនន្ទកៈ ក៏យ៉ាងដូច្នោះដែរ, ម្នាលភិក្ខុទាំងឡាយ បណ្តាភិក្ខុនី ៥០០ នោះ ភិក្ខុនីដែលមានគុណធម៌ថ្នាក់ទាប គឺជាសោតាបន្នមានការមិនធ្លាក់ទៅ (កាន់អបាយ) ជាធម្មតា ជាអ្នកទៀងទាត់ មានមុខឆ្ពោះទៅរកការត្រាស់ដឹង" ដូច្នេះ ។



ក៏ក្នុងភិក្ខុនីទាំងនោះ ភិក្ខុនីណា មានឧបនិស្ស័យនៃសោតាបត្តិផល ភិក្ខុនីនោះ ជាអ្នកមានសេចក្តីត្រិះរិះពេញបរិបូណ៌ ដោយសោតាបត្តិផលហ្នឹងឯង, ភិក្ខុនីណា ជាអ្នកមានឧបនិស្ស័យនៃសកទាគាមិផល អនាគាមិផល ។ល។ ជាអ្នកមានឧបនិស្ស័យនៃអរហត្តផល ភិក្ខុនីនោះ ជាអ្នកមានសេចក្តីត្រិះរិះពេញបរិបូណ៌ ប្រៀបដោយអរហត្តផលហ្នឹងឯង ។

មគ្គដែលអ្នកបំពេញវិបស្សនា ធ្វើឈានណាមួយ ឲ្យជាបាទហើយ ឲ្យកើតឡើង តាមសមគួរ ដល់អធ្យាស្រ័យរៀងៗ ខ្លួន រមែងស្មើគ្នានឹងឈាននោះៗ តែថា ការដែលមគ្គ កើតឡើងស្មើគ្នានឹងឈាននោះៗ នោះ បើប្រាសចាកឈានដែលជាបាទ ឬ ឈានដែលពិចារណាហើយ នឹងសំរេចដោយហេតុត្រឹមតែអធ្យាស្រ័យរៀងៗ ខ្លួនប៉ុណ្ណោះ ក៏មិនបានដែរ ដូចបានពោលមកនេះឯង ។ ការកំណត់ (នូវកាផ្សេងគ្នានៃអង្គឈានជាដើម) នៃវិបស្សនា សូម្បីក្នុងថេរវាទទី៣ នេះ គប្បីជ្រាប តាមដែលបានពោលមកនេះ ដូចគ្នាដែរ ។

គប្បីជ្រាបថា : សង្ខារុបេក្ខា កំណត់នូវពោជ្ឈង្គ អង្គមគ្គ និង អង្គឈាន ដូចបានពោលមកនេះឯង ជាដំបូងសិន ។

ក៏ប្រសិនបើ សង្ខារុបេក្ខានេះ ដំបូង កាលគ្របសង្កត់ នូវកិលេសអាចគ្របសង្កត់បានដោយលំបាក ព្រមទាំងប្រយោគ គឺឧស្សាហៈ ព្រមទាំងសង្ខារ គឺសេចក្តីព្យាយាម នឹងបានឈ្មោះថា ទុក្ខាបដិបទា (គឺបដិបត្តិបានដោយលំបាក) ។ ដោយបរិយាយខុសផ្សេងពីគ្នា បានឈ្មោះថា សុខាបដិបទា (គឺបដិបត្តិបានដោយងាយ) ។ តែលុះគ្របសង្កត់នូវកិលេសបានហើយ សន្សឹមៗ ធ្វើការគ្របសង្កត់នូវវិបស្សនា (ធ្វើ) ឲ្យមគ្គកើតឡើង បានឈ្មោះថា ទន្ធាភិញ្ញា(គឺត្រាស់ដឹងបានដោយយឺតយូរ)

ដោយបរិយាយផ្សេងពីគ្នា ក៏ឈ្មោះថា ខិប្បាភិញ្ញា (គឺត្រាស់ដឹងបាន ដោយរហ័ស) ។ សង្ខារុបេក្ខានេះ តាំងនៅ ក្នុងអាគមនីយដ្ឋានហើយ ឲ្យឈ្មោះ ដល់មគ្គ របស់ខ្លួន ៗ ដូច្នេះឯង ។ ដោយឈ្មោះនោះ មគ្គ ទើបបានឈ្មោះ ៤ យ៉ាង ។

ក៏បដិបទានេះនោះ មានផ្សេងគ្នា ដល់ភិក្ខុអង្គខ្លះ, សំរាប់ភិក្ខុអង្គខ្លះ មានបដិបទាមួយប៉ុណ្ណោះ ក្នុងមគ្គទាំង ៤ ។ ចំណែកមគ្គទាំង ៤ របស់ ព្រះពុទ្ធទាំងឡាយ បានជាសុខាបដិបទា ខិប្បាភិញ្ញាហ្នឹងឯង ។ របស់ ព្រះធម្មសេនាបតី ក៏យ៉ាងនោះដែរ ។ តែសំរាប់ព្រះមហាមោគ្គល្លានត្ថេរ បឋមមគ្គ ជាសុខាបដិបទា ខិប្បាបដិបទា មគ្គបីខាងលើ ជាទុក្ខាបដិបទា ទន្ធាភិញ្ញា ។ ម្យ៉ាងទៀត បដិបទា យ៉ាងណាមិញ, សូម្បីអធិបតីទាំង ឡាយ ក៏មានផ្សេងៗគ្នា ក្នុងមគ្គទាំង ៤ ដល់ភិក្ខុអង្គខ្លះ, សំរាប់ភិក្ខុអង្គ ខ្លះមានអធិបតី តែមួយប៉ុណ្ណោះ ក៏យ៉ាងនោះដែរ ។ សង្ខារុបេក្ខា រមែង កំណត់នូវការផ្សេងគ្នានៃបដិបទា ដូចពោលមកនេះឯង ។

ចំណែកសង្ខារុបេក្ខា កំណត់នូវការផ្សេងគ្នា នៃវិមោក្ខ យ៉ាងណា, ពាក្យនោះ ខ្ញុំបានពោលហើយខាងដើម ក៏យ៉ាងនោះដែរ ។

ម្យ៉ាងទៀត ធម្មតាមគ្គ រមែងបានឈ្មោះ ដោយហេតុ ៥ យ៉ាង គឺ ដោយរស របស់ខ្លួនខ្លះ ដោយធម៌ដែលជាសត្រូវខ្លះ ដោយគុណរបស់ ខ្លួនខ្លះ ដោយអារម្មណ៍ខ្លះ ដោយអាគមន៍ខ្លះ ។

ក៏ប្រសិនបើសង្ខារុបេក្ខា ចេញ ព្រោះពិចារណាសង្ខារទាំងឡាយ ថាមិនទៀង មគ្គសមង្គីបុគ្គល រមែងរួចផុត ដោយអនិមិត្តវិមោក្ខ ។ បើ ចេញ ព្រោះពិចារណាថា ជាទុក្ខ រមែងរួចផុតដោយអប្បណិហិតវិមោក្ខ, បើចេញ ព្រោះពិចារណាថាជាអនត្តា រមែងរួចផុតដោយសុញ្ញតវិមោក្ខ។



នេះ ឈ្មោះថា ជានាម ដោយរស របស់ខ្លួន ។

ចំណែកមគ្គនោះ ឈ្មោះថា អនិមិត្តមគ្គ ក៏ព្រោះធ្វើនូវការបំបែក កងនៃសង្ខារទាំងឡាយហើយ លះនូវនិច្ចនិមិត្ត ធុវនិមិត្ត សស្សតនិមិត្ត ទាំងឡាយ ដោយអនិច្ចានុបស្សនា មកហើយ ។ មួយទៀត មគ្គនោះ ឈ្មោះថា អប្បណិហិតមគ្គ ព្រោះលះនូវសុខសញ្ញា ញុំាងបណិធិ គឺ សេចក្ដីប្រាថ្នាឲ្យក្រៀមស្ងួត ដោយទុក្ខានុបស្សនា មកហើយ ។ ឈ្មោះ ថា សុញ្ញតមគ្គ ក៏ព្រោះលះបង់នូវអត្តសញ្ញា សត្តសញ្ញា និង បុគ្គល-សញ្ញា ហើយឃើញថា សង្ខារទាំងឡាយ ជារបស់សោះសូន្យ ដោយ អនត្តានុបស្សនា។ នេះឈ្មោះថា ជានាម ដោយធម៌ដែលជាសឹកសត្រូវ។

ឯមគ្គនោះ ឈ្មោះថា សុញ្ញតមគ្គ ព្រោះស្ងាត់ចាកកិលេស មាន រាគៈ ជាដើម ។ ឈ្មោះថា អនិមិត្តមគ្គ ព្រោះមិនមាននិមិត្តទាំងឡាយ មានរូបនិមិត្តជាដើម ឬ និមិត្តទាំងឡាយ មានរាគនិមិត្តជាដើម ។ ឈ្មោះ ថា អប្បណិហិតមគ្គ ព្រោះមិនមាននៃបណិធិទាំងឡាយ មានរាគបណិធិ ជាដើម ។ នេះជាឈ្មោះ ដោយគុណរបស់ខ្លួននៃមគ្គនោះ ។

មគ្គនោះ ឈ្មោះថា សុញ្ញតមគ្គ និមិត្តមគ្គ អប្បណិហិតមគ្គ ព្រោះ ធ្វើនូវនិព្វាន ដែលជាធម៌សោះសូន្យ ជាធម៌គ្មាននិមិត្ត ជាធម៌មិនមាន បណិធិឲ្យជាអារម្មណ៍ក៏បាន ។ នេះជានាម ដោយអារម្មណ៍នៃមគ្គនោះ។

ចំណែកឯអាគមន៍(ដែនជាទីមក) មាន ២ យ៉ាងគឺៈ វិបស្សនាគមន៍ (ដែនជាទីមកគឺវិបស្សនា) និង មគ្គាគមន៍ (ដែនជាទីមកគឺមគ្គ) ។ ក្នុង អាគមន៍ទាំង២ យ៉ាងនោះ វិបស្សនាគមន៍ តែងបានក្នុងមគ្គ ។ មគ្គាគមន៍ តែងបាន ក្នុងផល ។ ព្រោះថា អនត្តានុបស្សនា ឈ្មោះថា សុញ្ញត-វិបស្សនា ។ មគ្គនៃសុញ្ញតវិបស្សនា ឈ្មោះថា សុញ្ញតមគ្គ ។ អនិច្ចា-

នុបស្សនា ឈ្មោះថាអនិមិត្តវិបស្សនា ។ មគ្គនៃអនិមិត្តវិបស្សនា ឈ្មោះថា អនិមិត្តមគ្គ ។ តែឈ្មោះនេះ មិនមានតាមផ្លូវព្រះអភិធម្មទេ មានតែតាមផ្លូវនៃព្រះសូត្រប៉ុណ្ណោះ ព្រោះក្នុងផ្លូវនៃព្រះសូត្រនោះ អាចារ្យទាំងឡាយពោលថា “គោត្រភូញាណ ធ្វើព្រះនិព្វានដែលជាធម៌មិនមាននិមិត្តឲ្យជាអារម្មណ៍ ជាញាណ មានឈ្មោះថា និមិត្តៈ ខ្លួនឯងតាំងនៅ ក្នុងអាគមនីយដ្ឋានហើយ ឲ្យឈ្មោះដល់មគ្គ” ដូច្នេះ។ ព្រោះហេតុនោះ មគ្គទើបបានឈ្មោះថា និមិត្តៈ ។

តែបើពោលដោយមគ្គាគមន៍ ផលត្រូវបានឈ្មោះថា អនិមិត្តៈ ក៏សមគួរដូចគ្នាដែរ ។ ទុក្ខាវិបស្សនា ឈ្មោះថា អប្បណិហិតវិបស្សនា ព្រោះញុំាងសេចក្តីប្រាថ្នា ក្នុងសង្ខារទាំងឡាយឲ្យក្រៀមស្ងួតមកហើយ។ មគ្គ របស់អប្បណិហិតវិបស្សនា ឈ្មោះថា អប្បណិហិតមគ្គ ។ ផលរបស់អប្បណិហិតមគ្គ ឈ្មោះថា អប្បណិហិតផល ។

វិបស្សនា ឲ្យឈ្មោះរបស់ខ្លួនដល់មគ្គ, មគ្គ ឲ្យឈ្មោះរបស់ខ្លួនដល់ផល ។ នេះជាឈ្មោះ ដោយអាគមន៍ ។

សង្ខារុបេក្ខានេះ កំណត់នូវសេចក្តីផ្សេងគ្នានៃវិមោក្ខ ដូចដែលបានពោលមកនេះឯង ។ សង្ខារុបេក្ខាញាណ ចប់ហើយ ។

## អនុលោមញាណ

(៤៥២) កាលបើព្រះយោគាវចរនោះ សេព អប់រំ ធ្វើនូវសង្ខារុ-បេក្ខាញាណនោះ អធិមោក្ខសទ្ធា តែងកើតមានកម្លាំងក្រៃលែង វីរិយៈគឺព្រះយោគាវចរនោះ ផ្គងល្អហើយ សតិ ក៏តាំងនៅស៊ប់ល្អហើយ ចិត្តក៏តាំងនៅដោយប្រពៃ សង្ខារុបេក្ខា ដ៏ខ្លាំងក្លា ក៏កើតឡើង ។ កាលបើព្រះយោគាវចរនោះ ពិចារណាថា “មគ្គនឹងកើតឡើងក្នុងពេលឥឡូវនេះ”



សង្ខារុបេក្ខា ពិចារណានូវសង្ខារទាំងឡាយថា “ជារបស់មិនទៀង” ឬថា “ជាទុក្ខ” ឬថា “ជាអនត្តា” ហើយចុះកាន់ភវង្គៈ ។ ក្នុងលំដាប់នៃភវង្គៈមនោទ្វារាវជ្ជនៈ ធ្វើសង្ខារទាំងឡាយ ឲ្យជាអារម្មណ៍ថា “ជារបស់មិនទៀង ឬថា ជាទុក្ខ ឬថា ជាអនត្តា” ដោយន័យដែលសង្ខារុបេក្ខា ធ្វើមកហើយហ្នឹងឯង ទើបកើតឡើង ។ បន្ទាប់មក ជវនចិត្ត ទី១ ត-ភ្ជាប់នូវសន្តតិ ដែលមិនមានចន្លោះ ក្នុងលំដាប់នៃកិរិយាចិត្តដែលធ្វើភវង្គៈ ឲ្យត្រឡប់ហើយ កើតឡើងនោះ ក៏ធ្វើសង្ខារទាំងឡាយ ឲ្យជាអារម្មណ៍យ៉ាងដូច្នោះដែរ ហើយកើតឡើង ដែលលោកហៅថា “បរិកម្ម” ។ ក្នុងលំដាប់នោះ ជវនចិត្តទី២ ធ្វើសង្ខារទាំងឡាយ ឲ្យជាអារម្មណ៍ យ៉ាងនោះដែរ ហើយកើតឡើង ដែលលោកហៅថា “ឧបចារៈ” ។ សូម្បីក្នុងលំដាប់នោះ ជវនចិត្តទី៣ ក៏ធ្វើសង្ខារទាំងឡាយ ឲ្យជាអារម្មណ៍ យ៉ាងដូច្នោះឯង ទើបកើតឡើង ដែលលោកហៅ “អនុលោម” ។ នេះ គឺជាឈ្មោះថា ផ្សេងគ្នានៃចិត្តទាំងនោះ ។ តែនឹងហៅចិត្តទាំង ៣ យ៉ាងនោះថា “អាសេវនៈ” ក្តី ថា “បរិកម្ម” ក្តី ថា “ឧបចារៈ” ក្តី ថា “អនុលោម” ក្តី ដោយមិនប្លែកគ្នា ក៏គួរ ។

សួរថា: អនុលោមដល់អ្វី? ។ ឆ្លើយថា: អនុលោមដល់ធម៌ទាំងឡាយទាំងចំណែកខាងដើម ទាំងចំណែកខាងចុង។ ព្រោះថា អនុលោមញាណនោះ ឈ្មោះថាអនុលោមដល់វិបស្សនាញាណ៨ ខាងដើម ព្រោះមានកិច្ចយ៉ាងដូច្នោះ នឹងឈ្មោះថា អនុលោមដល់ពោធិបក្ខិយធម៌ ៣៧ ពួដ៏ខាងចុងផង ។ មែនពិត អនុលោមញាណនោះ ព្រោះប្រារព្ធនូវសង្ខារទាំងឡាយ ដោយអំណាចនៃត្រៃលក្ខណ៍ មានអនិច្ចលក្ខណៈ ជាដើម ហើយប្រព្រឹត្តទៅ ទើបឈ្មោះថា អនុលោមដល់ញាណ ៨ នេះ

ព្រោះមានកិច្ចដូចញាណ៨ នោះ ប្រៀបដូចចន្លុលប្រាប់ ដោយសេចក្តីថា “ឧទយព្វយញ្ញាណ បានឃើញការកើត និង ការសូន្យទៅ នៃធម៌ទាំងឡាយ ដែលមានការកើត និងការអស់ទៅហ្នឹងឯងហើយតើហ្ន៎” និង ថា “ភង្គានុបស្សនាញាណ បានឃើញនូវការបែកធ្លាយ នៃធម៌ទាំងឡាយដែលមានការបែកធ្លាយហ្នឹងឯងហើយតើហ្ន៎!” និង ថា “របស់ដែលមានភ័យ បានប្រាកដឡើងថា ជាភ័យ ដល់ភយតុប្បដ្ឋានញ្ញាណ មែនពិតហើយហ្ន៎” និង ថា “អាទីនវានុបស្សនាញាណ បានឃើញនូវទោស ក្នុងរបស់ដែលមានទោស មែនពិតហើយហ្ន៎” និង ថា “និព្វិទាញាណ បាននឿយណាយ ក្នុងរបស់ដែលគួរឲ្យនឿយណាយមែនពិតហើយហ្ន៎” និង ថា “មុញ្ចិតុកម្យតាញាណ កើតមានសេចក្តីប្រាថ្នានឹងលះបង់ ក្នុងរបស់ដែលគួលះបង់ មែនពិតហើយតើហ្ន៎” និង ថា “របស់ដែលគួរពិចារណា គឺបដិសង្ខាញាណ បានពិចារណាហើយមែនពិត” និង ថា “របស់ដែលគួរចូលទៅពិនិត្យមើល ត្រូវសង្ខារុបេក្ខាញាណ ពិនិត្យហើយមែនពិត” ដូច្នេះ និង ឈ្មោះថា អនុលោមដល់ពោធិបក្ខិយធម៌ទាំងឡាយ ៣៧ ពួដ៏ខាងចុងផង ព្រោះពោធិបក្ខិយធម៌ទាំងនោះ ជាធម៌ដែលគួរបានសំរេចដោយការប្រតិបត្តិនោះ ។

(សេចក្តីឧបមានៃអនុលោមញាណ)

មានឧបមាដូចជាព្រះរាជាដែលទ្រង់ធម៌ ប្រថាប់លើទីវិនិច្ឆ័យ ទ្រង់ស្តាប់នូវសេចក្តីវិនិច្ឆ័យ នៃវោហារិកមហាមាត្យទាំង ៨ ហើយទ្រង់លះបង់នូវអគតិ ទ្រង់តាំងព្រះទ័យជាកណ្តាល កាលទ្រង់អនុមោទនា ថា “ចូរដូចជាការវិនិច្ឆ័យនោះទៅចុះ” ទើបឈ្មោះថា ទ្រង់អនុលោមដល់ការវិនិច្ឆ័យ របស់វោហារិកមហាមាត្យទាំង ៨ នោះផង ដល់រាជធម៌ មកពីបូរាណផង យ៉ាងណាមិញ, សេចក្តីឧបមេយ្យនេះ បណ្ឌិតគប្បីជ្រាបយ៉ាងនោះដែរ ។



(សេចក្តីប្រៀបធៀប)

ក៏អនុលោមញាណ ប្រៀបដូចព្រះរាជា ។ ញាណ ៨ ប្រៀបដូចជាវោហារិកមហាមាត្យទាំង ៨ ។ ពោធិបក្ខិយធម៌ ៣៧ ប្រៀបដូចជាបូរាណរាជធម៌ ។ ក្នុងសេចក្តីឧបមានោះ ព្រះរាជា កាលទ្រង់ត្រាស់ថា “ចូរដូចជាការវិនិច្ឆ័យនោះទៅចុះ” ទើបឈ្មោះថា ទ្រង់អនុលោមដល់សេចក្តីវិនិច្ឆ័យ នៃវោហារិកមហាមាត្យទាំងឡាយផង ដល់រាជធម៌ផង យ៉ាងណាមិញ, អនុលោមញាណនេះ កាលប្រារព្ធនូវសង្ខារទាំងឡាយដោយអំណាចត្រៃលក្ខណ៍មានអនិច្ចលក្ខណៈជាដើមកើតឡើង ក៏ឈ្មោះថា អនុលោមដល់ញាណទាំង ៨ ព្រោះមានកិច្ចដូចគ្នានឹងញាណ ៨ នោះផង ដល់ពោធិបក្ខិយធម៌ទាំង ៣៧ ប្រការ ខាងចុងផង ក៏យ៉ាងដូច្នោះដែរ ។ ព្រោះហេតុដូច្នេះឯង ញាណនេះ ទើបលោកហៅថា “សច្ចានុលោមញាណ” យ៉ាងដូច្នេះ ។

អនុលោមញាណ ចប់ហើយ ។

(៤៥៣) ក៏អនុលោមញាណនេះ ជាញាណចុងបញ្ចប់នៃវុដ្ឋានគាមិនីវិបស្សនា ដែលមានសង្ខារជាអារម្មណ៍ ។ តែគោត្រភូញាណ ជាញាណចុងបញ្ចប់ នៃវុដ្ឋានគាមិនីវិបស្សនា ដោយប្រការទាំងពួង ។

(ឈ្មោះផ្សេងៗ នៃអនុលោមញាណ)

ឥឡូវនេះ ដើម្បីកុំឲ្យយល់ច្រឡំ ក្នុងវុដ្ឋានគាមិនីវិបស្សនានោះឯង គប្បីជ្រាបសេចក្តីប្រៀបធៀប ក្នុងព្រះសូត្រដូចតទៅនេះ ។

*សេចក្តីនេះ តើយ៉ាងដូចម្តេច? ។ គឺ វុដ្ឋានគាមិនីវិបស្សនា ក្នុងសឡាយតនវិភង្គសូត្រ [១] ព្រះមានព្រះភាគត្រាស់ហៅថា "អតម្មយតា (តណ្ហា)" ដោយសូត្រនេះថា "ម្នាលភិក្ខុទាំងឡាយ! អ្នកទាំងឡាយ ចូរអាស្រ័យនឹងតណ្ហា ពឹងផ្អែកនឹងតណ្ហា ហើយលះបង់ កន្លងឲ្យផុតនូវឧបេក្ខាជាមួយគ្នា មានអារម្មណ៍ជាមួយគ្នាចេញ"ដូច្នេះ, ក្នុងអលគទ្ទូបមសូត្រ [២] ត្រាស់ហៅថា "និព្វិទា" ដោយសូត្រនេះថា "កាលបើនឿយណាយហើយ ក៏លែងត្រេកអរ កាលបើលែងត្រេកអរហើយ ចិត្ត ក៏ផុតស្រឡះ"ដូច្នេះ, ក្នុងសុសិមសូត្រ [៣] ត្រាស់ថា "ធម្មដ្ឋិតិញាណ" ដោយព្រះសូត្រនេះថា "ម្នាលសុសិម! ធម្មដ្ឋិតិញាណគឺវិបស្សនាញាណ តែងកើតឡើងមុន ការដឹងក្នុងព្រះនិព្វាន គឺមគ្គញ្ញាណតែងកើតឡើងក្រោយ" ដូច្នេះ, ក្នុងបោដ្ឋបាទសូត្រ (៤) ទ្រង់ត្រាស់ថា "សញ្ញគ្គៈ (គឺសញ្ញា ជាកំពូល)" ដោយព្រះសូត្រនេះថា "ម្នាលបោដ្ឋបាទ! សញ្ញា កើតមុន, ញាណកើតក្រោយ" ដូច្នេះ, ក្នុងទសុត្តរសូត្រ (៥) ត្រាស់ថា "បារិសុទ្ធិប្បធានិយង្គៈ (គឺអង្គនៃសេចក្តីព្យាយាម ដើម្បីសេចក្តីបរិសុទ្ធិ)" ដោយព្រះសូត្រនេះថា "បដិទាញាណទស្សនវិសុទ្ធិ ជាអង្គនៃសេចក្តីព្យាយាម ដើម្បីសេចក្តីបរិសុទ្ធិ" ដូច្នេះ, ក្នុងបដិសម្ភិទាមគ្គ (៦) ទ្រង់ត្រាស់ហៅដោយឈ្មោះ ៣ ដោយព្រះសូត្រនេះថា "មុញ្ចិតុកម្យតាញាណ ឯណាក្តី បដិសង្ខានុបស្សនាញាណណាក្តី សង្ខារុបេក្ខាញាណណាក្តី ធម៌ទាំងនេះ*

---

*១- សុ. ភាគទី ២៨ ទំព័រទី ១១១ ។ ២- សុ. ភាគទី ២១ ទំព័រទី ៥៨ ។
៣- សុ. ភាគទី ៣១ ទំព័រទី ២៧៥ ។ ៤- សុ. ភាគទី ១៥ ទំព័រទី ១២៣ ។
៥- សុ. ភាគទី ១៩ ទំព័រទី ៣៣០ ។ ៦- សុ. ភាគទី ៧០ ទំព័រទី ៣៦០ ។*



*មានសេចក្តីជាមួយគ្នា តែព្យញ្ជនៈផ្សេងគ្នា" ដូច្នេះ, ក្នុងបដ្ឋាន [១] ទ្រង់ត្រាស់ហៅ ដោយឈ្មោះ ៣ ដោយព្រះសូត្រនេះថា "ញាណដែលអនុលោមដល់គោត្រភូ ញាណដែលអនុលោមដល់វោទានៈ" ដូច្នេះ, ក្នុងរថវិនីតិសូត្រ [២] ត្រាស់ហៅ "បដិបទាញាណទស្សនវិសុទ្ធិ" ដោយព្រះសូត្រនេះ ថា "ម្នាលអាវុសោ ! ចុះលោកដ៏មានអាយុ ប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់នៃព្រះដ៏មានព្រះភាគ ដើម្បីសេចក្តីបរិសុទ្ធិនៃបដិបទាញាណទស្សនៈ ឬ" ដូច្នេះ ។*

វុដ្ឋានគាមិនីវិបស្សនាឯណា ស្ងប់រម្ងាប់ល្អ បរិសុទ្ធិស្អាត ដែលព្រះមានព្រះភាគ ទ្រង់ស្វែងរកគុណដ៏ធំ ទ្រង់បានសរសើរហើយ ដោយឈ្មោះច្រើនជាអនេក ដូចបានពោលមកហើយនេះឯង, បុគ្គលអ្នកមានជាតិជាបណ្ឌិត អ្នកមានប្រាជ្ញា នឹងចេញអំពីភក់ គឺសង្សារ-ទុក្ខ ដែលមានភ័យដ៏ធំ គប្បីធ្វើសេចក្តីព្យាយាម ក្នុងវុដ្ឋានគាមិនីវិបស្សនានោះ ឲ្យបានរឿយៗ ចុះ ។

*បរិច្ឆេទ ទី២១ ឈ្មោះ បដិបទាញាណទស្សនវិសុទ្ធិ ក្នុងអធិការ
នៃបញ្ញាភាវនា ក្នុងគម្ពីរវិសុទ្ធិមគ្គ ដែលខ្ញុំរៀបរៀងហើយ
ដើម្បីប្រយោជន៍ដល់សេចក្តីរីករាយនៃសាធុជន
ចប់បរិបូណ៌ ដោយប្រការដូច្នេះ ។*

❀ ❀

---

*១- អភិ. ប. ។ ២- សុ. ម. មូ. ភាគទី ២១ ទំព័រទី ៨៨ ។*

## ញាណទស្សនវិសុទ្ធិនិទ្ទេស

(៤៥៤) បន្ទាប់ពីអនុលោមញាណនេះទៅ គឺជាគោត្រភូញាណ ។ គោត្រភូញាណនោះ មិនគប់រកនូវបដិបទាញាណទស្សនវិសុទ្ធិ មិនគប់រកញាណទស្សនវិសុទ្ធិឡើយ ព្រោះជាញាណដែលតាំងនៅក្នុងឋានៈ ជាអាវជ្ជនៈនៃមគ្គ ជាអព្វោហារិកៈ ក្នុងចន្លោះនោះឯង តែព្រោះធ្លាក់នៅក្នុងក្រសែនៃវិបស្សនា ទើបរាប់ថាជា "វិបស្សនា" ។ ឯខាងញាណក្នុងមគ្គទាំង៤ នេះ គឺ សោតាបត្តិមគ្គ សកទាគាមិមគ្គ អនាគាមិមគ្គ អរហត្តមគ្គ ឈ្មោះថា ញាណទស្សនវិសុទ្ធិ ។

### (បឋមមគ្គញាណ)

ក្នុងមគ្គញាណ ៤ នោះ ឈ្មោះថា កិច្ចអ្វីៗ ដទៃទៀត ដែលព្រះយោគាវចរ អ្នកប្រាថ្នានឹងញ៉ាំងបឋមមគ្គញាណឲ្យដល់ព្រម គប្បីធ្វើ ជាដំបូង មិនមានទេ។ ព្រោះថា កិច្ចណា ដែលព្រះយោគាវចរនេះ គប្បីធ្វើ កិច្ចនោះ គឺព្រះយោគាវចរអ្នកញ៉ាំងវិបស្សនាដែលមានអនុលោមញាណជាទីបំផុតឲ្យកើតឡើង បានធ្វើហើយ ។ មែនពិត ចិត្តរបស់ព្រះយោគាវចរ អ្នកមានអុលោមញាណ កើតឡើងហើយយ៉ាងនេះ កាលបើសេចក្តីងងឹតដ៏គ្រោតគ្រាត ដែលបិទបាំងនូវសច្ចៈ ត្រូវអនុលោមញាណទាំង ៣ នោះ ធ្វើឲ្យវិនាសហើយ តាមសមគួរដល់កម្លាំងរបស់ខ្លួនៗ រមែងមិនស្ទុះទៅ មិនតាំងនៅ មិនបង្អោនទៅ មិនជាប់ មិនជំពាក់ មិនពាក់ព័ន្ធក្នុងសង្ខារទាំងពួង រមែងរួញថយ រមែងរួញខ្លួន រមែងត្រឡប់ ដូចជាទឹករមៀលធ្លាក់ចេញពីស្លឹកឈូកដូច្នោះឯង ។ និមិត្តារម្មណ៍ទាំងពួងក្តី បវត្តារម្មណ៍ទាំងពួងក្តី រមែងប្រាកដថា ជាគ្រឿងកន្លល់ ។

### (គោត្រភូញាណ)



លំដាប់នោះ កាលបើនិមិត្តារម្មណ៍ និងបវត្តារម្មណ៍ទាំងពួងប្រាកដឡើងហើយថា ជាបលិពោធ ដល់ព្រះយោគាវចរនោះ, ក្នុងទីបំផុត នៃអាសេវនៈ នៃអនុលោមញាណ គោត្រភូញាណ ធ្វើព្រះនិព្វានដែលមិនមាននិមិត្ត មិនមានការប្រព្រឹត្តិ ប្រាសចាកសង្ខារ ជាទីរំលត់ ឲ្យជាអារម្មណ៍ កន្លងនូវគោត្រនៃបុថុជ្ជន ឈ្មោះនៃបុថុជ្ជន ភូមិនៃបុថុជ្ជន ចុះទៅកាន់គោត្រនៃអរិយ ឈ្មោះនៃអរិយៈ ភូមិនៃអរិយៈ ជាការពិចារណាជាដំបូង ជាការថ្លឹងថ្លែងជាដំបូង និង ជាការប្រមូលរួបរួមជាដំបូង ក្នុងនិព្វិទារម្មណ៍ ញ៉ាំងភាពជាបច្ច័យនៃមគ្គ ដោយអាការៈ៦ ដោយអំណាចនៃអនន្តរបច្ច័យ, សមនន្តរបច្ច័យ, អាសេវនបច្ច័យ, ឧបនិស្សយបច្ច័យ, អត្ថិបច្ច័យ និង វិគតបច្ច័យ ឲ្យបានសំរេច ជាញាណដល់កំពូល ជាប្រធាននៃវិបស្សនា មិនត្រឡប់មកវិញទៀត រមែងកើតឡើង ដែលលោកពោលសំដៅយកហើយ (ក្នុងបដិសម្ភិទាមគ្គ)ថា "បញ្ញា ក្នុងការចេញ និងការវិលត្រឡប់ចាកសង្ខារនិមិត្តខាងក្រៅ ឈ្មោះថា គោត្រភូញាណ តើដូចម្តេច? [១] ។ ញាណគ្របសង្កត់នូវការកើតឡើង ហេតុនោះ ឈ្មោះថា គោត្រភូ, ញាណ គ្របសង្កត់នូវការប្រព្រឹត្តិ ហេតុនោះ ឈ្មោះថា គោត្រភូ ។ល។ ញាណ គ្របសង្កត់នូវសេចក្តីចង្អៀតចង្អល់ចិត្ត ហេតុនោះ ឈ្មោះថា គោត្រភូ, ញាណ គ្របសង្កត់នូវសង្ខារនិមិត្តខាងក្រៅ ហេតុនោះ ឈ្មោះថា គោត្រភូ, ញាណ ស្ទុះទៅកាន់ការមិនផ្តើមកើតឡើង ហេតុនោះ ឈ្មោះថា គោត្រភូ, ញាណ ស្ទុះទៅកាន់ការមិនប្រព្រឹត្តិ ។ល។ កាន់ការមិនចង្អៀតចង្អល់ចិត្ត... កាន់ព្រះនិព្វានជាទីរំលត់ ហេតុនោះ ឈ្មោះថា គោត្រភូ, ញាណ គ្របសង្កត់នូវការ

១- សុ ខុ. បដិ. ភាគទី ៦៩ ទំព័រទី ១៨៧-១៨៨ ។

កើតឡើង ហើយស្ទុះទៅកាន់ការមិនកើតឡើង ហេតុនោះ ឈ្មោះថា គោត្រភូ" ដូច្នេះជាដើម ។ ព្រះសូត្រទាំងពួង គប្បី (នាំមកពណ៌នា) ឲ្យបានពិស្តារផងចុះ ។

(សេចក្តីឧបមានៃអនុលោមញាណ និង គោត្រភូញាណ)

ក្នុងការធ្វើកិច្ចនៃអនុលោមញាណ និង គោត្រភូញាណនោះ, នេះជាសេចក្តីឧបមាដែលសំដែងនូវអាការៈនៃការប្រព្រឹត្តិទៅ ក្នុងអារម្មណ៍ផ្សេងៗ នៃអនុលោមញាណ និងគោត្រភូញាណ សូម្បីកំពុងប្រព្រឹត្តទៅក្នុងវិថី(ចិត្ត) ជាមួយគ្នា ដោយអាវជ្ជនៈជាមួយគ្នា ។ ប្រៀបដូចជាបុរសអ្នកប្រាថ្នានឹងលោតផ្លោះនូវប្រឡាយដ៏ធំហើយ ឈរនៅត្រើយខាងនាយ រត់ទៅយ៉ាងលឿន ចាប់ខ្សែដែលចងព្យួរលើមែកឈើ ឬ ឈើបង្គោលត្រង់ត្រើយខាងអាយនៃប្រឡាយ លោតផ្លោះឡើងហើយ មានរាងកាយបង្អោន ជ្រេ រេ ឆ្ពោះទៅកាន់ត្រើយខាងនាយ រហូតដល់ចំណែកខាងលើនៃត្រើយខាងនាយ ហើយក៏លែងនូវខ្សែ និង បង្គោលឈើនោះចេញ ញ័រខ្លួនចំប្រេក់ ធ្លាក់ដល់ត្រើយខាងនាយហើយ ទើបសន្សឹមៗ ក្រោកឈរឡើង យ៉ាងណាមិញ, ឯព្រះយោគាវចរនេះ ក៏យ៉ាងដូច្នោះដែរ ជាអ្នកប្រាថ្នានឹងស្ថិតនៅស៊ប់ ក្នុងព្រះនិព្វានដែលជាត្រើយខាងនាយនៃភព, កំណើត, គតិ, ឋិតិ និង និវាសៈទាំងឡាយ ស្ទុះទៅយ៉ាងលឿន ដោយកម្លាំងមានឧទយព្វយានុបស្សនាញាណជាដើម ចាប់យកនូវខ្សែពោលគឺរូប ដែលចងព្យួរជាប់នឹងមែកឈើ ពោលគឺអត្តភាព ឬ ឈើពោលគឺនាមក្ខន្ធ មានវេទនាជាដើមណាមួយ ដោយអាវជ្ជនៈនៃអនុលោមញាណថា "វាជារបស់មិនទៀង ឬថា ជាទុក្ខ ឬថា ជាអនត្តា" ដូច្នេះហើយ មិនទាន់លែងនូវខ្សែ គឺរូប និង ឈើគឺនាមនោះចោលទេ លោតឡើងដោយ



អនុលោមចិត្តទី១ ជាអ្នកមានចិត្តបង្អោនទៅ ជ្រេរេឆ្ពោះទៅរកព្រះនិព្វាន ដោយអនុលោមចិត្តទី២ ដូចជាបុរសអ្នកមានកាយបង្អោន ជ្រេរេឆ្ពោះទៅត្រើយខាងនាយយ៉ាងនោះឯង ហើយជាអ្នកនៅក្បែរនឹងព្រះនិព្វាន ដែលខ្លួនគប្បីដល់ក្នុងពេលឥឡូវនេះ ដោយអនុលោមចិត្តទី៣ ដូចបុរសដែលដល់នូវចំណែកខាងលើនៃត្រើយខាងនាយដូច្នេះឯង ព្រោះការរលត់ទៅនៃចិត្តនោះ ទើបលះបង់នូវអារម្មណ៍ដែលជាសង្ខារនោះ ហើយធ្លាក់ទៅក្នុងព្រះនិព្វានដែលប្រាសចាកសង្ខារ ជាត្រើយខាងនាយ ដោយគោត្រភូចិត្ត តែព្រោះមិនបានអាសេវនៈ ក្នុងអារម្មណ៍មួយ ទើបមិនបានតាំងនៅស៊ប់ល្អ ដូចជាបុរសនោះដែល(មានខ្លួន) ញ័ររន្ធត់ដូច្នេះ បន្ទាប់អំពីនោះមក ទើបតាំងនៅមាំ ដោយមគ្គញ្ញាណ យ៉ាងដូច្នេះឯង ។

(ឧបមាការធ្វើកិច្ចនៃអនុលោមញាណ និង គោត្រភូញាណ)

ក្នុងញាណទាំង២ យ៉ាងនោះ អនុលោមញាណ អាចបន្ទោបង់នូវសេចក្តីងងឹត គឺកិលេសដែលបិទបាំងនូវសច្ចៈបាន តែមិនអាចធ្វើព្រះនិព្វាន ឲ្យជាអារម្មណ៍បានឡើយ ។ គោត្រភូញាណ អាចធ្វើព្រះនិព្វានឲ្យជាអារម្មណ៍បាន ដោយពិត (តែ) មិនអាចបន្ទោបង់នូវសេចក្តីងងឹតដែលបិទបាំងនូវសច្ចៈបានទេ ។ នេះ គឺជាសេចក្តីឧបមា ក្នុងការធ្វើកិច្ចនៃញាណទាំង ២ នោះ ។

បានឮថា បុរសមានចក្ខុភ្លឺម្នាក់គិតថា "អញនឹងដឹងនូវការប្រកបនៃនក្ខត្តឫក្ស" ហើយក៏ចេញទៅអើតមើលព្រះច័ន្ទ ក្នុងពេលរាត្រី ។ ព្រះច័ន្ទ មិនប្រាកដ ដល់បុគ្គលនោះឡើយ ព្រោះត្រូវពពកបិទបាំង ។ គ្រានោះ ខ្យល់មួយ បានកើតឡើង កំចាត់ពពកក្រាស់ៗចេញទៅ ។ ខ្យល់មួយទៀត កំចាត់ពពកយ៉ាងកណ្តាល ។ ខ្យល់ម្យ៉ាងទៀត កំចាត់ពពក

ដែលស្តើងៗ ចេញ ។ បន្ទាប់មក បុរសនោះ កាលបើផ្ទៃមេឃស្រឡះប្រាសចាកពពកអស់ហើយ ទើបឃើញព្រះច័ន្ទ ហើយដឹងនូវការប្រកបនៃនក្ខត្តឫក្ស ។

ក្នុងពាក្យឧបមា និង ពាក្យឧបមេយ្យនោះ សេចក្តីងងឹតគឺកិលេសយ៉ាងក្រាស់ យ៉ាងកណ្តាល និង យ៉ាងស្តើង ដែលបិទបាំងនូវសច្ចៈ ដូចជាពលាហកៈ៣ ជាន់ ។ អនុលោមចិត្ត ៣ ដូចជាខ្យល់កំចាត់ពពក ៣ យ៉ាង ។ គោត្រភូញាណ ដូចជាបុរសមានចក្ខុ ។ ព្រះនិព្វាន ដូចជាព្រះច័ន្ទ ។ ការបន្ទោបង់នូវងងឹត ដែលបិទបាំងនូវសច្ចៈនៃអនុលោមចិត្តនិមួយៗ ដូចជាការកំចាត់បង់នូវពពក ៣ ជាន់ ដោយលំដាប់ នៃខ្យល់មួយៗ ។ ការដែល- កាលបើងងឹតដែលបិទបាំងនូវសច្ចៈ ទៅប្រាសហើយ ឃើញនូវព្រះនិព្វាន ដ៏ស្អាតបរិសុទ្ធ នៃគោត្រភូញាណ ដូចជាការដែលបុរសនោះ កាលបើផ្ទៃមេឃប្រាសចាកពពកហើយ ឃើញព្រះច័ន្ទដ៏ស្អាតល្អ ។ មែនពិតហើយ ខ្យល់៣ មេ អាចកំចាត់តែពពកដែលបិទបាំងព្រះច័ន្ទប៉ុណ្ណោះ មិនអាចឃើញព្រះច័ន្ទបានទេ យ៉ាងណាមិញ, អនុលោមញាណទាំងឡាយ អាចកំចាត់បង់តែងងឹត ដែលបិទបាំងនូវសច្ចៈប៉ុណ្ណោះទេ មិនអាចឃើញព្រះនិព្វានបានឡើយ ក៏យ៉ាងនោះដែរ ។ បុរសនោះ អាចមើលឃើញតែព្រះច័ន្ទប៉ុណ្ណោះឯង (តែ) មិនអាចកំចាត់បង់នូវពពកបានទេ យ៉ាងណាមិញ, គោត្រភូញាណ អាចឃើញតែព្រះនិព្វានប៉ុណ្ណោះ មិនអាចលះបង់នូវងងឹតគឺកិលេសបានឡើយ ។ ក៏ព្រោះហេតុនោះឯង គោត្រភូញាណនោះ លោកហៅថា អាវជ្ជនៈ នៃមគ្គ ។

មែនពិត គោត្រភូញាណនោះ សូម្បីមិនមែនជាអាវជ្ជនៈ ក៏តាំងនៅក្នុងឋានៈនៃអាវជ្ជនៈ ដូចជាឲ្យសញ្ញាដល់មគ្គថា "ចូរអ្នកកើតយ៉ាងនេះ"



ហើយក៏រលត់ទៅ ។ ចំណែកមគ្គ ក៏មិនលះបង់នូវសញ្ញា ដែលគោត្រភូញាណនោះឲ្យហើយឡើយ ទៅតាមជាប់នឹងញាណនោះ ដោយអំណាចនៃសន្តតិ ដែលមិនដាច់រយៈ ចោះបំផ្លាញនូវគំនរលោភៈ គំនរទោសៈ គំនរមោហៈ ដែលមិនធ្លាប់បានចោះ មិនធ្លាប់បានទំលាយសោះ ទើបកើតឡើង ។ នេះជាឧបមា ក្នុងរឿងនោះ ។

បានឮមកថា: មានខ្មាន់ធ្នូម្នាក់ តម្រួតក្តារមួយរយជាន់ ក្នុងទីប្រមាណប៉ុន៨ គោឧសភៈ យកសំពត់រុំមុខ កាន់ព្រួញឈរនៅលើយន្តចក្រ ។ បុរសម្នាក់ទៀត បង្វិលចក្រយន្តហើយ ឲ្យសញ្ញា ដោយដម្បងក្នុងយន្តចក្រនោះ ក្នុងពេលដែលក្តារមានមុខឆ្ពោះ ទៅរកនាយខ្មាន់ធ្នូ ។ នាយខ្មាន់ធ្នូនោះ មិនលែងនូវសញ្ញា ដោយដម្បងឡើយ ហើយបាញ់ព្រួញទៅមុខក្តារទាំងមួយរយជាន់ ។ ក្នុងពាក្យឧបមា និងឧបមេយ្យនោះ គោត្រភូញាណ ដូចជាសេចក្តីសំគាល់ ដោយចុងដម្បង ។ មគ្គញាណ ដូចជានាយខ្មាន់ធ្នូ ។ កាលដែលមគ្គញាណ មិនលែងនូវសញ្ញា ដែលគោត្រភូញាណឲ្យហើយហ្នឹងឯង ហើយធ្វើព្រះនិព្វាន ឲ្យជាអារម្មណ៍ហើយចោះ និង ទំលាយនូវគំនរនៃលោភៈ ទោសៈ មោហៈ ដែលមិនធ្លាប់បានចោះ មិនធ្លាប់បានទំលាយ ដូចជានាយខ្មាន់ធ្នូមិនលែងនូវសញ្ញាដោយចុងដម្បង ហើយបាញ់ទំលាយនូវក្តារទាំងមួយរយជាន់ហ្នឹងឯង ។

(អានិសង្សផ្សេងៗ នៃមគ្គ)

ក៏មគ្គនុ៎ះ មិនមែនធ្វើតែការទំលាយនូវគំនរនៃកិលេស មានលោភៈជាដើមតែម្យ៉ាងប៉ុណ្ណោះទេ ។ គឺញាំងសមុទ្រគឺទុក្ខ ក្នុងសង្សារវដ្តដែលមានទីបំផុតគឺបុគ្គលមិនដឹងហើយ ឲ្យក្រៀមស្ងួតបានផង បិទទ្វារអបាយទាំងពួងបានផង ធ្វើអរិយទ្រព្យទាំង៧ ឲ្យកើតព្រមផង លះបង់មិច្ឆាមគ្គ

ដែលមានអង្គ ៨ បានផង រម្ងាប់ពៀរ និង ភ័យទាំងពួង ឲ្យស្ងប់បានផង ប្រគល់ខ្លួនជាបុត្រឱរសដល់ព្រះសម្មាសម្ពុទ្ធជាម្ចាស់បានផង និងប្រព្រឹត្តទៅដើម្បីទទួលនូវអានិសង្សផ្សេងៗ ទៀត ជាច្រើនរយបានផង ដោយប្រការដូច្នេះឯង ។

ញាណ ដ៏ប្រកបដោយសោតាបត្តិមគ្គ ដែលផ្តល់ឲ្យនូវអានិសង្សច្រើនជាអនេកដូចពោលមកនេះ គឺជាញាណក្នុងសោតាបត្តិមគ្គហ្នឹងឯង។

បឋមញ្ញាណ ចប់ហើយ

(ទុតិយញ្ញាណ)

(៤៥៥) ក៏ក្នុងលំដាប់នៃញាណនេះ ផលចិត្ត២ ឬ ៣ ដួង ដែលជាវិបាក នៃសោតាបត្តិមគ្គចិត្តនុ៎ះឯង រមែងកើតឡើង ។ ក៏ព្រោះភាវៈ នៃលោកុត្តរកុសលទាំងឡាយមានវិបាក ក្នុងលំដាប់នុ៎ះឯង ព្រះមានព្រះភាគ ទើបត្រាស់ថាៈ "សមាធិមានន្តរិកញ្ញមាហុ [១] បណ្ឌិតទាំងឡាយហៅ សមាធិ ឯណា ថាៈ អានន្តរិកៈ គឺឲ្យផលក្នុងលំដាប់នៃខ្លួន" ដូច្នេះ និងថា "បុគ្គលនោះរមែងសម្រេចអានន្តរិយគុណ [២] ដើម្បីអស់អាសវៈទាំងឡាយ ឃើតយូរ" ដូច្នេះជាដើម ។

ចំណែកអាចារ្យពួកខ្លះ ពោលថា "ផលចិត្ត ១, ២, ៣, ឬ ៤ ដួង រមែងកើតឡើង" ។ ពាក្យនោះមិនគួរប្រកាន់យកទេ ។ ព្រោះថា គោត្រភូញាណ រមែងកើតឡើងក្នុងលំដាប់ អំពីអាសេវនៈនៃអនុលោមញាណ ហេតុនោះ អនុលោមចិត្ត ត្រូវមាន២ ដួង ដោយកំណត់យកទាបបំផុត ។ ព្រោះអនុលោមចិត្ត១ នឹងមិនបាននូវអាសេវនបច្ច័យទេ និងអាវជ្ជនវិថី១ មានចិត្ត៧ ដួង យ៉ាងក្រៃលែង ព្រោះដូច្នោះ ញាណណា មានអនុលោម

១- សុ. ខុ. ខុ. ។ ២- សុ. អំ. ច. ភាគទី ៤៣ ទំព័រទី ២០-២១ ។



ចិត្ត ២ ដួង, ចិត្ត ទី៣ នៃញាណនោះ ជាគោត្រភូញាណ, ចិត្ត ទី៤ ជាមគ្គចិត្ត ចិត្ត៣ ដួង ជាផលចិត្ត, ញាណណា មានអនុលោមចិត្ត ៣, ចិត្តទី៤ នៃញាណនោះ ជាគោត្រភូញាណ ទី៥ ជាមគ្គចិត្ត, ចិត្ត ២ ដួង ជាផលចិត្ត ។ ព្រោះហេតុនោះ ទើបខ្ញុំពោលថា "ផលចិត្ត ២ ឬ ៣ តែងកើតឡើង" ។ ចំណែកខាងអាចារ្យពួកខ្លះ ពោលថាៈ ញាណឯណា មានអនុលោមចិត្ត ៤ ដួង ចិត្តទី៥ នៃញាណនោះ ជាគោត្រភូញាណ ចិត្តទី៦ ជាមគ្គចិត្ត ចិត្តប១ ដួង ជាផលចិត្ត" ។ ក៏ពាក្យនោះមិនត្រូវជឿថា ជាសារប្រយោជន៍ទេ ព្រោះបដិសេធបានថា "ចិត្ត ទី៤ ឬ ទី៥ ជាអប្បនា មិនខ្ពស់ជាងនោះទេ ព្រោះនៅជិតភវង្គ" ។

ក៏ដោយការកើតឡើងនៃផល ក្នុងលំដាប់បឋមមគ្គ មានប្រមាណប៉ុណ្ណេះ ព្រះយោគាវចរនុ៎ះ បានជាព្រះអរិយបុគ្គលទី២ ឈ្មោះថា ព្រះសោតាបន្ន ។ ព្រះសោតាបន្ននោះ សូម្បីនៅមានការប្រមាទជាច្រើនអន្ទោលទៅមក ក្នុងទេវតា និង មនុស្សទាំងឡាយ ៧ ជាតិ ហើយ ជាអ្នកអាចធ្វើទីបំផុតនៃទុក្ខបាន ។

(បច្ចវេក្ខណៈ ១៩)

តែក្នុងទីបំផុតនៃផល ចិត្ត របស់ព្រះសោតាបន្ននោះ រមែងចុះកាន់ភវង្គ ។ បន្ទាប់មក មនោទ្វារាវជ្ជនៈ កាត់ផ្តាច់នូវភវង្គហើយ កើតឡើងដើម្បីប្រយោជន៍ដល់ការពិចារណានូវមគ្គ កាលបើមនោទ្វារាវជ្ជនៈនោះរលត់ហើយ អាវជ្ជនៈសម្រាប់ពិចារណាមគ្គ ៧ ក៏កើតឡើងតាមលំដាប់លំដោយ ។ អាវជ្ជនៈជាដើម ចុះកាន់ភវង្គម្តងទៀងហើយ កើតឡើងដើម្បីប្រយោជន៍ដល់ការពិចារណាផលជាដើម តាមន័យនុ៎ះឯង ព្រោះការកើតឡើងនៃអាវជ្ជនៈ និង ជវនចិត្តទាំងឡាយណា ព្រះសោតាបន្ននុ៎ះ

ទើបពិចារណានូវមគ្គ ពិចារណាផល ពិចារណាកិលេសដែលលះបានហើយ ពិចារណាកិលេសដែលនៅសល់ ពិចារណានូវព្រះនិព្វាន ។

ក៏ព្រះសោតាបន្នទោះ រមែងពិចារណានូវមគ្គថា "អាត្មាអញ មកហើយ ដោយមគ្គហ្នុំ" បន្ទាប់មក ទើបពិចារណានូវផលថា "អានិសង្ស នេះ គឺអាត្មាអញបានហើយ" បន្ទាប់មក ទើបពិចារណាកិលេសដែលខ្លួនលះបានហើយថា "កិលេសទាំងឡាយឈ្មោះនេះៗ អាត្មាអញលះបានហើយ" បន្ទាប់ពីនោះមក ក៏ពិចារណានូវកិលេសទាំងឡាយដែលមគ្គ ៣ ខាងលើៗ គប្បីកំចាត់ថា "កិលេសរបស់អញឈ្មោះនេះៗនៅមានសេសសល់" ដូច្នេះ និង នៅក្នុងទីបំផុត ទើបពិចារណា នូវព្រះអមតនិព្វាន ថា "ធម៌នេះ អាត្មាអញបានចាក់ធ្លុះហើយ ដោយថា ជាអារម្មណ៍" ដូច្នេះ ។ ព្រោះហេតុនេះ ព្រះអរិយសាវក ជាសោតាបន្ន មានបច្ចវេក្ខណៈ ៥ ។ ក៏ព្រះសោតាបន្ន មានបច្ចវេក្ខណៈ៥ យ៉ាងណា, ព្រះសកទាគាមី និង ព្រះអនាគាមី ក៏មាន ៥ យ៉ាងនោះដែរ ។ សំរាប់ព្រះអរហន្ត ឈ្មោះថាការពិចារណាកិលេសដែលសេសសល់ មិនមានឡើយ ។ បច្ចវេក្ខណៈទាំងអស់មាន ១៩ ដោយប្រការដូច្នេះ ។ តែនុ៎ះ ជាការកំណត់យ៉ាងខ្ពស់មែនពិត ។ ព្រោះថា ការពិចារណាកិលេសដែលខ្លួនលះបានហើយ និង កិលេសដែលសេសសល់ តែងមានខ្លះ មិនមានខ្លះ ដល់ព្រះសេក្ខបុគ្គលទាំងឡាយ ។ ក៏ព្រោះការមិនមានបច្ចវេក្ខណៈយ៉ាងនោះឯង ព្រះមហានាម ទើបក្រាបទូលសួរព្រះមានព្រះភាគថា "ចុះធម៌អ្វីហ្នុំ [(១)] នៅក្នុងសន្តាន ដែលអាត្មាអញមិនទាន់លះបង់អស់ បានជាចួនកាល ធម៌គឺលោភៈ គ្របសង្កត់ចិត្តអាត្មាអញខ្លះ" ដូច្នេះជាដើម ។ បទនៃព្រះសូត្រ

១- សុ. ម. មូ. ភាគទី ២០ ទំព័រទី ៣៣៥ ។



ទាំងពួង បណ្ឌិតគប្បីជ្រាប ដោយពិស្តារ ។

ក៏ព្រះអរិយសាវក ជាព្រះសោតាបន្នទោះ លុះពិចារណា យ៉ាងនេះហើយ អង្គុយលើអាសនៈនោះឯង ឬ ដោយសម័យផ្សេងទៀត ធ្វើនូវសេចក្តីព្យាយាម ដើម្បីបានសម្រេចនូវភូមិទី២ ដើម្បីបន្ថយនូវកាមរាគៈ និង ព្យាបាទ ។ ព្រះអរិយសាវកនោះ ប្រមូលផ្តុំឥន្ទ្រីយ៍, ពលៈ និង ពោជ្ឈង្គគ្រប់ហើយ ញ៉ាំញីនូវសង្ខារ មានរូប, វេទនា, សញ្ញា, សង្ខារ និង វិញ្ញាណ ជាប្រភេទ ដោយញាណថា "វាជារបស់មិនទៀង ជាទុក្ខ ជាអនត្តា" ដូច្នេះ ត្រឡប់ទៅមក ឈានចូលដល់វិបស្សនាវិថី ។ កាលបើព្រះសោតាបន្នទោះ ប្រព្រឹត្តយ៉ាងនេះ, កាលបើអនុលោមញាណ និង គោត្រភូញាណ កើតឡើងហើយ ដោយអាវជ្ជនៈមួយ ក្នុងទីបំផុត នៃសង្ខារុបេក្ខាញាណ តាមន័យដែលពោលមកហើយនុ៎ះឯង, សកទាគាមីរមែងកើតឡើង ក្នុងលំដាប់នៃគោត្រភូញាណ ។ ក៏ញាណ ដែលប្រកបព្រមដោយសកទាគាមីនោះ ឈ្មោះថា ញាណក្នុងសកទាគាមិមគ្គ យ៉ាងនេះឯង ។

ទុតិយញ្ញាណ ចប់ហើយ ។

(តតិយញ្ញាណ)

(៤៥៦) ផលចិត្តក្នុងលំដាប់នៃញាណនេះឯង ក៏គប្បីជ្រាបតាមន័យដូចពោលមកហើយដូចគ្នាដែរ ។ ក៏ដោយសារការកើតឡើងនៃផល ក្នុងលំដាប់នៃទុតិយមគ្គប៉ុណ្ណោះនេះ ព្រះយោគាវចរនោះ បានជាព្រះអរិយបុគ្គល ទី៤ ឈ្មោះថា សកទាគាមី មកកាន់លោកនេះ តែមួយជាតិប៉ុណ្ណោះ ក៏អាចធ្វើទីបំផុតនៃទុក្ខបាន ។ ការពិចារណាលើសពីនោះទៅទៀត ក៏មានន័យហ្នឹងដែរ ។ ក៏លុះពិចារណាយ៉ាងនេះហើយ ព្រះអរិយ-

សាវកដែលជាព្រះសកទាគាមីនោះ អង្គុយលើអាសនៈនោះឯង ឬដោយសម័យក្រោយមក រមែងធ្វើនូវសេចក្ដីព្យាយាម ដើម្បីសម្រេចភូមិ ទី៣ ដើម្បីលះបង់នូវកាមរាគៈ និង ព្យាបាទ មិនឲ្យសេសសល់ ។ លោកប្រមូលនូវឥន្ទ្រិយ៍, ពលៈ និង ពោជ្ឈង្គ ឲ្យព្រមគ្នាហើយ ញ៉ាំញីសង្ខារនោះឯង ដោយញាណ ថា "វា ជារបស់មិនទៀង ជាទុក្ខ ជាអនត្តា" ត្រឡប់ទៅមក ក៏ឈានចុះដល់វិថីនៃវិបស្សនា ។ កាលបើព្រះអរិយបុគ្គលនោះ ប្រតិបត្តិយ៉ាងដូច្នេះឯង, កាលបើអនុលោមញាណ និង គោត្រភូញាណ កើតឡើងហើយ ដោយអាវជ្ជនៈមួយ ក្នុងទីបំផុត នៃសង្ខារុបេក្ខាញាណ តាមន័យដែលលោកបានពោលមកហើយហ្នឹងឯង អនាគាមិមគ្គ រមែងកើតឡើង ក្នុងលំដាប់នៃគោត្រភូញាណ ។ ញាណដែលប្រកបព្រម ដោយអនាគាមិមគ្គនោះ ឈ្មោះថា ញាណ ក្នុងអនាគាមិមគ្គ ដោយប្រការដូច្នេះឯង ។

តតិយញ្ញាណ ចប់ហើយ ។

(ចតុត្ថមគ្គញ្ញាណ)

(៤៥៧) ផលចិត្ត ក្នុងលំដាប់នៃញាណនោះឯង គប្បីជ្រាប តាមន័យដែលពោលហើយនុ៎ះឯង ។ ក៏ដោយសារការកើតឡើងនៃផល ក្នុងលំដាប់នៃតតិយមគ្គ មានប្រមាណប៉ុណ្ណេះនេះ ព្រះយោគាវចរនោះបានជាព្រះអរិយបុគ្គលទី៦ ឈ្មោះថា ព្រះអនាគាមី ជាឱបបាតិកៈ បរិនិព្វានក្នុងលោកដែលជាទីកើតនោះ មានការមិនត្រឡប់មកជាធម្មតា គឺមិនមកកាន់លោកនេះថ្មីទៀត ដោយអំណាចនៃបដិសន្ធិ ។ ការពិចារណាលើសពីនោះទៅទៀត ក៏មានន័យដូចពោលមកនុ៎ះឯង ។ ក៏លុះពិចារណាយ៉ាងនេះហើយ ព្រះអរិយសាវកដែលជាព្រះអនាគាមីនោះអង្គុយលើអាសនៈ



នោះឯង ឬ ដោយសម័យក្រោយមក ធ្វើសេចក្ដីព្យាយាម ដើម្បីបានសំរេចភូមិទី៤ ដើម្បីលះបង់នូវរូបរាគៈ, អរូបរាគៈ, មានៈ, ឧទ្ធច្ចៈ និង អវិជ្ជា មិនឲ្យមាននៅសេសសល់ ។ លោកប្រមូលឥន្ទ្រិយ៍, ពលៈ និង ពោជ្ឈង្គ ឲ្យព្រមគ្នាហើយ ញ៉ាំញីសង្ខារនោះឯង ដោយញាណ ថា "ជារបស់មិនទៀង ជាទុក្ខ ជាអនត្តា" ត្រឡប់ទៅមក ក៏ឈានចុះដល់វិថី នៃវិបស្សនា។ កាលបើលោកប្រតិបត្តិយ៉ាងនេះ, កាលបើអនុលោមញាណ និង គោត្រភូញាណ កើតឡើងហើយ ដោយអាវជ្ជនៈ១ ក្នុងទីបំផុត នៃសង្ខារុបេក្ខាញាណ តាមន័យដែលពោលមកហើយនេះឯង, អរហត្តមគ្គក៏កើតឡើង ក្នុងលំដាប់នៃគោត្រភូញាណ ។ ញាណ ដែលប្រកបដោយអរហត្តមគ្គនោះ ឈ្មោះថា ញាណ ក្នុងអរហត្តមគ្គ ដោយប្រការដូច្នេះ ។

ចតុត្ថញ្ញាណ ចប់ហើយ ។

ផលចិត្ត ក្នុងលំដាប់សូម្បីក្នុងញាណនេះ ក៏គប្បីជ្រាប តាមន័យដែលពោលមកហើយនុ៎ះឯង ។ ក៏ដោយសារការកើតឡើងនៃផល ក្នុងលំដាប់នៃចតុត្ថមគ្គ មានប្រមាណប៉ុណ្ណេះ, ព្រះយោគាវចរនោះ បានជាព្រះអរិយបុគ្គលទី៨ ឈ្មោះថា ព្រះអរហន្ត ជាព្រះខីណាស្រព ជាអ្នកទ្រទ្រង់នូវរាងកាយ ក្នុងទីបំផុត ដាក់ភារៈចុះហើយ មានប្រយោជន៍បានសំរេចហើយដោយលំដាប់ មានកិលេសជាគ្រឿងប្រកបទុកក្នុងភពអស់រលីងហើយ ដឹងដោយប្រពៃ រួចផុតស្រឡះហើយ ជាព្រះទក្ខិណេយ្យ-បុគ្គល ដ៏ប្រសើរបំផុត របស់មនុស្សលោក ព្រមទាំងទេវលោក ។

ដោយហេតុដែលបានពោលមកនេះ ពាក្យឯណា ដែលខ្ញុំពោលហើយថា "ចំណែកញាណ ក្នុងមគ្គទាំង៤ នេះ គឺសោតាបត្តិមគ្គ, សកទាគាមិមគ្គ, អនាគាមិមគ្គ, អរហត្តមគ្គ ឈ្មោះថា ញាណទស្សនវិសុទ្ធិ"

ដូច្នេះ, ពាក្យនោះ ខ្ញុំពោលហើយ សំដៅយកញាណ ៤ នេះ ដែលគប្បីសំរេច ដោយលំដាប់នេះ ។

(អានុភាពនៃមគ្គញ្ញាណ)

ឥឡូវនេះ ដើម្បីជ្រាបច្បាស់នូវអានុភាពនៃញាណ ៤ ដែលឈ្មោះថា ញាណទស្សនវិសុទ្ធិ នេះឯង

> បណ្ឌិត គប្បីជ្រាបភាវៈនៃពោធិបក្ខិយធម៌ពេញបរិបូរ គប្បីជ្រាបវុដ្ឋានៈ(ការចេញពីនិមិត្ត និង ការប្រព្រឹត្តិ) និង ពលសមាយោគៈ (គឺសេចក្ដីប្រកបស្មើគ្នា នៃសមថពលៈ និង វិបស្សនាពលៈ) គប្បីជ្រាបការលះបង់នូវធម៌ទាំងឡាយ ដែលញាណឯណា គប្បីលះបង់ នឹងគប្បីជ្រាបកិច្ច មានបរិញ្ញាកិច្ចជាដើម ដែលលោកពោលហើយ ក្នុងពេលត្រាស់ដឹង តាមសភាព យ៉ាងនេះឯង ។

(ពោធិបក្ខិយធម៌)

ក្នុងបទទាំងនោះ បទថា "បរិបុណ្ណពោធិបក្ខិយភាវោ" គឺ ភាពនៃពោធិបក្ខិយធម៌ទាំងឡាយ ពេញបរិបូណ៌ ។ ក៏ធម៌ ៣៧ នេះ គឺ សតិបដ្ឋាន ៤, សម្មប្បធាន ៤, ឥទ្ធិបាទ ៤ ឥន្ទ្រិយ៍ ៥, ពលៈ ៥, ពោជ្ឈង្គ ៧, មគ្គមានអង្គ ៨ ដ៏ប្រសើរ ឈ្មោះថា ពោធិបក្ខិយៈ ព្រោះជាធម៌មានក្នុងចំណែកនៃអរិយមគ្គ ដែលបានឈ្មោះថា "ពោធៈ" ដោយអត្ថថា ជាហេតុត្រាស់ដឹង ។ ពាក្យថា "ព្រោះជាធម៌មានក្នុងចំណែក" គឺ ព្រោះតាំងនៅ ក្នុងភាពជាធម៌មានឧបការៈ ។



(អត្ថនៃសតិបដ្ឋាន)

ក្នុងពោធិបក្ខិយធម៌ទាំងនោះ ធម៌ឈ្មោះថា បដ្ឋានៈ ព្រោះឈានស៊ុះទៅស្ថិតនៅក្នុងអារម្មណ៍ ។ បដ្ឋានៈ គឺសតិហ្នឹងឯង ទើបបានឈ្មោះថា សតិបដ្ឋាន ។ ក៏សតិនោះ មាន ៤ ប្រភេទ ព្រោះប្រព្រឹត្តទៅដោយអំណាចការប្រកាន់យក នូវអាការៈដែលមិនល្អ អាការៈជាទុក្ខ អាការៈមិនទៀង អាការៈមិនមែនជាខ្លួន ក្នុងកាយ, វេទនា, ចិត្ត និង ធម៌ និងដោយអំណាច នៃការញ៉ាំងកិច្ច គឺការលះបង់នូវសេចក្ដីសំគាល់ថា ល្អ សេចក្ដីសំគាល់ថា សុខ សេចក្ដីសំគាល់ថា ទៀងទាត់ និង សេចក្ដីសំគាល់ថា ជាខ្លួនប្រាណ ក្នុងកាយ, វេទនា, ចិត្ត និង ធម៌ ឲ្យសម្រេច ព្រោះហេតុនោះ ទើបហៅថា សតិបដ្ឋាន ៤ ។

(អត្ថនៃសម្មប្បធាន)

ធម៌ឈ្មោះថា បធាន ព្រោះជាហេតុព្យាយាម, សេចក្ដីព្យាយាមដ៏ល្អ ឈ្មោះថា សម្មប្បធាន (ធម៌ជាហេតុព្យាយាមដ៏ល្អ) ន័យមួយទៀត ធម៌ ដែលឈ្មោះថា សម្មប្បធាន ព្រោះជាហេតុព្យាយាមដោយប្រពៃ ។ មួយទៀត ធម្មជាតនោះ ឈ្មោះថា ល្អ ព្រោះវៀរចាករបស់ដែលគួរខ្ពើមព្រោះកិលេស និង ឈ្មោះថា បធាន ព្រោះនាំមកនូវភាពជាអ្នកប្រសើរ និង ព្រោះធ្វើនូវភាពជាប្រធាន ដោយអត្ថថាញ៉ាំងប្រយោជន៍សុខឲ្យបានសម្រេច ហេតុនោះ ធម្មជាតនោះ ទើបឈ្មោះថា សម្មប្បធាន ។ ពាក្យថា "សម្មប្បធាន" នោះ ជាឈ្មោះនៃវិរិយៈ ។ សម្មប្បធាននេះនោះ មាន ៤ យ៉ាង គឺ ញ៉ាំងកិច្ច គឺការលះ និង ការមិនឲ្យកើតឡើងនៃអកុសលទាំងឡាយដែលកើតឡើងហើយ និង មិនទាន់កើតឡើងហើយ និងញ៉ាំងកិច្ច គឺការឲ្យកើតឡើង និង ការតាំងនៅនៃកុសលទាំងឡាយ ដែលមិន

ទាន់កើតឡើង និង ដែលកើតឡើងហើយ ឲ្យសំរេច ព្រោះហេតុនោះ ទើបឈ្មោះថា សម្មប្បធាន ៤ ។

(អត្ថនៃឥទ្ធិបាទ)

គុណជាតិ ឈ្មោះថា ឥទ្ធិ ព្រោះអត្ថថា សម្រេច ដូចបានពោលហើយខាងដើម ។ ធម៌ណា ជាបាទនៃឥទ្ធិ ដោយអត្ថ គឺជាប្រធាន នៃសម្បយុត្តធម៌ នៃឥទ្ធិបាទនោះ និង ដោយអត្ថ គឺជាហេតុ នៃចំណែកខាងដើម នៃឥទ្ធិដែលជាផល ព្រោះហេតុនោះ ធម៌នោះ ទើបឈ្មោះថា ឥទ្ធិបាទ ។ ឥទ្ធិបាទនោះមាន ៤ ប្រការ ដោយអំណាចនៃធម៌មានឆន្ទៈជាដើម ព្រោះហេតុនោះ ទើបហៅថា ឥទ្ធិបាទ ៤ ។ ដូចជាបាលីថា :

“ចត្តារោ [១] ឥទ្ធិបាទា ឆន្ទិទ្ធិបាទោ វីរិយិទ្ធិបាទោ ចិត្តិទ្ធិបាទោ វីមំសិទ្ធិបាទោ ឥទ្ធិបាទ ៤ គឺ ឆន្ទិទ្ធិបាទ (ឥទ្ធិបាទ គឺឆន្ទៈ) វីរិយិទ្ធិបាទ (ឥទ្ធិបាទ គឺវីរិយៈ) ចិត្តិទ្ធិបាទ (ឥទ្ធិបាទ គឺចិត្ត) វីមំសិទ្ធិបាទ (ឥទ្ធិបាទ គឺវីមំសា)” ។ ធម៌ទាំងឡាយ មានឆន្ទៈជាដើមនេះ ជាលោកុត្តរៈ ដោយពិត ។ ចំណែកដែលជាលោកិយៈ សូម្បីជាធម៌ដែលបានហើយ ដោយអំណាចនៃឆន្ទាធិបតីជាដើម ក៏ហៅថា ជាឥទ្ធិបាទ ព្រោះបាលីថា “បើភិក្ខុធ្វើឆន្ទៈ [២] ឲ្យជាអធិបតី រមែងបាននូវសមាធិ បាននូវភាពនៃចិត្តមានអារម្មណ៍មូលតែមួយ នេះហៅថា ឆន្ទសមាធិ” ដូច្នេះជាដើម ។

(អត្ថនៃឥន្ទ្រិយ៍ និង ពលៈ)

ធម៌ ដែលឈ្មោះថា ឥន្ទ្រិយ៍ ព្រោះអត្ថថា ជាសភាព ជាអធិបតី ដែលបានឈ្មោះថា គ្របសង្កត់ ព្រោះគ្របសង្កត់បាន នូវការមិនជឿ, សេចក្ដីខ្ជិលប្រអូស, សេចក្ដីប្រមាទ, សេចក្ដីរាយមាយចិត្ត និង សេចក្ដី

១- អភិ. វិ. ភាគទី ៨១ ទំព័រ ២០២ ។ ២- អភិ. ភាគទី ៨១ ទំព័រ ១៧៨ ។



វង្វេង មិនដឹងការពិត, មួយទៀត ធម៌ឈ្មោះថា ពលៈ ដោយអត្ថថា មិនញាប់ញ័រ ព្រោះអកុសលទាំងឡាយ មានការមិនជឿជាដើម គ្របសង្កត់មិនបាន ។ ធម៌ទាំងពីរយ៉ាងនេះឯង មានវិភាគ ៥ យ៉ាង ដោយអំណាចនៃធម៌មានសទ្ធាជាដើម ព្រោះហេតុនោះ ទើបលោកហៅថា ឥន្ទ្រិយ៍ ៥ ពលៈ ៥ ។

(អត្ថនៃពោជ្ឈង្គ និង អដ្ឋមគ្គ)

ក៏ធម៌ទាំងឡាយ ៧ មានសតិជាដើម ឈ្មោះថា ពោជ្ឈង្គ ព្រោះជាអង្គនៃសត្វដែលត្រាស់ដឹង ។ មួយទៀត ធម៌ ៨ មានសម្មាទិដ្ឋិ ជាដើម ឈ្មោះថា អដ្ឋមគ្គ ដោយអត្ថថា នាំចេញចាកសង្សារវដ្ត ។ ហេតុនោះ ទើបលោកហៅថា ពោជ្ឈង្គ ៧ អរិយមគ្គ មានអង្គ ៨ ។

ពោធិបក្ខិយធម៌ ៣៧ ដូចពោលមក រមែងបានក្នុងចិត្តផ្សេងៗ ក្នុងបុព្វភាគ យ៉ាងនេះថា “កាលបើលោកិយវិបស្សនា ប្រព្រឹត្តទៅ កាយានុបស្សនាសតិបដ្ឋាន រមែងមានដល់ព្រះយោគាវចរអ្នកកំណត់យកកាយ ដោយអាការៈ ១៤ យ៉ាង, វេទនានុបស្សនាសតិបដ្ឋាន រមែងមានដល់ព្រះយោគាវចរ អ្នកកំណត់នូវវេទនា ដោយអាការៈ ៩ យ៉ាង, ចិត្តានុបស្សនាសតិបដ្ឋាន រមែងមានដល់ព្រះយោគាវចរ អ្នកកំណត់នូវចិត្ត ដោយអាការៈ ១៦ យ៉ាង, ធម្មានុបស្សនាសតិបដ្ឋាន រមែងមានដល់ព្រះយោគាវចរ អ្នកកំណត់នូវធម៌ទាំងឡាយ ដោយអាការៈ ៥ យ៉ាង ។ សម្មប្បធាន ទី១ រមែងមានក្នុងពេលដែលឃើញនូវអកុសល ដែលមិនធ្លាប់កើតឡើង (ដល់ខ្លួន) ក្នុងអត្តភាពនេះ (តែ) កើតឡើងហើយ ដល់អ្នកដទៃ ទើបគិតថា: អកុសលនុ៎ះ កើតឡើងហើយ ដល់អ្នកដទៃ ដែលប្រតិបត្តិ យ៉ាងណា, អាត្មាអញ នឹងមិនប្រតិបត្តិ យ៉ាងនោះទេ, កាលបើ

ដូច្នោះ អកុសលនេះ នឹងមិនកើតឡើង ដល់អាត្មាអញឡើយ ដូច្នេះហើយ ក៏ព្យាយាមមិនឲ្យអកុសលនោះ កើតឡើងបាន, សម្មប្បធានទី២ រមែងមាន ក្នុងពេលដែលឃើញ នូវអកុសលដែលកើតឡើង មកដល់ខ្លួនឯង ហើយព្យាយាមដើម្បីលះអកុសលនោះចោល, សម្មប្បធានទី៣ រមែងមាន ដល់អ្នកព្យាយាម ដើម្បីញ៉ាំងឈាន ឬ វិបស្សនា ដែលមិនទាន់បានកើតឡើង ក្នុងអត្តភាពនេះ ឲ្យកើតឡើង, សម្មប្បធាន ទី៤ រមែងមានដល់អ្នកដែលញ៉ាំងឈាន ឬ វិបស្សនា ដែលកើតឡើងហើយ ឲ្យកើតឡើងរឿយៗ ដោយប្រការដែលមិនសាបសូន្យទៅ, ឥទ្ធិបាទទាំងឡាយ មានឆន្ទិទ្ធិបាទជាដើម រមែងមានក្នុងពេលដែលធ្វើឥទ្ធិបាទ មានឆន្ទិទ្ធិបាទជាដើមនោះៗ ឲ្យជាធុរៈ ហើយញ៉ាំងកុសល ឲ្យកើតឡើង, សម្មាវាចាជាដើម រមែងមាន ក្នុងពេលដែលវៀរចាកពីមិច្ឆាវាចាជាដើម ដូច្នេះ, តែក្នុងពេលដែលញាណទាំង៤ នេះ កើតឡើង, ធម៌ទាំងនោះ រមែងបានក្នុងចិត្តតែមួយ ។ លើកលែងតែសម្មប្បធាន៤ ចេញ ធម៌ទាំងទាំងឡាយដ៏សេស៣៣ រមែងមានក្នុងខណៈនៃផលចិត្ត ។ ក៏ក្នុងធម៌ទាំងឡាយនោះ ដែលមានក្នុងចិត្តតែមួយយ៉ាងនេះ សតិ ដែលមានព្រះនិព្វានជាអារម្មណ៍ ក៏ជាមួយគ្នាហ្នឹងឯង លោកហៅថា សតិបដ្ឋាន ៤ ដោយអំណាចនៃការញ៉ាំងកិច្ច គឺការលះនូវសេចក្ដីសំគាល់ថាល្អ ជាដើម ក្នុងអារម្មណ៍ទាំងឡាយមានកាយជាដើម ឲ្យសម្រេច ។ វីរិយៈ ក៏ជាមួយគ្នាហ្នឹងឯង លោកហៅថា សម្មប្បធាន៤ ដោយអំណាចនៃការញ៉ាំងកិច្ច មានការញ៉ាំងអកុសល ដែលមិនទាន់កើតឡើងហើយ មិនឲ្យកើតឡើងបានជាដើម ឲ្យសម្រេច ។ តែក្នុងផ្នែកដែលនៅសល់ ការដក និង ការបន្ថែម មិនមានទេ ។



*វិភាគមួយទៀត ក្នុងពោធិបក្ខិយធម៌ ៣៧ ប្រការនោះ*

> ធម៌ទាំងឡាយនោះ មាន ៦ ប្រការ គឺធម៌ ៩ មាន
> ប្រការតែមួយ, ធម៌ ១ មាន ២ យ៉ាង, ម្យ៉ាង
> ទៀត ធម៌ ១ មាន ៤ យ៉ាង មាន ៥ យ៉ាង មាន
> ៨ យ៉ាង និង មាន ៩ យ៉ាង ។

ពាក្យថា “ធម៌មានប្រការតែ១” អធិប្បាយថា ធម៌ ៩ នេះ គឺឆន្ទៈ, ចិត្តៈ, បីតិ, បស្សទ្ធិ, ឧបេក្ខា, សង្កប្បៈ, វាចា, កម្មន្តៈ, អាជីវៈ មានប្រការតែមួយប៉ុណ្ណោះ ដោយអំណាចនៃឆន្ទិទ្ធិជាដើម មិនគប់រកនូវចំណែកដទៃឡើយ ។

ពាក្យថា “ធម៌ ១ មាន ២ ប្រការ” បានដល់សទ្ធា ស្ថិតនៅដោយចំណែក ២ យ៉ាង គឺ ឥន្ទ្រីយ៍ ១, ពលៈ ១ ។

ពាក្យថា “មួយទៀត ធម៌ ១ មាន ៤ ប្រការ មាន៥ ប្រការ” បានដល់ មួយទៀត ធម៌ ១ ទៀត ស្ថិតនៅ ដោយចំណែក ៤ យ៉ាង, មួយផ្សេងទៀត ស្ថិតនៅ ដោយចំណែក ៥ យ៉ាង ។ ក្នុងធម៌ ២ យ៉ាងនោះ សមាធិ១ ស្ថិតនៅ ដោយចំណែក៤ យ៉ាង គឺ ឥន្ទ្រីយ៍, ពលៈ, ពោជ្ឈង្គ និង មគ្គ, បញ្ញា ១ ស្ថិតនៅ ដោយចំណែក ៥ យ៉ាង ដោយអំណាចនៃធម៌ ៤ យ៉ាងនោះ និង ចំណែកនៃឥទ្ធិបាទ ។

ពាក្យថា “ធម៌ ១ មាន ៨ ប្រការ និង មាន៩ ប្រការ” សេចក្ដីថា ធម៌ ១ ផ្សេងទៀត ស្ថិតនៅដោយចំណែក៨ យ៉ាង, មួយទៀត ស្ថិតនៅដោយចំណែក៩ យ៉ាង។ គឺសតិ ស្ថិតនៅដោយចំណែក៨ យ៉ាង ដោយអំណាច នៃសតិបដ្ឋាន ៤, ឥន្ទ្រីយ៍, ពលៈ, ពោជ្ឈង្គ និង មគ្គ ។ វីរិយៈ

*ស្ថិតនៅ ដោយចំណែក ៩ ដោយអំណាចនៃសម្មប្បធាន ៤, ឥទ្ធិបាទ, ឥន្ទ្រិយ៍, ពលៈ, ពោជ្ឈង្គ និង មគ្គ ដូច្នេះឯង ។*

*តាមន័យដែលបានពោលមកហើយនេះ*

> ពោធិបក្ខិយធម៌ទាំងនោះ មិនច្រឡូកច្រឡំគ្នា មាន ១៤ យ៉ាងប៉ុណ្ណោះ ពោលដោយចំណែក មាន ៧ ប្រការ បើពោលដោយប្រភេទ មាន ៣៧ ប្រការ, ធម៌ទាំងអស់នោះឯង មានព្រមក្នុងខណៈនៃអរិយមគ្គ កើតឡើង ព្រោះធ្វើកិច្ចរបស់ខ្លួន ឲ្យសំរេច និង ព្រោះប្រព្រឹត្តទៅ ដោយមានរូបស្មើគ្នា ។

*ភាពនៃពោធិបក្ខិយធម៌ ពេញបរិបូណ៌ ក្នុងញាណទស្សនៈ នេះ គប្បីជ្រាប ដោយប្រការដូចបានពោលមកនេះឯង ជាដំបូងសិន ។*

*(៤៥៨) បទថា "វុដ្ឋានពលសមាយោគោ" ប្រែថា ការចេញ និង ការប្រកបព្រមដោយពលៈ ។ ព្រោះថា លោកិយវិបស្សនា ចេញពីនិមិត្ត មិនទាន់បាន ព្រោះនៅមាននិមិត្តជាអារម្មណ៍ និង ចេញពីបវត្តៈ (ការប្រព្រឹត្តិ)មិនទាន់បាន ព្រោះកាត់នូវសមុទយៈដែលជាហេតុនៃបវត្តៈ មិនទាន់បាន ។ គោត្រភូញាណ ក៏មិនទាន់ចេញពីបវត្តៈ ព្រោះកាត់សមុទយៈ មិនទាន់បាន ។ ប៉ុន្តែចេញពីនិមិត្តបាន ព្រោះមានព្រះនិព្វានជាអារម្មណ៍ ព្រោះហេតុនោះ គោត្រភូញាណនោះ ទើបជាឯកតោវុដ្ឋានៈ (ចេញដោយចំណែកមួយ) ។ ព្រោះហេតុនោះ ទើបលោកពោល ថា "បញ្ញា [១] ក្នុងការចេញ និង ការវិលត្រឡប់ ចាកសង្ខារនិមិត្តខាងក្រៅ*

*១- សុ. ខុ. បដិ. ភាគទី ៦៩ ទំព័រទី ១៥៥ ។*



*ឈ្មោះថា គោត្រភូញាណ" ។ ន័យដូចគ្នានោះដែរ ញាណ ត្រឡប់ចាកការកើតហើយ ស្ទុះទៅកាន់ការមិនកើត [១] ហេតុនោះ ទើបឈ្មោះថា គោត្រភូ, ញាណ ត្រឡប់ចាកការប្រព្រឹត្តិ (ហើយស្ទុះទៅកាន់ការមិនប្រព្រឹត្តិ ហេតុនោះ ឈ្មោះថា គោត្រភូ) ។ ពាក្យបាលីទាំងអស់ បណ្ឌិតគប្បីជ្រាប ។*

*ចំណែកញាណ ៤ យ៉ាងនេះ ឈ្មោះថា ចេញចាកនិមិត្ត ព្រោះមិនមាននិមិត្តជាអារម្មណ៍ ឈ្មោះថា ចេញចាកការប្រព្រឹត្តិ ព្រោះកាត់ផ្តាច់សមុទយៈបាន ហេតុនោះ ញាណទាំង៤ នេះ ទើបចាត់ជាឧភតោវុដ្ឋានៈ គឺចេញចាកសភាវៈទាំង ២ ព្រោះហេតុនោះ ទើបលោកពោលហើយថា "បញ្ញា ក្នុងការចេញ និង ការវិលត្រឡប់ចាកសភាវៈទាំង ២ ឈ្មោះថា មគ្គញ្ញាណ តើដូចម្តេច? [២] ។ ក្នុងខណៈនៃសោតាបត្តិមគ្គ សម្មាទិដ្ឋិ ដោយអត្ថថាឃើញ រមែងចេញចាកមិច្ឆាទិដ្ឋិ រមែងចេញចាកកិលេសដែលប្រព្រឹត្តទៅតាមមិច្ឆាទិដ្ឋិនោះផង ចាកខន្ធទាំងឡាយផង រមែងចេញចាកនិមិត្តទាំងពួងខាងក្រៅផង ហេតុនោះ ទើបលោកពោលថា "បញ្ញា ក្នុងការចេញ និង ការវិលត្រឡប់ចាកសភាវៈទាំង២ យ៉ាង ឈ្មោះថា មគ្គញ្ញាណ"។ សម្មាសង្កប្បៈដោយអត្ថថាលើកចិត្តឡើង(កាន់អារម្មណ៍) រមែងចេញចាកមិច្ឆាសង្កប្បៈ... សម្មាវាចា ដោយអត្ថថា រក្សាទុក រមែងចេញចាកមិច្ឆាវាចា... សម្មាកម្មន្តៈ ដោយអត្ថថា តាំងឡើង រមែងចេញចាកមិច្ឆាកម្មន្តៈ... សម្មាអាជីវៈ ដោយអត្ថថា ផូរផង់ រមែងចេញចាកមិច្ឆាអាជីវៈ... សម្មាវាយាមៈ ដោយអត្ថថា ផ្គងឡើង រមែងចេញចាកមិច្ឆាវាយាមៈ.... សម្មាសតិ ដោយអត្ថថា ប្រុងប្រយ័ត្ន រមែងចេញចាក*

*១- សុ. ខុ. បដិ. ភាគ ៦៩ ទំព័រ ១៥១ ។ ២□ សុ. ភាគ ៦៩ ទំព័រ ១៥៥ ។*

មិច្ឆាសតិ.... សម្មាសមាធិ ដោយអត្ថថា មិនរាយមាយ រមែងចេញចាក មិច្ឆាសមាធិ រមែងចេញចាកកិលេស ដែលប្រព្រឹត្តតាម នូវមិច្ឆាសមាធិ នោះផង ចាកខន្ធទាំងឡាយផង រមែងចេញចាកនិមិត្តទាំងពួងខាងក្រៅ ផង ព្រោះហេតុនោះ ទើបលោកពោលថា “បញ្ញា ក្នុងការចេញ និង ការវិលត្រឡប់ចាកសភាវៈទាំង ២ ឈ្មោះថា មគ្គញ្ញាណ” ដូច្នេះ ។

ក្នុងខណៈនៃសកទាគាមិមគ្គ សម្មាទិដ្ឋិ ដោយអត្ថថាឃើញ ។ល។ សម្មាសមាធិ ដោយអត្ថថា មិនរាយមាយ រមែងចេញចាកកាមរាគៈ សញ្ញោជនៈ និង បដិឃសញ្ញោជនៈដ៏គ្រោតគ្រាត ចាកកាមរាគានុស័យ និង បដិឃានុស័យ ដ៏គ្រោតគ្រាត .... ។ល។

ក្នុងខណៈនៃអនាគាមិមគ្គ សម្មាទិដ្ឋិ ដោយអត្ថថា ឃើញ ។ល។ សម្មាសមាធិ ដោយអត្ថថា មិនរាយមាយ រមែងចេញចាកកាមរាគៈ សញ្ញោជនៈ និង បដិឃសញ្ញោជនៈ ដ៏ល្អិត ចាកកាមរាគានុស័យ និង បដិឃានុស័យ ដ៏ល្អិត....។ល។

ក្នុងខណៈនៃអរហត្តមគ្គ សម្មាទិដ្ឋិ ដោយអត្ថថា ឃើញ ។ល។ សម្មាសមាធិ ដោយអត្ថថា មិនរាយមាយ រមែងចេញចាករូបរាគៈ, អរូបរាគៈ, មានះ, ឧទ្ធច្ចៈ, អវិជ្ជា, មានានុស័យ, ភវរាគានុស័យ និង អវិជ្ជានុស័យ រមែងចេញចាកកិលេស ដែលប្រព្រឹត្តតាម នូវអនុស័យ កិលេសនោះផង ចាកខន្ធទាំងឡាយផង រមែងចេញចាកនិមិត្តទាំងពួង ខាងក្រៅផង ព្រោះហេតុនោះ ទើបលោកពោលថា បញ្ញា ក្នុងការចេញ និង ការវិលត្រឡប់ចាកសភាវៈទាំង ២ ឈ្មោះថា មគ្គញ្ញាណ” ដូច្នេះ ។

(ពលសមាយោគៈ)

ក៏ក្នុងពេលដែលចំរើនសមាបត្តិ៨ ដែលជាលោកិយ, សមថពលៈ



រមែងមានកម្លាំងក្រៃលែង ។ ក្នុងពេលដែលចំរើនវិបស្សនា មានអនិច្ចា-នុបស្សនាជាដើម វិបស្សនាពលៈ រមែងមានកម្លាំងក្រៃលែង ។ តែក្នុង ខណៈនៃអរិយមគ្គ ធម៌ទាំងឡាយនោះ ឈ្មោះថា ជាប់គ្នាជាគូ ប្រព្រឹត្ត ទៅ ព្រោះអត្ថថា មិនប្រព្រឹត្តកន្លង ដល់គ្នានឹងគ្នា ។ ព្រោះហេតុនោះ ពលសមាយោគៈ (ការប្រកបព្រមដោយពលៈ) ទាំង ២ ទើបមាន ក្នុង ញាណទាំង៤ យ៉ាងនេះ ។ សមដូចបាលី ថា “កាលបុគ្គល ចេញចាក កិលេសដែលច្រឡំដោយឧទ្ធច្ចៈផង [១] ចាកខន្ធទាំងឡាយផង ភាពនៃ ចិត្តមានអារម្មណ៍តែមួយ ការមិនរាយមាយ គឺសមាធិ មាននិរោធ ជា គោចរ កាលបុគ្គលចេញចាកកិលេស ដែលច្រឡំដោយអវិជ្ជាផង ចាក ខន្ធទាំងឡាយផង វិបស្សនា ដោយអត្ថថា ឃើញរឿយៗ ក៏មាននិរោធ ជាគោចរដែរ សមថៈ និង វិបស្សនា ដោយអត្ថថា ចេញ ជាគុណជាតិ មានរសតែមួយ ជាប់គ្នាជាគូ មិនកន្លងនូវគ្នានឹងគ្នា ដោយប្រការដូច្នេះ ព្រោះហេតុនោះ ទើបលោកពោលថា កិក្ខុ ចំរើនធម៌ដែលជាប់គ្នាជាគូ គឺ សមថៈ និង វិបស្សនា ដោយអត្ថថា ចេញ” ដូច្នេះ ។

វុដ្ឋានៈ (ការចេញ) និង ពលសមាយោគៈ (ការប្រកបព្រមដោយ ពលៈ) ក្នុងញាណទស្សនវិសុទ្ធិនេះ បណ្ឌិតគប្បីជ្រាប ដូចបានពោល មកហើយនេះឯង ។

(បហានៈ)

(៤៥៩) ពាក្យថា “នឹងគួរជ្រាបការលះធម៌ទាំងឡាយ ដែលញាណ ឯណា គួរលះ” មានសេចក្ដីថា ក៏ធម៌ទាំងឡាយឯណា គឺញាណឯណា ក្នុងញាណទាំង៤ នេះ គប្បីលះ, គប្បីជ្រាបការលះ នូវធម៌ទាំងឡាយ

១- សុ. ខុ. បដិ. ភាគទី ៧១ ទំព័រទី ៣០ ។

នោះផង ។ ក៏ញាណទាំង៤ នោះ ជាអ្នកធ្វើនូវការលះនូវធម៌ទាំងឡាយ ដែលហៅថា សំយោជនៈ, កិលេស, មិច្ឆត្តៈ, លោកធម៌, មច្ឆរិយៈ, វិបល្លាសៈ, គន្ថៈ, អគតិ, អាសវៈ, ឱឃៈ, យោគៈ, នីវរណៈ, បរាមាសៈ, ឧបាទាន, អនុសយៈ, មលៈ, អកុសលកម្មបថ និង អកុសលចិត្តុប្បាទ តាមសមគួរដល់សេចក្តីព្យាយាម ។

(សំយោជនៈ)

ក្នុងធម៌ទាំងនោះ ធម៌១០ មានរូបរាគៈជាដើម ហៅថា សំយោជនៈ ព្រោះជាធម៌ចងខន្ធទាំងឡាយ ដោយខន្ធទាំងឡាយ ចងកម្ម ជាមួយនឹងផល ឬ ចងសត្វទាំងឡាយជាមួយនឹងទុក្ខ ។ មែនពិត ធម៌មានរូបរាគៈជាដើមនោះ មានដរាបណា, ខន្ធ ផល និង ទុក្ខទាំងឡាយនោះ ក៏នៅតែមិនដាច់អស់ទៅ ដរាបនោះដែរ ។ ក្នុងធម៌ទាំង១០ នោះ ធម៌ ៥ នេះ គឺ រូបរាគៈ អរូបរាគៈ មានះ ឧទ្ធច្ចៈ អវិជ្ជា ឈ្មោះថា ឧទ្ធម្ភាគិយ-សំយោជនៈ ព្រោះចងនូវខន្ធដែលកើត ឰដ៏ខាងលើជាដើម ។ ធម៌ ៥ នេះ គឺ សក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាសៈ កាមរាគៈ បដិឃៈ ឈ្មោះថា អធោភាគិយសំយោជនៈ ព្រោះចងនូវខន្ធ ដែលកើត ឰដ៏ខាងក្រោមជាដើម ។

(កិលេស)

ធម៌ ១០ នេះ គឺ លោភៈ ទោសៈ មោហៈ មានះ ទិដ្ឋិ វិចិកិច្ឆា ថីនៈ ឧទ្ធច្ចៈ អហិរិកៈ អនោត្តប្បៈ ឈ្មោះថា កិលេស ព្រោះសៅហ្មងខ្លួនឯងផង និង ព្រោះញុំាងសម្បយុត្តធម៌ ឲ្យសៅហ្មងផង ។

(មិច្ឆត្តៈ)

ធម៌ ៨ នេះ គឺ មិច្ឆាទិដ្ឋិ មិច្ឆាសង្កប្បៈ មិច្ឆាវាចា មិច្ឆាកម្មន្តៈ



មិច្ឆាអាជីវៈ មិច្ឆាវាយាមៈ មិច្ឆាសតិ មិច្ឆាសមាធិ ឬ ត្រូវជា ១០ ទាំង មិច្ឆាវិមុត្តិ និង មិច្ឆាញាណៈ ឈ្មោះថា មិច្ឆត្តៈ ព្រោះប្រព្រឹត្តទៅខុស ។

(លោកធម៌)

ធម៌ ៨ នេះ គឺ លាភ គ្មានលាភ យស គ្មានយស សុខ ទុក្ខ និន្ទា សរសើរ ឈ្មោះថា លោកធម៌ ព្រោះកាលបើលោកមាន, ការប្រព្រឹត្តិទៅ ជាធម៌មាន មិនចេះដាច់ ។ តែពាក្យថា "លោកធម៌" ក្នុងទីនេះនុ៎ះ គប្បីជ្រាបថា "លោកធ្វើការប្រកាន់យកការត្រេកអរ ដែលមានឥដ្ឋារម្មណ៍ មានលាភជាដើម ជាទីតាំង និង សេចក្តីថ្នាំងថ្នាក់ចិត្ត មានអនិដ្ឋារម្មណ៍ មានការមិនមានលាភជាដើម ជាទីតាំង ដោយស័ព្ទ គឺ លោកធម៌ ដោយជិតគ្នានឹងហេតុ" ។

(មច្ឆរិយៈ)

សេចក្តីកំណាញ់ ៥ យ៉ាងនេះ គឺ កំណាញ់អាវាស កំណាញ់ត្រកូល កំណាញ់លាភ កំណាញ់ធម៌ កំណាញ់វណ្ណៈ ដែលប្រព្រឹត្តទៅ ដោយអាការៈអត់ធន់មិនបាន នូវ (របស់ខ្លួន) ជាសាធារណៈ ដល់ជនដទៃ ក្នុងអាវាសជាដើម ឈ្មោះថា មច្ឆរិយៈ ។

(វិបល្លាស)

វិបល្លាស ៣ គឺ សញ្ញាវិបល្លាស ចិត្តវិបល្លាស ទិដ្ឋិវិបល្លាស ដែលប្រព្រឹត្តទៅយ៉ាងនេះ ថា "ជារបស់ទៀង ជាសុខ ជាខ្លួនប្រាណ ជារបស់ល្អ ក្នុងវត្ថុទាំងឡាយដែលមិនទៀង ជាទុក្ខ ជាអនត្តា និង មិនល្អហ្នឹងឯង" ឈ្មោះថា វិបល្លាស ។

(គន្ថៈ)

សង្កិលេសធម៌ ៤ មានអភិជ្ឈាជាដើម ឈ្មោះថា គន្ថៈ (កិលេស

ជាគ្រឿងដោតក្រង) ព្រោះដោតក្រងនូវនាមកាយ និង រូបកាយ ។ ពិតមែនដូច្នោះ សង្កិលេសធម៌ទាំងនោះ លោកពោលដូច្នេះថា “អភិជ្ឈា ជាកាយគន្ថៈ, ព្យាបាទ ជាកាយគន្ថៈ, សីលព្វតបរាមាសៈ ជាកាយគន្ថៈ, ឥទំសច្ចាភិនិវេសៈ (ការប្រកាន់ស្អិតថានេះជារឿងពិត) ជាកាយគន្ថៈ” ។

(អគតិ)

ពាក្យថា “អគតិ” ជាឈ្មោះនៃការធ្វើនូវរបស់ដែលមិនគួរធ្វើ និង ការមិនធ្វើនូវរបស់ដែលគួរធ្វើ ព្រោះសេចក្តីស្រឡាញ់ សេចក្តីស្អប់ សេចក្តីវង្វេង និង ការភ័យខ្លាច ។ មែនពិត ការធ្វើនូវរបស់ដែលមិនគួរធ្វើ និងការមិនធ្វើរបស់ដែលគួរធ្វើនោះ លោកហៅថា អគតិ (សេចក្តីលំអៀង) ព្រោះជាកិច្ចដែលព្រះអរិយៈទាំងឡាយ មិនគប្បីប្រព្រឹត្ត ។

(អាសវៈ ឱឃៈ យោគៈ)

ពាក្យថា “អាសវៈ” នុ៎ះ ជាឈ្មោះ នៃកាមរាគៈ ភវរាគៈ មិច្ឆាទិដ្ឋិ និង អវិជ្ជា ព្រោះហូរចេញមកពី “អា” គឺគោត្រភូ ដោយអំណាច នៃអារម្មណ៍ និង ពី “អា” គឺភវគ្គៈ (គឺភពខ្ពង់ខ្ពស់) ដោយអំណាច នៃឱកាស, ម្យ៉ាងទៀត ព្រោះហូរចេញមកពីទ្វារទាំងឡាយដែលមិនបានសង្រួមរាំងហើយ ដោយអត្ថ គឺហូរចេញជានិច្ចដូចជាទឹកហូរចេញពីក្អមដែលធ្លុះដូច្នោះឯង, មួយទៀត ព្រោះជាហេតុកើតនៃសំសារទុក្ខ ។

សូម្បីពាក្យថា “ឱឃៈ” ក៏ជាឈ្មោះ នៃសង្កិលេសធម៌ទាំងឡាយមានកាមរាគៈជាដើមនោះនុ៎ះឯង ព្រោះអត្ថថា ទាញទៅក្នុងសាគរ គឺភព និង ព្រោះអត្ថថា ឆ្លងបានដោយកម្រ ។

ឯពាក្យថា “យោគៈ” ក៏ជាឈ្មោះនៃសង្កិលេសធម៌ទាំងឡាយនោះ



ដែរ ព្រោះមិនឲ្យព្រាត់ប្រាសចាកអារម្មណ៍និងព្រាត់ប្រាសចាកទុក្ខបាន។

(នីវរណៈ)

ធម៌ទាំងឡាយ៥ មានកាមច្ឆន្ទៈជាដើម ឈ្មោះថា នីវរណៈ ព្រោះអត្ថថា ហាមប្រាមចិត្ត រាំងចិត្ត បិទបាំងចិត្ត ។

(បរាមាសៈ)

ពាក្យថា “បរាមាសៈ” នុ៎ះ ជាឈ្មោះនៃការយល់ឃើញខុស ព្រោះប្រព្រឹត្តទៅ ដោយអាការៈ គឺការប្រព្រឹត្តិកន្លង នូវសភាវៈនៃធម៌នោះៗ ហើយ ទៅចាប់យកនូវសភាវៈដែលមិនពិត ដទៃទៀតទៅវិញ ។

(ឧបាទាន)

ឧបាទាន ៤ មានកាមុបាទានជាដើម ដែលលោកពោលហើយ ក្នុងបដិច្ចសមុប្បាទនិទ្ទេស ដោយអាការៈទាំងពួង ឈ្មោះថា ឧបាទាន ។

(អនុស័យ)

ធម៌ទាំងឡាយ ៧ មានកាមរាគៈជាដើម ដែលលោកបានពោលហើយ យ៉ាងនេះថា “អនុស័យគឺកាមរាគៈ អនុស័យគឺបដិឃៈ អនុស័យគឺមានះ អនុស័យគឺទិដ្ឋិ អនុស័យគឺវិចិកិច្ឆា អនុស័យគឺភវរាគៈ អនុស័យគឺអវិជ្ជា” ឈ្មោះថា អនុស័យ ព្រោះអត្ថថា កម្លាំង ។ មែនពិត ធម៌ទាំងនោះ រមែងដេកនៅរឿយៗ ក្នុងសន្តាន ព្រោះកិលេសទាំងឡាយមានកាមរាគៈជាដើម ជាហេតុកើតឡើងរឿយៗ ព្រោះជាកម្លាំងហ្នឹងឯង ព្រោះហេតុនោះ ទើបបានឈ្មោះថា អនុស័យ ។

(មលៈ)

ធម៌ ៣ គឺលោភៈ ទោសៈ មោហៈ ឈ្មោះថា មលៈ ព្រោះខ្លួនឯងក៏មិនបរិសុទ្ធផង និង ព្រោះធ្វើសេចក្តីមិនបរិសុទ្ធិ ដល់អ្នកដទៃទៀតផង

ដូចជាប្រេងថ្នាំបន្តក់ភ្នែក និង ភក់ យ៉ាងដូច្នោះឯង ។

(អកុសលកម្មបថ)

ធម៌ ១០ នេះ គឺ បាណាតិបាត អទិន្នាទាន កាមេសុមិច្ឆាចារ មុសាវាទ បិសុណាវាចា ផរុសវាចា សម្ផប្បលាប អភិជ្ឈា ព្យាបាទ មិច្ឆាទិដ្ឋិ ឈ្មោះថា អកុសលកម្មបថ ព្រោះជាអកុសលកម្មផង ព្រោះជាផ្លូវ នៃទុគ្គតិទាំងឡាយផង ។

(អកុសលចិត្តុប្បាទ)

ធម៌ ១២ នេះ គឺ ធម៌ជាលោភមូល៨ ទោសមូល២ មោហមូល២ ឈ្មោះថា អកុសលចិត្តុប្បាទ ។

ញាណ ៤ នុ៎ះ ជាអ្នកធ្វើនាទីលះនូវធម៌ទាំងឡាយមានសំយោជនៈជាដើមនុ៎ះ ដូចបានពោលមកហើយ តាមសមគួរដល់សេចក្ដីព្យាយាមជាគ្រឿងប្រកប ។

តើលះយ៉ាងដូចម្ដេច? ។ ពោលក្នុងសំយោជនៈជាមុនសិន ធម៌ ៥ នេះ គឺ សក្កាយទិដ្ឋិ, វិចិកិច្ឆា, សីលព្វតបរាមាសៈ, កាមរាគៈ និង បដិឃៈដែលជាផ្លូវនៃអបាយជាធម៌គឺញាណទី១ គប្បីសម្លាប់, កាមរាគៈ និង បដិឃៈដ៏សេសដែលគ្រោតគ្រាត ជាធម៌គឺញាណ ទី២ គប្បីសម្លាប់, ចំណែកខាងល្អិត ជាធម៌គឺញាណ ទី៣ គប្បីសម្លាប់, ធម៌ដែលមានរូបរាគៈ ជាដើមទាំង ៥ យ៉ាង ជាធម៌គឺញាណ ទី៤ គប្បីសម្លាប់តែម្យ៉ាង ។

តពីនេះទៅ ក្នុងទីណា ខ្ញុំនឹងមិនធ្វើនូវការកំណត់ដោយ ឯវៈ សព្ទ ក្នុងទីនោះ ខ្ញុំនឹងពោលពាក្យណាៗ ថា "ជាធម៌ គឺញាណថ្នាក់ខ្ពស់ គប្បីកំចាត់ ធម៌នោះៗ គប្បីជ្រាបថា: ជាធម៌ដែលមានដំណើរទៅកាន់អបាយជាដើម គឺញាណខាងដើមៗ គប្បីកំចាត់ហ្នឹងឯង ទើបជាធម៌ គឺញាណ



ថ្នាក់ខ្ពស់ គប្បីកំចាត់" ។

ក្នុងកិលេសទាំងឡាយ ទិដ្ឋិ វិចិកិច្ឆា ជាធម៌ គឺញាណ ទី១ គប្បីកំចាត់, ទោសៈ ជាធម៌គឺញាណទី៣ គប្បីកំចាត់, លោភៈ មោហៈ មានៈ ថីនៈ ឧទ្ធច្ចៈ អហិរិកៈ និង អនោត្តប្បៈ ជាធម៌គឺញាណទី៤ គប្បីកំចាត់។

ក្នុងមិច្ឆត្តៈទាំងឡាយ ធម៌ទាំងឡាយនេះ គឺ មិច្ឆាទិដ្ឋិ មុសាវាទ មិច្ឆាកម្មន្តៈ មិច្ឆាអាជីវៈ ជាធម៌គឺញាណ ទី១ គប្បីកំចាត់, ធម៌ទាំងនេះ គឺ មិច្ឆាសង្កប្បៈ បិសុណាវាចា ផរុសវាចា ជាធម៌ គឺញាណ ទី៣ គប្បីកំចាត់ ។ ចេតនា ប៉ុណ្ណោះ គប្បីជ្រាបថា "វាចា" ក្នុងទីនេះ ។

សម្ផប្បលាបៈ មិច្ឆាវាយាមៈ មិច្ឆាសតិ មិច្ឆាសមាធិ មិច្ឆាវិមុត្តិ មិច្ឆាញាណៈ ជាធម៌ គឺញាណ ទី៤ គប្បីកំចាត់ ។

ក្នុងលោកធម៌ទាំងឡាយ បដិឃៈ (ការថ្នាំងថ្នាក់) ជាធម៌គឺញាណ ទី៣ គប្បីកំចាត់, សេចក្ដីត្រេកអរ ជាធម៌គឺញាណ ទី៤ គប្បីកំចាត់ ។

អាចារ្យពួកខ្លះ ពោលថា "សេចក្ដីត្រេកអរ និង សេចក្ដីសរសើរ ជាធម៌ គឺញាណ ទី៤ គប្បីកំចាត់" ។

មច្ឆរិយៈ ទាំងឡាយ ជាធម៌ គឺញាណ ទី១ គប្បីកំចាត់ តែម្យ៉ាងប៉ុណ្ណោះ ។

ក្នុងវិបល្លាសទាំងឡាយ វិបល្លាសទាំងនេះ គឺ សញ្ញាវិបល្លាស ចិត្តវិបល្លាស ទិដ្ឋិវិបល្លាស ថា "ទៀង ក្នុងរបស់ដែលមិនទៀង ថាជាអត្តា ក្នុងរបស់ដែលជាអនត្តា" ដូច្នេះក្ដី, ទិដ្ឋិវិបល្លាស ថា "ជាសុខ ក្នុងរបស់ដែលជាទុក្ខ ថា ជារបស់ល្អ ក្នុងរបស់ដែលមិនល្អ" ដូច្នេះក្ដី, ជាធម៌ គឺញាណទី១ គប្បីកំចាត់, សញ្ញាវិបល្លាស និង ចិត្តវិបល្លាស ថា "ជាសុខ ក្នុងរបស់ដែលជាទុក្ខ" ជាធម៌ គឺញាណ ទី៤ គប្បីកំចាត់ ។

ក្នុងគណ្ឋៈទាំងឡាយ កាយគណ្ឋៈ គឺ : សីលព្វតបរាមាសៈ និង ឥទំសច្ចាភិនិវេសៈ (ការប្រកាន់ស្អិតថា របស់ពិត) ជាធម៌ គឺញាណ ទី១ គប្បីកំចាត់, កាយគណ្ឋៈ គឺព្យាបាទ ជាធម៌ គឺញាណ ទី៣ គប្បីកំចាត់, កាយគណ្ឋៈ ដទៃទៀត (គឺអភិជ្ឈា) ជាធម៌ គឺញាណ ទី៤ គប្បីកំចាត់ ។

អគតិ ជាធម៌ គឺញាណ ទី១ គប្បីកំចាត់ តែម្យ៉ាងប៉ុណ្ណោះ ។

ក្នុងអាសវៈទាំងឡាយ ទិដ្ឋាសវៈ ជាធម៌គឺញាណ ទី១ គប្បីកំចាត់, កាមាសវៈ ជាធម៌ គឺញាណ ទី៣ គប្បីកំចាត់, អាសវៈ ២ ក្រៅពីនេះ ជាធម៌ គឺញាណ ទី ៤ គប្បីកំចាត់ ។ សូម្បីក្នុងឱឃៈ និង យោគៈទាំងឡាយ ក៏មានន័យដូចគ្នានេះដែរ ។

ក្នុងនីវរណៈទាំងឡាយ វិចិកិច្ឆានីវរណៈ ជាធម៌គឺញាណទី១ គប្បីកំចាត់, នីវរណៈ៣ នេះ គឺ កាមច្ឆន្ទៈ ព្យាបាទៈ កុក្កុច្ចៈ ជាធម៌គឺញាណទី៣ គប្បីកំចាត់, ថីនមិទ្ធៈ និង ឧទ្ធច្ចៈ ជាធម៌គឺញាណទី៤ គប្បីកំចាត់ ។

បរាមាសៈ ជាធម៌ គឺញាណទី១ គប្បីកំចាត់ តែប៉ុណ្ណោះ ។

ក្នុងឧបាទានទាំងឡាយ សូម្បីរូបរាគៈ និង អរូបរាគៈ ក៏ឈ្មោះថា ធ្លាក់ទៅក្នុងឧបាទាន ព្រោះលោកិយធម៌ទាំងឡាយចាត់ទុកថា “ជាកាម” ដោយអំណាចនៃវត្ថុកាម ព្រោះហេតុនោះឯង កាមុបាទាននោះ ជាធម៌ គឺញាណ ទី៤ គប្បីកំចាត់, ឧបាទានដ៏សេស ជាធម៌ គឺញាណ ទី១ គប្បីកំចាត់ ។

ក្នុងអនុស័យទាំងឡាយ ទិដ្ឋានុស័យ និង វិចិកិច្ឆានុស័យ ជាធម៌ គឺញាណ ទី១ គប្បីកំចាត់, កាមរាគានុស័យ និង បដិឃានុស័យ ជាធម៌ គឺញាណ ទី៣ គប្បីកំចាត់, មានានុស័យ ភវរាគានុស័យ និង អវិជ្ជានុស័យ ជាធម៌ គឺញាណ ទី៤ គប្បីកំចាត់ ។



ក្នុងមន្ទិលទាំងឡាយ មន្ទិល គឺទោសៈ ជាធម៌ គឺញាណ ទី៣ គប្បីកំចាត់, មន្ទិលក្រៅអំពីនេះ ជាធម៌គឺញាណ ទី៤ គប្បីកំចាត់ ។

ក្នុងអកុសលកម្មបថទាំងឡាយ ធម៌ទាំងនេះ គឺ បាណាតិបាត អទិន្នាទាន កាមេសុមិច្ឆាចារ មុសាវាទ មិច្ឆាទិដ្ឋិ ជាធម៌ គឺញាណ ទី១ គប្បីកំចាត់, ធម៌ទាំងនេះ គឺ បិសុណាវាចា ផរុសវាចា ព្យាបាទ ជាធម៌ គឺញាណ ទី៣ គប្បីកំចាត់, សម្ផប្បលាបៈ និង អភិជ្ឈា ជាធម៌ គឺញាណ ទី៤ គប្បីកំចាត់ ។

ក្នុងអកុសលចិត្តុប្បាទទាំងឡាយ អកុសលចិត្តុប្បាទ៥ គឺ ដែលជាទិដ្ឋិសម្បយុត្ត៤ ជាវិចិកិច្ឆាសម្បយុត្ត១ ជាធម៌ គឺញាណទី១ គប្បីកំចាត់មែនពិត, ដែលជាបដិឃសម្បយុត្ត២ ជាធម៌ គឺញាណទី៣ គប្បីកំចាត់, សេសសល់ពីនេះ ជាធម៌ គឺញាណ ទី៤ គប្បីកំចាត់ដោយប្រការដូច្នេះ។

ក៏របស់ណា គឺញាណឯណា គប្បីកំចាត់, របស់នោះ ក៏ឈ្មោះថា គឺញាណនោះ គប្បីលះ ។ ហេតុនោះ ទើបខ្ញុំពោលថា “ញាណ ៤ នោះ ជាអ្នកធ្វើនាទីលះ នូវធម៌ទាំងឡាយ មានសំយោជនៈជាដើម ដូចពោលមកហើយ ដោយសមគួរដល់សេចក្តីព្យាយាមជាគ្រឿងប្រកប” ។

(មគ្គញ្ញាណ លះកិលេស នៅពេលណា)

(៤៦០) សួរថា “ក៏ញាណទាំងនេះ លះនូវធម៌ទាំងឡាយនោះ ដែលជាអតីត អនាគត ឬ ជាបច្ចុប្បន្ន?” ។

ឆ្លើយថា “ក៏នឹងគប្បីពោលអ្វីក្នុងរឿងនុ៎ះ ដំបូង ប្រសិនបើញាណទាំងនោះ លះនូវធម៌ទាំងឡាយដែលជាអតីត និង អនាគត, សេចក្តីព្យាយាម ក៏នឹងមិនបានផល ព្រោះហេតុអ្វី ព្រោះមិនមានធម៌ទាំងឡាយដែលត្រូវលះ ក្នុងទីនេះ រមែងលះនូវធម៌ដែលជាបច្ចុប្បន្ន ទោះជាយ៉ាង

ដូច្នោះ សេចក្តីព្យាយាម ក៏មិនមានផល ព្រោះធម៌ទាំងឡាយ ដែលត្រូវលះ ព្រមជាមួយគ្នានឹងសេចក្តីព្យាយាមនៅមាន ទាំងមគ្គភាវនា ក៏រមែងបានជាសង្កិលេសធម៌ ឬ កិលេសទាំងឡាយ ជាវិប្បយុត្ត, ក៏បច្ចុប្បន្នកិលេស ឈ្មោះថា ចិត្តវិប្បយុត្ត មិនមានទេ” ដូច្នេះ ។

ក៏ពាក្យចោទនេះ មិនមែនជាពាក្យដែលគិតមកថ្មីទេ ។ ព្រោះថាក្នុងបាលីនុ៎ះឯង ក៏លោកពោលហើយថា “ភិក្ខុនេះនោះ [1] តែងលះនូវកិលេសទាំងឡាយ គឺលះកិលេសទាំងឡាយ ដែលកន្លងទៅហើយ លះកិលេសទាំងឡាយដែលមិនទាន់មកដល់ លះកិលេសទាំងឡាយ ដែលកើតចំពោះមុខ” ដូច្នេះហើយ ពោលទៀតថា “បើលះកិលេសដែលកន្លងទៅហើយ មានតែញ៉ាំងកិលេសដែលអស់ទៅហើយឲ្យអស់ទៅ ញ៉ាំងកិលេសដែលរលត់ហើយឲ្យរលត់ ញ៉ាំងកិលេសដែលសាបសូន្យហើយឲ្យសាបសូន្យ ញ៉ាំងកិលេសដែលវិនាសហើយឲ្យវិនាស គឺថា កិលេសជាតឯណា ដែលកន្លងហើយ មិនមានទេ លះកិលេសជាតនោះ មែនឬ” ដូច្នេះហើយ បដិសេធថា “មិនលះកិលេសដែលកន្លងទៅហើយទេ” ។

និងន័យដូចគ្នានោះ លោកពោលថា “បើលះកិលេសដែលមិនទាន់មានមក មានតែលះកិលេសដែលមិនទាន់កើត លះកិលេសដែលមិនទាន់ដុះ លះកិលេសដែលមិនទាន់ផុសឡើង លះកិលេសដែលមិនទាន់កើតប្រាកដ គឺថា កិលេសជាតឯណា ដែលមិនទាន់មានមក មិនទាន់មានទេ លះកិលេសជាតនោះឬ” ដូច្នេះហើយ បដិសេធថា “មិនមែនលះកិលេស ដែលមិនទាន់មានមកទេ” ដូច្នេះ ។

និង ន័យដូចគ្នានោះដែរ លោកពោលថា “បើលះកិលេសដែលមិន

១- សុ. ខុ. បដិ. ភាគទី ៧១ ទំព័រទី ២៩២ ។



កើតចំពោះមុខ, មានតែភិក្ខុអ្នកត្រេកអរ លះរាគៈ, អ្នកប្រទុស្ត លះទោសៈ, អ្នកវង្វេង លះមោហៈ, អ្នកប្រកួតប្រកាន់ លះមានះ, អ្នកស្ទាបអង្អែល លះទិដ្ឋិ, អ្នកមានចិត្តរាយមាយលះឧទ្ធច្ចៈ, អ្នកដល់នូវការមិនដាច់ស្រេច លះវិចិកិច្ឆា, អ្នកមានកិលេសខ្លាំងក្លា លះអនុស័យ, គឺថា ធម៌ខ្មៅ និង ធម៌-ស តែងជាប់គ្នាជាគូ ប្រព្រឹត្តទៅ, មគ្គភាវនា ប្រកបដោយសេចក្តីសៅហ្មង ដោយធម៌ទាំង ២ នោះ ឬ” ទើបបដិសេធទាំងអស់ថា “មិនមែនលះកិលេសដែលកន្លងទៅហើយ មិនមែនលះកិលេសដែលមិនទាន់មានមក មិនមែនលះកិលេសដែលកើតមានចំពោះមុខទេ” ដូច្នេះ, កាលបើបញ្ចប់ក្រោយថា “បើដូច្នោះ មានតែមគ្គភាវនា មិនមាន, ការធ្វើឲ្យជាក់ច្បាស់នូវផលមិនមាន, ការលះកិលេស មិនមាន, ការត្រាស់ដឹងធម៌ មិនមានមែនឬ” ដូច្នេះ ទើបលោកប្តេជ្ញាថា “មិនមែនដូច្នោះទេ, [1] មគ្គភាវនា មាន ។ល។ ការត្រាស់ដឹងធម៌ មាន” ដូច្នេះហើយពោលថា “ឧបមាដូចជាអ្វី” ទើបលោកពោលពាក្យនេះថា “ដូចជាដើមឈើជំទង់មិនទាន់មានផ្លែ បុរស កាត់ផ្តាច់ឈើនោះ នៅត្រង់គល់ឯអជាតផលណា របស់ឈើនោះដែលមិនទាន់ចេញក៏លែងចេញ ដែលមិនទាន់កើត ក៏លែងកើត ដែលមិនទាន់ពក ក៏លែងពក ដែលមិនទាន់កើតប្រាកដក៏លែងកើតប្រាកដ មានឧបមាដូចម្តេចមិញ, មានឧបមេយ្យដូចការកើតជាហេតុ ការកើតជាបច្ច័យ នៃការកើតកិលេស, ចិត្ត តែងស្ទុះទៅក្នុងការមិនកើត ព្រោះឃើញទោស ក្នុងការកើត ព្រោះតែចិត្តស្ទុះទៅ ក្នុងការមិនកើត បានជាកិលេសទាំងឡាយណា ដែលមានការកើតឡើងជាបច្ច័យ គប្បីកើតឡើង, កិលេសទាំងឡាយនោះ ដែលមិនទាន់

១- សុ. ខុ. បដិ. ភាគទី ៧១ ទំព័រទី ២៩៤ ។

កើត ក៏លែងកើត ។ល។ ដែលមិនកើតប្រាកដ ក៏លែងកើតប្រាកដ, ការរលត់ទុក្ខ(មាន) ព្រោះការរលត់ហេតុ យ៉ាងនេះឯង, ហេតុ គឺការប្រព្រឹត្តិទៅ ហេតុ គឺនិមិត្ត ហេតុ គឺការប្រមូលមក ឯការប្រមូលមក ជាបច្ច័យនៃការកើតកិលេស, ចិត្ត តែងស្ទុះទៅ ក្នុងការមិនប្រមូលមក បានជាកិលេសទាំងឡាយឯណា ដែលមានការប្រមូលមកជាបច្ច័យ គប្បីកើត កិលេសទាំងនោះ ដែលមិនទាន់កើត ក៏លែងកើត ដែលមិនទាន់ដុះ ក៏លែងដុះ ដែលមិនទាន់ផុសឡើង ក៏លែងផុសឡើង ដែលមិនទាន់កើតប្រាកដ ក៏លែងកើតប្រាកដ, ការរលត់ទុក្ខ (មាន) ព្រោះការរលត់ហេតុយ៉ាងនេះឯង, មគ្គភាវនា មាន, ការធ្វើឲ្យជាក់ច្បាស់នូវផល មាន, ការលះនូវកិលេស មាន, ការត្រាស់ដឹងនូវធម៌ មាន យ៉ាងនេះឯង” ដូច្នេះ ។

សួរថា “ដោយពាក្យថា កិលេសទាំងឡាយដែលមិនទាន់កើត ក៏លែងកើត ជាដើមនេះ តើលោកសំដែងអំពីអ្វី?” ។ ឆ្លើយថា “លោកសំដែងការលះនូវកិលេសដែលបាននូវភូមិ” ។ សួរថា “ក៏កិលេសទាំងឡាយដែលបានភូមិ ជាអតីត អនាគាត ឬក៏ ជាបច្ចុប្បន្ន?” ។ ឆ្លើយថា “កិលេសទាំងនោះ ឈ្មោះថា កើតឡើង ព្រោះបាននូវភូមិនុ៎ះឯង” ។

មែនពិត របស់ដែលកើតឡើងហើយ មានច្រើនប្រភេទ ដោយអំណាចនៃវត្តមានៈ(ដែលកំពុងប្រព្រឹត្តទៅ) ភូតាបគតៈ (មានមកហើយប្រាសចាកទៅវិញ) ឱកាសកតៈ (ធ្វើឱកាស) ភូមិលទ្ធៈ (បាននូវភូមិ) ។

ក្នុងឧប្បន្នៈទាំងនោះ របស់ទាំងពួងដែលរាប់បានថា ប្រកបព្រមដោយកិរិយាកើតឡើង ការទ្រុឌទ្រោម និង ការបែកធ្លាយ ឈ្មោះថា វត្តមានុប្បន្នៈ (គឺកើតឡើងដោយនៅមានការប្រព្រឹត្តិទៅ) ។

កុសល និង អកុសលដែលសោយ នូវអារម្មណ៍ហើយ រលត់ទៅ



វិញ ដែលរាប់ថា ភូតាបគតៈ (គឺសោយហើយប្រាសចាកទៅ)ក្តី កុសល និងអកុសលដែលជាសង្ខតៈដ៏សេស ដល់នូវលក្ខណៈ៣ មានការកើតឡើងជាដើម ដោយលំដាប់ហើយ ក៏រលត់ទៅវិញ ដែលរាប់ថា ភូតាប-គតៈ (គឺមានមកហើយ ប្រាសចាកទៅ) ក្តី ឈ្មោះថា ភូតាបគតុប្បន្នៈ (កើតឡើងហើយ មានហើយប្រាសចាកទៅ) ។ កម្មដែលលោកពោលហើយ ដោយន័យថា “កម្មទាំងឡាយនោះឯណា ជាកម្ម គឺបុគ្គលនោះធ្វើហើយក្នុងកាលមុន” ដូច្នេះជាដើម សូម្បីកម្មជាអតីតៈ ក៏ឈ្មោះថា ឱកាសកតុប្បន្នៈ (កើតឡើងដោយធ្វើឱកាស) ព្រោះហាមនូវវិបាកដទៃទៀត ហើយធ្វើឱកាសឲ្យដល់វិបាករបស់ខ្លួនហើយតាំងនៅ, និង ន័យដូចគ្នានោះដែរ វិបាកដែលមានឱកាស ដែលកម្មធ្វើហើយ សូម្បីជាវិបាកដែលមិនទាន់កើតឡើង ក៏ឈ្មោះថា ឱកាសកតុប្បន្នៈ (កើតឡើងដោយមានឱកាស គឺកម្មធ្វើហើយ) ព្រោះកាលបើឱកាស គឺកម្មធ្វើហើយយ៉ាងនោះ ក៏កើតឡើង ដោយពិត ។

អកុសល ដែលមិនទាន់ដកចេញហើយ ក្នុងភពទាំងឡាយនោះៗ ឈ្មោះថា ភូមិលទ្ធុប្បន្នៈ (គឺកើតឡើង ដោយបាននូវភូមិ) ។

(ការផ្សេងគ្នានៃភូមិ និង ភូមិលទ្ធៈ)

ក៏ក្នុងរឿងនេះ បណ្ឌិតគប្បីជ្រាបការផ្សេងគ្នានៃភូមិ និងភូមិលទ្ធៈ។ ក៏បញ្ចក្ខន្ធ ដែលប្រព្រឹត្តទៅក្នុងភូមិ៣ ជាអារម្មណ៍នៃវិបស្សនា ឈ្មោះថា ភូមិ ។ កិលេសជាតដែលគួរដល់ការកើតឡើង ក្នុងខន្ធទាំងឡាយនោះ ឈ្មោះថា ភូមិលទ្ធៈ ព្រោះភូមិនោះ ឈ្មោះថា ជាភូមិគឺកិលេសជាតនោះ បានហើយ ព្រោះហេតុនោះ កិលេសជាតនោះ ទើបឈ្មោះថា ភូមិលទ្ធៈ ។

តែភូមិនោះ មិនមែនបានដោយអំណាចនៃអារម្មណ៍ទេ ។ តាមពិត ព្រោះប្រារព្ធនូវខន្ធទាំងឡាយ សូម្បីដែលជាអតីតៈ និង អនាគតទាំងពួង និង ខន្ធរបស់ព្រះខីណាស្រពទាំងឡាយ សូម្បីជាខន្ធដែលលោកបានកំណត់ដឹងហើយ ដោយអំណាចនៃអារម្មណ៍ កិលេសទាំងឡាយរមែងកើតឡើងបាន ដូចកិលេសកើតដល់សោរេយ្យសេដ្ឋី និង នន្ទមាណពជាដើម ព្រោះប្រារព្ធនូវខន្ធទាំងឡាយរបស់ព្រះមហាកច្ចាយនៈ និង នាងឧប្បលវណ្ណាជាដើម យ៉ាងនោះឯង ។ មួយទៀត បើកិលេសជាតនោះគប្បីបានឈ្មោះថា ភូមិលទ្ធៈ, អ្នកណាមួយ ក៏មិនគប្បីលះនូវមូល នៃភពបានឡើយ ព្រោះកិលេសជាតនោះខ្ជួនមិនគប្បីលះបង់បាន ។

តែភូមិលទ្ធៈ បណ្ឌិតគប្បីជ្រាប ដោយអំណាចនៃវត្ថុ ។ សេចក្ដីថា ខន្ធទាំងឡាយដែលមិនបានកំណត់ដឹង ដោយវិបស្សនា រមែងកើតឡើងក្នុងភពណាៗ បន្ទាប់ពីការកើតឡើងក្នុងភពនោះៗ កិលេសជាតដែលជាមូលនៃវដ្ដៈ តែងដេករឿយៗក្នុងខន្ធទាំងឡាយនោះ កិលេសជាតនោះគប្បីជ្រាបថា ឈ្មោះថា ជាភូមិលទ្ធៈ (គឺបាននូវភូមិ) ដោយអត្ថ គឺលះមិនទាន់បាន ។ មួយទៀត ក្នុងខន្ធទាំងឡាយដែលជាភូមិនោះ កិលេសទាំងឡាយដែលដេកត្រាំនៅ ដោយអត្ថថា លះមិនទាន់បាន ក្នុងខន្ធទាំងឡាយណា របស់បុគ្គលណា មាន, ខន្ធទាំងឡាយនោះ របស់បុគ្គលនោះប៉ុណ្ណោះ ជាវត្ថុនៃកិលេសទាំងឡាយនោះ, ខន្ធទាំងឡាយដែលជារបស់អ្នកដទៃ មិនមែនជាវត្ថុទេ ។ ម្យ៉ាងទៀត ខន្ធដែលជាអតីតទាំងឡាយប៉ុណ្ណោះ ជាវត្ថុនៃកិលេសទាំងឡាយ ដែលដេកត្រាំងនៅ ក្នុងសន្ដានដោយអត្ថថា លះមិនទាន់បានក្នុងខន្ធដែលជាអតីតៈទាំងឡាយ, ខន្ធទាំងឡាយក្រៅពីនេះ មិនមែនជាវត្ថុទេ ។ ក្នុងខន្ធ ដែលជាអនាគតជាដើម



ក៏មានន័យដូចគ្នានេះដែរ ។ ន័យដូចគ្នានោះដែរ កាមាវចរខន្ធទាំងឡាយប៉ុណ្ណោះ ជាវត្ថុនៃកិលេសទាំងឡាយដែលដេកត្រាំនៅក្នុងសន្ដាន ដោយអត្ថថា លះមិនទាន់បាន ក្នុងកាមាវចរទាំងឡាយ, ខន្ធទាំងឡាយដទៃទៀត មិនមែនជាវត្ថុទេ ។ ក្នុងរូបាវចរខន្ធ និង អរូបាវចរខន្ធ ក៏ន័យនេះដែរ ។

ចំណែកក្នុងព្រះអរិយបុគ្គល មានព្រះសោតាបន្នជាដើម កិលេសជាត ដែលជាមូលនៃវដ្ដនោះៗ ក្នុងខន្ធទាំងឡាយ របស់ព្រះអរិយបុគ្គលណាៗ គឺលោកលះបានហើយ ដោយមគ្គនោះៗ, ខន្ធទាំងឡាយនោះៗ របស់ព្រះអរិយបុគ្គលនោះៗ មិនបានឈ្មោះថា “ភូមិ” ព្រោះមិនមែនជាវត្ថុនៃកិលេស ដែលជាមូលនៃវដ្ដៈទាំងឡាយនោះៗ ដែលលោកលះបានហើយ ។

ព្រោះកិលេសជាមូលនៃវដ្ដៈទាំងឡាយ គឺបុថុជ្ជន លះមិនទាន់បានដោយប្រការទាំងពួង កម្មដែលបុថុជ្ជនធ្វើឯណាមួយ ទើបជាកុសល ឬអកុសល ។ វដ្ដៈរបស់បុថុជ្ជននោះ តែងវិលត្រឡប់ ព្រោះបច្ច័យ គឺកម្ម និង កិលេស ដោយប្រការដូច្នេះ ។

កិលេសជាត ដែលជាមូលនៃវដ្ដៈនុ៎ះ របស់បុថុជ្ជននោះ មិនគួរពោលថា “កិលេសជាតនោះ ដេកត្រាំនៅក្នុងសន្ដាន ក្នុងរូបក្ខន្ធប៉ុណ្ណោះទេ មិនបានដេកត្រាំនៅ ក្នុងខន្ធដទៃផ្សេងទៀត មានវេទនាខន្ធជាដើមឡើយ ។ល។ ឬថា វាដេកត្រាំនៅ ក្នុងវិញ្ញាណក្ខន្ធ តែប៉ុណ្ណោះឯងមិនបានដេកត្រាំនៅក្នុងខន្ធឯទៀតៗ មានរូបក្ខន្ធជាដើមឡើយ” ។ ព្រោះហេតុអ្វី? ។ ព្រោះវាបានដេកត្រាំនៅក្នុងខន្ធទាំង៥ ដោយមិនខុសគ្នា ។ ពាក្យនោះ មានឧបមាដូចម្ដេច? ។ មានឧបមាដូចជារសជីជាដើម ក្នុង

ដើមឈើ ។ ប្រៀបឧបមាបីដូចជា កាលបើដើមឈើធំ ដុះនៅលើផែនដី អាស្រ័យរសជាតិដី និង រសជាតិទឹក ព្រោះមានរសជាតិដី និង ទឹក ជាបច្ច័យ ក៏លូតលាស់ដុះដាល ដោយឫស គល់ មែកតូចធំ ពន្លក ស្លឹក ផ្កា ផ្លែ ពេញអាកាស តពូជជាដើមឈើ ដោយការតភ្ជាប់គ្នាជាពូជ តាំងនៅ រហូតដល់អវសាននៃកប្ប, រសជាតិដីជាដើមនោះ មិនគួរពោលថា “វាជ្រាបចូលទៅក្នុងឫសតែប៉ុណ្ណោះឯងមិនបានជ្រាបចូលទៅ ក្នុងរបស់អ្វីទៀត មានគល់ឈើជាដើមទេ ។ល។ ឬថា វាជ្រាបចូលក្នុងផ្លែ តែប៉ុណ្ណោះឯង មិនបានជ្រាបចូលទៅ ក្នុងរបស់ផ្សេងៗ ទៀត មានឫសជាដើមទេ” ដូច្នេះឡើយ ។ ព្រោះហេតុអ្វី? ។ ព្រោះវាជ្រាបចូលទៅ ក្នុងអវយវៈទាំងឡាយ មានឫសជាដើមទាំងអស់ ដោយមិនប្លែកគ្នាឡើយ យ៉ាងណាមិញ ។

មួយទៀត ប្រៀបដូចជាបុរសខ្លះ ជាអ្នកនឿយណាយ ក្នុងផ្កា និង ផ្លែជាដើម នៃដើមឈើនោះឯង គប្បីបោះបន្ទាពិស (បង្គោលពិស) ឈ្មោះថា មណ្ឌូកកណ្តកៈ ចូលក្នុងទិសទាំង៤, គ្រានោះ ដើមឈើនោះ ត្រូវសម្ផស្សនៃពិសនោះ ពាល់ត្រូវហើយ ក៏ដល់នូវការមិនបញ្ចេញផលមកជាធម្មតា មិនអាចញ៉ាំងការបន្តពូជ(ជាឈើ) ឲ្យកើតឡើងទៀតបាន ព្រោះតែរសជាតិដី និង រសជាតិទឹក អស់កម្លាំងហើយ យ៉ាងណាមិញ, កុលបុត្រ អ្នកធុញទ្រាន់នឿយណាយ ក្នុងការប្រព្រឹត្តិទៅនៃខន្ធ ក៏យ៉ាងដូច្នោះដែរ ចាប់ផ្តើមចំរើនមគ្គ៤ ក្នុងសន្តានរបស់ខ្លួន ដូចជាការបញ្ចូលពិសទៅក្នុងដើមឈើ ត្រង់ទិសទាំង៤ របស់បុរសនោះ យ៉ាងនោះឯង, ក្នុងគ្រានោះ ខន្ធសន្តាននោះនៃកុលបុត្រនោះ ត្រូវសម្ផស្សនៃពិស គឺមគ្គ ៤ នោះ ពាល់ត្រូវហើយ ជាសន្តានមានការបែកធ្លាយ នៃកម្មទាំងពួង



មានកាយកម្មជាដើម ដោយចូលទៅដល់ភាពត្រឹមតែជាកិរិយា មកដល់នូវការមិនកើតក្នុងភពថ្មីជាធម្មតា តទៅទៀតបាន មិនអាចញ៉ាំងការតភ្ជាប់ ក្នុងភពឯទៀត ឲ្យកើតឡើងបានឡើយ ព្រោះកិលេសដែលជាមូលនៃវដ្តៈទាំងឡាយ អស់កម្លាំងហើយ ដោយប្រការទាំងពួង ជាអ្នកមិនមានសេចក្តីប្រកាន់មាំ បរិនិព្វាន ព្រោះការរលត់នូវវិញ្ញាណចុងក្រោយ ដូចជាភ្លើងរលត់ហើយ យ៉ាងនោះឯង ។

សេចក្តីផ្សេងគ្នា នៃភូមិ និង ភូមិលទ្ធៈ គប្បីជ្រាប ដូចបានពោលមកហើយនេះឯង ។

(ឧប្បន្នៈ ៤ ផ្សេងទៀត)

ន័យមួយទៀត នៅមានឧប្បន្នៈ៤ យ៉ាងផ្សេងទៀត គឺសមុទាចារៈ, អារម្មណាធិគ្គហិតៈ, អវិក្ខម្ភិតៈ និង អសមូហតៈ ។

ក្នុងឧប្បន្នៈ៤ នោះ សមុទាចារុប្បន្នៈ (កើតឡើងដោយការប្រព្រឹត្តិឡើងព្រម) ក៏គឺការកើតឡើង ដោយការប្រព្រឹត្តិទៅហ្នឹងឯង ។

ចំណែកកិលេសជាត សូម្បីមិនទាន់កើតឡើង ព្រោះអារម្មណ៍ដែលមកកាន់រង្វង់នៃទ្វារមានចក្ខុជាដើម ក្នុងចំណែកខាងដើម ក៏ហៅថា អារម្មណាធិគ្គហិតុប្បន្នៈ (គឺកើតឡើង ដោយចាប់យកអារម្មណ៍) ព្រោះចាប់យកអារម្មណ៍ហ្នឹងឯង ទើបវាកើតឡើងដោយពិតប្រាកដ ក្នុងពេលក្រោយមក ដូចជាកិលេសជាត កើតឡើងដល់ព្រះមហាតិស្សត្ថេរ អ្នកត្រាច់ទៅបិណ្ឌបាត ក្នុងស្រុកកល្យាណគ្រាម ព្រោះឃើញរូបដែលជាវិសភាគារម្មណ៍ ដូច្នោះ ។

កិលេសជាត ដែលមិនទាន់បានគ្របសង្កត់ហើយ ដោយអំណាចសមថៈ និង វិបស្សនាទាំងឡាយ ឯណាមួយ សូម្បីមិនទាន់បានឡើង

កាន់ចិត្តសន្តតិ ក៏ឈ្មោះថា អវិក្ខម្ភិតុប្បន្នៈ (កើតឡើង ដោយមិនបានគ្របសង្កត់) ព្រោះមិនមានហេតុដែលសំរាប់ការពាររារាំងការកើត ។

តែកិលេសជាត សូម្បីសង្កត់សង្កិនបានហើយ ដោយអំណាច នៃសមថៈ និង វិបស្សនា ក៏ហៅថា អសមូហតុប្បន្នៈ (កើតឡើងដោយមិនបានដកចេញ) ព្រោះហេតុដែលមិនបានដកចេញ ដោយអរិយមគ្គ មិនកន្លងនូវការកើតឡើងជាធម្មតាបាន ដូចជាកិលេសជាត ដែលកើតឡើងដល់ព្រះថេរៈ ដែលបានសមាបត្តិ៨ កំពុងហោះទៅ តាមអាកាស ព្រោះបានឮសំឡេងច្រៀង របស់មាតុគ្រាមដែលបេះផ្កាឈើ នៅក្រោមដើមឈើ ដែលមានផ្កាក្បែរព្រៃ ច្រៀងបណ្តើរៗ ដោយសំឡេងយ៉ាងពិរោះ យ៉ាងនោះឯង ។

ក៏អារម្មណាធិគ្គហិតុប្បន្នៈ អវិក្ខម្ភិតុប្បន្នៈ និង អសមូហតុប្បន្នៈ ទាំង៣ នុ៎ះ គប្បីជ្រាបថា "ដល់នូវការសេង្គ្រោះ ក្នុងភូមិលទ្ធៈហ្នឹងឯង" ។ ក្នុងឧប្បន្នៈ មានប្រការដូចពោលមកហើយនេះនោះ ឧប្បន្នៈ ៤ ប្រការ ពោលគឺវត្តមានុប្បន្នៈ ភូតាបគតុប្បន្នៈ ឱកាសកតុប្បន្នៈ សមុទាចា-រុប្បន្នៈ នុ៎ះឯណា, ឧប្បន្នៈ ៤ នោះ មិនមែនជារបស់ដែលញាណឯណាមួយ គប្បីលះបានឡើយ ព្រោះមិនមែនជារបស់ដែលមគ្គគប្បីកំចាត់ ។ ចំណែកឧប្បន្នៈ (៤) ពោលគឺភូមិលទ្ធុប្បន្នៈ អារម្មណាធិគ្គហតុប្បន្នៈ អវិក្ខម្ភិតុប្បន្នៈ និង អសមូហតុប្បន្ន នុ៎ះឯណា, ឧប្បន្នៈ (៤) ទាំងអស់នោះ ជារបស់ដែលញាណគប្បីលះ ព្រោះហេតុដែលលោកិយញាណ និង លោកុត្តរញាណនោះៗ ញុំាងភាវៈនៃការកើតឡើងនោះៗ នៃឧប្បន្នៈទាំង ៤ នោះ ឲ្យវិនាសទៅ ទើបកើតឡើង ។

បណ្ឌិត គប្បីជ្រាបការលះ នូវធម៌ទាំងឡាយ ដែលញាណ ឯណា



គប្បីលះផងដែរ ក្នុងញាណទស្សនវិសុទ្ធិនេះ ដោយប្រការដូច្នេះ ។

**(កិច្ចក្នុងអរិយសច្ចៈ)**

(៤៦១) ពាក្យថា "នឹងគប្បីជ្រាបកិច្ចមានបរិញ្ញាកិច្ចជាដើម ដែលលោកពោលហើយ ក្នុងពេលត្រាស់ដឹង តាមសភាពគ្រប់ប្រការ" មានសេចក្តីថា: កិច្ច ៤ ៗ មានបរិញ្ញាកិច្ច ជាដើមនោះ គឺ បរិញ្ញា (ការកំណត់ដឹង) បហានៈ (ការលះ) សច្ឆិកិរិយា (ការធ្វើឲ្យជាក់ច្បាស់) ភាវនា (ការចំរើន) ដែលលោកពោលហើយ ដោយលក្ខណៈ ជាមួយគ្នា ក្នុងញាណទាំង ៤ នោះ ញាណមួយៗ ក្នុងកាលត្រាស់ដឹងនូវសច្ចៈ, កិច្ចទាំងឡាយនោះ បណ្ឌិតគប្បីជ្រាប តាមសភាព ។

**(មគ្គញ្ញាណ ធ្វើកិច្ចដូចប្រទីប)**

មែនពិត ពាក្យនោះ បុរាណាចារ្យទាំងឡាយ ពោលថា "ប្រទីប (ចង្កៀង) រមែងធ្វើកិច្ច ៤ យ៉ាង ដោយលក្ខណៈជាមួយគ្នា មិនមុន មិនក្រោយ គឺដុតប្រឆេះឲ្យឆេះ កំចាត់ងងឹត ធ្វើពន្លឺឲ្យភ្លឺច្បាស់ បឺត (ជប់) ប្រេង ក្នុងខណៈជាមួយគ្នា យ៉ាងណា, ចំណែកមគ្គញ្ញាណ ត្រាស់ដឹងនូវសច្ចៈ ៤ យ៉ាង គឺត្រាស់ដឹងកំណត់ទុក្ខ ១ ត្រាស់ដឹងដោយកិរិយាលះបង់នូវសមុទយៈ ១ ត្រាស់ដឹងដោយកិរិយាចំរើនមគ្គ១ ត្រាស់ដឹងដោយកិរិយាធ្វើឲ្យជាក់ច្បាស់នូវនិរោធ ១ ក្នុងខណៈជាមួយគ្នា មិនមុន មិនក្រោយ ក៏យ៉ាងនោះដែរ ។ សួរថា "មានអធិប្បាយដូចម្តេច?" ។ ឆ្លើយថា "មានអធិប្បាយថា ព្រះយោគាវចរ ធ្វើនិរោធឲ្យជាអារម្មណ៍ហើយសំរេច គឺឃើញ ត្រាស់ដឹងនូវសច្ចៈទាំង ៤" ដូច្នេះ ។ សមដូចជាព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយថា "ម្នាលភិក្ខុទាំងឡាយ [១] បុគ្គលណា

១- សុ. សំ. មហា. ភាគទី ៣៩ ទំព័រទី ២៧១ ។

ឃើញទុក្ខ, បុគ្គលនោះ ឈ្មោះថា ឃើញទុក្ខសមុទ័យផង ឃើញទុក្ខនិរោធផង ឃើញទុក្ខនិរោធគាមិនីបដិបទាផង” ដូច្នេះជាដើម ។ ព្រះពុទ្ធវចនៈទាំងពួង បណ្ឌិត គប្បីជ្រាបផង ។ សូម្បីពាក្យបាលីដទៃទៀត ក៏ព្រះអង្គ ត្រាស់ហើយ ថា “ញាណ [1] របស់បុគ្គល ដែលប្រកបព្រម ដោយមគ្គ ឈ្មោះថា ទុក្ខញាណផង ឈ្មោះថា ទុក្ខសមុទយញាណផង ឈ្មោះថា ទុក្ខនិរោធញាណផង ឈ្មោះថា ទុក្ខនិរោធគាមិនីបដិបទាញាណផង” ដូច្នេះ ។

ក្នុងពាក្យឧបមានោះ គប្បីជ្រាបការប្រៀបធៀបនៃឧបមា យ៉ាងនេះ គឺ មគ្គញាណ កំណត់ដឹងនូវទុក្ខ ដូចជាប្រទីបដុតប្រឆេះឲ្យឆេះ លះបង់នូវសមុទយៈ ដូចជាប្រទីបកំចាត់នូវងងឹត ញុំាងមគ្គ ពោលគឺធម៌ មានសម្មាសង្កប្បៈជាដើម ឲ្យចំរើនឡើងដោយភាពជាបច្ច័យ មានសហជាតិបច្ច័យជាដើម ដូចជាប្រទីបធ្វើពន្លឺឲ្យភ្លឺច្បាស់ ធ្វើនិរោធ គឺការអស់ទៅនៃកិលេស ឲ្យជាក់ច្បាស់ ដូចជាប្រទីបជក់ប្រេងឲ្យអស់ទៅ ។

(មគ្គញ្ញាណ ធ្វើកិច្ចដូចព្រះអាទិត្យ)

ន័យម្យ៉ាងទៀត ព្រះអាទិត្យ កាលរះឡើង ធ្វើកិច្ច ៤ យ៉ាង ព្រមទាំងភាពប្រាកដឡើង មិនមុន មិនក្រោយ គឺបំភ្លឺរូបភាពទាំងឡាយ ឲ្យភ្លឺស្វាង កំចាត់បង់នូវងងឹត បញ្ចេញនូវពន្លឺ ធ្វើសេចក្តីត្រជាក់ ឲ្យស្ងប់រម្ងាប់ យ៉ាងណា, មគ្គញ្ញាណ ។ល។ ត្រាស់ដឹង ដោយកិរិយាធ្វើឲ្យជាក់ច្បាស់នូវនិរោធ ក៏យ៉ាងនោះដែរ ។ សូម្បីក្នុងពាក្យឧបមានេះ ក៏គប្បីជ្រាបការប្រៀបធៀបឧបមា យ៉ាងនេះ គឺៈ មគ្គញ្ញាណ កំណត់ដឹងទុក្ខ ដូចព្រះអាទិត្យ ធ្វើរូបភាពទាំងឡាយឲ្យភ្លឺស្វាង លះសមុទយៈ ដូច

[1] ១- សុ. ខុ. បដិ. ភាគទី ៦៩ ទំព័រទី ២៦៧ ។



ព្រះអាទិត្យ កំចាត់បង់នូវងងឹត ញុំាងមគ្គឲ្យចំរើន ដោយភាពជាបច្ច័យ មានសហជាតិបច្ច័យជាដើម ដូចព្រះអាទិត្យ បញ្ចេញនូវពន្លឺ ធ្វើនិរោធ គឺការរម្ងាប់កិលេស ឲ្យជាក់ច្បាស់ ដូចជាព្រះអាទិត្យ ធ្វើសេចក្តីត្រជាក់ ឲ្យស្ងប់រម្ងាប់ ។

(មគ្គញ្ញាណ ធ្វើកិច្ចដូចនាវាចំលងញ)

មួយទៀត នាវាធ្វើកិច្ច ៤ យ៉ាង ដោយខណៈជាមួយគ្នា មិនមុន មិនក្រោយ គឺលះត្រើយខាងអាយ កាត់ខ្សែ(ទឹក) នាំយកភណ្ឌៈ ទៅជាក់ដល់ត្រើយខាងនាយ យ៉ាងណាមិញ, មគ្គញ្ញាណ ។ល។ ត្រាស់ដឹង ដោយកិរិយាធ្វើឲ្យជាក់ច្បាស់នូវនិរោធ ក៏យ៉ាងនោះដែរ ។ សូម្បីក្នុងឧបមានេះ ក៏គប្បីជ្រាបការប្រៀបធៀបឧបមា យ៉ាងនេះ គឺៈ មគ្គញ្ញាណ កំណត់ដឹងទុក្ខ ដូចនាវា លះត្រើយខាងអាយ លះសមុទយៈ ដូចជានាវាកាត់)ខ្សែ(ទឹក) ញុំាងមគ្គ ឲ្យចំរើន ដោយសហជាតិបច្ច័យជាដើម ដូចនាវា នាំភណ្ឌៈទៅ ធ្វើនិរោធ គឺត្រើយខាងនាយ ឲ្យជាក់ច្បាស់ ដូចជានាវា ទៅដល់ត្រើយខាងនាយ យ៉ាងដូច្នោះឯង ។

(ត្រាស់ដឹងអរិយសច្ចៈ ដោយអាការៈ ១៦)

ក៏កាលបើមគ្គនោះ មានញាណដែលប្រព្រឹត្តទៅ ដោយអំណាចកិច្ច ៤ យ៉ាង ដោយខណៈជាមួយគ្នា ក្នុងកាលត្រាស់ដឹងនូវសច្ចៈ ដូចពោលមកហើយនេះ, សច្ចៈទាំង៤ នុ៎ះឯង ជាទីត្រាស់ដឹងតែមួយ ដោយអត្ថថា ជារបស់ពិត ដោយអាការៈ ១៦ យ៉ាង ។ ដូចបាលីថា “សច្ចៈទាំង ៤ ជាទីត្រាស់ដឹងតែមួយ [1] ដោយអត្ថថា ជារបស់ពិត តើដូចម្តេច? ។ សច្ចៈទាំង៤ ជាទីត្រាស់ដឹងតែមួយ ដោយអត្ថថា ជារបស់ពិត

[1] ១- សុ. ខុ. បដិ. ភាគទី ៧១ ទំព័រទី ៨៩ ។

ដោយអាការៈ ១៦ យ៉ាង គឺ ទុក្ខ មានអត្ថថា បៀតបៀន ១ មានអត្ថថា បច្ច័យប្រជុំតាក់តែង១ មានអត្ថថាក្ដៅក្រហាយ១ មានអត្ថថាប្រែប្រួល១ ជាអត្ថទៀង, សមុទយៈ មានអត្ថថាប្រមូលមក ១ មានអត្ថថាហេតុ ១ មានអត្ថថា ប្រកបទុក១ មានអត្ថថា កង្វល់១ ជាអត្ថថា ទៀង, និរោធ មានអត្ថថា រលាស់ចេញ១ មានអត្ថថា ស្ងប់ស្ងាត់១ មានអត្ថថា មិនមានបច្ច័យប្រជុំតាក់តែង១ មានអត្ថថា មិនស្លាប់១ ជាអត្ថថា ទៀង, មគ្គ មានអត្ថថា ស្រោចស្រង់១ មានអត្ថថា ជាហេតុ១ មានអត្ថថា ឃើញ១ មានអត្ថថា ជាអធិបតី១ ជាអត្ថថា ទៀង, នេះសច្ចៈទាំង៤ ដោយអត្ថថា ទៀង ដោយអាការៈ១៦ យ៉ាង ដែលលោកសង្គ្រោះយកតែមួយ សច្ចៈណា ដែលសង្គ្រោះយកតែមួយ សច្ចនោះមានភាពតែមួយ, បុគ្គលរមែងត្រាស់ដឹងនូវសច្ចៈដែលមានភាពតែមួយ ដោយញាណមួយ ហេតុនោះ សច្ចៈ ទាំង ៤ ឈ្មោះថា ជាទីត្រាស់ដឹងតែមួយ" ដូច្នេះ ។

ក្នុងរឿងនោះ បើមានពាក្យសួរថា "អត្ថទាំងឡាយដទៃៗទៀត ដូចភាវៈជារោគ និង ភាវៈជាបូសជាដើម នៃសច្ចៈ មានទុក្ខសច្ចជាដើម រមែងមាន ក្នុងពេលណា, ក្នុងពេលនោះ ព្រោះហេតុអ្វី ទើបលោកពោលតែអត្ថ៤ យ៉ាងប៉ុណ្ណោះ?" ។ ក្នុងរឿងនេះ យើងឆ្លើយថាៈ ព្រោះអត្ថ (ក្នុងសច្ចៈមួយ) ប្រាកដច្បាស់បាន ដោយអំណាចឃើញសច្ចៈដទៃទៀត ។ ព្រោះថា សច្ចញ្ញាណ លោកពោលហើយ ដោយអំណាចមានសច្ចៈមួយៗ ជាអារម្មណ៍ ដោយន័យថា "បណ្ដាញាណទាំងនោះ ទុក្ខញ្ញាណ តើដូចម្ដេច? បញ្ញា ការដឹងច្បាស់.......ឯណា ប្រារព្ធនូវសេចក្ដីទុក្ខ ហើយកើតឡើង (នេះលោកហៅថា ទុក្ខញ្ញាណ)" ដូច្នេះជាដើមខ្វះ, លោកបានពោលហើយ ដោយអំណាចធ្វើសច្ចៈមួយ ឲ្យជា



អារម្មណ៍ហើយ សំរេចកិច្ច ក្នុងសច្ចៈដ៏សេសផង ដោយន័យថា "ម្នាលភិក្ខុទាំងឡាយ (១) បុគ្គលណា ឃើញទុក្ខ បុគ្គលនោះ ឈ្មោះថា ឃើញនូវទុក្ខសមុទ័យផង" ដូច្នេះជាដើមខ្វះ ។ ក្នុងការឃើញសច្ចៈទាំង២ ន័យនោះ ពេលណា ព្រះយោគាវចរ ធ្វើសច្ចៈមួយៗ ឲ្យជាអារម្មណ៍ ពេលនោះ ព្រោះហេតុថា សេចក្ដីទុក្ខនោះ គឺសមុទ័យដែលមានការប្រមូលមកជាលក្ខណៈ ប្រមូលមកហើយ ប្រជុំតាក់តែងហើយ ធ្វើទៅជាគំនរហើយ អត្ថថា ត្រូវសមុទយៈ ប្រជុំតាក់តែងនោះ នៃទុក្ខសច្ចៈ ដែលសូម្បីដោយសភាព មានការបៀតបៀនជាលក្ខណៈជាដំបូងនោះ ក៏រមែងប្រាកដជាក់ច្បាស់ ដោយការឃើញសមុទយសច្ចៈ ។ មួយទៀត ព្រោះហេតុថា មគ្គ ជាធម៌នាំចេញនូវសេចក្ដីក្ដៅក្រហាយ ដោយអំណាច នៃកិលេស ជាធម៌ត្រជាក់ក្រៃលែង, ទុក្ខសច្ចនោះ មានអត្ថថាក្ដៅក្រហាយ រមែងប្រាកដច្បាស់ ដោយការឃើញនូវមគ្គសច្ចៈ ដូចភាពជាស្ត្រីនៃនាងសុន្ទរីដែលមិនល្អ រមែងប្រាកដដល់នន្ទៈ ដោយឃើញនាងទេពអប្សរយ៉ាងនោះឯង ។ មួយទៀត ទុក្ខសច្ចៈនោះ មានអត្ថថា ប្រែប្រួលទៅ រមែងប្រាកដច្បាស់ ដោយការបានឃើញនូវនិរោធសច្ចៈ ដែលមានការមិនប្រែប្រួលទៅជាធម្មតា ដោយប្រការដូច្នេះ ។ ពាក្យដែលត្រូវពោលក្នុងរឿងនេះ មិនមានមែនពិត ។

ន័យដូចគ្នានោះដែរ សមុទយសច្ចៈ សូម្បីមានការប្រមូលមក ជាលក្ខណៈ ដោយសភាព មានអត្ថថា ជាដើមហេតុ រមែងប្រាកដច្បាស់ ដោយការឃើញនូវទុក្ខសច្ចៈ ដូចភាវៈនៃភោជន ជាដើមហេតុ នៃជំងឺ រមែងប្រាកដច្បាស់ ដោយការឃើញនូវជម្ងឺដែលកើតឡើងព្រោះភោជន

១- សុ សំ. មហា. ភាគទី ៣៩ ទំព័រទី ២៧១ ។

ដែលមិនល្អដូច្នោះ, សមុទយសច្ចៈ មានអត្ថថា ប្រកបទុក រមែងប្រាកដច្បាស់ ដោយការឃើញ នូវនិរោធសច្ចៈ ដែលជាធម៌ប្រាសចាកគ្រឿងប្រកបទុក, មួយទៀត សមុទយសច្ចៈ មានអត្ថថា កង្វល់ រមែងប្រាកដច្បាស់ ដោយការឃើញមគ្គដែលជាធម៌នាំចេញទៅដោយប្រការដូច្នេះ ។

ន័យដូចគ្នានោះដែរ និរោធ សូម្បីមានការរលាស់ចេញជាលក្ខណៈ មានអត្ថថា ស្ងប់ស្ងាត់ រមែងប្រាកដច្បាស់ ដោយការឃើញនូវសមុទយសច្ចៈ ដែលជាធម៌មិនស្ងប់ស្ងាត់ ។ និរោធសច្ចៈ មានអត្ថថា មិនត្រូវបច្ច័យប្រជុំតាក់តែង រមែងប្រាកដច្បាស់ ដោយការឃើញនូវមគ្គសច្ចៈ ព្រោះមគ្គ ជាធម៌គឺព្រះយោគាវចរនេះ មិនធ្លាប់បានឃើញ ក្នុងសំសារ-វដ្តដែលមានទីបំផុតគឺមគ្គមិនដឹងហើយ, មួយទៀត មគ្គនោះសោត ជាសង្ខតធម៌ ដោយពិត ព្រោះជាធម៌ប្រព្រឹត្តទៅជាមួយបច្ច័យ ហេតុនោះភាវៈនៃនិរោធសច្ចៈ ដែលជាធម៌មិនមានបច្ច័យ ជាអសង្ខតធម៌ ទើបប្រាកដច្បាស់ក្រៃលែង ។ មួយទៀត និរោធនោះ មានអត្ថថា មិនស្លាប់ រមែងប្រាកដច្បាស់ ដោយការឃើញនូវទុក្ខសច្ចៈ ។ ព្រោះសេចក្តីទុក្ខជាពិស និព្វានជាអមតៈ ដោយប្រការដូច្នេះឯង ។

ន័យដូចគ្នានោះដែរ មគ្គសច្ចៈ សូម្បីជាធម៌មានការនាំចេញ ជាលក្ខណៈ មានអត្ថថា ជាហេតុ រមែងប្រាកដច្បាស់ ដោយការឃើញនូវសមុទយសច្ចៈ (ព្រោះឃើញ) ថា "សមុទយៈនេះ មិនមែនជាហេតុ, មគ្គនេះ ជាហេតុនៃការដល់ព្រះនិព្វាន" ដូច្នេះ ។ មគ្គសច្ចៈ មានអត្ថថា ឃើញ រមែងប្រាកដច្បាស់ ដោយការឃើញនិរោធសច្ចៈ ដូចភាវៈនៃភ្នែកដែលភ្លឺច្បាស់ រមែងប្រាកដច្បាស់ ដល់បុគ្គលអ្នកឃើញរូបទាំងឡាយដែលសុខុមក្រៃលែង (ព្រោះដឹង) ថា "ភ្នែក របស់អញ ភ្លឺច្បាស់



មែនទែន" ដូច្នោះឯង ។ មគ្គសច្ចៈ មានអត្ថថា ជាអធិបតី រមែងប្រាកដច្បាស់ ដោយការឃើញនូវទុក្ខសច្ចៈ ដូចជាគុណដ៏លើសលប់ របស់ឥស្សរជន រមែងប្រាកដច្បាស់ ដោយការឃើញនូវជនកំព្រា ដោយមានភាពឈឺចាប់ ដោយរោគច្រើនជាអនេក ដូច្នោះឯង ។

ក្នុងមគ្គញាណនិទ្ទេសនេះ លោកបានពោលអត្ថ នៃសច្ចៈ មួយៗ បួនៗ ព្រោះភាវៈនៃអត្ថមួយៗ ប្រាកដច្បាស់ ដោយអំណាចនៃលក្ខណៈរបស់ខ្លួន និង អត្ថបីៗ ក្រៅពីនោះ ប្រាកដច្បាស់ ដោយអំណាចការឃើញសច្ចៈដទៃទៀត ដូចពោលមកហើយនេះឯង ។ តែក្នុងខណៈ នៃមគ្គ អត្ថទាំងអស់នោះ តែងដល់នូវការចាក់ធ្លុះ ដោយញាណដែលមានកិច្ច ៤ ក្នុងទុក្ខសច្ចៈជាដើម តែមួយប៉ុណ្ណោះឯង ដោយប្រការដូច្នេះ ។

ឯបុគ្គលទាំងឡាយណា ប្រាថ្នានានាភិសម័យ (គឺការត្រាស់ដឹងនូវអរិយសច្ចៈ ៤ ដោយញាណផ្សេងៗគ្នា) ពាក្យឆ្លើយតបដ៏ប្រសើរ របស់បុគ្គលទាំងឡាយនោះ លោកក៏បានពោលហើយ ក្នុងគម្ពីរកថាវត្ថុ ក្នុងអភិធម្មបិដកនុ៎ះឯង ។

(កិច្ច ៤ យ៉ាង ក្នុងអរិយសច្ចៈ)

(៤៦២) ឥឡូវនេះ កិច្ចទាំងឡាយ៤ មានបរិញ្ញាកិច្ចជាដើមនោះឯង ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ, ក្នុងកិច្ចទាំងឡាយ ៤ នោះ

បរិញ្ញា មាន ៣ យ៉ាង បហានៈក្តី សច្ឆិកិរិយាក្តី
ក៏យ៉ាងដូច្នោះដែរ គឺមាន ៣ ដូចគ្នាដែរ, ភាវនា ត្រូវ
ដឹងថា មាន ២ គប្បីជ្រាបវិនិច្ឆ័យ ក្នុងកិច្ចទាំងនោះ ។

(បរិញ្ញាកិច្ច)

ពាក្យថា "បរិញ្ញាកិច្ច មានបីយ៉ាង" សេចក្តីថា បរិញ្ញា មានបីយ៉ាង ដូច្នេះ គឺ ញាតបរិញ្ញា (ការកំណត់ដឹងដោយកិរិយាដឹង) តីរណបរិញ្ញា (ការកំណត់ដឹង ដោយកិរិយាពិចារណា) បហានបរិញ្ញា (ការកំណត់ដឹង ដោយកិរិយាលះ) ។

(ញាតបរិញ្ញា)

បណ្តាបរិញ្ញាទាំង៣ នោះ ការកំណត់ដឹងដែលលោកសំដែងហើយ យ៉ាងនេះថា "អភិញ្ញាបញ្ញា (ប្រាជ្ញាជាគ្រឿងដឹងដ៏ក្រៃលែង) ឈ្មោះថា ញាណ ដោយអត្ថថា ដឹង" ដូច្នេះហើយ ពោលដោយន័យសង្ខេបយ៉ាងនេះថា "ពួកធម៌ណាៗ [១] ដែលបុគ្គលចេះប្រាកដហើយ ពួកធម៌នោះៗ ឈ្មោះថា បុគ្គលដឹងហើយ" ដូច្នេះជាដើម (ពោល)ដោយពិស្តារ ដោយន័យថា "ម្នាលភិក្ខុទាំងឡាយ! [២] អាយតនៈទាំងពួង បុគ្គលត្រូវដឹងច្បាស់, ម្នាលភិក្ខុទាំងឡាយ អាយតនៈទាំងអស់ បុគ្គលត្រូវដឹងច្បាស់ តើដូចម្តេច? ម្នាលភិក្ខុទាំងឡាយ ចក្ខុ បុគ្គលត្រូវដឹងច្បាស់" ដូច្នេះជាដើម ឈ្មោះថា ញាតបរិញ្ញា ។ ការដឹងចំពោះនូវនាមរូបព្រមទាំងបច្ច័យ ជាភូមិមួយ ដោយចំពោះនៃញាតបរិញ្ញានោះ ។

(តីរណបរិញ្ញា)

ចំណែកការកំណត់ដឹង ដែលលោកសំដែង យ៉ាងនេះថា "បរិញ្ញាបញ្ញា (បញ្ញាដែលជាគ្រឿងដឹងជ្រួតជ្រាប) ឈ្មោះថា ញាណ ដោយអត្ថថា ពិចារណា" ដូច្នេះជាដើមហើយ ពោលដោយសង្ខេប យ៉ាងនេះថា "ពួកធម៌ណាៗ ដែលបុគ្គលកំណត់ដឹងហើយ ពួកធម៌នោះៗ ឈ្មោះថា បុគ្គល ពិចារណាហើយ" ដូច្នេះជាដើម ហើយ (ពោល) ដោយពិស្តារ

១- សុ. ខុ. បដិ. ភាគទី ៦៩ ទំព័រទី ៤៩ ។ ២- ភាគទី ៦៩ ទំព័រទី ៩ ។



ដោយន័យថា "ម្នាលភិក្ខុទាំងឡាយ [១] អាយតនៈទាំងពួង បុគ្គលត្រូវកំណត់ដឹង ម្នាលភិក្ខុទាំងឡាយ ចុះអាយតនៈទាំងពួង បុគ្គលត្រូវកំណត់ដឹងតើដូចម្តេច? ម្នាលភិក្ខុទាំងឡាយ ចក្ខុ បុគ្គលត្រូវកំណត់ដឹង" ដូច្នេះជាដើម ឈ្មោះថា តីរណបរិញ្ញា ។ ការកំណត់ដឹង ដែលប្រព្រឹត្តទៅដោយអំណាចការពិចារណាថា "មិនទៀង ជាទុក្ខ ជាអនត្តា" ចាប់តាំងអំពីការពិចារណាជាកលាបៈ រហូតដល់អនុលោម ជាភូមិមួយ ដោយចំពោះ នៃតីរណបរិញ្ញានោះ ។

(បហានបរិញ្ញា)

ចំណែកឯការកំណត់ដឹង ដែលលោកសំដែងថា "បហានបញ្ញា (បញ្ញាជាគ្រឿងលះ) ឈ្មោះថា ញាណ ដោយអត្ថថា លះបង់" ដូច្នេះហើយ ពោលដោយន័យសង្ខេបថា "ពួកធម៌ណាៗ ដែលបុគ្គលលះហើយ ពួកធម៌នោះៗ ឈ្មោះថា បុគ្គលលះបង់បានហើយ" ដូច្នេះជាដើមហើយ ប្រព្រឹត្តទៅ ដោយន័យថា "លះនូវនិច្ចសញ្ញា បាន ដោយអនិច្ចានុបស្សនា" ដូច្នេះជាអាទិ៍ ឈ្មោះថា បហានបរិញ្ញា ។ ការកំណត់ដឹង ចាប់តាំងពីភង្គានុបស្សនា រហូតដល់មគ្គញាណ ជាភូមិនៃបហាន-បរិញ្ញានោះ ។ បហានបរិញ្ញានេះ លោកប្រាថ្នាហើយក្នុងបរិញ្ញាកិច្ចនេះ ។ ឬ បើមិនដូច្នោះទេ ព្រោះហេតុថា សូម្បីញាតបរិញ្ញា និង តីរណបរិញ្ញា ក៏មានមគ្គនោះជាគោលដៅ (អត្ថ) ហ្នឹងឯង, មួយទៀត ព្រោះហេតុថា ព្រះយោគាវចរ លះធម៌ណា, ធម៌ទាំងនោះ ជាធម៌ដែលព្រះយោគាវចរនោះបានដឹងហើយ និង បានពិចារណាហើយ ដោយពិតប្រាកដ ព្រោះហេតុនោះ គប្បីជ្រាបថា "សូម្បីបរិញ្ញាទាំង ៣ ក៏ជាកិច្ច នៃមគ្គញាណ

១- សុ. ខុ. បដិ. ភាគទី ៦៩ ទំព័រទី ៥០ ។

ដោយបរិយាយនេះផងដែរ” ដូច្នេះ ។

**(បហានកិច្ច)**

ពាក្យថា “សូម្បីបហានៈ ក៏ដូច្នោះដែរ” សេចក្ដីថា សូម្បីបហានៈ ក៏មាន ៣ យ៉ាង ដូចជាបរិញ្ញាដែរ គឺ វិក្ខម្ភនបហានៈ តទង្គបហានៈ សមុច្ឆេទបហានៈ ។

**(វិក្ខម្ភនបហានៈ)**

ក្នុងបហានៈទាំង ៣ នោះ ការសង្កត់សង្កិត នូវធម៌ដែលជាសត្រូវទាំងឡាយ មាននីវរណៈជាដើម ដោយលោកិយសមាធិនោះៗ ដូចទប់សង្កត់នូវសារាយ ដោយឆ្នាំងដែលដាក់ក្នុងទឹក ដែលមានសារាយឯណានេះ ឈ្មោះថា វិក្ខម្ភនបហានៈ។ តែក្នុងបាលី ពោលតែការសង្កត់សង្កិននូវនីវរណៈទាំងឡាយប៉ុណ្ណោះថា “មួយទៀត ការលះ ដោយការសង្កត់សង្កិននីវរណៈទាំងឡាយ នៃភិក្ខុអ្នកចំរើនបឋមជ្ឈាន” ដូច្នេះ ។ គប្បីជ្រាបពាក្យបាលីនោះថា “លោកពោលហើយ ព្រោះការសង្កត់សង្កិននូវនីវរណៈនោះ ជាការប្រាកដ” ដូច្នេះ ។ ព្រោះថា នីវរណៈទាំងឡាយតែងមិនគ្របសង្កត់ចិត្ត យ៉ាងប្រញាប់ ទាំងក្នុងចំណែកខាងដើម ទាំងខាងចុងនៃឈានទេ, ធម៌ដទៃទៀត មានវិតក្កៈជាដើម តែងរម្ងាប់ តែក្នុងខណៈដែលពិតប្រាកដប៉ុណ្ណោះឯង ព្រោះហេតុនោះ ការសង្កត់សង្កិននីវរណៈទាំងឡាយ ជាការប្រាកដ ។

**(តទង្គបហានៈ)**

ចំណែកការលះនូវធម៌ ដែលត្រូវលះនោះៗ ឯណា ដោយអង្គ គឺញាណដែលជាអវយវៈ នៃវិបស្សនានោះៗ ដោយអំណាចជាគូប្រឆាំងតែម្ដង ដូចជាលះ (កំចាត់) ងងឹត ដោយប្រទីប ដែលឆេះសន្ធោសន្ធៅ



ក្នុងពេលរាត្រីដូច្នោះឯង នេះឈ្មោះថា តទង្គបហានៈ ។ តទង្គបហានៈតើយ៉ាងដូចម្ដេច? ។

គឺ ដំបូង ការលះសក្កាយទិដ្ឋិ ដោយការកំណត់ឃើញថា គ្រាន់តែជានាមរូប លះនូវអហេតុវិសមហេតុទិដ្ឋិ (គឺការឃើញថា គ្មានហេតុ និងឃើញថា មានហេតុមិនស្មើគ្នា) និង មន្ទិល គឺសេចក្ដីសង្ស័យ ដោយកំណត់ដឹងបច្ច័យនៃនាមរូប លះនូវសមូហគាហៈ (គឺការប្រកាន់ថា ជាពួកក្រុម) ថា “អញ ថា ជារបស់អញ” ដោយកលាបសម្មសនៈ (គឺពិចារណាសង្ខេបចូលជាកលាបៈ) លះនូវសេចក្ដីសំគាល់ថា ជាផ្លូវ ក្នុងរបស់ដែលមិនមែនជាផ្លូវ ដោយការកំណត់ដឹងថា ជាផ្លូវ និង មិនមែនជាផ្លូវ លះឧច្ឆេទទិដ្ឋិ ដោយឧទយទស្សនញាណ (ញាណ ក្នុងការឃើញថា កើត) លះសស្សតទិដ្ឋិ ដោយវយទស្សនញាណ (ញាណ ក្នុងការឃើញថា អស់ទៅ) លះនូវសេចក្ដីសំគាល់ថា មិនមានភ័យ ក្នុងរបស់ដែលមានភ័យ ដោយភយតុបដ្ឋានញាណ (គឺញាណក្នុងការប្រាកដឡើងថា ជាភ័យ) លះនូវសេចក្ដីសំគាល់ថា បញ្ចក្ខន្ធ ជារបស់ដែលជាទីត្រេកអរ ដោយអាទីនវទស្សនញាណ (គឺញាណក្នុងការឃើញបញ្ចក្ខន្ធថា ជាទោស) លះនូវសេចក្ដីសំគាល់ថា បញ្ចក្ខន្ធ ជាទីត្រេកអរក្រៃលែង ដោយនិព្វិទានុបស្សនាញាណ (គឺញាណក្នុងការពិចារណាឃើញថា គួរឲ្យនឿយណាយ) លះនូវភាពជាអ្នកមិនប្រាថ្នា ដើម្បីនឹងរួចផុត ដោយមុញ្ចិតុកម្យតាញាណ (គឺញាណក្នុងភាពជាអ្នកប្រាថ្នាចង់ឲ្យរួចផុត) លះនូវការមិនពិចារណារកផ្លូវ ដោយបដិសង្ខាញាណ (គឺញាណ ក្នុងការពិចារណារកផ្លូវ) លះនូវការមិនព្រងើយកន្តើយ ដោយឧបេក្ខាញាណ (គឺញាណ ក្នុងការព្រងើយកន្តើយ ក្នុងសង្ខារ) លះនូវការប្រកាន់មាំ ក្នុង

សច្ចបដិលោម ដោយអនុលោមញាណ ។

ឬ មួយទៀត ក្នុងមហាវិបស្សនា ១៨ ការលះនិច្ចសញ្ញា ដោយអនិច្ចានុបស្សនា លះសុខសញ្ញា ដោយទុក្ខានុបស្សនា លះអត្តសញ្ញា ដោយអនត្តានុបស្សនា លះនន្ទិ ដោយនិព្វិទានុបស្សនា លះរាគៈ ដោយវិរាគានុបស្សនា លះសមុទយៈ ដោយនិរោធានុបស្សនា លះការប្រកាន់មាំ ដោយការពិចារណាក្នុងការរលាស់ចោល លះនូវសេចក្តីសំគាល់ថាជាពួកក្រុម ដោយពិចារណានូវការអស់ទៅ លះការប្រមូលមក ដោយការពិចារណា នូវការសាបសូន្យទៅ លះសេចក្តីសំគាល់ថា ទៀងទាត់ ដោយការពិចារណានូវការប្រែប្រួល លះនិមិត្ត ដោយការពិចារណា ថាមិនមាននិមិត្ត លះសេចក្តីប្រាថ្នា ដោយការពិចារណាឃើញថា មិនគួរប្រាថ្នា លះការប្រកាន់ស្អិត ដោយការពិចារណាឃើញសោះសូន្យ លះនូវការប្រកាន់ស្អិត ដោយគិតថា មានសារៈ ដោយការឃើញច្បាស់ ក្នុងធម៌ ដោយអធិបញ្ញា លះការប្រកាន់ស្អិត ដោយការវង្វេងស៊ប់ ដោយយថាញាណទស្សនៈ លះការប្រកាន់ស្អិត ដោយជាប់អាល័យ ក្នុងភព ដោយការពិចារណាឃើញថា ជាទោស លះនូវការមិនពិចារណារកផ្លូវ ដោយការពិចារណារកផ្លូវ លះការប្រកាន់ស្អិត ដោយការប្រកបទុក ក្នុងវដ្តៈ ដោយការពិចារណាឃើញវិវដ្តៈ គឺព្រះនិព្វានឯណា សូម្បីកិច្ចនេះក៏ឈ្មោះថា តទង្គប្បហានៈ ដូចគ្នាដែរ ។

ក្នុងមហាវិបស្សនាទាំងនោះ ការលះនូវនិច្ចសញ្ញាជាដើម ដោយមហាវិបស្សនា ៧ មាន អនិច្ចានុបស្សនា ជាដើម តើយ៉ាងដូចម្តេច? ការលះនោះ លោកពោលហើយ ក្នុងភង្គានុបស្សនា នុ៎ះឯង ។

ចំណែកពាក្យថា "ខយានុបស្សនា" បានដល់ ញាណ របស់ព្រះ



យោគាវចរ អ្នកធ្វើការបំបែកនូវដុំ ហើយឃើញនូវការសូន្យទៅ យ៉ាងដូច្នេះថា "ឈ្មោះថា មិនទៀង ដោយអត្ថថា សូន្យទៅ" ការលះនូវឃនសញ្ញា តែងមាន ដោយញាណនោះ ។

ពាក្យថា "វយានុបស្សនា" បានដល់ ការដែលឃើញការបែកធ្លាយ នៃសង្ខារទាំងឡាយ ដោយប្រចក្សច្បាស់ និង ដោយនឹកឃើញតាម ហើយបង្អោនចិត្តទៅ ក្នុងនិរោធ ពោលគឺការបែកធ្លាយនោះឯង ដែលលោកពោលហើយ យ៉ាងនេះ ថា :

ការកំណត់ នូវសភាពទាំង ២ ថា តែមួយ [1]
ដោយការប្រព្រឹត្តិតាមអារម្មណ៍ ភាពនៃបុគ្គល
មានចិត្តចុះស៊ប់ ក្នុងការរលត់ ឈ្មោះថា ពិចារណា
ឃើញនូវលក្ខណៈ នៃការសូន្យ ។

ការលះនូវការប្រមូលមករមែងមាន ដោយវយលក្ខណវិបស្សនានោះ ។ ក៏ចិត្តគប្បីប្រមូលមក ដើម្បីប្រយោជន៍ដល់សង្ខារទាំងឡាយណា កាលបើព្រះយោគាវចរ ឃើញច្បាស់ថា "សង្ខារទាំងឡាយនោះមានការសូន្យទៅយ៉ាងនុ៎ះឯងជាធម្មតា" ចិត្ត រមែងមិនបង្អោនទៅក្នុងការប្រមូលមក ។

ពាក្យថា "វិបរិណាមានុបស្សនា" បានដល់ ការឃើញនូវការប្រព្រឹត្តិទៅ ដោយប្រការផ្សេងទៀត កន្លងនូវការកំណត់នោះៗ ដោយអំណាចនៃកលាបៈ មានរូបសត្តកៈជាដើម ឬ ការឃើញនូវការប្រែប្រួល ដោយអាការៈ ២ យ៉ាង គឺ ជរា ១ មរណៈ ១ នៃរបស់ដែលកើតឡើងហើយ, ការលះ នូវសេចក្តីសំគាល់ ថា ជារបស់ទៀងទាត់ រមែងមាន ដោយ

១- សុ. ខុ. បដិ. ភាគទី ៦៩ ទំព័រទី ១៣១ ។

វិបរិណាមានុបស្សនានោះ ។

ពាក្យថា “អនិមិត្តានុបស្សនា” គឺអនិច្ចានុបស្សនាហ្នឹងឯង ការលះនូវនិច្ចនិមិត្ត រមែងមាន ដោយអនិមិត្តានុបស្សនានោះ ។

ពាក្យថា “អប្បណិហិតានុបស្សនា” គឺទុក្ខានុបស្សនាហ្នឹងឯង ការលះនូវការប្រាថ្នាចង់បានសេចក្ដីសុខ គឺប្រាថ្នានូវសុខ រមែងមាន ដោយអប្បណិហិតានុបស្សនានោះ ។

ពាក្យថា “សុញ្ញតានុបស្សនា” គឺអនត្តានុបស្សនាហ្នឹងឯង ការលះនូវការប្រកាន់ស្អិត ថា “អត្តា មាន” រមែងមាន ដោយសុញ្ញតានុ-បស្សនានោះ ។

ពាក្យថា “អធិប្បញ្ញាធម្មវិបស្សនា” បានដល់ ការឃើញច្បាស់ ដែលប្រព្រឹត្តទៅ ព្រោះដឹងនូវអារម្មណ៍ មានរូបជាដើម ហើយឃើញ កិរិយាបែកធ្លាយ នៃអារម្មណ៍នោះ និង នៃចិត្ត ដែលមានអារម្មណ៍ ជាអារម្មណ៍ផង ហើយប្រកាន់យកថា ជារបស់សោះសូន្យ ដោយអំណាច ការបែកធ្លាយថា “សង្ខារទាំងឡាយប៉ុណ្ណោះ តែងបែកធ្លាយ មរណៈ ក៏មានដល់សង្ខារទាំងឡាយ បុគ្គលណាមួយផ្សេងទៀត មិនមានឡើយ” ដូច្នោះ ដែលលោកពោលហើយ ថា :

> ការពិចារណា នូវអារម្មណ៍ក្ដី បុគ្គលឃើញ នូវការ
> បែកធ្លាយក្ដី ការប្រាកដឡើងថាសូន្យ ក្ដី ឈ្មោះថា
> ការពិចារណាឃើញ ដោយបញ្ញា ដ៏ក្រៃលែង ។

ការឃើញជាក់ច្បាស់នុ៎ះ លោកហៅថា “ការឃើញច្បាស់ក្នុងធម៌ ដោយបញ្ញាដ៏ក្រៃលែង” ព្រោះធ្វើវិគ្រោះថា “ជាអធិបតីផង ជាការឃើញជាក់



ច្បាស់ក្នុងធម៌ទាំងឡាយផង” ។ ការលះនូវការប្រកាន់ស្អិត ដោយការប្រកាន់ថា មានសារៈ រមែងមាន ដោយអធិប្បញ្ញាធម្មវិបស្សនានោះ ព្រោះឃើញដោយប្រពៃ នូវការមិនមាននៃនិច្ចសារៈ និង ការមិនមាននៃអត្តសារៈ ។

ពាក្យថា “យថាភូតញ្ញាណទស្សនៈ” បានដល់ ការកំណត់នូវនាមរូបព្រមទាំងបច្ច័យ ការលះនូវការប្រកាន់ស្អិត ដោយការវង្វេងស៊ប់ ដែលប្រព្រឹត្តទៅ ដោយអំណាចការសង្ស័យថា “អំពីអតីតកាល អាត្មាអញ បានកើតដែរឬ [១] ”ដូច្នេះជាដើម និង ដោយអំណាចការយល់ខុសថា “លោកនេះ មាន ព្រោះឥស្សរជន (ព្រះជាម្ចាស់)” ដូច្នេះជាអាទិ៍ រមែងមាន ដោយយថាភូតញ្ញាណទស្សនៈនោះ ។

ពាក្យថា “អាទីនវានុបស្សនា” បានដល់ ញាណ ដែលឃើញទោស ក្នុងសង្ខារធម៌ទាំងឡាយមានភពទាំងពួងជាដើម ដែលកើតឡើង ដោយអំណាចនៃភយតុបដ្ឋានញ្ញាណ ការលះនូវការប្រកាន់ស្អិត គឺការអាល័យក្នុងភព ដោយឃើញថា “របស់អ្វីមួយ ដែលគួរឲ្យជាប់ជំពាក់ មិនប្រាកដ” ដូច្នេះ រមែងមាន ដោយអាទីនវានុបស្សនាញាណនោះ ។

ពាក្យថា “បដិសង្ខានុបស្សនា” បានដល់ ញាណ ដែលជាគ្រឿងពិចារណា ដែលធ្វើនូវឧបាយនៃការរួចផុត ការលះនូវការមិនពិចារណា រមែងមាន ដោយបដិសង្ខានុបស្សនាញាណនោះ ។

ពាក្យថា “វិវដ្ដានុបស្សនា” បានដល់ សង្ខារុបេក្ខាញាណ និង អនុលោមញ្ញាណ ។ ព្រោះក្នុងខណៈនោះ ចិត្ត របស់ព្រះយោគាវចរនោះ លោកហៅថា “រមែងរាថយ រមែងរួញរា រមែងវិលត្រឡប់ចាក

១- សុ. ម. មូ. ភាគទី ២០ ទំព័រទី ២៥ ។

សង្ខារទាំងពួង ដូចជាតំណក់ទឹក លើស្លឹកឈូកដែលផ្អៀងបន្តិច រមែងរមៀលធ្លាក់ចេញ យ៉ាងនោះឯង” ។ ព្រោះហេតុនោះ ការលះនូវការប្រកាន់ស្អិត ក្នុងការប្រកបទុក រមែងមាន ដោយវិវដ្តានុបស្សនានោះ ។ អធិប្បាយថា ការលះនូវការប្រកាន់ស្អិត គឺកិលេស មានការប្រកប ក្នុងកាមជាដើម រមែងមាន ដោយការមិនប្រព្រឹត្តិទៅនៃកិលេស ។

តទង្គបហានៈ បណ្ឌិត គប្បីជ្រាប ដោយពិស្តារ ដូចបានពោលមកហើយនេះឯង ។ តែក្នុងបាលី លោកពោលហើយ ដោយសង្ខេបថា “ក៏តទង្គបហានៈ [១] រមែងមាន ដល់បុគ្គលអ្នកចំរើនសមាធិ ដែលជាចំណែកនៃការទំលុះទំលាយ នូវទិដ្ឋិទាំងឡាយ” ដូច្នេះ ។

(សមុច្ឆេទបហានៈ)

ចំណែកឯការលះធម៌ទាំងឡាយ មានសំយោជនៈជាដើម ឯណា ដោយអរិយមគ្គញ្ញាណ ដោយប្រការដែលសំយោជនៈទាំងនោះ ប្រព្រឹត្តទៅមិនបាន ដូចការទំលាយនៃដើមឈើដែលត្រូវរន្ទះបាញ់ យ៉ាងនោះឯង, នេះ ឈ្មោះថា សមុច្ឆេទបហានៈ ដែលលោកពោលសំដៅយកហើយថា “ក៏សមុច្ឆេទបហានៈ [២] រមែងមាន ដល់បុគ្គលអ្នកចំរើននូវមគ្គ ជាលោកុត្តរៈ ដែលដល់នូវការអស់ទៅ” ដូច្នេះ ។

បណ្តាបហានៈទាំង៣ ដូចបានពោលមកនេះ សមុច្ឆេទបហានៈ តែប៉ុណ្ណោះ គឺលោកប្រាថ្នាហើយ ក្នុងបហានកិច្ចនេះ ។ តែសូម្បីវិក្ខម្ភនបហានៈ និង តទង្គបហានៈ ក្នុងចំណែកខាងដើម នៃព្រះយោគាវចរនោះ ក៏មានមគ្គនោះ ជាគោលដៅនុ៎ះឯង ព្រោះហេតុណា, ព្រោះហេតុនោះ គប្បីជ្រាបថា “បហានៈទាំង៣ ក៏ជាកិច្ចនៃមគ្គញ្ញាណ ដោយបរិយាយនេះ

១- ២- សុ. ខុ. បដិ. ភាគទី ៧១ ទំព័រទី ៣០១ ។



ដូចគ្នា” ។ ប្រៀបដូចជា សូម្បីរបស់ណា ដែលអ្នកសម្លាប់ព្រះរាជាដែលជាសត្រូវហើយបានរាជសម្បត្តិ ធ្វើហើយក្នុងកាលមុន អំពីការបានរាជ-សម្បត្តិនោះ របស់ទាំងអស់នោះៗ លោកហៅថា “ព្រះរាជាទ្រង់ធ្វើដូចគ្នាហ្នឹងឯង” ។

(សច្ឆិកិរិយាកិច្ច)

ពាក្យថា “សូម្បីសច្ឆិកិរិយា (ក៏យ៉ាងដូច្នោះ)” សេចក្តីថា សច្ឆិ-កិរិយា សូម្បីចែកជា ២ គឺ លោកិយសច្ឆិកិរិយា លោកុត្តរសច្ឆិកិរិយា តែសំរាប់លោកុត្តរសច្ឆិកិរិយា មាន ៣ យ៉ាង ដោយប្រភេទ ដោយអំណាចនៃទស្សនៈ និង ភាវនា ។

ក្នុងសច្ឆិកិរិយាទាំង២ នោះ ការបានសម្ផស្សឈានមានបឋមជ្ឈានជាដើមដែលមកហើយ ដោយន័យថា “អាត្មាអញ ជាអ្នកបានបឋមជ្ឈាន អាត្មាអញ ជាអ្នកស្ទាត់ជំនាញ ក្នុងបឋមជ្ឈាន, បឋមជ្ឈាន អាត្មាអញធ្វើឲ្យជាក់ច្បាស់ហើយ” ដូច្នេះជាដើម ឈ្មោះថា លោកិយសច្ឆិកិរិយា ។

ពាក្យថា “ផស្សនា” គឺបានសំរេចហើយ ពាល់ត្រូវដោយញាណ-ផស្សៈ ដោយប្រចក្ស ថា “របស់នេះ អាត្មាអញ បានសំរេចហើយ” ។ មែនពិត បាលីដែលលោកសំដៅយកសេចក្តីនេះឯង ហើយសំដែងថា “សច្ឆិកិរិយា [១] ឈ្មោះថា ញាណ ដោយអត្ថថា បានពាល់ត្រូវ ដោយបញ្ញា” ដូច្នេះ ហើយពោលបន្ថែមសច្ឆិកិរិយាទៀតថា “ពួកធម៌ណាៗ គឺបុគ្គលធ្វើ ឲ្យជាក់ច្បាស់ហើយ, [២] ពួកធម៌នោះៗ គឺបុគ្គលពាល់ត្រូវហើយ” ដូច្នេះ ។ មួយទៀត ធម៌ទាំងឡាយ សូម្បីបុគ្គលមិនធ្វើឲ្យកើតឡើង ក្នុងសន្តាន របស់ខ្លួនហើយ ដឹង ដោយញាណ ដែលមិនមានអ្នក

១- សុ. ខុ. បដិ. ។ ២□ សុ. ខុ. ភាគទី ៦៩ ទំព័រទី ៨០ ។

ជវទៃជាបច្ច័យតែម្យ៉ាង, ធម៌ទាំងឡាយនោះ ឈ្មោះថា ជាធម៌ គឺបុគ្គលធ្វើឲ្យជាក់ច្បាស់ហើយដូចគ្នាដែរ ។ ព្រោះហេតុនោះឯង ទើបព្រះមានព្រះភាគ ត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ (១) អាយតនៈទាំងពួង បុគ្គលត្រូវធ្វើឲ្យជាក់ច្បាស់ ម្នាលភិក្ខុទាំងឡាយ ចុះអាយតនៈទាំងពួង ដែលបុគ្គលត្រូវធ្វើឲ្យជាក់ច្បាស់ តើដូចម្ដេច? ម្នាលភិក្ខុទាំងឡាយ ចក្ខុបុគ្គលត្រូវធ្វើឲ្យជាក់ច្បាស់” ដូច្នេះជាដើម ។ ពាក្យបាលីដទៃទៀត ក៏លោកពោលហើយថា “បុគ្គលកាលឃើញនូវរូប (២) រមែងធ្វើឲ្យជាក់ច្បាស់ កាលឃើញវេទនា រមែងធ្វើឲ្យជាក់ច្បាស់ ។ល។ កាលឃើញវិញ្ញាណ រមែងធ្វើឲ្យជាក់ច្បាស់ កាលឃើញនូវចក្ខុ... នូវជរាមរណៈ... នូវព្រះនិព្វានដែលឈ្មោះថា អមតៈ ជាទីពឹងរបស់សត្វ រមែងធ្វើឲ្យជាក់ច្បាស់ ហេតុនោះ ធម៌ទាំងឡាយណាៗ ដែលបុគ្គលធ្វើឲ្យជាក់ច្បាស់ហើយ, ធម៌ទាំងឡាយនោះៗ ឈ្មោះថាបុគ្គលពាល់ត្រូវហើយ” ដូច្នេះ ។

ចំណែកការឃើញព្រះនិព្វាន ក្នុងខណៈនៃបឋមមគ្គ ជាការធ្វើឲ្យជាក់ច្បាស់ ដោយការឃើញ(គឺទស្សនសច្ឆិកិរិយា) ការឃើញព្រះនិព្វានក្នុងខណៈមគ្គដ៏សេស ជាការធ្វើឲ្យជាក់ច្បាស់ ដោយការចំរើន(គឺភាវនាសច្ឆិកិរិយា) ។ សច្ឆិកិរិយាទាំង២ យ៉ាងនោះ លោកបំណងហើយ ក្នុងសច្ឆិកិរិយាកិច្ចនេះ ។ ព្រោះហេតុនោះ គប្បីជ្រាបថា “ការធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ដោយអំណាចនៃទស្សនៈ និង ភាវនា ជាកិច្ចនៃញាណនេះ” ដូច្នេះឯង ។

(ភាវនាកិច្ច)

ពាក្យថា “ភាវនា ត្រូវដឹងថាមាន ២” សេចក្ដីថា ភាវនា លោកប៉ង

១- សុ. ខុ. បដិ. ភាគទី ៦៩ ទំព័រ ៧៩ ។ ២□ សុ. ភាគទី ៦៩ ទំព័រទី ៨០ ។



យកតែភាវនា ២ យ៉ាងប៉ុណ្ណោះ គឺ លោកិយភាវនា លោកុត្តរភាវនា ។ ក្នុងភាវនាទាំង ២ យ៉ាងនោះ ការញ៉ាំងសីល សមាធិ បញ្ញា ដែលជាលោកិយៈ ឲ្យកើតឡើង និង ការអប់រំសន្ដាន ដោយសីល សមាធិ បញ្ញា ដែលជាលោកិយៈទាំងឡាយនោះ ឈ្មោះថា លោកិយភាវនា, ការញ៉ាំងសីល សមាធិ បញ្ញា ដែលជាលោកុត្តរៈ ឲ្យកើតឡើង និង ការអប់រំសន្ដាន ដោយសីល សមាធិ បញ្ញា ដែលជាលោកុត្តរៈទាំងឡាយនោះ ឈ្មោះថា លោកុត្តរភាវនា ។ ក្នុងភាវនាទាំង ២ យ៉ាងនោះ លោកុត្តរភាវនា លោកប៉ងយកហើយ ក្នុងញាណទស្សនវិសុទ្ធិនេះ ។ ព្រោះថា ញាណទាំង ៤ យ៉ាងនោះ ញ៉ាំងលោកុត្តរសីលជាដើម ឲ្យកើតឡើង ព្រោះភាវៈនៃញាណទាំង ៤ យ៉ាងនោះ ជាបច្ច័យ មានសហជាតប្បច្ច័យជាដើម នៃលោកុត្តរសីលជាដើមនោះ និង អប់រំសន្ដាន ដោយលោកុត្តរសីលជាដើមនោះផង ហេតុនោះ លោកុត្តរភាវនា តែប៉ុណ្ណោះ ជាកិច្ចនៃញាណនោះ ដោយប្រការដូច្នេះឯង ។

តាមន័យ ដូចដែលបានពោលមកហើយនេះឯង

បណ្ឌិត គប្បីជ្រាបកិច្ច មានបរិញ្ញាកិច្ចជាដើម
ដែលលោកពោលហើយ ក្នុងពេលដែលត្រាស់
ដឹង តាមសភាពទាំងអស់ យ៉ាងនេះឯង ។

ក៏ដោយការពណ៌នា មានប្រមាណប៉ុណ្ណោះ, ពាក្យឯណា ដែលខ្ញុំពោលហើយថា “បញ្ញា ដែលព្រះយោគី អ្នកញ៉ាំងវិសុទ្ធិទាំង ២ យ៉ាង (សីលវិសុទ្ធិ និង ចិត្តវិសុទ្ធិ) ដែលជាប្រធាន ឲ្យដល់ព្រមហើយ ញ៉ាំងវិសុទ្ធ ៥ (មានទិដ្ឋិវិសុទ្ធិជាដើម) ដែលជាតួ (បញ្ញា) ឲ្យដល់ព្រមហើយ

គប្បីចំរើន” ដូច្នេះ ដើម្បីសំដែងវិធីនៃការចំរើនបញ្ញា ដែលមកហើយដោយសរុប យ៉ាងនេះថា “នរជនណា ប្រកបដោយសជាតិបញ្ញា តាំងនៅស៊ប់ហើយ ក្នុងសីល ចំរើនសមាធិចិត្ត និង វិបស្សនាចិត្ត” ដូច្នេះជាដើម, ពាក្យនោះ គឺខ្ញុំបាន (សំដែង) ឲ្យពិស្តារហើយ ។ និង បញ្ហានេះ ថា “បញ្ញានោះ តើត្រូវចំរើនដូចម្តេច?” គឺខ្ញុំបានវិសជ្ជនាហើយ ។

*បរិច្ឆេទ ទី២២ ឈ្មោះ ញាណទស្សនវិសុទ្ធិនិទ្ទេស*
*ក្នុងអធិការនៃបញ្ញាភាវនា ក្នុងគម្ពីរវិសុទ្ធិមគ្គ*
*គឺខ្ញុំបានរចនាហើយ ដើម្បីប្រយោជន៍*
*ដល់បាមោជ្ជៈនៃសាធុជន តែប៉ុណ្ណោះ ។*

* * *



## បញ្ញាភាវនានិសំសនិទ្ទេស

(៤៦៣) ចំណែកបញ្ហាកម្មឯណា ដែលខ្ញុំពោលហើយថា “អ្វីជាអានិសង្សនៃការចំរើនបញ្ញា?” ដូច្នេះ, ក្នុងបញ្ហាកម្មនោះ ខ្ញុំនឹងពណ៌នាដូចតទៅនេះ ។

ក៏ធម្មតា ការអប់រំបញ្ញានេះ មានអានិសង្សច្រើនរយប្រការ ។ ការសំដែងអានិសង្ស នៃបញ្ញាភាវនានោះ ដោយពិស្តារ មិនមែនធ្វើបានដោយស្រួលទេ សូម្បីប្រើពេលវេលាវែងឆ្ងាយ ក៏ដោយ ។ តែដោយសង្ខេប គប្បីជ្រាបអានិសង្ស នៃបញ្ញាភាវនានោះ យ៉ាងនេះ គឺ :

(១) នានាកិលេសវិទ្ធំសនៈ កំចាត់បង់នូវកិលេសផ្សេងៗ បាន,

(២) អរិយផលរសានុភវនៈ សោយនូវរសនៃអរិយផល,

(៣) និរោធសមាបត្តិសមាបជ្ជនសមត្ថតា ជាអ្នកអង់អាច ក្នុងការចូលនិរោធសមាបត្តិ,

(៤) អាហុនេយ្យភាវាទិសិទ្ធិ បានសំរេចនូវភាវៈ នៃខ្លួនជាព្រះអាហុណេយ្យបុគ្គល ជាដើម ។

**(ការកំចាត់កិលេសផ្សេងៗ)**

ក្នុងអានិសង្សទាំងនោះ ការកំចាត់កិលេសផ្សេងៗ ឯណា ដោយអំណាចនៃសំយោជនៈ មានសក្កាយទិដ្ឋិជាដើម គឺលោកពោលហើយតាំងពីកំណត់នាមរូបទៅ, នេះ គប្បីជ្រាបថា “អានិសង្ស នៃបញ្ញាភាវនាដែលជាលោកិយៈ ។ ការកំចាត់កិលេសផ្សេងៗ ឯណា ដោយអំណាចនៃសំយោជនៈជាដើម ដែលលោកពោលហើយ ក្នុងខណៈនៃអរិយមគ្គ, នេះ គប្បីជ្រាបថា “ជាអានិសង្ស នៃបញ្ញាភាវនា ដែលជាលោកុត្តរៈ” ដូច្នេះ ។

មែនពិត បញ្ញាដែលព្រះយោគីវចរចំរើនហើយ រមែងកំចាត់បង់នូវបណ្តាញគឺកិលេស ដែលជាប់តាមហើយ អស់កាលដ៏យូរ ធ្វើអនត្ថៈ ឲ្យគ្រប់យ៉ាង ដូចជាកាំរន្ទះ ដែលធ្លាក់ចុះ ដោយកម្លាំងខ្លាំង ដែលគួរឲ្យភ័យខ្លាច លើគំនរសីលា កំចាត់នូវសីលា ដូចជាភ្លើងព្រៃឆេះឡើងហើយ ដោយកម្លាំងនៃខ្យល់ ឆេះកំទេចនូវព្រៃ ដូចព្រះអាទិត្យ (កាលរះឡើង) មានមណ្ឌលភ្លឺស្វាង ដោយតេជះ របស់ខ្លួន កំចាត់បង់នូវងងឹត យ៉ាងដូច្នោះឯង, បណ្ឌិត គប្បីជ្រាបអានិសង្ស នេះថា ជាអានិសង្ស ដែលព្រះយោគាវចរ គប្បីឃើញ ដោយខ្លួនឯង ក្នុងបញ្ញាភាវនានេះ ។

(ការសោយរសនៃអរិយផល)

*អានិសង្សថា “សោយនូវរសនៃអរិយផល” សេចក្តីថា មួយទៀត មិនត្រឹមតែកំចាត់នូវកិលេសផ្សេងៗ តែម្យ៉ាង បានប៉ុណ្ណោះទេ សូម្បីការសោយនូវរសនៃអរិយផល ក៏ជាអានិសង្សនៃបញ្ញាភាវនាផងដែរ ។ ក៏សាមញ្ញផល មានសោតាបត្តិផលជាដើម ហៅថា អរិយផល ។ ការសោយនូវរសនៃអរិយផលនោះ រមែងមាន ដោយអាការៈ ២ យ៉ាង គឺ ក្នុងការប្រព្រឹត្តិទៅ ក្នុងវិថីនៃមគ្គ ១ ក្នុងការប្រព្រឹត្តិទៅ ដោយអំណាចនៃផលសមាបត្តិ ១ ។ ក្នុងអាការៈ ២ យ៉ាងនោះ ការប្រព្រឹត្តិទៅ ក្នុងមគ្គវិថី នៃអរិយផលនោះ បានសំដែងរួចមកហើយ ។*

*ម្យ៉ាងទៀត អាចារ្យទាំងឡាយណា ពោលថា “គុណត្រឹមតែការ*



*លះសំយោជនៈប៉ុណ្ណោះ ឈ្មោះថា ផល, ធម៌អ្វីៗ ផ្សេងទៀត មិនមានទេ” ដូច្នេះ ដើម្បីប្រយោជន៍ដល់ការស្រេប តាមអាចារ្យទាំងឡាយនោះ គប្បីសំដែងព្រះសូត្រនេះផងដែរថា “បញ្ញា សំរាប់រម្ងាប់ នូវព្យាយាម ឈ្មោះថា ផលញ្ញាណ [1] តើដូចម្តេច, ក្នុងខណៈនៃសោតាបត្តិមគ្គ សម្មាទិដ្ឋិ ដោយអត្ថថា ឃើញ រមែងចេញចាកពីមិច្ឆាទិដ្ឋិ ចេញចាកពីកិលេស ដែលប្រព្រឹត្តទៅតាមនូវមិច្ឆាទិដ្ឋិនោះផង ចាកខន្ធទាំងឡាយផង ចេញចាកពីនិមិត្តទាំងពួងខាងក្រៅផង សម្មាទិដ្ឋិ រមែងកើតឡើង ព្រោះកិរិយារម្ងាប់នូវព្យាយាម ក្នុងការចេញនោះ, នុ៎ះ ជាផលរបស់មគ្គ” ដូច្នេះ, ពាក្យក្នុងព្រះសូត្រនោះ បណ្ឌិតគប្បី (សំដែង) ឲ្យពិស្តារ ។*

*មួយទៀត ពាក្យបាលីទាំងឡាយថា “ធម៌ទាំងឡាយនេះ [2] គឺ អរិយមគ្គ ៤ និង សាមញ្ញផល ៤ ជាអប្បមាណារម្មណ៍” ថា “មហគ្គតធម៌ ជាបច្ច័យ ដោយជាអនន្តរប្បច្ច័យនៃអប្បមាណធម៌” ដូច្នេះជាដើម ជាគ្រឿងសំរេច ក្នុងរឿងនេះបាន ។*

(បវត្តៈក្នុងផលសមាបត្តិ)

*តែដើម្បីសំដែងបវត្តៈ ក្នុងផលសមាបត្តិ នៃអរិយផលនោះ មានបញ្ហាកម្មនេះ គឺ ផលសមាបត្តិ គឺអ្វី, បុគ្គលប្រភេទណា ចូលផលសមាបត្តិនោះបាន, បុគ្គលប្រភេទណា ចូលមិនបាន ចូលព្រោះហេតុអ្វី និង ការចូលផលសមាបត្តិនោះ តើដូចម្តេច, តាំងនៅ យ៉ាងដូចម្តេច, ចេញ យ៉ាងដូចម្តេច, អ្វីមាន ក្នុងលំដាប់នៃផល និង ផលមាន ក្នុងលំដាប់នៃអ្វី? ។*

(ផលសមាបត្តិគឺអ្វី)

---

*១- សុ. ខុ. បដិ. ភាគ ៦៩ ទំព័រ ១៥៩ ។ ២- អភិ. សំ. ។*

ក្នុងបញ្ហាកម្មទាំងនោះ បញ្ហាកម្មថា "ផលសមាបត្តិគឺអ្វី" បានដល់ការអែបនែប ក្នុងនិរោធនៃអរិយផល ។

(អ្នកណាចូលផលសមាបត្តិបាន អ្នកណាមិនបាន)

បញ្ហាកម្មថា "បុគ្គលណា ចូលផលសមាបត្តិបាន បុគ្គលណាចូលមិនបាន" បានដល់ បុថុជ្ជនទាំងអស់ចូលមិនបាន ។ ព្រោះហេតុអ្វី? ។ ព្រោះមិនទាន់បានសំរេច(អរិយផល)។ ចំណែកព្រះអរិយបុគ្គលចូលបាន ព្រោះហេតុអ្វី ។ ព្រោះលោកបានសំរេច(អរិយផល)ហើយ។ ប៉ុន្តែព្រះអរិយបុគ្គលថ្នាក់ខ្ពស់ មិនចូលផលសមាបត្តិថ្នាក់ទាបទេ ព្រោះផលថ្នាក់ទាប ស្ងប់រម្ងាប់ហើយ ដោយការចូលទៅកាន់ភាពជាបុគ្គលផ្សេង ។ ឯព្រះអរិយៈថ្នាក់ទាប ក៏ចូលផលសមាបត្តិថ្នាក់ខ្ពស់ មិនបានដែរ ព្រោះលោកមិនទាន់បានសំរេច ។ ក៏ព្រះអរិយបុគ្គល តែងចូលផលសមាបត្តិ របស់ខ្លួនៗ ប៉ុណ្ណោះ, នេះ ជាការសន្និដ្ឋាន ក្នុងបញ្ហាកម្មនេះ ដោយប្រការដូច្នេះ ។

តែអាចារ្យពួកខ្លះ ពោលថា "សូម្បីព្រះសោតាបន្ន និង ព្រះសកទាគាមី ក៏ចូលមិនបាន, ព្រះអរិយថ្នាក់ខ្ពស់ ២ ពួកប៉ុណ្ណោះ ទើបចូលបាន" ក៏នេះជាហេតុនៃអាចារ្យទាំងនោះ គឺ ព្រោះព្រះអរិយៈ ថ្នាក់ខ្ពស់ ២ ពួកនោះ ជាអ្នកធ្វើឲ្យបរិបូណ៌ ក្នុងសមាធិ ។ ហេតុដែលអាចារ្យទាំងនោះពោលនោះ មិនសមហេតុឡើយ ព្រោះសូម្បីបុថុជ្ជន ក៏ចូលលោកិយសមាធិដែលខ្លួនបានហើយ បានដូចគ្នាដែរ ។ តែនឹងបានប្រយោជន៍អ្វីក្នុងការគិតថា ជាហេតុ និង មិនសមហេតុ ក្នុងបញ្ហានេះ ។ ក្នុងបាលីលោកក៏បានពោលហើយ មិនមែនទេឬ ថា "គោត្រភូធម៌ ១០ [១] ដូច

១- សុ. ខុ. បដិ. ភាគទី ៦៩ ទំព័រទី ១៥៣ ។



ម្តេចខ្លះ កើតឡើងដោយអំណាចនៃវិបស្សនា? ធម៌គ្របសង្កត់នូវការកើត ការប្រព្រឹត្តិ ។ល។ នូវការចង្អៀតចង្អល់ចិត្ត.......នូវសង្ខារនិមិត្តខាងក្រៅ ដើម្បីប្រយោជន៍ដល់ការបាន នូវសោតាបត្តិមគ្គ ហេតុនោះឈ្មោះថា គោត្រភូ, ធម៌គ្របសង្កត់នូវការកើត ។ល។ នូវសង្ខារនិមិត្តខាងក្រៅ ដើម្បីប្រយោជន៍ដល់សោតាបត្តិផលសមាបត្តិ........សកទា-គាមិមគ្គ ។ល។ ដើម្បីប្រយោជន៍ដល់អរហត្តផលសមាបត្តិ......ដើម្បីប្រយោជន៍ដល់សុញ្ញតវិហារសមាបត្តិ....ដើម្បីប្រយោជន៍ដល់អនិមិត្តវិហារសមាបត្តិ ហេតុនោះ ធម៌នោះ ឈ្មោះថា គោត្រភូ"ដូច្នេះ ។ ព្រោះហេតុនោះ ព្រះអរិយៈទាំងអស់ តែងចូលផលសមាបត្តិ របស់ខ្លួនៗ បានហេតុដូច្នេះ គប្បីចូលចិត្ត ក្នុងបញ្ហានេះ ។

(ចូលផលសមាបត្តិ ព្រោះហេតុអ្វី)

បញ្ហាកម្មថា "ចូលព្រោះហេតុអ្វី?" ឆ្លើយថា ដើម្បីប្រយោជន៍ដល់ការនៅជាសុខសប្បាយ ក្នុងបច្ចុប្បន្ន ។ ដូចព្រះរាជា សោយសេចក្តីសុខ ក្នុងរាជសម្បត្តិ ទេវតាសោយសេចក្តីសុខដែលជាទិព្វ យ៉ាងណា, ព្រះអរិយៈទាំងឡាយ គិតថា "យើងនឹងសោយនូវលោកុត្តរសុខ" ដូច្នេះហើយ ធ្វើការកំណត់កាលស្រេចហើយ ក៏ចូលផលសមាបត្តិ ក្នុងខណៈដែលខ្លួនត្រូវការហើយៗ ក៏យ៉ាងដូច្នោះដែរ ។

(ចូលដូចម្តេច តាំងនៅ ដូចម្តេច ចេញដូចម្តេច)

បញ្ហាកម្មថា "ក៏ការចូលផលសមាបត្តិនោះ យ៉ាងដូចម្តេច តាំងនៅ យ៉ាងដូចម្តេច ចេញយ៉ាងដូចម្តេច" ឆ្លើយថា ដំបូង ការចូលផលសមាបត្តិនោះ រមែងមាន ដោយអាការៈ ២ យ៉ាង គឺ ព្រោះមិនធ្វើទុកក្នុងចិត្តនូវអារម្មណ៍ផ្សេងៗទៀតក្រៅពីព្រះនិព្វាន ១ ព្រោះធ្វើទុកក្នុងចិត្ត

តែព្រះនិព្វាន ១ ។ ដូចជាព្រះសារីបុត្រ ពោល (នឹងព្រះមហាកោដ្ឋិកៈ) ថា “ម្នាលអាវុសោ [១] អនិមិត្តាចេតោវិមុត្តិសមាបត្តិ មានបច្ច័យ ២ គឺ ការមិនយកចិត្តទុកដាក់ ចំពោះអារម្មណ៍ទាំងពួង ១ ការយកចិត្តទុកដាក់ ចំពោះនិព្វានធាតុ ដែលប្រាសចាកអារម្មណ៍ ១ ” ។

ក៏នេះ គឺជាលំដាប់នៃការចូល ក្នុងការចូលផលសមាបត្តិនោះ ។ អធិប្បាយថា ព្រះអរិយសាវក អ្នកប្រាថ្នាផលសមាបត្តិ ត្រូវទៅកាន់ទីស្ងាត់ គេចចេញពីពួកហើយសម្ងំនៅ ពិចារណាសង្ខារ ដោយវិបស្សនាញាណ មានឧទយព្វយញ្ញាណជាដើម ។ ចិត្ត របស់ព្រះអរិយសាវក អ្នកមានវិបស្សនាញាណ តាមលំដាប់ដែលប្រព្រឹត្តទៅហើយនោះ រមែងអែបនែប ក្នុងនិរោធ ដោយអំណាចផលសមាបត្តិ ក្នុងលំដាប់នៃគោត្រភូញាណ ដែលមានសង្ខារជាអារម្មណ៍ ។ ក៏ក្នុងការចូលផលសមាបត្តិនេះ ព្រោះព្រះអរិយសាវកនោះ បង្អោនចិត្តទៅ ក្នុងផលសមាបត្តិ ទើបផលតែប៉ុណ្ណោះកើតឡើង ដល់ព្រះសេក្ខៈផង, មគ្គ មិនកើតឡើងទេ ។ ឯអាចារ្យទាំងឡាយណា ពោលថា “ព្រះសោតាបន្ន គិតថា អាត្មាអញនឹងចូលផលសមាបត្តិ ក៏ផ្ដើមតាំងវិបស្សនា បានជាព្រះសកទាគាមី និងព្រះសកទាគាមី ផ្ដើមតាំងវិបស្សនា បានជាព្រះអនាគាមី”ដូច្នេះ, អាចារ្យទាំងឡាយនោះ ត្រូវគេពោលថា “កាលបើយ៉ាងដូច្នោះ ព្រះអនាគាមីនឹងបានជាព្រះអរហន្ត, ព្រះអរហន្ត នឹងបានជាព្រះបច្ចេកពុទ្ធ និង ព្រះបច្ចេកពុទ្ធ នឹងបានជាព្រះពុទ្ធ” ដូច្នេះ ។ ព្រោះហេតុនោះ ពាក្យរបស់អាចារ្យទាំងនោះនុ៎ះ ទើបមិនគួរយកជាការបានបន្តិចសោះ, មួយទៀត ពាក្យអាចារ្យទាំងនោះនុ៎ះ ត្រូវបានគេបដិសេធហើយ ដោយអំណាចនៃ

១- សុ. ម. មូ. ភាគទី ២២ ទំព័រទី ២៨០ ។



បាលីហ្នឹងឯង ព្រោះហេតុនេះ ទើបមិនគួរយកជាការបាន ។ តែគួរយកពាក្យនេះតែប៉ុណ្ណោះថា “ផលតែប៉ុណ្ណោះ កើតឡើងដល់ព្រះសេក្ខៈ, មគ្គមិនកើតឡើងទេ, ចំណែកផល បើមគ្គដែលប្រកបដោយបឋមជ្ឈាន គឺព្រះអរិយបុគ្គលនោះ បានសំរេចហើយ ក៏បានជាបឋមជ្ឈានិកផល ដូចគ្នាដែរ រមែងកើតឡើង ដល់ព្រះអរិយបុគ្គលនោះ, បើបណ្ដាមគ្គ ដែលប្រកបដោយទុតិយជ្ឈានជាដើមមាន មគ្គ ដែលប្រកបដោយឈានណាមួយ ផល ក៏នឹងជាផលប្រកប ដោយឈានណាមួយ បណ្ដាផលដែលប្រកបដោយឈាន មានទុតិយជ្ឈាន ជាដើម ក៏ដូចគ្នាដែរ ។

ការចូលសមាបត្តិនោះ រមែងមាន ដោយអាការៈដូច្នេះជាមុនសិន។

ឯការតាំងនៅ នៃផលសមាបត្តិនោះ រមែងមាន ដោយអាការៈ ៣ ដោយពាក្យថា “ម្នាលអាវុសោ [១] បច្ច័យដែលឲ្យអនិមិត្តាចេតោវិមុត្តិតាំងនៅបានយូរ មាន ៣ ប្រការ គឺៈ ការមិនយកចិត្តទុកដាក់ ចំពោះអារម្មណ៍ទាំងពួង ១ ការយកចិត្តទុកដាក់ ចំពោះព្រះនិព្វានធាតុ ដែលប្រាសចាកអារម្មណ៍ ១ ការបានតាក់តែងទុកពីកាលមុន ១” ដូច្នេះ ។

ក្នុងពាក្យទាំងនោះ ពាក្យថា “ការបានតាក់តែងទុកពីកាលមុន ១ ” មានសេចក្ដីថា ការកំណត់កាលទុកមុននឹងចូលសមាបត្តិ អធិប្បាយថា ព្រោះកំណត់ថា “អាត្មាអញនឹងចេញក្នុងកាលឈ្មោះនោះ” ដូច្នេះ កាលនោះមិនទាន់មកដល់ ដរាបណា, ការតាំងនៅ នៃផលសមាបត្តិនោះ ក៏មាន ដរាបនោះដែរ, ការតាំងនៅ នៃផលសមាបត្តិនោះ រមែងមាន ដោយអាការៈ ដូច្នេះឯង ។

ចំណែកការចេញនៃផលសមាបត្តិនោះ រមែងមានដោយអាការៈ ២

១- សុ. ម. មូ. ភាគទី ២២ ទំព័រទី ២៨១ ។

តាមពាក្យ (របស់ព្រះសារីបុត្រ) ថា "ម្នាលអាវុសោ [១] បច្ច័យ នៃការចេញចាកអនិមិត្តាចេតោវិមុត្តិ មាន២ ប្រការ គឺ ការយកចិត្តទុកដាក់ចំពោះអារម្មណ៍ទាំងពួង ១ ការមិនយកចិត្តទុកដាក់ ចំពោះនិព្វានធាតុដែលមិនមានអារម្មណ៍១" ដូច្នេះ។ ក្នុងពាក្យទាំងនោះ ពាក្យថា "ចំពោះអារម្មណ៍ទាំងពួង" បានដល់ ចំពោះរូបនិមិត្ត វេទនានិមិត្ត សញ្ញានិមិត្ត សង្ខារនិមិត្ត វិញ្ញាណនិមិត្ត ។ ព្រះអរិយៈ មិនបានធ្វើទុកក្នុងចិត្ត នូវអារម្មណ៍ទាំងនោះជាមួយគ្នា ក៏ពិតមែនហើយ ទោះជាដូច្នោះ ពាក្យថា អារម្មណ៍ទាំងពួងនោះ លោកពោលហើយ ដោយអំណាចនៃការរួមគ្នាទាំងអស់ ។ ព្រោះហេតុនោះ និមិត្តណា ជាអារម្មណ៍នៃភវង្គ, កាលព្រះយោគាវចរ ធ្វើទុកក្នុងចិត្ត នូវនិមិត្តនោះ ការចេញចាកផលសមាបត្តិ រមែងមាន ។ ការចេញនៃផលសមាបត្តិនោះ គប្បីជ្រាបដូច្នេះឯង ។

(អ្វីមានក្នុងលំដាប់នៃផល)

បញ្ហាកម្មថា "អ្វីមានក្នុងលំដាប់នៃផល និង ផលមានក្នុងលំដាប់នៃអ្វី" ឆ្លើយថា ដំបូង ផលហ្នឹងឯង ឬ ភវង្គ មាន ក្នុងលំដាប់នៃផល ។ តែផល មានក្នុងលំដាប់នៃមគ្គ ក៏មាន ក្នុងលំដាប់នៃផល ក៏មាន ក្នុងលំដាប់នៃគោត្រភូក៏មាន ក្នុងលំដាប់នៃនេវសញ្ញានាសញ្ញាយតនៈ ក៏មាន។ ក្នុងផលទាំងនោះ ផលក្នុងលំដាប់នៃមគ្គ រមែងមាន ក្នុងមគ្គវិថី ផលខាងចុងៗ រមែងមាន ក្នុងលំដាប់នៃផលខាងដើមៗ, ផលខាងដើមៗ ក្នុងផលសមាបត្តិទាំងឡាយ រមែងមាន ក្នុងលំដាប់នៃគោត្រភូ ។ ពាក្យថា "គោត្រភូ" ក្នុងទីនេះ គប្បីជ្រាបថា បានដល់ អនុលោមញ្ញាណ ។ ដូចជាពាក្យដែលលោកពោលហើយ ក្នុងគម្ពីរបដ្ឋាន ថា "អនុលោមញ្ញាណ

១- សុ. ម. មូ. ភាគទី ២២ ទំព័រទី ២៨១ ។



របស់ព្រះអរហន្ត ជាបច្ច័យនៃផលសមាបត្តិ, អនុលោមញ្ញាណ របស់ព្រះសេក្ខៈទាំងឡាយ ជាបច្ច័យនៃផលសមាបត្តិ ដោយអនន្តរប្បច្ច័យ" ដូច្នេះ ។ ការចេញចាកនិរោធ រមែងមាន ដោយផលណា, ផលនោះជាផលដែលមានក្នុងលំដាប់ នៃនេវសញ្ញានាសញ្ញាយតនៈ" ដូច្នេះឯង ។

ក្នុងផលទាំងនោះ លើកលែងតែផល ដែលកើតឡើងហើយ ក្នុងមគ្គវិថីចេញ ផលដ៏សេស ឈ្មោះថា ជាផលដែលប្រព្រឹត្តទៅ ដោយអំណាច នៃផលសមាបត្តិទាំងអស់ ។ ដោយអំណាចដែលកើតឡើងក្នុងមគ្គវិថីខ្លះ ក្នុងផលសមាបត្តិខ្លះ ដូចបានពោលមកហើយនេះ ផលនុ៎ះ

គឺជាសាមញ្ញផល ដ៏ឧត្តម មានការក្រវល់ក្រវាយរម្ងាប់ហើយ មានអមតធម៌ជាអារម្មណ៍ ស្ងប់រម្ងាប់ល្អប្រសើរ មានអាមិសក្នុងលោកខ្ជាក់ចោលហើយ ជាផលដែលជ្រួតជ្រាប ដោយសេចក្ដីសុខ ដ៏ល្អមានឱជារសដែលជាអមតៈ មានរសជាតផ្អែម ក្រៃលែងជាងបង្អែម ប្រៀបដូចទឹកឃ្មុំ, បណ្ឌិត ញុំាងបញ្ញាឲ្យចំរើនឡើងហើយ ទើបបាននូវសេចក្ដីសុខនោះ ដែលជារសដ៏ប្រសើរបំផុត របស់អរិយផលនោះ ព្រោះហេតុណា, ព្រោះហេតុនោះ ការបានសោយនូវរសនៃអរិយផលនោះ លោកហៅថា ជាអានិសង្សនៃវិបស្សនាភាវនា ក្នុងបញ្ញាភាវនានេះ ។

(ភាពជាអ្នកអាចក្នុងការចូលនិរោធសមាបត្តិ)

(៤៦៤) អានិសង្សថា "ភាពជាអ្នកអាចក្នុងការចូលនិរោធសមាបត្តិ"

សេចក្តីថា មួយទៀត មិនមែនបានសោយនូវរសនៃអរិយផល តែម្យ៉ាង ប៉ុណ្ណោះទេ តែសូម្បីភាពជាអ្នកអាច ក្នុងការចូលនិរោធសមាបត្តិនេះ ក៏គួរជ្រាបថា “ជាអានិសង្ស នៃបញ្ញាភាវនានេះផងដែរ” ។

ក្នុងពាក្យថា “ភាពជាអ្នកអាច ក្នុងការចូលនិរោធសមាបត្តិ” នោះនេះ ជាបញ្ហាកម្ម ដើម្បីធ្វើឲ្យប្រាកដច្បាស់ ដល់និរោធសមាបត្តិ គឺ : និរោធសមាបត្តិ គឺជាអ្វី, បុគ្គលពួកណាខ្លះ ចូលនិរោធសមាបត្តិបាន បុគ្គលណាខ្លះ ចូលមិនបាន ចូលក្នុងទីណា ចូលព្រោះហេតុអ្វី មួយទៀត ការចូលនិរោធសមាបត្តិនោះ តើដូចម្តេច ការតាំងនៅ តើដូចម្តេច ការចេញ តើដូចម្តេច ចិត្តរបស់បុគ្គលអ្នកចេញហើយ ជាចិត្តបង្អោនទៅរកអ្វី អ្នកស្លាប់ហើយ និង អ្នកចូលនិរោធសមាបត្តិ មានការខុសគ្នាយ៉ាងដូចម្តេច និរោធសមាបត្តិ ជាសង្ខតៈ ឬ ជាអសង្ខតៈ ជាលោកិយៈ ឬ ជាលោកុត្តរៈ ជានិប្ផន្នៈ ឬ ជាអនិប្ផន្នៈ ។

**(និរោធសមាបត្តិ គឺអ្វី)**

ក្នុងបញ្ហាកម្មទាំងនោះ បញ្ហាកម្មថា “**និរោធសមាបត្តិ គឺអ្វី**” ឆ្លើយថា និរោធសមាបត្តិ គឺការមិនប្រព្រឹត្តិទៅ នៃចិត្តចេតសិកធម៌ទាំងឡាយ ដោយអំណាចការរលត់ទៅ ដោយលំដាប់ ។

**(អ្នកណាចូលនិរោធបាន អ្នកណាចូលមិនបាន)**

បញ្ហាកម្មថា “**អ្នកណាខ្លះ ចូលនិរោធសមាបត្តិនោះបាន អ្នកណាខ្លះ ចូលមិនបាន**” ឆ្លើយថា: បុថុជ្ជនទាំងអស់ ព្រះសោតាបន្ន ព្រះសកទាគាមីទាំងអស់ ព្រះអនាគាមី និង ព្រះអរហន្តទាំងឡាយ ដែលជាសុក្ខវិបស្សកៈ ចូលមិនបាន, តែព្រះអនាគាមី និង ព្រះខីណាស្រពទាំងឡាយដែលបាននូវសមាបត្តិ៨ ចូលបាន ។ ព្រោះលោកពោលហើយថា



“បញ្ញា [១] ដែលមានសភាពស្ទាត់ជំនាញ ព្រោះហេតុប្រកប ដោយកម្លាំង២ ផង ព្រោះរម្ងាប់នូវសង្ខារ ៣ ផង ព្រោះញាណចរិយា ១៦ ផង ព្រោះសមាធិចរិយាទាំង ៩ ផង ឈ្មោះថា និរោធសមាបត្តិញាណ” ។ ក៏សម្បទានេះ លើកលែងតែព្រះអនាគាមី និង ព្រះខីណាស្រពទាំងឡាយ អ្នកបានសមាបត្តិ ៨ ចេញហើយ មិនមានដល់បុគ្គលទាំងឡាយដទៃឡើយ ។ ព្រោះហេតុនោះ ព្រះអនាគាមី និង ព្រះខីណាស្រពទាំងឡាយដែលបានសមាបត្តិ ៨ ទាំងនុ៎ះប៉ុណ្ណោះ ទើបចូលបាន, ពួកបុគ្គលដទៃ ចូលមិនបានទេ ។ មានបញ្ហាកម្មថា “ក៏ក្នុងពាក្យបាលីនេះ កម្លាំង២ តើអ្វីខ្លះ សង្ខារ ៣ គឺអ្វីខ្លះ ញាណចរិយា ១៦ គឺអ្វីខ្លះ សមាធិចរិយា ៩ គឺអ្វីខ្លះ វសីភាវតា តើដូចម្តេច” ។ ក្នុងបញ្ហាកម្មនេះ ពាក្យឆ្លើយតបអ្វីៗ ដែលយើងត្រូវពោលមិនមានទេ ពាក្យឆ្លើយតបទាំងអស់នេះលោកបានពោលហើយ ក្នុងនិទ្ទេស នៃនិទ្ទេសនុ៎ះឯង ។ ដូចជាបាលី ដែលលោកពោលហើយ ថា :

(ពលៈ ២)

ពាក្យថា “**ដោយកម្លាំង ២**” សេចក្តីថា [២] កម្លាំងមាន ២ យ៉ាង គឺ កម្លាំងសមថៈ ១ កម្លាំងវិបស្សនា ១ ។ កម្លាំងសមថៈ តើដូចម្តេច? ។ ការមិនរាយមាយ គឺភាពនៃចិត្ត មានអារម្មណ៍តែមួយ ដោយអំណាចនៃនេក្ខម្មៈ ឈ្មោះថា កម្លាំងសមថៈ, ការមិនរាយមាយ គឺភាពនៃចិត្ត មានអារម្មណ៍តែមួយ ដោយអំណាចនៃការមិនព្យាបាទ.........ដោយអំណាចអាលោកសញ្ញា......ដោយអំណាចការមិនរាយមាយ ។ល។ ដោយអំណាចនៃការឃើញរឿយៗ នូវធម៌ជាគ្រឿងលះបង់ នូវកិលេស

១- សុ. ខុ. បដិ. ភាគទី ៦៩ ទំព័រទី ២២៣ ។ ២- ទំព័រ ២២៤ ។

ហើយដកដង្ហើមចេញ............ដោយអំណាចនៃកិរិយាឃើញរឿយៗ នូវធម៌ជាគ្រឿងលះបង់នូវកិលេស ហើយដកដង្ហើមចូល ឈ្មោះថា កម្លាំងសមថៈ ។ សំនួរត្រង់ពាក្យថា "កម្លាំងសមថៈ" តើកម្លាំងសមថៈ ដោយអត្ថ យ៉ាងដូចម្ដេច? ។ ធម្មជាតិ មិនកំរើកក្នុងនីវរណធម៌ ដោយកម្លាំងបឋមជ្ឈាន ឈ្មោះថា កម្លាំងសមថៈ, ធម្មជាតិ មិនកំរើក ដោយវិតក្កៈ និង វិចារៈដោយទុតិយជ្ឈាន ឈ្មោះថា កម្លាំងសមថៈ ។ល។ ធម្មជាតិ មិនកំរើក ក្នុងអាកិញ្ចញ្ញាយតនសញ្ញា ដោយនេវសញ្ញានាសញ្ញាយតនសមាបត្តិ ឈ្មោះថា កម្លាំងសមថៈ, ធម្មជាតិ មិនកំរើក មិនឃ្លេងឃ្លោង មិនញាប់ញ័រ ក្នុងឧទ្ធច្ចៈផង ក្នុងកិលេស ដែលប្រកបដោយឧទ្ធច្ចៈផង ក្នុងខន្ធផង ឈ្មោះថា កម្លាំងសមថៈ, នេះ គឺកម្លាំងសមថៈ ។

(វិបស្សនាពលៈ)

កម្លាំងវិបស្សនា តើដូចម្ដេច ? ។ ការឃើញរឿយៗ ថា មិនទៀង ឈ្មោះថា កម្លាំងវិបស្សនា ការឃើញរឿយៗ ថា ជាទុក្ខ........ការឃើញរឿយៗ ថា មិនមែនខ្លួន.......ការឃើញរឿយៗ ថា គួរនឿយណាយ.......ការឃើញរឿយៗ ថា ជាគ្រឿងប្រាសចាកតម្រេក.......ការឃើញរឿយៗ ថា រំលត់ទុក្ខ........ការឃើញរឿយៗ ថា គួរលះបង់ ឈ្មោះថា កម្លាំងវិបស្សនា........ការឃើញរឿយៗ ថា មិនទៀង ក្នុងរូប ឈ្មោះថា កម្លាំងវិបស្សនា ។ល។ ការឃើញរឿយៗ ថា ជាគ្រឿងលះបង់ ក្នុងរូប ឈ្មោះថា កម្លាំងវិបស្សនា ការឃើញរឿយៗ ថា មិនទៀង ក្នុងវេទនា ។ល។ ក្នុងសញ្ញា ក្នុងសង្ខារ ក្នុងវិញ្ញាណ ។ល។ ក្នុងចក្ខុ ក្នុងជរាមរណៈ ឈ្មោះថា កម្លាំងវិបស្សនា ។ល។ ការឃើញរឿយៗ ថា ជាគ្រឿងលះបង់ ក្នុងជរាមរណៈ ឈ្មោះថា កម្លាំងវិបស្សនា ។ សំណួរ ត្រង់ពាក្យថា



"កម្លាំងវិបស្សនា" តើកម្លាំងវិបស្សនា ដោយអត្ថ ដូចម្ដេច ។ ធម្មជាតិ មិនកំរើក ក្នុងនិច្ចសញ្ញា ដោយអនិច្ចានុបស្សនា ឈ្មោះថា កម្លាំងវិបស្សនា, ធម្មជាតិ មិនកំរើក ក្នុងសុខសញ្ញា ដោយទុក្ខានុបស្សនា ឈ្មោះថា កម្លាំងវិបស្សនា, ធម្មជាតិ មិនកំរើក ក្នុងអត្តសញ្ញា ដោយអនត្តានុបស្សនា ឈ្មោះថា កម្លាំងវិបស្សនា, ធម្មជាតិ មិនកំរើក ក្នុងសេចក្ដីត្រេកអរ ដោយនិព្វិទានុបស្សនា ឈ្មោះថា កម្លាំងវិបស្សនា, ធម្មជាតិ មិនកំរើក ក្នុងរាគៈ ដោយវិរាគានុបស្សនា ឈ្មោះថា កម្លាំងវិបស្សនា, ធម្មជាតិ មិនកំរើក ក្នុងសមុទ័យ ដោយនិរោធានុបស្សនា ឈ្មោះថា កម្លាំងវិបស្សនា, ធម្មជាតិ មិនកំរើក ក្នុងសេចក្ដីប្រកាន់មាំ ដោយបដិនិស្សគ្គានុបស្សនា ឈ្មោះថា កម្លាំងវិបស្សនា, ធម្មជាតិ មិនកំរើក មិនឃ្លេងឃ្លោង មិនញាប់ញ័រ ក្នុងអវិជ្ជាផង ក្នុងកិលេសដែលប្រកបដោយអវិជ្ជាផង ក្នុងខន្ធផង ឈ្មោះថា កម្លាំងវិបស្សនា, នេះ គឺកម្លាំងវិបស្សនា ។

(ការស្ងប់រម្ងាប់នៃសង្ខារ ៣)

សំណួរ ត្រង់ពាក្យថា "ការស្ងប់រម្ងាប់សង្ខារ ៣" តើការស្ងប់រម្ងាប់នៃសង្ខារ ដូចម្ដេច ។ កាលបុគ្គលចូលកាន់ទុតិយជ្ឈាន, វចីសង្ខារ គឺ វិតក្កៈ និង វិចារៈ រមែងស្ងប់រម្ងាប់, កាលបុគ្គលចូលកាន់ចតុត្ថជ្ឈាន, កាយសង្ខារ គឺអស្សាសៈ និង បស្សាសៈ រមែងស្ងប់រម្ងាប់, កាលបុគ្គលចូលកាន់សញ្ញាវេទយិតនិរោធ, ចិត្តសង្ខារ គឺសញ្ញា និង វេទនា រមែងស្ងប់រម្ងាប់, នេះ គឺការស្ងប់រម្ងាប់នៃសង្ខារ ៣ ។

(ញាណចរិយា ១៦)

សំណួរ ត្រង់ពាក្យថា "ញាណចរិយា ១៦" តើញាណចរិយា ១៦

ដូចម្តេច ។ ការឃើញរឿយៗ ថា មិនទៀង ឈ្មោះថា ញាណចរិយា ការឃើញរឿយៗ ថា ជាទុក្ខ....ការឃើញៗរឿយៗ ថា ជាអនត្តា.....ការឃើញរឿយៗ ថា គួរនឿយណាយ........ការឃើញរឿយៗ ថា ជាគ្រឿងប្រាសចាកតម្រេក....ការឃើញរឿយៗ ថា រំលត់ទុក្ខ...ការឃើញរឿយៗ ថា ជាគ្រឿងលះបង់កិលេស..ការឃើញរឿយៗ ថា ជាគ្រឿងប្រាសចាកការវិលវល់ ឈ្មោះថា ញាណចរិយា, សោតាបត្តិមគ្គ ឈ្មោះថា ញាណចរិយា សោតាបត្តិផលសមាបត្តិ ឈ្មោះថា ញាណចរិយា សកទាគាមិ-មគ្គ ឈ្មោះថា ញាណចរិយា ។បេ។ អរហត្តផលសមាបត្តិ ឈ្មោះថា ញាណចរិយា ដោយញាណចរិយា ១៦ នេះ ។

(សមាធិចរិយា ៩)

សំណួរ ត្រង់ពាក្យថា “សមាធិចរិយា ៩” តើសមាធិចរិយា ៩ ដូចម្តេច ។ បឋមជ្ឈាន ឈ្មោះថា សមាធិចរិយា, ទុតិយជ្ឈាន ឈ្មោះថា សមាធិចរិយា ។បេ។ នេវសញ្ញានាសញ្ញាយតនសមាបត្តិ ឈ្មោះថា សមាធិចរិយា, វិតក្កៈ វិចារៈ បីតិ សុខៈ និង ចិត្តេកគ្គតា (ប្រព្រឹត្តទៅ) ដើម្បីប្រយោជន៍ដល់កិរិយាបាននូវបឋមជ្ឈាន ។បេ។ វិតក្កៈ វិចារៈ បីតិ សុខៈ និង ចិត្តេកគ្គតា (ប្រព្រឹត្តទៅ) ដើម្បីប្រយោជន៍ដល់កិរិយាបាននូវនេវសញ្ញានាសញ្ញាយតនសមាបត្តិ, ដោយសមាធិចរិយា ៩ នេះ ។

(វសី ៥)

ពាក្យថា “សេចក្តីស្ទាត់” អធិប្បាយថា សេចក្តីស្ទាត់ មាន ៥ យ៉ាង គឺ សេចក្តីស្ទាត់ ក្នុងការនឹក ១ សេចក្តីស្ទាត់ ក្នុងការចូល ១ សេចក្តីស្ទាត់ ក្នុងការចេញ ១ សេចក្តីស្ទាត់ ក្នុងការអធិដ្ឋាន ១ សេចក្តីស្ទាត់ ក្នុងការពិចារណា ១ ។



បុគ្គលនឹកនូវបឋមជ្ឈានដែលខ្លួនប្រាថ្នា ក្នុងទីណា ប្រាថ្នាក្នុងកាលណា ប្រាថ្នាត្រឹមណា ។ សេចក្តីយឺតយូរ ក្នុងការនឹក មិនមាន ហេតុនោះ ឈ្មោះថា សេចក្តីស្ទាត់ ក្នុងការនឹក ។

បុគ្គលចូលកាន់នូវបឋមជ្ឈានដែលខ្លួនប្រាថ្នា ក្នុងទីណា ប្រាថ្នាក្នុងកាលណា ប្រាថ្នាត្រឹមណា ។ សេចក្តីយឺតយូរ ក្នុងការចូល មិនមាន ហេតុនោះ ឈ្មោះថា សេចក្តីស្ទាត់ ក្នុងការចូល ។

បុគ្គលអធិដ្ឋាននូវបឋមជ្ឈាន ដែលខ្លួនប្រាថ្នាក្នុងទីណា ប្រាថ្នាក្នុងកាលណា ប្រាថ្នាត្រឹមណា ។ សេចក្តីយឺតយូរ ក្នុងការអធិដ្ឋាន មិនមាន ហេតុនោះ ឈ្មោះថា សេចក្តីស្ទាត់ ក្នុងការអធិដ្ឋាន ។

បុគ្គលចេញពីបឋមជ្ឈានដែលខ្លួនប្រាថ្នាក្នុងទីណា ប្រាថ្នាក្នុងកាលណា ប្រាថ្នាត្រឹមណា ។ សេចក្តីយឺតយូរ ក្នុងការចេញ មិនមាន ហេតុនោះ ឈ្មោះថា សេចក្តីស្ទាត់ ក្នុងការចេញ ។

បុគ្គលពិចារណានូវបឋមជ្ឈាន ដែលខ្លួនប្រាថ្នា ក្នុងទីណា ប្រាថ្នាក្នុងកាលណា ប្រាថ្នាត្រឹមណា ។ សេចក្តីយឺតយូរ ក្នុងការពិចារណា មិនមាន ហេតុនោះ ឈ្មោះថា សេចក្តីស្ទាត់ ក្នុងការពិចារណា ។

បុគ្គលនឹកនូវបឋមជ្ឈាន ។បេ។ នូវនេវសញ្ញានាសញ្ញាយតនសមាបត្តិ ដែលខ្លួនប្រាថ្នា ក្នុងទីណា ប្រាថ្នា ក្នុងកាលណា ប្រាថ្នាត្រឹមណា ។ សេចក្តីយឺតយូរ ក្នុងការនឹក មិនមាន ហេតុនោះ ឈ្មោះថា សេចក្តីស្ទាត់ ក្នុងការនឹក ។បេ។ បុគ្គលអធិដ្ឋាន.....ចេញ....ពិចារណា សេចក្តីយឺតយូរក្នុងការពិចារណា មិនមាន ហេតុនោះ ឈ្មោះថា សេចក្តីស្ទាត់ ក្នុងការពិចារណា, នេះឯងសេចក្តីស្ទាត់ ៥ យ៉ាង ។

ក៏ក្នុងបាលីនុ៎ះ និទ្ទេសនៃពាក្យថា “ដោយញាណចរិយា ១៦” នេះ

ជានិទ្ទេសដ៏ខ្ពង់ខ្ពស់ ។ ព្រោះថា សំរាប់ព្រះអនាគាមី វសីភាវតាបញ្ញា រមែងមាន ដោយញាណចរិយា ១៤ ។ បើមានពាក្យចោទថា “បើដូច្នោះ សំរាប់ព្រះសកទាគាមី រមែងមាន ដោយញាណចរិយា ១២ និង សំរាប់ព្រះសោតាបន្ន រមែងមិនមាន ដោយញាណចរិយា ១០ ឬ” ដូច្នេះ ។ គប្បីឆ្លើយថា “សំរាប់ព្រះសេក្ខៈថ្នាក់ទាប ២ ពួកនេះ វសីភាវតាបញ្ញា មិនមានទេ ព្រោះរាគៈដែលប្រកបដោយកាមគុណ ៥ ដែលធ្វើអន្តរាយឲ្យដល់សមាធិ លោកលះបង់មិនទាន់បាន ។ ក៏ព្រោះរាគៈនោះ លោកលះពុំទាន់បាន ព្រោះហេតុនោះ កម្លាំងសមថៈ ទើបមិនបរិបូណ៌, កាលបើសមថពលៈនោះ មិនទាន់គ្រប់បរិបូណ៌ហើយ លោកក៏មិនអាចចូលនិរោធសមាបត្តិ ដែលត្រូវចូល ដោយកម្លាំងទាំង ២ បានឡើយ ព្រោះមានកម្លាំមិនគ្រប់គ្រាន់, ប៉ុន្តែ រាគៈនោះ គឺព្រះអនាគាមី លះបានហើយ ព្រោះហេតុនោះ ព្រះអនាគាមីនោះ ជាអ្នកមានកម្លាំងគ្រប់បរិបូណ៌ ព្រោះជាអ្នកមានកម្លាំងបរិបូណ៌ ទើបលោកអាច(ចូលនិរោធសមាបត្តិ) បាន ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ថា “កាលបុគ្គលចេញពីនិរោធសមាបត្តិ នេវសញ្ញានាសញ្ញាយតនកុសល ជាបច្ច័យ នៃផលសមាបត្តិ ដោយអនន្តរប្បច្ច័យ” ដូច្នេះ ។ ក៏ពាក្យនេះ ព្រះមានព្រះភាគត្រាស់ ក្នុងគម្ពីរមហាបករណបដ្ឋាន សំដៅយកការចេញពីនិរោធរបស់ព្រះអនាគាមីហ្នឹងឯង ។

(ចូលបានក្នុងទីណា)

ត្រង់សំណួរថា“ចូលបានក្នុងទីណា” ឆ្លើយថា ក្នុងបញ្ចវោការភព។ ព្រោះហេតុអ្វី? ។ ព្រោះនិរោធសមាបត្តិនោះ មានការចូលទៅ តាមលំដាប់លំដោយ ។ តែនៅក្នុងចតុវោការភព (គឺអរូបភព) ការកើតឡើងនៃរូបសមាបត្តិ មានបឋមជ្ឈានជាដើម មិនមានទេ ព្រោះហេតុនោះ ទើបមិនអាចចូល ក្នុងចតុវោការភពនោះបាន ។ តែអាចារ្យពួកខ្លះ ពោលថា “ចូលមិនបាន ព្រោះហទយវត្ថុ មិនមាន” ដូច្នេះ ។



(ចូលព្រោះហេតុអ្វី)

ត្រង់សំណួរថា “ចូលព្រោះហេតុអ្វី” ឆ្លើយថា លោកនឿយណាយក្នុងការប្រព្រឹត្តិទៅផ្សេងៗ នៃសង្ខារទាំងឡាយ ហើយចូល (និរោធ) ដោយមានបំណងថា “អាត្មាអញ ជាអ្នកមិនមានចិត្តដល់និរោធ គឺព្រះនិព្វាន ហើយនឹងនៅជាសុខ ក្នុងទិដ្ឋធម្ម(បច្ចុប្បន្ន) នេះឯង” ដូច្នេះ ។

(ចូលដូចម្ដេច)

ត្រង់សំណួរថា “ចូលដូចម្ដេច” ឆ្លើយថា ការចូលនិរោធសមាបត្តិនោះ រមែងមាន ដល់ព្រះអរិយបុគ្គល អ្នកព្យាយាម ដោយអំណាចនៃសមថៈ និង វិបស្សនា ធ្វើបុព្វកិច្ចស្រេចហើយ ញ៉ាំងនេវសញ្ញានាសញ្ញាយតនៈ ឲ្យរលត់ ។ ការចូលនិរោធសមាបត្តិនោះ ដូច្នេះឯង ។

ក៏នេះ ជាសេចក្ដីសង្ខេប ក្នុងនិរោធសមាបត្តិនោះ គឺបុគ្គលណាព្យាយាម ដោយអំណាចនៃសមថៈតែម្យ៉ាង បុគ្គលនោះ សម្រេចនូវនេវសញ្ញានាសញ្ញាយតនៈ ហើយស្ថិតនៅ, ឯបុគ្គលណា ព្យាយាមដោយអំណាចនៃវិបស្សនាតែម្យ៉ាង បុគ្គលនោះ សម្រេចផលសមាបត្តិ ហើយក៏ស្ថិតនៅ, តែបុគ្គលណាព្យាយាម ដោយអំណាចនៃសមថៈ និង វិបស្សនាទាំងពីរយ៉ាងនុ៎ះឯង ធ្វើបុព្វកិច្ចស្រេចហើយ ញ៉ាំងនេវសញ្ញានាសញ្ញាយតនៈ ឲ្យរលត់ បុគ្គលនោះ ចូលនិរោធសមាបត្តិនោះបាន ។

(៤៦៥) ប៉ុន្តែនេះជាសេចក្ដីពិស្ដារ គឺភិក្ខុ ក្នុងព្រះពុទ្ធសាសនានេះ ប្រាថ្នានឹងចូលកាន់និរោធ ធ្វើភត្តកិច្ចស្រេចហើយលាងដៃ និងជើងស្អាត

ល្អហើយ អង្គុយលើអាសនៈ ដែលក្រាលល្អហើយ ក្នុងឱកាសស្ងាត់ ពត់ភ្នែន តាំងកាយឲ្យត្រង់ តម្រង់សតិ ឲ្យនៅចំពោះមុខ, ភិក្ខុនោះ ចូលកាន់ឈាន ទី១ ចេញហើយ ពិចារណាសង្ខារទាំងឡាយ ក្នុងបឋមជ្ឈាននោះ ថា ជារបស់មិនទៀង ថា ជាទុក្ខ ថា ជារបស់មិនមែនខ្លួន ។

(វិបស្សនា ៣)

ក៏វិបស្សនានោះ មាន ៣ យ៉ាង គឺ សង្ខារបរិគ្គណ្ហណកវិបស្សនា (គឺវិបស្សនាដែលកំណត់នូវសង្ខារ) ផលសមាបត្តិវិបស្សនា (វិបស្សនាដែលសំរាប់ចូលកាន់ផលសមាបត្តិ) និរោធសមាបត្តិវិបស្សនា(វិបស្សនាដែលសំរាប់ចូលកាន់និរោធសមាបត្តិ) ។ ក្នុងសមាបត្តិទាំង ៣ នោះ សង្ខារបរិគ្គណ្ហណកវិបស្សនា ជាវិបស្សនាខ្ចី ឬ ចាស់ក្លា ក៏ដោយ ក៏ជាបទដ្ឋាននៃមគ្គទុំះឯង ។ ផលសមាបត្តិវិបស្សនា ជាវិបស្សនាចាស់ក្លា ទើបគួរ ដូចជាមគ្គភាវនា ។ ឯនិរោធសមាបត្តិវិបស្សនា ជាវិបស្សនាដែលមិនខ្ចីពេក មិនចាស់ក្លាពេក ទើបគួរ ។ ព្រោះហេតុនោះ បុគ្គលអ្នកចូលនិរោធសមាបត្តិនោះ ទើបឈ្មោះថា ពិចារណាសង្ខារទាំងនោះ ដោយវិបស្សនា ដែលមិនខ្ចីពេក មិនចាស់ពេក ។

(លំដាប់នៃការចូលសមាបត្តិ)

លំដាប់នោះ បុគ្គលនោះ ចូលកាន់ទុតិយជ្ឈាន ចេញហើយ ក៏ពិចារណានូវសង្ខារទាំងឡាយ ក្នុងទុតិយជ្ឈាននោះ ក៏យ៉ាងដូច្នោះដែរ, បន្ទាប់មក ក៏ចូលកាន់តតិយជ្ឈាន ។ល។ បន្ទាប់ពីនោះមក ក៏ចូលកាន់វិញ្ញាណញ្ចាយតនៈ ចេញហើយ ក៏ពិចារណាសង្ខារទាំងឡាយ ក្នុងវិញ្ញាណញ្ចាយតនៈនោះ យ៉ាងនេះដែរ ។ គ្រានោះ បុគ្គលនោះចូលកាន់អាកិញ្ចញ្ញាយតនៈចេញហើយធ្វើបុព្វកិច្ច៤ យ៉ាង គឺនានាពទ្ធអវិកោបនៈ



(គឺមិនញុំាងវត្ថុ ដែលជាប់ទាក់ទងនឹងភិក្ខុផ្សេងៗ ឲ្យកំរើក) សង្ឃប្បដិមាននៈ (គឺការរង់ចាំចំពោះនៃសង្ឃ) សត្ថុបកោសនៈ (គឺការត្រាស់ឲ្យហៅមក នៃព្រះសាស្ដា) អទ្ធានបរិច្ឆេទៈ (គឺការកំណត់កាលនៃជីវិត) ។

(នានាពទ្ធអវិកោបនៈ)

ក្នុងបុព្វកិច្ចទាំង៤ នោះ ពាក្យថា“នានាពទ្ធអវិកោបនៈ” អធិប្បាយថា វត្ថុឯណា មិនមែនជារបស់ ដែលជាប់ទាក់ទងជាមួយនឹងភិក្ខុរូបនេះតែម្នាក់ឯងទេ ជារបស់ដែលជាប់ទាក់ទង ជាមួយនឹងភិក្ខុផ្សេងៗ ទៀតតាំងនៅ ជាបាត្រចីវរក្តី ជាគ្រែតាំងក្តី ជាគ្រែកៅអីក្តី ជាផ្ទះសម្រាប់នៅអាស្រ័យក្តី ឬក៏ ជារបស់របរបរិក្ខារ ឯណាមួយដទៃទៀតក្តី វត្ថុទាំងនោះ មិនកំរើក គឺនឹងមិនវិនាសទៅ ដោយអំណាចអន្តរាយទាំងឡាយ មានភ្លើង ទឹក ខ្យល់ ចោរ និង កណ្ដុរជាដើម ដោយប្រការណា, គប្បីអធិដ្ឋាន ដោយប្រការនោះចុះ ។ នេះ ជាវិធីអធិដ្ឋាន ក្នុងរឿងនោះ គឺ អធិដ្ឋាន ថា “របស់នេះមួយ នោះមួយ ក្នុងរយៈពេល៧ ថ្ងៃនេះ កុំត្រូវភ្លើងឆេះ កុំត្រូវទឹកកួចនាំយកទៅ កុំត្រូវខ្យល់បំផ្លាញ កុំត្រូវចោរលួចយកទៅ កុំត្រូវសត្វចង្រៃទាំងឡាយមានកណ្ដុរជាដើម កាត់កកេរឡើយ” កាលបើអធិដ្ឋាន យ៉ាងនេះហើយ រហូត ៧ ថ្ងៃ អន្តរាយអ្វីៗ ក៏មិនមានដល់វត្ថុនោះ ។ ប៉ុន្តែបើមិនអធិដ្ឋានទេ វត្ថុនោះ តែងវិនាសទៅ ដោយអន្តរាយទាំងឡាយមានភ្លើងជាដើម ដូចជារបស់របរនៃព្រះមហានាគត្ថេរយ៉ាងនោះឯង ។

មានរឿងដំណាលថា: ព្រះថេរៈ និមន្តចូលទៅក្នុងផ្ទះ នៃឧបាសិកាដែលត្រូវជាម្ដាយ ដើម្បីបិណ្ឌបាត ។ ឧបាសិកា ប្រគេនយាគូហើយ ក៏និមន្តឲ្យលោកទៅគង់លើអាសនសាលា ។ ព្រះថេរៈ គង់ចូលនិរោធ ។

កាលដែលលោកគង់ចូលនិរោធហើយ អាសនសាលា ក៏ត្រូវភ្លើងឆេះ ។ ពួកភិក្ខុក្រៅពីនោះ ក៏ចាប់អាសនៈដែលខ្លួនគង់ហើយរៀងៗខ្លួន រត់ចេញហើយ ។ ពួកអ្នកស្រុកមកប្រជុំគ្នា ឃើញព្រះថេរៈហើយ ក៏ពោលថា "ព្រះថេរៈជាសមណៈខ្ជិលច្រអូសៗ" ដូច្នេះ។ ភ្លើងឆេះស្មៅ ឫស្សី និងឈើទាំងឡាយហើយតាំងនៅជុំវិញព្រះថេរៈ ។ ពួកមនុស្ស ក៏យកឆ្នាំងមកដងទឹករំលត់ភ្លើង ហើយបោសយកផេះចេញ ធ្វើ(ព័ទ្ធ) ជារង់ ជុំវិញ (ព្រះថេរៈ) បាចផ្កាហើយ ក៏ឈរនមស្សការ (ព្រះថេរៈ) ។ ព្រះថេរៈចេញពី (ពីនិរោធ) ដោយអំណាចនៃកាល ដែលបានកំណត់ទុកហើយ ឃើញពួកអ្នកស្រុកទាំងនោះ ក៏គិតថា "អាត្មាអញ ជាអ្នកប្រាកដហើយ" ដូច្នេះ ក៏ហោះទៅកាន់អាកាស បានដល់ទៅកោះ ឈ្មោះ បិយង្គុហើយ ។

នេះ ឈ្មោះថា នានាពទ្ធអវិកោបនៈ ។ ចំណែកវត្ថុណា ជារបស់ដែលជាប់ទាក់ទងតែខ្លួនម្នាក់ឯង ជារបស់ស្លៀកដណ្តប់ក្តី ជាអាសនៈដែលខ្លួនអង្គុយក្តី កិច្ចដែលត្រូវអធិដ្ឋាន ដោយឡែកផ្សេង ក្នុងវត្ថុនោះ មិនមានទេ ។ បុគ្គលអ្នកចូលនិរោធ រមែងរក្សាវត្ថុនោះ ដោយអំណាចសមាបត្តិហ្នឹងឯង ដូចវត្ថុរបស់ព្រះសញ្ជីវៈដ៏មានអាយុ យ៉ាងនោះឯង ។ ដូចពាក្យបាលី ដែលលោកពោលថា "ឫទ្ធិ គឺការផ្សាយចេញ នៃសមាធិរបស់ព្រះសញ្ជីវៈមានអាយុ [១] ឫទ្ធិ គឺការផ្សាយចេញនៃសមាធិ របស់ព្រះសារីបុត្រ មានអាយុ" ដូច្នេះ ។

(សង្ឃប្បដិមាននៈ)

ការរង់ចាំ គឺការរង់ចាំចំពោះនៃសង្ឃ ឈ្មោះថា សង្ឃប្បដិមាននៈ។ មានសេចក្តីថា: ភិក្ខុមួយរូប មិនទាន់មកដល់ ដរាបណា, ក៏មិនធ្វើ

១- សុ. ខុ. បដិ. ភាគទី ៧១ ទំព័រទី ២៨០ ។



សង្ឃកម្ម ដរាបនោះ ។ ក៏ក្នុងរឿងនេះ ការរង់ចាំ មិនមែនជាបុព្វកិច្ចរបស់ភិក្ខុអ្នកចូលនិរោធនោះឡើយ ។ តែការនឹកទៅដល់ការរង់ចាំ គឺជាបុព្វកិច្ច ។ ព្រោះហេតុនោះ ភិក្ខុអ្នកចូលនិរោធ គប្បីពិចារណា យ៉ាងនេះថា "បើអាត្មាអញអង្គុយចូលនិរោធ អស់៧ ថ្ងៃ, ព្រះសង្ឃនឹងប្រាថ្នាធ្វើនូវកម្មណាមួយ ក្នុងបណ្តាសង្ឃកម្មទាំងឡាយ មានញត្តិកម្មជាដើម អាត្មាអញនឹងចេញភ្លាម កុំឲ្យភិក្ខុណា មកហៅអាត្មាអញទាន់" ដូច្នេះ ។ ព្រោះថា ធ្វើដូច្នេះហើយទើបចូល ភិក្ខុនោះ ក៏ចេញ ក្នុងពេលនោះឯង ។ តែភិក្ខុរូបណា មិនធ្វើដូច្នោះទេ, ព្រះសង្ឃប្រជុំគ្នាហើយ មិនឃើញភិក្ខុនោះ ក៏សួរថា "ភិក្ខុឈ្មោះនោះ ទៅទីណា" កាលបើភិក្ខុមួយរូបប្រាប់ថា "លោកចូលនិរោធហើយ" ដូច្នេះ ព្រះសង្ឃ នឹងបញ្ជូនភិក្ខុរូបណាមួយទៅ ដោយប្រាប់ថា "ចូលលោកទៅហៅភិក្ខុរូបនោះ តាមពាក្យ របស់សង្ឃ" ដូច្នេះ ។ គ្រានោះ គ្រាន់តែភិក្ខុ អ្នកចូលទៅហៅនោះ ឈរនៅក្នុងទីជិតល្មមនឹងហៅឮ ហើយប្រាប់ ថា "អាវុសោ សង្ឃរង់ចាំលោក" ដូច្នេះឯង, ភិក្ខុ(អ្នកចូលនិរោធ) នោះ ទើបចេញ ។ ព្រោះធម្មតាសេចក្តីបង្គាប់(អាជ្ញា) របស់សង្ឃ ជាការសំខាន់ ដោយប្រការដូច្នេះ ។ ព្រោះហេតុនោះ ភិក្ខុអ្នកចូលនិរោធ ត្រូវពិចារណានឹកដល់ការរង់ចាំ នៃសង្ឃនោះ ហើយចាំចូល (និរោធ) ដូចដែលខ្លួនឯងចេញបាន (កុំចាំដល់ឲ្យគេហៅនោះ) ។

(សត្ថុបក្កោសនៈ)

(៤៦៦) សូម្បីក្នុងពាក្យថា"សត្ថុបក្កោសនៈ"នេះ ការនឹកពិចារណាដល់ការត្រាស់ឲ្យហៅមក របស់ព្រះសាស្តា ក៏ជាកិច្ចរបស់ភិក្ខុអ្នកចូលនិរោធនេះ ។ ហេតុនោះ សូម្បីព្រះតម្រាស់ ដែលត្រាស់ហៅមកនោះ

ក៏ភិក្ខុនោះ ត្រូវនឹកពិចារណា យ៉ាងនេះថា “ប្រសិនបើអាត្មាអញ អង្គុយចូលនិរោធ អស់៧ ថ្ងៃ, ព្រះសាស្តាទ្រង់បញ្ញត្តិសិក្ខាបទ ក្នុងរឿងដែលកើតហើយក្តី ទ្រង់សំដែងធម៌ ក្នុងការកើតហេតុ យ៉ាងដូច្នោះក្តី, អាត្មាអញ នឹងចេញភ្លាម មិនឲ្យអ្នកណាម្នាក់ មកហៅអញទាន់ទេ” ដូច្នេះ ។ ព្រោះថា លុះធ្វើយ៉ាងនេះហើយ អង្គុយ (ចូលនិរោធ) ភិក្ខុនោះ ក៏ចេញ (ពីនិរោធ) បានភ្លាម ក្នុងពេលនោះ ។ ឯភិក្ខុណា មិនធ្វើយ៉ាងដូច្នោះ និង ព្រះសាស្តា កាលបើសង្ឃប្រជុំគ្នាហើយ មិនឃើញភិក្ខុនោះ ទើបត្រាស់សួរថា “ចុះភិក្ខុឈ្មោះនោះទៅទីណា” កាលបើភិក្ខុមួយអង្គ ក្រាបទូលថា “លោកចូលនិរោធហើយ” ដូច្នេះ ទើបបញ្ជូនភិក្ខុរូបណាមួយទៅ ដោយព្រះតម្រាស់ថា “ចូរអ្នកទៅ ហៅភិក្ខុនោះមក តាមពាក្យតថាគត” ដូច្នេះ ។ គ្រានោះ គ្រាន់តែភិក្ខុនោះ ទៅឈរនៅក្បែរទីដែលនឹងហៅឮ ហើយប្រាប់ថា “ព្រះសាស្តា ទ្រង់ត្រាស់ឲ្យហៅលោកមានអាយុ” ដូច្នេះឯង, ភិក្ខុ(អ្នកចូលនិរោធ)នោះ ក៏ចេញបាន ។ ព្រោះថា ព្រះតម្រាស់ត្រាស់ឲ្យហៅ របស់ព្រះសាស្តា ជាការសំខាន់ យ៉ាងនេះឯង ។ ព្រោះហេតុនោះ ភិក្ខុអ្នកចូលនិរោធ ត្រូវនឹកពិចារណា នូវព្រះតម្រាស់ត្រាស់ឲ្យហៅ របស់ព្រះសាស្តានោះហើយ ចាំចូល (និរោធ) ដូចដែលចេញខ្លួនឯងចេញបាន (កុំចាំដល់ព្រះសាស្តាទ្រង់ត្រាស់ឲ្យហៅមក) ។

**(អទ្ធានបរិច្ឆេទ)**

ការកំណត់កាលនៃជីវិត ឈ្មោះថា អទ្ធានបរិច្ឆេទ ។ ក៏ភិក្ខុ(អ្នកចូលនិរោធ) នេះ ត្រូវតែឆ្លាតមែនទែន ក្នុងការកំណត់កាល ។ ត្រូវនឹកពិចារណាថា “អាយុសង្ខាររបស់ខ្លួន នឹងប្រព្រឹត្តទៅ នឹងមិនប្រព្រឹត្តទៅរហូត ៧ ថ្ងៃ” ដូច្នេះហើយ ទើបចូល ។ ព្រោះថាប្រសិនបើមិនបាននឹក



ពិចារណាអាយុសង្ខារដែលត្រូវរលត់ ក្នុងចន្លោះ៧ ថ្ងៃទេ ហើយ ក៏ចូល (និរោធ), និរោធសមាបត្តិ របស់ភិក្ខុនោះ មិនអាចការពារមរណបានទេ ។ ភិក្ខុនោះ រមែងចេញពីសមាបត្តិ ក្នុងចន្លោះនោះឯង ព្រោះសេចក្តីស្លាប់ខាងក្នុងនិរោធ មិនមានទេ ។ ហេតុនោះ ត្រូវនឹកពិចារណាដល់ការកំណត់កាល នៃជីវិតនោះសិន ចាំចូល (និរោធ) ។ ពិតមែន សូម្បីមិននឹកពិចារណា នូវបុព្វកិច្ចដ៏សេសក៏គួរ ។ ប៉ុន្តែ ការកំណត់កាល នៃជីវិតនោះ លោកពោលថា “ត្រូវតែនឹកពិចារណាឲ្យទាល់តែបាន” ។

**(ការចូលនិរោធ)**

ភិក្ខុនោះ លុះចូលអាកិញ្ចញ្ញាយតនៈ ចេញហើយ ធ្វើបុព្វកិច្ចនេះយ៉ាងនេះហើយ ក៏ចូលនេវសញ្ញានាសញ្ញាយតនៈ ។ គ្រានោះ កន្លងវារចិត្តមួយ ឬ ពីរ ហើយ ភិក្ខុនោះ ជាអ្នកមិនមានចិត្ត រមែងពាល់ត្រូវនិរោធ (សំរេចនិរោធ) ។

សួរថា “ក៏ព្រោះហេតុអ្វី ចិត្តទាំង ៤ របស់ភិក្ខុនោះ មិនប្រព្រឹត្តទៅលើចិត្ត ២?” ។ ឆ្លើយថា “ព្រោះជាប្រយោគនៃនិរោធ” ។ មែនពិតការធ្វើធម៌២ យ៉ាង គឺសមថៈ និង វិបស្សនា ឲ្យជាធម៌ជាប់គ្នាជាគូហើយលើកឡើងកាន់សមាបត្តិ ៨ របស់ភិក្ខុនោះ នេះ គឺជាប្រយោគនៃកិរិយារលត់ដោយលំដាប់ មិនមែនជាប្រយោគ នៃនេវសញ្ញានាសញ្ញាយតន-សមាបត្តិទេ ហេតុនោះ ចិត្តទាំងឡាយ របស់ភិក្ខុនោះ ទើបមិនប្រព្រឹត្តទៅលើចិត្ត ២ ដួង ព្រោះជាប្រយោគនៃនិរោធ ។ ចំណែកឯ ភិក្ខុណាចេញពីអាកិញ្ចញ្ញាយតនៈ មិនធ្វើបុព្វកិច្ចនេះ ហើយចូលនេវសញ្ញានា-សញ្ញាយតនៈហ្នឹងឯងវិញ ។ ក៏សេចក្តីឧបមា ដោយបុរសអ្នកមិនធ្លាប់ដើរផ្លូវ គួរពោលក្នុងរឿងនេះ ។ បានឮមកថា : បុរសម្នាក់មិនធ្លាប់ដើរ

ទៅកាន់ផ្លូវមួយ មកដល់ជ្រោះភ្នំ ឬ ផ្ទាំងថ្ម ដែលក្តៅ ព្រោះកំដៅខ្លាំង ដែលបុគ្គលដាក់សំរាប់ឆ្លងផ្លូវ មានភក់ដ៏ជ្រៅត្រង់ចន្លោះផ្លូវ មិនទាន់បានស្លៀកពាក់ស្រួលបួលផង ក៏ចុះទៅកាន់ជ្រោះភ្នំនោះហើយ ឈរនៅត្រង់មាត់ប្រាំងម្តងទៀត ព្រោះខ្លាចក្រែងបរិក្ខារទទឹក, មួយទៀត ជើងក្តៅ ព្រោះជាន់ផ្ទាំងថ្មនោះ ក៏ត្រូវឈរនៅត្រង់ប្រាំងអាយ ម្តងទៀតនុ៎ះឯង ។

ក្នុងសេចក្តីឧបមានោះ ប្រៀបដូចជាបុរសនោះ ព្រោះមិនទាន់បានរៀបចំសំលៀកបំពាក់ឲ្យស្រួលបួល គ្រាន់តែចុះទៅកាន់ជ្រោះភ្នំប៉ុណ្ណោះ និង គ្រាន់តែជាន់ផ្ទាំងថ្មក្តៅប៉ុណ្ណោះ ក៏ថយត្រឡប់មកឈរនៅត្រង់ប្រាំងអាយនុ៎ះឯង យ៉ាងណាមិញ, ឯព្រះយោគាវចរ ព្រោះមិនទាន់បានធ្វើបុព្វកិច្ច គ្រាន់តែចូលនេវសញ្ញានាសញ្ញាយតនៈប៉ុណ្ណោះ ក៏ថយត្រឡប់មកស្ថិតនៅក្នុងអាកិញ្ចញ្ញាយតនៈវិញ ក៏យ៉ាងនោះដែរ។ ចំណែកបុរសអ្នកធ្លាប់ដើរផ្លូវនោះ មកពីមុន ដល់ទិសនោះហើយ ស្លៀកសំពត់មួយយ៉ាងជាប់ ដែចាប់សំពត់មួយទៀត ក៏ចុះទៅកាន់ជ្រោះភ្នំ ឬ ធ្វើនូវការជាន់ផ្ទាំងថ្ម ក៏ក្តៅតែល្មមៗ ហើយក៏ដើរទៅខាងមុខ យ៉ាងណាមិញ, ភិក្ខុអ្នកបានធ្វើបុព្វកិច្ចហើយ ចូលនេវសញ្ញានាសញ្ញាយតនៈនុ៎ះឯង ជាអ្នកមិនមានចិត្ត ពាល់ត្រូវនិរោធ តទៅ ក៏យ៉ាងនោះឯង ។

(ចូលហើយស្ថិតនៅដូចម្តេច)

ត្រង់សំណួរថា "ស្ថិតនៅយ៉ាងដូចម្តេច" ឆ្លើយថា ក៏ការស្ថិតនៅនៃនិរោធសមាបត្តិ ដូចពោលមកហើយនេះនុ៎ះ រមែងមាន ដោយអំណាចកំណត់ពេលវេលាទុក និង ព្រោះមិនមានការអស់ទៅនៃអាយុ ការរង់ចាំនៃសង្ឃ និង ការទ្រង់ត្រាស់ឲ្យហៅមក នៃព្រះសាស្តា ក្នុងចន្លោះផង ។

(ចេញយ៉ាងដូចម្តេច)



ត្រង់សំណួរថា "ចេញដូចម្តេច" ឆ្លើយថា ការចេញមាន ២ យ៉ាង ដូច្នេះ គឺ : សំរាប់ព្រះអនាគាមី ការចេញ មាន ព្រោះការកើតឡើង នៃអនាគាមិផល, សំរាប់ព្រះអរហន្ត ការចេញ មាន ព្រោះការកើតឡើង នៃអរហត្តផល ។

(ចិត្តអ្នកចេញហើយបង្អោនទៅរកអ្វី)

ត្រង់សំណួរថា "ចិត្តរបស់លោកអ្នកចេញ(ពីនិរោធ)ហើយ ជាចិត្តបង្អោនទៅរកអ្វី" ឆ្លើយថា បង្អោនទៅរកព្រះនិព្វាន ។ ដូចជាព្រះនាងធម្មទិន្នាភិក្ខុនី ពោលហើយ (ក្នុងចូឡវេទល្លសូត្រ) ថា "ម្នាលអាវុសោវិសាខៈ [១] ភិក្ខុដែលចេញពីសញ្ញាវេទយិតនិរោធសមាបត្តិ ចិត្តលោកបង្អោនទៅរកវិវេក ទោរទន់ទៅរកវិវេក ឈមទៅរកវិវេក" ដូច្នេះ ។

(មនុស្សស្លាប់ និង មនុស្សចូលនិរោធ ផ្សេងគ្នាដូចម្តេច)

ត្រង់សំណួរថា "មនុស្សស្លាប់ និង មនុស្សចូលនិរោធ ផ្សេងគ្នាដូចម្តេច" ឆ្លើយថា សូម្បីក្នុងព្រះសូត្រ ក៏លោកពោលសេចក្តីនេះ ដូចគ្នាដែរ ។ សមដូចជាព្រះសារីបុត្តត្ថេរ ពោល (នឹងព្រះមហាកោដ្ឋិកៈ) ថា "អាវុសោ [២] បុគ្គលដែលធ្វើកាលកិរិយាក្ស័យ បុគ្គលនោះកាយសង្ខារ គឺខ្យល់ដង្ហើមចេញចូល រលត់ស្ងប់ឈឹង, វចីសង្ខារ គឺវិតក្កៈ និងវិចារៈ រលត់ស្ងប់ឈឹង, ចិត្តសង្ខារ គឺសញ្ញា និង វេទនា រលត់ស្ងប់ឈឹង, អាយុក៏អស់ ចំហាយភ្លើងធាតុ ក៏រលត់ស្ងប់ឈឹង, ឥន្ទ្រិយ៍ក៏បែកធ្លាយ, ឯភិក្ខុ ដែលចូលកាន់សញ្ញាវេទយិតនិរោធ ភិក្ខុនោះ មានកាយសង្ខារ រលត់ស្ងប់ឈឹង វចីសង្ខារ រលត់ស្ងប់ឈឹង ចិត្តសង្ខារ ក៏រលត់ស្ងប់ឈឹងដែរ, តែអាយុមិនអស់ ចំហាយធាតុភ្លើងមិនរលត់ស្ងប់ទេ ឥន្ទ្រិយ

១- សុ. ម. មូ. ភាគទី ២២ ទំព័រទី ២៩៧ ។ ២- ភាគទី ២២ ទំព័រទី ២៧៩ ។

មិនបែកធ្លាយឡើយ” ដូច្នេះ ។

(និរោធសមាបត្តិ ជាសង្ខតៈ ឬ អសង្ខតៈ)

ចំណែកត្រង់សំណួរថា “និរោធសមាបត្តិ ជាសង្ខតៈ ឬ អសង្ខតៈ” ដូច្នេះជាដើម មិនត្រូវឆ្លើយថា “និរោធសមាបត្តិ ជាសង្ខតៈ” ដូច្នេះក្តី ថា “ជាអសង្ខតៈ” ដូច្នេះក្តី ថា “ជាលោកិយៈ” ដូច្នេះក្តី ថា “ជាលោកុត្តរៈ” ដូច្នេះក្តី ។ ព្រោះហេតុអ្វី? ។ ព្រោះនិរោធសមាបត្តិនោះ មិនមាន ដោយសភាវៈ ។ ប៉ុន្តែនិរោធសមាបត្តិនោះ ឈ្មោះថា បានចូលហើយ ដោយអំណាចនៃព្រះអរិយអ្នកចូល ព្រោះហេតុណា, ព្រោះហេតុនោះ នឹងពោលថា “ជាកិរិយាសំរេច” ដូច្នេះ ក៏គួរ, មិនមែនមិនសំរេចទេ ។

បណ្ឌិតទាំងឡាយ ចំរើនអរិយបញ្ញាហើយ ចូលកាន់សមាបត្តិដែលជាធម្មជាតិស្ងប់ គឺព្រះអរិយសេពហើយដល់នូវការរាប់ថាជាព្រះនិព្វាន ក្នុងទិដ្ឋធម្មនេះ ដូចបានពោលមកនេះឯង ព្រោះហេតុណា, ព្រោះហេតុនោះ សូម្បីភាពជាអ្នកអាចចូលសមាបត្តិនេះ ទើបលោកហៅថា ជាអានិសង្សនៃបញ្ញា ក្នុងអរិយ-មគ្គទាំងឡាយ យ៉ាងនេះឯង ។

(អាហុនេយ្យភាវាទិសិទ្ធិ)

(៤៦៧) ត្រង់អានិសង្សថា “អាហុនេយ្យភាវាទិសិទ្ធិ បានសំរេចនូវភាវៈនៃខ្លួនជាអាហុនេយ្យបុគ្គលជាដើម” សេចក្តីថា : មិនមែនត្រឹមតែភាពជាអ្នកអាចចូលនិរោធសមាបត្តិបានតែម្យ៉ាងប៉ុណ្ណោះទេ សូម្បីតែការសំរេច នូវភាវៈនៃខ្លួនជាអាហុនេយ្យបុគ្គលជាដើមនេះ ក៏គប្បីជ្រាប



ថា ជាអានិសង្សនៃលោកុត្តរបញ្ញាភាវនានោះផងដែរ ។ ក៏បុគ្គល ឈ្មោះថា បានអប់រំបញ្ញាហើយ ព្រោះបានចំរើនលោកុត្តរបញ្ញាទាំង ៤ យ៉ាងនេះ ជាបុគ្គលគួរទទួលនូវបច្ច័យ ជាអ្នកគួរទទួលនូវអាគន្តុកទាន ជាអ្នកគួរទទួលនូវទានដែលបុគ្គលជឿនូវកម្ម និង ផលនៃកម្ម ជាអ្នកគួរដល់អញ្ជលិកម្ម របស់សត្វលោកព្រមទាំងទេវលោក ជាបុញ្ញក្ខេត្ត ដ៏ប្រសើរខ្ពង់ខ្ពស់ របស់សត្វលោក ដោយមិនប្លែកគ្នា ។

(ប្រភេទនៃព្រះអរិយបុគ្គល)

តែដោយប្លែកផ្សេងពីគ្នា ក្នុងលោកុត្តរបញ្ញាទាំង៤ ថ្នាក់នោះ ដំបូងបុគ្គលញ៉ាំងមគ្គប្បញ្ញា ទី១ ឲ្យចំរើនឡើងមកហើយ (បានសំរេចជាព្រះអរិយបុគ្គល) ដោយវិបស្សនាដែលខ្សោយ សូម្បីជាអ្នកមានឥន្រ្ទីយ៍ នៅទន់ខ្សោយ ក៏បានជាព្រះអរិយបុគ្គល ឈ្មោះថាសត្តក្ខត្តុបរមៈ គឺអន្ទោលទៅមកក្នុងសុគតិភព ៧ ជាតិ ហើយធ្វើទីបំផុតទុក្ខបាន ។ អ្នកមកហើយដោយវិបស្សនា ថ្នាក់កណ្តាល មានឥន្រ្ទីយ៍ជាកណ្តាល ក៏បានជាព្រះអរិយបុគ្គល ឈ្មោះថា កោលង្កោលៈ គឺត្រាច់រង្គាត់អន្ទោលទៅមកកាន់ត្រកូល ២ ឬ ៣ ហើយ ធ្វើទីបំផុតទុក្ខបាន ។ អ្នកមកហើយ ដោយវិបស្សនាចាស់ក្លា មានឥន្រ្ទីយ៍ចាស់ក្លា ក៏បានជាព្រះអរិយបុគ្គល ឈ្មោះថា ឯកពីជី ញ៉ាំងភាពដែលជារបស់មនុស្សមួយប៉ុណ្ណោះ ឲ្យកើតហើយ ក៏ធ្វើនូវទីបំផុតនៃទុក្ខបាន ។

បុគ្គលអ្នកចំរើនមគ្គប្បញ្ញា ទី២ បានជាព្រះអរិយបុគ្គល ឈ្មោះថា សកទាគាមី មកកាន់លោកនេះ តែម្តងប៉ុណ្ណោះ ក៏ធ្វើនូវទីបំផុតនៃទុក្ខ ។

បុគ្គលអ្នកចំរើនមគ្គប្បញ្ញា ទី៣ បានជាព្រះអរិយបុគ្គល ឈ្មោះថា អនាគាមី ។ ព្រះអនាគាមីនោះ ដោយអំណាចនៃការផ្សេងគ្នា នៃឥន្រ្ទីយ៍

*ជាអ្នកលះ (អត្តភាព) ក្នុងលោកនេះទៅហើយ ទើបសំរេច ដោយការបែកចេញទៅ ជា ៥ យ៉ាង គឺ អន្តរាបរិនិព្វាយី ឧបហច្ចបរិនិព្វាយី អសង្ខារបរិនិព្វាយី សសង្ខារបរិនិព្វាយី ឧទ្ធំសោតោអកនិដ្ឋគាមី ។*

*បណ្ដាបុគ្គល៥ ប្រភេទនោះ លោកអ្នកដែលទៅកើតក្នុងភពឈ្មោះសុទ្ធាវាស ភពណានីមួយ មិនទាន់ដល់ពាក់កណ្ដាលអាយុ ក៏បរិនិព្វានទៅ ឈ្មោះថា អន្តរាបរិនិព្វាយី ។ លោកអ្នកបរិនិព្វាន កន្លងហួសពាក់កណ្ដាលទៅហើយ ឈ្មោះថា ឧបហច្ចបរិនិព្វាយី។ លោកអ្នកញុំាងមគ្គថ្នាក់ខ្ពស់ឲ្យកើតឡើង ដោយមិនមានការតាក់តែង គឺមិនមានការប្រកបព្យាយាម ឈ្មោះថា អសង្ខារបរិនិព្វាយី ។ លោកអ្នកញុំាងមគ្គ ថ្នាក់ខ្ពស់ ឲ្យកើតឡើង ដោយមានការប្រជុំតាក់តែង គឺដោយមានការប្រកបព្យាយាម ឈ្មោះថា សសង្ខារបរិនិព្វាយី ។ លោកអ្នកដែលឡើងទៅខ្ពស់អំពីភពដែលខ្លួនកើត រហូតដល់អកនិដ្ឋភព ហើយក៏បរិនិព្វាន ក្នុងអកនិដ្ឋភពនោះ ឈ្មោះថា ឧទ្ធំសោតោអកនិដ្ឋគាមី ។*

*បុគ្គលអ្នកចំរើនមគ្គប្បញ្ញា ទី៤ អ្នកខ្លះ បានជាព្រះអរហន្ត ផ្នែកសទ្ធាវិមុត្តិ (រួចផុតស្រឡះដោយសទ្ធា) អ្នកខ្លះ ជាព្រះអរហន្ត ផ្នែកបញ្ញាវិមុត្តិ (រួចផុតដោយបញ្ញា) អ្នកខ្លះជាព្រះអរហន្ត ផ្នែកឧភតោភាគ-វិមុត្តិ (រួចផុតស្រឡះដោយចំណែកទាំង២) អ្នកខ្លះ ជាព្រះអរហន្ត ផ្នែកតេវិជ្ជៈ(អ្នកមានវិជ្ជា៣) អ្នកខ្លះ ជាព្រះអរហន្ត ផ្នែកឆឡភិញ្ញា (អ្នកបានអភិញ្ញា៦) អ្នកខ្លះជាព្រះអរហន្ត ផ្នែកបដិសម្ភិប្បភេទប្បត្តៈ (អ្នកដល់នូវការបានឈាន ក្នុងបដិសម្ភិទា) ជាព្រះមហាខីណាស្រព ដែលខ្ញុំពោលសំដៅយកហើយថា “ក៏ព្រះខីណាស្រពនោះ ឈ្មោះថា ស្រាយត្រដោះនូវព្រៃស្នាប់ គឺតណ្ហានោះ ក្នុងខណៈនៃមគ្គ ឈ្មោះថា ជាអ្នកមានព្រៃស្នាប់ ពោលគឺតណ្ហា បានស្រាយត្រដោះរួចហើយ ក្នុងខណៈនៃផលជាព្រះទក្ខិណេយ្យបុគ្គល ដ៏ប្រសើរខ្ពង់ខ្ពស់ នៃសត្វលោក ព្រមទាំងទេវលោក” យ៉ាងដូច្នេះឯង ។*



ការចំរើនអរិយបញ្ញា មានអានិសង្សច្រើនជាអនេក
មានប្រការដូចបានពោលមកហើយ ព្រោះហេតុ
ណា, ព្រោះហេតុនោះ បុគ្គលអ្នកមានប្រាជ្ញា ជា
គ្រឿងឃើញច្បាស់ គប្បីធ្វើនូវសេចក្ដីត្រេកអរ
ក្នុងការចំរើនអរិយបញ្ញានោះចុះ ។

*ក៏បញ្ញាភាវនា ព្រមទាំងអានិសង្ស ក្នុងគម្ពីរវិសុទ្ធិមគ្គ ដែលព្រះមានព្រះភាគទ្រង់សំដែងហើយ ដោយប្រធាន គឺ សីល សមាធិ បញ្ញា ក្នុងគាថានេះ ថា :*

**សីលេ បតិដ្ឋាយ នរោ សបញ្ញោ ចិត្តំ បញ្ញញ្ច ភាវយំ**
**អាតាបី និបកោ ភិក្ខុ សោ ឥមំ វិជដយេ ជដំ ។**

នរជនណា ប្រកបដោយសជាតបញ្ញា តាំងនៅស៊ប់
ក្នុងសីល ចំរើនសមាធិចិត្ត និងវិបស្សនាចិត្ត ឈ្មោះ
ថាជាអ្នកឃើញភ័យក្នុងសំសារវដ្ដៈ អ្នកមានព្យាយាម
ជាគ្រឿងដុតកិលេស អ្នកមានបញ្ញាជាគ្រឿងរក្សា នូវ
ខ្លួន, នរជននោះ គប្បីកាប់ឆ្ការនូវព្រៃស្នាប់ ពោលគឺ
តណ្ហានោះបាន ដូច្នេះ

*គឺខ្ញុំបានសំដែងចប់សព្វគ្រប់អស់ហើយ ដោយការពណ៌នាមានប្រមាណប៉ុណ្ណេះឯង ។*

*បរិច្ឆេទ ទី ២៣ ឈ្មោះថា បញ្ញាភាវនានិសំសនិទ្ទេស*
*ក្នុងគម្ពីរ ឈ្មោះថាវិសុទ្ធិមគ្គ*
*គឺខ្ញុំបានរចនាហើយ ដើម្បីប្រយោជន៍ ដល់ការញ៉ាំងសាធុជន*
*ឲ្យរីករាយជ្រះថ្លា ដោយប្រការដូច្នេះឯង ។*



*យើងខ្ញុំទាំងឡាយ បានតាំងនូវគាថានេះ ថា :*

**សីលេ បតិដ្ឋាយ នរោ សបញ្ញោ ចិត្តំ បញ្ញញ្ច ភាវយំ**
**អាតាបី និបកោ ភិក្ខុ សោ ឥមំ វិជដយេ ជដំ ។**

*ដូច្នេះស្រេចហើយ បានពោលនូវពាក្យឯណា ថា :*

“ឥឡូវនេះ ខ្ញុំកាលនឹងពណ៌នា នូវសេចក្តីដែលផ្សេងដោយគុណ មានសីលជាដើម ក្នុងគាថានេះ ដែលព្រះមានព្រះភាគជាអ្នកស្វែងរកគុណដ៏ធំ ទ្រង់ត្រាស់ហើយតាមសេចក្តីពិត នឹងពណ៌នានូវវិសុទ្ធិមគ្គដែលអាស្រ័យនូវន័យនៃទេសនា របស់ព្រះថេរៈ ដែលអាស្រ័យនៅក្នុងមហាវិហារទាំងឡាយ ដែលមានសេចក្តីវិនិច្ឆ័យបរិសុទ្ធិល្អ ជាគ្រឿងបណ្តុះសេចក្តីជ្រះថ្លាបាមោជ្ជៈដល់ពួកព្រះយោគី ក្នុងព្រះធម្មវិន័យនេះ អ្នកដែលបានបួសហើយ ក្នុងសាសនា នៃព្រះជិនស្រី ដែលបុគ្គលបានដោយលំបាកក្រៃលែង កាលបើមិនដឹងវិសុទ្ធិមគ្គដែលត្រង់ ក្សេមក្សាន្ត ដែលរួបរួមនូវគុណ មានសីលជាដើម តាមសេចក្តីពិត សូម្បីប្រាថ្នាសេចក្តីបរិសុទ្ធិ សូម្បីខំព្យាយាម ក៏មិនបានសំរេច ដល់សេចក្តីបរិសុទ្ធិដែរ, ម្នាលសាធុជនទាំងឡាយ! កាលបើខ្ញុំសំដែងវិសុទ្ធិមគ្គ ដោយគោរព, សូមលោកអ្នកទាំងឡាយទាំងពួង អ្នកប្រាថ្នានូវសេចក្តីបរិសុទ្ធិ ចូរតាំងចិត្តស្តាប់នូវវិសុទ្ធិមគ្គនោះ ដោយគោរពចុះ” *ដូច្នេះឯង ។*

*វិសុទ្ធិមគ្គ ដែលខ្ញុំបានប្តេជ្ញាថា នឹងពណ៌នា ក្នុងពាក្យនេះនោះ គឺខ្ញុំបានសំដែងហើយ ដោយអត្ថសំវណ្ណនា មានប្រមាណប៉ុណ្ណោះឯង ។*

*ក៏ក្នុងវិសុទ្ធិមគ្គនោះ*

សេចក្តីវិនិច្ឆ័យ នៃអត្ថទាំងឡាយ ផ្សេងដោយគុណមានសីលជាដើមនោះឯណា ជាសេចក្តីវិនិច្ឆ័យ ដែលលោកពោលហើយ ក្នុងអដ្ឋកថាន័យ នៃនិកាយទាំងឡាយ ៥, សេចក្តីវិនិច្ឆ័យនោះ រួចផុតចាកទោស គឺការច្របូកច្របល់ជាមួយនឹងវាទៈ នៃនិកាយដទៃទៀតទាំងអស់ ខ្ញុំបាននាំសេចក្តីវិនិច្ឆ័យទាំងអស់នោះ មកសំដែងហើយ យ៉ាងច្រើន ព្រោះហេតុណា, ព្រោះហេតុនោះ ការអើពើក្នុងវិសុទ្ធិមគ្គនោះ ព្រះយោគីទាំងឡាយ អ្នកមានប្រាជ្ញាបរិសុទ្ធ ប្រាថ្នានូវសេចក្តីបរិសុទ្ធិ គប្បីធ្វើ ដោយពិត ។

(ឧទ្ទិសកុសល)

កងបុណ្យកុសលឯណា ដែលខ្ញុំប្រាថ្នានូវការតាំងនៅនៃព្រះសទ្ធម្ម បានទទួលការនិមន្ត របស់ព្រះគុណម្ចាស់សង្ឃបាលៈ អ្នកកើតក្នុងវង្សនៃភិក្ខុ គណៈមហាវិហារទាំងឡាយ ដែលជាពួកថេរវាទ អ្នកមានឈ្មោះបោះសំឡេង ជាវិភជ្ជវាទី ដ៏ប្រសើរបំផុត លោកគឺជាព្រះមហាថេរៈ ដ៏រុងរឿង មានសេចក្តីប្រព្រឹត្តិប្រពៃ ជា



សល្លេខៈ ប្រកបដោយវិន័យ និង អាចារៈ ប្រកប (សេចក្តីព្យាយាម) ក្នុងការប្រតិបត្តិ មានចិត្តប្រកបដោយគុណ មានខន្តី សោរច្ចៈ និង មេត្តាជាដើមហើយ រចនានូវគម្ពីរវិសុទ្ធិមគ្គនេះ បានទទួលហើយដោយតេជៈ នៃកងបុណ្យនោះ, សូមឲ្យសព្វសត្វទាំងឡាយ បានដល់នូវសេចក្តីសុខចុះ! គម្ពីរវិសុទ្ធិមគ្គនេះឯង ចប់ហើយ ដោយព្រះបាលី ៥៨ ភាណវារ ប្រាសចាកអន្តរាយ ក្នុងទីនេះ យ៉ាងណាមិញ, សូមឲ្យមនោរថ(សេចក្តីប្រាថ្នាក្នុងចិត្ត) ទាំងឡាយ ដែលផ្តល់នូវសេចក្តីល្អ គ្រប់យ៉ាង នៃសត្វលោក សូមកុំឲ្យមានអន្តរាយ សូមឆាប់បានសម្រេច យ៉ាងរួសរាន់ទាន់ចិត្តក៏យ៉ាងដូច្នោះដែរ ។

គម្ពីរវិសុទ្ធិមគ្គប្រែបានចប់បរិបូណ៌ហើយ។

(ពាក្យសច្ចាធិដ្ឋាន)

(គុណសម្បត្តិព្រះពុទ្ធឃោសាចារ្យ ១១ យ៉ាង)

*គម្ពីរឈ្មោះវិសុទ្ធិមគ្គ គឺព្រះថេរៈអ្នកគួរនឹងហៅនាមថាមុរណ្ឌខេដៈ មានឈ្មោះ ដែលគ្រូទាំងឡាយ សន្មតដាក់ឲ្យថា "ពុទ្ធឃោសៈ" អ្នក (ប្រកបដោយគុណសម្បត្តិ គឺ)*

១- បរមវិសុទ្ធ សទ្ធា ពុទ្ធិ វីរិយប្បដិមណ្ឌិតេន *ប្រកបដោយសទ្ធា ពុទ្ធិ និង វីរិយៈ ដ៏បរិសុទ្ធ យ៉ាងក្រៃលែង,*

២- សីលាចារាជ្ជវមទ្ទវាទិគុណសមុទយសមុទិតេន *ប្រាកដច្បាស់ដោយសមុទយគុណ មានសីល អាចារៈ អាជ្ជវៈ និង មទ្ទវៈ ជាដើម,*

៣- សកសមយ សមយន្តរ គហនជ្ឈោគាហណ សមត្ថេន *ជាអ្នកអាច ក្នុងការចាបយកសេចក្តីវិនិច្ឆ័យ ដែលស្មុគស្មាញ ទាំងលទ្ធិរបស់ខ្លួន ទាំងក្នុងលទ្ធិនៃបុគ្គលដទៃ,*

៤- បញ្ញាវេយ្យត្តិយសមន្នាគតេន *ប្រកបដោយសេចក្តីប្រាកដជាក់ច្បាស់នៃបញ្ញា,*

៥- តិបិដកបរិយត្តិប្បភេទេ សាដ្ឋកថេ សត្ថុ សាសនេ អប្បដិហតញ្ញាណប្បភាវេន *មានអំណាចនៃញាណដែលមិនជាប់ជំពាក់ទើសទាក់ក្នុងសត្ថុសាសនា ផ្សេងដោយព្រះបរិយត្តិ គឺព្រះត្រៃបិដក ព្រមទាំងអដ្ឋកថា,*

៦- មហាវេយ្យាករណេន *អ្នកចេះវេយ្យាករណ៍ដ៏ស្ទាត់ជំនាញ ។*

៧- ករណសម្បត្តិជនិតសុខវិនិគ្គត មធុរោទាវចនលាវណ្ណយុត្តេន *ប្រកបដោយសេចក្តីល្អ នៃពាក្យពេចន៍ យ៉ាងពិរោះ ក្រអួន ដែលគួរ*



*ដល់ព្រម ដោយការបញ្ចេញសំឡេង ធ្វើស្វរស័ព្ទសំឡេង ចេញមកបានយ៉ាងងាយស្រួល,*

៨- យុត្តមុត្តវាទិនា វាទីវរេន *ជាអ្នកនិយាយបាន យ៉ាងឆ្នើម និយាយបាន ទាំងចង(បញ្ហា) ទាំងដោះស្រាយ(បញ្ហា),*

៩- មហាកវិនា *ជាអ្នកនិពន្ធ ដ៏ល្បីល្បាញ,*

១០- បភិន្នប្បដិសម្ភិទាបរិវារេន ឆឡភិញ្ញាទិភេទគុណប្បដិមណ្ឌិតេ ឧត្តរិមនុស្សធម្មេ អប្បដិហតពុទ្ធីនំ ថេរវំសប្បទីបានំ ថេរានំ មហាវិហារវាសីនំ វំសាលង្ការភូតេន *ជាអលង្ការ នៃវង្ស របស់ព្រះថេរៈទាំងឡាយ អ្នកអាស្រ័យនៅ ក្នុងមហាវិហារ ជាប្រទីបនៃថេរវង្ស មានចំណេះដឹង មិនទើសទាក់ ក្នុងឧត្តរិមនុស្សធម្ម ប្រដាប់ដោយគុណផ្សេងៗ មានអភិញ្ញា ៦ ជាដើម មានបដិសម្ភិទាចាក់ធ្លុះហើយ ជាបរិវារ,*

១១- វិបុលវិសុទ្ធពុទ្ធិនា *មានចំណេះចេះដឹង ដ៏បរិសុទ្ធ ត្រឹមត្រូវ យ៉ាងទូលំទូលាយ បានរចនាហើយ*

ចូរស្ថិតនៅ ក្នុងលោក សំដែងន័យនៃវិសុទ្ធិ មានសីល
ជាដើម ដល់កុលបុត្រទាំងឡាយ អ្នកស្វែងរកធម៌ដែល
ជាគ្រឿងរលាស់ខ្លួនចេញពីលោក ដរាបដល់ព្រះនាម
ថា "ពុទ្ធោ" របស់ព្រះពុទ្ធជាម្ចាស់ ដែលជាចម្បង ក្នុង
លោក ទ្រង់ស្វែងរកគុណដ៏ធំ ទ្រង់មានព្រះទ័យស្អាត
បរិសុទ្ធ ទ្រង់មិនញាប់ញ័រ ប្រព្រឹត្តទៅ ក្នុងលោក
តទៅហោង ។

* ❀ *

ចាប់តាំងពីពេលដែលព្រះពុទ្ធជាម្ចាស់ ព្រះអង្គមានជោគ បរិនិព្វានទៅ ឆ្នាំកន្លងទៅហើយ បាន ៩៥៦ ព្រះវស្សា មានព្រះរាជាព្រះនាមមហានាម ទ្រង់គ្រងរាជសម្បត្តិ នៅក្នុងលង្កាទ្វីប ។ មានរឿងដំណាលថា : ក្នុងសម័យនោះ មានមាណព ជាព្រាហ្មណ៍ម្នាក់ កើតក្នុងត្រកូលព្រាហ្មណ៍ នៅក្បែរពោធិមណ្ឌល ក្នុងមជ្ឈមប្រទេស ក្នុងជម្ពូទ្វីប ។ មាណពនោះ ជាអ្នកឈ្លាសវៃ ក្នុងសិល្បៈ គ្រប់យ៉ាង រៀនចប់ត្រៃវេទ ត្រាច់រង្គាច់ទៅ រហូតដល់ស្រុក និគមជនបទ រាជធានីទាំងឡាយ ក្នុងជម្ពូទ្វីប សមណព្រាហ្មណ៍ទាំងឡាយ ដែលជាបណ្ឌិត ឆ្លៀវឆ្លាត រស់នៅក្នុងទីណាៗ ក៏ទៅធ្វើសាកច្ឆា ក្នុងទីនោះៗ ។ ពួកអ្នកប្រាជ្ញដទៃៗ មិនអាចឆ្លើយដោះស្រាយនូវបញ្ហា ដែលមាណពនោះ សួរបានឡើយ ។ តែមាណពនោះ ដោះស្រាយនូវបញ្ហា ដែលពួកបណ្ឌិតដទៃៗ ទៀត សួរហើយបាន(ទាំងអស់) ។ មាណពនោះ ល្បីល្បាញ លើសកលជម្ពូទ្វីបទាំងមូល ដោយអាការៈយ៉ាងដូច្នេះហើយ ក៏បានទៅដល់វិហារមួយ ។

ក៏ក្នុងវិហារនោះ មានភិក្ខុនៅច្រើនរយរូប ។ ព្រះរេវតៈដ៏មានអាយុជាសង្ឃត្ថេរ របស់ភិក្ខុទាំងនោះ ជាព្រះមហាខីណាស្រព បានសំរេចបដិសម្ភិទា ជាអ្នកញ៉ាំញីនូវវាទៈនៃជនដទៃបាន ។ គ្រានោះឯង មាណពនោះ ស្វាធ្យាយបាតញ្ជលិមន្ត ធ្វើឲ្យមានបទពេញបរិបូណ៌ រហូតរាត្រី ។ លំដាប់នោះឯង ព្រះថេរៈ ឮសំឡេងព្រាហ្មណ៍ស្វាធ្យាយមន្ត ក៏ដឹងថា "ព្រាហ្មណ៍នេះ ជាអ្នកមានប្រាជ្ញាច្រើន, អាត្មាអញ ទូន្មាន ទាក់ទាញនូវព្រាហ្មណ៍នោះ ទើបគួរ" ដូច្នេះហើយ ទើបហៅព្រាហ្មណ៍មកសួរ យ៉ាងនេះ ថា "ម្នាលព្រាហ្មណ៍! អ្នកណាហ្ន៎ ស្រែកដូចសម្រែកសត្វលា" ។ ព្រាហ្មណ៍ សួរថា "បពិត្របព្វជិតដ៏ចំរើន! លោកម្ចាស់ ដឹងសំឡេងពួក



សត្វលាឬ? " ។ ព្រះថេរៈ ទទួលថា "មែនហើយ អាត្មាភាព ដឹង" ។ ព្រាហ្មណ៍នោះខ្លួនឯង ក៏មិនឃើញន័យនៃបញ្ហាដែលជាគ្រឿងចាក់ស្រែះទាំងឡាយ ក្នុងគម្ពីរត្រៃវេទ ទាំងគម្ពីរឥតិហាសៈ ជាគម្រប់ ៥ ទាំងអាចារ្យរបស់ខ្លួន ក៏មិនឃើញផងដែរ ។ ព្រាហ្មណ៍ បានសួរព្រះថេរៈ ក្នុងបញ្ហា ដែលជាគ្រឿងចាក់ស្រែះ ក្នុងគម្ពីរទាំងឡាយនោះ ។ ក៏តាមប្រក្រតី ព្រះថេរៈ ជាអ្នករៀនចប់ត្រៃវេទ ទាំងឥឡូវនេះសោត ក៏បានសំរេចបដិសម្ភិទាថែមទៀត ហេតុនោះ ភារៈដ៏ធ្ងន់ ក្នុងការដោះស្រាយនូវបញ្ហាទាំងឡាយនោះ មិនមានដល់ថេរៈនោះទេ ។ ហេតុនោះ ទើបលោកដោះស្រាយ នូវបញ្ហានោះបានភ្លាមៗ ហើយពោលនឹងព្រាហ្មណ៍នោះថា "ម្នាលព្រាហ្មណ៍ដ៏ចំរើន! អាត្មា ត្រូវអ្នកសួរមកហើយ ឥឡូវនេះ នឹងសួរអ្នកនូវបញ្ហាមួយ អ្នកនឹងព្យាករនូវបញ្ហា របស់អាត្មា បានដែរឬទេ" ។ ព្រាហ្មណ៍ ទទួលថា "បពិត្រសមណៈដ៏ចំរើន មែនហើយ សូមលោកម្ចាស់សួរមកចុះ" ។ ព្រះថេរៈក៏សួរបញ្ហា ក្នុងគម្ពីរចិត្តយមកៈនេះថា "យស្ស ចិត្តំ ឧប្បជ្ជតិ ន និរុជ្ឈតិ តស្ស ចិត្តំ និរុជ្ឈិស្សតិ ន ឧប្បជ្ជិស្សតិ យស្ស វា បន ចិត្តំ និរុជ្ឈិស្សតិ ន ឧប្បជ្ជិស្សតិ តស្ស ចិត្តំ ឧប្បជ្ជតិ ន និរុជ្ឈតិ ចិត្ត របស់បុគ្គលណា កើតឡើង មិនរលត់, ចិត្ត របស់បុគ្គលនោះ នឹងរលត់ នឹងមិនកើតឬ ឬក៏ ចិត្ត របស់បុគ្គលណា នឹងរលត់ នឹងមិនកើតឡើង, ចិត្ត របស់បុគ្គលនោះ កើតឡើង មិនរលត់ឬ?" ដូច្នេះជាដើម ។ ព្រាហ្មណ៍មាណព មិនអាចចាំបានទាំងខាងលើ ទាំងខាងក្រោម ទើបសួរថា "បពិត្រលោកដ៏ចំរើននេះ ឈ្មោះថាមន្តអ្វីទៅ?" ។ ព្រះថេរៈ ឆ្លើយថា "ម្នាលព្រាហ្មណ៍ នេះ ឈ្មោះថា ពុទ្ធមន្ត" ។ ព្រាហ្មណ៍សួរថា "លោកម្ចាស់ដ៏ចំរើន តើលោក

*ម្ចាស់ អាចឲ្យមន្តនេះ ដល់ខ្ញុំព្រះករុណាបានឬទេ?” ។ ព្រះថេរៈ ឆ្លើយថា “ម្នាលព្រាហ្មណ៍ អាត្មាភាព អាចឲ្យដល់បុគ្គលដែលបួស ដូចអាត្មាភាពនេះបាន” ។ លំដាប់នោះ ព្រាហ្មណ៍មាណព សុំបួស ដើម្បីត្រូវការរៀនមន្ត ។ ព្រះថេរៈ ឲ្យព្រាហ្មណ៍នោះបួស បំពេញឧបសម្បទាហើយ ក៏ឲ្យរៀនព្រះពុទ្ធវចនៈ គឺព្រះត្រៃបិដក ។ ភិក្ខុអង្គនោះ ក៏បានប្រាកដ (នាម) ក្នុងលោកថា “ព្រះពុទ្ធឃោសៈ” ។*

*ព្រះពុទ្ធឃោសៈនោះ កាលនៅក្នុងមហាវិហារនោះ បានរចនាគម្ពីរឈ្មោះញាណោទ័យ ក្នុងវិហារស្រេចហើយ ក៏បានប្រារព្ធចាប់ផ្ដើម តែងគម្ពីរអដ្ឋកថា អភិធម្មសង្គណិ និង គម្ពីរអដ្ឋកថា ខ្នាតតូច ឈ្មោះថាអដ្ឋសាលិនី ។ គ្រានោះ ព្រះថេរៈ ឃើញដូច្នោះហើយ ក៏ពោល យ៉ាងនេះថា “ម្នាលពុទ្ធឃោសៈដ៏មានអាយុ ក្នុងជម្ពូទ្វីបនេះ មានតែព្រះត្រៃបដិកបាលីប៉ុណ្ណោះឯង អដ្ឋកថា នៃព្រះត្រៃបដិកនោះ និង ថេរវាទ មិនមានទេ, តែអដ្ឋកថា ក្នុងភាសាសីហលៈ ដែលឡើងកាន់សង្គីតិ បីលើក គឺព្រះថេរៈទាំងឡាយ មានព្រះសារីបុត្តជាដើម បានចងក្រងហើយ, ព្រះមហិន្ទៈ ត្រួតពិនិត្យមើលកថាមគ្គហើយ តែងជាភាសាលីហលៈ មានប្រើនៅក្នុងសីហលទ្វីប, ឯអ្នក ចូរទៅក្នុងសីហលទ្វីបនោះ ពិនិត្យមើលសព្វគ្រប់ហើយ ចូរប្រែមកជាភាសាមគធៈ(ឲ្យបាន) អដ្ឋកថានោះនឹងនាំមកនូវប្រយោជន៍ ឲ្យដល់សត្វលោកទាំងពួង” ដូច្នេះ ។ លុះព្រះថេរៈណែនាំ យ៉ាងដូច្នេះហើយ ព្រះពុទ្ធឃោសៈមានអាយុ ក៏កើតបីតិ សោ-មនស្សរីករាយ ថ្វាយបង្គំ លាព្រះឧបជ្ឈាយ៍ និង ព្រះភិក្ខុសង្ឃហើយ ធ្វើដំណើរ តាមកំពង់ទូក តាមលំដាប់ ក៏ឡើងជិះទូកទៅ ឃើញនូវព្រះពុទ្ធទត្តត្ថេរ កំពុងតែនិមន្តមក តាមផ្លូវជួបគ្នា នៅកណ្ដាលសមុទ្រ បាន*



*និយាយប្រាស្រ័យទាក់ទងគ្នា ធ្វើដំណើរបន្តទៅ រហូតបានទៅដល់កំពង់ទីក្រុងលង្កា ។ ក្នុងពេលនោះ ព្រះរាជា ព្រះនាមមហានាម គ្រងរាជសម្បត្តិ ក្នុងលង្កាទ្វីប។ គ្រានោះឯង ព្រះពុទ្ធឃោសៈ ដ៏មានអាយុ បានទៅជួបភិក្ខុសង្ឃ ក្នុងមហាវិហារ ក្នុងទីក្រុងអនុរាធបុរី ហើយ ក៏បានទៅកាន់សំណាក់ព្រះសង្ឃបាលត្ថេរ នៅក្នុងមហាបធានឃរៈហើយ បានស្ដាប់អដ្ឋកថា ជាភាសាសីហលៈ និង ថេរវាទ សព្វគ្រប់អស់ហើយ ក៏សំរេចចិត្តថា “នេះ ជាសេចក្ដីអធិប្បាយ របស់ព្រះពុទ្ធជាម្ចាស់នៃធម៌” ដូច្នេះហើយ ដើរទៅកាន់ទីប្រជុំសង្ឃ ក្នុងវិហារនោះ ពោល យ៉ាងនេះថា “បពិត្រព្រះគុណម្ចាស់ដ៏ចំរើន! ខ្ញុំព្រះករុណា សុំឱកាស សូមព្រះគុណម្ចាស់ទាំងឡាយប្រទាននូវគម្ពីរទាំងឡាយ ដល់ខ្ញុំព្រះករុណា ដើម្បីចងក្រងរចនា ជាអដ្ឋកថាព្រះត្រៃបិដក” ដូច្នេះ ។*

*លំដាប់នោះឯង ដើម្បីសាកល្បងមើលសមត្ថភាព របស់ព្រះពុទ្ធឃោសៈនោះ ភិក្ខុសង្ឃក៏បានឲ្យគាថា ២ បទ ហើយប្រាប់ យ៉ាងនេះថា “ចូរអ្នកសំដែងសេចក្ដីអង់អាច ក្នុងគាថា ២ បទនេះ យើងឃើញសមត្ថភាព របស់លោកហើយ នឹងឲ្យគម្ពីរទាំងអស់” ។ គ្រានោះឯង ព្រះពុទ្ធឃោសៈ មានអាយុ អានបាលីព្រះត្រៃបិដក និង អដ្ឋកថានៃព្រះត្រៃបិដកនោះហើយ ក៏បានរួបរួមចងក្រងជាគម្ពីរ ឈ្មោះថា “វិសុទ្ធិមគ្គ” ។*

*ក្នុងពេលនោះ ពួកទេវតា បានប្រកាសថ្វីដៃ របស់ព្រះពុទ្ធឃោសៈនោះ ឲ្យប្រាកដក្នុងមហាជន ទើបបានធ្វើគម្ពីរនោះឲ្យអន្តរធានបាត់ទៅ ។ ព្រះពុទ្ធឃោសៈ ក៏បានតែងគម្ពីរថ្មីមួយចប់ទៀត ។ ពួកទេវតា ក៏បានបណ្ដាលធ្វើឲ្យគម្ពីរនោះអន្តរធានបាត់ទៅទៀត។ ព្រះពុទ្ធឃោសៈ ក៏បានតែងគម្ពីរថ្មីមួយទៀត ជាលើក ទី៣ ។ ក្នុងខណៈនោះ ពួកទេវតា ក៏បាន*

យកគម្ពីរទាំងពីរចប់ មកប្រគេន ដល់ព្រះពុទ្ធឃោសៈនោះវិញ ។ ក្នុងពេលនោះ ទើបបានជាគម្ពីរបីចប់ ។ គ្រានោះឯង ព្រះពុទ្ធឃោសៈ មានអាយុ បានយកគម្ពីរទាំង៣ចប់ ទៅប្រគេនដល់ភិក្ខុសង្ឃ ។ លំដាប់នោះឯង ភិក្ខុសង្ឃ បានអានគម្ពីរទាំង៣ នោះជាមួយគ្នា ។ ការខុសប្លាំងក្លាត់ក្នុងគម្ពីរទាំង៣ នោះ ដោយគណ្ឋៈក្តី ដោយអក្ខរៈក្តី ដោយបទក្តី ដោយព្យញ្ជនៈក្តី ដោយអត្ថក្តី ដោយអំណាចនៃខាងដើមនិងខាងចុងក្តី ដោយវាទៈទាំងឡាយមានថេរវាទជាដើមក្តី ដោយបាលីទាំងឡាយក្តី មិនមានសោះឡើយ ។ កាលបើព្រះពុទ្ធឃោសៈ បានចងក្រងគម្ពីរវិសុទ្ធិមគ្គទាំង ៣ ចប់ បានសំរេចបរិបូណ៌ យ៉ាងនេះហើយ, ពួកទេវតា ក៏បានធ្វើសាធុការ ។ ក៏សម័យនោះឯង ភិក្ខុទាំងឡាយច្រើនពាន់រូប មកប្រជុំគ្នាក្នុងមហាវិហារ បានឃើញហេតុអស្ចារ្យនោះហើយ ក៏ត្រេកអរ រីករាយប្រគេនសាធុការពរ ប៉ាវគងប្រកាស យ៉ាងគឹកកងថា “ព្រះពុទ្ធឃោសៈនេះ គឺជាព្រះមេត្តេយពោធិសត្វ ដោយពុំមានសង្ស័យឡើយ” ។

លំដាប់នោះ ព្រះមហារាជ ទ្រង់ព្រះសណ្តាប់នូវហេតុអស្ចារ្យនោះហើយ ចោមរោមដោយរាជបរិពារ យ៉ាងច្រើន ស្តេចចេញពីព្រះនគរយាងទៅកាន់មហាវិហារ ក្រាបថ្វាយបង្គំព្រះសង្ឃស្រេចហើយ ក៏ក្រាបថ្វាយបង្គំព្រះពុទ្ធឃោសៈ មានអាយុ ទ្រង់និមន្តថា “បពិត្រលោកម្ចាស់ដ៏ចំរើន! ប្រពៃណាស់! សូមព្រះគុណម្ចាស់ ទទួលនូវភិក្ខា ក្នុងរាជវាំងរបស់ខ្ញុំព្រះករុណា រហូតដល់រចនាចងក្រងគម្ពីរព្រះធម៌ចប់សព្វគ្រប់” ។ ព្រះពុទ្ធឃោសៈ បានទទួលនិមន្ត ដោយតុណ្ហីភាព ។

គ្រានោះឯង ភិក្ខុសង្ឃ ក៏បានប្រគេនគម្ពីរព្រះត្រៃបិដកបាលី ព្រមទាំងគម្ពីរអដ្ឋកថា ជាភាសាសីហលៈ ដល់លោក ។ លំដាប់នោះឯង



ព្រះពុទ្ធឃោសៈ មានអាយុនោះ បានទទួលគម្ពីរទាំងអស់ ទៅសំរាកនៅលើប្រាសាទមួយ ឈ្មោះបធានឃរៈ ក្នុងទិសទក្សិណ នៃមហាវិហារហើយ បានប្រែអដ្ឋកថា ជាសីហលភាសាទាំងអស់ មកធ្វើជាអដ្ឋកថានៃព្រះត្រៃបិដក ជាភាសាមគធៈ ដែលជាភាសាដើមហ្នឹងឯង ។

ក៏អដ្ឋកថា សីហលៈ នោះ មាន ៣ ភាគ គឺ មហាអដ្ឋកថា ១ បច្ចរិយអដ្ឋកថា ១ កុរុន្ទីអដ្ឋកថា ១ ។

អដ្ឋកថា ដែលបានឡើងកាន់មហាសង្គីតិ គឺព្រះមហាមហិន្ទៈ បាននាំមករចនា តែងជាភាសាសីហលៈ ឈ្មោះថា មហាអដ្ឋកថា ។

មានផ្ទះក្បូន ១ តាមភាសាសីហលៈ ឈ្មោះថា បច្ចរិយៈ, អដ្ឋកថាដែលពួកការកភិក្ខុ អង្គុយប្រជុំគ្នា ចងក្រង ក្នុងផ្ទះក្បូននោះ ឈ្មោះថា បច្ចរិយអដ្ឋកថា ។

មាន វិហារមួយ ឈ្មោះ កុរុន្ទិវេឡុវិហារ, អដ្ឋកថា ដែលការកភិក្ខុអង្គុយប្រជុំគ្នា រចនាចងក្រង ក្នុងវិហារនោះ ឈ្មោះថា កុរុន្ទីអដ្ឋកថា ។

វាទៈ ដែលព្រះថេរៈទាំងឡាយ ពីបូរាណមានព្រះថេរិកាចារ្យ ជាដើម នាំន័យបាលីមករចនាចងក្រងហើយ ឈ្មោះថា ថេរវាទ ។

ក៏ជាដំបូង ព្រះពុទ្ធឃោសៈមានអាយុ ប្រែកុរុន្ទីអដ្ឋកថា ពីភាសាសីហលៈ មករចនាអដ្ឋកថា វិន័យបិដក ឈ្មោះថា សមន្តបាសាទិកា ក្នុងភាសាមគធៈ ដែលជាភាសាដើមហើយ បន្ទាប់ពីនោះមក ក្នុងព្រះសុត្តន្តបិដក ក៏បានប្រែមហាអដ្ឋកថា ពីភាសាសីហលៈ ដាក់ជាអដ្ឋកថាទីឃនិកាយ ឈ្មោះថា សុមង្គលវិលាសិនី ជាអដ្ឋកថាមជ្ឈិមនិកាយ ឈ្មោះថា បបញ្ចសូទនី ជាអដ្ឋកថា សំយុត្តនិកាយ ឈ្មោះថា សារត្ថ-ប្បកាសិនី និង ជាអដ្ឋកថាអង្គុត្តរនិកាយ ឈ្មោះថា មនោរថបូរណី ។

*បន្ទាប់ពីនោះមក ក្នុងព្រះអភិធម្មបិដក ក៏បានប្រែបច្ចរិយអដ្ឋកថា ពីភាសាសីហលៈ ដាក់តាំងជាអដ្ឋកថាធម្មសង្គណី ឈ្មោះថា អដ្ឋសាលិនី ក្នុងភាសាមគធៈដែលជាមូលភាសា ជាអដ្ឋកថាវិភង្គប្បករណ៍ ឈ្មោះថា សម្មោហវិនោទនី និង ជាអដ្ឋកថា ៥ បករណ៍ ឈ្មោះថា បរមត្ថទីបនី ក៏យ៉ាងនោះដែរ ។*

*ព្រះពុទ្ធឃោសៈ មានអាយុ បានរចនាចងក្រងអដ្ឋកថាសីហលៈ ទាំងអស់ ឲ្យជាអដ្ឋកថា នៃព្រះត្រៃបិដកក្នុងភាសាមគធៈ ដែលជាមូលភាសា ដូចបានពណ៌នាមកនេះឯង ។ អដ្ឋកថា នោះឯង បាននាំមកនូវប្រយោជន៍សុខ ដល់ពួកជនដែលអាស្រ័យនៅក្នុងប្រទេសដទៃៗ គ្រប់គ្នា ។ ក្នុងពេលប្រែអដ្ឋកថាព្រះត្រៃបិដក ចប់ស្រេចហើយ ក៏កើតមានការរញ្ជួយផែនដី ។ អដ្ឋកថាព្រះត្រៃបិដក ដែលលោកធ្វើ (ចងក្រង) ដូចបានពោលមកនោះ អស់រយៈពេលមួយឆ្នាំគត់ ទើបបានចប់ ។*

*គ្រានោះឯង លុះចប់កិច្ចស្រេចអស់ហើយ ព្រះពុទ្ធឃោសៈ មានអាយុ មានបំណងចង់ទៅថ្វាយបង្គំព្រះមហាពោធិ៍ ទើបថ្វាយបង្គំ សុំលាព្រះភិក្ខុសង្ឃ ត្រឡប់ទៅកាន់ជម្ពូទ្វីបវិញ ដោយប្រការដូច្នេះឯង ។*

(សង្គហគាថា)

*មួយទៀត ក្នុងប្រវត្តិ របស់ព្រះពុទ្ធឃោសៈនេះ ព្រះបុរាណាចារ្យទាំងឡាយ ក្នុងសីហលទ្វីប សម័យនោះ បានពោលសង្គហគាថា (គាថារួបរួម) យ៉ាងដូច្នេះ ថា :*

តាំងពីពេលដែលព្រះសម្ពុទ្ធ ទ្រង់បរិនិព្វានទៅ ឆ្នាំ
កន្លងទៅហើយបាន ៩៥៦ ព្រះវស្សា, ព្រះរាជាទ្រង់
ព្រះនាមមហានាម ទ្រង់គ្រងរាជសម្បត្តិ ក្នុងលង្កាទ្វីប



ដោយទសពិធរាជធម៌ (ធម៌ ១០ យ៉ាង) ។ ព្រាហ្មណ៍មាណព អ្នកកើតក្នុងស្រុកក្បែរពោធិមណ្ឌល ជាអ្នកចេះដឹងវិជ្ជា និង សិល្បសាស្ត្រ រៀនចប់ត្រៃវេទ ចេះដឹងពិតប្រាកដក្នុងលទ្ធិ ឈ្លៀវឆ្លាតវាងវៃក្នុងវាទៈគ្រប់បែបយ៉ាង មានសេចក្តីត្រូវការដោយវាទៈ ទើបដើរត្រាច់រង្គាច់ទៅជជែកវែកញែក សាសង នៅក្នុងជម្ពូទ្វីប រហូតបានមកដល់វិហារមួយ នៅពេលរាត្រី ស្វាធ្យាយបាតញ្ជលីមន្តឲ្យមានបទ ពេញបរិបូណ៌ ជាបរិមណ្ឌល យ៉ាងល្អ ។

ព្រះមហាថេរៈមួយអង្គ ឈ្មោះរេវតៈ ក្នុងវិហារនោះ ដឹងច្បាស់ថា សត្វនេះ ជាអ្នកមានបញ្ញាច្រើន អាត្មាអញណែនាំអប់រំបាន គឺជាការល្អ ទើបលោកពោល ថា : អ្នកណាហ្ន៎ ស្រែកដូចជាសត្វលា ។ ព្រាហ្មណ៍មាណព សួរថាៈ តើព្រះគុណម្ចាស់ យល់សេចក្តី ក្នុងសំឡេងរបស់សត្វលាឬ?, កាលបើព្រះមហាថេរៈឆ្លើយថា អាត្មាដឹង, ទើបញ៉ាំងព្រះមហាថេរៈ ឲ្យស្តុងចុះទៅកាន់លទ្ធិរបស់ខ្លួន ។ ព្រះថេរៈ ក៏ដោះស្រាយបញ្ហាដែលមាណពសួរហើយៗបាន ព្រមទាំងបានពន្យល់បង្ហាញនូវបញ្ហាដែលភ្លាំងភ្លាត់ថែមទៀតផង កាលបើត្រូវព្រះមហាថេរៈចោទសួរថាៈ បើដូច្នោះ ចូរអ្នកញ៉ាំងវាទៈរបស់ខ្លួន ឲ្យស្តុងចុះ (កាន់លទ្ធិអាត្មា)ម្តង (គឺអាត្មាចង់សួរអ្នកវិញម្តង) មិនអាចដោះស្រាយសេចក្តី នៃបាលីមហាអភិធម្មបាន ក៏

ទូលសួរថា : នេះជាមន្តរបស់អ្នកណា?, ព្រះមហាថេរៈឆ្លើយថា: នេះ គឺជាមន្ត របស់ព្រះពុទ្ធ ហើយ ក៏បានសុំពុទ្ធមន្តនោះ នឹងព្រះមហាថេរៈៗ ឆ្លើយប្រាប់ថា: អាត្មានឹងឲ្យពុទ្ធមន្តនោះ ដល់បុគ្គលដែលទ្រទ្រង់នូវភេទ ដូចជារូបអាត្មានេះ ។ មាណពនោះ ត្រូវកុសល ក្នុងកាលមុនទាំងឡាយ ដាស់តឿនហើយ ក៏បានបួសដើម្បីត្រូវការមន្ត មាណព បានឧបសម្បទាស្រេចហើយ ក៏បានរៀនព្រះត្រៃបិដក ពេលខាងក្រោយមក ក៏បានជ្រើសរើសយកព្រះត្រៃបិដកនោះថា: នេះ គឺជាផ្លូវឯកតែមួយ (បន្ទាប់មក) លោកក៏បានល្បីល្បាញប្រាកដ ដូចជាភ្លើង ដូចព្រះច័ន្ទ ដូចព្រះអាទិត្យ ជាអ្នកបានព្យាករ ដោះស្រាយគម្ពីរដ៏ជ្រាលជ្រៅ ដល់សត្វទាំងឡាយ ដូចជាការព្យាករណ៍ របស់ព្រះពុទ្ធជាម្ចាស់ ហើយលោកបាននាមថា "ពុទ្ធឃោសៈ" ព្រោះជាអ្នកល្បីល្បាញលើផែនដី ដូចជាព្រះពុទ្ធជាអង្គម្ចាស់ ។

ក្នុងពេលនោះ លោកជាអ្នកចេះដឹង បានតែងគម្ពីរ ឈ្មោះ ញាណោទ័យ ក្នុងវិហានោះ ហើយតែងអដ្ឋកថាធម្មសង្គណី ចាប់ផ្តើមតែងអដ្ឋកថាតូច ឈ្មោះអដ្ឋសាលិនីផង, ក៏ព្រះរេវតត្ថេរ ឃើញដូច្នោះ ក៏ប្រាប់ដូច្នេះថា: គម្ពីរដែលបាននាំមក ក្នុងទីនេះ មានត្រឹមតែព្រះបាលីទេ អដ្ឋកថា មិនមានឡើយ, អាចារិយវាទ



ផ្សេងៗ ក៏មិនមាន ដូចគ្នាដែរ, ប៉ុន្តែអដ្ឋកថា ជាភាសាសីហលៈសុទ្ធសាធ ដែលព្រះមហិន្ទៈ អ្នកមានប្រាជ្ញាញាណ ត្រួតពិនិត្យមើលកថាមគ្គ ដែលបានឡើងកាន់សង្គីតិទាំង ៣ លើក ប្រកាន់ថា ជាព្រះតម្រាស់ ដែលព្រះសម្មាសម្ពុទ្ធ ទ្រង់បានសំដែងទុកហើយ និង ព្រះថេរៈទាំងឡាយ មានព្រះសារីបុត្រជាដើម ចងក្រងទុកហើយ បានរចនាហើយ ក្នុងសីហលភាសា មាននៅក្នុងសីហលទ្វីប, ចូរលោកនិមន្តទៅ ក្នុងសីហលទ្វីបនោះ ត្រួតមើលអដ្ឋកថាសីហលៈនោះហើយ ប្រែមកជាភាសាមគធៈ (ឲ្យបាន), អដ្ឋកថានោះ នឹងនាំមកនូវប្រយោជន៍សុខ ឲ្យដល់សត្វលោកទាំងពួង ។

កាលបើព្រះរេវតត្ថេរ ពន្យល់យ៉ាងដូច្នេះ, ព្រះពុទ្ធឃោសៈនោះ ក៏ជ្រះថ្លារីករាយ ចេញពីវិហារនោះ ហើយបានមកដល់ទ្វីបនេះ ក្នុងរជ្ជកាល នៃព្រះមហាក្សត្រអង្គនេះឯង លោកបានមកដល់មហាវិហារ ដែលជាទីលំនៅ របស់ពួកសាធុភិក្ខុទាំងពួង ហើយទៅកាន់មហាបធានឃរៈ បានស្តាប់អដ្ឋកថាសីហលៈ និង ថេរវាទ រៀងមក អំពីសំណាក់ព្រះសង្ឃបាល ហើយបានសំរេចចិត្ត ថា : នោះឯង ជាព្រះអធិប្បាយរបស់ព្រះពុទ្ធ ដែលជាម្ចាស់នៃធម៌ ដោយពិត ហើយក៏បាននិមន្តព្រះសង្ឃ ក្នុងវិហារនោះ មកប្រជុំព្រមគ្នាហើយ ពោលថា

សូមព្រះគុណម្ចាស់ទាំងឡាយ ប្រទានគម្ពីរទាំងឡាយទាំងពួង ដល់ខ្ញុំព្រះករុណា ដើម្បីចងក្រងជាអដ្ឋកថា, ដើម្បីសាកល្បងមើលសតិបញ្ញា ព្រះសង្ឃ បានឲ្យគាថា ២ បទ ដល់ព្រះពុទ្ធឃោសៈនោះហើយ ពោលថា : ចូរលោកសំដែងនូវសេចក្ដីអង់អាចរបស់លោក ក្នុងគាថា ២ បទនេះមកមើល, ពួកយើងឃើញសេចក្ដីអង់អាច របស់លោកហើយនឹងឲ្យគម្ពីរទាំងអស់។ ព្រះពុទ្ធឃោសៈបានរួបរួមព្រះត្រៃបិដក ព្រមទាំងអដ្ឋកថា ដោយសង្ខេបខ្លីហើយតែងគម្ពីរវិសុទ្ធិមគ្គ ក្នុងវិហារនោះឯង រួចហើយក៏និមន្តព្រះសង្ឃ ដែលឈ្លៀវឆ្លាតក្នុងព្រះសទ្ធម្ម របស់ព្រះសម្ពុទ្ធ ឲ្យមកប្រជុំគ្នា នៅក្បែរមហាពោធិមណ្ឌលប្រារព្ធដើម្បីនឹងអានគម្ពីរវិសុទ្ធិមគ្គនោះ(ឲ្យសង្ឃស្ដាប់)។

ពួកទេវតា ដើម្បីប្រកាសនូវថ្វីដៃ របស់លោកឲ្យបានប្រាកដ ក្នុងមហាជន ក៏បានបំបាំងគម្ពីរនោះទុកសិន, ឯព្រះពុទ្ធឃោសៈ ក៏បានតែងគម្ពីរនោះ សាថ្មីទៀត ជាលើកទី២-ទី៣ ។ កាលព្រះពុទ្ធឃោសៈ យកគម្ពីរមកដើម្បីឲ្យអាន ក្នុងលើក ទី៣, ពួកទេវតា ក៏ឈប់ (ធ្វើ) ហើយ យកគម្ពីរផ្សេងៗ ទៀត មកតម្កល់ទុក ព្រមគ្នាក្នុងទីនោះ ។ ក្នុងពេលនោះ ពួកភិក្ខុអានគម្ពីរទាំងបីភាគនោះជាមួយគ្នា, ការខុសភ្លាំងភ្លាត់ទៅជាប្រការដទៃ ក្នុងគម្ពីរទាំង ៣ ភាគនោះ ដោយគណ្ឋៈក្ដី ដោយអដ្ឋកថាក្ដី



ដោយអំណាចមុខក្រោយក្ដី ដោយថេរវាទទាំងឡាយក្ដី ដោយបាលីទាំងឡាយក្ដី ដោយបទទាំងឡាយក្ដី ដោយព្យញ្ជនៈទាំងឡាយក្ដី មិនមានសោះឡើយ ។

គ្រានោះ ព្រះសង្ឃ ត្រេកអររីករាយ ជាពិសេសបានប្រកាសយ៉ាងគឹកកង ម្ដងហើយម្ដងទៀតថា : ភិក្ខុរូបនេះជាតួអង្គព្រះមេត្តេយ្យៈ ឥតមានសង្ស័យឡើយ ហើយក៏បានប្រគល់គម្ពីរព្រះត្រៃបិដក ព្រមទាំងអដ្ឋកថា (ដល់ព្រះពុទ្ធឃោសៈ) ។

ព្រះពុទ្ធឃោសៈ លោកនៅក្នុងវិហារ ដែលជាទីកើតនៃគម្ពីរ ជាកន្លែងដែលនៅឆ្ងាយពីការច្របូកច្របល់ បានបកប្រែអដ្ឋកថាសីហលៈ ទាំងអស់ ក្នុងគ្រានោះ មកជាភាសាមគធៈ ដែលជាមូលភាសា នៃអដ្ឋកថា ទាំងអស់នោះ ។ អដ្ឋកថាដែលលោកបានបកប្រែនោះ បាននាំប្រយោជន៍សុខ ឲ្យដល់ពួកសត្វគ្រប់ភាសា, ព្រះអាចារ្យដែលជាថេរៈ គ្រប់រូប បានប្រកាន់យកអដ្ឋកថានោះ ទុកដូចបាលី ។

លំដាប់នោះ កាលបើចប់កិច្ចការ ស្រេចអស់ហើយ, ព្រះពុទ្ធឃោសៈ លោកបានវិលត្រឡប់ មកកាន់ជម្ពូទ្វីបវិញ ដើម្បីថ្វាយបង្គំព្រះមហាពោធិ៍ ។

ព្រះមហាក្សត្រ ព្រះនាមមហានាម គ្រងរាជសម្បត្តិ ១២ ឆ្នាំ ទ្រង់បានបំពេញបុណ្យ ជាច្រើនប្រការ ហើយ

ស្ដេចទៅតាមយថាកម្ម ។

ចំណែកព្រះថេរៈពុទ្ធឃោសៈនោះ លុះតែងអដ្ឋកថាព្រះត្រៃបដិក ធ្វើប្រយោជន៍សុខ ដល់សត្វលោក ជាច្រើនហើយ ស្ថិតនៅ រហូតកាលកំណត់នៃអាយុ ក៏បានទៅដល់សុគតិទេវលោកហោង ។

*គាថាដូចតទៅនេះ ព្រះធម្មត្រៃលោកាចារ្យ ខេមចារី រៀបរៀង*

ប្រវត្តិព្រះពុទ្ធឃោសៈនេះ ខ្ញុំបានរៀបរៀង តាមន័យដែលបានពោលហើយ ក្នុងគម្ពីរសទ្ធម្មសង្គហៈ និងក្នុងគម្ពីរបុរាណ ឈ្មោះ មហាវង្ស, វិញ្ញូជន អ្នកត្រូវការចង់ដឹងសេចក្ដីដែលប្លែកពីគ្នា គប្បីជ្រាប ក្នុងគម្ពីរនោះៗតាមសមគួរ គឺក្នុងពុទ្ធឃោសនិទានខ្លះ ឬ ក្នុងវិសមា-លិនីខ្លះ ក្នុងគម្ពីរពិសេស ឈ្មោះ ញាណោទ័យខ្លះ ។

ក៏អន្លង់ទឹកពោលគឺបុណ្យដ៏ច្រើន ដែលយើងខ្ញុំទាំងឡាយបានហើយ ដោយការរចនា ជម្រះនូវគម្ពីរវិសុទ្ធិមគ្គមានប្រមាណប៉ុណ្ណេះនេះ សូមទេវតាទាំងឡាយទាំងពួងអនុមោទនា នូវបុណ្យនោះ ដើម្បីបានសំរេច នូវសម្បត្តិទាំងពួង ! សូមសត្វទាំងឡាយ រក្សាសីល ចំរើនចិត្តភាវនា តាមសទ្ធា ! និង សូមកុំប្រមាទធ្វេសប្រហែសនូវបញ្ញាឡើយ! ព្រោះថា នោះជាផ្លូវនៃសេចក្ដីបរិសុទ្ធិ ។

សូមឲ្យសត្វទាំងឡាយ ដែលដល់ហើយនូវទុក្ខ សូម



ឲ្យជាសត្វបាត់ទុក្ខទៅ ! ដែលដល់ហើយនូវភ័យ សូមឲ្យជាសត្វបាត់ភ័យទៅ ! ដែលដល់ហើយ នូវសោក សូមឲ្យជាសត្វបាត់សោកទៅ និង សូមឲ្យសាធុជនទាំងឡាយ បានដល់នូវសេចក្ដីបរិសុទ្ធិទៅហោង ។

បានប្រែចប់សព្វគ្រប់នៅ
ថ្ងៃពុធ ៨ រោច ខែកត្តិក ឆ្នាំខាល សំរិទ្ធិស័ក ព. ស. ២៥៤២
ត្រូវនឹងថ្ងៃ ទី១១ ខែវិច្ឆិកា ឆ្នាំ ១៩៩៨
វេលាម៉ោង ៦:៤៧ នាទី ល្ងាច ។
ភិក្ខុវិនយធរោ មហាយិន-ឡឿន
វត្តខ្មែរសាន់តាអេណា
ទីក្រុងសាន់តាអេណា រដ្ឋកាលីហ្វូនីញ៉ា សហរដ្ឋអាមេរិក

* ❈ *

*វាយចប់សព្វគ្រប់នៅ*
*ថ្ងៃសៅរ៍ ៣ រោច ខែមិគសិរ ឆ្នាំថោះ ឯកស័ក ព.ស.២៥៤៣*
*ត្រូវនឹងថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ ១៩៩៩ វេលាម៉ោង ៨:៣០ ព្រឹក*
*វាយចេញជាអក្សរដោយ ព្រះភិក្ខុ (ទក្ខប្បញ្ញោ) អឿ-សៅ*

♣ ♣ ♣

## រាយនាមពុទ្ធបរិស័ទ ជួយឧបត្ថម្ភ ក្នុងធម្មទាននេះ

| | |
|---|---|
| ប្រអប់ធម្មបូជា (វត្តខ្មែរសាន់តាអាណា) | ៣,២០០ដុ |
| លោក ឡូ-ប៊ុនឡេង អ្នកស្រីអៀប-ឆៃគីម | ២,៦៩០ដុ |
| ឧបាសិកាអៀប-ឆៃគិម ឧបាសក ឡូ-ប៊ុនឡេង | ២,០០០ដុ |
| ធម្មបូជា បុណ្យចំរើនព្រះជន្ម ព្រះភិក្ខុ សែម-សុឃឿន | ១,៧៩០ដុ |
| ពុទ្ធបរិស័ទ វត្តសន្សំកុសល អាចារ្យអឿ-សៅ | ១,០០០ដុ |
| ឧបាសិកា អៀប-ឆៃហុង | ១,០០០ដុ |
| ឧបាសិកាឈឹម-គីមស្រ៊ុន និង កូនចៅ ព្រមទាំងញាតិមិត្រ | ១,០០០ដុ |
| ឧបាសិកា នួន-វណ្ណា ព្រមទាំងកូនចៅ | ១,០០០ដុ |
| ឧបាសិកា នួន-វណ្ណា | ៩០០ដុ |
| លោក វង់-ម៉ៅ អ្នកស្រីឆាន់-កាន់ជួង | ៨៨០ដុ |
| ឧបាសក វង្ស-ម៉ៅ ឧ:សិកា ឆាន់-កាន់ជួង | ៥៩៥ដុ |
| អ្នកស្រី ឆាន់-ហៃគីង | ៥០០ដុ |
| វត្តមិនីសុតារាម | ៥០០ដុ |
| ភិក្ខុ មាស-គឹមអេង សីលបញ្ញា | ៥០០ដុ |
| ភិក្ខុ ភាគ់-ឈួន | ៥០០ដុ |
| ឧបាសិកា ឆាន់-ហាយ ព្រមទាំងកូនចៅ | ៥០០ដុ |
| បុណ្យបច្ច័យ ៤ ឧបាសិកា យឹម-លឹម កូនចៅ និង ញាតិមិត្រ | ៥០០ដុ |
| ឧបាសិកា វ៉េន-ល្វន់ (សុខ-រស់) និង កូនចៅ | ៤៥០ដុ |
| ធម្មទេសនា ព្រះអង្គសឿន | ៤៤៨ដុ |
| ពុទ្ធបរិស័ទវត្តសាន់តាអាណា ថ្ងៃសីល | ៤២០ដុ |
| ឧបាសិកា ស៊ីណា-ផូ SOPHANNA LAO | ៤០២ដុ |
| បុណ្យឧបាសិកា លី-ឡាំងជាង និង កូនចៅ | ៤០០ដុ |
| ភិក្ខុ អាំង-ឃុង ឧបាសិកា តាន់-គឹមថាន់ បុត្រធីតា និង ចៅ | ៤០០ដុ |
| លោកតែ-ទាសៀ អ្នកស្រីលឹម-ណៃហ្គួង ព្រមទាំងញាតិមិត្រ | ៤០០ដុ |
| ភិក្ខុ អ៊ុង-អ៊ិន ឧបាសិកា សែម-ស៊ីផន | ៤០០ដុ |
| ភិក្ខុមហាសម-យស (វត្តម៉ាក់សី ប្រទេសបារាំង) | ៤០០ដុ |
| បច្ច័យ ៤ ពុទ្ធបរិស័ទ វត្តរតនប្រទីប អូតាវ៉ា | ៣៥០ដុ |
| បុណ្យលោកតា អ៊ាប-ភាវ | ៣៣០ដុ |
| ឧបាសិកាលឹម-គាមទី ព្រមទាំងបុត្រ, គី-សេរី ភរិយានិងបុត្រ, សុភាព-តាន់, ឈាងហ៊-តាន់, មុរីណា-តាន់, ចាន់បូណា-ហេង | ៣៣០ដុ |
| ព្រះធម្មទេសនា ធម្មាចារ្យ កែវ-វិមុត្តិ ក្នុងវត្តសាន់តាអាណា | ៣២៧ដុ |
| ព្រះតេជះគុណប្រកប វត្តជម្ពូវក្ខាវនារាម | ៣១៥ដុ |
| លោក ស៊ុន-សៀក ព្រមទាំងគ្រួសារ | ៣០៧ដុ |



| | |
|---|---|
| ភិក្ខុ អ៊ុន-រិន សង្ឃរក្ខិតោ | ៣០០ដុ |
| ឧបាសិកា អ៊ុក-ទូរេត | ៣០០ដុ |
| អ្នកស្រី សុផាត-ភឿង, ឧបាសិកា ផុន និង គ្រួសារ | ៣០០ដុ |
| ឧបាសក យស់-សាអ៊ុល ឧបាសិកា យស់-អានីតា (ឌី-ស៊ីវឡាំង | ៣០០ដុ |
| ព្រះតេជះព្រះគុណ ប្រកប វត្តជម្ពូរុក្ខារាម | ៣០០ដុ |
| ភិក្ខុវិនយធរោ មហាយិន-នឿន | ៣០០ដុ |
| ឧបាសក នង-ហាក់ ព្រមទាំងគ្រួសារ កូនចៅ | ៣០០ដុ |
| លោកគ្រូរក្ខិតធម្មោ គង់-សូផាន | ៣០០ដុ |
| លោកអាចារ្យ អ៊ុង-អ៊ិន ព្រមទាំងគ្រួសារ និង កូនចៅ | ៣០០ដុ |
| លោកសុជាតតោ-សំលឿង អ្នកស្រីស៊ុម-សាឡាត់ | ៣០០ដុ |
| អ្នកស្រី **RATH KIM & BILL CHHAY** | ២៦០ដុ |
| ពុទ្ធបរិស័ទ វត្តខ្មែរបាលិលេយ្យ | ២៦០ដុ |
| បច្ច័យបូជាព្រះធម៌ទេសនា ឆ្លងកុដិវត្តសាន់ហូសេ ០៨-០៦-១០ | ២៥៨ដុ |
| ឧបាសិកា សៅ-យ៉ៃ ព្រមទាំងកូនចៅ | ២៥០ដុ |
| ព្រះតេជះព្រះគុណធម្មថេរោ (សៅ-ឃន) | ២៥០ដុ |
| ឧបាសក ចេក-ឃាន ឧបាសិកា ច័ន្ទ-ឈួម ព្រមទាំងកូនចៅ | ២៥០ដុ |
| ឧបាសក ស៊ុម-ស៊ីម និង គ្រួសារ កូនចៅ | ២៥០ដុ |
| អ្នកស្រី ធីរ៉ា **RICHARCH (GA)** | ២២០ដុ |
| លោកអាចារ្យ ភាគ-ឈួន គ្រួសារ និង កូនចៅ | ២២០ដុ |
| ឧបាសិកា លឹម-គាមទី និង បុត្រធីតា | ២២០ដុ |
| ញោម សារុន និង កូន | ២១៧ដុ |
| លោក រិទ្ធិ-ស៊ាន អ្នកស្រីស៊ីវ-ង៉ោ,សុផានី, លីនដា, សោភ័ណ | ២១០ដុ |
| កេតុ-ថូ | ២០០ដុ |
| ឧបាសិកា លឹម-ណៃស្រីម កូនចៅ | ២០០ដុ |
| អ្នកស្រីស៊ូ-ហាច និង កូនចៅ | ២០០ដុ |
| លោកឈាន-សារឿន អ្នកស្រី ឡឹង-គីមស្រោន | ២០០ដុ |
| អាចារ្យប្រាក់-ភាច ឧបាសិកា សុខ-ភឿន | ២០០ដុ |
| ឧត្តមធម្មឃោសាចារ្យ កុត-កុសល កែវ-សុធម្មា ឡៃ-យ៉ុន | ២០០ដុ |
| លោក តាំង-ចឺ អ្នកស្រី ឡេា-គឹមឡេង | ២០០ដុ |
| លោក ឡាំ-រឿង ព្រមទាំងក្រុមគ្រួសារ | ២០០ដុ |
| **Mrs NAMTYHUY, Mr, & Mrs. KEIW LEE, TINATH LEE** | ២០០ដុ |
| ឧបាសិកា អ៊ឹង-សាយទាវ នាង អ៊ឹង-គិមអេង | ២០០ដុ |
| ព្រះតេជះគុណ ថុន-សុផុន | ២០០ដុ |
| លោកវោហា-ជួន អ្នកស្រីណាត្រី-ជួន | ២០០ដុ |

| | |
|---|---|
| ពុទ្ធិកសមាគម វត្តធម្មរង្សី | ២០០ដុ |
| លោក ឯក-ឆាលី អ្នកស្រី អោម-ខុន | ២០០ដុ |
| ឧបាសិកា ឡូ-មេងឃន ព្រមទាំងកូន | ២០០ដុ |
| លោក ឡូ-មេងហ៊ា | ២០០ដុ |
| ប៊ុន-ឡេង និង តែ-គិម | ២០០ដុ |
| ស៊ិម-គិម យ៉ុន | ២០០ដុ |
| លោក សុខ-មុត អ្នកស្រី មាស-សន្លាវុណ្ណ និង បងប្អូន | ២០០ដុ |
| ឧបាសិកា សុខ-មឿន ឧបាសិកា តាន់-សម្បត្តិ | ២០០ដុ |
| អ្នកស្រី មិញ-សូហាច ព្រមទាំង កូនចៅ | ២០០ដុ |
| ឧបាសិកា ចៅ-សារួន ព្រមទាំងកូនចៅ | ២០០ដុ |
| ពុទ្ធបរិស័ទវត្តវិបស្សនារាម | ២០០ដុ |
| ឧបាសក ជូ-មី ឧបាសិកា ឯក-បូលីន និង កូនចៅ | ១៨៥ដុ |
| អ្នកស្រី កុត-កណ្ណិកា សោម៉ា(សុជាតា) ស្វាមី និង បុត្រ | ១៧៥ដុ |
| លោកតាអ៊ឹម-ពន្លក និង ឧបាសិកាដួង-សុខុម | ១៧៥ដុ |
| ភិក្ខុ ប្រាជ្ញ-សារ៉ាន់ | ១៦៦ដុ |
| DARA HENG | ១៥០ដុ |
| ឧបាសិកា អ៊ុន-ហេង និង កូនចៅ | ១៥០ដុ |
| ឧបាសិកា រេន | ១៥០ដុ |
| ភិក្ខុ ម៉ែន-សុខ | ១៤០ដុ |
| ភិក្ខុ និង សាមណេរ វត្តអែរ៉ាប់ | ១៣០ដុ |
| ឧបាសក ជ្រុក-វួន ឧបាសិកា ម៉ែន-ផាត កូនចៅ | ១២០ដុ |
| ឧបាសិកា យឹម-លឹម ព្រមទាំងកូនចៅ | ១២០ដុ |
| ឧបាសិកា អ៊ុក-ស៊ីណា | ១៥០ដុ |
| ឧបាសិកា ផាវ-សារៀប, សក់-សាលឿន លោកអេង-កាំង | ១៥០ដុ |
| ឧបាសិកា ទួន-មុំ | ១៥០ដុ |
| ឧបាសិកា ប្រីយ៍-យ៉ុម | ១៤០ដុ |
| ឧបាសិកា ចែត-ទទឹម | ១៤០ដុ |
| លោក ឈុន-គីម អៀត និង គ្រួសារ | ១៤០ដុ |
| លោកអាចារ្យ ប៉េ-វី ឧបាសិកា ថូ-ញ៉ឹង និង កូនចៅ | ១២៥ដុ |
| ឧបាសក ជូ-មី ឧបាសិកា ឯក-បូលីន | ១២០ដុ |
| ឧបាសិកា លី-ឡាំងជាង និង កូនចៅ | ១២០ដុ |
| លោក ពា-ប៉ាវស្រី ព្រមទាំងគ្រួសារ | ១២០ដុ |
| អ្នកស្រី ញ៉ឹក-ស៊ីថា និង កូនចៅ | ១២០ដុ |
| ពុទ្ធបរិស័ទ វត្ត រតនារាម | ១១៨ដុ |



| | |
|---|---|
| ព្រះធម៌ទេសនា | ១១៥ដុ |
| ភិក្ខុ ប៉ាន-សំម៉ាយ និង ពុទ្ធបរិស័ទ វត្តច័ន្ទស៊ីសាមគ្គីធម៌ | ១១០ដុ |
| ឧបាសិកា ញ៉ែម-នីម និងកូនចៅ | ១១០ដុ |
| ភិក្ខុ មហាប៊ុន-ឈឺន | ១១០ដុ |
| ឧបាសិកា លី-គឹមស៊ា និង បុត្រធីតា | ១១០ដុ |
| ភិក្ខុ សោម-សុភា (ធម្មធរោ) | ១០៧ដុ |
| ភិក្ខុ ឫទ្ធិពល នាថបណ្ឌិតោ | ១០៥ដុ |
| CHHAY SEREI CHAN | ១០៥ដុ |
| អ្នកស្រី ជា-តោ | ១០៥ដុ |
| ភិក្ខុ យុន-ទុយ | ១០៥ដុ |
| លោក ញ៉ិន-ផុន អ្នកស្រី សុខ-សារ៉េត កញ្ញា ញ៉ិន-រ័ត្ន | ១០១ដុ |
| លោក អ៊ើ-សៅ, ឧបាសកប៊ូ-ហោនាង, | |
| ឧបាសិកា អ៊ឹង-រិទ្ធានី, ឧបាសិកាលី-ប៉ូលីន ស៊ីម-ប៉ូ | ១០០ដុ |
| លោក តាំង-ហាំងសាយ អ្នកស្រីជីវ-សុខមួយ និង កូនចៅ | ១០០ដុ |
| លោកអាចារ្យ ឡុង ឧបាសិកា ឃាង-សាមិន | ១០០ដុ |
| លោក សារិន អ្នកស្រី គឹម-លាង | ១០០ដុ |
| ឧបាសិកា សុខ-សាមឿន តាន់-សម្បត្តិ | ១០០ដុ |
| ឧបាសិកា អ៊ឹម-ណួយ | ១០០ដុ |
| MOLANIE, ALLAN, LONIS & MADELYN LIM | ១០០ដុ |
| អាចារ្យ វិសុទ្ធិ-ឌិម ឧបាសិកា សូត-សាខន | ១០០ដុ |
| អ្នកស្រី កែវ-បុប្ផាទិព្វ | ១០០ដុ |
| ឧបាសិកា កង-សាលី និង កូនចៅ | ១០០ដុ |
| TAING KIM LEAANG | ១០០ដុ |
| ឧបាសិកា ថោង-មុំ | ១០០ដុ |
| ឧបាសិកា ហ៊ឹង-ប៊ូ | ១០០ដុ |
| អ្នកស្រី គួយ-វ៉ាន់ | ១០០ដុ |
| ឧបាសិកា ភន-ស៊ាងហៃ និង បុត្រធីតា | ១០០ដុ |
| ឧបាសិកា យិន-ហ៊ុន ឧបាសក យិន-សឿន | ១០០ដុ |
| ឧបាសិកា យូ-ស្រ៊ន | ១០០ដុ |
| លោកអាចារ្យ ហេង អ្នកស្រី ហ៊ុន-គឹមសាយ | ១០០ដុ |
| ឧបាសក ឃុំ-កុសល ឧបាសិកា ហេង-យិន និង បុត្រធីតា | ១០០ដុ |
| លោក ស៊ីសុវណ្ណ-ណាយ និង ភរិយា | ១០០ដុ |
| ឧបាសិកា ញ៉ុក-ហ៊ួ ព្រមទាំងកូនចៅ | ១០០ដុ |

| | |
|---|---|
| លោក ផង់-វើម អ្នកស្រី វ៉េន-អឿន | ១០០ដុ |
| ឧបាសិកា សាន-អឿន ព្រមទាំងកូនចៅ | ១០០ដុ |
| ឧបាសិកា សួស-ណៃទៀង ព្រមទាំងកូនចៅ | ១០០ដុ |
| ឧបាសិកា ជិង-សាយ ថ ព្រមទាំងកូនចៅ | ១០០ដុ |
| ឧបាសិកា ណារ៉េត-អ៊ូ | ១០០ដុ |
| ឧបាសក ថ្លាង-សាវន ឧបាសិកា យិន-សំណាង | ១០០ដុ |
| ឧបាសិកា កាក់-កួយ | ១០០ដុ |
| ឧបាសក ស៊ិន-ផូ លោកយាយពុំ | ១០០ដុ |
| ឧបាសិកា ឌុច-សាមីន | ១០០ដុ |
| បណ្ឌិត តូច-ផលមាន និង គ្រួសារ | ១០០ដុ |
| កម្លោះ ពៅ រីឌៀល សម្បូរ | ១០០ដុ |
| ធួក-សុទ្ធី | ១១០ដុ |
| ឧបាសិកា កុល-យន់ យាយសម្ផា | ១០០ដុ |
| ឧបាសិកា ឈា លោកតា ហេន | ១០០ដុ |
| ឧបាសិកា ញ៉ែម-ឡាង និង បុត្រ | ១០០ដុ |
| ឧបាសិកា កាក់-គីគង់ និង បុត្រធីតា | ១០០ដុ |
| LAKHANA SAR (BONG LEAK) កូនយាយរេន | ១០០ដុ |
| លោក ប៉ុក-ប៊ុនរិទ្ធ ព្រមទាំងគ្រួសារ និង កូនចៅ | ១០០ដុ |
| ឧបាសិកា ទិត-សាត ព្រមទាំងកូនចៅ | ១០០ដុ |
| ឧបាសិកា អ៊ុក-ទូរ៉េត | ១០០ដុ |
| ម៉ន-ស៊ិងហេង ភរិយា ឡាយ-សុខគា | ១០០ដុ |
| ស៊ុម-រ៉ាត់ ភរិយា យិន-ឃីម និង បុត្រធីតា | ១០០ដុ |
| ឧបាសិកា ឌិម-សង្វាន លោកនេត្រ-ហេង និងកូនចៅ | ១០០ដុ |
| ឧបាសិកា គីម-សី លោក ប្រៀន-គាង និង ភរិយា | ១០០ដុ |
| ឧបាសិកា ជា-លឹមអេង | ១០០ដុ |
| ឧបាសិកាផាវ-សារៀប អ្នកស្រីសក់-សាលឿន គ្រួសារ | ១០០ដុ |
| ឧបាសិកា ផាន់-ឡាន និង បុត្រធីតា | ១០០ដុ |
| លោកគ្រូ ឆាយ-យស ឧបាសិកា ចាប-សំអៀន | ១០០ដុ |
| ឧបាសិកា កុត-សាខន និង បុត្រធិតា | ១០០ដុ |
| ភិក្ខុ អ៊ុន-វ៉ិន | ១០០ដុ |
| លោក ជា-ព្រហម៉ន នាង ផ្កាសារ៉េត | ១០០ដុ |
| នាង ព្រហ្ម-ច័ន្ទ សូវ៉ន និង កូនលក្ខណា | ១០០ដុ |
| លោកអាចារ្យ កែវ-ប៊ុន ឧបាសិកា ហាច-សួង | ១០០ដុ |
| ឧបាសិកា ប៉ាន-សារិទ្ធ ព្រមទាំងកូនចៅ | ១០០ដុ |



| | |
|---|---|
| អ្នកស្រី ប៊ុត-សុផានី | ១០០ដុ |
| ឧបាសិកា គាន-សរ | ១០០ដុ |
| លោក តាន់-កៅ អ្នកស្រី តាន់-សារឿន | ១០០ដុ |
| ឧបាសិកា ង៉ោ-ស៊ូអេង | ១០០ដុ |
| ព្រះវិភទ្ទញ្ញាណ (ព្រហ្ម-ខៀន) វត្តសុវណ្ណគិរី | ១០០ដុ |
| ភិក្ខុ ប៊ុន-ស្មៀន ធម្មវរោ | ១០០ដុ |
| ភិក្ខុ សឹម-សៀម ធម្មរក្ខិតោ | ១០០ដុ |
| ភិក្ខុ អឿ-សៅ | ១០០ដុ |
| ព្រះតេជះគុណមាស-គីមអេង | ១០០ដុ |
| ភិក្ខុ យិន-សាគុណ | ១០០ដុ |
| ព្រះតេជះគុណ ម៉ី-រស | ១០០ដុ |
| ភិក្ខុ ឡាយ-វិន | ១០០ដុ |
| ភិក្ខុ មហាមុនី-រត្ន | ១០០ដុ |
| ភិក្ខុ គង់-សុទ្ធី | ១០០ដុ |
| សាមណេរ ជិម-មាល័យ | ១០០ដុ |
| លោកអាចារ្យ ថាច់-សុង ហុង-គិមហ៊ន់ | ១០០ដុ |
| អ្នកស្រី ឆាន់-ហ្វុង | ១០០ដុ |
| លោកអាចារ្យសឺន-ដុង ឧបាសិកា ឡុង-ប៉ែន | ១០០ដុ |
| ឧបាសក លន់-ធន់ | ១០០ដុ |
| ឧបាសក ជិក-វិញ និង ឧបាសិកា គិម-ថាញ់ | ១០០ដុ |
| ឧបាសិកា ផាវ-សារៀប និង កូនចៅ | ១០០ដុ |
| អ្នកស្រី ឈុន-យ៉េន | ១០០ដុ |
| ឧបាសក ហ៊ឹម-ម៉ៅ ភរិយា និង បុត្រធីតា | ១០០ដុ |
| អ្នកស្រី លឹម-ចាន់ណា | ១០០ដុ |
| បុណ្យឧបាសក សឺន-អឿង ឧបាសិកា គិម-ចីសី | ១០០ដុ |
| ភិក្ខុ តាន់-ភោគ កិត្តិសារោ (វត្តធម្មរង្សី) | ១០០ដុ |
| ព្រះតេជគុណ ឡុង-សុខឡាំ (វត្តសាគរបុរី) | ១០០ដុ |
| ឱឧបាសិកា តាន់-ឈើវគិន និង កូនចៅ | |
| លី-ឆេងស៊ុន និង ទឹង-វួចហ៊ុន ព្រមទាំង កូនចៅ | ១០០ដុ |
| ភិក្ខុ សំ-រ័ត្ន | ១០០ដុ |
| ឧបាសិកា អ៊ូ-ហាំងចេង និង កូនចៅ | ១០០ដុ |
| ភិក្ខុ ប៊ូ-សាំងយ៉ុន កិត្តិកធម្មោ | ១០០ដុ |
| លោកអាចារ្យ អោក-យៀម និង កូនចៅ | ១០០ដុ |
| ឧបាសិកា ធិ-ប៊ុតស៊ាន | ១០០ដុ |

| | |
|---|---|
| លោក និង លោកស្រី សំបាន-នូ | ១០០ដុ |
| លោកខៀវ-ស៊ីណារ៉េត | ១០០ដុ |
| លោក សារិន អ្នកស្រី គីម-លាង | ១០០ដុ |
| លឹម-យ៉េត | ១០០ដុ |
| វង្ស-ករុណា និង គ្រួសារ | ១០០ដុ |
| វង្ស-វីណា ស្វាមី និង បុត្រ | ១០០ដុ |
| ឧបាសិកា លឹម-ណៃស្រីម | ១០០ដុ |
| ឧបាសិកា សេង-យ៉ាន | ១០០ដុ |
| ឧបាសិកា ព្រះឈាង ហៅ ញាណ-សុធា | ១០០ដុ |
| កុល-ស៊ិម | ១០០ដុ |
| ឧបាសក អឿ-សៅ | ១០០ដុ |
| ប៉ក់-បុប្ផ | ១០០ដុ |
| លោក និង លោកស្រី សុផាន | ១០០ដុ |
| ឧបាសិកា ភន-ស៊ាងហៃ | ១០០ដុ |
| ឧបាសិកា ភន-ស៊ាងហៃ និង បុត្រ, ឧបាសិកា យ៉ក-ស្រិន, ឧបាសិកា ជា-លាងហ៊ី, ឧបាសិកា ឈុន-គឹមស្រី | ១០០ដុ |
| ឧបាសិកា អ៊ុន-អ៊ន | ១០០ដុ |
| លោក ង៉ូវ-មួយឡាយ និង បុត្រ | ១០០ដុ |
| ឧបាសិកា អៀប-ឆៃហុង | ១០០ដុ |
| ឧបាសិកា ហុយ-ណាំទី | ១០០ដុ |
| ឧបាសិកា ឡុង-ប៉ែន ឧបាសក សន-ជុំ | ១០០ដុ |
| ឧបាសិកា ស៊ន-ឡេង | ១០០ដុ |
| បុណ្យ ១០០ ថ្ងៃ លោកអ៊ុង-ធារី | ១០០ដុ |
| ឧបាសិកា សរ-យុត | ១០០ដុ |
| ឧបាសក អៀង-ឆាយ ឧបាសិកា អៀ-កេសរ | ១០០ដុ |
| ឧបាសក អ៊ុន-ឆាយគ្រី | ១០០ដុ |
| ឧបាសក ហោ-លាន ឧបាសិកា ឆឹង-អុន | ១០០ដុ |
| លោកអាចារ្យ ម៉ន-ផាន  ផង់-គាំ | ១០០ដុ |
| ភិក្ខុ វិជ្ជាសម្បន្នោ វត្តពន្លឺពុទ្ធចក្រ | ១០០ដុ |
| ឧបាសិកា ថេត-រ៉ុន ឧបាសក វ៉ៃ-សារុន | ១០០ដុ |
| ឧបាសិកា សុផន-សូរ | ១០០ដុ |
| ឧបាសិកា តាន់-ណៃស៊ីន និង កូនចៅ | ១០០ដុ |
| ឧបាសិកា ឈុន-យ៉េន | ១០០ដុ |
| លោកអាចារ្យ ដោក-សុន ឧបាសិកា អ៊ូ-អ៊ូច និង កូនចៅ | ១០០ដុ |



| | |
|---|---|
| ឧបាសក យ៉ម-ដែង ឧបាសិកា ហេង-វណ្ណឌី កូនចៅ | ១០០ដុ |
| ឧបាសិកា ធូ-មុំ ឧបាសក កុយ-ធួន | ១០០ដុ |
| ឧបាសក លី-ថុង អ្នកស្រី គីម-សាន ព្រមទាំងកូនចៅ | ១០០ដុ |
| លោក ហៀប-បេ អ្នកស្រី ឡៅ-កែវម្លិះ | ១០០ដុ |
| អ្នកស្រី ញ៉ិក-សីថា ព្រមទាំងកូនចៅ | ១០០ដុ |
| ភិក្ខុ សុខ-ភាតរ: | ១០០ដុ |
| អ្នកស្រី សំបូ-រ័ត្ន (ហៅហ៊ីង-ស៊ុនថា) | ១០០ដុ |
| ភិក្ខុ គឹម-បាន | ១០០ដុ |
| ភិក្ខុ ទិម-ញ៉ុល (តិណកាមោ) | ១០០ដុ |
| ឧបាសក ម៉េង-ប៉ុង ឧបាសិកា ចាន់-ញ៉ឹម | ១០០ដុ |
| ឧបាសក ផេន-អាន ឧបាសិកា លន់-សេងហ៊ាង | ១០០ដុ |
| អ្នកស្រី ទេព-សូនី | ១០០ដុ |
| ឧបាសិកា ពៅ-តុន ព្រមទាំងកូនប្រុសស្រី | ១០០ដុ |
| លោក កែវ-សំអឿន អ្នកស្រី ហ៊ុន-វណ្ណា និង បុត្រ | ១០០ដុ |
| **PHNOM PENP EXPRESS** | ៩០ដុ |
| **LOEUNG NINA** | ៩០ដុ |
| អ្នកស្រី សន-លីណា ហៅ អាភាព កូនខ្ញុំ | ៩០ដុ |
| លោក តាំង-ហាំងឆាយ អ្នកស្រីជីវ-សុខម៉ួយ | ៩០ដុ |
| ឧបាសិកា លីម-មួយជូ | ៩០ដុ |
| ភិក្ខុ ជា-ហឿង ឧបាសិកា អ៊ូច-សូត្រ | ៩០ដុ |
| បូជាព្រះធម៌ទេសនា វត្តសាន់តាអាណា | ៨៨ដុ |
| ឧបាសក ជូ-មី ឧបាសិកា បូលីន កូនចៅ | ៨៥ដុ |
| ឧបាសិកា ទិត្យ-យ៉ាន ប៉ុក-សំអាន | ៨០ដុ |
| អ្នកស្រី សឿន-សុឃួន ព្រមទាំងគ្រួសារ | ៨០ដុ |
| ឧបាសិកា ព្រះ-ឈាង (ញាណសុភា) | ៨០ដុ |
| ឧបាសក សន-ជុង ឧបាសិកា ឡុង-ប៉ែន | ៨០ដុ |
| ឧបាសិកា ឃី-គីមលន | ៨០ដុ |
| ឧបាសិកា ទិត-សាធ | ៧០ដុ |
| ឧបាសក ទៀង ឧបាសិកា រួម និងកូនចៅ | ៧០ដុ |
| លោក ចាន់-យឿន អ្នកស្រី ងួន-ខន, អ្នកស្រី ងួន-ដកច័ន្ទ, ព្រមទាំងបុត្រធីតា | ៧០ដុ |
| អ្នកស្រី គឹម-សារុន និង លោក គិរី | ៧០ដុ |
| បច្ច័យធម្មទេសនា ភិក្ខុយិន-នឿន | ៦៥ដុ |
| ភិក្ខុ សន-សែន (វត្តព្រះពុទ្ធ) | ៦០ដុ |

| | |
|---|---|
| ឧបាសក តេង-ខាំសន ឧបាសិកា ធុយ-ប៊ុនម៉ា | ៦០ដុ |
| ឧបាសិកា យឹម-លឹម ព្រមទាំងកូនចៅ | ៦០ដុ |
| នាង គ្រួ | ៦០ដុ |
| ឧបាសិកា លឹម-អាង | ៦០ដុ |
| ឧបាសិកា ចេង-ប៉ោយ | ៦០ដុ |
| ឧបាសិកា ងី-ឆេ កូនចៅ | ៦០ដុ |
| លោក ឡេង-ឆាយ និង សុខ-មួយជាវ | ៦០ដុ |
| យាយ អ៊ឹង-ហ្គិច គ្រី-ម៉េងលាង គ្រី-ជិនណាំ | ៦០ដុ |
| ឧបាសក ឡឹម-ម៉ាតធីតា ឧបាសិកា តាំង-ធីយន | ៦០ដុ |
| ទៀវ-ឈីវហ៊ុន | ៦០ដុ |
| ឧបាសិកា ទួន-សារ៉េន (ហៅរ៉យ) | ៦០ដុ |
| អ្នកស្រី សី-អឹង | ៦០ដុ |
| អ្នកស្រី សំបួ-រ័ត្ន | ៦០ដុ |
| ឧបាសក ខោល-ឈិន ឧបាសិកា ឡូ-គីមហ៊ាង | ៦០ដុ |
| អ្នកស្រី ជូ-ជាតិ | ៦០ដុ |
| ថាច-សៀន | ៦០ដុ |
| លោក ទូច-សោភ័ណ  អ្នកស្រី ស៊ីនួន | ៦០ដុ |
| អ្នកស្រី គឹម-រួច | ៦០ដុ |
| អ្នកស្រី លីណា-តាន់ | ៦០ដុ |
| ឧបាសិកា ហេង-ស៊ន | ៦០ដុ |
| ក្រុមវេន គ្រួសារតាម៉ាន និង ញាតិមិត្រ នៅសៅមុនី | ៥៦ដុ |
| បច្ច័យបិណ្ឌបាត្រ ភិក្ខុ សឿ-សុជិន  វត្តសាន់ហូសេ | ៥៥ដុ |
| អ្នកស្រី ឡាច-វ៉ាន់ និង គ្រួសារ | ៥៥ដុ |
| **ROSS CHANTY** | ៥៥ដុ |
| តៅ-ច្រិក និង កូនចៅ | ៥៣ដុ |
| អ្នកស្រី ចាន់-កូឡាប, សេក-គ្រិច, សេក-ទី | ៥៣ដុ |
| ឧបាសក សុភោគ-ឧស្សរេន | ៥០ដុ |
| ឧបាសក អ៊ិន-លួង ឧបាសិកា ហ៊ាម-តេង | ៥០ដុ |
| ឧបាសិកា សេង-ម៉ាឡៃ, សាំង-ធារ៉ា, សាំង-ធារី | ៥០ដុ |
| លោក សាផូ-យន អ្នកស្រី ច័ន្ទ និង បុត្រ | ៥០ដុ |
| លោក យន-ឡាំង អ្នកស្រី អ៊ិត-លី និង បុត្រ | ៥០ដុ |
| លោក រឿន-ថន អ្នកស្រី លីង | ៥០ដុ |
| ឧបាសិកា ឡុង-អ៊ីម | ៥០ដុ |
| ឧបាសក សឿន ឧបាសិកា គឹម-ឈុន | ៥០ដុ |



| | |
|---|---|
| ឧបាសិកា ទឹម-ហ៊ន | ៥០ដុ |
| លោក ទូច-ស៊ីមន ប៊ិន | ៥០ដុ |
| យិម-ផល្លា រី-ផៃ | ៥០ដុ |
| អ្នកស្រី ហេង-ឈាប | ៥០ដុ |
| ឧបាសក ឡូ-ប៊ុនឡេង ឧបាសិកា អៀប-ឆៃគិម | ៥០ដុ |
| ឧបាសក គង់-វុត ឧបាសិកា អ៊ុក-ស៊ិនហួរ | ៥០ដុ |
| ឧបាសិកា លឹម-គាមទី ព្រមទាំងបុត្រ | ៥០ដុ |
| ឧបាសិកា លី-ប៉ូលីន ស៊ីម-ប៉ូ | ៥០ដុ |
| ឧបាសិកា សុខ-លន់ | ៥០ដុ |
| **SIDARY SAM** | ៥០ដុ |
| លោក ភួង-ប៊ុនហ៊ីម អ្នកស្រី ងួន-យានា | ៥០ដុ |
| អ្នកស្រី អ៊ុល-ស៊ីណា | ៥០ដុ |
| វត្តត្រៃកូដិ | ៥០ដុ |
| ឆាន់-ហ្វង និង គ្រួសារ | ៥០ដុ |
| ភាច-សារី | ៥០ដុ |
| សុភាក់ និង គ្រួសារ | ៥០ដុ |
| ពូធី ថង | ៥០ដុ |
| អ្នកស្រី លី-មឿន | ៥០ដុ |
| អ្នកស្រី គីមលី-ផ្លុង | ៥០ដុ |
| ឧបាសិកា ឌុច-សាខន | ៥០ដុ |
| ឧបាសិកា ថាប់-ថូ | ៥០ដុ |
| លោក ឈុន-គឹមអៀត និង ភរិយា | ៥០ដុ |
| ឧបាសិកា តាំង-គឹមលាង | ៥០ដុ |
| អ្នកស្រី សុខ-គាង | ៥០ដុ |
| មុនី-ឡាំ និង គ្រួសារ | ៥០ដុ |
| ម្តាយសាមណេរចេក | ៥០ដុ |
| លោក គង់-វុត អ្នកស្រី អ៊ុក-ស៊ិនហ៊ា | ៥០ដុ |
| ភិក្ខុ ធីង យីម ( វត្តធម្មនិការាម ) | ៥០ដុ |
| លោកយាយ ជិ ប៉ុនឡុង និង ប៊ូ រ៉ាស៊ី | ៥០ដុ |
| លោក វេង ណាំ និង សក់ សាន់នី | ៥០ដុ |
| ព្រះគ្រូចៅអធិការ ទេព-សៀង វត្តត្រៃរតនារាម ប្រទេសបារាំង | ៥០E |
| យុវជន ដារ៉ា-ហេង | ៥០ដុ |
| ឧបាសិកា ម៉ែន-ណៃស្រីម | ៥០ដុ |
| Mr. ANG CHUN | ៥០ដុ |

| | |
|---|---|
| ឧបាសិកា លី-ណារី និង កូនចៅ | ៥០ដុ |
| ឧបាសិកា សរ-យុត | ៥០ដុ |
| ឧបាសិកា ពា-តុប | ៥០ដុ |
| ឧបាសិកា គី-គង់ | ៥០ដុ |
| អ្នកស្រី សូរិយា អូស្ថិន | ៥០ដុ |
| បងតាំង | ៥០ដុ |
| អ្នកស្រី ឃុន-យេន | ៥០ដុ |
| អ្នកស្រី អ៊ុង-ស៊ីផាន់ណា | ៥០ដុ |
| លោក អ៊ីង-លី អ្នកស្រី ទូត-រ៉ុម | ៥០ដុ |
| អ្នកស្រី លីសា (LISA) | ៥០ដុ |
| គិម-ឡឹម ថាញ់ | ៥០ដុ |
| លោក សោម-ងន អ្នកស្រីឡៅ-ម៉ាឡៃ | ៥០ដុ |
| អ្នកស្រី ខៀវ□ស្រីវ៉ន ព្រមទាំងគ្រួសារ | ៥០ដុ |
| ពេទ្យ សម្បត្តិ និង គ្រួសារ | ៥០ដុ |
| លោកអាចារ្យ អ៊ុយ-យាន | ៥០ដុ |
| លោក លី-ហួ និង អ្នកស្រី វ៉ាស៊ី-ងួន | ៥០ដុ |
| ឧបាសិកា សួយ-សេន | ៥០ដុ |
| ភិក្ខុ នង-សុជាតិ | ៥០ដុ |
| លោក មុខ-សាម៉ន និង គ្រួសារ | ៥០ដុ |
| អ៊ាម-តាក់ និង ប៊ី-ស៊ីម | ៥០ដុ |
| ឧបាសិកា ហេង-ថូ ឧបាសក ស៊ា-ថូ កូនចៅ | ៥០ដុ |
| ឧបាសិកា ថ្លាង-ធៀម | ៥០ដុ |
| អ្នកស្រី ឡៃ-សៀង គ្រួសារ | ៥០ដុ |
| ឧបាសក ប៉ែន-ញឹម ឧបាសិកា តូ-សារិ | ៥០ដុ |
| ឧបាសិកា ប៉ោ-សៃគ្រិច | ៥០ដុ |
| ភិក្ខុ ច័ន្ទ-សុខា វត្តពោធិសុវណ្ណារាម | ៥០ដុ |
| អាចារ្យ ប៉េ-រី  ឧបាសិកា ញ៉ឹង | ៥០ដុ |
| ឧបាសិកា ស៊ិន-ង៉ែត | ៥០ដុ |
| កញ្ញា យុត | ៥០ដុ |
| ឧបាសិកា ឆាយ-ទន | ៥០ដុ |
| ភិក្ខុ អ៊ុយ-ហេង | ៥០ដុ |
| ឧបាសិកា ផលី | ៥០ដុ |
| លោក អាចារ្យ ទិក-ឃី | ៥០ដុ |
| ឧបាសិកា ង៉ូវ-ស៊ីលាន ព្រមទាំងកូនចៅ | ៥០ដុ |



| | |
|---|---|
| លោក អ៊ឹង-ង៉ួនហាវ អ្នកស្រី អ៊ឹង-សាយឃីម | ៥០ដុ |
| HOUT SOU PHALLY KHUTH | ៥០ដុ |
| អ្នកស្រី បាន-ជាហួ និង បុត្រធីតា | ៥០ដុ |
| ឧបាសិកា ដួង-យ៉ាន | ៥០ដុ |
| លោក ដុះ-ឆឺយ | ៥០ដុ |
| អ្នកស្រី ម៉ឹង-ឡៃ | ៥០ដុ |
| អ្នកស្រី បាន-ជាផិចជូ គ្រួសារ និង បុត្រ | ៥០ដុ |
| ឧបាសិកា អៀង-គីមហួយ | ៥០ដុ |
| ម៉ិល-យ៉ែម | ៥០ដុ |
| កញ្ញា ឆាយ-យុផល | ៥០ដុ |
| ឧបាសក ស៊ុន-ជាង ឧបាសិកា លី-ឡាំងជាង | ៥០ដុ |
| ភិក្ខុ ស៊ិន-ថោង ធម្មសុវណ្ណោ | ៥០ដុ |
| ភិក្ខុ បណ្ឌិតោ ជីក-ព្រហ្ម | ៥០ដុ |
| ឧបាសិកា ឈា-ហ៊ន | ៥០ដុ |
| ឧបាសិកា ចេង-ឆៃមាន | ៥០ដុ |
| ឧបាសិកា គ្រី-សេងលី | ៥០ដុ |
| ភិក្ខុ ស៊ិន-សុវត្ថា | ៥០ដុ |
| លោក ឌួង-ប៉ុន អ្នកស្រី ភី-រិន | ៥០ដុ |
| ឧបាសិកា យូ-ឡោ | ៥០ដុ |
| ភិក្ខុ ប្រាក់-ឈន | ៥០ដុ |
| ភិក្ខុ សុបណ្ណោ ហៀប-ឈាន | ៥០ដុ |
| អ្នកស្រី ប៉ុក-សុគន្ធមាលី លោកខៀវ-សំអាត បុត្រ | ៥០ដុ |
| ភិក្ខុ ឌឿ-ឧត្តម | ៥០ដុ |
| ឧបាសិកា ពឹជ | ៥០ដុ |
| លោក នូ-ច័ន្ទប៊ុននី និង ភរិយា | ៥០ដុ |
| ឧបាសិកា គង់-សូភន | ៥០ដុ |
| ឧបាសិកាអៀង-គីមហួយ កូនចៅ, ឧបាសកភោគ-ឈុំ  អ៊ឹង-ស៊ីណា | ៥០ដុ |
| គីម-សេង | ៥០ដុ |
| រាជ-រតនៈ, ចេង ហ៊ុយ ផេង ភរិយា និង បុត្រ, | |
| ឡាយ-នាង ជា-សុគុំ ភរិយា និង បុត្រ | ៥០ដុ |
| ឧបាសិកា នេត-ដានី (ទ៉ើម) | ៥០ដុ |
| ភិក្ខុ សុវណ្ណបញ្ញោ សោ-អ៊ូន | ៥០ដុ |
| អ្នកស្រី ស៊ូ-នឿន | ៥០ដុ |
| ឧបាសិកា ម៉ារ-បូរី (ផល) | ៥០ដុ |

| | |
|---|---|
| ឧបាសិកា សីល-ចាន់លន់ | ៥០ដុ |
| អ្នកស្រី អៀ-ប៊ិវ និង កូនចៅ | ៥០ដុ |
| DARIN & SAROM SOK | ៥០ដុ |
| អ្នកស្រី ហេង-ឈាប | ៥០ដុ |
| ឧបាសិកា ស៊ុម-រដ្ឋ ព្រមទាំងកូនចៅ | ៥០ដុ |
| អ្នកស៊ន-យ៉ាន គ្រួសារ និង កូនចៅ | ៥០ដុ |
| លោកម៉ៅ គ្រួសារតាចិន | ៥០ដុ |
| ឧបាសិកា មាស-ឌឹម | ៥០ដុ |
| អ្នកនាង ស៊ូសានណា-ច័ន្ទកៅ | ៥០ដុ |
| អ្នកស្រី CHAN SOKHA LIKE | ៥០ដុ |
| ព្រះតេជះព្រះគុណ KHUN BUNSON | ៥០ដុ |
| AMY CHEA | ៥០ដុ |
| លោក ទ្រី-គិមម៉េង អ្នកស្រី សៀក-អ៊ាមគុយ | ៥០ដុ |
| ឧបាសិកា ទូច-ឈុន ឧបាសក ឡាច | ៤៥ដុ |
| ឧបាសិកា ឡូ-ប៊ុនហ៊ាង ឧបាសក អោ-ឈីន | ៤៥ដុ |
| អ្នកស្រី សុខ-មួយលាង | ៤៥ដុ |
| ភិក្ខុ បញ្ញាទីបោ ភួង-ប៊ុនហ៊ីម | ៤៥ដុ |
| ឧបាសិកា គិម-ចេងស្រ៊ុន | ៤៥ដុ |
| ឧបាសក ហួន-ជូលាង | ៤៥ដុ |
| ឧបាសិកា ស៊ីវ-យក់លុយ | ៤៥ដុ |
| ណាតាលី និង ឌីណា | ៤៥ដុ |
| ឧបាសិកា រឿម | ៤៥ដុ |
| លោក ណិប-វង វង្សជ័យវិរៈ អ្នកស្រី ហុក-ច័ន្ទដាលីស | ៤៥ដុ |
| អ្នកស្រី ទិត្យ-សារិន គ្រួសារ និង បុត្រ | ៤៥ដុ |
| ឧបាសិកា នុប-រស់ | ៤៥ដុ |
| ឧបាសិកា ម៉ម-អុន | ៤៥ដុ |
| ឧបាសិកា ទេស-ស៊ីថា | ៤៥ដុ |
| ឧបាសក ជា-ហេង ឧបាសិកា អែម-មុំ | ៤៥ដុ |
| ឧបាសិកា ឈុន-គីមស្រ៊ី និង បុត្រធីតា | ៤៥ដុ |
| ឧបាសិកា ជា-លាងហ៊ី និង បុត្រធីតា | ៤៥ដុ |
| អ្នកស្រី ថាច, លោកមុត-ឆុត ភរិយា និង បុត្រធីតា | ៤៥ដុ |
| ធម្មាចារ្យ ថាច់-សៅ អាចារ្យវិបស្សនា | ៤៥ដុ |
| ឧបាសិកា យឹម-សារ៉ន | ៤៥ដុ |
| អ៊ឹង-លាងគង់, ទាឡាង មួយ | ៤៥ដុ |



| | |
|---|---|
| ជា-វួចលាង | ៤៥ដុ |
| មហាឧបាសិកា កែវ-ពេជ្រ ច័ន្ទ-ស៊ីថុល | ៤៤ដុ |
| ឧបាសក លាក់-ផន ឧបាសិកា ចុន-អេត | ៤៤ដុ |
| ឧបាសក គ្រូ តោ-ស្វាង | ៤៤ដុ |
| ឧបាសិកា ឈួន-ង៉ន | ៤៤ដុ |
| អ្នកស្រីសេក-ណារី សេក-មាធិន សេក-មុនីរតនា គីម-បុប្ផជនណា | ៤៤ដុ |
| លោក អាំង-ស្ងវ៉ាន់ និង ហែម-ច័ន្ទសុផល | ៤២ដុ |
| អ្នកស្រី វាំង-សុហ្វីនី, អ្នកស្រី វាំង-សុណន្ដា | ៤២ដុ |
| លោក សុនន-សុខ និហ ហែម-ចន្ធី | ៤២ដុ |
| ទ្រី-គីងឡេង ម៉ៅ-អៃអ៊ីវ ទ្រី-សុគា | ៤១ដុ |
| ឧបាសិកា លឿម-ឡម | ៤០ដុ |
| ឧបាសិកា តាំង-ក្លួយ | ៤០ដុ |
| លោក ឆាយ-ទ្រី និង អ្នកស្រី លី-អៀវឆេង | ៤០ដុ |
| ឧបាសិកា ឃុត-សុត, អ្នកស្រីវាំង-ផុន, | |
| ទុំ-ណារិទ្ធ សេង-ដានេត្រ និង បុត្រធីត | ៤០ដុ |
| ឧបាសិកា ឈូ-ច្រែង | ៤០ដុ |
| ភិក្ខុ ទឹម-ញ៉ុល | ៤០ដុ |
| លោក FRANK LY | ៤០ដុ |
| អោម-ដឿន | ៤០ដុ |
| ឧបាសិកា ផេង-នាង | ៤០ដុ |
| ឧបាសិកា ឡេង-ញ៉ូ | ៤០ដុ |
| ឧបាសក ផេង-ហ៊ីម ឧបាសិកា ស្រ៊ាង-អ៊ា និង កូនចៅ | ៤០ដុ |
| ឧបាសកថេត-រិន,ឧបាសិកាម៉ៅ-ខាត់, ថេត-កូ, អ៊ឹម-កឿត, | |
| រិន-កុសល, រិន-ចំរើន, ស៊ីវ-វិរៈ, ឫទ្ធិ-រតនៈ | ៤០ដុ |
| ឧបាសិកា ចាន់-ញឹម | ៤០ដុ |
| រឿន | ៤០ដុ |
| ឧបាសិកា កែវ-ប៊ូ | ៤០ដុ |
| លោក គាត-ជ្រឹម ហៅសារី អ្នកស្រី លឹម-យ៉ុម កូនចៅ | ៤០ដុ |
| អ្នកស្រី SU MARIE | ៤០ដុ |
| លោក អៀម-សៀកគិម អ្នកស្រីអៀម-គិមហ៊ន | ៤០ដុ |
| ឧបាសិកា ង៉ូម-យ៉ម | ៤០ដុ |
| យុវជន លី-សុរិចិត្រ (បូរ៉ា) | ៤០ដុ |
| ពុត-សុគន្ធវារី | ៤០ដុ |
| អ្នកមីង សន-ឡេន | ៤០ដុ |

| | |
|---|---|
| **NARY** | ៨០ដុ |
| អកស្រី ឱី-វណ្ណៈ និង គ្រួសារ | ៨០ដុ |
| ឧបាសិកា ជុំ-ឃន ឧបាសក ព្រុំ-រិត និង បុត្រ | ៨០ដុ |
| អ្នកស្រី វណ្ណារី និង គ្រួសារ | ៨០ដុ |
| គ្រួសារ សេង-គីម និង ភរិយា | ៨០ដុ |
| **MARY DY** | ៨០ដុ |
| ប៉ាន់-សុខហេង ភរិយា ប៉ាន់-សុខុន | ៨០ដុ |
| ឧបាសកគួយ-ធុន ឧបាសិកា ធូរ-មុំ | ៨០ដុ |
| អ្នកស្រី តូច-សារី | ៨០ដុ |
| ភិក្ខុ ចាប-ញ៉ែម | ៨០ដុ |
| **DIANE TAN & SOKLY TAN BRIAN** | ៨០ដុ |
| ឧបាសិកា នួន-ផន | ៨០ដុ |
| អ្នកស្រី សឹម-គិមឃុន ព្រមទាំងបុត្រ | ៨០ដុ |
| លោក ធម្មណាត ជនប្រសិទ្ធី | ៨០ដុ |
| ឧបាសិកា ញ៉ុក-ហួ | ៨០ដុ |
| នាង ញ៉ | ៨០ដុ |
| ឧបាសិកា ប្រី-យ៉ុម | ៨០ដុ |
| ឧបាសិកា ស្តើង-មុយ | ៨០ដុ |
| ឧបាសិកា មុី-រ៉ាវី | ៨០ដុ |
| ឧបាសិកា ម៉ូរ៉ា | ៨០ដុ |
| បណ្ឌិត ទួន-សុភ័ក្ត្រ | ៨០ដុ |
| តាំង-ង៉ុយឡាង | ៨០ដុ |
| អ្នកស្រី សឹម-ឡេន | ៨០ដុ |
| ឧបាសិកា ងី-ឆេ | ៨០ដុ |
| ឧបាសិកា ចាន់ថា ឡុន | ៨០ដុ |
| លោកអាចារ្យ គង់-យុត | ៨០ដុ |
| អៀវ-ថាញ់ និង កូនចៅ | ៣៥ដុ |
| យ៉ង់-មាលី | ៣៥ដុ |
| ទាន់-សាយ ទីវ-រ៉េម និង កូនចៅ | ៣៥ដុ |
| ត្រាំង-ដែន និង កូនចៅ | ៣៥ដុ |
| យូ-គុណវុត ភរិយា និង កញ្ញា យូ-មុនីរ័ត្ន | ៣៥ដុ |
| យក់-ព្រីដា កញ្ចនា និង កូន | ៣៥ដុ |
| លឹម-ប៊ុនធឿន មិន-សាវ៉ាន់ និង កុន | ៣៥ដុ |
| លោក ពៅ-កុច អ្នកស្រី ទេស-ហ៊ាន | ៣៥ដុ |



| | |
|---|---|
| ឧបាសិកា ថៃ-តាំង | ៣៥ដុ |
| លោក ព្រុំ-ឡាយ និង ភរិយា | ៣៥ដុ |
| លោក ជីន-សុគន្ធ អ្នកស្រី ហេង-ស៊ីហ៊ាង | ៣៥ដុ |
| ឧបាសិកា ហ៊ុន-ពត ព្រមទាំងបុត្រធីតា | ៣៥ដុ |
| ឧបាសិកា អ៊ិត-ឡុម | ៣៥ដុ |
| ឧបាសិកា កាន់-ឆន | ៣៥ដុ |
| ភិក្ខុ ពេជ្រ-សុធីរ | ៣៥ដុ |
| ភិក្ខុ សឹម-ឃីម | ៣៥ដុ |
| លោក រូឡង់-ឌី ពែក-សុផាន | ៣៥ដុ |
| លោក រូ-សាមលី ព្រមទាំងបុត្រ | ៣៥ដុ |
| លោក ញឹម-ពែក មុំ-សារឿន | ៣៥ដុ |
| លោក គួយ-សុថុន អ្នកស្រី លន់-ស៊ីនួន | ៣៥ដុ |
| លោក គួយ-សុវណ្ណារិទ្ធិ អ្នកស្រី ប៊ុត-រ័ត្ន | ៣៥ដុ |
| ឧបាសក យ៉ម-ដែង ឧ:សិកា ហេង-វ៉ាន់ឌី | ៣៥ដុ |
| កញ្ញា យ៉ម-ចិន្តា, កញ្ញា យ៉ម-ផលា, កញ្ញា យ៉ម-ច័ន្ទរ៉ុង | ៣៥ដុ |
| លោកស្រី ស៊ុយ-ផល្លី កុមារា អាឡិចសិនដា កុមារី អញ្ជលី | ៣៥ដុ |
| លោក យ៉ម-គីរីវ៉ាន់ អ្នកស្រី គឹម-សុភាព | |
| កុមារា យ៉ម-រ៉េនឌី កុមារី យ៉ម-ឃាលី ឧបាសិកា ចេង-ស្រ៊ុន | ៣៥ដុ |
| ឧបាសក ម៉ុ-សារ៉ន ឧបាសិកា ឡាំង-ជាង | ៣៥ដុ |
| ឧបាសិកា ហៀន-សូឯម | ៣៥ដុ |
| អ្នកស្រី ថង-ចួប | ៣៥ដុ |
| លោក អ៊ួង-គាងហេង អ្នកស្រី ហៅ-ម៉េង និង បុត្រធីតា | ៣៥ដុ |
| ឧបាសក ឌួង-ឆែម ឧបាសិកា អ៊ុយ-អ៊ាត | ៣៥ដុ |
| លោក បេង-ជុត អ្នកស្រី ស៊ីវ-ហេង និង បុត្រធីតា | ៣៥ដុ |
| ឧបាសិកា រឿន-រាជ ឧបាសក ឆ-ភោគ និង បុត្រធីតា | ៣៥ដុ |
| ឧបាសិកា អ៊ុន-ផូវ និង បុត្រធីតា | ៣៥ដុ |
| ឧបាសិកា ប៊ិល-សាគុណ និង បុត្រធីតា | ៣៥ដុ |
| អ្នកស្រី តាន់-ឆេងស៊ីម និង បុត្រធីតា | ៣៥ដុ |
| លោក ប៉ែន-សុខន អ្នកស្រី ឃិវ-សេដ្ឋា | ៣៥ដុ |
| លោក គូ-ប៊ុនកាន អ្នកស្រី សេង-ថង | ៣៥ដុ |
| លោក ផន-វី អ្នកស្រី លន-ឡេង | ៣៥ដុ |
| ឧបាសក អុន-លន ឧបាសិកា ហេង-លន់ | ៣៥ដុ |
| លោក អៀម-ឃុនណាវុធ អ្នកស្រី ណៃ-យុំ | ៣៥ដុ |
| លោក កាំង-ហេង អ្នកស្រីតាន់-អាយគួន | ៣៥ដុ |

| | |
|---|---|
| អ្នកស្រី ង៉ួន-គឹមសេង | ៣៥ដុ |
| គួ-ហ៊ីង និង កូនចៅ | ៣៥ដុ |
| គង់-សូ និង កូនចៅ | ៣៥ដុ |
| អែម-ដើង និង កូនចៅ | ៣៥ដុ |
| ឧបាសក សេង-សួត ឧបាសិកា សុន្ទរ៍-ធីង | ៣២ដុ |
| ឧបាសក ឆុង-ញិប ឧបាសិកា សរិត-សួម | ៣២ដុ |
| ថាន សូផុន និង ផឿនយ៉ាវ | ៣២ដុ |
| អ្នកស្រី មាស-ដម | ៣០ដុ |
| ជា-សាយ | ៣០ដុ |
| ឡាយ-មុំ | ៣០ដុ |
| ឧបាសិកា ប៊ុត-សាខន ព្រមទាំងគ្រួសារ | ៣០ដុ |
| ឧបាសិកា កែម-ថុល និង បុត្រ | ៣០ដុ |
| ឧបាសិកា អុន-ញ៉ៅ | ៣០ដុ |
| ឧបាសិកា រស់-សុផល | ៣០ដុ |
| ឧបាសក ជូ-មី គ្រួសារ | ៣០ដុ |
| លោក ស៊ីផាន បុប្ផា | ៣០ដុ |
| ឧបាសិកា អៀង-គីមហ៊ួយ | ៣០ដុ |
| ឧបាសិកា នឹម | ៣០ដុ |
| លោកអាចារ្យ ឱត្តប្បៈ អ្នកស្រី ស៊ុំ-ស៊ុក បុត្រធីតា | ៣០ដុ |
| អ្នកស្រី ក្រូច-អុល អ្នកស្រី សេង-បូ | ៣០ដុ |
| **SAREN TOUN** | ៣០ដុ |
| លោក ឱក-គិមអាន អ្នកស្រី ផល្លា | ៣០ដុ |
| ឧបាសិកា អ៊ី-ស្រ៊ុន | ៣០ដុ |
| អ្នកគ្រូ សេដា-លីថុន | ៣០ដុ |
| ពៅ-ណារីន | ៣០ដុ |
| ប៊ុនណារុំ-ជ័យ សុខា-សេង | ៣០ដុ |
| លោក **MAK NIMUL** | ៣០ដុ |
| គ្រី-សុផារី និង វណ្ណធី | ៣០ដុ |
| លោក ឈួម-ឈីត និង គ្រួសារ | ៣០ដុ |
| ឧបាសិកា ម៉ី-អ៊ួក | ៣០ដុ |
| ឧបាសិកា អ៊ុក-លឿប | ៣០ដុ |
| ឧបាសិកា សូ-សៀន ហៅ សូផន-សូ | ៣០ដុ |
| ក្រុមគ្រួសារ កូនចៅ ញោម អ៊ិន-សរ | ៣០ដុ |
| **YAN SIM** | ៣០ដុ |



| | |
|---|---|
| ឧបាសិកា អ៊ាត-អេង | ៣០ដុ |
| នាង ឆាត-ឆោម និង បុត្រធីតា | ៣០ដុ |
| ឧបាសិកា ប៊ិត-ថងខាំ | ៣០ដុ |
| លី-រ៉ានី វិត្ថារា-តាន់ | ៣០ដុ |
| ឧបាសិកា ប៉ោ-យេង និង បុត្រធីតា | ៣០ដុ |
| ឧបាសិកា ទន-យិន | ៣០ដុ |
| ឧបាសិកា ចាន់-គីមហ៊ួយ | ៣០ដុ |
| លោក ឌី-សូផល អ្នកស្រី ហួយ-សាត | ៣០ដុ |
| លោក គ្រី-ជិនលាង និង សុខា | ៣០ដុ |
| ឧបាសិកា សឿង-លឿង ឧបាសិកា យាន | ៣០ដុ |
| អ្នកស្រី ប៉ុក-សុគន្ធារុធ | ៣០ដុ |
| អ្នកស្រី ឡាយ-គុយអេង ព្រមទាំងបុត្រ | ៣០ដុ |
| លោក សំបូ-ចាន់ អ្នកស្រី អ៊ីន-ញ៉ី | ៣០ដុ |
| ឧបាសិកា មុំ-គីមឆេង | ៣០ដុ |
| ឧបាសក ជុំ-ហេង | ៣០ដុ |
| ឧបាសិកា គឹម-ហូ | ៣០ដុ |
| **LIHOUR PROM** | ៣០ដុ |
| អ្នកស្រី រស់-សៅរ៉ាន | ៣០ដុ |
| លោក មាស-គង់ អ្នកស្រី មាស-ទូច | ៣០ដុ |
| ឧបាសក ព្រម-ផន ឧបាសិកា ពោធិ-ពាជ | ៣០ដុ |
| ឧបាសិកា មួង-ច័ន្ទ និង បុត្រធីតា | ៣០ដុ |
| ឧបាសិកា អ៊ូ-យុត្តានី ឡេង ចាន់ រស្មី | ៣០ដុ |
| ឧបាសិកា **SENG SEANG LIM** | ៣០ដុ |
| ឧបាសិកា ខែត-ឃី | ៣០ដុ |
| ឧបាសិកា អ៊ឹម-សាវ | ៣០ដុ |
| ឧបាសកសៀក-ស្រ៊ុន ឧបាសិកា គិត-ស្រ៊ុន | ៣០ដុ |
| លោក ឃួន ណុន និង សក់ ស៊ីនួន | ៣០ដុ |
| លោក ចាន់-សាម៉ន់ អ្នកស្រី ផល្លី | ៣០ដុ |
| លោក ហឿត-មឿន អ្នកស្រី ជីវ៉ា | ៣០ដុ |
| ឧបាសក គាត-ជ្រឹម ហៅ សារី | ៣០ដុ |
| នាង ផាន់-ណា | ៣០ដុ |
| លោកអាចារ្យ ប៉ុក-ផឿន ឧបាសិកា ញាណ-ឈឿម | ៣០ដុ |
| ឧបាសិកា លឹម-ឈួន | ៣០ដុ |
| លោក គឹម-កន អ្នកស្រី គឹម-ណារិន និង បុត្រ | ៣០ដុ |

| | |
|---|---|
| ឧបាសិកា ប្រាក់-ហាន | ៣០ដុ |
| ឧបាសក កែម-សាន | ៣០ដុ |
| ឧបាសិកា សេង-គីមហ៊ន | ៣០ដុ |
| ឧបាសិកា អ៊ាក-គីម | ៣០ដុ |
| ឧបាសិកា ប៊ិត-ផងខាំ | ៣០ដុ |
| លោកអាចារ្យ នេត្រ-គឿន | ៣០ដុ |
| ឧបាសក សួគ៌-ស្រ៊ុន | ៣០ដុ |
| អ្នកស្រី សុផន-ខេន | ៣០ដុ |
| ឧបាសិកា ជិន-ស៊ីវអេង | ៣០ដុ |
| ឧបាសិកា អ៊ុន-យុន | ៣០ដុ |
| ភិក្ខុ សន្តិបាលត្ថេរ ឈន-អូន | ៣០ដុ |
| ភិក្ខុ ធម្មវិនយោ ទូច-ផន | ៣០ដុ |
| ភិក្ខុ យឹម-វិចិត្រ | ៣០ដុ |
| ភិក្ខុ ខេមិយោ អឿន-ហ៊ាង | ៣០ដុ |
| ភិក្ខុ ស៊ិមហក-ហេង | ៣០ដុ |
| ឧបាសិកា សរ-យុត | ៣០ដុ |
| លោក ភោ-សុផាត អ្នកស្រីសុខ-យី | ៣០ដុ |
| TOUCH & SIMONE | ៣០ដុ |
| ឧបាសិកា វ៉ាន់-ដា | ៣០ដុ |
| លោក ងិក-លី លក្ខិណា-លី និង ក្រុមគ្រួសារ | ៣០ដុ |
| លី-មឿន | ៣០ដុ |
| ឧបាសក ប្រាក់-ភាច ឧបាសិកា សុខ-ភឿន | ៣០ដុ |
| ម៉ាន-ចយ ផុន-អេង | ៣០ដុ |
| ឧបាសិកា រ័ត្ន-ស៊ុំ | ៣០ដុ |
| ជន-វណ្ណី ស្វាយអាត | ៣០ដុ |
| សៅ-ប៊ីលី កែវ-ម៉ាលី | ៣០ដុ |
| ឧបាសិកា ប៉ោ-យ៉េង | ៣០ដុ |
| រី-ដ៉េត តូវ-គេច លន | ៣០ដុ |
| លោកប្រាក់-ពុទ្ធី អ្នកស្រី នុប-សុភា | ៣០ដុ |
| ឧបាសិកា ខាត់ ឧបាសិកា នឿយ-ខឿម | ៣០ដុ |
| លោក ពេជ្រ-ឈីង និង គ្រួសារ | ៣០ដុ |
| ឧបាសិកា គីម-អ៊ិន | ៣០ដុ |
| លោក គិន-ប៊ុនវ៉ាណា អ្នកស្រី ប៊ុន-ណារី-ជ័យ | ៣០ដុ |
| ឧបាសិកា ប៊ុនណា-មឿន | ៣០ដុ |



| | |
|---|---|
| ឧបាសិកា មួង-សារុម និង បុត្រ | ៣០ដុ |
| ញោមស្រី ម៉ី-ផូ | ៣០ដុ |
| ឧបាសិកា ទូច-យ៉ូន | ៣០ដុ |
| អ្នកស្រី អ៊ំ-សុខឃឿន លោកកែ-ភារុណ និង បុត្រ | ៣០ដុ |
| អ្នកស្រី យុនធី-អ៊ីង និង កូនចៅ | ៣០ដុ |
| ឧបាសក ម៉ម-លាង ឧបាសិកា រស់-ហ៊ុត | ៣០ដុ |
| ឧបាសក ហ៊ុល-សារុំ ឧបាសិកា ហ៊ុល-តន | ៣០ដុ |
| ឧបាសិកា ដី ឧបាសក ប៉ូន | ៣០ដុ |
| ភិក្ខុ ពិសិដ្ឋ-កំសាន្ត | ៣០ដុ |
| ភិក្ខុ គល-ស៊ីនួន | ៣០ដុ |
| ឧបាសិកា មឿង-យាន | ៣០ដុ |
| លី-ពន្លក ហ៊ួ-ប៉ូលីណោ លី-ធីមថី | ៣០ដុ |
| ឌី-សៀង ប៉ូលី-ណែត-ហ៊ួ JONATHAN JULIE | ៣០ដុ |
| ឧបាសក ប្រាក់-វិឆ័យ ឧបាសិកា ដែង-ផុនចំរើន | ៣០ដុ |
| ឧបាសិកា ថោង-សុធី ស្វាមី និង បុត្រ | ៣០ដុ |
| អ្នកស្រី ផេង-គីមញ៉ោន | ៣០ដុ |
| កញ្ញា ផេង-ចិន្តា | ៣០ដុ |
| ឧបាសិកា រុន-ចរណៃ | ៣០ដុ |
| ឧបាសិកា ឌុច-សាខន និង បុត្រធីតា | ៣០ដុ |
| ឧបាសិកា អ៊ុំ-មន់ | ៣០ដុ |
| ឧបាសិកា យ៉ុន□ និង កូនចៅ | ៣០ដុ |
| CHAND YOUST & VI B. NGUYEN | ៣០ដុ |
| ឧបាសិកា វ៉ាយ-រុន | ២៧ដុ |
| លោកអាចារ្យ ធូរ-ម៉ៅ ឧបាសិកា យ៉ឹយ-យ៉ាង | ២៧ដុ |
| ឧបាសក យិម-ហ៊ីរិ និង ភរិយា ស៊ុម-ពេត | ២៧ដុ |
| ឧបាសិកា ចេង-លឹម | ២៥ដុ |
| លោក តេង-ភេ និង គ្រួសារ | ២៥ដុ |
| លោកអាចារ្យ ហ៊ីរិ អ្នកស្រី ស៊ុំ-ទេព និង បុត្រធីតា | ២៥ដុ |
| ឧបាសក សេ ឧបាសិកា សុង | ២៥ដុ |
| NCHIN & CHAI EATON | ២៥ដុ |
| ឧបាសិកា ទួន-មុំ | ២៥ដុ |
| ឧបាសិកា គិម-កន | ២៥ដុ |
| លោក ទីត-សាត | ២៥ដុ |
| ឧបាសិកា សាវ៉ាយ-ប្រាក់ | ២៥ដុ |

| | |
|---|---|
| លូត-ឈឿន | ២៥ដុ |
| អ្នកស្រី ឯម-ពៅ | ២៥ដុ |
| អ្នកស្រី និន-ឌិន | ២៥ដុ |
| អ៊ឹម-ចាន់ | ២៥ដុ |
| ប្រាក់-អាត់ | ២៥ដុ |
| អ្នកស្រី ស៊ុំ-សាគន់ និង គ្រួសារ | ២៥ដុ |
| **IM KIMCHHORN** | ២៥ដុ |
| ឧបាសិកា តាត-មុនី | ២៥ដុ |
| លោក បិន-កាន់ អ្នកស្រី រ័ត្ន-ថន កាន់-ធឿន កាន់-សុខា | |
| គាន់-ដា កាន់-សុធា | ២៤ដុ |
| អ្នកស្រី **TONG TIBET** | ២៤ដុ |
| ឧបាសិកា សរ-យុត និង បុត្រធីតា | ២២ដុ |
| បច្ច័យបំសុកូល នៅវត្តសាន់តាអាណា | ២២ដុ |
| អ្នកស្រី សារុំ និង កូនចៅ | ២២ដុ |
| ឧបាសិកា ខេម-ច្រែស | ២២ដុ |
| បងស្រី សារុម-ប៊ិច | ២២ដុ |
| លោក សាមួន-ប៉ុក | ២២ដុ |
| ឧបាសិកា បេស្កាលីន | ២១ដុ |
| អ្នកស្រី ប៊ិច | ២១ដុ |
| លោក សំរ៉ាន-វណ្ណដា អ្នកស្រី យិន-យ៉ាន កញ្ញា យិន-វន់ | ២១ដុ |
| ឧបាសក យ៉ាំង-ស៊ីង ឧបាសិកា ថង-ស៊យ | ២១ដុ |
| សេង-នី និង កូនចៅ | ២១ដុ |
| ប៉ុក-គួន និង កូនចៅ | ២១ដុ |
| លោក ហុង-ឯក អ្នកស្រី ផាត-ញ៉ិប | ២១ដុ |
| ឧបាសិកា សុខ-ហួង | ២១ដុ |
| លោក ថាច់-ប៊ុនធី អ្នកស្រី ឌឿង-សារ៉ាត | ២១ដុ |
| អ្នកស្រី កែវ-ច័ន្ទី និង បុត្រ | ២១ដុ |
| ឧបាសិកា ប៊ិច-សុខុម និង បុត្រ | ២១ដុ |
| លោក ឈិម-អឿង អ្នកស្រី ឈឹម-វណ្ណា | ២១ដុ |
| លោក ឈឹម-សាខន អ្នកស្រី ឡាច-សារឿន | ២១ដុ |
| លោក កៅ-ជិន អ្នកស្រី កែវ-លួន | ២១ដុ |
| អ្នកស្រី ម៉ុន-រ៉ាមី | ២១ដុ |
| អ្នកស្រី ម៉ុន-សូផន | ២១ដុ |



| | |
|---|---|
| ឧបាសិកា ហែម-សារី | ២០ដុ |
| ឧបាសិកា ស៊ុង-សឿម | ២០ដុ |
| ឧបាសិកា សុខុម-ស្រែ ឡេន-រឿង | ២០ដុ |
| ឧបាសិកា ហែម-យឹម | ២០ដុ |
| សាមណេរ ថែម-សារ៉ាត ឧបាសិកា ស៊ុម-ស៊ុក | ២០ដុ |
| យុវជន ថាច់-ចននី | ២០ដុ |
| អ្នកស្រី សុភក្រ្ត-ឌឿង | ២០ដុ |
| អ៊ឹម-សាលី | ២០ដុ |
| លោក ថាំង-ចេវ ព្រមទាំងគ្រួសារ | ២០ដុ |
| ឧបាសិកា មិល-ម៉ាលី | ២០ដុ |
| លោក ថាច់-ថេង អ្នកស្រី ប្រាក់-សាម | ២០ដុ |
| កញ្ញា លី-ថុងសូលីដា | ២០ដុ |
| កញ្ញា លី-សូលីណា | ២០ដុ |
| ឧបាសក លី-ថុង ឧបាសិកា មាឃ-គឹមសាន | ២០ដុ |
| **YONG SITHON** | ២០ដុ |
| ឧបាសិកា អ៊ូ-ឆេង និង កូនស្រី លីដា | ២០ដុ |
| លោក សារឿត-រិត និង គ្រួសារ | ២០ដុ |
| ឧបាសក សួន-សារិ ឧបាសិកា ទឹម-ញ៉ៀ | ២០ដុ |
| ឧបាសិកា ញាណ-សុំ | ២០ដុ |
| ឧបាសិកា ណាយ-ប៊ុនម៉ា | ២០ដុ |
| លោក ហួយ-យ៉ុង អ្នកស្រី ហ៊ុន-សារ៉ុម និង បុត្រ | ២០ដុ |
| ភិក្ខុ សុធម្មប្បញ្ញោ ចន្ទ-ស៊ី, ឧបាសិកា ស៊ុយ-សាង | ២០ដុ |
| លោកគ្រូសូត្រ ផល | ២០ដុ |
| លឹម-ញ៉ៀល ពិន-អ៊ិត និង កូនចៅ | ២០ដុ |
| ស៊ូ-ឡុង ណៃ-យឹម | ២០ដុ |
| ឧបាសិកា គង់-សុគន្ធា និង បុត្រធីតា | ២០ដុ |
| ឧបាសិកា ឡុង-ស៊ីនួន | ២០ដុ |
| លោក សន-ណាត និង គ្រួសារ | ២០ដុ |
| លោក ខៀវ-ដារារ័ត្ន អ្នកស្រី ងួន-ច័ន្ទថា | ២០ដុ |
| លោក សំ-សារឿន អ្នកស្រី មឿន-យ៉ឹង | ២០ដុ |
| **Mr. CHM KHOUN** | ២០ដុ |
| លឹម-ស៊ីវបី និង បុត្រក្មួយ អ៊ឹង-ប៊ុន-ម៉ៅ ពិសី-ជៀវ បុត្រធីតា | ២០ដុ |
| **PHATH RTH** | ២០ដុ |
| ឈិត-ដាវ សុជាតា លោក លី-សុខឌែន ឆី-ម៉ាលីណា | ២០ដុ |

| | |
|---|---|
| អ្នកនាង DIANNA KAO និង បុត្រ | ២០ដុ |
| RAKSMEY MEAS & MOEUN YIM | ២០ដុ |
| កុមារា DAVIS BOURAMAI CHHLAT | ២០ដុ |
| អ្នកស្រី SOPHY LONG | ២០ដុ |
| វឌ្ឍានី | ២០ដុ |
| ឧបាសក ផាត-សាវឿយ | ២០ដុ |
| NICOLE HOUR | ២០ដុ |
| ឧបាសិកា គង-សុគន្ធា | ២០ដុ |
| ឧបាសិកា ថុល | ២០ដុ |
| យាយ សឿម | ២០ដុ |
| សុភា-ថាវ | ២០ដុ |
| លាភ និង កូនចៅ | ២០ដុ |
| លោក ប៉ាន-រ៉ប អ្នកស្រី ណារី | ២០ដុ |
| លោក នូ-សំបាន និង គ្រួសារ | ២០ដុ |
| អ៊ុំ-ថុង | ២០ដុ |
| ប៉ក-ផុន | ២០ដុ |
| គង-អ៊ិន និង គ្រួសារ | ២០ដុ |
| ឧបាសិកា គីម-កន | ២០ដុ |
| ឧបាសិកា យ៉ែម-ទុម ឧបាសិកា យ៉ែម-តង | ២០ដុ |
| ឧបាសិកា មាស-ផា | ២០ដុ |
| ចំរើន និង ភរិយា | ២០ដុ |
| ឧបាសក ប៉ែន-ប៉ន | ២០ដុ |
| លោកឈាន-លីមហ៊ាង អ្នកស្រី តាំង-គីមឡេង | ២០ដុ |
| លោក ហុក-សុមនបុត្រ អ្នកស្រី ហុក-និមល | ២០ដុ |
| លោក រតនា | ២០ដុ |
| ឧបាសក ថេត-រិន ឧបាសិកា ម៉ៅ-ខាត់ កូនចៅ | ២០ដុ |
| អ្នកស្រី សិ-ចន | ២០ដុ |
| ឧបាសក ឡុង-រឿន | ២០ដុ |
| ព្រុំ-សឿម | ២០ដុ |
| គីម-ពន | ២០ដុ |
| ផារ៉ា | ២០ដុ |
| ថង-សៃ-គុំ ព្រមទាំងបុត្រ | ២០ដុ |
| លោក វុឌ្ឍី អ្នកស្រី ម៉ៅ | ២០ដុ |
| ឧបាសក ថាញ់-ផេង | ២០ដុ |



| | |
|---|---|
| ឧបាសិកា យុន-គៀន | ២០ដុ |
| កែ-ធី និង ឡេង-សុនី | ២០ដុ |
| LANG HIELL | ២០ដុ |
| SAM-YORK | ២០ដុ |
| លីម-ជូ | ២០ដុ |
| លោកចៅ-ង៉ោ អ្នកស្រីឡេា-នាង | ២០ដុ |
| អៀង-សុខ និង កូនចៅ | ២០ដុ |
| នាង-ហ៊ុន និង កូនចៅ | ២០ដុ |
| ឧបាសក លី-សន ឧបាសិកា សើន-ទ្រី | ២០ដុ |
| TAING MUY LANG | ២០ដុ |
| ឧបាសិកា កែវ-ពេជ្រចាំ ស៊ី-ថុល | ២០ដុ |
| យុវជន សោម-សុភក្តី | ២០ដុ |
| កញ្ញា សោម-សុជា | ២០ដុ |
| ឧបាសក ថាច់-សូផាត ឧបាសិកា យ៉ង-វន្នី | ២០ដុ |
| ភិក្ខុ រស់-យ៉ាន | ២០ដុ |
| ឧបាសិកា ថង-ខាំ | ២០ដុ |
| ឧបាសក ស៊ិន-មេន ឧបាសិកា ប៊ុន-រិ | ២០ដុ |
| កញ្ញា សោម-ច័ន្ទ សុពីន | ២០ដុ |
| ឧបាសិកា យ៉ាន-រុន | ២០ដុ |
| ឧបាសិកា ឃឿម និង គ្រួសារ | ២០ដុ |
| ភិក្ខុ យឹម-វិចិត្រ | ២០ដុ |
| អ្នកស្រី សុភោគ-គន្ធា | ២០ដុ |
| ឧបាសិកា ហ៊្វយ-គីមឡេង និង កូនចៅ | ២០ដុ |
| យុវជន សោម-សុភ័ណ | ២០ដុ |
| ម៉ែន-សុឃឿន | ២០ដុ |
| អ្នកស្រី អ៊ុង-សីផាន់ណា | ២០ដុ |
| KEN SOPHON | ២០ដុ |
| អាចារ្យ កាំង-ហេង និង គ្រួសារ | ២០ដុ |
| អ៊ីន-តង់ | ២០ដុ |
| លោក រឿន | ២០ដុ |
| លោក វៃ-មែម អ្នកស្រី ម៉ៅ-ស៊ីណាង | ២០ដុ |
| លោក ហា-ញ៉ូត ថន-ឌី | ២០ដុ |
| មីង-ឡឹង | ២០ដុ |
| អ្នកនាង DIEM KAO និង បុត្រ | ២០ដុ |

| | |
|---|---|
| ហាំ-ទី | ២០ដុ |
| យឹម-ផល្លា ព្រមទាំងគ្រួសារ | ២០ដុ |
| ឧបាសិកា ផា-អើន | ២០ដុ |
| ប៉ាន-ហួរ | ២០ដុ |
| ឧបាសិកា ណាំ-ស៊ី | ២០ដុ |
| ឧបាសិកា គីម-សៀន | ២០ដុ |
| លិម-ជូ | ២០ដុ |
| សេន-យ៉ាត | ២០ដុ |
| ឧបាសក សម្បត្តិ-ហ៊្វត ឧបាសិកា សម្បូរ-បាន | ២០ដុ |
| ឧបាសិកា អ៊ុក-ផៃ ឧបាសក ឈុន-អ៊ី | ២០ដុ |
| ឧបាសិកា សាន់-សុផាត | ២០ដុ |
| អ្នកស្រី ធិន-ណារិន្ទ និង បុត្រ | ២០ដុ |
| ឧបាសិកា កែ-យឿន | ២០ដុ |
| ញោម ហ៊ិន-ផាន | ២០ដុ |
| ឧបាសិកា ថោង-ឃាន | ២០ដុ |
| ឧបាសក ប៉ែន-ញ៉ឹម ឧបាសិកា តូ-សារី | ២០ដុ |
| ឧបាសិកា ម៉ឹង-លន់ | ២០ដុ |
| ឧបាសិកា លេង-អឿង | ២០ដុ |
| ឧបាសក តុល-ឃៀ | ២០ដុ |
| ឧបាសិកា ងីន-សាត | ២០ដុ |
| លោក តាន់-ស្រុន និង គ្រួសារ | ២០ដុ |
| តាំង-រី និង **SAMPHEARY** | ២០ដុ |
| លោកស្រី ផា-វណ្ណារី | ២០ដុ |
| លោក ប៉ែន-សុខ និង គ្រួសារ | ២០ដុ |
| លោក ទិត្យ-ណូរ៉ា | ២០ដុ |
| លោកប្រុស **HAM SOEUNG** | ២០ដុ |
| ចន្ទូ | ២០ដុ |
| ភិក្ខុ **KEM SOPHORN** | ២០ដុ |
| អ្នកស្រី សុផល-មុំ | ២០ដុ |
| ឧបាសក ឈុន-ប៊ុនទី | ២០ដុ |
| ឧបាសក យិន-គុណា | ២០ដុ |
| ភិក្ខុ សោម-វន្ថា វត្តអ៊ុកឡែន | ២០ដុ |
| គា-ឆេង លី-ភួង ស៊ីវ-អេង គីម-យិន | ២០ដុ |
| អ្នកស្រី ជុំ-សុជាត | ២០ដុ |



| | |
|---|---|
| លោកអាចារ្យ ថាច់-ង៉ុក ជា-គិមតាក | ២០ដុ |
| ឧបាសិកា ហង្ស-សំអុល | ២០ដុ |
| លោក សុយុទ្ធ-ចេឡា អ្នកស្រី ជ្រួក-បាច | ២០ដុ |
| អាចារ្យនាង-ណាត | ២០ដុ |
| សូម-វុទ្ធី វន្នី | ២០ដុ |
| រ៉ានី និង គ្រួសារ | ២០ដុ |
| អ្នកមីង ម៉ៅ-សារុន | ២០ដុ |
| អ្នកស្រី ឆុន-រិត និង គ្រួសារ | ២០ដុ |
| លោក ប្រាក់-ភន អ្នកស្រី ភិន-វ៉ាន់ណាន | ២០ដុ |
| លោក ប៉ុក-សុគន្ធាណា | ២០ដុ |
| អ្នកស្រី ស៊ីម-សាវ៉ែន លោក ផេង-ហួត និង បុត្រ | ២០ដុ |
| ឧបាសិកា ឈឺ-ស៊ីវហ៊ាង | ២០ដុ |
| ទូច-លីមសេង មែន-សុខឿន | ២០ដុ |
| ឧបាសិកា មាស-ដា | ២០ដុ |
| ឧបាសិកា ចាន់-សូផាត | ២០ដុ |
| ទាយិកា ពិសី | ២០ដុ |
| ឧបាសិកា ខាន់-ហួយ | ២០ដុ |
| ឈិត-ដាវ ច័ន្ទសិតា កែវ-សុវណ្ណា | ២០ដុ |
| ឧបាសក ឃុន-ម៉េហាវ ឧបាសិកា សៀវ-ឆេង | ២០ដុ |
| ឧបាសិកា គង់-យ៉េន | ២០ដុ |
| **SOPHAN TAN** | ២០ដុ |
| លោក សុខ-មឿត អ្នកស្រី ហេង-វ៉ាន់ | ២០ដុ |
| លោក ស៊ូ-ស៊ឹម អ្នកស្រី គិន-សំបូរ | ២០ដុ |
| ព្រហ្ម-មាស សុវណ្ណា | ២០ដុ |
| ឧបាសិកា យស-ម៉ន | ២០ដុ |
| លោក ឡាំង-គិមឆេង | ២០ដុ |
| ទាយក សុផល | ២០ដុ |
| អ្នកស្រីសក់-សំនៀង និង គ្រួសារ | ២០ដុ |
| អ្នកស្រី ហ៊ីម-ឡុង | ២០ដុ |
| អ្នកស្រី នី-ផា និង ភ្វាមី | ២០ដុ |
| អ្នកស្រី សួន-រី និង ស្វាមី | ២០ដុ |
| អ្នកស្រី វ៉ាន់-ភៀ | ២០ដុ |
| ឧបាសិកា ញ៉ក់-ហួ ព្រមទាំងបុត្រ | ២០ដុ |
| ឧបាសិកា ហា-ស៊ុន | ២០ដុ |

ឧបាសិកា សយ-ប៊ុន ២០ដុ
ឧបាសិកា សៀក-សៀន ២០ដុ
ឧបាសិកា លឹម-យ៉ុម ហៅ សាលី ២០ដុ
កញ្ញា យិន-ចាន់ណារា ២០ដុ
ឧបាសិកា ថាច់-រ៉េង ២០ដុ
លោក ខៀវ-សារឿន និង គ្រួសារ ២០ដុ
លោក ឌុក-ប៊ុនភិត និង ណាម-រិត ២០ដុ
សុខ-នីន នាង ជីម-កញ្ញា ២០ដុ
សុផាន់ណ្ណារី ADAM, CHRISTOPHER, SOUR
LENG KAO LEE ABEL ២០ដុ
SOPHEA KEN, MORN KEN, PHALLY SHMITH,
CHENDA KEN, GASSENDRA KEN, ALVIN KEN,
SOPHEAP SAMITH ២០ដុ
អ្នកស្រី ណុប-ណុំ ២០ដុ
ឧបាសិកា ជុក-សឿន ២០ដុ
អ្នកស្រី ប៉ូ-ណាន ២០ដុ
ឧបាសក ឈឹន-ប៊ុនលឹត និង ភរិយា ២០ដុ
ឧបាសិកា សយ-ប៊ុន ២០ដុ
ឧបាសិកា សៀក-សៀន ២០ដុ
ឧបាសិកា លឹម-យ៉ុម ហៅ សាលី ២០ដុ
កញ្ញា យិន-ចាន់ណារា ២០ដុ
ឧបាសិក ថាច់-រ៉េង ២០ដុ
ជា-កែវបូរុន សាន-សុខា ២០ដុ
លោក តូច-ឧប្បាលា (ឆឹត) ២០ដុ
SAORAN LATOUR ២០ដុ
BIN VETH ២០ដុ
BIN TOUCH ២០ដុ
BIN ARTH ២០ដុ
BIN RITH ២០ដុ
BIN BO ២០ដុ
អ្នកស្រី ស៊ីម-បុប្ផ និង បុត្រ ២០ដុ
អ្នកស្រី ហាំ-សំអាត និង បុត្រ ២០ដុ
មុត-សុផល ភោ-សូរឿន ២០ដុ



កម្លោះ ថេត-កូ និង ដារ: ២០ដុ
លោកតា រេត ២០ដុ
ឧបាសិកា កាន់-សារ៉ាន់ ២០ដុ
នាង បុប្ផ ២០ដុ
ខៀវ-ណាត ២០ដុ
ឧបាសិកា អោម-ចៀន ២០ដុ
អ្នកស្រី សំ-សាម៉ន ឧបាសក សេក-សឿន កូនចៅ ២០ដុ
ឧបាសិកា សេន-ជីម ២០ដុ
វ៉ាន-ចាន់ ២០ដុ
ឌី-ណែត គឿន ២០ដុ
ប៉ុន-ម៉ៅ ២០ដុ
សារ៉ាន ២០ដុ
សារ៉ាត ២០ដុ
ឧបាសិកា យិន-ឌីនុត ២០ដុ
អ្នកស្រី អ៊ុង-ធារី ២០ដុ
ពៅ-ទិត្យា ២០ដុ
សុជាត នាង ភឿង ២០ដុ
លោក មុនីសូតា-ទេព ២០ដុ
អ្នកស្រី សោភ័ណ ២០ដុ
ឧបាសិកា ឡុងប៉ែន ២០ដុ
អ្នកស្រី យី ២០ដុ
អ្នកស្រី យ៉ាន ២០ដុ
លោក លឹម-សៀង ២០ដុ
ឧបាសក ចេក-យាន ២០ដុ
ឧបាសិកា ប៉ែន-សួន ២០ដុ
ម៉ាក់-អ៊ុយ និង យឹម-ហ៊ុន ២០ដុ
រុន-ចណៃ ២០ដុ
អ្នកស្រី ណៃ លោកតា ភី ២០ដុ
ខ្លឹត និង គ្រួសារ ២០ដុ
លោក សារ៉ាត់ អ្នកស្រី អៀន ២០ដុ
ម៉ាច-ជន និង គ្រួសារ ២០ដុ
ប្រាក់-សម្បត្តិ ចាន់-ឡៃ និង គ្រួសារ ២០ដុ
លោក និង លោកស្រី ធាម-អុន ២០ដុ
SIA REN QA ២០ដុ

| | |
|---|---|
| អ្នកស្រី ម៉ៅ-ហៀង | ២០ដុ |
| លោក ផូ-ចយ អ្នកស្រី យី | ២០ដុ |
| ឧបាសិកា អ៊ុន-អ៊ន | ២០ដុ |
| លោក មេ-ប៉ុង | ២០ដុ |
| ហ៊ុន-គីមហេង | ២០ដុ |
| លោក ជា-ស៊ុវត្ថនា អ្នកស្រីឃុន-សូនីម៉ា និង បុត្រ | ២០ដុ |
| ហុង (HONG) | ២០ដុ |
| អ្នកស្រី លី-គីមស៊ី | ២០ដុ |
| វ៉ែន-សារឿន | ២០ដុ |
| ឧបាសក ចេក-ឃាន | ២០ដុ |
| ឧបាសក ឈុន-ម៉ៅ | ២០ដុ |
| លោក ជា-ហ៊្វាង អ្នកស្រី តូ-សុផាន់ណា | ២០ដុ |
| អ្នកស្រី ផា-ឆាយ៉ាស៊ី | ២០ដុ |
| អ្នកស្រី គីម-ហាន | ២០ដុ |
| អ្នកស្រី គីម-ហេង | ២០ដុ |
| អ្នកស្រី ម៉ី-សុធារ | ២០ដុ |
| SEAK CHEA | ២០ដុ |
| ឈិន-លី (CHIN LEE) | ២០ដុ |
| ឧបាសិកា តូច-ឃុនណាង | ២០ដុ |
| BOU SAMY | ២០ដុ |
| ឧបាសិកា ង៉ី-ឆេ | ២០ដុ |
| លោក ហ៊ិន-សុវណ្ណ នាង អ៊ឹង-មួយហ៊ាង | ២០ដុ |
| អ្នកស្រី លឹម-បុប្ផ | ២០ដុ |
| អ្នកស្រី លី-ង៉ែត លោកកូវ-គិហ្វលង់ | ២០ដុ |
| អ្នកស្រី ចាន់-លី | ២០ដុ |
| អ្នកស្រី ស៊ីម-សារ៉ន និងគ្រួសារ បុប្ផ-ស៊ីម | ២០ដុ |
| ឧបាសិកា ស៊ី-លេន | ២០ដុ |
| ជា-កែវបូរ៉ុន សាន-សុខា | ២០ដុ |
| តូច-ឧប្បាលា (ឆើត) | ២០ដុ |
| វ៉ាតធិរ: | ២០ដុ |
| ឧបាសិកា មួង-សឿន និង បុត្រ | ២០ដុ |
| សុខុម, លោករ័ត្ន-វ៉ុន, ឌី-យ៉ានី, រូសាលីន, រូសានីណារា | ២០ដុ |
| ឧបាសក គីម-សាំង ឧបាសិកា សួស | ២០ដុ |
| ឧបាសិកា លេង | ២០ដុ |



| | |
|---|---|
| លោក អ៊ាប-ហាំងឃុន អ្នកស្រី អ៊ឹង-លីគាង | ២០ដុ |
| ឧបាសិកា ស្តើង-មុយ | ២០ដុ |
| អ្នកស្រី ធឿន លោកម៉ៅ បុត្រធីតា | ២០ដុ |
| លោក ស៊ុម-វណ្ណៈ អ្នកស្រី វណ្ណី បុត្រធីតា | ២០ដុ |
| ឧបាសិកា ពេជ្រ-សួន | ២០ដុ |
| លោក កង-ជួន អ្នកស្រីទូច-រ៉េន | ២០ដុ |
| ឧបាសក ព្រុំ-យឿន | ១៩ដុ |
| ឧបាសក កែវ-ឆាត ឧបាសិកា នង-រុន | ១៨ដុ |
| ឧបាសក កៅ-លីសេង ឧបាសិកា ចាប់-ម៉ានី | ១៨ដុ |
| ស្រី-ហឿន និង កូន | ១៨ដុ |
| ស៊ីម-វេងគាវ និង កូន | ១៨ដុ |
| លោក ស៊ីម-សារិត អ្នកស្រី ហ៊ាយ-សែន និង បុត្រធីតា | ១៨ដុ |
| លោក សួត-តេង អ្នកស្រី ហ៊ាយ-សៀន និង បុត្រធីតា | ១៨ដុ |
| លោក លឹម-ទិត អ្នកស្រី សែម-សុខុន | ១៨ដុ |
| ឧបាសិកា អ៊ុន-ផៃ ហៅស៊ីថា | ១៨ដុ |
| លោក ហ៊ាយ-សុថាន អ្នកស្រី ស៊ុម-ម៉ាច និង បុត្រ | ១៨ដុ |
| អ្នកឥតមានឈ្មោះ | ១៧ដុ |
| ឧបាសិកា អ៊ាវ-ប៊ួយ និង បុត្រធីតា | ១៧ដុ |
| លោក សារួន និង គ្រួសារ | ១៥ដុ |
| អ្នកស្រី តាំង-ជាវណ្ណៈ | ១៥ដុ |
| អ៊ុង-សំខាន់ ជា-គុយហ៊ាង | ១៥ដុ |
| ឧបាសិកា ទ្បោ-សាម៉ុត | ១៥ដុ |
| ឧបាសិកា ឡុង-នាង | ១៥ដុ |
| លោក ចេង-គា អ្នកស្រី ឈឹម-ចន្ទី | ១៥ដុ |
| ប៉េ-សារ៉ង | ១៥ដុ |
| លោកប្រុស CHARO BAN | ១៥ដុ |
| មីន-សាង | ១៥ដុ |
| លោក ម៉ុក-គៀង និង គ្រួសារ | ១៥ដុ |
| លោក បួង-តាំង និង គ្រួសារ | ១៥ដុ |
| អាចារ្យ អ៊ុក-សែម ឧបាសិកា ហង់-ជីម | ១៥ដុ |
| ឧបាសិកា សាត់-ចាន់ | ១៥ដុ |
| លោក ប្រាក់-ផន អ្នកស្រី ភិន-បាណាន | ១៥ដុ |
| លោក គីម-សារុន អ្នកស្រី រូ-គីរី | ១៥ដុ |
| ឧបាសិកា ឆែម-ឡាប និង បុត្រធីតា | ១៥ដុ |

| | |
|---|---|
| **SOUPHAPHONE KEOVONGKOT** | ១៥ដុ |
| អ្នកស្រី វ៉ានី លោក ពុទ្ធជន និង បុត្រធីតា | ១៥ដុ |
| លោកសៀវ-គីមរួច និង ភរិយា | ១៥ដុ |
| លោក ទូច-ទិព អ្នកស្រី ខេម-ភាព | ១៥ដុ |
| លោក សៀន អ្នកស្រី ចរិយា | ១៥ដុ |
| លោក ពើង-យឿម | ១៥ដុ |
| អ្នកស្រី ពើង-សុខុម | ១៥ដុ |
| ពើង-ចិរតេជ | ១៥ដុ |
| ពើង-ចិរវណ្ណ | ១៥ដុ |
| យ៉ាំង-វិន្នា | ១៥ដុ |
| អុង-សំអាត និង គ្រួសារ | ១៥ដុ |
| ជឿ-ធី | ១៥ដុ |
| ជា-គឹមឡេង | ១៥ដុ |
| ញ៉ែម-ឡាង | ១៥ដុ |
| ឧបាសិកា ទួន-សារិន និង គ្រួសារ | ១៥ដុ |
| ឧបាសិកា ឡេា-ស៊ីរុន | ១៥ដុ |
| នាង លក្ខិណា | ១៨ដុ |
| លោក សូង-សុភាព អ្នកស្រី សូង-មាលី | ១៨ដុ |
| ឧបាសិកា ទេស-សុន និង កូនចៅ | ១៨ដុ |
| លោក សុខ-ហេង ឧបាសិកា សឿង-អេង | ១៨ដុ |
| លោក ថាច់-ឈួង អ្នកស្រី យ៉ែម-ចន្ថួ និង បុត្រធីតា | ១៨ដុ |
| អ្នកស្រី មឿន-រស្មី និង បុត្រធីតា | ១៣ដុ |
| យ៉ាំង-ដាំ | ១២ដុ |
| ឧបាសិកា ប្រាក់-ឃិន | ១២ដុ |
| លោក កែវ-កែន ពែក-សុភា | ១១ដុ |
| លោក ពែក-សំណាង ស្រី អែម | ១១ដុ |
| ភឹង-សារិត | ១២ដុ |
| ឧបាសិកា ចាប-ឃិន | ១១ដុ |
| ឧបាសិកា ម៉ៃ-សារ៉េត | ១១ដុ |
| ឧបាសិកា ផាន់-សួង | ១១ដុ |
| កញ្ញា ហុង-ភានី | ១១ដុ |
| លោក សេង-សុត អ្នកស្រី ហ៊យ-ពៅ | ១១ដុ |
| លោក សេង-ស៊ិន និង កូន សេង-សាលីណា | ១១ដុ |
| លោក សេង-ស៊ីម អ្នកស្រី ញ៉ែម-គឿន | ១១ដុ |



| | |
|---|---|
| កញ្ញា សេង-រតនា | ១១ដុ |
| អ្នកស្រី ឡាច-សុផល | ១១ដុ |
| ឧបាសិកា ង៉ែត-ហួយ | ១១ដុ |
| អ្នកស្រី ស៊ីសុវត្ថិ ច័ន្ទ វល្លក្ខិណា | ១១ដុ |
| លោក សេក-អាង | ១១ដុ |
| លោក ហ៊យ-សុខា អ្នកស្រី ចន្ធី និង បុត្រធីតា | ១១ដុ |
| នាង ឡាច-សុផាន | ១១ដុ |
| លោក ពែក-សម្ភស្ស | ១១ដុ |
| លោក ពែក-សំអៀត កុត-វ៉ៃ | ១១ដុ |
| ប៉េ-សារឿន | ១០ដុ |
| នាង បាឡៃ | ១០ដុ |
| នាង សុន្ទួន | ១០ដុ |
| អ្នកស្រី ញ៉ឹប | ១០ដុ |
| អ្នកស្រី យ៉ង់-ម៉ៅ | ១០ដុ |
| លោក ភូ-តេង អ្នកស្រី ធី | ១០ដុ |
| លោកស្រី ម៉ា-សុទ្ធ | ១០ដុ |
| អ្នកស្រី អ៊ាង-ជាវ | ១០ដុ |
| សាន-ស៊ីយន | ១០ដុ |
| ផល្លី-ឃុត | ១០ដុ |
| អ្នកស្រី សៅ-សារៀប លោក តាន់-សុខា | ១០ដុ |
| អ្នកស្រី ឡៅ-គឹមហ៊ាង លោក សៅ-សារួន | ១០ដុ |
| ប៉េ-សុខុម | ១០ដុ |
| គឹមសាន-ជា | ១០ដុ |
| ផូ-ភីរើក | ១០ដុ |
| ឧបាសិកា ស៊ើង-ធីហ៊ាន | ១០ដុ |
| ឧបាសិកិា ជុំ-ថន | ១០ដុ |
| លោក ស៊ិន-គៀម | ១០ដុ |
| លោក ម៉ែន-ម៉េត និង គ្រួសារ | ១០ដុ |
| ឧបាសក អ៊ិន-សន | ១០ដុ |
| លោក ញ៉ិល-មឿន ព្រមទាំងគ្រួសារ | ១០ដុ |
| អ្នកស្រី **CHAN DOUNG CHAN** | ១០ដុ |
| ឧបាសិកា សែ | ១០ដុ |
| ច័ន្ទតានីកែវ | ១០ដុ |
| ហួត និង គ្រួសារ | ១០ដុ |

| | |
|---|---|
| លោកអាចារ្យ ពេជ្រ-វិសុទ្ធីឱម ឧបាសិកា សូត-សាថន | ១០ដុ |
| អ្នកស្រី ស៊ីយ៉ាន-ណេត | ១០ដុ |
| Khmning Annie (Pann) Family | ១០ដុ |
| ភុំ ព្រមទាំងគ្រួសារ, វុណា-ព្រមទាំងគ្រួសារ | ១០ដុ |
| អ្នកស្រី ស-សុខា | ១០ដុ |
| អ្នកស្រី ញ៉ឹក-លី | ១០ដុ |
| កញ្ញា មៀច-មករា | ១០ដុ |
| លោក កែវ-កុសល | ១០ដុ |
| **KAO CHANDANY** | ១០ដុ |
| អ្នកស្រី ជាម-ហ៊្វឹង | ១០ដុ |
| លោក អ៊ុក-ស៊ុម អ្នកស្រី អ៊ុក-ផេងឡេង | ១០ដុ |
| លោក អ៊ិញ-សិញ អ្នកស្រី ជុយ-ណៃអ៊ិញ | ១០ដុ |
| អាភា | ១០ដុ |
| លោក មូត្រ-វិចិត្រ អ្នកស្រីកែ-សឿន | ១០ដុ |
| ឆាន់-ជន | ១០ដុ |
| លីម-សុខជូ | ១០ដុ |
| អ្នកស្រី តែ-ស៊ីវលាង | ១០ដុ |
| អ្នកស្រី អ៊ី-យ៉ឹក អែម-មី-យាំ | ១០ដុ |
| លោកជួង-ប៉ាន នាង ញ៉ិល-មាលិះ និង ញ៉ិល-ឥន្ទ្រីយ៍ | ១០ដុ |
| នាង **KIM ROS** | ១០ដុ |
| **CHAYA DARY** និង កូនទាំង ២ | ១០ដុ |
| ឧបាសិកា ឡុង-អ៊ី | ១០ដុ |
| ឧបាសិកា ទូច-យ៉ុន | ១០ដុ |
| ឧបាសិកា ប៊ន-វ៉ា | ១០ដុ |
| ឧបាសិកា ព្រះ-ឈាង | ១០ដុ |
| នាង លី-ឆែ | ១០ដុ |
| អ្នកស្រី ផាន់-សារីម | ១០ដុ |
| ឧបាសក ថាច់-សូផាត អ្នកស្រី យង-វន្នី | ១០ដុ |
| លោកយាយ តាន់-ប៉ាវ | ១០ដុ |
| ដារី-រិត | ១០ដុ |
| ឧបាសិកា ប្រីយ-យ៉ុម | ១០ដុ |
| ឧបាសិកា អ៊ួ-នង | ១០ដុ |
| លោក ធឿម អ្នកស្រី ណែប | ១០ដុ |
| ឧបាសិកា ង៉ូវ-មួយឡាយ | ១០ដុ |



| | |
|---|---|
| ឧបាសិកា ហេង-ស៊ីវទៀង និង បុត្រធីតា | ១០ដុ |
| ឧបាសិកា លី-សារី | ១០ដុ |
| ឧបាសិកា ពៅ-យឹន ឧបាសក អ៊ឹម-ឃន | ១០ដុ |
| នាង បាយ-អូន និង ក្រុមគ្រួសារ | ១០ដុ |
| ភិក្ខុ ព្រំ-សៀន | ១០ដុ |
| អ្នកស្រី ហេង-ឈាប | ១០ដុ |
| លោក សាវ៉ាត-រិត និង គ្រួសារ | ១០ដុ |
| ឧបាសិកា ចឹក-ង៉ឿន | ១០ដុ |
| **SOPOHY ROEUNG** ឥណា-តេ **SON** | ១០ដុ |
| សន-សួន | ១០ដុ |
| អ្នកស្រី ផៃ-លី | ១០ដុ |
| ឧបាសិកា ឡុង-អ៊ឹម | ១០ដុ |
| ឧបាសិកា ជឹម-អុល | ១០ដុ |
| ឧបាសិកា សេង-គីមហ៊ន និង បុត្រ | ១០ដុ |
| ឧបាសិកា រ័ត្ន | ១០ដុ |
| អ៊ុំ ឡាច | ១០ដុ |
| ឧបាសិកា ជា-ស៊ុនស៊ីម | ១០ដុ |
| គីម-ហៀង | ១០ដុ |
| គុយ-វ៉ាន់ណា | ១០ដុ |
| កែវ-សឿន | ១០ដុ |
| **MUY VOUN** | ១០ដុ |
| ឧបាសក អ៊ុន-សារុម | ១០ដុ |
| ចៅ-ឡៅហ្វុង ជុង-សុងម៉េង ចៅ-យោវលួង | ១០ដុ |
| ឧបាសិកា ណម | ១០ដុ |
| អ្នកស្រី ទូច-គីមអេង ព្រមទាំងបុត្រ | ១០ដុ |
| **KIM BERLY HUN SOK DIM IM** | ១០ដុ |
| ហួត-លឿត នាក-រីម | ១០ដុ |
| ហ៊ីង-ហ៊ន ហៅ កុក-សាវ៉ាន់ ខឹម-សាន់ | ១០ដុ |
| ឧបាសិកា មៀង-ម៉ៅ យឹម វណ្ណា | ១០ដុ |
| ឧបាសក លី-គីវ ឧបាសិកា តោ-អេង | ១០ដុ |
| វ៉ាន់-អ៊ឹម | ១០ដុ |
| ឧបាសិកា យី-ជ្រិន | ១០ដុ |
| អឿន-តុង ណារី | ១០ដុ |
| ផាន់-សាវ៉ាត | ១០ដុ |

| | |
|---|---|
| លោក មាស-សាំង | ១០ដុ |
| ឧបាសិកា ចាន់-ឡុង និង កូនចាន់-លី | ១០ដុ |
| អ្នកស្រី ឧង-បភាវត្តី ស្វាមី និង បុត្រ | ១០ដុ |
| អ្នកស្រី ព្រីន-វ៉ាន់ | ១០ដុ |
| អ្នកស្រី នួន-សុភី | ១០ដុ |
| អ្នកស្រី សួន-សុខុម | ១០ដុ |
| ទាយក ផន | ១០ដុ |
| ញោម សៀង-លិម | ១០ដុ |
| លោកសិរី-សំបាន និង គ្រួសារ | ១០ដុ |
| ឧបាសិកា សុខ-យ៉ាន | ១០ដុ |
| លោក យ៉ាវ-នាង នាងសុខា | ១០ដុ |
| ឧបាសិកា អ៊ឹម-អឿន | ១០ដុ |
| ញោម លីណា | ១០ដុ |
| ឧបាសិកា ម៉ិល-ប៉ិច | ១០ដុ |
| ឧបាសិកា តឹក-អុន | ១០ដុ |
| ឧបាសិកា អែម-ទេត | ១០ដុ |
| ឧបាសក សេក-ម៉ុន ឧបាសិកា កែវ-អ៊ិន | ១០ដុ |
| ឧបាសិកា អ៊ាប-ច័ន្ទលី | ១០ដុ |
| ឧបាសិកា យិន-កែម | ១០ដុ |
| ឧបាសិកា ម៉ឹង-លន់ | ១០ដុ |
| អ្នកស្រី អឿន-សារី | ១០ដុ |
| មែទ្បុ-ថានោកា | ១០ដុ |
| ឈិត-ដាវគុណទ្រី | ១០ដុ |
| ឈិត-ដាវចិត្រា | ១០ដុ |
| ឈិត-ដាវសៅ-វ៉ាន្នី | ១០ដុ |
| លោក ទេស-សាមិត | ១០ដុ |
| លោក ប៊ូ-យើន និង សុមាលី | ១០ដុ |
| ឧបាសិកា អឿង | ១០ដុ |
| ទាយិកា ចន្ទូ | ១០ដុ |
| នុត-ស៊ីម | ១០ដុ |
| អ៊ុ-ស៊ីន | ១០ដុ |
| អ្នកស្រី ពុំ-សូភី លោក មួង-សំអាត | ១០ដុ |
| ឧបាសិកា ម៉ុម-រី | ១០ដុ |
| លោក ប៊ុន-លឿង និង ភរិយា | ១០ដុ |



| | |
|---|---|
| លោក យឹម-សេង អ្នកស្រីសឿន | ១០ដុ |
| អ្នកស្រី ប៊ុន-ហេង | ១០ដុ |
| កញ្ញា យ៉ែម-ស្រីមុំ | ១០ដុ |
| កញ្ញា យ៉ែម-ស្រីអូន | ១០ដុ |
| លោក ប៉ឹក-ឈាង អ្នកស្រី ហែម-ឆេងប៉ោ | ១០ដុ |
| ឧបាសកា នួន-សេង ឧបាសិកា គង់-ណាវ៉ាន់ | ១០ដុ |
| ឧបាសិកា លី-សាយជូ | ១០ដុ |
| ឧបាសិកា បេ-យ៉េន | ១០ដុ |
| ដន្លងឧបាសិកាឆាន់-កាន់ដួង | ១០ដុ |
| ផេង-នាង | ១០ដុ |
| ប៉ិត-សុខា | ១០ដុ |
| ឧបាសក សាអឿន ឧបាសិកា ប៉ុក-មិន | ១០ដុ |
| លោក អ៊ុម-សុផល អ្នកស្រី ឡុង-ភា | ១០ដុ |
| លោក សានី អ្នកស្រី ភិរុន និងបុត្រធីតា | ១០ដុ |
| ឧបាសិកា ង៉ែត-ខុន | ១០ដុ |
| លោកអាចារ្យ សាម-គុណ ឧបាសិកា រ័ត្ន-រី | ១០ដុ |
| ឧបាសិកា រិន លោកតា ជឿម កូនចៅ | ១០ដុ |
| អ្នកស្រី វ៉ានី និង គ្រួសារ | ១០ដុ |
| អ្នកស្រី វ៉ាស៊ី និង គ្រួសារ | ១០ដុ |
| យុវជន មេ-ផាន់ណា | ១០ដុ |
| ឧបាសក ឌី□សុផល និង គ្រួសារ | ១០ដុ |
| ឧបាសិកា លី-សារី | ១០ដុ |
| ភិក្ខុ ថោង-អ៊ាត | ១០ដុ |
| ភិក្ខុ មុត-សុង | ១០ដុ |
| ឧបាសក ឈុន-សាវ៉ាន និង គ្រួសារ | ១០ដុ |
| អ្នកស្រី ស៊ឹម | ១០ដុ |
| ឧបាសិកា អ៊ឹម-ផុល | ១០ដុ |
| ភិក្ខុ មុនិន្ទត្ថេរោ មហាញ៉ា-ទេពមុនី | ១០ដុ |
| អ្នកស្រី ឈឹម-សាង៉ាត់ | ១០ដុ |
| លោក សុវណ្ណ អ្នកស្រី លឿម | ១០ដុ |
| អ្នកស្រី បាយ-អូន និង គ្រួសារ | ១០ដុ |
| លោក នួន-នឿន និង ភរិយា | ១០ដុ |
| ឧបាសិកា ឆេង-យាន | ១០ដុ |
| ឧបាសិកា អ៊ាត-អេង | ១០ដុ |

| | |
|---|---|
| មីន-មាលី | ១០ដុ |
| អ៊ឹង-សង | ១០ដុ |
| សាន-សុំផិត សុខ-ជា | ១០ដុ |
| សាន-សុខឃន យស់-សុវណ្ណ | ១០ដុ |
| ភិក្ខុ យ៉ែម-ណាក បស្សន្នោ | ១០ដុ |
| **TI CHHOR** | ១០ដុ |
| អ៊ាក-តាំង | ១០ដុ |
| អ្នកស្រី សុខ-សំ | ១០ដុ |
| អ្នកស្រី គួច-ឃីម | ១០ដុ |
| ឧបាសិកា អ៊ុម-ថុល | ១០ដុ |
| ឧបាសិកា ហ៊ុយ-ភន | ១០ដុ |
| លោក សុវណ្ណ-ឈុន ឧបាសិកា ប៉ែន | ១០ដុ |
| អ្នកស្រី សីម-គាវ | ១០ដុ |
| បោ-ណៃ   មីន-សារី | ១០ដុ |
| ចាន់ថា និង វណ្ណារី | ១០ដុ |
| ឧបាសិកា ផាន-ឡុង | ៩ដុ |
| យ៉ាំង-សគុណ | ៩ដុ |
| ហ៊ុយ-សវេត | ៩ដុ |
| យ៉ាំង-ស៊ីវុត | ៩ដុ |
| យ៉ាំង-សវេត | ៩ដុ |
| ឧបាសិកា ឈឿម-វ៉ាន់ | ៧ដុ |
| អ្នកស្រី ហង់-គីមយ៉ាន | ៧ដុ |
| ឧបាសិកា ឡាង | ៧ដុ |
| ឧបាសិកា សំ-ឃិន | ៧ដុ |
| ឧបាសិកា ឌួង-ច័ន្ទបុប្ផ និង បុត្រ | ៧ដុ |
| លោក វ៉េម-អួន | ៧ដុ |
| ឧបាសិកា ម៉ែន-ស៊ិម | ៧ដុ |
| ឧបាសិកា ឡាង | ៧ដុ |
| អ៊ូច-រឿន | ៧ដុ |
| ឧបាសិកា ស៊ុន-ឡាយ | ៧ដុ |
| អ្នកស្រី ជីច-ណាង និង អ៊ី-ខ្វាន់នី | ៧ដុ |
| លោកតា អឿ-សឿន លោកយាយ គិម-ឈុន | ៧ដុ |
| ឧបាសិកា វង-ហ្វឹង និង កូន ថូ-សាឡៅ | ៧ដុ |
| លោក ថូ-ច័ន្ទតារា និង គ្រួសារ | ៧ដុ |



| | |
|---|---|
| អ្នកស្រី ថូ-វ៉ាន់ឌី និង គ្រួសារ | ៧ដុ |
| អ្នកស្រី ថូ-និកា និង គ្រួសារ | ៧ដុ |
| លោក ប៉េង-លី និង សុរតន៍ | ៧ដុ |
| លោក ប៊ិល-អៀត អ្នកស្រី ស៊ីណា | ៧ដុ |
| អ្នកស្រី កែវ-វ៉េត | ៧ដុ |
| អ្នកស្រី ជិន-វីវ៉ា និង ស្វាមី | ៧ដុ |
| លោក ជិន-ប៉ៀល្លី និង ស្រី នុត | ៧ដុ |
| លោក សួន-ច័ន្ទី អ្នកស្រី គីម-លី | ៧ដុ |
| អ្នកស្រី ឈាន-ធឿន | ៧ដុ |
| អ្នកស្រី ដួង-ណារី | ៧ដុ |
| សួង-សុភា | ៧ដុ |
| ឧបាសិកា ជា-គួរ | ៧ដុ |
| លោក ថូ-សុខវ៉ាន់ និង គ្រួសារ | ៧ដុ |
| លោក ស៊ីម-សាម៉ុន អ្នកស្រី សំសុខន | ៧ដុ |
| ណោន-សុខជា | ៧ដុ |
| សួង-សុភ័ណ | ៧ដុ |
| សួង-ផែមម៉ាឡា | ៧ដុ |
| លោក លឹម-តៅខេង អ្នកស្រី ហេង-ស៊ីហាន | ៧ដុ |
| អូឡា-ថៃ   ចំប៉ាស៊ី | ៦ដុ |
| ឧបាសិកា ខាំ-ភូ | ៦ដុ |
| ហ៊ុយ-ប្រេសសិណ | ៦ដុ |
| ហ៊ុយ-ប្រេសតូន | ៦ដុ |
| ឧបាសិកា សុត-ទេព | ៦ដុ |
| ឧបាសិកា សេង-ណៃ | ៦ដុ |
| ស្រួយ-សេង | ៥ដុ |
| **BOUY T. TECH & WANNA W. SAO** | ៥ដុ |
| ប្រាក់-ភាជ សុខ-ភឿន | ៥ដុ |
| យុវជន លី-ធារី | ៥ដុ |
| ឧបាសក អែម-រិន ភួន-លឿម | ៥ដុ |
| យែម-សាវ៉ាន ឈាន-ហឺន | ៥ដុ |
| លោក គី-តុងជាង និង គ្រួសារ | ៥ដុ |
| ឧបាសិកា ផាន់-សារីម និង បុត្រ | ៥ដុ |
| អ្នកស្រី តឹក-ម៉ាលី និង គ្រួសារ | ៥ដុ |
| លោកអាចារ្យ ឈឺន-ប៊ុនលើត | ៥ដុ |

| | |
|---|---|
| ឧបាសិកា ញ៉ឹក-លេង | ៥ដុ |
| សិប-យេន | ៥ដុ |
| យឹម-យ៉ាន់ណា ព្រមទាំងបុត្រ | ៥ដុ |
| ឧបាសិកា សុខា-សរ | ៥ដុ |
| ឆែ-ឆេងហាក់ និង គ្រួសារ | ៥ដុ |
| អ្នកស្រី យម និង លោក សារឿន | ៥ដុ |
| លោក ប៊ុនលឿ-អាំខា | ៥ដុ |
| គុច-យូតាំ និបុត្រាបុត្រី | ៥ដុ |
| ឧបាសិកា អូន និងកូនចៅ | ៥ដុ |
| ឧបាសក លោ-សុខផន វ៉ែន-ឡាប | ៥ដុ |
| ស្វាយ-សារី | ៥ដុ |
| ច្រិច | ៥ដុ |
| ឧបាសិកា ប៊ូ-ឡាយ | ៥ដុ |
| ឧបាសិកា ប៊ុន-សុខឡាង | ៥ដុ |
| ភិក្ខុ សុខ-សឿន | ៥ដុ |
| ភែន-សុង | ៥ដុ |
| លោក វ៉ាម៉ូ នាង លី-សុភាព ព្រមទាំងបុត្រ | ៥ដុ |
| ឧបាសិកា រស់-សុំ | ៥ដុ |
| លោកយាយ ល នាង-ប៉ុក | ៥ដុ |
| ញ៉ែម-សារ៉េត | ៥ដុ |
| SADA EUM | ៥ដុ |
| HEANG VOUN | ៥ដុ |
| ឧបាសិកា ប៉ែន-ប៉ុន និង លី-ឈួន | ៥ដុ |
| សុធា-ជួង និង វេត | ៥ដុ |
| ចេក-រ៉ាត | ៥ដុ |
| ចក់-ជួន សត្យា | ៥ដុ |
| ឧបាសិកា ស៊ិន-យ៉ាំ និង បុត្រ | ៥ដុ |
| គាម-ឃឿន | ៥ដុ |
| យិន-ឌី | ៥ដុ |
| យង-កាំ | ៥ដុ |
| ឧបាសក ឈូក-សាន | ៥ដុ |
| សូភាព-មុតជា | ៥ដុ |
| ឈិត-ដាវសុខានី | ៥ដុ |
| លោក មាន-អានី | ៥ដុ |



| | |
|---|---|
| ឧបាសិកា ឌី | ៥ដុ |
| អ្នកស្រី ចាន់ | ៥ដុ |
| លោក ម៉ាល-ធាន អ្នកស្រី ចំរឿន | ៥ដុ |
| បូរេត និង ធារា-ស៊ឹម | ៥ដុ |
| លោក យ៉ុង-ជៀង អ្នកស្រី ថោម-ធាង | ៥ដុ |
| ឧបាសក ព្រិត-ឈុត | ៥ដុ |
| ឧបាសិកា ថាយ | ៥ដុ |
| **Chea & Dee** ព្រមទាំងកូនចៅ | ៥ដុ |
| **Srey Na Vuthy Try** | ៥ដុ |
| **Savan Chim, Roy Sarou** | ៥ដុ |
| មឿត | ៥ដុ |
| ឡាំ ព្រមទាំងកូនចៅ | ៥ដុ |
| សិន-ឌី | ៥ដុ |
| អចារ្យ ជូ-មី ឧបាសិកា បូលីន កូន | ៥ដុ |
| លោក ភួង-នេនៅ និង ភរិយា | ៥ដុ |
| ឧបាសិកា អ៊ុម-ម៉ុន | ៥ដុ |
| ឧបាសិកា ឃួន-ខាំ | ៥ដុ |
| លោក ប្រម-គ្រួច និង ភរិយា | ៥ដុ |
| លោក អាត់ អ្នកស្រី យិន-យិ | ៥ដុ |
| លោក មែក-សាខន អ្នកស្រី លី-ឡុង | ៥ដុ |
| លោកតា ជុំ-សុន | ៥ដុ |
| ឧបាសិកា ទិត្យ-លេន | ៥ដុ |
| លោក ទេស-ហ៊ន | ៥ដុ |
| ឧបាសិកា ឌី-ប៊ុនឆាន | ៥ដុ |
| អ្នកស្រី សេង-ផល្លិ | ៥ដុ |
| **CHOUK PHEUN** | ៥ដុ |
| **BUNHANG KON** | ៥ដុ |
| ឧបាសកា ឈាន | ៥ដុ |
| ឧបាសិកា ឆេង-យាន | ៥ដុ |
| ឧបាសិកា អ៊ុំ-ម៉ច | ៥ដុ |
| ឧបាសិកា ទូច-សំបូរ | ៥ដុ |
| **SAMNANG TOUCH & SOKHEUN** | ៥ដុ |
| អ្នកស្រី ភិន-នី | ៥ដុ |
| ឧបាសិកា ហេង-ហេង | ៥ដុ |

| | |
|---|---|
| ឧបាសិកា អ៊ែម-ណម | ៥ដុ |
| ឧបាសិកា ខុំ | ៥ដុ |
| ហេង-ផាន | ៥ដុ |
| ឧបាសិកា ជៀម-ថុន ហៅព្រះអង្គតូ-ញ៉ឹប | ៥ដុ |
| ឧបាសិកា យឿម | ៥ដុ |
| លោកលី លីសុដល់ នាងយា-រ៉ូឡាយ, លី-ចាន់ថា | ៥ដុ |
| លោក លី-ប៊ូន លី-សុផា ព្រមទាំងបុត្រ | ៥ដុ |
| ឧបាសិកា សម-សំផាន់ | ៥ដុ |
| លី-សុភ័ណ នាង វ៉ាន់ឌី ព្រមទាំងបុត្រ | ៥ដុ |
| លោក ហែម-ហុង អ្នកស្រីនុត-និននារី ព្រមទាំងកូនចៅ | ៥ដុ |
| ប៉េ-សារូ | ៥ដុ |
| លោកស្រី **LISA NAJARIAN** | ៥ដុ |
| លោក កៅ-ច័ន្ទដារ៉ា | ៥ដុ |
| អ្នកស្រី **ALYSSA HAN HENG** | ៥ដុ |
| កែម-ហេង | ៥ដុ |
| រុម-អ៊ុង | ៥ដុ |
| លោក កែវ-ចាន់ អ្នកស្រី ឃឹម-អេង | ៥ដុ |
| **CHOY PHANIXAY** | ៥ដុ |
| ឧបាសិកា អាង-ណយ | ៥ដុ |
| ឧបាសិកា ជុំ-ហ៊ីង | ៥ដុ |
| ឧបាសិកា នួន-ភិន | ៥ដុ |
| ឧបាសិកា ជុក-សឿន | ៥ដុ |
| អ្នកស្រី ឆាត់-ឆោម និង គ្រួសារ | ៥ដុ |
| លោក ស៊ិន-នី និង គ្រួសារ | ៥ដុ |
| លោក សូផាត សំអុន មែន និង គ្រួសារ | ៥ដុ |
| ទេព-សារិន្ទ | ៥ដុ |
| សូរិន-ហាក់ | ៥ដុ |
| ឧបាសិកា កៅ-សេងវ៉ាន | ៥ដុ |
| លោក សុឃុធា អ្នកស្រី ឈុន-ណាង | ៥ដុ |
| អ្នកស្រី លា | ៥ដុ |
| ឧបាសិកា កែវ-ហេ | ៥ដុ |
| ឧបាសិកា ផាន់-សារឹម | ៥ដុ |
| អ្នកស្រី តឹក-ចាន់ធឿន និង គ្រួសារ | ៥ដុ |



| | |
|---|---|
| លោក ថង-ឡាក់ អ្នកស្រី លុន | ៥ដុ |
| ឧបាសក ស៊ាន ឧបាសិកា សុភី | ៥ដុ |
| អ្នកស្រី ស៊ុ-នឿត | ៥ដុ |
| ឧបាសិកា ខៀវ-ណាត | ៥ដុ |
| អ្នកស្រី ស៊ុំ-សាគឿន និង គ្រួសារ | ៥ដុ |
| អ្នកស្រី ញ៉ង់-សុខន | ៥ដុ |
| ឧបាសិកា សាធ-ភឹម | ៥ដុ |
| លោក គ្រៀល-ឆោម អ្នកស្រី ឧស្សរា | ៥ដុ |
| ឧបាសិកា គីម-អេង | ៥ដុ |
| ភោ-គីមហួយ | ៥ដុ |
| អ្នកស្រី ចន្ធី លោក ជុំ-សាឯម | ៥ដុ |
| ឧបាសិកា ក្រិញ-ហុង | ៥ដុ |
| លោក ម៉ី-សាមឿន អ្នកស្រី ឈុន-សារុន | ៥ដុ |
| ឧបាសិកា ដោ-ស៊ីផាត | ៥ដុ |
| ឧបាសិកា នុត-ប៊ិច | ៥ដុ |
| ឧបាសិកា ហែម-ហេង | ៥ដុ |
| លោក ទឹម-យ៉ុន និង គ្រួសារ | ៥ដុ |
| ឧបាសក ហាវ ឧបាសិកា សាយ | ៥ដុ |
| ឧបាសិកា កង-ស៊ី | ៥ដុ |
| ឧបាសិកា ថ្លាង-ខន | ៥ដុ |
| ណោន-សាម៉េត | ៨ដុ |
| ណោន-សាមុត | ៨ដុ |
| ណោន-សុអេង | ៨ដុ |
| ណោន-ផាន់ណាត | ៨ដុ |
| លោក ញ៉ែម-សារឹម | ៨ដុ |
| លោក ប៊ុន-ញាង | ៨ដុ |
| សេម និង សុភ: | ៨ដុ |
| រ៉ននី-រិ លីយ៉ា | ៨ដុ |
| អ្នកស្រី សុខ-វណ្ណា | ៨ដុ |
| អ្នកស្រី រី-លីនអ៊ុប | ៨ដុ |
| អ្នកស្រី សុជាតិ និង គ្រួសារ | ៨ដុ |
| ឧបាសិកា ណែម | ៨ដុ |
| លោក ថង-ឈុត | ៨ដុ |
| ឧបាសិកា នី-វ៉ាន់ | ៨ដុ |

| | |
|---|---|
| លោក ហូ អ្នកស្រី ប៊ុង | ៨ដុ |
| ឧបាសិកា ខីម-រុន | ៨ដុ |
| ហ៊ាយ-គ្រីស្តហ្វី | ៨ដុ |
| ហ៊ាយ-គ្រីស្ទីណា | ៨ដុ |
| ឧបាសិកា ហេង-ស៊ន | ៣ដុ |
| ហ៊ុន-សោភ័ណ | ៣ដុ |
| ឧបាសិកា ឆោម | ៣ដុ |
| ឧបាសិកា ពក | ២ដុ |
| ឧបាសិកា ជុក-សៀវ | ២ដុ |
| ពិន-ឈុនហ៊ាង | ២ដុ |
| ឧបាសិកា ម៉ម-អឿន | ២ដុ |
| ម៉ៅ-រតនា | ២ដុ |
| សុវ៉ាត-ថាណាស និង ROBERT | ២ដុ |

## កំហុសតែងមានជាធម្មតា

ខ្ញុំសូមខន្តីអភ័យទោសអំពីសំណាក់ព្រះតេជះព្រះ
គុណព្រះថេរានុថេរៈ និង ពុទ្ធបរិស័ទទាំងអស់
កាលបើមានការបាត់ឈ្មោះ ឬ ខុសឈ្មោះ
និង
កាលបើមានការខុសឆ្គងដោយប្រការផ្សេងៗ
ទៀតនោះ សូមព្រះតេជះព្រះគុណ និង
ពុទ្ធបរិស័ទទាំងអស់ អនុគ្រោះផងចុះ ។
សូមអរព្រះគុណ និង អរគុណទុកជាមុន !
សូមប្រគេនពរ និង ជូនពរ



បើពុទ្ធបរិស័ទចង់បានសៀវភៅ **វិសុទ្ធិមគ្គប្រែ** ទាំង ៣ ភាគនេះ
យកទៅសិក្សារៀនសូត្រ

សូមទាក់ទង : ភិក្ខុវិនយធរោ មហាយិន-នឿន
វត្តខ្មែរសាន់តាអាណា
2630 N. Grand Ave. Santa Ana, CA 92705
(714) 744-2844
U.S.A

ទាក់ទង: ភិក្ខុ យ៉ាន-សារុន
**វត្តន្ទនមុនីរាម (ហៅវត្តថាន់) ភ្នំពេញ**
០១២-៨៧-៣០-០៩
និង
ទាក់ទង: ភិក្ខុប្រាក់-ផល្លី
**វត្តបទុមវតី ភ្នំពេញ**
០៩២-៩៤-៦៧-៨៧